# ព្រះ
# ត្រៃបិដកបាលី
និង
## សេចក្ដីប្រែជាភាសាខ្មែរ
# សុត្តន្តបិដក
## មជ្ឈិមនិកាយ មូលបណ្ណាសក
## បឋមភាគ
# ២០

ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ

ព.ស ២៥០២

# សុត្តន្តបិដកេ មជ្ឈិមនិកាយស្ស

## មូលបណ្ណាសកំ

## បឋមោ ភាគោ

---

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

## មូលបរិយាយវគ្គោ

---

### បឋមំ មូលបរិយាយសុត្តំ

(១) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា ឧក្កដ្ឋាយំ វិហរតិ សុភគវនេ សាលរាជមូលេ ។ តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ ភិក្ខវោតិ ។ ភទន្តេតិ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច សព្វធម្មមូលបរិយាយំ វោ ភិក្ខវេ ទេសិស្សាមិ[១] តំ សុណាថ សាធុកំ មនសិករោថ ភាសិស្សាមីតិ ។ ឯវំ ភន្តេតិ ខោ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។

---

១. ទេសេស្សាមិ ។

# សុត្តន្តបិដក មជ្ឈិមនិកាយ

## មូលបណ្ណាសក

## ភាគទី ១

---

សូមនមស្ការព្រះមានព្រះភាគអរហន្តសម្មាសម្ពុទ្ធព្រះអង្គនោះ ។

## មូលបរិយាយវគ្គ

---

### មូលបរិយាយសូត្រ ទី ១

(១) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយព្រះមានព្រះភាគទ្រង់គង់ក្រោមម្លប់សាលរាជព្រឹក្ស[១]ក្នុងសុភគវ័ន (ព្រៃជាទីត្រេកអរនៃជនច្រើន) ជិតក្រុងឧក្កដ្ឋា ។ ក្នុងសម័យនោះឯង ព្រះមានព្រះភាគទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ដូច្នេះ ។ ភិក្ខុទាំងនោះទទួលព្រះពុទ្ធដីកា នៃព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ។ ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែងនូវបរិយាយ ដែលជាឫសគល់នៃធម៌ទាំងពួង ប្រាប់អ្នកទាំងឡាយ អ្នកទាំងឡាយចូរស្តាប់នូវធម៌នោះ ចូរយកចិត្តទុកដាក់ដោយប្រពៃ តថាគតនឹងសំដែង ។ ភិក្ខុទាំងនោះទទួលព្រះពុទ្ធដីកា នៃព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។

---

១ ដើមរាំងភ្នំជាធំឬស្តេចរាំងភ្នំ ។ អដ្ឋកថា ។

(២) ភគវា ឯតទវោច ឥធ ភិក្ខវេ អស្សុតវា បុថុជ្ជនោ អរិយានំ អទស្សាវី អរិយធម្មស្ស អកោវិទោ អរិយធម្មេ អវិនីតោ សប្បុរិសានំ អទស្សាវី សប្បុរិសធម្មស្ស អកោវិទោ សប្បុរិសធម្មេ អវិនីតោ បឋវឹ បឋវិតោ សញ្ជានាតិ បឋវឹ បឋវិតោ សញ្ញត្វា



(២) ព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ បុថុជ្ជនក្នុងលោកនេះ ជាអ្នកមិនបានស្ដាប់ មិនបានឃើញ នូវព្រះអរិយៈទាំងឡាយ (មានព្រះពុទ្ធជាដើម) មិនឈ្លាស ក្នុងអរិយធម៌(១) មិនបានទូន្មានខ្លួន ក្នុងអរិយធម៌ គឺមិនមានអរិយធម៌(២) មិនឃើញនូវពួកសប្បុរស មានព្រះពុទ្ធជាដើម មិនឈ្លាស ក្នុងសប្បុរិសធម៌ មិនបានទូន្មានខ្លួន ក្នុងសប្បុរិសធម៌ រមែងសំគាល់នូវផែនដីថាជាផែនដីពិត លុះ

---

១ អរិយធម៌ក្នុងទីនេះ បានដល់សតិប្បដ្ឋាន ៤ ជាដើម ។ ២ មិនទូន្មានខ្លួនក្នុងអរិយធម៌ក្នុងទីនេះបានដល់វិន័យ ២ យ៉ាងគឺ សំវរវិន័យ ១ បហានវិន័យ ១ សំវរវិន័យមាន ៥ ប្រការគឺ (ក) សីលសំវរៈ សង្រួមក្នុងបាតិមោក្ខ (ខ) សតិសំវរៈ សង្រួមក្នុងចក្ខុន្ទ្រិយ (គ) ញាណសំវរៈ សង្រួមក្នុងខ្សែតណ្ហាដោយបញ្ញា (ឃ) ខន្តិសំវរៈ សង្រួមក្នុងខន្តិ គឺអត់ធន់នូវសភាព មានត្រជាក់និងក្ដៅជាដើម (ង) វីរិយសំវរៈ សង្រួមក្នុងវីរិយៈ គឺកំចាត់បង់នូវវិតក្កៈ ៣ យ៉ាង មានកាមវិតក្កៈជាដើម មួយទៀតសង្រួមក្នុងទុច្ចរិតទាំង ៣ មានកាយទុច្ចរិតជាដើម ក៏ឈ្មោះថាសំវរវិន័យដែរ ។ បហានវិន័យ មាន ៥ ប្រការគឺ (ក) តទង្គប្បហានៈ លះកិលេសដោយអង្គនោះ ៗ មានកិរិយាកំណត់នូវនាមនិងរូបដោយវិបស្សនាញាណជាដើម (ខ) វិក្ខម្ភនប្បហានៈ លះកិលេសមាននីវរណធម៌ជាដើមដោយសមាធិ (គ) សមុច្ឆេទប្បហានៈ លះកិលេសដាច់ស្រេចក្នុងខណៈដែលបាននូវអរិយមគ្គទាំង ៤ ប្រការ (ឃ) បដិប្បស្សទ្ធិប្បហានៈ លះកិលេសដាច់ស្រេចក្នុងខណៈដែលបាននូវអរិយផល (ង) និស្សរណប្បហានៈ លះកិលេសស្រះស្រឡះ គឺបានដល់នូវព្រះនិព្វាន ។ អដ្ឋកថា ។

បឋវឹ មញ្ញតិ បឋវិយា មញ្ញតិ បឋវិតោ មញ្ញតិ បឋវឹមេតិ មញ្ញតិ បឋវឹ អភិនន្ទតិ ។ តំ កិស្ស ហេតុ ។ អបរិញ្ញាតំ[១] តស្សាតិ វទាមិ ។ អាបំ អាបតោ សញ្ជានាតិ អាបំ អាបតោ សញ្ញត្វា អាបំ មញ្ញតិ អាបស្មឹ មញ្ញតិ អាបតោ មញ្ញតិ អាបំមេតិ មញ្ញតិ អាបំ អភិនន្ទតិ ។ តំ កិស្ស ហេតុ ។ អបរិញ្ញាតំ តស្សាតិ វទាមិ ។ តេជំ តេជតោ សញ្ជានាតិ តេជំ តេជតោ សញ្ញត្វា តេជំ មញ្ញតិ តេជស្មឹ មញ្ញតិ តេជតោ មញ្ញតិ តេជំមេតិ មញ្ញតិ តេជំ អភិនន្ទតិ ។ តំ កិស្ស ហេតុ ។ អបរិញ្ញាតំ តស្សាតិ វទាមិ ។ វាយំ វាយតោ សញ្ជានាតិ វាយំ វាយតោ សញ្ញត្វា វាយំ មញ្ញតិ វាយស្មឹ មញ្ញតិ វាយតោ មញ្ញតិ វាយំមេតិ មញ្ញតិ វាយំ អភិនន្ទតិ ។ តំ កិស្ស ហេតុ ។

១ សព្វត្ថ អបរិញ្ញាតន្តិ កត្ថចិ បោត្ថកេ ទិស្សតិ ។



សំគាល់នូវផែនដីថាជាផែនដីពិតហើយ ក៏ប្រកាន់នូវផែនដី ប្រកាន់ក្នុងផែនដី ប្រកាន់ថាជាផែនដីពិត ប្រកាន់ថាផែនដីជារបស់អញ ត្រេកអរនឹងផែនដី ។ ដំណើរនោះព្រោះហេតុអ្វី ។ តថាគតពោលថា ព្រោះបុថុជ្ជននោះ កំណត់នូវដំណើរនៃផែនដីនោះមិនបាន ។ បុថុជ្ជនតែងសំគាល់នូវទឹកថាជាទឹកពិត លុះសំគាល់នូវទឹកថាជាទឹកពិតហើយ ក៏ប្រកាន់នូវទឹក ប្រកាន់ក្នុងទឹក ប្រកាន់ថាជាទឹកពិត ប្រកាន់ថាទឹកជារបស់អញ ត្រេកអរនឹងទឹក ។ ដំណើរនោះព្រោះហេតុអ្វី ។ តថាគតពោលថា ព្រោះបុថុជ្ជននោះ កំណត់នូវដំណើរទឹកនោះមិនបាន ។ បុថុជ្ជនសំគាល់នូវភ្លើងថាជាភ្លើងពិត លុះសំគាល់នូវភ្លើងថាជាភ្លើងពិតហើយ ក៏ប្រកាន់នូវភ្លើង ប្រកាន់ក្នុងភ្លើង ប្រកាន់ថាជាភ្លើងពិត ប្រកាន់ថាភ្លើងជារបស់អញ ត្រេកអរនឹងភ្លើង ។ ដំណើរនោះព្រោះហេតុអ្វី ។ តថាគតពោលថា ព្រោះបុថុជ្ជននោះកំណត់នូវដំណើរភ្លើងនោះមិនបាន ។ បុថុជ្ជនសំគាល់នូវខ្យល់ថាជាខ្យល់ពិត លុះសំគាល់នូវខ្យល់ថាជាខ្យល់ពិតហើយ ក៏ប្រកាន់នូវខ្យល់ ប្រកាន់ក្នុងខ្យល់ ប្រកាន់ថាជាខ្យល់ពិត ប្រកាន់ថាខ្យល់ជារបស់អញ ត្រេកអរនឹងខ្យល់ ។ ដំណើរនោះព្រោះហេតុអ្វី ។

អបរិញ្ញាតំ តស្សាតិ វទាមិ ។ ភូតេ ភូតតោ សញ្ជានាតិ
ភូតេ ភូតតោ សញ្ញត្វា ភូតេ មញ្ញតិ ភូតេសុ
មញ្ញតិ ភូតតោ មញ្ញតិ ភូតេ មេតិ មញ្ញតិ ភូតេ
អភិនន្ទតិ ។ តំ កិស្ស ហេតុ ។ អបរិញ្ញាតំ តស្សាតិ
វទាមិ ។ ទេវេ ទេវតោ សញ្ជានាតិ ទេវេ ទេវតោ
សញ្ញត្វា ទេវេ មញ្ញតិ ទេវេសុ មញ្ញតិ ទេវតោ មញ្ញតិ
ទេវេ មេតិ មញ្ញតិ ទេវេ អភិនន្ទតិ ។ តំ កិស្ស ហេ-
តុ ។ អបរិញ្ញាតំ តស្សាតិ វទាមិ ។ បជាបតឹ បជា-
បតិតោ សញ្ជានាតិ បជាបតឹ បជាបតិតោ សញ្ញត្វា
បជាបតឹ មញ្ញតិ បជាបតិស្មឹ មញ្ញតិ បជាបតិតោ
មញ្ញតិ បជាបតិំ មេតិ មញ្ញតិ បជាបតឹ អភិនន្ទតិ ។
តំ កិស្ស ហេតុ ។ អបរិញ្ញាតំ តស្សាតិ វទាមិ ។
ព្រហ្មំ ព្រហ្មតោ សញ្ជានាតិ ព្រហ្មំ ព្រហ្មតោ សញ្ញត្វា
ព្រហ្មំ មញ្ញតិ ព្រហ្មនិ[១] មញ្ញតិ ព្រហ្មតោ មញ្ញតិ

១ ម. ព្រហ្មស្មឹ ។



តថាគតពោលថា ព្រោះបុថុជ្ជននោះកំណត់នូវដំណើរឲ្យល់នោះមិនបាន ។
បុថុជ្ជនសំគាល់នូវពួកសត្វថាជាសត្វពិត លុះសំគាល់នូវពួកសត្វថាជា
សត្វពិតហើយ ក៏ប្រកាន់នូវពួកសត្វ ប្រកាន់ក្នុងពួកសត្វ ប្រកាន់ថា
សត្វពិត ប្រកាន់ថាពួកសត្វជារបស់អញ ត្រេកអរនឹងពួកសត្វ ។ ដំណើរ
នោះ ព្រោះហេតុអ្វី ។ តថាគតពោលថា ព្រោះបុថុជ្ជននោះ កំណត់នូវដំ-
ណើរសត្វនោះមិនបាន ។ បុថុជ្ជនសំគាល់នូវពួកទេវតាថាជាទេវតាពិត លុះ
សំគាល់នូវពួកទេវតាថាជាទេវតាពិតហើយ ក៏ប្រកាន់នូវពួកទេវតា ប្រ
កាន់ក្នុងពួកទេវតា ប្រកាន់ថាទេវតាពិត ប្រកាន់ថាពួកទេវតាជារបស់
អញ ត្រេកអរនឹងពួកទេវតា ។ ដំណើរនោះ ព្រោះហេតុអ្វី ។ តថា-
គតពោលថា ព្រោះបុថុជ្ជននោះ កំណត់នូវដំណើរទេវតានោះមិនបាន ។
បុថុជ្ជនសំគាល់នូវមារថាជាមារពិត លុះសំគាល់នូវមារថាជាមារពិតហើយ
ក៏ប្រកាន់នូវមារ ប្រកាន់ក្នុងមារ ប្រកាន់ថាមារពិត ប្រកាន់ថាមារជា
របស់អញ ត្រេកអរនឹងមារ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ តថា-
គតពោលថា ព្រោះបុថុជ្ជននោះ កំណត់នូវដំណើរមារនោះមិនបាន ។
បុថុជ្ជនសំគាល់នូវព្រហ្មថាជាព្រហ្មពិត លុះសំគាល់នូវព្រហ្មថាព្រហ្ម
ពិតហើយ ក៏ប្រកាន់នូវព្រហ្ម ប្រកាន់ក្នុងព្រហ្ម ប្រកាន់ថាព្រហ្មពិត

ព្រហ្មំ មេតិ(១) មញ្ញតិ ព្រហ្មំ អភិនន្ទតិ ។ តំ កិស្ស ហេតុ ។ អបរិញ្ញាតំ តស្សាតិ វទាមិ ។ អាភស្សរេ អាភស្សរតោ សញ្ជានាតិ អាភស្សរេ អាភស្សរតោ សញ្ញត្វា អាភស្សរេ មញ្ញតិ អាភស្សរេសុ មញ្ញតិ អាភស្សរតោ មញ្ញតិ អាភស្សរេ មេតិ មញ្ញតិ អាភស្សរេ អភិនន្ទតិ ។ តំ កិស្ស ហេតុ ។ អបរិញ្ញាតំ តស្សាតិ វទាមិ ។ សុភកិណ្ហេ សុភកិណ្ហតោ(២) សញ្ជានាតិ សុភកិណ្ហេ សុភកិណ្ហតោ សញ្ញត្វា សុភកិណ្ហេ មញ្ញតិ សុភកិណ្ហេសុ មញ្ញតិ សុភកិណ្ហតោ មញ្ញតិ សុភកិណ្ហេ មេតិ មញ្ញតិ សុភកិណ្ហេ អភិនន្ទតិ ។ តំ កិស្ស ហេតុ ។ អបរិញ្ញាតំ តស្សាតិ វទាមិ ។ វេហប្ផលេ វេហប្ផលតោ សញ្ជានាតិ វេហប្ផលេ វេហប្ផលតោ សញ្ញត្វា

១ ឱ. ព្រហ្មមេតិ ។ ២ ឱ. សុភកិណ្ណេ សុភកិណ្ណតោ ។



ប្រកាន់ថាព្រហ្មជារបស់អញ ត្រេកអរនឹងព្រហ្ម ។ ដំណើរនោះព្រោះហេតុអ្វី ។ តថាគតពោលថា ព្រោះបុថុជ្ជននោះ កំណត់នូវដំណើរព្រហ្មនោះមិនបាន ។ បុថុជ្ជនសំគាល់នូវពួកអាភស្សរព្រហ្ម ថាជាអាភស្សរព្រហ្មពិត លុះសំគាល់នូវពួកអាភស្សរព្រហ្ម ថាជាអាភស្សរព្រហ្មពិតហើយ ក៏ប្រកាន់នូវពួកអាភស្សរព្រហ្ម ប្រកាន់ក្នុងពួកអាភស្សរព្រហ្ម ប្រកាន់ថាពួកអាភស្សរព្រហ្មពិត ប្រកាន់ថាពួកអាភស្សរព្រហ្មជារបស់អញ ត្រេកអរនឹងពួកអាភស្សរព្រហ្ម ។ ដំណើរនោះព្រោះហេតុអ្វី ។ តថាគតពោលថា ព្រោះបុថុជ្ជននោះ កំណត់នូវដំណើរអាភស្សរព្រហ្មមិនបាន ។ បុថុជ្ជនសំគាល់នូវពួកសុភកិណ្ហព្រហ្ម ថាជាសុភកិណ្ហព្រហ្មពិត លុះសំគាល់នូវពួកសុភកិណ្ហព្រហ្ម ថាជាសុភកិណ្ហព្រហ្មពិតហើយ ក៏ប្រកាន់នូវពួកសុភកិណ្ហព្រហ្ម ប្រកាន់ក្នុងពួកសុភកិណ្ហព្រហ្ម ប្រកាន់ថាពួកសុភកិណ្ហព្រហ្មពិត ប្រកាន់ថាពួកសុភកិណ្ហព្រហ្មជារបស់អញ ត្រេកអរនឹងពួកសុភកិណ្ហព្រហ្ម ។ ដំណើរនោះព្រោះហេតុអ្វី ។ តថាគតពោលថា ព្រោះបុថុជ្ជននោះ កំណត់នូវដំណើរសុភកិណ្ហព្រហ្មមិនបាន ។ បុថុជ្ជនសំគាល់នូវពួកវេហប្ផលព្រហ្ម ថាជាវេហប្ផលព្រហ្មពិត លុះសំគាល់នូវពួកវេហប្ផលព្រហ្ម ថាជាវេហ-

វេហប្ផលេ មញ្ញតិ វេហប្ផលេសុ មញ្ញតិ វេហប្ផលតោ មញ្ញតិ វេហប្ផលេ មេតិ មញ្ញតិ វេហប្ផលេ អភិនន្ទតិ ។ តំ កិស្ស ហេតុ ។ អបរិញ្ញាតំ តស្សាតិ វទាមិ ។ អភិភុំ អភិភុតោ សញ្ជានាតិ អភិភុំ អភិភុតោ សញ្ញត្វា អភិភុំ មញ្ញតិ អភិភុស្មឹ មញ្ញតិ អភិភុតោ មញ្ញតិ អភិភុំ មេតិ មញ្ញតិ អភិភុំ អភិនន្ទតិ ។ តំ កិស្ស ហេតុ ។ អបរិញ្ញាតំ តស្សាតិ វទាមិ ។ អាកាសានញ្ចាយតនំ អាកាសានញ្ចាយតនតោ សញ្ជានាតិ អាកាសានញ្ចាយតនំ អាកាសានញ្ចាយតនតោ សញ្ញត្វា អាកាសានញ្ចាយតនំ មញ្ញតិ អាកាសានញ្ចាយតនស្មឹ មញ្ញតិ អាកាសានញ្ចាយតនតោ មញ្ញតិ អាកាសានញ្ចាយតនំ មេតិ មញ្ញតិ អាកាសានញ្ចាយតនំ អភិនន្ទតិ ។ តំ កិស្ស ហេតុ ។ អបរិញ្ញាតំ តស្សាតិ វទាមិ ។



ប្ផលព្រហ្មពិតហើយ ក៏ប្រកាន់នូវពួកវេហប្ផលព្រហ្ម ប្រកាន់ក្នុងពួកវេហប្ផលព្រហ្ម ប្រកាន់ថា វេហប្ផលព្រហ្មពិត ប្រកាន់ថា វេហប្ផលព្រហ្មជារបស់អញ ត្រេកអរនឹងពួកវេហប្ផលព្រហ្ម ។ ដំណើរនោះព្រោះហេតុអ្វី ។ តថាគតពោលថា ព្រោះបុថុជ្ជននោះ កំណត់នូវដំណើរវេហប្ផលព្រហ្មនោះមិនបាន ។ បុថុជ្ជនសំគាល់នូវអសញ្ញសត្វ ថាជាអសញ្ញសត្វពិត លុះសំគាល់នូវអសញ្ញសត្វ ថាជាអសញ្ញសត្វពិតហើយ ក៏ប្រកាន់នូវអសញ្ញសត្វ ប្រកាន់ក្នុងអសញ្ញសត្វ ប្រកាន់ថាអសញ្ញសត្វពិត ប្រកាន់ថាអសញ្ញសត្វជារបស់អញ ត្រេកអរនឹងអសញ្ញសត្វ ។ ដំណើរនោះព្រោះហេតុអ្វី ។ តថាគតពោលថា ព្រោះបុថុជ្ជននោះ កំណត់នូវដំណើរអសញ្ញសត្វមិនបាន ។ បុថុជ្ជនសំគាល់នូវអាកាសានញ្ចាយតនព្រហ្ម ថាជាអាកាសានញ្ចាយតនព្រហ្មពិត លុះសំគាល់នូវអាកាសានញ្ចាយតនព្រហ្ម ថាជាអាកាសានញ្ចាយតនព្រហ្មពិតហើយ ប្រកាន់នូវអាកាសានញ្ចាយតនព្រហ្ម ប្រកាន់ក្នុងអាកាសានញ្ចាយតនព្រហ្ម ប្រកាន់ថា អាកាសានញ្ចាយតនព្រហ្មពិត ប្រកាន់ថាអាកាសានញ្ចាយតនព្រហ្មជារបស់អញ ត្រេកអរនឹងអាកាសានញ្ចាយតនព្រហ្ម ។ ដំណើរនោះព្រោះហេតុអ្វី ។ តថាគតពោលថា ព្រោះបុថុជ្ជននោះ កំណត់នូវដំណើរអាកាសានញ្ចាយតនព្រហ្មនោះមិនបាន ។

វិញ្ញាណញ្ចាយតនំ វិញ្ញាណញ្ចាយតនតោ សញ្ជានាតិ
វិញ្ញាណញ្ចាយតនំ វិញ្ញាណញ្ចាយតនតោ សញ្ញត្វា
វិញ្ញាណញ្ចាយតនំ មញ្ញតិ វិញ្ញាណញ្ចាយតនស្មឹ មញ្ញតិ
វិញ្ញាណញ្ចាយតនតោ មញ្ញតិ វិញ្ញាណញ្ចាយតនំ មេតិ
មញ្ញតិ វិញ្ញាណញ្ចាយតនំ អភិនន្ទតិ ។ តំ កិស្ស
ហេតុ ។ អបរិញ្ញាតំ តស្សាតិ វទាមិ ។ អាកិញ្ចញ្ញា-
យតនំ អាកិញ្ចញ្ញាយតនតោ សញ្ជានាតិ អាកិញ្ចញ្ញា-
យតនំ អាកិញ្ចញ្ញាយតនតោ សញ្ញត្វា អាកិញ្ចញ្ញា-
យតនំ មញ្ញតិ អាកិញ្ចញ្ញាយតនស្មឹ មញ្ញតិ អា-
កិញ្ចញ្ញាយតនតោ មញ្ញតិ អាកិញ្ចញ្ញាយតនំ មេតិ
មញ្ញតិ អាកិញ្ចញ្ញាយតនំ អភិនន្ទតិ ។ តំ កិស្ស
ហេតុ ។ អបរិញ្ញាតំ តស្សាតិ វទាមិ ។ នេវសញ្ញានា-
សញ្ញាយតនំ នេវសញ្ញានាសញ្ញាយតនតោ សញ្ជា-
នាតិ នេវសញ្ញានាសញ្ញាយតនំ នេវសញ្ញានា-
សញ្ញាយតនតោ សញ្ញត្វា នេវសញ្ញានាសញ្ញាយ-
តនំ មញ្ញតិ នេវសញ្ញានាសញ្ញាយតនស្មឹ មញ្ញតិ



បុថុជ្ជនសំគាល់នូវវិញ្ញាណញ្ចាយតនព្រហ្ម ថាជាវិញ្ញាណញ្ចាយតនព្រហ្ម
ពិត លុះសំគាល់នូវវិញ្ញាណញ្ចាយតនព្រហ្ម ថាជាវិញ្ញាណញ្ចាយ-
តនព្រហ្មពិតហើយ ក៏រប់អាននូវវិញ្ញាណញ្ចាយតនព្រហ្ម រប់អានក្នុង
វិញ្ញាណញ្ចាយតនព្រហ្ម រប់អានថាវិញ្ញាណញ្ចាយតនព្រហ្មពិត រប់
អានថាវិញ្ញាណញ្ចាយតនព្រហ្មជារបស់អញ ត្រេកអរនឹងវិញ្ញាណញ្ចា-
យតនព្រហ្ម ។ ដំណើរនោះព្រោះហេតុអ្វី ។ តថាគតពោលថា
ព្រោះ បុថុជ្ជននោះ កំណត់នូវដំណើរវិញ្ញាណញ្ចាយតនព្រហ្មនោះមិន
បាន ។ បុថុជ្ជនសំគាល់នូវអាកិញ្ចញ្ញាយតនព្រហ្ម ថាជាអាកិញ្ច-
ញ្ញាយតនព្រហ្មពិត លុះសំគាល់នូវអាកិញ្ចញ្ញាយតនព្រហ្ម ថាជាអា-
កិញ្ចញ្ញាយតនព្រហ្មពិតហើយ ក៏រប់អាននូវអាកិញ្ចញ្ញាយតនព្រហ្ម រប់
អានក្នុងអាកិញ្ចញ្ញាយតនព្រហ្ម រប់អានថាអាកិញ្ចញ្ញាយតនព្រហ្មពិត
រប់អានថាអាកិញ្ចញ្ញាយតនព្រហ្មជារបស់អញ ត្រេកអរនឹងអាកិញ្ចញ្ញា-
យតនព្រហ្ម ។ ដំណើរនោះព្រោះហេតុអ្វី ។ តថាគតពោលថា
ព្រោះ បុថុជ្ជននោះ កំណត់នូវអាកិញ្ចញ្ញាយតនព្រហ្មមិនបាន ។ បុថុជ្ជន
សំគាល់នូវនេវសញ្ញានាសញ្ញាយតនព្រហ្ម ថាជានេវសញ្ញានាសញ្ញា-
យតនព្រហ្មពិត លុះសំគាល់នូវនេវសញ្ញានាសញ្ញាយតនព្រហ្មពិតហើយ
ក៏រប់អាននូវនេវសញ្ញានាសញ្ញាយតនព្រហ្ម រប់អានក្នុងនេវសញ្ញានា-

នេវសញ្ញានាសញ្ញាយតនតោ មញ្ញតិ នេវសញ្ញានាសញ្ញាយតនម្មេតិ មញ្ញតិ នេវសញ្ញានាសញ្ញាយតនំ អភិនន្ទតិ ។ តំ កិស្ស ហេតុ ។ អបរិញ្ញាតំ តស្សាតិ វទាមិ ។ ទិដ្ឋំ ទិដ្ឋតោ សញ្ជានាតិ ទិដ្ឋំ ទិដ្ឋតោ សញ្ញត្វា ទិដ្ឋំ មញ្ញតិ ទិដ្ឋស្មឹ មញ្ញតិ ទិដ្ឋតោ មញ្ញតិ ទិដ្ឋម្មេតិ មញ្ញតិ ទិដ្ឋំ អភិនន្ទតិ ។ តំ កិស្ស ហេតុ ។ អបរិញ្ញាតំ តស្សាតិ វទាមិ ។ សុតំ សុតតោ សញ្ជានាតិ សុតំ សុតតោ សញ្ញត្វា សុតំ មញ្ញតិ សុតស្មឹ មញ្ញតិ សុតតោ មញ្ញតិ សុតម្មេតិ មញ្ញតិ សុតំ អភិនន្ទតិ ។ តំ កិស្ស ហេតុ ។ អបរិញ្ញាតំ តស្សាតិ វទាមិ ។ មុតំ មុតតោ សញ្ជានាតិ មុតំ មុតតោ សញ្ញត្វា



សញ្ញាយតនព្រហ្ម ក៏ប្រកាន់ថានេវសញ្ញានាសញ្ញាយតនព្រហ្មពិត ក៏ប្រកាន់ថានេវសញ្ញានាសញ្ញាយតនព្រហ្មជារបស់អញ ត្រេកអរនឹងនេវសញ្ញានាសញ្ញាយតនព្រហ្ម ។ ដំណើរនោះព្រោះហេតុអ្វី ។ តថាគតពោលថា ព្រោះបុថុជ្ជននោះ កំណត់នូវនេវសញ្ញានាសញ្ញាយតនព្រហ្មនោះមិនបាន ។ បុថុជ្ជនសំគាល់នូវរូបាយតនៈថាជារូបាយតនៈពិត លុះសំគាល់នូវរូបាយតនៈថាជារូបាយតនៈពិតហើយ ក៏ប្រកាន់នូវរូបាយតនៈ ក៏ប្រកាន់ក្នុងរូបាយតនៈ ក៏ប្រកាន់ថារូបាយតនៈពិត ក៏ប្រកាន់ថារូបាយតនៈជារបស់អញ ត្រេកអរនឹងរូបាយតនៈ ។ ដំណើរនោះព្រោះហេតុអ្វី ។ តថាគតពោលថា ព្រោះបុថុជ្ជននោះ កំណត់នូវដំណើររូបាយតនៈនោះមិនបាន ។ បុថុជ្ជនសំគាល់នូវសទ្ទាយតនៈថាជាសទ្ទាយតនៈពិត លុះសំគាល់នូវសទ្ទាយតនៈថាជាសទ្ទាយតនៈពិតហើយ ក៏ប្រកាន់ថាសទ្ទាយតនៈ ក៏ប្រកាន់ក្នុងសទ្ទាយតនៈ ក៏ប្រកាន់ថាសទ្ទាយតនៈពិត ក៏ប្រកាន់ថាសទ្ទាយតនៈជារបស់អញ ត្រេកអរនឹងសទ្ទាយតនៈ ។ ដំណើរនោះព្រោះហេតុអ្វី ។ តថាគតពោលថាព្រោះបុថុជ្ជននោះ កំណត់នូវដំណើរសទ្ទាយតនៈនោះមិនបាន ។ បុថុជ្ជនសំគាល់នូវមុតៈ[១] ថាជាមុតៈពិត លុះសំគាល់នូវមុតៈ ថាជាមុតៈពិតហើយ

---

១ មុតសព្ទក្នុងទីនេះ ជាឈ្មោះអាយតនៈទាំង ៣ គឺ គន្ធៈ រស, ផោដ្ឋព្វៈ ។

មុតំ មញ្ញតិ មុតស្មឹ មញ្ញតិ មុតតោ មញ្ញតិ មុតម្មេតិ មញ្ញតិ មុតំ អភិនន្ទតិ ។ តំ កិស្ស ហេតុ ។ អបរិញ្ញាតំ តស្សាតិ វទាមិ ។ វិញ្ញាតំ វិញ្ញាតតោ សញ្ជានាតិ វិញ្ញាតំ វិញ្ញាតតោ សញ្ញត្វា វិញ្ញាតំ មញ្ញតិ វិញ្ញាតស្មឹ មញ្ញតិ វិញ្ញាតតោ មញ្ញតិ វិញ្ញាតម្មេតិ មញ្ញតិ វិញ្ញាតំ អភិនន្ទតិ ។ តំ កិស្ស ហេតុ ។ អបរិញ្ញាតំ តស្សាតិ វទាមិ ។ ឯកត្តំ ឯកត្តតោ សញ្ជានាតិ ឯកត្តំ ឯកត្តតោ សញ្ញត្វា ឯកត្តំ មញ្ញតិ ឯកត្តស្មឹ មញ្ញតិ ឯកត្តតោ មញ្ញតិ ឯកត្តម្មេតិ មញ្ញតិ ឯកត្តំ អភិនន្ទតិ ។ តំ កិស្ស ហេតុ ។



គឺរប់អាននូវមុតៈ រប់អានក្នុងមុតៈ រប់អានថាមុតៈពិត រប់អានថាមុតៈជារបស់អញ ត្រេកអរនឹងមុតៈ ។ ដំណើរនោះព្រោះហេតុអ្វី ។ តថាគតពោលថា ព្រោះបុថុជ្ជននោះ កំណត់នូវដំណើរមុតៈនោះមិនបាន ។ បុថុជ្ជនសំគាល់នូវវិញ្ញាតៈ[១] ថាជាវិញ្ញាតៈពិត លុះសំគាល់នូវវិញ្ញាតៈ ថាជាវិញ្ញាតៈពិតហើយ គឺរប់អាននូវវិញ្ញាតៈ រប់អានក្នុងវិញ្ញាតៈ រប់អានថាវិញ្ញាតៈពិត រប់អានថាវិញ្ញាតៈជារបស់អញ ត្រេកអរនឹងវិញ្ញាតៈ ។ ដំណើរនោះព្រោះហេតុអ្វី ។ តថាគតពោលថា ព្រោះបុថុជ្ជននោះ កំណត់នូវដំណើរវិញ្ញាតៈនោះមិនបាន ។ បុថុជ្ជនសំគាល់នូវរបស់ដូចគ្នា[២] ថាជារបស់ដូចគ្នាពិត លុះសំគាល់នូវរបស់ដូចគ្នា ថាជារបស់ដូចគ្នាពិតហើយ គឺរប់អាននូវរបស់ដូចគ្នា រប់អានក្នុងរបស់ដូចគ្នា រប់អានថារបស់ដូចគ្នាពិត រប់អានថារបស់ដូចគ្នាជារបស់អញ ត្រេកអរនឹងរបស់ដូចគ្នា ។ ដំណើរនោះព្រោះហេតុអ្វី ។

---

១ វិញ្ញាតសព្ទក្នុងទីនេះ ជាឈ្មោះអាយតនៈទាំង ៧ គឺ ចក្ខុ-សោត-ឃាន-ជិវ្ហា-កាយ-មន និងធម្មាយតនៈ ។ ២ របស់ដូចគ្នា បានដល់ខន្ធទាំង ៤ គឺ វេទនា-សញ្ញា-សង្ខារ-វិញ្ញាណ ។ អដ្ឋកថា ។

អបរិញ្ញាតំ តស្សាតិ វទាមិ ។ នានត្តំ នានត្តតោ សញ្ជានាតិ នានត្តំ នានត្តតោ សញ្ញត្វា នានត្តំ មញ្ញតិ នានត្តស្មឹ មញ្ញតិ នានត្តតោ មញ្ញតិ នានត្តម្មេតិ មញ្ញតិ នានត្តំ អភិនន្ទតិ ។ តំ កិស្ស ហេតុ ។ អបរិញ្ញាតំ តស្សាតិ វទាមិ ។ សព្វំ សព្វតោ សញ្ជានាតិ សព្វំ សព្វតោ សញ្ញត្វា សព្វំ មញ្ញតិ សព្វស្មឹ មញ្ញតិ សព្វតោ មញ្ញតិ សព្វម្មេតិ មញ្ញតិ សព្វំ អភិនន្ទតិ ។



តថាគតពោលថា ព្រោះបុថុជ្ជននោះ កំណត់នូវដំណើររបស់ដូចគ្នា មិនបាន ។ បុថុជ្ជនសំគាល់នូវរបស់ផ្សេងគ្នា(១) ថាជារបស់ផ្សេងគ្នាពិត លុះសំគាល់នូវរបស់ផ្សេងគ្នា ថាជារបស់ផ្សេងគ្នាពិតហើយ ក៏រាប់អាន នូវរបស់ផ្សេងគ្នា រាប់អានក្នុងរបស់ផ្សេងគ្នា រាប់អានថារបស់ផ្សេងគ្នាពិត រាប់អានថារបស់ផ្សេងគ្នាជារបស់អញ ត្រេកអរនឹងរបស់ផ្សេងគ្នា ។ ដំណើរនោះព្រោះហេតុអ្វី ។ តថាគតពោលថាព្រោះបុថុជ្ជននោះ កំណត់នូវដំណើររបស់ផ្សេងគ្នានោះ មិនបាន ។ បុថុជ្ជនសំគាល់នូវវត្ថុទាំងពួង(២) ថាជាវត្ថុទាំងពួងពិត គឺសំដែងនូវទិដ្ឋិដែលមានសភាពប្រហែលគ្នា លុះសំគាល់នូវវត្ថុទាំងពួង ថាជាវត្ថុទាំងពួងពិតហើយក៏រាប់អាននូវវត្ថុទាំងពួង រាប់អានក្នុងវត្ថុទាំងពួង រាប់អានថាវត្ថុទាំងពួងពិត រាប់អានថាវត្ថុទាំងពួងជារបស់អញ ត្រេកអរនឹងវត្ថុទាំងពួង ។

---

១ របស់ផ្សេងគ្នា បានដល់ខន្ធទាំង ៥ មានរូបក្ខន្ធជាដើម មានវិញ្ញាណក្ខន្ធជាទីបំផុត ។

២ វត្ថុទាំងពួងក្នុងទីនេះ បានដល់ប្រជុំរបស់ទាំង ២ គឺរបស់ដូចគ្នា ១ ( ខន្ធទាំង ៥ ) របស់ផ្សេងគ្នា ១ (ខន្ធទាំង ៥) លោកហៅថារបស់ទាំងពួងឬវត្ថុទាំងពួងនុ៎ះ ។ ឯសេចក្ដីសំគាល់នេះមាន ៣ យ៉ាង គឺត្រេកអររីករាយនឹងរបស់ទាំងអស់នោះ ហៅថាសំគាល់ដោយតណ្ហា ។ សំគាល់ថារបស់ទាំងអស់គឺអាត្មាអញនិម្មិតដោយខ្លួនឯងហៅថាសំគាល់ដោយមានះ ។ សំគាល់ថារបស់ទាំងអស់មានកម្មដែលខ្លួនធ្វើអំពីមុនមកជាហេតុ របស់ទាំងអស់មិនមានហេតុ មិនមានបច្ច័យឡើយ របស់ទាំងអស់មានខ្លះ មិនមានខ្លះ ហៅថាសំគាល់ដោយទិដ្ឋិ ។ អដ្ឋកថា ។

តំ កិស្ស ហេតុ ។ អបរិញ្ញាតំ តស្សាតិ វទាមិ ។ និព្វានំ និព្វានតោ សញ្ជានាតិ និព្វានំ និព្វានតោ សញ្ញត្វា និព្វានំ មញ្ញតិ និព្វានស្មឹ មញ្ញតិ និព្វានតោ មញ្ញតិ និព្វានំ មេតិ មញ្ញតិ និព្វានំ អភិនន្ទតិ ។ តំ កិស្ស ហេតុ ។ អបរិញ្ញាតំ តស្សាតិ វទាមិ ។

បុថុជ្ជនវសេន បឋមនយភូមិបរិច្ឆេទោ[១] ។

(៣) យោបិ សោ ភិក្ខវេ ភិក្ខុ សេខោ អប្បត្ត-មានសោ អនុត្តរំ យោគក្ខេមំ បត្ថយមានោ វិហរតិ ។ សោបិ បឋវឹ បឋវិតោ អភិជានាតិ បឋវឹ បឋវិតោ អភិញ្ញាយ បឋវឹ មាមញ្ញិ[២] បឋវិយា មាមញ្ញិ[៣] បឋវិតោ មាមញ្ញិ[៤] បឋវឹមេតិ មាមញ្ញិ[៥] បឋវឹ មាភិនន្ទិ[៦] ។ តំ កិស្ស ហេតុ ។ បរិញ្ញេយ្យំ តស្សាតិ វទាមិ

១ ឱ. បឋមនយមិទំ ន ទិស្សតិ ។ ម. ឥតោ បរំ និទ្ទិដ្ឋោតិ សព្វត្ថ ទិស្សតិ ។ ២-៣-៤-៥ ឱ.ម. មាមញ្ញី ។ ៦ ឱ. មា អភិនន្ទិ ។ ម. មាភិនន្ទតិ ។



ដំណើរនោះព្រោះហេតុអ្វី ។ តថាគតពោលថា ព្រោះបុថុជ្ជននោះ កំណត់នូវដំណើរវត្ថុទាំងនោះមិនបាន ។ បុថុជ្ជន សំគាល់នូវនិព្វាន[១] ថាជានិព្វានពិត លុះសំគាល់នូវនិព្វាន ថាជានិព្វានពិតហើយ ក៏ប្រកាន់នូវនិព្វាន ប្រកាន់ក្នុងនិព្វាន ប្រកាន់ថានិព្វានពិត ប្រកាន់ថានិព្វានជារបស់អញ ត្រេកអរនឹងនិព្វាន ។ ដំណើរនេះព្រោះហេតុអ្វី ។ តថាគត-ពោលថា ព្រោះបុថុជ្ជននោះ កំណត់នូវដំណើរនិព្វាននោះមិនបាន ។

ចប់ នយភូមិបរិច្ឆេទ ទី ១ ដោយអំណាចបុថុជ្ជន ។

(៣) ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាជាសេក្ខបុគ្គល មិនទាន់បាន សម្រេចអរហត្ត កំពុងប្រាថ្នានូវធម៌ដ៏ក្សេមចាកយោគៈ (អរហត្តដ៏ប្រសើរ) ។ ភិក្ខុនោះឯងដឹងច្បាស់នូវផែនដី ថាជាផែនដីពិត លុះដឹងច្បាស់នូវផែនដី ថាជាផែនដីពិតហើយ ក៏មិនប្រកាន់នូវផែនដី មិនប្រកាន់ក្នុងផែនដី មិនប្រកាន់ថាជាផែនដីពិត មិនប្រកាន់ថាផែនដីជារបស់អញ មិនត្រេកអរនឹងផែនដី ។ ដំណើរនោះព្រោះហេតុអ្វី ។ តថាគតពោលថា ព្រោះភិក្ខុជាសេក្ខៈនោះ គប្បីកំណត់នូវដំណើរនៃផែនដីនោះបាន

១ និព្វានសព្ទក្នុងទីនេះ ជាឈ្មោះសេចក្តីសុខរបស់ អញ(ខ្លួន) ដែលបរិបូណ៌គ្រប់គ្រាន់ដោយកាមគុណ ៥ គឺ រូប–សំឡេង–ក្លិន–រស និងផោដ្ឋព្វ ហៅថា បរមទិដ្ឋធម្មនិព្វាន ។ អដ្ឋកថា ។

។ បេ ។ អាបំ តេជំ វាយំ ភូតេ ទេវេ បជាបតឹ ព្រហ្មំ អាភស្សរេ សុភកិណ្ហេ វេហប្ផលេ អភិភុំ អាកាសានញ្ចាយតនំ វិញ្ញាណញ្ចាយតនំ អាកិញ្ចញ្ញាយតនំ នេវសញ្ញានាសញ្ញាយតនំ ទិដ្ឋំ សុតំ មុតំ វិញ្ញាតំ ឯកត្តំ នានត្តំ សព្វំ និព្វានំ និព្វានតោ អភិជានាតិ និព្វានំ និព្វានតោ អភិញ្ញាយ និព្វានំ មាមញ្ញី និព្វានស្មឹ មាមញ្ញី និព្វានតោ មាមញ្ញី និព្វានំ មេតិ មាមញ្ញី និព្វានំ មាភិនន្ទី ។ តំ កិស្ស ហេតុ ។ បរិញ្ញេយ្យំ តស្សាតិ វទាមិ ។

សេក្ខវសេន ទុតិយនយភូមិបរិច្ឆេទោ(១) ។

(៤) យោបិ សោ ភិក្ខវេ ភិក្ខុ អរហំ ខីណាសវោ វុសិតវា កតករណីយោ ឱហិតភារោ អនុប្បត្តសទត្ថោ បរិក្ខីណភវសំយោជនោ សម្មទញ្ញាវិមុត្តោ សោបិ

១ ម. ឥទំ បទទ្វយំ ន ទិស្សតិ ។



។ បេ ។ ភិក្ខុជាសេក្ខបុគ្គលដឹងច្បាស់នូវទឹក ភ្លើង ខ្យល់ ពួកសត្វ ពួកទេវតា មារ ព្រហ្ម ពួកអាភស្សរព្រហ្ម ពួកសុភកិណ្ហព្រហ្ម ពួកវេហប្ផលព្រហ្ម អសញ្ញីសត្វ អាកាសានញ្ចាយតនព្រហ្ម វិញ្ញាណញ្ចាយតនព្រហ្ម អាកិញ្ចញ្ញាយតនព្រហ្ម នេវសញ្ញានាសញ្ញាយតនព្រហ្ម រូបាយតនៈ សទ្ទាយតនៈ មុតៈ វិញ្ញាតៈ របស់ដូចគ្នា របស់ផ្សេងគ្នា វត្ថុទាំងពួងទាំងនិព្វាន ថាជានិព្វានពិត លុះដឹងច្បាស់នូវនិព្វាន ថាជានិព្វានពិតហើយ ក៏មិនគប់គាននូវនិព្វាន មិនគប់គានក្នុងនិព្វាន មិនគប់គានថានិព្វានពិត មិនគប់គានថានិព្វានជារបស់អាត្មា មិនត្រេកអរនឹងនិព្វាន ។ ដំណើរនោះព្រោះហេតុអ្វី ។ តថាគតពោលថា ព្រោះភិក្ខុជាសេក្ខបុគ្គលនោះ គប្បីកំណត់នូវដំណើរនៃផែនដីជាដើមនោះបាន ។

ចប់ នយភូមិបរិច្ឆេទទី ២ ដោយអំណាចសេក្ខបុគ្គល ។

(៤) ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាជាអរហន្តខីណាស្រព មានព្រហ្មចរិយធម៌ប្រព្រឹត្តគ្រប់គ្រាន់ហើយ មានសោឡសកិច្ចបានធ្វើសម្រេចហើយ មានភារៈ(១)ដាក់ចុះហើយ មានប្រយោជន៍របស់ខ្លួនបានសម្រេចតាមលំដាប់ហើយ មានភវសំយោជនៈអស់រលីងហើយ មានចិត្តរួចស្រឡះ ព្រោះដឹងដោយប្រពៃហើយ ភិក្ខុជាអរហន្តខីណាស្រពនោះ

១ ភារៈមាន ៣ យ៉ាង គឺ ខន្ធភារៈ (ខន្ធទាំង៥ជាភារៈ) ១ កិលេសភារៈ (កិលេសទាំង១៥០០ មានលោភៈជាដើមជាភារៈ) ១ អភិសង្ខារភារៈ (កុសលាកុសលកម្មជាភារៈ) ១ ។ អដ្ឋកថា ។

បឋវឹ បឋវិតោ អភិជានាតិ បឋវឹ បឋវិតោ អភិញ្ញាយ បឋវឹ ន មញ្ញតិ បឋវិយា ន មញ្ញតិ បឋវិតោ ន មញ្ញតិ បឋវឹមេតិ ន មញ្ញតិ បឋវឹ នាភិនន្ទតិ ។ តំ កិស្ស ហេតុ ។ បរិញ្ញាតំ តស្សាតិ វទាមិ ។ បេ ។ អាបំ តេជំ វាយំ ភូតេ ទេវេ បជាបតឹ ព្រហ្មំ អាភស្សរេ សុភកិណ្ហេ វេហប្ផលេ អភិភុំ អាកាសានញ្ចាយតនំ វិញ្ញាណញ្ចាយតនំ អាកិញ្ចញ្ញាយតនំ នេវសញ្ញានាសញ្ញាយតនំ ទិដ្ឋំ សុតំ មុតំ វិញ្ញាតំ ឯកត្តំ នានត្តំ សព្វំ និព្វានំ និព្វានតោ អភិជានាតិ និព្វានំ និព្វានតោ អភិញ្ញាយ និព្វានំ ន មញ្ញតិ និព្វានស្មឹ ន មញ្ញតិ និព្វានតោ ន មញ្ញតិ និព្វានំមេតិ ន មញ្ញតិ និព្វានំ នាភិនន្ទតិ ។ តំ កិស្ស ហេតុ ។ បរិញ្ញាតំ តស្សាតិ វទាមិ ។

ខីណាសវវសេន តតិយនយភូមិបរិច្ឆេទោ[១] ។

១ ម. ឥទំ បទទ្វយំ ន ទិស្សតិ ។



ដឹងច្បាស់នូវផែនដី ថាជាផែនដីពិត លុះបានដឹងច្បាស់នូវផែនដីថាជាផែនដីពិតហើយ ក៏មិនប្រកាន់នូវផែនដី មិនប្រកាន់ក្នុងផែនដី មិនប្រកាន់ថាផែនដីពិត មិនប្រកាន់ថាផែនដីជារបស់អញ មិនត្រេកអរនឹងផែនដី ។ ដំណើរនោះព្រោះហេតុអ្វី ។ តថាគតពោលថា ព្រោះភិក្ខុជាអរហន្តខីណាស្រពនោះ កំណត់ដឹងនូវដំណើរនៃផែនដីនោះបាន ។ បេ ។ ភិក្ខុជាអរហន្តខីណាស្រព ដឹងច្បាស់នូវទឹក ភ្លើង ខ្យល់ ពួកសត្វ ពួកទេវតា មារ ព្រហ្ម ពួកអាភស្សរព្រហ្ម ពួកសុភកិណ្ហព្រហ្ម ពួកវេហប្ផលព្រហ្ម អសញ្ញីសត្វ អាកាសានញ្ចាយតនព្រហ្ម វិញ្ញាណញ្ចាយតនព្រហ្ម អាកិញ្ចញ្ញាយតនព្រហ្ម នេវសញ្ញានាសញ្ញាយតនព្រហ្ម រូបាយតនៈ សទ្ទាយតនៈ មុតៈ វិញ្ញាតៈ របស់ដូចគ្នា របស់ផ្សេងគ្នា វត្ថុទាំងពួង នូវនិព្វាន ថាជានិព្វានពិត លុះដឹងច្បាស់នូវនិព្វាន ថាជានិព្វានពិតហើយ ក៏មិនប្រកាន់នូវនិព្វាន មិនប្រកាន់ក្នុងនិព្វាន មិនប្រកាន់ថានិព្វានពិត មិនប្រកាន់ថានិព្វានជារបស់អញ មិនត្រេកអរនឹងនិព្វាន ។ ដំណើរនោះព្រោះហេតុអ្វី ។ តថាគតពោលថា ព្រោះភិក្ខុជាអរហន្តខីណាស្រពនោះ កំណត់ដឹងនូវដំណើរនៃនិព្វានជាដើមនោះបាន ។

ចប់ នយភូមិបរិច្ឆេទទី ៣ ដោយអំណាចនៃព្រះខីណាស្រព ។

(៤) យោបិ សោ ភិក្ខវេ ភិក្ខុ អរហំ ខីណាសវោ វុសិតវា កតករណីយោ ឱហិតភារោ អនុប្បត្តសទត្ថោ បរិក្ខីណភវសំយោជនោ សម្មទញ្ញាវិមុត្តោ សោបិ បឋវឹ បឋវិតោ អភិជានាតិ បឋវឹ បឋវិតោ អភិញ្ញាយ បឋវឹ ន មញ្ញតិ បឋវិយា ន មញ្ញតិ បឋវិតោ ន មញ្ញតិ បឋវឹ មេតិ ន មញ្ញតិ បឋវឹ នាភិនន្ទតិ ។ តំ កិស្ស ហេតុ ។ ខយា រាគស្ស វីតរាគត្តា ។ បេ ។ អាបំ តេជំ វាយំ ភូតេ ទេវេ បជាបតឹ ព្រហ្មំ អាភស្សរេ សុភកិណ្ហេ វេហប្ផលេ អភិភុំ អាកាសានញ្ចាយតនំ វិញ្ញាណញ្ចាយតនំ អាកិញ្ចញ្ញាយតនំ នេវសញ្ញានាសញ្ញាយតនំ ទិដ្ឋំ សុតំ មុតំ វិញ្ញាតំ ឯកត្តំ នានត្តំ សព្វំ និព្វានំ និព្វានតោ អភិជានាតិ



(៤) ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាជាអរហន្តខីណាស្រព មានព្រហ្មចរិយធម៌ប្រព្រឹត្តគ្រប់គ្រាន់ហើយ មានសោឡសកិច្ច ធ្វើស្រេចហើយ មានភារៈដាក់ចុះហើយ មានប្រយោជន៍របស់ខ្លួនសម្រេចតាមលំដាប់ហើយ មានភវសំយោជនៈអស់ហើយ មានចិត្តរួចស្រឡះព្រោះដឹងដោយប្រពៃហើយ ភិក្ខុនោះឯងដឹងច្បាស់នូវផែនដី ថាជាផែនដីពិត លុះដឹងច្បាស់នូវផែនដី ថាជាផែនដីពិតហើយ ក៏មិនប្រកាន់នូវផែនដី មិនប្រកាន់ក្នុងផែនដី មិនប្រកាន់ថាផែនដីពិត មិនប្រកាន់ថាផែនដីជារបស់អញ មិនត្រេកអរនឹងផែនដី ។ ដំណើរនោះព្រោះហេតុអ្វី ។ ព្រោះភិក្ខុនោះជាវីតរាគបុគ្គល ផុតអស់រាគៈហើយ ។បេ។ ភិក្ខុជាអរហន្តខីណាស្រព ដឹងច្បាស់នូវទឹក ភ្លើង ខ្យល់ ពួកសត្វ ពួកទេវតា មារ ព្រហ្ម ពួកអាភស្សរព្រហ្ម ពួកសុភកិណ្ហព្រហ្ម ពួកវេហប្ផលព្រហ្ម អសញ្ញីសត្វ អាកាសានញ្ចាយតនព្រហ្ម វិញ្ញាណញ្ចាយតនព្រហ្ម អាកិញ្ចញ្ញាយតនព្រហ្ម នេវសញ្ញានាសញ្ញាយតនព្រហ្ម រូបាយតនៈ សទ្ទាយតនៈ មុតៈ វិញ្ញាតៈ របស់ដូចគ្នា របស់ផ្សេងគ្នា វត្ថុទាំងពួងនិងនិព្វាន ថាជានិព្វានពិត លុះដឹងច្បាស់

និព្វានំ និព្វានតោ អភិញ្ញាយ និព្វានំ ន មញ្ញតិ និព្វានស្មឹ ន មញ្ញតិ និព្វានតោ ន មញ្ញតិ និព្វានំ មេតិ ន មញ្ញតិ និព្វានំ នាភិនន្ទតិ ។ តំ កិស្ស ហេតុ ។ ខយា រាគស្ស វីតរាគត្តា ។

ខីណាសវវារេន ចតុត្ថនយភូមិបរិច្ឆេទោ[១] ។

(៦) យោបិ សោ ភិក្ខវេ ភិក្ខុ អរហំ ខី-ណាសវោ វុសិតវា កតករណីយោ ឱហិតភារោ អនុប្បត្តសទត្ថោ បរិក្ខីណភវសំយោជនោ សម្មទញ្ញា-វិមុត្តោ សោបិ បឋវឹ បឋវិតោ អភិជានាតិ បឋវឹ បឋវិតោ អភិញ្ញាយ បឋវឹ ន មញ្ញតិ បឋវិយា ន មញ្ញតិ បឋវិតោ ន មញ្ញតិ បឋវឹ មេតិ ន មញ្ញតិ បឋវឹ នាភិនន្ទតិ ។ តំ កិស្ស ហេតុ ។ ខយា ទោសស្ស វីតទោសត្តា ។ បេ ។ អាបំ តេជំ វាយំ ភូតេ ទេវេ បជាបតឹ ព្រហ្មំ អាភស្សរេ សុភកិណ្ហេ

១ ឱ. ឥទំ បទទ្វយំ ន ទិស្សតិ ។



នូវនិព្វាន ថាជានិព្វានពិតហើយ ក៏មិនប្រកាន់នូវនិព្វាន មិនប្រកាន់ក្នុងនិព្វាន មិនប្រកាន់ថានិព្វានពិត មិនប្រកាន់ថានិព្វានជារបស់អញ មិនត្រេកអរនឹងនិព្វាន ។ ដំណើរនោះព្រោះហេតុអ្វី ។ ព្រោះភិក្ខុនោះជាវីតរាគបុគ្គល ផុតអស់រាគៈហើយ ។

ចប់ នយភូមិបរិច្ឆេទ ទី ៤ ដោយអំណាចនៃព្រះខីណាស្រព ។

(៦) ម្នាលភិក្ខុទាំងឡាយ ភិក្ខុណា ជាអរហន្តខីណាស្រព មានព្រហ្មចរិយធម៌ប្រព្រឹត្តគ្រប់គ្រាន់ហើយ មានសោឡសកិច្ចធ្វើស្រេចហើយ មានភារៈដាក់ចុះហើយ មានប្រយោជន៍របស់ខ្លួន សម្រេចតាមលំដាប់ហើយ មានភវសំយោជនៈអស់រលីងហើយ មានចិត្តរួចស្រឡះ ព្រោះដឹងដោយប្រពៃហើយ ភិក្ខុនោះដឹងច្បាស់នូវផែនដី ថាជាផែនដីពិត លុះដឹងច្បាស់នូវផែនដី ថាជាផែនដីពិតហើយ ក៏មិនប្រកាន់នូវផែនដី មិនប្រកាន់ក្នុងផែនដី មិនប្រកាន់ថាផែនដីពិត មិនប្រកាន់ថាផែនដីជារបស់អញ មិនត្រេកអរនឹងផែនដី ។ ដំណើរនោះព្រោះហេតុអ្វី ។ ព្រោះភិក្ខុនោះជាវីតទោសបុគ្គល ផុតអស់ទោសៈហើយ ។បេ។ ភិក្ខុជាអរហន្តខីណាស្រព ដឹងច្បាស់នូវទឹក ភ្លើង ខ្យល់ ពួកសត្វ ពួកទេវតា មារ ព្រហ្ម ពួកអាភស្សរព្រហ្ម ពួកសុភកិណ្ហព្រហ្ម

វេហប្ផលេ អភិភុំ អាកាសានញ្ចាយតនំ វិញ្ញាណញ្ចាយតនំ អាកិញ្ចញ្ញាយតនំ នេវសញ្ញានាសញ្ញាយតនំ ទិដ្ឋំ សុតំ មុតំ វិញ្ញាតំ ឯកត្តំ នានត្តំ សព្វំ និព្វានំ និព្វានតោ អភិជានាតិ និព្វានំ និព្វានតោ អភិញ្ញាយ និព្វានំ ន មញ្ញតិ និព្វានស្មឹ ន មញ្ញតិ និព្វានតោ ន មញ្ញតិ និព្វានំ មេតិ ន មញ្ញតិ និព្វានំ នាភិនន្ទតិ ។ តំ កិស្ស ហេតុ ។ ខយា ទោសស្ស វីតទោសត្តា ។

ខីណាសវវារេ ឆដ្ឋនយភូមិបរិច្ឆេទោ[១] ។

(៧) យោបិ សោ ភិក្ខវេ ភិក្ខុ អរហំ ខីណាសវោ វុសិតវា កតករណីយោ ឱហិតភារោ អនុប្បត្តសទត្ថោ បរិក្ខីណភវសំយោជនោ សម្មទញ្ញាវិមុត្តោ សោបិ

១ ឱ. ឥទំ បទទ្វយំ ន ទិស្សតិ ។



ពួកវេហប្ផលព្រហ្ម អសញ្ញីសត្វ អាកាសានញ្ចាយតនព្រហ្ម វិញ្ញាណញ្ចាយតនព្រហ្ម អាកិញ្ចញ្ញាយតនព្រហ្ម នេវសញ្ញានាសញ្ញាយតនព្រហ្ម រូបាយតនៈ សទ្ទាយតនៈ មុតៈ វិញ្ញាតៈ របស់ដូចគ្នា របស់ផ្សេងគ្នា វត្ថុទាំងពួង នូវនិព្វាន ថាជានិព្វានពិត លុះដឹងច្បាស់នូវនិព្វាន ថាជានិព្វានពិតហើយ ក៏មិនប្រកាន់នូវនិព្វាន មិនប្រកាន់ក្នុងនិព្វាន មិនប្រកាន់ថាជានិព្វានពិត មិនប្រកាន់ថានិព្វានជារបស់អញ មិនត្រេកអរនឹងនិព្វាន ។ ដំណើរនោះព្រោះហេតុអ្វី ។ ព្រោះភិក្ខុនោះជាវីតទោសបុគ្គល ដ្បិតអស់ទោសៈហើយ ។

ចប់ នយភូមិបរិច្ឆេទ ទី ៦ ដោយអំណាចនៃព្រះខីណាស្រព ។

(៧) ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាជាអរហន្តខីណាស្រព មានព្រហ្មចរិយធម៌ប្រព្រឹត្តគ្រប់គ្រាន់ហើយ មានសោឡសកិច្ច ធ្វើស្រេចហើយ មានភារៈដាក់ចុះហើយ មានប្រយោជន៍របស់ខ្លួនបានសម្រេចតាមលំដាប់ហើយ មានភវសំយោជនៈអស់រលីងហើយ មានចិត្តរួចស្រឡះ ព្រោះដឹងដោយប្រពៃហើយ ភិក្ខុជាអរហន្តខីណាស្រពនោះឯង

បឋវឹ បឋវិតោ អភិជានាតិ បឋវឹ បឋវិតោ អភិញ្ញាយ បឋវឹ ន មញ្ញតិ បឋវិយា ន មញ្ញតិ បឋវិតោ ន មញ្ញតិ បឋវឹ មេតិ ន មញ្ញតិ បឋវឹ នាភិនន្ទតិ ។ តំ កិស្ស ហេតុ ។ ខយា មោហស្ស វីតមោហត្តា ។ បេ ។ អាបំ តេជំ វាយំ ភូតេ ទេវេ បជាបតឹ ព្រហ្មំ អាភស្សរេ សុភកិណ្ហេ វេហប្ផលេ អភិភុំ អាកាសានញ្ចាយតនំ វិញ្ញាណញ្ចាយតនំ អាកិញ្ចញ្ញាយតនំ នេវសញ្ញានាសញ្ញាយតនំ ទិដ្ឋំ សុតំ មុតំ វិញ្ញាតំ ឯកត្តំ នានត្តំ សព្វំ និព្វានំ និព្វានតោ អភិជានាតិ និព្វានំ និព្វានតោ អភិញ្ញាយ និព្វានំ ន មញ្ញតិ និព្វានស្មឹ ន មញ្ញតិ និព្វានតោ ន មញ្ញតិ និព្វានំ មេតិ ន មញ្ញតិ និព្វានំ នាភិនន្ទតិ ។ តំ កិស្ស ហេតុ ។ ខយា មោហស្ស វីតមោហត្តា ។

ខីណាសវវសេន ឆដ្ឋនយភូមិបរិច្ឆេទោ(១) ។

១ ម. តំ បទទ្វយំ ន ទិស្សតិ ។



ដឹងនូវផែនដី ថាជាផែនដីពិត លុះដឹងច្បាស់នូវផែនដី ថាជាផែនដីពិតហើយ ក៏មិនប្រកាន់នូវផែនដី មិនប្រកាន់ក្នុងផែនដី មិនប្រកាន់ថាផែនដីពិត មិនប្រកាន់ថាផែនដីជារបស់អញ មិនត្រេកអរនឹងផែនដី ។ ដំណើរនោះព្រោះហេតុអ្វី ។ ព្រោះភិក្ខុនោះជាវីតមោហបុគ្គល ព្រោះអស់មោហៈហើយ ។ បេ ។ ភិក្ខុជាអរហន្តខីណាស្រពនោះដឹងច្បាស់នូវទឹក ភ្លើង ខ្យល់ ពួកសត្វ ពួកទេវតា មារ ព្រហ្ម ពួកអាភស្សរព្រហ្ម ពួកសុភកិណ្ហព្រហ្ម ពួកវេហប្ផលព្រហ្ម អសញ្ញីសត្វ អាកាសានញ្ចាយតនព្រហ្ម វិញ្ញាណញ្ចាយតនព្រហ្ម អាកិញ្ចញ្ញាយតនព្រហ្ម នេវសញ្ញានាសញ្ញាយតនព្រហ្ម រូបាយតនៈ សទ្ទាយតនៈ មុតៈ វិញ្ញាតៈ របស់ដូចគ្នា របស់ផ្សេងគ្នា និងចំណែកទាំងពួង ដឹងនូវនិព្វាន ថាជានិព្វានពិត លុះដឹងច្បាស់នូវនិព្វាន ថាជានិព្វានពិតហើយ ក៏មិនប្រកាន់នូវនិព្វាន មិនប្រកាន់ក្នុងនិព្វាន មិនប្រកាន់ថានិព្វានពិត មិនប្រកាន់ថានិព្វានជារបស់អញ មិនត្រេកអរនឹងនិព្វាន ។ ដំណើរនោះព្រោះហេតុអ្វី ។ ព្រោះភិក្ខុនោះជាវីតមោហបុគ្គល ព្រោះអស់មោហៈហើយ ។

ចប់ នយភូមិបរិច្ឆេទទី ៦ ដោយអំណាចនៃព្រះខីណាស្រព ។

(៨) តថាគតោបិ ភិក្ខវេ អរហំ សម្មាសម្ពុទ្ធោ បឋវឹ បឋវិតោ អភិជានាតិ បឋវឹ បឋវិតោ អភិញ្ញាយ បឋវឹ ន មញ្ញតិ បឋវិយា ន មញ្ញតិ បឋវិតោ ន មញ្ញតិ បឋវឹមេតិ ន មញ្ញតិ បឋវឹ នាភិនន្ទតិ ។ តំ កិស្ស ហេតុ ។ បរិញ្ញាតន្តំ តថាគតស្សាតិ វទាមិ ។ បេ ។ អាបំ តេជំ វាយំ ភូតេ ទេវេ បជាបតឹ ព្រហ្មំ អាភស្សរេ សុភកិណ្ហេ វេហប្ផលេ អភិភុំ អាកាសានញ្ចាយតនំ វិញ្ញាណញ្ចាយតនំ អាកិញ្ចញ្ញាយតនំ នេវសញ្ញានាសញ្ញាយតនំ ទិដ្ឋំ សុតំ មុតំ វិញ្ញាតំ ឯកត្តំ នានត្តំ សព្វំ និព្វានំ និព្វានតោ អភិជានាតិ និព្វានំ និព្វានតោ អភិញ្ញាយ និព្វានំ ន មញ្ញតិ និព្វានស្មឹ ន មញ្ញតិ និព្វានតោ ន មញ្ញតិ និព្វានំមេតិ ន មញ្ញតិ និព្វានំ នាភិនន្ទតិ ។ តំ កិស្ស ហេតុ ។ បរិញ្ញាតន្តំ តថាគតស្សាតិ វទាមិ ។

សត្ថុវសេន សត្តមនយភូមិបរិច្ឆេទោ[១] ។

១ ម. ឥទំ បទទ្វយំ ន ទិស្សតិ ។



(៨) ម្នាលភិក្ខុទាំងឡាយ ចំណែកព្រះតថាគត អរហន្តសម្មាសម្ពុទ្ធ រមែងជ្រាបច្បាស់នូវផែនដី ថាជាផែនដីពិត លុះជ្រាបច្បាស់នូវផែនដីថាជាផែនដីពិតហើយ ក៏មិនប្រកាន់នូវផែនដី មិនប្រកាន់ក្នុងផែនដី មិនប្រកាន់ថាផែនដីពិត មិនប្រកាន់ថាផែនដីជារបស់អញ មិនត្រេកអរនឹងផែនដី ។ ដំណើរនោះព្រោះហេតុអ្វី ។ តថាគតពោលថា ព្រោះព្រះតថាគតទ្រង់កំណត់នូវដំណើរនៃផែនដីនោះបាន ។ បេ ។ ព្រះតថាគត អរហន្តសម្មាសម្ពុទ្ធ ទ្រង់ជ្រាបច្បាស់នូវទឹក ភ្លើង ខ្យល់ ពួកសត្វ ពួកទេវតា មារ ព្រហ្ម ពួកអាភស្សរព្រហ្ម ពួកសុភកិណ្ហព្រហ្ម ពួកវេហប្ផលព្រហ្ម អសញ្ញីសត្វ អាកាសានញ្ចាយតនព្រហ្ម វិញ្ញាណញ្ចាយតនព្រហ្ម អាកិញ្ចញ្ញាយតនព្រហ្ម នេវសញ្ញានាសញ្ញាយតនព្រហ្ម រូបាយតនៈ សទ្ទាយតនៈ មុតៈ វិញ្ញាតៈ របស់ដូចគ្នា របស់ផ្សេងគ្នា វត្ថុទាំងពួងនិងនិព្វានថាជានិព្វានពិត លុះទ្រង់ជ្រាបនូវនិព្វាន ថាជានិព្វានពិតហើយ ក៏មិនប្រកាន់នូវនិព្វាន មិនប្រកាន់ក្នុងនិព្វាន មិនប្រកាន់ថាជានិព្វានពិត មិនប្រកាន់ថានិព្វានជារបស់អញ មិនត្រេកអរនឹងនិព្វាន ។ ដំណើរនោះព្រោះហេតុអ្វី ។ តថាគតពោលថា ព្រោះព្រះតថាគតទ្រង់កំណត់នូវដំណើរនៃនិព្វានជាដើមនោះបាន ។

ចប់ នយភូមិបរិច្ឆេទទី ៧ ដោយអំណាចនៃព្រះសាស្តា ។

(៩) តថាគតោបិ ភិក្ខវេ អរហំ សម្មាសម្ពុទ្ធោ បឋវឹ បឋវិតោ អភិជានាតិ បឋវឹ បឋវិតោ អភិញ្ញាយ បឋវឹ ន មញ្ញតិ បឋវិយា ន មញ្ញតិ បឋវិតោ ន មញ្ញតិ បឋវឹមេតិ ន មញ្ញតិ បឋវឹ នាភិនន្ទតិ ។ តំ កិស្ស ហេតុ ។ នន្ទិ(១) ទុក្ខស្ស មូលន្តិ ឥតិ វិទិត្វា ភវា ជាតិ ភូតស្ស ជរាមរណន្តិ ។ តស្មាតិហ ភិក្ខវេ តថាគតោ សព្វសោ តណ្ហានំ ខយា វិរាគា និរោធា ចាគា បដិនិស្សគ្គា អនុត្តរំ សម្មាសម្ពោធឹ អភិសម្ពុទ្ធោតិ វទាមិ ។ បេ ។ អាបំ តេជំ វាយំ ភូតេ ទេវេ បជាបតឹ ព្រហ្មំ អាភស្សរេ សុភកិណ្ហេ វេហប្ផលេ អភិភុំ អាកាសានញ្ចាយតនំ វិញ្ញាណញ្ចាយតនំ អាកិញ្ចញ្ញាយតនំ នេវសញ្ញានាសញ្ញាយតនំ ទិដ្ឋំ សុតំ មុតំ

១ ម. នន្ទី ។



(៩) ម្នាលភិក្ខុទាំងឡាយ ព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ ទ្រង់ជ្រាបនូវផែនដី ជាជាផែនដីពិត លុះទ្រង់ជ្រាបនូវផែនដី ជាជាផែនដីពិតហើយ ក៏មិនប្រកាន់នូវផែនដី មិនប្រកាន់ក្នុងផែនដី មិនប្រកាន់ថាជាផែនដីពិត មិនប្រកាន់ថាផែនដីជារបស់អញ មិនត្រេកអរនឹងផែនដី ដំណើរនោះព្រោះហេតុអ្វី ។ ព្រោះព្រះតថាគត ទ្រង់ជ្រាបច្បាស់ថា សេចក្តីត្រេកអរដែលមានហើយ (អំពីមុន) ជាឫសគល់នៃសេចក្តីទុក្ខ ទាំងជ្រាបច្បាស់ថា ជាតិ ជរា មរណៈរបស់សត្វដែលកើតអំពីកម្មភព គឺកុសលាកុសលចេតនា ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ក្នុងសាសនានេះ តថាគតពោលថា ព្រះតថាគត បានត្រាស់ដឹងនូវសម្មាសម្ពោធិញ្ញាណដ៏ប្រសើរ ព្រោះអស់តណ្ហា ព្រោះប្រាសចាកតណ្ហា ព្រោះរលត់តណ្ហា ព្រោះលះបង់នូវតណ្ហា ព្រោះរលាស់ចោលនូវតណ្ហា ដោយប្រការទាំងពួង ។ បេ ។ ព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ ទ្រង់ជ្រាបច្បាស់នូវទឹក ភ្លើង ខ្យល់ ពួកសត្វ ពួកទេវតា មារ ព្រហ្ម ពួកអាភស្សរព្រហ្ម ពួកសុភកិណ្ហព្រហ្ម វេហប្ផលព្រហ្ម អសញ្ញិសត្វ អាកាសានញ្ចាយតនព្រហ្ម វិញ្ញាណញ្ចាយតនព្រហ្ម អាកិញ្ចញ្ញាយតនព្រហ្ម នេវសញ្ញានាសញ្ញាយតនព្រហ្ម រូបាយតនៈ សទ្ទាយតនៈ មុតៈ

វិញ្ញាតំ ឯកត្តំ នានត្តំ សព្វំ និព្វានំ និព្វានតោ អភិជានាតិ និព្វានំ និព្វានតោ អភិញ្ញាយ និព្វានំ ន មញ្ញតិ និព្វានស្មឹ ន មញ្ញតិ និព្វានតោ ន មញ្ញតិ និព្វានម្មេតិ ន មញ្ញតិ និព្វានំ នាភិនន្ទតិ ។ តំ កិស្ស ហេតុ ។ នន្ទិ ទុក្ខស្ស មូលន្តិ ឥតិ វិទិត្វា ភវា ជាតិ ភូតស្ស ជរាមរណន្តិ ។ តស្មា-តិហ ភិក្ខវេ តថាគតោ សព្វសោ តណ្ហានំ ខយា វិរាគា និរោធា ចាគា បដិនិស្សគ្គា អនុត្តរំ សម្មាសម្ពោធឹ អភិសម្ពុទ្ធោតិ វទាមីតិ ។

សត្ថុវសេន អដ្ឋមនយភូមិបរិច្ឆេទោ(១) ។

ឥទមវោច ភគវា ។ អត្តមនា តេ ភិក្ខូ ភគវតោ ភាសិតំ អភិនន្ទុន្តិ ។

មូលបរិយាយសុត្តំ បឋមំ និដ្ឋិតំ(២) ។

១ ម. ឥទំ បទទ្វយំ ន ទិស្សតិ ។ ២ ឱ.ម. មូលបរិយាយសុត្តន្តំ បឋមំ ។



វិញ្ញាតៈ របស់ដូចគ្នា របស់ផ្សេងគ្នា វត្ថុទាំងពួងនឹងនិព្វាន ថាជានិព្វានពិត លុះទ្រង់ជ្រាបច្បាស់នូវនិព្វាន ថាជានិព្វានពិតហើយ ក៏មិនប្រកាន់នូវនិព្វាន មិនប្រកាន់ក្នុងនិព្វាន មិនប្រកាន់ថាជានិព្វានពិត មិនប្រកាន់ថានិព្វានជារបស់អញ មិនត្រេកអរនឹងនិព្វាន ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ព្រោះព្រះតថាគត អរហន្តសម្មាសម្ពុទ្ធ ទ្រង់ជ្រាបច្បាស់ថា សេចក្តីប្រាថ្នាដែលមានហើយ (អំពីមុន) ជាឫសគល់នៃសេចក្តីទុក្ខ ទាំងជ្រាបច្បាស់ថា ជាតិ ជរា មរណៈ របស់សត្វដែលកើតអំពីកម្មភព គឺកុសលាកុសលចេតនា ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ក្នុងសាសនានេះ តថាគតពោលថា ព្រះតថាគតបានត្រាស់ដឹងនូវសម្មាសម្ពោធិញ្ញាណដ៏ប្រសើរ ព្រោះអស់តណ្ហា ព្រោះប្រាសចាកតណ្ហា ព្រោះរលត់តណ្ហា ព្រោះលះបង់នូវតណ្ហា ព្រោះលាស់បង់នូវតណ្ហា ដោយប្រការទាំងពួង ។

ចប់ នយភូមិបរិច្ឆេទទី ៨ ដោយអំណាចនៃព្រះសាស្តា ។

លុះព្រះមានព្រះភាគទ្រង់សំដែងសូត្រនេះចប់ហើយ ភិក្ខុទាំងឡាយនោះក៏គ្មានចិត្តត្រេកអររីករាយ ចំពោះភាសិតនៃព្រះមានព្រះភាគឡើយ ។

ចប់ មូលបរិយាយសូត្រ ទី ១ ។

# ទុតិយំ សព្វាសវសុត្តំ

(១០) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ ភិក្ខវោតិ ។ ភទន្តេតិ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច សព្វាសវសំវរបរិយាយំ វោ ភិក្ខវេ ទេសិស្សាមិ តំ សុណាថ សាធុកំ មនសិករោថ ភាសិស្សាមីតិ ។ ឯវម្ភន្តេតិ ខោ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។

(១១) ភគវា ឯតទវោច ជានតោ អហំ ភិក្ខវេ បស្សតោ អាសវានំ ខយំ វទាមិ នោ អជានតោ នោ អបស្សតោ ។ កិញ្ច[១] ភិក្ខវេ

១ កិញ្ចីតិ កត្ថចិ ហេតូកេ ចស្សុតិ ។

# សព្វាសវសូត្រទី ២

(១០) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ ក្នុងសម័យនោះឯង ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ។ ពួកភិក្ខុទាំងនោះ ទទួលព្រះពុទ្ធដីកានៃព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ដូច្នេះ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែងនូវហេតុ នៃសេចក្តីសង្រួមក្នុងអាសវៈទាំងពួង ដល់អ្នកទាំងឡាយ អ្នកទាំងឡាយចូរប្រុងស្តាប់នូវហេតុនោះ ចូរធ្វើទុកក្នុងចិត្តឲ្យប្រពៃ តថាគតនឹងសំដែង ។ ពួកភិក្ខុទាំងនោះ ទទួលព្រះពុទ្ធដីកា នៃព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។

(១១) ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវការអស់ទៅនៃអាសវធម៌[១] ទាំងឡាយ របស់បុគ្គលអ្នកដឹង អ្នកឃើញ មិនមែនពោលនូវការអស់ទៅ នៃអាសវៈទាំងឡាយ របស់បុគ្គលអ្នកមិនដឹង មិនឃើញទេ ។ ម្នាលភិក្ខុទាំងឡាយ

១ អាសវធម៌ ប្រែថាសភាវៈដែលត្រាំឬហូរទៅអស់ពីភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ និងចិត្ត ហៅថា អាសវៈ ។ ក្នុងអដ្ឋកថា ថា អាសវៈមាន ៣ ក៏មាន មាន ៤ ក៏មាន ដែលមាន ៣ គឺកាមាសវៈ ១ ភវាសវៈ ១ អវិជ្ជាសវៈ ១ ។ ដែលមាន ៤ គឺថែមទិដ្ឋាសវៈចូលមកផង ។

ជានតោ ច បស្សតោ អាសវានំ ខយោ ហោតិ ។ យោនិសោ ច មនសិការំ អយោនិសោ ច មនសិការំ ។ អយោនិសោ ភិក្ខវេ មនសិករោតោ អនុប្បន្នា ចេវ អាសវា ឧប្បជ្ជន្តិ ឧប្បន្នា ច អាសវា បវឌ្ឍន្តិ ។ យោនិសោ ច ភិក្ខវេ មនសិករោតោ អនុប្បន្នា ចេវ អាសវា ន ឧប្បជ្ជន្តិ ឧប្បន្នា ច អាសវា បហីយន្តិ ។ អត្ថិ ភិក្ខវេ អាសវា ទស្សនា បហាតព្វា អត្ថិ អាសវា សំវរា បហាតព្វា អត្ថិ អាសវា បដិសេវនា បហាតព្វា



បុគ្គលដឹងឮ ឃើញឮ ទើបអស់ទៅនៃអាសវធម៌ទាំងឡាយ ។ បុគ្គលឃើញនូវយោនិសោមនសិការ[១] និងអយោនិសោមនសិការ[២] (ទើបអស់ទៅនៃអាសវធម៌ទាំងឡាយ) ។ ម្នាលភិក្ខុទាំងឡាយ កាលបើបុគ្គលធ្វើទុកក្នុងចិត្តដោយខុសទំនង អាសវៈទាំងឡាយ ដែលមិនទាន់កើតឡើង រមែងកើតឡើងផង អាសវៈទាំងឡាយដែលកើតឡើងហើយ រឹតតែចំរើនឡើងផង ។ ម្នាលភិក្ខុទាំងឡាយ កាលបើបុគ្គលធ្វើទុកក្នុងចិត្តដោយត្រូវទំនង អាសវៈទាំងឡាយ ដែលមិនទាន់កើតឡើង រមែងកើតឡើងមិនបានផង អាសវៈទាំងឡាយដែលកើតឡើងហើយ រមែងសាបសូន្យទៅវិញផង ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលត្រូវលះបង់អាសវៈដោយការឃើញគឺសោតាបត្តិមគ្គក៏មាន ត្រូវលះបង់អាសវៈដោយសេចក្តីសង្រួមឥន្ទ្រិយក៏មាន ត្រូវលះបង់អាសវៈដោយការសេពក៏មាន

---

១ ដែលជាយោនិសោមនសិការៈនោះ គឺតាំងចិត្ត ចងចិត្តប្រមូលអារម្មណ៍មកពិចារណាតាមសច្ចានុលោមិកញ្ញាណ ដោយន័យថា សេចក្តីមិនទៀងក្នុងរបស់ដែលមិនទៀង ។ ២ ដែលជាអយោនិសោមនសិការៈនោះ គឺយល់ច្រឡំ សំគាល់ថាទៀងក្នុងរបស់ដែលមិនទៀង ជាសុខក្នុងរបស់ដែលជាទុក្ខ សំគាល់ថាមានខ្លួនក្នុងរបស់ដែលមិនមានខ្លួន សំគាល់ថាស្អាតក្នុងរបស់ដែលមិនស្អាត ។ អដ្ឋកថា ។

អត្ថិ អាសវា អធិវាសនា បហាតព្វា អត្ថិ អាសវា បរិវជ្ជនា បហាតព្វា អត្ថិ អាសវា វិនោទនា បហាតព្វា អត្ថិ អាសវា ភាវនា បហាតព្វា ។

(១៦) កតមេ ច ភិក្ខវេ អាសវា ទស្សនា បហាតព្វា ។ ឥធ ភិក្ខវេ អស្សុតវា បុថុជ្ជនោ អរិយានំ អទស្សាវី អរិយធម្មស្ស អកោវិទោ អរិយធម្មេ អវិនីតោ សប្បុរិសានំ អទស្សាវី សប្បុរិសធម្មស្ស អកោវិទោ សប្បុរិសធម្មេ អវិនីតោ មនសិករណីយេ ធម្មេ នប្បជានាតិ អមនសិករណីយេ ធម្មេ នប្បជានាតិ ។ សោ មនសិករណីយេ ធម្មេ អប្បជានន្តោ អមនសិករណីយេ ធម្មេ អប្បជានន្តោ យេ ធម្មា ន មនសិករណីយា តេ ធម្មេ មនសិករោតិ យេ ធម្មា មនសិករណីយា តេ ធម្មេ ន មនសិករោតិ ។ កតមេ ច ភិក្ខវេ ធម្មា ន មនសិករណីយា យេ ធម្មេ មនសិករោតិ ។ យស្ស ភិក្ខវេ ធម្មេ មនសិករោតោ អនុប្បន្នោ វា កាមាសវោ



ត្រូវលះបង់អាសវៈដោយការអត់ធន់ក៏មាន ត្រូវលះបង់អាសវៈដោយការវៀរក៏មាន ត្រូវលះបង់អាសវៈដោយការបន្ទោបង់ក៏មាន ត្រូវលះបង់អាសវៈដោយការចំរើនក៏មាន ។

(១៦) ម្នាលភិក្ខុទាំងឡាយ អាសវៈដែលភិក្ខុត្រូវលះបង់ដោយការឃើញ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុថុជ្ជនក្នុងសាសនានេះ ជាអ្នកមិនបានចេះដឹង មិនបានឃើញនូវព្រះអរិយៈទាំងឡាយ (មានព្រះពុទ្ធជាដើម) មិនឈ្លាសក្នុងអរិយធម៌ មិនបានទូន្មានខ្លួន ក្នុងអរិយធម៌ មិនបានឃើញនូវសប្បុរសទាំងឡាយ(មានព្រះពុទ្ធជាដើម)មិនឈ្លាសក្នុងសប្បុរិសធម៌ មិនបានទូន្មានខ្លួនក្នុងសប្បុរិសធម៌ រមែងមិនដឹងច្បាស់ក្នុងធម៌ដែលគួរធ្វើទុកក្នុងចិត្ត មិនដឹងច្បាស់ក្នុងធម៌ដែលមិនគួរធ្វើទុកក្នុងចិត្ត ។ កាលបើបុថុជ្ជននោះ មិនដឹងច្បាស់នូវធម៌ដែលគួរធ្វើទុកក្នុងចិត្ត មិនដឹងច្បាស់នូវធម៌ដែលមិនគួរធ្វើទុកក្នុងចិត្ត ធម៌ណាដែលមិនគួរធ្វើទុកក្នុងចិត្ត ក៏ត្រឡប់ជាធ្វើទុកក្នុងចិត្តនូវធម៌ទាំងនោះវិញ ធម៌ណាដែលគួរធ្វើទុកក្នុងចិត្ត ក៏ត្រឡប់ជាមិនធ្វើទុកក្នុងចិត្តនូវធម៌ទាំងនោះវិញ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយដូចម្តេច ដែលមិនគួរធ្វើទុកក្នុងចិត្ត តែបុថុជ្ជនធ្វើទុកក្នុងចិត្ត ។ ម្នាលភិក្ខុទាំងឡាយ កាលបើបុថុជ្ជនធ្វើទុកក្នុងចិត្តនូវធម៌ គឺអយោនិសោមនសិការៈណាហើយ កាមាសវៈដែលមិនទាន់កើតឡើង

ឧប្បជ្ជតិ ឧប្បន្នោ វា កាមាសវោ បវឌ្ឍតិ អនុប្បន្នោ វា ភវាសវោ ឧប្បជ្ជតិ ឧប្បន្នោ វា ភវាសវោ បវឌ្ឍតិ អនុប្បន្នោ វា អវិជ្ជាសវោ ឧប្បជ្ជតិ ឧប្បន្នោ វា អវិជ្ជាសវោ បវឌ្ឍតិ ឥមេ ធម្មា ន មនសិករណីយា យេ ធម្មេ មនសិករោតិ ។ កតមេ ច ភិក្ខវេ ធម្មា មនសិករណីយា យេ ធម្មេ ន មនសិករោតិ ។ យស្ស ភិក្ខវេ ធម្មេ មនសិករោតោ អនុប្បន្នោ វា កាមាសវោ ន ឧប្បជ្ជតិ ឧប្បន្នោ វា កាមាសវោ បហីយតិ អនុប្បន្នោ វា ភវាសវោ ន ឧប្បជ្ជតិ ឧប្បន្នោ វា ភវាសវោ បហីយតិ អនុប្បន្នោ វា អវិជ្ជាសវោ ន ឧប្បជ្ជតិ ឧប្បន្នោ វា អវិជ្ជាសវោ បហីយតិ ឥមេ ធម្មា មនសិករណីយា យេ ធម្មេ ន មនសិករោតិ ។ តស្ស អមនសិករណីយានំ ធម្មានំ មនសិការា



រមែងកើតឡើងផង កាមាសវៈដែលកើតឡើងហើយ ក៏រឹងរឹតតែចំរើនឡើងផង ភវាសវៈដែលមិនទាន់កើតឡើង រមែងកើតឡើងផង ភវាសវៈដែលកើតឡើងហើយ ក៏រឹងរឹតតែចំរើនឡើងផង អវិជ្ជាសវៈដែលមិនទាន់កើតឡើង រមែងកើតឡើងផង អវិជ្ជាសវៈដែលកើតឡើងហើយ ក៏រឹងរឹតចំរើនឡើងផង ធម៌ទាំងនេះឯង ដែលមិនគួរធ្វើទុកក្នុងចិត្ត តែបុថុជ្ជនតែងធ្វើទុកក្នុងចិត្ត ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយដូចម្តេច ដែលគួរធ្វើទុកក្នុងចិត្ត តែបុថុជ្ជនមិនបានធ្វើទុកក្នុងចិត្ត ។ ម្នាលភិក្ខុទាំងឡាយ កាលបុថុជ្ជនធ្វើទុកក្នុងចិត្តនូវធម៌គឺយោនិសោមនសិការៈណាហើយ កាមាសវៈដែលមិនទាន់កើតឡើង ក៏រមែងកើតឡើងមិនបានផង កាមាសវៈដែលកើតឡើងហើយ រមែងសាបសូន្យទៅវិញផង ភវាសវៈដែលមិនទាន់កើតឡើងរមែងកើតឡើងមិនបានផង ភវាសវៈដែលកើតឡើងហើយរមែងសាបសូន្យទៅវិញផង អវិជ្ជាសវៈដែលមិនទាន់កើតឡើង រមែងកើតឡើងមិនបានផង អវិជ្ជាសវៈដែលកើតឡើងហើយ រមែងសាបសូន្យទៅវិញផង ធម៌ទាំងនេះឯង ដែលគួរធ្វើទុកក្នុងចិត្ត តែបុថុជ្ជនតែងមិនបានធ្វើទុកក្នុងចិត្ត ។ ព្រោះតែបុថុជ្ជននោះធ្វើទុកក្នុងចិត្តនូវធម៌ដែលមិនគួរធ្វើទុកក្នុងចិត្ត

មនសិការណីយានំ ធម្មានំ អមនសិការា អនុប្បន្នា ចេវ អាសវា ឧប្បជ្ជន្តិ ឧប្បន្នា ច អាសវា បវឌ្ឍន្តិ ។ សោ ឯវំ អយោនិសោ មនសិករោតិ អហោសឹ នុ ខោ អហំ អតីតមទ្ធានំ ន នុ ខោ អហោសឹ អតីតមទ្ធានំ កឹ នុ ខោ អហោសឹ អតីតមទ្ធានំ កថំ នុ ខោ អហោសឹ អតីតមទ្ធានំ កឹ ហុត្វា កឹ អហោសឹ នុ ខោ អហំ អតីតមទ្ធានំ ភវិស្សាមិ នុ ខោ អហំ អនាគតមទ្ធានំ ន នុ ខោ ភវិស្សាមិ អនាគតមទ្ធានំ កឹ នុ ខោ ភវិស្សាមិ អនាគតមទ្ធានំ កថំ នុ ខោ ភវិស្សាមិ អនាគតមទ្ធានំ កឹ ហុត្វា កឹ ភវិស្សាមិ នុ ខោ អហំ អនាគតមទ្ធានន្តិ ឯតរហិ វា បច្ចុប្បន្នមទ្ធានំ អជ្ឈត្តំ កថំកថី ហោតិ អហំ នុ[១] ខោស្មិ នោ នុ ខោស្មិ កឹ នុ ខោស្មិ កថំ នុ ខោស្មិ អយំ នុ ខោ សត្តោ កុតោ អាគតោ សោ

១ ឱ. អហន្នុ ។



មិនធ្វើទុកក្នុងចិត្តនូវធម៌ដែលគួរធ្វើទុកក្នុងចិត្ត (យ៉ាងនេះហើយ) ព្រោះជា អាសវៈទាំងឡាយដែលមិនទាន់កើតឡើង ក៏កើតឡើងផង អាសវៈទាំងឡាយដែលកើតឡើងហើយ ក៏នឹងតែចំរើនឡើង ៗ បុថុជ្ជននោះធ្វើទុកក្នុងចិត្តដោយខុសចំនងយ៉ាងនេះថា អំពីអតីតកាល អាត្មាអញបានកើតដែរឬ ។ អំពីអតីតកាល អាត្មាអញ មិនបានកើតទេ (មួយយ៉ាងទៀត) អំពីអតីតកាល អាត្មាអញមានជាតិជាអ្វី ឬអំពីអតីតកាល អាត្មាអញមានសណ្ឋានទ្រង់ទ្រាយដូចម្ដេច អំពីអតីតកាល អាត្មាអញកើតជាជាតិអ្វី ឬមួយអាត្មាអញមានសណ្ឋានទ្រង់ទ្រាយដូចម្ដេច ក្នុងអនាគតកាល អាត្មាអញនឹងកើតទៀតដែរឬ ។ ក្នុងអនាគតកាល អាត្មាអញនឹងមិនកើតទៀតទេ (មួយយ៉ាងទៀត) ក្នុងអនាគតកាល អាត្មាអញនឹងកើតជាជាតិអ្វី ឬក្នុងអនាគតកាល អាត្មាអញនឹងមានសណ្ឋានទ្រង់ទ្រាយដូចម្ដេច ក្នុងអនាគតកាល អាត្មាអញនឹងមានជាតិជាអ្វី ឬមានសណ្ឋានទ្រង់ទ្រាយដូចម្ដេច (មួយយ៉ាងទៀត) បុថុជ្ជននោះ ប្រារព្ធនូវបច្ចុប្បន្នកាល ក្នុងកាលឥឡូវនេះ ហើយមានសេចក្ដីសង្ស័យក្នុងខ្លួនថា ឥឡូវនេះ អាត្មាអញមានឬមិនមានទេ ឬឥឡូវនេះ អាត្មាអញមានជាតិជាអ្វី មានសណ្ឋានទ្រង់ទ្រាយដូចម្ដេច សត្វនេះមកអំពីណាហ្ន៎ សត្វនោះនឹងទៅ

កុហិំ គាមី ភវិស្សតីតិ ។ តស្ស ឯវំ អយោនិសោ
មនសិករោតោ ឆន្នំ ទិដ្ឋីនំ អញ្ញតរា ទិដ្ឋិ
ឧប្បជ្ជតិ ។ អត្ថិ មេ អត្តាតិ វា អស្ស សច្ចតោ
ថេតតោ ទិដ្ឋិ ឧប្បជ្ជតិ ។ នត្ថិ មេ អត្តាតិ
វា អស្ស សច្ចតោ ថេតតោ ទិដ្ឋិ ឧប្បជ្ជតិ ។ អត្តនា
វ អត្តានំ សញ្ជានាមីតិ វា អស្ស សច្ចតោ ថេតតោ
ទិដ្ឋិ ឧប្បជ្ជតិ ។ អត្តនា វ អនត្តានំ សញ្ជានាមីតិ
វា អស្ស សច្ចតោ ថេតតោ ទិដ្ឋិ ឧប្បជ្ជតិ ។ អនត្តនា
វ អត្តានំ សញ្ជានាមីតិ វា អស្ស សច្ចតោ ថេតតោ
ទិដ្ឋិ ឧប្បជ្ជតិ ។ អថ វា បនស្ស ឯវំ ទិដ្ឋិ ហោតិ
យោ មេ អយំ អត្តា វទោ វេទេយ្យោ តត្រ តត្រ
កល្យាណបាបកានំ កម្មានំ វិបាកំ បដិសំវេទេតិ
សោ ខោ បន មេ អយំ អត្តា និច្ចោ ធុវោ សស្សតោ



កាន់ទីណាវិញហ្ន៎ ។ កាលបុថុជ្ជននោះធ្វើទុកក្នុងចិត្តដោយខុសទំនងយ៉ាង
នេះហើយ បណ្ដាទិដ្ឋិទាំង ៦ ទិដ្ឋិណាមួយ គង់កើតឡើងបាន ។
ទិដ្ឋិកើតឡើងដល់បុថុជ្ជននោះ ព្រោះប្រកាន់សេចក្ដីទៀងទាត់ ថិត
ថេរថា ខ្លួនរបស់អាត្មាអញមាន ១ ។ ទិដ្ឋិកើតឡើងដល់បុថុជ្ជននោះ
ព្រោះប្រកាន់សេចក្ដីទៀងទាត់ ថិតថេរថា ខ្លួនរបស់អាត្មាអញ
មិនមាន ១ ។ ទិដ្ឋិកើតឡើងដល់បុថុជ្ជននោះ ព្រោះប្រកាន់សេច_
ក្ដីទៀងទាត់ ស្ថិតថេរថា អាត្មាអញដឹងច្បាស់នូវខ្លួនដោយសភាវៈថា
ជាខ្លួនពិត(១) ១ ។ ទិដ្ឋិកើតឡើងដល់បុថុជ្ជននោះព្រោះប្រកាន់សេចក្ដី
ទៀងទាត់ ថិតថេរថា អាត្មាអញដឹងច្បាស់នូវសភាវៈមិនមែនខ្លួន
ដោយសភាវៈថាជាខ្លួនពិត(២) ១ ។ ទិដ្ឋិកើតឡើងដល់បុថុជ្ជននោះ
ព្រោះប្រកាន់សេចក្ដីទៀងទាត់ ថិតថេរថា អាត្មាអញដឹងច្បាស់នូវ
ខ្លួនឯង ដោយសភាវៈថា មិនមែនខ្លួនពិត(៣) ១ ។ ពុំនោះសោត បុថុជ្ជន
នោះ មានសេចក្ដីយល់ឃើញយ៉ាងនេះថា ខ្លួនរបស់អាត្មាអញដែលប្រែ
ទទួល រមែងទទួលនូវផលកម្មល្អនិងអាក្រក់ក្នុងកំណើតនោះៗ តែ
ខ្លួនរបស់អាត្មាអញនោះ ជាសភាវៈទៀងទាត់ប្រាកដ ថិតថេរ

---

១ សំគាល់ខន្ធទាំង ៥ ជាជាខ្លួន លើកសញ្ញាខន្ធជាធំ ។ ២ សំគាល់សញ្ញាខន្ធ ១ ជាជាខ្លួន ឯខន្ធ ៤ មិនមែនជាខ្លួន ។ ៣ សំគាល់សញ្ញាខន្ធ ១ ជាមិនមែនខ្លួន ឯខន្ធទាំង ៤ ជាជាខ្លួន ។ អដ្ឋកថា ។

អវិបរិណាមធម្មោ សស្សតិសមំ តថេវ ឋស្សតីតិ ។ ឥទំ វុច្ចតិ ភិក្ខវេ ទិដ្ឋិគតំ ទិដ្ឋិគហនំ ទិដ្ឋិកន្តារំ(១) ទិដ្ឋិវិសូកំ ទិដ្ឋិវិប្ផន្ទិតំ ទិដ្ឋិសំយោជនំ ។ ទិដ្ឋិសំយោជនសំយុត្តោ ភិក្ខវេ អស្សុតវា បុថុជ្ជនោ ន បរិមុច្ចតិ ជាតិយា ជរាយ មរណេន សោកេហិ បរិទេវេហិ ទុក្ខេហិ ទោមនស្សេហិ ឧបាយាសេហិ[២] ន បរិមុច្ចតិ ទុក្ខស្មាតិ វទាមិ ។ សុតវា ច ខោ ភិក្ខវេ អរិយសាវកោ អរិយានំ ទស្សាវី អរិយធម្មស្ស កោវិទោ អរិយធម្មេ សុវិនីតោ សប្បុរិសានំ ទស្សាវី សប្បុរិសធម្មស្ស កោវិទោ សប្បុរិសធម្មេ សុវិនីតោ មនសិករណីយេ ធម្មេ បជានាតិ អមនសិករណីយេ ធម្មេ បជានាតិ ។ សោ មនសិករណីយេ ធម្មេ បជានន្តោ អមនសិករណីយេ ធម្មេ បជានន្តោ យេ ធម្មា ន មនសិករណីយា តេ ធម្មេ ន មនសិករោតិ ។ យេ ធម្មា មនសិករណីយា

---

១ ទិដ្ឋិកន្តារន្តិ កត្ថចិ បោត្ថកេ ទិស្សតិ ។ ២ ឱ.ម. សោកេហិ បរិទេវេហិ ទុក្ខេហិ ទោមនស្សេហិ ឧបាយាសេហិ ។



ជាសភាវៈមិនប្រែប្រួល ការនៅអស់ដូចជាសស្សតភាព (ព្រះអាទិត្យនិងព្រះចន្ទជាដើម) ដូច្នោះឯង ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ដំណើរនៃទិដ្ឋិ ព្រៃស្បាតគឺទិដ្ឋិ ផ្លូវឆ្ងាយដាច់ស្រយាលគឺទិដ្ឋិ ចំរូងគឺទិដ្ឋិ សេចក្តីញាប់ញ័រគឺទិដ្ឋិ ចំណងគឺទិដ្ឋិ ។ ម្នាលភិក្ខុទាំងឡាយ បុថុជ្ជនដែលជាប់ដោយចំណងគឺទិដ្ឋិ ជាអ្នកមិនចេះដឹង តថាគតហៅថាជាអ្នកមិនបានរួចស្រឡះចាក ជាតិទុក្ខ ជរាទុក្ខ មរណទុក្ខ សោកទុក្ខ បរិទេវទុក្ខ ទុក្ខទុក្ខ ទោមនស្សទុក្ខ និងឧបាយាសទុក្ខ ទាំងមិនរួចចាកទុក្ខ (ក្នុងវដ្ដៈទាំងអស់) ។ ម្នាលភិក្ខុទាំងឡាយ ឯអរិយសាវ័កដែលជាអ្នកបានចេះដឹង បានឃើញនូវព្រះអរិយៈទាំងឡាយ មានព្រះពុទ្ធជាដើម ឈ្លាសក្នុងអរិយធម៌ បានទូន្មានខ្លួនល្អក្នុងអរិយធម៌ បានឃើញនូវសប្បុរសទាំងឡាយ មានព្រះពុទ្ធជាដើម ឈ្លាសក្នុងសប្បុរិសធម៌ បានទូន្មានខ្លួនល្អក្នុងសប្បុរិសធម៌ រមែងដឹងច្បាស់នូវធម៌ដែលគួរធ្វើទុកក្នុងចិត្ត ដឹងច្បាស់នូវធម៌ដែលមិនគួរធ្វើទុកក្នុងចិត្ត ។ កាលអរិយសាវ័កនោះដឹងច្បាស់នូវធម៌ដែលគួរធ្វើទុកក្នុងចិត្ត ដឹងច្បាស់នូវធម៌ដែលមិនគួរធ្វើទុកក្នុងចិត្តហើយ ធម៌ទាំងឡាយណាដែលមិនគួរធ្វើទុកក្នុងចិត្ត ក៏មិនធ្វើទុកក្នុងចិត្តនូវធម៌ទាំងនោះឡើយ ។ ធម៌ទាំងឡាយណា ដែលគួរធ្វើទុក

តេ ធម្មេ មនសិករោតិ ។ កតមេ ច ភិក្ខវេ ធម្មា ន មនសិករណីយា យេ ធម្មេ ន មន-សិករោតិ ។ យស្ស ភិក្ខវេ ធម្មេ មនសិករោតោ អនុប្បន្នោ វា កាមាសវោ ឧប្បជ្ជតិ ឧប្បន្នោ វា កាមាសវោ បវឌ្ឍតិ អនុប្បន្នោ វា ភវាសវោ ឧប្បជ្ជតិ ឧប្បន្នោ វា ភវាសវោ បវឌ្ឍតិ អនុប្បន្នោ វា អវិជ្ជាសវោ ឧប្បជ្ជតិ ឧប្បន្នោ វា អវិជ្ជាសវោ បវឌ្ឍតិ ឥមេ ធម្មា ន មនសិករណីយា យេ ធម្មេ ន មនសិករោតិ ។ កតមេ ច ភិក្ខវេ ធម្មា មនសិករណីយា យេ ធម្មេ មនសិករោតិ ។ យស្ស ភិក្ខវេ ធម្មេ មនសិករោតោ អនុប្ប-ន្នោ វា កាមាសវោ ន ឧប្បជ្ជតិ ឧប្បន្នោ វា កាមាសវោ បហីយតិ អនុប្បន្នោ វា ភវាសវោ ន ឧប្បជ្ជតិ ឧប្បន្នោ វា ភវាសវោ



ទុកក្នុងចិត្ត គឺធ្វើទុកក្នុងចិត្តនូវធម៌ទាំងនោះ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយដូចម្ដេច ដែលមិនគួរធ្វើទុកក្នុងចិត្ត ហើយអរិយសាវ័កមិនធ្វើទុកក្នុងចិត្ត ។ ម្នាលភិក្ខុទាំងឡាយ កាលអរិយសាវ័កធ្វើទុកក្នុងចិត្តនូវធម៌ គឺអយោនិសោមនសិការៈហើយ កាមាសវៈដែលមិនទាន់កើតឡើង រមែងកើតឡើងផង កាមាសវៈដែលកើតឡើងហើយ ក៏រឹតតែចំរើនឡើងផង ភវាសវៈដែលមិនទាន់កើតឡើង រមែងកើតឡើងផង ភវាសវៈដែលកើតឡើងហើយ ក៏រឹតតែចំរើនឡើងផង អវិជ្ជាសវៈដែលមិនទាន់កើតឡើង រមែងកើតឡើងផង អវិជ្ជាសវៈដែលកើតឡើងហើយ ក៏រឹតតែចំរើនឡើងផង ធម៌ទាំងនេះឯងដែលមិនគួរធ្វើទុកក្នុងចិត្ត ហើយអរិយសាវ័កមិនធ្វើទុកក្នុងចិត្ត ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយដូចម្ដេច ដែលគួរធ្វើទុកក្នុងចិត្ត ហើយអរិយសាវ័កធ្វើទុកក្នុងចិត្ត ។ ម្នាលភិក្ខុទាំងឡាយ កាលអរិយសាវ័ក ធ្វើទុកក្នុងចិត្តនូវធម៌ គឺយោនិសោមនសិការៈហើយ កាមាសវៈដែលមិនទាន់កើតឡើង រមែងកើតឡើងមិនបានផង កាមាសវៈដែលកើតឡើងហើយ រមែងសាបសូន្យទៅវិញផង ភវាសវៈដែលមិនទាន់កើតឡើង រមែងកើតឡើងមិនបានផង ភវាសវៈដែលកើតឡើងហើយ

បហិយ្យតិ អនុប្បន្នោ វា អវិជ្ជាសវោ ន ឧប្បជ្ជតិ ឧប្បន្នោ វា អវិជ្ជាសវោ បហិយ្យតិ ឥមេ ធម្មា មនសិការណីយា យេ ធម្មេ មនសិករោតិ ។ តស្ស អមនសិការណីយានំ ធម្មានំ អមនសិការា មនសិការណីយានំ ធម្មានំ មនសិការា អនុប្បន្នា ចេវ អាសវា ន ឧប្បជ្ជន្តិ ឧប្បន្នា ច អាសវា បហិយ្យន្តិ ។ សោ ឥទំ ទុក្ខន្តិ យោនិសោ មនសិករោតិ អយំ ទុក្ខសមុទយោតិ យោនិសោ មនសិករោតិ អយំ ទុក្ខនិរោធោតិ យោនិសោ មនសិករោតិ អយំ ទុក្ខនិរោធគាមិនី បដិបទាតិ យោនិសោ មនសិករោតិ ។ តស្ស ឯវំ យោនិសោ(១) មនសិករោតោ តីណិ សំយោជនានិ បហិយ្យន្តិ សក្កាយទិដ្ឋិ វិចិកិច្ឆា សីលព្វតបរាមាសោ ។ ឥមេ វុច្ចន្តិ ភិក្ខវេ អាសវា ទស្សនា បហាតព្វា ។

១ ម. យោនិសោតិ ន ទិស្សតិ ។



រមែងសាបសូន្យទៅវិញផង អវិជ្ជាសវៈដែលមិនទាន់កើតឡើង រមែងកើតឡើងមិនបានផង អវិជ្ជាសវៈដែលកើតឡើងហើយ រមែងសាបសូន្យទៅវិញផង ធម៌ទាំងនេះឯងដែលគួរធ្វើទុកក្នុងចិត្ត ហើយអរិយសាវ័កធ្វើទុកក្នុងចិត្ត ។ ព្រោះតែអរិយសាវ័កនោះ មិនធ្វើទុកក្នុងចិត្តនូវធម៌ដែលមិនគួរធ្វើទុកក្នុងចិត្ត ធ្វើទុកក្នុងចិត្តនូវធម៌ដែលគួរធ្វើទុកក្នុងចិត្ត (យ៉ាងនេះហើយ) បានជាអាសវៈទាំងឡាយដែលមិនទាន់កើតឡើង ក៏កើតឡើងមិនបានផង អាសវៈទាំងឡាយដែលកើតឡើងហើយ រមែងសាបសូន្យទៅវិញផង ។ អរិយសាវ័កនោះធ្វើទុកក្នុងចិត្តដោយឧបាយថា នេះទុក្ខ ធ្វើទុកក្នុងចិត្តដោយឧបាយថា នេះតណ្ហា ជាដែនឲ្យកើតនូវទុក្ខ ធ្វើទុកក្នុងចិត្តដោយឧបាយថា នេះនិព្វានធម៌ ជាទីរលត់នូវកងទុក្ខ ធ្វើទុកក្នុងចិត្តដោយឧបាយថា នេះសេចក្ដីប្រតិបត្តិ ដើម្បីដល់នូវព្រះនិព្វានជាទីរលត់នូវកងទុក្ខ ។ កាលអរិយសាវ័កនោះ ធ្វើទុកក្នុងចិត្តដោយឧបាយយ៉ាងនេះហើយ សំយោជនៈទាំងឡាយ ៣ គឺ សក្កាយទិដ្ឋិ វិចិកិច្ឆា និងសីលព្វតបរាមាស ក៏សាបសូន្យទៅ ។ ម្នាលភិក្ខុទាំងឡាយ អាសវៈទាំងនេះឯងដែលតថាគតពោលថាត្រូវលះដោយការឃើញ គឺសោតាបត្តិមគ្គ ។

(១៣) កតមេ ច ភិក្ខវេ អាសវា សំវរា បហាតព្វា ។ ឥធ ភិក្ខវេ ភិក្ខុ បដិសង្ខា យោនិសោ ចក្ខុន្ទ្រិយសំវរសំវុតោ វិហរតិ ។ យញ្ហិស្ស ភិក្ខវេ ចក្ខុន្ទ្រិយសំវរំ អសំវុតស្ស វិហរតោ ឧប្បជ្ជេយ្យុំ អាសវា វិឃាតបរិឡាហា ចក្ខុន្ទ្រិយសំវរំ សំវុតស្ស វិហរតោ ឯវំស តេ អាសវា វិឃាតបរិឡាហា ន ហោន្តិ ។ បដិសង្ខា យោនិសោ សោតិន្ទ្រិយសំវរសំវុតោ វិហរតិ ។ បេ ។ បដិសង្ខា យោនិសោ ឃានិន្ទ្រិយសំវរសំវុតោ វិហរតិ ។ បេ ។ បដិសង្ខា យោនិសោ ជិវ្ហិន្ទ្រិយសំវរសំវុតោ វិហរតិ ។ បេ ។ បដិសង្ខា យោនិសោ កាយិន្ទ្រិយសំវរសំវុតោ វិហរតិ ។ បេ ។ បដិសង្ខា យោនិសោ មនិន្ទ្រិយសំវរសំវុតោ វិហរតិ ។ យញ្ហិស្ស ភិក្ខវេ មនិន្ទ្រិយសំវរំ អសំវុតស្ស វិហរតោ ឧប្បជ្ជេយ្យុំ អាសវា វិឃាតបរិឡាហា មនិន្ទ្រិយសំវរំ សំវុតស្ស វិហរតោ ឯវំស តេ អាសវា វិឃាតបរិឡាហា



(១៣) ម្នាលភិក្ខុទាំងឡាយ អាសវៈទាំងឡាយដូចម្តេច ដែលបុគ្គលត្រូវលះបង់ដោយការសង្រួម ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពិចារណាដោយឧបាយហើយ សង្រួមដោយការសង្រួមនូវចក្ខុន្ទ្រិយគ្រប់ឥរិយាបថទាំង៤ ។ ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុនោះមិនសង្រួមចក្ខុន្ទ្រិយសំវរៈ អាសវៈទាំងឡាយដែលជាគ្រឿងចង្អៀតចង្អល់ ក្តៅក្រហាយណាគប្បីកើតឡើងបាន តែកាលបើភិក្ខុនោះសង្រួមចក្ខុន្ទ្រិយសំវរៈយ៉ាងនេះវិញ អាសវៈទាំងឡាយដែលជាគ្រឿងចង្អៀតចង្អល់ក្តៅក្រហាយនោះរមែងមិនមានឡើយ ។ ភិក្ខុពិចារណាដោយឧបាយហើយ សង្រួមសោតិន្ទ្រិយសំវរៈគ្រប់ឥរិយាបថទាំង៤ ។ បេ ។ ពិចារណាដោយឧបាយហើយ សង្រួមនូវឃានិន្ទ្រិយសំវរៈគ្រប់ឥរិយាបថទាំង៤ ។ បេ ។ ពិចារណាដោយឧបាយហើយ សង្រួមនូវជិវ្ហិន្ទ្រិយសំវរៈគ្រប់ឥរិយាបថទាំង៤ ។ បេ ។ ពិចារណាដោយឧបាយហើយ សង្រួមនូវកាយិន្ទ្រិយសំវរៈគ្រប់ឥរិយាបថទាំង៤ ។ បេ ។ ពិចារណាដោយឧបាយហើយ សង្រួមនូវមនិន្ទ្រិយសំវរៈគ្រប់ឥរិយាបថទាំង៤ ។ ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុនោះមិនសង្រួមនូវមនិន្ទ្រិយសំវរៈ អាសវៈទាំងឡាយដែលជាគ្រឿងចង្អៀតចង្អល់ក្តៅក្រហាយណាគប្បីកើតឡើងបាន តែកាលបើភិក្ខុនោះសង្រួមនូវមនិន្ទ្រិយសំវរៈយ៉ាងនេះវិញ អាសវៈទាំងឡាយដែលជាគ្រឿងចង្អៀតចង្អល់ ក្តៅក្រហាយនោះ

ន ហោន្តិ ។ យញ្ហិស្ស ភិក្ខវេ សំវរំ អសំវុតស្ស វិហរតោ ឧប្បជ្ជេយ្យុំ អាសវា វិឃាតបរិឡាហា សំវរំ សំវុតស្ស វិហរតោ ឯវំស តេ អាសវា វិឃាតបរិឡាហា ន ហោន្តិ ។ ឥមេ វុច្ចន្តិ ភិក្ខវេ អាសវា សំវរា បហាតព្វា ។

(១៤) កតមេ ច ភិក្ខវេ អាសវា បដិសេវនា បហាតព្វា ។ ឥធ ភិក្ខវេ ភិក្ខុ បដិសង្ខា យោនិសោ ចីវរំ បដិសេវតិ យាវទេវ សីតស្ស បដិឃាតាយ ឧណ្ហស្ស បដិឃាតាយ ឌំសមកសវាតាតបសិរីសបសម្ផស្សានំ បដិឃាតាយ យាវទេវ ហិរិកោបិនបដិច្ឆាទនត្ថំ ។ បដិសង្ខា យោនិសោ បិណ្ឌបាតំ បដិសេវតិ នេវ ទវាយ ន មទាយ ន មណ្ឌនាយ ន វិភូសនាយ យាវទេវ ឥមស្ស កាយស្ស ឋិតិយា យាបនាយ



រមែងមិនមានឡើយ ។ ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុនោះ មិនសង្រួមនូវសំវរៈ អាសវៈទាំងឡាយ ដែលជាគ្រឿងចង្អៀតចង្អល់ក្តៅក្រហាយណា គប្បីកើតឡើងបាន កាលបើភិក្ខុនោះសង្រួម សំវរៈយ៉ាងនេះវិញ អាសវៈទាំងឡាយដែលជាគ្រឿងចង្អៀតចង្អល់ក្តៅក្រហាយនោះ រមែងមិនមានឡើយ ។ ម្នាលភិក្ខុទាំងឡាយ អាសវៈទាំងនេះ ដែលតថាគតពោលថាត្រូវលះបង់ដោយការសង្រួម ។

(១៤) ម្នាលភិក្ខុទាំងឡាយ អាសវៈទាំងឡាយដូចម្តេចដែល បុគ្គលត្រូវលះបង់ដោយការសេព ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពិចារណាដោយឧបាយហើយ អាស្រ័យសេព គឺប្រើប្រាស់នូវសំពត់ចីវរ គ្រាន់តែដើម្បីការពារនូវត្រជាក់ ដើម្បីការពារនូវកំដៅ ដើម្បីការពារនូវសម្ផស្ស រោម មូស ខ្យល់ កំដៅថ្ងៃនឹងពស់តូច ពស់ធំទាំងឡាយ គ្រាន់តែដើម្បីបិទបាំងនូវអវយវៈ ដែលធ្វើនូវសេចក្តីខ្មាស់ឲ្យកម្រើក ។ ពិចារណាដោយឧបាយហើយ អាស្រ័យសេព គឺបរិភោគនូវចង្ហាន់បិណ្ឌបាតដើម្បីលេងដូចក្មេងអ្នកស្រុកក៏ទេ ដើម្បីឲ្យកើតបុរិសមានៈស្រវឹងដូចអ្នកប្រដាល់ក៏ទេ ដើម្បីប្រដាប់តាក់តែងកាយដូចស្រីក្នុងបុរីក៏ទេ ដើម្បីធ្វើឲ្យផូរផង់ពណ៌សម្បុរដូចអ្នករាំក៏ទេ បរិភោគគ្រាន់តែដើម្បីឲ្យតាំងនៅនៃកាយនេះ ដើម្បីញ៉ាំងជីវិតិន្ទ្រិយឲ្យប្រព្រឹត្តទៅ

វិហឹសូបរតិយា ព្រហ្មចរិយានុគ្គហាយ ឥតិ បុរាណញ្ច វេទនំ បដិហង្ខាមិ នវញ្ច វេទនំ ន ឧប្បាទេស្សាមិ យាត្រា ច មេ ភវិស្សតិ អនវជ្ជតា ច ផាសុវិហារោ ចាតិ[១] ។ បដិសង្ខា យោនិសោ សេនាសនំ បដិសេវតិ យាវទេវ សីតស្ស បដិឃាតាយ ឧណ្ហស្ស បដិឃាតាយ ឌំសមកសវាតាតបសិរឹសបសម្ផស្សានំ បដិឃាតាយ យាវទេវ ឧតុបរិស្សយវិនោទនំ បដិសល្លានារាមត្ថំ[២] ។ បដិសង្ខា យោនិសោ គិលានប្បច្ចយភេសជ្ជបរិក្ខារំ បដិសេវតិ យាវទេវ ឧប្បន្នានំ វេយ្យាពាធិកានំ វេទនានំ បដិឃាតាយ អព្យាបជ្ឈបរមតាយ[៣] ។ យញ្ហិស្ស ភិក្ខវេ

១ ម. ច ។ ២ ឱ. បដិសល្លាណារាមត្ថំ ។ ៣ អព្យាបជ្ឈបរមតាយាតិ កត្ថចិ បោត្ថកេ ទិស្សតិ ។



ដើម្បីបំបាត់បង់នូវសេចក្តីលំបាក ដើម្បីអនុគ្រោះដល់ព្រហ្មចរិយធម៌ អាត្មាអញនឹងកំចាត់បង់នូវវេទនាចាស់ គឺសេចក្តីស្រេកឃ្លានដែលមានហើយផង មិនញុំាងវេទនាថ្មីគឺការផ្អកហួសប្រមាណ មិនឲ្យកើតឡើងបានផង កិរិយាប្រព្រឹត្តទៅនៃអរិយាបថទាំង៤ក្តី សេចក្តីមិនមានទោស គឺការមិនប្រមូលកាយ មិនប្រមូលចិត្តជាដើមក្តី កិរិយានៅសប្បាយក្នុងអរិយាបថទាំង៤ក្តី នឹងមានដល់អាត្មាអញ ដោយហេតុបរិភោគនូវចង្ហាន់បិណ្ឌបាតនេះ ។ ពិចារណាដោយឧបាយហើយ អាស្រ័យសេព គឺប្រើប្រាស់នូវសេនាសនៈ គ្រាន់តែដើម្បីការពារនូវត្រជាក់ ដើម្បីការពារនូវកំដៅ ដើម្បីការពារនូវសម្ផស្ស របោម មូសខ្យល់ កំដៅថ្ងៃ និងពស់តូចពស់ធំទាំងឡាយ គ្រាន់តែដើម្បីបន្ទោបង់នូវក្រវល់ក្រវាយ ដែលកើតអំពីរដូវ ហើយអភិរម្យសម្ងំនៅក្នុងព្រះកម្មដ្ឋាន ។ ពិចារណាដោយឧបាយហើយ អាស្រ័យសេពគឺបរិភោគនូវគ្រឿងបរិក្ខារជាទីរក្សានូវជីវិត គឺថ្នាំជាបច្ច័យដល់អ្នកជម្ងឺ គ្រាន់តែដើម្បីការពារនូវវេទនាទាំងឡាយ ដែលបៀតបៀនផ្សេងៗ ដែលកើតឡើងហើយ ដើម្បីប្រាសចាកទុក្ខទាំងជាធម្មតា ។ ម្នាលភិក្ខុទាំងឡាយ

អប្បដិសេវតោ ឧប្បជ្ជេយ្យុំ អាសវា វិឃាតបរិឡាហា បដិសេវតោ ឯវំស តេ អាសវា វិឃាតបរិឡាហា ន ហោន្តិ ។ ឥមេ វុច្ចន្តិ ភិក្ខវេ អាសវា បដិសេវនា បហាតព្វា ។

(១៤) កតមេ ច ភិក្ខវេ អាសវា អធិវាសនា បហាតព្វា ។ ឥធ ភិក្ខវេ ភិក្ខុ បដិសង្ខា យោនិសោ ខមោ ហោតិ សីតស្ស ឧណ្ហស្ស ជិឃច្ឆាយ បិបា- សាយ ឌំសមកសវាតាតបសិរឹសបសម្ផស្សានំ ទុរុត្តានំ ទុរាគតានំ វចនបថានំ ឧប្បន្នានំ សារីរិកានំ វេទនានំ ទុក្ខានំ តិព្វានំ(១) ខរានំ កដុកានំ អសាតានំ អមនាបានំ បាណហរានំ អធិវាសិកជាតិកោ(២) ហោតិ ។ យញ្ហិស្ស ភិក្ខវេ អនធិវាសយតោ ឧប្បជ្ជេយ្យុំ អាសវា វិឃាតបរិឡាហា អធិវាសយតោ

១ ម. តិប្បានំ ។ ២ អធិវាសកជាតិកោ ។



កាលភិក្ខុនោះមិនអាស្រ័យសេព នូវបច្ច័យណាមួយដោយឧបាយ អាស- វៈទាំងឡាយដែលជាគ្រឿងចង្អៀតចង្អល់ ក្តៅក្រហាយណា គប្បីកើតឡើងបាន តែកាលបើភិក្ខុនោះអាស្រ័យសេព នូវបច្ច័យណាមួយដោយឧបាយ យ៉ាងនេះវិញ អាសវៈទាំងឡាយដែលជាគ្រឿងចង្អៀតចង្អល់ ក្តៅក្រហាយនោះ រមែងមិនមានឡើយ ។ ម្នាលភិក្ខុទាំងឡាយ អាសវៈទាំងនេះឯង ដែលតថាគតពោលថាត្រូវលះបង់ដោយការសេព ។

(១៤) ម្នាលភិក្ខុទាំងឡាយ អាសវៈទាំងឡាយដូចម្តេច ដែលបុគ្គលត្រូវលះបង់ដោយការអត់ធន់ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះពិចារណាដោយឧបាយហើយ អត់ធន់ ចំពោះត្រជាក់ ក្តៅ ឃ្លាន ស្រេកជាអ្នកអត់ទ្រាំនូវសម្ផស្ស របោម មូស ខ្យល់ កំដៅថ្ងៃ និងពស់- តូច ពស់ធំទាំងឡាយ និងនូវពាក្យ ដែលគេពោលហើយមិនពីរោះស្រួលគោះ នូវទុក្ខវេទនាដែលកើតឡើង ប្រព្រឹត្តទៅក្នុងសរីរកាយដ៏ក្លា ក្រក់ ក្រោលផ្សា មិនជាទីត្រេកអរ មិនជាទីគាប់ចិត្ត និងនាំឲ្យរួចជីវិត ។ ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុនោះមិនអត់ទ្រាំនូវហេតុណាមួយហើយ អា- សវៈទាំងឡាយដែលជាគ្រឿងចង្អៀតចង្អល់ក្តៅក្រហាយ គប្បីកើតឡើងបាន តែកាលបើភិក្ខុនោះអត់ធន់ទ្រាំនូវហេតុណាមួយបានយ៉ាងនេះវិញ

វំស តេ អាសវា វិឃាតបរិឡាហា ន ហោន្តិ ។ ឥមេ វុច្ចន្តិ ភិក្ខវេ អាសវា អធិវាសនា បហាតព្វា ។

(១៦) កតមេ ច ភិក្ខវេ អាសវា បរិវជ្ជនា បហាតព្វា ។ ឥធ ភិក្ខវេ ភិក្ខុ បដិសង្ខា យោនិសោ ចណ្ឌំ ហត្ថឹ បរិវជ្ជេតិ ចណ្ឌំ អស្សំ បរិវជ្ជេតិ ចណ្ឌំ គោណំ បរិវជ្ជេតិ ចណ្ឌំ កុក្កុរំ បរិវជ្ជេតិ អហឹ ខាណុំ កណ្ដកដ្ឋានំ សោព្ភំ បបាតំ ចន្ទនិកំ ឱឡិគល្លំ ។ យថារូបេ អនាសនេ និសិន្នំ យថារូបេ អគោចរេ ចរន្តំ យថារូបេ បាបកេ មិត្តេ ភជន្តំ វិញ្ញូ សព្រហ្មចារី បាបកេសុ ឋានេសុ ឱកប្បេយ្យុំ ។ សោ តញ្ច អនាសនំ តញ្ច អគោចរំ តេ ច បាបកេ មិត្តេ បដិសង្ខា យោនិសោ បរិវជ្ជេតិ ។ យញ្ហិស្ស ភិក្ខវេ អបរិវជ្ជយតោ ឧប្បជ្ជេយ្យុំ អាសវា វិឃាតបរិឡាហា



អាសវៈទាំងឡាយដែលជាគ្រឿងចង្អៀតចង្អល់ក្ដៅក្រហាយនោះ រមែងមិនមានឡើយ ។ ម្នាលភិក្ខុទាំងឡាយ អាសវៈទាំងនេះឯងដែលគប្បីគេពោលថាត្រូវលះបង់ដោយការអត់ធន់ ។

(១៦) ម្នាលភិក្ខុទាំងឡាយ អាសវៈទាំងឡាយដូចម្ដេចដែលបុគ្គលត្រូវលះបង់ដោយការវៀរ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះពិចារណាដោយឧបាយហើយ វៀរនូវដំរីកាច វៀរសេះកាច វៀរគោកាច វៀរឆ្កែកាច វៀរសត្វពស់ ដង្គត់ឈើ ចម្រូងបន្លា អណ្ដូង ជ្រោះ រណ្ដៅទឹកស្អុយ ទីប្រឡាយទឹកស្អុយ ។ មួយវិញទៀត ភិក្ខុអង្គុយលើអាសនៈ មិនសមគួរមានសភាពយ៉ាងណា ត្រាច់ទៅក្នុងទីមិនគួរមានសភាពយ៉ាងណា សេពគប់នូវបាបមិត្រមានសភាពយ៉ាងណា ពួកសព្រហ្មចារីភិក្ខុ ជាអ្នកប្រាជ្ញ គប្បីជឿ (ថាភិក្ខុនោះជាអ្នកប្រព្រឹត្តទៅ) ក្នុងទីដ៏លាមកទាំងឡាយ ។ ភិក្ខុនោះពិចារណាដោយឧបាយហើយ វៀរនូវអាសនៈដែលមិនសមគួរនោះផង នូវទីគោចរដែលមិនសមគួរនោះផង នូវពួកបាបមិត្រនោះផង ។ ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុនោះ មិនវៀរនូវហេតុដែលគួរវៀរណាមួយ អាសវៈទាំងឡាយដែលជាគ្រឿងចង្អៀតចង្អល់ ក្ដៅក្រហាយ គប្បីកើតឡើងបាន

បរិវជ្ជយតោ ឯវំស តេ អាសវា វិឃាតបរិឡាហា ន ហោន្តិ ។ ឥមេ វុច្ចន្តិ ភិក្ខវេ អាសវា បរិវជ្ជនា បហាតព្វា ។

(១៧) កតមេ ច ភិក្ខវេ អាសវា វិនោទនា បហាតព្វា ។ ឥធ ភិក្ខវេ ភិក្ខុ បដិសង្ខា យោនិសោ ឧប្បន្នំ កាមវិតក្កំ នាធិវាសេតិ បជហតិ វិនោទេតិ ព្យន្តីករោតិ[១] អនភាវំ គមេតិ ឧប្បន្នំ ព្យាបាទវិតក្កំ ។ បេ ។ ឧប្បន្នំ វិហឹសាវិតក្កំ ។ បេ ។ ឧប្បន្នុប្បន្នេ បាបកេ អកុសលេ ធម្មេ នាធិវាសេតិ បជហតិ វិនោទេតិ ព្យន្តីករោតិ[២] អនភាវំ គមេតិ ។ យញ្ហិស្ស ភិក្ខវេ អវិនោទយតោ ឧប្បជ្ជេយ្យុំ អាសវា វិឃាតបរិឡាហា វិនោទយតោ ឯវំស តេ អាសវា វិឃាតបរិឡាហា ន ហោន្តិ ។ ឥមេ វុច្ចន្តិ ភិក្ខវេ អាសវា វិនោទនា បហាតព្វា ។

១-២ ឱ. ព្យន្តិករោតិ ។ ម. ព្យន្តីករោតិ ។



តែកាលបើភិក្ខុនោះវៀរនូវហេតុដែលគួរវៀរណាមួយយ៉ាងនេះវិញ អាសវៈទាំងឡាយដែលជាគ្រឿងចង្អៀតចង្អល់ ក្តៅក្រហាយនោះ រមែងមិនមានឡើយ ។ ម្នាលភិក្ខុទាំងឡាយ អាសវៈទាំងនេះឯង ដែលតថាគតពោលថាត្រូវលះបង់ដោយការវៀរ ។

(១៧) ម្នាលភិក្ខុទាំងឡាយ អាសវៈទាំងឡាយដូចម្តេច ដែលបុគ្គលត្រូវលះបង់ដោយការបន្ទោបង់ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពិចារណាដោយឧបាយហើយ អត់ធន់ លះបង់ បន្ទោបង់ ធ្វើឲ្យវិនាស បំផ្លាញ នូវកាមវិតក្កៈដែលកើតឡើងហើយ នូវព្យាបាទវិតក្កៈដែលកើតឡើងហើយ ។ បេ ។ នូវវិហឹសាវិតក្កៈដែលកើតឡើងហើយ ។ បេ ។ អត់ធន់ លះបង់ បន្ទោបង់ ធ្វើឲ្យវិនាស បំផ្លាញនូវពួកអកុសលធម៌ដ៏លាមកដែលកើតឡើងហើយ ។ ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុនោះមិនបន្ទោបង់នូវវិតក្កៈណាមួយហើយ អាសវៈទាំងឡាយដែលជាគ្រឿងចង្អៀតចង្អល់ក្តៅក្រហាយ គប្បីកើតឡើងបាន តែកាលបើភិក្ខុនោះបន្ទោបង់នូវវិតក្កៈណាមួយយ៉ាងនេះវិញ អាសវៈទាំងឡាយ ដែលជាគ្រឿងចង្អៀតចង្អល់ក្តៅក្រហាយនោះរមែងមិនមានឡើយ ។ ម្នាលភិក្ខុទាំងឡាយ អាសវៈទាំងនេះឯងដែលតថាគតពោលថា ត្រូវលះបង់ដោយការបន្ទោបង់ ។

(១៨) កតមេ ច ភិក្ខវេ អាសវា ភាវនា បហាតព្វា ។ ឥធ ភិក្ខវេ ភិក្ខុ បដិសង្ខា យោនិសោ សតិសម្ពោជ្ឈង្គំ ភាវេតិ វិវេកនិស្សិតំ វិរាគនិស្សិតំ និរោធនិស្សិតំ វោស្សគ្គបរិណាមឹ[១] បដិសង្ខា យោនិសោ ធម្មវិចយសម្ពោជ្ឈង្គំ ភាវេតិ ។ បេ ។ វីរិយសម្ពោជ្ឈង្គំ ភាវេតិ ។ បេ ។ បីតិសម្ពោជ្ឈង្គំ ភាវេតិ ។ បេ ។ បស្សទ្ធិសម្ពោជ្ឈង្គំ ភាវេតិ ។ បេ ។ សមាធិសម្ពោជ្ឈង្គំ ភាវេតិ ។ បេ ។ ឧបេក្ខាសម្ពោជ្ឈង្គំ ភាវេតិ វិវេកនិស្សិតំ វិរាគនិស្សិតំ និរោធនិស្សិតំ វោស្សគ្គបរិណាមឹ[២] ។ យញ្ហិស្ស ភិក្ខវេ អភាវយតោ ឧប្បជ្ជេយ្យុំ អាសវា វិឃាតបរិឡាហា

១-២ ម. វោស្សគ្គបរិណាមំ ។



(១៨) ម្នាលភិក្ខុទាំងឡាយ អាសវៈទាំងឡាយដូចម្តេច ដែលបុគ្គលត្រូវលះបង់ដោយការចំរើន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពិចារណាដោយឧបាយហើយ ចំរើននូវសតិសម្ពោជ្ឈង្គ ដែលអាស្រ័យនូវសេចក្តីស្ងប់ស្ងាត់[១] ដែលអាស្រ័យនូវធម៌ជាគ្រឿងប្រាសចាករាគៈ ដែលអាស្រ័យ នូវធម៌ជាទីរលត់ទុក្ខ ដែលជាធម៌បង្អោនទៅដើម្បីលះកិលេស ពិចារណាដោយឧបាយហើយ ទើបចំរើននូវធម្មវិចយសម្ពោជ្ឈង្គ ។ បេ ។ ចំរើននូវវីរិយសម្ពោជ្ឈង្គ ។ បេ ។ ចំរើននូវបីតិសម្ពោជ្ឈង្គ ។ បេ ។ ចំរើននូវបស្សទ្ធិសម្ពោជ្ឈង្គ ។ បេ ។ ចំរើននូវសមាធិសម្ពោជ្ឈង្គ ។ បេ ។ ចំរើននូវឧបេក្ខាសម្ពោជ្ឈង្គ ដែលអាស្រ័យនូវសេចក្តីស្ងប់ស្ងាត់ ដែលអាស្រ័យនូវធម៌ ជាគ្រឿងប្រាសចាករាគៈ ដែលអាស្រ័យនូវធម៌ជាទីរលត់ទុក្ខ ដែលជាធម៌បង្អោនទៅដើម្បីលះកិលេស ។ ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុនោះមិនចំរើននូវសម្ពោជ្ឈង្គណាមួយហើយ អាសវៈទាំងឡាយដែលជាគ្រឿងចង្អៀតចង្អល់ ក្តៅក្រហាយ គប្បីកើតឡើងបាន

១ ការស្ងប់ស្ងាត់មាន ៥ ប្រការ មានតទង្គវិវេកជាដើម អធិប្បាយនូវឧបហាន ៥ ប្រការ ក្នុងមូលបរិយាយសូត្រនោះហើយ ( ទំព័រលេខ ១ ) ។

ភាវយតោ ឯវំស តេ អាសវា វិឃាតបរិឡាហា ន ហោន្តិ ។ ឥមេ វុច្ចន្តិ ភិក្ខវេ អាសវា ភាវនា បហាតព្វា ។

(១៩) យតោ ច[1] ខោ ភិក្ខវេ ភិក្ខុនោ យេ អាសវា ទស្សនា បហាតព្វា តេ ទស្សនា បហីនា ហោន្តិ ។ យេ អាសវា សំវរា បហាតព្វា តេ សំវរា បហីនា ហោន្តិ ។ យេ អាសវា បដិសេវនា បហាតព្វា តេ បដិសេវនា បហីនា ហោន្តិ ។ យេ អាសវា អធិវាសនា បហាតព្វា តេ អធិវាសនា បហីនា ហោន្តិ ។ យេ អាសវា បរិវជ្ជនា បហាតព្វា តេ

១ ម.ម. ច សទ្ទោ ន ទិស្សតិ ។



តែកាលបើភិក្ខុនោះចំរើនពោជ្ឈង្គណាមួយយ៉ាងនេះហើយ អាសវៈទាំងឡាយដែលជាគ្រឿងចង្អៀតចង្អល់ ក្តៅក្រហាយនោះ រមែងមិនមានឡើយ ។ ម្នាលភិក្ខុទាំងឡាយ អាសវៈទាំងឡាយនេះឯង ដែលតថាគតពោលថាត្រូវលះបង់ដោយការចំរើន ។

(១៩) ម្នាលភិក្ខុទាំងឡាយ វេលាណាដែលភិក្ខុត្រូវលះបង់អាសវៈទាំងឡាយណា ដោយការឃើញគឺសោតាបត្តិមគ្គ អាសវៈទាំងនោះ ក៏ឈ្មោះថាភិក្ខុបានលះបង់ដោយការឃើញហើយ ។ អាសវៈទាំងឡាយណា ដែលភិក្ខុត្រូវលះបង់ដោយការសង្រួម អាសវៈទាំងនោះ ក៏ឈ្មោះថាភិក្ខុបានលះបង់ដោយការសង្រួមហើយ ។ អាសវៈទាំងឡាយណា ដែលភិក្ខុត្រូវលះបង់ដោយការសេព (នូវបច្ច័យ) អាសវៈទាំងនោះ ក៏ឈ្មោះថាភិក្ខុបានលះបង់ដោយការសេពហើយ ។ អាសវៈទាំងឡាយណា ដែលភិក្ខុត្រូវលះបង់ដោយការអត់ធន់ (នូវត្រជាក់ និងក្តៅជាដើម) អាសវៈទាំងនោះ ក៏ឈ្មោះថាភិក្ខុបានលះបង់ដោយការអត់ធន់ហើយ ។ អាសវៈទាំងឡាយណា ដែលភិក្ខុត្រូវលះបង់ដោយការវៀរ (ចាកវត្ថុមិនសមគួរជាដើម) អាសវៈទាំងនោះ

បរិវជ្ជនា បហីនា ហោន្តិ ។ យេ អាសវា វិនោទនា បហាតព្វា តេ វិនោទនា បហីនា ហោន្តិ ។ យេ អាសវា ភាវនា បហាតព្វា តេ ភាវនា បហីនា ហោន្តិ ។ អយំ វុច្ចតិ ភិក្ខវេ ភិក្ខុ សព្វាសវសំវរសំវុតោ វិហរតិ អច្ឆេច្ឆិ តណ្ហំ វិវត្តយិ សំយោជនំ[១] សម្មាមានាភិសមយា អន្តមកាសិ ទុក្ខស្សាតិ ។ ឥទមវោច ភគវា អត្តមនា តេ ភិក្ខូ ភគវតោ ភាសិតំ អភិនន្ទុន្តិ ។

សព្វាសវសំវរសុត្តំ ទុតិយំ[២] និដ្ឋិតំ ។

---

១ ម. វិវត្តយិ សំយោជនំ ។ ២ ម. សព្វាសវសំវរសុត្តំ ទុតិយំ ។ ម. សព្វាសវសុត្តំ ទុតិយំ ។



ក៏ឈ្មោះថាភិក្ខុបានលះបង់ដោយការវៀរហើយ ។ អាសវៈទាំងឡាយណា ដែលភិក្ខុត្រូវលះបង់ដោយការបន្ទោបង់ (នូវកាមវិតក្កៈជាដើម) អាសវៈទាំងនោះ ក៏ឈ្មោះថាភិក្ខុបានលះបង់ដោយការបន្ទោបង់ហើយ ។ អាសវៈទាំងឡាយណា ដែលភិក្ខុត្រូវលះបង់ដោយការចំរើន (សម្ពោជ្ឈង្គទាំង៧) អាសវៈទាំងនោះ ក៏ឈ្មោះថាភិក្ខុបានលះបង់ ដោយការចំរើនហើយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះតថាគតហៅថាជាអ្នកសង្រួមដោយការសង្រួម ក្នុងអាសវៈទាំងអស់ ហើយជាអ្នកផ្តាច់ផ្តិលនូវតណ្ហា ញុំាងសំយោជនៈ ឲ្យប្រែប្រួលគឺធ្វើមិនឲ្យមានមន្ទិល ធ្វើនូវទីបំផុតនៃទុក្ខ ដោយហេតុដែលបានលះបង់ នូវមានះដោយប្រពៃ ។ លុះព្រះមានព្រះភាគ ទ្រង់បានសំដែងសូត្រនេះចប់ហើយ ភិក្ខុទាំងឡាយនោះ ក៏មានចិត្តត្រេកអររីករាយ ចំពោះភាសិតនៃព្រះមានព្រះភាគ ។

ចប់ សព្វាសវសំវរសូត្រ ទី ២ ។

## តតិយំ ធម្មទាយាទសុត្តំ

(២០) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារា- មេ ។ តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ ភិក្ខវោ- តិ ។ ភទន្តេតិ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។

(២១) ភគវា ឯតទវោច ធម្មទាយាទា មេ ភិក្ខវេ ភវថ មា អាមិសទាយាទា អត្ថិ មេ តុម្ហេសុ អនុកម្បា កិន្តិ មេ សាវកា ធម្មទាយាទា ភវេយ្យុំ

## ធម្មទាយាទសូត្រ ទី ៣

(២០) ខ្ញុំបានស្ដាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ ក្នុងសម័យនោះឯង ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះ ទទួលព្រះពុទ្ធដីកាព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។

(២១) ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរយកធម៌[១] របស់តថាគតជាមត៌ក កុំយកអាមិស[២]ជាមត៌កឡើយ តថាគតមានសេចក្ដីអនុគ្រោះចំពោះអ្នកទាំងឡាយដូច្នេះថា ធ្វើម្ដេចហ្ន៎ ពួកសាវ័ករបស់តថាគត គួរយកធម៌ជាមត៌ក

---

១ ធម៌ជាមត៌កនេះ បានដល់ធម៌ ២ យ៉ាងគឺ និប្បរិយាយធម៌ ធម៌ជាចំណែកខាងលោកុត្តរ–ធម៌ទាំង ៩ មានសោតាបត្តិមគ្គជាដើម ១ បរិយាយធម៌ ធម៌ជាចំណែកខាងរបស់បុគ្គលដែលកំពុងប្រព្រឹត្តធ្វើនូវសីល–សមាធិ–បញ្ញា ឬឈានសមាបត្តិ ដើម្បីដល់នូវព្រះនិព្វាន ១ ។

២ អាមិសជាមត៌ក បានដល់អាមិស ២ យ៉ាងគឺ និប្បរិយាយាមិស បានដល់បច្ច័យទាំង ៤ មានចីវរប្បច្ច័យជាដើម ១ បរិយាយាមិស បានដល់ទានដ៏សេស មានអន្នទានជាដើម ១ ។ អដ្ឋកថា ។

នោ អាមិសទាយាទាតិ ។ តុម្ហេ ច មេ ភិក្ខវេ អាមិសទាយាទា ភវេយ្យាថ នោ ធម្មទាយាទា តុម្ហេបិ តេន អាទិស្សា[១] ភវេយ្យាថ អាមិសទាយាទា សត្ថុសាវកា វិហរន្តិ នោ ធម្មទាយាទាតិ ។ អហម្បិ តេន អាទិស្សោ[២] ភវេយ្យំ អាមិសទាយាទា សត្ថុសាវកា វិហរន្តិ នោ ធម្មទាយាទាតិ ។ តុម្ហេ ច មេ ភិក្ខវេ ធម្មទាយាទា ភវេយ្យាថ នោ អាមិសទាយាទា តុម្ហេបិ តេន ន អាទិស្សា ភវេយ្យាថ ធម្មទាយាទា សត្ថុសាវកា វិហរន្តិ នោ អាមិសទាយាទាតិ ។ អហម្បិ តេន ន អាទិស្សោ ភវេយ្យំ ធម្មទាយាទា សត្ថុសាវកា វិហរន្តិ នោ អាមិសទាយាទាតិ ។ តស្មាតិហ មេ ភិក្ខវេ ធម្មទាយាទា ភវថ មា អាមិសទាយាទា ។ អត្ថិ មេ តុម្ហេសុ អនុកម្បា កិន្តិ មេ សាវកា ធម្មទាយាទា ភវេយ្យុំ នោ អាមិសទាយាទាតិ ។

---

១ ម. អាទិយា ។ ២ ម. អាទិយោ ។



កុំយកអាមិសជាមត៌កឡើយ ។ ម្នាលភិក្ខុទាំងឡាយ បើអ្នកទាំងឡាយ យកអាមិសជាមត៌ក មិនយកធម៌របស់តថាគតជាមត៌កហើយ គង់មាន អ្នកដទៃតិះដៀលអ្នកទាំងឡាយ ដោយហេតុនោះថា ពួកសាវ័ករបស់ ព្រះសាស្ដា សុទ្ធតែយកអាមិសជាមត៌ក មិនយកធម៌ជាមត៌កទេ ។ ទាំង តថាគតក៏ត្រូវអ្នកដទៃតិះដៀលដោយហេតុនោះថា ពួកសាវ័ករបស់ព្រះ សាស្ដា សុទ្ធតែយកអាមិសជាមត៌ក មិនយកធម៌ជាមត៌កឡើយ ។ ម្នាលភិក្ខុទាំងឡាយ បើអ្នកទាំងឡាយយកធម៌របស់តថាគតជាមត៌ក មិន យកអាមិសជាមត៌កទេ ក៏គ្មានអ្នកដទៃតិះដៀលអ្នកទាំងឡាយដោយ ហេតុនោះថា ពួកសាវ័ករបស់ព្រះសាស្ដាសុទ្ធតែយកធម៌ជាមត៌ក មិន មែនយកអាមិសជាមត៌កទេ ។ ទាំងតថាគតក៏គ្មានអ្នកដទៃតិះដៀល ដោយហេតុនោះថា ពួកសាវ័ករបស់ព្រះសាស្ដា សុទ្ធតែយកធម៌ជា មត៌ក មិនមែនយកអាមិសជាមត៌កទេ ។ ម្នាលភិក្ខុទាំងឡាយ ព្រោះ ហេតុនោះ ក្នុងកាលឥឡូវនេះ អ្នកទាំងឡាយចូរយកធម៌របស់តថាគត ជាមត៌ក កុំយកអាមិសជាមត៌កឡើយ តថាគតមានសេចក្ដីអនុគ្រោះចំពោះ អ្នកទាំងឡាយថា ធ្វើម្ដេចហ្ន៎ ពួកសាវ័ករបស់តថាគត គួរយកធម៌ជា មត៌ក កុំយកអាមិសជាមត៌កឡើយ ។

(២២) ឥធាហំ ភិក្ខវេ ភុត្តាវី អស្សំ បវារិតោ បរិបុណ្ណោ បរិយោសិតោ សុហិតោ យាវទត្ថោ សិយា ច មេ បិណ្ឌបាតោ អតិរេកធម្មោ ឆឌ្ឌិយធម្មោ ។ អថ ទ្វេ ភិក្ខូ អាគច្ឆេយ្យុំ ជិឃច្ឆាទុព្វល្យបរេតា ត្យាហំ ឯវំ វទេយ្យំ អហំ ខោម្ហិ ភិក្ខវេ ភុត្តាវី បវារិតោ បរិបុណ្ណោ បរិយោសិតោ សុហិតោ យាវទត្ថោ អត្ថិ ច មេ អយំ បិណ្ឌបាតោ អតិរេកធម្មោ ឆឌ្ឌិយធម្មោ សចេ អាកង្ខថ ភុញ្ជថ សចេ តុម្ហេ ន ភុញ្ជិស្សថ ឥទានាហំ អប្បហរិតេ វា ឆឌ្ឌេស្សាមិ អប្បាណកេ វា ឧទកេ ឱបិលាបេស្សាមីតិ ។ តត្រេកស្ស(១) ភិក្ខុនោ ឯវមស្ស ភគវា ខោ ភុត្តាវី បវារិតោ បរិបុណ្ណោ បរិយោសិតោ សុហិតោ យាវទត្ថោ អត្ថិ ចាយំ ភគវតោ បិណ្ឌបាតោ អតិរេកធម្មោ ឆឌ្ឌិយធម្មោ សចេ មយំ ន ភុញ្ជិស្សាម ឥទានិ ភគវា

១ ម. តត្រេកស្ស ។



[២២] ម្នាលភិក្ខុទាំងឡាយ ក្នុងទីនេះ តថាគតបរិភោគស្រេច ឃាត់លែងទទួលទៀត គ្រប់គ្រាន់បរិបូណ៌ ឆ្អែតស្កប់ស្កល់ គួរតាមប្រមាណហើយ ឯបិណ្ឌបាតរបស់តថាគតនៅសល់ច្រើន ជារបស់គួរចាក់ចោលជាធម្មតា ។ គ្រានោះ មានភិក្ខុពីររូបមកដល់ កំពុងមានសេចក្ដីស្រេកឃ្លានគ្របសង្កត់ជាខ្លាំង តថាគតក៏ពោលទៅនឹងភិក្ខុទាំងពីររូបនោះ យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ តថាគតបរិភោគស្រេច ឃាត់លែងទទួលទៀត គ្រប់គ្រាន់បរិបូណ៌ ឆ្អែតស្កប់ស្កល់ គួរតាមប្រមាណហើយ ឯបិណ្ឌបាតរបស់តថាគតនេះ នៅសល់ច្រើន ជារបស់គួរចាក់ចោលជាធម្មតា បើអ្នកទាំងឡាយចង់ឆាន់ចូរឆាន់ចុះ បើអ្នកទាំងឡាយមិនឆាន់ទេ តថាគតនឹងចាក់ចោល ក្នុងទីដែលគ្មានស្មៅស្រស់ ឬនឹងចាក់ចោលក្នុងទឹកដែលគ្មានសត្វ ឥឡូវនេះ ។ បណ្ដាភិក្ខុទាំងពីររូបនោះ ភិក្ខុ១រូបគិតថា ព្រះមានព្រះភាគទ្រង់សោយស្រេច ឃាត់លែងទទួលទៀត គ្រប់គ្រាន់បរិបូណ៌ ឆ្អែតស្កប់ស្កល់ គួរតាមប្រមាណហើយ បិណ្ឌបាតនេះរបស់ព្រះមានព្រះភាគ នៅសល់ច្រើន ជារបស់គួរចាក់ចោលជាធម្មតា បើពួកយើងនឹងមិនឆាន់ ព្រះមានព្រះភាគនឹង

អប្បហរិតេ វា ឆឌ្ឌេស្សតិ អប្បាណកេ វា ឧទកេ ឱបិលាបេស្សតិ វុត្តំ ខោ បនេតំ ភគវតា ធម្មទាយាទា មេ ភិក្ខវេ ភវថ មា អាមិសទាយាទាតិ អាមិសញ្ញតរំ ខោ បនេតំ យទិទំ បិណ្ឌបាតោ យន្នូនាហំ ឥមំ បិណ្ឌបាតំ អភុញ្ជិត្វា ឥមិនា វ[១] ជិឃច្ឆាទុព្ពល្យេន[២] ឯវំ ឥមំ រត្តិន្ទិវំ វីតិនាមេយ្យន្តិ ។ សោ តំ បិណ្ឌបាតំ អភុញ្ជិត្វា តេនេវ ជិឃច្ឆាទុព្ពល្យេន[៣] ឯវំ តំ រត្តិន្ទិវំ វីតិនាមេយ្យ ។ អថ ទុតិយស្ស ភិក្ខុនោ ឯវមស្ស ភគវា ខោ ភុត្តាវី បវារិតោ បរិបុណ្ណោ បរិយោសិតោ សុហិតោ យាវទត្ថោ អត្ថិ ចាយំ ភគវតោ បិណ្ឌបាតោ អតិរេកធម្មោ ឆឌ្ឌិយធម្មោ សចេ មយំ ន ភុញ្ជិស្សាម ឥទានិ ភគវា អប្បហរិតេ វា ឆឌ្ឌេស្សតិ អប្បាណកេ វា ឧទកេ ឱបិលាបេស្សតិ យន្នូនាហំ ឥមំ បិណ្ឌបាតំ ភុញ្ជិត្វា ជិឃច្ឆាទុព្ពល្យំ បដិវិនោទេត្វា[៤] ឯវំ ឥមំ រត្តិន្ទិវំ វីតិនាមេយ្យន្តិ ។ សោ តំ បិណ្ឌបាតំ ភុញ្ជិត្វា

១ ឱ. ម. សេវេ ឥត្ថិ ។ ២-៣ ឱ. ជិឃច្ឆាទុព្ពល្យេន ។ ៤ ឱ. បដិវិនេត្វា ។



ចាក់ចោលឥឡូវនេះ ក្នុងទីដែលគ្មានស្មៅស្រស់ ឬនឹងចាក់ចោលក្នុងទឹកដែលគ្មានសត្វ នេះជាព្រះពុទ្ធដីកា ដែលព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរយកធម៌របស់តថាគតជាមត៌ក កុំយកអាមិសជាមត៌កឡើយ ឯបិណ្ឌបាតនេះក៏ជាអាមិសមួយដែរ បើដូច្នោះមានតែអាត្មាអញកុំបរិភោគបិណ្ឌបាតនេះឡើយ ពឹងទ្រាំអត់សេចក្តីស្រេកឃ្លាននេះ ឲ្យអស់មួយយប់មួយថ្ងៃចុះ ។ ភិក្ខុនោះ ក៏មិនឆាន់បិណ្ឌបាតនោះឡើយ ហើយទ្រាំអត់សេចក្តីស្រេកឃ្លាននោះអស់មួយយប់មួយថ្ងៃយ៉ាងនេះ ។ គ្រានោះ ភិក្ខុទី២ គិតយ៉ាងនេះថា ព្រះមានព្រះភាគ ទ្រង់សោយស្រេច ឃាត់លែងទទួលទៀត គ្រប់គ្រាន់ បរិបូណ៌ ឆ្អែតស្កប់ស្កល់ គួរតាមប្រមាណហើយ ឯបិណ្ឌបាតនេះ របស់ព្រះមានព្រះភាគ ក៏នៅសល់ច្រើន ជារបស់គួរចាក់ចោលជាធម្មតា បើពួកយើងមិនឆាន់ទេ ព្រះមានព្រះភាគនឹងទ្រង់ចាក់ចោលឥឡូវនេះ ក្នុងទីដែលគ្មានស្មៅស្រស់ ឬនឹងចាក់ចោលក្នុងទឹកដែលគ្មានសត្វ បើដូច្នោះមានតែអាត្មាអញ គួរឆាន់ចង្ហាន់បិណ្ឌបាតនេះ ឲ្យបាត់សេចក្តីស្រេកឃ្លាន ទើបបានប្រព្រឹត្តទៅអស់មួយយប់មួយថ្ងៃនេះឯង ។ ភិក្ខុនោះក៏ឆាន់ចង្ហាន់បិណ្ឌបាតនោះ បានបន្ទោបង់សេច-

ជិឃច្ឆាទុព្វល្យំ បដិវិនោទេត្វា ឯវំ តំ រត្តិន្ទិវំ វីតិនា-
មេយ្យ ។ កិញ្ចាបិ សោ ភិក្ខវេ ភិក្ខុ តំ បិណ្ឌបាតំ
ភុញ្ជិត្វា ជិឃច្ឆាទុព្វល្យំ បដិវិនោទេត្វា ឯវំ តំ រត្តិន្ទិវំ
វីតិនាមេយ្យ ។ អថ ខោ អសុយេវ មេ បុរិមោ ភិក្ខុ
បុជ្ជតរោ ច បាសំសតរោ ច ។ តំ កិស្ស ហេតុ ។
តញ្ហិ តស្ស ភិក្ខវេ ភិក្ខុនោ ទីឃរត្តំ អប្បិច្ឆតាយ
សន្តុដ្ឋិយា សល្លេខាយ សុភរតាយ វីរិយារម្ភាយ សំ-
វត្តិស្សតិ ។ តស្មាតិហ មេ ភិក្ខវេ ធម្មទាយាទា ភវថ
មា អាមិសទាយាទា ។ អត្ថិ មេ តុម្ហេសុ អនុកម្បា កិន្តិ
មេ សាវកា ធម្មទាយាទា ភវេយ្យុំ នោ អាមិសទា-
យាទាតិ ។ ឥទមវោច ភគវា ឥទំ វត្វាន[១] សុគតោ
ឧដ្ឋាយាសនា វិហារំ បាវិសិ ។

១ ម. វត្វា ។



ក្តីស្រេកឃ្លាន ចាត់អស់កំឡាំង ប្រព្រឹត្តទៅអស់មួយយប់មួយថ្ងៃនោះ
ឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះឆាន់ចង្ហាន់បិណ្ឌបាតនោះ បាន
បន្ទោបង់សេចក្តីស្រេកឃ្លាន ចាត់អស់កំឡាំង ប្រព្រឹត្តទៅអស់មួយយប់
មួយថ្ងៃនោះឯង ក៏មិនជាអ្វី ។ ឯភិក្ខុទីមួយនោះឯង គួរជាទីបូជាដោយ
វិសេសផង ជាទីសរសើររបស់តថាគតផង ។ ដំណើរនោះព្រោះហេតុ
អ្វី ។ ព្រោះថាការមិនឆាន់ចង្ហាន់បិណ្ឌបាតនោះ អាចធ្វើឲ្យភិក្ខុនោះ
ប្រព្រឹត្តទៅដើម្បីសេចក្តីប្រាថ្នាតិច ដើម្បីសេចក្តីសន្តោស ដើម្បីមានចិត្ត
ផូរផង់ ដើម្បីជាមនុស្សដែលគេចិញ្ចឹមងាយ ដើម្បីប្រារព្ធព្យាយាម
អស់កាលដ៏យូរអង្វែងទៅបាន ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ
ក្នុងសម័យនេះ អ្នកទាំងឡាយចូរយកធម៌របស់តថាគតជាមត៌ក កុំយក
អាមិសជាមត៌កឡើយ តថាគតមានសេចក្តីអនុគ្រោះចំពោះអ្នកទាំងឡាយ
ដូច្នេះថា ធ្វើម្តេចហ្ន៎ ពួកសាវ័ករបស់តថាគតគួរជាអ្នកយកធម៌ជាមត៌ក
កុំយកអាមិសជាមត៌កឡើយ ។ ព្រះមានព្រះភាគទ្រង់មានព្រះពុទ្ធដីកា
នេះ លុះព្រះសុគតមានពុទ្ធដីកានេះចប់ហើយ ក៏ទ្រង់ស្ទុះក្រោកចាក
អាសនៈ ទ្រង់ពុទ្ធដំណើរទៅកាន់វិហារ ។

(២៣) តត្រ ខោ អាយស្មា សារិបុត្តោ អចិរ-
បក្កន្តស្ស ភគវតោ ភិក្ខូ អាមន្តេសិ អាវុសោ
ភិក្ខវេតិ ។ អាវុសោតិ(១) តេ ភិក្ខូ អាយស្មតោ
សារិបុត្តស្ស បច្ចស្សោសុំ ។ អាយស្មា សារិបុត្តោ
ឯតទវោច កិត្តាវតា នុ ខោ អាវុសោ សត្ថុ
បវិវិត្តស្ស វិហរតោ សាវកា វិវេកំ នានុសិក្ខន្តិ
កិត្តាវតា ច បន សត្ថុ បវិវិត្តស្ស វិហរតោ សាវកា
វិវេកមនុសិក្ខន្តីតិ ។ ទូរតោបិ ខោ មយំ អាវុសោ

---

១ ម. អាវុសោតិ ខោ ។



(២៣) កាលដែលព្រះមានព្រះភាគ ទ្រង់ព្រះពុទ្ធដំណើរទៅ
មិនយូរប៉ុន្មាន ព្រះសារីបុត្តដ៏មានអាយុ ក៏ហៅភិក្ខុទាំងឡាយមកក្នុង
វេលានោះថា ម្នាលភិក្ខុទាំងឡាយដ៏មានអាយុ ។ ភិក្ខុទាំងនោះ
ទទួលពាក្យព្រះសារីបុត្តដ៏មានអាយុថា ម្នាលអាវុសោ ។ ព្រះ
សារីបុត្តដ៏មានអាយុ បាននិយាយដូច្នេះថា ម្នាលអាវុសោទាំងឡាយ ចុះ
ព្រះសាស្តា ទ្រង់មានសេចក្តីស្ងប់ស្ងាត់ហើយ ពួកសាវ័កមិនហាត់រៀន
វិវេក(១) គឺសេចក្តីស្ងប់ស្ងាត់ ដោយហេតុប៉ុន្មានយ៉ាង មួយទៀត ព្រះ
សាស្តា ទ្រង់មានសេចក្តីស្ងប់ស្ងាត់ហើយ ពួកសាវ័កហាត់រៀនវិវេក
ដោយហេតុប៉ុន្មានយ៉ាង ។ ពួកភិក្ខុតបថា ម្នាលអាវុសោ យើងខ្ញុំ

---

១ វិវេកមាន ៣ យ៉ាង គឺ កាយវិវេក ស្ងាត់កាយ បានដល់បុគ្គលដែលមានកាយស្ងប់ស្ងាត់ ត្រេកអរក្នុងនេក្ខម្មៈ លះបង់ចោលពួកគណៈ ហើយប្រព្រឹត្តនៅម្នាក់ឯង ១ ចិត្តវិវេក ស្ងាត់ចិត្ត បានដល់បុគ្គលដែលមានចិត្តបរិសុទ្ធផូរផង់ លះបង់ចោលនូវកិលេសដោយអំណាចសមាបត្តិប្រាំបី ១ ឧបធិវិវេក បានដល់បុគ្គលដែលមិនមានកិលេស មិនមានសង្ខារ លះបង់ចោលនូវពួកសង្ខារជ្រះប្រឡះ ១ ។ កាយវិវេកជាបច្ច័យនៃចិត្តវិវេក ចិត្តវិវេកជាបច្ច័យនៃឧបធិវិវេក គឺព្រះនិព្វាន ( អដ្ឋកថាទីឃនិកាយ សីលក្ខន្ធវគ្គ និងអដ្ឋកថាធម្មបទ ) ។

អាគច្ឆេយ្យាម អាយស្មតោ សារីបុត្តស្ស សន្តិកេ ឯតស្ស ភាសិតស្ស អត្ថមញ្ញាតុំ សាធុ វតាយស្មន្តំយេវ សារីបុត្តំ បដិភាតុ ឯតស្ស ភាសិតស្ស អត្ថោ អាយស្មតោ សារីបុត្តស្ស សុត្វា ភិក្ខូ ធារេស្សន្តីតិ ។ តេនហាវុសោ សុណាថ សាធុកំ មនសិករោថ ភាសិស្សាមីតិ ។ ឯវមាវុសោតិ ខោ តេ ភិក្ខូ អាយស្មតោ សារីបុត្តស្ស បច្ចស្សោសុំ ។

(២៤) អាយស្មា សារីបុត្តោ ឯតទវោច កិត្តាវតា នុ ខោ អាវុសោ សត្ថុ បវិវិត្តស្ស វិហរតោ សាវកា វិវេកំ នានុសិក្ខន្តិ[១] ឥធាវុសោ សត្ថុ បវិវិត្តស្ស វិហរតោ សាវកា វិវេកំ នានុសិក្ខន្តិ យេសញ្ច ធម្មានំ សត្ថា បហានមាហ តេ ច ធម្មេ នប្បជហន្តិ ពាហុល្លិកា[២] ច ហោន្តិ សាថិលិកា[៣] ឱក្កមនេ បុព្វង្គមា បវិវេកេ និក្ខិត្តធុរា ។ តត្រាវុសោ

១ ម. កិត្តាវតា នុ ខោ អាវុសោ សត្ថុ បវិវិត្តស្ស វិហរតោ សាវកា វិវេកំ នានុសិក្ខន្តិ ឥតិ ទិស្សតិ ។ ២ ម. ពាហុលិកា ។ ៣ ម. សាថលិកា ។



ទាំងឡាយមកពីចម្ងាយ ដោយប្រាថ្នាដើម្បីដឹង នូវសេចក្ដីនៃភាសិតនុ៎ះ ក្នុងសំណាក់ព្រះសារីបុត្រដ៏មានអាយុ តែសេចក្ដីនៃភាសិតនុ៎ះ ប្រាកដច្បាស់ចំពោះព្រះសារីបុត្រដ៏មានអាយុហើយ ពួកភិក្ខុអ្នកស្ដាប់ (នូវភាសិត)របស់ព្រះសារីបុត្រដ៏មានអាយុរួចហើយ នឹងចាំទុក ។ ព្រះសារីបុត្រដ៏មានអាយុ ឆ្លើយថា ម្នាលអាវុសោទាំងឡាយ បើដូច្នោះ អ្នកទាំងឡាយចូរប្រុងស្ដាប់ ចូរធ្វើទុកក្នុងចិត្តឲ្យប្រពៃ ខ្ញុំនឹងសំដែងឲ្យស្ដាប់ ។ ភិក្ខុទាំងនោះ ក៏ទទួលពាក្យរបស់ព្រះសារីបុត្រដ៏មានអាយុថា ព្រះករុណាអាវុសោ ។

(២៤) ព្រះសារីបុត្រដ៏មានអាយុ បានពោលដូច្នេះថា ម្នាលអាវុសោទាំងឡាយ ព្រះសាស្ដាទ្រង់មានសេចក្ដីស្ងប់ស្ងាត់ហើយ ពួកសាវ័កមិនហាត់ធ្វើនូវវិវេក ដោយហេតុប៉ុន្មានយ៉ាង ម្នាលអាវុសោទាំងឡាយ ព្រះសាស្ដាទ្រង់មានសេចក្ដីស្ងប់ស្ងាត់ហើយ ពួកសាវ័កក្នុងសាសនានេះមិនហាត់ធ្វើនូវវិវេក មិនលះបង់នូវពួកធម៌ដែលព្រះសាស្ដាទ្រង់ត្រាស់ឲ្យលះបង់ តែងជាអ្នកប្រព្រឹត្តល្មោភច្រើន ជាអ្នកកាន់សាសនាធូរៗ នាំគេឲ្យប្រព្រឹត្តខុសតាម ជាអ្នកដាក់ធុរៈក្នុងវិវេក គឺមិនបំពេញកិច្ចក្នុងព្រះវិវេក ។ ម្នាលអាវុសោទាំងឡាយ បណ្ដាភិក្ខុទាំងនោះ

ថេរា ភិក្ខូ តីហិ ឋានេហិ គារយ្ហា ភវន្តិ ។ សត្ថុ បវិវិត្តស្ស វិហរតោ សាវកា វិវេកំ នានុសិក្ខន្តិ ឥមិនា បឋមេន ឋានេន ថេរា ភិក្ខូ គារយ្ហា ភវន្តិ ។ យេសញ្ច ធម្មានំ សត្ថា បហានមាហ តេ ច ធម្មេ នប្បជហន្តិ ឥមិនា ទុតិយេន ឋានេន ថេរា ភិក្ខូ គារយ្ហា ភវន្តិ ។ ពាហុលិកា ច សាថលិកា ឱក្កមនេ បុព្វង្គមា បវិវេកេ និក្ខិត្តធុរា ឥមិនា តតិយេន ឋានេន ថេរា ភិក្ខូ គារយ្ហា ភវន្តិ ។ ថេរា អាវុសោ ភិក្ខូ ឥមេហិ តីហិ ឋានេហិ គារយ្ហា ភវន្តិ ។ តត្រាវុសោ មជ្ឈិមា ភិក្ខូ ។បេ។ នវា ភិក្ខូ តីហិ ឋានេហិ គារយ្ហា ភវន្តិ ។ សត្ថុ បវិវិត្តស្ស វិហរតោ សាវកា វិវេកំ នានុសិក្ខន្តិ ឥមិនា បឋមេន ឋានេន នវា ភិក្ខូ គារយ្ហា ភវន្តិ ។ យេសញ្ច ធម្មានំ សត្ថា បហានមាហ តេ ច ធម្មេ នប្បជហន្តិ ឥមិនា ទុតិយេន ឋានេន នវា ភិក្ខូ គារយ្ហា ភវន្តិ ។



ពួកភិក្ខុជាថេរៈទីនមានគេតិះដៀលដោយហេតុ ៣ យ៉ាង ។ ភិក្ខុជាថេរៈទាំងឡាយ ទីនមានគេតិះដៀល ដោយហេតុទី ១ នេះថា ព្រះសាស្តាទ្រង់មានសេចក្តីស្ងប់ស្ងាត់ហើយ តែមានពួកសាវ័កមិនហាត់ធ្វើនូវវិវេក ។ ភិក្ខុជាថេរៈទាំងឡាយទីនមានគេតិះដៀលដោយហេតុទី ២ នេះថា ពួកសាវ័កមិនលះបង់នូវពួកធម៌ដែលព្រះសាស្តាទ្រង់សំដែងប្រាប់ឲ្យលះបង់ ។ ភិក្ខុជាថេរៈទាំងឡាយទីនមានគេតិះដៀលដោយហេតុទី ៣ នេះថា ពួកសាវ័កជាអ្នកប្រព្រឹត្តល្មោភច្រើន ជាអ្នកកាន់ (សាសនា) ធូរ ៗ នាំគ្នាឲ្យប្រព្រឹត្តខុសតាម ជាអ្នកដាក់ធុរៈក្នុងវិវេក ។ ម្នាលអាវុសោទាំងឡាយ ពួកភិក្ខុជាថេរៈ រមែងមានគេតិះដៀល ដោយហេតុទាំង ៣ យ៉ាងនេះឯង ។ ម្នាលអាវុសោទាំងឡាយ បណ្តាភិក្ខុទាំងនោះពួកមជ្ឈិមភិក្ខុ ។បេ។ ពួកនវកភិក្ខុ រមែងមានគេតិះដៀល ដោយហេតុទាំង ៣ យ៉ាងនេះឯង ។ ពួកនវកភិក្ខុ ទីនមានគេតិះដៀល ដោយហេតុទី ១ នេះថា ព្រះសាស្តាទ្រង់មានសេចក្តីស្ងប់ស្ងាត់ហើយ តែពួកសាវ័កមិនហាត់ធ្វើនូវវិវេក ។ ពួកនវកភិក្ខុ ទីនមានគេតិះដៀល ដោយហេតុទី ២ នេះថា ពួកសាវ័ក មិនលះបង់នូវពួកធម៌ ដែលព្រះសាស្តាទ្រង់សំដែងប្រាប់ឲ្យលះបង់ ។

ពាហុល្លិកា ច សាថលិកា ឱក្កមនេ បុព្វង្គមា បវិវេកេ និក្ខិត្តធុរាតិ ឥមិនា តតិយេន ឋានេន នវា ភិក្ខូ គារយ្ហា ភវន្តិ ។ នវា អាវុសោ ភិក្ខូ ឥមេហិ តីហិ ឋានេហិ គារយ្ហា ភវន្តិ ។ ឯត្តាវតា ខោ អាវុសោ សត្ថុ បវិវិត្តស្ស វិហរតោ សាវកា វិវេកំ នានុសិក្ខន្តិ ។

(៤៨) កិត្តាវតា ច បនាវុសោ សត្ថុ[១] បវិវិត្តស្ស វិហរតោ សាវកា វិវេកមនុសិក្ខន្តិ ឥធាវុសោ សត្ថុ បវិវិត្តស្ស វិហរតោ សាវកា វិវេកមនុសិក្ខន្តិ យេសញ្ច ធម្មានំ សត្ថា បហានមាហ តេ ច ធម្មេ បជហន្តិ ន ច ពាហុល្លិកា ហោន្តិ ន សាថលិកា ឱក្កមនេ និក្ខិត្តធុរា បវិវេកេ បុព្វង្គមា ។ តត្រាវុសោ ថេរា ភិក្ខូ តីហិ ឋានេហិ បាសំសា ភវន្តិ ។

១ ម. ឱ បន សត្ថុ ។



ពួកនវកភិក្ខុនឹងមានគេតិះដៀលដោយហេតុទី ៣ នេះថា ពួកភិក្ខុជាអ្នកប្រព្រឹត្តល្មោភច្រើន ជាអ្នកកាន់ (សាសនា) ធូរ ៗ នាំគេឲ្យប្រព្រឹត្តទន់ទាប ជាអ្នកដាក់ធុរៈក្នុងវិវេក ។ ម្នាលអាវុសោទាំងឡាយ ពួកនវកភិក្ខុរមែងមានគេតិះដៀល ដោយហេតុទាំង ៣ យ៉ាងនេះឯង ។ ម្នាលអាវុសោទាំងឡាយ ព្រះសាស្តា ទ្រង់មានសេចក្តីស្ងប់ស្ងាត់ហើយ តែពួកសាវ័កមិនហាត់ធ្វើនូវវិវេក ដោយហេតុទាំង ៣ យ៉ាងប៉ុណ្ណោះឯង ។

(៤៨) ម្នាលអាវុសោទាំងឡាយ ចុះព្រះសាស្តាទ្រង់មានសេចក្តីស្ងប់ស្ងាត់ហើយ ទាំងពួកសាវ័កក៏សិក្សាតាមនូវវិវេក ដោយហេតុមានប៉ុន្មានយ៉ាង ម្នាលអាវុសោទាំងឡាយ ព្រះសាស្តាទ្រង់មានសេចក្តីស្ងប់ស្ងាត់ហើយ ពួកសាវ័កក៏សិក្សាតាមនូវវិវេកផង លះបង់នូវពួកធម៌ ដែលព្រះជាគ្រូទ្រង់សំដែងប្រាប់ឲ្យលះបង់ផង មិនជាអ្នកប្រព្រឹត្តល្មោភច្រើនផង មិនកាន់(សាសនា)ធូរផង មិនដាក់ធុរៈក្នុងការប្រព្រឹត្តទន់ទាបផង ជាប្រធានក្នុងវិវេកធម៌ព្រះនិព្វានផង ។ ម្នាលអាវុសោ បណ្តាភិក្ខុទាំងនោះ ថេរភិក្ខុទាំងឡាយរមែងមានអ្នកផងសរសើរដោយហេតុ ៣ យ៉ាង ។

សត្ថុ បវិវិត្តស្ស វិហរតោ សាវកា វិវេកមនុសិក្ខន្តិ ឥមិនា បឋមេន ឋានេន ថេរា ភិក្ខូ បាសំសា ភវន្តិ ។ យេសញ្ច ធម្មានំ សត្ថា បហានមាហ តេ ច ធម្មេ បជហន្តិ ឥមិនា ទុតិយេន ឋានេន ថេរា ភិក្ខូ បាសំសា ភវន្តិ ។ ន ច ពាហុលិកា ន សាថលិកា ឱក្កមនេ និក្ខិត្តធុរា បវិវេកេ បុព្វង្គមា ឥមិនា តតិយេន ឋានេន ថេរា ភិក្ខូ បាសំសា ភវន្តិ ។ ថេរា អាវុសោ ភិក្ខូ ឥមេហិ តីហិ ឋានេហិ បាសំសា ភវន្តិ ។ តត្រាវុសោ មជ្ឈិមា ភិក្ខូ ។ បេ ។ នវា ភិក្ខូ តីហិ ឋានេហិ បាសំសា ភវន្តិ ។ សត្ថុ បវិវិត្តស្ស វិហរតោ សាវកា វិវេកមនុសិក្ខន្តិ ឥមិនា បឋមេន ឋានេន នវា ភិក្ខូ បាសំសា ភវន្តិ ។ យេសញ្ច ធម្មានំ សត្ថា បហានមាហ តេ ច ធម្មេ បជហន្តិ ឥមិនា ទុតិយេន ឋានេន នវា ភិក្ខូ បាសំសា ភវន្តិ ។



គឺពួកភិក្ខុជាថេរៈ រមែងមានអ្នកផងសរសើរ ដោយហេតុទី ១ នេះថា ព្រះសាស្តាទ្រង់មានសេចក្តីស្ងប់ស្ងាត់ហើយ ទាំងពួកសាវ័កក៏សិក្សាតាមនូវវិវេក ។ ពួកភិក្ខុជាថេរៈរមែងមានអ្នកផងសរសើរ ដោយហេតុទី២ នេះថា ពួកសាវ័កជាអ្នកលះបង់នូវពួកធម៌ ដែលព្រះសាស្តាទ្រង់សំដែងប្រាប់ឲ្យលះបង់ ។ ពួកភិក្ខុជាថេរៈ រមែងមានអ្នកផងសរសើរ ដោយហេតុទី ៣ នេះថា ពួកសាវ័កមិនប្រព្រឹត្តល្មោភច្រើនផង មិនកាច់ (សាសនា) ធូរផង មិនដាក់ធុរៈក្នុងការប្រព្រឹត្តទន់ទាបផង ជាប្រធានក្នុងវិវេកធម៌គឺព្រះនិព្វានផង ។ ម្នាលអាវុសោទាំងឡាយ ពួកភិក្ខុជាថេរៈ រមែងមានអ្នកផងសរសើរដោយហេតុទាំង ៣ នេះឯង ។ ម្នាលអាវុសោទាំងឡាយ បណ្តាភិក្ខុទាំងនោះ ពួកមជ្ឈិមភិក្ខុ (ភិក្ខុកណ្តាល) ។ បេ ។ ពួកនវកភិក្ខុ (ភិក្ខុថ្មី) រមែងមានអ្នកផងសរសើរដោយហេតុ ៣ យ៉ាង ។ គឺពួកនវកភិក្ខុរមែងមានអ្នកផងសរសើរដោយហេតុទី ១ នេះថា ព្រះសា-ស្តាទ្រង់មានសេចក្តីស្ងប់ស្ងាត់ហើយ មានពួកសាវ័កសិក្សាតាមនូវវិវេក ។ ពួកនវកភិក្ខុរមែងមានអ្នកផងសរសើរដោយហេតុទី ២ នេះថា ពួកសាវ័កជាអ្នកលះបង់នូវពួកធម៌ ដែលព្រះសាស្តាទ្រង់សំដែងប្រាប់ឲ្យលះបង់ ។

ន ច ពាហុលិកា ន សាថលិកា ឱក្កមនេ និក្ខិត្ត-ធុរា បវិវេកេ បុព្វង្គមា ឥមិនា តតិយេន ឋានេន នវា ភិក្ខូ បាសំសា ភវន្តិ ។ នវា អាវុសោ ភិក្ខូ ឥមេហិ តីហិ ឋានេហិ បាសំសា ភវន្តិ ។ ឯត្តាវតា ខោ អាវុសោ សត្ថុ បវិវិត្តស្ស វិហរតោ សាវកា វិវេកមនុសិក្ខន្តិ ។

(២៦) តត្រាវុសោ លោភោ ច បាបកោ ទោសោ ច បាបកោ លោភស្ស ច បហានាយ ទោសស្ស ច បហានាយ អត្ថិ មជ្ឈិមា បដិបទា ចក្ខុករណី ញាណករណី ឧបសមាយ អភិញ្ញាយ សម្ពោធាយ និព្វានាយ សំវត្តតិ ។ កតមា ច សា អាវុសោ មជ្ឈិមា បដិបទា ចក្ខុករណី ញាណករណី ឧបសមាយ អភិញ្ញាយ សម្ពោធាយ និព្វានាយ សំវត្តតិ ។ អយមេវ



ពួកនវកភិក្ខុរមែងមានអ្នកផងសរសើរដោយហេតុទី ៣ នេះជា ពួកសាវកមិនប្រព្រឹត្តល្មោភច្រើនផង មិនកាន់ (សាសនា) ធូរថយផង មិនដាក់ធុរៈក្នុងការប្រព្រឹត្តទន់ទាបផង ជាប្រធានក្នុងវិវេកធម៌គឺព្រះនិព្វានផង ។ ម្នាលអាវុសោទាំងឡាយ ពួកនវកភិក្ខុរមែងមានអ្នកផងសរសើរ ដោយហេតុទាំង ៣ យ៉ាងនេះឯង ។ ម្នាលអាវុសោទាំងឡាយ ព្រះសាស្តាទ្រង់មានសេចក្តីស្ងប់ស្ងាត់ហើយ រមែងមានពួកសាវកជាអ្នកសិក្សាតាមនូវវិវេក ដោយហេតុទាំង ៣ យ៉ាងប៉ុណ្ណេះឯង ។

(២៦) ម្នាលអាវុសោទាំងឡាយ បណ្តាធម៌ទាំងនោះ លោភៈជាបាបធម៌ ១ ទោសៈជាបាបធម៌ ១ មជ្ឈិមាបដិបទា គឺសេចក្តីប្រតិបត្តិជាកណ្តាល ប្រព្រឹត្តទៅដើម្បីលះបង់នូវលោភៈផង ដើម្បីលះបង់នូវទោសៈផង ជាសេចក្តីប្រតិបត្តិធ្វើឲ្យកើតបញ្ញាចក្ខុឃើញនូវសច្ចៈទាំង ៤ ផង ជាសេចក្តីប្រតិបត្តិធ្វើឲ្យកើតញាណគឺដឹងនូវសច្ចទាំង ៤ ផង ប្រព្រឹត្តទៅដើម្បីរម្ងាប់កិលេស ដើម្បីដឹងច្បាស់នូវអរិយសច្ច ដើម្បីត្រាស់ដឹងនូវមគ្គ ដើម្បីព្រះនិព្វាន ។ ម្នាលអាវុសោទាំងឡាយ ក៏មជ្ឈិមាបដិបទានោះ ជាសេចក្តីប្រតិបត្តិធ្វើឲ្យកើតបញ្ញាចក្ខុ ជាសេចក្តីប្រតិបត្តិធ្វើឲ្យកើតញាណ ប្រព្រឹត្តទៅដើម្បីរម្ងាប់កិលេស ដើម្បីដឹងច្បាស់នូវអរិយ-សច្ច ដើម្បីត្រាស់ដឹងនូវមគ្គ ដើម្បីព្រះនិព្វាន តើដូចម្តេច ។ (មជ្ឈិមា-

អរិយោ អដ្ឋង្គិកោ មគ្គោ សេយ្យថីទំ សម្មាទិដ្ឋិ សម្មាសង្កប្បោ សម្មាវាចា សម្មាកម្មន្តោ សម្មាអាជីវោ សម្មាវាយាមោ សម្មាសតិ សម្មាសមាធិ ។ អយំ ខោ សា អាវុសោ មជ្ឈិមា បដិបទា ចក្ខុករណី ញាណករណី ឧបសមាយ អភិញ្ញាយ សម្ពោធាយ និព្វានាយ សំវត្តតិ ។ តត្រាវុសោ កោធោ ច បាបកោ ឧបនាហោ ច បាបកោ.. ។ មក្ខោ ច បាបកោ បឡាសោ ច បាបកោ.. ។ ឥស្សា ច បាបិកា មច្ឆរិយញ្ច បាបកំ... ។ មាយា ច បាបិកា សាឋេយ្យំ ច បាបកំ... ។ ថម្ភោ ច បាបកោ សារម្ភោ ច បាបកោ... ។ មានោ ច បាបកោ អតិមានោ ច បាបកោ... ។ មទោ ច បាបកោ បមាទោ ច បាបកោ មទស្ស ច បហានាយ បមាទស្ស ច បហានាយ អត្ថិ មជ្ឈិមា បដិបទា ចក្ខុករណី ញាណករណី



មាបដិបទានោះ ) គឺអរិយមគ្គប្រកបដោយអង្គ ៨ ប្រការនេះឯង ឯអរិយមគ្គប្រកបដោយអង្គ ៨ ប្រការគឺ សេចក្ដីឃើញត្រូវ ១ សេចក្ដីត្រិះរិះត្រូវ ១ សំដីត្រូវ ១ ការងារត្រូវ ១ ការចិញ្ចឹមជីវិតត្រូវ ១ សេចក្ដីព្យាយាមត្រូវ ១ ការរលឹកត្រូវ ១ ការតំកល់ចិត្តត្រូវ ១ ។ ម្នាលអាវុសោទាំងឡាយ មជ្ឈិមាបដិបទានេះឯង ជាសេចក្ដីប្រតិបត្តិធ្វើឲ្យកើតបញ្ញាចក្ខុ ជាសេចក្ដីប្រតិបត្តិធ្វើឲ្យកើតញាណ ប្រព្រឹត្តទៅដើម្បីរម្ងាប់កិលេស ដើម្បីដឹងច្បាស់នូវអរិយសច្ច ដើម្បីត្រាស់ដឹងនូវមគ្គ ដើម្បីព្រះនិព្វាន ។ ម្នាលអាវុសោទាំងឡាយ បណ្ដាធម៌ទាំងនោះ សេចក្ដីក្រោធជាបាបធម៌ ១ ការចងសេចក្ដីក្រោធទុកជាបាបធម៌ ១... ។ ការលុបគុណគេជាបាបធម៌ ១ ការប្រកួតស្មើជាបាបធម៌ ១... ។ សេចក្ដីឈ្នានីសជាបាបធម៌ ១ សេចក្ដីកំណាញ់ជាបាបធម៌ ១... ។ ការបិទបាំងទោសខ្លួនជាបាបធម៌ ១ សេចក្ដីអួតអាងជាបាបធម៌ ១... ។ សេចក្ដីរឹងត្អឹងជាបាបធម៌ ១ ប្រឡងរេសគ្នាជាបាបធម៌ ១... ។ មានះជាបាបធម៌ ១ អតិមានះជាបាបធម៌ ១... ។ សេចក្ដីស្រវឹងជាបាបធម៌ ១ សេចក្ដីធ្វេសប្រហែសជាបាបធម៌ ១ សេចក្ដីប្រតិបត្តិយ៉ាងកណ្ដាល ប្រព្រឹត្តទៅដើម្បីលះបង់ នូវសេចក្ដីស្រវឹងផង ដើម្បីលះបង់នូវសេចក្ដីធ្វេសប្រហែសផង ជាសេចក្ដីប្រតិបត្តិធ្វើឲ្យកើតបញ្ញាចក្ខុ ជាសេចក្ដី

ឧបសមាយ អភិញ្ញាយ សម្ពោធាយ និព្វានាយ សំវត្តតិ ។ កតមា ច សា អាវុសោ មជ្ឈិមា បដិបទា ចក្ខុករណី ញាណករណី ឧបសមាយ អភិញ្ញាយ សម្ពោធាយ និព្វានាយ សំវត្តតិ ។ អយមេវ អរិយោ អដ្ឋង្គិកោ មគ្គោ សេយ្យថីទំ សម្មាទិដ្ឋិ សម្មាសង្កប្បោ សម្មាវាចា សម្មាកម្មន្តោ សម្មាអាជីវោ សម្មាវាយាមោ សម្មាសតិ សម្មាសមាធិ ។ អយំ ខោ សា អាវុសោ មជ្ឈិមា បដិបទា ចក្ខុករណី ញាណករណី ឧបសមាយ អភិញ្ញាយ សម្ពោធាយ និព្វានាយ សំវត្តតីតិ ។ ឥទមវោច អាយស្មា សារីបុត្តោ អត្តមនា តេ ភិក្ខូ អាយស្មតោ សារីបុត្តស្ស ភាសិតំ អភិនន្ទុន្តិ ។

ធម្មទាយាទសុត្តំ តតិយំ(១) និដ្ឋិតំ ។

១ ម. ធម្មទាយាទសុត្តំ តតិយំ ។ ម. ធម្មទាយាទសុត្តន្តំ តតិយំ ។



ប្រតិបត្តិធ្វើឲ្យកើតញាណ ប្រព្រឹត្តទៅដើម្បីរម្ងាប់កិលេស ដើម្បីដឹងច្បាស់នូវអរិយសច្ច ដើម្បីត្រាស់ដឹងនូវមគ្គ ដើម្បីព្រះនិព្វាន ។ ម្នាលអាវុសោទាំងឡាយ សេចក្តីប្រតិបត្តិយ៉ាងកណ្តាលនោះ ជាសេចក្តីប្រតិបត្តិធ្វើឲ្យកើតបញ្ញាចក្ខុ ជាសេចក្តីប្រតិបត្តិធ្វើឲ្យកើតញាណ ប្រព្រឹត្តទៅដើម្បីរម្ងាប់កិលេស ដើម្បីដឹងច្បាស់នូវអរិយសច្ច ដើម្បីត្រាស់ដឹងនូវមគ្គ ដើម្បីព្រះនិព្វាន តើដូចម្តេច ។ (សេចក្តីប្រតិបត្តិយ៉ាងកណ្តាលនោះ) គឺអរិយមគ្គប្រកបដោយអង្គ៨ប្រការនេះឯង ឯអរិយមគ្គប្រកបដោយអង្គ៨ប្រការនោះគឺ សេចក្តីយល់ឃើញត្រូវ១ សេចក្តីត្រិះរិះត្រូវ១ សំដីត្រូវ១ ការងារត្រូវ១ ការចិញ្ចឹមជីវិតត្រូវ១ សេចក្តីព្យាយាមត្រូវ១ ការរលឹកត្រូវ១ ការដំកល់ចិត្តត្រូវ១ ។ ម្នាលអាវុសោទាំងឡាយ សេចក្តីប្រតិបត្តិយ៉ាងកណ្តាលនេះឯង ជាសេចក្តីប្រតិបត្តិធ្វើឲ្យកើតបញ្ញាចក្ខុ ជាសេចក្តីប្រតិបត្តិធ្វើឲ្យកើតញាណ ប្រព្រឹត្តទៅដើម្បីរម្ងាប់កិលេស ដើម្បីដឹងច្បាស់នូវអរិយសច្ច ដើម្បីត្រាស់ដឹងនូវមគ្គ ដើម្បីព្រះនិព្វាន ។ ព្រះសារីបុត្រដ៏មានអាយុ បានសំដែងនូវសូត្រនេះចប់ហើយ ភិក្ខុទាំងឡាយនោះ ក៏មានចិត្តត្រេកអររីករាយ ចំពោះភាសិតរបស់ព្រះសារីបុត្រដ៏មានអាយុ ។

ចប់ ធម្មទាយាទសូត្រ ទី៣ ។

# ចតុត្ថំ ភយភេរវសុត្តំ

(២៧) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ អថ ខោ ជាណុស្សោណិ ព្រាហ្មណោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវតា សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។

(២៨) ឯកមន្តំ និសិន្នោ ខោ ជាណុស្សោណិ ព្រាហ្មណោ ភគវន្តំ ឯតទវោច យេមេ ភោ គោតម កុលបុត្តា ភវន្តំ គោតមំ ឧទ្ទិស្ស សទ្ធា អគារស្មា អនគារិយំ បព្វជិតា ភវន្តេសំ(១) គោតមោ បុព្វង្គមោ ភវន្តេសំ(២) គោតមោ ពហុការោ ភវន្តេសំ(៣) គោតមោ

១-២-៣ ម.ម. ភវំ តេសំ ។

# ភយភេរវសូត្រ ទី ៤

(២៧) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង ជាណុស្សោណិព្រាហ្មណ៍ ចូលសំដៅទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ពោលពាក្យរាក់ទាក់ សំណេះសំណាល ជាមួយនឹងព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររលឹក ល្មមឲ្យកើតសេចក្ដីស្និទ្ធស្នាលហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ។

(២៨) លុះជាណុស្សោណិព្រាហ្មណ៍ អង្គុយក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះគោតមដ៏ចំរើន កុលបុត្រទាំងឡាយណា ដែលចេញចាកផ្ទះ ហើយចូលកាន់ផ្នួសដោយសទ្ធា ចំពោះព្រះគោតមដ៏ចំរើន ព្រះគោតមដ៏ចំរើន ទ្រង់ណែនាំកុល-បុត្រទាំងនោះ ព្រះគោតមដ៏ចំរើន ទ្រង់មានឧបការៈច្រើនដល់កុលបុត្រ

សមាទបេតា ភោតោ ច បន គោតមស្ស សា ជនតា ទិដ្ឋានុគតឹ អាបជ្ជតីតិ ។ ឯវមេតំ ព្រាហ្មណ ឯវមេតំ ព្រាហ្មណ យេ តេ ព្រាហ្មណ កុលបុត្តា មមំ ឧទ្ទិស្ស សទ្ធា អគារស្មា អនគារិយំ បព្វជិតា អហំ តេសំ បុព្វង្គមោ អហំ តេសំ ពហុការោ អហំ តេសំ សមាទបេតា មមញ្ច បន សា ជនតា ទិដ្ឋានុគតឹ អាបជ្ជតីតិ ។

(២៩) ទុរភិសម្ភវានិ ហិ[១] ភោ គោតម អរញ្ញវន-បត្ថានិ[២] បន្តានិ សេនាសនានិ ទុក្ករំ បវិវេកំ ទុរភិរមំ ឯកត្តេ ហរន្តិ មញ្ញេ មនោ វនានិ សមាធឹ អលភមានស្ស ភិក្ខុនោតិ ។ ឯវមេតំ ព្រាហ្មណ ឯវមេតំ ព្រាហ្មណ ទុរភិសម្ភវានិ ហិ[៣] ព្រាហ្មណ អរញ្ញវនបត្ថានិ បន្តានិ សេនាសនានិ ទុក្ករំ បវិវេកំ

១ ម. ហិ ភោ ។ ២ ម. អរញ្ញបត្ថានិ ។ ៣ ម. ហិ ភោ ។



ទាំងនោះ ព្រះគោតមដ៏ចំរើន ទ្រង់ឲ្យកុលបុត្រទាំងនោះសិក្សា (ឲ្យសិក្សា មានអធិសីលសិក្ខាជាដើម) ឯប្រជុំជនទាំងនោះក៏យកតម្រាប់តាមព្រះគោតមដ៏ចំរើនមែនឬ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលព្រាហ្មណ៍ សេចក្តីនេះយ៉ាងហ្នឹងហើយ ម្នាលព្រាហ្មណ៍ សេចក្តីនេះយ៉ាងហ្នឹងហើយ ម្នាលព្រាហ្មណ៍ កុលបុត្រទាំងឡាយណា ដែលចេញចាកផ្ទះហើយចូលទៅកាន់ផ្នួសដោយសទ្ធាចំពោះតថាគត តថាគតជាអ្នកណែនាំកុលបុត្រទាំងនោះ តថាគតជាអ្នកមានឧបការៈច្រើនដល់កុល-បុត្រទាំងនោះ តថាគតជាអ្នកឲ្យកុលបុត្រទាំងនោះសិក្សា (ឲ្យសិក្សា នូវអធិសីលសិក្ខាជាដើម) ឯប្រជុំជននោះក៏យកតម្រាប់តាមតថាគតមែន ។

[២៩] បពិត្រព្រះគោតមដ៏ចំរើន សេនាសនៈដ៏ស្ងាត់ទាំងនៅក្នុងព្រៃធំ ឬព្រៃឆ្ងាយ ជាទីដែលបុគ្គលធន់ទ្រាំនៅបានដោយកម្រ វិវេក បុគ្គលធ្វើបានដោយកម្រ ត្រេកអរបានដោយកម្រ ព្រៃទាំងនោះ ហាក់ដូចជាដឹកនាំចិត្តនៃភិក្ខុ ដែលមិនបានសមាធិក្នុងទីស្ងាត់ មែនឬទេ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលព្រាហ្មណ៍ សេចក្តីនេះយ៉ាងហ្នឹងហើយ ម្នាលព្រាហ្មណ៍ សេចក្តីនេះយ៉ាងហ្នឹងហើយ ម្នាលព្រាហ្មណ៍ ព្រោះថាសេនាសនៈស្ងាត់ ទាំងនៅក្នុងព្រៃធំឬព្រៃឆ្ងាយ ជាទីដែលបុគ្គលធន់ទ្រាំនៅបានដោយកម្រ វិវេក បុគ្គលធ្វើបានដោយកម្រ

ទុរភិរមំ ឯកត្តេ ហរន្តិ មញ្ញេ មនោ វនានិ សមាធឹ អលភមានស្ស ភិក្ខុនោតិ ។

(៣០) មយ្ហម្បិ ខោ ព្រាហ្មណ បុព្វេវ សម្ពោធា អនភិសម្ពុទ្ធស្ស ពោធិសត្តស្សេវ សតោ ឯតទហោសិ ទុរភិសម្ភវានិ ហិ ខោ អរញ្ញវនបត្ថានិ បន្តានិ សេនាសនានិ ទុក្ករំ បវិវេកំ ទុរភិរមំ ឯកត្តេ ហរន្តិ មញ្ញេ មនោ វនានិ សមាធឹ អលភមានស្ស ភិក្ខុនោតិ ។

(៣១) តស្ស មយ្ហំ ព្រាហ្មណ ឯតទហោសិ យេ ខោ កេចិ សមណា វា ព្រាហ្មណា វា អបរិសុទ្ធកាយកម្មន្តា អរញ្ញវនបត្ថានិ បន្តានិ សេនាសនានិ បដិសេវន្តិ អបរិសុទ្ធកាយកម្មន្តសន្ទោសហេតុ ហវេ តេ ភោន្តោ សមណព្រាហ្មណា អកុសលំ ភយភេរវំ អវ្ហាយន្តិ ។ ន ខោ បនាហំ អបរិសុទ្ធកាយកម្មន្តោ អរញ្ញវនបត្ថានិ បន្តានិ សេនាសនានិ បដិសេវាមិ បរិសុទ្ធកាយកម្មន្តោហមស្មិ ។ យេ ហិ វោ អរិយា បរិសុទ្ធកាយកម្មន្តា



ត្រេកអរបានដោយកម្រ ព្រៃ (ទាំងនោះ) ហាក់ដូចជាដឹកនាំចិត្តនៃភិក្ខុដែលមិនបានសមាធិក្នុងទីស្ងាត់មែន ។

(៣០) ម្នាលព្រាហ្មណ៍ សូម្បីតែតថាគតនៅជាពោធិសត្វនៅឡើយ ក្នុងកាលមុនដែលមិនទាន់បានត្រាស់ដឹងនូវសម្ពោធិញ្ញាណ មានសេចក្តីត្រិះរិះដូច្នេះថា សេនាសនៈស្ងាត់ទាំងនៅក្នុងព្រៃជិតឬព្រៃឆ្ងាយនេះឯង ជាទីដែលបុគ្គលធន់ទ្រាំនៅបានដោយកម្រ វិវេក បុគ្គលធ្វើបានដោយកម្រ ត្រេកអរបានដោយកម្រ ព្រៃ (ទាំងនោះ) ហាក់ដូចជាដឹកនាំចិត្តនៃភិក្ខុដែលមិនបានសមាធិក្នុងទីស្ងាត់ ។

(៣១) ម្នាលព្រាហ្មណ៍ តថាគតនោះឯង មានសេចក្តីត្រិះរិះដូច្នេះថា សមណព្រាហ្មណ៍ណាមួយ ដែលមានកាយកម្មមិនបរិសុទ្ធ សេពនូវសេនាសនៈស្ងាត់ ទាំងនៅក្នុងព្រៃជិតឬព្រៃឆ្ងាយ សមណព្រាហ្មណ៍ដ៏ចំរើនទាំងនោះ តែងហៅអកុសលធម៌ដែលគួរភ័យគួរខ្លាច ព្រោះហេតុនៃទោសរបស់ខ្លួនដែលមានកាយកម្មមិនបរិសុទ្ធនោះឯង ។ ចំណែកតថាគត មិនមែនជាមានកាយកម្មមិនបរិសុទ្ធ សេពនូវសេនាសនៈស្ងាត់ទាំងនៅក្នុងព្រៃជិតឬព្រៃឆ្ងាយដូច្នោះទេ តថាគតជាអ្នកមានកាយកម្មបរិសុទ្ធមែន ។ ព្រោះអរិយៈទាំងឡាយណា ដែលមានកាយកម្មបរិសុទ្ធ

អរញ្ញវនបត្ថានិ បន្តានិ សេនាសនានិ បដិសេវន្តិ តេសមហំ អញ្ញតរោ[១] ឯតមហំ ព្រាហ្មណ បរិសុទ្ធកាយកម្មន្តតំ អត្តនិ សម្បស្សមានោ ភិយ្យោ បល្លោមមាបាទឹ អរញ្ញេ វិហារាយ ។

(៣៦) តស្ស មយ្ហំ ព្រាហ្មណ ឯតទហោសិ យេ ខោ កេចិ សមណា វា ព្រាហ្មណា វា អបរិសុទ្ធវចីកម្មន្តា ។ បេ ។ អបរិសុទ្ធមនោកម្មន្តា អបរិសុទ្ធាជីវា អរញ្ញវនបត្ថានិ បន្តានិ សេនាសនានិ បដិសេវន្តិ អបរិសុទ្ធាជីវសន្ទោសហេតុ ហវេ តេ ភោន្តោ សមណព្រាហ្មណា អកុសលំ ភយភេរវំ អវ្ហាយន្តិ ។ ន ខោ បនាហំ អបរិសុទ្ធាជីវោ អរញ្ញវនបត្ថានិ បន្តានិ សេនាសនានិ បដិសេវាមិ បរិសុទ្ធាជីវោហមស្មិ ។ យេ ហិ វោ អរិយា បរិសុទ្ធាជីវា អរញ្ញវនបត្ថានិ បន្តានិ សេនាសនានិ បដិសេវន្តិ តេសមហំ អញ្ញតរោ[២] ឯតមហំ ព្រាហ្មណ បរិសុទ្ធាជីវតំ អត្តនិ សម្បស្សមានោ ភិយ្យោ បល្លោមមាបាទឹ អរញ្ញេ វិហារាយ ។

១-២ ម. អញ្ញតមោ ។ ឯវំ សព្វត្ថ ។



រមែងសេពនូវសេនាសនៈស្ងាត់ គឺទីនៅក្នុងព្រៃផង ទីព្រៃឆ្ងាយ បណ្តាព្រះអរិយៈទាំងឡាយនោះ តថាគតជាព្រះអរិយៈមួយដែរ ម្នាលព្រាហ្មណ៍ តថាគតបានពិចារណាឃើញនូវកាយកម្មដ៏បរិសុទ្ធនុ៎ះ ក្នុងខ្លួនហើយ ទើបតថាគតបានដល់នូវសួស្តីច្រើន គួរនឹងនៅក្នុងព្រៃបាន ។

(៣៦) ម្នាលព្រាហ្មណ៍ តថាគតឯងមានសេចក្តីត្រិះរិះដូច្នេះថា ពួកសមណព្រាហ្មណ៍ណាមួយ ដែលមានវចីកម្មមិនបរិសុទ្ធ ។ បេ ។ ដែលមានមនោកម្មមិនបរិសុទ្ធ មានអាជីវៈមិនបរិសុទ្ធ សេពនូវសេនាសនៈស្ងាត់ គឺទីនៅក្នុងព្រៃផង ទីព្រៃឆ្ងាយ សមណព្រាហ្មណ៍ដ៏ចំរើនទាំងនោះ តែងហៅអកុសលដែលគួរភ័យគួរខ្លាច ព្រោះហេតុនៃទោសរបស់ខ្លួន ដែលមានអាជីវៈមិនបរិសុទ្ធនោះឯង ។ ឯតថាគតមិនមែនជាមានអាជីវៈមិនបរិសុទ្ធ សេពនូវសេនាសនៈស្ងាត់ គឺទីនៅក្នុងព្រៃផង ទីព្រៃឆ្ងាយដូច្នោះទេ តថាគតជាអ្នកមានអាជីវៈបរិសុទ្ធមែន ។ ពួកព្រះអរិយៈណា ដែលមានអាជីវៈបរិសុទ្ធ រមែងសេពនូវសេនាសនៈស្ងាត់ គឺទីនៅក្នុងព្រៃផង ទីព្រៃឆ្ងាយ បណ្តាព្រះអរិយៈទាំងនោះ តថាគតក៏ជាព្រះអរិយៈមួយដែរ ម្នាលព្រាហ្មណ៍ តថាគតពិចារណាឃើញ នូវអាជីវៈដ៏បរិសុទ្ធនុ៎ះ ក្នុងខ្លួនហើយ ទើបតថាគតបានដល់នូវសួស្តី ដោយច្រើន គួរនឹងនៅក្នុងព្រៃបាន ។

(៣៣) តស្ស មយ្ហំ ព្រាហ្មណ ឯតទហោសិ យេ ខោ កេចិ សមណា វា ព្រាហ្មណា វា អភិជ្ឈាលូ កាមេសុ តិព្វសារាគា អរញ្ញវនបត្ថានិ បន្តានិ សេនាសនានិ បដិសេវន្តិ អភិជ្ឈាលុកាមេសុតិព្វសារាគសន្ទោសហេតុ ហវេ តេ ភោន្តោ សមណព្រាហ្មណា អកុសលំ ភយភេរវំ អវ្ហាយន្តិ ។ ន ខោ បនាហំ អភិជ្ឈាលុ កាមេសុ តិព្វសារាគោ អរញ្ញវនបត្ថានិ សេនាសនានិ បដិសេវាមិ អនភិជ្ឈាលុហមស្មិ ។ យេ ហិ វោ អរិយា អនភិជ្ឈាលូ អរញ្ញវនបត្ថានិ បន្តានិ សេនាសនានិ បដិសេវន្តិ តេសមហំ អញ្ញតរោ ឯតមហំ ព្រាហ្មណ អនភិជ្ឈាលុតំ អត្តនិ សម្បស្សមានោ ភិយ្យោ បល្លោមមាបាទឹ អរញ្ញេ វិហារាយ ។



(៣៣) ម្នាលព្រាហ្មណ៍ តថាគតឯងមានសេចក្តីត្រិះរិះដូច្នេះថា ពួកសមណព្រាហ្មណ៍ណាមួយ ដែលមានអភិជ្ឈាជាប្រក្រតី មានសេចក្តីត្រេកត្រអាលដ៏ក្លៀវក្លា ក្នុងកាមទាំងឡាយ សេពនូវសេនាសនៈស្ងាត់ តាំងនៅក្នុងព្រៃជិតនឹងព្រៃឆ្ងាយ សមណព្រាហ្មណ៍ដ៏ចំរើន ទាំងនោះ តែងហៅអកុសលធម៌ដែលគួរភ័យគួរខ្លាច ព្រោះហេតុនៃទោសរបស់ខ្លួន ដែលមានអភិជ្ឈាជាប្រក្រតី មានសេចក្តីត្រេកត្រអាលដ៏ក្លៀវក្លាក្នុងកាម ទាំងឡាយនោះឯង ។ ឯតថាគតនឹងមានអភិជ្ឈាជាប្រក្រតី មានសេចក្តី ត្រេកត្រអាលដ៏ក្លៀវក្លា ក្នុងកាមទាំងឡាយ សេពនូវសេនាសនៈស្ងាត់ តាំងនៅក្នុងព្រៃជិតនឹងព្រៃឆ្ងាយដូច្នោះក៏ទេ តថាគតមិនមានអភិជ្ឈាជា ប្រក្រតីមែន ។ ពួកព្រះអរិយៈណា ដែលមិនមានអភិជ្ឈាជាប្រក្រតី សេពនូវសេនាសនៈស្ងាត់ តាំងនៅក្នុងព្រៃជិតនឹងព្រៃឆ្ងាយ បណ្តាព្រះ អរិយៈទាំងនោះ តថាគតក៏ជាព្រះអរិយៈមួយដែរ ម្នាលព្រាហ្មណ៍ តថា- គតបានពិចារណាឃើញនូវគុណ ដែលមិនមែនជាអភិជ្ឈានុ៎ះ ក្នុងខ្លួនហើយ ទើបតថាគតបានដល់នូវសួស្តីដោយច្រើន គួរនឹងនៅក្នុងព្រៃបាន ។

(៣៤) តស្ស មយ្ហំ ព្រាហ្មណ ឯតទហោសិ យេ ខោ កេចិ សមណា វា ព្រាហ្មណា វា ព្យាបន្នចិត្តា បទុដ្ឋមនសង្កប្បា អរញ្ញវនបត្ថានិ បន្តានិ សេនាសនានិ បដិសេវន្តិ ព្យាបន្នចិត្តបទុដ្ឋមនសង្កប្បសន្ទោសហេតុ ហវេ តេ ភោន្តោ សមណព្រាហ្មណា អកុសលំ ភយភេរវំ អវ្ហាយន្តិ ។ ន ខោ បនាហំ ព្យាបន្នចិត្តោ បទុដ្ឋមនសង្កប្បោ អរញ្ញវនបត្ថានិ បន្តានិ សេនាសនានិ បដិសេវាមិ មេត្តចិត្តោ ហមស្មិ ។ យេ ហិ វោ អរិយា មេត្តចិត្តា អរញ្ញវនបត្ថានិ បន្តានិ សេនាសនានិ បដិសេវន្តិ តេសមហំ អញ្ញតរោ ឯតមហំ ព្រាហ្មណ មេត្តចិត្តតំ អត្តនិ សម្បស្សមានោ ភិយ្យោ បល្លោមមាបាទឹ អរញ្ញេ វិហារាយ ។



(៣៤) ម្នាលព្រាហ្មណ៍ តថាគតឯង មានសេចក្តីត្រិះរិះដូច្នេះថា ពួកសមណព្រាហ្មណ៍ណាមួយ មានចិត្តព្យាបាទ មានចិត្តគិតប្រទូស្ត សេពនូវសេនាសនៈស្ងាត់ គឺទីនៅក្នុងព្រៃដ៏តូចនិងព្រៃធំ សមណព្រាហ្មណ៍ដ៏ចំរើនទាំងនោះ តែងហៅអកុសលធម៌ ដែលគួរភ័យគួរខ្លាច ព្រោះហេតុនៃទោសរបស់ខ្លួន ដែលមានចិត្តព្យាបាទ និងចិត្តគិតប្រទូស្ត នោះឯង ។ ឯតថាគតមិនមែនជាអ្នកមានចិត្តព្យាបាទ មានចិត្តគិតប្រទូស្ត សេពនូវសេនាសនៈស្ងាត់ គឺទីនៅក្នុងព្រៃដ៏តូចនិងព្រៃធំទេ ព្រោះតែ តថាគត ជាអ្នកមានចិត្តប្រកបដោយមេត្តា ។ ព្រះអរិយៈទាំងឡាយណា ដែលមានចិត្តប្រកបដោយមេត្តា រមែងសេពនូវសេនាសនៈស្ងាត់ គឺទីនៅក្នុងព្រៃដ៏តូចនិងព្រៃធំ បណ្តាព្រះអរិយៈទាំងនោះ តថាគតក៏ជាព្រះអរិយៈមួយដែរ ម្នាលព្រាហ្មណ៍ តថាគតបានពិចារណាឃើញនូវចិត្តប្រកបដោយមេត្តានុ៎ះ ក្នុងខ្លួនហើយ ទើបដល់នូវ[illegible]ដោយច្រើន ក្នុងទីនៅក្នុងព្រៃបាន ។

(៣៥) តស្ស មយ្ហំ ព្រាហ្មណ ឯតទហោសិ យេ ខោ កេចិ សមណា វា ព្រាហ្មណា វា ថីនមិទ្ធបរិយុដ្ឋិតា អរញ្ញវនបត្ថានិ បន្តានិ សេនាសនានិ បដិសេវន្តិ ថីនមិទ្ធបរិយុដ្ឋានសន្ទោសហេតុ ហវេ តេ ភោន្តោ សមណព្រាហ្មណា អកុសលំ ភយភេរវំ អវ្ហាយន្តិ ។ ន ខោ បនាហំ ថីនមិទ្ធបរិយុដ្ឋិតោ អរញ្ញវនបត្ថានិ បន្តានិ សេនាសនានិ បដិសេវាមិ វិគតថីនមិទ្ធោហមស្មិ ។ យេ ហិ វោ អរិយា វិគតថីនមិទ្ធា អរញ្ញវនបត្ថានិ បន្តានិ សេនាសនានិ បដិសេវន្តិ តេសមហំ អញ្ញតរោ ឯតមហំ ព្រាហ្មណ វិគតថីនមិទ្ធតំ អត្តនិ សម្បស្សមានោ ភិយ្យោ បល្លោមមាបាទឹ អរញ្ញេ វិហារាយ ។

(៣៦) តស្ស មយ្ហំ ព្រាហ្មណ ឯតទហោសិ យេ ខោ កេចិ សមណា វា ព្រាហ្មណា វា ឧទ្ធតា អវូបសន្តចិត្តា អរញ្ញវនបត្ថានិ បន្តានិ សេនាសនានិ បដិសេវន្តិ



(៣៥) ម្នាលព្រាហ្មណ៍ តថាគតនោះ មានសេចក្តីត្រិះរិះដូច្នេះថា ពួកសមណព្រាហ្មណ៍ណាមួយ ដែលថីនមិទ្ធៈ (សេចក្តីច្រអូសចិត្តនិងច្រអូសកាយ) គ្របសង្កត់ហើយ សេពនូវសេនាសនៈស្ងាត់ គឺនៅក្នុងព្រៃជិតនិងព្រៃឆ្ងាយ សមណព្រាហ្មណ៍ដ៏ចំរើនទាំងនោះ តែងហៅអកុសលធម៌ដែលគួរភ័យគួរខ្លាច ព្រោះហេតុនៃទោសរបស់ខ្លួនដែលថីនមិទ្ធៈគ្របសង្កត់នោះឯង ។ ឯតថាគតមិនមែនជាអ្នកដែលថីនមិទ្ធៈគ្របសង្កត់ សេពនូវសេនាសនៈស្ងាត់ គឺនៅក្នុងព្រៃជិត និងព្រៃឆ្ងាយដូច្នោះទេ តថាគត ជាអ្នកមានថីនមិទ្ធៈទៅប្រាសហើយ ។ ព្រះអរិយៈទាំងឡាយណា មានថីនមិទ្ធៈទៅប្រាសហើយ សេពនូវសេនាសនៈស្ងាត់ គឺនៅក្នុងព្រៃជិតនិងព្រៃឆ្ងាយ បណ្តាព្រះអរិយៈទាំងនោះ តថាគតក៏ជាព្រះអរិយៈមួយដែរ ម្នាលព្រាហ្មណ៍ តថាគតពិចារណាឃើញ នូវថីនមិទ្ធៈទៅប្រាសហើយក្នុងខ្លួន ទើបដល់នូវសួស្តីដោយច្រើន គួរនឹងនៅក្នុងព្រៃបាន ។

(៣៦) ម្នាលព្រាហ្មណ៍ តថាគតនោះ មានសេចក្តីត្រិះរិះដូច្នេះថា ពួកសមណព្រាហ្មណ៍ណាមួយ ដែលមានចិត្តរវើរវាយ មានចិត្តមិនស្ងប់ស្ងាត់ សេពនូវសេនាសនៈស្ងាត់ គឺនៅក្នុងព្រៃជិតនិងព្រៃឆ្ងាយ

ឧទ្ធតាវូបសន្តចិត្តសន្ទោសហេតុ ហវេ តេ ភោន្តោ សមណព្រាហ្មណា អកុសលំ ភយភេរវំ អវ្ហាយន្តិ ។ ន ខោ បនាហំ ឧទ្ធតោ អវូបសន្តចិត្តោ អរញ្ញវនបត្ថានិ បន្តានិ សេនាសនានិ បដិសេវាមិ វូបសន្តចិត្តោហមស្មិ ។ យេ ហិ វោ អរិយា វូបសន្តចិត្តា អរញ្ញវនបត្ថានិ បន្តានិ សេនាសនានិ បដិសេវន្តិ តេសមហំ អញ្ញតរោ ឯតមហំ ព្រាហ្មណ វូបសន្តចិត្តតំ អត្តនិ សម្បស្សមានោ ភិយ្យោ បល្លោមមាបាទឹ អរញ្ញេ វិហារាយ ។

(៣៧) តស្ស មយ្ហំ ព្រាហ្មណ ឯតទហោសិ យេ ខោ កេចិ សមណា វា ព្រាហ្មណា វា កង្ខី វិចិកិច្ឆី អរញ្ញវនបត្ថានិ បន្តានិ សេនាសនានិ បដិសេវន្តិ កង្ខីវិចិកិច្ឆីសន្ទោសហេតុ ហវេ តេ ភោន្តោ សមណព្រាហ្មណា អកុសលំ ភយភេរវំ អវ្ហាយន្តិ ។ ន ខោ បនាហំ កង្ខី វិចិកិច្ឆី អរញ្ញវនបត្ថានិ បន្តានិ សេនាសនានិ បដិសេវាមិ តិណ្ណវិចិកិច្ឆោហមស្មិ ។



ពួកសមណព្រាហ្មណ៍ដ៏ចំរើនទាំងនោះ តែងហៅអកុសលធម៌ដែលគួរភ័យគួរខ្លាច ព្រោះហេតុនៃទោសរបស់ខ្លួន ដែលមានចិត្តរវើរវាយ មានចិត្តមិនស្ងប់ស្ងាប់នោះឯង ។ ឯតថាគតមិនមានចិត្តរវើរវាយ មានចិត្តមិនស្ងប់ស្ងាប់ សេពនូវសេនាសនៈស្ងាត់ គឺទីនៅក្នុងព្រៃធំនិងព្រៃឆ្ងាយ ដូច្នោះទេ តថាគតជាអ្នកមានចិត្តស្ងប់ស្ងាប់ ។ ព្រះអរិយៈទាំងឡាយណា មានចិត្តស្ងប់ស្ងាប់ សេពនូវសេនាសនៈស្ងាត់ គឺទីនៅក្នុងព្រៃធំនិងព្រៃឆ្ងាយ បណ្ដាព្រះអរិយៈទាំងនោះ តថាគតក៏ជាព្រះអរិយៈមួយដែរ ម្នាលព្រាហ្មណ៍ តថាគតបានពិចារណាឃើញ នូវចិត្តស្ងប់ស្ងាប់នុ៎ះ ក្នុងខ្លួនហើយ ទើបដល់នូវសួស្ដីដោយច្រើន គួរនឹងនៅក្នុងព្រៃបាន ។

(៣៧) ម្នាលព្រាហ្មណ៍ តថាគតនឹងមានសេចក្ដីត្រិះរិះដូច្នេះថា ពួកសមណព្រាហ្មណ៍ណាមួយ ដែលមានសេចក្ដីសង្ស័យមិនដាច់ស្រេច សេពនូវសេនាសនៈស្ងាត់ គឺទីនៅក្នុងព្រៃធំនិងព្រៃឆ្ងាយ ពួកសមណព្រាហ្មណ៍ដ៏ចំរើនទាំងនោះ តែងហៅអកុសលធម៌ ដែលគួរភ័យគួរខ្លាច ព្រោះហេតុនៃទោសរបស់ខ្លួន ដែលមានសេចក្ដីសង្ស័យ មិនដាច់ស្រេចនោះឯង ។ ឯតថាគតមិនមានសេចក្ដីសង្ស័យ មិនដាច់ស្រេច សេពនូវសេនាសនៈស្ងាត់ គឺទីនៅក្នុងព្រៃធំ និងព្រៃឆ្ងាយ ដូច្នោះទេ តថាគតជាអ្នកឆ្លងផុត ចាកសេចក្ដីសង្ស័យ មិនដាច់ស្រេចបាន ។

យេ ហិ វោ អរិយា តិណ្ណវិចិកិច្ឆា អរញ្ញវនបត្ថានិ បន្តានិ សេនាសនានិ បដិសេវន្តិ តេសមហំ អញ្ញតរោ ឯតមហំ ព្រាហ្មណ តិណ្ណវិចិកិច្ឆតំ អត្តនិ សម្បស្សមានោ ភិយ្យោ បល្លោមមាបាទឹ អរញ្ញេ វិហារាយ ។

(៣៨) តស្ស មយ្ហំ ព្រាហ្មណ ឯតទហោសិ យេ ខោ កេចិ សមណា វា ព្រាហ្មណា វា អត្តុក្កំសកា បរវម្ភី អរញ្ញវនបត្ថានិ បន្តានិ សេនាសនានិ បដិសេវន្តិ អត្តុក្កំសនបរវម្ភនសន្ទោសហេតុ ហវេ តេ ភោន្តោ សមណព្រាហ្មណា អកុសលំ ភយភេរវំ អវ្ហាយន្តិ ។ ន ខោ បនាហំ អត្តុក្កំសកោ បរវម្ភី អរញ្ញវនបត្ថានិ បន្តានិ សេនាសនានិ បដិសេវាមិ អនត្តុក្កំសកោ អបរវម្ភីហមស្មិ ។ យេ ហិ វោ អរិយា អនត្តុក្កំសកា



ព្រះអរិយៈទាំងឡាយណា ដែលកន្លងផុតសេចក្តីសង្ស័យមិនជាប់ស្រេច សេពនូវសេនាសនៈស្ងាត់ ទាំងនៅក្នុងព្រៃនិងទីព្រៃឆ្ងាយ បណ្តាព្រះអរិយៈទាំងនោះ តថាគតក៏ជាព្រះអរិយៈមួយដែរ ម្នាលព្រាហ្មណ៍ តថាគតកាលពិចារណាឃើញនូវចិត្ត ដែលកន្លងផុតសេចក្តីសង្ស័យមិនជាប់ស្រេច ក្នុងខ្លួនហើយ ទើបដល់នូវសួស្តីដោយច្រើន ក្នុងទីនៅក្នុងព្រៃបាន ។

(៣៨) ម្នាលព្រាហ្មណ៍ តថាគត មានសេចក្តីត្រិះរិះដូច្នេះថា ពួកសមណព្រាហ្មណ៍ណាមួយ ជាអ្នកលើកតំកើងខ្លួនឯង បន្តុះបង្អាប់អ្នកដទៃ សេពនូវសេនាសនៈស្ងាត់ ទាំងនៅក្នុងព្រៃនិងទីព្រៃឆ្ងាយ សមណព្រាហ្មណ៍ដ៏ចំរើនទាំងនោះ តែងហៅអកុសលធម៌ដែលគួរភ័យគួរខ្លាច ព្រោះហេតុនៃទោសរបស់ខ្លួន ដែលលើកតំកើងខ្លួនឯង និងបន្តុះបង្អាប់អ្នកដទៃនោះឯង ។ ឯតថាគតមិនជាអ្នកលើកតំកើងខ្លួនឯង បន្តុះបង្អាប់អ្នកដទៃ សេពនូវសេនាសនៈស្ងាត់ ទាំងនៅក្នុងព្រៃនិងទីព្រៃឆ្ងាយ ដូច្នោះក៏ទេ តថាគតជាអ្នកមិនលើកតំកើងខ្លួនឯង មិនបន្តុះបង្អាប់អ្នកដទៃទេ ។ ព្រះអរិយៈទាំងឡាយណា ជាអ្នកមិនលើកតំកើងខ្លួនឯង

អបរវម្ភី អរញ្ញវនបត្ថានិ បន្តានិ សេនាសនានិ បដិសេវន្តិ តេសមហំ អញ្ញតរោ ឯតមហំ ព្រាហ្មណ អនត្តុក្កំសកតំ អបរវម្ភិតំ អត្តនិ សម្បស្សមានោ ភិយ្យោ បល្លោមមាបាទឹ អរញ្ញេ វិហារាយ ។

(៣៩) តស្ស មយ្ហំ ព្រាហ្មណ ឯតទហោសិ យេ ខោ កេចិ សមណា វា ព្រាហ្មណា វា ឆម្ភី ភីរុកជាតិកា អរញ្ញវនបត្ថានិ បន្តានិ សេនាសនានិ បដិសេវន្តិ ឆម្ភីភីរុកជាតិកសន្ទោសហេតុ ហវេ តេ ភោន្តោ សមណព្រាហ្មណា អកុសលំ ភយភេរវំ អវ្ហាយន្តិ ។ ន ខោ បនាហំ ឆម្ភី ភីរុកជាតិកោ អរញ្ញវនបត្ថានិ បន្តានិ សេនាសនានិ បដិសេវាមិ វិគតលោមហំសោហមស្មិ ។ យេ ហិ វោ អរិយា វិគតលោមហំសា អរញ្ញវនបត្ថានិ បន្តានិ សេនាសនានិ បដិសេវន្តិ



មិនបន្ទះបង្អាប់អ្នកដទៃ សេពនូវសេនាសនៈស្ងាត់ ទាំងនៅក្នុងព្រៃស្ងាត់ និងព្រៃឆ្ងាយ បណ្ដាព្រះអរិយៈទាំងនោះ តថាគតក៏ជាព្រះអរិយៈមួយដែរ ម្នាលព្រាហ្មណ៍ តថាគតឃើញច្បាស់នូវសេចក្ដីមិនលើកតំកើងខ្លួនឯង មិនបន្ទះបង្អាប់អ្នកដទៃនុ៎ះ ក្នុងខ្លួនហើយ ទើបដល់នូវសួស្ដីដោយច្រើន គួរនឹងនៅក្នុងព្រៃបាន ។

(៣៩) ម្នាលព្រាហ្មណ៍ តថាគត មានសេចក្ដីត្រិះរិះដូច្នេះថា ពួកសមណព្រាហ្មណ៍ណាមួយ ជាអ្នកតក់ស្លុត ប្រកបដោយជាតិជាអ្នកខ្លាច សេពនូវសេនាសនៈស្ងាត់ ទាំងនៅក្នុងព្រៃស្ងាត់និងព្រៃឆ្ងាយ សមណព្រាហ្មណ៍ដ៏ចំរើនទាំងនោះ តែងហៅអកុសលធម៌ដែលគួរភ័យគួរខ្លាច ព្រោះហេតុនៃទោសរបស់ខ្លួនដែលមានសេចក្ដីតក់ស្លុត និងការប្រកបដោយជាតិជាអ្នកខ្លាចនោះឯង ។ ឯតថាគតមិនមានសេចក្ដីតក់ស្លុត ប្រកបដោយជាតិជាអ្នកខ្លាច សេពនូវសេនាសនៈស្ងាត់ ទាំងនៅក្នុងព្រៃស្ងាត់និងព្រៃឆ្ងាយដូច្នោះទេ តថាគតជាអ្នកប្រាសចាកសេចក្ដីព្រឺព្រួចរោមហើយ ។ ព្រះអរិយៈទាំងឡាយណា ប្រាសចាកសេចក្ដីព្រឺព្រួចរោមហើយ សេពនូវសេនាសនៈស្ងាត់ ទាំងនៅក្នុងព្រៃស្ងាត់និងព្រៃឆ្ងាយ

តេសមហំ អញ្ញតរោ ឯតមហំ ព្រាហ្មណ វិគតលោម-ហំសតំ អត្តនិ សម្បស្សមានោ ភិយ្យោ បល្លោមមា-បាទឹ អរញ្ញេ វិហារាយ ។

(៤០) តស្ស មយ្ហំ ព្រាហ្មណ ឯតទហោសិ យេ ខោ កេចិ សមណា វា ព្រាហ្មណា វា លាភសក្ការ-សិលោកំ និកាមយមានា អរញ្ញវនបត្ថានិ បន្តានិ សេនាសនានិ បដិសេវន្តិ លាភសក្ការសិលោកនិ-កាមយមានសន្ទោសហេតុ ហវេ តេ ភោន្តោ សម-ណព្រាហ្មណា អកុសលំ ភយភេរវំ អវ្ហាយន្តិ ។ ន ខោ បនាហំ លាភសក្ការសិលោកំ និកាមយមា-នោ អរញ្ញវនបត្ថានិ បន្តានិ សេនាសនានិ បដិសេវាមិ អប្បិច្ឆោហមស្មិ ។ យេ ហិ វោ អរិយា អប្បិច្ឆា



បណ្តាព្រះអរិយៈទាំងនោះ តថាគតក៏ជាព្រះអរិយៈមួយដែរ ម្នាលព្រាហ្មណ៍ តថាគតពិចារណាឃើញ នូវការប្រាសចាកសេចក្តីព្រឺព្រួចរោមនុ៎ះ ក្នុងខ្លួនហើយ ទើបដល់នូវសួស្តីដោយច្រើន ក្នុងទីនៅក្នុងព្រៃផ្ទាន ។

(៤០) ម្នាលព្រាហ្មណ៍ តថាគតមានសេចក្តីត្រិះរិះដូច្នេះថា ពួកសមណព្រាហ្មណ៍ណាមួយ ដែលត្រូវការចង់បានលាភសក្ការៈ[១] និងសេចក្តីសរសើរ[២] សេពនូវសេនាសនៈស្ងាត់ ទាំងនៅក្នុងព្រៃធំនិងព្រៃឆ្ងាយ សមណព្រាហ្មណ៍ដ៏ចំរើនទាំងនោះ រមែងហៅអកុសលភ័យដែលគួរភ័យគួរខ្លាច ព្រោះហេតុនៃទោសរបស់ខ្លួន ដែលត្រូវការចង់បានលាភសក្ការៈនិងសេចក្តីសរសើរនោះឯង ។ ឯតថាគតមិនត្រូវការចង់បានលាភសក្ការៈនិងសេចក្តីសរសើរ សេពនូវសេនាសនៈស្ងាត់ទាំងនៅក្នុងព្រៃធំនិងព្រៃឆ្ងាយដូច្នោះទេ តថាគតជាអ្នកមានសេចក្តីប្រាថ្នាតិច ។ ព្រះអរិយៈទាំងឡាយណា ដែលមានសេចក្តីប្រាថ្នាតិច សេពនូវ

---

១ ត្រង់ដែលថា លាភៈនិងសក្ការៈ គឺបានដល់បច្ច័យទាំង ៤ មានចីវរបច្ច័យជាដើម ឬបានដល់របស់ផ្សេងៗ មានសំពត់អាវជាដើម ។ សក្ការៈបានដល់បច្ច័យនិងរបស់ទាំងអស់នោះ ដែលគេតាក់តែងធ្វើឲ្យល្អវិសេសបន្ទុះជារបស់មានតំលៃ ។ ២ ត្រង់ដែលថាសរសើរ គឺនិយាយសរសើរគុណ ។ អដ្ឋកថា ។

អរញ្ញវនបត្ថានិ បន្តានិ សេនាសនានិ បដិសេវន្តិ តេសមហំ អញ្ញតរោ ឯតមហំ ព្រាហ្មណ អប្បិច្ឆតំ អត្តនិ សម្បស្សមានោ ភិយ្យោ បល្លោមមាបាទឹ អរញ្ញេ វិហារាយ ។

(៤៧) តស្ស មយ្ហំ ព្រាហ្មណ ឯតទហោសិ យេ ខោ កេចិ សមណា វា ព្រាហ្មណា វា កុសីតា ហីនវីរិយា អរញ្ញវនបត្ថានិ បន្តានិ សេនាសនានិ បដិសេវន្តិ កុសីតហីនវីរិយសន្ទោសហេតុ ហវេ តេ ភោន្តោ សមណព្រាហ្មណា អកុសលំ ភយភេរវំ អវ្ហាយន្តិ ។ ន ខោ បនាហំ កុសីតោ ហីនវីរិយោ អរញ្ញវនបត្ថានិ បន្តានិ សេនាសនានិ បដិសេវាមិ អារទ្ធវីរិយោហមស្មិ ។ យេ ហិ វោ អរិយា អារទ្ធវីរិយា អរញ្ញវនបត្ថានិ បន្តានិ សេនាសនានិ បដិសេវន្តិ តេសមហំ អញ្ញតរោ ឯតមហំ ព្រាហ្មណ អារទ្ធវីរិយតំ អត្តនិ សម្បស្សមានោ ភិយ្យោ បល្លោមមាបាទឹ អរញ្ញេ វិហារាយ ។



សេនាសនៈស្ងាត់តាំងនៅក្នុងព្រៃផងនឹងព្រៃឆ្ងាយ បណ្តាព្រះអរិយៈទាំងនោះ តថាគតក៏ជាព្រះអរិយៈមួយដែរ ម្នាលព្រាហ្មណ៍ តថាគតបានពិចារណាឃើញសេចក្តីប្រាថ្នាតិចនុ៎ះ ក្នុងខ្លួនហើយ ទើបដល់នូវសួស្តីដោយច្រើន គួរនឹងនៅក្នុងព្រៃបាន ។

(៤៧) ម្នាលព្រាហ្មណ៍ តថាគតមានសេចក្តីត្រិះរិះដូច្នេះថា ពួកសមណព្រាហ្មណ៍ណាមួយ ជាអ្នកខ្ជិល[១] ច្រអូស មិនមានព្យាយាម[២] សេពនូវសេនាសនៈស្ងាត់ តាំងនៅក្នុងព្រៃផងនឹងព្រៃឆ្ងាយ សមណព្រាហ្មណ៍ដ៏ចំរើនទាំងនោះ តែងហៅអកុសលធម៌ដែលគួរភ័យគួរខ្លាច ព្រោះហេតុនៃទោសរបស់ខ្លួនដែលមានសេចក្តីខ្ជិលច្រអូសនឹងគ្មានព្យាយាមនោះឯង ។ ឯតថាគតមិនដែលជាអ្នកខ្ជិលច្រអូសមិនមានព្យាយាមសេពនូវសេនាសនៈស្ងាត់តាំងនៅក្នុងព្រៃផងនឹងព្រៃឆ្ងាយដូច្នោះទេ តថាគតជាអ្នកមានព្យាយាមប្រារព្ធហើយ ។ ព្រះអរិយៈទាំងឡាយណា ដែលមានព្យាយាមប្រារព្ធហើយ សេពនូវសេនាសនៈស្ងាត់តាំងនៅក្នុងព្រៃផងនឹងព្រៃឆ្ងាយ បណ្តាព្រះអរិយៈទាំងនោះ តថាគតក៏ជាព្រះអរិយៈមួយដែរ ម្នាលព្រាហ្មណ៍ តថាគតបានពិចារណាឃើញនូវសេចក្តីព្យាយាម ដែលប្រារព្ធហើយនុ៎ះ ក្នុងខ្លួនហើយ ទើបដល់នូវសួស្តីដោយច្រើន គួរនឹងនៅក្នុងព្រៃបាន ។

---

១ ត្រង់ដែលថា ខ្ជិល បានដល់បុគ្គលដែលមិនប្រារព្ធព្យាយាមក្នុងផ្លូវកាយ ។ ២ ត្រង់ដែលថា មិនព្យាយាម បានដល់បុគ្គលដែលមិនប្រារព្ធព្យាយាមក្នុងផ្លូវចិត្ត ។

[៤២] តស្ស មយ្ហំ ព្រាហ្មណ ឯតទហោសិ យេ ខោ កេចិ សមណា វា ព្រាហ្មណា វា មុដ្ឋស្សតី អសម្បជានា អរញ្ញវនបត្ថានិ បន្តានិ សេនាសនានិ បដិសេវន្តិ មុដ្ឋស្សតិអសម្បជានសន្ទោសហេតុ ហវេ តេ ភោន្តោ សមណព្រាហ្មណា អកុសលំ ភយភេរវំ អវ្ហាយន្តិ ។ ន ខោ បនាហំ មុដ្ឋស្សតិ អសម្បជានោ អរញ្ញវនបត្ថានិ បន្តានិ សេនាសនានិ បដិសេវាមិ ឧបដ្ឋិតស្សតិហមស្មិ ។ យេ ហិ វោ អរិយា ឧបដ្ឋិតស្សតី អរញ្ញវនបត្ថានិ បន្តានិ សេនាសនានិ បដិសេវន្តិ តេសមហំ អញ្ញតរោ ឯតមហំ ព្រាហ្មណ ឧបដ្ឋិតស្សតិតំ អត្តនិ សម្បស្សមានោ ភិយ្យោ បល្លោមមាបាទឹ អរញ្ញេ វិហារាយ ។

[៤៣] តស្ស មយ្ហំ ព្រាហ្មណ ឯតទហោសិ យេ ខោ កេចិ សមណា វា ព្រាហ្មណា វា អសមាហិតា វិព្ភន្តចិត្តា អរញ្ញវនបត្ថានិ បន្តានិ សេនាសនានិ បដិសេវន្តិ



[៤២] ម្នាលព្រាហ្មណ៍ តថាគតមានសេចក្តីត្រិះរិះដូច្នេះថា ពួកសមណព្រាហ្មណ៍ណាមួយ ជាអ្នកភ្លេចស្មារតី មិនដឹងខ្លួន (ប្រាសចាកបញ្ញា) សេពនូវសេនាសនៈស្ងាត់ គឺទីនៅក្នុងព្រៃផង ទីព្រៃឆ្ងាយ ពួកសមណព្រាហ្មណ៍ដ៏ចំរើនទាំងនោះ តែងហៅអកុសលធម៌ដែលគួរភ័យ គួរខ្លាច ព្រោះហេតុនៃទោសរបស់ខ្លួនដែលភ្លេចស្មារតី មិនដឹងខ្លួននោះឯង ។ ឯតថាគតមិនជាអ្នកភ្លេចស្មារតី មិនដឹងខ្លួន សេពនូវសេនាសនៈស្ងាត់ គឺទីនៅក្នុងព្រៃផង ទីព្រៃឆ្ងាយដូច្នោះទេ តថាគតជាអ្នកមានស្មារតីតំកល់មាំ ។ ព្រះអរិយៈទាំងឡាយណា ជាអ្នកមានស្មារតីតំកល់មាំ សេពនូវសេនាសនៈស្ងាត់ គឺទីនៅក្នុងព្រៃផង ទីព្រៃឆ្ងាយ បណ្តាព្រះអរិយៈទាំងនោះ តថាគតក៏ជាព្រះអរិយៈម្នាក់ដែរ ម្នាលព្រាហ្មណ៍ តថាគតបានពិចារណាឃើញនូវការតំកល់ស្មារតីមាំនុ៎ះ ក្នុងខ្លួនហើយ ទើបដល់នូវសួស្តីដោយច្រើន គួរនឹងនៅក្នុងព្រៃបាន ។

[៤៣] ម្នាលព្រាហ្មណ៍ តថាគតមានសេចក្តីត្រិះរិះដូច្នេះថា ពួកសមណព្រាហ្មណ៍ណាមួយ មានចិត្តមិនតំកល់មាំ (ប្រាសចាកឧបចារសមាធិនិងអប្បនាសមាធិ) មានចិត្តវិលវល់ សេពនូវសេនាសនៈស្ងាត់

អសមាហិតវិព្ភន្តចិត្តសន្ទោសហេតុ ហវេ តេ ភោន្តោ សមណព្រាហ្មណា អកុសលំ ភយភេរវំ អវ្ហាយន្តិ ។ ន ខោ បនាហំ អសមាហិតោ វិព្ភន្តចិត្តោ អរញ្ញវនបត្ថានិ បន្តានិ សេនាសនានិ បដិសេវាមិ សមាធិសម្បន្នោហមស្មិ ។ យេ ហិ វោ អរិយា សមាធិសម្បន្នា អរញ្ញវនបត្ថានិ បន្តានិ សេនាសនានិ បដិសេវន្តិ តេសមហំ អញ្ញតរោ ឯតមហំ ព្រាហ្មណ សមាធិសម្បទំ អត្តនិ សម្បស្សមានោ ភិយ្យោ បល្លោមមាបាទឹ អរញ្ញេ វិហារាយ ។

(៦៦) តស្ស មយ្ហំ ព្រាហ្មណ ឯតទហោសិ យេ ខោ កេចិ សមណា វា ព្រាហ្មណា វា ទុប្បញ្ញា ឯឡមូគា អរញ្ញវនបត្ថានិ បន្តានិ សេនាសនានិ បដិ-សេវន្តិ ទុប្បញ្ញឯឡមូគសន្ទោសហេតុ ហវេ តេ ភោន្តោ សមណព្រាហ្មណា អកុសលំ ភយភេរវំ អវ្ហាយន្តិ ។



តាំងនៅក្នុងព្រៃជិតនិងព្រៃឆ្ងាយ ពួកសមណព្រាហ្មណ៍ដ៏ចំរើនទាំងនោះ តែងហៅអកុសលធម៌ ដែលគួរភ័យគួរខ្លាច ព្រោះហេតុនៃទោសរបស់ខ្លួន ដែលមានចិត្តមិនតំកល់មាំនិងចិត្តវិលវល់នោះឯង ។ ឯតថាគតមិនមានចិត្តមិនតំកល់មាំ មានចិត្តវិលវល់ សេពនូវសេនាសនៈស្ងាត់ តាំងនៅក្នុងព្រៃជិតនិងព្រៃឆ្ងាយដូច្នោះក៏ទេ តថាគតជាអ្នកមានសមាធិបរិបូណ៌ ។ ព្រះអរិយៈទាំងឡាយណា ដែលមានសមាធិបរិបូណ៌ សេពនូវសេនាសនៈស្ងាត់ តាំងនៅក្នុងព្រៃជិតនិងព្រៃឆ្ងាយ បណ្ដាព្រះអរិយៈទាំងនោះ តថាគតក៏ជាព្រះអរិយៈមួយដែរ ម្នាលព្រាហ្មណ៍ តថាគតលុះពិចារណាឃើញសមាធិសម្បទានុ៎ះ ក្នុងខ្លួនហើយ ទើបដល់នូវសេចក្ដីស្រួលក្រៃលែងច្រើន គួរនឹងនៅក្នុងព្រៃបាន ។

(៦៦) ម្នាលព្រាហ្មណ៍ តថាគតមានសេចក្ដីត្រិះរិះដូច្នេះថា ពួកសមណព្រាហ្មណ៍ណាមួយ ជាអ្នកឥតប្រាជ្ញា ល្ងង់លេលា សេពនូវសេនាសនៈស្ងាត់តាំងនៅក្នុងព្រៃជិតនិងព្រៃឆ្ងាយ ពួកសមណព្រាហ្មណ៍ដ៏ចំរើនទាំងនោះ តែងហៅអកុសលធម៌ ដែលគួរភ័យគួរខ្លាច ព្រោះហេតុនៃទោសរបស់ខ្លួន ដែលឥតប្រាជ្ញា ល្ងង់លេលានោះឯង ។

ន ខោ បនាហំ ទុប្បញ្ញោ ឯឡមូគោ អរញ្ញវន-
បត្ថានិ បន្តានិ សេនាសនានិ បដិសេវាមិ បញ្ញា-
សម្បន្នោហមស្មិ ។ យេ ហិ វោ អរិយា
បញ្ញាសម្បន្នា អរញ្ញវនបត្ថានិ បន្តានិ សេនាសនានិ
បដិសេវន្តិ តេសមហំ អញ្ញតរោ ឯតមហំ ព្រាហ្មណ
បញ្ញាសម្បទំ អត្តនិ សម្បស្សមានោ ភិយ្យោ
បល្លោមមាបាទឹ អរញ្ញេ វិហារាយ ។

សោឡសបរិយាយំ និដ្ឋិតំ ។

(៤៨) តស្ស មយ្ហំ ព្រាហ្មណ ឯតទហោសិ
យន្នូនាហំ យា តា រត្តិយោ អភិញ្ញាតា អភិលក្ខិតា
ចាតុទ្ទសី បញ្ចទសី អដ្ឋមី ច បក្ខស្ស តថារូបាសុ
រត្តីសុ យានិ តានិ អារាមចេតិយានិ វនចេតិ-
យានិ រុក្ខចេតិយានិ ភឹសនកានិ សលោមហំសានិ



ឯតថាគតមិនមែនជាអ្នកអប្បឥតប្រាជ្ញា ល្ងង់លេលា សេពនូវសេនាសនៈ
ស្ងាត់ ទាំងនៅក្នុងព្រៃធំនិងទីនៅព្រៃឆ្ងាយដូច្នោះទេ តថាគតជាអ្នកបរិបូណ៌
ដោយប្រាជ្ញា ។ ព្រះអរិយៈទាំងឡាយណា ដែលបរិបូណ៌ដោយប្រាជ្ញា
សេពនូវសេនាសនៈស្ងាត់ ទាំងនៅក្នុងព្រៃធំនិងទីនៅព្រៃឆ្ងាយ បណ្ដា
ព្រះអរិយៈទាំងនោះ តថាគតក៏ជាព្រះអរិយៈមួយដែរ ម្នាលព្រាហ្មណ៍
តថាគតបានពិចារណាឃើញបញ្ញាសម្បទានុ៎ះ ក្នុងខ្លួនហើយ ទើបដល់
នូវសួស្ដីដោយច្រើន ក្នុងទីនៅក្នុងព្រៃបាន ។

ចប់ បរិយាយ ១៦ ។

(៤៨) ម្នាលព្រាហ្មណ៍ តថាគត មានសេចក្ដីត្រិះរិះដូច្នេះថា
រាត្រីទាំងឡាយណា ដែលគេដឹងច្បាស់ ដែលគេកំណត់ដឹងជាដាច់ថា
ទី ១៤ ទី ១៥ ទី ៨ នៃបក្ស បើដូច្នេះមានអញ គួរនៅក្នុងអារាមចេតិយ
វនចេតិយ រុក្ខចេតិយទាំងឡាយដែលគួរភ័យ គួរក្ដុក គួរឲ្យព្រឺព្រួចរោម

តថារូបេសុ សេនាសនេសុ វិហរេយ្យំ ។ អប្បេវនាម តំ ភយភេរវំ បស្សេយ្យន្តិ ។ សោ ខោ អហំ ព្រាហ្មណ អបរេន សមយេន យា តា រត្តិយោ អភិញ្ញាតា អភិលក្ខិតា ចាតុទ្ទសី បញ្ចទសី អដ្ឋមី ច បក្ខស្ស តថារូបាសុ រត្តីសុ យានិ តានិ អារាមចេតិយានិ វនចេតិយានិ រុក្ខចេតិយានិ ភឹសនកានិ សលោមហំសានិ តថារូបេសុ សេនាសនេសុ វិហរាមិ ។ តត្ថ ច មេ ព្រាហ្មណ វិហរតោ មិគោ វា អាគច្ឆតិ មោរោ វា កដ្ឋំ បាតេតិ វាតោ វា បណ្ណកសដំ(១) ឯរេតិ ។ តស្ស មយ្ហំ ព្រាហ្មណ ឯវំ ហោតិ ឯតំ នូន តំ ភយភេរវំ អាគច្ឆតីតិ ។ តស្ស មយ្ហំ ព្រាហ្មណ ឯតទហោសិ កិន្នុ ខោ អហំ អញ្ញទត្ថុ ភយបដិកង្ខី វិហរាមិ យន្នូនាហំ យថាភូតស្ស(២) យថាភូតស្ស មេ តំ ភយភេរវំ អាគច្ឆតិ តថាភូតោ(៣) តថាភូតោវ តំ ភយភេរវំ បដិវិនេយ្យន្តិ ។ តស្ស មយ្ហំ ព្រាហ្មណ ចង្កមន្តស្ស

១ ឱ. បណ្ណសដំ ។ ម. បណ្ណសង្កដំ ។ ២ ឱ. ម. យថាភូតំ ។ ៣ ឱ. ម.



ក្នុងរាត្រីទាំងឡាយមានសភាពដូច្នោះ ។ ធ្វើម្តេចតថាគតគប្បីឃើញភ័យនិងសេចក្តីស្ញើបនោះបាន ។ ម្នាលព្រាហ្មណ៍ លុះសម័យមកខាងក្រោយ រាត្រីទាំងឡាយណាដែលគេដឹងច្បាស់ ដែលគេកំណត់ដឹងថា ជាតិថី ទី១៤ ទី១៥ ទី៨ នៃបក្ស តថាគតក៏នៅក្នុងអារាមចេតិយ វនចេតិយ រុក្ខចេតិយទាំងឡាយដែលគួរស្ញែងខ្លាច គួរឲ្យព្រឺព្រួចរោម ក្នុងរាត្រីទាំងឡាយមានសភាពដូច្នោះ ម្នាលព្រាហ្មណ៍ កាលតថាគតនៅក្នុងទីនោះ ម្រឹគក៏មកខ្លះ ក្ងោកក៏បាក់មែកឈើឲ្យធ្លាក់ចុះខ្លះ ខ្យល់ក៏បក់ផាត់ស្លឹកឈើនិងសម្រាមមកខ្លះ ។ ម្នាលព្រាហ្មណ៍ តថាគតក៏មានសេចក្តីត្រិះរិះដូច្នេះថា ភ័យនិងសេចក្តីស្ញើបនោះមកដល់ (តថាគត) ដែរហើយតើ ។ ម្នាលព្រាហ្មណ៍ តថាគតមានសេចក្តីត្រិះរិះដូច្នេះថា អាត្មាអញជាអ្នកប្រាថ្នានូវភ័យ ដោយចំណែកមួយឬអ្វីហ្ន៎ ភ័យនិងសេចក្តីស្ញើបនោះមកដល់អាត្មាអញ ដែលសម្រេចឥរិយាបថណា ។ អាត្មាអញនឹងមិនផ្លាស់ឥរិយាបថនោះ ។ ដោយគិត ត្រូវតែបន្ទោបង់នូវភ័យនិងសេចក្តីស្ញើបនោះចេញ ។ ម្នាលព្រាហ្មណ៍ តថាគតកំពុងចង្រ្កម ក៏ស្រាប់តែ

តំ ភយភេរវំ អាគច្ឆតិ ។ សោ ខោ អហំ ព្រាហ្មណ នេវ តាវ តិដ្ឋាមិ ន និសីទាមិ ន និបជ្ជាមិ យាវ ចង្កមន្តោវ តំ ភយភេរវំ បដិវិនេមិ ។ តស្ស មយ្ហំ ព្រាហ្មណ ឋិតស្ស តំ ភយភេរវំ អាគច្ឆតិ ។ សោ ខោ អហំ ព្រាហ្មណ នេវ តាវ ចង្កមាមិ ន និសីទាមិ ន និបជ្ជាមិ យាវ ឋិតោវ តំ ភយភេរវំ បដិវិនេមិ ។ តស្ស មយ្ហំ ព្រាហ្មណ និសិន្នស្ស តំ ភយភេរវំ អាគច្ឆតិ ។ សោ ខោ អហំ ព្រាហ្មណ នេវ តាវ និបជ្ជាមិ ន តិដ្ឋាមិ ន ចង្កមាមិ យាវ និសិន្នោវ តំ ភយភេរវំ បដិវិនេមិ ។ តស្ស មយ្ហំ ព្រាហ្មណ និបន្នស្ស តំ ភយភេរវំ អាគច្ឆតិ ។ សោ ខោ អហំ ព្រាហ្មណ នេវ តាវ និសីទាមិ ន តិដ្ឋាមិ ន ចង្កមាមិ យាវ និបន្នោវ តំ ភយភេរវំ បដិវិនេមិ ។



មានភ័យនឹងសេចក្ដីស្ញើបនោះមកដល់ ។ ម្នាលព្រាហ្មណ៍ តថាគតក៏មិនឈរមិនអង្គុយមិនដេកសោះ ខំចង្ក្រមដរាបទាល់តែបន្ទោបង់ភ័យនឹងសេចក្ដីស្ញើបនោះបាន ។ ម្នាលព្រាហ្មណ៍ កាលតថាគត កំពុងឈរក៏ស្រាប់តែមានភ័យនឹងសេចក្ដីស្ញើបនោះមកដល់ ។ ម្នាលព្រាហ្មណ៍ តថាគតក៏មិនចង្ក្រម មិនអង្គុយ មិនដេក ប្រឹងឈរដរាបទាល់តែបន្ទោបង់នូវភ័យនឹងសេចក្ដីស្ញើបនោះបាន ។ ម្នាលព្រាហ្មណ៍ កាលតថាគត កំពុងអង្គុយ ក៏ស្រាប់តែមានភ័យនឹងសេចក្ដីស្ញើបនោះមកដល់ ។ ម្នាលព្រាហ្មណ៍ តថាគតក៏មិនដេក មិនឈរ មិនចង្ក្រមសោះ ប្រឹងអង្គុយដរាបទាល់តែបន្ទោបង់ភ័យនឹងសេចក្ដីស្ញើបនោះបាន ។ ម្នាលព្រាហ្មណ៍ កាលតថាគតកំពុងដេកក៏ស្រាប់តែមានភ័យ នឹងសេចក្ដីស្ញើបនោះមកដល់ ។ ម្នាលព្រាហ្មណ៍ តថាគតក៏មិនអង្គុយ មិនឈរ មិនចង្ក្រមសោះ ប្រឹងដេកដរាបទាល់តែបន្ទោបង់ភ័យ នឹងសេចក្ដីស្ញើបនោះបាន ។

(៤៦) សន្តិ ខោ បន ព្រាហ្មណ ឯកេ សមណព្រាហ្មណា រត្តិំយេវ សមានំ ទិវាតិ សញ្ជានន្តិ ទិវាយេវ សមានំ រត្តីតិ សញ្ជានន្តិ ឥទមហំ តេសំ សមណព្រាហ្មណានំ សម្មោហវិហារស្មិំ វទាមិ ។ អហំ ខោ បន ព្រាហ្មណ រត្តិំយេវ សមានំ រត្តីតិ សញ្ជានាមិ ទិវាយេវ សមានំ ទិវាតិ សញ្ជានាមិ ។ យំ ខោ តំ ព្រាហ្មណ សម្មា វទមានោ វទេយ្យ អសម្មោហធម្មោ សត្តោ លោកេ ឧប្បន្នោ ពហុជនហិតាយ ពហុជនសុខាយ លោកានុកម្បាយ[១] អត្ថាយ ហិតាយ សុខាយ ទេវមនុស្សានន្តិ ។ មមេវ តំ សម្មា វទមានោ វទេយ្យ អសម្មោហធម្មោ សត្តោ លោកេ ឧប្បន្នោ ពហុជនហិតាយ ពហុជនសុខាយ លោកានុកម្បាយ អត្ថាយ ហិតាយ សុខាយ ទេវមនុស្សានន្តិ ។

(៤៧) អារទ្ធំ ខោ បន មេ ព្រាហ្មណ វីរិយំ អហោសិ អសល្លីនំ ឧបដ្ឋិតា សតិ អប្បម្មុដ្ឋា[២] បស្សទ្ធោ កាយោ អសារទ្ធោ សមាហិតំ ចិត្តំ

១ ឱ. ម. លោកានុកម្បាយ ។ ២ ឱ. អសម្មុដ្ឋា ។ ម. អសំមុដ្ឋា ។



(៤៦) ម្នាលព្រាហ្មណ៍ មានសមណព្រាហ្មណ៍ ១ ពួក សំគាល់យប់ថាជាថ្ងៃ សំគាល់ថ្ងៃថាជាយប់ តថាគតពោលថាការសំគាល់នេះរបស់ពួកសមណព្រាហ្មណ៍ទាំងនោះ ជាការនៅវង្វេងកាន់ស្មារតីទៅ ឡើយ ។ ម្នាលព្រាហ្មណ៍ ចំណែកខាងតថាគតដឹងច្បាស់នូវយប់ថាជាយប់មែន ដឹងច្បាស់នូវថ្ងៃថាជាថ្ងៃមែន ។ ម្នាលព្រាហ្មណ៍ ដំណើរនោះមានទំនងគួរឲ្យអ្នកផងនិយាយថា សត្វដែលមានសភាពមិនវង្វេងកើតហើយក្នុងលោក ដើម្បីប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីសេចក្តីចំរើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខដល់ទេវតានិងមនុស្សទាំងឡាយ ។ ដំណើរនោះ មានទំនងគួរឲ្យអ្នកផងនិយាយចំពោះតថាគតថា សត្វដែលមានសភាពមិនវង្វេងកើតឡើងហើយក្នុងលោក ដើម្បីប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីសេចក្តីចំរើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់ទេវតានិងមនុស្សទាំងឡាយ ។

(៤៧) ម្នាលព្រាហ្មណ៍ តថាគត បានផ្តើមសេចក្តីព្យាយាម មិនបន្ធូរបន្ថយឡើយ តាំងស្មារតីជាគតក៏ប្រុងប្រយ័ត្ន មិនឲ្យមានភ្លាត់ កាយសោតក៏ស្ងប់រម្ងាប់ មិនក្រវល់ក្រវាយ ចិត្តក៏នឹងល្អ ជាចិត្ត

បក្កន្តំ ។ សោ ខោ អហំ ព្រាហ្មណ វិវិច្ចេវ កាមេហិ វិវិច្ច អកុសលេហិ ធម្មេហិ សវិតក្កំ សវិចារំ វិវេកជំ បីតិសុខំ បឋមំ ឈានំ ឧបសម្បជ្ជ វិហាសិំ វិតក្កវិចារានំ វូបសមា អជ្ឈត្តំ សម្បសាទនំ ចេតសោ ឯកោទិភាវំ អវិតក្កំ អវិចារំ សមាធិជំ បីតិសុខំ ទុតិយំ ឈានំ ឧបសម្បជ្ជ វិហាសិំ បីតិយា ច វិរាគា ឧបេក្ខកោ ច វិហាសិំ សតោ ច សម្បជានោ សុខញ្ច កាយេន បដិសំវេទេសិំ យន្តំ អរិយា អាចិក្ខន្តិ ឧបេក្ខកោ សតិមា សុខវិហារីតិ តតិយំ ឈានំ ឧបសម្បជ្ជ វិហាសិំ សុខស្ស ច បហានា ទុក្ខស្ស ច បហានា បុព្វេវ សោមនស្សទោមនស្សានំ អត្ថង្គមា អទុក្ខមសុខំ ឧបេក្ខាសតិបារិសុទ្ធិំ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហាសិំ ។



មានអារម្មណ៍មូលតែមួយ ។ ម្នាលព្រាហ្មណ៍ តថាគតឯង លុះប្រាកដជាស្ងាត់ចាកកាមទាំងឡាយ ប្រាកដជាស្ងាត់ចាកធម៌ទាំងឡាយជាអកុសលហើយ ក៏ចូលបឋមជ្ឈាន ដែលប្រកបដោយវិតក្កៈវិចារៈ មានបីតិនិងសុខៈ ដែលកើតអំពីសេចក្ដីស្ងប់ស្ងាត់ជាអារម្មណ៍ លុះរម្ងាប់វិតក្កៈវិចារៈហើយ ក៏បានចូលដល់ទុតិយជ្ឈានជាទីផូរផង់ ប្រព្រឹត្តទៅខាងក្នុង ដ៏ញុំាងចិត្តជាសមាធិឲ្យចំរើនឡើង គ្មានវិតក្កៈវិចារៈទេ មានតែបីតិនិងសុខៈដែលកើតអំពីសមាធិ លុះលះបង់បីតិចេញហើយ តថាគតជាបុគ្គលព្រងើយ មានសតិនិងសេចក្ដីដឹងច្បាស់ តថាគតសោយសុខដោយនាមកាយផង អរិយបុគ្គលទាំងឡាយ តែងសរសើរនូវបុគ្គលដែលបានតតិយជ្ឈាននោះណា ថាជាបុគ្គលមានចិត្តព្រងើយ ជាអ្នកមានស្មារតី មានប្រក្រតីនៅជាសុខ តថាគតក៏បានដល់នូវតតិយជ្ឈាននោះហើយ ព្រោះលះបង់នូវសេចក្ដីសុខផង ព្រោះលះបង់នូវសេចក្ដីទុក្ខផង ព្រោះរំលត់នូវសោមនស្សនិងទោមនស្សអំពីមុនផង តថាគតបានចូលដល់ចតុត្ថជ្ឈានឥតទុក្ខឥតសុខ មានសតិដ៏ស្អាតដោយឧបេក្ខា ។

[៤៨] សោ ឯវំ សមាហិតេ ចិត្តេ បរិសុទ្ធេ បរិយោទាតេ អនង្គណេ វិគតូបក្កិលេសេ មុទុភូតេ កម្មនិយេ ឋិតេ អានេញ្ជប្បត្តេ(១) បុព្វេនិវាសានុស្សតិញ្ញាណាយ ចិត្តំ អភិនិន្នាមេសឹ ។ សោ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរាមិ សេយ្យថីទំ ឯកម្បិ ជាតឹ ទ្វេបិ ជាតិយោ តិស្សោបិ ជាតិយោ ចតស្សោបិ ជាតិយោ បញ្ចបិ ជាតិយោ ទសបិ ជាតិយោ វីសម្បិ ជាតិយោ តឹសម្បិ ជាតិយោ ចត្តាឡីសម្បិ ជាតិយោ បញ្ញាសម្បិ ជាតិយោ ជាតិសតម្បិ ជាតិសហស្សម្បិ ជាតិសតសហស្សម្បិ អនេកេបិ សំវដ្ដកប្បេ អនេកេបិ វិវដ្ដកប្បេ អនេកេបិ សំវដ្ដវិវដ្ដកប្បេ អមុត្រាសឹ ឯវំនាមោ ឯវំគោត្តោ ឯវំវណ្ណោ ឯវមាហារោ ឯវំសុខទុក្ខប្បដិសំវេទី ឯវមាយុបរិយន្តោ សោ តតោ ចុតោ អមុត្រ ឧទបាទឹ តត្រាបាសឹ ឯវំនាមោ ឯវំគោត្តោ ឯវំវណ្ណោ ឯវមាហារោ ឯវំសុខទុក្ខប្បដិសំវេទី

១ ម. អានេញ្ជប្បត្តេ ។



[៤៨] កាលដែលចិត្តខ្ជាប់ខ្ជួន បរិសុទ្ធ ផូរផង់ មិនមានកិលេស ប្រាសចាកសេចក្តីសៅហ្មង ជាចិត្តទន់ សមគួរដល់កម្ម ជាចិត្តនឹងធឹង មិនញាប់ញ័រ យ៉ាងនេះហើយ តថាគត ក៏បានបង្អោនចិត្តទៅក្នុងបុព្វេនិវាសានុស្សតិញ្ញាណ (ប្រាជ្ញាជាគ្រឿងរលឹកជាតិ ដែលអាស្រ័យនៅពីមុន) ។ តថាគតនោះ រលឹកជាតិដែលបានអាស្រ័យនៅ អំពីមុន ជាអនេកជាតិ រលឹកជាតិបានដូចម្តេច គឺរលឹកបាន ១ ជាតិ ២ ជាតិ ៣ ជាតិ ៤ ជាតិ ៥ ជាតិ ១០ ជាតិ ២០ ជាតិ ៣០ ជាតិ ៤០ ជាតិ ៥០ ជាតិ ១០០ ជាតិ ១ ពាន់ជាតិ ១ សែនជាតិ ក៏បាន រលឹកបានច្រើនសំវដ្តកប្ប ច្រើនវិវដ្តកប្ប ច្រើនសំវដ្តវិវដ្តកប្ប ក៏បាន ដូច្នេះថា តថាគតបានកើត ក្នុងភពឯនោះ មានឈ្មោះ យ៉ាងនេះ មានគោត្រ យ៉ាងនេះ មានសម្បុរ យ៉ាងនេះ មានអាហារ យ៉ាងនេះ បានសោយសុខទុក្ខ យ៉ាងនេះ មានកំណត់អាយុប៉ុណ្ណេះ តថាគត ច្យុតចាកអត្តភាពនោះ ហើយបានទៅកើត ក្នុងភពឯនោះ ដែលទៅកើតក្នុងភពនោះ តថាគតក៏មានឈ្មោះយ៉ាងនេះ មានគោត្រយ៉ាងនេះ មានសម្បុរយ៉ាងនេះ មានអាហារយ៉ាងនេះ បានសោយសុខទុក្ខយ៉ាងនេះ

ឯវមាយុបរិយន្តោ សោ តតោ ចុតោ ឥធូបបន្នោតិ ។ ឥតិ សាការំ សឧទ្ទេសំ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរាមិ ។ អយំ ខោ មេ ព្រាហ្មណ រត្តិយា បឋមេ យាមេ បឋមា វិជ្ជា អធិគតា អវិជ្ជា វិហតា វិជ្ជា ឧប្បន្នា តមោ វិហតោ អាលោកោ ឧប្បន្នោ យថាតំ អប្បមត្តស្ស អាតាបិនោ បហិតត្តស្ស វិហរតោ ។

(៤៩) សោ ឯវំ សមាហិតេ ចិត្តេ បរិសុទ្ធេ បរិយោទាតេ អនង្គណេ វិគតូបក្កិលេសេ មុទុភូតេ កម្មនិយេ ឋិតេ អានេញ្ជប្បត្តេ សត្តានំ ចុតូបបាតញាណាយ ចិត្តំ អភិនិន្នាមេសឹ ។ សោ ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន សត្តេ បស្សាមិ ចវមានេ ឧបបជ្ជមានេ ហីនេ បណីតេ សុវណ្ណេ ទុព្វណ្ណេ សុគតេ ទុគ្គតេ



មានកំណត់អាយុប៉ុណ្ណេះ តថាគតច្យុតចាកអត្តភាពនោះហើយ មកកើតក្នុងភពនេះ ។ តថាគតរលឹកឃើញនូវជាតិដែលអាស្រ័យនៅពីមុនបានច្រើនជាតិ ព្រមទាំងអាការព្រមទាំងឧទ្ទេស យ៉ាងនេះ ។ ម្នាលព្រាហ្មណ៍ បឋមវិជ្ជានេះឯង ដែលតថាគតបានត្រាស់ដឹង ក្នុងយាមជាដំបូងនៃរាត្រី លុះដល់សេចក្ដីល្ងង់ខ្លៅបាត់ទៅ សេចក្ដីចេះដឹងក៏កើតឡើង ងងឹតខ្ចាត់បាត់ទៅ ពន្លឺក៏កើតឡើងដល់តថាគត ដែលកំពុងអង្គុយប្រុងស្មារតី មិនប្រហែសធ្វេស ខំប្រឹងដុតកំដៅញាំកិលេស មានចិត្តមូលស៊ប់ ( ឥតអាល័យនឹកនា ដល់កាយនិងជីវិតឡើយ ) ដូចជាបណ្ឌិតទាំងឡាយ ដែលបាននូវបឋមវិជ្ជាទាំងនោះដែរ ។

( ៤៩ ) កាលដែលចិត្តខ្ជាប់ខ្ជួន បរិសុទ្ធផូរផង់ មិនមានកិលេស ប្រាសចាកសេចក្ដីសៅហ្មង ជាចិត្តទន់ភ្លន់ សមគួរដល់កម្ម ជាចិត្តនឹងធឹង មិនញាប់ញ័រយ៉ាងនេះហើយ តថាគតក៏បង្អោនចិត្តទៅក្នុងចុតូបបាតញ្ញាណ ( ញាណដែលនាំឲ្យបានត្រាស់ដឹងនូវចុតិនិងបដិសន្ធិ ) នៃសត្វទាំងឡាយ ។ តថាគតមើលឃើញនូវសត្វទាំងឡាយ ដែលច្យុតនិងចាប់បដិសន្ធិ ទាបថោកនិងឧត្ដម មានសម្បុរល្អនិងអាក្រក់ ទៅកាន់សុគតិនិងទុគ្គតិដោយចក្ខុដូចជាទិព្វ ដ៏បរិសុទ្ធ ក្រៃលែងជាងចក្ខុរបស់

យថាកម្មូបគេ សត្តេ បជានាមិ ឥមេ វត ភោន្តោ សត្តា កាយទុច្ចរិតេន សមន្នាគតា វចីទុច្ចរិតេន សមន្នាគតា មនោទុច្ចរិតេន សមន្នាគតា អរិយានំ ឧបវាទកា មិច្ឆាទិដ្ឋិកា មិច្ឆាទិដ្ឋិកម្មសមាទានា តេ កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបន្នា ឥមេ វា បន ភោន្តោ សត្តា កាយសុចរិតេន សមន្នាគតា វចីសុចរិតេន សមន្នាគតា មនោសុចរិតេន សមន្នាគតា អរិយានំ អនុបវាទកា សម្មាទិដ្ឋិកា សម្មាទិដ្ឋិកម្មសមាទានា តេ កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបន្នាតិ ។ ឥតិ ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន សត្តេ បស្សាមិ ចវមានេ ឧបបជ្ជមានេ ហីនេ បណីតេ សុវណ្ណេ ទុព្វណ្ណេ សុគតេ ទុគ្គតេ យថាកម្មូបគេ សត្តេ បជានាមិ ។ អយំ ខោ មេ ព្រាហ្មណ



មនុស្សសាមញ្ញ ក៏ដឹងច្បាស់នូវសត្វទាំងឡាយ ដែលអន្ទោលទៅតាមកម្មថា អើហ្ន៎ សត្វទាំងអម្បាលនេះ ប្រកបដោយកាយទុច្ចរិត ប្រកបដោយវចីទុច្ចរិត ប្រកបដោយមនោទុច្ចរិត ជាអ្នកតិះដៀលនូវព្រះអរិយៈ ជាមិច្ឆាទិដ្ឋិ ប្រកាន់មាំនូវកម្មជាមិច្ឆាទិដ្ឋិ សត្វទាំងនោះលុះដល់ការបែកខន្ធ បន្ទាប់អំពីមរណៈ ក៏ទៅកើតឯអបាយ(១) ទុគ្គតិ(២) វិនិបាត(៣) នរក(៤) អើហ្ន៎ ចំណែកខាងសត្វទាំងអម្បាលនេះ ប្រកបដោយកាយសុចរិតប្រកបដោយវចីសុចរិត ប្រកបដោយមនោសុចរិត ជាអ្នកមិនតិះដៀលនូវពួកព្រះអរិយៈ ជាសម្មាទិដ្ឋិ ប្រកាន់មាំនូវកម្មជាសម្មាទិដ្ឋិ សត្វទាំងអម្បាលនោះ លុះដល់ការបែកខន្ធបន្ទាប់អំពីមរណៈ ក៏ទៅកើតឯឋានសុគតិ(៥) និងសួគ៌(៦) ទេវលោក ។ តថាគតមើលឃើញនូវសត្វទាំងឡាយ ដែលច្យុតនិងចាប់បដិសន្ធិ ថោកទាបនិងឧត្តម មានសម្បុរល្អ និងអាក្រក់ ទៅកាន់សុគតិនិងទុគ្គតិ ដោយចក្ខុជាទិព្វដ៏បរិសុទ្ធ ក្រៃលែងជាងចក្ខុ របស់មនុស្សសាមញ្ញ ក៏ដឹងច្បាស់ នូវសត្វទាំងឡាយ ដែលអន្ទោលទៅតាមកម្ម ដោយប្រការដូច្នេះ ។ ម្នាលព្រាហ្មណ៍

---

១ កំណើតសត្វតិរច្ឆាន ។ ២ ប្រេតវិស័យ ។ ៣ អសុរកាយដែលមានមហាទុក្ខ ដូចកាលកញ្ជិកអសុរជាដើម ។ ៤ លោកដែលគ្មានសេចក្តីចំរើន មានប្រការច្រើន មានអវិចីនរកជាដើម ។ ៥ សង្គ្រោះយកគតិរបស់មនុស្សចូលផង ។ ៦ ចំពោះយកគតិនៃទេវតាតែម្យ៉ាង ។

រត្តិយា មជ្ឈិមេ យាមេ ទុតិយា វិជ្ជា អធិគតា អវិជ្ជា វិហតា វិជ្ជា ឧប្បន្នា តមោ វិហតោ អាលោកោ ឧប្បន្នោ យថាតំ អប្បមត្តស្ស អាតាបិនោ បហិតត្តស្ស វិហរតោ ។

(៤០) សោ ឯវំ សមាហិតេ ចិត្តេ បរិសុទ្ធេ បរិយោទាតេ អនង្គណេ វិគតូបក្កិលេសេ មុទុភូតេ កម្មនិយេ ឋិតេ អានេញ្ជប្បត្តេ អាសវានំ ខយញាណាយ ចិត្តំ អភិនិន្នាមេសឹ ។ សោ ឥទំ ទុក្ខន្តិ យថាភូតំ អព្ភញ្ញាសឹ អយំ ទុក្ខសមុទយោតិ យថាភូតំ អព្ភញ្ញាសឹ អយំ ទុក្ខនិរោធោតិ យថាភូតំ អព្ភញ្ញាសឹ អយំ ទុក្ខនិរោធគាមិនី បដិបទាតិ យថាភូតំ អព្ភញ្ញាសឹ ឥមេ អាសវាតិ យថាភូតំ អព្ភញ្ញាសឹ អយំ អាសវសមុទយោតិ យថាភូតំ អព្ភញ្ញាសឹ អយំ អាសវនិរោធោតិ យថាភូតំ អព្ភញ្ញាសឹ អយំ អាសវនិរោធគាមិនី បដិបទាតិ យថាភូតំ អព្ភញ្ញាសឹ ។ តស្ស មេ ឯវំ ជានតោ ឯវំ បស្សតោ



វិជ្ជាទី ២ នេះឯងហើយ ដែលតថាគតបានត្រាស់ដឹងក្នុងយាមជាកណ្ដាលនៃរាត្រី លុះដល់សេចក្ដីល្ងង់ខ្លៅបាត់ទៅ សេចក្ដីត្រាស់ដឹងក៏កើតឡើង ងងឹតបាត់ទៅ ពន្លឺក៏កើតឡើងដល់តថាគត ដែលកំពុងប្រុងស្មារតី មិនប្រហែសធ្វេស ព្យាយាមដុតបំផ្លាញកិលេស មានចិត្តមូលស្ងួន ( ឥតមានអាល័យដល់កាយនិងជីវិតឡើយ ) ដូចជាបណ្ឌិតទាំងឡាយ ដែលបាននូវវិជ្ជាទី ២ នុះដូច្នោះដែរ ។

(៤០) កាលដែលចិត្តខ្ជាប់ខ្ជួន បរិសុទ្ធ ផូរផង់ មិនមានកិលេស ប្រាសចាកសេចក្ដីសៅហ្មង ជាចិត្តទន់ភ្លន់ សមគួរដល់កម្ម ជាចិត្តនឹងធឹង មិនញាប់ញ័រ យ៉ាងនេះហើយ តថាគតក៏បង្អោនចិត្តទៅ ក្នុងអាសវក្ខយញ្ញាណ ( ញាណជាហេតុឲ្យបានអស់ទៅនូវអាសវៈ ) ។ តថាគតដឹងច្បាស់តាមពិតថា នេះជាទុក្ខ ដឹងច្បាស់តាមពិតថា នេះជាហេតុនាំឲ្យកើតទុក្ខ ដឹងច្បាស់តាមពិតថា នេះជាសេចក្ដីរលត់ទុក្ខ ដឹងច្បាស់តាមពិតថា នេះជាផ្លូវឲ្យដល់នូវសេចក្ដីរលត់ទុក្ខ ដឹងច្បាស់តាមពិតថា ធម៌ប៉ុណ្ណេះជាអាសវៈ ដឹងច្បាស់តាមពិតថា ធម៌នេះជាហេតុនាំឲ្យកើតអាសវៈ ដឹងច្បាស់តាមពិតថា នេះជាសេចក្ដីរលត់នៃអាសវៈ ដឹងច្បាស់តាមពិតថា នេះជាផ្លូវឲ្យបានដល់នូវសេចក្ដីរលត់នៃអាសវៈ ។ កាលដែលតថាគតដឹងយ៉ាងនេះ ឃើញយ៉ាងនេះ

កាមាសវាបិ ចិត្តំ វិមុច្ចិត្ថ ភវាសវាបិ ចិត្តំ វិមុច្ចិត្ថ អវិជ្ជាសវាបិ ចិត្តំ វិមុច្ចិត្ថ វិមុត្តស្មឹ វិមុត្តមិតិ ញាណំ អហោសិ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ អព្ភញ្ញាសឹ ។ អយំ ខោ មេ ព្រាហ្មណ រត្តិយា បច្ឆិមេ យាមេ តតិយា វិជ្ជា អធិគតា អវិជ្ជា វិហតា វិជ្ជា ឧប្បន្នា តមោ វិហតោ អាលោកោ ឧប្បន្នោ យថាតំ អប្បមត្តស្ស អាតាបិនោ បហិតត្តស្ស វិហរតោ ។



ចិត្តនៃតថាគត ក៏ផុតចាកគ្រឿងត្រាំគឺកាមផង ចិត្តនៃតថាគតក៏ផុតចាកគ្រឿងត្រាំគឺភពផង ចិត្តនៃតថាគតក៏ផុតចាកគ្រឿងត្រាំគឺអវិជ្ជាផង (កាលបើចិត្តតថាគតបានរួចផុតស្រឡះហើយ) ប្រាជ្ញាក៏កើតប្រាកដដល់តថាគតថា អាត្មារួចស្រឡះចាកអាសវធម៌ហើយ ចិត្តរបស់អាត្មាផុតស្រឡះហើយ តថាគតដឹងច្បាស់ថា កំណើតរបស់អាត្មាអស់ហើយ ព្រហ្មចរិយធម៌អាត្មាបានប្រព្រឹត្តគ្រប់គ្រាន់ហើយ សោឡសកិច្ច អាត្មាក៏បានធ្វើស្រេចហើយ ដឹងថានកិច្ចដទៃក្រៅពីសោឡសកិច្ចនេះទៀត មិនមានឡើយ ។ ម្នាលព្រាហ្មណ៍ វិជ្ជាទី ៣ នេះឯង ដែលតថាគតបានត្រាស់ដឹងក្នុងយាមជាទីបំផុតនៃរាត្រី លុះដល់សេចក្ដីល្ងង់ខ្លៅខ្ចាត់បាត់ទៅ សេចក្ដីចេះដឹងក៏កើតឡើង ងងឹតខ្ចាត់បាត់ទៅ ពន្លឺក៏កើតឡើងដល់តថាគតដែលកំពុងអង្គុយប្រុងស្មារតី មិនប្រហែសធ្វេស ខំប្រឹងដុតបំផ្លាញកិលេស មានចិត្តមូលស្ងួន (ឥតមាននឹកនាដល់កាយនិងជីវិតឡើយ) ដូចជាបណ្ឌិតទាំងឡាយ ដែលបានវិជ្ជាទី ៣ នុ៎ះដូច្នោះដែរ ។

(៤១) សិយា ខោ បន តេ ព្រាហ្មណ ឯវមស្ស អជ្ជាបិ នូន សមណោ គោតមោ អវីតរាគោ អវីតទោសោ អវីតមោហោ តស្មា អរញ្ញវនបត្ថានិ បន្តានិ សេនា-សនានិ បដិសេវតីតិ ។ ន ខោ បនេតំ ព្រាហ្មណ ឯវំ ទដ្ឋព្វំ ។ ទ្វេ ខោ អហំ ព្រាហ្មណ អត្ថវសេ សម្បស្ស-មានោ អរញ្ញវនបត្ថានិ បន្តានិ សេនាសនានិ បដិសេ-វាមិ អត្តនោ ច ទិដ្ឋធម្មសុខវិហារំ សម្បស្សមានោ បច្ឆិមញ្ច ជនតំ អនុកម្បមានោតិ ។

(៤២) អនុកម្បិតរូបា តាយំ(១) ភោតា គោតមេន បច្ឆិមា ជនតា យថាតំ អរហតា សម្មាសម្ពុទ្ធេន ។ អភិក្កន្តំ ភោ គោតម អភិក្កន្តំ ភោ គោតម

១ ម. យំ ។



(៤១) ម្នាលព្រាហ្មណ៍ ឯសមណព្រាហ្មណ៍ទាំងនោះ មានសេចក្តីត្រិះរិះដូច្នេះថា ថ្ងៃនេះឯង ព្រះសមណគោតម ប្រហែលជាមិនទាន់ប្រាសចាករាគៈ មិនទាន់ប្រាសចាកទោសៈ មិនទាន់ប្រាសចាកមោហៈ នៅឡើយ ព្រោះហេតុនោះបានជាលោកសេពនូវសេនាសនៈស្ងាត់ គាំងនៅក្នុងព្រៃធំនិងព្រៃឆ្ងាយ ។ ម្នាលព្រាហ្មណ៍ ដំណើរនុ៎ះអ្នកកុំគប្បីឃើញយ៉ាងនេះឡើយ ។ ម្នាលព្រាហ្មណ៍ តថាគតបានពិចារណាឃើញនូវអំណាចនៃប្រយោជន៍ ២ ប្រការ គឺពិចារណាឃើញនូវការនៅជាសុខក្នុងបច្ចុប្បន្នចំពោះខ្លួន ១ អនុគ្រោះដល់ប្រជុំជនពួកកើតខាងក្រោយ ១ បានជាសេពនូវសេនាសនៈស្ងាត់ គាំងនៅក្នុងព្រៃធំនិងព្រៃឆ្ងាយ ។

(៤២) ជាណុស្សោណិព្រាហ្មណ៍ក្រាបបង្គំទូលថា បពិត្រព្រះគោតមដ៏ចំរើន ព្រះអង្គមានសេចក្តីអនុគ្រោះ ដល់ប្រជុំជនខាងក្រោយមែន ព្រោះព្រះអង្គបានជាព្រះអរហន្តសម្មាសម្ពុទ្ធហើយ ។ បពិត្រព្រះគោតមដ៏ចំរើន ពីរោះណាស់ បពិត្រព្រះគោតមដ៏ចំរើន ពីរោះណាស់

សេយ្យថាបិ ភោ គោតម និក្កុជ្ជិតំ វា ឧក្កុជ្ជេយ្យ បដិច្ឆន្នំ វា វិវរេយ្យ មូឡ្ហស្ស វា មគ្គំ អាចិក្ខេយ្យ អន្ធការេ វា តេលបជ្ជោតំ ធារេយ្យ ចក្ខុមន្តោ រូបានិ ទក្ខន្តីតិ ឯវមេវ[១] ភោតា គោតមេន អនេកបរិយាយេន ធម្មោ បកាសិតោ ។ ឯសាហំ ភវន្តំ គោតមំ សរណំ គច្ឆាមិ ធម្មញ្ច ភិក្ខុសង្ឃញ្ច ឧបាសកំ មំ ភវំ គោតមោ ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណំ គតន្តិ[២] ។

ភយភេរវសុត្តំ ចតុត្ថំ និដ្ឋិតំ[៣] ។

១ ឱ.ម. ឯវមេវំ ។ ២ ឱ. សរណគតន្តិ ទិស្សតិ ។ ៣ ឱ ម. និដ្ឋិតន្តិ ន ទិស្សតិ ។



បពិត្រព្រះគោតមដ៏ចំរើន ធម៌ដែលព្រះអង្គសំដែងហើយ ដោយអនេកបរិយាយយ៉ាងនេះ (ក៏ច្បាស់ណាស់) ដូចជាគេផ្ងាររបស់ដែលផ្កាប់ ឬក៏ដូចជាគេបើកបង្ហាញរបស់ដែលកំបាំង ពុំនោះដូចជាគេប្រាប់ផ្លូវដល់អ្នកវង្វេងទិស ពុំនោះសោតដូចជាគេទ្រោលប្រទីបបំភ្លឺក្នុងទីងងឹត ដោយគិតថា បុរសអ្នកមានចក្ខុទាំងឡាយ នឹងឃើញនូវរូបបាន ។ ខ្ញុំព្រះអង្គនោះសូមដល់នូវព្រះគោតមដ៏ចំរើនផង ព្រះធម៌ផង ព្រះភិក្ខុសង្ឃផង ជាទីពឹងទីរលឹក តាំងដើមអំពីថ្ងៃនេះទៅ សូមព្រះគោតមដ៏ចំរើនជ្រាបនូវខ្ញុំព្រះអង្គ ថាជាឧបាសកដល់នូវសរណគមន៍ស្មើដោយជីវិត ។

ចប់ ភយភេរវសូត្រ ទី ៤ ។

# បញ្ចមំ អនង្គណសុត្តំ

(៥៧) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តត្រ ខោ អាយស្មា សារីបុត្តោ ភិក្ខូ អាមន្តេសិ អាវុសោ ភិក្ខវេតិ ។ អាវុសោតិ ខោ តេ ភិក្ខូ អាយស្មតោ សារីបុត្តស្ស បច្ចស្សោសុំ ។

(៥៨) អាយស្មា សារីបុត្តោ ឯតទវោច ចត្តារោមេ អាវុសោ បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មឹ ។ កតមេ ចត្តារោ ។ ឥធាវុសោ ឯកច្ចោ បុគ្គលោ សង្គណោវ(១) សមានោ អត្ថិ មេ អជ្ឈត្តំ អង្គណន្តិ យថាភូតំ នប្បជានាតិ ។ ឥធ បនាវុសោ ឯកច្ចោ បុគ្គលោ សង្គណោវ(២) សមានោ អត្ថិ មេ អជ្ឈត្តំ អង្គណន្តិ យថាភូតំ បជានាតិ ។ ឥធាវុសោ ឯកច្ចោ បុគ្គលោ អនង្គណោវ សមានោ នត្ថិ មេ អជ្ឈត្តំ អង្គណន្តិ យថាភូតំ នប្បជានាតិ ។

១-២ សង្គណោ ឥតិ កត្ថចិ បោត្ថកេ ទិស្សតិ ។

# អង្គណសូត្រទី ៥

(៥៧) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងជេតវនារាម របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ ព្រះសារីបុត្រដ៏មានអាយុ ហៅភិក្ខុទាំងឡាយក្នុងទីនោះថា ម្នាលភិក្ខុដ៏មានអាយុទាំងឡាយ ។ ភិក្ខុទាំងនោះទទួលថេរពាក្យរបស់ព្រះសារីបុត្រដ៏មានអាយុថា ព្រះថេរៈដ៏មានអាយុ ដូច្នេះ ។

(៥៨) ព្រះសារីបុត្រដ៏មានអាយុ បានពោលពាក្យនេះថា ម្នាលអាវុសោទាំងឡាយ បុគ្គល ៤ ពួកនេះ តែងមាននៅក្នុងលោក ។ បុគ្គល ៤ ពួក តើដូចម្តេច ។ ម្នាលអាវុសោទាំងឡាយ បុគ្គលពួកមួយក្នុងលោកនេះ នៅមានអង្គណៈ(១) ក៏មិនដឹងច្បាស់តាមពិតថា អាត្មាអញនៅមានអង្គណៈក្នុងខ្លួន ១ ។ ម្នាលអាវុសោទាំងឡាយ បុគ្គលពួកមួយទៀតក្នុងលោកនេះ នៅមានអង្គណៈ តែដឹងច្បាស់តាមពិតថា អាត្មាអញនៅមានអង្គណៈក្នុងខ្លួន ១ ។ ម្នាលអាវុសោទាំងឡាយ បុគ្គលពួកមួយក្នុងលោកនេះ មិនមានអង្គណៈ ក៏មិនដឹងច្បាស់តាមពិតថា អាត្មាអញមិនមានអង្គណៈក្នុងខ្លួន ១ ។ ម្នាលអាវុសោទាំងឡាយ

១ បានដល់កិលេសដ៏គ្រោតគ្រាត មានប្រការផ្សេងៗ ។ អដ្ឋកថា ។

ឥធ បនាវុសោ ឯកច្ចោ បុគ្គលោ អនង្គណោវ សមានោ នត្ថិ មេ អជ្ឈត្តំ អង្គណន្តិ យថាភូតំ បជានាតិ ។ តត្រាវុសោ យ្វាយំ បុគ្គលោ សង្គណោវ សមានោ អត្ថិ មេ អជ្ឈត្តំ អង្គណន្តិ យថាភូតំ នប្បជានាតិ អយំ ឥមេសំ ទ្វិន្នំ បុគ្គលានំ សង្គណានំយេវ សតំ ហីនបុរិសោ អក្ខាយតិ ។ តត្រាវុសោ យ្វាយំ បុគ្គលោ សង្គណោវ សមានោ អត្ថិ មេ អជ្ឈត្តំ អង្គណន្តិ យថាភូតំ បជានាតិ អយំ ឥមេសំ ទ្វិន្នំ បុគ្គលានំ សង្គណានំយេវ សតំ សេដ្ឋបុរិសោ អក្ខាយតិ ។ តត្រាវុសោ យ្វាយំ បុគ្គលោ អនង្គណោវ សមានោ នត្ថិ មេ អជ្ឈត្តំ អង្គណន្តិ យថាភូតំ នប្បជានាតិ អយំ ឥមេសំ ទ្វិន្នំ បុគ្គលានំ អនង្គណានំយេវ សតំ ហីនបុរិសោ អក្ខាយតិ ។ តត្រាវុសោ យ្វាយំ បុគ្គលោ អនង្គណោវ សមានោ នត្ថិ មេ អជ្ឈត្តំ អង្គណន្តិ យថាភូតំ បជានាតិ អយំ ឥមេសំ ទ្វិន្នំ បុគ្គលានំ អនង្គណានំយេវ សតំ សេដ្ឋបុរិសោ អក្ខាយតីតិ ។



បុគ្គលពួកមួយទៀត ក្នុងលោកនេះ មិនមានអង្គណៈ តែងដឹងច្បាស់តាមពិតថា អាត្មាអញមិនមានអង្គណៈ ក្នុងខ្លួន ១ ។ ម្នាលអាវុសោទាំងឡាយ បណ្តាបុគ្គលទាំង ៤ ពួកនោះ បុគ្គលណា នៅមានអង្គណៈ តែមិនដឹងច្បាស់តាមពិតថា អាត្មាអញមានអង្គណៈក្នុងខ្លួន បណ្តាបុគ្គលដែលមានអង្គណៈទាំងពីរពួកនេះ បុគ្គលនេះ ប្រាកដជាជាបុរសថោកថយ ។ ម្នាលអាវុសោ ទាំងឡាយ បណ្តាបុគ្គលទាំង ៤ ពួកនោះ បុគ្គលណានៅមានអង្គណៈ តែដឹងច្បាស់តាមពិតថា អាត្មាអញនៅមានអង្គណៈក្នុងខ្លួន បណ្តាបុគ្គលដែលមានអង្គណៈទាំងពីរពួកនេះ បុគ្គលនេះប្រាកដជាជាបុរសដ៏ប្រសើរ ។ ម្នាលអាវុសោទាំងឡាយ បណ្តាបុគ្គលទាំង ៤ ពួកនោះ បុគ្គលណាមិនមានអង្គណៈ តែមិនដឹងច្បាស់តាមពិតថា អាត្មាអញមិនមានអង្គណៈក្នុងខ្លួន បណ្តាបុគ្គល ដែលមិនមានអង្គណៈទាំងពីរពួកនេះ បុគ្គលនេះ ប្រាកដជាជាបុរសថោកថយ ។ ម្នាលអាវុសោទាំងឡាយ បណ្តាបុគ្គលទាំង ៤ ពួកនោះ បុគ្គលណា មិនមានអង្គណៈ តែដឹងច្បាស់តាមពិតថា អាត្មាអញ មិនមានអង្គណៈ ក្នុងខ្លួន បណ្តាបុគ្គល ដែលមិនមានអង្គណៈទាំងពីរពួកនេះ បុគ្គលនេះ ប្រាកដជាជាបុរសដ៏ប្រសើរ ។

(៥៥) ឯវំ វុត្តេ អាយស្មា មហាមោគ្គល្លានោ អាយស្មន្តំ សារិបុត្តំ ឯតទវោច កោ នុ ខោ អាវុសោ សារិបុត្ត ហេតុ កោ បច្ចយោ យេនិមេសំ ទ្វិន្នំ បុគ្គលានំ សង្គណានំយេវ សតំ ឯកោ ហីនបុរិសោ អក្ខាយតិ ឯកោ សេដ្ឋបុរិសោ អក្ខាយតិ កោ បនាវុសោ សារិបុត្ត ហេតុ កោ បច្ចយោ យេនិមេសំ ទ្វិន្នំ បុគ្គលានំ អនង្គណានំយេវ សតំ ឯកោ ហីនបុរិសោ អក្ខាយតិ ឯកោ សេដ្ឋបុរិសោ អក្ខាយតីតិ ។ តត្រាវុសោ យ្វាយំ បុគ្គលោ សង្គណោវ សមានោ អត្ថិ មេ អជ្ឈត្តំ អង្គណន្តិ យថាភូតំ នប្បជានាតិ តស្សេតំ បាដិកង្ខំ ន ឆន្ទំ ជនេស្សតិ ន វាយមិស្សតិ ន វីរិយំ អារភិស្សតិ តស្ស អង្គណស្ស បហានាយ ។ សោ សរាគោ សទោសោ សមោហោ សង្គណោ សង្កិលិដ្ឋចិត្តោ កាលំ ករិស្សតិ ។ សេយ្យថាបិ អាវុសោ កំសបាតិ អាភតា អាបណា វា



(៥៥) កាលបើព្រះសារីបុត្រមានប្រសាសន៍យ៉ាងនេះហើយ ព្រះមហាមោគ្គល្លានដ៏មានអាយុ ក៏បានពោលពាក្យនេះ នឹងព្រះសារីបុត្រដ៏មានអាយុថា ម្នាលអាវុសោសារីបុត្រ ហេតុដូចម្តេច បច្ច័យដូចម្តេច បានជាមានបុគ្គល ដែលមានអង្គណៈទាំងពីរពួកនេះ ហើយបុគ្គលម្នាក់ ប្រាកដជាជាបុរសថោកទាប បុគ្គលម្នាក់ទៀតប្រាកដជាជាបុរសប្រសើរវិញ ម្នាលអាវុសោសារីបុត្រ ហេតុដូចម្តេច បច្ច័យដូចម្តេច បានជាមានបុគ្គល ដែលមិនមានអង្គណៈទាំងពីរពួកនេះ ហើយបុគ្គលម្នាក់ប្រាកដជាជាបុរសថោកទាប បុគ្គលម្នាក់ (ទៀត) ប្រាកដជាជាបុរសប្រសើរវិញ ។ ព្រះសារីបុត្រមានប្រសាសន៍ថា ម្នាលអាវុសោ បណ្តាបុគ្គលទាំងពីរពួកនោះ បុគ្គលណា នៅមានអង្គណៈ តែមិនដឹងច្បាស់តាមពិតថា អាត្មាអញមានអង្គណៈក្នុងខ្លួន អង្គណៈនេះគឺមានប្រាកដដល់បុគ្គលនោះ បុគ្គលនោះ នឹងមិនញុំាងឆន្ទៈឲ្យកើតឡើង មិនសង្កាត់ មិនប្រារព្ធព្យាយាម ដើម្បីលះបង់នូវអង្គណៈនោះចេញ ។ បុគ្គលនោះមុខជានឹងធ្វើមរណកាលទាំងរាគៈ ទោសៈ មោហៈ អង្គណៈ ទាំងចិត្តសៅហ្មង ។ ម្នាលអាវុសោ ដូចជាថាសសំរិទ្ធ ដែលគេទិញយកមកពីផ្សារ

កម្មារកុលា វា រជេន ច មលេន ច បរិយោនទ្ធា តមេនំ សាមិកា ន ចេវ បរិភុញ្ជេយ្យុំ ន ច បរិយោ-ទបេយ្យុំ រជាបថេ ច នំ និក្ខិបេយ្យុំ ឯវញ្ហិ សា អាវុសោ កំសបាតិ អបរេន សមយេន សង្កិលិដ្ឋតរា អស្ស មលគ្គហិតាតិ ។ ឯវមាវុសោតិ ។ ឯវមេវ ខោ អាវុសោ យ្វាយំ បុគ្គលោ សង្គណោវ សមានោ អត្ថិ មេ អជ្ឈត្តំ អង្គណន្តិ យថាភូតំ នប្បជានាតិ តស្សេតំ បាដិកង្ខំ ន ឆន្ទំ ជនេស្សតិ ន វាយ-មិស្សតិ ន វីរិយំ អារភិស្សតិ តស្ស អង្គណស្ស បហានាយ ។ សោ សរាគោ សទោសោ សមោហោ សង្គណោ សង្កិលិដ្ឋចិត្តោ កាលំ ករិស្សតិ ។ តត្រាវុសោ យ្វាយំ បុគ្គលោ សង្គណោវ សមានោ អត្ថិ មេ អជ្ឈត្តំ អង្គណន្តិ យថាភូតំ បជានាតិ តស្សេតំ បាដិកង្ខំ ឆន្ទំ ជនេស្សតិ វាយមិស្សតិ វីរិយំ អារភិស្សតិ តស្ស អង្គណស្ស បហានាយ ។ សោ អរាគោ អទោសោ អមោហោ អនង្គណោ



ឬអំពីត្រកូលជាងលោហៈ ជាភាជន៍ប្រឡាក់ដោយធូលីនិងស្នឹម បុគ្គលជាម្ចាស់ទាំងឡាយ មិនបានប្រើប្រាស់នូវភាជន៍នោះផង មិនបានដុសខាត់ផង ថែមទាំងដាក់ភាជន៍នោះ ទៅក្នុងផ្លូវធូលី ម្នាលអាវុសោ កាលបើដូច្នេះ ភាជន៍សំរិទ្ធនោះដល់សម័យជាខាងក្រោយមក រឹតតែសៅហ្មង មានស្នឹមជាប់ដែរឬ ។ ព្រះមហាមោគ្គល្លានក៏ទូលថា អើ អាវុសោ ។ ព្រះសារីបុត្រមានថេរដីកាតទៅទៀតថា ម្នាលអាវុសោ បុគ្គលណានៅមានអង្គណៈ មិនដឹងច្បាស់តាមពិតថា អាត្មាអញ មានអង្គណៈក្នុងខ្លួន អង្គណៈនេះក៏មានប្រាកដ ដល់បុគ្គលនោះ បុគ្គលនោះនឹងមិនញ៉ាំងឆន្ទៈឲ្យកើតឡើង មិនសង្វាត មិនប្រារព្ធព្យាយាមដើម្បីលះបង់អង្គណៈនោះចេញ ក៏ដូច្នោះដែរ ។ បុគ្គលនោះមុខជានឹងធ្វើមរណកាលទៅទាំងរាគៈ ទោសៈ មោហៈ ទាំងអង្គណៈ ទាំងចិត្តដ៏សៅហ្មង ។ ម្នាលអាវុសោ បណ្តាបុគ្គលទាំង ៤ ពួកនោះ បុគ្គលណានៅមានអង្គណៈ តែដឹងច្បាស់តាមពិតថា អាត្មាអញមានអង្គណៈក្នុងខ្លួន អង្គណៈនេះក៏មានប្រាកដដល់បុគ្គលនោះតែបុគ្គលនោះ មុខជានឹងញ៉ាំងឆន្ទៈឲ្យកើតឡើង មុខជានឹងសង្វាត ប្រារព្ធព្យាយាម ដើម្បីលះបង់នូវអង្គណៈនោះចេញ ។ បុគ្គលនោះ មុខជាមិនមានរាគៈ ទោសៈ មោហៈ មិនមានអង្គណៈ

អសង្កិលិដ្ឋចិត្តោ កាលំ ករិស្សតិ ។ សេយ្យថាបិ អាវុសោ កំសបាតិ អាភតា អាបណា វា កម្មារកុលា វា រជេន ច មលេន ច បរិយោនទ្ធា តមេនំ សាមិកា បរិសោធេយ្យុំ បរិយោទបេយ្យុំ ន ច នំ រជាបថេ និក្ខិបេយ្យុំ ឯវញ្ហិ សា អាវុសោ កំសបាតិ អបរេន សមយេន បរិសុទ្ធា អស្ស បរិយោទាតាតិ ។ ឯវមាវុសោតិ ។ ឯវមេវ ខោ អាវុសោ យ្វាយំ បុគ្គលោ សង្គណោវ សមានោ អត្ថិ មេ អជ្ឈត្តំ អង្គណន្តិ យថាភូតំ បជានាតិ តស្សេតំ បាដិកង្ខំ ឆន្ទំ ជនេស្សតិ វាយមិស្សតិ វិរិយំ អារភិស្សតិ តស្ស អង្គណស្ស បហានាយ ។ សោ អរាគោ អទោសោ អមោហោ អនង្គណោ អសង្កិលិដ្ឋចិត្តោ កាលំ ករិស្សតិ ។ តត្រាវុសោ យ្វាយំ បុគ្គលោ អនង្គណោវ សមានោ នត្ថិ មេ អជ្ឈត្តំ អង្គណន្តិ យថាភូតំ នប្បជានាតិ តស្សេតំ បាដិកង្ខំ សុភនិមិត្តំ មនសិករិស្សតិ



មិនមានចិត្តសៅហ្មង ហើយធ្វើមរណកាលទៅ ។ ម្នាលអាវុសោ ដូចជាភាជនសំរិទ្ធដែលគេយកមកអំពីផ្សារ ឬអំពីត្រកូលជាងលោហៈ ជាភាជន៍ប្រឡាក់ដោយធូលីនិងស្នឹម បុគ្គលជាម្ចាស់ទាំងឡាយ ក៏បានប្រើប្រាស់ភាជនៈនោះផង បានដុសខាត់ផង ថែមទាំងមិនទុកដាក់ភាជន៍នោះ ក្នុងផ្លូវធូលី ម្នាលអាវុសោ កាលបើដូច្នេះ ភាជនសំរិទ្ធនោះ លុះដល់សម័យជាខាងក្រោយ នឹងបរិសុទ្ធផូរផង់ដែរឬ ។ ព្រះមហាមោគ្គល្លានក៏ទូលថា អើអាវុសោ ។ ព្រះសារីបុត្រមានថេរវាទតទៅទៀតថា ម្នាលអាវុសោ បុគ្គលណាទៅមានអង្គណៈ ដឹងច្បាស់តាមពិតថា អាត្មាអញមានអង្គណៈក្នុងខ្លួន អង្គណៈនេះក៏មានប្រាកដ ដល់បុគ្គលនោះ បុគ្គលនោះមុខជានឹងញ៉ាំងឆន្ទៈឲ្យកើតឡើង មុខជានឹងសង្វាត ព្យាយាមដើម្បីលះបង់អង្គណៈនោះចេញ ក៏ដូច្នោះដែរ ។ បុគ្គលនោះមុខជាមិនមានរាគៈ ទោសៈ មោហៈ មិនមានអង្គណៈ មិនមានចិត្តសៅហ្មងហើយធ្វើមរណកាលទៅ ។ ម្នាលអាវុសោ បណ្ដាបុគ្គលទាំង ៤ ពួកនោះ បុគ្គលណា មិនមានអង្គណៈ មិនដឹងច្បាស់ តាមពិតថា អាត្មាអញមិនមានអង្គណៈ ក្នុងខ្លួន អង្គណៈនេះ ក៏ត្រឡប់ទៅជាប្រាកដដល់បុគ្គលនោះវិញ បុគ្គលនោះមុខជានឹងធ្វើទុកក្នុងចិត្ត នូវសុភនិមិត្ត

តស្ស សុភនិមិត្តស្ស មនសិការា រាគោ ចិត្តំ អនុទ្ធំ-
សេស្សតិ ។ សោ សរាគោ សទោសោ សមោហោ
សង្គណោ សង្កិលិដ្ឋចិត្តោ កាលំ ករិស្សតិ ។
សេយ្យថាបិ អាវុសោ កំសបាតិ អាភតា អាបណា
វា កម្មារកុលា វា បរិសុទ្ធា បរិយោទាតា តមេនំ
សាមិកា ន ចេវ បរិភុញ្ជេយ្យុំ ន ច បរិយោទបេយ្យុំ
រជាបថេ ច នំ និក្ខិបេយ្យុំ ឯវញ្ហិ សា អាវុសោ
កំសបាតិ អបរេន សមយេន សង្កិលិដ្ឋា[1] អស្ស
មលគ្គហិតាតិ ។ ឯវមាវុសោតិ ។ ឯវមេវ ខោ អា-
វុសោ យ្វាយំ បុគ្គលោ អនង្គណោវ សមានោ
នត្ថិ មេ អជ្ឈត្តំ អង្គណន្តិ យថាភូតំ នប្បជានាតិ
តស្សេតំ បាដិកង្ខំ សុភនិមិត្តំ មនសិករិស្សតិ តស្ស
សុភនិមិត្តស្ស មនសិការា រាគោ ចិត្តំ អនុទ្ធំ-
សេស្សតិ ។ សោ សរាគោ សទោសោ សមោហោ
សង្គណោ សង្កិលិដ្ឋចិត្តោ កាលំ ករិស្សតិ ។ តត្រា-
វុសោ យ្វាយំ បុគ្គលោ អនង្គណោវ សមានោ
នត្ថិ មេ អជ្ឈត្តំ អង្គណន្តិ យថាភូតំ បជានាតិ

[1] ម.ម. សង្កិលិដ្ឋតរា ។



លុះធ្វើទុកក្នុងចិត្តនូវសុភនិមិត្តនោះហើយ រាគៈមុខជានឹងតាមកំចាត់ចិត្តមិន
ខាន ។ បុគ្គលនោះមុខជានឹងធ្វើមរណកាលទៅទាំងរាគៈ ទោសៈ មោហៈ
ទាំងអង្គណៈ ទាំងចិត្តដ៏សៅហ្មង ។ ម្នាលអាវុសោ ដូចជាភាជនៈសំរិទ្ធ
ដែលគេនាំយកមកអំពីផ្សារ ឬអំពីត្រកូលជាងលោហៈ ជាភាជនៈដ៏បរិសុទ្ធ
ផូរផង់ តែបុគ្គលជាម្ចាស់ទាំងឡាយ មិនបានប្រើប្រាស់ភាជនៈនោះផង
មិនបានជូតខាត់ផង ថែមទាំងទុកភាជនៈនោះ ក្នុងផ្លូវធូលីទៀត ម្នាល
អាវុសោ កាលបើដូច្នេះ ភាជនៈសំរិទ្ធនោះ លុះដល់សម័យខាងក្រោយ
ទៅជាសៅហ្មង មានស្នឹមចាប់ដែរឬ ។ ព្រះមហាមោគ្គល្លាន ក៏ទូល
ថា អើអាវុសោ ។ ព្រះសារីបុត្រមានថេរដីកាតទៅទៀតថា ម្នាលអាវុ-
សោ បុគ្គលណាមិនមានអង្គណៈ មិនដឹងច្បាស់ តាមពិតថា អាត្មា
អញមិនមានអង្គណៈក្នុងខ្លួន អង្គណៈនេះក៏ត្រឡប់ទៅជាមានប្រាកដ ដល់
បុគ្គលនោះវិញ បុគ្គលនោះមុខជានឹងធ្វើទុក ក្នុងចិត្តនូវសុភនិមិត្ត លុះ
ធ្វើទុកក្នុងចិត្ត នូវសុភនិមិត្តនោះហើយ រាគៈមុខជានឹងតាមកំចាត់ចិត្តមិន
ខាន ។ បុគ្គលនោះ មុខជានឹងធ្វើមរណកាលទៅទាំងរាគៈ ទោសៈ
មោហៈ ទាំងអង្គណៈ ទាំងចិត្តសៅហ្មង ក៏យ៉ាងនោះឯង ។
ម្នាលអាវុសោ បណ្តាបុគ្គលទាំង ៤ ពួកនោះ បុគ្គលណា មិនមាន
អង្គណៈ តែដឹងច្បាស់តាមពិតថា អាត្មាអញ មិនមានអង្គណៈក្នុងខ្លួន

តស្សេតំ បាដិកង្ខំ សុភនិមិត្តំ មនសិការិស្សតិ តស្ស សុភនិមិត្តស្ស មនសិការា រាគោ ចិត្តំ នានុទ្ធំសេស្សតិ ។ សោ អរាគោ អទោសោ អមោហោ អនង្គណោ អសង្កិលិដ្ឋចិត្តោ កាលំ ករិស្សតិ ។ សេយ្យថាបិ អាវុសោ កំសបាតិ អាភតា អាបណា វា កម្មារកុលា វា បរិសុទ្ធា បរិយោទាតា តមេនំ សាមិកា បរិភុញ្ជេយ្យុំ ចេវ បរិយោទបេយ្យុំ ច ន ច នំ រជាបថេ និក្ខិបេយ្យុំ ឯវញ្ហិ សា អាវុសោ កំសបាតិ អបរេន សមយេន បរិសុទ្ធតរា អស្ស បរិយោទាតាតិ ។ ឯវមាវុសោតិ ។ ឯវមេវ ខោ អាវុសោ យ្វាយំ បុគ្គលោ អនង្គណោ វ សមានោ នត្ថិ មេ អជ្ឈត្តំ អង្គណន្តិ យថាភូតំ បជានាតិ តស្សេតំ បាដិកង្ខំ សុភនិមិត្តំ ន មនសិការិស្សតិ តស្ស សុភនិមិត្តស្ស អមនសិការា រាគោ ចិត្តំ នានុទ្ធំសេស្សតិ ។ សោ អរាគោ អទោសោ



អង្គណៈនេះក៏ត្រឡប់ទៅជាមានប្រាកដ ដល់បុគ្គលនោះវិញ បុគ្គលនោះមុខជានឹងធ្វើទុក ក្នុងចិត្តនូវសុភនិមិត្ត លុះធ្វើទុកក្នុងចិត្ត នូវសុភនិមិត្តនោះហើយ រាគៈមុខជានឹងមិនតាមកំចាត់ចិត្តបានឡើយ ។ បុគ្គលនោះមុខជា មិនមានរាគៈ ទោសៈ មោហៈ មិនមានអង្គណៈ មានចិត្ត មិនសៅហ្មង ហើយធ្វើនូវមរណកាលទៅ ។ ម្នាលអាវុសោ ដូចភាជន៍សំរឹទ្ធ ដែលគេនាំយកមកអំពីផ្សារ ឬអំពីត្រកូលជាងលោហៈ ជាភាជន៍ដ៏បរិសុទ្ធផូរផង់ បុគ្គលជាម្ចាស់ទាំងឡាយ បានប្រើប្រាស់នូវភាជន៍នោះផង បានដុសខាត់ផង ដែលទាំងមិនទុកភាជន៍នោះ ក្នុងផ្លូវធូលីផង ម្នាលអាវុសោ កាលបើដូច្នេះ ភាជន៍សំរឹទ្ធនោះ លុះកាលខាងក្រោយមក ទៅជាភាជន៍ដ៏បរិសុទ្ធផូរផង់ក្រៃលែងវិញ ។ ព្រះមហាមោគ្គល្លាន ក៏ទូលថា អើអាវុសោ ។ ព្រះសារីបុត្រពោលតទៅទៀតថា ម្នាលអាវុសោ បុគ្គលណាមិនមានអង្គណៈ ដឹងច្បាស់តាមពិតថា អាត្មាអញមិនមានអង្គណៈក្នុងខ្លួន អង្គណៈនេះក៏មានប្រាកដដល់បុគ្គលនោះ មុខជាបុគ្គលនោះមិនបានធ្វើទុកក្នុងចិត្ត ចំពោះសុភនិមិត្ត លុះមិនធ្វើទុកក្នុងចិត្ត នូវសុភនិមិត្តនោះហើយ រាគៈមុខជានឹងមិនតាមកំចាត់ចិត្ត ក៏ដូច្នោះដែរ ។ បុគ្គលនោះមុខជាមិនមានរាគៈ ទោសៈ មោហៈ

អមោហោ អនង្គណោ អសង្កិលិដ្ឋចិត្តោ កាលំ ករិស្សតិ ។ អយំ ខោ អាវុសោ មោគ្គល្លាន ហេតុ អយំ បច្ចយោ យេនិមេសំ ទ្វិន្នំ បុគ្គលានំ សង្គណានំយេវ សតំ ឯកោ ហីនបុរិសោ អក្ខាយតិ ឯកោ សេដ្ឋបុរិសោ អក្ខាយតិ អយំ ខោ បនាវុសោ មោគ្គល្លាន ហេតុ អយំ បច្ចយោ យេនិមេសំ ទ្វិន្នំ បុគ្គលានំ អនង្គណានំយេវ សតំ ឯកោ ហីនបុរិសោ អក្ខាយតិ ឯកោ សេដ្ឋបុរិសោ អក្ខាយតីតិ ។

(៥៦) អង្គណំ អង្គណន្តិ អាវុសោ វុច្ចតិ កិស្ស នុ ខោ ឯតំ អាវុសោ អធិវចនំ យទិទំ អង្គណន្តិ ។ បាបកានំ[១] ឯតំ អាវុសោ អកុសលានំ ឥច្ឆាវចរានំ អធិវចនំ យទិទំ អង្គណន្តិ[២] ។

(៥៧) ឋានំ ខោ បនេតំ អាវុសោ វិជ្ជតិ យំ ឥធេកច្ចស្ស ភិក្ខុនោ ឯវំ ឥច្ឆា ឧប្បជ្ជេយ្យ អាបត្តិញ្ច វត អាបន្នោ អស្សំ ន ច មំ ភិក្ខូ ជានេយ្យុំ អាបត្តឹ អាបន្នោតិ ។ ឋានំ ខោ បនេតំ អាវុសោ វិជ្ជតិ

១ ឱ. បាបកានំ ខោ ។ ២ ម. អង្គណំ [illegible] ។



មិនមានអង្គណៈ មិនមានចិត្តសៅហ្មង ធ្វើមរណកាលទៅ ។ ម្នាលអាវុសោមោគ្គល្លាន ហេតុបច្ច័យនេះឯង ដែលនាំឲ្យមានបុគ្គល មានអង្គណៈទាំងពីរពួកនេះ ហើយបុគ្គលពួកមួយ ប្រាកដជាបុរសថោកទាប បុគ្គលពួកមួយទៀត ប្រាកដជាបុរសប្រសើរ ម្នាលអាវុសោមោគ្គល្លាន ហេតុបច្ច័យនេះឯង ដែលនាំឲ្យមានបុគ្គល ដែលមិនមានអង្គណៈទាំងពីរពួកនេះ ហើយបុគ្គលពួកមួយ ប្រាកដជាបុរសថោកទាប បុគ្គលពួកមួយទៀត ប្រាកដជាបុរសប្រសើរ ។

(៥៦) ព្រះមហាមោគ្គល្លានដ៏មានអាយុសួរថា ម្នាលអាវុសោ ពាក្យដែលលោកហៅថា អង្គណៈ អង្គណៈ ដូច្នេះ ម្នាលអាវុសោ ចុះពាក្យថា អង្គណៈនេះ ជាឈ្មោះនៃវត្ថុអ្វី ។ ព្រះសារីបុត្រឆ្លើយថា ម្នាលអាវុសោ ពាក្យថា អង្គណៈនេះ ជាឈ្មោះនៃអកុសលដ៏លាមក ដែលគ្របសង្កត់ចិត្ត ដោយអំណាចនៃសេចក្តីប្រាថ្នា ។

(៥៧) ម្នាលអាវុសោ ហេតុនេះ តែងមានជាប្រាកដ ត្រង់ថា សេចក្តីប្រាថ្នាកើតឡើងដល់ភិក្ខុពួកខ្លះ ក្នុងសាសនានេះ យ៉ាងនេះថា ឱហ្ន៎ អាត្មាអញត្រូវអាបត្តិមែនហើយ តែពួកភិក្ខុមិនដឹងថា អាត្មាអញត្រូវអាបត្តិទេ ។ ម្នាលអាវុសោ ហេតុនេះ តែងមានជាប្រាកដ ត្រង់ពាក្យថា ពួក

យន្តំ ភិក្ខុំ ភិក្ខូ ជានេយ្យុំ អាបត្តឹ អាបន្នោតិ ។ ជានន្តិ មំ ភិក្ខូ អាបត្តឹ អាបន្នោតិ ឥតិ សោ កុបិតោ ហោតិ អប្បតីតោ ។ យោ ចេវ ខោ អាវុសោ កោបោ យោ ច អប្បច្ចយោ ឧភយមេតំ អង្គណំ ។

(៤៨) ឋានំ ខោ បនេតំ អាវុសោ វិជ្ជតិ យំ ឥធេកច្ចស្ស ភិក្ខុនោ ឯវំ ឥច្ឆា ឧប្បជ្ជេយ្យ អាបត្តិញ្ច វត អាបន្នោ អស្សំ អនុរហោ មំ ភិក្ខូ ចោទេយ្យុំ នោ សង្ឃមជ្ឈេតិ ។ ឋានំ ខោ បនេតំ អាវុសោ វិជ្ជតិ យន្តំ ភិក្ខុំ ភិក្ខូ សង្ឃមជ្ឈេ ចោទេយ្យុំ នោ អនុរហោ ។ សង្ឃមជ្ឈេ មំ ភិក្ខូ ចោទេន្តិ នោ អនុរហោតិ ឥតិ សោ កុបិតោ ហោតិ អប្បតីតោ ។ យោ ចេវ ខោ អាវុសោ កោបោ យោ ច អប្បច្ចយោ ឧភយមេតំ អង្គណំ ។

(៤៩) ឋានំ ខោ បនេតំ អាវុសោ វិជ្ជតិ យំ ឥធេកច្ចស្ស ភិក្ខុនោ ឯវំ ឥច្ឆា ឧប្បជ្ជេយ្យ អាបត្តិញ្ច វត អាបន្នោ អស្សំ សប្បដិបុគ្គលោ មំ ចោទេយ្យ



ភិក្ខុដឹងភិក្ខុនោះថាជាអ្នកត្រូវអាបត្តិហើយ ។ ភិក្ខុនោះក៏ខឹងមិនត្រេកអរ ដោយហេតុព្រោះថា ពួកភិក្ខុដឹងថាអាត្មាអញជាអ្នកត្រូវអាបត្តិហើយ ។ ម្នាលអាវុសោ សេចក្តីខឹងណាក្តី សេចក្តីមិនត្រេកអរណាក្តី ទាំងពីរនេះឯង ឈ្មោះថា អង្គណៈដែរ ។

(៤៨) ម្នាលអាវុសោ ហេតុនេះតែងមានជាប្រាកដ គ្រង់ថា សេចក្តីប្រាថ្នាកើតឡើងដល់ភិក្ខុពួកខ្លះ ក្នុងសាសនានេះ យ៉ាងនេះថា ឱហ្ន៎ អាត្មាអញ ត្រូវអាបត្តិមែនហើយ ពួកភិក្ខុចោទអាត្មាអញ ក្នុងទីស្ងាត់ចុះ សូមកុំចោទក្នុងកណ្តាលជំនុំសង្ឃឡើយ ។ ម្នាលអាវុសោ ហេតុនេះតែងមានជាប្រាកដ គ្រង់ពាក្យថា ពួកភិក្ខុចោទភិក្ខុនោះក្នុងកណ្តាលជំនុំសង្ឃ មិនចោទក្នុងទីស្ងាត់ ។ ភិក្ខុនោះខឹងមិនត្រេកអរ ដោយហេតុព្រោះថា ពួកភិក្ខុចោទអាត្មាអញ ក្នុងកណ្តាលជំនុំសង្ឃ មិនបានចោទក្នុងទីស្ងាត់ ។ ម្នាលអាវុសោ សេចក្តីខឹងឯណាក្តី សេចក្តីមិនត្រេកអរឯណាក្តី ទាំងពីរនេះឯង ឈ្មោះថា អង្គណៈដែរ ។

(៤៩) ម្នាលអាវុសោ ហេតុនេះតែងមានជាប្រាកដ គ្រង់ថា សេចក្តីប្រាថ្នាកើតឡើង ដល់ភិក្ខុពួកខ្លះ ក្នុងសាសនានេះ យ៉ាងនេះថា អាត្មាអញត្រូវអាបត្តិមែនហើយ បុគ្គលស្មើគ្នាគួរចោទអាត្មាអញ

នោ អប្បដិបុគ្គលោតិ ។ ឋានំ ខោ បនេតំ អាវុសោ វិជ្ជតិ យន្តំ ភិក្ខុំ អប្បដិបុគ្គលោ ភវេយ្យ នោ សប្បដិបុគ្គលោ ។ អប្បដិបុគ្គលោ មំ ភវេតិ នោ សប្បដិបុគ្គលោតិ ឥតិ សោ កុបិតោ ហោតិ អប្បតីតោ ។ យោ ចេវ ខោ អាវុសោ កោបោ យោ ច អប្បច្ចយោ ឧភយមេតំ អង្គណំ ។

(៦០) ឋានំ ខោ បនេតំ អាវុសោ វិជ្ជតិ យំ ឥធេកច្ចស្ស ភិក្ខុនោ ឯវំ ឥច្ឆា ឧប្បជ្ជេយ្យ អហោ វត មមេវ សត្ថា បដិបុច្ឆិត្វា បដិបុច្ឆិត្វា ភិក្ខូនំ ធម្មំ ទេសេយ្យ ន អញ្ញំ ភិក្ខុំ សត្ថា បដិបុច្ឆិត្វា បដិបុច្ឆិត្វា ភិក្ខូនំ ធម្មំ ទេសេយ្យាតិ ។ ឋានំ ខោ បនេតំ អាវុសោ វិជ្ជតិ យំ អញ្ញំ ភិក្ខុំ សត្ថា បដិបុច្ឆិត្វា បដិបុច្ឆិត្វា ភិក្ខូនំ ធម្មំ ទេសេយ្យ ន តំ ភិក្ខុំ សត្ថា បដិបុច្ឆិត្វា បដិបុច្ឆិត្វា ភិក្ខូនំ ធម្មំ ទេសេយ្យ ។



បុគ្គលមិនស្មើគ្នា មិនគួរទៅរកអាត្មាអញទេ ។ ម្នាលអាវុសោ ហេតុនេះ តែងមានជាប្រាកដ គឺថា បុគ្គលមិនស្មើគ្នា ទៅរកភិក្ខុនោះ បុគ្គលស្មើគ្នា មិនទៅរកភិក្ខុនោះឡើយ ។ ភិក្ខុនោះ ក៏មិនត្រេកអរ ដោយហេតុប៉ុណ្ណេះថា បុគ្គលមិនស្មើគ្នា ទៅរកអាត្មាអញ បុគ្គលស្មើគ្នាមិនទៅរកអាត្មាអញឡើយ ។ ម្នាលអាវុសោ សេចក្ដីខឹងណាក្ដី សេចក្ដីមិនត្រេកអរណាក្ដី ទាំងពីរនេះឯង ឈ្មោះថា អង្គណៈដែរ ។

(៦០) ម្នាលអាវុសោ ហេតុនេះតែងមានជាប្រាកដ គឺថា សេចក្ដីប្រាថ្នាកើតឡើងដល់ភិក្ខុពួកខ្លះ ក្នុងសាសនានេះ យ៉ាងនេះថា ឱហ្ន៎ ព្រះសាស្ដាគប្បីសួរអាត្មាអញរឿយៗ ហើយទើបសំដែងធម៌ដល់ពួកភិក្ខុ ព្រះសាស្ដាកុំគប្បីសួរភិក្ខុឯទៀតរឿយៗ ហើយសំដែងធម៌ដល់ពួកភិក្ខុឡើយ ។ ម្នាលអាវុសោ ហេតុនេះ តែងមានជាប្រាកដ គឺថា ព្រះសាស្ដាសួរភិក្ខុឯទៀតរឿយៗ ហើយសំដែងធម៌ដល់ពួកភិក្ខុ ព្រះសាស្ដាមិនសួរភិក្ខុនោះរឿយៗ ហើយសំដែងធម៌ ដល់ពួកភិក្ខុឡើយ ។

អញ្ញំ ភិក្ខុំ សត្ថា បដិបុច្ឆិត្វា បដិបុច្ឆិត្វា ភិក្ខូនំ ធម្មំ ទេសេតិ ន មំ សត្ថា បដិបុច្ឆិត្វា បដិបុច្ឆិត្វា ភិក្ខូនំ ធម្មំ ទេសេតីតិ ឥតិ សោ កុបិតោ ហោតិ អប្បតីតោ ។ យោ ចេវ ខោ អាវុសោ កោបោ យោ ច អប្បច្ចយោ ឧភយមេតំ អង្គណំ ។

(៦១) ឋានំ ខោ បនេតំ អាវុសោ វិជ្ជតិ យំ ឥធេកច្ចស្ស ភិក្ខុនោ ឯវំ ឥច្ឆា ឧប្បជ្ជេយ្យ អហោ វត មមេវ ភិក្ខូ បុរក្ខត្វា បុរក្ខត្វា គាមំ ភត្តាយ បវិសេយ្យុំ ន អញ្ញំ ភិក្ខុំ ភិក្ខូ បុរក្ខត្វា បុរក្ខត្វា គាមំ ភត្តាយ បវិសេយ្យុន្តិ ។ ឋានំ ខោ បនេតំ អាវុសោ វិជ្ជតិ យំ អញ្ញំ ភិក្ខុំ ភិក្ខូ បុរក្ខត្វា បុរក្ខត្វា គាមំ ភត្តាយ បវិសេយ្យុំ ន តំ ភិក្ខុំ ភិក្ខូ បុរក្ខត្វា បុរក្ខត្វា គាមំ ភត្តាយ បវិសេយ្យុំ ។ អញ្ញំ ភិក្ខុំ ភិក្ខូ បុរក្ខត្វា បុរក្ខត្វា គាមំ ភត្តាយ បវិសន្តិ ន មំ ភិក្ខូ បុរក្ខត្វា បុរក្ខត្វា គាមំ ភត្តាយ បវិសន្តីតិ ឥតិ សោ កុបិតោ ហោតិ អប្បតីតោ ។ យោ ចេវ ខោ អាវុសោ កោបោ យោ ច អប្បច្ចយោ ឧភយមេតំ អង្គណំ ។



ភិក្ខុនោះខឹងមិនត្រេកអរ ដោយហេតុដូច្នេះថា ព្រះសាស្តាសួរភិក្ខុឯទៀត ហើយ ៗ ហើយសំដែងធម៌ ដល់ពួកភិក្ខុ ព្រះសាស្តាមិនសួរអាត្មាអញ ហើយ ៗ ហើយសំដែងធម៌ ដល់ពួកភិក្ខុ ។ ម្នាលអាវុសោ សេចក្តីខឹងណាក្តី សេចក្តីមិនត្រេកអរណាក្តី ទាំងពីរនេះឯង ឈ្មោះថាអង្គណៈដែរ ។

(៦១) ម្នាលអាវុសោ ហេតុនេះតែងមានជាប្រាកដ គឺថា សេចក្តីប្រាថ្នាកើតឡើងដល់ភិក្ខុពួកខ្លះ ក្នុងសាសនានេះ យ៉ាងនេះថា ធ្វើម្តេចហ្ន៎ ពួកភិក្ខុគប្បីហែហមអាត្មាអញ ចូលទៅកាន់ស្រុក ដើម្បីភត្ត ពួកភិក្ខុកុំគប្បីហែហមភិក្ខុឯទៀត ចូលទៅកាន់ស្រុក ដើម្បីភត្តឡើយ ។ ម្នាលអាវុសោ ហេតុនេះតែងមានជាប្រាកដ គឺថា ពួកភិក្ខុ គប្បីហែហមភិក្ខុឯទៀតហើយ ៗ ចូលទៅកាន់ស្រុក ដើម្បីភត្ត ពួកភិក្ខុមិនគប្បីហែហមភិក្ខុនោះហើយ ៗ ចូលទៅកាន់ស្រុក ដើម្បីភត្ត ។ ភិក្ខុនោះខឹងមិនត្រេកអរដោយហេតុដូច្នេះថា ពួកភិក្ខុហែហមភិក្ខុឯទៀតហើយ ៗ ចូលទៅកាន់ស្រុក ដើម្បីភត្ត ពួកភិក្ខុមិនហែហមអាត្មាអញហើយ ៗ ចូលទៅកាន់ស្រុក ដើម្បីភត្ត ។ ម្នាលអាវុសោ សេចក្តីខឹងណាក្តី សេចក្តីមិនត្រេកអរណាក្តី ទាំងពីរនេះឯងឈ្មោះថា អង្គណៈដែរ ។

(៦២) ឋានំ ខោ បនេតំ អាវុសោ វិជ្ជតិ យំ ឥធេកច្ចស្ស ភិក្ខុនោ ឯវំ ឥច្ឆា ឧប្បជ្ជេយ្យ អហោ វត អហមេវ លភេយ្យំ ភត្តគ្គេ អគ្គាសនំ អគ្គោទកំ អគ្គបិណ្ឌំ ន អញ្ញោ ភិក្ខុ លភេយ្យ ភត្តគ្គេ អគ្គាសនំ អគ្គោទកំ អគ្គបិណ្ឌន្តិ ។ ឋានំ ខោ បនេតំ អាវុសោ វិជ្ជតិ យំ អញ្ញោ ភិក្ខុ លភេយ្យ ភត្តគ្គេ អគ្គាសនំ អគ្គោទកំ អគ្គបិណ្ឌំ ន សោ ភិក្ខុ លភេយ្យ ភត្តគ្គេ អគ្គាសនំ អគ្គោទកំ អគ្គបិណ្ឌំ ។ អញ្ញោ ភិក្ខុ លភតិ ភត្តគ្គេ អគ្គាសនំ អគ្គោទកំ អគ្គបិណ្ឌំ នាហំ លភាមិ ភត្តគ្គេ អគ្គាសនំ អគ្គោទកំ អគ្គបិណ្ឌន្តិ ឥតិ សោ កុបិតោ ហោតិ អប្បតីតោ ។ យោ ចេវ ខោ អាវុសោ កោបោ យោ ច អប្បច្ចយោ ឧភយមេតំ អង្គណំ ។

(៦៣) ឋានំ ខោ បនេតំ អាវុសោ វិជ្ជតិ យំ ឥធេកច្ចស្ស ភិក្ខុនោ ឯវំ ឥច្ឆា ឧប្បជ្ជេយ្យ អហោ វត អហមេវ ភត្តគ្គេ ភុត្តាវី អនុមោទេយ្យំ ន អញ្ញោ ភិក្ខុ





(៦២) ម្នាលអាវុសោ ហេតុនេះតែងមានជាប្រាកដ គឺថា សេចក្តីប្រាថ្នាកើតឡើង ដល់ភិក្ខុពួកខ្លះក្នុងសាសនានេះ យ៉ាងនេះថា ឱហ្ន៎ អាត្មាអញគប្បីបានអាសនៈដ៏ប្រសើរ ទឹកដ៏ប្រសើរ បច្ច័យបិណ្ឌបាតដ៏ប្រសើរក្នុងរោងភត្ត ភិក្ខុឯទៀតកុំគប្បីបានអាសនៈដ៏ប្រសើរ ទឹកដ៏ប្រសើរ បច្ច័យបិណ្ឌបាតដ៏ប្រសើរក្នុងរោងភត្តឡើយ ។ ម្នាលអាវុសោ ហេតុនេះ តែងមានជាប្រាកដ គឺថា ភិក្ខុឯទៀត គប្បីបានអាសនៈដ៏ប្រសើរ ទឹកដ៏ប្រសើរ បច្ច័យបិណ្ឌបាតដ៏ប្រសើរក្នុងរោងភត្ត ភិក្ខុនោះមិនគប្បីបានអាសនៈដ៏ប្រសើរ ទឹកដ៏ប្រសើរ បច្ច័យបិណ្ឌបាតដ៏ប្រសើរក្នុងរោងភត្ត ។ ភិក្ខុនោះខឹងមិនត្រេកអរ ដោយហេតុដូច្នេះថា ភិក្ខុឯទៀតបានអាសនៈដ៏ប្រសើរ ទឹកដ៏ប្រសើរ បច្ច័យបិណ្ឌបាតដ៏ប្រសើរក្នុងរោងភត្ត អាត្មាអញមិនបានអាសនៈដ៏ប្រសើរ ទឹកដ៏ប្រសើរ បច្ច័យបិណ្ឌបាតដ៏ប្រសើរក្នុងរោងភត្តឡើយ ។ ម្នាលអាវុសោ សេចក្តីខឹងណាក្តី សេចក្តីមិនត្រេកអរណាក្តី ទាំងពីរនេះឯង ឈ្មោះថា អង្គណៈដែរ ។

(៦៣) ម្នាលអាវុសោ ហេតុនេះតែងមានជាប្រាកដ គឺថា សេចក្តីប្រាថ្នាកើតឡើង ដល់ភិក្ខុពួកខ្លះក្នុងសាសនានេះ យ៉ាងនេះថា ឱហ្ន៎ អាត្មាអញឆាន់ហើយ បានអនុមោទនាក្នុងរោងភត្ត ភិក្ខុឯទៀតឆាន់ហើយ

ភត្តគ្គេ ភុត្តាវី អនុមោទេយ្យាតិ ។ ឋានំ ខោ បនេតំ អាវុសោ វិជ្ជតិ យំ អញ្ញោ ភិក្ខុ ភត្តគ្គេ ភុត្តាវី អនុមោទេយ្យ ន សោ ភិក្ខុ ភត្តគ្គេ ភុត្តាវី អនុមោទេយ្យ ។ អញ្ញោ ភិក្ខុ ភត្តគ្គេ ភុត្តាវី អនុមោទតិ នាហំ ភត្តគ្គេ ភុត្តាវី អនុមោទាមីតិ ឥតិ សោ កុបិតោ ហោតិ អប្បតីតោ ។ យោ ចេវ ខោ អាវុសោ កោបោ យោ ច អប្បច្ចយោ ឧភយមេតំ អង្គណំ ។

(៦៨) ឋានំ ខោ បនេតំ អាវុសោ វិជ្ជតិ យំ ឥធេកច្ចស្ស ភិក្ខុនោ ឯវំ ឥច្ឆា ឧប្បជ្ជេយ្យ អហមេវ អារាមគតានំ ភិក្ខូនំ ធម្មំ ទេសេយ្យំ ន អញ្ញោ ភិក្ខុ អារាមគតានំ ភិក្ខូនំ ធម្មំ ទេសេយ្យាតិ ។ ឋានំ ខោ បនេតំ អាវុសោ វិជ្ជតិ យំ អញ្ញោ ភិក្ខុ អារាមគតានំ ភិក្ខូនំ ធម្មំ ទេសេយ្យ ន សោ ភិក្ខុ

៩០
សុត្តន្តបិដក មជ្ឈិមនិកាយ មូលបណ្ណាសក

មិនគប្បីអនុមោទនាក្នុងរោងភត្តឡើយ ។ ម្នាលអាវុសោ ហេតុនេះ តែងមានជាប្រាកដ ត្រង់ថា ភិក្ខុឯទៀតឆាន់ហើយ គប្បីអនុមោទនា ក្នុងរោងភត្ត ភិក្ខុនោះឆាន់ហើយមិនគប្បីបានអនុមោទនា ក្នុងរោងភត្តឡើយ ។ ភិក្ខុនោះខឹងមិនត្រេកអរ ដោយហេតុដូច្នេះថា ភិក្ខុឯទៀតឆាន់ហើយបាន អនុមោទនាក្នុងរោងភត្ត អាត្មាអញឆាន់ហើយ មិនបានអនុមោទនា ក្នុងរោងភត្តឡើយ ។ ម្នាលអាវុសោ សេចក្តីខឹងណាក្តី សេចក្តីមិនត្រេកអរណាក្តី ទាំងពីរនេះឯង ឈ្មោះថា អង្គណៈដែរ ។

(៦៨) ម្នាលអាវុសោ ហេតុនេះ តែងមានជាប្រាកដ ត្រង់ថា សេចក្តីប្រាថ្នាកើតឡើងដល់ភិក្ខុពួកខ្លះ ក្នុងសាសនានេះ យ៉ាងនេះថា ឱហ្ន៎ អាត្មាអញគប្បីសំដែងធម៌ ដល់ពួកភិក្ខុដែលឋិតនៅក្នុងអារាម ភិក្ខុឯទៀត មិនគប្បីសំដែងធម៌ ដល់ពួកភិក្ខុដែលឋិតនៅក្នុងអារាមឡើយ ។ ម្នាលអាវុសោ ហេតុនេះ តែងមានជាប្រាកដ ត្រង់ថា ភិក្ខុឯទៀត សំដែងធម៌ ដល់ពួកភិក្ខុដែលឋិតនៅក្នុងអារាម ភិក្ខុនោះ មិនគប្បី

អារាមគតានំ ភិក្ខូនំ ធម្មំ ទេសេយ្យ ។ អញ្ញេ ភិក្ខូ អារាមគតានំ ភិក្ខូនំ ធម្មំ ទេសេន្តិ នាហំ អារាមគតានំ ភិក្ខូនំ ធម្មំ ទេសេមីតិ ឥតិ សោ កុបិតោ ហោតិ អប្បតីតោ ។ យោ ចេវ ខោ អាវុសោ កោបោ យោ ច អប្បច្ចយោ ឧភយមេតំ អង្គណំ ។

(៦៨) ឋានំ ខោ បនេតំ អាវុសោ វិជ្ជតិ យំ ឥធេកច្ចស្ស ភិក្ខុនោ ឯវំ ឥច្ឆា ឧប្បជ្ជេយ្យ អហោ វត អហមេវ អារាមគតានំ ភិក្ខូនំ ធម្មំ ទេសេយ្យំ ។ បេ ។ ឧបាសកានំ ធម្មំ ទេសេយ្យំ ។ បេ ។ ឧបាសិកានំ ធម្មំ ទេសេយ្យំ ន អញ្ញេ ភិក្ខូ អារាមគតានំ ឧបាសិកានំ ធម្មំ ទេសេយ្យុន្តិ ។ ឋានំ ខោ បនេតំ អាវុសោ វិជ្ជតិ យំ អញ្ញេ ភិក្ខូ អារាមគតានំ ឧបាសិកានំ ធម្មំ ទេសេយ្យុំ ន សោ ភិក្ខុ អារាមគតានំ ឧបាសិកានំ ធម្មំ ទេសេយ្យ ។



សំដែងធម៌ ដល់ពួកភិក្ខុដែលឋិតនៅក្នុងអារាមឡើយ ។ ភិក្ខុនោះទើបមិនត្រេកអរ ដោយហេតុដូច្នេះថា ភិក្ខុឯទៀតបានសំដែងធម៌ ដល់ពួកភិក្ខុដែលឋិតនៅក្នុងអារាម អាត្មាអញមិនបានសំដែងធម៌ ដល់ពួកភិក្ខុដែលឋិតនៅក្នុងអារាម ។ ម្នាលអាវុសោ សេចក្តីទឹងក្រោធក្តី សេចក្តីមិនត្រេកអរក្តី ទាំងពីរនេះឯងឈ្មោះថា អង្គណៈដែរ ។

(៦៨) ម្នាលអាវុសោ ហេតុនេះ តែងមានជាប្រាកដ ត្រង់ថា សេចក្តីប្រាថ្នាកើតឡើង ដល់ភិក្ខុពួកខ្លះក្នុងសាសនានេះ យ៉ាងនេះថា ឱហ្ន៎ អាត្មាអញគប្បីសំដែងធម៌ ដល់ពួកភិក្ខុនីដែលឋិតនៅក្នុងអារាម ។ បេ ។ គប្បីសំដែងធម៌ ដល់ពួកឧបាសក ។ បេ ។ គប្បីសំដែងធម៌ ដល់ពួកឧបាសិកា ភិក្ខុឯទៀតមិនគប្បីសំដែងធម៌ ដល់ពួកឧបាសិកាដែលមកកាន់អារាម ។ ម្នាលអាវុសោ ហេតុនេះតែងមានជាប្រាកដ ត្រង់ថាភិក្ខុឯទៀតគប្បីសំដែងធម៌ដល់ពួកឧបាសិកា ដែលមកកាន់អារាម ភិក្ខុនោះមិនគប្បីបានសំដែងធម៌ ដល់ពួកឧបាសិកាដែលមកកាន់អារាម ។ ភិក្ខុនោះ

អញ្ញោ ភិក្ខុ អារាមគតានំ ឧបាសិកានំ ធម្មំ ទេសេតិ នាហំ អារាមគតានំ ឧបាសិកានំ ធម្មំ ទេសេមីតិ ឥតិ សោ កុបិតោ ហោតិ អប្បតីតោ ។ យោ ចេវ ខោ អាវុសោ កោបោ យោ ច អប្បច្ចយោ ឧភយមេតំ អង្គណំ ។

(៦៦) ឋានំ ខោ បនេតំ អាវុសោ វិជ្ជតិ យំ ឥធេកច្ចស្ស ភិក្ខុនោ ឯវំ ឥច្ឆា ឧប្បជ្ជេយ្យ អហោ វត មមេវ ភិក្ខូ សក្ករេយ្យុំ គរុការេយ្យុំ មានេយ្យុំ បូជេយ្យុំ ន អញ្ញំ ភិក្ខុំ ភិក្ខូ សក្ករេយ្យុំ គរុការេយ្យុំ មានេយ្យុំ បូជេយ្យុន្តិ ។ ឋានំ ខោ បនេតំ អាវុសោ វិជ្ជតិ យំ អញ្ញំ ភិក្ខុំ ភិក្ខូ សក្ករេយ្យុំ គរុការេយ្យុំ មានេយ្យុំ បូជេយ្យុំ ន តំ ភិក្ខុំ ភិក្ខូ សក្ករេយ្យុំ គរុការេយ្យុំ មានេយ្យុំ



ខឹងមិនត្រេកអរ ដោយហេតុដូច្នេះថា ភិក្ខុឯទៀតបានសំដែងធម៌ ដល់ពួកឧបាសិកាដែលមកកាន់អារាម អាត្មាអញមិនបានសំដែងធម៌ ដល់ពួកឧបាសិកាដែលមកកាន់អារាម ។ ម្នាលអាវុសោ សេចក្ដីខឹងណាក្ដី សេចក្ដីមិនត្រេកអរណាក្ដី ទាំងពីរនេះឯងឈ្មោះថា អង្គណៈដែរ ។

(៦៦) ម្នាលអាវុសោ ហេតុនេះ តែងមានជាប្រាកដ ត្រង់ថា សេចក្ដីប្រាថ្នាកើតឡើង ដល់ភិក្ខុពួកខ្លះក្នុងសាសនានេះ យ៉ាងនេះថា ឱហ្ន៎ ពួកភិក្ខុគប្បីធ្វើសក្ការៈ គោរព រាប់អាន បូជាអាត្មាអញ ពួកភិក្ខុមិនគប្បីធ្វើសក្ការៈ គោរព រាប់អាន បូជាភិក្ខុឯទៀតឡើយ ។ ម្នាលអាវុសោ ហេតុនេះ តែងមានជាប្រាកដ ត្រង់ថា ពួកភិក្ខុគប្បីធ្វើសក្ការៈ គោរព រាប់អាន បូជាភិក្ខុឯទៀត ពួកភិក្ខុមិនគប្បីធ្វើសក្ការៈ គោរព រាប់អាន

បូជេយ្យុំ ។ អញ្ញំ ភិក្ខុំ ភិក្ខូ សក្ករោន្តិ គរុការោន្តិ មានេន្តិ បូជេន្តិ ន មំ ភិក្ខូ សក្ករោន្តិ គរុការោន្តិ មានេន្តិ បូជេន្តីតិ ឥតិ សោ កុបិតោ ហោតិ អប្បតីតោ ។ យោ ចេវ ខោ អាវុសោ កោបោ យោ ច អប្បច្ចយោ ឧភយមេតំ អង្គណំ ។

(៦៧) ឋានំ ខោ បនេតំ អាវុសោ វិជ្ជតិ យំ ឥធេកច្ចស្ស ភិក្ខុនោ ឯវំ ឥច្ឆា ឧប្បជ្ជេយ្យ អហោ វត មមេវ ភិក្ខុនិយោ ។ បេ ។ ឧបាសកា ។ បេ ។ ឧបាសិកាយោ[១] សក្ករេយ្យុំ គរុករេយ្យុំ មានេយ្យុំ បូជេយ្យុំ ន អញ្ញំ ភិក្ខុំ ឧបាសិកាយោ[២] សក្ករេយ្យុំ គរុករេយ្យុំ មានេយ្យុំ បូជេយ្យុន្តិ ។ ឋានំ ខោ បនេតំ អាវុសោ វិជ្ជតិ យំ អញ្ញំ ភិក្ខុំ ឧបាសិកាយោ សក្ករេយ្យុំ គរុករេយ្យុំ មានេយ្យុំ បូជេយ្យុំ ន តំ ភិក្ខុំ ឧបាសិកាយោ សក្ករេយ្យុំ គរុករេយ្យុំ មានេយ្យុំ បូជេយ្យុំ ។ អញ្ញំ ភិក្ខុំ ឧបាសិកាយោ សក្ករោន្តិ គរុករោន្តិ មានេន្តិ បូជេន្តិ



បូជាភិក្ខុនោះឡើយ ។ ភិក្ខុនោះខឹងមិនត្រេកអរ ដោយហេតុដូច្នេះថា ពួកភិក្ខុធ្វើសក្ការៈ គោរព រាប់អាន បូជាភិក្ខុឯទៀត ពួកភិក្ខុមិនធ្វើសក្ការៈ គោរព រាប់អាន បូជាអាត្មាអញ ។ ម្នាលអាវុសោ សេចក្តីខឹងណាក្តី សេចក្តីមិនត្រេកអរណាក្តី ទាំងពីរនេះឯង ឈ្មោះថា អង្គណៈ ។

(៦៧) ម្នាលអាវុសោ ហេតុនេះ តែងមានជាប្រាកដ ត្រង់ថា សេចក្តីប្រាថ្នាកើតឡើង ដល់ភិក្ខុពួកខ្លះ ក្នុងសាសនានេះ យ៉ាងនេះថា ឱហ្ន៎ ពួកភិក្ខុនី ។ បេ ។ ពួកឧបាសក ។ បេ ។ ពួកឧបាសិកា គប្បីធ្វើសក្ការៈ គោរព រាប់អាន បូជាអាត្មាអញ ពួកឧបាសិកា កុំ គប្បីធ្វើសក្ការៈ គោរព រាប់អាន បូជាភិក្ខុឯទៀតឡើយ ។ ម្នាលអាវុសោ ហេតុនេះ តែងមានជាប្រាកដ ត្រង់ថា ពួកឧបាសិកាគប្បីធ្វើសក្ការៈ គោរព រាប់អាន បូជាភិក្ខុឯទៀត ពួកឧបាសិកា មិនគប្បីធ្វើសក្ការៈ គោរព រាប់អាន បូជាភិក្ខុនោះ ។ ភិក្ខុនោះខឹងមិនត្រេកអរ ដោយហេតុដូច្នេះថា ពួកឧបាសិកាធ្វើសក្ការៈ គោរព រាប់អាន បូជាតែភិក្ខុឯទៀត

ន មំ ឧបាសិកាយោ សក្ករោន្តិ គរុករោន្តិ មានេន្តិ បូជេន្តីតិ ឥតិ សោ កុបិតោ ហោតិ អប្បតីតោ ។ យោ ចេវ ខោ អាវុសោ កោបោ យោ ច អប្បច្ចយោ ឧភយមេតំ អង្គណំ ។

(៦៨) ឋានំ ខោ បនេតំ អាវុសោ វិជ្ជតិ យំ ឥធេកច្ចស្ស ភិក្ខុនោ ឯវំ ឥច្ឆា ឧប្បជ្ជេយ្យ អហោ វត អហមេវ លាភី អស្សំ បណីតានំ ចីវរានំ ន អញ្ញោ ភិក្ខុ លាភី អស្ស បណីតានំ ចីវរានន្តិ ។ ឋានំ ខោ បនេតំ អាវុសោ វិជ្ជតិ យំ អញ្ញោ ភិក្ខុ លាភី អស្ស បណីតានំ ចីវរានំ ន សោ ភិក្ខុ លាភី អស្ស បណីតានំ ចីវរានំ ។ អញ្ញំ ភិក្ខុំ លាភឹ បណីតានំ ចីវរានំ អហំ អលាភី បណីតានំ ចីវរានន្តិ ឥតិ សោ កុបិតោ ហោតិ អប្បតីតោ ។ យោ ចេវ ខោ អាវុសោ កោបោ យោ ច អប្បច្ចយោ ឧភយមេតំ អង្គណំ ។



ពួកឧបាសិកា មិនធ្វើសក្ការៈ គោរព កោតក្រែង បូជាអាត្មាអញឡើយ ។ ម្នាលអាវុសោ សេចក្តីខឹងណាក្តី សេចក្តីមិនត្រេកអរណាក្តី ទាំងពីរនេះឯង ឈ្មោះថា អង្គណៈដែរ ។

(៦៨) ម្នាលអាវុសោ ហេតុនេះ តែងមានជាប្រាកដ ត្រង់ថា សេចក្តីប្រាថ្នាកើតឡើង ដល់ភិក្ខុពួកខ្លះ ក្នុងសាសនានេះ យ៉ាងនេះថា ឱហ្ន៎ អាត្មាអញគប្បីបានចីវរដ៏ប្រសើរ ភិក្ខុឯទៀតកុំគប្បីបានចីវរដ៏ប្រសើរឡើយ ។ ម្នាលអាវុសោ ហេតុនេះ តែងមានជាប្រាកដ ត្រង់ថា ភិក្ខុឯទៀតគប្បីបានចីវរដ៏ប្រសើរ ភិក្ខុនោះមិនគប្បីបានចីវរដ៏ប្រសើរ ។ ភិក្ខុនោះខឹងមិនត្រេកអរ ដោយហេតុដូច្នេះថា ភិក្ខុឯទៀតបានចីវរដ៏ប្រសើរ អាត្មាអញមិនបានចីវរដ៏ប្រសើរ ។ ម្នាលអាវុសោ សេចក្តីខឹងណាក្តី សេចក្តីមិនត្រេកអរណាក្តី ទាំងពីរនេះឯង ឈ្មោះថា អង្គណៈដែរ ។

(៦៩) ឋានំ ខោ បនេតំ អាវុសោ វិជ្ជតិ យំ ឥធេកច្ចស្ស ភិក្ខុនោ ឯវំ ឥច្ឆា ឧប្បជ្ជេយ្យ អហោ វត អហមេវ លាភី អស្សំ បណីតានំ បិណ្ឌបាតានំ ។ បេ ។ បណីតានំ សេនាសនានំ ។ បេ ។ បណីតានំ គិលានប្បច្ចយភេសជ្ជបរិក្ខារានំ ន អញ្ញោ ភិក្ខុ លាភី អស្ស បណីតានំ គិលានប្បច្ចយភេសជ្ជបរិក្ខារានន្តិ ។ ឋានំ ខោ បនេតំ អាវុសោ វិជ្ជតិ យំ អញ្ញោ ភិក្ខុ លាភី អស្ស បណីតានំ គិលានប្បច្ចយភេសជ្ជបរិក្ខារានំ ន សោ ភិក្ខុ លាភី អស្ស បណីតានំ គិលានប្បច្ចយភេសជ្ជបរិក្ខារានំ ។ អញ្ញោ ភិក្ខុ លាភី បណីតានំ គិលានប្បច្ចយភេសជ្ជបរិក្ខារានំ នាហំ លាភី បណីតានំ គិលានប្បច្ចយភេសជ្ជបរិក្ខារានន្តិ ឥតិ សោ កុបិតោ ហោតិ អប្បតីតោ ។ យោ ចេវ ខោ អាវុសោ កោបោ យោ ច អប្បច្ចយោ ឧភយមេតំ អង្គណំ ។ ឥមេសំ ខោ ឯតំ អាវុសោ បាបកានំ អកុសលានំ ឥច្ឆាវចរានំ អធិវចនំ យទិទំ អង្គណន្តិ ។



(៦៩) ម្នាលអាវុសោ ហេតុនេះ តែងមានជាប្រាកដ គឺថា សេចក្តីប្រាថ្នាកើតឡើង ដល់ភិក្ខុពួកខ្លះ ក្នុងសាសនានេះ យ៉ាងនេះថា ឱហ្ន៎ អាត្មាអញគប្បីបានចង្ហាន់បិណ្ឌបាតដ៏ប្រសើរ ។ បេ ។ សេនាសនៈដ៏ប្រសើរ ។ បេ ។ គិលានប្បច្ចយភេសជ្ជបរិក្ខារដ៏ប្រសើរ ភិក្ខុឯទៀត កុំគប្បីបាននូវគិលានប្បច្ចយភេសជ្ជបរិក្ខារដ៏ប្រសើរឡើយ ។ ម្នាលអាវុសោ ហេតុនេះ តែងមានជាប្រាកដ គឺថា ភិក្ខុឯទៀតគប្បីបាននូវគិលានប្បច្ចយភេសជ្ជបរិក្ខារដ៏ប្រសើរ ភិក្ខុនោះមិនគប្បីបាននូវគិលានប្បច្ចយភេសជ្ជបរិក្ខារដ៏ប្រសើរឡើយ ។ ភិក្ខុនោះខឹងមិនត្រេកអរ ដោយហេតុដូច្នេះថា ភិក្ខុឯទៀតបាននូវគិលានប្បច្ចយភេសជ្ជបរិក្ខារដ៏ប្រសើរ អាត្មាអញមិនបាននូវគិលានប្បច្ចយភេសជ្ជបរិក្ខារ ដ៏ប្រសើរឡើយ ។ ម្នាលអាវុសោ សេចក្តីខឹងណាក្តី សេចក្តីមិនត្រេកអរណាក្តី ទាំងពីរនេះឯង ឈ្មោះថា អង្គណៈដែរ ។ ម្នាលអាវុសោ ពាក្យថា អង្គណៈនេះ ជាឈ្មោះអកុសលធម៌លាមក ដែលគ្របសង្កត់ចិត្តដោយអំណាចសេចក្តីប្រាថ្នានេះឯង ។

(៧០) យស្ស កស្សចិ អាវុសោ ភិក្ខុនោ ឥមេ បាបកា អកុសលា វិតក្កា អប្បហីនា ទិស្សន្តិ ចេវ សុយ្យន្តិ ច ។ កិញ្ចាបិ សោ ហោតិ អារញ្ញកោ បន្តសេនាសនោ បិណ្ឌបាតិកោ សបទានចារី បំសុកូលិកោ[១] លូខចីវរធរោ អថខោ នំ សព្រហ្មចារី ចេវ[២] សក្ករោន្តិ ន គរុករោន្តិ ន មានេន្តិ ន បូជេន្តិ ។ តំ កិស្ស ហេតុ ។ តេ ហិ តស្ស អាយស្មតោ បាបកា អកុសលា វិតក្កា អប្បហីនា ទិស្សន្តិ ចេវ សុយ្យន្តិ ច ។ សេយ្យថាបិ អាវុសោ កំសបាតិ អាភតា អាបណា វា កម្មារកុលា វា បរិសុទ្ធា បរិយោទាតា ។ តមេនំ សាមិកា អហិកុណបំ វា កុក្កុរកុណបំ វា មនុស្សកុណបំ វា រចយិត្វា អញ្ញិស្សា កំសបាតិយា បដិកុជ្ជិត្វា អន្តរាបណំ បដិបជ្ជេយ្យុំ ។ តមេនំ ជនោ ទិស្វា ឯវំ វទេយ្យ

១ ឱ.ម. បំសុកូលិកោ ។ ២ ឱ. ន ។ ម. ន ចេវ ។



(៧០) ម្នាលអាវុសោ អកុសលដ៏លាមក ដែលគ្របសង្កត់ចិត្ត ដោយអំណាចសេចក្តីប្រាថ្នាទាំងនេះ ភិក្ខុណាមួយ មិនលះបង់ចោល ហើយ អ្នកផងឃើញច្បាស់ផង ឮច្បាស់ផង ។ បើទុកជាភិក្ខុនោះ ប្រព្រឹត្តអារញ្ញកធុតង្គ មានសេនាសនៈស្ងាត់ ប្រព្រឹត្តបិណ្ឌបាតិកធុតង្គ សបទានចារិកធុតង្គ បំសុកូលិកធុតង្គ ទ្រទ្រង់ចីវរសៅហ្មង ក៏គង់តែពួក សព្រហ្មចារីមិនធ្វើសក្ការៈ មិនគោរព មិនរាប់អាន មិនបូជាភិក្ខុនោះ ឡើយ ។ ដំណើរនោះព្រោះហេតុអ្វី ។ ព្រោះថាអកុសល ដ៏លាមក ដែលគ្របសង្កត់ចិត្ត ដោយអំណាចសេចក្តីប្រាថ្នាទាំងនោះ របស់លោកមាន អាយុនោះ មិនលះបង់ចោល អ្នកផងឃើញច្បាស់ផង ឮច្បាស់ផង ។ ម្នាលអាវុសោ ដូចជាភាជន៍សំរិទ្ធ ដែលគេនាំមកអំពីផ្សារ ឬអំពីត្រកូលជាងលោហៈ ជាភាជន៍បរិសុទ្ធផូរផង់ ។ បុគ្គលជាម្ចាស់ទាំងឡាយ យកសាកសពពស់ ឬសាកសពឆ្កែ ឬសាកសពមនុស្ស ដាក់ពេញ ក្នុងភាជន៍នោះ ហើយគ្របដោយភាជន៍សំរិទ្ធដទៃ ហើយដើរទៅ ក្នុងចន្លោះផ្សារ ។ អ្នកផងឃើញភាជន៍នោះហើយ និយាយយ៉ាង

អម្ភោ កិមេវិទំ ហរីយតិ ជញ្ញំ ជញ្ញំ(១) វិយាតិ ។ តមេនំ ឧដ្ឋហិត្វា អវាបុរិត្វា ឱលោកេយ្យ តស្ស សហទស្សនេន អមនាបតា ច សណ្ឋហេយ្យ បាដិក្កុល្យតា ច សណ្ឋហេយ្យ ជេគុច្ឆតា ច សណ្ឋហេយ្យ ជិឃច្ឆិតានម្បិ ន ភោត្តុកម្យតា អស្ស បគេវ សុហិតានំ ឯវមេវ ខោ អាវុសោ យស្ស កស្សចិ ភិក្ខុនោ ឥមេ បាបកា អកុសលា ឥច្ឆាវចរា អប្បហីនា ទិស្សន្តិ ចេវ សុយ្យន្តិ ច ។ កិញ្ចាបិ សោ ហោតិ អារញ្ញកោ បន្តសេនាសនោ បិណ្ឌបាតិកោ សបទានចារី បំសុកូលិកោ លូខចីវរធរោ អថ ខោ នំ សព្រហ្មចារី នេវ សក្ករោន្តិ ន គរុករោន្តិ ន មានេន្តិ ន បូជេន្តិ ។ តំ កិស្ស ហេតុ ។ តេ ហិ តស្ស អាយស្មតោ បាបកា អកុសលា ឥច្ឆាវចរា អប្បហីនា ទិស្សន្តិ ចេវ សុយ្យន្តិ ច ។

១ ម.ម. ជញ្ញជញ្ញំ ។



នេះជា ម្នាលអ្នកដ៏ចំរើន ភាជន៍នេះហាក់ដូចជាគួរពេញចិត្តក្រៃលែង អ្នកឯងនាំទៅធ្វើអ្វីនេះ ។ លុះអ្នកផងក្រោកឡើងហើយបើកភាជន៍នោះមើល សេចក្តីមិនគាប់ចិត្តក្តី សេចក្តីខ្ពើមរអើមក្តី សេចក្តីធុញទ្រាន់ក្តីក៏តាំងឡើងប្រាកដដល់គេក្នុងខណៈដែលបានឃើញ សូម្បីបុគ្គលដែលស្រេកឃ្លានហើយ ក៏មិនគួរប្រាថ្នានឹងបរិភោគឡើយ នឹងបាច់និយាយថ្វី ដល់ពួកជនដែលបរិភោគឆ្អែតហើយ ម្នាលអាវុសោ អកុសលដ៏លាមកដែលគ្របសង្កត់ចិត្ត ដោយអំណាចសេចក្តីប្រាថ្នាទាំងនេះ ដែលភិក្ខុណាមួយ មិនទាន់លះបានហើយ អ្នកផងឃើញច្បាស់ផង ឮច្បាស់ផង ក៏យ៉ាងនោះឯង ។ បើទុកជាភិក្ខុនោះប្រព្រឹត្តអារញ្ញកធុតង្គ មានសេនាសនៈស្ងាត់ ប្រព្រឹត្តបិណ្ឌបាតិកធុតង្គ សបទានចារិកធុតង្គ បំសុកូលិកធុតង្គ ទ្រទ្រង់ចីវរសៅហ្មង ក៏គង់តែពួកសព្រហ្មចារី មិនធ្វើសក្ការៈ មិនគោរព មិនរាប់អាន មិនបូជាភិក្ខុនោះឡើយ ។ ដំណើរនោះព្រោះហេតុអ្វី ។ ព្រោះថាអកុសលដ៏លាមក ដែលគ្របសង្កត់ចិត្ត ដោយអំណាចសេចក្តីប្រាថ្នានោះ លោកដ៏មានអាយុនោះ មិនទាន់លះបាន អ្នកផងឃើញច្បាស់ផង ឮច្បាស់ផង ។

(៧១) យស្ស កស្សចិ អាវុសោ ភិក្ខុនោ ឥមេ បាបកា អកុសលា ឥច្ឆាវចរា បហីនា ទិស្សន្តិ ចេវ សុយ្យន្តិ ច ។ កិញ្ចាបិ សោ ហោតិ គាមន្តវិហារី នេមន្តនិកោ គហបតិចីវរធរោ អថ ខោ នំ សព្រហ្មចារី សក្ករោន្តិ គរុំករោន្តិ មានេន្តិ បូជេន្តិ ។ តំ កិស្ស ហេតុ ។ តេ ហិ តស្ស អាយស្មតោ បាបកា អកុសលា ឥច្ឆាវចរា បហីនា ទិស្សន្តិ ចេវ សុយ្យន្តិ ច ។ សេយ្យថាបិ អាវុសោ កំសបាតិ អាភតា អាបណា វា កម្មារកុលា វា បរិសុទ្ធា បរិយោទាតា ។ តមេនំ សាមិកា សាលីនំ ឱទនំ វិចិតកាឡកំ អនេកសូបំ អនេកព្យញ្ជនំ រចយិត្វា អញ្ញិស្សា កំសបាតិយា បដិកុជ្ជិត្វា អន្តរាបណំ បដិបជ្ជេយ្យុំ ។ តមេនំ ជនោ ទិស្វា ឯវំ វទេយ្យ អម្ភោ កិមេវិទំ ហរិយ្យតិ ជញ្ញជញ្ញំ វិយាតិ ។ តមេនំ ឧដ្ឋហិត្វា អបាបុរិត្វា ឱលោកេយ្យ





(៧១) ម្នាលអាវុសោ អកុសលដ៏លាមក ដែលគ្របសង្កត់ចិត្ត ដោយអំណាចនៃសេចក្តីប្រាថ្នាទាំងនេះ ដែលភិក្ខុណាមួយ លះបង់ហើយ អ្នកផងឃើញច្បាស់ផង ឮច្បាស់ផង ។ បើទុកជាភិក្ខុនោះ ជាអ្នកនៅក្នុងស្រុក ត្រេកអរនឹងការនិមន្ត ទ្រទ្រង់នូវគហបតិចីវរ ក៏គង់តែពួកសព្រហ្មចារី តែងធ្វើសក្ការៈ គោរព រាប់អាន បូជាភិក្ខុនោះ ។ ដំណើរនោះព្រោះហេតុអ្វី ។ ព្រោះថាអកុសលដ៏លាមក ដែលគ្របសង្កត់ចិត្ត ដោយអំណាចសេចក្តីប្រាថ្នាទាំងនោះ លោកមានអាយុនោះលះបង់ហើយ អ្នកផងឃើញច្បាស់ផង ឮច្បាស់ផង ។ ម្នាលអាវុសោ ដូចជាថាសសំរិទ្ធ ដែលគេយកមកអំពីផ្សារឬអំពីត្រកូលជាងលោហៈ ជាថាសបរិសុទ្ធផូរផង់ ។ បុគ្គលជាម្ចាស់ទាំងឡាយ យកបាយស្រូវសាលីដែលប្រាសចាកពណ៌ខ្មៅ មានសម្លនិងម្ហូបគ្រឿងច្រើនមុខដាក់ពេញក្នុងថាសនោះ ហើយគ្របដោយថាសសំរិទ្ធដទៃ ហើយដើរទៅក្នុងចន្លោះផ្សារ ។ ជនឃើញថាសនោះហើយនិយាយយ៉ាងនេះថា ម្នាលអ្នកដ៏ចំរើន ថាសនេះហាក់ដូចជាទីពេញចិត្តក្រៃលែង អ្នកឯងនាំទៅធ្វើអ្វីនេះ ។ លុះជននោះស្ទុះទៅបើកថាសនោះមើល

តស្ស សហទស្សនេន មនាបតា ច សណ្ឋហេយ្យ អប្បដិក្កូលតា ច សណ្ឋហេយ្យ អជេគុច្ឆតា ច សណ្ឋហេយ្យ សុហិតានម្បិ ភោត្តុកម្យតា អស្ស បគេវ ជិឃច្ឆិតានំ ឯវមេវ ខោ អាវុសោ យស្ស កស្សចិ ឥមេ បាបកា អកុសលា ឥច្ឆាវចរា បហីនា ទិស្សន្តិ ចេវ សុយ្យន្តិ ច ។ កិញ្ចាបិ សោ ហោតិ គាមន្តវិហារី នេមន្តនិកោ គហបតិចីវរធរោ អថ ខោ នំ សព្រហ្មចារី សក្ករោន្តិ គរុំ ករោន្តិ មានេន្តិ បូជេន្តិ ។ តំ កិស្ស ហេតុ ។ តេ ហិ តស្ស អាយស្មតោ បាបកា អកុសលា ឥច្ឆាវចរា បហីនា ទិស្សន្តិ ចេវ សុយ្យន្តិ ចាតិ ។

(៧២) ឯវំ វុត្តេ អាយស្មា មហាមោគ្គល្លានោ អាយស្មន្តំ សារីបុត្តំ ឯតទវោច ឧបមា មំ អាវុសោ សារីបុត្ត បដិភាតីតិ ។ បដិភាតុ តំ អាវុសោ



សេចក្ដីគាប់ចិត្តក្ដី សេចក្ដីមិនខ្ពើមរអើមក្ដី សេចក្ដីមិនធុញទ្រាន់ក្ដី ក៏កើតឡើងព្រោងដល់ជននោះ ក្នុងខណៈដែលបានឃើញ សូម្បីតែពួកជនដែលបរិភោគឆ្អែតហើយ ក៏គួរបរិភោគទៀត មិនបាច់និយាយទៅថ្វី ដល់ពួកជនដែលស្រេកឃ្លាននោះ ម្នាលអាវុសោ អកុសលដ៏លាមកដែលគ្របសង្កត់ចិត្ត ដោយអំណាចនៃសេចក្ដីប្រាថ្នាទាំងនេះ ដែលភិក្ខុណាមួយលះចោលហើយ អ្នកផងឃើញច្បាស់ផង ឮច្បាស់ផង ក៏ឈ្មោះនោះឯង ៗ បើទុកជាភិក្ខុនោះ ជាអ្នកនៅក្នុងស្រុក ត្រេកអរនឹងការនិមន្ត ទ្រទ្រង់នូវគហបតិចីវរ ក៏គង់តែពួកសព្រហ្មចារី តែងធ្វើសក្ការៈ គោរព រាប់អាន បូជាភិក្ខុនោះ ៗ ដំណើរនោះព្រោះហេតុអ្វី ៗ ព្រោះថាអកុសលដ៏លាមក ដែលគ្របសង្កត់ចិត្ត ដោយអំណាចសេចក្ដីប្រាថ្នាទាំងនោះ លោកមានអាយុនោះលះចោលហើយ អ្នកផងឃើញច្បាស់ផង ឮច្បាស់ផង ។

(៧៦) កាលបើព្រះសារីបុត្រ មានថេរដីកាយ៉ាងនេះហើយ ព្រះមហាមោគ្គល្លានមានអាយុ ក៏បាននិយាយពាក្យនេះទៅនឹងព្រះសារីបុត្រមានអាយុថា ម្នាលអាវុសោសារីបុត្រ ខ្ញុំសូមនាំយកពាក្យឧបមាមកសំដែងនៅទីនេះ ។ ព្រះសារីបុត្រតបថា ម្នាលអាវុសោមោគ្គល្លាន

មោគ្គល្លានោតិ ។ ឯកមិទាហំ អាវុសោ សមយំ រាជគហេ វិហរាមិ គិរិព្វជេ ។ អថ ខ្វាហំ អាវុសោ បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ រាជគហំ បិណ្ឌាយ បាវិសឹ ។ តេន ខោ បន សមយេន សមីតិ យានការបុត្តោ រថស្ស នេមឹ តច្ឆតិ[១] ។ តមេនំ បណ្ឌុបុត្តោ អាជីវកោ បុរាណយានការបុត្តោ បច្ចុបដ្ឋិតោ ហោតិ ។ អថខោ អាវុសោ បណ្ឌុបុត្តស្ស អាជីវកស្ស បុរាណយានការបុត្តស្ស ឯវំ ចេតសោ បរិវិតក្កោ ឧទបាទិ អហោ វតាយំ សមីតិ យានការបុត្តោ ឥមិស្សា នេមិយា ឥមញ្ច វង្កំ ឥមញ្ច ជិម្ហំ ឥមញ្ច ទោសំ តច្ឆេយ្យ ឯវាយំ នេមិ អបគតវង្កា អបគតជិម្ហា អបគតទោសា សុទ្ធា អស្ស សារេ[២] បតិដ្ឋិតាតិ ។ យថា យថា ខោ អាវុសោ បណ្ឌុបុត្តស្ស អាជីវកស្ស បុរាណយានការបុត្តស្ស ចេតសោ បរិវិតក្កោ[៣] ហោតិ

១ ម. តច្ឆតិ ។ ២ ម. សុទ្ធស្ស សារេ ។ យ. សុទ្ធា សារេ ។ ៣ ម. បរិវិតក្កំ ។



ចូរលោកពោលយកពាក្យឧបមា មកសំដែងចុះ ។ ព្រះមហាមោគ្គល្លានមានអាយុ មានថេរដីកាតទៅថា ម្នាលអាវុសោ សម័យមួយ ខ្ញុំនៅក្នុងក្រុងរាជគ្រឹះ ដែលមានភ្នំព័ទ្ធជុំវិញដូចក្រោល ។ ម្នាលអាវុសោ កាលនោះ ខ្ញុំស្លៀកស្បង់ប្រដាប់ដោយបាត្រនិងចីវរ ចូលទៅក្រុងរាជគ្រឹះ ដើម្បីបិណ្ឌបាតក្នុងបុព្វណ្ហសម័យ ។ សម័យនោះឯង សមីតិមាណព ជាកូនជាងរថ កំពុងចាំងខ្នងកង់រថ ។ ចំណែកអាជីវក (ម្នាក់) ឈ្មោះបណ្ឌុបុត្រ ជាកូនជាងរថជាន់ចាស់ ចូលមកឈរជិតសមីតិមាណពនោះដែរ ។ ម្នាលអាវុសោ លំដាប់នោះ អាជីវកឈ្មោះបណ្ឌុបុត្រ ជាកូនជាងរថជាន់ចាស់ មានសេចក្តីត្រិះរិះក្នុងចិត្តកើតឡើងយ៉ាងនេះថា ឱហ្ន៎ សមីតិមាណព ជាកូនជាងរថនេះ ចាំងឈើកោងនេះផង ឈើវៀចនេះផង ឈើប្រកបដោយទោស[១]នេះផង ដើម្បីធ្វើឲ្យខ្នងកង់នេះ ខ្នងកង់នេះឯងត្រឡប់ទៅជាខ្នងកង់មិនកោង មិនវៀច មិនប្រកបដោយទោស ជាខ្នងកង់បរិសុទ្ធ នៅស្ងួតត្រឹម ។ ម្នាលអាវុសោ អាជីវកឈ្មោះបណ្ឌុបុត្រ ជាកូនជាងរថជាន់ចាស់ មានសេចក្តីត្រិះរិះក្នុងចិត្តយ៉ាងណា ៗ

១ ឈើដែលជាប់ស្រោយ និងមានពកពេរពេញ មិនស្មើជាដើម ។

តថា តថា សមីតិ យានការបុត្តោ តស្សា នេមិយា តញ្ច វង្កំ តញ្ច ជិម្ហំ តញ្ច ទោសំ តច្ឆតិ ។ អថខោ អាវុសោ បណ្ឌុបុត្តោ អាជីវកោ បុរាណយានការបុត្តោ អត្តមនោ អត្តមនវាចំ និច្ឆារេសិ ហទយា ហទយំ មញ្ញេ អញ្ញាយ តច្ឆតីតិ ។ ឯវមេវ ខោ អាវុសោ យេ តេ បុគ្គលា អស្សទ្ធា ជីវិកត្ថា ន សទ្ធា អគារស្មា អនគារិយំ បព្វជិតា សឋា មាយាវិនោ កេដុភិនោ ឧទ្ធតា ឧន្នឡា ចបលា មុខរា វិកិណ្ណ-វាចា ឥន្ទ្រិយេសុ អគុត្តទ្វារា ភោជនេ អមត្តញ្ញុនោ ជាគរិយំ អននុយុត្តា សាមញ្ញេ អនបេក្ខវន្តោ សិក្ខា-យ ន តិព្វគារវា ពាហុលិកា សាថលិកា ឱក្កមនេ បុព្វង្គមា បវិវេកេ និក្ខិត្តធុរា កុសីតា ហីនវីរិយា មុដ្ឋស្សតី អសម្បជានា អសមាហិតា វិព្ភន្តចិត្តា ទុប្បញ្ញា ឯឡមូគា តេសំ អាយស្មា សារីបុត្តោ



គឺសមីតិមាណព ជាកូនជាងរថ ចាំងឈើកាងនោះផង ឈើវៀចនោះផង ឈើប្រកបដោយទោសនោះផង ដើម្បីធ្វើនូវកង់រថនោះ យ៉ាងនោះៗ ដែរ ។ ម្នាលអាវុសោ លំដាប់នោះ អាជីវកឈ្មោះ បណ្ឌុបុត្រ ជាកូនជាងរថជាន់ចាស់ មានចិត្តត្រេកអរ ហើយបញ្ចេញវាចាគួរជាទីត្រេកអរថា សមីតិមាណពនេះហាក់ដូចជាដឹងចិត្ត ដោយចិត្ត ហើយទើបចាំង ( នូវឈើ ) ។ ម្នាលអាវុសោ ពួកបុគ្គលណាដែល មិនមានសទ្ធា ត្រូវការតែទីពឹងចិញ្ចឹមជីវិត ចេញចាកផ្ទះហើយចូលទៅកាន់ផ្នួស ដោយមិនមានសទ្ធា ជាអ្នកអួតអាង ជាអ្នកមានមាយា ជាអ្នកបោកប្រាស ជាអ្នកមានចិត្តរាយមាយ លើកកំពស់ មានចិត្តរយេង-រយោង មានមាត់រឹង មានសំដីផ្ដេសផ្ដាស មិនគ្រប់គ្រងទ្វារក្នុងឥន្ទ្រិយទាំងឡាយ មិនដឹងប្រមាណក្នុងភោជន មិនប្រកបក្នុងការភ្ញាក់រលឹក មិនបានក្រឡេកមើល ក្នុងធម៌របស់សមណៈ ( ផ្នួស ) មិនមានសេចក្ដីគោរពដ៏ក្លៀវក្លា ក្នុងសិក្ខា ជាអ្នកល្មោភ មានសេចក្ដីព្យាយាមធូរថយ ជាប្រធានក្នុងការប្រព្រឹត្តជ្រោកជ្រាក ដាក់ចោលនូវធុរៈក្នុងវិវេក ខ្ជិលច្រអូសមានព្យាយាមថោកថយ មានសតិភ្លេចភ្លាំង មិនមានសម្បជញ្ញៈ មិនបានតាំងចិត្តមាំ មានចិត្តវិលទៅខុស ជាមនុស្សអប្បឥតប្រាជ្ញា ជាមនុស្សខ្លៅ ព្រះសារីបុត្រដ៏មានអាយុ ហាក់ដូច

ឥមិនា ធម្មបរិយាយេន ហទយា ហទយំ មញ្ញេ អញ្ញាយ តច្ឆតិ ។ យេ បន តេ កុលបុត្តា សទ្ធា អគារស្មា អនគារិយំ បព្វជិតា អសឋា អមាយាវិនោ អកេដុភិនោ អនុទ្ធតា អនុន្នឡា អចបលា អមុខរា អវិកិណ្ណវាចា ឥន្ទ្រិយេសុ គុត្តទ្វារា ភោជនេ មត្តញ្ញុនោ ជាគរិយំ អនុយុត្តា សាមញ្ញំ អបេក្ខវន្តោ សិក្ខាយ តិព្វគារវា ន ពាហុលិកា ន សាថលិកា ឱក្កមនេ និក្ខិត្តធុរា បវិវេកេ បុព្វង្គមា អារទ្ធវីរិយា បហិតត្តា ឧបដ្ឋិតស្សតី សម្បជានា សមាហិតា ឯកគ្គចិត្តា បញ្ញវន្តោ អនេឡមូគា តេ អាយស្មតោ សារីបុត្តស្ស ឥមំ ធម្មបរិយាយំ សុត្វា បិវន្តិ មញ្ញេ ឃសន្តិ មញ្ញេ វចសា ចេវ មនសា ច សាធុ វត ភោ សព្រហ្មចារី អកុសលា វុដ្ឋាបេត្វា កុសលេ បតិដ្ឋាបេតីតិ(១) ។ សេយ្យថាបិ អាវុសោ ឥត្ថី វា បុរិសោ វា

១ ម.ម. បតិដ្ឋាបេតិ ។



ជាទីទំចិត្ត របស់ជនទាំងឡាយនោះ ដោយចិត្ត ហើយរើបន្ទាន់តាមធម្មបរិយាយនេះឯង ។ ចំណែកខាងពួកកុលបុត្រណា មានសទ្ធា ចេញចាកផ្ទះ ចូលទៅកាន់ផ្នួសមិនមែនជាអ្នកអួតអាង មិនមានមាយា មិនមែនជាអ្នកបោកប្រាស មិនមានចិត្តរាយមាយ មិនលើកកំពស់ មិនមានចិត្តរវើរវាយ មិនមានមាត់រឹង មិនមានសំដីផ្ដេសផ្ដាស គ្រប់គ្រងទ្វារក្នុងឥន្ទ្រិយទាំងឡាយ ដឹងប្រមាណក្នុងភោជន ប្រកបរឿយៗក្នុងការភ្ញាក់រលឹក មានការក្រឡេកមើលក្នុងសមណធម៌ មានសេចក្តីគោរពក្រៀវក្លា ក្នុងសិក្ខា មិនល្មោភ មិនប្រព្រឹត្តធូរ ដាក់ធុរៈចោលក្នុងការប្រព្រឹត្តិជ្រោកជ្រាក ជាប្រធានក្នុងវិវេកធម៌ មានព្យាយាមតឹង មានចិត្តបញ្ជូនទៅកាន់ (ព្រះនិព្វាន) មានសតិខ្ជាប់ខ្ជួន មានសម្បជញ្ញៈ មានសមាធិ មានចិត្តនឹងនៅក្នុងអារម្មណ៍តែមួយ មានប្រាជ្ញា មិនមែនជាមនុស្សខ្លៅ លុះកុលបុត្រទាំងនោះ បានស្តាប់ធម្មបរិយាយនេះរបស់ព្រះសារីបុត្រដ៏មានអាយុហើយ ក៏ហាក់ដូចបានក្រេបផឹក បានលេបដោយពាក្យសំដីនិងចិត្តដូច្នេះថា ឱហ្ន៎ ព្រះសារីបុត្រជាសព្រហ្មចារីបុគ្គល រមែង (ញុំាងពួកយើង) ឲ្យឃ្លាតចាកអកុសល ហើយឲ្យតាំងនៅក្នុងកុសលដោយប្រពៃបាន ។ ម្នាលអាវុសោ ដូចជាស្រីឬប្រុស

ទហរោ យុវា មណ្ឌនកជាតិកោ សីសន្ហាតោ[១] ឧប្បលមាលំ វា វស្សិកមាលំ វា អតិមុត្តកមាលំ វា លភិត្វា ឧភោហិ ហត្ថេហិ បដិគ្គហេត្វា ឧត្តមង្គេ សិរស្មឹ បតិដ្ឋបេយ្យ ឯវមេវ ខោ អាវុសោ យេ តេ កុលបុត្តា សទ្ធា អគារស្មា អនគារិយំ បព្វជិតា អសឋា អមាយាវិនោ អកេតុភិនោ អនុទ្ធតា អនុន្នឡា អចបលា អមុខរា អវិកិណ្ណវាចា ឥន្ទ្រិយេសុ គុត្តទ្វារា ភោជនេ មត្តញ្ញុនោ ជាគរិយំ អនុយុត្តា សាមញ្ញេ អបេក្ខវន្តោ សិក្ខាយ តិព្វគារវា ន ពាហុលិកា ន សាថលិកា ឱក្កមនេ និក្ខិត្តធុរា បវិវេកេ បុព្វង្គមា អារទ្ធវីរិយា បហិតត្តា ឧបដ្ឋិតស្សតី សម្បជានា សមាហិតា ឯកគ្គចិត្តា បញ្ញវន្តោ អនេឡមូគា តេ អាយស្មតោ សារីបុត្តស្ស ឥមំ ធម្មបរិយាយំ សុត្វា

១ ម. សីសំ នហាតោ ។





ជំទង់ឬកំឡោះ កំពុងចូលចិត្តនឹងការប្រដាប់កាយ កក់សីសៈរួចហើយ បាននូវកម្រងផ្កាឧប្បល ឬកម្រងផ្កាម្លិះ នឹងកម្រងផ្ការំដួល ក៏ទទួលយកដោយដៃទាំងពីរ ហើយតម្កល់លើសិរសាជាអវយវៈដ៏ខ្ពង់ខ្ពស់ ម្នាលអាវុសោ ពួកកុលបុត្រណាមានសទ្ធា ចេញចាកផ្ទះចូលទៅកាន់ផ្នួស មិនមែនជាអ្នកអួតអាង មិនមានមាយា មិនមែនជាអ្នកពោកព្រោស មិនមានចិត្តរាយមាយ មិនលើកកំពស់ មិនមានចិត្តឃ្លេងឃ្លោង មិនមានមាត់រឹង មិនមានសំដីផ្ដេសផ្ដាស គ្រប់គ្រងទ្វារ ក្នុងឥន្ទ្រិយទាំងឡាយ ដឹងប្រមាណក្នុងភោជន ប្រកបរឿយ ៗ ក្នុងការភ្ញាក់រលឹក [illegible] ទៀតមើល ក្នុងសមណធម៌ មានសេចក្ដីគោរព [illegible] មិនល្មោភ មិនប្រព្រឹត្តធូរ ជាអ្នកដាក់ធុរៈចោល ក្នុងការប្រព្រឹត្តិប្រោកប្រាក ជាប្រធានក្នុងវិវេកធម៌ មានព្យាយាមរឹង មានចិត្តបញ្ជូនទៅកាន់ (ព្រះនិព្វាន) មានសតិខ្ជាប់ខ្ជួន មានសម្បជញ្ញៈ មានសមាធិ មានចិត្តនឹងនៅ ក្នុងអារម្មណ៍តែមួយ ជាអ្នកមានប្រាជ្ញា មិនមែនជាមនុស្សល្ងៅ កុលបុត្រទាំងនោះ បានស្ដាប់ធម្មបរិយាយនេះ របស់ព្រះសារីបុត្រ

បិវន្តិ មញ្ញេ ឃសន្តិ មញ្ញេ វចសា ចេវ មនសា ច សាធុ វត ភោ សព្រហ្មចារី អកុសលា វុដ្ឋាបេត្វា កុសលេ បតិដ្ឋាបេតីតិ ។ ឥតិហ តេ ឧភោ មហានាគា អញ្ញមញ្ញស្ស សុភាសិតំ សមនុមោទឹសូតិ ។

អនង្គណសុត្តំ បញ្ចមំ និដ្ឋិតំ ។

១ ឱ.ម. ឥម្ពិកន្ទំ ទិស្សតិ ។



ដ៏មានអាយុហើយ ក៏ហាក់ដូចជាបានក្រេបផឹក បានលេប ដោយពាក្យសំដីនឹងចិត្តដូច្នេះថា ឱហ្ន៎ ព្រះសារីបុត្រ ជាសព្រហ្មចារីបុគ្គល រមែង (ញុំាងពួកយើង) ឲ្យឃ្លាតចាកអកុសល ហើយឲ្យតម្កល់នៅក្នុងកុសលដោយប្រពៃ ដូចសេចក្តីឧបមានោះឯង ។ ព្រះមហានាគ[១] ទាំងពីរអង្គនោះ រីករាយ ចំពោះសុភាសិតរបស់គ្នាទៅវិញទៅមក ដោយប្រការយ៉ាងនេះឯង ។

ចប់ អនង្គណសូត្រ ជាគំរប់ ៥ ។

១ អដ្ឋកថា ថា អគ្គសាវកទាំងពីរអង្គ គឺព្រះសារីបុត្រ ១ ព្រះមហាមោគ្គល្លាន ១ ទាំងពីរអង្គនេះ លោកហៅថា មហានាគ ។ ( មួយទៀត ) ព្រះថេរទាំងពីរអង្គនោះ រមែងមិនលំអៀងទៅតាមអគតិ មានឆន្ទាគតិជាដើម ហៅថា នាគ ។ ( ម្យ៉ាងទៀត ) បុគ្គលដែលលែងមកកាន់កិលេស ដែលលោកលះបង់កិលេសបានហើយ ក៏ហៅថា នាគ ។ (មួយវិញទៀត) លោកលែងធ្វើកម្មដ៏លាមកមានប្រការផ្សេង ៗ ក៏ហៅថា នាគ ដែរ ។

## ៦. អាកង្ខេយ្យសុត្តំ

(៧៣) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ ភិក្ខវោតិ ។ ភទន្តេតិ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច សម្បន្នសីលា ភិក្ខវេ វិហរថ សម្បន្នបាតិមោក្ខា បាតិមោក្ខសំវរសំវុតា វិហរថ អាចារគោចរសម្បន្នា អណុមត្តេសុ វជ្ជេសុ ភយទស្សាវិនោ[១] សមាទាយ សិក្ខថ សិក្ខាបទេសុ ។

(៧៤) អាកង្ខេយ្យ ចេ ភិក្ខវេ ភិក្ខុ សព្រហ្មចារីនំ បិយោ ច អស្សំ មនាបោ ច[២] គរុ ច[៣] ភាវនីយោ ចាតិ សីលេស្វេវស្ស បរិបូរការី អជ្ឈត្តំ ចេតោសមថមនុយុត្តោ អនិរាកតជ្ឈានោ វិបស្សនាយ សមន្នាគតោ ព្រូហេតា សុញ្ញាគារានំ ។

១ ម. ភយទស្សាវី ។ ២-៣ ម. ចសទ្ទោ ន ទិស្សតិ ។

## អាកង្ខេយ្យសូត្រ ទី ៦

(៧៣) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងជេតវនារាម របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកក្នុងទីនោះថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះ ក៏ទទួលព្រះពុទ្ធដីកាព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះមានព្រះភាគ មានព្រះពុទ្ធដីកាដូច្នេះថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរជាអ្នកមានសីលបរិបូណ៌ មានបាតិមោក្ខបរិបូណ៌ សង្រួមក្នុងបាតិមោក្ខសំវរៈ ចូរជាអ្នកមានអាចារៈនិងគោចរដ៏បរិបូណ៌ ឃើញភ័យក្នុងទោសត្រឹមតែបន្តិចបន្តួច សមាទានសិក្សា ក្នុងសិក្ខាបទទាំងឡាយ ។

(៧៤) ម្នាលភិក្ខុទាំងឡាយ បើភិក្ខុប្រាថ្នាថា គប្បីអញ ជាទីស្រឡាញ់ផង ជាទីពេញចិត្តផង ជាទីគោរពផង ជាទីសរសើរផង របស់ពួកសព្រហ្មចារី ដូច្នេះ គួរធ្វើសីលឲ្យបរិបូណ៌ ប្រកបក្នុងការរម្ងាប់នូវចិត្តដ៏ខាងក្នុង មានឈានមិនសាបសូន្យ ប្រកបដោយវិបស្សនា ហើយចំរើននូវសុញ្ញាគារស្ថាន[១] ។

១ ភិក្ខុរៀនកម្មដ្ឋាន ហើយចូលទៅកាន់ផ្ទះស្ងាត់ អង្គុយពោតាំងយប់ទាំងថ្ងៃ ។

(៧៥) អាកង្ខេយ្យ ចេ ភិក្ខវេ ភិក្ខុ លាភី អស្សំ ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារានន្តិ សីលេស្វេវស្ស បរិបូរការី អជ្ឈត្តំ ចេតោសមថមនុយុត្តោ អនិរាកតជ្ឈានោ វិបស្សនាយ សមន្នាគតោ ព្រូហេតា សុញ្ញាគារានំ ។

(៧៦) អាកង្ខេយ្យ ចេ ភិក្ខវេ ភិក្ខុ យេសាហំ ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារំ បរិភុញ្ជាមិ តេសន្តេ[1] ការា មហប្ផលា អស្សុ មហានិសំសាតិ សីលេស្វេវស្ស បរិបូរការី អជ្ឈត្តំ ចេតោសមថមនុយុត្តោ អនិរាកតជ្ឈានោ វិបស្សនាយ សមន្នាគតោ ព្រូហេតា សុញ្ញាគារានំ ។

(៧៧) អាកង្ខេយ្យ ចេ ភិក្ខវេ ភិក្ខុ យេ មេ[2] ញាតិសាលោហិតា បេតា កាលង្កតា បសន្នចិត្តា អនុស្សរន្តិ តេសន្តំ[3] មហប្ផលំ អស្ស មហានិសំសន្តិ សីលេស្វេវស្ស បរិបូរការី អជ្ឈត្តំ ចេតោសមថមនុយុត្តោ អនិរាកតជ្ឈានោ វិបស្សនាយ សមន្នាគតោ ព្រូហេតា សុញ្ញាគារានំ ។

១ ម.ម. តេសំ តេ ។ ២ ម. មំ ។ ៣ ម. តេសំ តំ ។



(៧៥) ម្នាលភិក្ខុទាំងឡាយ បើភិក្ខុប្រាថ្នាថា អាត្មាអញគប្បីបាន ចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ច័យភេសជ្ជបរិក្ខារផងចុះ គួរធ្វើសីលឲ្យបរិបូណ៌ ប្រកបក្នុងការរម្ងាប់នូវចិត្តក្នុងខាងក្នុង មានឈានមិនបានសាបសូន្យ ប្រកបដោយវិបស្សនា ហើយចំរើននូវសុញ្ញាគារស្ថាន ។

(៧៦) ម្នាលភិក្ខុទាំងឡាយ បើភិក្ខុប្រាថ្នាថា អាត្មាអញប្រើប្រាស់នូវចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ច័យភេសជ្ជបរិក្ខារ របស់ពួកទេវតានិងមនុស្សណា ការបូជាទាំងនោះ របស់ពួកទេវតានិងមនុស្សនោះ សូមឲ្យមានផលច្រើន មានអានិសង្សច្រើនផងចុះ គួរធ្វើសីលឲ្យបរិបូណ៌ ប្រកបក្នុងការរម្ងាប់ នូវចិត្តក្នុងខាងក្នុង មានឈានមិនបានសាបសូន្យ ប្រកបដោយវិបស្សនា ចំរើននូវសុញ្ញាគារស្ថាន ។

(៧៧) ម្នាលភិក្ខុទាំងឡាយ បើភិក្ខុប្រាថ្នាថា ពួកញាតិនិងសាលោហិត របស់អាត្មាអញណា ដែលធ្វើមរណកាលទៅកាន់លោកខាងមុខហើយ មានចិត្តជ្រះថ្លា រលឹកឃើញ ( អាត្មាអញ ) ការនឹករលឹករបស់ញាតិនិងសាលោហិតទាំងនោះ សូមឲ្យមានផលច្រើន មានអានិសង្សច្រើនផងចុះ គួរធ្វើសីលឲ្យបរិបូណ៌ ប្រកបក្នុងការរម្ងាប់នូវចិត្តក្នុងខាងក្នុង មានឈានមិនបានសាបសូន្យ ប្រកបដោយវិបស្សនា ចំរើននូវសុញ្ញាគារស្ថាន ។

(៧៨) អាកង្ខេយ្យ ចេ ភិក្ខវេ ភិក្ខុ អរតិរតិសហោ អស្សំ ន ច មំ អរតិ សហេយ្យ ឧប្បន្នំ អរតឹ អភិភុយ្យ អភិភុយ្យ វិហរេយ្យន្តិ សីលេស្វេវស្ស បរិបូរការី ។ បេ ។ ព្រូហេតា សុញ្ញាគារានំ ។

(៧៩) អាកង្ខេយ្យ ចេ ភិក្ខវេ ភិក្ខុ ភយភេរវសហោ អស្សំ ន ច មំ ភយភេរវំ សហេយ្យ ឧប្បន្នំ ភយភេរវំ អភិភុយ្យ អភិភុយ្យ វិហរេយ្យន្តិ សីលេស្វេវស្ស បរិបូរការី ។ បេ ។ ព្រូហេតា សុញ្ញាគារានំ ។

(៨០) អាកង្ខេយ្យ ចេ ភិក្ខវេ ភិក្ខុ ចតុន្នំ ឈានានំ អាភិចេតសិកានំ ទិដ្ឋធម្មសុខវិហារានំ និកាមលាភី អស្សំ អកិច្ឆលាភី អកសិរលាភីតិ សីលេស្វេវស្ស បរិបូរការី ។ បេ ។ ព្រូហេតា សុញ្ញាគារានំ ។



(៧៨) ម្នាលភិក្ខុទាំងឡាយ បើភិក្ខុប្រាថ្នាថា អាត្មាអញ គប្បីគ្របសង្កត់នូវសេចក្តីអផ្សុក[១] នឹងសេចក្តីត្រេកអរ[២] សេចក្តីអផ្សុកកុំគប្បីគ្របសង្កត់អាត្មាអញឡើយ អាត្មាអញគប្បីគ្របសង្កត់រឿយៗ នូវសេចក្តីអផ្សុក ដែលកើតឡើងដូច្នេះ គួរធ្វើសីលឲ្យបរិបូណ៌ ។ បេ ។ ចំរើន នូវសុញ្ញាគារស្ងាត ។

(៧៩) ម្នាលភិក្ខុទាំងឡាយ បើភិក្ខុប្រាថ្នាថា អាត្មាអញគប្បីគ្របសង្កត់នូវសេចក្តីខ្លាច ចំពោះអារម្មណ៍ដែលគួរស្ញប់ ឯសេចក្តីខ្លាចចំពោះអារម្មណ៍ដែលគួរស្ញប់ កុំគប្បីគ្របសង្កត់អាត្មាអញឡើយ អាត្មាអញគប្បីគ្របសង្កត់រឿយៗ នូវសេចក្តីខ្លាច ចំពោះអារម្មណ៍ដែលគួរស្ញប់ ដែលកើតឡើងដូច្នេះ គួរធ្វើសីលឲ្យបរិបូណ៌ ។ បេ ។ ចំរើនបំពេញ នូវសុញ្ញាគារស្ងាត ។

(៨០) ម្នាលភិក្ខុទាំងឡាយ បើភិក្ខុប្រាថ្នាថា អាត្មាអញគប្បីបាន តាមប្រាថ្នា បានដោយមិនលំបាក បានដោយមិនខុសវេលាកំណត់ នូវឈានទាំង ៤ ដែលកើតក្នុងចិត្តដ៏ថ្លៃថ្លា ជាគ្រឿងនៅជាសុខក្នុងបច្ចុប្បន្ន ដូច្នេះ គួរធ្វើសីលឲ្យបរិបូណ៌ ។ បេ ។ ចំរើននូវសុញ្ញាគារស្ងាត ។

---

១ សេចក្តីអផ្សុកក្នុងអធិកុសលធម៌ ឬក្នុងសេនាសនៈដ៏ស្ងាត់ ។ ២ បានដល់តម្រេកក្នុងកាមគុណ ។

(៨១) អាកង្ខេយ្យ ចេ ភិក្ខវេ ភិក្ខុ យេ តេ សន្តា វិមោក្ខា អតិក្កម្ម រូបេ អារុប្បា តេ កាយេន ផុសិត្វា វិហរេយ្យន្តិ សីលេស្វេវស្ស បរិបូរការី ។ បេ ។ ព្រូហេតា សុញ្ញាគារានំ ។

(៨២) អាកង្ខេយ្យ ចេ ភិក្ខវេ ភិក្ខុ តិណ្ណំ សំយោជនានំ បរិក្ខយា សោតាបន្នោ អស្សំ អវិនិបាតធម្មោ និយតោ សម្ពោធិបរាយណោតិ សីលេស្វេវស្ស បរិបូរការី ។ បេ ។ ព្រូហេតា សុញ្ញាគារានំ ។

(៨៣) អាកង្ខេយ្យ ចេ ភិក្ខវេ ភិក្ខុ តិណ្ណំ សំយោជនានំ បរិក្ខយា រាគទោសមោហានំ តនុត្តា សកទាគាមី អស្សំ សកិទេវ ឥមំ លោកំ អាគន្ត្វា ទុក្ខស្សន្តំ ករេយ្យន្តិ សីលេស្វេវស្ស បរិបូរការី អជ្ឈត្តំ ចេតោសមថមនុយុត្តោ អនិរាកតជ្ឈានោ វិបស្សនាយ សមន្នាគតោ ព្រូហេតា សុញ្ញាគារានំ ។



(៨១) ម្នាលភិក្ខុទាំងឡាយ បើភិក្ខុប្រាថ្នាថា វិមោក្ខធម៌ដ៏ស្ងប់រម្ងាប់ទាំងឡាយណា ជាអរូបជ្ឈាន កន្លងហួសនូវរូបាវចរជ្ឈាន សូមឲ្យអាត្មាអញបាននូវវិមោក្ខធម៌ទាំងនោះ ដោយនាមកាយដូច្នេះ គួរធ្វើសីលឲ្យបរិបូណ៌ ។ បេ ។ ចំរើននូវសុញ្ញាគារស្ថាន ។

(៨២) ម្នាលភិក្ខុទាំងឡាយ បើភិក្ខុប្រាថ្នាថា សូមឲ្យអាត្មាអញជាសោតាបន្នបុគ្គល ព្រោះអស់ទៅនៃសំយោជនធម៌ ៣ ប្រការ មានកិរិយាមិនធ្លាក់ចុះជាធម្មតា ជាបុគ្គលទៀងទាត់ មានកិរិយាត្រាស់ដឹងប្រព្រឹត្តទៅខាងមុខដូច្នេះ គួរធ្វើសីលឲ្យបរិបូណ៌ ។ បេ ។ ចំរើននូវសុញ្ញាគារស្ថាន ។

(៨៣) ម្នាលភិក្ខុទាំងឡាយ បើភិក្ខុប្រាថ្នាថា សូមឲ្យអាត្មាអញបានជាសកទាគាមិបុគ្គល ព្រោះអស់ទៅនៃសំយោជនធម៌ទាំងឡាយ ៣ ប្រការ ព្រោះរាគៈទោសៈមោហៈស្រាលស្តើង មកកាន់លោកនេះម្តងទៀត ហើយធ្វើនូវទីបំផុតនៃទុក្ខ ដូច្នេះ គួរធ្វើសីលឲ្យបរិបូណ៌ ប្រកបរឿយៗនូវការរម្ងាប់ចិត្តខាងក្នុង មានឈានមិនឃ្លាតសាបសូន្យ ប្រកបដោយវិបស្សនា ចំរើននូវសុញ្ញាគារស្ថាន ។

(៨៦) អាកង្ខេយ្យ ចេ ភិក្ខវេ ភិក្ខុ បញ្ចន្នំ ឱរម្ភាគិយានំ សំយោជនានំ បរិក្ខយា ឱបបាតិកោ អស្សំ តត្ថ បរិនិព្វាយី អនាវត្តិធម្មោ តស្មា លោកាតិ សីលេស្វេវស្ស បរិបូរការី ។ បេ ។ ព្រូហេតា សុញ្ញាគារានំ ។

(៨៧) អាកង្ខេយ្យ ចេ ភិក្ខវេ ភិក្ខុ អនេកវិហិតំ ឥទ្ធិវិធំ បច្ចនុភវេយ្យំ ឯកោបិ ហុត្វា ពហុធា អស្សំ ពហុធាបិ ហុត្វា ឯកោ អស្សំ អាវិភាវំ តិរោភាវំ តិរោកុឌ្ឌំ តិរោបាការំ តិរោបព្វតំ អសជ្ជមានោ គច្ឆេយ្យំ សេយ្យថាបិ អាកាសេ បឋវិយាបិ ឧម្មុជ្ជនិមុជ្ជំ ករេយ្យំ សេយ្យថាបិ ឧទកេ ឧទកេបិ អភិជ្ជមានេ គច្ឆេយ្យំ សេយ្យថាបិ បឋវិយំ អាកាសេបិ បល្លង្កេន កមេយ្យំ សេយ្យថាបិ បក្ខី សកុណោ ឥមេបិ ចន្ទិមសុរិយេ ឯវំមហិទ្ធិកេ ឯវំមហានុភាវេ បាណិនា បរាមសេយ្យំ[១] បរិមជ្ជេយ្យំ

១ ម បរិមសេយ្យំ ។



(៨៦) ម្នាលភិក្ខុទាំងឡាយ បើភិក្ខុប្រាថ្នាថា សូមឲ្យអាត្មាអញបានជាឧបបាតិកបុគ្គល (អនាគាមី) ព្រោះអស់ទៅនៃសំយោជនធម៌ទាំងឡាយ ៥ ប្រការ ជាចំណែកខាងក្រោម បរិនិព្វាន ក្នុងព្រហ្មលោកនោះ មានកិរិយាមិនត្រឡប់ចាកលោកនោះ ដូច្នេះ គួរធ្វើសីលឲ្យបរិបូណ៌ ។ បេ ។ ចំរើននូវសុញ្ញាគារស្ថាន ។

(៨៧) ម្នាលភិក្ខុទាំងឡាយ បើភិក្ខុប្រាថ្នាថា សូមឲ្យអាត្មាអញបាននូវឫទ្ធិវិធញ្ញាណច្រើនប្រការគឺ អាត្មាអញម្នាក់ឯង និម្មិតខ្លួនឲ្យបានទៅជាមនុស្សច្រើននាក់ក៏បាន ច្រើននាក់និម្មិតខ្លួនឲ្យបានទៅជាមនុស្សម្នាក់ក៏បាន ដើរទៅក្នុងទីណាក៏ចេះតែបាន [illegible] ទីកំបាំង ដើរទៅក្នុងទីវាលក៏បាន ទៅខាងក្នុង [illegible] ទៅខាងក្នុងជញ្ជាំង ចេញទៅខាងក្រៅជញ្ជាំងក៏បាន ទៅខាងក្នុងកំផែង ចេញទៅ ខាងក្រៅកំផែងក៏បាន ទៅខាងក្នុងភ្នំ ចេញទៅខាងក្រៅភ្នំក៏បាន ឥតទើសទាល់ឡើយ ដូចជាគេដើរក្នុងទីវាល អាត្មាអញងើបមុជ ៗ ក្នុងផែនដី ដូចជាគេងើបមុជក្នុងទឹកក៏បាន អាត្មាអញដើរលើទឹកមិនបែកធ្លាយ ដូចជាគេដើរលើផែនដីក៏បាន អាត្មាអញ គប្បីទៅទាំងភ្នែនព្ធដ៏អាកាស ដូចជាសត្វបក្សីសកុណៈក៏បាន អាត្មាអញ យកដៃទៅស្ទាបអង្អែល ចាប់ពាល់ (មណ្ឌល) ព្រះចន្ទនឹងព្រះអាទិត្យទាំងពីរនេះ

យាវ ព្រហ្មលោកាបិ កាយេន វសំ វត្តេយ្យន្តិ សីលេស្វេវស្ស បរិបូរការី ។ បេ ។ ព្រូហេតា សុញ្ញាគារានំ ។

(៨៦) អាកង្ខេយ្យ ចេ ភិក្ខវេ ភិក្ខុ ទិព្វាយ សោតធាតុយា វិសុទ្ធាយ អតិក្កន្តមានុសិកាយ ឧភោ សទ្ទេ សុណេយ្យំ ទិព្វេ ច មានុសេ ច យេ ទូរេ សន្តិកេ ចាតិ សីលេស្វេវស្ស បរិបូរការី ។ បេ ។ ព្រូហេតា សុញ្ញាគារានំ ។

(៨៧) អាកង្ខេយ្យ ចេ ភិក្ខវេ ភិក្ខុ បរសត្តានំ បរបុគ្គលានំ ចេតសា ចេតោ បរិច្ច បជានេយ្យំ សរាគំ វា ចិត្តំ សរាគំ ចិត្តន្តិ បជានេយ្យំ វីតរាគំ វា ចិត្តំ វីតរាគំ ចិត្តន្តិ បជានេយ្យំ សទោសំ វា ចិត្តំ សទោសំ ចិត្តន្តិ បជានេយ្យំ វីតទោសំ វា ចិត្តំ វីតទោសំ ចិត្តន្តិ បជានេយ្យំ សមោហំ វា ចិត្តំ សមោហំ ចិត្តន្តិ បជា-នេយ្យំ វីតមោហំ វា ចិត្តំ វីតមោហំ ចិត្តន្តិ បជានេយ្យំ



ដែលមានឫទ្ធិច្រើន យ៉ាងនេះ មានអានុភាពច្រើន យ៉ាងនេះក៏បាន ធ្វើអំណាចកាយ ឲ្យប្រព្រឹត្តទៅ រហូតដល់ព្រហ្មលោកនាយក៏បាន ដូច្នេះ គួរធ្វើសីលឲ្យបរិបូណ៌ ។ បេ ។ ចំរើននូវសុញ្ញាគារស្ថាន ។

(៨៦) ម្នាលភិក្ខុទាំងឡាយ បើភិក្ខុប្រាថ្នាថា សូមឲ្យអាត្មាអញមានសោតធាតុ ជាទិព្វដ៏បរិសុទ្ធ កន្លងនូវសោតធាតុ របស់មនុស្សធម្មតា ឮនូវសំឡេងពីរប្រការ គឺសំឡេងទិព្វ១ សំឡេងរបស់មនុស្ស១ ដែលជាសំឡេងឆ្ងាយក៏បាន ជិតក៏បាន ដូច្នេះ គួរធ្វើសីលឲ្យបរិបូណ៌ ។ បេ ។ ចំរើននូវសុញ្ញាគារស្ថាន ។

(៨៧) ម្នាលភិក្ខុទាំងឡាយ បើភិក្ខុប្រាថ្នាថា សូមឲ្យអាត្មាអញកំណត់ដឹងចិត្តរបស់សត្វដទៃ បុគ្គលដទៃ ដោយចិត្តរបស់ខ្លួន គឺចិត្តប្រកបដោយរាគៈក្តី អាត្មាអញគប្បីដឹងច្បាស់ថា ចិត្តប្រកបដោយរាគៈ ចិត្តប្រាសចាករាគៈក្តី ក៏អាត្មាអញគប្បីដឹងច្បាស់ថា ចិត្តប្រាសចាករាគៈ ចិត្តប្រកបដោយទោសៈក្តី គប្បីដឹងច្បាស់ថា ចិត្តប្រកបដោយទោសៈ ចិត្តប្រាសចាកទោសៈក្តី គប្បីដឹងច្បាស់ថា ចិត្តប្រាសចាកទោសៈ ចិត្តប្រកបដោយមោហៈក្តី គប្បីដឹងច្បាស់ថា ចិត្តប្រកបដោយមោហៈ ចិត្តប្រាសចាកមោហៈក្តី គប្បីដឹងច្បាស់ថា ចិត្តប្រាសចាកមោហៈ ចិត្ត

សង្ខិត្តំ វា ចិត្តំ សង្ខិត្តំ ចិត្តន្តិ បជានេយ្យំ វិក្ខិត្តំ វា ចិត្តំ វិក្ខិត្តំ ចិត្តន្តិ បជានេយ្យំ មហគ្គតំ វា ចិត្តំ មហគ្គតំ ចិត្តន្តិ បជានេយ្យំ អមហគ្គតំ វា ចិត្តំ អមហគ្គតំ ចិត្តន្តិ បជានេយ្យំ សឧត្តរំ វា ចិត្តំ សឧត្តរំ ចិត្តន្តិ បជានេយ្យំ អនុត្តរំ វា ចិត្តំ អនុត្តរំ ចិត្តន្តិ បជានេយ្យំ សមាហិតំ វា ចិត្តំ សមាហិតំ ចិត្តន្តិ បជានេយ្យំ អសមាហិតំ វា ចិត្តំ អសមាហិតំ ចិត្តន្តិ បជានេយ្យំ វិមុត្តំ វា ចិត្តំ វិមុត្តំ ចិត្តន្តិ បជានេយ្យំ អវិមុត្តំ វា ចិត្តំ អវិមុត្តំ ចិត្តន្តិ បជានេយ្យន្តិ សីលេស្វេវស្ស បរិបូរការី ។បេ។ ព្រូហេតា សុញ្ញាគារានំ ។

(៥៥) អាកង្ខេយ្យ ចេ ភិក្ខវេ ភិក្ខុ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរេយ្យំ សេយ្យថីទំ ឯកម្បិ ជាតឹ ទ្វេបិ ជាតិយោ តិស្សោបិ ជាតិយោ ចតស្សោបិ ជាតិយោ បញ្ចបិ ជាតិយោ ទសបិ ជាតិយោ វីសម្បិ ជាតិយោ តឹសម្បិ ជាតិយោ ចត្តាឡីសម្បិ ជាតិយោ



រួញរាក្តី គប្បីដឹងច្បាស់ថា ចិត្តរួញរា ចិត្តរាយមាយក្តី គប្បីដឹងច្បាស់ថា ចិត្តរាយមាយ ចិត្តជាមហគ្គតៈ គឺរូបាវចរនឹងអរូបាវចរក្តី គប្បីដឹងច្បាស់ថា ចិត្តជាមហគ្គតៈ ចិត្តមិនមែនជាមហគ្គតៈក្តី គប្បីដឹងច្បាស់ថា ចិត្តមិនមែនជាមហគ្គតៈ ចិត្តជាសឧត្តរៈគឺលោកិយចិត្តក្តី គប្បីដឹងច្បាស់ថា ចិត្តជាសឧត្តរៈ ចិត្តជាអនុត្តរៈគឺលោកុត្តរចិត្តក្តី គប្បីដឹងច្បាស់ថា ចិត្តជាអនុត្តរៈ ចិត្តតាំងនឹងមាំក្តី គប្បីដឹងច្បាស់ថា ចិត្តតាំងនឹងមាំ ចិត្តមិនតាំងនឹងមាំក្តី គប្បីដឹងច្បាស់ថា ចិត្តមិនតាំងនឹងមាំ ចិត្តរួចចាកកិលេសក្តី គប្បីដឹងច្បាស់ថា ចិត្តរួចចាកកិលេស ចិត្តមិនទាន់រួចចាកកិលេសក្តី គប្បីដឹងច្បាស់ថា ចិត្តមិនទាន់រួចចាកកិលេសដូច្នេះ គួរធ្វើសីលឲ្យបរិបូណ៌ ។បេ។ ចំរើននូវសុញ្ញាគារស្ងាត់ ។

(៥៥) ម្នាលភិក្ខុទាំងឡាយ បើភិក្ខុប្រាថ្នាថា សូមឲ្យអាត្មាអញរលឹកឃើញនូវបុព្វេនិវាស (ជាតិដែលធ្លាប់អាស្រ័យនៅ ក្នុងកាលមុន) គឺរលឹកបាន ១ ជាតិខ្លះ ២ ជាតិខ្លះ ៣ ជាតិខ្លះ ៤ ជាតិខ្លះ ៥ ជាតិខ្លះ ១០ ជាតិខ្លះ ២០ ជាតិខ្លះ ៣០ ជាតិខ្លះ ៤០ ជាតិខ្លះ ៥០ ជាតិខ្លះ

បញ្ញាសម្បិ ជាតិយោ ជាតិសតម្បិ ជាតិសហស្សម្បិ ជាតិសតសហស្សម្បិ អនេកេបិ សំវដ្ដកប្បេ អនេកេបិ វិវដ្ដកប្បេ អនេកេបិ សំវដ្ដវិវដ្ដកប្បេ អមុត្រាសឹ ឯវំនាមោ ឯវំគោត្តោ ឯវំវណ្ណោ ឯវមាហារោ ឯវំសុខទុក្ខប្បដិសំវេទី ឯវមាយុបរិយន្តោ សោ តតោ ចុតោ អមុត្រ ឧទបាទឹ តត្រាបាសឹ ឯវំនាមោ ឯវំគោត្តោ ឯវំវណ្ណោ ឯវមាហារោ ឯវំសុខទុក្ខប្បដិសំវេទី ឯវមាយុបរិយន្តោ សោ តតោ ចុតោ ឥធូបបន្នោតិ ឥតិ សាការំ សឧទ្ទេសំ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរេយ្យន្តិ សីលេស្វេវស្ស បរិបូរការី ។ បេ ។ ព្រូហេតា សុញ្ញាគារានំ ។

(៨៩) អាកង្ខេយ្យ ចេ ភិក្ខវេ ភិក្ខុ ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន សត្តេ បស្សេយ្យំ ចវមានេ ឧបបជ្ជមានេ ហីនេ បណីតេ សុវណ្ណេ ទុព្វណ្ណេ សុគតេ ទុគ្គតេ យថាកម្មុបគេ សត្តេ បជានេយ្យំ ឥមេ វត ភោន្តោ



១០០ ជាតិខ្លះ ១.០០០ ជាតិខ្លះ ១០០.០០០ ជាតិខ្លះ សំវដ្តកប្បដ៏ច្រើនខ្លះ វិវដ្តកប្បដ៏ច្រើនខ្លះ សំវដ្តវិវដ្តកប្បដ៏ច្រើនខ្លះ ថាអាត្មាអញកើត ក្នុងភពនោះ មានឈ្មោះយ៉ាងនេះ មានគោត្រយ៉ាងនេះ មានសម្បុរយ៉ាងនេះ មានអាហារយ៉ាងនេះ ទទួលសុខទុក្ខយ៉ាងនេះ មានកំណត់អាយុប៉ុណ្ណោះ លុះអាត្មាអញច្យុតចាកអត្តភាពនោះហើយ ទៅកើតក្នុងទីនោះ លុះអាត្មាអញទៅកើត ក្នុងទីនោះហើយ មានឈ្មោះយ៉ាងនេះ មានគោត្រយ៉ាងនេះ មានសម្បុរយ៉ាងនេះ មានអាហារយ៉ាងនេះ ទទួលសុខទុក្ខយ៉ាងនេះ មានកំណត់អាយុប៉ុណ្ណោះ លុះអាត្មាអញច្យុតចាកអត្តភាពនោះហើយ ក៏មកកើតក្នុងទីនេះ អាត្មាអញសូមឲ្យរលឹកឃើញនូវខន្ធ ដែលធ្លាប់អាស្រ័យនៅក្នុងកាលមុន មានច្រើនប្រការ ព្រមទាំងអាការ ព្រមទាំងឧទ្ទេស ដូច្នេះ គួរធ្វើសីលឲ្យបរិបូណ៌ ។ បេ ។ ចំរើននូវសុញ្ញាគារ[illegible] ។

(៨៩) ម្នាលភិក្ខុទាំងឡាយ បើភិក្ខុប្រាថ្នាថា សូមឲ្យអាត្មាអញមានទិព្វចក្ខុដ៏បរិសុទ្ធ កន្លងហួសចក្ខុរបស់មនុស្សធម្មតា ឃើញនូវសត្វទាំងឡាយដែលច្យុតដែលកើត ជាសត្វថោកទាប ខ្ពង់ខ្ពស់ មានសម្បុរល្អ មានសម្បុរអាក្រក់ មានគតិល្អ មានគតិអាក្រក់ សូមឲ្យដឹងច្បាស់នូវពួកសត្វដែលប្រព្រឹត្តទៅ តាមកម្មរបស់ខ្លួនថា អើហ្ន៎សត្វ

សត្តា កាយទុច្ចរិតេន សមន្នាគតា វចីទុច្ចរិតេន សមន្នាគតា មនោទុច្ចរិតេន សមន្នាគតា អរិយានំ ឧបវាទកា មិច្ឆាទិដ្ឋិកា មិច្ឆាទិដ្ឋិកម្មសមាទានា តេ កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបន្នា ឥមេ វា បន ភោន្តោ សត្តា កាយសុចរិតេន សមន្នាគតា វចីសុចរិតេន សមន្នាគតា មនោសុចរិតេន សមន្នាគតា អរិយានំ អនុបវាទកា សម្មាទិដ្ឋិកា សម្មាទិដ្ឋិកម្មសមាទានា តេ កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបន្នាតិ ឥតិ ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន សត្តេ បស្សេយ្យំ ចវមានេ ឧបបជ្ជមានេ ហីនេ បណីតេ សុវណ្ណេ ទុព្វណ្ណេ សុគតេ ទុគ្គតេ យថាកម្មូបគេ សត្តេ បជានេយ្យន្តិ សីលេស្វេវស្ស បរិបូរការី អជ្ឈត្តំ ចេតោសមថមនុយុត្តោ អនិរាកតជ្ឈានោ វិបស្សនាយ សមន្នាគតោ ព្រូហេតា សុញ្ញាគារានំ ។



ទាំងឡាយនេះ ប្រកបដោយកាយទុច្ចរិត ប្រកបដោយវចីទុច្ចរិត ប្រកបដោយមនោទុច្ចរិត ជាសត្វតិះដៀលនូវពួកព្រះអរិយៈ ជាមិច្ឆាទិដ្ឋិ ប្រកាន់នូវកម្មជាមិច្ឆាទិដ្ឋិ សត្វទាំងនោះលុះបែកធ្លាយរាងកាយ បន្ទាប់អំពីសេចក្តីស្លាប់ទៅ ក៏ទៅកាន់កំណើតតិរច្ឆាន ប្រេត អសុរកាយ នរក ហើយ ចំណែកខាងសត្វទាំងនេះ ប្រកបដោយកាយសុចរិត ប្រកបដោយវចីសុចរិត ប្រកបដោយមនោសុចរិត ជាសត្វមិនតិះដៀលពួកព្រះអរិយៈ ជាសម្មាទិដ្ឋិ ប្រកាន់នូវកម្មជាសម្មាទិដ្ឋិ សត្វទាំងនោះលុះបែកធ្លាយរាងកាយ បន្ទាប់អំពីសេចក្តីស្លាប់ទៅ ក៏ទៅកាន់មនុស្សសុគតិ និងឋានសួគ៌ទេវលោក អាត្មាអញ សូមឲ្យឃើញដោយចក្ខុទិព្វដ៏បរិសុទ្ធ កន្លងហួសចក្ខុ របស់មនុស្សធម្មតា ឃើញពួកសត្វដែលកំពុងច្យុតិ កំពុងកើត ថោកទាប ខ្ពង់ខ្ពស់ មានសម្បុរល្អ មានសម្បុរអាក្រក់ មានគតិល្អ មានគតិអាក្រក់ (មួយទៀត) អាត្មាអញសូមឲ្យដឹងច្បាស់នូវសត្វទាំងឡាយដែលប្រព្រឹត្តទៅ តាមកម្មរបស់ខ្លួន ដោយប្រការយ៉ាងនេះដូច្នេះ គួរធ្វើសីលឲ្យបរិបូណ៌ ប្រកបរឿយៗ ក្នុងការរម្ងាប់នូវចិត្តខាងក្នុង មានឈានមិនឃ្លាតសាបសូន្យ ប្រកបដោយវិបស្សនា ចំរើននូវសុញ្ញាគារ ។

(៩០) អាកង្ខេយ្យ ចេ ភិក្ខវេ ភិក្ខុ អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរេយ្យន្តិ សីលេស្វេវស្ស បរិបូរការី អជ្ឈត្តំ ចេតោសមថមនុយុត្តោ អនិរាកតជ្ឈានោ វិបស្សនាយ សមន្នាគតោ ព្រូហេតា សុញ្ញាគារានំ ។ សម្បន្នសីលា ភិក្ខវេ វិហរថ សម្បន្នបាតិមោក្ខា បាតិមោក្ខសំវរសំវុតា វិហរថ អាចារគោចរសម្បន្នា អណុមត្តេសុ វជ្ជេសុ ភយទស្សាវី សមាទាយ សិក្ខថ សិក្ខាបទេសូតិ ។ ឥតិ យន្តំ វុត្តំ ឥទមេតំ បដិច្ច វុត្តន្តិ ។ ឥទមវោច ភគវា អត្តមនា តេ ភិក្ខូ ភគវតោ ភាសិតំ អភិនន្ទុន្តិ ។

អាកង្ខេយ្យសុត្តំ ឆដ្ឋំ និដ្ឋិតំ (១) ។

១ ឱ.ម. និដ្ឋិតន្តិ ន ទិស្សតិ ។





(៩០) ម្នាលភិក្ខុទាំងឡាយ បើភិក្ខុប្រាថ្នាថា សូមឲ្យអាត្មាអញបានធ្វើឲ្យជាក់ច្បាស់នូវចេតោវិមុត្តិនិងបញ្ញាវិមុត្តិ (១) ដ៏មិនមានអាសវៈ ព្រោះអស់ទៅនៃអាសវធម៌ទាំងឡាយ ដោយប្រាជ្ញារបស់ខ្លួន ដោយខ្លួនឯងក្នុងបច្ចុប្បន្ន ចូលទៅសម្រេចសម្រាន្តនៅ ដោយឥរិយាបថទាំង ៤ ដូច្នេះ គួរធ្វើសីលឲ្យបរិបូណ៌ ប្រកបរឿយ ៗ ក្នុងការរម្ងាប់នូវចិត្តខាងក្នុង មានឈានមិនបានសាបសូន្យ ប្រកបដោយវិបស្សនា ចំរើននូវសុញ្ញាគារស្ថាន ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរជាអ្នកមានសីលបរិបូណ៌ មានបាតិមោក្ខបរិបូណ៌ ចូរសង្រួមក្នុងបាតិមោក្ខសំវរៈ បរិបូណ៌ដោយអាចារៈនិងគោចរ ជាអ្នកឃើញភ័យក្នុងទោសទាំងឡាយ ត្រឹមតែបន្តិចបន្តួច ចូរសមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ ។ ពាក្យណាដែលតថាគតបានពោលហើយ (ក្នុងកាលមុន) ពាក្យនោះ តថាគតពោលនេះ ព្រោះអាស្រ័យយកពាក្យនុ៎ះឯង ដោយប្រការដូច្នេះ ។ លុះព្រះមានព្រះភាគទ្រង់សំដែងសូត្រនេះចប់ហើយ ពួកភិក្ខុទាំងនោះក៏មានចិត្តត្រេកអររីករាយនឹងភាសិតរបស់ព្រះមានព្រះភាគដោយក្រៃលែង ។

ចប់ អាកង្ខេយ្យសូត្រ ទី ៦ ។

១ សមាធិប្រកបដោយអរហត្តផល ហៅថា ចេតោវិមុត្តិ, បញ្ញាប្រកបដោយអរហត្តផល ហៅថា បញ្ញាវិមុត្តិ ។ ម្យ៉ាងទៀត សមាធិបានជាហៅថា ចេតោវិមុត្តិ ព្រោះរួចចាករាគៈ បញ្ញាបានជាហៅថា បញ្ញាវិមុត្តិ ព្រោះរួចចាកអវិជ្ជា ។ មួយវិញទៀត ផលនៃសមថៈហៅថា ចេតោវិមុត្តិ ផលនៃវិបស្សនា ហៅថា បញ្ញាវិមុត្តិ ។

## សត្តមំ វត្ថូបមសុត្តំ

(៩១) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ ភិក្ខវោតិ ។ ភទន្តេតិ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។

(៩២) ភគវា ឯតទវោច សេយ្យថាបិ ភិក្ខវេ វត្ថំ សង្កិលិដ្ឋំ មលគ្គហិតំ តមេនំ រជកោ យស្មិំ យស្មិំ រង្គជាតេ ឧបសំហរេយ្យ យទិ នីលកាយ យទិ បីតកាយ យទិ លោហិតកាយ យទិ មញ្ជិដ្ឋកាយ[១] ទុរត្តវណ្ណមេវស្ស[២] អបរិសុទ្ធវណ្ណមេវស្ស ។ តំ កិស្ស ហេតុ ។ អបរិសុទ្ធត្តា ភិក្ខវេ វត្ថស្ស ។ ឯវមេវ ខោ ភិក្ខវេ ចិត្តេ សង្កិលិដ្ឋេ ទុគ្គតិ បាដិកង្ខា ។ សេយ្យថាបិ ភិក្ខវេ វត្ថំ បរិសុទ្ធំ បរិយោទាតំ តមេនំ រជកោ យស្មិំ យស្មិំ រង្គជាតេ ឧបសំហរេយ្យ យទិ នីលកាយ យទិ បីតកាយ យទិ លោហិតកាយ យទិ មញ្ជិដ្ឋកាយ សុរត្តវណ្ណមេវស្ស បរិសុទ្ធវណ្ណមេវស្ស ។ តំ

១ ឱ. មជ្ជេដ្ឋកាយ ។ ម. មជ្ជិដ្ឋកាយ ។ ២ ឱ. ទុរត្តវណ្ណមេវស្ស ។

## វត្ថូបមសូត្រ ទី ៧

(៩១) ខ្ញុំបានស្តាប់មក យ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅ ក្នុងជេតវនារាម ជារបស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ ក្នុងទីនោះឯង ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ដូច្នេះ ។ ពួកភិក្ខុទាំងនោះ ទទួលព្រះពុទ្ធដីកាព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ដូច្នេះ ។

(៩២) ព្រះមានព្រះភាគ ទ្រង់មានព្រះពុទ្ធដីកាដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ដូចជាសំពត់ដែលសៅហ្មង មានមន្ទិលកាន់ ជាងជ្រលក់យកសំពត់នោះដាក់ ក្នុងគ្រឿងជ្រលក់ណា ៗ ដែលមានពណ៌ខៀវក្តី លឿងក្តី ក្រហមក្តី ហង្សបាទក្តី សំពត់នោះក៏នៅជាមានពណ៌មិនល្អ មានពណ៌មិនស្អាត ។ ដំណើរនោះព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថាសំពត់នោះមិនស្អាត ម្នាលភិក្ខុទាំងឡាយ កាលបើចិត្តសៅហ្មងហើយ ទុគ្គតិទីមានប្រាកដ ដូចសេចក្តីឧបមានោះដែរ ។ ម្នាលភិក្ខុទាំងឡាយ ដូចជាសំពត់ស្អាតផូរផង់ ជាងជ្រលក់យកសំពត់នោះដាក់ ក្នុងគ្រឿងជ្រលក់ណា ៗ ដែលមានពណ៌ខៀវក្តី លឿងក្តី ក្រហមក្តី ហង្សបាទក្តី សំពត់នោះក៏នៅជាមានពណ៌ល្អ មានពណ៌ស្អាត ។

កិស្ស ហេតុ ។ បរិសុទ្ធត្តា ភិក្ខវេ វត្ថស្ស ឯវមេវ ខោ ភិក្ខវេ ចិត្តេ អសង្កិលិដ្ឋេ សុគតិ បាដិកង្ខា ។

(៤៣) កតមេ ច ភិក្ខវេ ចិត្តស្ស ឧបក្កិលេសា ។ អភិជ្ឈាវិសមលោភោ ចិត្តស្ស ឧបក្កិលេសោ ព្យាបាទោ ចិត្តស្ស ឧបក្កិលេសោ កោធោ ចិត្តស្ស ឧបក្កិលេសោ ឧបនាហោ ចិត្តស្ស ឧបក្កិលេសោ មក្ខោ ចិត្តស្ស ឧបក្កិលេសោ បឡាសោ ចិត្តស្ស ឧបក្កិលេសោ ឥស្សា ចិត្តស្ស ឧបក្កិលេសោ មច្ឆរិយំ ចិត្តស្ស ឧបក្កិលេសោ មាយា ចិត្តស្ស ឧបក្កិលេសោ សាឋេយ្យំ



ដំណើរនោះនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះជាសំពត់ដ៏ស្អាត ម្នាលភិក្ខុទាំងឡាយ កាលបើចិត្តមិនសៅហ្មងហើយ សុគតិទីដ៏មានប្រាកដ ដូចសេចក្តីឧបមានោះដែរ ។

(៤៣) ម្នាលភិក្ខុទាំងឡាយ ពួកឧបក្កិលេស គឺសេចក្តីសៅហ្មងនៃចិត្ត តើដូចម្តេច ។ គឺអភិជ្ឈាវិសមលោភៈ[1] ជាឧបក្កិលេសនៃចិត្ត ១ ព្យាបាទជាឧបក្កិលេសនៃចិត្ត ១ ក្រោធៈជាឧបក្កិលេសនៃចិត្ត ១ ឧបនាហៈ (ការចងគំនុំទុក) ជាឧបក្កិលេសនៃចិត្ត ១ មក្ខៈ (ការលុបគុណរបស់លោកអ្នកមានគុណ) ជាឧបក្កិលេសនៃចិត្ត ១ បឡាសៈ (ការកាន់យកឫកប្រៀបផ្ទឹម ឬប្រណាំងនឹងគ្នា) ជាឧបក្កិលេសនៃចិត្ត ១ ឥស្សា (សេចក្តីច្រណែន) ជាឧបក្កិលេសនៃចិត្ត ១ មច្ឆរិយៈ (សេចក្តីកំណាញ់) ជាឧបក្កិលេសនៃចិត្ត ១ មាយា (ការបិទបាំងលាក់ពុតបិទបាំងទោស) ជាឧបក្កិលេសនៃចិត្ត ១ សាឋេយ្យៈ[2]

---

១ សេចក្តីត្រេកត្រអាលក្នុងទ្រព្យរបស់ខ្លួន ហៅថាអភិជ្ឈា សេចក្តីត្រេកអរក្នុងទ្រព្យរបស់អ្នកដទៃ ហៅថាវិសមលោភៈ មួយទៀតថា សេចក្តីត្រេកអរក្នុងទ្រព្យរបស់ខ្លួនក្តី របស់អ្នកដទៃក្តី ក្នុងទីដែលគួរ ហៅថាអភិជ្ឈា សេចក្តីត្រេកអរក្នុងទ្រព្យរបស់ខ្លួនក្តី របស់អ្នកដទៃក្តី ក្នុងទីដែលមិនគួរ ហៅថាវិសមលោភៈ ។ ២ សាឋេយ្យៈ ប្រែថាការអួតអាង ឬអែបអប នេះជាអំពើពុតត្បុតរបស់បុគ្គលជាអ្នកឡើងឫកអួតគុណដែលមិនមានក្នុងខ្លួន ធ្វើអាការមិនឲ្យខុសនឹងអ្នកណា មានអាការដូចត្រីអន្ទង់មច្ឆៈ ឃើញពួកត្រីមកក៏បង្ហាញកន្ទុយថាយើងជាត្រីដូចគ្នា ឃើញពួកពស់មកក៏បង្ហាញក្បាលថាយើងជាពស់ដូចគ្នា តែក្នុងអដ្ឋកថាព្រះអភិធម្មថា បុគ្គលដែលប្រកបដោយសាឋេយ្យៈ មានភេទដូចសត្វម្យ៉ាង មើលអំពីខាងឆ្វេងដូចជាសត្វជ្រូក មើលអំពីខាងស្តាំដូចសត្វពពែ ស្តាប់សំឡេងដូចសំឡេងចៀម មើលទៅស្នែងដូចគោឈ្មោល ។

ចិត្តស្ស ឧបក្កិលេសោ ថម្ភោ ចិត្តស្ស ឧបក្កិលេសោ សារម្ភោ ចិត្តស្ស ឧបក្កិលេសោ មានោ ចិត្តស្ស ឧបក្កិលេសោ អតិមានោ ចិត្តស្ស ឧបក្កិលេសោ មទោ ចិត្តស្ស ឧបក្កិលេសោ បមាទោ ចិត្តស្ស ឧបក្កិលេសោ ។

(៤៦) ស ខោ សោ[១] ភិក្ខវេ ភិក្ខុ អភិជ្ឈាវិសមលោភោ ចិត្តស្ស ឧបក្កិលេសោតិ ឥតិ វិទិត្វា អភិជ្ឈាវិសមលោភំ ចិត្តស្ស ឧបក្កិលេសំ បជហតិ ។ ព្យាបាទោ ចិត្តស្ស ឧបក្កិលេសោតិ ឥតិ វិទិត្វា ព្យាបាទំ ចិត្តស្ស ឧបក្កិលេសំ បជហតិ ។ កោធោ ចិត្តស្ស ឧបក្កិលេសោតិ ឥតិ វិទិត្វា កោធំ ចិត្តស្ស

១ ម. សេ ខោ សោ ។



ជាឧបក្កិលេសនៃចិត្ត១ ថម្ភៈ[១] (សេចក្តីរឹងត្អឹង) ជាឧបក្កិលេសនៃចិត្ត ១ សារម្ភៈ[២] (ការប្រណាំងប្រជែង) ជាឧបក្កិលេសនៃចិត្ត១ មានះ (សេចក្តីប្រកាន់ខ្លួន) ជាឧបក្កិលេសនៃចិត្ត១ អតិមានះ (សេចក្តីប្រកាន់ខ្លួនហួសពេក) ជាឧបក្កិលេសនៃចិត្ត ១ មទៈ (សេចក្តីស្រវឹង) ជាឧបក្កិលេសនៃចិត្ត ១ បមាទៈ (ការប្រហែសធ្វេសឬបណ្តែតបណ្តោយចិត្ត ទៅក្នុងកាមគុណ) ជាឧបក្កិលេសនៃចិត្ត ១ ។

(៤៦) ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះឯង លុះដឹងច្បាស់ថា អភិជ្ឈាវិសមលោភៈ ជាឧបក្កិលេសនៃចិត្តដូច្នេះហើយ ក៏រមែងលះនូវអភិជ្ឈាវិសមលោភៈ ជាឧបក្កិលេសនៃចិត្តចេញបាន ។ លុះដឹងច្បាស់ថា ព្យាបាទ ជាឧបក្កិលេសនៃចិត្តដូច្នេះហើយ ក៏រមែងលះនូវព្យាបាទជាឧបក្កិលេសនៃចិត្តចេញបាន ។ លុះដឹងច្បាស់ថា ក្រោធៈ ជាឧបក្កិលេសនៃចិត្ត

១ ក្នុងអដ្ឋកថាព្រះអភិធម្មថា សេចក្តីរឹងត្អឹងរបស់ចិត្តប្រៀបដូចសំពត់សាដកដែលរឹងដោយបាយម៉ាន់ បុគ្គលដែលប្រកបដោយថម្ភៈនោះ រមែងជាអ្នកគ្មានសភាពទាប ជាអ្នកព្រហើនប៉ោងឡើង ប្រៀបដូចពស់ថ្លាន់ដែលលេបឆ្អៀងឆ្អល់ ឬប្រៀបដូចធ្លោកស្បែកដែលពេញដោយខ្យល់ កាលបើឃើញចេតិយ ឬបុគ្គលចាស់ជាងខ្លួន ក៏មិនធ្វើសេចក្តីទន់ទោន ។ ២ សារម្ភៈ មានលក្ខណៈធ្វើអំពើឲ្យលើសលុបជាងគេ ចែកជាពីរផ្នែក ជាអកុសលក៏មាន ជាកុសលក៏មាន ចំណែកខាងគ្រហស្ថកាលបើឃើញគេធ្វើគ្រឿងប្រដាប់កាយជាដើម ក៏ប្រឹងឲ្យប្រសើរជាងគេជាទ្វេគុណ ចំណែកអ្នកបួស កាលបើឃើញគេរៀនធម៌បានប៉ុន្មានៗ ក៏ខំប្រឹងរៀនឲ្យបានច្រើនជាងគេជាទ្វេគុណ ម្យ៉ាងទៀត ចំណែកគ្រហស្ថកាលបើឃើញគេធ្វើសលាក–ភត្ត ១ ខ្លួនក៏ចង់ធ្វើឲ្យបានពីរឬបី ចំណែកអ្នកបួសកាលបើឃើញគេរៀនបានគម្ពីរនិកាយ ១ ខ្លួនក៏ចង់រៀនឲ្យបានពីរនិកាយដែរ តែក្នុងទីនេះសំដៅយកតែអកុសល ។

ឧបក្កិលេសំ បជហតិ ។ ឧបនាហោ ចិត្តស្ស ឧបក្កិលេសោតិ ឥតិ វិទិត្វា ឧបនាហំ ចិត្តស្ស ឧបក្កិលេសំ បជហតិ ។ មក្ខោ ចិត្តស្ស ឧបក្កិលេសោតិ ឥតិ វិទិត្វា មក្ខំ ចិត្តស្ស ឧបក្កិលេសំ បជហតិ ។ បឡាសោ ចិត្តស្ស ឧបក្កិលេសោតិ ឥតិ វិទិត្វា បឡាសំ ចិត្តស្ស ឧបក្កិលេសំ បជហតិ ។ ឥស្សា ចិត្តស្ស ឧបក្កិលេសោតិ ឥតិ វិទិត្វា ឥស្សំ ចិត្តស្ស ឧបក្កិលេសំ បជហតិ ។ មច្ឆរិយំ ចិត្តស្ស ឧបក្កិលេសោតិ ឥតិ វិទិត្វា មច្ឆរិយំ ចិត្តស្ស ឧបក្កិលេសំ បជហតិ ។ មាយា ចិត្តស្ស ឧបក្កិលេសោតិ ឥតិ វិទិត្វា មាយំ ចិត្តស្ស ឧបក្កិលេសំ បជហតិ ។ សាឋេយ្យំ ចិត្តស្ស ឧបក្កិលេសោតិ ឥតិ វិទិត្វា សាឋេយ្យំ ចិត្តស្ស ឧបក្កិលេសំ បជហតិ ។ ថម្ភោ ចិត្តស្ស ឧបក្កិលេសោតិ ឥតិ វិទិត្វា ថម្ភំ ចិត្តស្ស ឧបក្កិលេសំ បជហតិ ។ សារម្ភោ ចិត្តស្ស ឧបក្កិលេសោតិ ឥតិ វិទិត្វា សារម្ភំ ចិត្តស្ស ឧបក្កិលេសំ បជហតិ ។ មានោ ចិត្តស្ស ឧបក្កិលេសោតិ ឥតិ



ដូច្នេះហើយ ក៏រមែងលះនូវក្រោធៈ ជាឧបក្កិលេសនៃចិត្តចេញបាន ។ លុះដឹងច្បាស់ថា ឧបនាហៈ ជាឧបក្កិលេសនៃចិត្តដូច្នេះហើយ ក៏រមែងលះនូវឧបនាហៈ ជាឧបក្កិលេសនៃចិត្តចេញបាន ។ លុះដឹងច្បាស់ថា មក្ខៈ ជាឧបក្កិលេសនៃចិត្តដូច្នេះហើយ ក៏រមែងលះនូវមក្ខៈ ជាឧបក្កិលេសនៃចិត្តចេញបាន ។ លុះដឹងច្បាស់ថា បឡាសៈ ជាឧបក្កិលេសនៃចិត្តដូច្នេះហើយ ក៏រមែងលះនូវបឡាសៈ ជាឧបក្កិលេសនៃចិត្តចេញបាន ។ លុះដឹងច្បាស់ថា ឥស្សា ជាឧបក្កិលេសនៃចិត្តដូច្នេះហើយ ក៏រមែងលះនូវឥស្សា ជាឧបក្កិលេសនៃចិត្តចេញបាន ។ លុះដឹងច្បាស់ថា មច្ឆរិយៈ ជាឧបក្កិលេសនៃចិត្តដូច្នេះហើយ ក៏រមែងលះនូវមច្ឆរិយៈ ជាឧបក្កិលេសនៃចិត្តចេញបាន ។ លុះដឹងច្បាស់ថា មាយា ជាឧបក្កិលេសនៃចិត្តដូច្នេះហើយ ក៏រមែងលះនូវមាយា ជាឧបក្កិលេសនៃចិត្តចេញបាន ។ លុះដឹងច្បាស់ថា សាឋេយ្យៈ ជាឧបក្កិលេសនៃចិត្តដូច្នេះហើយ ក៏រមែងលះនូវសាឋេយ្យៈ ជាឧបក្កិលេសនៃចិត្តចេញបាន ។ លុះដឹងច្បាស់ថា ថម្ភៈ ជាឧបក្កិលេសនៃចិត្តដូច្នេះហើយ ក៏រមែងលះនូវថម្ភៈ ជាឧបក្កិលេសនៃចិត្តចេញបាន ។ លុះដឹងច្បាស់ថា សារម្ភៈ ជាឧបក្កិលេសនៃចិត្តដូច្នេះហើយ ក៏រមែងលះនូវសារម្ភៈ ជាឧបក្កិលេសនៃចិត្តចេញបាន ។ លុះដឹងច្បាស់ថា មានៈ ជាឧបក្កិលេសនៃចិត្តដូច្នេះហើយ ក៏រមែង

វិទិត្វា មានំ ចិត្តស្ស ឧបក្កិលេសំ បជហតិ ។ អតិមានោ ចិត្តស្ស ឧបក្កិលេសោ ឥតិ វិទិត្វា អតិ-មានំ ចិត្តស្ស ឧបក្កិលេសំ បជហតិ ។ មទោ ចិត្តស្ស ឧបក្កិលេសោ ឥតិ វិទិត្វា មទំ ចិត្តស្ស ឧបក្កិលេសំ បជហតិ ។ បមាទោ ចិត្តស្ស ឧបក្កិ-លេសោតិ ឥតិ វិទិត្វា បមាទំ ចិត្តស្ស ឧបក្កិលេសំ បជហតិ ។

(៤៨) យតោ ខោ ភិក្ខវេ ភិក្ខុនោ អភិជ្ឈាវិស-មលោភោ ចិត្តស្ស ឧបក្កិលេសោតិ ឥតិ វិទិត្វា អភិជ្ឈាវិសមលោភោ ចិត្តស្ស ឧបក្កិលេសោ បហីនោ ហោតិ ។ ព្យាបាទោ ចិត្តស្ស ឧបក្កិលេសោតិ ឥតិ វិទិត្វា ព្យាបាទោ ចិត្តស្ស ឧបក្កិលេសោ បហីនោ ហោតិ ។ កោធោ ចិត្តស្ស ឧបក្កិលេសោតិ ឥតិ វិទិត្វា កោធោ ចិត្តស្ស ឧបក្កិលេសោ បហីនោ ហោតិ ។ ឧបនាហោ ចិត្តស្ស ឧបក្កិលេសោតិ ឥតិ វិទិត្វា ឧប-នាហោ ចិត្តស្ស ឧបក្កិលេសោ បហីនោ ហោតិ ។ មក្ខោ ចិត្តស្ស ឧបក្កិលេសោតិ ឥតិ វិទិត្វា មក្ខោ





លះនូវមានះ ជាឧបក្កិលេសនៃចិត្តចេញបាន ។ លុះដឹងច្បាស់ថា អតិមានះ ជាឧបក្កិលេសនៃចិត្តដូច្នេះហើយ ក៏រមែងលះនូវអតិមានះ ជាឧបក្កិលេសនៃចិត្តចេញបាន ។ លុះដឹងច្បាស់ថា មទះ ជាឧបក្កិលេសនៃចិត្តដូច្នេះហើយ ក៏រមែងលះនូវមទះ ជាឧបក្កិលេសនៃចិត្តចេញបាន ។ លុះដឹងច្បាស់ថា បមាទះ ជាឧបក្កិលេសនៃចិត្តដូច្នេះហើយ ក៏រមែងលះនូវបមាទះ ជាឧបក្កិលេសនៃចិត្តចេញបាន ។

(៤៨) ម្នាលភិក្ខុទាំងឡាយ កាលណា ភិក្ខុដឹងច្បាស់ថា អភិ-ជ្ឈាវិសមលោភៈ ជាឧបក្កិលេស នៃចិត្តដូច្នេះ ហើយបានលះ អភិជ្ឈាវិសមលោភៈ ជាឧបក្កិលេសនៃចិត្ត ។ ដឹងច្បាស់ថា ព្យាបាទៈ ជាឧបក្កិ-លេសនៃចិត្តដូច្នេះ ហើយបានលះ ព្យាបាទៈ ជាឧបក្កិលេសនៃចិត្ត ។ ដឹងច្បាស់ថា កោធៈ ជាឧបក្កិលេស នៃចិត្តដូច្នេះ ហើយបានលះ កោធៈ ជាឧបក្កិលេសនៃចិត្ត ។ ដឹងច្បាស់ថា ឧបនាហៈ ជាឧបក្កិលេសនៃចិត្តដូច្នេះ ហើយបានលះ ឧបនាហៈ ជាឧបក្កិលេសនៃចិត្ត ។ ដឹងច្បាស់ថា មក្ខៈ ជាឧបក្កិលេសនៃចិត្តដូច្នេះ ហើយបានលះមក្ខៈ ជាឧបក្កិលេស នៃ

ចិត្តស្ស ឧបក្កិលេសោ បហីនោ ហោតិ ។ បឡាសោ ចិត្តស្ស ឧបក្កិលេសោតិ ឥតិ វិទិត្វា បឡាសោ ចិត្តស្ស ឧបក្កិលេសោ បហីនោ ហោតិ ។ ឥស្សា ចិត្តស្ស ឧបក្កិលេសោតិ ឥតិ វិទិត្វា ឥស្សា ចិត្តស្ស ឧបក្កិលេសោ បហីនោ ហោតិ ។ មច្ឆរិយំ ចិត្តស្ស ឧបក្កិលេសោតិ ឥតិ វិទិត្វា មច្ឆរិយំ ចិត្តស្ស ឧបក្កិលេសោ បហីនោ ហោតិ ។ មាយា ចិត្តស្ស ឧបក្កិលេសោតិ ឥតិ វិទិត្វា មាយា ចិត្តស្ស ឧបក្កិលេសោ បហីនោ ហោតិ ។ សាឋេយ្យំ ចិត្តស្ស ឧបក្កិលេសោតិ ឥតិ វិទិត្វា សាឋេយ្យំ ចិត្តស្ស ឧបក្កិលេសោ បហីនោ ហោតិ ។ ថម្ភោ ចិត្តស្ស ឧបក្កិលេសោតិ ឥតិ វិទិត្វា ថម្ភោ ចិត្តស្ស ឧបក្កិលេសោ បហីនោ ហោតិ ។ សារម្ភោ ចិត្តស្ស ឧបក្កិលេសោតិ ឥតិ វិទិត្វា សារម្ភោ ចិត្តស្ស ឧបក្កិលេសោ បហីនោ ហោតិ ។ មានោ ចិត្តស្ស ឧបក្កិលេសោតិ ឥតិ វិទិត្វា មានោ ចិត្តស្ស ឧបក្កិលេសោ បហីនោ ហោតិ ។ អតិមានោ ចិត្តស្ស ឧបក្កិលេសោតិ ឥតិ វិទិត្វា អតិមានោ ចិត្តស្ស ឧបក្កិ-



ចិត្ត ។ ដឹងច្បាស់ថា បឡាសៈ ជាឧបក្កិលេសនៃចិត្តដូច្នេះ ហើយបានលះបឡាសៈជាឧបក្កិលេសនៃចិត្ត ។ ដឹងច្បាស់ថា ឥស្សា ជាឧបក្កិលេសនៃចិត្តដូច្នេះ ហើយបានលះឥស្សាជាឧបក្កិលេសនៃចិត្ត ។ ដឹងច្បាស់ថា មច្ឆរិយៈ ជាឧបក្កិលេសនៃចិត្តដូច្នេះ ហើយបានលះ មច្ឆរិយៈ ជាឧបក្កិលេសនៃចិត្ត ។ ដឹងច្បាស់ថា មាយា ជាឧបក្កិលេសនៃចិត្តដូច្នេះ ហើយបានលះ មាយា ជាឧបក្កិលេសនៃចិត្ត ។ ដឹងច្បាស់ថា សាថេយ្យៈ ជាឧបក្កិលេសនៃចិត្តដូច្នេះ ហើយបានលះ សាថេយ្យៈ ជាឧបក្កិលេសនៃចិត្ត ។ ដឹងច្បាស់ថា ថម្ភៈ ជាឧបក្កិលេសនៃចិត្តដូច្នេះ ហើយបានលះ ថម្ភៈ ជាឧបក្កិលេសនៃចិត្ត ។ ដឹងច្បាស់ថា សារម្ភៈ ជាឧបក្កិលេសនៃចិត្តដូច្នេះ ហើយបានលះ សារម្ភៈ ជាឧបក្កិលេសនៃចិត្ត ។ ដឹងច្បាស់ថាមានៈ ជាឧបក្កិលេសនៃចិត្តដូច្នេះ ហើយបានលះមានៈ ជាឧបក្កិលេសនៃចិត្ត ។ ដឹងច្បាស់ថាអតិមានៈជាឧបក្កិលេសនៃចិត្តដូច្នេះ ហើយបានលះ អតិមានៈ ជាឧបក្កិលេសនៃចិត្ត ។

លេសោ បហីនោ ហោតិ ។ មទោ ចិត្តស្ស ឧបក្កិលេសោតិ ឥតិ វិទិត្វា មទោ ចិត្តស្ស ឧបក្កិលេសោ បហីនោ ហោតិ ។ បមាទោ ចិត្តស្ស ឧបក្កិលេសោតិ ឥតិ វិទិត្វា បមាទោ ចិត្តស្ស ឧបក្កិលេសោ បហីនោ ហោតិ ។ សោ ពុទ្ធេ អវេច្ចប្បសាទេន សមន្នាគតោ ហោតិ ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ សុគតោ លោកវិទូ អនុត្តរោ បុរិសទម្មសារថិ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ ។ ធម្មេ អវេច្ចប្បសាទេន សមន្នាគតោ ហោតិ ស្វាក្ខាតោ ភគវតា ធម្មោ សន្ទិដ្ឋិកោ អកាលិកោ ឯហិ-



ដឹងច្បាស់ថា មទៈ ជាឧបក្កិលេសនៃចិត្តដូច្នេះ ហើយបានលះ មទៈ ជាឧបក្កិលេសនៃចិត្ត ។ ដឹងច្បាស់ថា បមាទៈ ជាឧបក្កិលេស នៃចិត្តដូច្នេះ ហើយបានលះ បមាទៈ ជាឧបក្កិលេសនៃចិត្ត ។ ភិក្ខុនោះរមែងជាអ្នកប្រកបដោយសេចក្តីជ្រះថ្លា មិនញាប់ញ័រ ក្នុងព្រះពុទ្ធដូច្នេះថា ព្រះមានព្រះភាគនោះ ព្រះអង្គឆ្ងាយចាកសេចក្តីសៅហ្មងគ្រប់យ៉ាង ព្រះអង្គត្រាស់ដឹង នូវញេយ្យធម៌ទាំងពួងដោយប្រពៃចំពោះព្រះអង្គ ព្រះអង្គបរិបូណ៌ដោយវិជ្ជានិងចរណៈ គឺសេចក្តីចេះដឹងនិងកិរិយាដែលបុគ្គលគប្បីប្រព្រឹត្ត ព្រះអង្គមានដំណើរល្អ ព្រះអង្គជ្រាបច្បាស់នូវត្រៃលោក ព្រះអង្គប្រសើរដោយសីលាទិគុណរកបុគ្គលណាមួយស្មើគ្មាន ព្រះអង្គជាសារថីអ្នកទូន្មាននូវបុរសដែលគួរទូន្មានបាន ព្រះអង្គជាគ្រូនៃទេវតានិងមនុស្សទាំងឡាយ ព្រះអង្គបានត្រាស់ដឹងនូវអរិយសច្ចធម៌ ព្រះអង្គលែងវិលត្រឡប់មកកាន់ភពថ្មីទៀត ។ រមែងជាអ្នកប្រកបដោយសេចក្តីជ្រះថ្លា មិនញាប់ញ័រក្នុងព្រះធម៌ថា ព្រះបរិយត្តិធម៌ដែលព្រះមានព្រះភាគទ្រង់ត្រាស់សំដែងហើយដោយល្អ ព្រះលោកុត្តរធម៌ ជាធម៌ដែលព្រះអរិយបុគ្គលទាំងពួង ដឹងពិត ឃើញពិត ដោយបច្ចវេក្ខណញ្ញាណ ជាធម៌ឲ្យនូវផលមិនរង់ចាំកាល ជាធម៌គួរដល់ឯហិបស្សវិធី ជាធម៌ដែលព្រះអរិយ-

បស្សិកោ ឱបនយិកោ បច្ចត្តំ វេទិតព្វោ វិញ្ញូហីតិ ។ សង្ឃេ អវេច្ចប្បសាទេន សមន្នាគតោ ហោតិ សុបដិបន្នោ ភគវតោ សាវកសង្ឃោ ឧជុបដិបន្នោ ភគវតោ សាវកសង្ឃោ ញាយបដិបន្នោ ភគវតោ សាវកសង្ឃោ សាមីចិបដិបន្នោ ភគវតោ សាវកសង្ឃោ យទិទំ ចត្តារិ បុរិសយុគានិ អដ្ឋ បុរិសបុគ្គលា ឯស ភគវតោ សាវកសង្ឃោ អាហុនេយ្យោ បាហុនេយ្យោ ទក្ខិណេយ្យោ អញ្ជលិករណីយោ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ ។ យតោធិ ខោ បនស្ស ចត្តំ ហោតិ វន្តំ មុត្តំ បហីនំ បដិនិស្សដ្ឋំ ។ សោ



បុគ្គលគប្បីបង្អោនចូលមករកក្នុងខ្លួនដោយអំណាចនៃការឃើញ ជាធម៌ដែលអ្នកប្រាជ្ញទាំងឡាយមានឧគ្ឃដិតញ្ញូបុគ្គលជាដើម គប្បីដឹងច្បាស់ក្នុងចិត្តនៃខ្លួន ៗ រមែងជាអ្នកប្រកបដោយសេចក្ដីជ្រះថ្លា មិនញាប់ញ័រក្នុងព្រះសង្ឃថា ពួកសាវ័ក នៃព្រះមានព្រះភាគប្រតិបត្តិប្រពៃ ពួកសាវ័ក នៃព្រះមានព្រះភាគ ប្រតិបត្តិត្រង់ ពួកសាវ័ក នៃព្រះមានព្រះភាគ ប្រតិបត្តិដើម្បីព្រះនិព្វាន ពួកសាវ័ក នៃព្រះមានព្រះភាគ ប្រតិបត្តិសមគួរ គឺប្រតិបត្តិគួរដល់សីល សមាធិ បញ្ញា បុរសបុគ្គលណា បើរាប់ជាគូ បាន ៤ គូ បើរាប់រៀងទៅ បាន ៨ ពួកសាវ័ក របស់ព្រះមានព្រះភាគនេះ គួរទទួលនូវចតុប្បច្ច័យ ដែលបុគ្គលនាំមកអំពីចម្ងាយបូជា គួរទទួលនូវអាគន្តុកទាន គួរទទួលនូវទក្ខិណាទាន គួរដល់អញ្ជលីកម្ម ជាបុញ្ញក្ខេត្តនៃសត្វលោក រកខេត្តដទៃក្រៃលែងជាងគ្មាន ។ កាលណា បើកិលេសនោះលះចោលហើយ ខ្ជាក់ចោលហើយ ដោះចោលហើយ លះលែងចោលហើយ រលាស់ចោលហើយ (នូវចំណែកកិលេសទាំងនោះ) ដោយខណ្ឌ[1] គឺមគ្គខាងក្រោមទាំង ៣ ។ ភិក្ខុនោះរមែងបាននូវ

១ ខណ្ឌ ប្រែថាចំណែកឬដុំ ។

ពុទ្ធេ អវេច្ចប្បសាទេន សមន្នាគតោម្ហីតិ លភតិ អត្ថវេទំ លភតិ ធម្មវេទំ លភតិ ធម្មូបសញ្ហិតំ បាមុជ្ជំ បមុទិតស្ស បីតិ ជាយតិ បីតិមនស្ស កាយោ បស្សម្ភតិ បស្សទ្ធកាយោ សុខំ វេទេតិ សុខិនោ ចិត្តំ សមាធិយតិ ។ ធម្មេ ។ បេ ។ សង្ឃេ អវេច្ចប្បសាទេន សមន្នាគតោម្ហីតិ លភតិ អត្ថវេទំ លភតិ ធម្មវេទំ លភតិ ធម្មូបសញ្ហិតំ បាមុជ្ជំ បមុទិតស្ស បីតិ ជាយតិ បីតិមនស្ស កាយោ បស្សម្ភតិ បស្សទ្ធកាយោ សុខំ វេទេតិ សុខិនោ ចិត្តំ សមាធិយតិ ។ យតោ ខោ បន មេ ចត្តំ វន្តំ មុត្តំ បហីនំ បដិនិស្សដ្ឋន្តិ លភតិ អត្ថវេទំ លភតិ ធម្មវេទំ លភតិ ធម្មូបសញ្ហិតំ បាមុជ្ជំ បមុទិតស្ស



សេចក្ដីត្រេកអរក្នុងអត្ថ បាននូវសេចក្ដីត្រេកអរក្នុងធម៌ បាននូវសេចក្ដីរីករាយប្រកបដោយធម៌ ដោយគិតថា អាត្មាអញជាអ្នកប្រកបដោយសេចក្ដីជ្រះថ្លា មិនញាប់ញ័រ ក្នុងព្រះពុទ្ធដូច្នេះ កាលបើភិក្ខុនោះមានចិត្តរីករាយហើយ បីតិក៏កើត កាលបើភិក្ខុមានចិត្តប្រកបដោយបីតិហើយ កាយក៏ស្ងប់រម្ងាប់ លុះភិក្ខុមានកាយស្ងប់រម្ងាប់ហើយ រមែងទទួលនូវសេចក្ដីសុខ កាលបើភិក្ខុមានសេចក្ដីសុខហើយ ចិត្តក៏តម្កល់នៅល្អ ។ ក្នុងព្រះធម៌ ។ បេ ។ រមែងបាននូវសេចក្ដីត្រេកអរក្នុងអត្ថ បាននូវសេចក្ដីត្រេកអរក្នុងធម៌ បាននូវសេចក្ដីរីករាយប្រកបដោយធម៌ ដោយគិតថា អាត្មាអញជាអ្នកប្រកបដោយសេចក្ដីជ្រះថ្លា មិនញាប់ញ័រ ក្នុងព្រះសង្ឃដូច្នេះ កាលបើភិក្ខុនោះមានចិត្តរីករាយហើយ បីតិក៏កើត កាលបើភិក្ខុមានចិត្តប្រកបដោយបីតិហើយ កាយក៏ស្ងប់រម្ងាប់ លុះភិក្ខុមានកាយស្ងប់រម្ងាប់ហើយ រមែងទទួលនូវសេចក្ដីសុខ កាលបើភិក្ខុមានសេចក្ដីសុខហើយ ចិត្តក៏បានតម្កល់នៅល្អ ។ រមែងបាននូវសេចក្ដីត្រេកអរក្នុងអត្ថ បាននូវសេចក្ដីត្រេកអរក្នុងធម៌ បាននូវសេចក្ដីរីករាយប្រកបដោយធម៌ ដោយគិតថា អាត្មាអញបានលះចោលហើយ ខ្ជាក់ចោលហើយ ដោះចោលហើយ លះលែងចោលហើយ លោះចោលហើយ នូវឧបក្កិលេសទាំងនោះ ដោយទុតិយមគ្គខាងក្រោមទាំង ៣ ដូច្នេះ កាលបើភិក្ខុមានចិត្តរីករាយហើយ

បីតិ ជាយតិ បីតិមនស្ស កាយោ បស្សម្ភតិ បស្សទ្ធកាយោ សុខំ វេទេតិ សុខិនោ ចិត្តំ សមាធិយតិ ។

(៩៦) ស ខោ សោ ភិក្ខវេ ភិក្ខុ ឯវំសីលោ ឯវំធម្មោ ឯវំបញ្ញោ សាលីនញ្ចេបិ បិណ្ឌបាតំ ភុញ្ជតិ វិចិតកាឡកំ អនេកសូបំ អនេកព្យញ្ជនំ នេវស្ស តំ ហោតិ អន្តរាយាយ ។ សេយ្យថាបិ ភិក្ខវេ វត្ថំ សំកិលិដ្ឋំ មលគ្គហិតំ អច្ឆំ ឧទកំ[១] អាគម្ម បរិសុទ្ធំ ហោតិ បរិយោទាតំ ឧក្កាមុខំ វា បនាគម្ម ជាតរូបំ សុបរិសុទ្ធំ[២] ហោតិ បរិយោទាតំ ឯវមេវ ខោ ភិក្ខវេ ភិក្ខុ ឯវំសីលោ ឯវំធម្មោ ឯវំបញ្ញោ សាលីនញ្ចេបិ បិណ្ឌបាតំ ភុញ្ជតិ វិចិតកាឡកំ អនេកសូបំ អនេកព្យញ្ជនំ នេវស្ស តំ ហោតិ អន្តរាយាយ ។

១ ម. អច្ឆោទកំ ។ ២ ម. បរិសុទ្ធំ ។



បីតិក៏កើត កាលបើភិក្ខុមានចិត្តប្រកបដោយបីតិហើយ កាយក៏ស្ងប់រម្ងាប់ លុះភិក្ខុមានកាយស្ងប់រម្ងាប់ហើយ រមែងទទួលនូវសេចក្តីសុខ កាលបើភិក្ខុមានសេចក្តីសុខហើយ ចិត្តក៏រមែងតម្កល់នៅល្អ ។

(៩៦) ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះឯង មានសីលយ៉ាងនេះ មានធម៌យ៉ាងនេះ មានប្រាជ្ញាយ៉ាងនេះ រមែងបរិភោគនូវបាយនៃស្រូវសាលីដែលប្រាសចាកពណ៌ខ្មៅ មានសំឡរច្រើនមុខ មានម្ហូបគ្រឿងច្រើនមុខ ការបរិភោគនោះមិនមានអន្តរាយដល់ភិក្ខុនោះឡើយ ។ ម្នាលភិក្ខុទាំងឡាយ ដូចជាសំពត់ដែលសៅហ្មង មានប្រឡាក់មន្ទិល ហើយនៅជាសំពត់ស្អាតផូរផង់ ព្រោះតែអាស្រ័យទឹកថ្លា ម្យ៉ាងទៀត មាសដែលបរិសុទ្ធស្អាត ផូរផង់ ព្រោះអាស្រ័យមាត់ជ្រាវ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានសីលយ៉ាងនេះ មានធម៌យ៉ាងនេះ មានប្រាជ្ញាយ៉ាងនេះ បរិភោគនូវបិណ្ឌបាតនៃស្រូវសាលី ដែលប្រាសចាកពណ៌ខ្មៅ មានសំឡរច្រើនមុខ មានម្ហូបគ្រឿងច្រើនមុខ ការបរិភោគនោះ មិនមានអន្តរាយដល់ភិក្ខុនោះ យ៉ាងនោះដែរ ។

(៩៧) សោ មេត្តាសហគតេន ចេតសា ឯកំ ទិសំ ផរិត្វា វិហរតិ តថា ទុតិយំ តថា តតិយំ តថា ចតុត្ថំ ។ ឥតិ ឧទ្ធមធោ តិរិយំ សព្វធិ សព្វត្តតាយ សព្វាវន្តំ លោកំ មេត្តាសហគតេន ចេតសា វិបុលេន មហគ្គតេន អប្បមាណេន អវេរេន អព្យាបជ្ជេន ផរិត្វា វិហរតិ ។ ករុណាសហគតេន ចេតសា ។ បេ ។ មុទិតាសហគតេន ចេតសា ។ បេ ។ ឧបេក្ខាសហគតេន ចេតសា ឯកំ ទិសំ ផរិត្វា វិហរតិ តថា ទុតិយំ តថា តតិយំ តថា ចតុត្ថំ ។ ឥតិ ឧទ្ធមធោ តិរិយំ សព្វធិ សព្វត្តតាយ សព្វាវន្តំ លោកំ ឧបេក្ខាសហគតេន ចេតសា វិបុលេន មហគ្គតេន អប្បមាណេន អវេរេន អព្យាបជ្ជេន ផរិត្វា វិហរតិ ។ សោ អត្ថិ ឥទំ អត្ថិ ហីនំ អត្ថិ បណីតំ អត្ថិ ឥមស្ស សញ្ញាគតស្ស ឧត្តរឹ និស្សរណន្តិ បជានាតិ ។ តស្ស ឯវំ ជានតោ ឯវំ បស្សតោ កាមាសវាបិ ចិត្តំ វិមុច្ចតិ ភវាសវាបិ ចិត្តំ វិមុច្ចតិ អវិជ្ជាសវាបិ ចិត្តំ វិមុច្ចតិ



(៩៧) ភិក្ខុនោះរមែងមានចិត្តប្រកបដោយមេត្តា ផ្សាយទៅកាន់ទិស ១ ផ្សាយទៅកាន់ទិសទី ២ ទី ៣ ទី ៤ ក៏ដូចគ្នា ។ រមែងមានចិត្តប្រកបដោយមេត្តា ជាចិត្តធំទូលាយ ដល់នូវភាវៈជាធំ រកប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់ទិសខាងលើ ខាងក្រោម និងទិសទទឹង[1] ផ្សាយទៅកាន់ទិសទាំងពួង ដោយប្រការទាំងពួង គ្រប់ទីទាំងពួង ។ មានចិត្តប្រកបដោយករុណា ។ បេ ។ មានចិត្តប្រកបដោយមុទិតា ។ បេ ។ មានចិត្តប្រកបដោយឧបេក្ខា ផ្សាយទៅកាន់ទិស ១ ផ្សាយទៅកាន់ទិសទី ២ ទី ៣ ទី ៤ ក៏ដូចគ្នា ។ មានចិត្តប្រកបដោយឧបេក្ខា ជាចិត្តធំទូលាយ ដល់នូវភាវៈជាធំ រកប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់ទិសខាងលើ ខាងក្រោម និងទិសទទឹង ផ្សាយទៅកាន់លោកទាំងពួង ដោយប្រការទាំងពួង គ្រប់ទីទាំងពួង ។ ភិក្ខុនោះរមែងដឹងច្បាស់ថា ទុក្ខសច្ចនេះនៅមាន សមុទយសច្ចដែលគួរលះបង់នៅមាន មគ្គសច្ចដ៏ប្រសើរក៏នៅមាន និរោធសច្ចជាគ្រឿងរលាស់ចេញនូវសញ្ញានេះតទៅក៏នៅមាន ។ កាលភិក្ខុនោះដឹងយ៉ាងនេះហើយ ឃើញយ៉ាងនេះហើយ ចិត្តរមែងរួចចាកកាមាសវៈផង ចិត្តរមែងរួចចាកភវាសវៈផង ចិត្តរមែងរួចចាកអវិជ្ជាសវៈផង

---

១ ទិសអាគ្នេយ៍ ១ ទិសនិរតី ១ ទិសពាយ័ព្យ ១ ទិសឦសាន ១ ។

វិមុត្តស្មឹ វិមុត្តមិតិ ញាណំ ហោតិ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាតិ ។ អយំ វុច្ចតិ ភិក្ខវេ ភិក្ខុ សិនាតោ អន្តរេន សិនានេនាតិ ។

[៤៨] តេន ខោ បន សមយេន សុន្ទរិកភារទ្វាជោ ព្រាហ្មណោ ភគវតោ អវិទូរេ និសិន្នោ ហោតិ ។ អថខោ សុន្ទរិកភារទ្វាជោ ព្រាហ្មណោ ភគវន្តំ ឯតទវោច គច្ឆតិ បន ភវំ គោតមោ ពាហុកំ នទឹ សិនាយិតុន្តិ ។ កឹ ព្រាហ្មណ ពាហុកាយ នទិយា កឹ ពាហុកា នទី ករិស្សតីតិ ។ លោកសម្មតា[១] ហិ ភោ គោតម ពាហុកា នទី ពហុជនស្ស បុញ្ញសម្មតា ហិ ភោ គោតម ពាហុកា នទី ពហុជនស្ស ពាហុកាយ ច[២] បន នទិយា ពហុជនោ

១ ឱ. មោក្ខសម្មតា ។ ២ ម. ចការោ ន ទិស្សតិ ។



កាលបើចិត្តរួចស្រឡះហើយ ប្រាជ្ញាក៏កើតឡើងថា ចិត្តរួចស្រឡះហើយ ដូច្នេះ ភិក្ខុនោះក៏ដឹងច្បាស់ថា ជាតិ (របស់អាត្មាអញ) អស់ហើយ មគ្គព្រហ្មចារ្យ (របស់អាត្មាអញ) បាននៅរួចហើយ សោឡសកិច្ចដែលអាត្មាអញត្រូវធ្វើ ក៏បានធ្វើហើយ មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះតថាគតហៅថាជាអ្នកលាងដំរះដោយគ្រឿងសម្រាប់លាងដំរះ (នូវកិលេស) ខាងក្នុង ។

[៤៨] សម័យនោះឯង មានព្រាហ្មណ៍ម្នាក់ឈ្មោះសុន្ទរិកភារទ្វាជៈ អង្គុយនៅជិតព្រះមានព្រះភាគ ។ លំដាប់នោះឯង សុន្ទរិកភារទ្វាជព្រាហ្មណ៍ក្រាបបង្គំទូលសួរព្រះមានព្រះភាគដូច្នេះថា ព្រះគោតមដ៏ចំរើន ធ្លាប់ស្ដេចទៅកាន់ស្ទឹងពាហុកា ដើម្បីលាងដំរៅដែរឬ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលព្រាហ្មណ៍ ប្រយោជន៍អ្វីដោយស្ទឹងពាហុកា ស្ទឹងពាហុកានោះនឹងធ្វើអ្វីបាន ។ ព្រាហ្មណ៍ក្រាបបង្គំទូលថា បពិត្រព្រះគោតមដ៏ចំរើន ព្រោះថាស្ទឹងពាហុកា មានជនច្រើនគ្នាសន្មតហើយថាជាស្ទឹងបរិសុទ្ធ បពិត្រព្រះគោតមដ៏ចំរើន ព្រោះថាស្ទឹងពាហុកា មានជនច្រើនគ្នាសន្មតហើយថាជាបុណ្យ ម្យ៉ាងទៀត ជនច្រើនគ្នាតែង

ពាបកម្មំ កតំ(១) បវាហេតីតិ ។ អថខោ ភគវា សុន្ទរិកំ ភារទ្វាជំ ព្រាហ្មណំ គាថាហិ អជ្ឈភាសិ

ពាហុកំ អធិកក្កញ្ច
គយំ សុន្ទរិកាមបិ(២)
សរស្សតឹ បយាគញ្ច
អថោ ពាហុមតឹ នទឹ
និច្ចម្បិ ពាលោ បក្ខន្ទោ(៣)
កណ្ហកម្មោ ន សុជ្ឈតិ
កឹ សុន្ទរិកា ករិស្សតិ
កឹ បយាគោ កឹ ពាហុកា នទី ។
វេរឹ កតកិព្ពិសំ នរំ
ន ហិ នំ សោធយេ បាបកម្មិនំ
សុទ្ធស្ស វេ សទា ផគ្គុ
សុទ្ធស្សុបោសថោ សទា
សុទ្ធស្ស សុចិកម្មស្ស
សទា សម្បជ្ជតេ វតំ ។

១ ម. បាបំ កតំ កម្មំ ។ ២ ម. សុន្ទរិកំ មហឹ ។ ៣ ម. បក្ខន្តោ ។





បណ្តាលបាបកម្ម ដែលគេធ្វើហើយ ទៅលាងក្នុងស្ទឹងពាហុកា (នេះ ដែរ) ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់សំដែងដោយបទគាថា ទាំងឡាយ ចំពោះសុន្ទរិកភារទ្វាជព្រាហ្មណ៍ថា

ជនពាលមានកម្មអាក្រក់ (ក្នុងសន្តាន) បើចុះងូតជាចូលទៅ កាន់ស្ទឹងពាហុកាក្តី កាន់កំពង់ឈ្មោះអធិកក្កៈក្តី កាន់កំពង់ ឈ្មោះគយាក្តី(១) កាន់ស្ទឹងឈ្មោះសុន្ទរិកាក្តី កាន់ស្ទឹងឈ្មោះ សរស្សតីក្តី កាន់កំពង់ឈ្មោះបយាគៈក្តី ឬកាន់ស្ទឹងឈ្មោះ ពាហុមតីក្តី អស់កាលជានិច្ច ក៏នៅតែមិនស្អាតឡើយ ព្រោះ ថាស្ទឹងឈ្មោះសុន្ទរិកានឹងធ្វើអ្វីឲ្យ កំពង់ឈ្មោះបយាគៈនឹងធ្វើ អ្វីឲ្យ ស្ទឹងឈ្មោះពាហុកានឹងធ្វើអ្វីឲ្យ ។ ព្រោះថាស្ទឹងឈ្មោះ សុន្ទរិកាជាដើម មិនដែលលាងជនពាលមានពៀរ មានបាប កម្មដ៏ក្រៀវក្រា ដែលខ្លួនធ្វើហើយ មានកម្មដ៏លាមកនោះ ឲ្យ ស្អាតបានឡើយ ផគ្គុណឫក្ស តែងមានសព្វៗ កាល ដល់ បុគ្គលដែលបរិសុទ្ធ ឧបោសថ តែងមានសព្វៗ កាល ដល់ បុគ្គលដែលបរិសុទ្ធ ការកាន់យកវត្ត តែងសម្រេចសព្វៗ កាល ដល់បុគ្គលដែលបរិសុទ្ធ មានកម្មដ៏ស្អាត ។

១ កំពង់មានសណ្ឋានដូចចិនមូល ។

ឥធេវ សិនាហិ ព្រាហ្មណ
សព្វភូតេសុ ករោហិ ខេមតំ
សចេ មុសា ន ភណសិ
សចេ បាណំ ន ហឹសសិ
សចេ អទិន្នំ នាទិយសិ
សទ្ទហានោ អមច្ឆរី
កឹ កាហសិ គយំ គន្ត្វា
ឧទបានោបិ តេ គយា ។

(៤៩) ឯវំ វុត្តេ សុន្ទរិកភារទ្វាជោ ព្រាហ្មណោ ភគវន្តំ ឯតទវោច អភិក្កន្តំ ភោ គោតម អភិក្កន្តំ ភោ គោតម សេយ្យថាបិ ភោ គោតម និក្កុជ្ជិតំ វា ឧក្កុជ្ជេយ្យ បដិច្ឆន្នំ វា វិវរេយ្យ មូឡ្ហស្ស វា មគ្គំ អាចិក្ខេយ្យ អន្ធការេ វា តេលបជ្ជោតំ ធារេយ្យ ចក្ខុមន្តោ រូបានិ ទក្ខន្តីតិ ឯវមេវំ ភោតា គោតមេន អនេកបរិយាយេន ធម្មោ បកាសិតោ



ម្នាលព្រាហ្មណ៍ អ្នកចូរលាងជំរះខ្លួនក្នុងសាសនាតថាគតនេះវិញ អ្នកចូរធ្វើសេចក្ដីក្សេមក្សាន្តចំពោះពួកសត្វទាំងពួងចុះ បើអ្នកមិននិយាយកុហក បើអ្នកមិនបៀតបៀនសត្វ បើអ្នកមិនកាន់យកនូវទ្រព្យ ដែលគេមិនបានឲ្យ មានចិត្តជឿហើយ មិនមានសេចក្ដីកំណាញ់ អ្នកចាំបាច់ទៅកាន់កំពង់ទឹកធ្វើអ្វីទៀត អ្នកផឹកទឹក ( ឬងូត ) ក្នុងកំពង់ទឹក របស់អ្នកឯង (បានហើយ) ។

(៤៩) កាលបើព្រះមានព្រះភាគ មានព្រះពុទ្ធដីកា យ៉ាងនេះហើយ ទើបសុន្ទរិកភារទ្វាជព្រាហ្មណ៍ ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះគោតមដ៏ចំរើន ពីរោះណាស់ បពិត្រព្រះគោតមដ៏ចំរើន ពីរោះណាស់ បពិត្រព្រះគោតមដ៏ចំរើន ធម៌ដែលព្រះអង្គសំដែងហើយ ដោយអនេកបរិយាយយ៉ាងនេះ ហាក់ដូចជាគេផ្ងាររបស់ដែលផ្កាប់ ឬក៏ដូចជាគេបើកបង្ហាញរបស់ដែលកំបាំង ពុំនោះសោត ដូចជាគេប្រាប់ផ្លូវដល់អ្នកវង្វេងទិស ពុំនោះសោត ដូចជាគេកាន់ប្រទីបទ្រោលបំភ្លឺក្នុងទីងងឹតដោយគិតថា មនុស្សមានភ្នែកនឹងមើលឃើញរូបទាំងឡាយបាន

ឯសាហំ ភវន្តំ គោតមំ សរណំ គច្ឆាមិ ធម្មញ្ច ភិក្ខុសង្ឃញ្ច លភេយ្យាហំ ភោតោ គោតមស្ស សន្តិកេ បព្វជ្ជំ លភេយ្យំ ឧបសម្បទន្តិ ។ អលត្ថ ខោ សុន្ទរិកភារទ្វាជោ ព្រាហ្មណោ ភគវតោ សន្តិកេ បព្វជ្ជំ អលត្ថ ឧបសម្បទំ ។ អចិរូបសម្បន្នោ ខោ បនាយស្មា ភារទ្វាជោ ឯកោ វូបកដ្ឋោ អប្បមត្តោ អាតាបី បហិតត្តោ វិហរន្តោ នចិរស្សេវ យស្សត្ថាយ កុលបុត្តា សម្មទេវ អគារស្មា អនគារិយំ បព្វជន្តិ តទនុត្តរំ ព្រហ្មចរិយបរិយោសានំ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញាយ សច្ឆិកត្វា ឧបសម្បជ្ជ វិហាសិ[១] ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ អព្ភញ្ញាសិ ។ អញ្ញតរោ ខោ បនាយស្មា ភារទ្វាជោ អរហតំ អហោសីតិ ។

វត្ថូបមសុត្តំ សត្តមំ និដ្ឋិតំ (២) ។

---

១ ឱ. វិហរតិ ។ ២ ឱ. វត្ថូបមសុត្តំ សត្តមំ ។ ម. វត្ថសុត្តំ សត្តមំ ។



ខ្ញុំព្រះអង្គសូមដល់នូវព្រះគោតមដ៏ចំរើនផង ព្រះធម៌ផង ព្រះសង្ឃផង ជាទីពឹង ទីរលឹក ខ្ញុំព្រះអង្គសូមបាននូវបព្វជ្ជា សូមបាននូវឧបសម្បទា ក្នុងសំណាក់នៃព្រះគោតមដ៏ចំរើន ។ សុន្ទរិកភារទ្វាជព្រាហ្មណ៍ក៏បាន បព្វជ្ជា បានឧបសម្បទា ក្នុងសំណាក់ នៃព្រះមានព្រះភាគ ។ ភារទ្វាជភិក្ខុដ៏មានអាយុ ដែលបានឧបសម្បទា មិនទាន់អស់កាលយូរ ប៉ុន្មាន ជាភិក្ខុម្នាក់ឯង ចៀសចេញ (ចាកពួក) ជាអ្នកមិនប្រមាទ មាន ព្យាយាមដុតបំផ្លាញកិលេស មានចិត្តសុនទៅកាន់ (ព្រះនិព្វាន) ពួកកុលបុត្រដែលចេញចាកផ្ទះ ហើយចូលទៅកាន់ផ្នួស ដោយប្រពៃ ដើម្បីប្រយោជន៍ ដល់អនុត្តរធម៌ណា (ភារទ្វាជភិក្ខុ) ក៏បានធ្វើឲ្យជាក់ច្បាស់នូវអនុត្តរធម៌នោះ ជាទីបំផុតនៃមគ្គព្រហ្មចារ្យ ដោយប្រាជ្ញារបស់ខ្លួនដោយខ្លួនឯងក្នុងបច្ចុប្បន្ននេះ បានសម្រេចសម្រាន្តនៅដោយឥរិយា-បថទាំង ៤ មិនយូរប៉ុន្មានក៏បានដឹងច្បាស់ថា ជាតិកំណើតរបស់អាត្មាអញ អស់ហើយ ព្រហ្មចរិយធម៌អញក៏បាននៅរួចហើយ កិច្ចដែលត្រូវធ្វើអញ ក៏បានធ្វើហើយ មគ្គភាវនាកិច្ចដទៃ ប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះ ទៀតមិនមានឡើយ ។ បណ្តាព្រះអរហន្តទាំងឡាយ ភារទ្វាជភិក្ខុដ៏ មានអាយុ ក៏ជាព្រះអរហន្តមួយអង្គដែរ ។

ចប់ វត្ថូបមសូត្រ ជាគំរប់ ៧ ។

## អដ្ឋមំ សល្លេខសុត្តំ

(១០០) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ អថខោ អាយស្មា មហាចុន្ទោ សាយណ្ហសមយំ បដិសល្លានា វុដ្ឋិតោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា មហាចុន្ទោ ភគវន្តំ ឯតទវោច យា ឥមា ភន្តេ អនេកវិហិតា ទិដ្ឋិយោ លោកេ ឧប្បជ្ជន្តិ អត្តវាទប្បដិសំយុត្តា វា លោកវាទប្បដិសំយុត្តា វា អាទិមេវ នុ ខោ ភន្តេ ភិក្ខុនោ មនសិករោតោ ឯវមេតាសំ ទិដ្ឋីនំ បហានំ ហោតិ ឯវមេតាសំ ទិដ្ឋីនំ បដិនិស្សគ្គោ ហោតីតិ ។

## សល្លេខសូត្រ ទី ៨

(១០០) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគគង់ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះឯង ព្រះមហាចុន្ទមានអាយុ ចេញអំពីទីសម្ងំ ក្នុងសាយណ្ហសម័យ ហើយចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយ ក្នុងទីដ៏សមគួរ ។ លុះព្រះមហាចុន្ទមានអាយុ អង្គុយក្នុងទីដ៏សមគួរហើយ ទើបក្រាបទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន ទិដ្ឋិ[១] ទាំងឡាយច្រើនប្រការណា ដែលជាទិដ្ឋិប្រកបដោយអត្តវាទះ[២] ប្រកបដោយលោកវាទះ[៣] កើតឡើងក្នុងលោក បពិត្រព្រះអង្គដ៏ចំរើន កាលបើភិក្ខុធ្វើទុកក្នុងចិត្តជាដំបូង តើលះទិដ្ឋិទាំងនុ៎ះ ដោយងាយយ៉ាងនេះ ពោលទិដ្ឋិទាំងនុ៎ះ ដោយងាយយ៉ាងនេះបានឬទេ ។

---

១ បានដល់មិច្ឆាទិដ្ឋិ ។ ២ ប្រកបដោយសក្កាយទិដ្ឋិ ២០ មានឃើញរូបជារបស់ខ្លួនជាដើម ។ ៣ ប្រកបដោយមិច្ឆាទិដ្ឋិ ៨ មានឃើញថា ខ្លួនក្តី លោកក្តី ជារបស់ទៀងជាដើម អដ្ឋកថា ។

(១០១) យា ឥមា ចុន្ទ អនេកវិហិតា ទិដ្ឋិយោ លោកេ ឧប្បជ្ជន្តិ អត្តវាទបដិសំយុត្តា វា លោកវាទបដិសំយុត្តា វា យត្ថ ចេតា ទិដ្ឋិយោ ឧប្បជ្ជន្តិ យត្ថ ច អនុសេន្តិ យត្ថ ច សមុទាចរន្តិ(១) នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ បស្សតោ ឯវមេតាសំ ទិដ្ឋីនំ បហានំ ហោតិ ឯវមេតាសំ ទិដ្ឋីនំ បដិនិស្សគ្គោ ហោតិ ។

(១០២) ឋានំ ខោ បនេតំ ចុន្ទ វិជ្ជតិ យំ ឥធេកច្ចោ ភិក្ខុ វិវិច្ចេវ កាមេហិ វិវិច្ច អកុសលេហិ ធម្មេហិ សវិតក្កំ សវិចារំ វិវេកជំ បីតិសុខំ បឋមំ ឈានំ ឧបសម្បជ្ជ វិហរេយ្យ តស្ស ឯវមស្ស សល្លេខេន វិហរាមីតិ ន ខោ បនេតេ ចុន្ទ អរិយស្ស វិនយេ សល្លេខា វុច្ចន្តិ ទិដ្ឋធម្មសុខវិហារា ឯតេ អរិយស្ស វិនយេ វុច្ចន្តិ ។ ឋានំ ខោ បនេតំ

១ ម.ម. គន្ថ ឃាហេ ទិស្សតិ ។



(១០១) ព្រះអង្គត្រាស់ថា ម្នាលចុន្ទ ទិដ្ឋិទាំងឡាយមានច្រើនប្រការណា ដែលជាទិដ្ឋិប្រកបដោយអត្តវាទខ្លះ ប្រកបដោយលោកវាទខ្លះ កើតឡើងក្នុងលោក ក៏ទិដ្ឋិទាំងឡាយនោះ កើតក្នុងបញ្ចក្ខន្ធណា ដេកសម្ងំនៅក្នុងបញ្ចក្ខន្ធណា ផុសផុលឡើងក្នុងបញ្ចក្ខន្ធណា កាលបើភិក្ខុឃើញច្បាស់នូវបញ្ចក្ខន្ធនុ៎ះ តាមសេចក្តីពិត ដោយប្រាជ្ញាដ៏ប្រពៃយ៉ាងនេះថា នេះមិនមែនរបស់អញ នេះមិនមែនអញ នេះមិនមែនខ្លួនរបស់អញដូច្នេះ ការលះបង់នូវទិដ្ឋិទាំងឡាយនេះ គង់មានដោយឧបាយយ៉ាងនេះបាន ការរលាស់ចោលនូវទិដ្ឋិទាំងឡាយនោះ គង់មានដោយឧបាយយ៉ាងនេះបាន ។

(១០២) ម្នាលចុន្ទ ហេតុនេះ តែងមានជាប្រាកដ គឺភិក្ខុពួកខ្លះក្នុងសាសនានេះ ស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយហើយ ចូលបឋមជ្ឈាន ប្រកបដោយវិតក្កៈវិចារៈ មានបីតិនិងសុខៈដែលកើតអំពីវិវេក ភិក្ខុនោះជាប់សេចក្តីត្រិះរិះ យ៉ាងនេះថា អាត្មាអញនៅដោយសេចក្តីផូរផង់ដូច្នេះ ម្នាលចុន្ទ តែថាគត មិនដាក់ឲ្យឈ្មោះធម៌ទាំងនុ៎ះ ថាជាសេចក្តីផូរផង់ ក្នុងវិន័យរបស់ព្រះអរិយៈទេ គ្រាន់តែឲ្យឈ្មោះធម៌ទាំងនុ៎ះថាជាការនៅសប្បាយក្នុងបច្ចុប្បន្ន ក្នុងវិន័យរបស់ព្រះអរិយៈ ( ប៉ុណ្ណោះ ) ។ ម្នាលចុន្ទ ហេតុនេះ តែងមានជា

ចុន្ទ វិជ្ជតិ យំ ឥធេកច្ចោ ភិក្ខុ វិតក្កវិចារានំ វូបសមា អជ្ឈត្តំ សម្បសាទនំ ចេតសោ ឯកោទិភាវំ អវិតក្កំ អវិចារំ សមាធិជំ បីតិសុខំ ទុតិយំ ឈានំ ឧបសម្បជ្ជ វិហរេយ្យ តស្ស ឯវមស្ស សល្លេខេន វិហរាមីតិ ន ខោ បនេតេ ចុន្ទ អរិយស្ស វិនយេ សល្លេខា វុច្ចន្តិ ទិដ្ឋធម្មសុខវិហារា ឯតេ អរិយស្ស វិនយេ វុច្ចន្តិ ។ ឋានំ ខោ បនេតំ ចុន្ទ វិជ្ជតិ យំ ឥធេកច្ចោ ភិក្ខុ បីតិយា ច វិរាគា ឧបេក្ខកោ ច វិហរេយ្យ សតោ ច សម្បជានោ សុខញ្ច កាយេន បដិសំវេទេយ្យ យន្តំ អរិយា អាចិក្ខន្តិ ឧបេក្ខកោ សតិមា សុខវិហារីតិ តតិយំ ឈានំ ឧបសម្បជ្ជ វិហរេយ្យ តស្ស ឯវមស្ស សល្លេខេន វិហរាមីតិ ន ខោ បនេតេ ចុន្ទ អរិយស្ស វិនយេ សល្លេខា វុច្ចន្តិ ទិដ្ឋធម្មសុខវិហារា ឯតេ អរិយស្ស វិនយេ វុច្ចន្តិ ។ ឋានំ ខោ បនេតំ ចុន្ទ វិជ្ជតិ យំ





ប្រាកដ ថាភិក្ខុពួកខ្លះក្នុងសាសនានេះ ចូលទុតិយជ្ឈាន ដែលកើតក្នុងសន្តាននៃខ្លួន ប្រកបដោយសេចក្តីជ្រះថ្លាតិសព្វ មានសភាពជាចិត្តខ្ពស់ឯក មិនមានវិតក្កៈ មិនមានវិចារៈ មានតែបីតិនិងសុខ កើតអំពីសមាធិ ព្រោះស្ងប់ម្ងាប់វិតក្កៈនិងវិចារៈ ភិក្ខុនោះមានសេចក្តីសំគាល់ថា អាត្មាអញនៅដោយសេចក្តីផូរផង់ផូរច្លុះ ម្នាលចុន្ទ តែថាតថាគត មិនទាន់ឲ្យឈ្មោះធម៌ទាំងនុ៎ះថាជាសេចក្តីផូរផង់ ក្នុងអរិយវិន័យទេ គ្រាន់តែឲ្យឈ្មោះធម៌ទាំងនុ៎ះថាជាការនៅសប្បាយក្នុងបច្ចុប្បន្ន ក្នុងអរិយវិន័យប៉ុណ្ណោះ ។ ម្នាលចុន្ទ ហេតុនេះ តែងមានជាប្រាកដ ថាភិក្ខុពួកខ្លះក្នុងសាសនានេះ មានចិត្តព្រងើយកន្តើយ ព្រោះនឿយណាយចាកបីតិ តែមានស្មារតីនិងដឹងខ្លួន ទទួលសេចក្តីសុខដោយនាមកាយ ព្រះអរិយៈទាំងឡាយ តែងសរសើរបុគ្គលប្រកបដោយតតិយជ្ឈាននោះថា បុគ្គលប្រកបដោយតតិយជ្ឈានមានចិត្តព្រងើយកន្តើយ មានស្មារតីនៅជាសុខដូច្នេះដោយតតិយជ្ឈានណា (ភិក្ខុនោះ) ក៏បានចូលតតិយជ្ឈាននោះ ភិក្ខុនោះមានសេចក្តីសំគាល់ថា អាត្មាអញនៅដោយសេចក្តីផូរផង់ផូរច្លុះ ម្នាលចុន្ទ តែថាតថាគត មិនទាន់ឲ្យឈ្មោះធម៌ទាំងនុ៎ះថាជាសេចក្តីផូរផង់ ក្នុងអរិយវិន័យទេ គ្រាន់តែឲ្យឈ្មោះធម៌ទាំងនុ៎ះថាជាការនៅសប្បាយក្នុងបច្ចុប្បន្ន ក្នុងអរិយវិន័យប៉ុណ្ណោះ ។ ម្នាលចុន្ទ ហេតុនេះ តែងមានជា

ឥធេកច្ចោ ភិក្ខុ សុខស្ស ច បហានា ទុក្ខស្ស ច បហានា បុព្វេវ សោមនស្សទោមនស្សានំ អត្ថង្គមា អទុក្ខមសុខំ[១] ឧបេក្ខាសតិបារិសុទ្ធិំ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរេយ្យ តស្ស ឯវមស្ស សល្លេខេន វិហរាមីតិ ន ខោ បនេតេ ចុន្ទ អរិយស្ស វិនយេ សល្លេខា វុច្ចន្តិ ទិដ្ឋធម្មសុខវិហារា ឯតេ អរិយស្ស វិនយេ វុច្ចន្តិ ។

(១០៣) ឋានំ ខោ បនេតំ ចុន្ទ វិជ្ជតិ យំ ឥធេកច្ចោ ភិក្ខុ សព្វសោ រូបសញ្ញានំ សមតិក្កមា បដិឃសញ្ញានំ អត្ថង្គមា នានត្តសញ្ញានំ អមនសិការា អនន្តោ អាកាសោតិ អាកាសានញ្ចាយតនំ ឧបសម្បជ្ជ វិហរេយ្យ តស្ស ឯវមស្ស សល្លេខេន វិហរាមីតិ ន ខោ បនេតេ ចុន្ទ អរិយស្ស វិនយេ សល្លេខា វុច្ចន្តិ សន្តា ឯតេ វិហារា អរិយស្ស វិនយេ វុច្ចន្តិ ។ ឋានំ ខោ បនេតំ ចុន្ទ វិជ្ជតិ យំ ឥធេកច្ចោ ភិក្ខុ សព្វសោ អាកាសានញ្ចាយតនំ សមតិក្កម្ម អនន្តំ វិញ្ញាណន្តិ វិញ្ញាណញ្ចាយតនំ

១ ម. អទុក្ខំ អសុខំ ។





ប្រាកដ គឺភិក្ខុពួកខ្លះក្នុងសាសនានេះ ចូលចតុត្ថជ្ឈាន មានសតិដ៏បរិសុទ្ធ ដោយឧបេក្ខា មិនទុក្ខមិនសុខ ព្រោះលះបង់នូវសុខផង លះបង់នូវទុក្ខផង វិនាសទៅនៃសោមនស្សនិងទោមនស្សក្នុងកាលមុនផង ភិក្ខុនោះមានសេចក្តីសំគាល់យ៉ាងនេះថា អាត្មាអញនៅ ដោយសេចក្តីផូរផង់ដូច្នេះ ម្នាលចុន្ទ តែថាតថាគតមិនតាំងឲ្យឈ្មោះធម៌ទាំងនុ៎ះថាជាសេចក្តីផូរផង់ ក្នុងអរិយវិន័យទេ គ្រាន់តែឲ្យឈ្មោះធម៌ទាំងនុ៎ះថាជាការនៅសប្បាយក្នុងបច្ចុប្បន្ន ក្នុងអរិយវិន័យប៉ុណ្ណោះ ។

(១០៣) ម្នាលចុន្ទ ហេតុនេះ តែងមានជាប្រាកដ គឺភិក្ខុពួកខ្លះក្នុងសាសនានេះ ចូលអាកាសានញ្ចាយតនៈដោយគិតថា អាកាសមិនមានទីបំផុត ព្រោះកន្លងនូវពួករូបសញ្ញា វិនាសទៅនៃពួកបដិឃសញ្ញា មិនធ្វើទុកក្នុងចិត្តនូវពួកនានត្តសញ្ញា ដោយសព្វគ្រប់ ភិក្ខុនោះមានសេចក្តីសំគាល់យ៉ាងនេះថា អាត្មាអញនៅដោយសេចក្តីផូរផង់ដូច្នេះ ម្នាលចុន្ទ តែថាតថាគតមិនតាំងឲ្យឈ្មោះធម៌ទាំងនុ៎ះថាជាសេចក្តីផូរផង់ក្នុងអរិយវិន័យទេ គ្រាន់តែឲ្យឈ្មោះធម៌ទាំងនុ៎ះ ថាជាគ្រឿងនៅដ៏ស្ងប់ម្ងាប់ក្នុងបច្ចុប្បន្ន ក្នុងអរិយវិន័យប៉ុណ្ណោះ ។ ម្នាលចុន្ទ ហេតុនេះ តែងមានជាប្រាកដ គឺភិក្ខុពួកខ្លះក្នុងសាសនានេះ កន្លងផុតអាកាសានញ្ចាយតនៈដោយសព្វគ្រប់ ហើយចូលវិញ្ញាណញ្ចាយតនៈ ដោយគិតថា វិញ្ញាណមិនមានទីបំផុត

ឧបសម្បជ្ជ វិហរេយ្យ តស្ស ឯវមស្ស សល្លេខេន វិហរាមីតិ ន ខោ បនេតេ ចុន្ទ អរិយស្ស វិនយេ សល្លេខា វុច្ចន្តិ សន្តា ឯតេ វិហារា អរិយស្ស វិនយេ វុច្ចន្តិ ។ ឋានំ ខោ បនេតំ ចុន្ទ វិជ្ជតិ យំ ឥធេកច្ចោ ភិក្ខុ សព្វសោ វិញ្ញាណញ្ចាយតនំ សមតិក្កម្ម នត្ថិ កិញ្ចីតិ អាកិញ្ចញ្ញាយតនំ ឧបសម្បជ្ជ វិហរេយ្យ តស្ស ឯវមស្ស សល្លេខេន វិហរាមីតិ ន ខោ បនេតេ ចុន្ទ អរិយស្ស វិនយេ សល្លេខា វុច្ចន្តិ សន្តា ឯតេ វិហារា អរិយស្ស វិនយេ វុច្ចន្តិ ។ ឋានំ ខោ បនេតំ ចុន្ទ វិជ្ជតិ យំ ឥធេកច្ចោ ភិក្ខុ សព្វសោ អាកិញ្ចញ្ញាយតនំ សមតិក្កម្ម នេវសញ្ញានាសញ្ញាយតនំ ឧបសម្បជ្ជ វិហរេយ្យ តស្ស ឯវមស្ស សល្លេខេន វិហរាមីតិ ន ខោ បនេតេ ចុន្ទ អរិយស្ស វិនយេ សល្លេខា វុច្ចន្តិ សន្តា ឯតេ វិហារា អរិយស្ស វិនយេ វុច្ចន្តិ ។



ភិក្ខុនោះគឺមានសេចក្តីសំគាល់យ៉ាងនេះថា អាត្មាអញនៅ ដោយសេចក្តីផូរផង់ផូរខ្ទះ ម្នាលចុន្ទ តែតថាគតមិនទាន់ឲ្យឈ្មោះធម៌ទាំងនុ៎ះ ថាជាសេចក្តីផូរផង់ ក្នុងអរិយវិន័យទេ គ្រាន់តែឲ្យឈ្មោះធម៌ទាំងនុ៎ះ ថាជាគ្រឿងនៅ ដ៏ស្ងប់រម្ងាប់ ក្នុងអរិយវិន័យប៉ុណ្ណោះ ។ ម្នាលចុន្ទ ហេតុនេះ តែងមានជាប្រាកដ គឺភិក្ខុពួកខ្លះក្នុងសាសនានេះកន្លងហួសនូវវិញ្ញាណញ្ចាយតនៈដោយសព្វគ្រប់ ហើយចូលអាកិញ្ចញ្ញាយតនៈដោយគិតថា វត្ថុតិចតួចមិនមាន ភិក្ខុនោះគឺមានសេចក្តីសំគាល់យ៉ាងនេះថា អាត្មាអញនៅដោយសេចក្តីផូរផង់ផូរខ្ទះ ម្នាលចុន្ទ តែតថាគតមិនទាន់ឲ្យឈ្មោះធម៌ទាំងនុ៎ះ ថាជាសេចក្តីផូរផង់ ក្នុងអរិយវិន័យទេ គ្រាន់តែឲ្យឈ្មោះធម៌ទាំងនុ៎ះ ថាជាគ្រឿងនៅដ៏ស្ងប់រម្ងាប់ ក្នុងអរិយវិន័យប៉ុណ្ណោះ ។ ម្នាលចុន្ទ ហេតុនេះ តែងមានជាប្រាកដ គឺភិក្ខុពួកខ្លះក្នុងសាសនានេះ កន្លងហួសនូវអាកិញ្ចញ្ញាយតនៈដោយសព្វគ្រប់ ហើយចូលនេវសញ្ញានាសញ្ញាយតនៈ ភិក្ខុនោះគឺមានសេចក្តីសំគាល់យ៉ាងនេះថា អាត្មាអញនៅដោយសេចក្តីផូរផង់ផូរខ្ទះ ម្នាលចុន្ទ តែតថាគតមិនទាន់ឲ្យឈ្មោះធម៌ទាំងនុ៎ះ ថាជាសេចក្តីផូរផង់ ក្នុងអរិយវិន័យទេ គ្រាន់តែឲ្យឈ្មោះធម៌ទាំងនុ៎ះថាជាគ្រឿងនៅដ៏ស្ងប់រម្ងាប់ ក្នុងអរិយវិន័យប៉ុណ្ណោះ ។

(១០៤) ឥធ ខោ បន វោ ចុន្ទ សល្លេខោ ករណីយោ ។ បរេ វិហឹសកា ភវិស្សន្តិ មយមេត្ថ អវិហឹសកា ភវិស្សាមាតិ សល្លេខោ ករណីយោ ។ បរេ បាណាតិបាតី ភវិស្សន្តិ មយមេត្ថ បាណាតិបាតា បដិវិរតា ភវិស្សាមាតិ សល្លេខោ ករណីយោ ។ បរេ អទិន្នាទាយី ភវិស្សន្តិ មយមេត្ថ អទិន្នាទានា បដិវិរតា ភវិស្សាមាតិ សល្លេខោ ករណីយោ ។ បរេ អព្រហ្មចារី ភវិស្សន្តិ មយមេត្ថ ព្រហ្មចារី ភវិស្សាមាតិ សល្លេខោ ករណីយោ ។ បរេ មុសាវាទី ភវិស្សន្តិ មយមេត្ថ មុសាវាទា បដិវិរតា ភវិស្សាមាតិ សល្លេខោ ករណីយោ ។ បរេ បិសុណាវាចា[១] ភវិស្សន្តិ មយមេត្ថ បិសុណាយ វាចាយ បដិវិរតា ភវិស្សាមាតិ សល្លេខោ ករណីយោ ។ បរេ ផរុសាវាចា[២] ភវិស្សន្តិ មយមេត្ថ ផរុសាយ វាចាយ បដិវិរតា ភវិស្សាមាតិ សល្លេខោ ករណីយោ ។

១ ម. បិសុណា វាចា ។ ២ ផរុសា វាចា ។



(១០៤) ម្នាលចុន្ទ អ្នកត្រូវធ្វើសេចក្តីផូរផង់ ក្នុងវត្ថុមានការមិនបៀតបៀនជាដើមនេះ ។ ពួកអ្នកត្រូវធ្វើនូវសេចក្តីផូរផង់យ៉ាងនេះថា ជនទាំងឡាយដទៃនឹងជាអ្នកបៀតបៀនក្នុងវត្ថុណា ពួកយើងនឹងជាអ្នកមិនបៀតបៀនក្នុងវត្ថុនុះ ។ ពួកអ្នកត្រូវធ្វើនូវសេចក្តីផូរផង់យ៉ាងនេះថា ជនទាំងឡាយដទៃនឹងជាអ្នកបំបាត់ជីវិតសត្វ ក្នុងវត្ថុណា ពួកយើងនឹងជាអ្នកវៀរចាកកិរិយាបំបាត់ជីវិតក្នុងវត្ថុនុះ ។ ពួកអ្នកត្រូវធ្វើសេចក្តីផូរផង់យ៉ាងនេះថា ជនទាំងឡាយដទៃនឹងកាន់យកនូវរបស់ដែលគេមិនបានឲ្យក្នុងវត្ថុណា ពួកយើងនឹងវៀរចាកការកាន់យកនូវរបស់ ដែលគេមិនបានឲ្យក្នុងវត្ថុនោះ ។ ពួកអ្នកត្រូវធ្វើនូវសេចក្តីផូរផង់ យ៉ាងនេះថា ជនទាំងឡាយដទៃនឹងប្រព្រឹត្តនូវធម៌មិនប្រសើរ ក្នុងវត្ថុណា ពួកយើងនឹងប្រព្រឹត្តនូវធម៌ដ៏ប្រសើរក្នុងវត្ថុនុះ ។ ពួកអ្នកត្រូវធ្វើនូវសេចក្តីផូរផង់យ៉ាងនេះថា ជនទាំងឡាយដទៃ នឹងនិយាយពាក្យកុហកក្នុងវត្ថុណា ពួកយើងនឹងវៀរចាកការនិយាយពាក្យកុហក ក្នុងវត្ថុនុះ ។ ពួកអ្នកត្រូវធ្វើនូវសេចក្តីផូរផង់យ៉ាងនេះថា ជនទាំងឡាយដទៃ នឹងមានសំដីញុះញង់ក្នុងវត្ថុណា ពួកយើងនឹងវៀរចាកសំដីញុះញង់ ក្នុងវត្ថុនោះ ។ ពួកអ្នកត្រូវធ្វើនូវសេចក្តីផូរផង់យ៉ាងនេះថា ជនទាំងឡាយដទៃ នឹងមានសំដីទ្រគោះក្នុងវត្ថុណា ពួកយើងនឹងវៀរចាកសំដីទ្រគោះក្នុងវត្ថុនោះ ។

បរេ សម្ផប្បលាបី ភវិស្សន្តិ មយមេត្ថ សម្ផប្បលាបា បដិវិរតា ភវិស្សាមាតិ សល្លេខោ ករណីយោ ។ បរេ អភិជ្ឈាលូ ភវិស្សន្តិ មយមេត្ថ អនភិជ្ឈាលូ ភវិស្សាមាតិ សល្លេខោ ករណីយោ ។ បរេ ព្យាបន្នចិត្តា ភវិស្សន្តិ មយមេត្ថ អព្យាបន្នចិត្តា ភវិស្សាមាតិ សល្លេខោ ករណីយោ ។ បរេ មិច្ឆាទិដ្ឋិកា(១) ភវិស្សន្តិ មយមេត្ថ សម្មាទិដ្ឋិកា(២) ភវិស្សាមាតិ សល្លេខោ ករណីយោ ។ បរេ មិច្ឆាសង្កប្បា ភវិស្សន្តិ មយមេត្ថ សម្មាសង្កប្បា ភវិស្សាមាតិ សល្លេខោ ករណីយោ ។ បរេ មិច្ឆាវាចា ភវិស្សន្តិ មយមេត្ថ សម្មាវាចា ភវិស្សាមាតិ សល្លេខោ ករណីយោ ។ បរេ មិច្ឆាកម្មន្តា ភវិស្សន្តិ មយមេត្ថ សម្មាកម្មន្តា ភវិស្សាមាតិ សល្លេខោ ករណីយោ ។ បរេ មិច្ឆាអាជីវា ភវិស្សន្តិ មយមេត្ថ សម្មាអាជីវា ភវិស្សាមាតិ សល្លេខោ ករណីយោ ។

១ ឱ.ម. មិច្ឆាទិដ្ឋី ។ ២ ឱ.ម. សម្មាទិដ្ឋី ។



ពួកអ្នកត្រូវធ្វើនូវសេចក្ដីផូរផង់យ៉ាងនេះថា ជនទាំងឡាយដទៃនឹងពោលពាក្យឥតប្រយោជន៍ក្នុងវត្ថុណា ពួកយើង នឹងវៀរចាកការពោលពាក្យឥតប្រយោជន៍ក្នុងវត្ថុនុ៎ះ ។ ពួកអ្នកត្រូវធ្វើនូវសេចក្ដីផូរផង់យ៉ាងនេះថា ជនទាំងឡាយដទៃមានសេចក្ដីគយគន់ (ចង់បានទ្រព្យអ្នកដទៃ) ក្នុងវត្ថុណា ពួកយើងនឹងមិនមានសេចក្ដីគយគន់ក្នុងវត្ថុនុ៎ះ ។ ពួកអ្នកត្រូវធ្វើនូវសេចក្ដីផូរផង់យ៉ាងនេះថា ជនទាំងឡាយដទៃ នឹងមានចិត្តគំនុំក្នុងវត្ថុណា ពួកយើងនឹងមិនមានចិត្តគំនុំក្នុងវត្ថុនុ៎ះ ។ ពួកអ្នកត្រូវធ្វើនូវសេចក្ដីផូរផង់យ៉ាងនេះថា ជនទាំងឡាយដទៃនឹងជាមិច្ឆាទិដ្ឋិក្នុងវត្ថុណា ពួកយើងនឹងជាសម្មាទិដ្ឋិក្នុងវត្ថុនុ៎ះ ។ ពួកអ្នកត្រូវធ្វើនូវសេចក្ដីផូរផង់យ៉ាងនេះថា ជនទាំងឡាយដទៃនឹងមានតម្រិះខុសក្នុងវត្ថុណា ពួកយើងនឹងមានតម្រិះត្រូវក្នុងវត្ថុនុ៎ះ ។ ពួកអ្នកត្រូវធ្វើនូវសេចក្ដីផូរផង់យ៉ាងនេះថា ជនទាំងឡាយដទៃនឹងមានសំដីខុសក្នុងវត្ថុណា ពួកយើងនឹងមានសំដីត្រូវក្នុងវត្ថុនុ៎ះ ។ ពួកអ្នកត្រូវធ្វើនូវសេចក្ដីផូរផង់យ៉ាងនេះថា ជនទាំងឡាយដទៃ នឹងមានការងារខុសក្នុងវត្ថុណា ពួកយើងនឹងមានការងារត្រូវក្នុងវត្ថុនុ៎ះ ។ ពួកអ្នកត្រូវធ្វើនូវសេចក្ដីផូរផង់យ៉ាងនេះថា ជនទាំងឡាយដទៃនឹងចិញ្ចឹមជីវិតខុសក្នុងវត្ថុណា ពួកយើងនឹងចិញ្ចឹមជីវិតត្រូវក្នុងវត្ថុនុ៎ះ ។

បរេ មិច្ឆាវាយាមា ភវិស្សន្តិ មយមេត្ថ សម្មាវាយាមា ភវិស្សាមាតិ សល្លេខោ ករណីយោ ។ បរេ មិច្ឆាសតី ភវិស្សន្តិ មយមេត្ថ សម្មាសតី ភវិស្សាមាតិ សល្លេខោ ករណីយោ ។ បរេ មិច្ឆាសមាធី ភវិស្សន្តិ មយមេត្ថ សម្មាសមាធី ភវិស្សាមាតិ សល្លេខោ ករណីយោ ។ បរេ មិច្ឆាញាណី ភវិស្សន្តិ មយមេត្ថ សម្មាញាណី ភវិស្សាមាតិ សល្លេខោ ករណីយោ ។ បរេ មិច្ឆាវិមុត្តី ភវិស្សន្តិ មយមេត្ថ សម្មាវិមុត្តី ភវិស្សាមាតិ សល្លេខោ ករណីយោ ។ បរេ ថីនមិទ្ធបរិយុដ្ឋិតា ភវិស្សន្តិ មយមេត្ថ វិគតថីនមិទ្ធា[១] ភវិស្សាមាតិ សល្លេខោ ករណីយោ ។ បរេ ឧទ្ធតា ភវិស្សន្តិ មយមេត្ថ អនុទ្ធតា ភវិស្សាមាតិ សល្លេខោ ករណីយោ ។ បរេ វេចិកិច្ឆី ភវិស្សន្តិ

១ ម. វិគតថីនមិទ្ធា ។



ពួកអ្នកត្រូវធ្វើនូវសេចក្ដីផ្សះផង់យ៉ាងនេះថា ជនទាំងឡាយដទៃ នឹងមានព្យាយាមខុសក្នុងវត្តណា ពួកយើងនឹងមានព្យាយាមត្រូវ ក្នុងវត្តនុ៎ះ ។ ពួកអ្នកត្រូវធ្វើនូវសេចក្ដីផ្សះផង់យ៉ាងនេះថា ជនទាំងឡាយដទៃនឹងមានសេចក្ដីរលឹកខុសក្នុងវត្តណា ពួកយើងនឹងមានសេចក្ដីរលឹកត្រូវ ក្នុងវត្តនុ៎ះ ។ ពួកអ្នកត្រូវធ្វើនូវសេចក្ដីផ្សះផង់យ៉ាងនេះថា ជនទាំងឡាយដទៃនឹងមានសមាធិខុសក្នុងវត្តណា ពួកយើងនឹងមានសមាធិត្រូវ ក្នុងវត្តនុ៎ះ ។ ពួកអ្នកត្រូវធ្វើនូវសេចក្ដីផ្សះផង់យ៉ាងនេះថា ជនទាំងឡាយដទៃ នឹងមានញាណខុស ក្នុងវត្តណា ពួកយើងនឹងមានញាណត្រូវ ក្នុងវត្តនុ៎ះ ។ ពួកអ្នកត្រូវធ្វើនូវសេចក្ដីផ្សះផង់យ៉ាងនេះថា ជនទាំងឡាយដទៃនឹងមានវិមុត្តិខុសក្នុងវត្តណា ពួកយើងនឹងមានវិមុត្តិត្រូវ ក្នុងវត្តនុ៎ះ ។ ពួកអ្នកត្រូវធ្វើនូវសេចក្ដីផ្សះផង់យ៉ាងនេះថា ជនទាំងឡាយដទៃនឹងមានថីនមិទ្ធៈគ្របសង្កត់ ក្នុងវត្តណា ពួកយើងនឹងមានថីនមិទ្ធៈទៅប្រាសហើយក្នុងវត្តនុ៎ះ ។ ពួកអ្នកត្រូវធ្វើនូវសេចក្ដីផ្សះផង់ យ៉ាងនេះថា ជនទាំងឡាយដទៃ នឹងប្រកបដោយសេចក្ដីរាយមាយ ក្នុងវត្តណា ពួកយើងនឹងមិនមានសេចក្ដីរាយមាយ ក្នុងវត្តនុ៎ះ ។ ពួកអ្នកត្រូវធ្វើនូវសេចក្ដីផ្សះផង់យ៉ាងនេះថា ជនទាំងឡាយដទៃនឹងមានសេចក្ដីសង្ស័យ ក្នុងវត្តណា

មយមេត្ថ តិណ្ណវិចិកិច្ឆា ភវិស្សាមាតិ សល្លេខោ ករណីយោ ។ បរេ កោធនា ភវិស្សន្តិ មយមេត្ថ អក្កោធនា ភវិស្សាមាតិ សល្លេខោ ករណីយោ ។ បរេ ឧបនាហី ភវិស្សន្តិ មយមេត្ថ អនុបនាហី ភវិស្សាមាតិ សល្លេខោ ករណីយោ ។ បរេ មក្ខី ភវិស្សន្តិ មយមេត្ថ អមក្ខី ភវិស្សាមាតិ សល្លេខោ ករណីយោ ។ បរេ បឡាសី ភវិស្សន្តិ មយមេត្ថ អបឡាសី ភវិស្សាមាតិ សល្លេខោ ករណីយោ ។ បរេ ឥស្សុកី ភវិស្សន្តិ មយមេត្ថ អនិស្សុកី ភវិស្សាមាតិ សល្លេខោ ករណីយោ ។ បរេ មច្ឆរី ភវិស្សន្តិ មយមេត្ថ អមច្ឆរី ភវិស្សាមាតិ សល្លេខោ ករណីយោ ។ បរេ សឋា ភវិស្សន្តិ មយមេត្ថ អសឋា ភវិស្សាមាតិ សល្លេខោ ករណីយោ ។ បរេ មាយាវី ភវិស្សន្តិ មយមេត្ថ អមាយាវី ភវិស្សាមាតិ សល្លេខោ ករណីយោ ។



ពួកយើងនឹងមានសេចក្តីសង្ស័យកន្លងផុតហើយ ក្នុងវត្ថុនុ៎ះ ។ ពួកអ្នកត្រូវធ្វើនូវសេចក្តីផូរផង់យ៉ាងនេះថា ជនទាំងឡាយដទៃនឹងមានសេចក្តីក្រេវក្រោធ ក្នុងវត្ថុណា ពួកយើងនឹងមិនមានសេចក្តីក្រេវក្រោធ ក្នុងវត្ថុនុ៎ះ ។ ពួកអ្នកត្រូវធ្វើនូវសេចក្តីផូរផង់យ៉ាងនេះថា ជនទាំងឡាយដទៃនឹងចងសេចក្តីក្រេវក្រោធទុក ក្នុងវត្ថុណា ពួកយើងនឹងមិនចងសេចក្តីក្រេវក្រោធទុក ក្នុងវត្ថុនុ៎ះ ។ ពួកអ្នកត្រូវធ្វើនូវសេចក្តីផូរផង់ យ៉ាងនេះថា ជនទាំងឡាយដទៃនឹងលុបលាងគុណគេ ក្នុងវត្ថុណា ពួកយើងនឹងមិនលុបលាងគុណគេក្នុងវត្ថុនុ៎ះ ។ ពួកអ្នកត្រូវធ្វើនូវសេចក្តីផូរផង់យ៉ាងនេះថា ជនទាំងឡាយដទៃនឹងកប៉ួនបុគ្គលស្មើ ក្នុងវត្ថុណា ពួកយើងនឹងមិនកប៉ួនបុគ្គលស្មើ ក្នុងវត្ថុនុ៎ះ ។ ពួកអ្នកត្រូវធ្វើនូវសេចក្តីផូរផង់យ៉ាងនេះថា ជនទាំងឡាយដទៃ នឹងប្រច័ណ្ឌ ក្នុងវត្ថុណា ពួកយើងនឹងមិនប្រច័ណ្ឌ ក្នុងវត្ថុនុ៎ះ ។ ពួកអ្នកត្រូវធ្វើនូវសេចក្តីផូរផង់យ៉ាងនេះថា ជនទាំងឡាយដទៃនឹងមានសេចក្តីកំណាញ់ ក្នុងវត្ថុណា ពួកយើងនឹងមិនមានសេចក្តីកំណាញ់ ក្នុងវត្ថុនុ៎ះ ។ ពួកអ្នកត្រូវធ្វើនូវសេចក្តីផូរផង់យ៉ាងនេះថា ជនទាំងឡាយដទៃ នឹងអួតអាង ក្នុងវត្ថុណា ពួកយើងនឹងមិនអួតអាងក្នុងវត្ថុនុ៎ះ ។ ពួកអ្នកត្រូវធ្វើនូវសេចក្តីផូរផង់ យ៉ាងនេះថា ជនទាំងឡាយដទៃនឹងមានមាយា ក្នុងវត្ថុណា ពួកយើងនឹងមិនមានមាយា ក្នុងវត្ថុនុ៎ះ ។

បរេ ថទ្ធា ភវិស្សន្តិ មយមេត្ថ អថទ្ធា ភវិស្សាមាតិ សល្លេខោ ករណីយោ ។ បរេ អតិមានី ភវិស្សន្តិ មយមេត្ថ អនតិមានី ភវិស្សាមាតិ សល្លេខោ ករណីយោ ។ បរេ ទុព្វចា ភវិស្សន្តិ មយមេត្ថ សុវចា ភវិស្សាមាតិ សល្លេខោ ករណីយោ ។ បរេ បាបមិត្តា ភវិស្សន្តិ មយមេត្ថ កល្យាណមិត្តា ភវិស្សាមាតិ សល្លេខោ ករណីយោ ។ បរេ បមត្តា ភវិស្សន្តិ មយមេត្ថ អប្បមត្តា ភវិស្សាមាតិ សល្លេខោ ករណីយោ ។ បរេ អស្សទ្ធា ភវិស្សន្តិ មយមេត្ថ សទ្ធា ភវិស្សាមាតិ សល្លេខោ ករណីយោ ។ បរេ អហិរិកា ភវិស្សន្តិ មយមេត្ថ ហិរិមនា ភវិស្សាមាតិ សល្លេខោ ករណីយោ ។ បរេ អនោត្តប្បី(១) ភវិស្សន្តិ មយមេត្ថ ឱត្តប្បី ភវិស្សាមាតិ សល្លេខោ ករណីយោ ។

១ ម. អនោត្តាបី ។



ពួកអ្នកត្រូវធ្វើនូវសេចក្ដីផូរផង់យ៉ាងនេះថា ជនទាំងឡាយដទៃនឹងរឹងត្អឹង ក្នុងវត្ថុណា ពួកយើងនឹងមិនរឹងត្អឹង ក្នុងវត្ថុនុ៎ះ ។ ពួកអ្នកត្រូវធ្វើនូវសេចក្ដីផូរផង់យ៉ាងនេះថា ជនទាំងឡាយដទៃ នឹងមានសេចក្ដីមើលងាយគេ ក្នុងវត្ថុណា ពួកយើង នឹងមិនមានសេចក្ដីមើលងាយគេ ក្នុងវត្ថុនុ៎ះ ។ ពួកអ្នកត្រូវធ្វើនូវសេចក្ដីផូរផង់យ៉ាងនេះថា ជនទាំងឡាយដទៃ នឹងជាអ្នកដែលគេប្រដៅក្រ ក្នុងវត្ថុណា ពួកយើង នឹងជាអ្នកដែលគេប្រដៅងាយ ក្នុងវត្ថុនុ៎ះ ។ ពួកអ្នកត្រូវធ្វើនូវសេចក្ដីផូរផង់យ៉ាងនេះថា ជនទាំងឡាយដទៃ នឹងមានមិត្តអាក្រក់ ក្នុងវត្ថុណា ពួកយើងនឹងមានមិត្តល្អ ក្នុងវត្ថុនុ៎ះ ។ ពួកអ្នកត្រូវធ្វើនូវសេចក្ដីផូរផង់យ៉ាងនេះថា ជនទាំងឡាយដទៃនឹងប្រហែសធ្វេស ក្នុងវត្ថុណា ពួកយើងនឹងមិនប្រហែសធ្វេស ក្នុងវត្ថុនុ៎ះ ។ ពួកអ្នកត្រូវធ្វើនូវសេចក្ដីផូរផង់យ៉ាងនេះថា ជនទាំងឡាយដទៃនឹងមិនមានសទ្ធា ក្នុងវត្ថុណា ពួកយើងនឹងមានសទ្ធា ក្នុងវត្ថុនុ៎ះ ។ ពួកអ្នកត្រូវធ្វើនូវសេចក្ដីផូរផង់យ៉ាងនេះថា ជនទាំងឡាយដទៃនឹងមិនខ្មាសបាប ក្នុងវត្ថុណា ពួកយើងនឹងមានចិត្តខ្មាសបាប ក្នុងវត្ថុនុ៎ះ ។ ពួកអ្នកត្រូវធ្វើនូវសេចក្ដីផូរផង់យ៉ាងនេះថា ជនទាំងឡាយដទៃនឹងមិនខ្លាចបាប ក្នុងវត្ថុណា ពួកយើងនឹងខ្លាចបាប ក្នុងវត្ថុនោះ ។

បរេ អប្បស្សុតា ភវិស្សន្តិ មយមេត្ថ ពហុស្សុតា ភវិស្សាមាតិ សល្លេខោ ករណីយោ ។ បរេ កុសីតា ភវិស្សន្តិ មយមេត្ថ អារទ្ធវីរិយា ភវិស្សាមាតិ សល្លេខោ ករណីយោ ។ បរេ មុដ្ឋស្សតី ភវិស្សន្តិ មយមេត្ថ ឧបដ្ឋិតស្សតី ភវិស្សាមាតិ សល្លេខោ ករណីយោ ។ បរេ ទុប្បញ្ញា ភវិស្សន្តិ មយមេត្ថ បញ្ញាសម្បន្នា ភវិស្សាមាតិ សល្លេខោ ករណីយោ ។ បរេ សន្ទិដ្ឋិបរាមាសិ អាធានគ្គាហិ ទុប្បដិនិស្សគ្គី[១] ភវិស្សន្តិ មយមេត្ថ អសន្ទិដ្ឋិបរាមាសិ អនាធានគ្គាហិ សុប្បដិនិស្សគ្គី ភវិស្សាមាតិ សល្លេខោ ករណីយោ ។

(១០៨) ចិត្តុប្បាទម្បិ[២] ខោ អហំ ចុន្ទ កុសលេសុ ធម្មេសុ ពហុការំ វទាមិ កោ បន វាទោ កាយេន វាចាយ អនុវិធិយនាសុ[៣] ។ តស្មាតិហ ចុន្ទ បរេ

១ ម. សន្ទិដ្ឋិបរាមាសី អាធានគ្គាហី ។ ២ ម. ចិត្តុប្បាទំបិ ។ ៣ ឱ.ម. អនុវិធីយា។



ពួកអ្នកត្រូវធ្វើនូវសេចក្ដីផូរផង់យ៉ាងនេះថា ជនទាំងឡាយដទៃ នឹងមិនរៀនសូត្រ ក្នុងវត្ថុណា ពួកយើង នឹងរៀនសូត្រច្រើន ក្នុងវត្ថុនុ៎ះ ។ ពួកអ្នកត្រូវធ្វើនូវសេចក្ដីផូរផង់យ៉ាងនេះថា ជនទាំងឡាយដទៃនឹងខ្ជិលច្រអូស ក្នុងវត្ថុណា ពួកយើងនឹងមានព្យាយាមប្រឹងប្រែង ក្នុងវត្ថុនុ៎ះ ។ ពួកអ្នកត្រូវធ្វើនូវសេចក្ដីផូរផង់យ៉ាងនេះថា ជនទាំងឡាយដទៃ នឹងមានសេចក្ដីភ្លេចភ្លាំង ក្នុងវត្ថុណា ពួកយើងនឹងប្រុងស្មារតី ក្នុងវត្ថុនុ៎ះ ។ ពួកអ្នកត្រូវធ្វើនូវសេចក្ដីផូរផង់យ៉ាងនេះថា ជនទាំងឡាយដទៃ នឹងអាប់ឥតប្រាជ្ញា ក្នុងវត្ថុណា ពួកយើងនឹងមានប្រាជ្ញា ក្នុងវត្ថុនុ៎ះ ។ ពួកអ្នកត្រូវធ្វើនូវសេចក្ដីផូរផង់យ៉ាងនេះថា ជនទាំងឡាយដទៃ នឹងប្រកាន់តាមសេចក្ដីយល់ឃើញរបស់ខ្លួន ជាអ្នកប្រកាន់មាំ ជាអ្នកដែលគេឲ្យលះបង់ (លទ្ធិ) បានដោយក្រ ក្នុងវត្ថុណា ពួកយើងនឹងមិនប្រកាន់តាមសេចក្ដីយល់ឃើញរបស់ខ្លួន ជាអ្នកមិនប្រកាន់មាំ នឹងជាអ្នកដែលគេឲ្យលះបង់ (លទ្ធិ) បានដោយងាយ ។

(១០៨) ម្នាលចុន្ទ តថាគតពោលចំពោះការកើតឡើងនៃចិត្តក្នុងកុសលធម៌ទាំងឡាយថា មានឧបការៈច្រើន ចាំបាច់ពោលទៅថ្វីក្នុងការតាក់តែងដោយកាយ ឬដោយវាចា ។ ម្នាលចុន្ទ ព្រោះហេតុនោះអ្នកត្រូវ

វិហឹសកា ភវិស្សន្តិ មយមេត្ថ អវិហឹសកា ភវិស្សាមាតិ ចិត្តំ ឧប្បាទេតព្វំ ។ បរេ បាណាតិបាតី ភវិស្សន្តិ មយមេត្ថ បាណាតិបាតា បដិវិរតា ភវិស្សាមាតិ ចិត្តំ ឧប្បាទេតព្វំ ។ បេ ។ បរេ សន្ទិដ្ឋិបរាមាសី អាធានគ្គាហី ទុប្បដិនិស្សគ្គី ភវិស្សន្តិ មយមេត្ថ អសន្ទិដ្ឋិបរាមាសី អនាធានគ្គាហី សុប្បដិនិស្សគ្គី ភវិស្សាមាតិ ចិត្តំ ឧប្បាទេតព្វំ ។

[១០៦] សេយ្យថាបិ ចុន្ទ វិសមោ មគ្គោ តស្សាស្ស(១) អញ្ញោ សមោ មគ្គោ បរិក្កមនាយ សេយ្យថាបិ បន ចុន្ទ វិសមំ តិត្ថំ តស្សាស្ស អញ្ញំ សមំ តិត្ថំ បរិក្កមនាយ ឯវមេវ ខោ ចុន្ទ វិហឹសកស្ស បុរិសបុគ្គលស្ស អវិហឹសា ហោតិ បរិក្កមនាយ ។ បាណាតិបាតិស្ស បុរិសបុគ្គលស្ស បាណាតិបាតា វេរមណី

១ ម. អស្ស តស្ស ។



ញុំាងចិត្តឲ្យកើតឡើងយ៉ាងនេះថា ជនទាំងឡាយដទៃ នឹងបៀតបៀនក្នុងវត្ថុណា ពួកយើងនឹងមិនបៀតបៀន ក្នុងវត្ថុនុ៎ះ ។ អ្នកត្រូវញុំាងចិត្តឲ្យកើតឡើងយ៉ាងនេះថា ជនទាំងឡាយដទៃ នឹងបំបាត់ជីវិតសត្វ ក្នុងវត្ថុណា ពួកយើងនឹងវៀរចាកការបំបាត់ជីវិតសត្វ ក្នុងវត្ថុនុ៎ះ ។ បេ ។ អ្នកត្រូវញុំាងចិត្តឲ្យកើតឡើងយ៉ាងនេះថា ជនទាំងឡាយដទៃ នឹងប្រកាន់តាមសេចក្តីយល់ឃើញរបស់ខ្លួន ជាអ្នកប្រកាន់មាំ ជាអ្នកដែលគេឲ្យលះបង់ (លទ្ធិ) បានដោយក្រ ក្នុងវត្ថុណា ពួកយើងនឹងមិនប្រកាន់តាមសេចក្តីយល់ឃើញរបស់ខ្លួន ជាអ្នកមិនប្រកាន់មាំ ជាអ្នកដែលគេឲ្យលះបង់ (លទ្ធិ) បានដោយងាយ ក្នុងវត្ថុនុ៎ះ ។

[១០៦] ម្នាលចុន្ទ ផ្លូវជាផ្លូវមិនស្មើ(១) មានផ្លូវស្មើដទៃ សម្រាប់វៀសវាងផ្លូវមិនស្មើនោះ ម្នាលចុន្ទ ពុំនោះសោត ផ្លូវកំពង់មិនស្មើ(២) មានកំពង់ស្មើដទៃទៀត សម្រាប់វៀសវាងកំពង់មិនស្មើនោះ មានឧបមាយ៉ាងណា ម្នាលចុន្ទ បុរសបុគ្គលជាអ្នកបៀតបៀន រមែងមានការមិនបៀតបៀនសម្រាប់វៀសវាងចេញ មានឧបមេយ្យយ៉ាងនោះ ។ បុរសបុគ្គលអ្នកសម្លាប់សត្វ មានចេតនាវៀរចាកការសម្លាប់សត្វ

១ ផ្លូវដែលមានគល់ឈើ បន្លា និងថ្មជាដើម ។ ២ កំពង់ចំឡងប្រកបដោយគល់ឈើ ដុំថ្ម មានក្រពើនិងមករជាដើម ។ អដ្ឋកថា ។

ហោតិ បរិក្កមនាយ ។ អទិន្នាទាយិស្ស បុរិសបុគ្គលស្ស អទិន្នាទានា វេរមណី ហោតិ បរិក្កមនាយ ។ អព្រហ្មចារិស្ស បុរិសបុគ្គលស្ស ព្រហ្មចរិយំ ហោតិ បរិក្កមនាយ ។ មុសាវាទិស្ស បុរិសបុគ្គលស្ស មុសាវាទា វេរមណី ហោតិ បរិក្កមនាយ ។ បិសុណវាចស្ស[១] បុរិសបុគ្គលស្ស បិសុណាយ វាចាយ វេរមណី ហោតិ បរិក្កមនាយ ។ ផរុសវាចស្ស[២] បុរិសបុគ្គលស្ស ផរុសាយ វាចាយ វេរមណី ហោតិ បរិក្កមនាយ ។ សម្ផប្បលាបិស្ស បុរិសបុគ្គលស្ស សម្ផប្បលាបា វេរមណី ហោតិ បរិក្កមនាយ ។ អភិជ្ឈាលុស្ស បុរិសបុគ្គលស្ស អនភិជ្ឈា ហោតិ បរិក្កមនាយ ។ ព្យាបន្នចិត្តស្ស បុរិសបុគ្គលស្ស អព្យាបាទោ ហោតិ បរិក្កមនាយ ។ មិច្ឆាទិដ្ឋិកស្ស បុរិសបុគ្គលស្ស សម្មាទិដ្ឋិ ហោតិ បរិក្កមនាយ ។ មិច្ឆាសង្កប្បស្ស បុរិសបុគ្គលស្ស សម្មាសង្កប្បោ ហោតិ បរិក្កមនាយ ។

១ ម. បិសុណាវាចស្ស ។ ២ ម. ផរុសាវាចស្ស ។



សម្រាប់ចៀសវាង ។ បុរសបុគ្គលអ្នកកាន់យកទ្រព្យ ដែលគេមិនបានឲ្យ មានចេតនាវៀរចាកការកាន់យកទ្រព្យ ដែលគេមិនបានឲ្យសម្រាប់ចៀសវាង ។ បុរសបុគ្គល អ្នកប្រព្រឹត្តធម៌មិនប្រសើរ មានការប្រព្រឹត្តធម៌ដ៏ប្រសើរសម្រាប់ចៀសវាង ។ បុរសបុគ្គលអ្នកនិយាយពាក្យកុហក មានចេតនាវៀរចាកពាក្យកុហក សម្រាប់ចៀសវាង ។ បុរសបុគ្គលអ្នកមានសំដីញុះញង់ មានចេតនាវៀរចាកសំដីញុះញង់ សម្រាប់ចៀសវាង ។ បុរសបុគ្គលអ្នកមានសំដីទ្រគោះ មានចេតនាវៀរចាកសំដីទ្រគោះសម្រាប់ចៀសវាង ។ បុរសបុគ្គលអ្នកពោលពាក្យឥតប្រយោជន៍ មានចេតនាវៀរចាកការពោលពាក្យឥតប្រយោជន៍ សម្រាប់ចៀសវាង ។ បុរសបុគ្គល អ្នកមានចិត្តរំពៃចង់បានទ្រព្យរបស់គេ មានការមិនរំពៃចង់បានទ្រព្យរបស់គេសម្រាប់ចៀសវាង ។ បុរសបុគ្គលអ្នកមានចិត្តចង់ឲ្យគេវិនាស មានការមិនចង់ឲ្យគេវិនាសសម្រាប់ចៀសវាង ។ បុរសបុគ្គលអ្នកមានសេចក្តីយល់ឃើញខុស មានការយល់ឃើញត្រូវសម្រាប់ចៀសវាង ។ បុរសបុគ្គលអ្នកមានតម្រិះខុស មានតម្រិះត្រូវសម្រាប់ចៀសវាង ។

មិច្ឆាវាចស្ស បុរិសបុគ្គលស្ស សម្មាវាចា ហោតិ បរិក្កមនាយ ។ មិច្ឆាកម្មន្តស្ស បុរិសបុគ្គលស្ស សម្មាកម្មន្តោ ហោតិ បរិក្កមនាយ ។ មិច្ឆាអាជីវស្ស បុរិសបុគ្គលស្ស សម្មាអាជីវោ ហោតិ បរិក្កមនាយ ។ មិច្ឆាវាយាមស្ស បុរិសបុគ្គលស្ស សម្មាវាយាមោ ហោតិ បរិក្កមនាយ ។ មិច្ឆាសតិស្ស បុរិស-បុគ្គលស្ស សម្មាសតិ ហោតិ បរិក្កមនាយ ។ មិច្ឆាសមាធិស្ស បុរិសបុគ្គលស្ស សម្មាសមាធិ ហោតិ បរិក្កមនាយ ។ មិច្ឆាញាណិស្ស បុរិសបុគ្គលស្ស សម្មាញាណំ ហោតិ បរិក្កមនាយ ។ មិច្ឆាវិមុត្តិស្ស បុរិសបុគ្គលស្ស សម្មាវិមុត្តិ ហោតិ បរិក្កមនាយ ។ ថីនមិទ្ធបរិយុដ្ឋិតស្ស បុរិសបុគ្គលស្ស វិគតថីនមិទ្ធតា ហោតិ បរិក្កមនាយ ។ ឧទ្ធតស្ស បុរិសបុគ្គលស្ស អនុទ្ធច្ចំ ហោតិ បរិក្កមនាយ ។ វេចិកិច្ឆិស្ស បុរិ-សបុគ្គលស្ស តិណ្ណវិចិកិច្ឆតា ហោតិ បរិក្កមនាយ ។ កោធនស្ស បុរិសបុគ្គលស្ស អក្កោធោ ហោតិ បរិក្កមនាយ ។ ឧបនាហិស្ស បុរិសបុគ្គលស្ស





បុរសបុគ្គលអ្នកមានសំដីខុស មានសំដីត្រូវសម្រាប់ចៀសវាង ។ បុរសបុគ្គលអ្នកមានការងារខុស មានការងារត្រូវសម្រាប់ចៀសវាង ។ បុរសបុគ្គលមានការចិញ្ចឹមជីវិតខុស មានការចិញ្ចឹមជីវិតត្រូវ សម្រាប់ចៀសវាង ។ បុរសបុគ្គលអ្នកមានសេចក្ដីព្យាយាមខុស មានសេចក្ដីព្យាយាមត្រូវសម្រាប់ចៀសវាង ។ បុរសបុគ្គលអ្នកមានសេចក្ដីរលឹកខុស មានសេចក្ដីរលឹកត្រូវសម្រាប់ចៀសវាង ។ បុរសបុគ្គលអ្នកមានសមាធិខុស មានសមាធិត្រូវសម្រាប់ចៀសវាង ។ បុរសបុគ្គលអ្នកមានញាណខុស មានញាណត្រូវសម្រាប់ចៀសវាង ។ បុរសបុគ្គលអ្នកមានវិមុត្តិខុស មានវិមុត្តិត្រូវសម្រាប់ចៀសវាង ។ បុរសបុគ្គលអ្នកមានថីនមិទ្ធៈគ្របសង្កត់ មានការប្រាសចាកថីនមិទ្ធៈសម្រាប់ចៀសវាង ។ បុរសបុគ្គលអ្នកមានចិត្តរាយមាយ មានចិត្តមិនរាយមាយ សម្រាប់ចៀសវាង ។ បុរសបុគ្គលអ្នកមានសេចក្ដីសង្ស័យ មានការឆ្លងសេចក្ដីសង្ស័យសម្រាប់ចៀសវាង ។ បុរសបុគ្គលអ្នកមានសេចក្ដីក្រេវក្រោធ មានសេចក្ដីមិនក្រេវក្រោធសម្រាប់ចៀសវាង ។ បុរសបុគ្គលអ្នកចងសេចក្ដីក្រោធទុក

អនុបនាហោ ហោតិ បរិក្កមនាយ ។ មក្ខិស្ស បុរិស-
បុគ្គលស្ស អមក្ខោ ហោតិ បរិក្កមនាយ ។ បឡាសិស្ស
បុរិសបុគ្គលស្ស អបឡាសោ ហោតិ បរិក្កមនាយ ។
ឥស្សុកិស្ស បុរិសបុគ្គលស្ស អនិស្សា ហោតិ បរិក្ក-
មនាយ ។ មច្ឆរិស្ស បុរិសបុគ្គលស្ស អមច្ឆរិយំ
ហោតិ បរិក្កមនាយ ។ សឋស្ស បុរិសបុគ្គលស្ស
អសាឋេយ្យំ ហោតិ បរិក្កមនាយ ។ មាយាវិស្ស
បុរិសបុគ្គលស្ស អមាយា ហោតិ បរិក្កមនាយ ។
ថទ្ធស្ស បុរិសបុគ្គលស្ស អថទ្ធិយំ ហោតិ បរិក្កម-
នាយ ។ អតិមានិស្ស បុរិសបុគ្គលស្ស អនតិមានោ
ហោតិ បរិក្កមនាយ ។ ទុព្វចស្ស បុរិសបុគ្គលស្ស
សោវចស្សតា ហោតិ បរិក្កមនាយ ។ បាបមិត្តស្ស
បុរិសបុគ្គលស្ស កល្យាណមិត្តតា ហោតិ បរិក្កមនា-
យ ។ បមត្តស្ស បុរិសបុគ្គលស្ស អប្បមាទោ ហោតិ
បរិក្កមនាយ ។ អស្សទ្ធស្ស បុរិសបុគ្គលស្ស សទ្ធា
ហោតិ បរិក្កមនាយ ។ អហិរិកស្ស បុរិសបុគ្គលស្ស



មានការមិនចងសេចក្តីក្រោធទុកសម្រាប់ចៀសវាង ។ បុរសបុគ្គល
អ្នកលុបគុណគេ មានការមិនលុបគុណគេសម្រាប់ចៀសវាង ។ បុរស
បុគ្គលអ្នកប្រណាំងវាសនា មានការមិនប្រណាំងវាសនា សម្រាប់ចៀស
វាង ។ បុរសបុគ្គលអ្នកច្រណែន មានការមិនច្រណែនសម្រាប់ចៀស
វាង ។ បុរសបុគ្គលអ្នកកំណាញ់ មានសេចក្តីមិនកំណាញ់សម្រាប់ចៀស
វាង ។ បុរសបុគ្គលអ្នកអួតអាង មានការមិនអួតអាងសម្រាប់ចៀស
វាង ។ បុរសបុគ្គលអ្នកលាក់ពុត មានការមិនលាក់ពុតសម្រាប់ចៀស
វាង ។ បុរសបុគ្គលអ្នករឹងត្អឹង មានសេចក្តីមិនរឹងត្អឹងសម្រាប់ចៀសវាង ។
បុរសបុគ្គលអ្នកមើលងាយគេ មានសេចក្តីមិនមើលងាយគេ សម្រាប់
ចៀសវាង ។ បុរសបុគ្គលដែលគេប្រដៅបានដោយក្រ មានការប្រដៅ
បានងាយសម្រាប់ចៀសវាង ។ បុរសបុគ្គលអ្នកមានមិត្តអាក្រក់ មាន
ភាវៈជាអ្នកមានមិត្តល្អសម្រាប់ចៀសវាង ។ បុរសបុគ្គលអ្នកធ្វេសប្រ-
ហែស មានសេចក្តីមិនធ្វេសប្រហែសសម្រាប់ចៀសវាង ។ បុរសបុគ្គល
អ្នកមិនជឿ មានការជឿសម្រាប់ចៀសវាង ។ បុរសបុគ្គលអ្នកមិនខ្មាសបាប

ហិរិ ហោតិ បរិក្កមនាយ ។ អនោត្តប្បិស្ស បុរិសបុគ្គលស្ស ឱត្តប្បំ ហោតិ បរិក្កមនាយ ។ អប្បស្សុតស្ស បុរិសបុគ្គលស្ស ពាហុសច្ចំ ហោតិ បរិក្កមនាយ ។ កុសីតស្ស បុរិសបុគ្គលស្ស វីរិយារម្ភោ ហោតិ បរិក្កមនាយ ។ មុដ្ឋស្សតិស្ស បុរិសបុគ្គលស្ស ឧបដ្ឋិតស្សតិតា ហោតិ បរិក្កមនាយ ។ ទុប្បញ្ញស្ស បុរិសបុគ្គលស្ស បញ្ញាសម្បទា ហោតិ បរិក្កមនាយ ។ សន្ទិដ្ឋិបរាមាសិអាធានគ្គាហិទុប្បដិនិស្សគ្គិស្ស បុរិសបុគ្គលស្ស អសន្ទិដ្ឋិបរាមាសិអនាធានគ្គាហិសុប្បដិនិស្សគ្គិតា ហោតិ បរិក្កមនាយ ។

(១០៨) សេយ្យថាបិ ចុន្ទ យេ កេចិ អកុសលា ធម្មា សព្វេ តេ អធោភាគង្គមនីយា(១) យេ កេចិ កុសលា ធម្មា សព្វេ តេ ឧបរិភាគង្គមនីយា ឯវមេវ ខោ ចុន្ទ វិហឹសកស្ស បុរិសបុគ្គលស្ស អវិហឹសា ហោតិ ឧបរិភាគាយ(២) ។ បាណាតិបាតិស្ស បុរិសបុគ្គលស្ស បាណាតិបាតា វេរមណី ហោតិ

១ ម. អធោគមនីយា ។ ២ ឧបរិភាវាយ ។



មានសេចក្តីខ្មាសបាបសម្រាប់ចៀសវាង ។ បុរសបុគ្គលអ្នកមិនខ្លាចបាប មានសេចក្តីខ្លាចបាបសម្រាប់ចៀសវាង ។ បុរសបុគ្គលអ្នករៀនសូត្រតិច មានការរៀនសូត្រច្រើនសម្រាប់ចៀសវាង ។ បុរសបុគ្គលអ្នកខ្ជិលច្រអូស មានការប្រារព្ធព្យាយាមសម្រាប់ចៀសវាង ។ បុរសបុគ្គលអ្នកមានស្មារតីភ្លេចភ្លាំង មានភាវៈជាអ្នកមានស្មារតីតម្កល់ខ្ជាប់សម្រាប់ចៀសវាង ។ បុរសបុគ្គលអ្នកឥតប្រាជ្ញា មានការបរិបូណ៌ដោយប្រាជ្ញាសម្រាប់ចៀសវាង ។ បុរសបុគ្គលជាអ្នកមានសេចក្តីប្រកាន់តាមសេចក្តីយល់ឃើញរបស់ខ្លួន ប្រកាន់មាំ ទាំងជាអ្នកដែលគេឲ្យលះបង់បានដោយក្រ មានភាវៈជាអ្នកមិនបានប្រកាន់តាមសេចក្តីយល់ឃើញរបស់ខ្លួន មិនបានប្រកាន់មាំ ទាំងជាអ្នកដែលគេឲ្យលះបង់បានដោយងាយសម្រាប់ចៀសវាង ។

(១០៨) ម្នាលចុន្ទ ធម៌ទាំងឡាយណាមួយ ជាអកុសល ធម៌ទាំងអស់នោះ តែងញុំាងសត្វឲ្យធ្លាក់ទៅទាប ធម៌ទាំងឡាយណានីមួយ ជាកុសល ធម៌ទាំងអស់នោះ តែងញុំាងសត្វឲ្យឡើងទៅទីខ្ពស់ មានឧបមាយ៉ាងណា ម្នាលចុន្ទ បុរសបុគ្គលអ្នកបៀតបៀន មានការមិនបៀតបៀនសម្រាប់ញុំាងខ្លួនឲ្យបានខ្ពស់ ក៏មានឧបមេយ្យយ៉ាងនោះ ។ បុរសបុគ្គលអ្នកសម្លាប់សត្វ មានកិរិយាវៀរចាកការសម្លាប់សត្វ

ឧបរិភាវាយ(១)។ អទិន្នាទាយិស្ស ។ បេ ។ សន្ទិដ្ឋិបរាមាសិអាធានគ្គាហិទុប្បដិនិស្សគ្គិស្ស បុរិសបុគ្គលស្ស អសន្ទិដ្ឋិបរាមាសិអនាធានគ្គាហិសុប្បដិនិស្សគ្គិតា ហោតិ ឧបរិភាវាយ ។

(១០៨) សោ វត ចុន្ទ អត្តនា បលិបបលិបន្នោ បរំ បលិបបលិបន្នំ ឧទ្ធរិស្សតីតិ នេតំ ឋានំ វិជ្ជតិ ។ សោ វត ចុន្ទ អត្តនា អបលិបបលិបន្នោ បរំ បលិបបលិបន្នំ ឧទ្ធរិស្សតីតិ ឋានមេតំ វិជ្ជតិ ។ សោ វត ចុន្ទ អត្តនា អទន្តោ អវិនីតោ អបរិនិព្វុតោ បរំ ទមេស្សតិ វិនេស្សតិ បរិនិព្វាបេស្សតីតិ នេតំ ឋានំ វិជ្ជតិ ។ សោ វត ចុន្ទ អត្តនា ទន្តោ វិនីតោ បរិនិព្វុតោ បរំ ទមេស្សតិ វិនេស្សតិ បរិនិព្វាបេស្សតីតិ

១ ម. ឧបរិភាគាយ ។



សម្រាប់ញ៉ាំងខ្លួនឲ្យបានខ្ពស់ ។ បុរសបុគ្គលអ្នកកាន់យកទ្រព្យដែលគេមិនបានឲ្យ ។ បេ ។ បុរសបុគ្គលអ្នកប្រកាន់តាមសេចក្តីយល់ឃើញរបស់ខ្លួន ប្រកាន់មាំ នឹងជាអ្នកដែលគេឲ្យលះបង់ចិត្តបានដោយក្រ មានការមិនប្រកាន់តាមសេចក្តីយល់ឃើញរបស់ខ្លួន មិនបានប្រកាន់មាំ នឹងជាអ្នកដែលគេឲ្យលះបង់ចិត្តបានដោយងាយ សម្រាប់ញ៉ាំងខ្លួនឲ្យបានខ្ពស់ ។

(១០៨) ម្នាលចុន្ទ បុគ្គលណា មុជចុះក្នុងភក់ គឺកាមគុណដោយខ្លួនឯងហើយ បុគ្គលនោះឯង នឹងជួយស្រង់បុគ្គលដទៃដែលមុជចុះក្នុងភក់ គឺកាមគុណដូចគ្នា ហេតុដូច្នេះនេះ មិនដែលមានទេ ។ ម្នាលចុន្ទ លុះតែបុគ្គលណា មិនមុជចុះក្នុងភក់ គឺកាមគុណដោយខ្លួនឯងទេ បុគ្គលនោះឯង ទើបជួយស្រង់បុគ្គលដទៃដែលមុជចុះក្នុងភក់ គឺកាមគុណ ហេតុដូច្នេះ នេះទើបមាន ។ ម្នាលចុន្ទ បុគ្គលណា មិនទាន់បានប្រដៅចិត្ត មិនទាន់បានទូន្មានចិត្ត មិនទាន់រលត់កិលេសដោយខ្លួនឯង បុគ្គលនោះឯង នឹងប្រដៅ នឹងទូន្មាន នឹងញ៉ាំងបុគ្គលដទៃឲ្យរលត់កិលេស ហេតុដូច្នេះនេះ មិនដែលមានទេ ។ ម្នាលចុន្ទ បុគ្គលណា បានប្រដៅ បានទូន្មាន បានរលត់កិលេសដោយខ្លួនឯង បុគ្គលនោះឯង នឹងប្រដៅ នឹងទូន្មាន នឹងញ៉ាំងបុគ្គលដទៃឲ្យរលត់កិលេស

ឋានមេតំ វិជ្ជតិ ។ ឯវមេវ ខោ ចុន្ទ វិហឹសកស្ស បុរិសបុគ្គលស្ស អវិហឹសា ហោតិ បរិនិព្វានាយ ។ បាណាតិបាតិស្ស បុរិសបុគ្គលស្ស បាណាតិបាតា វេរមណី ហោតិ បរិនិព្វានាយ ។ អទិន្នាទាយិស្ស បុរិសបុគ្គលស្ស អទិន្នាទានា វេរមណី ហោតិ បរិនិព្វានាយ ។ អព្រហ្មចារិស្ស បុរិសបុគ្គលស្ស ព្រហ្មចរិយំ ហោតិ បរិនិព្វានាយ ។ មុសាវាទិស្ស បុរិសបុគ្គលស្ស មុសាវាទា វេរមណី ហោតិ បរិនិព្វានាយ ។ បិសុណាវាចស្ស បុរិសបុគ្គលស្ស បិសុណាយ វាចាយ វេរមណី ហោតិ បរិនិព្វានាយ ។ ផរុសវាចស្ស បុរិសបុគ្គលស្ស ផរុសាយ វាចាយ វេរមណី ហោតិ បរិនិព្វានាយ ។ សម្ផប្បលាបិស្ស បុរិសបុគ្គលស្ស សម្ផប្បលាបា វេរមណី ហោតិ បរិនិព្វានាយ ។ អភិជ្ឈាលុស្ស បុរិសបុគ្គលស្ស អនភិជ្ឈា ហោតិ បរិនិព្វានាយ ។ ព្យាបន្នចិត្តស្ស បុរិសបុគ្គលស្ស អព្យាបាទោ ហោតិ បរិនិព្វានាយ ។ មិច្ឆាទិដ្ឋិកស្ស បុរិសបុគ្គលស្ស សម្មាទិដ្ឋិ ហោតិ បរិនិព្វានាយ ។ មិច្ឆាសង្កប្បស្ស បុរិសបុគ្គលស្ស



ហេតុដូច្នោះនេះ រមែងមាន ។ ម្នាលចុន្ទ ដូចយ៉ាងបុរសបុគ្គលអ្នកបៀតបៀន មានការមិនបៀតបៀនសម្រាប់រលត់ ។ បុរសបុគ្គលអ្នកសម្លាប់សត្វ មានចេតនាវៀរចាកការសម្លាប់សត្វសម្រាប់រលត់ ។ បុរសបុគ្គលអ្នកកាន់យកទ្រព្យដែលគេមិនបានឱ្យ មានចេតនាវៀរចាកការកាន់យកទ្រព្យដែលគេមិនបានឱ្យសម្រាប់រលត់ ។ បុរសបុគ្គលអ្នកប្រព្រឹត្តធម៌មិនប្រសើរ មានការប្រព្រឹត្តធម៌ដ៏ប្រសើរសម្រាប់រលត់ ។ បុរសបុគ្គលអ្នកនិយាយពាក្យកុហក មានចេតនាវៀរចាកពាក្យកុហកសម្រាប់រលត់ ។ បុរសបុគ្គលអ្នកមានសំដីញុះញង់ មានចេតនាវៀរចាកសំដីញុះញង់សម្រាប់រលត់ ។ បុរសបុគ្គលអ្នកមានសំដីទ្រគោះ មានចេតនាវៀរចាកសំដីទ្រគោះសម្រាប់រលត់ ។ បុរសបុគ្គលអ្នកនិយាយពាក្យឥតប្រយោជន៍ មានចេតនាវៀរចាកការនិយាយពាក្យឥតប្រយោជន៍សម្រាប់រលត់ ។ បុរសបុគ្គលអ្នកមានចិត្តរំពឹងចង់បានទ្រព្យរបស់គេ មានចិត្តមិនរំពឹងចង់បានទ្រព្យរបស់គេសម្រាប់រលត់ ។ បុរសបុគ្គលអ្នកមានចិត្តចង់ឲ្យគេវិនាស មានការមិនចង់ឲ្យគេវិនាសសម្រាប់រលត់ ។ បុរសបុគ្គលអ្នកយល់ខុស មានសេចក្តីយល់ត្រូវសម្រាប់រលត់ ។ បុរសបុគ្គលអ្នកមានតម្រិះខុស

សម្មាសង្កប្បោ ហោតិ បរិនិព្វានាយ ។ មិច្ឆាវាចស្ស បុរិសបុគ្គលស្ស សម្មាវាចា ហោតិ បរិនិព្វានាយ ។ មិច្ឆាកម្មន្តស្ស បុរិសបុគ្គលស្ស សម្មាកម្មន្តោ ហោតិ បរិនិព្វានាយ ។ មិច្ឆាអាជីវស្ស បុរិសបុគ្គលស្ស សម្មាអាជីវោ ហោតិ បរិនិព្វានាយ ។ មិច្ឆាវាយាមស្ស បុរិសបុគ្គលស្ស សម្មាវាយាមោ ហោតិ បរិនិព្វានាយ ។ មិច្ឆាសតិស្ស បុរិសបុគ្គលស្ស សម្មាសតិ ហោតិ បរិនិព្វានាយ ។ មិច្ឆាសមាធិស្ស បុរិសបុគ្គលស្ស សម្មាសមាធិ ហោតិ បរិនិព្វានាយ ។ មិច្ឆាញាណិស្ស បុរិសបុគ្គលស្ស សម្មាញាណំ ហោតិ បរិនិព្វានាយ ។ មិច្ឆាវិមុត្តិស្ស បុរិសបុគ្គលស្ស សម្មាវិមុត្តិ ហោតិ បរិនិព្វានាយ ។ ថីនមិទ្ធបរិយុដ្ឋិតស្ស បុរិសបុគ្គលស្ស វិគតថីនមិទ្ធតា ហោតិ បរិនិព្វានាយ ។ ឧទ្ធតស្ស បុរិសបុគ្គលស្ស អនុទ្ធច្ចំ ហោតិ បរិនិព្វានាយ ។ វេចិកិច្ឆិស្ស បុរិសបុគ្គលស្ស តិណ្ណវិចិកិច្ឆតា ហោតិ បរិនិព្វានាយ ។ កោធនស្ស បុរិសបុគ្គលស្ស អក្កោធោ ហោតិ



មានតម្រិះត្រូវសម្រាប់រលត់ ។ បុរសបុគ្គលអ្នកមានសំដីខុស មានសំដីត្រូវសម្រាប់រលត់ ។ បុរសបុគ្គលអ្នកមានការងារខុស មានការងារត្រូវសម្រាប់រលត់ ។ បុរសបុគ្គលអ្នកចិញ្ចឹមជីវិតខុស មានការចិញ្ចឹមជីវិតត្រូវសម្រាប់រលត់ ។ បុរសបុគ្គល អ្នកមានសេចក្ដីព្យាយាមខុស មានសេចក្ដីព្យាយាមត្រូវសម្រាប់រលត់ ។ បុរសបុគ្គលអ្នកមានសេចក្ដីរលឹកខុស មានសេចក្ដីរលឹកត្រូវសម្រាប់រលត់ ។ បុរសបុគ្គលអ្នកមានសមាធិខុស មានសមាធិត្រូវសម្រាប់រលត់ ។ បុរសបុគ្គលអ្នកមានញាណខុស មានញាណត្រូវសម្រាប់រលត់ ។ បុរសបុគ្គលអ្នកមានវិមុត្តិខុស មានវិមុត្តិត្រូវសម្រាប់រលត់ ។ បុរសបុគ្គលអ្នកមានថីនមិទ្ធៈគ្របសង្កត់ មានការប្រាសចាកថីនមិទ្ធៈសម្រាប់រលត់ ។ បុរសបុគ្គលអ្នកមានចិត្តរាយមាយ មានការមិនមានចិត្តរាយមាយសម្រាប់រលត់ ។ បុរសបុគ្គលអ្នកមានសេចក្ដីសង្ស័យ មានការឆ្លងសេចក្ដីសង្ស័យសម្រាប់រលត់ ។ បុរសបុគ្គល អ្នកមានសេចក្ដីក្រោធ មានសេចក្ដីមិនក្រោធ

បរិនិព្វានាយ ។ ឧបនាហិស្ស បុរិសបុគ្គលស្ស អនុបនាហោ ហោតិ បរិនិព្វានាយ ។ មក្ខិស្ស បុរិសបុគ្គលស្ស អមក្ខោ ហោតិ បរិនិព្វានាយ ។ បឡាសិស្ស បុរិសបុគ្គលស្ស អបឡាសោ ហោតិ បរិនិព្វានាយ ។ ឥស្សុកិស្ស បុរិសបុគ្គលស្ស អនិស្សា ហោតិ បរិនិព្វានាយ ។ មច្ឆរិស្ស បុរិសបុគ្គលស្ស អមច្ឆរិយំ ហោតិ បរិនិព្វានាយ ។ សឋស្ស បុរិសបុគ្គលស្ស អសាឋេយ្យំ ហោតិ បរិនិព្វានាយ ។ មាយាវិស្ស បុរិសបុគ្គលស្ស អមាយា ហោតិ បរិនិព្វានាយ ។ ថទ្ធស្ស បុរិសបុគ្គលស្ស អថទ្ធិយំ ហោតិ បរិនិព្វានាយ ។ អតិមានិស្ស បុរិសបុគ្គលស្ស អនតិមានោ ហោតិ បរិនិព្វានាយ ។ ទុព្វចស្ស បុរិសបុគ្គលស្ស សោវចស្សតា ហោតិ បរិនិព្វានាយ ។ បាបមិត្តស្ស បុរិសបុគ្គលស្ស កល្យាណមិត្តតា ហោតិ បរិនិព្វានាយ ។ បមត្តស្ស បុរិសបុគ្គលស្ស អប្បមាទោ ហោតិ បរិនិព្វានាយ ។ អស្សទ្ធស្ស បុរិសបុគ្គលស្ស សទ្ធា ហោតិ បរិនិព្វានាយ ។ អហិរិកស្ស បុរិសបុគ្គលស្ស



សម្រាប់រលត់ ។ បុរសបុគ្គលអ្នកចងសេចក្តីក្រោធទុក មានការមិនចងសេចក្តីក្រោធទុកសម្រាប់រលត់ ។ បុរសបុគ្គលអ្នកលុបគុណគេ មានការមិនលុបគុណគេសម្រាប់រលត់ ។ បុរសបុគ្គលអ្នកប្រណាំងនឹងសខា មានការមិនប្រណាំងនឹងសខាសម្រាប់រលត់ ។ បុរសបុគ្គលអ្នកប្រច្រណែន មានការមិនប្រច្រណែនសម្រាប់រលត់ ។ បុរសបុគ្គលអ្នកកំណាញ់ មានសេចក្តីមិនកំណាញ់សម្រាប់រលត់ ។ បុរសបុគ្គលអ្នកអួតអាង មានការមិនអួតអាងសម្រាប់រលត់ ។ បុរសបុគ្គលអ្នកលាក់ពុត មានការមិនលាក់ពុតសម្រាប់រលត់ ។ បុរសបុគ្គលអ្នករឹងត្អឹង មានសេចក្តីមិនរឹងត្អឹងសម្រាប់រលត់ ។ បុរសបុគ្គលអ្នកមើលងាយគេ មានសេចក្តីមិនមើលងាយគេសម្រាប់រលត់ ។ បុរសបុគ្គលដែលគេប្រដៅបានដោយក្រ មានការប្រដៅបានដោយងាយសម្រាប់រលត់ ។ បុរសបុគ្គលអ្នកមានមិត្រអាក្រក់ មានមិត្រល្អ សម្រាប់រលត់ ។ បុរសបុគ្គលអ្នកធ្វេសប្រហែស មានសេចក្តីមិនធ្វេសប្រហែសសម្រាប់រលត់ ។ បុរសបុគ្គលអ្នកមិនជឿ មានការជឿសម្រាប់រលត់ ។ បុរសបុគ្គលអ្នកមិនខ្មាសបាប

ហិរី ហោតិ បរិនិព្វានាយ ។ អនោត្តប្បិស្ស បុរិសបុគ្គលស្ស ឱត្តប្បំ ហោតិ បរិនិព្វានាយ ។ អប្បស្សុតស្ស បុរិសបុគ្គលស្ស ពាហុសច្ចំ ហោតិ បរិនិព្វានាយ ។ កុសីតស្ស បុរិសបុគ្គលស្ស វីរិយារម្ភោ ហោតិ បរិនិព្វានាយ ។ មុដ្ឋស្សតិស្ស បុរិសបុគ្គលស្ស ឧបដ្ឋិតស្សតិតា ហោតិ បរិនិព្វានាយ ។ ទុប្បញ្ញស្ស បុរិសបុគ្គលស្ស បញ្ញាសម្បទា ហោតិ បរិនិព្វានាយ ។ សន្ទិដ្ឋិបរាមាសិអាធានគ្គាហិទុប្បដិនិស្សគ្គិស្ស បុរិសបុគ្គលស្ស អសន្ទិដ្ឋិបរាមាសិអនាធានគ្គាហិសុប្បដិនិស្សគ្គិតា ហោតិ បរិនិព្វានាយ ។

(១០៩) ឥតិ ខោ ចុន្ទ ទេសិតោ មយា សល្លេខបរិយាយោ ទេសិតោ ចិត្តុប្បាទបរិយាយោ ទេសិតោ បរិក្កមនបរិយាយោ ទេសិតោ ឧបរិភាវបរិយាយោ[1] ទេសិតោ បរិនិព្វានបរិយាយោ ។ យំ ខោ ចុន្ទ

១ ម. ឧបរិភាគ... ។



មានសេចក្តីខ្មាសបាបសម្រាប់រលត់ ។ បុរសបុគ្គលអ្នកមិនខ្លាចបាប មានសេចក្តីខ្លាចបាបសម្រាប់រលត់ ។ បុរសបុគ្គលអ្នករៀនសូត្រតិច មានការរៀនសូត្រច្រើនសម្រាប់រលត់ ។ បុរសបុគ្គលអ្នកខ្ជិលច្រអូស មានការប្រារព្ធព្យាយាមសម្រាប់រលត់ ។ បុរសបុគ្គលអ្នកមានស្មារតីភ្លេចភាំង មានស្មារតីតម្កល់ខ្ជាប់សម្រាប់រលត់ ។ បុរសបុគ្គលឥតប្រាជ្ញា មានការបរិបូណ៌ដោយប្រាជ្ញាសម្រាប់រលត់ ។ បុរសបុគ្គលអ្នកប្រកាន់តាមសេចក្តីយល់ឃើញរបស់ខ្លួន ប្រកាន់មាំ នឹងមានលទ្ធិដែលគេឲ្យលះបង់បានដោយក្រ មានសេចក្តីមិនប្រកាន់តាមសេចក្តីយល់ឃើញរបស់ខ្លួន មិនបានប្រកាន់មាំ នឹងមានលទ្ធិដែលគេឲ្យលះបង់បានដោយងាយសម្រាប់រលត់ ។

(១០៩) ម្នាលចុន្ទ តថាគតបានសំដែងនូវហេតុនៃសេចក្តីផូរផង់ហើយ បានសំដែងនូវហេតុនៃការកើតឡើងនៃចិត្តហើយ បានសំដែងនូវហេតុនៃការចៀសវាង (នូវបាបធម៌មានការបៀតបៀនជាដើម) ហើយ បានសំដែងនូវហេតុនៃការកើតក្នុងជាន់ខ្ពស់ហើយ បានសំដែងនូវហេតុនៃគ្រឿងរំលត់ហើយ ដោយប្រការដូច្នេះឯង ។ ម្នាលចុន្ទ កិច្ចណា

សត្ថារា ករណីយំ សាវកានំ ហិតេសិនា អនុកម្បកេន អនុកម្បំ ឧបាទាយ កតំ វោ តំ មយា ។ ឯតានិ ចុន្ទ រុក្ខមូលានិ ឯតានិ សុញ្ញាគារានិ ឈាយថ ចុន្ទ មា បមាទត្ថ មា បច្ឆា វិប្បដិសារិនោ អហុវត្ថ ។ អយំ វោ(១) អម្ហាកំ អនុសាសនីតិ ។ ឥទមវោច ភគវា អត្តមនោ អាយស្មា មហាចុន្ទោ ភគវតោ ភាសិតំ អភិនន្ទីតិ ។

ចតុត្តាឡីស បទា វុត្តា
សន្ធយោ បញ្ច ទេសិតា
សល្លេខោ នាម សុត្តន្តោ
គម្ភីរោ សាគរូបមោតិ(២) ។

សល្លេខសុត្តំ អដ្ឋមំ និដ្ឋិតំ ។

១ ម. តេ ។ ២ ម. ចតុត្តាឡីស បទា វុត្តា សន្ធិយោ បញ្ច ទេសិតា សល្លេខោ នាម សុត្តន្តោ គម្ភីរោ សាគរូបមោតិ ទិស្សតិ ។ ឧ. ចតុត្តាឡីស បទា វុត្តា សន្ធិយោ បញ្ច ទេសិតា សល្លេខោ នាម សុត្តន្តោ គម្ភីរោ សាគរូបមោតិ ន ទិស្សតិ ។ ៣ ឧ. ម. សល្លេខសុត្តន្តំ អដ្ឋមំ ។



ដែលសាស្តា ជាអ្នកស្វែងរកនូវប្រយោជន៍ ជាអ្នកអនុគ្រោះ គប្បីធ្វើដល់សាវ័កទាំងឡាយ គឺថាអាស្រ័យសេចក្តីអនុគ្រោះ បានធ្វើហើយដល់អ្នកទាំងឡាយ ។ ម្នាលចុន្ទ ពួកអ្នកចូរពិចារណានូវរុក្ខមូលសេនាសនៈ នឹងផ្ទះស្ងាត់ទាំងនុ៎ះ ម្នាលចុន្ទ ពួកអ្នកកុំប្រមាទឡើយ កុំជាបុគ្គលមានសេចក្តីក្តៅក្រហាយក្នុងក្រោយឡើយ ។ នេះជាពាក្យប្រៀនប្រដៅ របស់យើង ដល់អ្នកទាំងឡាយ ។ លុះព្រះមានព្រះភាគ បានត្រាស់សំដែងព្រះសូត្រនេះ ចប់ហើយ ព្រះមហាចុន្ទមានអាយុ ក៏មានចិត្តត្រេកអរ រីករាយ ចំពោះភាសិត របស់ព្រះមានព្រះភាគ ។

បទ(១) ៤៤ ព្រះមានព្រះភាគ បានត្រាស់សំដែងហើយ
សន្ធិ(២) ៥ ព្រះមានព្រះភាគ ក៏បានសំដែងហើយ សូត្រ
(នេះ) ឈ្មោះសល្លេខៈ ព្រោះមានសេចក្តីជ្រាលជ្រៅ
ឧបមាដូចសាគរ ។

ចប់ សល្លេខសូត្រ ទី ៨ ។

១ បានដល់ពួកធម៌ មានអាការ ៤៤ គឺមានការមិនបៀតបៀនជាដើម មានភាពជាអ្នកលះបង់ទិដ្ឋិបានដោយងាយ ជាទីបំផុត ។ ២ បានដល់ហេតុជាគ្រឿងតនៃធម៌ ៥ យ៉ាង គឺ សេចក្តីសួរផង ១ ការកើតឡើងនៃចិត្ត ១ ការចៀសវាង ១ ការកើតក្នុងជាន់ខ្ពស់ ១ ការរំលត់កិលេស ១ ។

# នវមំ សម្មាទិដ្ឋិសុត្តំ

(១១០) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អា-រាមេ ។ តត្រ ខោ អាយស្មា សារីបុត្តោ ភិក្ខូ អាមន្តេសិ អាវុសោ(១) ភិក្ខវោតិ ។ អាវុសោតិ(២) តេ ភិក្ខូ អាយស្មតោ សារីបុត្តស្ស បច្ចស្សោសុំ ។ អាយស្មា សារីបុត្តោ ឯតទវោច សម្មាទិដ្ឋិ សម្មា-ទិដ្ឋីតិ អាវុសោ វុច្ចតិ កិត្តាវតា នុ ខោ អាវុសោ អរិយសាវកោ សម្មាទិដ្ឋិ ហោតិ ឧជុគតាស្ស

១ ឱ. អាវុសោតិ ន ទិស្សតិ ។ ២ ឱ.ម. អាវុសោតិ ខោ ។

# សម្មាទិដ្ឋិសូត្រ ទី ៩

(១១០) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសា-វត្ថី ។ ក្នុងទីនោះឯង ព្រះសារីបុត្រដ៏មានអាយុ ហៅភិក្ខុទាំងឡាយមកថា ម្នាលអាវុសោ(១) ភិក្ខុទាំងឡាយ ។ ភិក្ខុទាំងឡាយនោះ ទទួលតបពាក្យព្រះសារីបុត្រដ៏មានអាយុដោយពាក្យថា ម្នាលអាវុសោ(២) ដូច្នេះ ។ ព្រះសារីបុត្រដ៏មានអាយុ បានសួរពាក្យនេះថា ម្នាលអាវុសោទាំងឡាយ ព្រះមានព្រះភាគ តែងត្រាស់ថា សម្មាទិដ្ឋិ(៣) ដូច្នេះ ម្នាលអាវុសោទាំងឡាយ អរិយសាវ័ក ជាសម្មាទិដ្ឋិ(៤) ជាអ្នកមានទិដ្ឋិត្រង់

១–២ ក្នុងពុទ្ធសម័យ ភិក្ខុចាស់វស្សានិងខ្ចីវស្សា ហៅគ្នាទៅមកថា អាវុសោ តែក្នុងសម័យនៃព្រះអង្គជិតបរិនិព្វាន ទ្រង់មានបន្ទូលនឹងព្រះអានន្ទថា អំណេះតអំពីព្រះអង្គទៅ ត្រូវភិក្ខុចាស់វស្សាហៅភិក្ខុខ្ចីវស្សាថា អាវុសោ ចំណែកភិក្ខុខ្ចីវស្សាត្រូវហៅភិក្ខុចាស់វស្សាថា ភន្តេ ឬ អាយស្មា (មហាបរិនិព្វានសូត្រ) ។ ៣ សម្មាទិដ្ឋិ មាន ២ យ៉ាង គឺ លោកិយ-សម្មាទិដ្ឋិ បានដល់សេចក្តីដឹងថា សត្វមានកម្មជារបស់ខ្លួន និងសេចក្តីដឹងដែលអនុលោមតាមសច្ចៈ ឬប្រាជ្ញាដែលប្រកបដោយអាសវៈទាំងអស់ ១ លោកុត្តរសម្មាទិដ្ឋិ បានដល់ប្រាជ្ញាដែលប្រកបដោយអរិយមគ្គអរិយផល ១ ។ ៤ បុគ្គលជាសម្មាទិដ្ឋិមាន ៣ ពួក គឺ បុថុជ្ជន ១ សេក្ខបុគ្គល ១ អសេក្ខបុគ្គល ១ ។ អដ្ឋកថា ។

ទិដ្ឋិ ធម្មេ អវេច្ចប្បសាទេន សមន្នាគតោ អាគតោ ឥមំ សទ្ធម្មន្តិ ។ ទូរតោបិ ខោ មយំ អាវុសោ អាគច្ឆេយ្យាម អាយស្មតោ សារីបុត្តស្ស សន្តិកេ ឯតស្ស ភាសិតស្ស អត្ថមញ្ញាតុំ សាធុ វតាយស្មន្តំយេវ សារីបុត្តំ បដិភាតុ ឯតស្ស ភាសិតស្ស អត្ថោ អាយស្មតោ សារីបុត្តស្ស សុត្វា ភិក្ខូ ធារេស្សន្តីតិ ។ តេនហាវុសោ(១) សុណាថ សាធុកំ មនសិករោថ ភាសិស្សាមីតិ ។ ឯវមាវុសោតិ ខោ តេ ភិក្ខូ អាយស្មតោ សារីបុត្តស្ស បច្ចស្សោសុំ ។

(១១១) អាយស្មា សារីបុត្តោ ឯតទវោច យតោ ខោ អាវុសោ អរិយសាវកោ អកុសលញ្ច បជានាតិ អកុសលមូលញ្ច បជានាតិ កុសលញ្ច បជានាតិ កុសលមូលញ្ច បជានាតិ ឯត្តាវតាបិ ខោ អាវុសោ អរិយសាវកោ សម្មាទិដ្ឋិ ហោតិ ឧជុគតាស្ស ទិដ្ឋិ ធម្មេ អវេច្ចប្បសាទេន សមន្នាគតោ

១ ឱ. តេនហាវុសោ ។



ប្រកបដោយសេចក្តីជ្រះថ្លា មិនញាប់ញ័រក្នុងធម៌ ហើយបានមកកាន់ព្រះសទ្ធម្មនេះ ដោយហេតុប៉ុន្មានយ៉ាងហ្ន៎ ។ ភិក្ខុទាំងឡាយនោះតបថា ម្នាលអាវុសោ យើងទាំងឡាយមកអំពីចម្ងាយ ដើម្បីដឹងសេចក្តីនៃភាសិតនេះ ក្នុងសំណាក់នៃព្រះសារីបុត្រដ៏មានអាយុ យើងសូមអង្វរសូមព្រះសារីបុត្រដ៏មានអាយុ សំដែងសេចក្តីនៃភាសិតនុ៎ះឲ្យ[illegible] ភិក្ខុទាំងឡាយ បានស្តាប់ភាសិតរបស់ព្រះសារីបុត្រដ៏មានអាយុហើយ នឹងចាំទុក ។ ព្រះសារីបុត្រមានថេរដីកាថា ម្នាលអាវុសោទាំងឡាយ បើដូច្នោះ ចូរលោកទាំងឡាយប្រុងស្តាប់ចុះ ចូរធ្វើទុកក្នុងចិត្តឲ្យប្រពៃចុះ ខ្ញុំនឹងសំដែងឥឡូវនេះ ។ ពួកភិក្ខុទាំងនោះ ទទួលស្តាប់ពាក្យព្រះសារីបុត្រដ៏មានអាយុ ដោយពាក្យថា ករុណាអាវុសោ ។

(១១១) ព្រះសារីបុត្រដ៏មានអាយុ ក៏បានសំដែងសេចក្តីនេះថា ម្នាលអាវុសោទាំងឡាយ កាលណាអរិយសាវក ដឹងច្បាស់នូវអកុសលផង ដឹងច្បាស់នូវអកុសលមូលផង ដឹងច្បាស់នូវកុសលផង ដឹងច្បាស់នូវកុសលមូលផង ម្នាលអាវុសោទាំងឡាយ ព្រះអរិយសាវកជាសម្មាទិដ្ឋិ ជាអ្នកមានទិដ្ឋិត្រង់ ប្រកបដោយសេចក្តីជ្រះថ្លា មិនញាប់ញ័រ

អាគតោ ឥមំ សទ្ធម្មន្តិ(១) ។ កតមំ បនាវុសោ អកុសលំ(២) ។ បាណាតិបាតោ ខោ អាវុសោ អកុសលំ អទិន្នាទានំ អកុសលំ កាមេសុមិច្ឆាចារោ អកុសលំ មុសាវាទោ អកុសលំ បិសុណា វាចា អកុសលំ ផរុសា វាចា អកុសលំ សម្ផប្បលាបោ អកុសលំ អភិជ្ឈា អកុសលំ ព្យាបាទោ អកុសលំ មិច្ឆាទិដ្ឋិ អកុសលំ ឥទំ វុច្ចតាវុសោ អកុសលំ ។ កតមញ្ចាវុសោ អកុសលមូលំ ។ លោភោ អកុសលមូលំ ទោសោ អកុសលមូលំ មោហោ អកុសលមូលំ ឥទំ វុច្ចតាវុសោ អកុសលមូលំ ។ កតមញ្ចាវុសោ កុសលំ ។ បាណាតិបាតា វេរមណី កុសលំ អទិន្នាទានា វេរមណី កុសលំ កាមេសុមិច្ឆាចារា វេរមណី កុសលំ មុសាវាទា វេរមណី កុសលំ បិសុណាយ វាចាយ វេរមណី កុសលំ ផរុសាយ វាចាយ វេរមណី កុសលំ សម្ផប្បលាបា វេរមណី កុសលំ

១ ឧ.ម. សទ្ធម្មំ ។ ២ ឧ.ម. ឥតោ បរំ កតមំ អកុសលមូលំ កតមំ កុសលំ កតមំ កុសលមូលន្តិ ទិស្សតិ ។



ក្នុងព្រះធម៌ ហើយបានមកកាន់ព្រះសទ្ធម្មនេះ ក្នុងកាលនោះ ដោយហេតុប៉ុណ្ណេះឯង ។ ម្នាលអាវុសោទាំងឡាយ អកុសលតើដូចម្តេច ។ ម្នាលអាវុសោទាំងឡាយ បាណាតិបាត ជាអកុសល ១ អទិន្នាទាន ជាអកុសល ១ កាមេសុមិច្ឆាចារ ជាអកុសល ១ មុសាវាទ ជាអកុសល ១ បិសុណាវាចា ជាអកុសល ១ ផរុសវាចា ជាអកុសល ១ សម្ផប្បលាបៈ ជាអកុសល ១ អភិជ្ឈា ជាអកុសល ១ ព្យាបាទ ជាអកុសល ១ មិច្ឆាទិដ្ឋិ ជាអកុសល ១ ម្នាលអាវុសោទាំងឡាយ នេះហៅថា អកុសល ។ ម្នាលអាវុសោទាំងឡាយ អកុសលមូលតើដូចម្តេច ។ លោភៈជាអកុសលមូល ១ ទោសៈជាអកុសលមូល ១ មោហៈជាអកុសលមូល ១ ម្នាលអាវុសោទាំងឡាយ នេះហៅថាអកុសលមូល ។ ម្នាលអាវុសោទាំងឡាយ កុសលតើដូចម្តេច ។ ចេតនាវៀរចាកបាណាតិបាត ជាកុសល ១ ចេតនាវៀរចាកអទិន្នាទាន ជាកុសល ១ ចេតនាវៀរចាកកាមេសុមិច្ឆាចារ ជាកុសល ១ ចេតនាវៀរចាកមុសាវាទ ជាកុសល ១ ចេតនាវៀរចាកបិសុណាវាចា ជាកុសល ១ ចេតនាវៀរចាកផរុសវាចា ជាកុសល ១ ចេតនាវៀរចាកសម្ផប្បលាបៈ ជាកុសល ១

អនភិជ្ឈា កុសលំ អព្យាបាទោ កុសលំ សម្មាទិដ្ឋិ កុសលំ ឥទំ វុច្ចតាវុសោ កុសលំ ។ កតមញ្ចាវុសោ កុសលមូលំ ។ អលោភោ កុសលមូលំ អទោសោ កុសលមូលំ អមោហោ កុសលមូលំ ឥទំ វុច្ចតាវុសោ កុសលមូលំ ។ យតោ ខោ អាវុសោ អរិយសាវកោ ឯវំ អកុសលំ បជានាតិ ឯវំ អកុសលមូលំ បជានាតិ ឯវំ កុសលំ បជានាតិ ឯវំ កុសលមូលំ បជានាតិ សោ សព្វសោ រាគានុសយំ បហាយ បដិឃានុសយំ បដិវិនោទេត្វា អស្មីតិ ទិដ្ឋិមានានុសយំ សមូហនិត្វា អវិជ្ជំ បហាយ វិជ្ជំ ឧប្បាទេត្វា ទិដ្ឋេវ ធម្មេ ទុក្ខស្សន្តករោ ហោតិ ។ ឯត្តាវតាបិ ខោ អាវុសោ អរិយសាវកោ សម្មាទិដ្ឋិ ហោតិ ឧជុគតាស្ស ទិដ្ឋិ ធម្មេ អវេច្ចប្បសាទេន សមន្នាគតោ អាគតោ ឥមំ សទ្ធម្មន្តិ ។

(១១៦) សាធាវុសោតិ ខោ តេ ភិក្ខូ អាយស្មតោ សារីបុត្តស្ស ភាសិតំ អភិនន្ទិត្វា អនុមោទិត្វា អាយស្មន្តំ សារីបុត្តំ ឧត្តរឹ បញ្ហំ អបុច្ឆុំ[1]

---

១ ម. ឱ. អបុច្ឆំ ។



ការមិនមានអភិជ្ឈា ជាកុសល ១ ការមិនមានព្យាបាទ ជាកុសល ១ សម្មាទិដ្ឋិ ជាកុសល ១ ម្នាលអាវុសោទាំងឡាយ នេះហៅថា កុសល ។ ម្នាលអាវុសោទាំងឡាយ កុសលមូលតើដូចម្តេច ។ អលោភៈ ជាកុសលមូល ១ អទោសៈ ជាកុសលមូល ១ អមោហៈ ជាកុសលមូល ១ ម្នាលអាវុសោទាំងឡាយ នេះហៅថា កុសលមូល ។ ម្នាលអាវុសោទាំងឡាយ កាលណាអរិយសាវ័ក ដឹងច្បាស់នូវអកុសលយ៉ាងនេះ ដឹងច្បាស់នូវអកុសលមូលយ៉ាងនេះ ដឹងច្បាស់នូវកុសលយ៉ាងនេះ ដឹងច្បាស់នូវកុសលមូលយ៉ាងនេះ អរិយសាវ័កនោះលះបង់រាគានុស័យ បន្ទោបង់នូវបដិឃានុស័យ ដកចេញនូវមានានុស័យប្រហែលនឹងទិដ្ឋិថា អាត្មាអញមានដូច្នេះ ហើយលះបង់នូវអវិជ្ជា ញុំាងវិជ្ជាឲ្យកើត ធ្វើនូវទីបំផុតនៃទុក្ខក្នុងបច្ចុប្បន្ន ដោយសព្វគ្រប់បាន ក្នុងកាលនោះ ។ ម្នាលអាវុសោទាំងឡាយ អរិយសាវ័ក ជាសម្មាទិដ្ឋិ ជាអ្នកមានទិដ្ឋិត្រង់ ប្រកបដោយសេចក្តីជ្រះថ្លា មិនញាប់ញ័រក្នុងព្រះធម៌ ហើយបានមកកាន់ព្រះសទ្ធម្មនេះ ដោយហេតុប៉ុណ្ណេះឯង ។

(១១៦) ភិក្ខុទាំងឡាយនោះ ត្រេកអរ អនុមោទនាចំពោះភាសិតរបស់ព្រះសារីបុត្រដ៏មានអាយុ ដោយពាក្យថា ម្នាលអាវុសោ ប្រពៃហើយ ទើបសួរប្រស្នាតទៅទៀតនឹងព្រះសារីបុត្រដ៏មានអាយុថា

សិយា បនាវុសោ អញ្ញោបិ បរិយាយោ យថា អរិយសាវកោ សម្មាទិដ្ឋិ ហោតិ ឧជុគតាស្ស ទិដ្ឋិ ធម្មេ អវេច្ចប្បសាទេន សមន្នាគតោ អាគតោ ឥមំ សទ្ធម្មន្តិ ។

(១១៣) សិយាវុសោតិ អាយស្មា សារិបុត្តោ អវោច យតោ ខោ អាវុសោ[១] អរិយសាវកោ អាហារញ្ច បជានាតិ អាហារសមុទយញ្ច បជានាតិ អាហារនិរោធញ្ច បជានាតិ អាហារនិរោធគាមិនឹ បដិបទញ្ច បជានាតិ ឯត្តាវតាបិ ខោ អាវុសោ អរិយសាវកោ សម្មាទិដ្ឋិ ហោតិ ឧជុគតាស្ស ទិដ្ឋិ ធម្មេ អវេច្ចប្បសាទេន សមន្នាគតោ អាគតោ ឥមំ សទ្ធម្មំ ។ កតមោ បនាវុសោ អាហារោ កតមោ អាហារសមុទយោ កតមោ អាហារនិរោធោ កតមា អាហារនិរោធគាមិនី បដិបទា ។

១ ឱ.ម. សិយា អាវុសោ ។ យតោ ខោ អាវុសោតិ ទិស្សតិ ។



ម្នាលអាវុសោ អរិយសាវ័ក ជាសម្មាទិដ្ឋិ ជាអ្នកមានទិដ្ឋិត្រង់ ប្រកបដោយសេចក្តីជ្រះថ្លា មិនញាប់ញ័រក្នុងព្រះធម៌ ហើយបានមកកាន់ព្រះសទ្ធម្មនេះដោយបរិយាយដទៃទៀត មានដែរឬ ។

(១១៣) ព្រះសារីបុត្រដ៏មានអាយុ បានឆ្លើយថា ម្នាលអាវុសោទាំងឡាយ មានដែរ ហើយបាននិយាយ (តទៅថា) ម្នាលអាវុសោទាំងឡាយ កាលណាអរិយសាវ័ក ស្គាល់ច្បាស់នូវអាហារគឺបច្ច័យផង ស្គាល់ច្បាស់នូវសេចក្តីកើតឡើងនៃអាហារផង ស្គាល់ច្បាស់នូវសេចក្តីរលត់អាហារផង ស្គាល់ច្បាស់ នូវសេចក្តីប្រតិបត្តិ ជាដំណើរដើម្បីរលត់អាហារផង ម្នាលអាវុសោទាំងឡាយ អរិយសាវ័ក ជាសម្មាទិដ្ឋិ ជាអ្នកមានចិត្តត្រង់ ប្រកបដោយសេចក្តីជ្រះថ្លា មិនញាប់ញ័រក្នុងព្រះធម៌ ហើយបានមកកាន់ព្រះសទ្ធម្មនេះ ដោយហេតុប៉ុណ្ណេះឯង ក្នុងកាលនោះ ។ ម្នាលអាវុសោទាំងឡាយ អាហារតើដូចម្តេច សេចក្តីកើតឡើងនៃអាហារ តើដូចម្តេច សេចក្តីរលត់នៃអាហារ តើដូចម្តេច សេចក្តីប្រតិបត្តិ ជាដំណើរដើម្បីរលត់អាហារ តើដូចម្តេច ។

ចត្តារោមេ អាវុសោ អាហារា ភូតានំ វា សត្តានំ ឋិតិយា សម្ភវេសីនំ វា អនុគ្គហាយ ។ កតមេ ចត្តារោ ។ កពឡិង្ការោ(១) អាហារោ ឱឡារិកោ វា សុខុមោ វា ផស្សោ ទុតិយោ មនោសញ្ចេតនា តតិយា វិញ្ញាណំ ចតុត្ថំ ។ តណ្ហាសមុទយា អាហារសមុទយោ តណ្ហានិរោធា អាហារនិរោធោ អយមេវ អរិយោ អដ្ឋង្គិកោ មគ្គោ

១. កពឡិង្ការោ ។ ម. កពឡីការោ ។



ម្នាលអាវុសោទាំងឡាយ អាហារ ៤ យ៉ាងនេះ តែងប្រព្រឹត្តទៅ ដើម្បីឋិតនៅ ដល់ពួកសត្វដែលជាភូត(១)ផង ដើម្បីអនុគ្រោះដល់ពួកសត្វដែលជាសម្ភវេសី(២)ផង ។ អាហារទាំង ៤ យ៉ាងតើដូចម្តេច ។ គឺអាហារធ្វើជាពំនូតគ្រោតគ្រាតឬល្អិត (ជាទី១) ការពាល់ត្រូវ (មានចក្ខុសម្ផស្សជាដើម) ជាអាហារទី ២ ការត្រិះរិះក្នុងចិត្ត(៣) ជាអាហារទី ៣ វិញ្ញាណ (នាំមកនូវបដិសន្ធិនៃនាមរូប) ជាអាហារទី ៤ ។ សេចក្តីកើតឡើងនៃអាហារ ព្រោះសេចក្តីកើតឡើងនៃតណ្ហា សេចក្តីរលត់អាហារ ព្រោះសេចក្តីរលត់នៃតណ្ហា បានដល់មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរនេះឯង

១–២ សត្វដែលកើតស្រេចហើយ ហៅថា ភូត ។ សត្វដែលកំពុងកើត ហៅថា សម្ភវេសី ។ ឧទាហរណ៍ដូចជាសត្វកើតក្នុងពង (មានមាន់ជាដើម) ដែលមិនទាន់ញាស់ ពួកសត្វកើតក្នុងផ្ទៃ (មានមនុស្សជាដើម) ដែលមិនទាន់ទំលាយស្រោមសម្រាល ពួកសត្វកើតពីញើសក្តីនិង ពួកសត្វដែលកើតឯងក្តី នៅក្នុងខណៈចិត្តជាដំបូង ទាំងអស់នេះជាសម្ភវេសី ព្រោះកើតមិនទាន់ស្រេច ។ ដែលញាស់ផុតហើយ សម្រាលចេញហើយ និងពួកសត្វកើតពីញើសក្តី កើតឯងក្តី រាប់តាំងពីខណៈចិត្តទី២ ទៅ ឈ្មោះជាភូត ឬពួកសត្វដែលកើតដោយឥរិយាបថណា ហើយមិនទាន់ផ្លាស់ឥរិយាបថនោះទេ ក៏នៅជាសម្ភវេសី ផ្លាស់ទៅរកឥរិយាបថដទៃហើយទុកជាភូត ។ មួយទៀតថា ពួកសត្វដែលអស់ជាតិហើយមិនលែងកើតទៅទៀតហើយនិងពួកព្រះខីណាស្រព ហៅថា ភូត ។ ពួកសេក្ខនិងបុថុជ្ជន ហៅថា សម្ភវេសី ព្រោះនៅស្វែងរកភពទៀត ។ ៣ ការត្រិះរិះក្នុងចិត្ត វែងនាំមកនូវភពទាំង ៣ ។ អដ្ឋកថា ។

អាហារនិរោធគាមិនី បដិបទា សេយ្យថីទំ សម្មាទិដ្ឋិ សម្មាសង្កប្បោ សម្មាវាចា សម្មាកម្មន្តោ សម្មាអាជីវោ សម្មាវាយាមោ សម្មាសតិ សម្មាសមាធិ ។ យតោ ខោ អាវុសោ អរិយសាវកោ ឯវំ អាហារំ បជានាតិ ឯវំ អាហារសមុទយំ បជានាតិ ឯវំ អាហារនិរោធំ បជានាតិ ឯវំ អាហារនិរោធគាមិនឹ បដិបទំ បជានាតិ សោ សព្វសោ រាគានុសយំ បហាយ បដិឃានុសយំ បដិវិនោទេត្វា អស្មីតិ ទិដ្ឋិមានានុសយំ សមូហនិត្វា អវិជ្ជំ បហាយ វិជ្ជំ ឧប្បាទេត្វា ទិដ្ឋេវ ធម្មេ ទុក្ខស្សន្តករោ ហោតិ ឯត្តាវតាបិ ខោ អាវុសោ អរិយសាវកោ សម្មាទិដ្ឋិ ហោតិ ឧជុគតាស្ស ទិដ្ឋិ ធម្មេ អវេច្ចប្បសាទេន សមន្នាគតោ អាគតោ ឥមំ សទ្ធម្មន្តិ ។

(១១៤) សាធាវុសោតិ ខោ តេ ភិក្ខូ អាយស្មតោ សារីបុត្តស្ស ភាសិតំ អភិនន្ទិត្វា អនុមោទិត្វា អាយស្មន្តំ សារីបុត្តំ ឧត្តរឹ បញ្ហំ អបុច្ឆិំសុ សិយា បនាវុសោ ។បេ។



ជាសេចក្តីប្រតិបត្តិជាដំណើរទៅ ដើម្បីរលត់អាហារ គឺ សម្មាទិដ្ឋិ ១ សម្មាសង្កប្បៈ ១ សម្មាវាចា ១ សម្មាកម្មន្តៈ ១ សម្មាអាជីវៈ ១ សម្មាវាយាមៈ ១ សម្មាសតិ ១ សម្មាសមាធិ ១ ។ ម្នាលអាវុសោទាំងឡាយ អរិយសាវ័ក ស្គាល់ច្បាស់នូវអាហារយ៉ាងនេះ ស្គាល់ច្បាស់នូវសេចក្តីកើតឡើងនៃអាហារយ៉ាងនេះ ស្គាល់ច្បាស់នូវសេចក្តីរលត់អាហារយ៉ាងនេះ ស្គាល់ច្បាស់នូវសេចក្តីប្រតិបត្តិ ជាដំណើរ ដើម្បីរលត់អាហារយ៉ាងនេះ កាលណា អរិយសាវ័កនោះ លះបង់នូវរាគានុស័យ បន្ទោបង់នូវបដិឃានុស័យ ដកចេញនូវមានានុស័យប្រហែលនឹងទិដ្ឋិថា អាត្មាអញមានដូច្នេះ លះបង់អវិជ្ជាហើយ ញុំាងវិជ្ជាឲ្យកើតឡើង ធ្វើនូវទីបំផុតនៃទុក្ខក្នុងបច្ចុប្បន្នដោយសព្វគ្រប់ ក្នុងកាលនោះ ម្នាលអាវុសោទាំងឡាយ អរិយសាវ័ក ជាសម្មាទិដ្ឋិ ជាអ្នកមានទិដ្ឋិត្រង់ ប្រកបដោយសេចក្តីជ្រះថ្លា មិនញាប់ញ័រក្នុងព្រះធម៌ ហើយបានមកកាន់ព្រះសទ្ធម្មនេះ ដោយហេតុប៉ុណ្ណេះឯង ។

(១១៤) ពួកភិក្ខុទាំងនោះ ត្រេកអរអនុមោទនាភាសិត របស់ព្រះសារីបុត្រដ៏មានអាយុថា អាវុសោ ប្រពៃហើយ ទើបសួរប្រស្នាតទៅទៀតនឹងព្រះសារីបុត្រដ៏មានអាយុថា ម្នាលអាវុសោ បរិយាយដទៃនៅមានទៀតដែរឬ ។បេ។

(១១៨) សិយាវុសោតិ អាយស្មា សារីបុត្តោ អវោច យតោ ខោ អាវុសោ អរិយសាវកោ ទុក្ខញ្ច បជានាតិ ទុក្ខសមុទយញ្ច បជានាតិ ទុក្ខនិរោធញ្ច បជានាតិ ទុក្ខនិរោធគាមិនឹ បដិបទញ្ច បជានាតិ ឯត្តាវតាបិ ខោ អាវុសោ អរិយសាវកោ សម្មាទិដ្ឋិ ហោតិ ឧជុគតាស្ស ទិដ្ឋិ ធម្មេ អវេច្ចប្បសាទេន សមន្នាគតោ អាគតោ ឥមំ សទ្ធម្មំ ។ កតមញ្ចាវុសោ ទុក្ខំ(១) ជាតិបិ ទុក្ខា ជរាបិ ទុក្ខា មរណម្បិ ទុក្ខំ សោកបរិទេវទុក្ខទោមនស្សុបាយាសាបិ ទុក្ខា អប្បិយេហិ សម្បយោគោ ទុក្ខោ បិយេហិ វិប្បយោគោ ទុក្ខោ(២) យម្បិច្ឆំ ន លភតិ តម្បិ(៣) ទុក្ខំ សង្ខិត្តេន បញ្ចុបាទានក្ខន្ធា ទុក្ខា ឥទំ វុច្ចតាវុសោ ទុក្ខំ ។ កតមោ ចាវុសោ ទុក្ខសមុទយោ យាយំ តណ្ហា បោនោព្ភវិកា នន្ទិរាគសហគតា តត្រតត្រាភិនន្ទិនី

១ ឱ.ម. កតមំ បនាវុសោ ទុក្ខំ ។ កតមោ ទុក្ខសមុទយោ ។ កតមោ ទុក្ខនិរោធោ ។ កតមា ទុក្ខនិរោធគាមិនី បដិបទាតិ ទិស្សន្តិ ។ ២ ឱ.ម. អប្បិយេហិ សម្បយោគោ ទុក្ខោ បិយេហិ វិប្បយោគោតិ ន ទិស្សន្តិ ។ ៣ ម. តំបិ ។





(១១៨) ព្រះសារីបុត្តមានអាយុឆ្លើយតបថា ម្នាលអាវុសោទាំងឡាយ មានដែរ ហើយបាននិយាយថា ម្នាលអាវុសោទាំងឡាយ កាលណាអរិយសាវកដឹងច្បាស់នូវទុក្ខផង ដឹងច្បាស់នូវសេចក្តីកើតឡើងនៃទុក្ខផង ដឹងច្បាស់នូវសេចក្តីរលត់ទុក្ខផង ដឹងច្បាស់នូវសេចក្តីប្រតិបត្តិជាដំណើរដើម្បីរលត់ទុក្ខផង ម្នាលអាវុសោទាំងឡាយ អរិយសាវកជាសម្មាទិដ្ឋិ ជាអ្នកមានទិដ្ឋិត្រង់ ប្រកបដោយសេចក្តីជ្រះថ្លា មិនញាប់ញ័រក្នុងព្រះធម៌ ហើយមកកាន់ព្រះសទ្ធម្មនេះ ដោយហេតុប៉ុណ្ណោះឯង ។ ម្នាលអាវុសោទាំងឡាយ សេចក្តីទុក្ខ តើដូចម្តេច គឺជាតិ ក៏ជាទុក្ខ ជរា ក៏ជាទុក្ខ មរណៈក៏ជាទុក្ខ សេចក្តីសោកខ្សឹកខ្សួល លំបាកកាយ ទោមនស្ស ចង្អៀតចង្អល់ចិត្ត ក៏ជាទុក្ខ ការប្រកបដោយរបស់មិនជាទីស្រឡាញ់ទាំងឡាយក៏ជាទុក្ខ ការព្រាត់ប្រាសចាករបស់ជាទីស្រឡាញ់ទាំងឡាយ ក៏ជាទុក្ខ ប្រាថ្នានូវរបស់ណា មិនបានរបស់នោះ ក៏ជាទុក្ខ ដោយសង្ខេប ឧបាទានក្ខន្ធទាំង ៥ ក៏ជាទុក្ខ ម្នាលអាវុសោទាំងឡាយ នេះហៅថាទុក្ខ ។ ម្នាលអាវុសោទាំងឡាយ សេចក្តីកើតឡើងនៃទុក្ខ តើដូចម្តេច តណ្ហាដែលជាធម្មជាតិនាំសត្វឲ្យកើតទៀត ប្រកបដោយសេចក្តីរីករាយនឹងសេចក្តីត្រេកត្រអាល ជាធម្មជាតិត្រេកអរបំពោះក្នុងអារម្មណ៍

សេយ្យថីទំ កាមតណ្ហា ភវតណ្ហា វិភវតណ្ហា អយំ វុច្ចតាវុសោ ទុក្ខសមុទយោ ។ កតមោ ចាវុសោ ទុក្ខនិរោធោ យោ តស្សាយេវ តណ្ហាយ អសេសវិរាគ-និរោធោ ចាគោ បដិនិស្សគ្គោ មុត្តិ អនាលយោ អយំ វុច្ចតាវុសោ ទុក្ខនិរោធោ ។ កតមា ចាវុសោ ទុក្ខនិរោធគាមិនី បដិបទា អយមេវ អរិយោ អដ្ឋង្គិ-កោ មគ្គោ[១] សេយ្យថីទំ សម្មាទិដ្ឋិ ។ បេ ។ សម្មា-សមាធិ ។ យតោ ខោ អាវុសោ អរិយសាវកោ ឯវំ ទុក្ខំ បជានាតិ ឯវំ ទុក្ខសមុទយំ បជានាតិ ឯវំ ទុក្ខនិរោធំ បជានាតិ ឯវំ ទុក្ខនិរោធគាមិនិំ បដិបទំ បជានាតិ សោ សព្វសោ រាគានុសយំ បហាយ បដិឃានុសយំ បដិវិនោទេត្វា អស្មីតិ ទិដ្ឋិមានានុសយំ សមូហនិត្វា អវិជ្ជំ បហាយ វិជ្ជំ ឧប្បាទេត្វា ទិដ្ឋេវ ធម្មេ ទុក្ខស្សន្តករោ ហោតិ ឯត្តាវតាបិ ខោ អាវុសោ អរិយសាវកោ សម្មាទិដ្ឋិ ហោតិ ឧជុគតាស្ស ទិដ្ឋិ ធម្មេ អវេច្ចប្បសាទេន សមន្នាគតោ អាគតោ ឥមំ សទ្ធម្មន្តិ ។

១. ម. មគ្គោ ទុក្ខនិរោធគាមិនី បដិបទា ។



នោះៗ គឺកាមតណ្ហា ភវតណ្ហា វិភវតណ្ហា ម្នាលអាវុសោទាំងឡាយ នេះហៅថាសេចក្តីកើតឡើងនៃទុក្ខ ។ ម្នាលអាវុសោទាំងឡាយ សេចក្តីរលត់ទុក្ខតើដូចម្តេច សេចក្តីអស់ទៅ និងសេចក្តីរលត់ដោយមិនសល់ណា នៃតណ្ហានោះឯង គឺការលះបង់ រលាស់ចោល ផុតស្រឡះចោល ឥតមានអាល័យ ម្នាលអាវុសោទាំងឡាយ នេះហៅថា ទុក្ខនិរោធ ។ ម្នាលអាវុសោទាំងឡាយ សេចក្តីប្រតិបត្តិជាដំណើរដើម្បីរលត់ទុក្ខតើដូចម្តេច អរិយមគ្គប្រកបដោយអង្គ ៨ នេះឯង គឺ សម្មាទិដ្ឋិ ។ បេ ។ សម្មាសមាធិ ។ ម្នាលអាវុសោទាំងឡាយ កាលណាអរិយសាវ័ក ដឹងច្បាស់នូវទុក្ខយ៉ាងនេះ ដឹងច្បាស់នូវទុក្ខសមុទ័យយ៉ាងនេះ ដឹងច្បាស់នូវទុក្ខនិរោធយ៉ាងនេះ ដឹងច្បាស់នូវទុក្ខនិរោធគាមិនីបដិបទាយ៉ាងនេះ អរិយសាវ័កនោះលះចោលរាគានុស័យគ្រប់ៗ បន្ទោបង់អនុស័យគឺបដិឃៈ ដកចេញនូវអនុស័យ គឺមានះព្រមទាំងទិដ្ឋិថា អាត្មាអញមានដូច្នេះ លះបង់នូវអវិជ្ជា ញុំាងវិជ្ជាឲ្យកើតឡើងដោយសព្វគ្រប់ ហើយធ្វើនូវទីបំផុតនៃទុក្ខបានក្នុងបច្ចុប្បន្ននេះ ក្នុងកាលនោះ ម្នាលអាវុសោទាំងឡាយ អរិយសាវ័ក ជាសម្មាទិដ្ឋិ ជាអ្នកមានទិដ្ឋិត្រង់ ប្រកបដោយសេចក្តីជ្រះថ្លា មិនញាប់ញ័រក្នុងព្រះធម៌ ហើយបានមកកាន់ព្រះសទ្ធម្មនេះ ដោយហេតុប៉ុណ្ណេះឯង ។

[១១៦] សាធាវុសោតិ ខោ តេ ភិក្ខូ អាយស្មតោ សារីបុត្តស្ស ភាសិតំ អភិនន្ទិត្វា អនុមោទិត្វា អាយស្មន្តំ សារីបុត្តំ ឧត្តរឹ បញ្ហំ អបុច្ឆុំ សិយា បនាវុសោ អញ្ញោបិ បរិយាយោ យថា អរិយសាវកោ សម្មាទិដ្ឋិ ហោតិ ឧជុគតាស្ស ទិដ្ឋិ ធម្មេ អវេច្ចប្បសាទេន សមន្នាគតោ អាគតោ ឥមំ សទ្ធម្មន្តិ ។

[១១៧] សិយាវុសោតិ អាយស្មា សារីបុត្តោ អវោច យតោ ខោ អាវុសោ អរិយសាវកោ ជរាមរណញ្ច បជានាតិ ជរាមរណសមុទយញ្ច បជានាតិ ជរាមរណនិរោធញ្ច បជានាតិ ជរាមរណនិរោធគាមិនឹ បដិបទញ្ច បជានាតិ ឯត្តាវតាបិ ខោ អាវុសោ អរិយសាវកោ សម្មាទិដ្ឋិ ហោតិ ឧជុគតាស្ស ទិដ្ឋិ ធម្មេ អវេច្ចប្បសាទេន សមន្នាគតោ អាគតោ ឥមំ សទ្ធម្មំ ។ កតមំ បនាវុសោ ជរាមរណំ កតមោ ជរាមរណសមុទយោ កតមោ ជរាមរណនិរោធោ



[១១៦] ភិក្ខុទាំងឡាយនោះ ត្រេកអរអនុមោទនា ចំពោះភាសិតរបស់ព្រះសារីបុត្រដ៏មានអាយុថា អាវុសោប្រពៃហើយ ទើបសួរប្រស្នាតទៅទៀត នឹងព្រះសារីបុត្រដ៏មានអាយុថា ម្នាលអាវុសោ អរិយសាវ័ក ជាសម្មាទិដ្ឋិ មានទិដ្ឋិត្រង់ ប្រកបដោយសេចក្ដីជ្រះថ្លា មិនញាប់ញ័រក្នុងព្រះធម៌ ហើយបានមកកាន់ព្រះសទ្ធម្មនេះ ដោយបរិយាយដទៃទៀត មានដែរឬ ។

[១១៧] ព្រះសារីបុត្រដ៏មានអាយុឆ្លើយតបថា ម្នាលអាវុសោទាំងឡាយ បរិយាយដទៃនៅមានទៀត ដូច្នេះ ហើយនិយាយថា ម្នាលអាវុសោទាំងឡាយ កាលណាអរិយសាវ័ក ស្គាល់ច្បាស់នូវជរានិងមរណៈផង ស្គាល់ច្បាស់នូវសេចក្ដីកើតឡើងនៃជរានិងមរណៈផង ស្គាល់ច្បាស់នូវសេចក្ដីរលត់ជរានិងមរណៈផង ស្គាល់ច្បាស់នូវសេចក្ដីប្រតិបត្តិជាដំណើរដើម្បីរលត់ជរានិងមរណៈផង ម្នាលអាវុសោទាំងឡាយ អរិយសាវ័កជាសម្មាទិដ្ឋិ ជាអ្នកមានទិដ្ឋិត្រង់ ប្រកបដោយសេចក្ដីជ្រះថ្លា មិនញាប់ញ័រក្នុងព្រះធម៌ ហើយមកកាន់ព្រះសទ្ធម្មនេះ ដោយហេតុប៉ុណ្ណោះឯង ក្នុងកាលនោះ ។ ម្នាលអាវុសោទាំងឡាយ ជរានិងមរណៈតើដូចម្ដេច សេចក្ដីកើតឡើងនៃជរានិងមរណៈតើដូចម្ដេច សេចក្ដីរលត់ទៅនៃជរានិងមរណៈ

កតមា ជរាមរណនិរោធគាមិនី បដិបទាតិ[១] ។ យា តេសំ តេសំ សត្តានំ តម្ហិ តម្ហិ សត្តនិកាយេ ជរា ជីរណតា ខណ្ឌិច្ចំ បាលិច្ចំ វលិត្តចតា[២] អាយុនោ សំហានិ ឥន្ទ្រិយានំ បរិបាកោ អយំ វុច្ចតិ[៣] ជរា ។ យា[៤] តេសំ តេសំ សត្តានំ តម្ហា តម្ហា សត្តនិកាយា ចុតិ ចវនតា ភេទោ អន្តរធានំ មច្ចុ មរណំ កាលកិរិយា ខន្ធានំ ភេទោ កឡេវរស្ស និក្ខេបោ ជីវិតិន្ទ្រិយស្ស ឧបច្ឆេទោ ឥទំ វុច្ចតិ មរណំ[៥] ។ ឥតិ អយញ្ច ជរា ឥទញ្ច មរណំ ឥទំ វុច្ចតាវុសោ ជរាមរណំ ។ ជាតិសមុទយា ជរាមរណសមុទយោ ជាតិនិរោធា ជរាមរណនិរោធោ អយមេវ អរិយោ អដ្ឋង្គិកោ មគ្គោ ជរាមរណនិរោធគាមិនី បដិបទា សេយ្យថីទំ សម្មាទិដ្ឋិ ។ បេ ។

១ ឱ. ម. បរិបាក ។ ២ ឱ. ម. វលិត្តចតា ។ វលិត្តចតាតិ អដ្ឋកថា ទន្ទី ។ ៣ ឱ. ម. វុច្ចតាវុសោ ។ ៤ ឱ. ម. តិច ( កតមញ្ចាវុសោ មរណំ ) យំ ។ ៥ ឱ. ឥទំ វុច្ចតាវុសោ មរណំ ។



តើដូចម្តេច សេចក្តីប្រតិបត្តិ ជាដំណើរដើម្បីរលត់ជរានិងមរណៈតើដូចម្តេច ។ សេចក្តីគ្រាំគ្រាណា គឺសេចក្តីទ្រុឌទ្រោម ធ្មេញបាក់ សក់ស្កូវ ស្បែកជ្រួញ ជរាកាយ ចាស់ទុំឥន្ទ្រិយ របស់ពួកសត្វនោះ ៗ ក្នុងសត្តនិកាយនោះ ៗ នេះ ហៅថា ជរា ។ សេចក្តីឃ្លាតចាកសត្តនិកាយនោះ ៗ គឺច្យុតិ បែកធ្លាយ អន្តរធាន មច្ចុ មរណៈ កាលកិរិយា ការបែកធ្លាយនៃខន្ធទាំងឡាយ ការដាក់ចោលនូវសាកសព ការផ្តាច់បង់នូវជីវិតិន្ទ្រិយ នៃពួកសត្វនោះ ៗ នេះ ហៅថា មរណៈ ។ ម្នាលអាវុសោទាំងឡាយ ជរានេះផង មរណៈនេះផង ហៅថា ជរាមរណៈ ដោយប្រការដូច្នេះឯង ។ សេចក្តីកើតឡើងនៃជរានិងមរណៈ ព្រោះសេចក្តីកើតឡើងនៃជាតិ សេចក្តីរលត់ជរានិងមរណៈ ព្រោះសេចក្តីរលត់ជាតិ អរិយមគ្គប្រកបដោយអង្គ ៨ នេះឯង ជាសេចក្តីប្រតិបត្តិ ជាដំណើរដើម្បីរលត់ជរានិងមរណៈ អរិយមគ្គនោះគឺ សម្មាទិដ្ឋិ ។ បេ ។

សម្មាសមាធិ ។ យតោ ខោ អាវុសោ អរិយសាវកោ ឯវំ ជរាមរណំ បជានាតិ ឯវំ ជរាមរណសមុទយំ បជានាតិ ឯវំ ជរាមរណនិរោធំ បជានាតិ ឯវំ ជរាមរណនិរោធគាមិនិំ បដិបទំ បជានាតិ សោ សព្វសោ រាគានុសយំ បហាយ ។បេ។ ឯត្តាវតាបិ ខោ អាវុសោ អរិយសាវកោ សម្មាទិដ្ឋិ ហោតិ ឧជុគតាស្ស ទិដ្ឋិ ធម្មេ អវេច្ចប្បសាទេន សមន្នាគតោ អាគតោ ឥមំ សទ្ធម្មន្តិ ។

(១១៨) សិយា បនាវុសោ ។បេ។ សិយាវុសោតិ អាយស្មា សារីបុត្តោ អវោច យតោ ខោ អាវុសោ អរិយសាវកោ ជាតិញ្ច បជានាតិ ជាតិសមុទយញ្ច បជានាតិ ជាតិនិរោធញ្ច បជានាតិ ជាតិនិរោធគាមិនិំ បដិបទញ្ច បជានាតិ ឯត្តាវតាបិ ខោ អាវុសោ អរិយសាវកោ សម្មាទិដ្ឋិ ហោតិ ឧជុគតាស្ស ទិដ្ឋិ ធម្មេ អវេច្ចប្បសាទេន សមន្នាគតោ អាគតោ ឥមំ សទ្ធម្មន្តិ ។ កតមា បនាវុសោ



សម្មាសមាធិ ។ ម្នាលអាវុសោទាំងឡាយ កាលណាអរិយសាវក ដឹងច្បាស់នូវជរានិងមរណៈយ៉ាងនេះ ដឹងច្បាស់នូវសេចក្តីកើតឡើងនៃជរានិងមរណៈយ៉ាងនេះ ដឹងច្បាស់នូវសេចក្តីរលត់ជរានិងមរណៈយ៉ាងនេះ ដឹងច្បាស់នូវសេចក្តីប្រតិបត្តិ ជាដំណើរដើម្បីរលត់ជរានិងមរណៈយ៉ាងនេះ អរិយសាវកនោះ លះបង់នូវអនុស័យគឺរាគៈដោយសព្វគ្រប់ ក្នុងកាលនោះ ។បេ។ ម្នាលអាវុសោទាំងឡាយ អរិយសាវក ជាសម្មាទិដ្ឋិ មានទិដ្ឋិត្រង់ ប្រកបដោយសេចក្តីជ្រះថ្លា មិនញាប់ញ័រក្នុងព្រះធម៌ ហើយមកកាន់ព្រះសទ្ធម្មនេះ ដោយហេតុប៉ុណ្ណេះឯង ។

(១១៨) ភិក្ខុទាំងឡាយនិយាយថា ម្នាលអាវុសោ បរិយាយដទៃទៀត នៅមានដែរឬ ។បេ។ ព្រះសារីបុត្តដ៏មានអាយុឆ្លើយតបថា ម្នាលអាវុសោទាំងឡាយ មានដែរ ដូច្នេះហើយនិយាយថា ម្នាលអាវុសោទាំងឡាយ កាលណាអរិយសាវកស្គាល់ច្បាស់នូវជាតិផង ស្គាល់ច្បាស់នូវសេចក្តីកើតឡើងនៃជាតិផង ស្គាល់ច្បាស់នូវសេចក្តីរលត់ជាតិផង ស្គាល់ច្បាស់នូវសេចក្តីប្រតិបត្តិ ជាដំណើរដើម្បីរលត់ជាតិផង ម្នាលអាវុសោទាំងឡាយ អរិយសាវក ជាសម្មាទិដ្ឋិ ជាអ្នកមានទិដ្ឋិត្រង់ ប្រកបដោយសេចក្តីជ្រះថ្លា មិនញាប់ញ័រក្នុងព្រះធម៌ ហើយមកកាន់ព្រះសទ្ធម្មនេះ ដោយហេតុប៉ុណ្ណេះឯង ក្នុងកាលនោះ ។ ម្នាលអាវុសោទាំងឡាយ

ជាតិ កតមោ ជាតិសមុទយោ កតមោ ជាតិនិរោធោ
កតមា ជាតិនិរោធគាមិនី បដិបទាតិ ។ យា តេសំ
តេសំ សត្តានំ តម្ហិ តម្ហិ សត្តនិកាយេ ជាតិ សញ្ជាតិ
ឱក្កន្តិ និព្វត្តិ(១) អភិនិព្វត្តិ ខន្ធានំ បាតុភាវោ អា-
យតនានំ បដិលាភោ អយំ វុច្ចតាវុសោ ជាតិ ។
ភវសមុទយា ជាតិសមុទយោ ភវនិរោធា ជាតិនិរោធោ
អយមេវ អរិយោ អដ្ឋង្គិកោ មគ្គោ ជាតិនិរោធគា-
មិនី បដិបទា សេយ្យថីទំ សម្មាទិដ្ឋិ ។ បេ ។
សម្មាសមាធិ ។ យតោ ខោ អាវុសោ អរិយសាវកោ
ឯវំ ជាតឹ បជានាតិ ឯវំ ជាតិសមុទយំ បជានាតិ
ឯវំ ជាតិនិរោធំ បជានាតិ ឯវំ ជាតិនិរោធគាមិនឹ
បដិបទំ បជានាតិ សោ សព្វសោ រាគានុសយំ
បហាយ ។ បេ ។ ឯត្តាវតាបិ ខោ អាវុសោ អ-
រិយសាវកោ សម្មាទិដ្ឋិ ហោតិ ឧជុគតាស្ស ទិដ្ឋិ
ធម្មេ អវេច្ចប្បសាទេន សមន្នាគតោ អាគតោ ឥមំ
សទ្ធម្មន្តិ ។

១ ឱ. ម. និព្វត្តិ ន ទិស្សតិ ។





ជាតិតើដូចម្តេច សេចក្តីកើតឡើងនៃជាតិតើដូចម្តេច សេចក្តីរលត់ជាតិ
តើដូចម្តេច សេចក្តីប្រតិបត្តិ ជាដំណើរដើម្បីរលត់ជាតិ តើដូចម្តេច ។
កំណើតណា គឺសេចក្តីកើតគ្រប់គ្រាន់ ចាប់បដិសន្ធិ កកើត ស្រើស
ឡើង កើតប្រាកដជាគ្រឿងខន្ធឡើង ការបានចំពោះនូវអាយតនៈទាំងឡាយ
របស់ពួកសត្វនោះ ៗ ក្នុងសត្តនិកាយនោះ ៗ ម្នាលអាវុសោទាំងឡាយ
នេះ ហៅថា ជាតិ ។ សេចក្តីកើតឡើងនៃជាតិ ព្រោះសេចក្តីកើតឡើង
នៃភព សេចក្តីរលត់ជាតិ ព្រោះសេចក្តីរលត់ភព អរិយមគ្គប្រកបដោយ
អង្គ ៨ នេះឯង ឈ្មោះថាជាសេចក្តីប្រតិបត្តិ ជាដំណើរដើម្បីរលត់ជាតិ
អរិយមគ្គនោះគឺ សម្មាទិដ្ឋិ ។ បេ ។ សម្មាសមាធិ ។ ម្នាលអាវុសោ
ទាំងឡាយ កាលណាអរិយសាវ័កដឹងច្បាស់នូវជាតិយ៉ាងនេះ ដឹងច្បាស់
នូវសេចក្តីកើតឡើងនៃជាតិយ៉ាងនេះ ដឹងច្បាស់នូវសេចក្តីរលត់ជាតិយ៉ាង
នេះ ដឹងច្បាស់នូវសេចក្តីប្រតិបត្តិ ជាដំណើរដើម្បីរលត់ជាតិយ៉ាងនេះ
អរិយសាវ័កនោះ លះចោលអនុស័យគឺរាគៈដោយសព្វគ្រប់ក្នុងកាលនោះ
។ បេ ។ ម្នាលអាវុសោទាំងឡាយ អរិយសាវ័ក ជាសម្មាទិដ្ឋិ ជាអ្នកមាន
ទិដ្ឋិត្រង់ ប្រកបដោយសេចក្តីជ្រះថ្លា មិនញាប់ញ័រក្នុងធម៌ ហើយមកកាន់
ព្រះសទ្ធម្មនេះ ដោយហេតុប៉ុណ្ណេះឯង ។

(១១៩) សិយា បនាវុសោ បេ ។ សិយាវុសោតិ អាយស្មា សារីបុត្តោ អវោច យតោ ខោ អាវុសោ អរិយសាវកោ ភវញ្ច បជានាតិ ភវសមុទយញ្ច បជានាតិ ភវនិរោធញ្ច បជានាតិ ភវនិរោធគាមិនី បដិបទញ្ច បជានាតិ ឯត្តាវតាបិ ខោ អាវុសោ អរិយសាវកោ សម្មាទិដ្ឋិ ហោតិ ឧជុគតាស្ស ទិដ្ឋិ ធម្មេ អវេច្ចប្បសាទេន សមន្នាគតោ អាគតោ ឥមំ សទ្ធម្មន្តិ ។ កតមោ បនាវុសោ ភវោ កតមោ ភវសមុទយោ កតមោ ភវនិរោធោ កតមា ភវនិរោធគាមិនី បដិបទាតិ[១] ។ តយោមេ អាវុសោ ភវា កាមភវោ រូបភវោ អរូបភវោ ។ ជាតិសមុទយា ភវសមុទយោ ជាតិនិរោធា ភវនិរោធោ អយមេវ អរិយោ អដ្ឋង្គិកោ មគ្គោ ភវនិរោធគាមិនី បដិបទា សេយ្យថីទំ សម្មាទិដ្ឋិ ។ បេ ។ សម្មាសមាធិ ។ យតោ ខោ អាវុសោ អរិយសាវកោ ឯវំ ភវំ បជានាតិ

១ ឱ.ម. បដិបទា ។



(១១៩) ភិក្ខុទាំងឡាយនិយាយថា ម្នាលអាវុសោ បរិយាយឯទៀតនៅមានដែរឬ ។ បេ ។ ព្រះសារីបុត្រដ៏មានអាយុឆ្លើយតបថា ម្នាលអាវុសោទាំងឡាយ នៅមានដែរដូច្នេះ ហើយនិយាយថា ម្នាលអាវុសោទាំងឡាយ កាលណាអរិយសាវ័ក ដឹងច្បាស់នូវភពផង ដឹងច្បាស់នូវសេចក្ដីកើតឡើងនៃភពផង ដឹងច្បាស់នូវសេចក្ដីរលត់ភពផង ដឹងច្បាស់នូវសេចក្ដីប្រតិបត្តិ ជាដំណើរដើម្បីរលត់ភពផង ម្នាលអាវុសោទាំងឡាយ អរិយសាវ័ក ជាសម្មាទិដ្ឋិ ជាអ្នកមានទិដ្ឋិត្រង់ ប្រកបដោយសេចក្ដីជ្រះថ្លា មិនញាប់ញ័រក្នុងព្រះធម៌ ហើយមកកាន់ព្រះសទ្ធម្មនេះ ដោយហេតុប៉ុណ្ណោះឯង ក្នុងកាលនោះ ។ ម្នាលអាវុសោទាំងឡាយ ភពតើដូចម្ដេច សេចក្ដីប្រជុំកើតឡើងនៃភពតើដូចម្ដេច សេចក្ដីរលត់ភពតើដូចម្ដេច សេចក្ដីប្រតិបត្តិ ជាដំណើរដើម្បីរលត់ភពតើដូចម្ដេច ។ ម្នាលអាវុសោទាំងឡាយ ភពទាំងឡាយនេះមាន ៣ គឺ កាមភព១ រូបភព១ អរូបភព១ ។ សេចក្ដីកើតឡើងនៃភព ព្រោះសេចក្ដីកើតនៃជាតិ សេចក្ដីរលត់ភព ព្រោះសេចក្ដីរលត់ជាតិ អរិយមគ្គប្រកបដោយអង្គ ៨ នេះឯង ជាសេចក្ដីប្រតិបត្តិ ជាដំណើរ ដើម្បីរលត់ភព អរិយមគ្គនោះ គឺ សម្មាទិដ្ឋិ ។ បេ ។ សម្មាសមាធិ ។ ម្នាលអាវុសោទាំងឡាយ កាលណាអរិយសាវ័ក ដឹងច្បាស់នូវភពយ៉ាងនេះ

ឯវំ ភវសមុទយំ បជានាតិ ឯវំ ភវនិរោធំ បជានាតិ ឯវំ ភវនិរោធគាមិនឹ បដិបទំ បជានាតិ សោ សព្វសោ រាគានុសយំ បហាយ ។ បេ ។ ឯត្តាវតាបិ ខោ អាវុសោ អរិយសាវកោ សម្មាទិដ្ឋិ ហោតិ ឧជុគតាស្ស ទិដ្ឋិ ធម្មេ អវេច្ចប្បសាទេន សមន្នាគតោ អាគតោ ឥមំ សទ្ធម្មន្តិ ។

(១២០) សិយា បនាវុសោ ។ បេ ។ សិយាវុសោតិ អាយស្មា សារីបុត្តោ អវោច យតោ ខោ អាវុសោ អរិយសាវកោ ឧបាទានញ្ច បជានាតិ ឧបាទានសមុទយញ្ច បជានាតិ ឧបាទាននិរោធញ្ច បជានាតិ ឧបាទាននិរោធគាមិនឹ បដិបទញ្ច បជានាតិ ឯត្តាវតាបិ ខោ អាវុសោ អរិយសាវកោ សម្មាទិដ្ឋិ ហោតិ ឧជុគតាស្ស ទិដ្ឋិ ធម្មេ អវេច្ចប្បសាទេន សមន្នាគតោ អាគតោ ឥមំ សទ្ធម្មន្តិ ។ កតមំ បនាវុសោ ឧបាទានំ កតមោ ឧបាទានសមុទយោ



ដឹងច្បាស់នូវសេចក្តីកើតឡើងនៃភពយ៉ាងនេះ ដឹងច្បាស់នូវសេចក្តីរលត់ភពយ៉ាងនេះ ដឹងច្បាស់នូវសេចក្តីប្រតិបត្តិ ដំណើរដើម្បីរលត់ភពយ៉ាងនេះ អរិយសាវកនោះ លះបង់អនុស័យគឺរាគៈដោយសព្វគ្រប់ ។ បេ ។ ម្នាលអាវុសោទាំងឡាយ អរិយសាវក ជាសម្មាទិដ្ឋិ ជាអ្នកមានទិដ្ឋិត្រង់ ប្រកបដោយសេចក្តីជ្រះថ្លា មិនញាប់ញ័រ ក្នុងព្រះធម៌ ហើយមកកាន់ព្រះសទ្ធម្មនេះ ដោយហេតុប៉ុណ្ណោះឯង ក្នុងកាលនោះ ។

(១២០) ភិក្ខុទាំងឡាយនិយាយថា ម្នាលអាវុសោ បរិយាយឯទៀតនៅមានដែរឬ ។ បេ ។ ព្រះសារីបុត្រមានអាយុឆ្លើយតបថា ម្នាលអាវុសោទាំងឡាយ នៅមានដែរ ដូច្នេះហើយនិយាយថា ម្នាលអាវុសោទាំងឡាយ កាលណាអរិយសាវក ដឹងច្បាស់នូវឧបាទានផង ដឹងច្បាស់នូវសេចក្តីកើតឡើងនៃឧបាទានផង ដឹងច្បាស់នូវសេចក្តីរលត់ឧបាទានផង ដឹងច្បាស់នូវសេចក្តីប្រតិបត្តិ ដំណើរដើម្បីរលត់ឧបាទានផង ម្នាលអាវុសោទាំងឡាយ អរិយសាវក ជាសម្មាទិដ្ឋិ ជាអ្នកមានទិដ្ឋិត្រង់ ប្រកបដោយសេចក្តីជ្រះថ្លា មិនញាប់ញ័រក្នុងព្រះធម៌ ហើយមកកាន់ព្រះសទ្ធម្មនេះដោយហេតុប៉ុណ្ណោះឯង ក្នុងកាលនោះ ។ ម្នាលអាវុសោទាំងឡាយ ឧបាទានដូចម្តេច សេចក្តីកើតឡើងនៃឧបាទានកើតដូចម្តេច

កតមោ ឧបាទាននិរោធោ កតមា ឧបាទាននិរោធគាមិនី បដិបទា ។ ចត្តារិមានិ អាវុសោ ឧបាទានានិ(១) កាមុបាទានំ ទិដ្ឋុបាទានំ សីលព្វតុបាទានំ អត្តវាទុបាទានំ ។ តណ្ហាសមុទយា ឧបាទានសមុទយោ តណ្ហានិរោធា ឧបាទាននិរោធោ អយមេវ អរិយោ អដ្ឋង្គិកោ មគ្គោ ឧបាទាននិរោធគាមិនី បដិបទា សេយ្យថីទំ សម្មាទិដ្ឋិ ។ បេ ។ សម្មាសមាធិ ។ យតោ ខោ អាវុសោ អរិយសាវកោ ឯវំ ឧបាទានំ បជានាតិ ឯវំ ឧបាទានសមុទយំ បជានាតិ ឯវំ ឧបាទាននិរោធំ បជានាតិ ឯវំ ឧបាទាននិរោធគាមិនឹ បដិបទំ បជានាតិ សោ សព្វសោ រាគានុសយំ បហាយ ។ បេ ។ ឯត្តាវតាបិ ខោ អាវុសោ អរិយសាវកោ សម្មាទិដ្ឋិ ហោតិ ឧជុគតាស្ស ទិដ្ឋិ ធម្មេ អវេច្ចប្បសាទេន សមន្នាគតោ អាគតោ ឥមំ សទ្ធម្មន្តិ ។

១ ឱ. ចត្តារោមេ អាវុសោ ឧបាទានា ។



សេចក្តីរលត់ឧបាទានតើដូចម្តេច សេចក្តីប្រតិបត្តិ ជាដំណើរ ដើម្បីរលត់ឧបាទានតើដូចម្តេច ។ ម្នាលអាវុសោទាំងឡាយ ឧបាទាននេះ មាន៤ គឺ កាមុបាទាន១ ទិដ្ឋុបាទាន១ សីលព្វតុបាទាន១ អត្តវាទុបាទាន១ ។ សេចក្តីកើតឡើងនៃឧបាទាន ព្រោះសេចក្តីកើតឡើងនៃតណ្ហា សេចក្តីរលត់ឧបាទាន ព្រោះសេចក្តីរលត់តណ្ហា អរិយមគ្គប្រកបដោយអង្គ ៨ នេះឯង ជាសេចក្តីប្រតិបត្តិ ជាដំណើរ ដើម្បីរលត់ឧបាទាន អរិយមគ្គនោះគឺ សម្មាទិដ្ឋិ ។ បេ ។ សម្មាសមាធិ ។ ម្នាលអាវុសោទាំងឡាយ កាលណាអរិយសាវ័ក ដឹងច្បាស់នូវឧបាទានយ៉ាងនេះ ដឹងច្បាស់នូវសេចក្តីកើតឡើងនៃឧបាទានយ៉ាងនេះ ដឹងច្បាស់នូវសេចក្តីរលត់ឧបាទានយ៉ាងនេះ ដឹងច្បាស់នូវសេចក្តីប្រតិបត្តិ ជាដំណើរ ដើម្បីរលត់ឧបាទានយ៉ាងនេះ អរិយសាវ័កនោះ លះបង់នូវអនុស័យគឺរាគៈដោយប្រការទាំងពួង ។ បេ ។ ម្នាលអាវុសោទាំងឡាយ អរិយសាវ័ក ជាសម្មាទិដ្ឋិ ជាអ្នកមានទិដ្ឋិត្រង់ ប្រកបដោយសេចក្តីជ្រះថ្លា មិនញាប់ញ័រ ក្នុងព្រះធម៌ ហើយមកកាន់ព្រះសទ្ធម្មនេះ ដោយហេតុប៉ុណ្ណោះឯង ក្នុងកាលនោះ ។

(១៦១) សិយា បនាវុសោ ។ បេ ។ សិយាវុសោតិ អាយស្មា សារីបុត្តោ អវោច យតោ ខោ អាវុសោ អរិយសាវកោ តណ្ហញ្ច បជានាតិ តណ្ហាសមុទយញ្ច បជានាតិ តណ្ហានិរោធញ្ច បជានាតិ តណ្ហានិរោធគាមិនឹ បដិបទញ្ច បជានាតិ ឯត្តាវតាបិ ខោ អាវុសោ អរិយសាវកោ សម្មាទិដ្ឋិ ហោតិ ឧជុគតាស្ស ទិដ្ឋិ ធម្មេ អវេច្ចប្បសាទេន សមន្នាគតោ អាគតោ ឥមំ សទ្ធម្មន្តិ ។ កតមា បនាវុសោ តណ្ហា កតមោ តណ្ហាសមុទយោ កតមោ តណ្ហានិរោធោ កតមា តណ្ហានិរោធគាមិនី បដិបទាតិ ។ ឆយិមេ អាវុសោ តណ្ហាកាយា រូបតណ្ហា សទ្ទតណ្ហា គន្ធតណ្ហា រសតណ្ហា ផោដ្ឋព្វតណ្ហា ធម្មតណ្ហា ។ វេទនាសមុទយា តណ្ហាសមុទយោ វេទនានិរោធា តណ្ហានិរោធោ អយមេវ អរិយោ អដ្ឋង្គិកោ មគ្គោ តណ្ហានិរោធគាមិនី បដិបទា សេយ្យថីទំ



(១៦១) ភិក្ខុទាំងឡាយនិយាយថា ម្នាលអាវុសោ បរិយាយឯទៀតនៅមានដែរឬ ។ បេ ។ ព្រះសារីបុត្រមានអាយុ ឆ្លើយតបថា ម្នាលអាវុសោទាំងឡាយ នៅមានដែរ ហើយនិយាយថា ម្នាលអាវុសោទាំងឡាយ កាលណាអរិយសាវកដឹងច្បាស់នូវតណ្ហាផង ដឹងច្បាស់នូវសេចក្តីកើតឡើងនៃតណ្ហាផង ដឹងច្បាស់នូវសេចក្តីរលត់តណ្ហាផង ដឹងច្បាស់នូវសេចក្តីប្រតិបត្តិ ជាដំណើរដើម្បីរលត់តណ្ហាផង ម្នាលអាវុសោទាំងឡាយ អរិយសាវក ជាសម្មាទិដ្ឋិ ជាអ្នកមានទិដ្ឋិត្រង់ ប្រកបដោយសេចក្តីជ្រះថ្លា មិនញាប់ញ័រក្នុងព្រះធម៌ ហើយមកកាន់ព្រះសទ្ធម្មនេះ ដោយហេតុប៉ុណ្ណេះឯង ក្នុងកាលនោះ ។ ម្នាលអាវុសោទាំងឡាយ តណ្ហាតើដូចម្តេច សេចក្តីកើតឡើងនៃតណ្ហាតើដូចម្តេច សេចក្តីរលត់តណ្ហាតើដូចម្តេច សេចក្តីប្រតិបត្តិ ជាដំណើរ ដើម្បីរលត់តណ្ហាតើដូចម្តេច ។ ម្នាលអាវុសោទាំងឡាយ ពួកតណ្ហានេះមាន ៦ គឺ សេចក្តីប្រាថ្នាក្នុងរូប ១ ប្រាថ្នាក្នុងសំឡេង ១ ប្រាថ្នាក្នុងក្លិន ១ ប្រាថ្នាក្នុងរស ១ ប្រាថ្នាក្នុងការពាល់ត្រូវ ១ ប្រាថ្នាក្នុងធម្មារម្មណ៍គឺអារម្មណ៍ ដែលខ្លួនធ្លាប់សន្សំទុកមកក្នុងចិត្ត ១ ។ សេចក្តីកើតឡើងនៃតណ្ហា ព្រោះសេចក្តីកើតឡើងនៃវេទនា សេចក្តីរលត់តណ្ហា ព្រោះសេចក្តីរលត់វេទនា អរិយមគ្គ ប្រកបដោយអង្គ ៨ នេះឯង ជាសេចក្តីប្រតិបត្តិ ជាដំណើរ ដើម្បីរលត់តណ្ហា

សម្មាទិដ្ឋិ ។ បេ ។ សម្មាសមាធិ ។ យតោ ខោ អាវុសោ អរិយសាវកោ ឯវំ តណ្ហំ បជានាតិ ឯវំ តណ្ហាសមុទយំ បជានាតិ ឯវំ តណ្ហានិរោធំ បជានាតិ ឯវំ តណ្ហានិរោធគាមិនឹ បដិបទំ បជានាតិ សោ សព្វសោ រាគានុសយំ បហាយ ។ បេ ។ ឯត្តាវតាបិ ខោ អាវុសោ អរិយសាវកោ សម្មាទិដ្ឋិ ហោតិ ឧជុគតាស្ស ទិដ្ឋិ ធម្មេ អវេច្ចប្បសាទេន សមន្នាគតោ អាគតោ ឥមំ សទ្ធម្មន្តិ ។

(១៦៦) សិយា បនាវុសោ ។ បេ ។ សិយាវុសោតិ អាយស្មា សារីបុត្តោ អវោច យតោ ខោ អាវុសោ អរិយសាវកោ វេទនញ្ច បជានាតិ វេទនាសមុទយញ្ច បជានាតិ វេទនានិរោធញ្ច បជានាតិ វេទនានិរោធគាមិនិញ្ច បដិបទំ បជានាតិ ឯត្តាវតាបិ ខោ អាវុសោ អរិយសាវកោ សម្មាទិដ្ឋិ ហោតិ ឧជុគតាស្ស ទិដ្ឋិ ធម្មេ អវេច្ចប្បសាទេន សមន្នាគតោ អាគតោ ឥមំ សទ្ធម្មន្តិ ។



អរិយមគ្គនោះគឺ សម្មាទិដ្ឋិ ។ បេ ។ សម្មាសមាធិ ។ ម្នាលអាវុសោទាំងឡាយ កាលណា អរិយសាវ័ក ដឹងច្បាស់នូវតណ្ហាយ៉ាងនេះ ដឹងច្បាស់នូវសេចក្តីកើតឡើងនៃតណ្ហាយ៉ាងនេះ ដឹងច្បាស់នូវសេចក្តីរលត់តណ្ហាយ៉ាងនេះ ដឹងច្បាស់នូវសេចក្តីប្រតិបត្តិ ជាដំណើរ ដើម្បីរលត់តណ្ហាយ៉ាងនេះ អរិយសាវ័កនោះ លះបង់អនុស័យគឺរាគៈដោយសព្វគ្រប់ ។ បេ ។ ម្នាលអាវុសោទាំងឡាយ អរិយសាវ័ក ជាសម្មាទិដ្ឋិ ជាអ្នកមានទិដ្ឋិត្រង់ ប្រកបដោយសេចក្តីជ្រះថ្លា មិនញាប់ញ័រ ក្នុងព្រះធម៌ ហើយមកកាន់ព្រះសទ្ធម្មនេះ ដោយហេតុប៉ុណ្ណេះឯង ក្នុងកាលនោះ ។

(១៦៦) ភិក្ខុទាំងឡាយ និយាយថា ម្នាលអាវុសោ បរិយាយឯទៀតនៅមានដែរឬ ។ បេ ។ ព្រះសារីបុត្រមានអាយុ ឆ្លើយតបថា ម្នាលអាវុសោទាំងឡាយ នៅមានដែរ ហើយនិយាយថា ម្នាលអាវុសោទាំងឡាយ កាលណាអរិយសាវ័ក ដឹងច្បាស់នូវវេទនាផង ដឹងច្បាស់នូវសេចក្តីកើតឡើងនៃវេទនាផង ដឹងច្បាស់នូវសេចក្តីរលត់វេទនាផង ដឹងច្បាស់នូវសេចក្តីប្រតិបត្តិ ជាដំណើរ ដើម្បីរលត់វេទនាផង ម្នាលអាវុសោទាំងឡាយ អរិយសាវ័ក ជាសម្មាទិដ្ឋិ ជាអ្នកមានទិដ្ឋិត្រង់ ប្រកបដោយសេចក្តីជ្រះថ្លា មិនញាប់ញ័រ ក្នុងព្រះធម៌ ហើយមកកាន់ព្រះសទ្ធម្មនេះ ដោយហេតុប៉ុណ្ណេះឯង ក្នុងកាលនោះ ។

កតមា បនាវុសោ វេទនា កតមោ វេទនាសមុទយោ កតមោ វេទនានិរោធោ កតមា វេទនានិរោធគាមិនី បដិបទា ។ ឆយិមេ អាវុសោ វេទនាកាយា ចក្ខុសម្ផស្សជា វេទនា សោតសម្ផស្សជា វេទនា ឃានសម្ផស្សជា វេទនា ជិវ្ហាសម្ផស្សជា វេទនា កាយសម្ផស្សជា វេទនា មនោសម្ផស្សជា វេទនា ។ ផស្សសមុទយា វេទនាសមុទយោ ផស្សនិរោធា វេទនានិរោធោ អយមេវ អរិយោ អដ្ឋង្គិកោ មគ្គោ វេទនានិរោធគាមិនី បដិបទា សេយ្យថីទំ សម្មាទិដ្ឋិ ។ បេ ។ សម្មាសមាធិ ។ យតោ ខោ អាវុសោ អរិយសាវកោ ឯវំ វេទនំ បជានាតិ ឯវំ វេទនាសមុទយំ បជានាតិ ឯវំ វេទនានិរោធំ បជានាតិ ឯវំ វេទនានិរោធគាមិនឹ បដិបទំ បជានាតិ សោ សព្វសោ រាគានុសយំ បហាយ ។ បេ ។ ឯត្តាវតាបិ ខោ អាវុសោ



ម្នាលអាវុសោទាំងឡាយ វេទនាតើដូចម្តេច សេចក្តីកើតឡើងនៃវេទនាតើដូចម្តេច សេចក្តីរលត់វេទនាតើដូចម្តេច សេចក្តីប្រតិបត្តិជាដំណើរដើម្បីរលត់វេទនាតើដូចម្តេច ។ ម្នាលអាវុសោទាំងឡាយ ពួកវេទនានេះមាន ៦ គឺ វេទនាកើតអំពីការពាល់ត្រូវដោយភ្នែក ១ វេទនាកើតអំពីការពាល់ត្រូវដោយត្រចៀក ១ វេទនាកើតអំពីការពាល់ត្រូវដោយច្រមុះ១ វេទនាកើតអំពីការពាល់ត្រូវដោយអណ្តាត១ វេទនាកើតអំពីការពាល់ត្រូវដោយកាយ ១ វេទនាកើតអំពីការពាល់ត្រូវដោយចិត្ត ១ ។ សេចក្តីកើតឡើងនៃវេទនា ព្រោះសេចក្តីកើតឡើងនៃផស្សៈ សេចក្តីរលត់វេទនា ព្រោះសេចក្តីរលត់ផស្សៈ អរិយមគ្គប្រកបដោយអង្គ ៨ នេះឯង ជាសេចក្តីប្រតិបត្តិជាដំណើរដើម្បីរលត់វេទនា អរិយមគ្គនោះគឺ សម្មាទិដ្ឋិ ។ បេ ។ សម្មាសមាធិ ។ ម្នាលអាវុសោទាំងឡាយ កាលណាអរិយសាវក ដឹងច្បាស់នូវវេទនាយ៉ាងនេះ ដឹងច្បាស់នូវសេចក្តីកើតឡើងនៃវេទនាយ៉ាងនេះ ដឹងច្បាស់នូវសេចក្តីរលត់វេទនាយ៉ាងនេះ ដឹងច្បាស់នូវសេចក្តីប្រតិបត្តិ ជាដំណើរ ដើម្បីរលត់វេទនាយ៉ាងនេះ អរិយសាវកនោះលះចោលអនុស័យគឺរាគៈដោយសព្វគ្រប់ ។ បេ ។ ម្នាលអាវុសោទាំងឡាយ

អរិយសាវកោ សម្មាទិដ្ឋិ ហោតិ ឧជុគតាស្ស ទិដ្ឋិ ធម្មេ អវេច្ចប្បសាទេន សមន្នាគតោ អាគតោ ឥមំ សទ្ធម្មន្តិ ។

(១៦៣) សិយា បនាវុសោ ។ បេ ។ សិយាវុ-សោតិ អាយស្មា សារីបុត្តោ អវោច យតោ ខោ អាវុសោ អរិយសាវកោ ផស្សញ្ច បជានាតិ ផស្ស-សមុទយញ្ច បជានាតិ ផស្សនិរោធញ្ច បជានាតិ ផស្សនិរោធគាមិនឹ បដិបទញ្ច បជានាតិ ឯត្តាវតាបិ ខោ អាវុសោ អរិយសាវកោ សម្មាទិដ្ឋិ ហោតិ ឧជុគតាស្ស ទិដ្ឋិ ធម្មេ អវេច្ចប្បសាទេន សមន្នាគតោ អាគតោ ឥមំ សទ្ធម្មន្តិ ។ កតមោ បនាវុសោ ផស្សោ កតមោ ផស្សសមុទយោ កតមោ ផស្សនិរោធោ កតមា ផស្សនិរោធគាមិនី បដិបទា ។ ឆយិមេ អាវុសោ ផស្សកាយា ចក្ខុសម្ផស្សោ សោតសម្ផស្សោ



អរិយសាវកជា សម្មាទិដ្ឋិ ជាអ្នកមានទិដ្ឋិត្រង់ ប្រកបដោយសេចក្តីជ្រះថ្លា មិនញាប់ញ័រក្នុងព្រះធម៌ ហើយមកកាន់ព្រះសទ្ធម្មនេះ ដោយហេតុប៉ុណ្ណេះឯង ក្នុងកាលនោះ ។

(១៦៣) ភិក្ខុទាំងឡាយ និយាយថា ម្នាលអាវុសោ បរិយាយឯទៀតនៅមានដែរឬ ។ បេ ។ ព្រះសារីបុត្រមានអាយុ ឆ្លើយតបថា ម្នាលអាវុសោទាំងឡាយ នៅមានដែរ ហើយនិយាយថា ម្នាលអាវុសោទាំងឡាយ កាលណា អរិយសាវក ដឹងច្បាស់នូវផស្សៈផង ដឹងច្បាស់នូវសេចក្តីកើតឡើង នៃផស្សៈផង ដឹងច្បាស់នូវសេចក្តីរលត់ផស្សៈផង ដឹងច្បាស់នូវសេចក្តីប្រតិបត្តិ ជាដំណើរដើម្បីរលត់ផស្សៈផង ក្នុងកាលណាហើយ ម្នាលអាវុសោទាំងឡាយ អរិយសាវក ជាសម្មា-ទិដ្ឋិ ជាអ្នកមានទិដ្ឋិត្រង់ ប្រកបដោយសេចក្តីជ្រះថ្លា មិនញាប់ញ័រក្នុងព្រះធម៌ ហើយមកកាន់ព្រះសទ្ធម្មនេះ ដោយហេតុប៉ុណ្ណេះឯង ក្នុងកាលនោះ ។ ម្នាលអាវុសោទាំងឡាយ ផស្សៈតើដូចម្តេច សេចក្តីកើតឡើងនៃផស្សៈតើដូចម្តេច សេចក្តីរលត់ផស្សៈតើដូចម្តេច សេចក្តីប្រតិបត្តិ ជាដំណើរ ដើម្បីរលត់ផស្សៈតើដូចម្តេច ។ ម្នាលអាវុសោទាំងឡាយ ពួកផស្សៈនេះមាន ៦ គឺ ចក្ខុសម្ផស្ស ១ សោតសម្ផស្ស ១

ឃានសម្ផស្សោ ជិវ្ហាសម្ផស្សោ កាយសម្ផស្សោ ម-
នោសម្ផស្សោ ។ សឡាយតនសមុទយា ផស្សសមុ-
ទយោ សឡាយតននិរោធា ផស្សនិរោធោ អយមេវ
អរិយោ អដ្ឋង្គិកោ មគ្គោ ផស្សនិរោធគាមិនី បដិបទា
សេយ្យថីទំ សម្មាទិដ្ឋិ ។ បេ ។ សម្មាសមាធិ ។
យតោ ខោ អាវុសោ អរិយសាវកោ ឯវំ ផស្សំ
បជានាតិ ឯវំ ផស្សសមុទយំ បជានាតិ ឯវំ ផស្ស-
និរោធំ បជានាតិ ឯវំ ផស្សនិរោធគាមិនី បដិបទំ
បជានាតិ សោ សព្វសោ រាគានុសយំ បហាយ
។ បេ ។ ឯត្តាវតាបិ ខោ អាវុសោ អរិយសាវកោ
សម្មាទិដ្ឋិ ហោតិ ឧជុគតាស្ស ទិដ្ឋិ ធម្មេ អវេច្ចប្ប-
សាទេន សមន្នាគតោ អាគតោ ឥមំ សទ្ធម្មន្តិ ។

(១២៦) សិយា បនាវុសោ ។ បេ ។ សិយាវុសោ-
តិ អាយស្មា សារីបុត្តោ អវោច យតោ ខោ អាវុសោ



ឃានសម្ផស្ស ១ ជិវ្ហាសម្ផស្ស ១ កាយសម្ផស្ស ១ មនោសម្ផស្ស ១ ។
សេចក្តីកើតឡើងនៃផស្សៈ ព្រោះសេចក្តីកើតឡើងនៃអាយតនៈ៦ សេចក្តី
រលត់ផស្សៈ ព្រោះសេចក្តីរលត់អាយតនៈ៦ អរិយមគ្គ ប្រកបដោយ
អង្គ៨នេះឯង ជាសេចក្តីប្រតិបត្តិ ជាដំណើរ ដើម្បីរលត់ផស្សៈ អរិយមគ្គ
នោះគឺ សម្មាទិដ្ឋិ ។ បេ ។ សម្មាសមាធិ ។ ម្នាលអាវុសោទាំងឡាយ
កាលណាអរិយសាវ័ក ដឹងច្បាស់នូវផស្សៈយ៉ាងនេះ ដឹងច្បាស់នូវសេចក្តី
កើតឡើងនៃផស្សៈយ៉ាងនេះ ដឹងច្បាស់នូវសេចក្តីរលត់ផស្សៈយ៉ាងនេះ
ដឹងច្បាស់នូវសេចក្តីប្រតិបត្តិ ជាដំណើរដើម្បីរលត់ផស្សៈយ៉ាងនេះ អរិយ-
សាវ័កនោះ លះរាគានុស័យ ដោយសព្វគ្រប់ ។ បេ ។ ម្នាល
អាវុសោទាំងឡាយ អរិយសាវ័ក ជាសម្មាទិដ្ឋិ ជាអ្នកមានទិដ្ឋិត្រង់ ប្រកប
ដោយសេចក្តីជ្រះថ្លា មិនញាប់ញ័រក្នុងព្រះធម៌ ហើយមកកាន់ព្រះសទ្ធម្ម
នេះ ដោយហេតុប៉ុណ្ណោះឯង ក្នុងកាលនោះ ។

(១២៦) ភិក្ខុទាំងឡាយ និយាយថា ម្នាលអាវុសោ បរិ-
យាយឯទៀត នៅមានដែរឬ ។ បេ ។ ព្រះសារីបុត្រមានអាយុ
ឆ្លើយតបថា ម្នាលអាវុសោទាំងឡាយ នៅមានដែរ ជួនះហើយ
និយាយ (តទៅទៀត) ថា ម្នាលអាវុសោទាំងឡាយ កាលណា

អរិយសាវកោ សឡាយតនញ្ច បជានាតិ សឡាយតនសមុទយញ្ច បជានាតិ សឡាយតននិរោធញ្ច បជានាតិ សឡាយតននិរោធគាមិនិំ បដិបទញ្ច បជានាតិ ឯត្តាវតាបិ ខោ អាវុសោ អរិយសាវកោ សម្មាទិដ្ឋិ ហោតិ ឧជុគតាស្ស ទិដ្ឋិ ធម្មេ អវេច្ចប្បសាទេន សមន្នាគតោ អាគតោ ឥមំ សទ្ធម្មន្តិ ។ កតមំ បនាវុសោ សឡាយតនំ កតមោ សឡាយតនសមុទយោ កតមោ សឡាយតននិរោធោ កតមា សឡាយតននិរោធគាមិនី បដិបទាតិ ។ ឆយិមានិ អាវុសោ អាយតនានិ ចក្ខាយតនំ(១) សោតាយតនំ ឃានាយតនំ ជិវ្ហាយតនំ កាយាយតនំ មនាយតនំ ។ នាមរូបសមុទយា សឡាយតនសមុទយោ នាមរូបនិរោធា សឡាយតននិរោធោ អយមេវ អរិយោ អដ្ឋង្គិកោ មគ្គោ សឡាយតននិរោធគាមិនី បដិបទា សេយ្យថីទំ សម្មាទិដ្ឋិ ។ បេ ។ សម្មាសមាធិ ។ យតោ ខោ អាវុសោ អរិយសាវកោ

១ ម. ចក្ខាយតនំ ។



អរិយសាវក ដឹងច្បាស់នូវអាយតនៈ ៦ ផង ដឹងច្បាស់នូវសេចក្តីកើតឡើងនៃអាយតនៈ ៦ ផង ដឹងច្បាស់នូវសេចក្តីរលត់អាយតនៈ ៦ ផង ដឹងច្បាស់នូវសេចក្តីប្រតិបត្តិ ជាដំណើរ ដើម្បីរលត់អាយតនៈ ៦ ផង ម្នាលអាវុសោទាំងឡាយ អរិយសាវក ជាសម្មាទិដ្ឋិ ជាអ្នកមានទិដ្ឋិត្រង់ ប្រកបដោយសេចក្តីជ្រះថ្លា មិនញាប់ញ័រក្នុងព្រះធម៌ ហើយមកកាន់ព្រះសទ្ធម្មនេះ ដោយហេតុប៉ុណ្ណេះឯង ក្នុងកាលនោះ ។ ម្នាលអាវុសោទាំងឡាយ អាយតនៈ ៦ តើដូចម្តេច សេចក្តីកើតឡើងនៃអាយតនៈ ៦ តើដូចម្តេច សេចក្តីរលត់អាយតនៈ ៦ តើដូចម្តេច សេចក្តីប្រតិបត្តិ ជាដំណើរ ដើម្បីរលត់អាយតនៈ៦តើដូចម្តេច ។ ម្នាលអាវុសោទាំងឡាយ អាយតនៈ(១) នេះមាន ៦ គឺចក្ខាយតនៈ១ សោតាយតនៈ១ ឃានាយតនៈ១ ជិវ្ហាយតនៈ១ កាយាយតនៈ១ មនាយតនៈ១ ។ សេចក្តីកើតឡើងនៃអាយតនៈ ៦ បាន ព្រោះសេចក្តីកើតឡើងនៃនាមរូប សេចក្តីរលត់អាយតនៈ៦បាន ព្រោះសេចក្តីរលត់នាមរូប អរិយមគ្គប្រកបដោយអង្គ៨នេះឯង ជាសេចក្តីប្រតិបត្តិ ជាដំណើរ ដើម្បីរលត់អាយតនៈ ៦ អរិយមគ្គនោះគឺ សម្មាទិដ្ឋិ ។ បេ ។ សម្មាសមាធិ ។ ម្នាលអាវុសោទាំងឡាយ កាលណាអរិយសាវក

ឯវំ សឡាយតនំ បជានាតិ ឯវំ សឡាយតនសមុទយំ បជានាតិ ឯវំ សឡាយតននិរោធំ បជានាតិ ឯវំ សឡាយតននិរោធគាមិនឹ បដិបទំ បជានាតិ សោ សព្វសោ រាគានុសយំ បហាយ ។ បេ ។ ឯត្តាវតាបិ ខោ អាវុសោ អរិយសាវកោ សម្មាទិដ្ឋិ ហោតិ ឧជុគតាស្ស ទិដ្ឋិ ធម្មេ អវេច្ចប្បសាទេន សមន្នាគតោ អាគតោ ឥមំ សទ្ធម្មន្តិ ។

(១២៨) សិយា បនាវុសោ ។ បេ ។ សិយាវុសោតិ អាយស្មា សារីបុត្តោ អវោច យតោ ខោ អាវុសោ អរិយសាវកោ នាមរូបញ្ច បជានាតិ នាមរូបសមុទយញ្ច បជានាតិ នាមរូបនិរោធញ្ច បជានាតិ នាមរូបនិរោធគាមិនឹ បដិបទញ្ច បជានាតិ ឯត្តាវតាបិ ខោ អាវុសោ អរិយសាវកោ សម្មាទិដ្ឋិ ហោតិ ឧជុគតាស្ស ទិដ្ឋិ ធម្មេ អវេច្ចប្បសាទេន សមន្នាគតោ អាគតោ ឥមំ សទ្ធម្មន្តិ ។ កតមំ បនាវុសោ នាមរូបំ



ដឹងច្បាស់នូវអាយតនៈ៦ យ៉ាងនេះ ដឹងច្បាស់នូវសេចក្ដីកើតឡើងនៃអាយតនៈ៦ យ៉ាងនេះ ដឹងច្បាស់នូវសេចក្ដីរលត់អាយតនៈ ៦ យ៉ាងនេះ ដឹងច្បាស់នូវសេចក្ដីប្រតិបត្តិ ជាដំណើរដើម្បីរលត់អាយតនៈ ៦ យ៉ាងនេះ អរិយសាវកនោះ លះបង់អនុស័យគឺរាគៈ ដោយសព្វគ្រប់ ។ បេ ។ ម្នាលអាវុសោទាំងឡាយ អរិយសាវក ជាសម្មាទិដ្ឋិ ជាអ្នកមានទិដ្ឋិត្រង់ ប្រកបដោយសេចក្ដីជ្រះថ្លា មិនញាប់ញ័រក្នុងព្រះធម៌ ហើយមកកាន់ព្រះសទ្ធម្មនេះ ដោយហេតុប៉ុណ្ណេះឯង ក្នុងកាលនោះ ។

(១២៨) ភិក្ខុទាំងឡាយនិយាយថា ម្នាលអាវុសោ ហេតុឯទៀតនៅមានដែរឬ ។ បេ ។ ព្រះសារីបុត្តមានអាយុ ឆ្លើយថា ម្នាលអាវុសោទាំងឡាយ ហេតុមានដែរ ព្រោះហេតុនោះ ម្នាលអាវុសោទាំងឡាយ កាលណាអរិយសាវក ដឹងច្បាស់នូវនាមរូបផង ដឹងច្បាស់នូវសេចក្ដីកើតឡើងនៃនាមរូបផង ដឹងច្បាស់នូវសេចក្ដីរលត់នាមរូបផង ដឹងច្បាស់នូវសេចក្ដីប្រតិបត្តិ ជាដំណើរដើម្បីរលត់នាមរូបផង ម្នាលអាវុសោទាំងឡាយ អរិយសាវកជាសម្មាទិដ្ឋិ ជាអ្នកមានទិដ្ឋិត្រង់ ប្រកបដោយសេចក្ដីជ្រះថ្លា មិនញាប់ញ័រក្នុងព្រះធម៌ ហើយមកកាន់ព្រះសទ្ធម្មនេះ ដោយហេតុប៉ុណ្ណេះឯង ក្នុងកាលនោះ ។ ម្នាលអាវុសោទាំងឡាយ

កតមោ នាមរូបសមុទយោ កតមោ នាមរូបនិរោធោ កតមា នាមរូបនិរោធគាមិនី បដិបទា ។ វេទនា សញ្ញា ចេតនា ផស្សោ មនសិការោ ឥទំ វុច្ចតិ[១] នាមំ ។ ចត្តារិ ច មហាភូតានិ ចតុន្នញ្ច មហាភូតានំ ឧបាទាយ រូបំ ឥទំ វុច្ចតិ[២] រូបំ ។ ឥតិ ឥទញ្ច នាមំ ឥទញ្ច រូបំ ឥទំ វុច្ចតាវុសោ នាមរូបំ ។ វិញ្ញាណសមុទយា នាមរូបសមុទយោ វិញ្ញាណនិរោធា នាមរូបនិរោធោ អយមេវ អរិយោ អដ្ឋង្គិកោ មគ្គោ នាមរូបនិរោធគាមិនី បដិបទា សេយ្យថីទំ សម្មាទិដ្ឋិ ។ បេ ។ សម្មាសមាធិ ។ យតោ ខោ អាវុសោ អរិយសាវកោ ឯវំ នាមរូបំ បជានាតិ ឯវំ នាមរូបសមុទយំ បជានាតិ ឯវំ នាមរូបនិរោធំ បជានាតិ ឯវំ នាមរូបនិរោធគាមិនី បដិបទំ បជានាតិ សោ សព្វសោ រាគានុសយំ បហាយ ។ បេ ។ ឯត្តាវតាបិ ខោ អាវុសោ

១-២ ឱ. ម. វុច្ចតាវុសោ ។





នាមរូប តើដូចម្តេច សេចក្តីកើតឡើងនៃនាមរូប តើដូចម្តេច សេចក្តីរលត់នាមរូប តើដូចម្តេច សេចក្តីប្រតិបត្តិ ជាដំណើរដើម្បីរលត់នាមរូប តើដូចម្តេច ។ វេទនា ១ សញ្ញា ១ ចេតនា ១ ផស្សៈ១ មនសិការៈ១ នេះហៅថា នាម ។ មហាភូតទាំង ៤ និងរូបដែលអាស្រ័យមហាភូតរូបទាំង ៤ នេះ ហៅថា រូប ។ ម្នាលអាវុសោ នាមនេះនិងរូបនេះ ហៅថា នាមរូប ដោយប្រការដូច្នេះ ។ សេចក្តីកើតឡើងនៃនាមរូប ព្រោះសេចក្តីកើតឡើងនៃវិញ្ញាណ សេចក្តីរលត់នាមរូប ព្រោះសេចក្តីរលត់វិញ្ញាណ អរិយមគ្គប្រកបដោយអង្គ ៨ នេះឯង ជាសេចក្តីប្រតិបត្តិ ជាដំណើរដើម្បីរលត់នាមរូប អរិយមគ្គនោះ គឺ សម្មាទិដ្ឋិ ។ បេ ។ សម្មាសមាធិ ។ ម្នាលអាវុសោទាំងឡាយ កាលណាអរិយសាវកដឹងច្បាស់នូវនាមរូបយ៉ាងនេះ ដឹងច្បាស់នូវសេចក្តីកើតឡើងនៃនាមរូបយ៉ាងនេះ ដឹងច្បាស់នូវសេចក្តីរលត់នាមរូបយ៉ាងនេះ ដឹងច្បាស់នូវសេចក្តីប្រតិបត្តិ ជាដំណើរដើម្បីរលត់នាមរូបយ៉ាងនេះ អរិយសាវកនោះលះបង់អនុស័យ គឺរាគៈដោយសព្វគ្រប់ ។ បេ ។ ម្នាលអាវុសោទាំងឡាយ

អរិយសាវកោ សម្មាទិដ្ឋិ ហោតិ ឧជុគតាស្ស ទិដ្ឋិ ធម្មេ អវេច្ចប្បសាទេន សមន្នាគតោ អាគតោ ឥមំ សទ្ធម្មន្តិ ។

(១៦៦) សិយា បនាវុសោ ។ បេ ។ សិយាវុសោតិ អាយស្មា សារីបុត្តោ អវោច យតោ ខោ អាវុសោ អរិយសាវកោ វិញ្ញាណញ្ច បជានាតិ វិញ្ញាណសមុទយញ្ច បជានាតិ វិញ្ញាណនិរោធញ្ច បជានាតិ វិញ្ញាណនិរោធគាមិនិំ បដិបទញ្ច បជានាតិ ឯត្តាវតាបិ ខោ អាវុសោ អរិយសាវកោ សម្មាទិដ្ឋិ ហោតិ ឧជុគតាស្ស ទិដ្ឋិ ធម្មេ អវេច្ចប្បសាទេន សមន្នាគតោ អាគតោ ឥមំ សទ្ធម្មន្តិ ។ កតមំ បនាវុសោ វិញ្ញាណំ កតមោ វិញ្ញាណសមុទយោ កតមោ វិញ្ញាណនិរោធោ កតមា វិញ្ញាណនិរោធគាមិនី បដិបទាតិ ។ ឆយិមេ អាវុសោ វិញ្ញាណកាយា ចក្ខុវិញ្ញាណំ សោតវិញ្ញាណំ ឃានវិញ្ញាណំ ជិវ្ហាវិញ្ញាណំ កាយវិញ្ញាណំ



អរិយសាវក ជាសម្មាទិដ្ឋិ ជាអ្នកមានទិដ្ឋិត្រង់ ប្រកបដោយសេចក្តីជ្រះថ្លា មិនញាប់ញ័រក្នុងព្រះធម៌ បានមកកាន់ព្រះសទ្ធម្មនេះ ដោយហេតុប៉ុណ្ណេះឯង ក្នុងកាលនោះ ។

(១៦៦) ភិក្ខុទាំងឡាយ និយាយថា ម្នាលអាវុសោ បរិយាយឯទៀត នៅមានតទៅទៀតដែរឬ ។ បេ ។ ព្រះសារីបុត្រឆ្លើយតបថា ម្នាលអាវុសោទាំងឡាយ នៅមានដែរ ដូច្នេះហើយនិយាយថា ម្នាលអាវុសោទាំងឡាយ កាលណាអរិយសាវកស្គាល់ច្បាស់នូវវិញ្ញាណផង ស្គាល់ច្បាស់នូវសេចក្តីកើតឡើងនៃវិញ្ញាណផង ស្គាល់ច្បាស់នូវសេចក្តីរលត់វិញ្ញាណផង ស្គាល់ច្បាស់នូវសេចក្តីប្រតិបត្តិ ជាដំណើរដើម្បីរលត់វិញ្ញាណផង ម្នាលអាវុសោទាំងឡាយ អរិយសាវក ជាសម្មាទិដ្ឋិ ជាអ្នកមានទិដ្ឋិត្រង់ ប្រកបដោយសេចក្តីជ្រះថ្លា មិនញាប់ញ័រក្នុងព្រះធម៌ បានមកកាន់ព្រះសទ្ធម្មនេះ ដោយហេតុប៉ុណ្ណេះឯង ក្នុងកាលនោះ ។ ម្នាលអាវុសោទាំងឡាយ វិញ្ញាណតើដូចម្តេច សេចក្តីកើតឡើងនៃវិញ្ញាណតើដូចម្តេច សេចក្តីរលត់វិញ្ញាណតើដូចម្តេច សេចក្តីប្រតិបត្តិ ជាដំណើរដើម្បីរលត់វិញ្ញាណ តើដូចម្តេច ។ ម្នាលអាវុសោទាំងឡាយ ពួកវិញ្ញាណនេះមាន ៦ គឺចក្ខុវិញ្ញាណ ១ សោតវិញ្ញាណ ១ ឃានវិញ្ញាណ ១ ជិហ្វាវិញ្ញាណ ១ កាយវិញ្ញាណ ១

មនោវិញ្ញាណំ ។ សង្ខារសមុទយា វិញ្ញាណសមុទយោ សង្ខារនិរោធា វិញ្ញាណនិរោធោ អយមេវ អរិយោ អដ្ឋង្គិកោ មគ្គោ វិញ្ញាណនិរោធគាមិនី បដិបទា សេយ្យថីទំ សម្មាទិដ្ឋិ ។ បេ ។ សម្មាសមាធិ ។ យតោ ខោ អាវុសោ អរិយសាវកោ ឯវំ វិញ្ញាណំ បជានាតិ ឯវំ វិញ្ញាណសមុទយំ បជានាតិ ឯវំ វិញ្ញាណនិរោធំ បជានាតិ ឯវំ វិញ្ញាណនិរោធគាមិនឹ បដិបទំ បជានាតិ សោ សព្វសោ រាគានុសយំ បហាយ ។ បេ ។ ឯត្តាវតាបិ ខោ អាវុសោ អរិយសាវកោ សម្មាទិដ្ឋិ ហោតិ ឧជុគតាស្ស ទិដ្ឋិ ធម្មេ អវេច្ចប្បសាទេន សមន្នាគតោ អាគតោ ឥមំ សទ្ធម្មន្តិ ។

(១៦៧) សិយា បនាវុសោ ។ បេ ។ សិយាវុសោតិ អាយស្មា សារីបុត្តោ អវោច យតោ ខោ អាវុសោ អរិយសាវកោ សង្ខារេ ច បជានាតិ





មនោវិញ្ញាណ១ ។ សេចក្ដីកើតឡើងនៃវិញ្ញាណ ព្រោះសេចក្ដីកើតនៃសង្ខារ សេចក្ដីរលត់វិញ្ញាណ ព្រោះសេចក្ដីរលត់សង្ខារ អរិយមគ្គប្រកបដោយអង្គ៨នេះឯង ជាសេចក្ដីប្រតិបត្តិជាដំណើរដើម្បីរលត់វិញ្ញាណ អរិយមគ្គនោះគឺ សម្មាទិដ្ឋិ ។ បេ ។ សម្មាសមាធិ ។ ម្នាលអាវុសោទាំងឡាយ កាលណាអរិយសាវកស្គាល់ច្បាស់នូវវិញ្ញាណយ៉ាងនេះ ស្គាល់ច្បាស់នូវសេចក្ដីកើតឡើងនៃវិញ្ញាណយ៉ាងនេះ ស្គាល់ច្បាស់នូវសេចក្ដីរលត់វិញ្ញាណយ៉ាងនេះ ស្គាល់ច្បាស់នូវសេចក្ដីប្រតិបត្តិ ជាដំណើរដើម្បីរលត់វិញ្ញាណយ៉ាងនេះ អរិយសាវកនោះ លះរាគានុស័យចេញដោយសព្វគ្រប់ ។ បេ ។ ម្នាលអាវុសោទាំងឡាយ អរិយសាវក ជាសម្មាទិដ្ឋិ ជាអ្នកមានទិដ្ឋិត្រង់ ប្រកបដោយសេចក្ដីជ្រះថ្លា មិនញាប់ញ័រក្នុងព្រះធម៌ ហើយមកកាន់ព្រះសទ្ធម្មនេះ ដោយហេតុប៉ុណ្ណោះឯង ក្នុងកាលនោះ ។

(១៦៧) ភិក្ខុទាំងឡាយ និយាយថា ម្នាលអាវុសោ បរិយាយដទៃទៀតនៅមានដែរឬ ។ បេ ។ ព្រះសារីបុត្រឆ្លើយតបថា ម្នាលអាវុសោទាំងឡាយ បរិយាយដទៃទៀតនៅមាន ហើយនិយាយថា ម្នាលអាវុសោទាំងឡាយ កាលណាអរិយសាវកស្គាល់ច្បាស់នូវសង្ខារផង ស្គាល់

សង្ខារសមុទយញ្ច បជានាតិ សង្ខារនិរោធញ្ច បជានាតិ សង្ខារនិរោធគាមិនឹ បដិបទញ្ច បជានាតិ ឯត្តាវតាបិ ខោ អាវុសោ អរិយសាវកោ សម្មាទិដ្ឋិ ហោតិ ឧជុគតាស្ស ទិដ្ឋិ ធម្មេ អវេច្ចប្បសាទេន សមន្នាគតោ អាគតោ ឥមំ សទ្ធម្មន្តិ ។ កតមេ បនាវុសោ សង្ខារា កតមោ សង្ខារសមុទយោ កតមោ សង្ខារនិរោធោ កតមា សង្ខារនិរោធគាមិនី បដិបទាតិ ។ តយោមេ អាវុសោ សង្ខារា កាយសង្ខារោ វចីសង្ខារោ ចិត្តសង្ខារោ ។ អវិជ្ជាសមុទយា សង្ខារសមុទយោ អវិជ្ជានិរោធា សង្ខារនិរោធោ អយមេវ អរិយោ អដ្ឋង្គិកោ មគ្គោ សង្ខារនិរោធគាមិនី បដិបទា សេយ្យថីទំ សម្មាទិដ្ឋិ ។បេ។ សម្មាសមាធិ ។ យតោ ខោ អាវុសោ អរិយសាវកោ ឯវំ សង្ខារេ បជានាតិ ឯវំ សង្ខារសមុទយំ បជានាតិ ឯវំ សង្ខារនិរោធំ បជានាតិ ឯវំ សង្ខារនិរោធគាមិនឹ បដិបទំ បជានាតិ សោ សព្វសោ រាគានុសយំ បហាយ បដិឃានុសយំ បដិវិនោទេត្វា



ច្បាស់នូវសេចក្តីកើតឡើង នៃសង្ខារផង ស្គាល់ច្បាស់នូវសេចក្តីរលត់សង្ខារផង ស្គាល់ច្បាស់នូវសេចក្តីប្រតិបត្តិ ជាដំណើរដើម្បីរលត់សង្ខារផង ម្នាលអាវុសោទាំងឡាយ អរិយសាវ័ក ជាសម្មាទិដ្ឋិ ជាអ្នកមានទិដ្ឋិត្រង់ ប្រកបដោយសេចក្តីជ្រះថ្លា មិនញាប់ញ័រក្នុងព្រះធម៌ហើយ បានមកកាន់ព្រះសទ្ធម្មនេះ ដោយហេតុប៉ុណ្ណេះឯង ក្នុងកាលនោះ ។ ម្នាលអាវុសោទាំងឡាយ សង្ខារទាំងឡាយ តើដូចម្តេច សេចក្តីកើតឡើងនៃសង្ខារតើដូចម្តេច សេចក្តីរលត់សង្ខារតើដូចម្តេច សេចក្តីប្រតិបត្តិជាដំណើរដើម្បីរលត់សង្ខារ តើដូចម្តេច ។ ម្នាលអាវុសោទាំងឡាយ សង្ខារនេះមាន៣គឺ កាយសង្ខារ១ វចីសង្ខារ១ ចិត្តសង្ខារ១ សេចក្តីកើតឡើងនៃសង្ខារ ព្រោះសេចក្តីកើតឡើងនៃអវិជ្ជា សេចក្តីរលត់សង្ខារ ព្រោះសេចក្តីរលត់អវិជ្ជា អរិយមគ្គប្រកបដោយអង្គ៨ នេះឯង ជាសេចក្តីប្រតិបត្តិ ជាដំណើរដើម្បីរលត់សង្ខារ គឺ សម្មាទិដ្ឋិ ។បេ។ សម្មាសមាធិ ។ ម្នាលអាវុសោទាំងឡាយ កាលណាអរិយសាវ័កស្គាល់ច្បាស់នូវសង្ខារយ៉ាងនេះ ស្គាល់ច្បាស់នូវសេចក្តីកើតឡើងនៃសង្ខារយ៉ាងនេះ ស្គាល់ច្បាស់នូវសេចក្តីរលត់សង្ខារយ៉ាងនេះ ស្គាល់ច្បាស់នូវសេចក្តីប្រតិបត្តិ ជាដំណើរដើម្បីរលត់សង្ខារយ៉ាងនេះ អរិយសាវ័កនោះលះបង់រាគានុស័យដោយសព្វគ្រប់ បន្ទោបង់នូវបដិឃានុស័យ

អស្មីតិ ទិដ្ឋិមានានុសយំ សមូហនិត្វា អវិជ្ជំ បហាយ វិជ្ជំ ឧប្បាទេត្វា ទិដ្ឋេវ ធម្មេ ទុក្ខស្សន្តករោ ហោតិ ឯត្តាវតាបិ ខោ អាវុសោ អរិយសាវកោ សម្មាទិដ្ឋិ ហោតិ ឧជុគតាស្ស ទិដ្ឋិ ធម្មេ អវេច្ចប្បសាទេន សមន្នាគតោ អាគតោ ឥមំ សទ្ធម្មន្តិ ។

(១៦៨) សិយា បនាវុសោ ។បេ។ សិយាវុសោតិ អាយស្មា សារីបុត្តោ អវោច យតោ ខោ អាវុសោ អរិយសាវកោ អវិជ្ជញ្ច បជានាតិ អវិជ្ជាសមុទយញ្ច បជានាតិ អវិជ្ជានិរោធញ្ច បជានាតិ អវិជ្ជានិរោធគាមិនិំ បដិបទញ្ច បជានាតិ ឯត្តាវតាបិ ខោ អាវុសោ អរិយសាវកោ សម្មាទិដ្ឋិ ហោតិ ឧជុគតាស្ស ទិដ្ឋិ ធម្មេ អវេច្ចប្បសាទេន សមន្នាគតោ អាគតោ ឥមំ សទ្ធម្មន្តិ ។ កតមា បនាវុសោ អវិជ្ជា កតមោ អវិជ្ជាសមុទយោ កតមោ អវិជ្ជានិរោធោ កតមា អវិជ្ជានិរោធគាមិនី បដិបទាតិ ។ យំ ខោ អាវុសោ ទុក្ខេ អញ្ញាណំ ទុក្ខសមុទយេ អញ្ញាណំ



ដកចេញនូវអនុស័យគឺមានះ ប្រហែលនឹងទិដ្ឋិថា អញៗមានអញ ហើយលះបង់នូវអវិជ្ជា ញុំាងវិជ្ជាឲ្យកើតឡើង ហើយធ្វើនូវទីបំផុតនៃទុក្ខ ក្នុងបច្ចុប្បន្ននេះបាន ម្នាលអាវុសោទាំងឡាយ អរិយសាវ័ក ជាសម្មាទិដ្ឋិ ជាអ្នកមានទិដ្ឋិត្រង់ ប្រកបដោយសេចក្តីជ្រះថ្លា មិនញាប់ញ័រក្នុងព្រះធម៌ បានមកកាន់ព្រះសទ្ធម្មនេះ ដោយហេតុប៉ុណ្ណេះឯង ក្នុងកាលនោះ ។

(១៦៨) ភិក្ខុទាំងឡាយ និយាយថា ម្នាលអាវុសោ បរិយាយឯទៀតនៅមានដែរឬ ។បេ។ ព្រះសារីបុត្រឆ្លើយតបថា ម្នាលអាវុសោទាំងឡាយ នៅមានដែរ ហើយនិយាយថា ម្នាលអាវុសោទាំងឡាយ កាលណាអរិយសាវ័ក ស្គាល់ច្បាស់នូវអវិជ្ជាផង ស្គាល់ច្បាស់នូវសេចក្តីកើតឡើងនៃអវិជ្ជាផង ស្គាល់ច្បាស់នូវសេចក្តីរលត់អវិជ្ជាផង ស្គាល់ច្បាស់នូវសេចក្តីប្រតិបត្តិ ជាដំណើរដើម្បីរលត់អវិជ្ជាផង ម្នាលអាវុសោទាំងឡាយ អរិយសាវ័ក ជាសម្មាទិដ្ឋិជាអ្នកមានទិដ្ឋិត្រង់ ប្រកបដោយសេចក្តីជ្រះថ្លា មិនញាប់ញ័រក្នុងព្រះធម៌ បានមកកាន់ព្រះសទ្ធម្មនេះ ដោយហេតុប៉ុណ្ណេះឯង ក្នុងកាលនោះ ។ ម្នាលអាវុសោទាំងឡាយ អវិជ្ជា តើដូចម្តេច សេចក្តីកើតឡើងនៃអវិជ្ជា តើដូចម្តេច សេចក្តីរលត់អវិជ្ជា តើដូចម្តេច សេចក្តីប្រតិបត្តិ ជាដំណើរដើម្បីរលត់អវិជ្ជាតើដូចម្តេច ។ ម្នាលអាវុសោទាំងឡាយ សេចក្តីមិនដឹងទុក្ខ ១ សេចក្តីមិនដឹងហេតុឲ្យកើតទុក្ខ ១

ទុក្ខនិរោធេ អញ្ញាណំ ទុក្ខនិរោធគាមិនិយា[១] បដិ-
បទាយ អញ្ញាណំ អយំ វុច្ចតាវុសោ អវិជ្ជា ។ អាសវស-
មុទយា អវិជ្ជាសមុទយោ អាសវនិរោធា អវិជ្ជានិរោធោ
អយមេវ អរិយោ អដ្ឋង្គិកោ មគ្គោ អវិជ្ជានិរោធគាមិនី
បដិបទា សេយ្យថីទំ សម្មាទិដ្ឋិ ។ បេ ។ សម្មាស-
មាធិ ។ យតោ ខោ អាវុសោ អរិយសាវកោ ឯវំ
អវិជ្ជំ បជានាតិ ឯវំ អវិជ្ជាសមុទយំ បជានាតិ ឯវំ
អវិជ្ជានិរោធំ បជានាតិ ឯវំ អវិជ្ជានិរោធគាមិនឹ បដិ-
បទំ បជានាតិ សោ សព្វសោ រាគានុសយំ បហាយ
បដិឃានុសយំ បដិវិនោទេត្វា អស្មីតិ ទិដ្ឋិមានានុសយំ
សមូហនិត្វា អវិជ្ជំ បហាយ វិជ្ជំ ឧប្បាទេត្វា ទិដ្ឋេវ
ធម្មេ ទុក្ខស្សន្តករោ ហោតិ ឯត្តាវតាបិ ខោ អាវុសោ
អរិយសាវកោ សម្មាទិដ្ឋិ ហោតិ ឧជុគតាស្ស ទិដ្ឋិ
ធម្មេ អវេច្ចប្បសាទេន សមន្នាគតោ អាគតោ ឥមំ
សទ្ធម្មន្តិ ។

១ ឱ.ម. ទុក្ខនិរោធគាមិនី ។





សេចក្តីមិនដឹងនូវព្រះនិព្វានជាគ្រឿងរលត់ទុក្ខ ១ សេចក្តីមិនដឹងនូវបដិបទា
ជាដំណើរ ដើម្បីរលត់ទុក្ខ ១ ម្នាលអាវុសោ នេះឯងហៅថា អវិជ្ជា ។
សេចក្តីកើតឡើងនៃអវិជ្ជា ព្រោះសេចក្តីកើតឡើងនៃអាសវៈ សេចក្តីរលត់
អវិជ្ជា ព្រោះសេចក្តីរលត់អាសវៈ អរិយមគ្គប្រកបដោយអង្គ ៨ នេះឯង
ជាសេចក្តីប្រតិបត្តិ ជាដំណើរ ដើម្បីរលត់អវិជ្ជាគឺ សម្មាទិដ្ឋិ ។ បេ ។
សម្មាសមាធិ ។ ម្នាលអាវុសោទាំងឡាយ កាលណាអរិយសាវក ស្គាល់
ច្បាស់នូវអវិជ្ជាយ៉ាងនេះ ស្គាល់ច្បាស់នូវសេចក្តីកើតឡើងនៃអវិជ្ជាយ៉ាង
នេះ ស្គាល់ច្បាស់នូវសេចក្តីរលត់អវិជ្ជាយ៉ាងនេះ ស្គាល់ច្បាស់នូវសេចក្តី
ប្រតិបត្តិ ជាដំណើរដើម្បីរលត់អវិជ្ជាយ៉ាងនេះ អរិយសាវកនោះលះចោល
អនុស័យគឺរាគៈ បន្ទោបង់អនុស័យគឺបដិឃៈ ដកចេញនូវអនុស័យគឺមានះ
ប្រហែលនឹងទិដ្ឋិថា អាត្មាអញមានដូច្នេះ លះបង់នូវអវិជ្ជា ញុំាងវិជ្ជាឲ្យ
កើតឡើង ហើយធ្វើនូវទីបំផុតនៃទុក្ខក្នុងបច្ចុប្បន្ននេះបាន ម្នាលអាវុសោ
ទាំងឡាយ អរិយសាវក ជាសម្មាទិដ្ឋិ ជាអ្នកមានទិដ្ឋិត្រង់ ប្រកបដោយ
សេចក្តីជ្រះថ្លា មិនញាប់ញ័រក្នុងព្រះធម៌ មកកាន់ព្រះសទ្ធម្មនេះ ដោយ
ហេតុប៉ុណ្ណោះឯង ក្នុងកាលនោះ ។

(១៦៩) សាធាវុសោតិ ខោ តេ ភិក្ខូ អាយស្មតោ សារីបុត្តស្ស ភាសិតំ អភិនន្ទិត្វា អនុមោទិត្វា អាយស្មន្តំ សារីបុត្តំ ឧត្តរឹ បញ្ហំ អបុច្ឆិំសុ[១] សិយា បនាវុសោ អញ្ញោបិ បរិយាយោ យថា អរិយសាវកោ សម្មាទិដ្ឋិ ហោតិ ឧជុគតាស្ស ទិដ្ឋិ ធម្មេ អវេច្ចប្បសាទេន សមន្នាគតោ អាគតោ ឥមំ សទ្ធម្មន្តិ ។

(១៧០) សិយាវុសោតិ អាយស្មា សារីបុត្តោ អវោច យតោ ខោ អាវុសោ អរិយសាវកោ អាសវញ្ច បជានាតិ អាសវសមុទយញ្ច បជានាតិ អាសវនិរោធញ្ច បជានាតិ អាសវនិរោធគាមិនឹ បដិបទញ្ច បជានាតិ ឯត្តាវតាបិ ខោ អាវុសោ អរិយសាវកោ សម្មាទិដ្ឋិ ហោតិ ឧជុគតាស្ស ទិដ្ឋិ ធម្មេ អវេច្ចប្បសាទេន សមន្នាគតោ អាគតោ ឥមំ សទ្ធម្មំ ។ កតមោ បនាវុសោ អាសវោ កតមោ អាសវសមុទយោ

១ ម. អបុច្ឆុំ ។



(១៦៩) ភិក្ខុទាំងអម្បាលនោះ ត្រេកអរអនុមោទនា នូវភាសិតរបស់ព្រះសារីបុត្រដ៏មានអាយុថា ម្នាលអាវុសោ ប្រពៃហើយ បានសួរប្រស្នានឹងព្រះសារីបុត្រដ៏មានអាយុតទៅទៀតថា ម្នាលអាវុសោ អរិយសាវក ជាសម្មាទិដ្ឋិ ជាអ្នកមានទិដ្ឋិត្រង់ ប្រកបដោយសេចក្ដីជ្រះថ្លា មិនញាប់ញ័រក្នុងព្រះធម៌ បានមកកាន់ព្រះសទ្ធម្មនេះ ដោយបរិយាយដទៃទៀតមានដែរឬ ។

(១៧០) ព្រះសារីបុត្រ ឆ្លើយតបថា ម្នាលអាវុសោទាំងឡាយ បរិយាយដទៃទៀតនៅមាន ហើយនិយាយថា ម្នាលអាវុសោទាំងឡាយ កាលណា អរិយសាវក ស្គាល់ច្បាស់នូវអាសវៈផង ស្គាល់ច្បាស់នូវសេចក្ដីកើតឡើងនៃអាសវៈផង ស្គាល់ច្បាស់នូវសេចក្ដីរលត់អាសវៈផង ស្គាល់ច្បាស់នូវសេចក្ដីប្រតិបត្តិ ជាដំណើរដើម្បីរលត់អាសវៈផង ម្នាលអាវុសោទាំងឡាយ អរិយសាវក ជាសម្មាទិដ្ឋិ ជាអ្នកមានទិដ្ឋិត្រង់ ប្រកបដោយសេចក្ដីជ្រះថ្លា មិនញាប់ញ័រក្នុងព្រះធម៌ បានមកកាន់ព្រះសទ្ធម្មនេះ ដោយហេតុប៉ុណ្ណេះឯង ក្នុងកាលនោះ ។ ម្នាលអាវុសោទាំងឡាយ អាសវៈតើដូចម្ដេច សេចក្ដីកើតឡើងនៃអាសវៈ តើដូចម្ដេច

កតមោ អាសវនិរោធោ កតមា អាសវនិរោធគាមិនី បដិបទាតិ ។ តយោមេ អាវុសោ អាសវា កាមាសវោ ភវាសវោ អវិជ្ជាសវោ ។ អវិជ្ជាសមុទយា អាសវសមុទយោ អវិជ្ជានិរោធា អាសវនិរោធោ អយមេវ អរិយោ អដ្ឋង្គិកោ មគ្គោ អាសវនិរោធគាមិនី បដិបទា សេយ្យថីទំ សម្មាទិដ្ឋិ សម្មាសង្កប្បោ សម្មាវាចា សម្មាកម្មន្តោ សម្មាអាជីវោ សម្មាវាយាមោ សម្មាសតិ សម្មាសមាធិ ។ យតោ ខោ អាវុសោ អរិយសាវកោ ឯវំ អាសវំ បជានាតិ ឯវំ អាសវសមុទយំ បជានាតិ ឯវំ អាសវនិរោធំ បជានាតិ ឯវំ អាសវនិរោធគាមិនី បដិបទំ បជានាតិ សោ សព្វសោ រាគានុសយំ បហាយ បដិឃានុសយំ បដិវិនោទេត្វា អស្មីតិ ទិដ្ឋិមានានុសយំ សមូហនិត្វា អវិជ្ជំ បហាយ វិជ្ជំ ឧប្បាទេត្វា ទិដ្ឋេវ ធម្មេ ទុក្ខស្សន្តករោ ហោតិ



សេចក្តីរលត់អាសវៈតើដូចម្តេច សេចក្តីប្រតិបត្តិ ជាដំណើរដើម្បីរលត់អាសវៈតើដូចម្តេច ។ ម្នាលអាវុសោទាំងឡាយ អាសវៈនេះមាន ៣ គឺ កាមាសវៈ ១ ភវាសវៈ ១ អវិជ្ជាសវៈ ១ ។ សេចក្តីកើតឡើងនៃអាសវៈ ព្រោះសេចក្តីកើតឡើងនៃអវិជ្ជា សេចក្តីរលត់អាសវៈ ព្រោះសេចក្តីរលត់អវិជ្ជា អរិយមគ្គប្រកបដោយអង្គ ៨ នេះឯង ជាសេចក្តីប្រតិបត្តិ ជាដំណើរដើម្បីរលត់អាសវៈ អរិយមគ្គនោះគឺ សម្មាទិដ្ឋិ ១ សម្មាសង្កប្បៈ ១ សម្មាវាចា ១ សម្មាកម្មន្តៈ ១ សម្មាអាជីវៈ ១ សម្មាវាយាមៈ ១ សម្មាសតិ ១ សម្មាសមាធិ ១ ។ ម្នាលអាវុសោទាំងឡាយ កាលណា អរិយសាវក ស្គាល់ច្បាស់នូវអាសវៈយ៉ាងនេះ ស្គាល់ច្បាស់នូវសេចក្តីកើតឡើងនៃអាសវៈយ៉ាងនេះ ស្គាល់ច្បាស់នូវសេចក្តីរលត់អាសវៈយ៉ាងនេះ ស្គាល់ច្បាស់នូវសេចក្តីប្រតិបត្តិ ជាដំណើរដើម្បីរលត់អាសវៈយ៉ាងនេះ អរិយសាវកនោះ លះរាគានុស័យគឺកាមៈ ដោយសព្វគ្រប់ បន្ទោបង់អនុស័យគឺបដិឃៈ ដកចេញនូវអនុស័យគឺមានះប្រហែលនឹងទិដ្ឋិថា អាត្មាអញមានដូច្នេះ លះបង់នូវអវិជ្ជា ញ៉ាំងវិជ្ជាឲ្យកើត ហើយធ្វើនូវទីបំផុតនៃទុក្ខក្នុងបច្ចុប្បន្ននេះបាន

ឯត្តាវតាបិ ខោ អាវុសោ អរិយសាវកោ សម្មាទិដ្ឋិ ហោតិ ឧជុគតាស្ស ទិដ្ឋិ ធម្មេ អវេច្ចប្បសាទេន សមន្នាគតោ អាគតោ ឥមំ សទ្ធម្មន្តិ ។ ឥទមវោច អាយស្មា សារីបុត្តោ អត្តមនា តេ ភិក្ខូ អាយស្មតោ សារីបុត្តស្ស ភាសិតំ អភិនន្ទុន្តិ ។

សម្មាទិដ្ឋិសុត្តំ នវមំ និដ្ឋិតំ (១) ។

ទុក្ខំ ជរាមរណំ ឧបាទានំ
សឡាយតនំ នាមរូបំ វិញ្ញាណំ
យំ នវបទេ កថយំ
បញ្ចាវុសោ វិត្ថារេតោ ។
ជាតិ តណ្ហា ច វេទនា
អវិជ្ជាយ ចតុក្កោ
យា ចត្តារិ បទេ កថយា
បញ្ចាវុសោ វិត្ថារេតោ ។

១ ម. សម្មាទិដ្ឋិសុត្តំ នវមំ ។





ម្នាលអាវុសោទាំងឡាយ អរិយសាវ័កជាសម្មាទិដ្ឋិ ជាអ្នកមានទិដ្ឋិត្រង់ ប្រកបដោយសេចក្ដីជ្រះថ្លា មិនញាប់ញ័រក្នុងព្រះធម៌ បានមកកាន់ព្រះសទ្ធម្មនេះ ដោយហេតុប៉ុណ្ណោះឯង ក្នុងកាលនោះ ។ លុះព្រះសារីបុត្រដ៏មានអាយុពោលពាក្យនេះហើយ ភិក្ខុទាំងឡាយនោះ មានចិត្តត្រេកអររីករាយចំពោះភាសិតរបស់ព្រះសារីបុត្រដ៏មានអាយុ ។

ចប់ សម្មាទិដ្ឋិសូត្រទី ៩ ។

ធម្មជាតណា ក្នុងពាក្យដែលលោកពោលថា កតមំ បញ្ចាវុសោ (ម្នាលអាវុសោ តើដូចម្ដេច) មាន ៩ បទ គឺ ទុក្ខ ជរា មរណ ឧបាទាន សឡាយតន នាមរូប វិញ្ញាណ ។ ធម្មជាតិណា ក្នុងពាក្យដែលលោកពោលថា កតមា បញ្ចាវុសោ (ម្នាលអាវុសោ តើដូចម្ដេច) មាន ៤ គឺ ជាតិ តណ្ហា វេទនា ជាគម្រប់ ៤ នឹងអវិជ្ជា ។

អាហារោ ច ភវោ ផស្សោ

សង្ខារោ អាសវបច្ចយោ

យំ បញ្ចមេ គតកម្មំ

បនាវុសោ វោសានេ ។

គតមត្ថិ ឆព្វិធា វុត្តិ

គតមានិ ចតុព្វិធា

គតមោ បញ្ចវិធោ វុត្តោ

សព្វសង្ខារានំ បញ្ចទស បនានិ ជាតិ[1] ។

---

១ ម. ទុក្ខំ ជរាមរណំ ញាតានំ សឡាយតនំ នាមរូបំ វិញ្ញាណំ យា សា បរ កតមា បនាវុសោ បទានំ ក៏ជាតិ តណ្ហា ច វេទនា អវិជ្ជាយ ចត្តារោ យោ ចត្តារិ បរ កតមា បនាវុសោ បទានិ កេវលំ ។ អាហារេ ច ភវេ ផស្សេ សង្ខារេ អាសវបច្ចយោ យោ បញ្ចមេ កតមោ បនាវុសោ បទានំ ក៏ កតមន្ទិ ឆព្វិធា វុត្តំ ។ កតមានិ ចតុព្វិធានិ កតមោ បញ្ចវិធោ វុត្តោ សព្វេសំ ឆកសង្ខានំ បញ្ចវយបទានិ ជាតិ ទំសុត្តិ ។



សភាវៈណា ក្នុងពាក្យដែលលោកពោលថា កតមំ បនាវុសោ (ម្នាលអាវុសោ តើដូចម្តេច) មាន ៥ បទ គឺ អាហារ គតិ ផស្សៈ សង្ខារ ជាគម្រប់៥ នឹងអាសវៈ ។ ធម្មជាតនោះ លោកពោលថា មាន កតមំ (តើដូចម្តេច) ៦ លើក មាន កតមានិ (តើដូចម្តេច) ៤ លើក លោកពោលថាមាន កតមោ (តើដូចម្តេច) ៥ លើក រួមបទនៃសង្ខារធម៌ទាំងអស់ត្រូវជា ១៥ ។

# ទសមំ សតិប្បដ្ឋានសុត្តំ

(១៣១) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា កុរូសុ វិហរតិ កម្មាសធម្មំ នាម កុរូនំ និគមោ ។ តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ ភិក្ខវោតិ ។ ភទន្តេតិ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។

(១៣២) ភគវា ឯតទវោច ឯកាយនោ អយំ ភិក្ខវេ មគ្គោ សត្តានំ វិសុទ្ធិយា សោកបរិទេវានំ សមតិក្កមាយ ទុក្ខទោមនស្សានំ អត្ថង្គមាយ ញាយស្ស អធិគមាយ និព្វានស្ស សច្ឆិកិរិយាយ ។ យទិទំ ចត្តារោ សតិប្បដ្ឋានា ។ កតមេ ចត្តារោ ។ ឥធ ភិក្ខវេ ភិក្ខុ កាយេ កាយានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា

# សតិបដ្ឋានសូត្រទី ១០

(១៣១) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយព្រះមានព្រះភាគ ទ្រង់គង់នៅកម្មាសធម្មនិគម[1] របស់អ្នកកុរុក្នុងដែនកុរុ ។ ក្នុងសម័យនោះឯង ព្រះមានព្រះភាគទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ដូច្នេះ ។ ភិក្ខុទាំងនោះទទួលព្រះពុទ្ធដីកានៃព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ដូច្នេះ ។

(១៣២) ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ផ្លូវគឺសតិបដ្ឋានទាំង ៤ ជាផ្លូវមូលតែមួយ[2] (ប្រព្រឹត្តទៅ) ដើម្បីសេចក្តីបរិសុទ្ធិនៃសត្វទាំងឡាយ ដើម្បីលះបង់នូវសេចក្តីសោកនិងសេចក្តីខ្សឹកខ្សួល ដើម្បីរំលត់នូវទុក្ខនិងទោមនស្ស ដើម្បីបាននូវអរិយមគ្គប្រកបដោយអង្គ ៨ ប្រការ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ។ នេះហៅថា សតិបដ្ឋាន ៤ ។ សតិបដ្ឋាន ៤ គឺអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពិចារណាឃើញរឿយ ៗ នូវកាយក្នុងកាយជាប្រក្រតី គ្រប់ឥរិយាបថទាំង៤ មានព្យាយាមជាគ្រឿងដុតកំដៅកិលេស ជាអ្នកដឹងខ្លួន ជាអ្នកមានស្មារតី (ជាគ្រឿងកំណត់)

---

១ ហៅថា កម្មាសទម្មនិគមខ្លះ ។ ២ ន័យថា ផ្លូវមូលតែមួយ មានសេចក្តីពន្យល់ក្នុងមហាសតិបដ្ឋានសូត្រ ទីឃនិកាយ មហាវគ្គទី៧ ១ ។

វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ វេទនាសុ វេទនានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ ចិត្តេ ចិត្តានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ ធម្មេសុ ធម្មានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។

(១៣៣) កថញ្ច ភិក្ខវេ ភិក្ខុ កាយេ កាយានុបស្សី វិហរតិ ។ ឥធ ភិក្ខវេ ភិក្ខុ អរញ្ញគតោ វា រុក្ខមូលគតោ វា សុញ្ញាគារគតោ វា និសីទតិ បល្លង្កំ អាភុជិត្វា ឧជុំ កាយំ បណិធាយ



កំចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោក[១] ចេញ ។ ភិក្ខុពិចារណាឃើញរឿយ ៗ នូវវេទនាក្នុងវេទនាទាំងឡាយជាប្រក្រតី គ្រប់សរិយាបថទាំង ៤ មានព្យាយាមជាគ្រឿងដុតកំដៅកិលេស ជាអ្នកដឹងខ្លួន មានស្មារតី (ជាគ្រឿងកំណត់) កំចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោកចេញ ។ ភិក្ខុពិចារណាឃើញរឿយ ៗ នូវចិត្តក្នុងចិត្តជាប្រក្រតី គ្រប់សរិយាបថទាំង ៤ មានព្យាយាមជាគ្រឿងដុតកំដៅកិលេស ជាអ្នកដឹងខ្លួន មានស្មារតី (ជាគ្រឿងកំណត់) កំចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោកចេញ ។ ភិក្ខុពិចារណាឃើញរឿយ ៗ នូវធម៌ក្នុងធម៌ទាំងឡាយជាប្រក្រតី គ្រប់សរិយាបថទាំង ៤ មានព្យាយាមជាគ្រឿងដុតកំដៅកិលេស ជាអ្នកដឹងខ្លួន មានស្មារតី (ជាគ្រឿងកំណត់) កំចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោកចេញ ។

(១៣៣) ម្នាលភិក្ខុទាំងឡាយ ភិក្ខុពិចារណាឃើញរឿយ ៗ នូវកាយក្នុងកាយជាប្រក្រតី គ្រប់សរិយាបថទាំង ៤ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ទៅនៅក្នុងព្រៃក្តី នៅក្រោមម្លប់ឈើក្តី នៅក្នុងផ្ទះស្ងាត់ក្តី អង្គុយពែនភ្នែន តាំងកាយឲ្យត្រង់

១ លោក ក្នុងទីនេះ មានសេចក្តីពន្យល់ក្នុងមហាសតិបដ្ឋានសូត្រ ទីឃនិកាយ មហាវគ្គ ទំព័រ ២ រួចហើយ ។

បរិមុខំ សតឹ ឧបដ្ឋបេត្វា ។ សោ សតោវ អស្សសតិ សតោ[១] បស្សសតិ ។ ទីឃំ វា អស្សសន្តោ ទីឃំ អស្សសាមីតិ បជានាតិ ។ ទីឃំ វា បស្សសន្តោ ទីឃំ បស្សសាមីតិ បជានាតិ ។ រស្សំ វា អស្ស-សន្តោ រស្សំ អស្សសាមីតិ បជានាតិ ។ រស្សំ វា បស្សសន្តោ រស្សំ បស្សសាមីតិ បជានាតិ ។ សព្វកាយប្បដិសំវេទី អស្សសិស្សាមីតិ សិក្ខតិ ។ សព្វកាយប្បដិសំវេទី បស្សសិស្សាមីតិ សិក្ខតិ ។ បស្សម្ភយំ កាយសង្ខារំ អស្សសិស្សាមីតិ សិក្ខតិ ។ បស្សម្ភយំ កាយសង្ខារំ បស្សសិស្សាមីតិ សិក្ខតិ ។ សេយ្យថាបិ ភិក្ខវេ ទក្ខោ ភមការោ វា ភមកា-រន្តេវាសី វា ទីឃំ វា អញ្ឆន្តោ ទីឃំ អញ្ឆាមីតិ បជានាតិ ។ រស្សំ វា អញ្ឆន្តោ រស្សំ អញ្ឆាមីតិ បជានាតិ ។ ឯវមេវ ខោ ភិក្ខវេ ភិក្ខុ ទីឃំ វា អស្សសន្តោ ទីឃំ អស្សសាមីតិ បជានាតិ ។ ទីឃំ វា បស្សសន្តោ ទីឃំ បស្សសាមីតិ បជានាតិ ។



ដំកល់សតិឲ្យមានមុខឆ្ពោះទៅរក (កម្មដ្ឋាន) ។ ភិក្ខុនោះមានសតិ ដកដង្ហើមចេញ មានសតិ ដកដង្ហើមចូល ។ កាលដកដង្ហើមចេញវែង ក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចេញវែង ។ កាលដកដង្ហើមចូលវែង ក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចូលវែង ។ កាលដកដង្ហើមចេញខ្លី ក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចេញខ្លី ។ កាលដកដង្ហើមចូលខ្លី ក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចូលខ្លី ។ ភិក្ខុសិក្សាថា អាត្មាអញនឹងកំណត់ដឹងនូវកាយគឺខ្យល់ទាំងពួង សឹមដកដង្ហើមចេញ ។ ភិក្ខុសិក្សាថា អាត្មាអញនឹងកំណត់ដឹងនូវកាយគឺខ្យល់ទាំងពួង សឹមដកដង្ហើមចូល ។ ភិក្ខុសិក្សាថា អាត្មាអញនឹងរម្ងាប់នូវកាយសង្ខារ គឺដង្ហើមចេញ និងដង្ហើមចូល សឹមដកដង្ហើមចេញ ។ ភិក្ខុសិក្សាថា អាត្មាអញនឹងរម្ងាប់នូវកាយសង្ខារ សឹមដកដង្ហើមចូល ។ ម្នាលភិក្ខុទាំងឡាយ ជាងក្រឡឹងឬកូនជាងរបស់ជាងក្រឡឹងដែលប៉ិនប្រសប់ កាលទាញខ្សែក្រឡឹងវែងក៏ដឹងច្បាស់ថា អាត្មាអញទាញខ្សែក្រឡឹងវែង ។ កាលទាញខ្សែក្រឡឹងខ្លី ក៏ដឹងច្បាស់ថា អាត្មាអញទាញខ្សែក្រឡឹងខ្លី មានឧបមាដូចម្តេចមិញ ។ ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុដកដង្ហើមចេញវែង ក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចេញវែង ។ កាលដកដង្ហើមចូលវែង ក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចូលវែង ។

រស្សំ វា អស្សសន្តោ រស្សំ អស្សសាមីតិ បជានាតិ ។ រស្សំ វា បស្សសន្តោ រស្សំ បស្សសាមីតិ បជានាតិ ។ សព្វកាយប្បដិសំវេទី អស្សសិស្សាមីតិ សិក្ខតិ ។ សព្វកាយប្បដិសំវេទី បស្សសិស្សាមីតិ សិក្ខតិ ។ បស្សម្ភយំ កាយសង្ខារំ អស្សសិស្សាមីតិ សិក្ខតិ ។ បស្សម្ភយំ កាយសង្ខារំ បស្សសិស្សាមីតិ សិក្ខតិ ។ ឥតិ អជ្ឈត្តំ វា កាយេ កាយានុបស្សី វិហរតិ ពហិទ្ធា វា កាយេ កាយានុបស្សី វិហរតិ អជ្ឈត្តពហិទ្ធា វា កាយេ កាយានុបស្សី វិហរតិ សមុទយធម្មានុបស្សី វា កាយស្មឹ វិហរតិ វយធម្មានុបស្សី វា កាយស្មឹ វិហរតិ



កាលដកដង្ហើមចេញខ្លីក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចេញខ្លី ។ កាលដកដង្ហើមចូលខ្លីក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចូលខ្លី ។ មានឧបមេយ្យដូច្នោះឯង ។ ភិក្ខុសិក្សាថា អាត្មាអញនឹងកំណត់ដឹងនូវកាយគឺខ្យល់ទាំងពួង សឹមដកដង្ហើមចេញ ។ ភិក្ខុសិក្សាថា អាត្មាអញនឹងកំណត់ដឹងនូវកាយគឺខ្យល់ទាំងពួង សឹមដកដង្ហើមចូល ។ ភិក្ខុសិក្សាថា អាត្មាអញនឹងរម្ងាប់នូវកាយសង្ខារ សឹមដកដង្ហើមចេញ ។ ភិក្ខុសិក្សាថា អាត្មាអញនឹងរម្ងាប់នូវកាយសង្ខារ សឹមដកដង្ហើមចូល ។ ភិក្ខុពិចារណាឃើញរឿយៗ នូវកាយក្នុងកាយជាខាងក្នុង គឺកាយរបស់ខ្លួនជាប្រក្រតី គ្រប់ឥរិយាបថទាំង៤ យ៉ាងនេះឯង ពិចារណាឃើញរឿយៗនូវកាយក្នុងកាយជាខាងក្រៅ គឺកាយរបស់បុគ្គលដទៃជាប្រក្រតី គ្រប់ឥរិយាបថទាំង៤ ពិចារណាឃើញរឿយៗ នូវកាយក្នុងកាយ ទាំងខាងក្នុងខាងក្រៅ គឺកាយរបស់ខ្លួន នឹងកាយរបស់បុគ្គលដទៃជាប្រក្រតី គ្រប់ឥរិយាបថទាំង៤ក្តី ពិចារណាឃើញរឿយៗនូវធម៌ដែលប្រជុំកើតឡើង[១]ក្នុងកាយ គ្រប់ឥរិយាបថទាំង៤ក្តី ពិចារណាឃើញរឿយៗ នូវធម៌ដែលសូន្យ[២]ទៅក្នុងកាយ[៣]

---

១–២ ខ្យល់អស្សាសបស្សាសៈ អាស្រ័យនូវករជកាយផង ក្ពោងច្រមុះផង ចិត្តផង ទើបចេញចូលទៅមកបាន ព្រោះហេតុនោះ ធម៌ទាំងនេះ ឈ្មោះថាធម៌ប្រជុំកើតឡើង ដល់ធម៌ទាំងនេះរលត់ទៅវិញ ឈ្មោះថាធម៌សូន្យទៅ ។ ៣ ក្នុងទីនេះ មានសេចក្តីពន្យល់ដូចក្នុងមហាសតិបដ្ឋានសូត្រ ទីឃនិកាយ មហាវគ្គ ត្រង់ទំព័រ ៦ ។

សមុទយវយធម្មានុបស្សី វា កាយស្មឹ វិហរតិ អត្ថិ កាយោតិ វា បនស្ស សតិ បច្ចុបដ្ឋិតា ហោតិ យាវទេវ ញាណមត្តាយ បដិស្សតិមត្តាយ អនិស្សិតោ ច វិហរតិ ន ច កិញ្ចិ លោកេ ឧបាទិយតិ ឯវម្បិ ខោ ភិក្ខវេ ភិក្ខុ កាយេ កាយានុបស្សី វិហរតិ ។

អានាបានបព្វំ ។

(១៣៦) បុន ចបរំ ភិក្ខវេ ភិក្ខុ គច្ឆន្តោ វា គច្ឆាមីតិ បជានាតិ ឋិតោ វា ឋិតោម្ហីតិ បជានាតិ និសិន្នោ វា និសិន្នោម្ហីតិ បជានាតិ សយានោ វា សយានោម្ហីតិ បជានាតិ ។ យថា យថា វា បនស្ស កាយោ បណិហិតោ ហោតិ តថា តថា នំ បជានាតិ ។ ឥតិ អជ្ឈត្តំ វា កាយេ កាយានុបស្សី

១ ឱ. អានាបានបព្វំ និដ្ឋិតំ ។ ម. អស្សាសបព្វំ ។



គ្រប់ឥរិយាបថទាំង ៤ ក្តី ពិចារណាឃើញរឿយ ៗ នូវធម៌ដែលប្រជុំកើតឡើងនិងធម៌ដែលសូន្យទៅក្នុងកាយ គ្រប់ឥរិយាបថទាំង ៤ ក្តី មួយទៀត ស្មារតីជាគ្រឿងកំណត់នូវកាយរបស់ភិក្ខុនោះក៏ផុសឡើងចំពោះថា កាយនេះមាន (ប៉ុន្តែមិនមែនសត្វ មិនមែនបុគ្គល មិនមែនស្រី មិនមែនប្រុសជាដើម) ល្មមតែកំណត់ដើម្បីឲ្យចំរើនប្រាជ្ញា ដើម្បីឲ្យចំរើនស្មារតីប៉ុណ្ណោះ ភិក្ខុនោះមានចិត្តមិនអាស្រ័យ (តណ្ហានិស្ស័យ និងទិដ្ឋិនិស្ស័យ) គ្រប់ឥរិយាបថទាំង ៤ មិនប្រកៀកប្រកាន់អ្វីតិចតួចក្នុងលោកផង ម្នាលភិក្ខុទាំងឡាយ ភិក្ខុពិចារណាឃើញរឿយ ៗ នូវកាយក្នុងកាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ យ៉ាងនេះឯង ។

អានាបានបព្វៈ ។

(១៣៦) ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុកាលដើរក្តី ក៏ដឹងច្បាស់ថា អាត្មាអញដើរ កាលឈរក្តី ក៏ដឹងច្បាស់ថា អាត្មាអញឈរ កាលអង្គុយក្តី ក៏ដឹងច្បាស់ថា អាត្មាអញអង្គុយ កាលដេកក្តី ក៏ដឹងច្បាស់ថា អាត្មាអញដេក ។ ម្យ៉ាងទៀត កាយរបស់ភិក្ខុនោះ ដំកល់នៅដោយអាការយ៉ាងណា ៗ ក៏ដឹងច្បាស់នូវកាយ ដោយអាការយ៉ាងនោះ ៗ ភិក្ខុពិចារណាឃើញរឿយ ៗ នូវកាយក្នុងកាយខាងក្នុង

វិហរតិ ។ បេ ។ ឯវម្បិ ភិក្ខវេ ភិក្ខុ កាយេ កាយានុបស្សី វិហរតិ ។

ឥរិយាបថបព្វំ[1] ។

(១៣៨) បុន ចបរំ ភិក្ខវេ ភិក្ខុ អភិក្កន្តេ បដិក្កន្តេ សម្បជានការី ហោតិ អាលោកិតេ វិលោកិតេ សម្បជានការី ហោតិ សមិញ្ជិតេ បសារិតេ សម្បជានការី ហោតិ សង្ឃាដិបត្តចីវរធារណេ សម្បជានការី ហោតិ អសិតេ បីតេ ខាយិតេ សាយិតេ សម្បជានការី ហោតិ ឧច្ចារបស្សាវកម្មេ សម្បជានការី ហោតិ គតេ ឋិតេ និសិន្នេ សុត្តេ ជាគរិតេ ភាសិតេ តុណ្ហីភាវេ សម្បជានការី ហោតិ ។

១ ម. ឥរិយាបថបព្វំ ន ទិស្សតិ ។



(ដោយការកំណត់នូវឥរិយាបថទាំង ៤ របស់ខ្លួន) ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ដូច្នេះ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុពិចារណាឃើញរឿយ ៗ នូវកាយក្នុងកាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ យ៉ាងនេះឯង ។

ឥរិយាបថបព្វៈ ។

(១៣៨) ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុធ្វើនូវសម្បជញ្ញៈ[1] គឺសេចក្ដីដឹងខ្លួនជាប្រក្រតី ក្នុងការដើរទៅមុខ និងថយក្រោយ ធ្វើសេចក្ដីដឹងខ្លួនជាប្រក្រតីក្នុងការក្រឡេកមើលទៅមុខ និងក្រឡេកមើលទៅទិសផ្សេង ៗ ធ្វើសេចក្ដីដឹងខ្លួនជាប្រក្រតីក្នុងការបត់ដៃបត់ជើង និងលាដៃជើង ធ្វើនូវសេចក្ដីដឹងខ្លួនជាប្រក្រតីក្នុងការទ្រទ្រង់នូវសង្ឃាដិ បាត្រ និងចីវរ ធ្វើនូវសេចក្ដីដឹងខ្លួនជាប្រក្រតីក្នុងការបរិភោគភោជន ផឹកទឹក ទំពាស៊ីខាទនីយវត្ថុ ជញ្ជក់រស ធ្វើនូវសេចក្ដីដឹងខ្លួនជាប្រក្រតីក្នុងការបន្ទោបង់នូវឧច្ចារៈនិងបស្សាវៈ ធ្វើនូវសេចក្ដីដឹងខ្លួនជាប្រក្រតីក្នុងការដើរ ឈរ អង្គុយ ដេក ភ្ញាក់ឡើង និយាយ និងការស្ងៀមជាប្រក្រតី ។

១ សម្បជញ្ញៈក្នុងទីនេះ មានសេចក្ដីពន្យល់ក្នុងមហាសតិបដ្ឋានសូត្រ ទីឃនិកាយ មហាវគ្គ ទំព័រ ៩ ។

ឥតិ អជ្ឈត្តំ វា កាយេ កាយានុបស្សី វិហរតិ ។ បេ ។ ឯវម្បិ ភិក្ខវេ ភិក្ខុ កាយេ កាយានុបស្សី វិហរតិ ។

សម្បជញ្ញបព្វំ ។

(១៣៦) បុន ចបរំ ភិក្ខវេ ភិក្ខុ ឥមមេវ កាយំ ឧទ្ធំ បាទតលា អធោ កេសមត្ថកា តចបរិយន្តំ បូរន្នានប្បការស្ស អសុចិនោ បច្ចវេក្ខតិ អត្ថិ ឥមស្មឹ កាយេ កេសា លោមា នខា ទន្តា តចោ មំសំ ន្ហារូ អដ្ឋី អដ្ឋិមិញ្ជំ វក្កំ ហទយំ យកនំ កិលោមកំ បិហកំ បប្ផាសំ អន្តំ អន្តគុណំ ឧទរិយំ ករីសំ បិត្តំ សេម្ហំ បុព្វោ លោហិតំ សេទោ មេទោ អស្សុ វសា ខេឡោ សិង្ឃាណិកា លសិកា មុត្តន្តិ[២] ។ សេយ្យថាបិ ភិក្ខវេ ឧភតោមុខា មុតោឡិ[៣]

---

១ ឧ. សម្បជញ្ញបព្វំ និដ្ឋិតំ ។ ២ ម. មុត្តំ មត្ថលុង្គន្តិ ។ ៣ ឧ. មុតោឡី ។ ម. បុតោឡី ។



ភិក្ខុពិចារណាឃើញរឿយៗ នូវកាយក្នុងកាយខាងក្នុង (ដោយការកំណត់នូវសម្បជញ្ញៈទាំង៤) ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ដូច្នេះ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុពិចារណាឃើញរឿយៗ នូវកាយក្នុងកាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ យ៉ាងនេះឯង ។

សម្បជញ្ញបព្វៈ ។

(១៣៦) ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុ(ក្នុងសាសនានេះ) ពិចារណាឃើញនូវកាយនេះឯង ខាងលើតាំងពីបាតជើងឡើងទៅ ខាងក្រោមតាំងពីចុងសក់ចុះមក ដែលបិទបាំងដោយស្បែក ពេញដោយវត្ថុមិនស្អាតមានប្រការផ្សេងៗ ដូច្នេះថា ក្នុងកាយនេះ មានសក់ រោម ក្រចក ធ្មេញ ស្បែក សាច់ សរសៃទាំងឡាយ ឆ្អឹងទាំងឡាយ ខួរក្នុងឆ្អឹង តាប បេះដូង ថ្លើម វាវ ក្រពះ សួត ពោះវៀនធំ ពោះវៀនតូច អាហារថ្មី អាហារចាស់ ទឹកប្រមាត់ ស្លេស្ម ខ្ទុះ ឈាម ញើស ខ្លាញ់ខាប់ ទឹកភ្នែក ខ្លាញ់រាវ ទឹកមាត់ ទឹកសម្បោរ ទឹករំអិល ទឹកមូត្រ ។ ម្នាលភិក្ខុទាំងឡាយ (ធម្មតា) ថង់ដែលមានមាត់ទាំងពីរខាង

បូរា នានាវិហិតស្ស ធញ្ញស្ស សេយ្យថីទំ សាលីនំ វីហីនំ មុគ្គានំ មាសានំ តិលានំ តណ្ឌុលានំ ។ តមេនំ ចក្ខុមា បុរិសោ មុញ្ចិត្វា បច្ចវេក្ខេយ្យ ឥមេ សាលី ឥមេ វីហី ឥមេ មុគ្គា ឥមេ មាសា ឥមេ តិលា ឥមេ តណ្ឌុលាតិ ឯវមេវ ខោ ភិក្ខវេ ភិក្ខុ ឥមមេវ កាយំ ឧទ្ធំ បាទតលា អធោ កេសមត្ថកា តចបរិយន្តំ បូរន្នានប្បការស្ស អសុចិនោ បច្ចវេក្ខតិ អត្ថិ ឥមស្មឹ កាយេ កេសា លោមា ។ បេ ។ លសិកា មុត្តន្តិ ។ ឥតិ អជ្ឈត្តំ វា កាយេ កាយានុបស្សី វិហរតិ ។ បេ ។ ឯវម្បិ ភិក្ខវេ ភិក្ខុ កាយេ កាយានុបស្សី វិហរតិ ។

បដិក្កូលបព្វំ[១] ។

១ ម. បដិក្កូលបព្វន្តិ ន ទិស្សតិ ។



ពេញដោយធញ្ញជាតិជាច្រើនប្រការផ្សេង ៗ ធញ្ញជាតិទាំងនោះគឺ ស្រូវខ្សាយស ស្រូវខ្សាយក្រហម សណ្តែកបាយ សណ្តែកដំណាស ល្ង អង្ករ ។ បុរសមានចក្ខុ គប្បីស្រាយនូវមាត់ថង់នោះ ហើយពិចារណាឃើញច្បាស់ដូច្នេះថា នេះស្រូវខ្សាយស នេះស្រូវខ្សាយក្រហម នេះសណ្តែកបាយ នេះសណ្តែកដំណាស នេះល្ង នេះអង្ករ មានឧបមាដូចម្តេចមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុពិចារណាឃើញនូវកាយនេះឯង ខាងលើអំពីបាតជើងឡើងទៅ ខាងក្រោមអំពីចុងសក់ចុះមក ដែលបាំងជុំវិញដោយស្បែក ពេញទៅដោយវត្ថុមិនស្អាតមានប្រការផ្សេង ៗ ដូច្នេះថា ក្នុងកាយនេះ មានសក់ រោម ។ បេ ។ ទឹករំអិល ទឹកមូត្រ មានឧបមេយ្យដូច្នោះឯង ។ ភិក្ខុពិចារណាឃើញរឿយ ៗ នូវកាយក្នុងកាយជាខាងក្នុង (ដោយការកំណត់នូវអាការមានសក់ជាដើម) ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ដូច្នេះ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុពិចារណាឃើញរឿយ ៗ នូវកាយក្នុងកាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ យ៉ាងនេះឯង ។

បដិក្កូលបព្វៈ ។

(១៣៧) បុន ចបរំ ភិក្ខវេ ភិក្ខុ ឥមមេវ កាយំ យថាឋិតំ យថាបណិហិតំ ធាតុសោ បច្ចវេក្ខតិ អត្ថិ ឥមស្មឹ កាយេ បឋវីធាតុ អាបោធាតុ តេជោធាតុ វាយោធាតូតិ ។ សេយ្យថាបិ ភិក្ខវេ ទក្ខោ គោឃាតកោ វា គោឃាតកន្តេវាសី វា គាវឹ វធិត្វា ចាតុម្មហាបថេ ពិលសោ បដិវិភជិត្វា និសិន្នោ អស្ស ឯវមេវ ខោ ភិក្ខវេ ភិក្ខុ ឥមមេវ កាយំ យថាឋិតំ យថាបណិហិតំ ធាតុសោ បច្ចវេក្ខតិ អត្ថិ ឥមស្មឹ កាយេ បឋវីធាតុ អាបោធាតុ តេជោធាតុ វាយោធាតូតិ ។ ឥតិ អជ្ឈត្តំ វា កាយេ កាយានុបស្សី វិហរតិ ។ បេ ។ ឯវម្បិ ភិក្ខវេ ភិក្ខុ កាយេ កាយានុបស្សី វិហរតិ ។

ធាតុបព្វំ (១) ។

១ ឱ. ធាតុបព្វំ ន ទិស្សតិ ។



(១៣៧) ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត ភិក្ខុពិចារណាឃើញនូវកាយនេះឯង ដែលស្ថិតនៅហើយយ៉ាងណា ដែលដំកល់នៅហើយយ៉ាងណា ដោយកំណត់ថាជាធាតុ ដូច្នេះថា ក្នុងកាយនេះ មានបឋវីធាតុ អាបោធាតុ តេជោធាតុ វាយោធាតុ ។ ម្នាលភិក្ខុទាំងឡាយ ឧបមាបុរសអ្នកសម្លាប់គោក្តី អន្តេវាសិក(១)នៃបុរសអ្នកសម្លាប់គោក្តី ដែលប៉ិនប្រសប់ សម្លាប់គោហើយកាត់ជាចំណែក អង្គុយនៅលើផ្លូវធំមានមុខ ៤ មានឧបមាដូចម្តេចមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុពិចារណាឃើញនូវកាយនេះឯង ដែលស្ថិតនៅហើយយ៉ាងណា ដែលដំកល់នៅហើយយ៉ាងណា ដោយកំណត់ថាជាធាតុ ដូច្នេះថា ក្នុងកាយនេះ មានបឋវីធាតុ អាបោធាតុ តេជោធាតុ វាយោធាតុ មានឧបមេយ្យដូច្នោះឯង ។ ភិក្ខុពិចារណាឃើញរឿយៗ នូវកាយក្នុងកាយជាខាងក្នុង ដោយ(ការកំណត់នូវធាតុទាំង៤) ជាប្រក្រតី គ្រប់សតិបដ្ឋានទី ៤ ដូច្នេះ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុពិចារណាឃើញរឿយៗ នូវកាយក្នុងកាយជាប្រក្រតី គ្រប់សតិបដ្ឋានទី ៤ យ៉ាងនេះឯង ។

ធាតុបព្វៈ ។

១ ពួកអ្នកជំនួយការ ។

(១៣៨) បុន ចបរំ ភិក្ខវេ ភិក្ខុ សេយ្យថាបិ បស្សេយ្យ សរីរំ សិវថិកាយ ឆឌ្ឌិតំ ឯកាហមតំ វា ទ្វីហមតំ វា តីហមតំ វា ឧទ្ធុមាតកំ វិនីលកំ វិបុព្វកជាតំ ។ សោ ឥមមេវ កាយំ ឧបសំហរតិ អយម្បិ ខោ កាយោ ឯវំធម្មោ ឯវំភាវី ឯវំ អនតីតោតិ[១] ។ ឥតិ អជ្ឈត្តំ វា កាយេ កាយានុបស្សី វិហរតិ ។ បេ ។ ឯវម្បិ ភិក្ខវេ ភិក្ខុ កាយេ កាយានុបស្សី វិហរតិ ។ បុន ចបរំ ភិក្ខវេ ភិក្ខុ សេយ្យថាបិ បស្សេយ្យ សរីរំ សិវថិកាយ ឆឌ្ឌិតំ កាកេហិ វា ខជ្ជមានំ គិជ្ឈេហិ វា ខជ្ជមានំ កុលលេហិ វា[២] ខជ្ជមានំ សុនខេហិ វា ខជ្ជមានំ[៣] សិង្គាលេហិ វា ខជ្ជមានំ វិវិធេហិ វា បាណកជាតេហិ ខជ្ជមានំ ។ សោ ឥមមេវ កាយំ ឧបសំហរតិ អយម្បិ ខោ កាយោ

---

១ ឱ. ឯវំ អនតីតោតិ បាឋោ ។ ២ ឱ. ម. កុលលេហិ វា ខជ្ជមានំ គិជ្ឈេហិ វាតិ ទិស្សន្តិ ។ ៣ ឱ. សុវាណេហិ វា ខជ្ជមានំ ។ ម. កង្កេហិ វា ខជ្ជមានំ សុនខេហិ វា ខជ្ជមានំ ព្យគ្ឃេហិ វា ខជ្ជមានំ ទីបីហិ វា ខជ្ជមានំ ទិស្សន្តិ ។





(១៣៨) ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុគប្បីឃើញសរីរៈស្លាប់ ដែលគេបោះចោលក្នុងព្រៃស្មសាន នោះស្លាប់ហើយអស់១ថ្ងៃក្តី ស្លាប់ហើយអស់២ថ្ងៃក្តី ស្លាប់ហើយអស់៣ថ្ងៃក្តី ដែលកំពុងហើម មានពណ៌ខៀវ (ដោយរបៀប) មានខ្ទុះហូរចេញ(តាមទ្វារទាំង៩)ដូចម្តេចមិញ ។ ភិក្ខុនោះ កំបង្អោនសរីរៈស្លាប់នោះ មកប្រៀបធៀបនឹងកាយនេះឯងថា សូម្បីកាយនេះ សោតកំគង់នឹងមានសភាពជារបស់ស្អុយយ៉ាងនេះ គង់នឹងក្លាយទៅជាខ្ទុះធាតុអស្អុក ជាដើមយ៉ាងនេះ នឹងកន្លងផុតការខ្ទុះធាតុអស្អុកជាដើមនោះពុំបានឡើយ ។ ភិក្ខុពិចារណាឃើញរឿយ ៗ នូវកាយក្នុងកាយជាខាងក្នុង(ដោយការកំណត់នូវសេចក្តី ... ដើមជាប្រក្រតី ត្រង់សំណាបទាំង៤ផ្សេងៗ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុពិចារណាឃើញរឿយ ៗ នូវកាយក្នុងកាយជាប្រក្រតី ត្រង់សំណាបទាំង៤យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុគប្បីឃើញនូវសរីរៈស្លាប់ ដែលគេបោះចោលក្នុងព្រៃស្មសាន ដែលក្អែកកំពុងចឹកស៊ីក្តី ដែលពួកត្មាតកំពុងដណ្តើមស៊ីក្តី ដែលពួកត្រដក់កំពុងចឹកស៊ីក្តី ដែលពួកស្វានកំពុងកកេរស៊ីក្តី ដែលពួកចចកកំពុងខាំស៊ីក្តី ដែលពួកបាណក-ជាតិផ្សេងៗកំពុងស៊ីក្តី ។ ភិក្ខុនោះ (កំបង្អោនសរីរៈស្លាប់នោះ) មកប្រៀបធៀបនឹងកាយនេះឯងថា សូម្បីកាយនេះឯងសោត កំគង់នឹងមាន

ឯវំធម្មោ ឯវំភាវី ឯវំ អនតីតោតិ ។ ឥតិ អជ្ឈត្តំ វា កាយេ កាយានុបស្សី វិហរតិ ។ បេ ។ ឯវម្បិ ភិក្ខវេ ភិក្ខុ កាយេ កាយានុបស្សី វិហរតិ ។

បុន ចបរំ ភិក្ខវេ ភិក្ខុ សេយ្យថាបិ បស្សេយ្យ សរីរំ សីវថិកាយ ឆឌ្ឌិតំ អដ្ឋិសង្ខលិកំ[១] សមំសលោហិតំ ន្ហារុសម្ពន្ធំ ។ បេ ។ អដ្ឋិសង្ខលិកំ និម្មំសលោហិតមក្ខិតំ ន្ហារុសម្ពន្ធំ ។ បេ ។ អដ្ឋិសង្ខលិកំ អបគតមំសលោហិតំ ន្ហារុសម្ពន្ធំ ។ បេ ។ អដ្ឋិកានិ អបគតន្ហារុសម្ពន្ធានិ[២] ទិសា វិទិសា វិក្ខិត្តានិ

១ ឱ. អដ្ឋិកសង្ខលិកន្តិ ទិស្សតិ ។ ២ ឱ. អបគតសម្ពន្ធានិ ។



សភាពជារបស់គួរខ្ពើមយ៉ាងនោះ គង់នឹងក្លាយទៅជាយ៉ាងនោះ មិនកន្លងនូវភាពយ៉ាងនោះ ពុំបានឡើយ ។ ភិក្ខុពិចារណាឃើញរឿយ ៗ នូវកាយក្នុងកាយជាខាងក្នុង (ដោយការកំណត់នូវអសុភ មានអសុភដែលកំពុងហើមជាដើម) ជាប្រក្រតី គ្រប់សីវថិកាបព្វទាំង ៤ នេះ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុពិចារណាឃើញរឿយ ៗ នូវកាយក្នុងកាយជាប្រក្រតី គ្រប់សីវថិកាបព្វទាំង ៤ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុគប្បីឃើញសរីរៈស្លាប់ ដែលគេបោះចោលក្នុងព្រៃស្មសាន មានតែរាងឆ្អឹង ព្រមទាំងសាច់និងឈាម [illegible] ។ បេ ។ នៅតែរាងឆ្អឹង ឥតមានសាច់ តែនៅប្រឡាក់ទៅដោយឈាម មានសរសៃជាគ្រឿងចង ។ បេ ។ នៅមានតែរាងឆ្អឹង ឥតមានសាច់និងឈាម មានតែសរសៃជាគ្រឿងចង ។ បេ ។ នៅតែរាងឆ្អឹងទទេ មិនមានសរសៃចងរួតរឹតភ្ជាប់ខ្ចាត់ខ្ចាយរាត់រាយទៅ ក្នុងទិសតូចនិងទិសធំ ឆ្អឹងដៃ

អញ្ញេន ហត្ថដ្ឋិកំ អញ្ញេន បាទដ្ឋិកំ អញ្ញេន ជង្ឃដ្ឋិកំ អញ្ញេន ឩរុដ្ឋិកំ អញ្ញេន កដិដ្ឋិកំ អញ្ញេន បិដ្ឋិកណ្ដកដ្ឋិកំ អញ្ញេន ផាសុកដ្ឋិកំ អញ្ញេន ឧរដ្ឋិកំ អញ្ញេន ពាហុដ្ឋិកំ អញ្ញេន អំសដ្ឋិកំ អញ្ញេន គីវដ្ឋិកំ អញ្ញេន ហនុដ្ឋិកំ អញ្ញេន ទន្តដ្ឋិកំ អញ្ញេន សីសកដាហំ[១] ។ សោ ឥមមេវ កាយំ ឧបសំហរតិ អយម្បិ ខោ កាយោ ឯវំធម្មោ ឯវំភាវី ឯវំ អនតីតោតិ ។ ឥតិ អជ្ឈត្តំ វា កាយេ កាយានុបស្សី វិហរតិ ។ បេ ។ ឯវម្បិ ភិក្ខវេ ភិក្ខុ កាយេ កាយានុបស្សី វិហរតិ ។ បុន ចបរំ ភិក្ខវេ ភិក្ខុ សេយ្យថាបិ បស្សេយ្យ សរីរំ សិវថិកាយ ឆឌ្ឌិតំ អដ្ឋិកានិ សេតានិ សង្ខវណ្ណបដិភាគានិ[២]... ។

១ ឱ. អញ្ញេន ហត្ថដ្ឋិកំ អញ្ញេន បាទដ្ឋិកំ អញ្ញេន ជង្ឃដ្ឋិកំ អញ្ញេន ឩរដ្ឋិកំ អញ្ញេន កដដ្ឋិកំ អញ្ញេន បិដ្ឋិកណ្ដកំ អញ្ញេន សីសកដាហន្តិ ទិស្សន្តិ ។ ម. អញ្ញេន ហត្ថដ្ឋិកំ អញ្ញេន បាទដ្ឋិកំ អញ្ញេន គោប្ផកដ្ឋិកំ អញ្ញេន ជង្ឃដ្ឋិកំ អញ្ញេន ឩរុដ្ឋិកំ អញ្ញេន កដដ្ឋិកំ អញ្ញេន ផាសុកដ្ឋិកំ អញ្ញេន បិដ្ឋិដ្ឋិកំ អញ្ញេន ខន្ធដ្ឋិកំ អញ្ញេន គីវដ្ឋិកំ អញ្ញេន ហនុកដ្ឋិកំ អញ្ញេន ទន្តដ្ឋិកំ អញ្ញេន សីសកដាហន្តិ ទិស្សន្តិ ។ ២ ម. សង្ខវណ្ណូបនិភានីតិ ។



ទៅដោយឡែក ឆ្អឹងជើងទៅដោយឡែក ឆ្អឹងស្មងទៅដោយឡែក ឆ្អឹងភ្លៅទៅដោយឡែក ឆ្អឹងចង្កេះទៅដោយឡែក ឆ្អឹងខ្នងទៅដោយឡែក ឆ្អឹងជំនីរទៅដោយឡែក ឆ្អឹងទ្រូងទៅដោយឡែក ឆ្អឹងដើមដៃទៅដោយឡែក ឆ្អឹងស្មាទៅដោយឡែក ឆ្អឹងកទៅដោយឡែក ឆ្អឹងចង្កាទៅដោយឡែក ឆ្អឹងធ្មេញទៅដោយឡែក ឆ្អឹងក្បាលទៅដោយឡែក ។ ភិក្ខុនោះ (គឺបង្អោនសរីរៈស្លាប់នោះ) មកប្រៀបផ្ទឹមនឹងកាយនេះឯងថា សូម្បីកាយនេះសោត ក៏គង់នឹងមានសភាព ជារបស់ស្អុយយ៉ាងនេះ គង់នឹងមានប្រភេទ (ក្លាយទៅ) ជាយ៉ាងនោះ នឹងកន្លងផុតសភាពយ៉ាងនោះពុំបានឡើយ ។ ភិក្ខុពិចារណាឃើញរឿយៗនូវកាយ ក្នុងកាយជាខាងក្នុង (ដោយការកំណត់នូវកេសុក មានទុក្ខាគកាសុកជាដើម) ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ យ៉ាងនេះក្ដី ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុពិចារណាឃើញរឿយៗ នូវកាយក្នុងកាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត ភិក្ខុគប្បីឃើញសរីរៈស្លាប់ ដែលគេបោះចោលក្នុងព្រៃស្មសាន នៅសល់តែកងឆ្អឹងទទេ មានពណ៌ស ដូចជាពណ៌នៃស័ង្ខ យ៉ាងណាមិញ... ។

អដ្ឋិកានិ បុញ្ជកិតានិ(១) តេរោវស្សិកានិ... ។ អដ្ឋិកានិ បូតីនិ ចុណ្ណកជាតានិ ។ សោ ឥមមេវ កាយំ ឧបសំហរតិ អយម្បិ ខោ កាយោ ឯវំធម្មោ ឯវំភាវី ឯវំ អនតីតោតិ ។ ឥតិ អជ្ឈត្តំ វា កាយេ កាយានុបស្សី វិហរតិ ពហិទ្ធា វា កាយេ កាយានុបស្សី វិហរតិ អជ្ឈត្តពហិទ្ធា វា កាយេ កាយានុបស្សី វិហរតិ សមុទយធម្មានុបស្សី វា កាយស្មឹ វិហរតិ វយធម្មានុបស្សី វា កាយស្មឹ វិហរតិ សមុទយវយធម្មានុបស្សី វា កាយស្មឹ វិហរតិ អត្ថិ កាយោតិ វា បនស្ស សតិ បច្ចុបដ្ឋិតា ហោតិ

១ ម. បុញ្ជកិតានិ ។



សល់តែឆ្អឹង គេយកគរជាពំនូកៗ កន្លងទៅ ១ ឆ្នាំហើយ ... ។ នៅសល់តែឆ្អឹងទទេ ពុកផុយខ្ទិចខ្ទី ជាលំអិតដូចជាម្សៅ ។ ភិក្ខុនោះ (បង្អោនសរីរៈស្លាប់នោះ) មកប្រៀបផ្ទឹមនឹងកាយនេះឯងថា សូម្បីកាយនេះសោតក៏គង់នឹងមានសភាព ជារបស់គួរខ្ពើមយ៉ាងនោះ គង់នឹងមានប្រភេទកាយទៅជាយ៉ាងនោះ នឹងកន្លងផុតសភាពយ៉ាងនោះ ពុំបានឡើយ ។ ភិក្ខុពិចារណាឃើញហើយ ។ នូវកាយ ក្នុងកាយជាខាងក្នុង (ដោយការកំណត់នូវអសុភ ដែលសត្វកំពុងចឹកស៊ីជាដើម) ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ដូច្នេះក្ដី ពិចារណាឃើញហើយ ។ នូវកាយ ក្នុងកាយជាខាងក្រៅជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ក្ដី ពិចារណាឃើញហើយ ។ នូវកាយក្នុងកាយជាខាងក្នុង និងខាងក្រៅជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ក្ដី ពិចារណាឃើញហើយ ។ នូវសមុទយធម៌ក្នុងកាយជាប្រក្រតី គ្រប់ឥរិយាបថទាំង៤ក្ដី ពិចារណាឃើញនូវវយធម៌ក្នុងកាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ក្ដី ពិចារណាឃើញហើយ ។ នូវសមុទយធម៌និងវយធម៌ក្នុងកាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ក្ដី ពុំនោះសោតស្មារតីរបស់ភិក្ខុនោះ ក៏ផ្ចង់ឡើងចំពោះថា កាយនេះមានមែន (តែមិនមែនសត្វ មិនមែនបុគ្គល មិនមែនស្រី មិនមែនប្រុសជាដើម)

យាវទេវ ញាណមត្តាយ បដិស្សតិមត្តាយ អនិស្សិតោ ច វិហរតិ ន ច កិញ្ចិ លោកេ ឧបាទិយតិ ឯវំ ខោ ភិក្ខវេ ភិក្ខុ កាយេ កាយានុបស្សី វិហរតិ ។

នវសីវថិកបព្វំ ។

កាយានុបស្សនាសតិបដ្ឋានំ ។

(១៣៩) កថញ្ច ភិក្ខវេ ភិក្ខុ វេទនាសុ វេទនានុបស្សី វិហរតិ ។ ឥធ ភិក្ខវេ ភិក្ខុ សុខំ វេទនំ វេទិយមានោ សុខំ វេទនំ វេទិយាមីតិ បជានាតិ ទុក្ខំ វេទនំ វេទិយមានោ ទុក្ខំ វេទនំ វេទិយាមីតិ បជានាតិ អទុក្ខមសុខំ វេទនំ វេទិយមានោ អទុក្ខមសុខំ វេទនំ វេទិយាមីតិ បជានាតិ ។ សាមិសំ វា សុខំ វេទនំ វេទិយមានោ សាមិសំ សុខំ វេទនំ វេទិយាមីតិ បជានាតិ និរាមិសំ វា សុខំ វេទនំ វេទិយមានោ និរាមិសំ សុខំ វេទនំ វេទិយាមីតិ បជានាតិ ។ សាមិសំ វា ទុក្ខំ វេទនំ វេទិយមានោ សាមិសំ ទុក្ខំ វេទនំ វេទិយាមីតិ បជានាតិ

១ ឱ. នវសីវថិកបព្វំ ។ កាយានុបស្សនាសតិបដ្ឋានន្តិ ន ទិស្សតិ ។ ម. ចុទ្ទស កាយានុបស្សនាសតិបដ្ឋានានិ ទិស្សតិ ។



គ្រាន់តែជាទីកំណត់ ដើម្បីឲ្យកើតប្រាជ្ញា ដើម្បីឲ្យចំរើនស្មារតីប៉ុណ្ណោះ ។ ភិក្ខុនោះមានចិត្តមិនអាស្រ័យ (តណ្ហានិស្ស័យនិងទិដ្ឋិនិស្ស័យ) ផង មិនប្រកាន់អ្វីតិចតួចក្នុងលោកផង ម្នាលភិក្ខុទាំងឡាយ ភិក្ខុពិចារណាឃើញរឿយ ៗ នូវកាយក្នុងកាយ គ្រប់តាមបែបទាំង ៤ យ៉ាងនេះឯង ។

នវសីវថិកបព្វៈ ។

ចប់ កាយានុបស្សនាសតិប្បដ្ឋាន ។

(១៣៩) ម្នាលភិក្ខុទាំងឡាយ ភិក្ខុពិចារណាឃើញរឿយ ៗ នូវវេទនា ក្នុងវេទនាទាំងឡាយជាប្រក្រតី គ្រប់តាមបែបទាំង ៤ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ កាលទទួលសុខវេទនាក្តី ក៏ដឹងច្បាស់ថា អាត្មាអញទទួលសុខវេទនា កាលទទួលទុក្ខវេទនាក្តី ក៏ដឹងច្បាស់ថា អាត្មាអញទទួលទុក្ខវេទនា កាលទទួលអទុក្ខមសុខវេទនាក្តី ក៏ដឹងច្បាស់ថា អាត្មាអញទទួលអទុក្ខមសុខវេទនា ដូច្នេះ ។ កាលទទួលសុខវេទនា ប្រកបដោយអាមិសៈ(១) គឺបញ្ចកាមគុណក្តី ក៏ដឹងច្បាស់ថា អាត្មាអញទទួលសុខវេទនា ប្រកបដោយអាមិសៈ កាលទទួលសុខវេទនា មិនប្រកបដោយអាមិសៈ(២)ក្តី ក៏ដឹងច្បាស់ថា អាត្មាអញទទួលសុខវេទនា មិនប្រកបដោយអាមិសៈ ។ កាលទទួលទុក្ខវេទនាប្រកបដោយអាមិសៈក្តី ក៏ដឹងច្បាស់ថា អាត្មាអញទទួលទុក្ខវេទនា ប្រកបដោយ

១-២ អាមិសក្នុងទីនេះមានសេចក្តីពន្យល់ក្នុងមហាសតិបដ្ឋានសូត្រ ទីឃនិកាយ អដ្ឋកថា ទំព័រ ២៦, ២៨ ។

និរាមិសំ វា ទុក្ខំ វេទនំ វេទយមានោ និរាមិសំ ទុក្ខំ វេទនំ វេទយាមីតិ បជានាតិ ។ សាមិសំ វា អទុក្ខមសុខំ វេទនំ វេទយមានោ សាមិសំ អទុក្ខមសុខំ វេទនំ វេទយាមីតិ បជានាតិ និរាមិសំ វា អទុក្ខមសុខំ វេទនំ វេទយមានោ និរាមិសំ អទុក្ខមសុខំ វេទនំ វេទយាមីតិ បជានាតិ ។ ឥតិ អជ្ឈត្តំ វា វេទនាសុ វេទនានុបស្សី វិហរតិ ពហិទ្ធា វា វេទនាសុ វេទនានុបស្សី វិហរតិ អជ្ឈត្តពហិទ្ធា វា វេទនាសុ វេទនានុបស្សី វិហរតិ សមុទយធម្មានុបស្សី វា វេទនាសុ វិហរតិ វយធម្មានុបស្សី វា វេទនាសុ វិហរតិ សមុទយវយធម្មានុបស្សី វា វេទនាសុ វិហរតិ អត្ថិ វេទនាតិ វា បនស្ស សតិ



អាមិស កាលទទួលទុក្ខវេទនា មិនប្រកបដោយអាមិសក្តី ក៏ដឹងច្បាស់ថា អាត្មាអញទទួលទុក្ខវេទនា មិនប្រកបដោយអាមិស ។ កាលទទួលអទុក្ខមសុខវេទនាប្រកបដោយអាមិសក្តី ក៏ដឹងច្បាស់ថា អាត្មាអញទទួលអទុក្ខមសុខវេទនាប្រកបដោយអាមិស កាលទទួលអទុក្ខមសុខ-វេទនាមិនប្រកបដោយអាមិសក្តី ក៏ដឹងច្បាស់ថា អាត្មាអញទទួលអទុក្ខម-សុខវេទនាមិនប្រកបដោយអាមិសដូច្នេះ ។ ភិក្ខុពិចារណាឃើញរឿយ ៗ នូវវេទនាក្នុងវេទនាទាំងឡាយជាខាងក្នុងជាប្រក្រតី (ដោយការកំណត់នូវវេទនាមានសុខវេទនាជាដើម) គ្រប់សិរិយាបថទាំង ៤ ដូច្នេះក្តី ពិចារណាឃើញរឿយ ៗ នូវវេទនាក្នុងវេទនាទាំងឡាយជាខាងក្រៅជាប្រក្រតី គ្រប់សិរិយាបថទាំង ៤ ក្តី ពិចារណាឃើញរឿយ ៗ នូវវេទនាក្នុងវេទនាទាំងឡាយជាខាងក្នុងទាំងខាងក្រៅជាប្រក្រតី គ្រប់សិរិយាបថទាំង ៤ ក្តី ពិ-ចារណាឃើញរឿយ ៗ នូវធម៌ដែលជាទីប្រជុំកើតឡើង(១)ក្នុងវេទនាទាំងឡាយ គ្រប់សិរិយាបថទាំង ៤ ក្តី ពិចារណាឃើញរឿយ ៗ នូវធម៌ដែលសូន្យទៅ(២)ក្នុងវេទនាទាំងឡាយ គ្រប់សិរិយាបថទាំង ៤ ក្តី ពិចារណាឃើញរឿយ ៗ នូវធម៌ដែលប្រជុំកើតឡើង ទាំងធម៌ដែលសូន្យទៅក្នុងវេទនាទាំងឡាយ គ្រប់សិរិយាបថទាំង ៤ ក្តី ពុំនោះសោត ស្មារតី

១ ធម៌ដែលជាទីប្រជុំកើតឡើងក្នុងវេទនាទាំងឡាយ នឹងមានសេចក្តីពន្យល់ក្នុងខន្ធបព្វៈខាងចុង ។ ២ ធម៌ដែលសូន្យទៅក្នុងវេទនាទាំងឡាយ មានសេចក្តីពន្យល់ក្នុងខន្ធបព្វៈខាងចុង ។

បច្ចុបដ្ឋិតា ហោតិ យាវទេវ ញាណមត្តាយ បដិស្សតិមត្តាយ អនិស្សិតោ ច វិហរតិ ន ច កិញ្ចិ លោកេ ឧបាទិយតិ ឯវំ ខោ ភិក្ខវេ ភិក្ខុ វេទនាសុ វេទនានុបស្សី វិហរតិ ។

### វេទនានុបស្សនាសតិបដ្ឋានំ[១]។

(១៤០) កថញ្ច ភិក្ខវេ ភិក្ខុ ចិត្តេ ចិត្តានុបស្សី វិហរតិ ។ ឥធ ភិក្ខវេ ភិក្ខុ សរាគំ វា ចិត្តំ សរាគំ ចិត្តន្តិ បជានាតិ វីតរាគំ វា ចិត្តំ វីតរាគំ ចិត្តន្តិ បជានាតិ ។ សទោសំ វា ចិត្តំ សទោសំ ចិត្តន្តិ បជានាតិ វីតទោសំ វា ចិត្តំ វីតទោសំ ចិត្តន្តិ បជានាតិ ។

១. វេទនានុបស្សនាសតិបដ្ឋានន្តិ ទិស្សតិ ។



(ជាគ្រឿងកំណត់ប៉ុណ្ណោះ) របស់ភិក្ខុនោះក៏ផ្សំឡើងចំពោះថា វេទនាមានមែន (តែមិនមែនសត្វ មិនមែនបុគ្គល មិនមែនស្រី មិនមែនប្រុសជាដើម) ត្រឹមតែជាទីកំណត់ដើម្បីឲ្យចំរើនប្រាជ្ញា ដើម្បីឲ្យចំរើនស្មារតីប៉ុណ្ណោះ ។ ភិក្ខុនោះមានចិត្តមិនអាស្រ័យ (ដោយតណ្ហានិស្ស័យ និងទិដ្ឋិនិស្ស័យ) ជាប្រក្រតី គ្រប់គ្រងឥរិយាបថទាំង ៤ ផង មិនប្រកៀកប្រកាន់អ្វីតិចតួចក្នុងលោកផង ម្នាលភិក្ខុទាំងឡាយ ភិក្ខុពិចារណាឃើញរឿយ ៗ នូវវេទនាក្នុងវេទនាទាំងឡាយជាប្រក្រតី គ្រប់គ្រងឥរិយាបថទាំង ៤ យ៉ាងនេះឯង ។

### វេទនានុបស្សនាសតិប្បដ្ឋាន ។

(១៤០) ម្នាលភិក្ខុទាំងឡាយ ភិក្ខុពិចារណាឃើញរឿយ ៗ នូវចិត្តក្នុងចិត្តជាប្រក្រតី គ្រប់គ្រងឥរិយាបថទាំង៤ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ កាលចិត្តប្រកបដោយរាគៈ (គឺលោភមូល៨ប្រការ) ក៏ដឹងច្បាស់ថា ចិត្តប្រកបដោយរាគៈ កាលចិត្តប្រាសចាករាគៈ (គឺលោកិយកុសលចិត្ត និងអព្យាកតចិត្ត) ក៏ដឹងច្បាស់ថា ចិត្តប្រាសចាករាគៈ ។ កាលចិត្តប្រកបដោយទោសៈ (គឺទោសមូល ២ ប្រការ) ក៏ដឹងច្បាស់ថា ចិត្តប្រកបដោយទោសៈ កាលចិត្តប្រាសចាកទោសៈ (គឺលោកិយកុសលចិត្ត និងអព្យាកតចិត្ត) ក៏ដឹងច្បាស់ថា ចិត្តប្រាសចាកទោសៈ ។

សមោហំ វា ចិត្តំ សមោហំ ចិត្តន្តិ បជានាតិ វីត-មោហំ វា ចិត្តំ វីតមោហំ ចិត្តន្តិ បជានាតិ ។ សង្ខិត្តំ វា ចិត្តំ សង្ខិត្តំ ចិត្តន្តិ បជានាតិ វិក្ខិត្តំ វា ចិត្តំ វិក្ខិត្តំ ចិត្តន្តិ បជានាតិ ។ មហគ្គតំ វា ចិត្តំ មហគ្គតំ ចិត្តន្តិ បជានាតិ អមហគ្គតំ វា ចិត្តំ អមហគ្គតំ ចិត្តន្តិ បជានាតិ ។ សឧត្តរំ វា ចិត្តំ សឧត្តរំ ចិត្តន្តិ បជានាតិ អនុត្តរំ វា ចិត្តំ អនុត្តរំ ចិត្តន្តិ បជានាតិ ។ សមាហិតំ វា ចិត្តំ សមាហិតំ ចិត្តន្តិ បជានាតិ អសមាហិតំ វា ចិត្តំ អសមាហិតំ ចិត្តន្តិ បជា-នាតិ ។ វិមុត្តំ វា ចិត្តំ វិមុត្តំ ចិត្តន្តិ បជានាតិ អវិមុត្តំ វា ចិត្តំ អវិមុត្តំ ចិត្តន្តិ បជានាតិ ។



ពោះចិត្តប្រកបដោយមោហៈ (គឺមោហមូល ២ ប្រការ) ក៏ដឹងច្បាស់ថា ចិត្តប្រកបដោយមោហៈ ពោះចិត្តប្រាសចាកមោហៈ (គឺលោកិយកុសលចិត្ត និងអព្យាកតចិត្ត) ក៏ដឹងច្បាស់ថា ចិត្តប្រាសចាកមោហៈ ។ ពោះចិត្តរួញ (គឺចិត្តដែលថីនមិទ្ធៈគ្របសង្កត់) ក៏ដឹងច្បាស់ថា ចិត្តរួញ ពោះចិត្តរាយមាយ (គឺឧទ្ធច្ចសហគតចិត្ត) ក៏ដឹងច្បាស់ថា ចិត្តរាយមាយ ។ ពោះចិត្តដល់នូវភាវៈប្រសើរ (គឺជារូបាវចរចិត្ត និងអរូបាវចរចិត្ត) ក៏ដឹងច្បាស់ថាចិត្តដល់នូវភាវៈប្រសើរ ពោះចិត្តមិនដល់នូវភាវៈប្រសើរ (គឺកាមាវចរចិត្ត) ក៏ដឹងច្បាស់ថា ចិត្តមិនដល់នូវភាវៈប្រសើរ ។ ពោះចិត្តនៅមានចិត្តដទៃប្រសើរជាង (គឺកាមាវចរចិត្ត) ក៏ដឹងច្បាស់ថា ចិត្តនៅមានចិត្តដទៃប្រសើរជាង ពោះចិត្តមិនមានចិត្តដទៃប្រសើរជាង (គឺរូបាវចរចិត្ត និងអរូបាវចរចិត្ត) ក៏ដឹងច្បាស់ថា ចិត្តមិនមានចិត្តដទៃប្រសើរជាង ។ ពោះចិត្តដំកល់នៅមាំ (គឺជាអប្បនាសមាធិ និងឧបចារសមាធិ) ក៏ដឹងច្បាស់ថា ចិត្តដំកល់នៅមាំ ពោះចិត្តមិនដំកល់នៅមាំ (គឺប្រាសចាកសមាធិទាំង ២) ក៏ដឹងច្បាស់ថាចិត្តមិនដំកល់នៅមាំ ។ ពោះចិត្តរួចស្រឡះ[១] ក៏ដឹងច្បាស់ថា ចិត្តរួចស្រឡះ ពោះចិត្តមិនទាន់រួចស្រឡះ ក៏ដឹងច្បាស់ថា ចិត្តមិនទាន់រួចស្រឡះ ។

---

១ ចិត្តរួចស្រឡះក្នុងទីនេះ មានសេចក្ដីពន្យល់ក្នុងមហាសតិបដ្ឋានសូត្រ ទីឃនិកាយ មហាវគ្គ ទំព័រ ២៨ ។

រតិ អជ្ឈត្តំ វា ចិត្តេ ចិត្តានុបស្សី វិហរតិ ពហិទ្ធា វា ចិត្តេ ចិត្តានុបស្សី វិហរតិ អជ្ឈត្តពហិទ្ធា វា ចិត្តេ ចិត្តានុបស្សី វិហរតិ សមុទយធម្មានុបស្សី វា ចិត្តស្មឹ វិហរតិ វយធម្មានុបស្សី វា ចិត្តស្មឹ វិហរតិ សមុទយវយធម្មានុបស្សី វា ចិត្តស្មឹ វិហរតិ អត្ថិ ចិត្តន្តិ វា បនស្ស សតិ បច្ចុបដ្ឋិតា ហោតិ យាវទេវ ញាណមត្តាយ បតិស្សតិមត្តាយ



ភិក្ខុពិចារណាឃើញរឿយ ៗ នូវចិត្តក្នុងចិត្តជាខាងក្នុង (ដោយការកំណត់នូវចិត្តប្រកបដោយរាគៈជាដើម) ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ក្តី ពិចារណាឃើញរឿយ ៗ នូវចិត្តក្នុងចិត្តជាខាងក្រៅជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ក្តី ពិចារណាឃើញរឿយ ៗ នូវចិត្តក្នុងចិត្តជាខាងក្នុងនិងខាងក្រៅជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ក្តី ពិចារណាឃើញរឿយ ៗ នូវធម៌ដែលជាទីប្រជុំកើតឡើង(១) ក្នុងចិត្ត ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ក្តី ពិចារណាឃើញរឿយ ៗ នូវធម៌ដែលសូន្យទៅក្នុងចិត្តជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ក្តី ពិចារណាឃើញរឿយ ៗ នូវធម៌ដែលជាទីប្រជុំកើតឡើង(២) និងធម៌ដែលសូន្យទៅក្នុងចិត្តជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ក្តី ពុំនោះសោត ស្មារតី (ជាគ្រឿងកំណត់នូវចិត្តដែលប្រកបដោយរាគៈជាដើម) របស់ភិក្ខុនោះក៏ចូលឡើងចំពោះថា ចិត្តមានមែន (តែមិនមែនសត្វ មិនមែនបុគ្គល មិនមែនស្រី មិនមែនប្រុសជាដើម) គ្រាន់តែជាទីកំណត់ដើម្បីឲ្យចំរើនប្រាជ្ញា ដើម្បីឲ្យចំរើនស្មារតីប៉ុណ្ណោះ

---

១–២ ធម៌ដែលជាទីប្រជុំឲ្យកើតឡើង និងធម៌ដែលសូន្យទៅ មានសេចក្តីពន្យល់ក្នុងធម្មានុបស្សនា ត្រង់ខន្ធបព្វៈខាងមុខ ។

អនិស្សិតោ ច វិហរតិ ន ច កិញ្ចិ លោកេ ឧបាទិយតិ ឯវំបិ ខោ ភិក្ខវេ ភិក្ខុ ចិត្តេ ចិត្តានុបស្សី វិហរតិ ។

ចិត្តានុបស្សនាសតិបដ្ឋានំ(១)។

(១៤១) កថញ្ច ភិក្ខវេ ភិក្ខុ ធម្មេសុ ធម្មានុបស្សី វិហរតិ ។ ឥធ ភិក្ខវេ ភិក្ខុ ធម្មេសុ ធម្មានុបស្សី វិហរតិ បញ្ចសុ នីវរណេសុ ។ កថញ្ច ភិក្ខវេ ភិក្ខុ ធម្មេសុ ធម្មានុបស្សី វិហរតិ បញ្ចសុ នីវរណេសុ ។ ឥធ ភិក្ខវេ ភិក្ខុ សន្តំ វា អជ្ឈត្តំ កាមច្ឆន្ទំ អត្ថិ មេ អជ្ឈត្តំ កាមច្ឆន្ទោតិ បជានាតិ អសន្តំ វា អជ្ឈត្តំ កាមច្ឆន្ទំ នត្ថិ មេ អជ្ឈត្តំ កាមច្ឆន្ទោតិ បជានាតិ ។ យថា ច អនុប្បន្នស្ស កាមច្ឆន្ទស្ស ឧប្បាទោ ហោតិ តញ្ច បជានាតិ យថា ច ឧប្បន្នស្ស កាមច្ឆន្ទស្ស បហានំ ហោតិ

១ ម. ចិត្តានុបស្សនាសតិបដ្ឋានំ និដ្ឋិតំ ។



ភិក្ខុនោះមានចិត្តមិនអាស្រ័យ (តណ្ហានិស្ស័យ និងទិដ្ឋិនិស្ស័យ) គ្រប់ឥរិយាបថទាំង៤ផង មិនប្រកៀកប្រកាន់នូវអ្វីតិចតួចក្នុងលោកផង ម្នាលភិក្ខុទាំងឡាយ ភិក្ខុពិចារណាឃើញរឿយៗ នូវចិត្តក្នុងចិត្តជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ យ៉ាងនេះឯង ។

ចិត្តានុបស្សនាសតិបដ្ឋាន ។

(១៤១) ម្នាលភិក្ខុទាំងឡាយ ភិក្ខុពិចារណាឃើញរឿយៗ នូវធម៌ក្នុងធម៌ទាំងឡាយជាប្រក្រតី គ្រប់ឥរិយាបថទាំង៤តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពិចារណាឃើញរឿយៗ នូវធម៌ក្នុងធម៌ទាំងឡាយជាប្រក្រតី គឺនីវរណៈទាំង៥យ៉ាង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុពិចារណាឃើញរឿយៗនូវធម៌ក្នុងធម៌ទាំងឡាយជាប្រក្រតី គឺនីវរណៈទាំង៥តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពោះកាមច្ឆន្ទមាននៅក្នុងសន្តានចិត្តនៃខ្លួន ក៏ដឹងច្បាស់ថា កាមច្ឆន្ទមាននៅក្នុងសន្តានចិត្តរបស់អាត្មាអញ ពោះកាមច្ឆន្ទមិនមាននៅក្នុងសន្តានចិត្តនៃខ្លួន ក៏ដឹងច្បាស់ថា កាមច្ឆន្ទមិនមាននៅក្នុងសន្តានចិត្តរបស់អាត្មាអញ ។ ពោះកាមច្ឆន្ទដែលមិនទាន់កើតឡើង ហើយកើតឡើងបាន ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះ(១)ផង ការលះបង់នូវកាមច្ឆន្ទដែលកើតឡើង

១ ហេតុដែលកាមច្ឆន្ទកើត គឺធ្វើទុកក្នុងចិត្តក្នុងសុភនិមិត្ត ដោយគ្មានឧបាយនៃប្រាជ្ញា ។

តញ្ច បជានាតិ យថា ច បហីនស្ស កាមច្ឆន្ទស្ស អាយតឹ អនុប្បាទោ ហោតិ តញ្ច បជានាតិ ។ សន្តំ វា អជ្ឈត្តំ ព្យាបាទំ អត្ថិ មេ អជ្ឈត្តំ ព្យាបាទោតិ បជានាតិ អសន្តំ វា អជ្ឈត្តំ ព្យាបាទំ នត្ថិ មេ អជ្ឈត្តំ ព្យាបាទោតិ បជានាតិ ។ យថា ច អនុប្បន្នស្ស ព្យាបាទស្ស ឧប្បាទោ ហោតិ តញ្ច បជានាតិ យថា ច ឧប្បន្នស្ស ព្យាបាទស្ស បហានំ ហោតិ



ហើយដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះ[1] ផង កាមច្ឆន្ទដែលលះបង់បានហើយ មិនកើតតទៅទៀត ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះ[2] ផង ។ ពេលព្យាបាទមាននៅក្នុងសន្តានចិត្តនៃខ្លួន ក៏ដឹងច្បាស់ថា ព្យាបាទមាននៅក្នុងសន្តានចិត្តរបស់អាត្មាអញ ពេលព្យាបាទមិនមាននៅក្នុងសន្តានចិត្តនៃខ្លួន ក៏ដឹងច្បាស់ថា ព្យាបាទមិនមាននៅក្នុងសន្តានចិត្តរបស់អាត្មាអញ ។ ពេលព្យាបាទដែលមិនទាន់កើតឡើងហើយ កើតឡើងបាន ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះ[3] ផង ការលះបង់នូវព្យាបាទដែលកើតឡើងហើយ ដោយហេតុណា

---

១ លះបង់នូវកាមច្ឆន្ទ ដោយធ្វើទុកក្នុងចិត្តក្នុងអសុភនិមិត្ត ដោយឧបាយនៃប្រាជ្ញា ។ ម្យ៉ាងទៀតថា លះបង់ដោយធម៌ ៦ យ៉ាងគឺ អសុភនិមិត្តឧគ្គហៈ រៀននូវអសុភនិមិត្ត ១ អសុភ–ភាវនានុយោគ ប្រកបព្យាយាមរឿយៗ ក្នុងអសុភភាវនា ១ ឥន្ទ្រិយេសុ គុត្តទ្វារតា ភាពជាអ្នកមានទ្វារគ្រប់គ្រងល្អក្នុងឥន្ទ្រិយទាំងឡាយ ១ ភោជនេ មត្តញ្ញុតា ភាពជាអ្នកដឹងប្រមាណក្នុងភោជន ១ កល្យាណមិត្តតា ភាពជាអ្នកសេពគប់តែកល្យាណមិត្ត ១ សប្បាយកថា ពោលឬស្តាប់នូវពាក្យដែលជាទីសប្បាយ ១ ។ ២ កាមច្ឆន្ទកើតតទៅទៀតមិនបានដោយអរហត្តមគ្គ ។ ៣ ហេតុដែលព្យាបាទកើត គឺធ្វើទុកក្នុងចិត្តដោយគ្មានឧបាយនៃប្រាជ្ញាក្នុងបដិឃនិមិត្ត ។ អដ្ឋកថា ។

តញ្ច បជានាតិ យថា ច បហីនស្ស ព្យាបាទស្ស អាយតឹ អនុប្បាទោ ហោតិ តញ្ច បជានាតិ ។ សន្តំ វា អជ្ឈត្តំ ថីនមិទ្ធំ អត្ថិ មេ អជ្ឈត្តំ ថីនមិទ្ធន្តិ បជានាតិ អសន្តំ វា អជ្ឈត្តំ ថីនមិទ្ធំ នត្ថិ មេ អជ្ឈត្តំ ថីនមិទ្ធន្តិ បជានាតិ ។ យថា ច អនុប្បន្នស្ស ថីនមិទ្ធស្ស ឧប្បាទោ ហោតិ តញ្ច បជានាតិ យថា ច ឧប្បន្នស្ស ថីនមិទ្ធស្ស បហានំ ហោតិ



ក៏ដឹងច្បាស់នូវហេតុនោះ[១] ផង ព្យាបាទដែលលះបង់ហើយ មិនកើតតទៅទៀតដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះ[២] ផង ។ ពោះថីនមិទ្ធៈមានទៅក្នុងសន្តានចិត្តខ្លួន ក៏ដឹងច្បាស់ថា ថីនមិទ្ធៈមានទៅក្នុងសន្តានចិត្តរបស់អាត្មាអញ ពោះថីនមិទ្ធៈមិនមានទៅក្នុងសន្តានចិត្តខ្លួន ក៏ដឹងច្បាស់ថា ថីនមិទ្ធៈមិនមានទៅក្នុងសន្តានចិត្តរបស់អាត្មាអញ ។ ពោះថីនមិទ្ធៈដែលមិនទាន់កើតឡើង ហើយកើតឡើងបានដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះ[៣] ផង ការលះបង់នូវថីនមិទ្ធៈដែលកើតឡើង

---

១ លះបង់នូវព្យាបាទដោយធ្វើទុកក្នុងចិត្តដោយឧបាយនៃប្រាជ្ញាក្នុងមេត្តាចេតោវិមុត្តិ ។ ម្យ៉ាងទៀតថា លះបង់ដោយធម៌ ៦ យ៉ាងគឺ មេត្តានិមិត្តុគ្គហៈ រៀននូវមេត្តានិមិត្ត ១ មេត្តាភាវនានុយោគ ប្រកបព្យាយាមរឿយៗ ក្នុងមេត្តាភាវនា ១ កម្មស្សកតាបច្ចវេក្ខណៈ ពិចារណានូវភាពដែលសត្វមានកម្មជារបស់ខ្លួន ១ បដិសង្ខានពហុលតា ភាពជាអ្នកច្រើនដោយការពិចារណា ១ កល្យាណមិត្តតា ភាពជាអ្នកសេពគប់តែកល្យាណមិត្ត ១ សប្បាយកថា ពោលឬស្តាប់នូវពាក្យដែលជាទីសប្បាយ ១ ។ ២ ព្យាបាទកើតតទៅទៀតមិនបានដោយអនាគាមិមគ្គ ។ ៣ ហេតុដែលកើតថីនមិទ្ធៈមាន ៥ យ៉ាងគឺៈ អរតិ សេចក្តីមិនត្រេកអរ ១ តន្ទិ ចំអៀកឬទម្រន់ ១ វិជម្ភិតា មិទ្ធគត់ឬអែនអន ១ ភត្តសម្មទៈ ស្រវឹងក្នុងភត្ត ១ ចេតសោលីនត្តៈ ច្រអូសចិត្ត ១ អន្ទឹកថា ។

តញ្ច បជានាតិ យថា ច បហីនស្ស ថីនមិទ្ធស្ស អាយតឹ អនុប្បាទោ ហោតិ តញ្ច បជានាតិ ។ សន្តំ វា អជ្ឈត្តំ ឧទ្ធច្ចកុក្កុច្ចំ អត្ថិ មេ អជ្ឈត្តំ ឧទ្ធច្ចកុក្កុច្ចន្តិ បជានាតិ អសន្តំ វា អជ្ឈត្តំ ឧទ្ធច្ចកុក្កុច្ចំ នត្ថិ មេ អជ្ឈត្តំ ឧទ្ធច្ចកុក្កុច្ចន្តិ បជានាតិ ។ យថា ច អនុប្បន្នស្ស ឧទ្ធច្ចកុក្កុច្ចស្ស ឧប្បាទោ ហោតិ តញ្ច បជានាតិ យថា ច ឧប្បន្នស្ស ឧទ្ធច្ចកុក្កុច្ចស្ស បហានំ ហោតិ



ហើយលះបង់បានដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះ[១] ផង ថីនមិទ្ធៈដែលលះបង់ចេញហើយ មិនកើតតទៅទៀតដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះ[២] ផង ។ កាលឧទ្ធច្ចកុក្កុច្ចៈ ដែលមានទៅក្នុងសន្តានចិត្តនៃខ្លួន ក៏ដឹងច្បាស់ថា ឧទ្ធច្ចកុក្កុច្ចៈមានទៅក្នុងសន្តានចិត្តរបស់អាត្មាអញ កាលឧទ្ធច្ចកុក្កុច្ចៈ មិនមានទៅក្នុងសន្តានចិត្តនៃខ្លួន ក៏ដឹងច្បាស់ថា ឧទ្ធច្ចកុក្កុច្ចៈមិនមានទៅក្នុងសន្តានចិត្តរបស់អាត្មាអញ ។ កាលឧទ្ធច្ចកុក្កុច្ចៈដែលមិនទាន់កើតឡើងផង ដោយហេតុណា ក៏ដឹងច្បាស់ នូវហេតុនោះ[៣] ផង ការលះបង់នូវឧទ្ធច្ចកុក្កុច្ចៈដែលកើតឡើង ដោយហេតុណា

---

១ លះបង់ថីនមិទ្ធៈ ដោយព្យាយាម ៣ យ៉ាង គឺ អារម្ភធាតុ ព្យាយាមដែលប្រារព្ធឡើងជាដំបូង ១ និក្កមធាតុ ព្យាយាមយ៉ាងកណ្តាលជាគ្រឿងចេញចាកកោសជ្ជៈ ១ បរក្កមធាតុ ព្យាយាមយ៉ាងក្រៃលែង ដែលកន្លងរួចកោសជ្ជៈ ១ ។ ម្យ៉ាងទៀតថា លះបង់ដោយធម៌ ៦ យ៉ាងគឺ អតិភោជនេនិមិត្តគ្គាហ កាន់យកនូវនិមិត្តក្នុងកិរិយាបរិភោគនូវភោជនកន្លងប្រមាណ ១ ឥរិយាបថសម្បរិវត្តនតា ភាពនៃកិរិយាផ្លាស់ប្តូរឥរិយាបថ ១ អាលោកសញ្ញាមនសិការ ធ្វើទុកក្នុងចិត្តនូវភាពអាលោកសញ្ញា ១ អព្ភោកាសវាស នៅក្នុងទីវាលដែលស្រឡះ ១ កល្យាណមិត្តតា ជាអ្នកសេពគប់តែកល្យាណមិត្ត ១ សប្បាយកថា ពោលឬស្តាប់នូវពាក្យដែលជាទីសប្បាយ ១ ។ ២ ថីនមិទ្ធៈកើតឡើងតទៅទៀតមិនបាន ដោយអរហត្តមគ្គ ។ ៣ ហេតុដែលឧទ្ធច្ចកុក្កុច្ចៈកើតគឺធ្វើទុកក្នុងចិត្តដោយឃ្លាតឆ្ងាយនៃប្រាជ្ញា ក្នុងធម៌ដែលមិនមែនជាគ្រឿងរម្ងាប់ចិត្ត ។ អដ្ឋកថា ។

តញ្ច បជានាតិ យថា ច បហីនស្ស ឧទ្ធច្ចកុក្កុច្ចស្ស អាយតឹ អនុប្បាទោ ហោតិ តញ្ច បជានាតិ ។ សន្តំ វា អជ្ឈត្តំ វិចិកិច្ឆំ អត្ថិ មេ អជ្ឈត្តំ វិចិកិច្ឆាតិ បជានាតិ អសន្តំ វា អជ្ឈត្តំ វិចិកិច្ឆំ នត្ថិ មេ អជ្ឈត្តំ វិចិកិច្ឆាតិ បជានាតិ ។ យថា ច អនុប្បន្នាយ វិចិកិច្ឆាយ ឧប្បាទោ ហោតិ តញ្ច បជានាតិ យថា ច ឧប្បន្នាយ វិចិកិច្ឆាយ បហានំ ហោតិ



ក៏ដឹងច្បាស់នូវហេតុនោះ(១) ផង ឧទ្ធច្ចកុក្កុច្ចដែលលះបង់ហើយ មិនកើតតទៅទៀត ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះ(២) ផង ។ កាលវិចិកិច្ឆាមានទៅក្នុងសន្តានចិត្តខាងក្នុង ក៏ដឹងច្បាស់ថា វិចិកិច្ឆាមានទៅក្នុងសន្តានចិត្តរបស់អាត្មាអញ កាលវិចិកិច្ឆាមិនមានទៅក្នុងសន្តានចិត្តខាងក្នុងក៏ដឹងច្បាស់ថា វិចិកិច្ឆាមិនមានទៅក្នុងសន្តានចិត្តរបស់អាត្មាអញ ។ កាលវិចិកិច្ឆាមិនទាន់កើតឡើង ហើយកើតឡើងបាន ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះ(៣) ផង ការលះបង់នូវវិចិកិច្ឆាដែលកើតឡើង

---

១ លះបង់នូវឧទ្ធច្ចកុក្កុច្ចៈ ដោយធ្វើទុកក្នុងចិត្តដោយឧបាយនៃប្រាជ្ញា ក្នុងធម៌ដែលជាគ្រឿងរម្ងាប់ចិត្ត ។ ម្យ៉ាងទៀត លះបង់ដោយធម៌ ៦ យ៉ាងគឺ ពហុស្សុតតា ភាពជាអ្នកស្តាប់ច្រើន ១ បរិបុច្ឆកតា ភាពជាអ្នកសាកសួរច្រើន ១ វិនយេ បកតញ្ញុតា ភាពជាអ្នកដឹងក្នុងវិន័យ ១ វុឌ្ឍសេវិតា ភាពជាអ្នកសេពបុគ្គលដែលចំរើន ១ កល្យាណមិត្តតា ភាពជាអ្នកសេពគប់នូវកល្យាណមិត្ត ១ សប្បាយកថា ពោលឬស្តាប់ពាក្យជាទីសប្បាយ ១ ។ ២ ឧទ្ធច្ចកើតទៅទៀតមិនបានដោយអរហត្តមគ្គ ឯកុក្កុច្ចកើតទៀតមិនបានដោយអនាគាមិមគ្គ ។ ៣ ហេតុដែលវិចិកិច្ឆាកើត គឺធ្វើទុកក្នុងចិត្តមិនដោយឧបាយនៃប្រាជ្ញាក្នុងធម៌ដែលជាទីតាំងនៃសេចក្តីសង្ស័យ។ អន្ទិកជា ។

តញ្ច បជានាតិ យថា ច បហីនាយ វិចិកិច្ឆាយ អាយតឹ អនុប្បាទោ ហោតិ តញ្ច បជានាតិ ។ ឥតិ អជ្ឈត្តំ វា ធម្មេសុ ធម្មានុបស្សី វិហរតិ ពហិទ្ធា វា ធម្មេសុ ធម្មានុបស្សី វិហរតិ អជ្ឈត្តពហិទ្ធា វា ធម្មេសុ ធម្មានុបស្សី វិហរតិ សមុទយធម្មានុបស្សី វា ធម្មេសុ វិហរតិ



ហើយ ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះ[១] ផង វិចិកិច្ឆាដែលលះបង់បានហើយ មិនកើតតទៅទៀត ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះ[២] ផង ។ ភិក្ខុពិចារណាឃើញរឿយៗ នូវធម៌ក្នុងធម៌ទាំងឡាយជាខាងក្នុង ( ដោយការកំណត់នូវនីវរណធម៌ ៥ យ៉ាង ) ជាប្រក្រតី គ្រប់សរិយាបថទាំង ៤ ក្ដី ពិចារណាឃើញរឿយៗ នូវធម៌ក្នុងធម៌ទាំងឡាយជាខាងក្រៅជាប្រក្រតី គ្រប់សរិយាបថទាំង ៤ ក្ដី ពិចារណាឃើញរឿយៗ នូវធម៌ក្នុងធម៌ទាំងឡាយជាខាងក្នុងនិងខាងក្រៅជាប្រក្រតី គ្រប់សរិយាបថទាំង ៤ ក្ដី ពិចារណាឃើញរឿយ ៗ នូវធម៌ដែលនាំប្រជុំកើតឡើង ក្នុងធម៌ទាំងឡាយ ជាប្រក្រតី គ្រប់សរិយាបថទាំង ៤ ក្ដី

---

១ លះបង់នូវវិចិកិច្ឆាដោយធ្វើទុកក្នុងចិត្តដោយឧបាយនៃប្រាជ្ញាក្នុងកុសលធម៌ជាដើមម្យ៉ាងទៀត លះបង់ដោយធម៌ ៦ យ៉ាងគឺ ពហុស្សុតតា ភាពជាអ្នកស្ដាប់ច្រើន ១ បរិបុច្ឆកតា ភាពជាអ្នកសាកសួរច្រើន ១ វិនយេ បកតញ្ញុតា ភាពជាអ្នកដឹងក្នុងវិន័យ១ អធិមោក្ខពហុលតា ភាពជាអ្នកច្រើនដោយចិត្តដែលជឿស៊ប់ ១ កល្យាណមិត្តតា ភាពជាអ្នកសេពគប់នឹងកល្យាណមិត្ត១ សប្បាយកថា ពោលឬស្ដាប់នូវពាក្យដែលជាទីសប្បាយ១ ។ ២ វិចិកិច្ឆាកើតតទៅទៀតមិនបាន ដោយសោតាបត្តិមគ្គ ។ អដ្ឋកថា ។

វយធម្មានុបស្សី វា ធម្មេសុ វិហរតិ សមុទយវយ-
ធម្មានុបស្សី វា ធម្មេសុ វិហរតិ អត្ថិ ធម្មាតិ
វា បនស្ស សតិ បច្ចុបដ្ឋិតា ហោតិ យាវទេវ
ញាណមត្តាយ បដិស្សតិមត្តាយ អនិស្សិតោ ច
វិហរតិ ន ច កិញ្ចិ លោកេ ឧបាទិយតិ ឯវម្បិ
ខោ ភិក្ខវេ ភិក្ខុ ធម្មេសុ ធម្មានុបស្សី វិហរតិ
បញ្ចសុ នីវរណេសុ ។

នីវរណបព្វំ[១]។

(១៤២) បុន ចបរំ ភិក្ខវេ ភិក្ខុ ធម្មេសុ ធម្មា-
នុបស្សី វិហរតិ បញ្ចសុ ឧបាទានក្ខន្ធេសុ ។ កថញ្ច
ភិក្ខវេ ភិក្ខុ ធម្មេសុ ធម្មានុបស្សី វិហរតិ បញ្ច-
សុ ឧបាទានក្ខន្ធេសុ ។ ឥធ ភិក្ខវេ ភិក្ខុ

១ ម. នីវរណបព្វន្តិ ន ទិស្សតិ ។



ពិចារណាឃើញរឿយ ៗ នូវធម៌ដែលវិនាសទៅ ក្នុងធម៌ទាំងឡាយជា
ប្រក្រតី គ្រប់អរិយាបថទាំង ៤ ក្តី ពិចារណាឃើញរឿយៗ នូវធម៌ដែល
ជាទីប្រជុំកើតឡើង ទាំងធម៌ដែលវិនាសទៅ ក្នុងធម៌ទាំងឡាយជាប្រក្រតី
គ្រប់អរិយាបថទាំង ៤ ក្តី ពុំនោះសោត ស្មារតី ( ជាគ្រឿងកំណត់នូវ
នីវរណធម៌ ៥ យ៉ាង ) របស់ភិក្ខុនោះ ក៏ផ្សំឡើងចំពោះថា ធម៌មាននៅមែន
( តែមិនមែនសត្វ មិនមែនបុគ្គល មិនមែនស្រី មិនមែនប្រុសជាដើម )
ត្រាន់តែជាទីកំណត់ ដើម្បីឲ្យចំរើនប្រាជ្ញា ដើម្បីឲ្យចំរើនស្មារតីប៉ុណ្ណោះ
ភិក្ខុមានចិត្តមិនអាស្រ័យ ( ដោយតណ្ហានិងទិដ្ឋិ ) គ្រប់អរិយាបថទាំង
៤ ផង មិនប្រកៀកប្រកាន់អ្វីតិចតួចក្នុងលោកផង ម្នាលភិក្ខុទាំងឡាយ
ភិក្ខុពិចារណាឃើញរឿយ ៗ នូវធម៌ក្នុងធម៌ទាំងឡាយ គឺនីវរណធម៌ទាំង៥
ជាប្រក្រតី គ្រប់អរិយាបថទាំង ៤ យ៉ាងនេះឯង ។

នីវរណបព្វៈ

(១៤២) ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុពិចារណាឃើញ
រឿយៗនូវធម៌ក្នុងធម៌ទាំងឡាយ គឺឧបាទានក្ខន្ធទាំង ៥ ជាប្រក្រតី គ្រប់
អរិយាបថទាំង៤ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុពិចារណាឃើញរឿយ ៗ នូវ
ធម៌ក្នុងធម៌ទាំងឡាយ គឺឧបាទានក្ខន្ធទាំង ៥ ជាប្រក្រតី គ្រប់អរិយាបថ
ទាំង៤តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ (ពិចារណា

អត្ថិ រូបំ អត្ថិ រូបស្ស សមុទយោ អត្ថិ រូបស្ស អត្ថង្គមោ អត្ថិ វេទនា អត្ថិ វេទនាយ សមុទយោ អត្ថិ វេទនាយ អត្ថង្គមោ អត្ថិ សញ្ញា អត្ថិ សញ្ញាយ សមុទយោ អត្ថិ សញ្ញាយ អត្ថង្គមោ អត្ថិ សង្ខារា អត្ថិ សង្ខារានំ សមុទយោ អត្ថិ សង្ខារានំ អត្ថង្គមោ អត្ថិ វិញ្ញាណំ អត្ថិ វិញ្ញាណស្ស សមុទយោ



ឃើញរឿយៗដូច្នេះថា រូបមានប្រមាណ(១)ប៉ុណ្ណេះ ធម៌ដែលជាដែនកើតឡើងនៃរូបមានប្រមាណ(២)ប៉ុណ្ណេះ ធម៌ដែលជាដែនរលត់ទៅនៃរូបមានប្រមាណ(៣)ប៉ុណ្ណេះ វេទនាមានប្រមាណ(៤)ប៉ុណ្ណេះ ធម៌ដែលជាដែនកើតឡើងនៃវេទនាមានប្រមាណ(៥)ប៉ុណ្ណេះ ធម៌ដែលជាដែនរលត់ទៅនៃវេទនាមានប្រមាណ(៦)ប៉ុណ្ណេះ សញ្ញាមានប្រមាណ(៧)ប៉ុណ្ណេះ ធម៌ដែលជាដែនកើតឡើងនៃសញ្ញាមានប្រមាណ(៨)ប៉ុណ្ណេះ ធម៌ដែលជាដែនរលត់ទៅនៃសញ្ញាមានប្រមាណ(៩)ប៉ុណ្ណេះ សង្ខារទាំងឡាយមានប្រមាណ(១០)ប៉ុណ្ណេះ ធម៌ដែលជាដែនកើតឡើងនៃសង្ខារទាំងឡាយមានប្រមាណ(១១)ប៉ុណ្ណេះ ធម៌ដែលជាដែនរលត់ទៅនៃសង្ខារទាំងឡាយមានប្រមាណ(១២)

---

១ រូបមាន ២៨ គឺមហាភូតរូប ៤ ឧបាទាយរូប ២៤ ។ វិសុទ្ធិមគ្គ ខន្ធនិទ្ទេស ។ ២ ធម៌ជាដែនកើតរូប មាន ៥ គឺ អវិជ្ជា ១ តណ្ហា ១ កម្ម ១ អាហារ ១ និព្វត្តិលក្ខណៈ ១ ។ ៣ ធម៌ដែលជាដែនរលត់នៃរូប មាន ៥ យ៉ាង គឺ រលត់អវិជ្ជា ១ តណ្ហា ១ កម្ម ១ អាហារ ១ បរិណាមលក្ខណៈ ១ ។ មគ្គាមគ្គញាណទស្សនវិសុទ្ធិនិទ្ទេស គ្រង់និយាយពីឧទយព្វយញ្ញាណ ក្នុងគម្ពីរវិសុទ្ធិមគ្គ បញ្ញានិទ្ទេស ។ ៤ វេទនា មាន ៨៩ ឬ ១២១ ។ ៥ ធម៌ជាដែនកើតវេទនា មាន ៥ គឺ អវិជ្ជា ១ តណ្ហា ១ កម្ម ១ ផស្សៈ ១ និព្វត្តិលក្ខណៈ ១ ។ ៦ ធម៌ជាដែនរលត់វេទនា មាន ៥ គឺ រលត់អវិជ្ជា ១ តណ្ហា ១ កម្ម ១ ផស្សៈ ១ បរិណាមលក្ខណៈ ១ ។ ៧ សញ្ញា មាន ៨៩ ឬ ១២១ ។ ៨ ធម៌ជាដែនកើតសញ្ញា មាន ៥ គឺ អវិជ្ជា ១ តណ្ហា ១ កម្ម ១ ផស្សៈ ១ និព្វត្តិលក្ខណៈ ១ ។ ៩ ធម៌ជាដែនរលត់សញ្ញា មាន ៥ គឺ រលត់អវិជ្ជា ១ តណ្ហា ១ កម្ម ១ ផស្សៈ ១ បរិណាមលក្ខណៈ ១ ។ ១០ សង្ខារ មាន ៥០ សង្គ្រោះក្នុងចេតសិក ៥២ លើកតែវេទនាចេតសិកនិងសញ្ញាចេតសិកចេញ ។ ១១ ធម៌ជាដែនកើតឡើងនៃសង្ខារ មាន ៥ គឺ អវិជ្ជា ១ តណ្ហា ១ កម្ម ១ ផស្សៈ ១ និព្វត្តិលក្ខណៈ ១ ។ ១២ ធម៌ជាដែនរលត់សង្ខារ មាន ៥ គឺ រលត់អវិជ្ជា ១ តណ្ហា ១ កម្ម ១ ផស្សៈ ១ បរិណាមលក្ខណៈ ១ ។

ឥតិ វិញ្ញាណស្ស អត្ថង្គមោតិ ។ ឥតិ អជ្ឈត្តំ វា ធម្មេសុ ធម្មានុបស្សី វិហរតិ ពហិទ្ធា វា ធម្មេសុ ធម្មានុបស្សី វិហរតិ អជ្ឈត្តពហិទ្ធា វា ធម្មេសុ ធម្មានុបស្សី វិហរតិ សមុទយធម្មានុបស្សី វា ធម្មេសុ វិហរតិ វយធម្មានុបស្សី វា ធម្មេសុ វិហរតិ សមុទយវយធម្មានុបស្សី វា ធម្មេសុ វិហរតិ



ប៉ុណ្ណេះ វិញ្ញាណមានប្រមាណ[1] ប៉ុណ្ណេះ ធម៌ដែលជាដែនកើតឡើងនៃវិញ្ញាណមានប្រមាណ[2] ប៉ុណ្ណេះ ធម៌ដែលជាដែនរលត់ទៅនៃវិញ្ញាណមានប្រមាណប៉ុណ្ណេះ[3] ។ ភិក្ខុពិចារណាឃើញរឿយៗនូវធម៌ក្នុងធម៌ទាំងឡាយជាខាងក្នុង (ដោយការកំណត់នូវខន្ធទាំង៥) ជាប្រក្រតី គ្រប់ឥរិយាបថទាំង៤ក្តី ពិចារណាឃើញរឿយៗ នូវធម៌ក្នុងធម៌ទាំងឡាយជាខាងក្រៅជាប្រក្រតី គ្រប់ឥរិយាបថទាំង៤ក្តី ពិចារណាឃើញរឿយៗ នូវធម៌ក្នុងធម៌ទាំងឡាយជាខាងក្នុងនិងខាងក្រៅជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ក្តី ពិចារណាឃើញរឿយៗ នូវធម៌ដែលជាទីប្រជុំកើតឡើងក្នុងធម៌ទាំងឡាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ក្តី ពិចារណាឃើញរឿយៗ នូវធម៌ដែលសូន្យទៅក្នុងធម៌ទាំងឡាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ក្តី ពិចារណាឃើញរឿយៗនូវធម៌ដែលជាទីប្រជុំកើតឡើង ទាំងធម៌ដែលសូន្យទៅក្នុងធម៌ទាំងឡាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ក្តី

---

១ វិញ្ញាណមាន ៨៩ ឬ ១២១ ។ ២ ធម៌ដែលជាដែនកើតឡើងនៃវិញ្ញាណមាន៥យ៉ាងគឺ អវិជ្ជា ១ តណ្ហា ១ កម្ម ១ នាមរូប ១ និព្វត្តិលក្ខណៈ ១ ។ ក្នុងវិសុទ្ធិមគ្គបញ្ញានិទ្ទេស ត្រង់និយាយពីមគ្គាមគ្គញាណទស្សនវិសុទ្ធិនិទ្ទេស ឧទយព្វយញ្ញាណ ។ ៣ ធម៌ជាដែនរលត់នៃវិញ្ញាណមាន ៥ យ៉ាងគឺ អវិជ្ជា ១ តណ្ហា ១ កម្ម ១ នាមរូប ១ វិបរិណាមលក្ខណៈ ១ ។ វិសុទ្ធិមគ្គបញ្ញានិទ្ទេស ឧទយព្វយញ្ញាណនិទ្ទេស ។

អត្ថិ ធម្មាតិ វា បនស្ស សតិ បច្ចុបដ្ឋិតា ហោតិ យាវទេវ ញាណមត្តាយ បដិស្សតិមត្តាយ អនិស្សិតោ ច វិហរតិ ន ច កិញ្ចិ លោកេ ឧបាទិយតិ ឯវម្បិ ខោ ភិក្ខវេ ភិក្ខុ ធម្មេសុ ធម្មានុបស្សី វិហរតិ បញ្ចសុ ឧបាទានក្ខន្ធេសុ ។

ខន្ធបព្វំ ។

(១៤៣) បុន ចបរំ ភិក្ខវេ ភិក្ខុ ធម្មេសុ ធម្មានុបស្សី វិហរតិ ឆសុ អជ្ឈត្តិកពាហិរេសុ អាយតនេសុ ។ កថញ្ច ភិក្ខវេ ភិក្ខុ ធម្មេសុ ធម្មានុបស្សី វិហរតិ ឆសុ អជ្ឈត្តិកពាហិរេសុ អាយតនេសុ ។ ឥធ ភិក្ខវេ ភិក្ខុ ចក្ខុញ្ច បជានាតិ រូបេ ច បជានាតិ

១ ម. ខន្ធបព្វំ និដ្ឋិតំ ។



តាំងនៅស្រាប់ សតិ (ជាគ្រឿងកំណត់នូវថាមានធម៌) របស់ភិក្ខុនោះ ក៏ចូលទៅរៀងចំពោះជា ពាក្យថាមែន (គឺមិនមែនសត្វ មិនមែនបុគ្គល មិនមែនស្រី មិនមែនប្រុសជាដើម) គ្រាន់តែជាទីកំណត់ដើម្បីឲ្យចំរើនប្រាជ្ញា ដើម្បីឲ្យចំរើនស្មារតីប៉ុណ្ណោះ ភិក្ខុមានចិត្តមិនអាស្រ័យ (ដោយតណ្ហានិងទិដ្ឋិ) គ្រប់ឥរិយាបថទាំង៤ផង មិនប្រកៀកប្រកាន់អ្វីតិចតួចក្នុងលោកផង ម្នាលភិក្ខុទាំងឡាយ ភិក្ខុពិចារណាឃើញរឿយៗ នូវធម៌ក្នុងធម៌ទាំងឡាយ គឺឧបាទានក្ខន្ធទាំង៥ ជាប្រក្រតី គ្រប់ឥរិយាបថទាំង៤ យ៉ាងនេះឯង ។

ខន្ធបព្វៈ ។

(១៤៣) ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុពិចារណាឃើញរឿយៗ នូវធម៌ក្នុងធម៌ទាំងឡាយ គឺអាយតនៈ៦ ខាងក្នុងនិងខាងក្រៅជាប្រក្រតី គ្រប់ឥរិយាបថទាំង៤ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុពិចារណាឃើញរឿយៗ នូវធម៌ក្នុងធម៌ទាំងឡាយ គឺ អាយតនៈ៦ ខាងក្នុង និងខាងក្រៅជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ដឹងច្បាស់នូវចក្ខុប្រសាទផង ដឹងច្បាស់នូវរូបារម្មណ៍ទាំងឡាយផង មួយវិញទៀត

យញ្ច តទុភយំ បដិច្ច ឧប្បជ្ជតិ សញ្ញោជនំ[១] តញ្ច បជានាតិ ។ យថា ច អនុប្បន្នស្ស សញ្ញោជនស្ស ឧប្បាទោ ហោតិ តញ្ច បជានាតិ យថា ច ឧប្បន្នស្ស សញ្ញោជនស្ស បហានំ ហោតិ តញ្ច បជានាតិ យថា ច បហីនស្ស សញ្ញោជនស្ស អាយតឹ អនុប្បាទោ ហោតិ តញ្ច បជានាតិ ។ សោតញ្ច បជានាតិ សទ្ទេ ច បជានាតិ... ។ ឃានញ្ច បជានាតិ គន្ធេ ច បជានាតិ... ។ ជិវ្ហញ្ច បជានាតិ រសេ ច បជានាតិ... ។ កាយញ្ច បជានាតិ ផោដ្ឋព្វេ ច បជានាតិ... ។ មនញ្ច បជានាតិ ធម្មេ ច បជានាតិ យញ្ច តទុភយំ បដិច្ច ឧប្បជ្ជតិ សញ្ញោជនំ

១ ម. សំយោជនំ ។



សំយោជនធម៌ណា ដែលអាស្រ័យនូវភ្នែកនិងរូបទាំងពីរនោះ ហើយកើតឡើង ក៏ដឹងច្បាស់នូវសញ្ញោជនធម៌[១] នោះផង ។ សំយោជនធម៌ដែលមិនទាន់កើតឡើងហើយកើតឡើងបាន ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះ[២] ផង ការលះបង់បាននូវសំយោជនធម៌ដែលកើតឡើង ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះ[៣] ផង សំយោជនធម៌ដែលលះបង់បានហើយ មិនកើតតទៅទៀត ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះ[៤] ផង ។ ភិក្ខុដឹងច្បាស់នូវសោតប្រសាទផង ដឹងច្បាស់នូវសទ្ទារម្មណ៍ទាំងឡាយផង ... ។ ដឹងច្បាស់នូវឃានប្រសាទផង ដឹងច្បាស់នូវគន្ធារម្មណ៍ទាំងឡាយផង... ។ ដឹងច្បាស់នូវជិវ្ហាប្រសាទផង ដឹងច្បាស់នូវរសារម្មណ៍ទាំងឡាយផង... ។ ដឹងច្បាស់នូវកាយប្រសាទផង ដឹងច្បាស់នូវផោដ្ឋព្វារម្មណ៍ទាំងឡាយផង... ។ ដឹងច្បាស់នូវចិត្ត[៥] ផង ដឹងច្បាស់នូវធម្មារម្មណ៍[៦] ទាំងឡាយផង មួយទៀត សំយោជនធម៌ណា ដែលអាស្រ័យ នូវចិត្តនិងធម្មារម្មណ៍ទាំងពីរនោះ

១ មានសេចក្តីពន្យល់ក្នុងមហាសតិបដ្ឋានសូត្រ ទីឃនិកាយ មហាវគ្គ ទំព័រ ៣៩-៤០ ។
២-៣-៤ មានសេចក្តីពន្យល់ក្នុងមហាសតិបដ្ឋានសូត្រទីឃនិកាយ មហាវគ្គ ទំព័រ ៣៩ ៤០ ។ ៥ ចិត្ត ៨៩ ឬ ១២១ ។ ៦ ធម៌ ៦ យ៉ាងគឺ បសាទរូប ១ សុខុមរូប ១ ចិត្ត ១ ចេតសិក ១ និព្វាន ១ បញ្ញត្តិ ១ ។ វិសុទ្ធិមគ្គ អាយតននិទ្ទេស ។

តញ្ច បជានាតិ ។ យថា ច អនុប្បន្នស្ស សញ្ញោ-
ជនស្ស ឧប្បាទោ ហោតិ តញ្ច បជានាតិ យថា ច
ឧប្បន្នស្ស សញ្ញោជនស្ស បហានំ ហោតិ តញ្ច
បជានាតិ យថា ច បហីនស្ស សញ្ញោជនស្ស
អាយតឹ អនុប្បាទោ ហោតិ តញ្ច បជានាតិ ។ ឥតិ
អជ្ឈត្តំ វា ធម្មេសុ ធម្មានុបស្សី វិហរតិ ពហិទ្ធា
វា ធម្មេសុ ធម្មានុបស្សី វិហរតិ អជ្ឈត្តពហិទ្ធា វា
ធម្មេសុ ធម្មានុបស្សី វិហរតិ សមុទយធម្មានុបស្សី
វា ធម្មេសុ វិហរតិ វយធម្មានុបស្សី វា ធម្មេសុ
វិហរតិ សមុទយវយធម្មានុបស្សី វា ធម្មេសុ វិហរតិ



ហើយកើតឡើង ក៏ដឹងច្បាស់នូវសញ្ញោជនធម៌នោះផង ។ សំយោជន-
ធម៌ដែលមិនទាន់កើតឡើង ក៏កើតឡើងបាន ដោយហេតុណា ក៏ដឹង
ច្បាស់នូវហេតុនោះផង ការលះបង់នូវសំយោជនធម៌ ដែលកើតឡើង
ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង សំយោជនធម៌ដែលលះ
បង់បានហើយ មិនកើតតទៅទៀត ដោយហេតុណា ក៏ដឹងច្បាស់នូវ
ហេតុនោះផង ។ ភិក្ខុពិចារណាឃើញរឿយ ៗ នូវធម៌ក្នុងធម៌ទាំងឡាយជា
ចំណែកខាងក្នុង (ដោយការកំណត់នូវអាយតនៈខាងក្នុង) ជាប្រក្រតីគ្រប់
ឥរិយាបថទាំង ៤ ក្តី ពិចារណាឃើញរឿយ ៗ នូវធម៌ក្នុងធម៌ទាំងឡាយ
ជាចំណែកខាងក្រៅក្តី ពិចារណាឃើញរឿយ ៗ នូវធម៌ក្នុងធម៌ទាំងឡាយ
ជាចំណែកខាងក្នុងនិងខាងក្រៅជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ក្តី ពិចារ-
ណាឃើញរឿយ ៗ នូវសមុទយធម៌[១] ទាំងឡាយជាប្រក្រតី គ្រប់ឥរិយា
បថទាំង ៤ ក្តី ពិចារណាឃើញរឿយ ៗ នូវវយធម៌[២] ក្នុងធម៌ទាំងឡាយ
ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ក្តី ពិចារណាឃើញរឿយ ៗ នូវសមុទយ-
ធម៌និងវយធម៌ ក្នុងធម៌ទាំងឡាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ក្តី

---

១-២ សមុទយវយធម៌ដែលជាទីប្រជុំកើតឡើងនិងសូន្យទៅនៃអាយតនៈទាំង ៨ មានចក្ខា-
យតនៈជាដើម និងបញ្ជាក់ទីកើតទីរលត់នៃរូប ឯមនាយតនៈនិងបញ្ជាក់នូវវិញ្ញាណ ។ មានសេចក្តី
ពន្យល់រួចហើយ ក្នុងធម្មានុបស្សនា ខន្ធបព្វៈ ។ អដ្ឋកថា ។

អត្ថិ ធម្មាតិ វា បនស្ស សតិ បច្ចុបដ្ឋិតា ហោតិ យាវទេវ ញាណមត្តាយ បតិស្សតិមត្តាយ អនិស្សិតោ ច វិហរតិ ន ច កិញ្ចិ លោកេ ឧបាទិយតិ ឯវម្បិ ខោ ភិក្ខវេ ភិក្ខុ ធម្មេសុ ធម្មានុបស្សី វិហរតិ ឆសុ អជ្ឈត្តិកពាហិរេសុ អាយតនេសុ ។

អាយតនបព្វំ[១]។

(១៦៤) បុន ចបរំ ភិក្ខវេ ភិក្ខុ ធម្មេសុ ធម្មានុបស្សី វិហរតិ សត្តសុ ពោជ្ឈង្គេសុ ។ កថញ្ច ភិក្ខវេ ភិក្ខុ ធម្មេសុ ធម្មានុបស្សី វិហរតិ សត្តសុ ពោជ្ឈង្គេសុ ។ ឥធ ភិក្ខវេ ភិក្ខុ សន្តំ វា អជ្ឈត្តំ សតិសម្ពោជ្ឈង្គំ អត្ថិ មេ អជ្ឈត្តំ សតិសម្ពោជ្ឈង្គោតិ

១ ម. អាយតនបព្វន្តិ ន ទិស្សតិ ។





ពុំនោះសោត ស្មារតី (ជាគ្រឿងកំណត់ប្រាកដ) របស់ភិក្ខុនោះ ក៏ផ្សំឡើងចំពោះថា ធម៌ទាំងឡាយ មានមែន (តែមិនមែនសត្វ មិនមែនបុគ្គល មិនមែនស្រី មិនមែនប្រុសជាដើម) ត្រឹមតែជាទីកំណត់ដើម្បីឲ្យចំរើនប្រាជ្ញា ដើម្បីឲ្យចំរើនស្មារតីប៉ុណ្ណោះ ។ ភិក្ខុមានចិត្តមិនអាស្រ័យ (តណ្ហានិស្ស័យនិងទិដ្ឋិនិស្ស័យ) គ្រប់ឥរិយាបថទាំង ៤ ផង មិនប្រកៀកប្រកាន់អ្វីៗក្នុងលោកផង ម្នាលភិក្ខុទាំងឡាយ ភិក្ខុពិចារណាឃើញរឿយៗ នូវធម៌ក្នុងធម៌ទាំងឡាយ គឺអាយតនៈ ៦ ទាំងខាងក្នុង ខាងក្រៅជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ យ៉ាងនេះឯង ។

អាយតនបព្វៈ ។

(១៦៤) ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុពិចារណាឃើញរឿយៗ នូវធម៌ក្នុងធម៌ទាំងឡាយ គឺពោជ្ឈង្គៈ (អង្គធម៌ជាគ្រឿងត្រាស់ដឹង) ៧ ប្រការជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុពិចារណាឃើញរឿយៗ នូវធម៌ក្នុងធម៌ទាំងឡាយ គឺពោជ្ឈង្គ ៧ ប្រការជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពោះសតិសម្ពោជ្ឈង្គ ដែលមាននៅក្នុងសន្តានចិត្តនៃខ្លួន ក៏ដឹងច្បាស់ថា សតិសម្ពោជ្ឈង្គមាននៅក្នុង

បជានាតិ អសន្តំ វា អជ្ឈត្តំ សតិសម្ពោជ្ឈង្គំ នត្ថិ មេ អជ្ឈត្តំ សតិសម្ពោជ្ឈង្គោតិ បជានាតិ ។ យថា ច អនុប្បន្នស្ស សតិសម្ពោជ្ឈង្គស្ស ឧប្បាទោ ហោតិ តញ្ច បជានាតិ យថា ច ឧប្បន្នស្ស សតិសម្ពោជ្ឈង្គស្ស ភាវនាបារិបូរី[១] ហោតិ តញ្ច បជានាតិ ។ សន្តំ វា អជ្ឈត្តំ ធម្មវិចយសម្ពោជ្ឈង្គំ... ។ សន្តំ វា អជ្ឈត្តំ វីរិយសម្ពោជ្ឈង្គំ... ។ សន្តំ វា អជ្ឈត្តំ បីតិសម្ពោជ្ឈង្គំ...។ សន្តំ វា អជ្ឈត្តំ បស្សទ្ធិសម្ពោជ្ឈង្គំ...។ សន្តំ វា អជ្ឈត្តំ សមាធិសម្ពោជ្ឈង្គំ... ។ សន្តំ វា អជ្ឈត្តំ ឧបេក្ខាសម្ពោជ្ឈង្គំ អត្ថិ មេ អជ្ឈត្តំ ឧបេក្ខាសម្ពោជ្ឈង្គោតិ បជានាតិ អសន្តំ វា អជ្ឈត្តំ ឧបេក្ខាសម្ពោជ្ឈង្គំ នត្ថិ មេ អជ្ឈត្តំ ឧបេក្ខាសម្ពោជ្ឈង្គោតិ បជានាតិ ។ យថា ច អនុប្បន្នស្ស ឧបេក្ខាសម្ពោជ្ឈង្គស្ស ឧប្បាទោ ហោតិ តញ្ច បជានាតិ

១ ម. ភាវនាបារិបូរី ។



សន្តានចិត្តរបស់អាត្មាអញ ព្រោះសតិសម្ពោជ្ឈង្គ ដែលមិនមាននៅក្នុងសន្តានចិត្តនៃខ្លួន ក៏ដឹងច្បាស់ថា សតិសម្ពោជ្ឈង្គ មិនមានក្នុងសន្តានចិត្តរបស់អាត្មាអញ ។ ព្រោះសតិសម្ពោជ្ឈង្គ ដែលមិនទាន់កើតឡើង កើតឡើងបាន ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះ[១]ផង ការចំរើនឡើងបរិបូណ៌នៃសតិសម្ពោជ្ឈង្គ ដែលកើតឡើងហើយ ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះ[២]ផង ។ ព្រោះធម្មវិចយសម្ពោជ្ឈង្គ ដែលមាននៅក្នុងសន្តានចិត្តនៃខ្លួន... ។ ព្រោះវីរិយសម្ពោជ្ឈង្គ ដែលមាននៅក្នុងសន្តានចិត្តនៃខ្លួន... ។ ព្រោះបីតិសម្ពោជ្ឈង្គ ដែលមាននៅក្នុងសន្តានចិត្តនៃខ្លួន... ។ ព្រោះបស្សទ្ធិសម្ពោជ្ឈង្គ ដែលមាននៅក្នុងសន្តានចិត្តនៃខ្លួន... ។ ព្រោះសមាធិសម្ពោជ្ឈង្គ ដែលមាននៅក្នុងសន្តានចិត្តនៃខ្លួន... ។ ព្រោះឧបេក្ខាសម្ពោជ្ឈង្គ ដែលមាននៅក្នុងសន្តានចិត្តនៃខ្លួន ក៏ដឹងច្បាស់ថា ឧបេក្ខាសម្ពោជ្ឈង្គមាននៅក្នុងសន្តានចិត្តរបស់អាត្មាអញ ព្រោះឧបេក្ខាសម្ពោជ្ឈង្គ ដែលមិនមាននៅក្នុងសន្តានចិត្តនៃខ្លួន ក៏ដឹងច្បាស់ថា ឧបេក្ខាសម្ពោជ្ឈង្គ មិនមាននៅក្នុងសន្តានចិត្តរបស់អាត្មាអញ ។ ព្រោះឧបេក្ខាសម្ពោជ្ឈង្គ ដែលមិនទាន់កើតឡើង កើតឡើងបានដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង ការចំរើនពេញ

១-២ ហេតុនោះ ក្នុងទីនេះ មានសេចក្តីពន្យល់ក្នុងមហាសតិបដ្ឋានសូត្រ ទីឃនិកាយ មហាវគ្គ ។

យថា ច ឧប្បន្នស្ស ឧបេក្ខាសម្ពោជ្ឈង្គស្ស ភាវនា-
បារិបូរិ ហោតិ តំ បជានាតិ ។ ឥតិ អជ្ឈត្តំ វា
ធម្មេសុ ធម្មានុបស្សី វិហរតិ ពហិទ្ធា វា ធម្មេសុ
ធម្មានុបស្សី វិហរតិ អជ្ឈត្តពហិទ្ធា វា ធម្មេសុ
ធម្មានុបស្សី វិហរតិ សមុទយធម្មានុបស្សី វា ធម្មេសុ
វិហរតិ វយធម្មានុបស្សី វា ធម្មេសុ វិហរតិ អត្ថិ
ធម្មាតិ វា បនស្ស សតិ បច្ចុបដ្ឋិតា ហោតិ យាវ-
ទេវ ញាណមត្តាយ បតិស្សតិមត្តាយ អនិស្សិតោ
ច វិហរតិ ន ច កិញ្ចិ លោកេ ឧបាទិយតិ



បរិបូណ៌នៃឧបេក្ខាសម្ពោជ្ឈង្គ ដែលកើតឡើងហើយ ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង ។ ភិក្ខុពិចារណាឃើញរឿយ ៗ នូវធម៌ក្នុងធម៌ទាំងឡាយជាចំណែកខាងក្នុងជាប្រក្រតី (ដោយការកំណត់នូវសម្ពោ-ជ្ឈង្គទាំង ៧ ) គ្រប់ឥរិយាបថទាំង ៤ ក្តី ពិចារណាឃើញរឿយ ៗ នូវធម៌ក្នុងធម៌ទាំងឡាយជាចំណែកខាងក្រៅជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ក្តី ពិចារណាឃើញរឿយ ៗ នូវធម៌ក្នុងធម៌ទាំងឡាយជាចំណែកខាងក្នុងនិងខាងក្រៅជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ក្តី ពិចារណាឃើញរឿយ ៗ នូវសមុទយធម៌ក្នុងធម៌ទាំងឡាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ក្តី ពិចារណាឃើញរឿយ ៗ នូវវយធម៌ក្នុងធម៌ទាំងឡាយជាប្រក្រតី គ្រប់ឥរិយាបថទាំង៤ ក្តី ពិចារណាឃើញរឿយ ៗ នូវសមុទយធម៌ និងវយធម៌ក្នុងធម៌ទាំងឡាយជាប្រក្រតី គ្រប់ឥរិយាបថទាំង៤ក្តី ពុំនោះសោតស្មារតី (ជាគ្រឿងកំណត់ នូវសម្ពោជ្ឈង្គទាំង ៧ ) របស់ភិក្ខុនោះ ក៏ផ្ចង់ឡើងចំពោះថា ធម៌មានមែន (តែមិនមែនសត្វ មិនមែនបុគ្គល មិនមែនស្រី មិនមែនប្រុសជាដើម ) ត្រាន់តែជាទីកំណត់ដើម្បីឲ្យចំរើនប្រាជ្ញា ដើម្បីឲ្យចំរើនស្មារតីប៉ុណ្ណោះ ភិក្ខុមានចិត្តមិនអាស្រ័យ (តណ្ហានិងទិដ្ឋិ) គ្រប់ឥរិយាបថទាំង ៤ ផង មិនប្រកៀកប្រកាន់អ្វីតិចតួចក្នុងលោកផង ម្នាល

ឯវម្បិ ខោ ភិក្ខវេ ភិក្ខុ ធម្មេសុ ធម្មានុបស្សី វិហរតិ សត្តសុ ពោជ្ឈង្គេសុ ។

ពោជ្ឈង្គបព្វំ(១)។

(១៤៨) បុន ចបរំ ភិក្ខវេ ភិក្ខុ ធម្មេសុ ធម្មានុបស្សី វិហរតិ ចតូសុ អរិយសច្ចេសុ ។ កថញ្ច ភិក្ខវេ ភិក្ខុ ធម្មេសុ ធម្មានុបស្សី វិហរតិ ចតូសុ អរិយសច្ចេសុ ។ ឥធ ភិក្ខវេ ភិក្ខុ ឥទំ ទុក្ខន្តិ យថាភូតំ បជានាតិ អយំ ទុក្ខសមុទយោតិ យថាភូតំ បជានាតិ អយំ ទុក្ខនិរោធោតិ យថាភូតំ បជានាតិ អយំ ទុក្ខនិរោធគាមិនី បដិបទាតិ យថាភូតំ បជានាតិ ។ ឥតិ អជ្ឈត្តំ វា ធម្មេសុ ធម្មានុបស្សី វិហរតិ ពហិទ្ធា វា ធម្មេសុ ធម្មានុបស្សី វិហរតិ អជ្ឈត្តពហិទ្ធា វា ធម្មេសុ

១ ឆដ្ឋបោត្ថកេ បុន ចបរំ ភិក្ខវេតិ ទិស្សតិ ។ ២. ពោជ្ឈង្គបព្វន្តិ ទិស្សតិ ។





ភិក្ខុទាំងឡាយ ភិក្ខុពិចារណាឃើញរឿយ ៗ នូវធម៌ ក្នុងធម៌ទាំងឡាយ គឺពោជ្ឈង្គទាំង ៧ ប្រការជាប្រក្រតី គ្រប់អរិយាបថទាំង ៤ យ៉ាងនេះឯង ។

ពោជ្ឈង្គបព្វៈ ។

(១៤៨) ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុពិចារណាឃើញរឿយ ៗ នូវធម៌ក្នុងធម៌ទាំងឡាយ គឺអរិយសច្ចទាំង ៤ គ្រប់អរិយាបថទាំង ៤ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុពិចារណាឃើញរឿយ ៗ នូវធម៌ក្នុងធម៌ទាំងឡាយ គឺអរិយសច្ច ៤ គ្រប់អរិយាបថទាំង ៤ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ដឹងច្បាស់តាមពិតថា នេះជាទុក្ខ ដឹងច្បាស់តាមពិតថា នេះជាទុក្ខសមុទយ ដឹងច្បាស់តាមពិតថា នេះជាទុក្ខនិរោធ ដឹងច្បាស់តាមពិតថា នេះជាទុក្ខនិរោធគាមិនីបដិបទា ។ ភិក្ខុពិចារណាឃើញរឿយ ៗ នូវធម៌ក្នុងធម៌ទាំងឡាយជាចំណែកខាងក្នុង (ដោយការកំណត់នូវអរិយសច្ចទាំង ៤) ជាប្រក្រតី គ្រប់អរិយាបថទាំង ៤ ក្តី ពិចារណាឃើញរឿយ ៗ នូវធម៌ក្នុងធម៌ទាំងឡាយជាចំណែកខាងក្រៅជាប្រក្រតី គ្រប់អរិយាបថទាំង៤ក្តី ពិចារណាឃើញរឿយ ៗ នូវធម៌ក្នុងធម៌ទាំងឡាយជាចំណែកខាងក្នុងខាងក្រៅជាប្រក្រតី

ធម្មានុបស្សី វិហរតិ សមុទយធម្មានុបស្សី វា ធម្មេសុ វិហរតិ វយធម្មានុបស្សី វា ធម្មេសុ វិហរតិ សមុទយវ-យធម្មានុបស្សី វា ធម្មេសុ វិហរតិ អត្ថិ ធម្មាតិ វា បនស្ស សតិ បច្ចុបដ្ឋិតា ហោតិ យាវទេវ ញាណ-មត្តាយ បតិស្សតិមត្តាយ អនិស្សិតោ ច វិហរតិ ន ច កិញ្ចិ លោកេ ឧបាទិយតិ ឯវំ ខោ ភិក្ខវេ ភិក្ខុ ធម្មេសុ ធម្មានុបស្សី វិហរតិ ចតូសុ អរិយសច្ចេសុ(១) ។

សត្តមំ ។ បឋមភាណវារោ ។

១ ឆាបនូរ ឥតិ អជ្ឈត្តំ វា ។ បេ ។ បឋមភាណវារោតិ ឥមានិ ន ទិស្សន្តិ ។





គ្រប់អរិយាបថទាំង ៤ ក្តី ពិចារណាឃើញរឿយ ៗ នូវសមុទយធម៌(១) ក្នុងធម៌ទាំងឡាយជាប្រក្រតី គ្រប់អរិយាបថទាំង ៤ ក្តី ពិចារណាឃើញរឿយ ៗ នូវវយធម៌(២) ក្នុងធម៌ទាំងឡាយជាប្រក្រតី គ្រប់អរិយាបថទាំង ៤ ក្តី ពិចារណាឃើញរឿយ ៗ នូវសមុទយធម៌និងវយធម៌ ក្នុងធម៌ទាំងឡាយជាប្រក្រតី គ្រប់អរិយាបថទាំង ៤ ក្តី ពុំនោះសោត ស្មារតី (ជាគ្រឿងកំណត់នូវអរិយសច្ចទាំង ៤) របស់ភិក្ខុនោះ ក៏ផ្ចង់ឡើងចំពោះថា ធម៌មានមែន (តែមិនមែនសត្វ មិនមែនបុគ្គល មិនមែនស្រី មិនមែនប្រុសជាដើម) គ្រាន់តែជាគ្រឿងកំណត់ ដើម្បីឲ្យចំរើនប្រាជ្ញា ដើម្បីឲ្យចំរើនស្មារតីប៉ុណ្ណោះ ភិក្ខុមានចិត្តមិនអាស្រ័យ (តណ្ហានិងទិដ្ឋិ) គ្រប់អរិ-យាបថទាំង ៤ផង មិនប្រកៀកប្រកាន់អ្វីមួយក្នុងលោកផង ម្នាលភិក្ខុទាំងឡាយ ភិក្ខុពិចារណាឃើញរឿយ ៗ នូវធម៌ក្នុងធម៌ទាំងឡាយ គឺអរិយសច្ចទាំង ៤ ជាប្រក្រតី គ្រប់អរិយាបថទាំង ៤ យ៉ាងនេះឯង ។

សត្តមៈ ។ ចប់ ភាណវារៈ ទីបឋម ។

១-២ សមុទយធម៌និងវយធម៌ដែលជាដែនឲ្យកើតឡើងនិងសូន្យទៅនៃសច្ចៈទាំងនោះ ជាផលសម្ពោជ្ឈង្គទាំង ៣ ប្រការ មានសតិសម្ពោជ្ឈង្គជាដើម ។ អដ្ឋកថា ។

(១៦៦)[១] កតមញ្ច ភិក្ខវេ ទុក្ខំ អរិយសច្ចំ ។ ជាតិបិ ទុក្ខា ជរាបិ ទុក្ខា មរណម្បិ ទុក្ខំ សោកបរិទេវទុក្ខទោមនស្សុបាយាសាបិ ទុក្ខា អប្បិយេហិ សម្បយោគោ ទុក្ខោ បិយេហិ វិប្បយោគោ ទុក្ខោ យម្បិច្ឆំ ន លភតិ តម្បិ ទុក្ខំ សង្ខិត្តេន បញ្ចុបាទានក្ខន្ធា ទុក្ខា ។ កតមា ច ភិក្ខវេ ជាតិ ។ យា តេសំ តេសំ សត្តានំ តម្ហិ តម្ហិ សត្តនិកាយេ ជាតិ សញ្ជាតិ ឱក្កន្តិ និព្វត្តិ អភិនិព្វត្តិ ខន្ធានំ បាតុភាវោ អាយតនានំ បដិលាភោ អយំ វុច្ចតិ ភិក្ខវេ ជាតិ ។ កតមា ច ភិក្ខវេ ជរា ។ យា តេសំ តេសំ សត្តានំ តម្ហិ តម្ហិ សត្តនិកាយេ ជរា ជីរណតា ខណ្ឌិច្ចំ បាលិច្ចំ វលិត្តចតា អាយុនោ សំហានិ ឥន្ទ្រិយានំ

១ ស្យាមបោត្ថកេ វិត្ថារបាឋោ ។



[១៦៦] ម្នាលភិក្ខុទាំងឡាយ ចុះទុក្ខអរិយសច្ច តើដូចម្តេច ។ ជាតិ ក៏ជាទុក្ខ ជរា ក៏ជាទុក្ខ មរណៈ ក៏ជាទុក្ខ សោកៈ បរិទេវៈ គឺសេចក្តីខ្សឹកខ្សួល ទុក្ខៈ គឺសេចក្តីលំបាកកាយ ទោមនស្សៈ គឺសេចក្តីអាក់អន់ក្នុងចិត្ត ឧបាយាសៈ គឺសេចក្តីចង្អៀតចង្អល់ចិត្ត ក៏សុទ្ធតែជាទុក្ខ អប្បិយេហិសម្បយោគៈ គឺជំណើរជួបប្រសព្វដោយសត្វនិងសង្ខារទាំងឡាយ ដែលមិនជាទីស្រឡាញ់ ក៏ជាទុក្ខ បិយេហិវិប្បយោគៈ គឺសេចក្តីព្រាត់ប្រាសចាកសត្វនិងសង្ខារទាំងឡាយ ដែលជាទីស្រឡាញ់ ក៏ជាទុក្ខ យម្បិច្ឆំនលភតិតម្បិ គឺបុគ្គលចង់បាននូវរបស់ណា ហើយមិនបាននូវរបស់នោះ ក៏ជាទុក្ខ បើពោលដោយសេចក្តីបំប្រួញ ឧបាទានក្ខន្ធទាំង ៥ មានរូបក្ខន្ធជាដើម ក៏ជាទុក្ខ ។ ម្នាលភិក្ខុទាំងឡាយ ចុះដូចម្តេចហៅថា ជាតិ ។ កិរិយាកើតជាដំបូង កិរិយាកើតព្រម ការចុះចាប់ផ្ទៃ ការវិលត្រឡប់មកកើត កិរិយាកើតប្រាកដនៃខន្ធទាំងឡាយ ការបាននូវអាយតនៈ ទាំងឡាយណា របស់សត្វទាំងឡាយនោះ ៗ ក្នុងសត្តនិកាយនោះ ៗ ម្នាលភិក្ខុទាំងឡាយ នេះតថាគតហៅថាជាតិ ។ ម្នាលភិក្ខុទាំងឡាយ ចុះដូចម្តេចហៅថា ជរា ។ ជរា គឺ សេចក្តីគ្រាំគ្រាឬការប្រែប្រួល ធ្មេញបាក់ សក់ស្កូវ ស្បែកជ្រួញជ្រីវយារ កិរិយាថយទៅនៃអាយុ កិរិយាទ្រុឌទ្រោមទៅនៃឥន្ទ្រិយទាំងឡាយ

បរិបាកោ អយំ វុច្ចតិ ភិក្ខវេ ជរា ។ កតមញ្ច ភិក្ខវេ មរណំ ។ យា តេសំ តេសំ សត្តានំ តម្ហា តម្ហា សត្តនិកាយា ចុតិ ចវនតា ភេទោ អន្តរធានំ មច្ចុ មរណំ កាលកិរិយា ខន្ធានំ ភេទោ កឡេវរស្ស និក្ខេបោ ជីវិតិន្ទ្រិយស្ស ឧបច្ឆេទោ ឥទំ វុច្ចតិ ភិក្ខវេ មរណំ ។ កតមោ ច ភិក្ខវេ សោកោ ។ យោ ខោ ភិក្ខវេ អញ្ញតរញ្ញតរេន ព្យសនេន សមន្នាគតស្ស អញ្ញតរញ្ញតរេន ទុក្ខធម្មេន ផុដ្ឋស្ស សោកោ សោចនា សោចិតត្តំ អន្តោសោកោ អន្តោបរិសោកោ អយំ វុច្ចតិ ភិក្ខវេ សោកោ ។ កតមោ ច ភិក្ខវេ បរិទេវោ ។ យោ ខោ ភិក្ខវេ អញ្ញតរញ្ញតរេន ព្យសនេន សមន្នាគតស្ស អញ្ញតរញ្ញតរេន ទុក្ខធម្មេន ផុដ្ឋស្ស អាទេវោ បរិទេវោ អាទេវនា បរិទេវនា អាទេវិតត្តំ បរិទេវិតត្តំ អយំ



ណា របស់សត្វទាំងឡាយនោះ ៗ ក្នុងសត្តនិកាយនោះ ៗ ម្នាលភិក្ខុទាំងឡាយ នេះតថាគតហៅថា ជរា ។ ម្នាលភិក្ខុទាំងឡាយ ចុះដូចម្ដេចហៅថា មរណៈ ។ ភាវៈនៃចិត្តដែលឃ្លាតចេញ ភាវៈនៃចិត្តដែលឃ្លាតទៅ កិរិយាបែកធ្លាយទៅ កិរិយាបាត់បង់ទៅ សេចក្ដីវិនាសនៃជីវិត សេចក្ដីស្លាប់ កាលកិរិយា សេចក្ដីបែកធ្លាយនៃខន្ធទាំងឡាយ កិរិយាដាក់ចុះនៃសាកសព កិរិយាផ្ដាច់បង់នូវជីវិតិន្ទ្រិយណា របស់សត្វទាំងឡាយនោះៗ ចាកសត្តនិកាយនោះៗ ម្នាលភិក្ខុទាំងឡាយ នេះតថាគតហៅថា មរណៈ ។ ម្នាលភិក្ខុទាំងឡាយ ចុះដូចម្ដេចហៅថា សោកៈ ។ ម្នាលភិក្ខុទាំងឡាយ សោកៈ គឺសេចក្ដីស្ដាយស្រណោះ សេចក្ដីស្រងេះស្រងោច សេចក្ដីសោយសោក សេចក្ដីស្ងួតក្នុងចិត្ត សេចក្ដីក្រៀមក្រំក្នុងចិត្តណា របស់សត្វ ដែលប្រកបដោយសេចក្ដីវិនាសណាមួយ ដែលសេចក្ដីទុក្ខណាមួយពាល់ត្រូវ ម្នាលភិក្ខុទាំងឡាយ នេះតថាគតហៅថា សោកៈ ។ ម្នាលភិក្ខុទាំងឡាយ ចុះដូចម្ដេចហៅថា បរិទេវៈ ។ ម្នាលភិក្ខុទាំងឡាយ ភាវៈខ្ញុរក (ប៉ះដល់មានគុណជាដើម) ភាវៈខ្ញុរៀបរាប់ (សរសើរគុណ) កិរិយាយំអណ្ដឺតអណ្ដក កិរិយាយំបម្រាសទទៀល ភាវៈនៃកិរិយាយំអណ្ដឺតអណ្ដក ភាវៈនៃកិរិយាយំបម្រាសទទៀលណា របស់សត្វ ដែលប្រកបដោយសេចក្ដីវិនាសណាមួយ ដែល

វុច្ចតិ ភិក្ខវេ បរិទេវោ ។ កតមញ្ច ភិក្ខវេ ទុក្ខំ ។ យំ ខោ ភិក្ខវេ កាយិកំ ទុក្ខំ កាយិកំ អសាតំ កាយសម្ផស្សជំ ទុក្ខំ អសាតំ វេទយិតំ ឥទំ វុច្ចតិ ភិក្ខវេ ទុក្ខំ ។ កតមញ្ច ភិក្ខវេ ទោមនស្សំ ។ យំ ខោ ភិក្ខវេ ចេតសិកំ ទុក្ខំ ចេតសិកំ អសាតំ មនោសម្ផស្សជំ ទុក្ខំ អសាតំ វេទយិតំ ឥទំ វុច្ចតិ ភិក្ខវេ ទោមនស្សំ ។ កតមោ ច ភិក្ខវេ ឧបាយាសោ ។ យោ ខោ ភិក្ខវេ អញ្ញតរញ្ញតរេន ព្យសនេន សមន្នាគតស្ស អញ្ញតរញ្ញតរេន ទុក្ខធម្មេន ផុដ្ឋស្ស អាយាសោ ឧបាយាសោ អាយាសិតត្តំ ឧបាយាសិតត្តំ អយំ វុច្ចតិ ភិក្ខវេ ឧបាយាសោ ។ កតមោ ច ភិក្ខវេ អប្បិយេហិ សម្បយោគោ ទុក្ខោ ។ ឥធ ភិក្ខវេ



សេចក្តីទុក្ខណាមួយពាល់ត្រូវ ម្នាលភិក្ខុទាំងឡាយ នេះគេហៅថា បរិទេវៈ ។ ម្នាលភិក្ខុទាំងឡាយ ចុះដូចម្តេចហៅថា ទុក្ខៈ ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីលំបាកកាយ សេចក្តីមិនសប្បាយកាយ សេចក្តីលំបាកដែលកើតអំពីកាយសម្ផស្ស ការទទួលនូវសេចក្តីមិនស្រួលណា ម្នាលភិក្ខុទាំងឡាយ នេះគេហៅថា ទុក្ខៈ ។ ម្នាលភិក្ខុទាំងឡាយ ចុះដូចម្តេចហៅថា ទោមនស្សៈ ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីលំបាកក្នុងចិត្ត សេចក្តីមិនសប្បាយក្នុងចិត្ត សេចក្តីលំបាកដែលកើតអំពីមនោសម្ផស្ស ការសោយអារម្មណ៍មិនស្រួលណា ម្នាលភិក្ខុទាំងឡាយ នេះគេហៅថា ទោមនស្សៈ ។ ម្នាលភិក្ខុទាំងឡាយ ចុះដូចម្តេចហៅថា ឧបាយាសៈ ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីតានតឹងក្នុងចិត្ត សេចក្តីចង្អៀតចង្អល់ចិត្ត ភាពនៃសេចក្តីតានតឹងក្នុងចិត្ត ភាពនៃសេចក្តីចង្អៀតចង្អល់ចិត្តណា របស់សត្វដែលប្រកបដោយសេចក្តីវិនាសណាមួយ ដែលសេចក្តីទុក្ខណាមួយពាល់ត្រូវ ម្នាលភិក្ខុទាំងឡាយ នេះគេហៅថា ឧបាយាសៈ ។ ម្នាលភិក្ខុទាំងឡាយ ចុះដូចម្តេចហៅថា អប្បិយេហិសម្បយោគទុក្ខ ។ ម្នាលភិក្ខុទាំងឡាយ

យស្ស តេ ហោន្តិ អនិដ្ឋា អកន្តា អមនាបា រូបា សទ្ទា គន្ធា រសា ផោដ្ឋព្វា យេ វា បនស្ស តេ ហោន្តិ អនត្ថកាមា អហិតកាមា អផាសុកកាមា អយោគក្ខេមកាមា យា តេហិ សង្គតិ(១) សមាគមោ សមោធានំ មិស្សីភាវោ អយំ វុច្ចតិ ភិក្ខវេ អប្បិយេហិ សម្បយោគោ ទុក្ខោ ។ កតមោ ច ភិក្ខវេ បិយេហិ វិប្បយោគោ ទុក្ខោ ។ ឥធ ភិក្ខវេ យស្ស តេ ហោន្តិ ឥដ្ឋា កន្តា មនាបា រូបា សទ្ទា គន្ធា រសា ផោដ្ឋព្វា យេ វា បនស្ស តេ ហោន្តិ អត្ថកាមា ហិតកាមា ផាសុកកាមា យោគក្ខេមកាមា មាតា វា បិតា វា ភាតា វា ភគិនី វា មិត្តា វា អមច្ចា វា ញាតិសាលោហិតា វា យា តេហិ អសង្គតិ អសមាគមោ អសមោធានំ អមិស្សីភាវោ

---

១ ម. សង្គំ សង្គតិ ។



រូបារម្មណ៍ សទ្ទារម្មណ៍ គន្ធារម្មណ៍ រសារម្មណ៍ ផោដ្ឋព្វារម្មណ៍ទាំងឡាយណា ដែលមិនជាទីប្រាថ្នា មិនជាទីត្រេកអរ មិនជាទីគាប់ចិត្ត ក្នុងលោកនេះ មានដល់ជននោះ ពុំនោះសោត ពួកជនណា ដែលប្រាថ្នានូវសេចក្តីមិនចំរើន ប្រាថ្នានូវអំពើឥតប្រយោជន៍ ប្រាថ្នានូវសេចក្តីមិនសប្បាយ ប្រាថ្នានូវសេចក្តីមិនក្សេមក្សាន្តចាកយោគ ដល់សត្វនោះ ការបានជួបគ្នា ការជួបជុំគ្នា ការប្រជុំគ្នា ការនៅច្របូកច្របល់គ្នាណា ដោយអារម្មណ៍និងជនទាំងឡាយនោះ ម្នាលភិក្ខុទាំងឡាយ នេះតថាគតហៅថា អប្បិយេហិ សម្បយោគទុក្ខ ។ ម្នាលភិក្ខុទាំងឡាយ ចុះដូចម្តេចហៅថា បិយេហិ វិប្បយោគទុក្ខ ។ ម្នាលភិក្ខុទាំងឡាយ រូបារម្មណ៍ សទ្ទារម្មណ៍ គន្ធារម្មណ៍ រសារម្មណ៍ ផោដ្ឋព្វារម្មណ៍ទាំងឡាយណា ដែលជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត ក្នុងលោកនេះ មានដល់ជននោះ ពុំនោះសោត ពួកជនណា ទោះមាតាក្តី បិតាក្តី បងប្អូនប្រុសក្តី បងប្អូនស្រីក្តី មិត្តក្តី អាមាត្យក្តី ញាតិសាលោហិតក្តី ដែលជាអ្នកប្រាថ្នាសេចក្តីចំរើន ប្រាថ្នាប្រយោជន៍ ប្រាថ្នាសេចក្តីសប្បាយ ប្រាថ្នាសេចក្តីក្សេមក្សាន្តចាកយោគៈ មានដល់ជននោះ ការមិនបានជួបគ្នា ការមិនជួបជុំគ្នា ការមិនបានប្រជុំគ្នា ការមិនបាននៅច្របូកច្របល់ណា ដោយអារម្មណ៍និងជនទាំងឡាយនោះ

អយំ វុច្ចតិ ភិក្ខវេ បិយេហិ វិប្បយោគោ ទុក្ខោ ។ កតមញ្ច ភិក្ខវេ យម្បិច្ឆំ ន លភតិ តម្បិ ទុក្ខំ ។ ជាតិធម្មានំ ភិក្ខវេ សត្តានំ ឯវំ ឥច្ឆា ឧប្បជ្ជតិ អហោ វត មយំ ន ជាតិធម្មា អស្សាម ន ច វត នោ ជាតិ អាគច្ឆេយ្យាតិ ន ខោ បនេតំ ឥច្ឆាយ បត្តព្វំ ឥទម្បិ យម្បិច្ឆំ ន លភតិ តម្បិ ទុក្ខំ ។ ជរាធម្មានំ ភិក្ខវេ សត្តានំ ... ។ ព្យាធិធម្មានំ ភិក្ខវេ សត្តានំ ... ។ មរណធម្មានំ ភិក្ខវេ សត្តានំ ... ។ សោកបរិទេវទុក្ខ-ទោមនស្សុបាយាសធម្មានំ ភិក្ខវេ សត្តានំ ឯវំ ឥច្ឆា ឧប្បជ្ជតិ អហោ វត មយំ ន សោកបរិទេវទុក្ខ-ទោមនស្សុបាយាសធម្មា អស្សាម ន ច វត នោ សោកបរិទេវទុក្ខទោមនស្សុបាយាសា អាគច្ឆេយ្យុន្តិ



ម្នាលភិក្ខុទាំងឡាយ នេះតថាគតហៅថា បិយេហិ វិប្បយោគទុក្ខ ។ ម្នាលភិក្ខុទាំងឡាយ ចុះដូចម្តេចហៅថា យម្បិច្ឆំ ន លភតិ តម្បិ ទុក្ខំ ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វដែលមានជាតិជាធម្មតា តែងមានសេចក្តីប្រាថ្នា កើតឡើងយ៉ាងនេះថា ធ្វើដូចម្តេចហ្ន៎ ឲ្យយើងទាំងឡាយកុំគប្បីមានជាតិជាធម្មតា ពុំនោះសោត ធ្វើដូចម្តេចហ្ន៎ ជាតិកុំគប្បីមកដល់យើងឡើយ សេចក្តីនេះពួកសត្វគឺមិនបានសម្រេចតាមប្រាថ្នាឡើយ នេះឯង តថាគតហៅថា យម្បិច្ឆំ ន លភតិ តម្បិ ទុក្ខំ ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វដែលមានសេចក្តីគ្រាំគ្រាប្រែប្រួលជាធម្មតា... ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វដែលមានសេចក្តីឈឺចាប់ជាធម្មតា... ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វដែលមានសេចក្តីស្លាប់ជាធម្មតា... ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វដែលមានសេចក្តីសោក សេចក្តីខ្សឹកខ្សួល សេចក្តីលំបាកកាយ សេចក្តីអាក់អន់តូចចិត្ត សេចក្តីខ្វាចផ្សាចិត្ត ជាធម្មតា តែងមានសេចក្តីប្រាថ្នាកើតឡើងយ៉ាងនេះថា ធ្វើដូចម្តេចហ្ន៎ ឲ្យយើងទាំងឡាយកុំគប្បីមានសោក សេចក្តីខ្សឹកខ្សួល សេចក្តីលំបាកកាយ សេចក្តីអាក់អន់តូចចិត្ត សេចក្តីខ្វាចផ្សាចិត្តឡើយ មួយទៀត ធ្វើដូចម្តេចហ្ន៎ សេចក្តីសោក សេចក្តីខ្សឹកខ្សួល សេចក្តីលំបាកកាយ សេចក្តីអាក់អន់តូចចិត្ត សេចក្តីខ្វាចផ្សាចិត្ត កុំគប្បីមកដល់យើងឡើយ

ន ខោ បនេតំ ឥច្ឆាយ បត្តព្វំ ឥទម្បិ យម្បិច្ឆំ ន លភតិ តម្បិ ទុក្ខំ ។ កតមេ ច ភិក្ខវេ សង្ខិត្តេន បញ្ចុបាទានក្ខន្ធា ទុក្ខា ។ សេយ្យថីទំ រូបុបាទានក្ខន្ធោ វេទនុបាទានក្ខន្ធោ សញ្ញុបាទានក្ខន្ធោ សង្ខារុបាទានក្ខន្ធោ វិញ្ញាណុបាទានក្ខន្ធោ ឥមេ វុច្ចន្តិ ភិក្ខវេ សង្ខិត្តេន បញ្ចុបាទានក្ខន្ធា ទុក្ខា ។ ឥទំ វុច្ចតិ ភិក្ខវេ ទុក្ខំ អរិយសច្ចំ ។

[១៤៧] កតមញ្ច ភិក្ខវេ ទុក្ខសមុទយោ អរិយសច្ចំ ។ យាយំ តណ្ហា ពោនោព្ភវិកា នន្ទិរាគសហគតា តត្រតត្រាភិនន្ទិនី សេយ្យថីទំ កាមតណ្ហា ភវតណ្ហា វិភវតណ្ហា ។ សា ខោ បនេសា ភិក្ខវេ តណ្ហា កត្ថ ឧប្បជ្ជមានា ឧប្បជ្ជតិ កត្ថ និវិសមានា និវិសតិ ។ យំ លោកេ បិយរូបំ សាតរូបំ ឯត្ថេសា



សេចក្ដីនេះពុំគប្បីសម្រេចតាមសេចក្ដីប្រាថ្នា នេះឯង ក៏ជាគេហៅ-ថា យម្បិច្ឆំ ន លភតិ តម្បិ ទុក្ខំ ។ ម្នាលភិក្ខុទាំងឡាយ ចុះដូចម្ដេច ឧបាទានក្ខន្ធទាំង ៥ ដោយបំប្រួញ ដែលជាទុក្ខ ។ ឧបាទានក្ខន្ធទាំង ៥ នោះគឺអ្វីខ្លះ គឺ រូប ជាឧបាទានក្ខន្ធ ១ វេទនា ជាឧបាទានក្ខន្ធ ១ សញ្ញា ជាឧបាទានក្ខន្ធ ១ សង្ខារ ជាឧបាទានក្ខន្ធ ១ វិញ្ញាណ ជាឧបាទា-នក្ខន្ធ ១ ម្នាលភិក្ខុទាំងឡាយ ទាំងនេះគេហៅថា ឧបាទានក្ខន្ធទាំងឡាយ ៥ ដោយសេចក្ដីបំប្រួញ ដែលជាទុក្ខ ។ ម្នាលភិក្ខុទាំងឡាយ នេះគេហៅថា ទុក្ខអរិយសច្ច ។

(១៤៧) ម្នាលភិក្ខុទាំងឡាយ ចុះដូចម្ដេចហៅថា ទុក្ខសមុទយអរិយសច្ច ។ តណ្ហាណា ជាធម្មជាតិនាំសត្វ ឲ្យកើតទៀត ប្រកបដោយតម្រេកត្រេកអរ ជាធម្មជាតិនាំសត្វ ឲ្យត្រេកត្រអាលនៅក្នុងភពនោះ ៗ ឬក្នុងអារម្មណ៍នោះ ៗ តណ្ហានោះ តើគឺអ្វីខ្លះ គឺ កាមតណ្ហា (សេចក្ដីប្រាថ្នាក្នុងកាមគុណ[១])១ ភវតណ្ហា (សេចក្ដីប្រាថ្នាក្នុងរូប-ភពនិងអរូបភព[២])១ វិភវតណ្ហា (សេចក្ដីប្រាថ្នាក្នុងភពសូន្យ[៣])១ ។ ម្នាលភិក្ខុទាំងឡាយ ចុះតណ្ហានោះ កាលដែលកើតឡើង រមែងកើតឡើងក្នុងទីណា កាលដែលជាប់នៅ តើជាប់នៅក្នុងទីណា ។ អារម្មណ៍ណាដែលមានសភាវៈគួរស្រឡាញ់ មានសភាវៈគួរត្រេកអរ ក្នុងលោក

១-២-៣ មើលន័យលក្ខណៈ ក្នុងមហាសតិបដ្ឋានសូត្រ ។

តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ ឯត្ថ និវិសមានា និវិសតិ ។ កិញ្ច(១) លោកេ បិយរូបំ សាតរូបំ ។ ចក្ខុំ លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ ឯត្ថ និវិសមានា និវិសតិ ។ សោតំ ឃានំ ជិវ្ហា កាយោ មនោ លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ ឯត្ថ និវិសមានា និវិសតិ ។ រូបា សទ្ទា គន្ធា រសា ផោដ្ឋព្វា ធម្មា លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ ឯត្ថ និវិសមានា និវិសតិ ។ ចក្ខុវិញ្ញាណំ សោតវិញ្ញាណំ ឃានវិញ្ញាណំ ជិវ្ហាវិញ្ញាណំ កាយវិញ្ញាណំ មនោវិញ្ញាណំ លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ ឯត្ថ និវិសមានា និវិសតិ ។ ចក្ខុសម្ផស្សោ សោតសម្ផស្សោ ឃានសម្ផស្សោ ជិវ្ហាសម្ផស្សោ កាយសម្ផស្សោ មនោ-

១ ម. កិញ្ច ។



តណ្ហានុ៎ះ កាលដែលកើតឡើង ក៏កើតឡើងក្នុងអារម្មណ៍នុ៎ះ កាលដែលជាប់នៅ ក៏ជាប់នៅក្នុងអារម្មណ៍នុ៎ះ ។ អារម្មណ៍អ្វីមួយ ដែលមានសភាវៈគួរស្រឡាញ់ មានសភាវៈគួរត្រេកអរក្នុងលោក ។ ភ្នែកមានសភាវៈគួរស្រឡាញ់ មានសភាវៈគួរត្រេកអរក្នុងលោក តណ្ហានុ៎ះកាលដែលកើតឡើង ក៏កើតឡើងក្នុងភ្នែកនុ៎ះ កាលដែលជាប់នៅ ក៏ជាប់នៅក្នុងភ្នែកនុ៎ះ ។ ត្រចៀក ច្រមុះ អណ្តាត កាយ ចិត្ត មានសភាវៈគួរស្រឡាញ់ មានសភាវៈគួរត្រេកអរក្នុងលោក តណ្ហានុ៎ះ កាលដែលកើតឡើង ក៏កើតឡើងក្នុងត្រចៀកជាដើមនុ៎ះ កាលដែលជាប់នៅ ក៏ជាប់នៅក្នុងត្រចៀកជាដើមនុ៎ះ ។ រូប សំឡេង ក្លិន រស ផោដ្ឋព្វៈ និងធម្មារម្មណ៍ ដែលមានសភាវៈគួរស្រឡាញ់ មានសភាវៈគួរត្រេកអរក្នុងលោក តណ្ហានុ៎ះ កាលដែលកើតឡើង ក៏កើតឡើងក្នុងរូបជាដើមនុ៎ះ កាលដែលជាប់នៅក៏ជាប់នៅក្នុងរូបជាដើមនុ៎ះ ។ ចក្ខុវិញ្ញាណ សោតវិញ្ញាណ ឃានវិញ្ញាណ ជិវ្ហាវិញ្ញាណ កាយវិញ្ញាណ មនោវិញ្ញាណ មានសភាវៈគួរស្រឡាញ់ មានសភាវៈគួរត្រេកអរក្នុងលោក តណ្ហានុ៎ះ កាលដែលកើតឡើង ក៏កើតឡើងក្នុងចក្ខុវិញ្ញាណជាដើមនុ៎ះ កាលដែលជាប់នៅ ក៏ជាប់នៅក្នុងចក្ខុវិញ្ញាណជាដើមនុ៎ះ ។ ចក្ខុសម្ផ័ស្ស សោតសម្ផ័ស្ស ឃានសម្ផ័ស្ស ជិវ្ហាសម្ផ័ស្ស កាយសម្ផ័ស្ស មនោសម្ផ័ស្ស

សម្ផស្សោ លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ ឯត្ថ និវិសមានា និវិសតិ ។ ចក្ខុសម្ផស្សជា វេទនា សោតសម្ផស្សជា វេទនា ឃានសម្ផស្សជា វេទនា ជិវ្ហាសម្ផស្សជា វេទនា កាយសម្ផស្សជា វេទនា មនោសម្ផស្សជា វេទនា លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ ឯត្ថ និវិសមានា និវិសតិ ។ រូបសញ្ញា សទ្ទសញ្ញា គន្ធសញ្ញា រសសញ្ញា ផោដ្ឋព្វសញ្ញា ធម្មសញ្ញា លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ ឯត្ថ និវិសមានា និវិសតិ ។ រូបសញ្ចេតនា សទ្ទសញ្ចេតនា គន្ធសញ្ចេតនា រសសញ្ចេតនា ផោដ្ឋព្វសញ្ចេតនា



មានសភាវៈគួរស្រឡាញ់ មានសភាវៈគួរត្រេកអរក្នុងលោក តណ្ហានុ៎ះ កាលដែលកើតឡើង ក៏កើតឡើងក្នុងចក្ខុសម្ផស្សជាដើមនុ៎ះ កាលដែលជាប់នៅ ក៏ជាប់នៅក្នុងចក្ខុសម្ផស្សជាដើមនុ៎ះ ។ វេទនាដែលកើតអំពីចក្ខុសម្ផស្ស វេទនាដែលកើតអំពីសោតសម្ផស្ស វេទនាដែលកើតអំពីឃានសម្ផស្ស វេទនាដែលកើតអំពីជិវ្ហាសម្ផស្ស វេទនាដែលកើតអំពីកាយសម្ផស្ស វេទនាដែលកើតអំពីមនោសម្ផស្ស មានសភាវៈគួរស្រឡាញ់ មានសភាវៈគួរត្រេកអរក្នុងលោក តណ្ហានុ៎ះ កាលដែលកើតឡើង ក៏កើតឡើងតែក្នុងវេទនាដែលកើតអំពីចក្ខុសម្ផស្សជាដើមនុ៎ះ កាលដែលជាប់នៅ ក៏ជាប់នៅក្នុងវេទនាដែលកើតអំពីចក្ខុសម្ផស្សជាដើមនុ៎ះ ។ រូបសញ្ញា (សេចក្តីសំគាល់ក្នុងរូប) សទ្ទសញ្ញា (សេចក្តីសំគាល់ក្នុងសំឡេង) គន្ធសញ្ញា (សេចក្តីសំគាល់ក្នុងក្លិន) រសសញ្ញា (សេចក្តីសំគាល់ក្នុងរស) ផោដ្ឋព្វសញ្ញា (សេចក្តីសំគាល់ក្នុងផោដ្ឋព្វៈ) ធម្មសញ្ញា (សេចក្តីសំគាល់ក្នុងធម្មារម្មណ៍) មានសភាវៈគួរស្រឡាញ់ មានសភាវៈគួរត្រេកអរក្នុងលោក តណ្ហានុ៎ះ កាលដែលកើតឡើង ក៏កើតឡើងតែក្នុងរូបសញ្ញាជាដើមនុ៎ះ កាលដែលជាប់នៅ ក៏ជាប់នៅក្នុងរូបសញ្ញាជាដើមនុ៎ះ ។ រូបសញ្ចេតនា (ការគិតសន្សំនូវរូបារម្មណ៍) សទ្ទសញ្ចេតនា គន្ធសញ្ចេតនា រសសញ្ចេតនា ផោដ្ឋព្វសញ្ចេតនា

ធម្មសញ្ចេតនា លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ ឯត្ថ និវិសមានា និវិសតិ ។ រូបតណ្ហា សទ្ទតណ្ហា គន្ធតណ្ហា រសតណ្ហា ផោដ្ឋព្វតណ្ហា ធម្មតណ្ហា លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ ឯត្ថ និវិសមានា និវិសតិ ។ រូបវិតក្កោ សទ្ទវិតក្កោ គន្ធវិតក្កោ រសវិតក្កោ ផោដ្ឋព្វវិតក្កោ ធម្មវិតក្កោ លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ ឯត្ថ និវិសមានា និវិសតិ ។ រូបវិចារោ សទ្ទវិចារោ គន្ធវិចារោ រសវិចារោ ផោដ្ឋព្វវិចារោ ធម្មវិចារោ លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ ឯត្ថ និវិសមានា និវិសតិ ។ ឥទំ វុច្ចតិ ភិក្ខវេ ទុក្ខសមុទយោ អរិយសច្ចំ ។



ធម្មសញ្ចេតនា មានសភាវៈគួរស្រឡាញ់ មានសភាវៈគួរត្រេកអរក្នុងលោក តណ្ហានុ៎ះ កាលដែលកើតឡើង ក៏កើតឡើងក្នុងការគិតសម្រេចនូវធម្មារម្មណ៍ជាដើមនុ៎ះ កាលដែលជាប់នៅ ក៏ជាប់នៅក្នុងធម្មារម្មណ៍ជាដើមនុ៎ះ ។ រូបតណ្ហា (សេចក្ដីស្រេកឃ្លានក្នុងរូបារម្មណ៍) សទ្ទតណ្ហា គន្ធតណ្ហា រសតណ្ហា ផោដ្ឋព្វតណ្ហា ធម្មតណ្ហា មានសភាវៈគួរស្រឡាញ់ មានសភាវៈគួរត្រេកអរក្នុងលោក តណ្ហានុ៎ះ កាលដែលកើតឡើង ក៏កើតឡើងក្នុងរូបារម្មណ៍ជាដើមនុ៎ះ កាលដែលជាប់នៅ ក៏ជាប់នៅក្នុងរូបជាដើមនុ៎ះ ។ រូបវិតក្កៈ (សេចក្ដីត្រិះរិះក្នុងរូបារម្មណ៍) សទ្ទវិតក្កៈ គន្ធវិតក្កៈ រសវិតក្កៈ ផោដ្ឋព្វវិតក្កៈ ធម្មវិតក្កៈ មានសភាវៈគួរស្រឡាញ់ មានសភាវៈគួរត្រេកអរក្នុងលោក តណ្ហានុ៎ះ កាលដែលកើតឡើង ក៏កើតឡើងក្នុងសេចក្ដីត្រិះរិះក្នុងរូបជាដើមនុ៎ះ កាលដែលជាប់នៅ ក៏ជាប់នៅក្នុងសេចក្ដីត្រិះរិះក្នុងរូបជាដើមនុ៎ះ ។ រូបវិចារៈ (សភាពពិចារណានូវរូបារម្មណ៍) សទ្ទវិចារៈ គន្ធវិចារៈ រសវិចារៈ ផោដ្ឋព្វវិចារៈ ធម្មវិចារៈ មានសភាវៈគួរស្រឡាញ់ មានសភាវៈគួរត្រេកអរក្នុងលោក តណ្ហានុ៎ះ កាលដែលកើតឡើង ក៏កើតឡើងក្នុងសេចក្ដីពិចារណានូវរូបជាដើមនុ៎ះ កាលដែលជាប់នៅ ក៏ជាប់នៅក្នុងរូបជាដើមនុ៎ះ ។ ម្នាលភិក្ខុទាំងឡាយ នេះតថាគតហៅថា ទុក្ខសមុទយអរិយសច្ច ។

(១៤៨) កតមញ្ច ភិក្ខវេ ទុក្ខនិរោធោ អរិយសច្ចំ ។ យោ តស្សាយេវ តណ្ហាយ អសេសវិរាគនិរោធោ ចាគោ បដិនិស្សគ្គោ មុត្តិ អនាលយោ ។ សា ខោ បនេសា ភិក្ខវេ តណ្ហា កត្ថ បហីយមានា បហីយតិ កត្ថ និរុជ្ឈមានា និរុជ្ឈតិ ។ យំ លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា បហីយមានា បហីយតិ ឯត្ថ និរុជ្ឈមានា និរុជ្ឈតិ ។ កិញ្ច លោកេ បិយរូបំ សាតរូបំ ។ ចក្ខុំ លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា បហីយមានា បហីយតិ ឯត្ថ និរុជ្ឈមានា និរុជ្ឈតិ ។ សោតំ ឃានំ ជិវ្ហា កាយោ មនោ លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា បហីយមានា បហីយតិ ឯត្ថ និរុជ្ឈមានា និរុជ្ឈតិ ។ រូបា សទ្ទា គន្ធា រសា ផោដ្ឋព្វា ធម្មា លោកេ បិយរូបំ សាតរូបំ ឯត្ថេសា



(១៤៨) ម្នាលភិក្ខុទាំងឡាយ ចុះដូចម្តេចហៅថា ទុក្ខនិរោធអរិយសច្ច ។ គឺការប្រាសចាកតម្រេកនិងរលត់មិនមានសេសសល់ដោយអរិយមគ្គ ការលះបង់ ការលះចេញ ការរួចស្រឡះ ការមិនអាល័យនូវតណ្ហានោះ (ឈ្មោះថាទុក្ខនិរោធអរិយសច្ច) ។ ម្នាលភិក្ខុទាំងឡាយ តណ្ហានោះឯង ដែលបុគ្គលលះបង់ តើលះបង់ក្នុងទីណា កាលដែលរលត់ទៅ តើរលត់ទៅក្នុងទីណា ។ អារម្មណ៍ណា ដែលមានសភាវៈគួរស្រឡាញ់ មានសភាវៈគួរត្រេកអរក្នុងលោក តណ្ហានុ៎ះ កាលដែលបុគ្គលលះបង់ ក៏លះបង់ក្នុងអារម្មណ៍នុ៎ះ កាលរលត់ ក៏រលត់ក្នុងអារម្មណ៍នុ៎ះ ។ អារម្មណ៍ដូចម្តេច ដែលមានសភាវៈគួរស្រឡាញ់ មានសភាវៈគួរត្រេកអរក្នុងលោក ។ ភ្នែកមានសភាវៈគួរស្រឡាញ់ មានសភាវៈគួរត្រេកអរក្នុងលោក តណ្ហានុ៎ះ កាលដែលបុគ្គលលះបង់ ក៏លះបង់ក្នុងភ្នែកនុ៎ះ កាលរលត់ទៅ ក៏រលត់ទៅក្នុងភ្នែកនុ៎ះ ។ ត្រចៀក ច្រមុះ អណ្តាត កាយ ចិត្ត មានសភាវៈគួរស្រឡាញ់ មានសភាវៈគួរត្រេកអរក្នុងលោក តណ្ហានុ៎ះ កាលដែលបុគ្គលលះបង់ ក៏លះបង់ក្នុងត្រចៀកជាដើមនុ៎ះ កាលរលត់ទៅ ក៏រលត់ទៅក្នុងត្រចៀកជាដើមនុ៎ះ ។ រូបារម្មណ៍ សទ្ទារម្មណ៍ គន្ធារម្មណ៍ រសារម្មណ៍ ផោដ្ឋព្វារម្មណ៍ ធម្មារម្មណ៍ មានសភាវៈគួរស្រឡាញ់ មានសភាវៈគួរត្រេកអរក្នុងលោក តណ្ហានុ៎ះ កាលដែល

តណ្ហា បហីយមានា បហីយតិ ឯត្ថ និរុជ្ឈមានា និរុជ្ឈតិ ។ ចក្ខុវិញ្ញាណំ សោតវិញ្ញាណំ ឃានវិញ្ញា-ណំ ជិវ្ហាវិញ្ញាណំ កាយវិញ្ញាណំ មនោវិញ្ញាណំ លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា ប-ហីយមានា បហីយតិ ឯត្ថ និរុជ្ឈមានា និរុជ្ឈតិ ។ ចក្ខុសម្ផស្សោ សោតសម្ផស្សោ ឃានសម្ផស្សោ ជិវ្ហា-សម្ផស្សោ កាយសម្ផស្សោ មនោសម្ផស្សោ លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា បហីយមានា បហីយតិ ឯត្ថ និរុជ្ឈមានា និរុជ្ឈតិ ។ ចក្ខុសម្ផស្សជា វេទនា សោតសម្ផស្សជា វេទនា ឃានសម្ផស្សជា វេទនា ជិវ្ហាសម្ផស្សជា វេទនា កាយសម្ផស្សជា វេទនា មនោសម្ផស្សជា វេទនា លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា បហីយមានា បហីយតិ ឯត្ថ និរុជ្ឈ-មានា និរុជ្ឈតិ ។ រូបសញ្ញា សទ្ទសញ្ញា គន្ធសញ្ញា



បុគ្គលលះបង់ ក៏លះបង់ក្នុងរូបារម្មណ៍ជាដើមនុ៎ះ កាលរលត់ទៅ ក៏រលត់ទៅក្នុងរូបារម្មណ៍ជាដើមនុ៎ះ ។ ចក្ខុវិញ្ញាណ សោតវិញ្ញាណ ឃាន-វិញ្ញាណ ជិវ្ហាវិញ្ញាណ កាយវិញ្ញាណ មនោវិញ្ញាណ មានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរក្នុងលោក តណ្ហានុ៎ះ កាលដែលបុគ្គលលះបង់ ក៏លះបង់ក្នុងចក្ខុវិញ្ញាណជាដើមនុ៎ះ កាលរលត់ទៅ ក៏រលត់ទៅក្នុងចក្ខុវិញ្ញាណជាដើមនុ៎ះ ។ ចក្ខុសម្ផស្ស សោតសម្ផស្ស ឃានសម្ផស្ស ជិវ្ហាសម្ផស្ស កាយសម្ផស្ស មនោសម្ផស្ស មានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរក្នុងលោក តណ្ហានុ៎ះ កាលដែលបុគ្គលលះបង់ ក៏លះបង់ក្នុងចក្ខុសម្ផស្សជាដើមនុ៎ះ កាលរលត់ទៅ ក៏រលត់ទៅក្នុងចក្ខុសម្ផស្សជាដើមនុ៎ះ ។ វេទនាដែលកើតអំពីចក្ខុសម្ផស្ស វេទនាដែលកើតអំពីសោតសម្ផស្ស វេទនាដែលកើតអំពីឃានសម្ផស្ស វេទនាដែលកើតអំពីជិវ្ហាសម្ផស្ស វេទនាដែលកើតអំពីកាយសម្ផស្ស វេ-ទនាដែលកើតអំពីមនោសម្ផស្ស មានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរក្នុងលោក តណ្ហានុ៎ះ កាលដែលបុគ្គលលះបង់ ក៏លះបង់ក្នុងវេទនាដែលកើតអំពីចក្ខុសម្ផស្សជាដើមនុ៎ះ កាលរលត់ទៅ ក៏រលត់ទៅក្នុងវេទនាដែលកើតអំពីចក្ខុសម្ផស្សជាដើមនុ៎ះ ។ រូបសញ្ញា សទ្ទសញ្ញា គន្ធសញ្ញា

រសសញ្ញា ផោដ្ឋព្វសញ្ញា ធម្មសញ្ញា លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា បហីយមានា បហីយតិ ឯត្ថ និរុជ្ឈមានា និរុជ្ឈតិ ។ រូបសញ្ចេតនា សទ្ទសញ្ចេតនា គន្ធសញ្ចេតនា រសសញ្ចេតនា ផោដ្ឋព្វសញ្ចេតនា ធម្មសញ្ចេតនា លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា បហីយមានា បហីយតិ ឯត្ថ និរុជ្ឈមានា និរុជ្ឈតិ ។ រូបតណ្ហា សទ្ទតណ្ហា គន្ធតណ្ហា រសតណ្ហា ផោដ្ឋព្វតណ្ហា ធម្មតណ្ហា លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា បហីយមានា បហីយតិ ឯត្ថ និរុជ្ឈមានា និរុជ្ឈតិ ។ រូបវិតក្កោ សទ្ទវិតក្កោ គន្ធវិតក្កោ រសវិតក្កោ ផោដ្ឋព្វវិតក្កោ ធម្មវិតក្កោ លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា បហីយមានា បហីយតិ ឯត្ថ និរុជ្ឈមានា និរុជ្ឈតិ ។ រូបវិចារោ សទ្ទវិចារោ គន្ធវិចារោ រសវិចារោ ផោដ្ឋព្វវិចារោ ធម្មវិចារោ លោកេ បិយរូបំ សាតរូបំ



រសសញ្ញា ផោដ្ឋព្វសញ្ញា ធម្មសញ្ញា មានសភាវៈគួរស្រឡាញ់ មានសភាវៈគួរត្រេកអរក្នុងលោក តណ្ហានុ៎ះ កាលដែលបុគ្គលលះបង់ ក៏លះបង់ក្នុងរូបសញ្ញាជាដើមនុ៎ះ កាលរលត់ទៅ ក៏រលត់ទៅក្នុងរូបសញ្ញាជាដើមនុ៎ះ ។ រូបសញ្ចេតនា សទ្ទសញ្ចេតនា គន្ធសញ្ចេតនា រសសញ្ចេតនា ផោដ្ឋព្វសញ្ចេតនា ធម្មសញ្ចេតនា មានសភាវៈគួរស្រឡាញ់ មានសភាវៈគួរត្រេកអរក្នុងលោក តណ្ហានុ៎ះ កាលដែលបុគ្គលលះបង់ ក៏លះបង់ក្នុងរូបសញ្ចេតនាជាដើមនុ៎ះ កាលរលត់ទៅ ក៏រលត់ទៅក្នុងរូបសញ្ចេតនាជាដើមនុ៎ះ ។ រូបតណ្ហា សទ្ទតណ្ហា គន្ធតណ្ហា រសតណ្ហា ផោដ្ឋព្វតណ្ហា ធម្មតណ្ហា មានសភាវៈគួរស្រឡាញ់ មានសភាវៈគួរត្រេកអរ ក្នុងលោក តណ្ហានុ៎ះ កាលដែលបុគ្គលលះបង់ ក៏លះបង់ក្នុងរូបតណ្ហា ជាដើមនុ៎ះ កាលរលត់ទៅ ក៏រលត់ទៅក្នុងរូបតណ្ហាជាដើមនុ៎ះ ។ រូបវិតក្កៈ សទ្ទវិតក្កៈ គន្ធវិតក្កៈ រសវិតក្កៈ ផោដ្ឋព្វវិតក្កៈ ធម្មវិតក្កៈ មានសភាវៈគួរស្រឡាញ់ មានសភាវៈគួរត្រេកអរ ក្នុងលោក តណ្ហានុ៎ះ កាលដែលបុគ្គលលះបង់ ក៏លះបង់ក្នុងរូបវិតក្កៈជាដើមនុ៎ះ កាលរលត់ទៅ ក៏រលត់ទៅក្នុងរូបវិតក្កៈជាដើមនុ៎ះ ។ រូបវិចារៈ សទ្ទវិចារៈ គន្ធវិចារៈ រសវិចារៈ ផោដ្ឋព្វវិចារៈ ធម្មវិចារៈ មានសភាវៈគួរស្រឡាញ់ មានសភាវៈគួរត្រេកអរ ក្នុងលោក តណ្ហានុ៎ះ

ឯត្ថេសា តណ្ហា បហីយមានា បហីយតិ ឯត្ថ និរុជ្ឈមានា និរុជ្ឈតិ ។ ឥទំ វុច្ចតិ ភិក្ខវេ ទុក្ខនិរោធោ អរិយសច្ចំ ។

(១៤៩) កតមញ្ច ភិក្ខវេ ទុក្ខនិរោធគាមិនី បដិបទា អរិយសច្ចំ ។ អយមេវ អរិយោ អដ្ឋង្គិកោ មគ្គោ សេយ្យថីទំ សម្មាទិដ្ឋិ សម្មាសង្កប្បោ សម្មាវាចា សម្មាកម្មន្តោ សម្មាអាជីវោ សម្មាវាយាមោ សម្មាសតិ សម្មាសមាធិ ។ កតមា ច ភិក្ខវេ សម្មាទិដ្ឋិ ។ យំ ខោ ភិក្ខវេ ទុក្ខេ ញាណំ ទុក្ខសមុទយេ ញាណំ ទុក្ខនិរោធេ ញាណំ ទុក្ខនិរោធគាមិនិយា បដិបទាយ ញាណំ អយំ វុច្ចតិ ភិក្ខវេ សម្មាទិដ្ឋិ ។ កតមោ ច ភិក្ខវេ សម្មាសង្កប្បោ ។ នេក្ខម្មសង្កប្បោ អព្យាបាទសង្កប្បោ អវិហឹសាសង្កប្បោ អយំ វុច្ចតិ ភិក្ខវេ សម្មាសង្កប្បោ ។ កតមា ច ភិក្ខវេ



កាលដែលបុគ្គលលះបង់ ក៏លះបង់ក្នុងបិយតារៈជាដើមនុ៎ះ កាលរលត់ទៅ ក៏រលត់ទៅក្នុងបិយតារៈជាដើមនុ៎ះ ។ ម្នាលភិក្ខុទាំងឡាយ នេះតថាគតហៅថា ទុក្ខនិរោធអរិយសច្ច ។

(១៤៩) ម្នាលភិក្ខុទាំងឡាយ ចុះដូចម្តេចហៅថា ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច ។ អរិយមគ្គប្រកបដោយអង្គ ៨ ប្រការនេះ គឺសម្មាទិដ្ឋិ (ប្រាជ្ញាយល់ត្រូវ) ១ សម្មាសង្កប្បៈ (ប្រាជ្ញាត្រិះរិះត្រូវ) ១ សម្មាវាចា (សំដីត្រូវ) ១ សម្មាកម្មន្តៈ (ការងារត្រូវ) ១ សម្មាអាជីវៈ (ចិញ្ចឹមជីវិតត្រូវ) ១ សម្មាវាយាមៈ (ការព្យាយាមត្រូវ) ១ សម្មាសតិ (ការរំលឹកស្មារតីត្រូវ) ១ សម្មាសមាធិ (ការតាំងចិត្តត្រូវ) ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះដូចម្តេចហៅថា សម្មាទិដ្ឋិ ។ ម្នាលភិក្ខុទាំងឡាយ ប្រាជ្ញាជាគ្រឿងដឹងក្នុងកងទុក្ខណា ប្រាជ្ញាជាគ្រឿងដឹងក្នុងតណ្ហា ជាដែនកើតនៃកងទុក្ខណា ប្រាជ្ញាជាគ្រឿងដឹងក្នុងធម៌ជាទីរលត់នៃកងទុក្ខណា ប្រាជ្ញាជាគ្រឿងដឹងក្នុងដំណើរជាទីទៅកាន់ទីរលត់ទុក្ខណា ម្នាលភិក្ខុទាំងឡាយ នេះតថាគតហៅថា សម្មាទិដ្ឋិ ។ ម្នាលភិក្ខុទាំងឡាយ ចុះដូចម្តេចហៅថា សម្មាសង្កប្បៈ ។ សេចក្តីត្រិះរិះក្នុងការចេញចាកកាម ១ សេចក្តីត្រិះរិះក្នុងការមិនព្យាបាទ ១ សេចក្តីត្រិះរិះក្នុងការមិនបៀតបៀន ១ ម្នាលភិក្ខុទាំងឡាយ នេះតថាគតហៅថា សម្មាសង្កប្បៈ ។ ម្នាលភិក្ខុទាំងឡាយ ចុះដូចម្តេច

សម្មាវាចា ។ មុសាវាទា វេរមណី បិសុណាយ វា-
ចាយ វេរមណី ផរុសាយ វាចាយ វេរមណី សម្ផប្ប-
លាបា វេរមណី អយំ វុច្ចតិ ភិក្ខវេ សម្មាវាចា ។
កតមោ ច ភិក្ខវេ សម្មាកម្មន្តោ ។ បាណាតិបាតា
វេរមណី អទិន្នាទានា វេរមណី កាមេសុ មិច្ឆាចារា
វេរមណី អយំ វុច្ចតិ ភិក្ខវេ សម្មាកម្មន្តោ ។
កតមោ ច ភិក្ខវេ សម្មាអាជីវោ ។ ឥធ ភិក្ខវេ
អរិយសាវកោ មិច្ឆាអាជីវំ បហាយ សម្មាអាជីវេន
ជីវិកំ កប្បេតិ អយំ វុច្ចតិ ភិក្ខវេ សម្មាអាជីវោ ។
កតមោ ច ភិក្ខវេ សម្មាវាយាមោ ។ ឥធ ភិក្ខវេ
ភិក្ខុ អនុប្បន្នានំ បាបកានំ អកុសលានំ ធម្មានំ
អនុប្បាទាយ ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ
ចិត្តំ បគ្គណ្ហាតិ បទហតិ ឧប្បន្នានំ បាបកានំ
អកុសលានំ ធម្មានំ បហានាយ ឆន្ទំ ជនេតិ
វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ



ហៅថា សម្មាវាចា ។ ចេតនាវៀរចាកមុសាវាទ ១ ចេតនាវៀរចាក
បិសុណាវាចា ១ ចេតនាវៀរចាកផរុសវាចា ១ ចេតនាវៀរចាកសម្ផ-
ប្បលាបៈ ១ ម្នាលភិក្ខុទាំងឡាយ នេះតថាគតហៅថា សម្មាវាចា ។ ម្នាល
ភិក្ខុទាំងឡាយ ចុះដូចម្ដេចហៅថា សម្មាកម្មន្តៈ ។ ចេតនាវៀរចាក
បាណាតិបាត ១ ចេតនាវៀរចាកអទិន្នាទាន ១ ចេតនាវៀរចាកកាមេ-
សុមិច្ឆាចារ ១ ម្នាលភិក្ខុទាំងឡាយ នេះតថាគតហៅថា សម្មាកម្មន្តៈ ។
ម្នាលភិក្ខុទាំងឡាយ ចុះដូចម្ដេចហៅថា សម្មាអាជីវៈ ។ ម្នាលភិក្ខុ
ទាំងឡាយ អរិយសាវ័កក្នុងសាសនានេះ លះបង់នូវមិច្ឆាអាជីវៈ គឺការ
ចិញ្ចឹមជីវិតខុស ហើយប្រព្រឹត្តចិញ្ចឹមជីវិតដោយសម្មាអាជីវៈ គឺការចិញ្ចឹម
ជីវិតត្រូវ ម្នាលភិក្ខុទាំងឡាយ នេះតថាគតហៅថា សម្មាអាជីវៈ ។
ម្នាលភិក្ខុទាំងឡាយ ចុះដូចម្ដេចហៅថា សម្មាវាយាមៈ ។ ម្នាល
ភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ញុំាងឆន្ទៈឲ្យកើត ធ្វើនូវព្យាយាម
ប្រារព្ធព្យាយាម ផ្គងចិត្ត តាំងចិត្ត ដើម្បីធ្វើអកុសលធម៌ទាំងឡាយ
ដ៏លាមក ដែលមិនទាន់កើតឡើង មិនឲ្យកើតឡើងបាន ធ្វើឆន្ទៈឲ្យ
កើត ធ្វើព្យាយាម ប្រារព្ធព្យាយាម ផ្គងចិត្ត តាំងចិត្ត ដើម្បីលះបង់នូវអ-
កុសលធម៌ទាំងឡាយដ៏លាមក ដែលកើតឡើងហើយ (ឲ្យសាបសូន្យទៅ)

អនុប្បន្នានំ កុសលានំ ធម្មានំ ឧប្បាទាយ ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ឧប្បន្នានំ កុសលានំ ធម្មានំ ឋិតិយា អសម្មោសាយ ភិយ្យោភាវាយ វេបុល្លាយ ភាវនាយ បារិបូរិយា ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ អយំ វុច្ចតិ ភិក្ខវេ សម្មា-វាយាមោ ។ កតមា ច ភិក្ខវេ សម្មាសតិ ។ ឥធ ភិក្ខវេ ភិក្ខុ កាយេ កាយានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ វេទនាសុ វេទនានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ ចិត្តេ ចិត្តានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោ-កេ អភិជ្ឈាទោមនស្សំ ។ ធម្មេសុ ធម្មានុបស្សី



ញុំាងឆន្ទៈឲ្យកើត ព្យាយាម ប្រារព្ធព្យាយាម ផ្គងចិត្ត តាំងចិត្ត ដើម្បីធ្វើកុសលធម៌ទាំងឡាយ ដែលមិនទាន់កើតឡើង ឲ្យកើតឡើង បាន ញុំាងឆន្ទៈឲ្យកើត ព្យាយាម ប្រារព្ធព្យាយាម ផ្គងចិត្ត តាំងចិត្ត ដើម្បីធ្វើកុសលធម៌ទាំងឡាយ ដែលកើតឡើងហើយ ឲ្យឋិតនៅយូរអង្វែង មិនឲ្យសាបសូន្យ ឲ្យចំរើនឡើង ឲ្យធំទូលាយ ឲ្យចំរើនពេញបរិបូណ៌ ។ ម្នាលភិក្ខុទាំងឡាយ នេះតថាគតហៅថា សម្មាវាយាមៈ ។ ម្នាលភិក្ខុទាំងឡាយ ចុះដូចម្តេចហៅថា សម្មាសតិ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពិចារណាឃើញរឿយៗ នូវកាយក្នុងកាយជាប្រក្រតី គ្រប់សរិយាបថទាំង ៤ មានព្យាយាមជាគ្រឿងដុតកំដៅនូវកិ-លេស មានសេចក្តីដឹងខ្លួន ទាំងមានស្មារតីបន្ទោបង់នូវអភិជ្ឈា និងទោមនស្សក្នុងលោកចេញ ។ ភិក្ខុពិចារណាឃើញរឿយៗនូវវេទនាក្នុងវេទនាទាំងឡាយជាប្រក្រតី គ្រប់សរិយាបថទាំង ៤ មានព្យាយាមជាគ្រឿងដុតកំដៅនូវកិលេស មានសេចក្តីដឹងខ្លួន ទាំងមានស្មារតី បន្ទោបង់នូវអភិជ្ឈា និងទោ-មនស្សក្នុងលោកចេញ ។ ពិចារណាឃើញរឿយ ៗ នូវចិត្តក្នុងចិត្តជាប្រ-ក្រតី គ្រប់សរិយាបថទាំង៤ មានព្យាយាមជាគ្រឿងដុតកំដៅកិលេស មានសេចក្តីដឹងខ្លួន ទាំងមានស្មារតីបន្ទោបង់នូវអភិជ្ឈា និងទោមនស្សក្នុងលោកចេញ ។ ពិចារណាឃើញរឿយ ៗ នូវធម៌ក្នុងធម៌ទាំងឡាយជាប្រក្រតី

វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ អយំ វុច្ចតិ ភិក្ខវេ សម្មាសតិ ។ កតមោ ច ភិក្ខវេ សម្មាសមាធិ ។ ឥធ ភិក្ខវេ ភិក្ខុ វិវិច្ចេវ កាមេហិ វិវិច្ច អកុសលេហិ ធម្មេហិ សវិតក្កំ សវិចារំ វិវេកជំ បីតិសុខំ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ វិតក្កវិចារានំ វូបសមា អជ្ឈត្តំ សម្បសាទនំ ចេតសោ ឯកោទិភាវំ អវិតក្កំ អវិចារំ សមាធិជំ បីតិសុខំ ទុតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ បីតិយា ច វិរាគា ឧបេក្ខកោ ច វិហរតិ សតោ ច សម្បជានោ សុខញ្ច កាយេន បដិសំវេទេតិ យន្តំ អរិយា អាចិក្ខន្តិ ឧបេក្ខកោ សតិមា សុខវិហារីតិ តតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ សុខស្ស ច បហានា ទុក្ខស្ស ច បហានា បុព្វេវ សោមនស្សទោមនស្សានំ អត្ថង្គមា



គ្រប់ឥរិយាបថទាំង ៤ មានព្យាយាមជាគ្រឿងដុតកំដៅកិលេស មានសេចក្ដីដឹងខ្លួន មានសតិ បន្ទោបង់នូវអភិជ្ឈានិងទោមនស្ស ក្នុងលោកចេញ ម្នាលភិក្ខុទាំងឡាយ នេះតថាគតហៅថា សម្មាសតិ ។ ម្នាលភិក្ខុទាំងឡាយ ចុះដូចម្ដេចហៅថា សម្មាសមាធិ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ស្ងប់ស្ងាត់ចាកកាមទាំងឡាយ ស្ងប់ស្ងាត់ចាកអកុសលធម៌ ទាំងឡាយហើយ ក៏ចូលបឋមជ្ឈាន ដែលប្រកបដោយវិតក្កៈ វិចារៈ មានបីតិនិងសុខៈដែលកើតអំពីសេចក្ដីស្ងប់ស្ងាត់ជាអារម្មណ៍ លុះភិក្ខុនោះចូលទៅដល់ការរម្ងាប់នូវវិតក្កៈវិចារៈរួចហើយ ក៏បានចូលដល់ទុតិយជ្ឈាន ជាទីជ្រះថ្លាប្រព្រឹត្តទៅខាងក្នុង ញុំាងចិត្តឲ្យជាធំចំរើនឡើង មិនមានវិតក្កៈ មិនវិចារៈទេ មានតែបីតិនិងសុខៈ ដែលកើតអំពីសមាធិប៉ុណ្ណោះ លុះលះបង់បីតិចេញហើយ ភិក្ខុនោះជាបុគ្គលមានចិត្តព្រងើយ មានសតិនិងសម្បជញ្ញៈ សោយសេចក្ដីសុខដោយនាមកាយផង ព្រោះអរិយបុគ្គលទាំងឡាយ តែងហៅនូវភិក្ខុដែលបានតតិយជ្ឈាននោះថា ជាអ្នកមានចិត្តព្រងើយកន្តើយ ជាអ្នកមានសតិ ជាអ្នកនៅជាសុខ ភិក្ខុនោះក៏បានដល់តតិយជ្ឈាន លុះលះបង់នូវសេចក្ដីសុខនិងសេចក្ដីទុក្ខបានហើយ ក៏រលត់នូវសោមនស្សនិងទោមនស្សអំពីមុន

អទុក្ខមសុខំ ឧបេក្ខាសតិបារិសុទ្ធិំ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ អយំ វុច្ចតិ ភិក្ខវេ សម្មាសមាធិ ។ ឥទំ វុច្ចតិ ភិក្ខវេ ទុក្ខនិរោធគាមិនី បដិបទា អរិយសច្ចំ ។

(១៤០) ឥតិ អជ្ឈត្តំ វា ធម្មេសុ ធម្មានុបស្សី វិហរតិ ពហិទ្ធា វា ធម្មេសុ ធម្មានុបស្សី វិហរតិ អជ្ឈត្តពហិទ្ធា វា ធម្មេសុ ធម្មានុបស្សី វិហរតិ សមុទយធម្មានុបស្សី វា ធម្មេសុ វិហរតិ វយធម្មានុបស្សី វា ធម្មេសុ វិហរតិ សមុទយវយធម្មានុបស្សី វា ធម្មេសុ វិហរតិ អត្ថិ ធម្មាតិ វា បនស្ស សតិ បច្ចុបដ្ឋិតា ហោតិ យាវទេវ ញាណមត្តាយ



ចូលកាន់ចតុត្ថជ្ឈាន ដ៏ឥតទុក្ខឥតសុខ មានសតិដ៏ស្អាតបំពោះត្រង់ឧបេក្ខា ម្នាលភិក្ខុទាំងឡាយ នេះតថាគតហៅថា សម្មាសមាធិ ។ ម្នាលភិក្ខុទាំងឡាយ នេះតថាគតហៅថា ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច ។

(១៤០) ភិក្ខុពិចារណាឃើញរឿយៗ នូវធម៌ក្នុងធម៌ទាំងឡាយជាខាងក្នុង (ដោយការកំណត់នូវអរិយសច្ចទាំង៤) ជាប្រក្រតី គ្រប់អរិយាបថទាំង ៤ ក្តី ពិចារណាឃើញរឿយៗ នូវធម៌ក្នុងធម៌ទាំងឡាយជាខាងក្រៅជាប្រក្រតី គ្រប់អរិយាបថទាំង ៤ ក្តី ពិចារណាឃើញរឿយៗ នូវធម៌ក្នុងធម៌ទាំងឡាយជាខាងក្នុងខាងក្រៅជាប្រក្រតី គ្រប់អរិយាបថទាំង ៤ ក្តី ពិចារណាឃើញរឿយៗ នូវសភាវៈដែលកើតឡើងនៃសច្ចៈទាំង ៤ គួរតាមពិត ក្នុងសច្ចធម៌ទាំងឡាយជាប្រក្រតី គ្រប់អរិយាបថទាំង ៤ ក្តី ពិចារណាឃើញរឿយៗ នូវសភាវៈសូន្យទៅនៃសច្ចៈទាំង៤ គួរតាមពិត ក្នុងសច្ចធម៌ទាំងឡាយជាប្រក្រតី គ្រប់អរិយាបថទាំង៤ក្តី ពិចារណាឃើញរឿយៗ នូវសភាវៈដែលកើតឡើងនិងសូន្យទៅនៃសច្ចៈទាំង៤ គួរតាមពិតក្នុងសច្ចធម៌ទាំងឡាយជាប្រក្រតី គ្រប់អរិយាបថទាំង៤ក្តី ពុំនោះសោត ស្មារតី (ជាគ្រឿងកំណត់នូវសច្ចៈទាំង៤) របស់ភិក្ខុនោះ ក៏ផ្ចង់ឡើងចំពោះថា ធម៌មានមែន (តែមិនមែនសត្វ មិនមែនបុគ្គល មិនមែនស្រី មិនមែនប្រុសជាដើម) គ្រាន់តែជាទីកំណត់ ដើម្បីឲ្យចំរើនប្រាជ្ញា

បតិស្សតិមត្តាយ អនិស្សិតោ ច វិហរតិ ន ច កិញ្ចិ លោកេ ឧបាទិយតិ ឯវម្បិ ខោ ភិក្ខវេ ភិក្ខុ ធម្មេសុ ធម្មានុបស្សី វិហរតិ ចតូសុ អរិយសច្ចេសុ(១) ។

(១៨១) យោ ហិ កោចិ ភិក្ខវេ ឥមេ ចត្តារោ សតិប្បដ្ឋានេ ឯវំ ភាវេយ្យ សត្ត វស្សានិ តស្ស ទ្វិន្នំ ផលានំ អញ្ញតរំ ផលំ បាដិកង្ខំ ទិដ្ឋេវ ធម្មេ អញ្ញា សតិ វា ឧបាទិសេសេ អនាគាមិតា តិដ្ឋន្តុ ភិក្ខវេ សត្ត វស្សានិ ។ យោ ហិ កោចិ ភិក្ខវេ ឥមេ ចត្តារោ សតិ-ប្បដ្ឋានេ ឯវំ ភាវេយ្យ ឆ វស្សានិ បញ្ច វស្សានិ ចត្តារិ វស្សានិ តីណិ វស្សានិ ទ្វេ វស្សានិ ឯកំ វស្សំ... តិដ្ឋតុ ភិក្ខវេ ឯកំ វស្សំ ។ យោ ហិ កោចិ ភិក្ខវេ ឥមេ ចត្តារោ សតិប្បដ្ឋានេ ឯវំ ភាវេយ្យ សត្ត មាសានិ

១ ឍាបន្តរ បុន សព្វបទំ ។ ធម្មានុបស្សនាសតិប្បដ្ឋានំ និដ្ឋិតំ ។





ដើម្បីឲ្យបានចំរើនស្មារតីប៉ុណ្ណោះ ភិក្ខុនោះឈ្មោះថាមិនអាស្រ័យ (តណ្ហានិងទិដ្ឋិ) ផង មិនប្រកៀកប្រកាន់អ្វីតិចតួចក្នុងលោកផង ម្នាលភិក្ខុទាំងឡាយ ភិក្ខុពិចារណាឃើញរឿយ ៗ នូវធម៌ក្នុងធម៌ទាំងឡាយ គឺអរិយសច្ចទាំង៤ យ៉ាងនេះឯង ។

(១៨១) ម្នាលភិក្ខុទាំងឡាយ បុគ្គលណាមួយ បានចំរើនសតិប្បដ្ឋានទាំង ៤ អស់ ៧ ឆ្នាំ តាមលំដាប់នៃវិធីចំរើនដែលតថាគតបានពោលហើយយ៉ាងនេះ បណ្ដាផលទាំងឡាយ ២ ផលណាមួយគឺគង់នឹងបានសម្រេចដល់បុគ្គលនោះ តាមសេចក្ដីប្រាថ្នាដោយពិត គឺបាននឹងបានសម្រេចនូវព្រះអរហត្តក្នុងបច្ចុប្បន្នជាតិក្ដី កាលបើនៅមានឧបាទានក្ខន្ធសេសសល់នៅ ក៏គង់នឹងបានសម្រេចអនាគាមិផលដល់បុគ្គល ពុំខានឡើយ ម្នាលភិក្ខុទាំងឡាយ កុំថាដល់ទៅអស់ ៧ ឆ្នាំឡើយ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលណាមួយ បានចំរើនសតិ-ប្បដ្ឋានទាំង ៤ នេះ អស់ ៦ ឆ្នាំ ៥ ឆ្នាំ ៤ ឆ្នាំ ៣ ឆ្នាំ ២ ឆ្នាំ ១ ឆ្នាំ តាមលំដាប់វិធីចំរើនដែលតថាគតបានពោលហើយយ៉ាងនេះ ម្នាលភិក្ខុទាំងឡាយ កុំថាដល់ទៅអស់ ១ ឆ្នាំឡើយ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលណាមួយ បានចំរើនសតិប្បដ្ឋានទាំង ៤ នេះ អស់ ៧ ខែ តាម

តស្ស ទ្វិន្នំ ផលានំ អញ្ញតរំ ផលំ បាដិកង្ខំ ទិដ្ឋេវ ធម្មេ អញ្ញា សតិ វា ឧបាទិសេសេ អនាគាមិតា តិដ្ឋន្តុ ភិក្ខវេ សត្ត មាសានិ ។ យោ ហិ កោចិ ភិក្ខវេ ឥមេ ចត្តារោ សតិបដ្ឋានេ ឯវំ ភាវេយ្យ ឆ មាសានិ បញ្ច មាសានិ ចត្តារិ មាសានិ តីណិ មាសានិ ទ្វេ មាសានិ មាសំ(១) អឌ្ឍមាសំ... តិដ្ឋតុ ភិក្ខវេ អឌ្ឍមាសោ ។ យោ ហិ កោចិ ភិក្ខវេ ឥមេ ចត្តារោ សតិបដ្ឋានេ ឯវំ ភាវេយ្យ សត្តាហំ តស្ស ទ្វិន្នំ ផលានំ អញ្ញតរំ ផលំ បាដិកង្ខំ ទិដ្ឋេវ ធម្មេ អញ្ញា សតិ វា ឧបាទិសេសេ អនាគាមិតា ។

---

១ ម. ឯកំ មាសំ ។



លំដាប់វិធីចំរើនដែលតថាគតបានពោលហើយយ៉ាងនេះ បណ្ដាផលទាំងឡាយ ២ ផលណាមួយក៏គង់នឹងបានសម្រេច ដល់បុគ្គលនោះ តាមសេចក្ដីប្រាថ្នាដោយពិត គឺថានឹងបានសម្រេចនូវភាវៈជាព្រះអរហន្ត ក្នុងបច្ចុប្បន្នទាន់ភ្នែក ពុំនោះសោត បើមានឧបាទានក្ខន្ធសេសសល់នៅ ក៏គង់នឹងបានសម្រេចនូវភាវៈ ជាអនាគាមិបុគ្គលពុំខានឡើយ ម្នាលភិក្ខុទាំងឡាយ កុំថាដល់ទៅអស់ ៧ ខែឡើយ ។ ម្នាលភិក្ខុទាំងឡាយ សូម្បីបុគ្គលណាមួយបានចំរើនសតិប្បដ្ឋានទាំង ៤ នេះ អស់ ៦ ខែ ៥ ខែ ៤ ខែ ៣ ខែ ២ ខែ ១ ខែ កន្លះខែ តាមលំដាប់វិធីចំរើនដែលតថាគតបានពោលហើយយ៉ាងនេះ... ម្នាលភិក្ខុទាំងឡាយ កុំថាដល់ទៅអស់កន្លះខែឡើយ ។ ម្នាលភិក្ខុទាំងឡាយ សូម្បីបុគ្គលណាមួយបានចំរើនសតិប្បដ្ឋានទាំង ៤ នេះ អស់ ៧ ថ្ងៃ តាមលំដាប់វិធីចំរើនដែលតថាគតបានពោលហើយយ៉ាងនេះ បណ្ដាផលទាំងឡាយ ២ ផលណាមួយក៏គង់នឹងបានសម្រេចដល់បុគ្គលនោះ តាមសេចក្ដីប្រាថ្នាដោយពិត គឺថានឹងបានសម្រេចនូវភាវៈជាអរហន្ត ក្នុងបច្ចុប្បន្នទាន់ភ្នែក ពុំនោះសោត បើមានឧបាទានក្ខន្ធសេសសល់នៅ ក៏គង់នឹងបានសម្រេចនូវភាវៈជាអនាគាមិបុគ្គលពុំខានឡើយ ។

(១០៦) ឯកាយនោ អយំ ភិក្ខវេ មគ្គោ សត្តានំ វិសុទ្ធិយា សោកបរិទេវានំ សមតិក្កមាយ ទុក្ខទោម-នស្សានំ អត្ថង្គមាយ ញាយស្ស អធិគមាយ និព្វា-នស្ស សច្ឆិកិរិយាយ យទិទំ ចត្តារោ សតិបដ្ឋានាតិ ។ ឥតិ យំ តំ វុត្តំ ឥទមេតំ បដិច្ច វុត្តន្តិ ។ ឥទមវោច ភគវា អត្តមនា តេ ភិក្ខូ ភគវតោ ភាសិតំ អភិ-នន្ទុន្តិ ។

សតិបដ្ឋានសុត្តំ ទសមំ និដ្ឋិតំ ។

មូលបរិយាយវគ្គោ បឋមោ ។



(១០៦) ម្នាលភិក្ខុទាំងឡាយ ផ្លូវគឺសតិប្បដ្ឋានទាំង ៤ នេះឯង ជាផ្លូវមួយតែមួយ ប្រព្រឹត្តទៅដើម្បីសេចក្តីបរិសុទ្ធិដោយវិសេសនៃសត្វទាំងឡាយ ដើម្បីកន្លងបង់នូវសេចក្តីសោក និងសេចក្តីខ្សឹកខ្សួល ដើម្បីរលត់នូវទុក្ខនិងទោមនស្ស ដើម្បីបាននូវអរិយមគ្គប្រកបដោយអង្គ ៨ ប្រ-ការ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ។ ពាក្យណាដែលតថាគតបានពោលហើយថា (សាសនារបស់តថាគតជាគុណសម្រាប់ស្រោចស្រង់សត្វ) ដូច្នេះ ពាក្យនុ៎ះតថាគតពោលហើយ ព្រោះអាស្រ័យនូវផ្លូវដ៏ប្រ-សើរគឺសតិប្បដ្ឋានទាំង ៤ នេះឯង ។ លុះព្រះមានព្រះភាគត្រាស់ព្រះធម៌សតិប្បដ្ឋានសូត្រនេះចប់ហើយ ភិក្ខុទាំងឡាយនោះ ក៏មានសេចក្តីរីករាយចិត្ត ត្រេកអរចំពោះភាសិតរបស់ព្រះមានព្រះភាគ ។

ចប់ សតិប្បដ្ឋានសូត្រ ទី ១០ ។

ចប់ មូលបរិយាយវគ្គ ទី ១ ។

តស្សុទ្ទានំ

អជរំ អមរំ អមតាធិគមំ
ជរមច្ចុនិទស្សនំ ធុទ្ធុធុនំ
សហិតត្ថមហារហស្សការំ
ពហុប្បីតិហរំ វិវិធំ សុណាថ
តឡាការំ សុបូរិតំ យត្ថុបថេ
និវិត្តកិលេសសីតនិព្វានំ
ញាណិបតោធនទិបនេយោ
មជ្ឈិមសុត្តវរ បបិតា
មធុមន្ទមន្ទរសា
រមកំ ចិត្តរតិជនំ
មនុស្សានំ ចំ សុត្តព្យាករណាញ្
បបិតា សក្យបុត្តានមាតិមត្តា



បញ្ជីរឿងក្នុងមូលបណ្ណាសកនោះគឺ

អ្នកទាំងឡាយចូរស្តាប់ (នូវពាក្យដែលបរិយាយដល់ព្រះនិព្វាន) ជាធម្មជាតមិនចាស់ មិនស្លាប់ ជាទីលុះដល់អមតៈ ជាគ្រឿងសំដែងនូវមគ្គផល បន្ទោបង់នូវសេចក្តីទុក្ខធ្វើនូវទីកំបាំងដ៏ ដែលមានប្រយោជន៍នឹងនាំសេចក្តីចំរើន នាំមក នូវបីតិជាច្រើន មានប្រការផ្សេង ៗ ជាទីញ៉ាំងភ្លើង ទាំងបី[១] ប្រការឲ្យរលត់ ដូចជាស្រះមានទឹកពេញ ប្រៀប (ដែលព្រះករុណាឲ្យរលត់) គឺនូវសូត្រ ៗ សូត្រដ៏ប្រសើរ គឺមជ្ឈិមនិកាយទាំងឡាយ ជាគ្រឿង បន្ទោបង់នូវព្យាធិ មានរសដ៏ឆ្ងាញ់ ទន់ភ្លន់ នឹងញ៉ាំងសេចក្តីត្រេកអរសប្បាយ ឲ្យកើតឡើងដល់ពួក ទេវតា ជាសូត្រដែលព្រះតថាគតទេសនា ដំកល់ទុកហើយ ផង ជាសូត្រដែលពួកសក្យបុត្រដំកល់ទុកដើម្បីញ៉ាំងពួក មនុស្សឲ្យត្រេកអរចំពោះសូត្រ និងព្យាករណ៍នោះផង

១ ភ្លើងឬឫសទាំង ៣ ប្រការនេះ សំដៅយក លោភៈ ទោសៈ មោហៈ ។ អត្ថនោមតិ ។

ឆិបញ្ញាសបទំ ខិយឡ្ហសន្ធិ
ចុទ្ទ ច វេយ្យាករណំ អដ្ឋ ច ទេ
អសមេ បវត្តវត្ត អនុបុព្វេន
ឯកាមនា និសាមេថ មុនត្ថំ
មូលអាសវធម្មទាយាទ-
ភេរវង្គណាកង្ខសុត្តំ
វត្ថសល្លេខទិដ្ឋិសតិ
បវត្តវគ្គោ តេន សមុត្តោ ។





អ្នកទាំងឡាយ ចូរមានចិត្តតែមួយ គឺ បានចិត្តមិនរួម គាប់សោតប្រសាទស្តាប់នូវសូត្រដ៏ប្រសើរនោះ ដែលមានវគ្គដ៏ប្រសើរ ៥៣ ទីដ ១៥០ គឺវេយ្យាករណ៍ ៤ ប្រការ នឹងគាថាភាសិតគួរចាំ ១ ទៀត ក្នុងបទវគ្គទាំងអស់ ដែលមិនស្មើគ្នាតាមលំដាប់នូវបទ គឺ មូលបរិយាយសូត្រ ១ សព្វាសវសំវរសូត្រ ១ ធម្មទាយាទសូត្រ ១ ភយភេរវសូត្រ ១ អនង្គណសូត្រ ១ អាកង្ខេយ្យសូត្រ ១ វត្ថូបមសូត្រ ១ សល្លេខសូត្រ ១ សម្មាទិដ្ឋិសូត្រ ១ សតិប្បដ្ឋានសូត្រ ១ ចប់វគ្គដ៏ប្រសើរទាំងនោះ ចប់តែប៉ុណ្ណេះហើយ ។

# សីហនាទវគ្គោ

## បឋមំ ចូឡសីហនាទសុត្តំ

(១៤៣) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ ភិក្ខវោតិ ។ ភទន្តេតិ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។

(១៤៤) ភគវា ឯតទវោច ឥធេវ ភិក្ខវេ សមណោ ឥធ ទុតិយោ សមណោ ឥធ តតិយោ សមណោ ឥធ ចតុត្ថោ សមណោ សុញ្ញា បរប្បវាទា សមណេហិ អញ្ញេហីតិ ឯវមេវ[១] ភិក្ខវេ សម្មា សីហនាទំ នទថ ។ ឋានំ ខោ បនេតំ ភិក្ខវេ វិជ្ជតិ

---

១ ម. ឯវមេតំ ។

# សីហនាទវគ្គ

## ចូឡសីហនាទសូត្រ ទី ១

(១៤៣) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគគង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋីជិតក្រុងសាវត្ថី ។ លំដាប់នោះ ព្រះមានព្រះភាគទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ដូច្នេះ ។ ភិក្ខុទាំងឡាយនោះ បានទទួលតបសំដីរបស់ព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ។

(១៤៤) ព្រះមានព្រះភាគទ្រង់ត្រាស់យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ សមណៈ (ទី ១) (គឺសោតាបន្ន) មានតែក្នុងសាសនានេះ សមណៈទី ២ (គឺសកទាគាមី) ក៏មានតែក្នុងសាសនានេះ សមណៈទី ៣ (គឺអនាគាមី) ក៏មានតែក្នុងសាសនានេះ សមណៈទី ៤ (គឺអរហន្ត) ក៏មានតែក្នុងសាសនានេះ វាទៈ (គឺទិដ្ឋិ ៦២) របស់សាសនាដទៃ សូន្យចាកសមណៈទាំងឡាយ (ដែលស្ថិតនៅក្នុងផលទាំង ៤ ពួក) និងសមណៈទាំងឡាយដទៃ (ដែលស្ថិតនៅក្នុងមគ្គទាំង ៤ ពួកជាដើម) ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរបន្លឺនូវសីហនាទៈដោយប្រពៃ យ៉ាងនេះឯងចុះ ។ ម្នាលភិក្ខុទាំងឡាយ ហេតុនុ៎ះតែងមាន

យំ ឥធ អញ្ញតិត្ថិយា បរិព្វាជកា ឯវំ វទេយ្យុំ កោ បនាយស្មន្តានំ អស្សាសោ កឹ ពលំ យេន តុម្ហេ អាយស្មន្តោ អត្តនិ សម្មស្សមានា[១] ឯវំ វទេថ ឥធេវ សមណោ ឥធ ទុតិយោ សមណោ ឥធ តតិយោ សមណោ ឥធ ចតុត្ថោ សមណោ សុញ្ញា បរប្បវាទា សមណេហិ អញ្ញេហីតិ ឯវំវាទិនោ ភិក្ខវេ អញ្ញតិត្ថិយា បរិព្វាជកា ឯវមស្សុ វចនីយា អត្ថិ ខោ នោ អាវុសោ តេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន ចត្តារោ ធម្មា អក្ខាតា យេ មយំ អត្តនិ សម្មស្សមានា ឯវំ វទេម ឥធេវ សមណោ ឥធ ទុតិយោ សមណោ ឥធ តតិយោ សមណោ ឥធ ចតុត្ថោ សមណោ

១ ឱ. ម. អត្តនិ សម្បស្សមានាតិ ទិស្សតិ ។



ពួកបរិព្វាជកជាអន្យតិរ្ថិយ[១] ក្នុងលោកនេះ សម្តែងនិយាយយ៉ាងនេះថា លោកមានអាយុទាំងឡាយ បានអ្វីជាគ្រឿងក្សាន្ត បានអ្វីជាកំឡាំង ដែលជាហេតុឲ្យលោកមានអាយុទាំងឡាយ ពិចារណាឃើញច្បាស់ក្នុងខ្លួន ហើយពោលយ៉ាងនេះថា សមណៈ(ទី១) មានតែក្នុងសាសនានេះ សមណៈទី២ មានតែក្នុងសាសនានេះ សមណៈទី៣ មានតែក្នុងសាសនានេះ សមណៈទី៤ មានតែក្នុងសាសនានេះ ពាក្យរបស់សាសនាដទៃសូន្យចាកសមណៈទាំងឡាយទាំងសមណៈទាំងឡាយដទៃ ម្នាលភិក្ខុទាំងឡាយ បើពួកបរិព្វាជកជាអន្យតិរ្ថិយនិយាយយ៉ាងនេះ អ្នកទាំងឡាយគួរនិយាយយ៉ាងនេះវិញថា ម្នាលអាវុសោទាំងឡាយ មានធម៌ ៤ យ៉ាងដែលព្រះមានព្រះភាគអរហន្តសម្មាសម្ពុទ្ធអង្គនោះទ្រង់ជ្រាប ទ្រង់ឃើញ ទ្រង់ត្រាស់សំដែងហើយ ដែលយើងទាំងឡាយ [illegible] ឃើញច្បាស់ក្នុងខ្លួន ហើយនិយាយយ៉ាងនេះថា សមណៈ(ទី១) មានតែក្នុងសាសនានេះ សមណៈទី២ ក៏មានតែក្នុងសាសនានេះ សមណៈទី៣ក៏មានតែក្នុងសាសនានេះ សមណៈទី៤ក៏មានតែក្នុងសាសនានេះ ពាក្យរបស់

១ តិរ្ថ ប្រែថាកំពង់ សំដៅយកទិដ្ឋិ ៦២ ព្រោះពួកសត្វតែងធ្លងតែងជាប់នឹកពាក់ក្នុងលទ្ធិទាំងនេះ ។ ពួកអ្នកបួសដែលប្រកាន់លទ្ធិទាំងនេះ ហៅថា តិរ្ថិយ ។ តិរ្ថិយដទៃអំពីផ្សេងពីពុទ្ធសាសនា ហៅថា អន្យតិរ្ថិយ ។

សុញ្ញា បរប្បវាទា សមណេហិ អញ្ញេហីតិ កតមេ ចត្តារោ អត្ថិ ខោ នោ អាវុសោ សត្ថរិ បសាទោ អត្ថិ ធម្មេ បសាទោ អត្ថិ សីលេសុ បរិបូរការិតា សហធម្មិកា ខោ បន(១) បិយា មនាបា គហដ្ឋា ចេវ បព្វជិតា ច ឥមេ ខោ នោ អាវុសោ តេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន ចត្តារោ ធម្មា អក្ខាតា យេ មយំ អត្តនិ សម្បស្សមានា ឯវំ វទេម ឥធេវ សមណោ ឥធ ទុតិយោ សមណោ ឥធ តតិយោ សមណោ ឥធ ចតុត្ថោ សមណោ សុញ្ញា បរប្បវាទា សមណេហិ អញ្ញេហីតិ ។ ឋានំ ខោ បនេតំ ភិក្ខវេ វិជ្ជតិ យំ អញ្ញតិត្ថិយា បរិព្វាជកា ឯវំ វទេយ្យុំ អម្ហាកម្បិ ខោ អាវុសោ អត្ថិ សត្ថរិ បសាទោ យោ(២) អម្ហាកំ សត្ថា អម្ហាកម្បិ អត្ថិ ធម្មេ បសាទោ យោ(៣) អម្ហាកំ

១ ឱ. បន ខោ ។ ២–៣ ឱ. ម. យោ ។



សាសនាដទៃសូន្យចាកសមណៈទាំងឡាយ គឺសមណៈទាំងឡាយដទៃ ធម៌ទាំង ៤ ប្រការតើដូចម្តេច ម្នាលអាវុសោទាំងឡាយ គឺយើងទាំងឡាយ មានសេចក្តីជ្រះថ្លាក្នុងព្រះសាស្តា ១ មានសេចក្តីជ្រះថ្លាក្នុងព្រះធម៌ ១ មាន ការជាអ្នកធ្វើឲ្យបរិបូណ៌ក្នុងសីលទាំងឡាយ ១ ពួកសហធម្មិក(១) ដែល ជាគ្រហស្ថក្តី ជាបព្វជិតក្តី ក៏ជាទីស្រឡាញ់ ជាទីពេញចិត្ត ១ ម្នាល អាវុសោទាំងឡាយ ធម៌ទាំង ៤ ប្រការនេះឯង ដែលព្រះមានព្រះភាគជា អរហន្តសម្មាសម្ពុទ្ធអង្គនោះទ្រង់ជ្រាប ទ្រង់ឃើញ ទ្រង់បានសំដែងហើយ ដល់យើងទាំងឡាយ ជាធម៌នាំឲ្យយើងទាំងឡាយពិចារណាឃើញច្បាស់ ក្នុងខ្លួន ហើយនិយាយយ៉ាងនេះថា សមណៈ(ទី១) មានតែក្នុងសាសនា នេះ សមណៈទី ២ ក៏មានតែក្នុងសាសនានេះ សមណៈទី ៣ ក៏មាន តែក្នុងសាសនានេះ សមណៈទី ៤ ក៏មានតែក្នុងសាសនានេះ វាទៈរបស់ សាសនាដទៃសូន្យចាកសមណៈទាំងឡាយនឹងសមណៈទាំងឡាយដទៃ ៗ ម្នាលភិក្ខុទាំងឡាយ គង់មានហេតុជាទំនងយ៉ាងនេះ គឺ ពួកបរិព្វាជកជា អន្យតិរ្ថិយគប្បីនិយាយយ៉ាងនេះថា យើងទាំងឡាយមានសេចក្តីជ្រះថ្លា ក្នុងព្រះសាស្តា ដែលជាសាស្តារបស់ពួកយើងដែរ យើងទាំងឡាយមាន សេចក្តីជ្រះថ្លាក្នុងព្រះធម៌ ដែលជាធម៌របស់ពួកយើងដែរ យើងទាំងឡាយ

១ មាន ៧ ពួក គឺ ភិក្ខុ ១ ភិក្ខុនី ១ សិក្ខមានា ១ សាមណេរ ១ សាមណេរី ១ ឧបាសក ១ ឧបាសិកា ១ ។ អដ្ឋកថា ។

ធម្មោ អយម្បិ សីលេសុ បរិបូរការិតា យានិ អម្ហាកំ សីលានិ អម្ហាកម្បិ សហធម្មិកា បិយា មនាបា គហដ្ឋា ចេវ បព្វជិតា ច ។ ឥធ នោ អាវុសោ កោ វិសេសោ កោ អធិប្បាយោ(១) កិំ នានាករណំ យទិទំ តុម្ហាកញ្ចេវ អម្ហាកញ្ចាតិ ។ ឯវំវាទិនោ ភិក្ខវេ អញ្ញតិត្ថិយា បរិព្វាជកា ឯវមស្សុ វចនីយា កិំ បនាវុសោ ឯកា និដ្ឋា ឧទាហុ បុថុ និដ្ឋាតិ ។ សម្មា ព្យាករមានា ភិក្ខវេ អញ្ញតិត្ថិយា បរិព្វាជកា ឯវំ ព្យាករេយ្យុំ ឯកា ហាវុសោ និដ្ឋា ន បុថុ និដ្ឋាតិ ។ សា បនាវុសោ និដ្ឋា សរាគស្ស ឧទាហុ វីតរាគស្សាតិ ។ សម្មា ព្យាករមានា ភិក្ខវេ អញ្ញតិត្ថិយា បរិព្វាជកា ឯវំ ព្យាករេយ្យុំ វីតរាគស្សាវុសោ សា និដ្ឋា ន សា និដ្ឋា សរាគស្សាតិ ។ សា បនាវុសោ និដ្ឋា

១ អធិប្បាយោតិបិ បាឋោ ។





ធ្វើឲ្យបរិបូណ៌ក្នុងសីលទាំងឡាយ ដែលជាសីលរបស់ពួកយើងដែរ ពួកសហធម្មិក គឺគ្រហស្ថនិងបព្វជិត ក៏ជាទីស្រឡាញ់ ជាទីពេញចិត្តរបស់យើងទាំងឡាយដែរ ។ ម្នាលអាវុសោទាំងឡាយ កាលបើយ៉ាងនេះ ពួកលោកនិងពួកយើងមានសេចក្តីប្លែកគ្នាត្រង់ណា មានអធិប្បាយដូចម្តេច មានការធ្វើឲ្យផ្សេងគ្នាដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ពួកបរិព្វាជកជាអន្យតិរ្ថិយ គប្បីនិយាយយ៉ាងនេះ អ្នកទាំងឡាយត្រូវនិយាយយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ទីបំផុតនៃសេចក្តីជ្រះថ្លា(១) មានតែ ១ ឬមានច្រើន ។ ម្នាលភិក្ខុទាំងឡាយ ពួកបរិព្វាជកជាអន្យតិរ្ថិយ កាលដែលព្យាករឲ្យត្រូវ គប្បីព្យាករយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ឯទីបំផុតនៃសេចក្តីជ្រះថ្លាមានតែមួយ មិនមានច្រើនទេ ។ អ្នកទាំងឡាយត្រូវសួរថា ម្នាលអាវុសោទាំងឡាយ ទីបំផុតនៃសេចក្តីជ្រះថ្លានោះជារបស់បុគ្គលប្រកបដោយរាគៈ ឬជារបស់បុគ្គលប្រាសចាករាគៈ ។ ម្នាលភិក្ខុទាំងឡាយ ពួកបរិព្វាជកអន្យតិរ្ថិយ កាលដែលព្យាករឲ្យត្រូវ គប្បីព្យាករយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ទីបំផុតនៃសេចក្តីជ្រះថ្លានោះ ជារបស់បុគ្គលប្រាសចាករាគៈ ទីបំផុតនៃសេចក្តីជ្រះថ្លានោះ មិនមែនជារបស់បុគ្គលដែលប្រកបដោយរាគៈទេ ។ អ្នកទាំងឡាយត្រូវសួរថា

១ បានដល់ព្រះអរហត្តផល ។ អដ្ឋកថា ។

សទោសស្ស ឧទាហុ វីតទោសស្សាតិ ។ សម្មា ព្យាករមានា ភិក្ខវេ អញ្ញតិត្ថិយា បរិព្វាជកា ឯវំ ព្យាករេយ្យុំ វីតទោសស្សាវុសោ សា និដ្ឋា ន សា និដ្ឋា សទោសស្សាតិ ។ សា បនាវុសោ និដ្ឋា សមោហស្ស ឧទាហុ វីតមោហស្សាតិ ។ សម្មា ព្យាករមានា ភិក្ខវេ អញ្ញតិត្ថិយា បរិព្វាជកា ឯវំ ព្យាករេយ្យុំ វីតមោហស្សាវុសោ សា និដ្ឋា ន សា និដ្ឋា សមោហស្សាតិ ។ សា បនាវុសោ និដ្ឋា សតណ្ហស្ស ឧទាហុ វីតតណ្ហស្សាតិ ។ សម្មា ព្យាករមានា ភិក្ខវេ អញ្ញតិត្ថិយា បរិព្វាជកា ឯវំ ព្យាករេយ្យុំ វីតតណ្ហស្សាវុសោ



ទីបំផុតនៃសេចក្តីជ្រះថ្លានោះ ជារបស់បុគ្គលប្រកបដោយទោសៈ ឬជារបស់បុគ្គលប្រាសចាកទោសៈ ។ ម្នាលភិក្ខុទាំងឡាយ ពួកបរិព្វាជកជាអន្យតិរ្ថិយ កាលដែលព្យាករឲ្យត្រូវ គប្បីព្យាករយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ទីបំផុតនៃសេចក្តីជ្រះថ្លានោះ ជារបស់បុគ្គលប្រាសចាកទោសៈ ទីបំផុតនៃសេចក្តីជ្រះថ្លានោះ មិនមែនជារបស់បុគ្គលប្រកបដោយទោសៈទេ ។ អ្នកទាំងឡាយគួរសួរថា ម្នាលអាវុសោទាំងឡាយ ទីបំផុតនៃសេចក្តីជ្រះថ្លានោះ ជារបស់បុគ្គលប្រកបដោយមោហៈ ឬជារបស់បុគ្គលប្រាសចាកមោហៈ ។ ម្នាលភិក្ខុទាំងឡាយ ពួកបរិព្វាជកជាអន្យតិរ្ថិយ កាលព្យាករឲ្យត្រូវ គប្បីព្យាករយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ទីបំផុតនៃសេចក្តីជ្រះថ្លានោះ ជារបស់បុគ្គលប្រាសចាកមោហៈ ទីបំផុតនៃសេចក្តីជ្រះថ្លានោះ មិនមែនជារបស់បុគ្គលប្រកបដោយមោហៈទេ ។ អ្នកទាំងឡាយគួរសួរថា ម្នាលអាវុសោទាំងឡាយ ទីបំផុតនៃសេចក្តីជ្រះថ្លានោះ ជារបស់បុគ្គលប្រកបដោយតណ្ហា ឬជារបស់បុគ្គលប្រាសចាកតណ្ហា ។ ម្នាលភិក្ខុទាំងឡាយ ពួកបរិព្វាជកជាអន្យតិរ្ថិយ កាលព្យាករដោយត្រឹមត្រូវ គប្បីព្យាករយ៉ាងនេះថា ទីបំផុតនៃសេចក្តីជ្រះថ្លានោះ ជារបស់បុគ្គលប្រាស

សា និដ្ឋា ន សា និដ្ឋា សតណ្ហស្សាតិ ។ សា បនាវុសោ និដ្ឋា សឧបាទានស្ស ឧទាហុ អនុបាទានស្សាតិ ។ សម្មា ព្យាករមានា ភិក្ខវេ អញ្ញតិត្ថិយា បរិព្វាជកា ឯវំ ព្យាករេយ្យុំ អនុបាទានស្សាវុសោ សា និដ្ឋា ន សា និដ្ឋា សឧបាទានស្សាតិ ។ សា បនាវុសោ វិទ្ទសុនោ ឧទាហុ អវិទ្ទសុនោតិ ។ សម្មា ព្យាករមានា ភិក្ខវេ អញ្ញតិត្ថិយា បរិព្វាជកា ឯវំ ព្យាករេយ្យុំ វិទ្ទសុនោ អាវុសោ សា និដ្ឋា ន សា និដ្ឋា អវិទ្ទសុនោតិ ។ សា បនាវុសោ និដ្ឋា អនុរុទ្ធប្បដិវិរុទ្ធស្ស ឧទាហុ អននុរុទ្ធប្បដិវិរុទ្ធស្សាតិ[១] ។ សម្មា ព្យាករមានា ភិក្ខវេ អញ្ញតិត្ថិយា បរិព្វាជកា

១ អននុរុទ្ធប្បដិវិរុទ្ធស្សាតិ ឥតិបិ បាឋោ ។



ចាកតណ្ហា ទីបំផុតនៃសេចក្តីជ្រះថ្លានោះ មិនមែនជារបស់បុគ្គលប្រកបដោយតណ្ហាទេ ។ អ្នកទាំងឡាយត្រូវសួរថា ម្នាលអាវុសោទាំងឡាយ ទីបំផុតនៃសេចក្តីជ្រះថ្លានោះ ជារបស់បុគ្គលប្រកបដោយឧបាទាន ឬជារបស់បុគ្គលមិនមានឧបាទាន ។ ម្នាលភិក្ខុទាំងឡាយ ពួកបរិព្វាជកជាអន្យតិរ្ថិយ កាលព្យាករដោយត្រឹមត្រូវ គប្បីព្យាករយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ទីបំផុតនៃសេចក្តីជ្រះថ្លានោះ ជារបស់បុគ្គលមិនមានឧបាទាន ទីបំផុតនៃសេចក្តីជ្រះថ្លានោះ មិនមែនជារបស់បុគ្គលប្រកបដោយឧបាទានទេ ។ អ្នកទាំងឡាយត្រូវសួរថា ម្នាលអាវុសោទាំងឡាយ ទីបំផុតនៃសេចក្តីជ្រះថ្លានោះ ជារបស់បណ្ឌិត ឬជារបស់បុគ្គលមិនមែនជាបណ្ឌិត ។ ម្នាលភិក្ខុទាំងឡាយ ពួកបរិព្វាជកជាអន្យតិរ្ថិយ កាលព្យាករដោយត្រឹមត្រូវ គប្បីព្យាករយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ទីបំផុតនៃសេចក្តីជ្រះថ្លានោះ ជារបស់បណ្ឌិត ទីបំផុតនៃសេចក្តីជ្រះថ្លានោះ មិនមែនជារបស់បុគ្គលដែលមិនមែនជាបណ្ឌិតទេ ។ អ្នកទាំងឡាយត្រូវសួរថា ម្នាលអាវុសោទាំងឡាយ ទីបំផុតនៃសេចក្តីជ្រះថ្លានោះ ជារបស់បុគ្គលដែលនៅមានត្រេកអរ នៅមានក្រោធ ឬជារបស់បុគ្គលដែលមិនមានត្រេកអរ មិនមានក្រោធ ម្នាលភិក្ខុទាំងឡាយ ពួកបរិព្វាជកជាអន្យតិរ្ថិយ កាលដែលព្យាករដោយត្រឹមត្រូវ គប្បីព្យាករយ៉ាងនេះថា

ឯវំ ព្យាករេយ្យុំ អននុរុទ្ធប្បដិវិរុទ្ធស្សាវុសោ សា និដ្ឋា ន សា និដ្ឋា អនុរុទ្ធប្បដិវិរុទ្ធស្សាតិ ។ សា បនាវុសោ និដ្ឋា បបញ្ចារាមស្ស បបញ្ចរតិនោ ឧទាហុ និប្បបញ្ចារាមស្ស និប្បបញ្ចរតិនោតិ ។ សម្មា ព្យាករមានា ភិក្ខវេ អញ្ញតិត្ថិយា បរិព្វាជកា ឯវំ ព្យាករេយ្យុំ និប្បបញ្ចារាមស្សាវុសោ សា និដ្ឋា និប្បបញ្ចរតិនោ ន សា និដ្ឋា បបញ្ចារាមស្ស បបញ្ចរតិនោតិ ។



ទីបំផុតនៃសេចក្តីជ្រះថ្លានោះ ជារបស់បុគ្គលមិនមានត្រេកអរ មិនមានក្រោធ ទីបំផុតនៃសេចក្តីជ្រះថ្លានោះ មិនមែនជារបស់បុគ្គលនៅមានត្រេកអរ នៅមានក្រោធទេ ។ អ្នកទាំងឡាយគួរសួរថា ម្នាលអាវុសោទាំងឡាយ ទីបំផុតនៃសេចក្តីជ្រះថ្លានោះ ជារបស់បុគ្គលមានបបញ្ចធម៌[១] ជាទីត្រេកអរ មានសេចក្តីត្រេកអរក្នុងបបញ្ចធម៌ ឬជារបស់បុគ្គលមិនមានបបញ្ចធម៌ជាទីត្រេកអរ មិនមានសេចក្តីត្រេកអរក្នុងបបញ្ចធម៌ ។ ម្នាលភិក្ខុទាំងឡាយ ពួកបរិព្វាជកជាអន្យតិរ្ថិយ កាលព្យាករដោយត្រឹមត្រូវ គប្បីព្យាករយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ទីបំផុតនៃសេចក្តីជ្រះថ្លានោះ ជារបស់បុគ្គលមិនមានបបញ្ចធម៌ជាទីត្រេកអរ មិនមានសេចក្តីត្រេកអរក្នុងបបញ្ចធម៌ ទីបំផុតនៃសេចក្តីជ្រះថ្លានោះ មិនមែនជារបស់បុគ្គលមានបបញ្ចធម៌ជាទីត្រេកអរ មានសេចក្តីត្រេកអរក្នុងបបញ្ចធម៌ទេ ។

---

១ បបញ្ចធម៌ សំដៅយកកិលេសដែលធ្វើដំណើររបស់សត្វឲ្យយឺតយូរក្នុងភព បានដល់ តណ្ហា ទិដ្ឋិ មានះ ។ អវិជ្ជា ។

(១៥៥) ទ្វេមា ភិក្ខវេ ទិដ្ឋិយោ ភវទិដ្ឋិ ច វិភវទិដ្ឋិ ច ។ យេ ហិ កេចិ ភិក្ខវេ សមណា វា ព្រាហ្មណា វា ភវទិដ្ឋឹ អល្លីនា ភវទិដ្ឋឹ ឧបគតា ភវទិដ្ឋឹ អជ្ឈោសិតា វិភវទិដ្ឋិយា តេ បដិវិរុទ្ធា ។ យេ ហិ កេចិ ភិក្ខវេ សមណា វា ព្រាហ្មណា វា វិភវទិដ្ឋឹ អល្លីនា វិភវទិដ្ឋឹ ឧបគតា វិភវទិដ្ឋឹ អជ្ឈោសិតា ភវទិដ្ឋិយា តេ បដិវិរុទ្ធា ។ យេ ហិ កេចិ ភិក្ខវេ សមណា វា ព្រាហ្មណា វា ឥមាសំ ទ្វិន្នំ ទិដ្ឋីនំ សមុទយញ្ច អត្ថង្គមញ្ច អស្សាទញ្ច អាទីនវញ្ច និស្សរណញ្ច យថាភូតំ នប្បជានន្តិ តេ សរាគា តេ សទោសា តេ សមោហា តេ សតណ្ហា តេ សឧបាទានា តេ អវិទ្ទសុនោ តេ អនុរុទ្ធប្បដិវិរុទ្ធា តេ បបញ្ចារាមា បបញ្ចរតិនោ



(១៥៥) ម្នាលភិក្ខុទាំងឡាយ ទិដ្ឋិនេះមាន ២ ប្រការគឺ ភវទិដ្ឋិ[១] ១ វិភវទិដ្ឋិ[២] ១ ។ ម្នាលភិក្ខុទាំងឡាយ ពួកសមណៈឬព្រាហ្មណ៍ណាមួយ ជាអ្នកគាប់ជាប់នឹងភវទិដ្ឋិ ចូលទៅកាន់ភវទិដ្ឋិ ចុះស៊ប់កាន់ភវទិដ្ឋិ ពួកសមណៈឬព្រាហ្មណ៍នោះក៏ស្អប់ខ្ពើមវិភវទិដ្ឋិ[៣] ។ ម្នាលភិក្ខុទាំងឡាយ ពួកសមណៈឬព្រាហ្មណ៍ណាមួយ ជាអ្នកគាប់ជាប់នៅនឹងវិភវទិដ្ឋិ ចូលទៅកាន់វិភវទិដ្ឋិ ចុះស៊ប់កាន់វិភវទិដ្ឋិ ពួកសមណៈឬព្រាហ្មណ៍នោះក៏ស្អប់ខ្ពើមភវទិដ្ឋិ ។ ម្នាលភិក្ខុទាំងឡាយ ពួកសមណៈឬព្រាហ្មណ៍ណាមួយ មិនដឹងច្បាស់នូវសេចក្តីកើតឡើងផង នូវសេចក្តីវិនាសផង នូវអានិសង្សផង នូវទោសផង នៃទិដ្ឋិទាំង ២ នេះ នូវសេចក្តីរលាស់ចេញនូវទិដ្ឋិទាំង២នោះផង តាមសេចក្តីពិតទេ គប្បីគេពោលថា ពួកសមណៈឬព្រាហ្មណ៍ទាំងនោះ ជាអ្នកប្រកបដោយរាគៈ ជាអ្នកប្រកបដោយទោសៈ ជាអ្នកប្រកបដោយមោហៈ ជាអ្នកប្រកបដោយតណ្ហា ជាអ្នកប្រកបដោយឧបាទាន ជាអ្នកល្ងង់ខ្លៅ អ្នកនៅមានត្រេកអរ នៅមានក្រេវក្រោធ ជាអ្នកមានបបញ្ចធម៌ជាទីត្រេកអរ មានសេចក្តីត្រេកអរ ក្នុងបបញ្ចធម៌

---

១ បានដល់សស្សតទិដ្ឋិ ។ ២ បានដល់ឧច្ឆេទទិដ្ឋិ ។ អដ្ឋកថា ។ ៣ អដ្ឋកថា ថា មនុស្សពួកនេះ ឈ្មោះប្រកែកនឹងអ្នកប្រកាន់វិភវទិដ្ឋិ ថា ពួកអ្នកជាមនុស្សល្ងង់ខ្លៅ មិនស្គាល់ច្បាស់ថា លោកនេះទៀងទាត់ លោកនេះមិនដាច់សូន្យ ដូច្នេះឡើយ ។

តេ ន បរិមុច្ចន្តិ ជាតិយា ជរាមរណេន សោកេហិ ប-រិទេវេហិ ទុក្ខេហិ ទោមនស្សេហិ ឧបាយាសេហិ[១] ន បរិមុច្ចន្តិ ទុក្ខស្មាតិ វទាមិ ។ យេ ច ខោ កេចិ[២] សមណា វា ព្រាហ្មណា វា ឥមាសំ ទ្វិន្នំ ទិដ្ឋីនំ សមុទយញ្ច អត្ថង្គមញ្ច អស្សាទញ្ច អាទីនវញ្ច និស្សរណញ្ច យថាភូតំ បជានន្តិ តេ វីតរាគា តេ វីតទោសា តេ វីតមោហា តេ វីតតណ្ហា តេ អនុបាទានា តេ វិទ្ទសុនោ តេ អននុរុទ្ធប្បដិវិរុទ្ធា តេ និប្បបញ្ចារាមា និប្បបញ្ចរតិនោ តេ បរិមុច្ចន្តិ ជាតិយា ជរាមរណេន សោកេហិ បរិទេវេហិ ទុក្ខេហិ ទោមនស្សេហិ ឧបាយាសេហិ បរិមុច្ចន្តិ ទុក្ខស្មាតិ វទាមិ ។

(១៥៦) ចត្តារិមានិ ភិក្ខវេ ឧបាទានានិ កតមានិ ចត្តារិ កាមុបាទានំ ទិដ្ឋុបាទានំ សីលព្វតុបាទានំ

---

១ ឱ.ម. សោកេហិ បរិទេវេហិ ទុក្ខេហិ ទោមនស្សេហិ ឧបាយាសេហិ ។ ២ ឱ.ម. យេ ច ខោ កេចិ ភិក្ខវេ ។



ពួកសមណៈឬព្រាហ្មណ៍ទាំងនោះ មិនរួចស្រឡះចាកជាតិ ជរា មរណៈ សោក ខ្សឹកខ្សួល ទុក្ខទោមនស្ស និងសេចក្តីចង្អៀតចង្អល់ចិត្ត រមែងមិនរួចស្រឡះចាកផុតទុក្ខឡើយ ។ ម្នាលភិក្ខុទាំងឡាយ ក៏ពួកសមណៈឬព្រាហ្មណ៍ណាមួយ ដឹងច្បាស់ នូវសេចក្តីកើតឡើងផង នូវសេចក្តីវិនាសផង នូវអានិសង្សផង នូវទោសផង នៃទិដ្ឋិទាំង ២ នេះ នូវសេចក្តីរលាស់ចេញ (នូវទិដ្ឋិទាំង ២ នោះ) ផង តាមសេចក្តីពិត តថាគតពោលថា ពួកសមណៈឬព្រាហ្មណ៍ទាំងនោះ ជាអ្នកប្រាសចាករាគៈ ជាអ្នកប្រាសចាកទោសៈ ជាអ្នកប្រាសចាកមោហៈ ជាអ្នកប្រាសចាកតណ្ហា ជាអ្នកមិនមានឧបាទាន ជាអ្នកចេះដឹង ជាអ្នកមិនមានសេចក្តីត្រេកអរ និងសេចក្តីក្រោធ ជាអ្នកមិនមានបបញ្ចធម៌ជាទីត្រេកអរ មិនមានសេចក្តីត្រេកអរក្នុងបបញ្ចធម៌ ពួកសមណៈឬព្រាហ្មណ៍ទាំងនោះ រមែងរួចស្រឡះចាកជាតិ ជរា មរណៈ សោក ខ្សឹកខ្សួល ទុក្ខទោមនស្ស និងសេចក្តីចង្អៀតចង្អល់ចិត្ត រមែងរួចស្រឡះចាកផុតទុក្ខ ។

(១៥៦) ម្នាលភិក្ខុទាំងឡាយ ឧបាទាន (សេចក្តីប្រកាន់មាំ) នេះ មាន ៤ ប្រការ ឧបាទាន ៤ តើដូចម្តេច គឺ កាមុបាទាន (សេចក្តីប្រកាន់មាំក្នុងកាម) ១ ទិដ្ឋុបាទាន (សេចក្តីប្រកាន់មាំក្នុងទិដ្ឋិ) ១ សីលព្វតុបាទាន

អត្តវាទុបាទានំ ។ សន្តិ ភិក្ខវេ ឯកេ សមណព្រាហ្ម-
ណា សព្វុបាទានបរិញ្ញាវាទា បដិជានមានា តេ ន
សម្មា សព្វុបាទានបរិញ្ញំ បញ្ញបេន្តិ កាមុបាទានស្ស
បរិញ្ញំ បញ្ញបេន្តិ ន ទិដ្ឋុបាទានស្ស បរិញ្ញំ បញ្ញ-
បេន្តិ ន សីលព្វតុបាទានស្ស បរិញ្ញំ បញ្ញបេន្តិ
ន អត្តវាទុបាទានស្ស បរិញ្ញំ បញ្ញបេន្តិ តំ កិស្ស
ហេតុ ឥមានិ ហិ តេ ភោន្តោ សមណព្រាហ្មណា
តីណិ ឋានានិ យថាភូតំ នប្បជានន្តិ តស្មា តេ
ភោន្តោ សមណព្រាហ្មណា សព្វុបាទានបរិញ្ញាវាទា
បដិជានមានា តេ ន សម្មា សព្វុបាទានបរិញ្ញំ បញ្ញ-
បេន្តិ កាមុបាទានស្ស បរិញ្ញំ បញ្ញបេន្តិ ន ទិដ្ឋុ-
បាទានស្ស បរិញ្ញំ បញ្ញបេន្តិ ន សីលព្វតុបាទានស្ស
បរិញ្ញំ បញ្ញបេន្តិ ន អត្តវាទុបាទានស្ស បរិញ្ញំ
បញ្ញបេន្តិ ។ សន្តិ ភិក្ខវេ ឯកេ សមណ-
ព្រាហ្មណា សព្វុបាទានបរិញ្ញាវាទា បដិជានមានា





(សេចក្តីប្រកាន់ក្នុងសីលព្វត)១ អត្តវាទុបាទាន (សេចក្តីប្រកាន់មាំ
ក្នុងពាក្យពោលថាខ្លួនប្រាណ)១ ។ ម្នាលភិក្ខុទាំងឡាយ មានសមណ-
ព្រាហ្មណ៍ពួកមួយ ប្តេជ្ញាថាជាអ្នកពោលនូវការកំណត់ដឹង នូវឧបាទាន
ទាំងអស់ តែសមណព្រាហ្មណ៍ទាំងនោះ មិនបញ្ញត្តនូវការកំណត់ដឹងនូវ
ឧបាទានទាំងអស់ ដោយប្រពៃទេ បញ្ញត្តតែការកំណត់ដឹងនូវកាមុបាទាន
(ប៉ុណ្ណោះ) មិនបញ្ញត្តនូវការកំណត់ដឹងនូវទិដ្ឋុបាទាន មិនបញ្ញត្តនូវការ
កំណត់ដឹងនូវសីលព្វតុបាទាន មិនបញ្ញត្តនូវការកំណត់ដឹងនូវអត្តវាទុបា-
ទានទេ ដំណើរនោះព្រោះហេតុអ្វី ព្រោះថាសមណព្រាហ្មណ៍ដ៏ចំរើន
ទាំងនោះ មិនបានដឹងច្បាស់នូវហេតុទាំង ៣ ប្រការនេះតាមសេចក្តីពិត
ឡើយ ព្រោះហេតុនោះបានជា ពួកសមណព្រាហ្មណ៍ដ៏ចំរើននោះ
ប្តេជ្ញាថាជាអ្នកពោលនូវការកំណត់ដឹងនូវឧបាទានទាំងអស់ តែពួកគេទាំង
នោះ មិនបញ្ញត្តនូវការកំណត់ដឹងនូវឧបាទានទាំងអស់ ដោយប្រពៃទេ
បញ្ញត្តតែការកំណត់ដឹងនូវកាមុបាទានប៉ុណ្ណោះ មិនបញ្ញត្តនូវការកំណត់ដឹង
នូវទិដ្ឋុបាទាន មិនបញ្ញត្តនូវការកំណត់ដឹងនូវសីលព្វតុបាទាន មិនបញ្ញត្ត
នូវការកំណត់ដឹងនូវអត្តវាទុបាទានទេ ។ ម្នាលភិក្ខុទាំងឡាយ មានសម-
ណព្រាហ្មណ៍ពួកមួយ ប្តេជ្ញាថាជាអ្នកពោលនូវការកំណត់ដឹងនូវឧបាទាន

តេ ន សម្មា សព្វុបាទានបរិញ្ញំ បញ្ញាបេន្តិ កាមុ-
បាទានស្ស បរិញ្ញំ បញ្ញាបេន្តិ ទិដ្ឋុបាទានស្ស បរិញ្ញំ
បញ្ញាបេន្តិ ន សីលព្វតុបាទានស្ស បរិញ្ញំ បញ្ញាបេន្តិ
ន អត្តវាទុបាទានស្ស បរិញ្ញំ បញ្ញាបេន្តិ តំ កិស្ស
ហេតុ ឥមានិ ហិ តេ ភោន្តោ សមណព្រាហ្មណា
ទ្វេ ឋានានិ យថាភូតំ នប្បជានន្តិ តស្មា តេ
ភោន្តោ សមណព្រាហ្មណា សព្វុបាទានបរិញ្ញាវាទា
បដិជានមានា តេ ន សម្មា សព្វុបាទានស្ស
បរិញ្ញំ បញ្ញាបេន្តិ កាមុបាទានស្ស បរិញ្ញំ បញ្ញា-
បេន្តិ ទិដ្ឋុបាទានស្ស បរិញ្ញំ បញ្ញាបេន្តិ សីលព្វតុបា-
ទានស្ស បរិញ្ញំ បញ្ញាបេន្តិ ន អត្តវាទុបាទានស្ស
បរិញ្ញំ បញ្ញាបេន្តិ ។ សន្តិ ភិក្ខវេ ឯកេ សម-
ណព្រាហ្មណា សព្វុបាទានបរិញ្ញាវាទា បដិជានមានា
តេ ន សម្មា សព្វុបាទានស្ស បរិញ្ញំ បញ្ញាបេន្តិ កាមុ-
បាទានស្ស បរិញ្ញំ បញ្ញាបេន្តិ ទិដ្ឋុបាទានស្ស បរិញ្ញំ
បញ្ញាបេន្តិ សីលព្វតុបាទានស្ស បរិញ្ញំ បញ្ញាបេន្តិ ន
អត្តវាទុបាទានស្ស បរិញ្ញំ បញ្ញាបេន្តិ តំ កិស្ស ហេតុ



ទាំងអស់ តែសមណព្រាហ្មណ៍ទាំងនោះ មិនបញ្ញត្តនូវការកំណត់ដឹងនូវ
ឧបាទានទាំងអស់ ដោយប្រពៃទេ បញ្ញត្តតែការកំណត់ដឹងនូវកាមុបាទាន
បញ្ញត្តតែការកំណត់ដឹងនូវទិដ្ឋុបាទានប៉ុណ្ណោះ មិនបញ្ញត្តនូវការកំណត់ដឹង
នូវសីលព្វតុបាទាន មិនបញ្ញត្តនូវការកំណត់ដឹងនូវអត្តវាទុបាទានទេ ដំ-
ណើរនោះព្រោះហេតុអ្វី ព្រោះថាពួកសមណព្រាហ្មណ៍ដ៏ចំរើននោះ មិន
ដឹងច្បាស់នូវហេតុទាំង ២ ប្រការនេះតាមពិតទេ ព្រោះហេតុនោះបានជា
ពួកសមណព្រាហ្មណ៍ដ៏ចំរើននោះ ប្តេជ្ញាថាជាអ្នកពោលនូវការកំណត់
ដឹងនូវឧបាទានទាំងអស់ តែពួកគេនោះមិនបញ្ញត្តនូវការកំណត់ដឹងនូវ
ឧបាទានទាំងអស់ដោយប្រពៃទេ បញ្ញត្តតែការកំណត់ដឹងនូវកាមុបាទាន
បញ្ញត្តតែការកំណត់ដឹងនូវទិដ្ឋុបាទាន បញ្ញត្តតែការកំណត់ដឹងនូវសីល-
ព្វតុបាទានប៉ុណ្ណោះ មិនបញ្ញត្តនូវការកំណត់ដឹងនូវអត្តវាទុបាទានទេ ។
ម្នាលភិក្ខុទាំងឡាយ មានសមណព្រាហ្មណ៍ពួកមួយ ប្តេជ្ញាថាជាអ្នក
ពោលនូវការកំណត់ដឹងនូវឧបាទានទាំងអស់ តែពួកគេទាំងនោះ មិន
បញ្ញត្តនូវការកំណត់ដឹងនូវឧបាទានទាំងអស់ដោយប្រពៃទេ បញ្ញត្តតែ
ការកំណត់ដឹងនូវកាមុបាទាន បញ្ញត្តតែការកំណត់ដឹង នូវទិដ្ឋុបា-
ទាន បញ្ញត្តតែការកំណត់ដឹងនូវសីលព្វតុបាទានប៉ុណ្ណោះ មិនបញ្ញត្ត
នូវការកំណត់ដឹង នូវអត្តវាទុបាទានទេ ដំណើរនោះ តើព្រោះហេតុអ្វី

ឥមានិ ហិ តេ ភោន្តោ សមណព្រាហ្មណា តីណិ ឋានានិ យថាភូតំ នប្បជានន្តិ តស្មា តេ ភោន្តោ សមណព្រាហ្មណា សព្វុបាទានបរិញ្ញាវាទា បដិជានមានា តេ ន សម្មា សព្វុបាទានស្ស បរិញ្ញំ បញ្ញបេន្តិ កាមុបាទានស្ស បរិញ្ញំ បញ្ញបេន្តិ ទិដ្ឋុបាទានស្ស បរិញ្ញំ បញ្ញបេន្តិ សីលព្វតុបាទានស្ស បរិញ្ញំ បញ្ញបេន្តិ ន អត្តវាទុបាទានស្ស បរិញ្ញំ បញ្ញបេន្តិ ។ ឯវរូបេ ខោ ភិក្ខវេ ធម្មវិនយេ យោ សត្ថរិ បសាទោ សោ ន សម្មគ្គតោ អក្ខាយតិ យោ ធម្មេ បសាទោ សោ ន សម្មគ្គតោ អក្ខាយតិ យា សីលេសុ បរិបូរការិតា(១) សា ន សម្មគ្គតា អក្ខាយតិ យា សហធម្មិកេសុ បិយមនាបតា សា ន សម្មគ្គតា អក្ខាយតិ តំ កិស្ស ហេតុ ឯវញ្ហេតំ ភិក្ខវេ ហោតិ យថាតំ ទុរក្ខាតេ ធម្មវិនយេ ទុប្បវេទិតេ អនិយ្យានិកេ អនុបសមសំវត្តនិកេ អសម្មាសម្ពុទ្ធប្បវេទិតេ ។

១ បរិបូរិការិតាតិបិ បាឋោ ។



ព្រោះថាពួកសមណព្រាហ្មណ៍ដ៏ចំរើននោះ មិនដឹងច្បាស់នូវហេតុ ៣ ប្រការនេះតាមពិតទេ ព្រោះហេតុនោះបានជា ពួកសមណព្រាហ្មណ៍ដ៏ចំរើននោះ ប្តេជ្ញាថាជាអ្នកពោលនូវការកំណត់ដឹងនូវឧបាទានទាំងអស់ តែពួកគេនោះ មិនបញ្ញត្តនូវការកំណត់ដឹងនូវឧបាទានទាំងអស់ទេ បញ្ញត្តតែការកំណត់ដឹងនូវកាមុបាទាន បញ្ញត្តតែការកំណត់ដឹងនូវទិដ្ឋុបាទាន បញ្ញត្តតែការកំណត់ដឹង នូវសីលព្វតុបាទានប៉ុណ្ណោះ មិនបញ្ញត្តនូវការកំណត់ដឹងនូវអត្តវាទុបាទានទេ ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីជ្រះថ្លាណាក្នុងសាស្តា ក្នុងធម្មវិន័យបែបនេះឯង សេចក្តីជ្រះថ្លានោះមិនហៅថាប្រព្រឹត្តទៅដោយប្រពៃទេ សេចក្តីជ្រះថ្លាក្នុងធម៌ ក៏មិនហៅថាប្រព្រឹត្តទៅដោយប្រពៃទេ ការធ្វើឲ្យបរិបូណ៌ក្នុងសីលទាំងឡាយ ក៏មិនហៅថាប្រព្រឹត្តទៅដោយប្រពៃទេ សេចក្តីស្រឡាញ់និងសេចក្តីគាប់ចិត្ត ក្នុងសហធម្មិកទាំងឡាយ ក៏មិនហៅថាប្រព្រឹត្តទៅដោយប្រពៃទេ ដំណើរនោះតើព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ បានជាយ៉ាងនុ៎ះ ព្រោះហេតុតែធម្មវិន័យដែលគេពោលហើយមិនត្រឹមត្រូវ ប្រកាសទុកមិនល្អ មិនមែនជាធម៌ស្រោចស្រង់សត្វ មិនប្រព្រឹត្តទៅដើម្បីសេចក្តីស្ងប់ទុក្ខ ជាធម៌ដែលគ្រូមិនមែនជាសម្មាសម្ពុទ្ធសំដែងទុកដោយពិត ។

(១៨៧) យោ ច ខោ សោ ភិក្ខវេ តថាគតោ អរហំ សម្មាសម្ពុទ្ធោ សព្វុបាទានបរិញ្ញាវាទោ បដិជានមានោ សម្មា សព្វុបាទានបរិញ្ញំ បញ្ញាបេតិ កាមុបាទានស្ស បរិញ្ញំ បញ្ញាបេតិ ទិដ្ឋុបាទានស្ស បរិញ្ញំ បញ្ញាបេតិ សីលព្វតុបាទានស្ស បរិញ្ញំ បញ្ញាបេតិ អត្តវាទុបាទានស្ស បរិញ្ញំ បញ្ញាបេតិ ។ ឯវរូបេ ខោ ភិក្ខវេ ធម្មវិនយេ យោ សត្ថរិ បសាទោ សោ សម្មគ្គតោ អក្ខាយតិ យោ ធម្មេ បសាទោ សោ សម្មគ្គតោ អក្ខាយតិ យា សីលេសុ បរិបូរការិតា សា សម្មគ្គតា អក្ខាយតិ យា សហធម្មិកេសុ បិយមនាបតា សា សម្មគ្គតា អក្ខាយតិ តំ កិស្ស ហេតុ ឯវញ្ហេតំ ភិក្ខវេ ហោតិ យថាតំ ស្វាក្ខាតេ ធម្មវិនយេ សុប្បវេទិតេ និយ្យានិកេ ឧបសមសំវត្តនិកេ សម្មាសម្ពុទ្ធប្បវេទិតេ ។

(១៨៨) ឥមេ ច ភិក្ខវេ ចត្តារោ ឧបាទានា កឹនិទានា កឹសមុទយា កឹជាតិកា កឹបភវា ។



(១៨៧) ម្នាលភិក្ខុទាំងឡាយ ចំណែកព្រះតថាគតជាអរហន្តសម្មាសម្ពុទ្ធ ប្តេជ្ញាថាជាអ្នកពោលនូវការកំណត់ដឹងនូវឧបាទានទាំងអស់ តែងបញ្ញត្តនូវការកំណត់ដឹងនូវឧបាទានទាំងអស់ដោយប្រពៃ គឺបញ្ញត្តនូវការកំណត់ដឹងកាមុបាទាន បញ្ញត្តនូវការកំណត់ដឹងទិដ្ឋុបាទាន បញ្ញត្តនូវការកំណត់ដឹងសីលព្វតុបាទាន បញ្ញត្តនូវការកំណត់ដឹងអត្តវាទុបាទាន ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីជ្រះថ្លាណាក្នុងសាស្តា ក្នុងធម្មវិន័យបែបនេះឯង សេចក្តីជ្រះថ្លានោះ ហៅថាប្រព្រឹត្តទៅដោយប្រពៃ សេចក្តីជ្រះថ្លាក្នុងធម៌ ក៏ហៅថាប្រព្រឹត្តទៅដោយប្រពៃ ការធ្វើឲ្យបរិបូណ៌ក្នុងសីលទាំងឡាយ ក៏ហៅថាប្រព្រឹត្តទៅដោយប្រពៃ សេចក្តីស្រឡាញ់ពេញចិត្ត ក្នុងសហធម្មិកទាំងឡាយ ក៏ហៅថាប្រព្រឹត្តទៅដោយប្រពៃ ដំណើរនោះតើព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ មុខជាយ៉ាងនេះ ព្រោះហេតុតែធម្មវិន័យដែលព្រះតថាគតសំដែងល្អហើយ ប្រកាសទុកល្អហើយ ជាធម៌ស្រោចស្រង់សត្វ ប្រព្រឹត្តទៅដើម្បីសេចក្តីស្ងប់រម្ងាប់ ជាធម៌ដែលព្រះសម្មាសម្ពុទ្ធសំដែងទុកហើយ ដោយពិត ។

(១៨៨) ម្នាលភិក្ខុទាំងឡាយ ឧបាទានទាំង ៤ នេះឯងមានអ្វីជាហេតុ មានអ្វីនាំឲ្យកើត មានអ្វីជាកំណើត មានអ្វីជាដែនកើតមុន ។

ឥមេ ចត្តារោ ឧបាទានា តណ្ហានិទានា តណ្ហាសមុទយា តណ្ហាជាតិកា តណ្ហាបភវា ។ តណ្ហា ចាយំ ភិក្ខវេ កឹនិទានា កឹសមុទយា កឹជាតិកា កឹបភវា ។ តណ្ហា វេទនានិទានា វេទនាសមុទយា វេទនាជាតិកា វេទនាបភវា ។ វេទនា ចាយំ ភិក្ខវេ កឹនិទានា កឹសមុទយា កឹជាតិកា កឹបភវា ។ វេទនា ផស្សនិទានា ផស្សសមុទយា ផស្សជាតិកា ផស្សប្បភវា ។ ផស្សោ ចាយំ ភិក្ខវេ កឹនិទានោ កឹសមុទយោ កឹជាតិកោ កឹបភវោ ។ ផស្សោ សឡាយតននិទានោ សឡាយតនសមុទយោ សឡាយតនជាតិកោ សឡាយតនប្បភវោ ។ សឡាយតនញ្ចិទំ ភិក្ខវេ កឹនិទានំ កឹសមុទយំ កឹជាតិកំ កឹបភវំ ។ សឡាយតនំ នាមរូបនិទានំ នាមរូបសមុទយំ នាមរូបជាតិកំ នាមរូបប្បភវំ ។ នាមរូបញ្ចិទំ ភិក្ខវេ កឹនិទានំ កឹសមុទយំ កឹជាតិកំ





ឧបាទានទាំង ៤ នេះ មានតណ្ហាជាហេតុ មានតណ្ហាជាទីកើត មានតណ្ហាជាកំណើត មានតណ្ហាជាដែនកើតមុន ។ ម្នាលភិក្ខុទាំងឡាយ ចំណែកតណ្ហានេះ មានអ្វីជាហេតុ មានអ្វីជាទីកើត មានអ្វីជាកំណើត មានអ្វីជាដែនកើតមុន ។ តណ្ហាមានវេទនាជាហេតុ មានវេទនាជាទីកើត មានវេទនាជាកំណើត មានវេទនាជាដែនកើតមុន ។ ម្នាលភិក្ខុទាំងឡាយ ឯវេទនានេះមានអ្វីជាហេតុ មានអ្វីជាទីកើត មានអ្វីជាកំណើត មានអ្វីជាដែនកើតមុន ។ វេទនាមានផស្សៈជាហេតុ មានផស្សៈជាទីកើត មានផស្សៈជាកំណើត មានផស្សៈជាដែនកើតមុន ។ ម្នាលភិក្ខុទាំងឡាយ ចុះផស្សៈនេះតើមានអ្វីជាហេតុ មានអ្វីជាទីកើត មានអ្វីជាកំណើត មានអ្វីជាដែនកើតមុន ។ ផស្សៈមានសឡាយតនៈជាហេតុ មានសឡាយតនៈជាទីកើត មានសឡាយតនៈជាកំណើត មានសឡាយតនៈជាដែនកើតមុន ។ ម្នាលភិក្ខុទាំងឡាយ សឡាយតនៈនេះតើមានអ្វីជាហេតុ មានអ្វីជាទីកើត មានអ្វីជាកំណើត មានអ្វីជាដែនកើតមុន ។ សឡាយតនៈមាននាមរូបជាហេតុ មាននាមរូបជាទីកើត មាននាមរូបជាកំណើត មាននាមរូបជាដែនកើតមុន ។ ម្នាលភិក្ខុទាំងឡាយ នាមរូបនេះតើមានអ្វីជាហេតុ មានអ្វីជាទីកើត មានអ្វីជាកំណើត មានអ្វីជា

កិំបភវំ ។ នាមរូបំ វិញ្ញាណនិទានំ វិញ្ញាណសមុទយំ វិញ្ញាណជាតិកំ វិញ្ញាណប្បភវំ ។ វិញ្ញាណញ្ចិទំ ភិក្ខវេ កិំនិទានំ កិំសមុទយំ កិំជាតិកំ កិំបភវំ ។ វិញ្ញាណំ សង្ខារនិទានំ សង្ខារសមុទយំ សង្ខារជាតិកំ សង្ខារប្បភវំ ។ សង្ខារា ចិមេ ភិក្ខវេ កិំនិទានា កិំសមុទយា កិំជាតិកា កិំបភវា ។ សង្ខារា អវិជ្ជានិទានា អវិជ្ជាសមុទយា អវិជ្ជាជាតិកា អវិជ្ជាបភវា ។ យតោ ច ខោ ភិក្ខវេ ភិក្ខុនោ អវិជ្ជា បហីនា ហោតិ វិជ្ជា ឧប្បន្នា សោ អវិជ្ជាវិរាគា វិជ្ជុប្បាទា នេវ កាមុបាទានំ ឧបាទិយតិ ន ទិដ្ឋុបាទានំ ឧបាទិយតិ ន សីលព្វតុបាទានំ ឧបាទិយតិ ន អត្តវាទុបាទានំ ឧបាទិយតិ អនុបាទិយំ ន បរិតស្សតិ អបរិតស្សំ បច្ចត្តញ្ញេវ[១] បរិនិព្វាយតិ

១ ម. បច្ចត្តំយេវ ។



ដែលកើតមុន ។ នាមរូបមានវិញ្ញាណជាហេតុ មានវិញ្ញាណជាទីកើត មានវិញ្ញាណជាកំណើត មានវិញ្ញាណជាដែនកើតមុន ។ ម្នាលភិក្ខុទាំងឡាយ វិញ្ញាណនេះកើតមានអ្វីជាហេតុ មានអ្វីជាទីកើត មានអ្វីជាកំណើត មានអ្វីជាដែនកើតមុន ។ វិញ្ញាណមានសង្ខារជាហេតុ មានសង្ខារជាទីកើត មានសង្ខារជាកំណើត មានសង្ខារជាដែនកើតមុន ។ ម្នាលភិក្ខុទាំងឡាយ សង្ខារទាំងឡាយនេះកើតមានអ្វីជាហេតុ មានអ្វីជាទីកើត មានអ្វីជាកំណើត មានអ្វីជាដែនកើតមុន ។ សង្ខារទាំងឡាយមានអវិជ្ជាជាហេតុ មានអវិជ្ជាជាទីកើត មានអវិជ្ជាជាកំណើត មានអវិជ្ជាជាដែនកើតមុន ។ ម្នាលភិក្ខុទាំងឡាយ កាលណាភិក្ខុលះបង់អវិជ្ជាបានហើយ វិជ្ជាក៏កើតឡើង ភិក្ខុនោះលែងប្រកាន់មាំនូវកាមុបាទាន លែងប្រកាន់មាំនូវទិដ្ឋុបាទាន លែងប្រកាន់មាំនូវសីលព្វតុបាទាន លែងប្រកាន់មាំនូវអត្តវាទុបាទាន កាលបើលែងប្រកាន់មាំហើយ ក៏មិនមានតក់ស្លុត (ដោយតណ្ហា) កាលបើមិនតក់ស្លុតហើយ ក៏រមែងរលត់ (កិលេស) ចំពោះខ្លួនឯង ព្រោះអស់ទៅនៃអវិជ្ជា ព្រោះវិជ្ជាកើតឡើង

ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាតិ(១) ។ ឥទមវោច ភគវា អត្តមនា តេ ភិក្ខូ ភគវតោ ភាសិតំ អភិនន្ទុន្តិ ។

ចូឡសីហនាទសុត្តំ បឋមំ និដ្ឋិតំ ។

---

១ ម. បជានាតីតិ ។



ហើយដឹងច្បាស់ដូច្នេះថា ជាតិអស់ហើយ ព្រហ្មចរិយធម៌អាត្មាអញ នៅចប់ស្រេចហើយ សោឡសកិច្ចអាត្មាអញបានធ្វើរួចហើយ កិច្ចក្រៅអំពីនេះទៅទៀត មិនមានឡើយ ។ លុះព្រះមានព្រះភាគបានត្រាស់ព្រះសូត្រនេះចប់ហើយ ភិក្ខុទាំងឡាយនោះក៏មានចិត្តត្រេកអររីករាយ ចំពោះភាសិតរបស់ព្រះមានព្រះភាគ ។

ចប់ចូឡសីហនាទសូត្រ ទី ១ ។

## ទុតិយំ មហាសីហនាទសុត្តំ

(១៥៩) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា វេសាលិយំ វិហរតិ ពហិនគរេ អបរបុរេ[១] វនសណ្ឌេ ។ តេន ខោ បន សមយេន សុនក្ខត្តោ លិច្ឆវិបុត្តោ អចិរបក្កន្តោ ហោតិ ឥមស្មា ធម្មវិនយា ។ សោ វេសាលិយំ បរិសតិ[២] ឯវំ[៣] វាចំ ភាសតិ នត្ថិ សមណស្ស គោតមស្ស ឧត្តរិ[៤] មនុស្សធម្មា អលមរិយញាណទស្សនវិសេសោ តក្កបរិយាហតំ សមណោ គោតមោ ធម្មំ ទេសេតិ វីមំសានុចរិតំ សយំបដិភាណំ យស្ស ច ខ្វាស្ស អត្ថាយ ធម្មោ ទេសិតោ សោ និយ្យាតិ តក្ករស្ស សម្មា ទុក្ខក្ខយាយាតិ ។

---

១ ឱ. អបរបុរេតិ បាឋោ បញ្ញាយតិ ។ ២ ឱ. បរិសតិន្តិ បាឋោ ទិស្សតិ ។ ៣ ឱ. ម. ឯតំ ។ ៤ ឱ. ឧត្តរី ។

## មហាសីហនាទសូត្រ ទី ២

(១៥៩) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគទ្រង់គង់ក្នុងដងព្រៃក្រៅនគរ ជាខាងលិចក្រុងវេសាលី ។ សម័យនោះឯង សុនក្ខត្តលិច្ឆវីបុត្ត ទើបនឹងសឹកចេញចាកធម្មវិន័យនេះទៅមិនយូរប៉ុន្មាន ។ គេនិយាយពាក្យក្នុងកណ្តាលបរិស័ទ ក្នុងក្រុងវេសាលី យ៉ាងនេះថា គុណវិសេសគឺញាណទស្សនៈ[១] ជាគុណគួរដើម្បីធ្វើខ្លួនឲ្យជាព្រះអរិយៈដ៏ក្រៃលែងជាងមនុស្សធម៌[២] នៃព្រះសមណគោតមមិនមានទេ ព្រះសមណគោតម សំដែងធម៌ដែលខ្លួនស្រាវជ្រាវដោយសេចក្តីត្រិះរិះ ដែលខ្លួនស្ទាបស្ទង់ដោយការពិចារណា ជាការឈ្លាសវៃដោយខ្លួនឯង តែធម៌ដែលព្រះអង្គសំដែងហើយ ដើម្បីប្រយោជន៍ដល់គុណវិសេសណា គុណវិសេសនោះរមែងប្រព្រឹត្តទៅដើម្បីសេចក្តីអស់ទៅនៃវដ្តទុក្ខដោយប្រពៃដល់បុគ្គលអ្នកធ្វើតាមធម៌នោះ ។

---

១ បានដល់លោកុត្តរមគ្គ ។ ២ បានដល់កុសលកម្មបថ ១០ ។

(១៦០) អថខោ អាយស្មា សារីបុត្តោ បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ វេសាលឹ បិណ្ឌាយ បាវិសិ ។ អស្សោសិ ខោ អាយស្មា សារីបុត្តោ សុនក្ខត្តស្ស លិច្ឆវិបុត្តស្ស វេសាលិយំ បរិសតិ ឯវំ វាចំ ភាសមានស្ស នត្ថិ សមណស្ស គោតមស្ស ឧត្តរិ មនុស្សធម្មា អលមរិយញាណទស្សនវិសេសោ តក្កបរិយាហតំ សមណោ គោតមោ ធម្មំ ទេសេតិ វីមំសានុចរិតំ សយំបដិភានំ យស្ស ច ខ្វាស្សត្ថាយ ធម្មោ ទេសិតោ សោ និយ្យាតិ តក្ករស្ស សម្មា ទុក្ខក្ខយាយាតិ ។ អថខោ អាយស្មា សារីបុត្តោ វេសាលិយំ បិណ្ឌាយ ចរិត្វា បច្ឆាភត្តំ បិណ្ឌបាតបដិក្កន្តោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា សារីបុត្តោ ភគវន្តំ ឯតទវោច សុនក្ខត្តោ ភន្តេ លិច្ឆវិបុត្តោ អចិរបក្កន្តោ ឥមស្មា ធម្មវិនយា សោ វេសាលិយំ បរិសតិ ឯវំ វាចំ ភាសតិ នត្ថិ



(១៦០) លំដាប់នោះ ព្រះសារីបុត្តដ៏មានអាយុ ស្លៀកស្បង់ ប្រដាប់បាត្រនិងចីវរ ក្នុងបុព្វណ្ហសម័យ ចូលទៅកាន់ក្រុងវេសាលីដើម្បីបិណ្ឌបាត ។ ព្រះសារីបុត្តមានអាយុ បានឮសុនក្ខត្តលិច្ឆវិបុត្តកំពុងពោលវាចាក្នុងកណ្តាលបរិស័ទ្យ ក្នុងក្រុងវេសាលីយ៉ាងនេះថា គុណវិសេសគឺញាណទស្សនៈ ដែលគួរដើម្បីធ្វើនូវឲ្យជាអរិយៈដ៏ក្រៃលែងជាងមនុស្សធម៌នៃព្រះសមណគោតមមិនមានទេ ព្រះសមណគោតមសំដែងធម៌ដែលខ្លួនស្រាវជ្រាវដោយសេចក្តីត្រិះរិះ ដែលខ្លួនស្ទាបស្ទង់ដោយការពិចារណា ជាការឈ្លាសវៃខ្លួនឯង តែធម៌ដែលព្រះអង្គសំដែងហើយដើម្បីប្រយោជន៍ដល់គុណវិសេសណា គុណវិសេសនោះ រមែងប្រព្រឹត្តទៅដើម្បីឲ្យអស់ទៅនៃវដ្តទុក្ខដោយប្រពៃ ដល់បុគ្គលអ្នកធ្វើតាមធម៌នោះ ។ លុះព្រះសារីបុត្តមានអាយុ ត្រាច់ទៅក្នុងក្រុងវេសាលីដើម្បីបិណ្ឌបាត ត្រឡប់អំពីបិណ្ឌបាតហើយ ក្នុងវេលាខាងក្រោយភត្ត ក៏ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះព្រះសារីបុត្តមានអាយុ អង្គុយក្នុងទីសមគួរហើយ ទើបក្រាបបង្គំទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន សុនក្ខត្តលិច្ឆវិបុត្ត ទើបនឹងសឹកចេញចាកធម្មវិន័យនេះមិនយូរប៉ុន្មាន តែងពោលវាចាក្នុងកណ្តាលបរិស័ទ្យ ក្នុងក្រុង

សមណស្ស គោតមស្ស ឧត្តរិ មនុស្សធម្មា អលម-
រិយញាណទស្សនវិសេសោ តក្កបរិយាហតំ សមណោ គោតមោ ធម្មំ ទេសេតិ វីមំសានុចរិតំ សយំបដិភាណំ យស្ស ច ខ្វាស្សត្ថាយ ធម្មោ ទេសិតោ សោ និយ្យាតិ តក្ករស្ស សម្មា ទុក្ខក្ខយាយាតិ ។

(១៦១) កោធនោ សោ[1] សារីបុត្ត សុនក្ខត្តោ មោឃបុរិសោ កោធា ច បនស្ស ឯសា វាចា ភាសិតា វណ្ណំ ភាសិស្សាមីតិ សោ សារីបុត្ត សុនក្ខត្តោ មោឃបុរិសោ អវណ្ណំយេវ តថាគតស្ស ភាសតិ វណ្ណោ ហេសោ សារីបុត្ត តថាគតស្ស យោ ឯវំ វទេយ្យ យស្ស ច ខ្វាស្សត្ថាយ ធម្មោ ទេសិតោ សោ និយ្យាតិ តក្ករស្ស សម្មា ទុក្ខក្ខយាយាតិ ។

(១៦២) អយម្បិ[2] ហិ នាម សារីបុត្ត សុ-
នក្ខត្តស្ស មោឃបុរិសស្ស មយិ ធម្មន្វយោ ន ភ-
វិស្សតិ ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ

១ ឱ. ម. កោធនោ ទំស្សតិ ។ ២ ម. អយំបិ ។



វេសាលីយ៉ាងនេះថា គុណវិសេសគឺញាណទស្សនៈ ជាគុណអាចធ្វើខ្លួនឲ្យជាព្រះអរិយៈដ៏ក្រៃលែងជាងមនុស្សធម៌នៃព្រះសមណគោតមមិនមានទេ ព្រះសមណគោតមសំដែងធម៌ដែលខ្លួនស្រាវជ្រាវដោយសេចក្តីត្រិះរិះ ដែលខ្លួនស្ទាបស្ទង់ ដោយការពិចារណា ជាការឈ្លាសវៃដោយខ្លួនឯង តែធម៌ ដែលព្រះអង្គសំដែងហើយ ដើម្បីប្រយោជន៍ដល់គុណវិសេសណា គុណវិសេសនោះ រមែងប្រព្រឹត្តទៅដើម្បីសេចក្តីអស់ទៅ នៃវដ្តទុក្ខ ដោយប្រពៃ ដល់បុគ្គលអ្នកធ្វើតាមធម៌នោះ ។

(១៦១) ព្រះអង្គត្រាស់ថា ម្នាលសារីបុត្ត សុនក្ខត្តជាមនុស្សកាច ជាមោឃបុរស ព្រោះវាចានោះគាត់ពោលដោយសេចក្តីក្រេវក្រោធ ម្នាលសារីបុត្ត សុនក្ខត្តជាមោឃបុរសនោះគិតថា អាត្មាអញនឹងតិះដៀល ហើយត្រឡប់ជាសរសើរតថាគតវិញ ម្នាលសារីបុត្ត ព្រោះការនិយាយយ៉ាងនេះថា ធម៌ដែលព្រះសមណគោតមសំដែងហើយ ដើម្បីប្រយោជន៍ដល់គុណវិសេសណា គុណវិសេសនោះរមែងប្រព្រឹត្តទៅដើម្បីសេចក្តីអស់ទៅនៃវដ្តទុក្ខៈដោយប្រពៃ ដល់បុគ្គលអ្នកធ្វើតាមធម៌នោះ នេះឯងជាគុណរបស់តថាគត ។

(១៦២) ម្នាលសារីបុត្ត សុនក្ខត្តជាមោឃបុរសមិនបានយល់ធម៌គួរតថាគតនេះថា ព្រះមានព្រះភាគអង្គនោះ ជាអរហន្តសម្មាសម្ពុទ្ធ

វិជ្ជាចរណសម្បន្នោ សុគតោ លោកវិទូ អនុត្តរោ បុរិសទម្មសារថិ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ ។

(១៦៣) អយម្បិ[១] ហិ នាម សារីបុត្ត សុនក្ខត្តស្ស មោឃបុរិសស្ស មយិ ធម្មន្វយោ ន ភវិស្សតិ ឥតិបិ សោ ភគវា អនេកវិហិតំ ឥទ្ធិវិធំ បច្ចនុភោតិ ឯកោបិ ហុត្វា ពហុធា ហោតិ ពហុធាបិ ហុត្វា ឯកោ ហោតិ អាវិភាវំ តិរោភាវំ តិរោកុឌ្ឌំ តិរោបាការំ តិរោបព្វតំ អសជ្ជមានោ គច្ឆតិ សេយ្យថាបិ អាកាសេ ។ បឋវិយាបិ ឧម្មុជ្ជនិមុជ្ជំ ករោតិ សេយ្យថាបិ ឧទកេ ។ ឧទកេបិ អភិជ្ជមានេ គច្ឆតិ សេយ្យថា បឋវិយំ ។ អាកាសេបិ បល្លង្កេន កមតិ សេយ្យថាបិ បក្ខី សកុណោ ។ ឥមេបិ ចន្ទិមសុរិយេ ឯវំមហិទ្ធិកេ ឯវំមហានុភាវេ បាណិនា បរិមសតិ បរិមជ្ជតិ យាវ ព្រហ្មលោកាបិ កាយេន វសំ វត្តេតីតិ[២] ។

១ ម. យម្បិ ហិ ។ ២ ម. [illegible] វត្តេតីតិ ។



បរិបូណ៌ដោយវិជ្ជានិងចរណៈ ជាព្រះសុគត ជ្រាបច្បាស់នូវលោក ជាសារថីទូន្មាននូវបុរស មិនមានអ្នកណាប្រសើរជាង ជាសាស្តានៃទេវតានិងមនុស្ស ជាបុគ្គលត្រាស់ដឹង ទ្រង់មានជោគ ។

(១៦៣) ម្នាលសារីបុត្ត សុនក្ខត្តជាមោឃបុរសនឹងមិនបាន ត្រាស់ដឹងនូវធម៌ក្នុងតថាគតនេះថា ព្រះមានព្រះភាគអង្គនោះតែងសំដែង នូវឫទ្ធិបានច្រើនប្រការ គឺសូម្បីតែម្នាក់ ធ្វើឲ្យទៅជាច្រើននាក់ក៏បាន សូម្បីច្រើននាក់ធ្វើឲ្យទៅជាមនុស្សម្នាក់ក៏បាន ទៅកាន់ទីវាល ជាទីខាង ក្រៅ ខាងក្រៅជញ្ជាំង ខាងក្រៅកំពែង ខាងក្រៅភ្នំ ក៏ឥតមានទើស ដូចជាគេដើរលើអាកាស ។ ងើបមុជក្នុងផែនដី ដូចជាគេងើបមុជ ក្នុងទឹកក៏បាន ។ ដើរលើទឹកក៏បានឥតមានបែកធ្លាយ ដូចជាគេដើរលើ ផែនដី ។ អង្គុយពែនភ្នែន ទៅតាំងក្នុងអាកាសក៏បាន ដូចជាសត្វ សកុណជាតិដែលមានស្លាប ។ យកដៃស្ទាបអង្អែលព្រះចន្ទនិងព្រះអា- ទិត្យទាំងនេះ ដែលមានឫទ្ធិច្រើនយ៉ាងនេះ មានអានុភាពច្រើនយ៉ាងនេះ ក៏បាន ញ៉ាំងអំណាចកាយឲ្យអណ្តែតហូតដល់ព្រហ្មលោកក៏បាន ។

(១៦២) អយម្បិ ហិ នាម សារីបុត្ត សុនក្ខ-
ត្តស្ស មោឃបុរិសស្ស មយិ ធម្មន្វយោ ន ភវិស្សតិ
ឥតិបិ សោ ភគវា ទិព្វាយ សោតធាតុយា វិសុទ្ធាយ
អតិក្កន្តមានុសិកាយ ឧភោ សទ្ទេ សុណាតិ ទិព្វេ
ច មានុសេ ច យេ ទូរេ សន្តិកេ ចាតិ ។

(១៦៣) អយម្បិ ហិ នាម សារីបុត្ត សុនក្ខត្តស្ស
មោឃបុរិសស្ស មយិ ធម្មន្វយោ ន ភវិស្សតិ ឥ-
តិបិ សោ ភគវា បរសត្តានំ បរបុគ្គលានំ ចេតសា
ចេតោ បរិច្ច បជានាតិ ។ សរាគំ វា ចិត្តំ សរាគំ
ចិត្តន្តិ បជានាតិ វីតរាគំ វា ចិត្តំ វីតរាគំ ចិត្តន្តិ
បជានាតិ ។ សទោសំ វា ចិត្តំ សទោសំ ចិត្តន្តិ
បជានាតិ វីតទោសំ វា ចិត្តំ វីតទោសំ ចិត្តន្តិ បជា-
នាតិ ។ សមោហំ វា ចិត្តំ សមោហំ ចិត្តន្តិ បជា-
នាតិ វីតមោហំ វា ចិត្តំ វីតមោហំ ចិត្តន្តិ បជានាតិ ។



(១៦២) ម្នាលសារីបុត្ត សុនក្ខត្តជាមោឃបុរសនឹងមិនបានត្រាស់
ដឹងធម៌ក្នុងតថាគតនេះថា ព្រះមានព្រះភាគអង្គនោះ មានសោតធាតុ
ជាទិព្វដ៏បរិសុទ្ធកន្លងហួសត្រចៀកមនុស្សធម្មតា រមែងឮសំឡេងពីរប្រ-
ការ គឺសំឡេងទិព្វនិងសំឡេងមនុស្ស ក្នុងទីឆ្ងាយក៏បាន ទីជិតក៏បាន ។

(១៦៣) ម្នាលសារីបុត្ត សុនក្ខត្តជាមោឃបុរសនឹងមិនបានត្រាស់
ដឹងធម៌ក្នុងតថាគតនេះថា ព្រះមានព្រះភាគអង្គនោះ កាលកំណត់នូវចិត្ត
របស់សត្វដទៃ បុគ្គលដទៃហើយ ជ្រាបច្បាស់ដោយព្រះទ័យបាន ។
ចិត្តដែលប្រកបដោយរាគៈក្តី ក៏ជ្រាបច្បាស់ថា ចិត្តប្រកបដោយរាគៈ
ចិត្តដែលប្រាសចាករាគៈក្តី ក៏ជ្រាបច្បាស់ថា ចិត្តប្រាសចាករាគៈ ។ ចិត្ត
ដែលប្រកបដោយទោសៈក្តី ក៏ជ្រាបច្បាស់ថា ចិត្តប្រកបដោយទោសៈ
ចិត្តដែលប្រាសចាកទោសៈក្តី ក៏ជ្រាបច្បាស់ថា ចិត្តប្រាសចាកទោសៈ ។
ចិត្តដែលប្រកបដោយមោហៈក្តី ក៏ជ្រាបច្បាស់ថា ចិត្តប្រកបដោយមោហៈ
ចិត្តដែលប្រាសចាកមោហៈក្តី ក៏ជ្រាបច្បាស់ថា ចិត្តប្រាសចាកមោហៈ ។

សង្ខិត្តំ វា ចិត្តំ សង្ខិត្តំ ចិត្តន្តិ បជានាតិ វិក្ខិត្តំ វា ចិត្តំ វិក្ខិត្តំ ចិត្តន្តិ បជានាតិ ។ មហគ្គតំ វា ចិត្តំ... អមហគ្គតំ វា ចិត្តំ... ។ សឧត្តរំ វា ចិត្តំ... អនុត្តរំ វា ចិត្តំ... ។ សមាហិតំ វា ចិត្តំ... អសមាហិតំ វា ចិត្តំ... ។ វិមុត្តំ វា ចិត្តំ វិមុត្តំ ចិត្តន្តិ បជានាតិ អវិមុត្តំ វា ចិត្តំ អវិមុត្តំ ចិត្តន្តិ បជានាតិ ។

(១៦៦) ទស ខោ បនិមានិ សារីបុត្ត តថាគតស្ស តថាគតពលានិ យេហិ ពលេហិ សមន្នាគតោ



ចិត្តរួញរាក្តី ក៏ជ្រាបច្បាស់ថា ចិត្តរួញរា ចិត្តរាយមាយក្តី ក៏ជ្រាបច្បាស់ថា ចិត្តរាយមាយ ។ ចិត្តដែលជាមហគ្គតៈ គឺរូបាវចរនិងអរូបាវចរក្តី... ចិត្តដែលមិនមែនជាមហគ្គតៈក្តី... ។ ចិត្តដែលជាសឧត្តរៈ គឺលោកិយចិត្តក្តី... ចិត្តដែលជាអនុត្តរៈគឺលោកុត្តរចិត្តក្តី... ។ ចិត្តដែលតាំងមាំក្តី... ចិត្តដែលមិនបានតាំងមាំក្តី... ។ ចិត្តដែលផុតស្រឡះចាកអាសវៈក្តី ក៏ជ្រាបច្បាស់ថា ចិត្តផុតស្រឡះចាកអាសវៈ ចិត្តដែលមិនទាន់ផុតចាកអាសវៈក្តី ក៏ជ្រាបច្បាស់ថា ចិត្តមិនទាន់ផុតចាកអាសវៈ ។

[១៦៦] ម្នាលសារីបុត្ត តថាគតពលញ្ញាណ[១] របស់តថាគតនេះមាន ១០ ប្រការ គឺជាពលញ្ញាណ ដែលតថាគតប្រកបហើយ

---

១ អដ្ឋកថា ថា ព្រះតថាគតមានកំឡាំងកាយ ១០ មានកំឡាំងញាណ ១០ ។ កំឡាំងកាយ ១០ នោះ គណនាតាមកំឡាំងដំរី ១០ ត្រកូល គឺកំឡាំងដំរីត្រកូលកាឡាវក ដំរីប្រក្រតី ១០ ស្មើនឹងកំឡាំងដំរីត្រកូលគង្គេយ្យ ១ កំឡាំងគង្គេយ្យ ១០ ស្មើនឹងកំឡាំងដំរីត្រកូលបណ្ឌរ ១ កំឡាំងបណ្ឌរ ១០ ស្មើនឹងកំឡាំងដំរីត្រកូលតម្ព កំឡាំងតម្ព ១០ ស្មើនឹងបិង្គល ១ កំឡាំងបិង្គល ១០ ស្មើនឹងកំឡាំងគន្ធ ១ កំឡាំងគន្ធ ១០ ស្មើនឹងមង្គល ១ មង្គល ១០ ស្មើនឹងហេមវត ១ ហេមវត ១០ ស្មើនឹងឧបោសថ ១ ឧបោសថ ១០ ស្មើនឹងកំឡាំងដំរីឆទ្ទន្ត ១ កំឡាំងដំរីឆទ្ទន្ត ១០ ទើបស្មើនឹងកំឡាំងកាយព្រះតថាគត ១ ។ ដោយទំនងនេះ កំឡាំងកាយព្រះតថាគត ១ ស្មើនឹងកំឡាំងដំរីប្រក្រតី ១ ពាន់កោដិ ឬស្មើនឹងកំឡាំងបុរស ១០ ពាន់កោដិ មានកំឡាំងព្រះកាយយ៉ាងនេះ ១០ ភាគ ។ ចំណែកកំឡាំងព្រះញាណទាំង ១០ នោះ នឹងមាននៅក្នុងសូត្រនេះស្រាប់ ។

តថាគតោ អាសភណ្ឋានំ បដិជានាតិ បរិសាសុ សីហនាទំ នទតិ ព្រហ្មចក្កំ បវត្តេតិ ។ កតមានិ ទស ។ ឥធ សារីបុត្ត តថាគតោ ឋានញ្ច ឋានតោ អដ្ឋានញ្ច អដ្ឋានតោ យថាភូតំ បជានាតិ ។ យម្បិ សារីបុត្ត តថាគតោ ឋានញ្ច ឋានតោ អដ្ឋានញ្ច អដ្ឋានតោ យថាភូតំ បជានាតិ ឥទម្បិ សារីបុត្ត តថាគតស្ស តថាគតពលំ ហោតិ យំ ពលំ អាគម្ម តថាគតោ អាសភណ្ឋានំ បដិជានាតិ បរិសាសុ សីហនាទំ នទតិ ព្រហ្មចក្កំ បវត្តេតិ ។ បុន ចបរំ សារីបុត្ត តថាគតោ អតីតានាគតបច្ចុប្បន្នានំ កម្មសមាទានានំ ឋានសោ ហេតុសោ វិបាកំ យថាភូតំ បជានាតិ ។ យម្បិ សារីបុត្ត តថាគតោ អតីតានាគតបច្ចុប្បន្នានំ កម្មសមាទានានំ ឋានសោ ហេតុសោ វិបាកំ យថាភូតំ បជានាតិ



ទើបដឹងច្បាស់នូវហេតុដ៏ប្រសើរ បន្លឺសីហនាទ ក្នុងបរិស័ទទាំងឡាយ ញុំាងព្រហ្មចក្រ (ចក្រដ៏ប្រសើរ) ឲ្យប្រព្រឹត្តទៅ ។ ឯតថាគតពលញ្ញាណ ១០ តើដូចម្តេច ។ ម្នាលសារីបុត្ត ព្រះតថាគតក្នុងលោកនេះ រមែងដឹងច្បាស់នូវហេតុតាមហេតុផង ដឹងច្បាស់នូវអំពើមិនមែនជាហេតុ តាមអំពើមិនមែនជាហេតុផង តាមសេចក្តីពិត ។ ម្នាលសារីបុត្ត ត្រង់ដែលព្រះតថាគតដឹងច្បាស់នូវហេតុតាមហេតុផង ដឹងច្បាស់នូវអំពើមិនមែនជាហេតុ តាមអំពើមិនមែនជាហេតុផង តាមសេចក្តីពិត ម្នាលសារីបុត្ត នេះឯង ជាតថាគតពលញ្ញាណរបស់តថាគតទី ១ ជាពលញ្ញាណដែលព្រះតថាគតតែងអាស្រ័យ ទើបបានដល់នូវឋានៈដ៏ប្រសើរ បន្លឺសីហនាទក្នុងពួកបរិស័ទ ញុំាងព្រហ្មចក្រ (ចក្រដ៏ប្រសើរ) ឲ្យប្រព្រឹត្តទៅ ។ ម្នាលសារីបុត្ត មួយទៀត ព្រះតថាគតរមែងដឹងច្បាស់នូវវិបាកនៃកុសលកម្មនិងអកុសលកម្ម ដែលសត្វបានធ្វើហើយ ទាំងអតីត អនាគត និងបច្ចុប្បន្ន តាមបច្ច័យ តាមហេតុ ដោយសេចក្តីពិតមែន ។ ម្នាលសារីបុត្ត ត្រង់ដែលតថាគតដឹងច្បាស់នូវវិបាកនៃកុសលកម្មនិងអកុសលកម្ម ដែលសត្វបានធ្វើហើយ ទាំងអតីត អនាគត និងបច្ចុប្បន្ន តាមបច្ច័យ តាមហេតុ ដោយសេចក្តីពិត

ឥទម្បិ សារីបុត្ត តថាគតស្ស តថាគតពលំ ហោតិ យំ ពលំ អាគម្ម តថាគតោ អាសភណ្ឋានំ បដិជានាតិ បរិសាសុ សីហនាទំ នទតិ ព្រហ្មចក្កំ បវត្តេតិ ។ បុន ចបរំ សារីបុត្ត តថាគតោ សព្វត្ថគាមិនឹ បដិបទំ យថាភូតំ បជានាតិ ។ យម្បិ សារីបុត្ត តថាគតោ សព្វត្ថគាមិនឹ បដិបទំ យថាភូតំ បជានាតិ ឥទម្បិ សារីបុត្ត តថាគតស្ស តថាគតពលំ ហោតិ យំ ពលំ អាគម្ម តថាគតោ អាសភណ្ឋានំ បដិ-ជានាតិ បរិសាសុ សីហនាទំ នទតិ ព្រហ្មចក្កំ បវត្តេតិ ។ បុន ចបរំ សារីបុត្ត តថាគតោ អនេ-កធាតុនានាធាតុលោកំ យថាភូតំ បជានាតិ ។ យម្បិ សារីបុត្ត តថាគតោ អនេកធាតុនានាធាតុលោកំ យថាភូតំ បជានាតិ ឥទម្បិ សារីបុត្ត តថាគតស្ស តថាគតពលំ ហោតិ យំ ពលំ អាគម្ម តថាគតោ អាសភណ្ឋានំ បដិជានាតិ



ម្នាលសារីបុត្ត នេះឯងជាតថាគតពលញ្ញាណរបស់តថាគត (ទី ២) ជាពលញ្ញាណដែលតថាគតតែងអាស្រ័យ ទើបបានដល់នូវថ្នាក់ដ៏ប្រសើរ បន្លឺឡើងនូវសីហនាទក្នុងបរិស័ទទាំងឡាយ ញុំាងចក្រដ៏ប្រសើរឲ្យប្រព្រឹត្តទៅ ។ ម្នាលសារីបុត្ត មួយទៀត តថាគតដឹងច្បាស់នូវបដិបទាជាដំណើរ ទៅកាន់សុគតិនិងទុគ្គតិគ្រប់ទាំងពួង តាមសេចក្តីពិត ។ ម្នាលសារីបុត្ត ត្រង់ដែលព្រះតថាគតដឹងច្បាស់នូវបដិបទា ដំណើរទៅកាន់សុគតិនិងទុគ្គតិគ្រប់ទាំងពួង ម្នាលសារីបុត្ត នេះឯងជាតថាគត-ពលញ្ញាណរបស់ព្រះតថាគត (ទី ៣) ជាពលញ្ញាណដែលព្រះតថាគតតែងអាស្រ័យហើយ ទើបដល់នូវថ្នាក់ដ៏ប្រសើរ បន្លឺសីហនាទក្នុងបរិស័ទទាំងឡាយ ញុំាងព្រហ្មចក្រដ៏ប្រសើរឲ្យប្រព្រឹត្តទៅ ។ ម្នាលសារីបុត្ត មួយទៀត តថាគតដឹងច្បាស់នូវលោក[១] ដែលមានធាតុ[២] ច្រើនយ៉ាង មានធាតុ[៣] ផ្សេង ៗ គ្នា តាមសេចក្តីពិត ។ ម្នាលសារីបុត្ត ត្រង់ដែលតថាគត ដឹងច្បាស់នូវលោកដែលមានធាតុច្រើនយ៉ាង មានធាតុផ្សេង ៗ គ្នា តាមសេចក្តីពិត ម្នាលសារីបុត្ត នេះឯងជាតថាគតពលញ្ញាណ (ទី ៤) ជាពលញ្ញាណ ដែលព្រះតថាគតបានដល់នូវថ្នាក់ដ៏ប្រសើរ

---

១ អដ្ឋកថា ថា បានដល់ខន្ធ អាយតនៈ ធាតុ ។ ២ បានដល់ចក្ខុធាតុជាដើមឬកាមធាតុជាដើម ។ ៣ បានដល់លក្ខណៈផ្សេង ៗ របស់ធាតុទាំងនោះ ។

បរិសាសុ សីហនាទំ នទតិ ព្រហ្មចក្កំ បវត្តេតិ ។ បុន ចបរំ សារីបុត្ត តថាគតោ សត្តានំ នានាធិមុត្តិកតំ យថាភូតំ បជានាតិ ។ យម្បិ សារីបុត្ត តថាគតោ សត្តានំ នានាធិមុត្តិកតំ យថាភូតំ បជានាតិ ឥទម្បិ សារីបុត្ត តថាគតស្ស តថាគតពលំ ហោតិ យំ ពលំ អាគម្ម តថាគតោ អាសភណ្ឋានំ បដិជានាតិ បរិសាសុ សីហនាទំ នទតិ ព្រហ្មចក្កំ បវត្តេតិ ។ បុន ចបរំ សារីបុត្ត តថាគតោ បរសត្តានំ បរបុគ្គលានំ ឥន្ទ្រិយបរោបរិយត្តំ យថាភូតំ បជានាតិ ។ យម្បិ សារីបុត្ត តថាគតោ បរសត្តានំ បរបុគ្គលានំ ឥន្ទ្រិយបរោបរិយត្តំ យថាភូតំ បជានាតិ ឥទម្បិ សារីបុត្ត តថាគតស្ស តថាគតពលំ ហោតិ យំ ពលំ អាគម្ម តថាគតោ អាសភណ្ឋានំ បដិជានាតិ បរិសាសុ សីហនាទំ នទតិ ព្រហ្មចក្កំ បវត្តេតិ ។



ទើបបន្លឺសីហនាទក្នុងបរិស័ទទាំងឡាយ ញុំាងព្រហ្មចក្រឲ្យប្រព្រឹត្តទៅ ។ ម្នាលសារីបុត្ត មួយទៀត ព្រះតថាគតដឹងច្បាស់នូវអធ្យាស្រ័យផ្សេង ៗ គ្នា របស់សត្វទាំងឡាយ តាមសេចក្តីពិត ។ ម្នាលសារីបុត្ត ត្រង់ដែលព្រះតថាគតដឹងច្បាស់នូវអធ្យាស្រ័យផ្សេង ៗ គ្នា របស់សត្វទាំងឡាយតាមសេចក្តីពិត ម្នាលសារីបុត្ត នេះឯងជាតថាគតពលញ្ញាណរបស់ព្រះតថាគត ( ទី ៥ ) ជាពលញ្ញាណដែលព្រះតថាគតតែងអាស្រ័យហើយ ទើបបានដល់នូវឋានៈដ៏ប្រសើរ បន្លឺសីហនាទក្នុងបរិស័ទទាំងឡាយ ញុំាងព្រហ្មចក្រឲ្យប្រព្រឹត្តទៅ ។ ម្នាលសារីបុត្ត មួយទៀត តថាគតដឹងច្បាស់នូវឥន្ទ្រិយក្លៀវក្លានិងខ្ទន់ របស់ពួកសត្វដទៃ[១] របស់ពួកបុគ្គលដទៃ[២] តាមសេចក្តីពិត ។ ម្នាលសារីបុត្ត ត្រង់ដែលព្រះតថាគតដឹងច្បាស់ នូវឥន្ទ្រិយក្លៀវក្លានិងខ្ទន់ របស់ពួកសត្វដទៃ ពួកបុគ្គលដទៃ តាមសេចក្តីពិត ម្នាលសារីបុត្ត នេះឯងជាតថាគតពលញ្ញាណរបស់ព្រះតថាគត ( ទី ៦ ) ជាពលញ្ញាណដែលព្រះតថាគតតែងអាស្រ័យហើយ ទើបបានដល់នូវឋានៈដ៏ប្រសើរ បន្លឺសីហនាទក្នុងបរិស័ទទាំងឡាយ ញុំាងព្រហ្មចក្រឲ្យប្រព្រឹត្តទៅ ។

---

១ សំដៅពួកសត្វជាមេ ជាប្រធាន ។ ២ សំដៅពួកសត្វថោកទាប ។

បុន ចបរំ សារីបុត្ត តថាគតោ ឈានវិមោក្ខសមាធិសមាបត្តីនំ សង្កិលេសំ វោទានំ វុដ្ឋានំ យថាភូតំ បជានាតិ ។ យម្បិ សារីបុត្ត តថាគតោ ឈានវិមោក្ខសមាធិសមាបត្តីនំ សង្កិលេសំ វោទានំ វុដ្ឋានំ យថាភូតំ បជានាតិ ឥទម្បិ សារីបុត្ត តថាគតស្ស តថាគតពលំ ហោតិ យំ ពលំ អាគម្ម តថាគតោ អាសភណ្ឋានំ បដិជានាតិ បរិសាសុ សីហនាទំ នទតិ ព្រហ្មចក្កំ បវត្តេតិ ។ បុន ចបរំ សារីបុត្ត តថាគតោ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរតិ សេយ្យថីទំ ឯកម្បិ ជាតឹ ទ្វេបិ ជាតិយោ តិស្សោបិ ជាតិយោ ចតស្សោបិ ជាតិយោ បញ្ចបិ ជាតិយោ ទសបិ ជាតិយោ វីសម្បិ ជាតិយោ តឹសម្បិ ជាតិយោ ចត្តាឡីសម្បិ ជាតិយោ បញ្ញាសម្បិ ជាតិយោ ជាតិសតម្បិ ជាតិសហស្សម្បិ ជាតិសតសហស្សម្បិ អនេកេបិ សំវដ្ដកប្បេ អនេកេបិ វិវដ្ដកប្បេ អនេកេបិ សំវដ្ដវិវដ្ដកប្បេ អមុត្រាសឹ ឯវំនាមោ ឯវំគោត្តោ ឯវំវណ្ណោ ឯវមាហារោ ឯវំសុខទុក្ខប្បដិសំវេទី



ម្នាលសារីបុត្ត មួយទៀត ព្រះតថាគត ដឹងច្បាស់នូវសេចក្តីសៅហ្មង សេចក្តីផូរផង់ និងការចេញនៃឈាន វិមោក្ខ សមាធិ និងសមាបត្តិទាំងឡាយ តាមសេចក្តីពិត ។ ម្នាលសារីបុត្ត ត្រង់ដែលព្រះតថាគត ដឹងច្បាស់នូវសេចក្តីសៅហ្មង សេចក្តីផូរផង់ និងការចេញនៃឈាន វិមោក្ខ សមាធិ និងសមាបត្តិទាំងឡាយ តាមសេចក្តីពិត ម្នាលសារីបុត្ត នេះឯងជាតថាគតពលញ្ញាណ របស់ព្រះតថាគត (ទី៧) ជាពលញ្ញាណដែលព្រះតថាគតតែងអាស្រ័យហើយ ទើបបានដល់នូវថ្នាក់ដ៏ប្រសើរ បន្លឺសីហនាទ ក្នុងបរិស័ទទាំងឡាយ ញុំាងព្រហ្មចក្រឲ្យប្រព្រឹត្តទៅ ។ ម្នាលសារីបុត្ត មួយទៀត ព្រះតថាគតរលឹកជាតិដែលបាននៅអាស្រ័យក្នុងកាលមុនជាអនេកជាតិ គឺរលឹកបាន ១ ជាតិ ២ ជាតិ ៣ ជាតិ ៤ ជាតិ ៥ ជាតិ ១០ ជាតិ ២០ ជាតិ ៣០ ជាតិ ៤០ ជាតិ ៥០ ជាតិ ១០០ ជាតិ ១ ពាន់ជាតិ ១ សែនជាតិក៏បាន រលឹកបានច្រើនសំវដ្តកប្ប ច្រើនវិវដ្តកប្ប ច្រើនសំវដ្តវិវដ្តកប្បក៏បាន ថាក្នុងភពឯណោះ អាត្មាអញមានឈ្មោះយ៉ាងនេះ មានគោត្រយ៉ាងនេះ មានសម្បុរយ៉ាងនេះ មានអាហារយ៉ាងនេះ បានទទួលសុខទុក្ខយ៉ាងនេះ

ឯវមាយុបរិយន្តោ សោ តតោ ចុតោ អមុត្រ ឧទបាទឹ តត្រាបាសឹ ឯវំនាមោ ឯវំគោត្តោ ឯវំវណ្ណោ ឯវមាហារោ ឯវំសុខទុក្ខប្បដិសំវេទី ឯវមាយុបរិយន្តោ សោ តតោ ចុតោ ឥធូបបន្នោតិ ។ ឥតិ សាការំ សឧទ្ទេសំ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរតិ ។ យម្បិ សារីបុត្ត តថាគតោ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរតិ សេយ្យថីទំ ឯកម្បិ ជាតឹ ទ្វេបិ ជាតិយោ ។ បេ ។ ឥតិ សាការំ សឧទ្ទេសំ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរតិ ឥទម្បិ សារីបុត្ត តថាគតស្ស តថាគតពលំ ហោតិ យំ ពលំ អាគម្ម តថាគតោ អាសភណ្ឋានំ បដិជានាតិ បរិសាសុ សីហនាទំ នទតិ ព្រហ្មចក្កំ បវត្តេតិ ។ បុន ចបរំ សារីបុត្ត តថាគតោ ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន សត្តេ បស្សតិ ចវមានេ ឧបបជ្ជមានេ ហីនេ



មានកំណត់អាយុត្រឹមប៉ុណ្ណេះ គ្នាអញច្យុតចាកអត្តភាពនោះហើយ បានទៅកើតក្នុងភពឯណោះ ដែលទៅកើតក្នុងភពឯណោះទៀត គ្នាអញ ក៏មានឈ្មោះយ៉ាងនេះ មានគោត្រយ៉ាងនេះ មានសម្បុរយ៉ាងនេះ មានអាហារយ៉ាងនេះ ទទួលសុខទុក្ខយ៉ាងនេះ មានកំណត់អាយុត្រឹមប៉ុណ្ណេះ លុះគ្នាអញច្យុតចាកអត្តភាពនោះហើយ ទើបមកកើតក្នុងភពនេះឯង ។ ព្រះតថាគតរលឹកជាតិដែលបាននៅអាស្រ័យក្នុងកាលមុនជាអនេកជាតិ ព្រមទាំងអាការ ព្រមទាំងឧទ្ទេសយ៉ាងនេះឯង ។ ម្នាលសារីបុត្ត ត្រង់ដែលព្រះតថាគតរលឹកជាតិ ដែលបាននៅអាស្រ័យក្នុងកាលមុនជាអនេកជាតិ គឺរលឹកបាន ១ ជាតិ ២ ជាតិ ។ បេ ។ រលឹកជាតិដែលបាននៅអាស្រ័យក្នុងកាលមុនជាអនេកជាតិ ព្រមទាំងអាការ ព្រមទាំងឧទ្ទេសយ៉ាងនេះ ម្នាលសារីបុត្ត នេះឯងជាតថាគតពលញ្ញាណរបស់ព្រះតថាគត (ទី៨) ជាពលញ្ញាណដែលព្រះតថាគតតែងអាស្រ័យហើយ ទើបបានដល់នូវឋានៈដ៏ប្រសើរ បន្លឺសីហនាទក្នុងបរិស័ទទាំងឡាយ ញុំាងព្រហ្មចក្រឲ្យប្រព្រឹត្តទៅ ។ ម្នាលសារីបុត្ត មួយទៀត ព្រះតថាគតមានចក្ខុដូចជាទិព្វដ៏បរិសុទ្ធ កន្លងហួសចក្ខុរបស់មនុស្សធម្មតា តែងឃើញនូវសត្វទាំងឡាយ កំពុងច្យុតកំពុងកើត ជាសត្វទាបថោកខ្លះ

បណីតេ សុវណ្ណេ ទុព្វណ្ណេ សុគតេ ទុគ្គតេ យថាកម្មូ-
បគេ សត្តេ បជានាតិ ឥមេ វត ។ បេ ។ បជានាតិ ។
យម្បិ សារីបុត្ត តថាគតោ ទិព្វេន ចក្ខុនា វិសុទ្ធេន
អតិក្កន្តមានុសកេន សត្តេ បស្សតិ ចវមានេ ឧប-
បជ្ជមានេ ហីនេ បណីតេ សុវណ្ណេ ទុព្វណ្ណេ សុគតេ
ទុគ្គតេ យថាកម្មូបគេ សត្តេ បជានាតិ ឥមេ វត ។បេ។
បជានាតិ ឥទម្បិ សារីបុត្ត តថាគតស្ស តថាគតពលំ
ហោតិ យំ ពលំ អាគម្ម តថាគតោ អាសភណ្ឋានំ បដិ-
ជានាតិ បរិសាសុ សីហនាទំ នទតិ ព្រហ្មចក្កំ ប-
វត្តេតិ ។ បុន ចបរំ សារីបុត្ត តថាគតោ អាសវានំ
ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ
សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតិ ។



ខ្ពង់ខ្ពស់ខ្លះ មានសម្បុរល្អខ្លះ មានសម្បុរអាក្រក់ខ្លះ មានគតិល្អខ្លះ
មានគតិអាក្រក់ខ្លះ ដឹងច្បាស់នូវសត្វទាំងឡាយដែលអន្ទោលទៅតាមកម្ម
(របស់ខ្លួន) ថា អើហ្ន៎ សត្វទាំងអម្បាលនេះ ។ បេ ។ រមែងដឹងច្បាស់
(យ៉ាងនេះឯង) ។ ម្នាលសារីបុត្ត ត្រង់ដែលព្រះតថាគតមានចក្ខុដូចជាទិព្វ
ដ៏បរិសុទ្ធកន្លងហួសចក្ខុរបស់មនុស្សធម្មតា តែងឃើញនូវសត្វទាំងឡាយ
ដែលច្យុត ដែលកើត ជាសត្វទាបថោកខ្លះ ខ្ពង់ខ្ពស់ខ្លះ មានសម្បុរល្អខ្លះ
មានសម្បុរអាក្រក់ខ្លះ មានគតិល្អខ្លះ មានគតិអាក្រក់ខ្លះ ដឹងច្បាស់នូវ
សត្វទាំងឡាយដែលអន្ទោលទៅតាមកម្ម (របស់ខ្លួន) ថា អើហ្ន៎ សត្វទាំង
អម្បាលនេះ ។ បេ ។ រមែងដឹងច្បាស់ (យ៉ាងនេះ) ម្នាលសារីបុត្ត នេះឯង
ជាតថាគតពលញ្ញាណរបស់ព្រះតថាគត (ទី៩) ដែលពលញ្ញាណនោះ ព្រះ
តថាគតតែងអាស្រ័យហើយ ទើបប្តេជ្ញានូវឋានៈដ៏ប្រសើរ បន្លឺសីហនាទ
ក្នុងបរិស័ទទាំងឡាយ ញុំាងព្រហ្មចក្រឲ្យប្រព្រឹត្តទៅ ។ ម្នាលសារីបុត្ត
មួយទៀត ព្រះតថាគតធ្វើឲ្យជាក់ច្បាស់នូវចេតោវិមុត្តិ បញ្ញាវិមុត្តិ
មិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ដោយប្រាជ្ញារបស់
ខ្លួនក្នុងបច្ចុប្បន្ន ហើយសម្រេចសម្រាន្តនៅ [illegible] ។ ម្នាល

យម្បិ សារីបុត្ត តថាគតោ អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតិ ឥទម្បិ សារីបុត្ត តថាគតស្ស តថាគតពលំ ហោតិ យំ ពលំ អាគម្ម តថាគតោ អាសភណ្ឋានំ បដិជានាតិ បរិសាសុ សីហនាទំ នទតិ ព្រហ្មចក្កំ បវត្តេតិ ។ ឥមានិ ខោ សារីបុត្ត ទស តថាគតស្ស តថាគតពលានិ យេហិ ពលេហិ សមន្នាគតោ តថាគតោ អាសភណ្ឋានំ បដិជានាតិ បរិសាសុ សីហនាទំ នទតិ ព្រហ្មចក្កំ បវត្តេតិ ។ យោ ខោ មំ សារីបុត្ត ឯវំ ជានន្តំ ឯវំ បស្សន្តំ ឯវំ វទេយ្យ នត្ថិ សមណស្ស គោតមស្ស ឧត្តរិ មនុស្សធម្មា អលមរិយញាណទស្សនវិសេសោ តក្កបរិយាហតំ សមណោ គោតមោ ធម្មំ ទេសេតិ វីមំសានុចរិតំ សយំបដិភានន្តិ តំ សារីបុត្ត វាចំ អប្បហាយ តំ ចិត្តំ អប្បហាយ



សារីបុត្ត ត្រង់ដែលព្រះតថាគតបានធ្វើឲ្យជាក់ច្បាស់ នូវចេតោវិមុត្តិ នូវបញ្ញាវិមុត្តិ មិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ដោយប្រាជ្ញាខ្លួនឯងក្នុងបច្ចុប្បន្ន ហើយសម្រេចសម្រាន្តនៅដោយឥរិយាបថ ៤ ម្នាលសារីបុត្ត នេះឯងជាតថាគតពលញ្ញាណរបស់ព្រះតថាគត (ទី១០) ជាពលញ្ញាណដែលព្រះតថាគតតែងអាស្រ័យហើយ ទើបបានដល់នូវឋានៈដ៏ប្រសើរ បន្លឺសីហនាទក្នុងបរិស័ទទាំងឡាយ ញុំាងព្រហ្មចក្រឲ្យប្រព្រឹត្តទៅ ។ ម្នាលសារីបុត្ត តថាគតពលញ្ញាណទាំង ១០ ប្រការ របស់ព្រះតថាគតនេះឯង ជាពលញ្ញាណដែលតថាគតបានប្រកបហើយ ទើបបានដល់នូវឋានៈដ៏ប្រសើរ បន្លឺសីហនាទក្នុងបរិស័ទទាំងឡាយ ញុំាងព្រហ្មចក្រឲ្យប្រព្រឹត្តទៅ ។ ម្នាលសារីបុត្ត បុគ្គលណាពោលយ៉ាងនេះ ចំពោះតថាគតដែលដឹងយ៉ាងនេះ ដែលឃើញយ៉ាងនេះថា គុណវិសេស គឺញាណទស្សនៈ ជាគុណអាចធ្វើខ្លួនឲ្យជាអរិយៈដ៏ក្រៃលែងជាងមនុស្សធម៌នៃព្រះសមណគោតមមិនមានទេ ព្រះសមណគោតមសំដែងធម៌ដែលខ្លួនស្រាវជ្រាវបានមក ដោយសេចក្តីត្រិះរិះ ដែលខ្លួនស្ទាបស្ទង់ដោយការពិចារណា ជាការឈ្លាសវៃដោយខ្លួនឯងផ្ទាល់ ម្នាលសារីបុត្ត បុគ្គលនោះឯង បើមិនលះបង់វាចានោះទេ មិនលះបង់ចិត្តនោះទេ

តំ ទិដ្ឋឹ អប្បដិនិស្សជ្ជិត្វា យថាភតំ និក្ខិត្តោ ឯវំ និរ-យេ ។ សេយ្យថាបិ សារីបុត្ត ភិក្ខុ សីលសម្បន្នោ សមាធិសម្បន្នោ បញ្ញាសម្បន្នោ ទិដ្ឋេវ ធម្មេ អញ្ញំ អារាធេយ្យ ឯវំ សម្បទមិទំ សារីបុត្ត វទាមិ ។ តំ វាចំ អប្បហាយ តំ ចិត្តំ អប្បហាយ តំ ទិដ្ឋឹ អប្បដិ-និស្សជ្ជិត្វា យថាភតំ និក្ខិត្តោ ឯវំ និរយេ ។

(១៦៣) ចត្តារិមានិ សារីបុត្ត តថាគតស្ស វេសា-រជ្ជានិ យេហិ វេសារជ្ជេហិ សមន្នាគតោ តថាគតោ អាសភណ្ឋានំ បដិជានាតិ បរិសាសុ សីហនាទំ នទតិ ព្រហ្មចក្កំ បវត្តេតិ ។ កតមានិ ចត្តារិ ។



មិនលះបង់ទិដ្ឋិនោះទេ នឹងធ្លាក់ទៅកើតក្នុងនរក ដូចជាគេនាំយកទៅទម្លាក់យ៉ាងនោះឯង ។ ម្នាលសារីបុត្ត ភិក្ខុបរិបូណ៌ដោយសីលហើយ បរិបូណ៌ដោយសមាធិហើយ បរិបូណ៌ដោយបញ្ញាហើយ តែងនឹងសម្រេចនូវអរហត្តផលក្នុងបច្ចុប្បន្ននេះឯង យ៉ាងណាមិញ ម្នាលសារីបុត្ត តថា-គតពោលនូវហេតុ (នៃការមិនលះបង់នូវវាចាជាដើមរបស់បុគ្គលនោះ) ជាឧបមេយ្យប្រៀបគ្នាយ៉ាងនោះដែរ ។ បុគ្គលនោះ បើមិនលះបង់នូវវាចានោះទេ មិនលះបង់នូវចិត្តនោះទេ មិនលះបង់នូវទិដ្ឋិនោះទេ នឹងធ្លាក់ទៅកើតក្នុងនរក ដូចជាគេនាំយកទៅទម្លាក់យ៉ាងនោះឯង ។

(១៦៣) ម្នាលសារីបុត្ត ព្រះតថាគតប្រកបហើយដោយវេសារជ្ជ-ញ្ញាណទាំងឡាយណា រមែងបាននូវឋានដ៏ប្រសើរ បន្លឺសីហនាទក្នុងបរិស័ទទាំងឡាយ ញុំាងព្រហ្មចក្រឲ្យប្រព្រឹត្តទៅ វេសារជ្ជញ្ញាណរបស់ព្រះតថាគតនេះមាន ៤ យ៉ាង ។ វេសារជ្ជញ្ញាណទាំង ៤ ដូចម្តេច ។

សម្មាសម្ពុទ្ធស្ស តេ បដិជានតោ ឥមេ ធម្មា អនភិសម្ពុទ្ធាតិ តត្រ វត មំ សមណោ វា ព្រាហ្មណោ វា ទេវោ វា មារោ វា ព្រហ្មា វា កោចិ វា លោកស្មឹ សហធម្មេន បដិចោទេស្សតីតិ និមិត្តមេតំ សារីបុត្ត ន សមនុបស្សាមិ ឯតមហំ[១] សារីបុត្ត និមិត្តំ អសមនុបស្សន្តោ ខេមប្បត្តោ អភយប្បត្តោ វេសារជ្ជប្បត្តោ វិហរាមិ ។ ខីណាសវស្ស តេ បដិជានតោ ឥមេ អាសវា អបរិក្ខីណាតិ តត្រ វត មំ សមណោ វា ព្រាហ្មណោ វា ទេវោ វា មារោ វា ព្រហ្មា វា កោចិ វា លោកស្មឹ សហធម្មេន បដិចោទេស្សតីតិ និមិត្តមេតំ សារីបុត្ត ន សមនុបស្សាមិ ឯតមហំ សារីបុត្ត និមិត្តំ អសមនុបស្សន្តោ ខេមប្បត្តោ អភយប្បត្តោ

១ ម. ឯតំបហំ ។



ម្នាលសារីបុត្ត ព្រះតថាគតពិចារណាមិនឃើញនូវនិមិត្ត[១] នេះឡើយ ថា សមណៈក្តី ព្រាហ្មណ៍ក្តី ទេវតាក្តី មារក្តី ព្រហ្មក្តី ឬនរណាមួយក្នុងលោកនេះ នឹងចោទតថាគតប្រកបដោយហេតុ ក្នុងធម៌ទាំងឡាយនោះថា ព្រះអង្គគ្រាន់តែប្តេជ្ញាខ្លួនថាជាអ្នកត្រាស់ដឹងដោយប្រពៃ តែធម៌ទាំងនេះ ព្រះអង្គឥតបានត្រាស់ដឹងឡើយ ម្នាលសារីបុត្ត តថាគតកាលពិចារណាមិនឃើញ នូវនិមិត្តនុ៎ះហើយ ក៏ដល់នូវសេចក្តីក្សេមក្សាន្ត មិនដល់នូវភ័យ ដល់នូវភាវៈជាអ្នកក្លៀវក្លា ១ ។ ម្នាលសារីបុត្ត តថាគតពិចារណាមិនឃើញនូវនិមិត្តនេះឡើយថា សមណៈក្តី ព្រាហ្មណ៍ក្តី ទេវតាក្តី មារក្តី ព្រហ្មក្តី ឬនរណាមួយ ក្នុងលោកនេះនឹងចោទតថាគតប្រកបដោយហេតុ ក្នុងធម៌ទាំងឡាយនោះថា ព្រះអង្គគ្រាន់តែប្តេជ្ញាខ្លួនថាជាអ្នកអស់អាសវៈ តែព្រះអង្គមិនទាន់អស់អាសវៈទាំងនេះទេ ម្នាលសារីបុត្ត តថាគតកាលពិចារណាមិនឃើញនូវនិមិត្តនុ៎ះហើយ ក៏បានដល់នូវសេចក្តីក្សេមក្សាន្ត មិនដល់នូវភ័យ ដល់នូវ

១ សំដៅយកបុគ្គលនុ៎ះ ធម៌នុ៎ះ ។ អធិប្បាយថា ព្រះអង្គមិនឃើញបុគ្គលណាមួយដែលហ៊ានចោទព្រះអង្គ ឬមិនឃើញមានធម៌ណាមួយដែលគេលើកឡើងចោទថា ធម៌នេះព្រះអង្គមិនបានត្រាស់ដឹងទេ ។ អដ្ឋកថា តែពាក្យថា និមិត្តនេះ ប្រែថាកំណត់សម្គាល់ ស្រមោល មូលហេតុគ្រឿងសំគាល់ក៏បាន ។

វេសារជ្ជប្បត្តោ វិហរាមិ ។ យេ ខោ បន តេ[១] អន្តរាយិកា ធម្មា វុត្តា តេ បដិសេវតោ នាលំ អន្តរាយាយាតិ តត្រ វត មំ សមណោ វា ព្រាហ្មណោ វា ទេវោ វា មារោ វា ព្រហ្មា វា កោចិ វា លោកស្មឹ សហធម្មេន បដិចោទេស្សតីតិ និមិត្តមេតំ សារីបុត្ត ន សមនុបស្សាមិ ឯតមហំ សារីបុត្ត និមិត្តំ អសមនុបស្សន្តោ ខេមប្បត្តោ អភយប្បត្តោ វេសារជ្ជប្បត្តោ វិហរាមិ ។ យស្ស ខោ បន តេ អត្ថាយ ធម្មោ ទេសិតោ សោ ន និយ្យាតិ តក្ករស្ស សម្មា ទុក្ខក្ខយាយាតិ តត្រ វត មំ សមណោ វា ព្រាហ្មណោ វា ទេវោ វា មារោ វា ព្រហ្មា វា កោចិ វា លោកស្មឹ សហធម្មេន បដិចោទេស្សតីតិ និមិត្តមេតំ សារីបុត្ត ន សមនុបស្សាមិ ឯតមហំ សារីបុត្ត និមិត្តំ អសមនុបស្សន្តោ ខេមប្បត្តោ អភយប្បត្តោ វេសារជ្ជប្បត្តោ វិហរាមិ ។ ឥមានិ ខោ សារីបុត្ត ចត្តារិ តថាគតស្ស វេសារជ្ជានិ យេហិ វេសារជ្ជេហិ

១ ម. បនេតេ ។



ភាវៈជាអ្នកក្លៀវក្លា ១ ។ ម្នាលសារីបុត្ត តថាគតពិចារណាមិនឃើញនូវនិមិត្តនេះឡើយថា សមណៈក្តី ព្រាហ្មណ៍ក្តី ទេវតាក្តី មារក្តី ព្រហ្មក្តី អ្នកណាមួយក្នុងលោកនេះ នឹងចោទតថាគតប្រកបដោយហេតុក្នុងធម៌ទាំងឡាយនោះថា ធម៌ទាំងឡាយណា ដែលព្រះអង្គត្រាស់ថាជាធម៌ធ្វើនូវសេចក្តីអន្តរាយ[១] ឯធម៌ទាំងឡាយនោះ មិនគួរដល់នូវសេចក្តីអន្តរាយចំពោះបុគ្គលណាមួយដែលសេពឡើយ ម្នាលសារីបុត្ត តថាគតកាលពិចារណាមិនឃើញនូវនិមិត្តនុ៎ះ ក៏បានដល់នូវសេចក្តីក្សេមក្សាន្ត មិនដល់នូវភ័យ ដល់នូវភាវៈជាអ្នកក្លៀវក្លា ១ ។ ម្នាលសារីបុត្ត តថាគតពិចារណាមិនឃើញនូវនិមិត្តនេះឡើយថា សមណៈក្តី ព្រាហ្មណ៍ក្តី ទេវតាក្តី មារក្តី ព្រហ្មក្តី អ្នកណាមួយក្នុងលោកនេះ នឹងចោទតថាគតប្រកបដោយហេតុ ក្នុងនិយ្យានិកធម៌នោះថា ធម៌ដែលព្រះអង្គសំដែងហើយ ដើម្បីប្រយោជន៍ដល់គុណវិសេសណា គុណវិសេសនោះមិនប្រព្រឹត្តទៅដើម្បីអស់ទៅនៃទុក្ខដោយប្រពៃ ដល់បុគ្គលអ្នកធ្វើតាមធម៌នោះទេ ម្នាលសារីបុត្ត តថាគតកាលពិចារណាមិនឃើញនូវនិមិត្តនុ៎ះ ក៏បានដល់នូវសេចក្តីក្សេមក្សាន្ត មិនដល់នូវភ័យ ដល់នូវភាវៈជាអ្នកក្លៀវក្លា ១ ។ ម្នាលសារីបុត្ត តថាគតប្រកបដោយវេសារជ្ជញ្ញាណ

១ សំដៅយកមេថុនធម្ម ព្រោះជា កាលបើបុគ្គល សេពមេថុនធម្មនឹងដល់នូវសេចក្តីអន្តរាយមគ្គផល ។ អដ្ឋកថា ។

សមន្នាគតោ តថាគតោ អាសភណ្ឋានំ បដិជានាតិ
បរិសាសុ សីហនាទំ នទតិ ព្រហ្មចក្កំ បវត្តេតិ ។
យោ ខោ មំ សារីបុត្ត ឯវំ ជានន្តំ ឯវំ បស្សន្តំ
ឯវំ វទេយ្យ នត្ថិ សមណស្ស គោតមស្ស ឧត្តរិ
មនុស្សធម្មា អលមរិយញ្ញាណទស្សនវិសេសោ តក្ក-
បរិយាហតំ សមណោ គោតមោ ធម្មំ ទេសេតិ
វីមំសានុចរិតំ សយំបដិភានន្តិ តំ សារីបុត្ត វាចំ
អប្បហាយ តំ ចិត្តំ អប្បហាយ តំ ទិដ្ឋឹ អប្បដិ-
និស្សជ្ជិត្វា យថាភតំ និក្ខិត្តោ ឯវំ និរយេ ។
សេយ្យថាបិ សារីបុត្ត ភិក្ខុ សីលសម្បន្នោ សមាធិ-
សម្បន្នោ បញ្ញាសម្បន្នោ ទិដ្ឋេវ ធម្មេ អញ្ញំ
អារាធេយ្យ ឯវំ សម្បទមិទំ សារីបុត្ត វទាមិ ។
តំ វាចំ អប្បហាយ តំ ចិត្តំ អប្បហាយ តំ ទិដ្ឋឹ
អប្បដិនិស្សជ្ជិត្វា យថាភតំ និក្ខិត្តោ ឯវំ និរយេ ។



តាំងខ្លួនណាហើយ បានដល់នូវថ្នាក់ដ៏ប្រសើរ បន្លឺសីហនាទក្នុង
បរិសទ្យទាំងឡាយ ញុំាងព្រហ្មចក្រឲ្យប្រព្រឹត្តទៅ វិសេសញ្ញាណ
របស់ព្រះតថាគតមាន ៤ នេះឯង ។ ម្នាលសារីបុត្ត បុគ្គលណា
ពោលយ៉ាងនេះចំពោះតថាគតដែលដឹងយ៉ាងនេះ ដែលឃើញយ៉ាងនេះ
ថា គុណវិសេសគឺញាណទស្សនៈ ជាគុណគួរធ្វើខ្លួនឲ្យជាអរិយៈ
ដ៏ក្រៃលែងជាងមនុស្សធម៌នៃព្រះសមណគោតមមិនមាន ព្រះសមណ-
គោតមសំដែងធម៌ដែលខ្លួនស្រាវជ្រាវបានមកដោយសេចក្តីត្រិះរិះ ដែល
ខ្លួនស្ទាបស្ទង់ដោយការពិចារណា ជាសេចក្តីឈ្លាសវៃដោយខ្លួនឯងប៉ុណ្ណោះ
ម្នាលសារីបុត្ត បុគ្គលនោះបើមិនលះបង់នូវវាចានោះទេ មិនលះបង់នូវចិត្ត
នោះទេ មិនលះបង់នូវទិដ្ឋិនោះទេ មុខជាធ្លាក់ទៅក្នុងនរក ដូចគេនាំ
យកទៅទំលាក់យ៉ាងនោះដែរ ។ ម្នាលសារីបុត្ត ភិក្ខុបរិបូណ៌ដោយ
សីលហើយ *បរិបូណ៌ដោយសមាធិហើយ បរិបូណ៌ដោយបញ្ញាហើយ
រមែងសម្រេចនូវអរហត្តផលក្នុងបច្ចុប្បន្ននេះឯង យ៉ាងណាមិញ ម្នាល
សារីបុត្ត តថាគតពោលនូវហេតុនេះ ជាគ្រឿងផ្តល់នូវពាក្យឧបមេយ្យ
ក៏យ៉ាងនោះដែរ ។ បុគ្គលនោះ បើមិនលះបង់នូវវាចានោះទេ មិនលះ
បង់នូវចិត្តនោះទេ មិនលះបង់នូវទិដ្ឋិនោះទេ មុខជាធ្លាក់ទៅក្នុងនរក
ដូចជាគេនាំយកទៅទំលាក់ យ៉ាងនោះដែរ ។

(១៦៨) អដ្ឋ ខោ ឥមា សារីបុត្ត បរិសា កតមា អដ្ឋ ខត្តិយបរិសា ព្រាហ្មណបរិសា គហបតិបរិសា សមណបរិសា ចាតុម្មហារាជិកបរិសា តាវតឹសបរិសា មារបរិសា ព្រហ្មបរិសា ឥមា ខោ សារីបុត្ត អដ្ឋ បរិសា ។ ឥមេហិ ខោ សារីបុត្ត ចតូហិ វេសារជ្ជេហិ សមន្នាគតោ តថាគតោ ឥមា អដ្ឋ បរិសា ឧបសង្កមតិ អជ្ឈោគាហតិ ។ អភិជានាមិ ខោ បនាហំ សារីបុត្ត អនេកសតំ ខត្តិយបរិសំ ឧបសង្កមិតា តត្រាបិ មយា សន្និសិន្នបុព្វញ្ចេវ សល្លបិតបុព្វញ្ច សាកច្ឆា ច សមាបជ្ជិតបុព្វា តត្រ វត មំ ភយំ វា សារជ្ជំ វា ឱក្កមិស្សតីតិ និមិត្តមេតំ សារីបុត្ត ន សមនុបស្សាមិ ឯតមហំ សារីបុត្ត និមិត្តំ អសមនុបស្សន្តោ ។ បេ ។ វិហរាមិ ។ អភិជានាមិ ខោ បនាហំ សារីបុត្ត អនេកសតំ ព្រាហ្មណបរិសំ គហបតិបរិសំ សមណបរិសំ ចាតុម្មហារាជិកបរិសំ តាវតឹសបរិសំ មារបរិសំ ព្រហ្មបរិសំ ឧបសង្កមិតា តត្រាបិ មយា សន្និសិន្នបុព្វញ្ចេវ សល្លបិតបុព្វញ្ច សាកច្ឆា ច



(១៦៨) ម្នាលសារីបុត្ត បរិស័ទនេះមាន ៨ ពួក បរិស័ទទាំង ៨ ពួកតើដូចម្តេច គឺខត្តិយបរិស័ទ ១ ព្រាហ្មណបរិស័ទ ១ គហបតិបរិស័ទ ១ សមណបរិស័ទ ១ ចាតុម្មហារាជិកបរិស័ទ ១ តាវត្តឹសបរិស័ទ ១ មារបរិស័ទ ១ ព្រហ្មបរិស័ទ ១ ម្នាលសារីបុត្ត បរិស័ទមាន ៨ ពួកនេះឯង ។ ម្នាលសារីបុត្ត ព្រះតថាគតប្រកបព្រមដោយវេសារជ្ជញ្ញាណ ៤ យ៉ាងនេះឯង តែងចូលទៅរក តែងចូលទៅជិតនូវពួកបរិស័ទទាំង ៨ នេះ ។ ម្នាលសារីបុត្ត តថាគតធ្លាប់ចូលទៅរកខត្តិយបរិស័ទជាច្រើនរយនាក់ តថាគតធ្លាប់អង្គុយប្រជុំផង ធ្លាប់ចរចាផង ធ្លាប់ដល់ប្រមូលសាកច្ឆាផង ក្នុងពួកខត្តិយបរិស័ទទាំងនោះ ម្នាលសារីបុត្ត តថាគតពិចារណាមិនឃើញនូវនិមិត្តនេះថា ភ័យឬសេចក្តីតក់ស្លុតនឹងគ្របសង្កត់តថាគតក្នុងពួកខត្តិយបរិស័ទនោះដូច្នេះឡើយ ម្នាលសារីបុត្ត តថាគតកាលពិចារណាមិនឃើញនូវនិមិត្តនុ៎ះ ។ បេ ។ ម្នាលសារីបុត្ត តថាគតធ្លាប់ចូលទៅរកព្រាហ្មណបរិស័ទ គហបតិបរិស័ទ សមណបរិស័ទ ចាតុម្មហារាជិកបរិស័ទ តាវត្តឹសបរិស័ទ មារបរិស័ទ នឹងព្រហ្មបរិស័ទ ជាច្រើនរយនាក់ តថាគតធ្លាប់អង្គុយប្រជុំផង ធ្លាប់ចរចាផង ធ្លាប់ដល់ប្រមូលសាកច្ឆាផង ក្នុងពួកបរិស័ទទាំងនោះ ម្នាលសារីបុត្ត តថាគត

សមាបជ្ជិតបុព្វា តត្រ វត មំ ភយំ វា សារជ្ជំ វា ឱក្កមិស្សតីតិ និមិត្តមេតំ សារីបុត្ត ន សមនុបស្សាមិ ឯតមហំ សារីបុត្ត និមិត្តំ អសមនុបស្សន្តោ ខេមប្បត្តោ ។ បេ ។ វិហរាមិ ។ យោ ខោ មំ សារីបុត្ត ឯវំ ជានន្តំ ឯវំ បស្សន្តំ ឯវំ វទេយ្យ នត្ថិ សមណស្ស គោតមស្ស ឧត្តរិ មនុស្សធម្មា អលមរិយញាណទស្សនវិសេសោ តក្កបរិយាហតំ សមណោ គោតមោ ធម្មំ ទេសេតិ វីមំសានុចរិតំ សយំ បដិភានន្តិ តំ សារីបុត្ត វាចំ អប្បហាយ តំ ចិត្តំ អប្បហាយ តំ ទិដ្ឋឹ អប្បដិនិស្សជ្ជិត្វា យថាភតំ និក្ខិត្តោ ឯវំ និរយេ ។ សេយ្យថាបិ សារីបុត្ត ភិក្ខុ សីលសម្បន្នោ សមាធិសម្បន្នោ បញ្ញាសម្បន្នោ ទិដ្ឋេវ ធម្មេ អញ្ញំ អារាធេយ្យ ឯវំ សម្បទមិទំ សារីបុត្ត វទាមិ ។ តំ វាចំ អប្បហាយ តំ ចិត្តំ អប្បហាយ តំ ទិដ្ឋឹ អប្បដិនិស្សជ្ជិត្វា យថាភតំ និក្ខិត្តោ ឯវំ និរយេ ។



ពិចារណាមិនឃើញនូវនិមិត្តនុ៎ះថា ភ័យឬសេចក្តីកក់ស្លុត នឹងគ្របសង្កត់តថាគតក្នុងពួកបរិស័ទនោះដូច្នេះឡើយ ម្នាលសារីបុត្ត តថាគត កាលពិចារណាមិនឃើញនូវនិមិត្តនុ៎ះ ក៏បានដល់នូវសេចក្តីក្សេមក្សាន្ត ។ បេ ។ ម្នាលសារីបុត្ត បុគ្គលណាពោលយ៉ាងនេះ ចំពោះតថាគត ដែលដឹងយ៉ាងនេះ ដែលឃើញយ៉ាងនេះថា គុណវិសេសគឺញាណទស្សនៈដែលអាចធ្វើខ្លួនឲ្យជាអរិយៈដ៏ក្រៃលែងជាងមនុស្សធម៌ នៃព្រះសមណគោតមមិនមានទេ ព្រះសមណគោតមសំដែងធម៌ដែលខ្លួនស្រាវជ្រាវបានមកដោយសេចក្តីត្រិះរិះ ដែលខ្លួនស្ទាបស្ទង់ដោយការពិចារណា ជាការឈ្លាសវៃដោយខ្លួនឯងដូច្នេះ ម្នាលសារីបុត្ត បុគ្គលនោះ បើមិនលះបង់វាចានោះទេ មិនលះបង់ចិត្តនោះទេ មិនលះបង់ទិដ្ឋិនោះទេ នឹងធ្លាក់ទៅកើតក្នុងនរក ដូចជាគេនាំយកទៅទំលាក់យ៉ាងនោះឯង ។ ម្នាលសារីបុត្ត ភិក្ខុបរិបូណ៌ដោយសីលហើយ បរិបូណ៌ដោយសមាធិហើយ បរិបូណ៌ដោយបញ្ញាហើយ រមែងសម្រេចនូវអរហត្តផលក្នុងបច្ចុប្បន្ននេះបាន យ៉ាងណាមិញ ម្នាលសារីបុត្ត តថាគតពោលនូវហេតុនេះជាគ្រឿងដល់នូវពាក្យឧបមេយ្យ ក៏យ៉ាងនោះដែរ ។ បុគ្គលនោះបើមិនលះបង់នូវវាចានោះទេ មិនលះបង់នូវចិត្តនោះទេ មិនលះបង់នូវទិដ្ឋិនោះចេញទេ នឹងធ្លាក់ទៅកើតក្នុងនរក ដូចជាគេនាំយកទៅទំលាក់យ៉ាងនោះឯង ។

(១៦៩) ចតស្សោ ខោ ឥមា សារីបុត្ត យោនិយោ ។ កតមា ចតស្សោ អណ្ឌជា យោនិ ជលាពុជា យោនិ សំសេទជា យោនិ ឱបបាតិកា យោនិ ។ កតមា ច សារីបុត្ត អណ្ឌជា យោនិ យេ ខោ តេ សារីបុត្ត សត្តា អណ្ឌកោសំ អភិនិព្ភិជ្ជ ជាយន្តិ អយំ វុច្ចតិ សារីបុត្ត អណ្ឌជា យោនិ ។ កតមា ច សារីបុត្ត ជលាពុជា យោនិ យេ ខោ តេ សារីបុត្ត សត្តា វត្ថិកោសំ អភិនិព្ភិជ្ជ ជាយន្តិ អយំ វុច្ចតិ សារីបុត្ត ជលាពុជា យោនិ ។ កតមា ច សារីបុត្ត សំសេទជា យោនិ យេ ខោ តេ សារីបុត្ត សត្តា បូតិមច្ឆេ វា ជាយន្តិ បូតិកុណបេ វា បូតិកុម្មាសេ វា ចន្ទនិកាយ វា ឱឡិគល្លេ វា ជាយន្តិ អយំ វុច្ចតិ សារីបុត្ត សំសេទជា យោនិ ។ កតមា ច សារីបុត្ត ឱបបាតិកា យោនិ ទេវា នេរយិកា ឯកច្ចេ ច មនុស្សា ឯកច្ចេ ច វិនិបាតិកា អយំ វុច្ចតិ សារីបុត្ត ឱបបាតិកា យោនិ ។ ឥមា ខោ សារីបុត្ត ចតស្សោ យោនិយោ ។



(១៦៩) ម្នាលសារីបុត្ត កំណើត (របស់សត្វ) នេះមាន ៤ កំណើតទាំង ៤ តើដូចម្តេច គឺកំណើតដែលកើតអំពីស៊ុត ១ កំណើតដែលកើតអំពីទឹក ១ កំណើតដែលកើតអំពីញើស ១ កំណើតហាក់ដូចជាអណ្តែតទៅកើត ១ ។ ម្នាលសារីបុត្ត ចុះកំណើតដែលកើតអំពីស៊ុតនោះដូចម្តេច ម្នាលសារីបុត្ត សត្វទាំងឡាយដែលទំលាយនូវសំបកស៊ុតហើយកើតចេញមក ម្នាលសារីបុត្ត នេះតថាគតហៅថា កំណើតដែលកើតអំពីស៊ុត ។ ម្នាលសារីបុត្ត ចុះកំណើតដែលកើតអំពីទឹកតើដូចម្តេច ម្នាលសារីបុត្ត សត្វទាំងឡាយដែលទំលាយនូវស្រោមទឹកភ្លោះហើយកើត ម្នាលសារីបុត្ត នេះតថាគតហៅថា កំណើតដែលកើតអំពីទឹក ។ ម្នាលសារីបុត្ត កំណើតដែលកើតអំពីញើសតើដូចម្តេច ម្នាលសារីបុត្ត សត្វទាំងឡាយដែលកើតក្នុងត្រីស្អុយក្តី ក្នុងសាកសពស្អុយក្តី ក្នុងនំបូមក្តី ក្នុងរណ្តៅជ្រាំក្តី ក្នុងប្រឡាយទឹកស្អុយក្តី ម្នាលសារីបុត្ត នេះតថាគតហៅថា កំណើតដែលកើតអំពីញើសក្អែល ។ ម្នាលសារីបុត្ត ចុះកំណើតហាក់ដូចជាអណ្តែតទៅកើត តើដូចម្តេច ពួកទេវតា ពួកសត្វនរក មនុស្សពួកខ្លះ និងវិនិបាតពួកខ្លះ ម្នាលសារីបុត្ត នេះតថាគតហៅថា កំណើតហាក់ដូចជាអណ្តែតទៅកើត ។ ម្នាលសារីបុត្ត កំណើត (របស់សត្វ) មាន ៤ នេះ

យោ ខោ មំ សារីបុត្ត ឯវំ ជានន្តំ ឯវំ បស្សន្តំ ឯវំ វទេយ្យ នត្ថិ សមណស្ស គោតមស្ស ឧត្តរិ មនុស្សធម្មា អលមរិយញ្ញាណទស្សនវិសេសោ តក្កបរិយាហតំ ស–មណោ គោតមោ ធម្មំ ទេសេតិ វីមំសានុចរិតំ សយំ–បដិភានន្តិ តំ សារីបុត្ត វាចំ អប្បហាយ តំ ចិត្តំ អប្បហាយ តំ ទិដ្ឋឹ អប្បដិនិស្សជ្ជិត្វា យថាភតំ និក្ខិត្តោ ឯវំ និរយេ ។ សេយ្យថាបិ សារីបុត្ត ភិក្ខុ សីលសម្បន្នោ សមាធិសម្បន្នោ បញ្ញាសម្បន្នោ ទិដ្ឋេវ ធម្មេ អញ្ញំ អារាធេយ្យ ឯវំ សម្បទមិទំ សារីបុត្ត វទាមិ ។ តំ វាចំ អប្បហាយ តំ ចិត្តំ អប្បហាយ តំ ទិដ្ឋឹ អប្បដិនិស្សជ្ជិត្វា យថាភតំ និក្ខិត្តោ ឯវំ និរយេ ។

(១៧០) បញ្ច ខោ ឥមា សារីបុត្ត គតិយោ កតមា បញ្ច និរយោ តិរច្ឆានយោនិ បិត្តិវិសយោ មនុស្សា ទេវា ។ និរយញ្ចាហំ សារីបុត្ត បជានាមិ



ឯង ។ ម្នាលសារីបុត្ត បុគ្គលណាពោលយ៉ាងនេះ ចំពោះតថាគត ដែលដឹងយ៉ាងនេះ ដែលឃើញយ៉ាងនេះថា គុណវិសេសគឺញាណ–ទស្សនៈ ដែលគួរធ្វើខ្លួនឲ្យជាអរិយៈដ៏ក្រៃលែងជាងធម៌មនុស្សរបស់ព្រះសមណគោតមមិនមានទេ ព្រះសមណគោតមសំដែងធម៌ដែលខ្លួនស្រាវជ្រាវបានមកដោយសេចក្តីត្រិះរិះ ដែលខ្លួនស្ទាបស្ទង់ដោយការពិចារណា ជាការឈ្លាសវៃដោយខ្លួនឯងដូច្នេះ ម្នាលសារីបុត្ត បុគ្គលនោះបើមិនលះបង់នូវវាចានោះទេ មិនលះបង់នូវចិត្តនោះទេ មិនលះបង់នូវទិដ្ឋិនោះចេញទេ នឹងធ្លាក់ទៅក្នុងនរកដូចជាគេនាំយកទៅទំលាក់យ៉ាងនោះឯង ។ ម្នាលសារីបុត្ត ភិក្ខុបរិបូណ៌ដោយសីលហើយ បរិបូណ៌ដោយសមាធិហើយ បរិបូណ៌ដោយបញ្ញាហើយ គប្បីសម្រេចនូវអរហត្តផលក្នុងបច្ចុប្បន្ននេះឯង យ៉ាងណាមិញ តថាគតពោលនូវហេតុនេះជាគ្រឿងផ្ទឹមពាក្យឧបមេយ្យ គឺយ៉ាងនោះដែរ ។ បុគ្គលនោះ បើមិនលះបង់នូវវាចានោះទេ មិនលះបង់នូវចិត្តនោះទេ មិនលះបង់នូវទិដ្ឋិនោះចេញទេ នឹងធ្លាក់ទៅក្នុងនរកដូចជាគេនាំយកទៅទំលាក់យ៉ាងនោះឯង ។

(១៧០) ម្នាលសារីបុត្ត គតិនេះមាន ៥ ប្រការ គតិ ៥ ប្រការតើដូចម្តេច គឺ នរក ១ កំណើតតិរច្ឆាន ១ បិត្តិវិស័យ ១ ពួកមនុស្ស ១ ពួកទេវតា ១ ។ ម្នាលសារីបុត្ត តថាគតស្គាល់នរកផង ស្គាល់ផ្លូវជាទីទៅ

និរយគាមិញ្ច មគ្គំ និរយគាមិនិញ្ច បដិបទំ យថា បដិបន្នោ ច កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជតិ តញ្ច បជានាមិ ។ តិរច្ឆានយោនិញ្ចាហំ សារីបុត្ត បជានាមិ តិរច្ឆានយោនិគាមិញ្ច មគ្គំ តិរច្ឆានយោនិគាមិនិញ្ច បដិបទំ យថា បដិបន្នោ ច កាយស្ស ភេទា បរម្មរណា តិរច្ឆានយោនឹ ឧបបជ្ជតិ តញ្ច បជានាមិ ។ បិត្តិវិសយញ្ចាហំ សារីបុត្ត បជានាមិ បិត្តិវិសយគាមិញ្ច មគ្គំ បិត្តិវិសយគាមិនិញ្ច បដិបទំ យថា បដិបន្នោ ច កាយស្ស ភេទា បរម្មរណា បិត្តិវិសយំ ឧបបជ្ជតិ តញ្ច បជានាមិ ។ មនុស្សេ ចាហំ សារីបុត្ត បជានាមិ មនុស្សលោកគាមិញ្ច មគ្គំ មនុស្សលោកគាមិនិញ្ច បដិបទំ យថា បដិបន្នោ ច កាយស្ស ភេទា បរម្មរណា មនុស្សេសុ ឧបបជ្ជតិ



កាន់នរកផង ស្គាល់សេចក្ដីប្រតិបត្តិជាទីទៅកាន់នរកផង ឯបុគ្គលប្រតិបត្តិយ៉ាងណាហើយ លុះបែកធ្លាយរាងកាយខាងមុខ រមែងទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក តថាគតស្គាល់ច្បាស់នូវប្រតិបត្តិនោះផង ។ ម្នាលសារីបុត្ត តថាគតស្គាល់ច្បាស់នូវកំណើតតិរច្ឆានផង ស្គាល់ច្បាស់នូវផ្លូវជាទីទៅកាន់កំណើតតិរច្ឆានផង ស្គាល់ច្បាស់នូវសេចក្ដីប្រតិបត្តិជាទីទៅកាន់កំណើតតិរច្ឆានផង ឯបុគ្គលប្រតិបត្តិយ៉ាងណាហើយ លុះបែកធ្លាយរាងកាយខាងមុខអំពីមរណៈទៅកើតក្នុងកំណើតតិរច្ឆាន តថាគតស្គាល់ច្បាស់នូវសេចក្ដីប្រតិបត្តិនោះផង ។ ម្នាលសារីបុត្ត តថាគតស្គាល់ច្បាស់នូវបិត្តិវិស័យផង ស្គាល់ច្បាស់នូវផ្លូវជាទីទៅកាន់បិត្តិវិស័យផង ស្គាល់ច្បាស់នូវសេចក្ដីប្រតិបត្តិជាទីទៅកាន់បិត្តិវិស័យផង ឯបុគ្គលប្រតិបត្តិយ៉ាងណាហើយ លុះបែកធ្លាយរាងកាយខាងមុខអំពីមរណៈទៅកើតក្នុងបិត្តិវិស័យ តថាគតក៏ស្គាល់ច្បាស់នូវសេចក្ដីប្រតិបត្តិនោះផង ។ ម្នាលសារីបុត្ត តថាគតស្គាល់ច្បាស់នូវមនុស្សទាំងឡាយផង ស្គាល់ច្បាស់នូវផ្លូវជាទីទៅកាន់មនុស្សលោកផង ស្គាល់ច្បាស់នូវសេចក្ដីប្រតិបត្តិជាទីទៅកាន់មនុស្សលោកផង ឯបុគ្គលប្រតិបត្តិយ៉ាងណា លុះបែកធ្លាយរាងកាយខាងមុខអំពីមរណៈទៅកើតក្នុងមនុស្សលោក

តញ្ច បជានាមិ ។ ទេវេ ចាហំ សារីបុត្ត បជានាមិ ទេវលោកគាមិញ្ច មគ្គំ ទេវលោកគាមិនិញ្ច បដិបទំ យថា បដិបន្នោ ច កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជតិ តញ្ច បជានាមិ ។ និព្វានញ្ចាហំ សារីបុត្ត បជានាមិ និព្វានគាមិញ្ច មគ្គំ និព្វានគាមិនិញ្ច បដិបទំ យថា បដិបន្នោ ច អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតិ តញ្ច បជានាមិ ។

(១៨១) ឥធាហំ សារីបុត្ត ឯកច្ចំ បុគ្គលំ ឯវំ ចេតសា ចេតោ បរិច្ច ជានាមិ[១] តថាយំ បុគ្គលោ បដិបន្នោ តថា ច ឥរិយតិ តញ្ច មគ្គំ សមារុឡ្ហោ យថា កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ

១ ម. បជានាមិ ។



តថាគតស្គាល់ច្បាស់នូវសេចក្តីប្រតិបត្តិនោះ ។ ម្នាលសារីបុត្ត តថាគតស្គាល់ច្បាស់នូវទេវតាទាំងឡាយផង ស្គាល់ច្បាស់នូវផ្លូវជាទីទៅកាន់ទេវលោកផង ស្គាល់ច្បាស់នូវសេចក្តីប្រតិបត្តិជាទីទៅកាន់ទេវលោកផង ឯបុគ្គលប្រតិបត្តិយ៉ាងណា លុះបែកធ្លាយរាងកាយ ខាងមុខអំពីមរណៈទៅកើតក្នុងសុគតិ សួគ៌ ទេវលោក តថាគតស្គាល់ច្បាស់នូវសេចក្តីប្រតិបត្តិនោះផង ។ ម្នាលសារីបុត្ត តថាគតស្គាល់ច្បាស់នូវព្រះនិព្វានផង ស្គាល់ច្បាស់នូវផ្លូវជាទីទៅកាន់ព្រះនិព្វានផង ស្គាល់ច្បាស់នូវសេចក្តីប្រតិបត្តិជាទីទៅកាន់ព្រះនិព្វានផង ឯបុគ្គលប្រតិបត្តិយ៉ាងណាហើយ ធ្វើឲ្យជាក់ច្បាស់នូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ មិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ដោយប្រាជ្ញាដ៏ឧត្តមរបស់ខ្លួនក្នុងបច្ចុប្បន្ន ហើយសម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ តថាគតក៏ស្គាល់ច្បាស់នូវសេចក្តីប្រតិបត្តិនោះផង ។

(១៨១) ម្នាលសារីបុត្ត តថាគតកំណត់នូវចិត្តដោយចិត្ត ដឹងនូវបុគ្គលពួកមួយក្នុងលោកនេះយ៉ាងនេះថា បុគ្គលនេះប្រតិបត្តិដូច្នោះផង ប្រព្រឹត្តដូច្នោះផង ឡើងកាន់ផ្លូវ[១] នោះផង លុះបែកធ្លាយរាងកាយខាងមុខអំពីមរណៈ មុខជានឹងទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក មិនខាន

១ អដ្ឋកថា ថា អំពើ ឬសេចក្តីប្រព្រឹត្តិ ដែលជានាំឲ្យសត្វទៅកើតក្នុងភពថ្មីទៀត ហៅថា ផ្លូវ ក្នុងទីនេះ ។

និរយំ ឧបបជ្ជិស្សតីតិ តមេនំ បស្សាមិ អបរេន សមយេន ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបន្នំ ឯកន្តទុក្ខា តិប្បា[១] កដុកា វេទនា វេទិយមានំ ។ សេយ្យថាបិ សារីបុត្ត អង្គារកាសុ សាធិកបោរិសា បុណ្ណា អង្គារានំ វីតច្ចិកានំ វីតធូមានំ អថ បុរិសោ អាគច្ឆេយ្យ ឃម្មាភិតត្តោ ឃម្មបរេតោ កិលន្តោ តសិតោ បិបាសិតោ ឯកាយនេន មគ្គេន តមេវ អង្គារកាសុំ បណិធាយ តមេនំ ចក្ខុមា បុរិសោ ទិស្វា ឯវំ វទេយ្យ តថាយំ ភវំ បុរិសោ បដិបន្នោ តថា ច ឥរិយតិ តញ្ច មគ្គំ សមារុឡ្ហោ យថា ឥមំយេវ អង្គារកាសុំ អាគមិស្សតីតិ តមេនំ បស្សេយ្យ អបរេន សមយេន តស្សា អង្គារកាសុយា បតិតំ ឯកន្តទុក្ខា តិប្បា កដុកា វេទនា វេទិយមានំ ។ ឯវមេវ ខោ អហំ សារីបុត្ត ឥធេកច្ចំ បុគ្គលំ ឯវំ ចេតសា ចេតោ បរិច្ច បជានាមិ តថាយំ បុគ្គលោ បដិបន្នោ តថា ច ឥរិយតិ តញ្ច មគ្គំ សមារុឡ្ហោ

១ ម. តិព្វា ។



លុះសម័យខាងក្រោយមក តថាគតឃើញបុគ្គលនោះឯង បែកធ្លាយរាងកាយខាងមុខអំពីមរណៈ ក៏ទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក សោយទុក្ខវេទនាដ៏ក្លៀវក្លា ខ្លោចផ្សាឥតស្រាក ដោយចក្ខុជាទិព្វដ៏បរិសុទ្ធ កន្លងហួសចក្ខុរបស់មនុស្សធម្មតា ។ ម្នាលសារីបុត្ត រណ្តៅរងើកភ្លើងមានជម្រៅជាងមួយជួរបុរស[១] ពេញដោយរងើកភ្លើងដែលឥតមានអណ្តាតឥតមានផ្សែង គ្រានោះ មានបុរសម្នាក់ក្តៅក្រហល់ក្រហាយដោយកំដៅថ្ងៃ មានកំដៅថ្ងៃគ្របសង្កត់ មានខ្លួនលំបាក ស្ងួតស្រេកទឹក ដើរមកតាមផ្លូវដែលទៅបានតែម្នាក់ សំដៅទៅត្រង់រងើកភ្លើងនោះឯង បុរសអ្នកមានភ្នែកបានឃើញបុរសនោះហើយ ក៏និយាយយ៉ាងនេះថា បុរសដ៏ចំរើននេះ ដើរទៅផ្លូវយ៉ាងនោះផង ប្រព្រឹត្តយ៉ាងនោះផង ឡើងកាន់ផ្លូវនោះផង មុខជានឹងមកកាន់រណ្តៅរងើកភ្លើងនេះពុំខាន លុះសម័យខាងក្រោយមក (បុរសមានភ្នែកនោះ) ក៏ឃើញនូវបុរសនោះឯងធ្លាក់ទៅក្នុងរណ្តៅរងើកភ្លើងនោះ សោយទុក្ខវេទនាដ៏ក្លៀវក្លា ខ្លោចផ្សាឥតស្រាក សេចក្តីនេះមានឧបមាយ៉ាងណាមិញ ម្នាលសារីបុត្ត មានឧបមេយ្យដូចតថាគតដែលកំណត់នូវចិត្តដោយចិត្ត ដឹងនូវបុគ្គលពួកមួយក្នុងលោកនេះ យ៉ាងនេះថា បុគ្គលនេះប្រតិបត្តិយ៉ាងនោះផង ប្រព្រឹត្តយ៉ាងនោះផង ឡើងកាន់ផ្លូវនោះផង

១ ជាង ៥ ហត្ថនៃបុរស (ជាង ១ ខ្លួនបុរស) ។

យថា កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជិស្សតីតិ តមេនំ បស្សាមិ អបរេន សមយេន ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបន្នំ ឯកន្តទុក្ខា តិព្វា កដុកា វេទនា វេទិយមានំ ។

(១៧៤) ឥធ បនាហំ សារីបុត្ត ឯកច្ចំ បុគ្គលំ ឯវំ ចេតសា ចេតោ បរិច្ច បជានាមិ តថាយំ បុគ្គលោ បដិបន្នោ តថា ច ឥរិយតិ តញ្ច មគ្គំ សមារុឡ្ហោ យថា កាយស្ស ភេទា បរម្មរណា តិរច្ឆានយោនឹ ឧបបជ្ជិស្សតីតិ តមេនំ បស្សាមិ អបរេន សមយេន ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន កាយស្ស ភេទា បរម្មរណា តិរច្ឆានយោនឹ ឧបបន្នំ ទុក្ខា តិព្វា កដុកា វេទនា វេទិយមានំ ។ សេយ្យថាបិ សារីបុត្ត គូថកូបោ សាធិកបោរិសោ បូរោ គូថស្ស



លុះបែកធ្លាយរាងកាយ ខាងមុខអំពីមរណៈ មុខជានឹងទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក មិនខាន លុះសម័យខាងក្រោយមក តថាគតក៏ឃើញបុគ្គលនោះ ដែលបែកធ្លាយរាងកាយ ខាងមុខអំពីមរណៈទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក សោយទុក្ខវេទនាដ៏ក្លៀវក្លា ក្តៅផ្សាឥតស្រាក ដោយចក្ខុដូចជាទិព្វដ៏បរិសុទ្ធកន្លងហួសចក្ខុរបស់មនុស្សធម្មតា ដូច្នោះឯង ។

(១៧៤) ម្នាលសារីបុត្ត តថាគតកំណត់នូវចិត្តដោយចិត្ត ដឹងនូវបុគ្គលពួកមួយក្នុងលោកនេះយ៉ាងនេះថា បុគ្គលនេះប្រតិបត្តិដូច្នោះផង ប្រព្រឹត្តដូច្នោះផង ឡើងកាន់ផ្លូវនោះផង លុះបែកធ្លាយរាងកាយខាងមុខអំពីមរណៈ មុខជានឹងកើតក្នុងកំណើតតិរច្ឆាន មិនខាន លុះសម័យខាងក្រោយមក តថាគតក៏ឃើញបុគ្គលនោះ ដែលបែកធ្លាយរាងកាយខាងមុខអំពីមរណៈទៅកើតក្នុងកំណើតតិរច្ឆាន សោយទុក្ខវេទនាដ៏ក្លៀវក្លា ក្តៅផ្សា ដោយចក្ខុដូចជាទិព្វដ៏បរិសុទ្ធកន្លងហួសចក្ខុរបស់មនុស្សធម្មតា ។ ម្នាលសារីបុត្ត រណ្តៅលាមកមានជម្រៅជាងមួយជួរបុរស ពេញដោយលាមក

អថ បុរិសោ អាគច្ឆេយ្យ ឃម្មាភិតត្តោ ឃម្មបរេតោ កិលន្តោ តសិតោ បិបាសិតោ ឯកាយនេន មគ្គេន តមេវ គូថកូបំ បណិធាយ តមេនំ ចក្ខុមា បុរិសោ ទិស្វា ឯវំ វទេយ្យ តថាយំ ភវំ បុរិសោ បដិបន្នោ តថា ច ឥរិយតិ តញ្ច មគ្គំ សមារុឡ្ហោ យថា ឥមំយេវ គូថកូបំ អាគមិស្សតីតិ តមេនំ បស្សេយ្យ អបរេន សមយេន តស្មិំ គូថកូបេ បតិតំ ទុក្ខា តិព្វា កដុកា វេទនា វេទយមានំ ឯវមេវ ខោ អហំ សារីបុត្ត ឥធេកច្ចំ បុគ្គលំ ឯវំ ចេតសា ចេតោ បរិច្ច បជានាមិ តថាយំ បុគ្គលោ បដិបន្នោ តថា ច ឥរិយតិ តញ្ច មគ្គំ សមារុឡ្ហោ យថា កាយស្ស ភេទា បរម្មរណា តិរច្ឆានយោនឹ ឧបបជ្ជិស្សតីតិ តមេនំ បស្សាមិ អបរេន សមយេន ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន កាយស្ស ភេទា បរម្មរណា តិរច្ឆានយោនឹ ឧបបន្នំ ទុក្ខា តិព្វា កដុកា វេទនា វេទយមានំ ។



គ្រានោះ មានបុរសម្នាក់ក្តៅក្រហល់ក្រហាយដោយកំដៅថ្ងៃ ដែលកំដៅថ្ងៃគ្របសង្កត់ លំបាក ផ្សាក់ ស្រេកទឹក ដើរមកតាមផ្លូវដែលទៅបានតែម្នាក់ សំដៅទៅត្រង់រណ្តៅលាមកនោះឯង បុរសមានចក្ខុបានឃើញបុរសនោះហើយ និយាយយ៉ាងនេះថា បុរសដ៏ចំរើននេះ ដើរទៅផ្លូវនោះផង ប្រព្រឹត្តផ្លូវនោះផង ឡើងកាន់ផ្លូវនោះផង មុខជានឹងមកកាន់រណ្តៅលាមកនេះពុំខាន លុះសម័យខាងក្រោយមក (បុរសមានចក្ខុនោះ) ក៏ឃើញបុរសនោះ ធ្លាក់ទៅក្នុងរណ្តៅលាមកនោះ សោយទុក្ខវេទនាដ៏ក្លៀវក្លា ខ្លោចផ្សា សេចក្តីនេះមានឧបមាដូចម្តេចមិញ ម្នាលសារីបុត្ត មានឧបមេយ្យដូចតថាគតកំណត់នូវចិត្តដោយចិត្ត ដឹងនូវបុគ្គលពួកមួយក្នុងលោកនេះយ៉ាងនេះថា បុគ្គលនេះប្រតិបត្តិផ្លូវនោះផង ប្រព្រឹត្តផ្លូវនោះផង ឡើងកាន់ផ្លូវនោះផង លុះបែកធ្លាយរាងកាយខាងមុខអំពីមរណៈ មុខជានឹងទៅកើតក្នុងកំណើតតិរច្ឆាន មិនខាន លុះសម័យខាងក្រោយមក តថាគតក៏ឃើញបុគ្គលនោះ ដែលបែកធ្លាយរាងកាយខាងមុខអំពីមរណៈ ទៅកើតក្នុងកំណើតនៃតិរច្ឆាន សោយទុក្ខវេទនាដ៏ក្លៀវក្លា ខ្លោចផ្សា ដោយចក្ខុដូចជាទិព្វដ៏បរិសុទ្ធកន្លងហួសចក្ខុរបស់មនុស្សធម្មតាដូច្នោះឯង ។

[១៧៣] ឥធាហំ សារីបុត្ត ឯកច្ចំ បុគ្គលំ ឯវំ ចេតសា ចេតោ បរិច្ច បជានាមិ តថាយំ បុគ្គលោ បដិបន្នោ តថា ច ឥរិយតិ តញ្ច មគ្គំ សមារូឡ្ហោ យថា កាយស្ស ភេទា បរម្មរណា បេត្តិវិសយំ ឧប- បជ្ជិស្សតីតិ តមេនំ បស្សាមិ អបរេន សមយេន ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន កា- យស្ស ភេទា បរម្មរណា បេត្តិវិសយំ ឧបបន្នំ ទុក្ខពហុ- លា វេទនា វេទិយមានំ ។ សេយ្យថាបិ សារីបុត្ត រុក្ខោ វិសមេ ភូមិភាគេ ជាតោ តនុបត្តបលាសោ កពរច្ឆាយោ[១] អថ បុរិសោ ឃម្មាភិតត្តោ ឃម្មបរេតោ កិលន្តោ តសិតោ បិបាសិតោ ឯកា- យនេន មគ្គេន តមេវ រុក្ខំ បណិធាយ តមេនំ ចក្ខុមា បុរិសោ ទិស្វា ឯវំ វទេយ្យ តថាយំ ភវំ បុរិសោ បដិ- បន្នោ តថា ច ឥរិយតិ តញ្ច មគ្គំ សមារូឡ្ហោ

១ ឱ.ម. កពរច្ឆាយោ ។



(១៧៣) ម្នាលសារីបុត្ត តថាគតកំណត់ដឹងនូវចិត្តដោយចិត្ត ដឹងនូវបុគ្គលពួកមួយក្នុងលោកនេះយ៉ាងនេះថា បុគ្គលនេះប្រតិបត្តិផ្លូវនោះផង ប្រព្រឹត្តផ្លូវនោះផង ឡើងកាន់ផ្លូវនោះផង លុះបែកធ្លាយរាងកាយ ខាងមុខអំពីមរណៈ មុខជានឹងទៅកើតក្នុងបិត្តិវិស័យ លុះសម័យខាងក្រោយមក តថាគតក៏ឃើញបុគ្គលនោះ ដែលបែកធ្លាយរាងកាយ ខាងមុខអំពីមរណៈទៅកើតក្នុងបិត្តិវិស័យ សោយទុក្ខវេទនាដ៏ច្រើន ដោយចក្ខុជាទិព្វដ៏បរិសុទ្ធកន្លងហួសចក្ខុរបស់មនុស្សធម្មតា ។ ម្នាលសារីបុត្ត ដើមឈើដែលដុះលើផែនដីមិនរាបស្មើ មានស្លឹកនិងមែកស្តើង មានម្លប់ស្រីមស្រីម គ្រានោះ មានបុរសម្នាក់ក្តៅក្រហល់ក្រហាយដោយកំដៅថ្ងៃ ដែលកំដៅថ្ងៃគ្របសង្កត់ លំបាក ស្រេកទឹក ដើរមកតាមផ្លូវ ដែលត្រង់ទៅបានតែម្នាក់ សំដៅទៅរកដើមឈើនោះឯង បុរសអ្នកមានភ្នែកបានឃើញបុរសនោះហើយនិយាយយ៉ាងនេះថា បុរសដ៏ចំរើននេះដើរទៅផ្លូវនោះផង ប្រព្រឹត្តផ្លូវនោះផង ឡើងកាន់ផ្លូវនោះផង

យថា ឥមំយេវ រុក្ខំ អាគមិស្សតីតិ តមេនំ បស្សេយ្យ អបរេន សមយេន តស្ស រុក្ខស្ស ឆាយាយំ[១] និសិន្នំ វា និបន្នំ វា ទុក្ខពហុលា វេទនា វេទិយមានំ ឯវមេវ ខោ អហំ សារីបុត្ត ឥធេកច្ចំ បុគ្គលំ ឯវំ ចេតសា ចេតោ បរិច្ច បជានាមិ តថាយំ បុគ្គលោ បដិបន្នោ តថា ច ឥរិយតិ តញ្ច មគ្គំ សមារុឡ្ហោ យថា កាយស្ស ភេទា បរម្មរណា បិត្តិវិសយំ ឧបបជ្ជិស្សតីតិ តមេនំ បស្សាមិ អបរេន សមយេន ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន កាយស្ស ភេទា បរម្មរណា បិត្តិវិសយំ ឧបបន្នំ ទុក្ខពហុលា វេទនា វេទិយមានំ ។

(១៧៤) ឥធ បនាហំ សារីបុត្ត ឯកច្ចំ បុគ្គលំ ឯវំ ចេតសា ចេតោ បរិច្ច បជានាមិ តថាយំ បុគ្គលោ បដិបន្នោ តថា ច ឥរិយតិ តញ្ច មគ្គំ សមារុឡ្ហោ យថា កាយស្ស ភេទា បរម្មរណា មនុស្សេសុ ឧបបជ្ជិស្សតីតិ តមេនំ បស្សាមិ អបរេន សមយេន

១ ម. ឆាយាយ ។



មុខជានឹងមកកាន់ដើមឈើនេះមិនខាន លុះសម័យខាងក្រោយមក (បុរសមានចក្ខុនោះ) ក៏ឃើញបុរសនោះអង្គុយឬដេកទទួលទុក្ខវេទនាដ៏ច្រើន ក្រោមម្លប់ដើមឈើនោះ សេចក្តីនេះមានឧបមាយ៉ាងណាមិញ ម្នាលសារីបុត្ត មានឧបមេយ្យដូចតថាគតដែលកំណត់ដឹងនូវចិត្តដោយចិត្ត ដឹងនូវបុគ្គលពួកមួយក្នុងលោកនេះយ៉ាងនេះថា បុគ្គលនេះប្រតិបត្តិដូច្នោះផង ប្រព្រឹត្តដូច្នោះផង ឡើងកាន់ផ្លូវនោះផង លុះបែកធ្លាយរាងកាយខាងមុខអំពីមរណៈ មុខជាទៅកើតក្នុងបិត្តិវិស័យមិនខាន លុះសម័យខាងក្រោយមក តថាគតក៏ឃើញបុគ្គលនោះ បែកធ្លាយរាងកាយខាងមុខអំពីមរណៈទៅកើតក្នុងបិត្តិវិស័យ សោយទុក្ខវេទនាដ៏ច្រើន ដោយចក្ខុជាទិព្វដ៏បរិសុទ្ធកន្លងហួសចក្ខុរបស់មនុស្សសាមញ្ញដូច្នោះឯង ។

(១៧៤) ម្នាលសារីបុត្ត តថាគតកំណត់នូវចិត្តដោយចិត្ត ដឹងនូវបុគ្គលពួកមួយក្នុងលោកនេះយ៉ាងនេះថា បុគ្គលនេះប្រតិបត្តិដូច្នោះផង ប្រព្រឹត្តដូច្នោះផង ឡើងកាន់ផ្លូវនោះផង លុះបែកធ្លាយរាងកាយខាងមុខអំពីមរណៈ មុខជានឹងទៅកើតក្នុងពួកមនុស្ស លុះសម័យខាងក្រោយមក

ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន កាយស្ស ភេទា បរម្មរណា មនុស្សេសុ ឧបបន្នំ សុខពហុលា វេទនា វេទិយមានំ ។ សេយ្យថាបិ សារីបុត្ត រុក្ខោ សមេ ភូមិភាគេ ជាតោ ពហលៈ-បត្តបលាសោ សន្ទច្ឆាយោ អថ បុរិសោ អាគច្ឆេយ្យ ឃម្មាភិតត្តោ ឃម្មបរេតោ កិលន្តោ តសិតោ បិបា-សិតោ ឯកាយនេន មគ្គេន តមេវ រុក្ខំ បណិធាយ តមេនំ ចក្ខុមា បុរិសោ ទិស្វា ឯវំ វទេយ្យ តថាយំ បុរិសោ បដិបន្នោ តថា ច ឥរិយតិ តញ្ច មគ្គំ សមារុឡ្ហោ យថា ឥមំយេវ រុក្ខំ អាគមិស្សតីតិ តមេនំ បស្សេយ្យ អបរេន សមយេន តស្ស រុក្ខស្ស ឆា-យាយ និសិន្នំ វា និបន្នំ វា សុខពហុលា វេទនា វេទិយមានំ ឯវមេវ ខោ អហំ សារីបុត្ត ឥធេកច្ចំ បុគ្គលំ ឯវំ ចេតសា ចេតោ បរិច្ច បជានាមិ តថាយំ បុគ្គលោ បដិបន្នោ តថា ច ឥរិយតិ តញ្ច មគ្គំ សមារុឡ្ហោ ។បេ។ មនុស្សេសុ ឧបបន្នំ សុខ-ពហុលា វេទនា វេទិយមានំ ។



តថាគតក៏ឃើញបុគ្គលនោះ ដែលបែកធ្លាយរាងកាយខាងមុខអំពីមរណៈ ទៅកើតក្នុងពួកមនុស្ស សោយសុខវេទនាជាច្រើន ដោយចក្ខុដូចជាទិព្វ ដ៏បរិសុទ្ធកន្លងហួសចក្ខុរបស់មនុស្សធម្មតា ។ ម្នាលសារីបុត្ត ដើមឈើ ដែលដុះលើផែនដីរាបស្មើល្អ មានស្រទាប់ស្លឹកដ៏ក្រាស់ មានម្លប់ត្រៃឈ ត្រានោះ មានបុរសក្តៅក្រហល់ក្រហាយដោយកំដៅថ្ងៃ ដែលកំដៅថ្ងៃ គ្របសង្កត់ លំបាក ដង្ហក់ ស្រេកទឹក ដើរមកតាមផ្លូវដែលត្រង់ទៅបាន តែម្នាក់ សំដៅទៅរកដើមឈើនោះឯង បុរសអ្នកមានចក្ខុបានឃើញបុរស នោះ ក៏និយាយយ៉ាងនេះថា បុរសនេះដើរទៅដូច្នោះផង ប្រព្រឹត្តដូច្នោះផង ឡើងកាន់ផ្លូវនោះផង មុខជានឹងមកកាន់ដើមឈើនេះពុំខាន លុះសម័យ ខាងក្រោយមក (បុរសមានចក្ខុនោះ) ក៏ឃើញបុរសនោះឯង អង្គុយ ឬដេកសោយសុខវេទនាជាច្រើន ក្រោមម្លប់នៃដើមឈើនោះ សេចក្តី នេះមានឧបមាដូចម្តេចមិញ ម្នាលសារីបុត្ត មានឧបមេយ្យដូចតថាគត ដែលកំណត់ដួងចិត្តដោយចិត្ត ដឹងនូវចិត្តនៃបុគ្គលពួកមួយក្នុងលោកនេះ យ៉ាងនេះថា បុគ្គលប្រតិបត្តិដូច្នោះផង ប្រព្រឹត្តដូច្នោះផង ឡើងកាន់ផ្លូវ នោះផង ។បេ។ ទៅកើតក្នុងពួកមនុស្ស សោយសុខវេទនាជាច្រើន ដូច្នោះឯង ។

(១៧៨) ឥធាហំ សារិបុត្ត ឯកច្ចំ បុគ្គលំ ឯវំ ចេតសា ចេតោ បរិច្ច បជានាមិ តថាយំ បុគ្គលោ បដិបន្នោ តថា ច ឥរិយតិ តញ្ច មគ្គំ សមារុឡ្ហោ យថា កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជិស្សតីតិ តមេនំ បស្សាមិ អបរេន សមយេន ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបន្នំ ឯកន្តសុខា វេទនា វេទិយមានំ ។ សេយ្យថាបិ សារិបុត្ត បាសាទោ តត្រស្ស កូដាគារំ ឧល្លិត្តាវលិត្តំ និវាតំ ផុសិតគ្គឡំ(១) បិហិតវាតបានំ តត្រស្ស បល្លង្កោ គោនកត្ថតោ បដិកត្ថតោ បដលិកត្ថតោ កទលិមិគបវរប្បច្ចត្ថរណោ សឧត្តរច្ឆទោ ឧភតោលោហិតកូបធានោ អថ បុរិសោ អាគច្ឆេយ្យ ឃម្មាភិតត្តោ ឃម្មបរេតោ កិលន្តោ តសិតោ បិបាសិតោ ឯកាយនេន មគ្គេន តមេវ បាសាទំ បណិធាយ តមេនំ ចក្ខុមា បុរិសោ ទិស្វា

១ ម. និស្សិតគ្គឡំ ។



(១៧៨) ម្នាលសារីបុត្ត តថាគតកំណត់នូវចិត្តដោយចិត្ត ដឹងនូវបុគ្គលពួកមួយក្នុងលោកនេះយ៉ាងនេះថា បុគ្គលនេះប្រតិបត្តិផ្លូវណាផង ប្រព្រឹត្តផ្លូវណាផង ឡើងកាន់ផ្លូវនោះផង លុះបែកធ្លាយរាងកាយខាងមុខអំពីមរណៈ មុខជានឹងទៅកើតក្នុងសុគតិ សួគ៌ ទេវលោក មិនខាន លុះសម័យខាងក្រោយមក តថាគតក៏ឃើញបុគ្គលនោះ ដែលបែកធ្លាយរាងកាយខាងមុខអំពីមរណៈ ទៅកើតក្នុងសុគតិ សួគ៌ ទេវលោក សោយសេចក្តីសុខជានិច្ច ដោយចក្ខុជាទិព្វ ដ៏បរិសុទ្ធកន្លងហួសចក្ខុរបស់មនុស្សធម្មតា ។ ម្នាលសារីបុត្ត ប្រាសាទមានកូដាគារ (ផ្ទះមានកំពូល) ដែលលាបពាំងខាងក្នុងពាំងខាងក្រៅ ជិតខ្យល់ មានទ្វារជិត មានបង្អួចបើកបិទបាន ក្នុងកូដាគារនោះមានបល្ល័ង្កដែលក្រាលដោយព្រំមានរោមវែងជាង ៤ ធ្នាប់ ក្រាលដោយកម្រាលមានពណ៌សធ្វើដោយរោម សត្វ ជាផ្កាបង្កើប មានកម្រាលដ៏ឧត្តម ដែលគេធ្វើដោយស្បែកសត្វឈ្លូស មានខ្នើយពណ៌ក្រហមទាំងពីរខាង គឺខ្នើយក្បាលនិងខ្នើយជើង ព្រមទាំងពិតានដែលមានពណ៌ក្រហម គ្រានោះ មានបុរសម្នាក់ក្តៅក្រហល់ក្រហាយដោយកំដៅថ្ងៃ ដែលកំដៅថ្ងៃគ្របសង្កត់ លំបាក ផ្អាក់ស្រេកទឹក ដើរមកតាមផ្លូវដែលត្រង់ទៅបានតែម្យ៉ាង សំដៅទៅត្រង់ប្រាសាទនោះឯង បុរសអ្នកមានចក្ខុបានឃើញបុរសនោះហើយនិយាយ

ឯវំ វទេយ្យ តថាយំ ភវំ បុរិសោ បដិបន្នោ តថា ច ឥរិយតិ តញ្ច មគ្គំ សមារូឡ្ហោ យថា ឥមំ-យេវ បាសាទំ អាគមិស្សតីតិ តមេនំ បស្សេយ្យ អបរេន សមយេន តស្មិំ បាសាទេ តស្មិំ កូដា-គារេ តស្មិំ បល្លង្កេ និសិន្នំ វា និបន្នំ វា ឯកន្ត-សុខា វេទនា វេទិយមានំ ឯវមេវ ខោ អហំ សារីបុត្ត ឥធេកច្ចំ បុគ្គលំ ឯវំ ចេតសា ចេតោ បរិច្ច បជានាមិ តថាយំ បុគ្គលោ បដិបន្នោ តថា ច ឥរិយតិ តញ្ច មគ្គំ សមារូឡ្ហោ យថា កាយស្ស ភេទា បរម្មរណា សុគតិំ សគ្គំ លោកំ ឧបបជ្ជិ-ស្សតីតិ តមេនំ បស្សាមិ អបរេន សមយេន ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន កាយស្ស ភេទា បរម្មរណា សុគតិំ សគ្គំ លោកំ ឧបបន្នំ ឯកន្តសុខា វេទនា វេទិយមានំ ។

(១៧៦) ឥធ បនាហំ សារីបុត្ត ឯកច្ចំ បុគ្គលំ ឯវំ ចេតសា ចេតោ បរិច្ច បជានាមិ តថាយំ បុគ្គលោ បដិបន្នោ តថា ច ឥរិយតិ តញ្ច មគ្គំ សមារូឡ្ហោ



យ៉ាងនេះថា បុរសដ៏ចំរើននេះដើរទៅផ្លូវយ៉ាងនោះផង ប្រព្រឹត្តផ្លូវយ៉ាងនោះផង ឡើងកាន់ផ្លូវនោះផង មុខជានឹងមកកាន់ប្រាសាទនេះដោយពិត លុះសម័យខាងក្រោយមក (បុរសមានចក្ខុនោះ) ក៏ឃើញនូវបុរសនោះ កំពុងអង្គុយឬដេកសោយសុខវេទនាជានិច្ច លើបល្ល័ង្កក្នុងកូដាគារប្រាសាទនោះ សេចក្តីនេះមានឧបមាដូចម្តេចមិញ ម្នាលសារីបុត្ត មានឧបមេយ្យដូចតថាគតដែលកំណត់ដឹងនូវចិត្តដោយចិត្តដឹងនូវបុគ្គលពួកមួយក្នុងលោកនេះយ៉ាងនេះថា បុគ្គលនេះប្រតិបត្តិផ្លូវយ៉ាងនោះផង ប្រព្រឹត្តផ្លូវយ៉ាងនោះផង ឡើងកាន់ផ្លូវនោះផង លុះបែកធ្លាយរាងកាយខាងមុខអំពីមរណៈ មុខជានឹងទៅកើតក្នុងសុគតិ សួគ៌ ទេវលោក លុះសម័យខាងក្រោយមក តថាគតក៏ឃើញបុគ្គលនោះ ដែលបែកធ្លាយរាងកាយខាងមុខអំពីមរណៈ ទៅកើតក្នុងសុគតិ សួគ៌ ទេវលោក សោយសុខវេទនាជានិច្ច ដោយចក្ខុដ៏ជាទិព្វដ៏បរិសុទ្ធកន្លងបង់ចក្ខុរបស់មនុស្សប្រក្រតី ដូច្នោះឯង ។

(១៧៦) ម្នាលសារីបុត្ត តថាគតកំណត់ដឹងនូវចិត្តដោយចិត្ត ដឹងនូវបុគ្គលពួកមួយក្នុងលោកនេះយ៉ាងនេះថា បុគ្គលនេះប្រតិបត្តិផ្លូវយ៉ាងនោះផង ប្រព្រឹត្តផ្លូវយ៉ាងនោះផង ឡើងកាន់ផ្លូវនោះផង មុខជានឹងធ្វើឲ្យជាក់

យថា អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញា-វិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរិស្សតីតិ តមេនំ បស្សាមិ អបរេន សមយេន អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរន្តំ ឯកន្តសុខា វេទនា វេទិយមានំ ។ សេយ្យថាបិ សារីបុត្ត បោក្ខរណី អច្ឆោទកា សា-តោទកា សីតោទកា សេតកា សុបតិត្ថា រម-ណីយា អវិទូរេ ចស្សា តិព្វោ វនសណ្ឌោ អថ បុរិសោ ឃម្មាភិតត្តោ ឃម្មបរេតោ កិលន្តោ តសិតោ បិបាសិតោ ឯកាយនេន មគ្គេន តមេវ បោក្ខរណឹ បណិធាយ តមេនំ ចក្ខុមា បុរិសោ ទិស្វា ឯវំ វទេយ្យ តថាយំ ភវំ បុរិសោ បដិបន្នោ តថា ច ឥរិ-យតិ តញ្ច មគ្គំ សមារូឡ្ហោ យថា ឥមំយេវ បោក្ខរណឹ អាគមិស្សតីតិ តមេនំ បស្សេយ្យ អបរេន សមយេន



ច្បាស់នូវចេតោវិមុត្តិ បញ្ញាវិមុត្តិ មិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយដោយប្រាជ្ញាដ៏ក្រៃលែង ដោយខ្លួនឯងក្នុងបច្ចុប្បន្ន សម្រេចសម្រាន្តដោយឥរិយាបថទាំង ៤ លុះសម័យតទៅក្រោយមក តថាគតក៏ឃើញបុគ្គលនោះ ដែលបានធ្វើឲ្យជាក់ច្បាស់នូវចេតោវិមុត្តិ បញ្ញាវិមុត្តិ មិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ដោយប្រាជ្ញាដ៏ក្រៃលែងដោយខ្លួនឯងក្នុងបច្ចុប្បន្ន សម្រេចសម្រាន្តដោយឥរិយាបថទាំង ៤ សោយសុខវេទនាដ៏ទៃ ។ ម្នាលសារីបុត្ត ស្រះបោក្ខរណីមានទឹកថ្លា មានទឹកឆ្ងាញ់ មានទឹកត្រជាក់ មានទឹកស្អាត មានកំពង់រាបទាបល្អ គួរជាទីរីករាយ មានដងព្រៃស្រោងស្រោង មិនឆ្ងាយអំពីស្រះបោក្ខរណីនោះ គ្រានោះ មានបុរសម្នាក់ ក្តៅក្រហល់ក្រហាយដោយកំដៅថ្ងៃ ដែលកំដៅថ្ងៃគ្របសង្កត់ លំបាក ដង្ហក់ ស្រេកទឹក ដើរមកតាមផ្លូវដែលត្រង់ទៅបានតែម្នាក់ សំដៅទៅកាន់ស្រះបោក្ខរណីនោះ បុរសអ្នកមានចក្ខុ បានឃើញបុរសនោះហើយ ក៏និយាយយ៉ាងនេះថា បុរសដ៏ចំរើននេះ ដើរទៅផ្លូវណោះផង ប្រព្រឹត្តផ្លូវណោះផង ឡើងកាន់ផ្លូវនោះផង មុខជានឹងមកកាន់ស្រះបោក្ខរណីនេះ ដោយពិត លុះសម័យតទៅក្រោយមក (បុរសមានចក្ខុនោះ) ក៏ឃើញបុរសនោះ

តំ បោក្ខរណឹ ឱគាហេត្វា(១) នហាត្វា ច បិវិត្វា(២) ច សព្វទរថកិលមថបរិឡាហំ បដិបស្សម្ភេត្វា បច្ចុត្តរិត្វា តស្មឹំយេវ វនសណ្ឌេ និសិន្នំ វា និបន្នំ វា ឯកន្តសុខា វេទនា វេទិយមានំ ឯវមេវ ខោ អហំ សារីបុត្ត ឥធេកច្ចំ បុគ្គលំ ឯវំ ចេតសា ចេតោ បរិច្ច បជានាមិ តថាយំ បុគ្គលោ បដិបន្នោ តថា ច ឥរិយតិ តញ្ច មគ្គំ សមារុឡ្ហោ យថា អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរិស្សតីតិ តមេនំ បស្សាមិ អបរេន សមយេន អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរន្តំ ឯកន្តសុខា វេទនា វេទិយមានំ ។ ឥមា ខោ សារីបុត្ត បញ្ច គតិយោ ។ យោ ខោ មំ សារីបុត្ត ឯវំ ជានន្តំ ឯវំ បស្សន្តំ ឯវំ វទេយ្យ នត្ថិ សមណស្ស គោតមស្ស ឧត្តរិ មនុស្សធម្មា អលមរិយញាណទស្សនវិសេសោ

១ ម. នហាយិត្វា ។ ២ ឱ. បិវិត្វា ច ។ ម. បិវិត្វា ចាតិ ន ទិស្សតិ ។



ចុះទៅក្នុងស្រះបោក្ខរណីនោះ ងូតផង ផឹកផង បំបាត់បង់នូវសេចក្តីក្រវល់ក្រវាយ នឿយហត់ និងសេចក្តីក្តៅក្រហល់ក្រហាយគ្រប់យ៉ាង ហើយឡើងមកអង្គុយឬដេកសោយសុខតែសុខវេទនា ក្នុងដងព្រៃនោះ សេចក្តីនេះមានឧបមាដូចម្តេចមិញ ម្នាលសារីបុត្ត មានឧបមេយ្យដូចតថាគត ដែលកំណត់នូវចិត្តដោយចិត្ត ដឹងនូវបុគ្គលពួកមួយក្នុងលោកនេះយ៉ាងនេះថា បុគ្គលនេះប្រតិបត្តិដូច្នោះផង ប្រព្រឹត្តដូច្នោះផង ឡើងទៅកាន់ផ្លូវនោះផង មុខជានឹងធ្វើឲ្យជាក់ច្បាស់នូវចេតោវិមុត្តិ បញ្ញាវិមុត្តិ មិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ដោយប្រាជ្ញាដ៏ក្រៃលែងខ្លួនឯងក្នុងបច្ចុប្បន្ន សម្រេចសម្រាន្តដោយឥរិយាបថយ៉ាង ៤ លុះសម័យខាងក្រោយមក តថាគតក៏ឃើញបុគ្គលនោះធ្វើឲ្យជាក់ច្បាស់នូវចេតោវិមុត្តិ បញ្ញាវិមុត្តិ មិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ដោយប្រាជ្ញាដ៏ក្រៃលែងខ្លួនឯងក្នុងបច្ចុប្បន្ន សម្រេចសម្រាន្តដោយឥរិយាបថទាំង ៤ សោយសុខតែសុខវេទនាដូច្នោះឯង ។ ម្នាលសារីបុត្ត គតិនេះឯងមាន ៥ យ៉ាង ។ ម្នាលសារីបុត្ត អ្នកណាពោលយ៉ាងនេះ ចំពោះតថាគតដែលដឹងយ៉ាងនេះ ដែលឃើញយ៉ាងនេះថា គុណវិសេសគឺញាណទស្សនៈ អាចធ្វើខ្លួនឲ្យជាអរិយៈដ៏ក្រៃលែងជាងមនុស្សធម៌របស់ព្រះសមណគោតមមិនមានទេ ព្រះសមណ-

តក្កបរិយាហតំ សមណោ គោតមោ ធម្មំ ទេសេតិ វីមំសានុចរិតំ សយំ បដិភានន្តិ តំ សារីបុត្ត វាចំ អប្បហាយ តំ ចិត្តំ អប្បហាយ តំ ទិដ្ឋឹ អប្បដិនិស្សជ្ជិត្វា យថាភតំ និក្ខិត្តោ ឯវំ និរយេ ។ សេយ្យថាបិ សារីបុត្ត ភិក្ខុ សីលសម្បន្នោ សមាធិសម្បន្នោ បញ្ញាសម្បន្នោ ទិដ្ឋេវ ធម្មេ អញ្ញំ អារាធេយ្យ ឯវំ សម្បទមិទំ សារីបុត្ត វទាមិ ។ តំ វាចំ អប្បហាយ តំ ចិត្តំ អប្បហាយ តំ ទិដ្ឋឹ អប្បដិនិស្សជ្ជិត្វា យថាភតំ និក្ខិត្តោ ឯវំ និរយេ ។

(១៧៧) អភិជានាមិ ខោ បនាហំ សារីបុត្ត ចតុរង្គសមន្នាគតំ ព្រហ្មចរិយំ ចរិតា ។ តបស្សីសុទំ



គោតមសំដែងធម៌ដែលខ្លួនស្រាវជ្រាវបានមកដោយសេចក្តីត្រិះរិះ ដែលខ្លួនស្ទាបស្ទង់ដោយការពិចារណា ជាធម៌កើតមានដោយប្រាជ្ញារបស់ខ្លួនដូច្នេះ បុគ្គលនោះ បើមិនលះបង់នូវវាចានោះចេ មិនលះបង់នូវចិត្តនោះចេ មិនលះបង់នូវទិដ្ឋិនោះចេ នឹងធ្លាក់ទៅក្នុងនរកដូចជាគេនាំយកទៅទំលាក់ដូច្នោះឯង ។ ម្នាលសារីបុត្ត ភិក្ខុបរិបូណ៌ដោយសីលហើយ បរិបូណ៌ដោយសមាធិហើយ បរិបូណ៌ដោយបញ្ញាហើយ សម្រេចអរហត្តផលក្នុងបច្ចុប្បន្ននេះឯង យ៉ាងណាមិញ ម្នាលសារីបុត្ត តថាគតពោលនូវហេតុនេះជាគ្រឿងផ្តល់នូវពាក្យឧបមេយ្យយ៉ាងនោះដែរ ។ បុគ្គលនោះ បើមិនលះបង់នូវវាចានោះចេ មិនលះបង់នូវចិត្តនោះចេ មិនលះបង់នូវទិដ្ឋិនោះចេ នឹងធ្លាក់ទៅក្នុងនរកដូចជាគេនាំយកទៅទំលាក់ដូច្នោះឯង ។

(១៧៧) ម្នាលសារីបុត្ត មួយទៀត តថាគតដឹងច្បាស់នូវប្រព្រឹត្តព្រហ្មចរិយៈ(១)ដែលប្រកបដោយអង្គ ៤(២) ។ តថាគតជាអ្នកមានតបៈ

---

១ ពាក្យថា ព្រហ្មចរិយៈ បានដល់ទាន វេយ្យាវច្ចៈ សិក្ខាបទ ព្រហ្មវិហារ ធម្មទេសនា មេថុនវិរតិ សទារសន្តោស វីរិយៈ ឧបោសថ អរិយមគ្គ សាសនាទាំងអស់ទាំងអង្គស្រាយក៏បាន តែក្នុងសូត្រនេះ សំដៅយក វីរិយៈ (សេចក្តីព្យាយាម) ។ ២ សេចក្តីព្យាយាមនោះ ដែលបុគ្គលធ្វើឲ្យតឹង ៤ យ៉ាងក្នុងអត្តភាពមួយ ឈ្មោះថាប្រកបដោយអង្គ ៤ ដូចមានក្នុងសូត្រនេះស្រាប់ ។ អដ្ឋកថា ។

ហោមិ បរមតបស្សី លូខោ សុទំ[១] ហោមិ បរមលូខោ ជេគុច្ឆី សុទំ ហោមិ បរមជេគុច្ឆី បវិវិត្តោ សុទំ[២] ហោមិ បរមប្បវិវិត្តោ ។

(១៧៨) តត្រាស្សុ មេ ឥទំ សារីបុត្ត តបស្សិតាយ ហោតិ អចេលកោ ហោមិ មុត្តាចារោ ហត្ថាបលេខនោ ន ឯហិភទន្តិកោ ន តិដ្ឋភទន្តិកោ ន អភិហដំ[៣] ន ឧទ្ទិស្សកតំ ន និមន្តនំ សាទិយាមិ ។ សោ ន កុម្ភិមុខា បដិគ្គណ្ហាមិ ន កឡោបិមុខា បដិគ្គណ្ហាមិ ន ឯឡកមន្តរំ ន ទណ្ឌមន្តរំ ន មុសលមន្តរំ

១ ឱ. លូខស្សុទំ ។ ២ ឱ. បវិវិត្តស្សុទំ ។ ៣ ឱ.ម. នាភិហដំ ។



តថាគតជាអ្នកមានតបៈដ៏ក្រៃលែង បើនិយាយពីអ្នកសៅហ្មង តថាគត ជាអ្នកសៅហ្មងដ៏ក្រៃលែង បើនិយាយពីអ្នកមានសេចក្តីខ្ពើមឆ្អប តថាគត ជាអ្នកមានសេចក្តីខ្ពើមឆ្អបដ៏ក្រៃលែង បើនិយាយពីអ្នកស្ងប់ស្ងាត់ តថាគត ជាអ្នកស្ងប់ស្ងាត់ដ៏ក្រៃលែង ។

(១៧៨) ម្នាលសារីបុត្ត ការមានតបៈរបស់តថាគតក្នុងព្រហ្មចរិយៈ ប្រកបដោយអង្គ ៤ នោះដូច្នេះ គឺតថាគតជាអ្នកអាក្រាត លះបង់មារយាទល្អ[១] ប្រព្រឹត្តហត្ថាវលេខនបត្ត[២] ជាអ្នកកាន់ត្តមិនចូលមក (ទទួលភត្ត) ដែលគេនិមន្តថា លោកដ៏ចំរើនចូរចូលមក មិនឈរចាំ តាមគេនិមន្តថា លោកដ៏ចំរើនសូមឈរចាំសិន មិនត្រេកអរនឹងចង្ហាន់ ដែលគេនាំយកមកមុន មិនត្រេកអរនឹងចង្ហាន់ដែលគេប្រាប់ថាធ្វើចំពោះខ្លួន មិនត្រេកអរនឹងចង្ហាន់ដែលគេនិមន្ត[៣] ។ តថាគតនោះមិនទទួលចង្ហាន់ ដែលគេកំពុងដួសអំពីឆ្នាំង មិនទទួលចង្ហាន់អំពីមាត់កញ្ជើ មិនទទួលចង្ហាន់ដែលគេឲ្យក្រោមចន្លោះធរណី មិនទទួលចង្ហាន់ដែលគេឲ្យក្រោមចន្លោះត្បាល់ មិនទទួលចង្ហាន់ដែលគេឲ្យក្រោមចន្លោះអង្រែ មិនទទួល

១ ឈរបន្ទោបង់ទ្វារៈបស្សាវៈ ទាំងឈរបរិភោគ ។ ២ បរិភោគភោជនហើយលិទ្ធដៃ ឬ យកស្រាមដៃកិតឈើមក ព្រោះសំគាល់កំណាត់ឈើជាសត្វ ។ ៣ នាំរន្តកក្រុមហ្មាលទៅ កាន់ត្រកូលបច្ចុប្បន្ន ស្រុកឯណោះ ។

ន ទ្វិន្នំ ភុញ្ជមានានំ ន គព្ភិនិយា ន បាយមានាយ ន បុរិសន្តរគតាយ ន សង្កិត្តីសុ ន យត្ថ សា ឧបដ្ឋិតោ ហោតិ ន យត្ថ មក្ខិកា សណ្ឌសណ្ឌចារិនី ន មច្ឆំ ន មំសំ ន សុរំ ន មេរយំ ន ថុសោទកំ បិវតិ ។ សោ ឯកាគារិកោ វា ហោតិ ឯកាលោបិកោ ទ្វាគារិកោ វា ហោតិ ទ្វាលោបិកោ ។ បេ ។ សត្តាគារិកោ វា ហោតិ សត្តាលោបិកោ ។ ឯកិស្សាបិ ទត្តិយា យាបេតិ ទ្វីហិបិ ទត្តីហិ យាបេតិ ។ បេ ។ សត្តហិបិ យាបេតិ ឯកាហិកម្បិ(១) អាហារំ អាហារេតិ ទ្វីហិកម្បិ អាហារំ អាហារេតិ ។ បេ ។ សត្តាហិកម្បិ អាហារំ អាហារេតិ ឥតិ ឯវរូបំ អឌ្ឍមាសិកម្បិ បរិយាយភត្តភោជនានុយោគមនុយុត្តោ វិហរតិ ។ សោ សាកភក្ខោ វា ហោតិ សាមាកភក្ខោ វា ហោតិ នីវារភក្ខោ វា ហោតិ ទទ្ទុលភក្ខោ វា ហោតិ ហដភក្ខោ វា ហោតិ កណភក្ខោ វា ហោតិ អាចាមភក្ខោ វា ហោតិ បិញ្ញាកភក្ខោ វា ហោតិ តិណភក្ខោ វា ហោតិ

---

១ ឱ. សត្តហិបិ ទត្តីហិ យាបេតិ ។ ឯកាហិកម្បិ ។ ម. សត្តហិបិ ទត្តីហិ យាបេតិ ។ ឯកាហិកំបិ ។ ២ ម. អាចាមភក្ខោ វា ហោតិ បិញ្ញាកភក្ខោ វា ហោតីតិ ន ទិស្សន្តិ ។



ចង្ហាន់របស់មនុស្សដែលកំពុងបរិភោគពីរនាក់ មិនទទួលចង្ហាន់របស់ស្ត្រីមានគភ៌ មិនទទួលចង្ហាន់របស់ស្ត្រីដែលកំពុងបំបៅកូន មិនទទួលចង្ហាន់របស់ស្ត្រីដែលកំពុងនៅរួមនឹងបុរស មិនទទួលចង្ហាន់ដែលគេរៃអង្គាសគ្នាធ្វើ មិនទទួលចង្ហាន់ក្នុងទីដែលមានឆ្កែនៅចាំ មិនទទួលចង្ហាន់ដែលមានរុយរោមរោម មិនបរិភោគត្រី មិនបរិភោគសាច់ មិនផឹកសុរា មិនផឹកមេរ័យ មិនផឹកទឹកថ្នាំត្រាំដោយស្រូវចាំងពួន ។ អចេលកនោះទទួលចង្ហាន់ក្នុងផ្ទះមួយឬបរិភោគដោយទទួលតែមួយពំនូត ទទួលចង្ហាន់ក្នុងផ្ទះពីរ ឬបរិភោគដោយទទួលតែពីរពំនូត ។ បេ ។ ទទួលចង្ហាន់ក្នុងផ្ទះ៧ ឬបរិភោគតែ៧ ពំនូត ។ អចេលកនោះចិញ្ចឹមអត្តភាពដោយចង្ហាន់ ១ កាដងខ្លះ ចិញ្ចឹមអត្តភាពដោយចង្ហាន់ ២ កាដងខ្លះ ។ បេ ។ ចិញ្ចឹមអត្តភាពដោយចង្ហាន់ ៧ កាដងខ្លះ ឆាន់អាហារមួយ ១ ថ្ងៃខ្លះ ឆាន់អាហារមួយ ២ ថ្ងៃខ្លះ ។ បេ ។ ឆាន់អាហារមួយ ៧ ថ្ងៃខ្លះ អចេលកប្រកបរឿយៗ នូវការបរិភោគភត្តតាមលំដាប់ថ្ងៃយ៉ាងនេះ ហួតដល់មួយកន្លះខែខ្លះ ដូចសំដែងមកនេះឯង ។ អចេលកមានបន្លែជាអាហារខ្លះ មានស្រងែជាអាហារខ្លះ មានស្មៅកែលលកជាអាហារខ្លះ មានចំរៀកស្បែកដែលគេចៀរចោលជាអាហារខ្លះ មានសារាយជាអាហារខ្លះ មានកុណ្ឌកជាអាហារខ្លះ មានបាយក្តាំងជាអាហារខ្លះ មានម្សៅជាអាហារខ្លះ មានស្មៅជាអាហារខ្លះ

គោមយភក្ខោ វា ហោតិ វនមូលផលាហារោ យាបេតិ បវត្តផលភោជី ។ សោ សាណានិបិ ធារេតិ មសាណានិបិ ធារេតិ ឆវទុស្សានិបិ ធារេតិ បំសុកូលានិបិ ធារេតិ តិរីដានិបិ ធារេតិ អជិនានិបិ(១) ធារេតិ អជិនក្ខិបម្បិ ធារេតិ កុសចីរម្បិ ធារេតិ វាកចីរម្បិ ធារេតិ ផលកចីរម្បិ ធារេតិ កេសកម្ពលម្បិ ធារេតិ វាលកម្ពលម្បិ ធារេតិ ឧលូកបក្ខម្បិ ធារេតិ កេសមស្សុលោចកោបិ ហោតិ កេសមស្សុលោចនានុយោគមនុយុត្តោ ឧព្ភដ្ឋកោ(២) ហោតិ អាសនបដិក្ខិត្តោ ឧក្កុដិកោបិ ហោតិ ឧក្កុដិកប្បធានមនុយុត្តោ កណ្ដកាបស្សយិកោបិ ហោតិ កណ្ដកាបស្សយេ សេយ្យំ កប្បេតិ សាយតតិយកម្បិ ឧទកោរោហនានុយោគមនុយុត្តោ វិហរតិ

១ ឱ. អជិនម្បិ ។ ម. អជិនំបិ ។ ២ ឱ.ម. ឧព្ភដ្ឋកោបិ ។



មានអាចម៍គោជាអាហារខ្លះ មានមើមនិងផ្លែឈើជាអាហារចិញ្ចឹមជីវិតខ្លះ ស៊ីតែផ្លែឈើដែលជ្រុះឯងចិញ្ចឹមជីវិតខ្លះ ។ គេជាអ្នកប្រើប្រាស់សំពត់ដែលត្បាញដោយសំបកធ្មៃខ្លះ ប្រើប្រាស់សំពត់ដែលត្បាញលាយចម្រុះគ្នាខ្លះ ប្រើប្រាស់សំពត់ដែលគេរុំសាកសពខ្លះ ប្រើប្រាស់សំពត់បង្សុកូល(១)ខ្លះ ប្រើប្រាស់សំពត់សំបកឈើខ្លះ ប្រើប្រាស់ស្បែកខ្លាខ្លះ ប្រើប្រាស់ស្បែកខ្លាទាំងក្រចកខ្លះ ប្រើប្រាស់សំពត់ដែលក្រងដោយស្បូវខ្លះ ប្រើប្រាស់សំពត់ដែលក្រងដោយសំបកក្រចៅខ្លះ ប្រើប្រាស់សំពត់ ដែលក្រងដោយសំបកផ្លែឈើខ្លះ ប្រើប្រាស់សំពត់កម្ពលដែលត្បាញដោយសក់មនុស្សខ្លះ ប្រើប្រាស់សំពត់ ដែលត្បាញដោយរោមកន្ទុយសត្វខ្លះ ប្រើប្រាស់សំពត់ដែលត្បាញដោយស្លាបមៀមខ្លះ ជាអ្នកដកសក់និងពុកមាត់ពុកចង្កា ប្រកបរឿយ ៗ នូវសេចក្ដីព្យាយាមដកសក់និងពុកមាត់ពុកចង្កាខ្លះ ជាអ្នកប្រព្រឹត្តតែឈរ មិនអង្គុយខ្លះ ជាអ្នកអង្គុយច្រហោង ប្រកបរឿយ ៗ នូវសេចក្ដីព្យាយាមអង្គុយច្រហោងខ្លះ ជាអ្នកដេកលើបន្លា សម្រេចការដេកលើបន្លាខ្លះ ប្រកបរឿយ ៗ នូវសេចក្ដីព្យាយាមចុះត្រាំក្នុងទឹក (ដើម្បីបន្សាត់បាប) ក្នុង ១ ថ្ងៃ ៣ ដង(២)

១ កំណាត់សំពត់ដែលគេបោះបង់ចោលលើផែនដី ។ ២ គឺពេលព្រឹកព្រហាមម្ដង ថ្ងៃត្រង់ម្ដង ល្ងាចម្ដង ។ អដ្ឋកថា ។

ឥតិ ឯវរូបំ អនេកវិហិតំ កាយស្ស អាតាបនបរិ-
តាបនានុយោគមនុយុត្តោ វិហរាមិ ។ ឥទំសុ មេ
សារីបុត្ត តបស្សិតាយ ហោតិ ។

(១៧៥) តត្រាស្សុ មេ ឥទំ សារីបុត្ត លូខស្មឹ
ហោតិ ។ នេកវស្សគណិកំ រជោជល្លំ កាយេ សន្និ-
ចិតំ ហោតិ បប្បដិកជាតំ ។ សេយ្យថាបិ សារីបុត្ត
តិណ្ឌុកខាណុ[១] នេកវស្សគណិកោ សន្និចិតោ
ហោតិ បប្បដិកជាតោ ឯវមេវស្សុ មេ សារីបុត្ត
នេកវស្សគណិកំ រជោជល្លំ កាយេ សន្និចិតំ ហោតិ
បប្បដិកជាតំ ។ តស្ស មយ្ហំ សារីបុត្ត ន ឯវំ ហោតិ
អហោ វតាហំ ឥមំ រជោជល្លំ បាណិនា បរិមជ្ជេយ្យំ[២] ។
អញ្ញេ វា បន មេ ឥមំ រជោជល្លំ បាណិនា បរិ-
មជ្ជេយ្យុន្តិ ឯវម្បិ មេ សារីបុត្ត ន ហោតិ ។ ឥទំសុ
មេ សារីបុត្ត លូខស្មឹ ហោតិ ។

១ ម.ម. តិន្ទុកខាណុ ។ ២ បរិមជ្ជេយ្យន្តិ បាឋេន ភវិតព្វំ ។



ប្រកបរឿយៗនូវសេចក្តីព្យាយាមដុតកំដៅកិលេស កាលខ្លួនកាយច្រើនប្រការ
មានសភាពយ៉ាងនេះ ដូច្នេះឯង ។ ម្នាលសារីបុត្ត នេះឯងជាភាពនៃ
អ្នកមានតបៈរបស់តថាគត ។

(១៧៥) ម្នាលសារីបុត្ត សេចក្តីសៅហ្មងរបស់តថាគតក្នុងព្រហ្ម-
ចរិយធម៌ប្រកបដោយអង្គ ៤ នេះដូច្នេះ ។ មន្ទិលគឺធូលីកប់ដោយឆ្នាំដ៏ច្រើន
ដែលជាប់នៅនឹងកាយ ក៏ក្លាយទៅជាក្រមស្រគាប់ ។ ម្នាលសារីបុត្ត
ដង្គត់ដើមដង្កោដែលតាំងនៅកប់ដោយឆ្នាំដ៏ច្រើន ក៏កើតជាក្រមរ មាន
ឧបមាដូចម្តេចមិញ ម្នាលសារីបុត្ត មានឧបមេយ្យដូចមន្ទិលគឺធូលីកប់
ដោយឆ្នាំដ៏ច្រើនដែលជាប់នៅនឹងកាយតថាគត ក៏ក្លាយទៅជាក្រមដូច្នោះ
ឯង ។ ម្នាលសារីបុត្ត តថាគតនោះ មិនមានសេចក្តីត្រិះរិះយ៉ាងនេះថា
ឱហ្ន៎ អាត្មាអញគប្បីយកបាតដៃជូតមន្ទិលគឺធូលីនេះចេញដូច្នេះឡើយ ។
ម្នាលសារីបុត្ត សូម្បីតែគំនិតយ៉ាងនេះថា ជនទាំងឡាយដទៃ គប្បីយក
បាតដៃជូតមន្ទិលរបស់តថាគតនេះដូច្នេះ ក៏មិនមានដល់តថាគតឡើយ ។
ម្នាលសារីបុត្ត នេះជាវត្តនៃសេចក្តីសៅហ្មងរបស់តថាគត ។

(១៨០) តត្រាស្សុ មេ ឥទំ សារីបុត្ត ជេគុច្ឆិស្មឹ ហោតិ ។ សោ ខោ អហំ សារីបុត្ត សតោវ អភិក្កមាមិ សតោ បដិក្កមាមិ ។ យាវ ឧទកពិន្ទុម្ហិបិ មេ ទយា បច្ចុបដ្ឋិតា ហោតិ មាហំ ខុទ្ទកេ បាណេ វិសមគតេ សង្ឃាតំ អាបាទេសិន្តិ ។ ឥទំសុ មេ សារីបុត្ត ជេគុច្ឆិស្មឹ ហោតិ ។

(១៨១) តត្រាស្សុ មេ ឥទំ សារីបុត្ត បវិវិត្តស្មឹ ហោតិ ។ សោ ខោ អហំ សារីបុត្ត អញ្ញតរំ អរញ្ញាយតនំ អជ្ឈោគាហេត្វា វិហរាមិ ។ យទា បស្សាមិ គោបាលកំ វា បសុបាលកំ វា តិណហារកំ វា កដ្ឋហារកំ វា វនកម្មិកំ វា វនេន វនំ គហនេន គហនំ និន្នេន និន្នំ ថលេន ថលំ បបតាមិ តំ កិស្ស ហេតុ មា មំ តេ អទ្ទសំសុ អហញ្ច មា តេ អទ្ទសន្តិ ។



(១៨០) ម្នាលសារីបុត្ត វត្តខាងសេចក្ដីខ្ពើមបាប របស់តថាគត ក្នុងព្រហ្មចរិយធម៌ប្រកបដោយអង្គ ៤ នោះដូច្នេះ ។ ម្នាលសារីបុត្ត តថាគតនោះឯង ឈានទៅមុខក៏មានស្មារតី ថយក្រោយក៏មានស្មារតី ។ តថាគតដំកល់នូវសេចក្ដីករុណាចំពោះដំណក់ទឹក(១) ដរាបមកថា តថាគតមិនបានញាំញីពួកសត្វតូច ៗ គឺដំណក់ទឹកដែលដក់ជាប់នៅក្នុងទីវិសម ។ ឲ្យដល់នូវសេចក្ដីវិនាសឡើយ ។ ម្នាលសារីបុត្ត នេះឯងជាវត្តខាងការខ្ពើមបាប របស់តថាគត ។

(១៨១ ម្នាលសារីបុត្ត វត្តខាងការស្ងប់ស្ងាត់ របស់តថាគត ក្នុងព្រហ្មចរិយធម៌ ប្រកបដោយអង្គ ៤ នោះដូច្នេះ ។ ម្នាលសារីបុត្ត តថាគតនោះឯង តែងចូលសំដៅទៅនៅអាស្រ័យក្នុងព្រៃណាមួយ ។ កាលណាបើតថាគតឃើញអ្នកគង្វាលគោក្ដី អ្នកគង្វាលសត្វចិញ្ចឹមក្ដី អ្នកកេះស្មៅក្ដី អ្នករកឧសក្ដី អ្នករកបរក្នុងព្រៃក្ដី តថាគតក៏ចេញអំពីព្រៃទៅកាន់ព្រៃ ចេញអំពីព្រៃស្បាតទៅកាន់ព្រៃស្បាត ចេញអំពីទីទាបទៅកាន់ទីទាប ចេញពីទីទួលទៅកាន់ទីទួល ដំណើរនោះតើព្រោះហេតុអ្វី ព្រោះតថាគតបានអធិដ្ឋានថា សូមកុំឲ្យជនទាំងឡាយនោះ បានឃើញតថាគត ទាំងតថាគតសោតក៏កុំបានឃើញជនទាំងឡាយនោះឡើយ ។

១ អដ្ឋកថា ថា ដំណក់ទឹក ក្រួស ឬ កំណាត់ឈើដែលនៅខ្ចប់ជាដើម ពួកនិគ្រន្ថបញ្ញត្តជាជីវសត្វតូច ៗ ។

សេយ្យថាបិ សារីបុត្ត អារញ្ញកោ មិគោ មនុស្សេ ទិស្វា វនេន វនំ គហនេន គហនំ និន្នេន និន្នំ ថលេន ថលំ សម្បតតិ សម្បបតតិ ឯវមេវ ខោ អហំ សារីបុត្ត យទា បស្សាមិ គោបាលកំ វា បសុបាលកំ វា តិណហារកំ វា កដ្ឋហារកំ វា វនេន វនំ គហនេន គហនំ និន្នេន និន្នំ ថលេន ថលំ សម្បតាមិ តំ កិស្ស ហេតុ មា មំ តេ អទ្ទសំសុ អហញ្ច មា តេ អទ្ទសន្តិ ។ ឥទំសុ មេ សារីបុត្ត បវិវិត្តស្មឹ ហោតិ ។

(១៨៦) សោ ខោ អហំ សារីបុត្ត យេ តេ គោដ្ឋា បក្កន្តគាវោ អបគតគោបាលកា[១] តត្ថ ចតុក្កុណ្ឌិកោ ឧបសង្កមិត្វា យានិ តានិ វច្ឆកានំ តរុណកានំ ធេនុបកានំ គោមយានិ តានិ សុទំ អាហារេមិ ។ យាវកីវញ្ច មេ សារីបុត្ត សកំ មុត្តករីសំ អបរិយាទិន្នំ ហោតិ សកំយេវ សុទំ មុត្តករីសំ អាហារេមិ ។ ឥទំសុ មេ សារីបុត្ត មហាវិកដភោជនស្មឹ ហោតិ ។

១ ឱ.ម. អបគតគោបាលកា ។



ម្នាលសារីបុត្ត ប្រៀបដូចម្រឹគព្រៃឃើញមនុស្សទាំងឡាយ តែងរត់ចេញពីព្រៃ ចូលទៅកាន់ព្រៃ ចេញពីព្រៃស្បាត ចូលទៅកាន់ព្រៃស្បាត ចេញអំពីទីទាប ចូលទៅកាន់ទីទាប ចេញអំពីទីខ្ពស់ ចូលទៅកាន់ទីខ្ពស់ យ៉ាងណាមិញ ម្នាលសារីបុត្ត កាលណាតថាគត ឃើញអ្នកគង្វាលគោក្តី អ្នកគង្វាលសត្វចិញ្ចឹមក្តី អ្នករកស្មៅក្តី អ្នករកឧសក្តី អ្នករកបេះផ្លែព្រៃក្តី តថាគតក៏ចេញអំពីព្រៃទៅកាន់ព្រៃ ចេញអំពីព្រៃស្បាត ទៅកាន់ព្រៃស្បាត ចេញអំពីទីទាប ទៅកាន់ទីទាប ចេញអំពីទីខ្ពស់ ទៅកាន់ទីខ្ពស់ ក៏យ៉ាងនោះដែរ ដំណើរនោះ តើព្រោះហេតុអ្វី ព្រោះតថាគតបាន អធិដ្ឋានថា សូមកុំឲ្យជនទាំងឡាយនោះបានឃើញតថាគត ទាំងតថាគត សោត ក៏កុំបានឃើញជនទាំងឡាយនោះឡើយ ។ ម្នាលសារីបុត្ត នេះឯងជាវត្តខាងសេចក្តីស្ងប់ស្ងាត់ របស់តថាគត ។

(១៨៦) ម្នាលសារីបុត្ត តថាគតជាអ្នកវារដោយជង្គង់ ៤ ចូលទៅរកក្រោលគោដែលមានគោចេញហើយ មានអ្នកគង្វាលគោចៀសចេញទៅហើយ ហើយស៊ីលាមករបស់កូនគោដំទន់ដែលនៅបៅមេ ។ ម្នាលសារីបុត្ត មូត្រនិងករីសខ្លួនឯង របស់តថាគត មិនទាន់អស់ដរាបណា តថាគតក៏ស៊ីនូវមូត្រនិងករីសរបស់ខ្លួនឯងដរាបនោះ ។ ម្នាលសារីបុត្ត នេះឯងជាវត្តខាងភោជនយ៉ាងចំឡែកធំ របស់តថាគត ។

(១៨៣) សោ ខោ អហំ សារីបុត្ត អញ្ញតរំ ភឹសនកំ វនសណ្ឌំ អជ្ឈោគាហេត្វា វិហរាមិ ។ តត្រស្សុទំ សារីបុត្ត ភឹសនកស្ស វនសណ្ឌស្ស ភឹសនកត្តស្មិំ ហោតិ ។ យោ កោចិ អវីតរាគោ តំ វនសណ្ឌំ បវិសតិ យេភុយ្យេន លោមានិ ហំសន្តិ ។ សោ ខោ អហំ សារីបុត្ត យា តា រត្តិយោ សីតា ហេមន្តិកា អន្តរដ្ឋកា ហិមបាតសមយា(១) តថារូបាសុ រត្តីសុ អព្ភោកាសេ វិហរាមិ ទិវា វនសណ្ឌេ ទិវា អព្ភោកាសេ វិហរាមិ រត្តឹ វនសណ្ឌេ ។ អបិស្សុ មំ សារីបុត្ត អយំ អនច្ឆរិយា គាថា បដិភាសិ បុព្វេ អស្សុតបុព្វា

សោតត្តោ សោសិនោ ចេវ
ឯកោ ភឹសនកេ វនេ
នគ្គោ ន ចគ្គិមាសីនោ
ឯសនាបសុតោ មុនីតិ ។

១ ម. អន្តរដ្ឋកេ ហិមបាតសមយេ ។



(១៨៣) ម្នាលសារីបុត្ត តថាគតចូលទៅអាស្រ័យនៅក្នុងដងព្រៃ ១ ដែលគួរស្ញែង ។ ម្នាលសារីបុត្ត សេចក្តីគួរខ្លាចក្នុងដងព្រៃដែលគួរស្ញែងនោះតែងមាន ។ បុគ្គលណាមួយ មិនទាន់ប្រាសចាកតណ្ហានៅ ចូលទៅកាន់ដងព្រៃនោះ ច្រើនតែព្រឺព្រួចរោម ។ ម្នាលសារីបុត្ត រាត្រីទាំង ៨ ជាចន្លោះនៃខែមាឃនឹងខែផល្គុន(១) ក្នុងហេមន្តរដូវ ជាសម័យធ្លាក់ទឹកសន្សើមដ៏ត្រជាក់ ក្នុងរាត្រីទាំងឡាយមានសភាពដូច្នោះ តថាគតនៅទីវាល ក្នុងវេលាយប់ នៅក្នុងដងព្រៃវេលាថ្ងៃ ខែជាខាងចុងនៃហេមន្តរដូវ តថាគតនៅទីវាលក្នុងវេលាថ្ងៃ នៅក្នុងដងព្រៃវេលាយប់ ។ ម្នាលសារីបុត្ត អភិគាថាដែលគួរអស្ចារ្យនេះ មិនមែនតថាគតធ្លាប់បានស្តាប់ក្នុងកាលពីមុនមកទេ ស្រាប់តែភ្លឺច្បាស់ប្រាកដ មកកាន់តថាគត

អ្នកប្រាជ្ញដែលខ្វល់ខ្វាយក្នុងកិរិយាស្វែងរក (នូវសេចក្តីបរិ-
សុទ្ធ) អ្នកប្រាជ្ញនោះត្រូវតែក្តៅ អ្នកប្រាជ្ញនោះត្រូវតែត្រ
ជាក់ម្នាក់ឯង ជាអ្នកត្រូវតែនៅក្នុងព្រៃ គួរស្ញែងតែម្នាក់ឯង
អាក្រាតមិនចូលទៅកៀកភ្លើងឡើយ ។

១ អដ្ឋកថា ថា រាត្រី ៨ នោះក្នុងចន្លោះនៃខែទាំងពីរ គឺខាងចុងខែមាឃ ៤ រាត្រី ខាងដើមខែផល្គុន ៤ រាត្រី រួមជា ៨ រាត្រី ។

(១៨៤) សោ ខោ អហំ សារីបុត្ត សុសានេ សេយ្យំ កប្បេមិ អដ្ឋិកានិ ឧបធាយ ។ អបិស្សុ មំ សារីបុត្ត គោមណ្ឌលា ឧបសង្កមិត្វា ឱដ្ឋុភន្តិបិ[១] ឱមុត្តេន្តិបិ បំសុកេនបិ ឱកិរន្តិ[២] កណ្ណសោតេសុបិ សលាកំ បវេសេន្តិ ។ ន ខោ បនាហំ សារីបុត្ត អភិជានាមិ តេសុ បាបកំ ចិត្តំ ឧប្បាទេតា ។ ឥទំបិស្សុ មេ សារីបុត្ត ឧបេក្ខាវិហារស្មឹ ហោតិ ។

(១៨៥) សន្តិ ខោ បន សារីបុត្ត ឯកេ សមណព្រាហ្មណា ឯវំវាទិនោ ឯវំទិដ្ឋិនោ អាហារេន សុទ្ធីតិ ។ តេ ឯវមាហំសុ កោលេហិ យាបេមាតិ ។ តេ កោលម្បិ ខាទន្តិ កោលចុណ្ណម្បិ ខាទន្តិ កោលោទកម្បិ បិវន្តិ អនេកវិហិតម្បិ កោលវិកតឹ បរិភុញ្ជន្តិ ។ អភិជានាមិ ខោ បនាហំ សារីបុត្ត ឯកំយេវ កោលំ អាហារំ អាហារិតា ។ សិយា ខោ បន តេ សារីបុត្ត ឯវមស្ស មហា នូន តេន សមយេន កោលោ អហោសីតិ ។

១ ម. ឱដ្ឋុភន្តិបិ ។ ២ ម. បំសុកេន ឱកិរន្តិបិ ។



(១៨៤) ម្នាលសារីបុត្ត តថាគតនោះសម្រេចនូវសេយ្យាបថដេកក្នុងព្រៃស្មសាន ហើយកើយឆ្អឹងសាកសពទាំងឡាយ ។ ម្នាលសារីបុត្ត ចំណែកពួកក្មេងឃ្វាលគោនាំគ្នាចូលទៅជិតតថាគត ហើយស្តោះដាក់ខ្លះ នោមដាក់ខ្លះ យកដីកាយដាក់ខ្លះ យកកំណាត់ឈើមកញែកត្រចៀកខ្លះ[១] ។ ម្នាលសារីបុត្ត តថាគតមិនដែលឲ្យចិត្តអាក្រក់កើតឡើងចំពោះពួកក្មេងឃ្វាលគោទាំងនោះឡើយ ។ ម្នាលសារីបុត្ត នេះឯងឈ្មោះថា ជាវត្តខាងការនៅប្រកបដោយឧបេក្ខា របស់តថាគត ។

(១៨៥) ម្នាលសារីបុត្ត មានសមណព្រាហ្មណ៍ពួកមួយ តែងនិយាយយ៉ាងនេះ តែងយល់យ៉ាងនេះថា សេចក្តីបរិសុទ្ធកើតមានព្រោះអាហារ ។ ពួកសមណព្រាហ្មណ៍ទាំងនោះពោលយ៉ាងនេះថា យើងទាំងឡាយនឹងចិញ្ចឹមអត្តភាពដោយផ្លែពុទ្រាទាំងឡាយ ។ ពួកសមណព្រាហ្មណ៍ទាំងនោះ ក៏ស៊ីផ្លែពុទ្រាខ្លះ ស៊ីលំអិតនៃផ្លែពុទ្រាខ្លះ ផឹកទឹកដែលច្របាច់លាយដោយផ្លែពុទ្រាខ្លះ បរិភោគនូវដែលធ្វើដោយផ្លែពុទ្រាច្រើនយ៉ាងខ្លះ ។ ម្នាលសារីបុត្ត តថាគតធ្លាប់យកផ្លែពុទ្រាតែ ១ ប៉ុណ្ណោះមកធ្វើជាអាហារ ។ ម្នាលសារីបុត្ត សមជាអ្នកមានសេចក្តីយល់យ៉ាងនេះថា ផ្លែពុទ្រាក្នុងសម័យនោះជាផ្លែធំៗណាស់ ។

១ អដ្ឋកថា សំដែងសេចក្តីថា ពួកក្មេងទាំងនោះកាលចូលទៅកាន់សំណាក់ព្រះពោធិសត្វ ហើយនិយាយបង្ខំឲ្យព្រះពោធិសត្វនិយាយ តែព្រះពោធិសត្វមិនតបពាក្យឡើយ បានជាពួកទាំងនោះធ្វើអំពើអាក្រក់មានស្តោះដាក់ជាដើម ។

ន ខោ បនេតំ សារីបុត្ត ឯវំ ទដ្ឋព្វំ ។ តទាបិ ឯតបរមោយេវ កោលោ អហោសិ សេយ្យថាបិ ឯតរហិ ។ តស្ស មយ្ហំ សារីបុត្ត ឯកំយេវ កោលំ អាហារំ អាហារយតោ អធិមត្តកសិមានំ បត្តោ កាយោ ហោតិ ។ សេយ្យថាបិ នាម អាសីតិកបព្វានិ វា កាឡបព្វានិ វា ឯវមេវស្សុ មេ អង្គប្បច្ចង្គានិ ភវន្តិ តាយេវប្បាហារតាយ ។ សេយ្យថាបិ នាម ឱដ្ឋបទំ ឯវមេវស្សុ មេ អានិសទំ ហោតិ តាយេវប្បាហារតាយ ។ សេយ្យថាបិ នាម វដ្ដនាវឡី ឯវមេវស្សុ មេ បិដ្ឋិកណ្ដកោ ឧន្នតាវនតោ ហោតិ តាយេវប្បាហារតាយ ។ សេយ្យថាបិ នាម ជរសាលាយ គោបានសិយោ ឱលុគ្គវិលុគ្គា ភវន្តិ ឯវមេវស្សុ មេ ផាសុឡិយោ ឱលុគ្គវិលុគ្គា ភវន្តិ តាយេវប្បាហារតាយ ។ សេយ្យថាបិ នាម គម្ភីរេ ឧទបានេ ឧទកតារកា គម្ភីរគតា ឱក្ខាយិកា ទិស្សន្តិ ឯវមេវស្សុ មេ អក្ខិកូបេសុ អក្ខិតារកា គម្ភីរគតា ឱក្ខាយិកា ទិស្សន្តិ តាយេវប្បាហារតាយ ។



ម្នាលសារីបុត្ត ដំណើរនុ៎ះអ្នកមិនគួរយល់ឃើញនោះទៀយ ។ ព្រោះថាផ្លែពុទ្រា ក្នុងកាលឥឡូវនេះ មានទំហំប៉ុនណា ក្នុងកាលពីដើមក៏មានទំហំប៉ុណ្ណោះដែរ ។ ម្នាលសារីបុត្ត កាលដែលតថាគតនោះ យកផ្លែពុទ្រាតែ១ ប៉ុណ្ណោះមកធ្វើអាហារ កាយក៏ដល់នូវភាពស្គាំងស្គមហួសប្រមាណ ។ ព្រោះតែអាហារតិចនោះឯង អវយវៈតូចធំរបស់តថាគតក៏ដូចជាថ្នាំងវល្លិ៍ ឈ្មោះអសីតិ (ដកគន់ឬវល្លិខតែន) ឬដូចជាថ្នាំងវល្លិ៍កាឡា (វល្លិ៍អណ្ដាក ត្រកួត) ។ ព្រោះតែអាហារតិចនោះឯង ទេគាករបស់តថាគតក៏ដូចជា ជើងសត្វអូដ្ឋ ។ ព្រោះតែអាហារតិចនោះឯង ឆ្អឹងខ្នងរបស់តថាគតគើម គោមដូចជាខ្សែដែលគេវេញ ។ ព្រោះតែអាហារតិចនោះឯង ឆ្អឹងជំនីរ ទាំងឡាយរបស់តថាគត ក៏គើមគោមដូចបង្កង់សាលាចាស់ដែលរេចរោក ។ ព្រោះតែអាហារតិចនោះឯង ប្រស្រីភ្នែកក្នុងកន្ធក់ភ្នែករបស់តថាគតក៏ចូលជ្រៅទៅក្នុងរណ្ដៅភ្នែក ដូចជាក្រពេញទឹកដែលជ្រៅចូលទៅក្នុង

សេយ្យថាបិ នាម តិត្តកាលាពុ អាមកច្ឆិន្នោ វាតាត-
បេន សំផុដិតោ ហោតិ សម្មិលាតោ ឯវមេវស្ស មេ
សីសច្ឆវី សំផុដិតា ហោតិ សម្មិលាតា តាយេវប្បា-
ហារតាយ ។ សោ ខោ អហំ សារីបុត្ត ឧទរច្ឆវឹ
បរិមសិស្សាមីតិ បិដ្ឋិកណ្ដកំយេវ បរិគ្គណ្ហាមិ បិដ្ឋិ-
កណ្ដកំ បរិមសិស្សាមីតិ ឧទរច្ឆវឹយេវ បរិគ្គណ្ហាមិ
យាវស្សុ មេ សារីបុត្ត ឧទរច្ឆវី បិដ្ឋិកណ្ដកំ អល្លីនា
ហោតិ តាយេវប្បាហារតាយ ។ សោ ខោ អហំ សារី-
បុត្ត វច្ចំ វា មុត្តំ វា ករិស្សាមីតិ តត្ថេវ អវកុជ្ជោ
បបតាមិ តាយេវប្បាហារតាយ ។ សោ ខោ អហំ
សារីបុត្ត តមេវ កាយំ អស្សាសេន្តោ បាណិនា គត្តានិ
អនោមជ្ជាមិ ។ តស្ស មយ្ហំ សារីបុត្ត បាណិនា
គត្តានិ អនោមជ្ជតោ បូតិមូលានិ លោមានិ កាយស្មា
បបតន្តិ តាយេវប្បាហារតាយ ។

(១៨៦) សន្តិ ខោ បន សារីបុត្ត ឯកេ
សមណព្រាហ្មណា ឯវំវាទិនោ ឯវំទិដ្ឋិនោ អាហា-
រេន សុទ្ធីតិ ។ តេ ឯវមាហំសុ កោលេហិ យាបេម



អណ្ដូងទឹកដ៏ជ្រៅ ។ ព្រោះតែអាហារតិចនោះឯង ស្បែកក្បាលរបស់តថា-
គតក៏ស្រពោនស្វិតស្រពោន ដូចផ្លែឃ្លោកល្វីងដែលគេកាត់ទាំងខ្ចី រីងរួញ
ស្វិតស្រពោនព្រោះខ្យល់និងកំដៅថ្ងៃ ។ ម្នាលសារីបុត្ត តថាគតនោះ
គិតថា នឹងស្ទាបស្បែកពោះ ហើយចាប់ត្រូវខ្នងឆ្អឹងខ្នងវិញ តថាគត
គិតថា នឹងស្ទាបខ្នងឆ្អឹងខ្នង ហើយចាប់ត្រូវស្បែកពោះវិញ ម្នាល
សារីបុត្ត ស្បែកពោះរបស់តថាគត ក៏ជាប់ខ្នាប់នឹងខ្នងឆ្អឹងខ្នងដោយពិត
ព្រោះតែអាហារតិចនោះឯង ។ ម្នាលសារីបុត្ត តថាគតនោះគិតថា នឹង
បន្ទោបង់វច្ចៈឬទឹកមូត្រ ក៏ដួលផ្កាប់មុខទៅលើផែនដី ព្រោះតែអាហារតិច
នោះឯង ។ ម្នាលសារីបុត្ត តថាគតនោះកាលធ្វើកាយនោះឯងឲ្យមាន
ស្រួល ក៏យកដៃស្ទាបខ្លួន ។ ម្នាលសារីបុត្ត កាលតថាគតនោះយក
ដៃស្ទាបខ្លួន រោមទាំងឡាយដែលមានគល់ស្អុយ ក៏ជ្រុះចេញពីកាយ
ព្រោះតែអាហារតិចនោះឯង ។

(១៨៦) ម្នាលសារីបុត្ត មានសមណព្រាហ្មណ៍ពួកមួយ តែង
និយាយយ៉ាងនេះ តែងយល់យ៉ាងនេះថា សេចក្ដីបរិសុទ្ធិកើតមានព្រោះ
អាហារ (តិច) ។ ពួកសមណព្រាហ្មណ៍ទាំងនោះ បាននិយាយយ៉ាង
នេះថា យើងទាំងឡាយនឹងចិញ្ចឹមអត្តភាពដោយសណ្ដែកបាយទាំងឡាយ

។ បេ ។ តិលេហិ យាបេម ។ បេ ។ តណ្ឌុលេហិ យាបេមាតិ ។ តេ តណ្ឌុលម្បិ ខាទន្តិ តណ្ឌុលចុណ្ណម្បិ ខាទន្តិ តណ្ឌុលោទកម្បិ បិវន្តិ អនេកវិហិតម្បិ តណ្ឌុលវិកតឹ បរិភុញ្ជន្តិ ។ អភិជានាមិ ខោ បនាហំ សារីបុត្ត ឯកំយេវ តណ្ឌុលំ អាហារំ អាហារិតា ។ សិយា ខោ បន តេ សារីបុត្ត ឯវមស្ស មហា នូន តេន សមយេន តណ្ឌុលោ អហោសីតិ ។ ន ខោ បនេតំ សារីបុត្ត ឯវំ ទដ្ឋព្វំ ។ តទាបិ ឯតបរមោយេវ តណ្ឌុលោ អហោសិ សេយ្យថាបិ ឯតរហិ ។ តស្ស មយ្ហំ សារីបុត្ត ឯកំយេវ តណ្ឌុលំ អាហារំ អាហារយតោ អធិមត្តកសិមានំ បត្តោ កាយោ ហោតិ ។ សេយ្យថាបិ នាម អាសីតិកបព្វានិ វា កាឡបព្វានិ វា ឯវមេវស្សុ មេ អង្គបច្ចង្គានិ ភវន្តិ តាយេវប្បាហារតាយ ។ សេយ្យថាបិ នាម ឱដ្ឋបទំ ។ បេ ។ ហោតិ តាយេវប្បាហារតាយ ។ សេយ្យថាបិ នាម វដ្ដនាវឡី ។ បេ ។ តាយេវប្បាហារតាយ ។ សេយ្យថាបិ នាម ជរសាលាយ ។ បេ ។ សេយ្យថាបិ





។ បេ ។ ចិញ្ចឹមអត្តភាពដោយល្ងទាំងឡាយ ។ បេ ។ ចិញ្ចឹមអត្តភាពដោយអង្ករទាំងឡាយ ។ ពួកសមណព្រាហ្មណ៍ទាំងនោះ ទំពាស៊ីអង្ករខ្លះ ទំពាស៊ីម្សៅអង្ករខ្លះ ផឹកទឹកអង្ករខ្លះ បរិភោគនំដែលធ្វើពីអង្ករច្រើនយ៉ាងខ្លះ ។ ម្នាលសារីបុត្ត ចំណែកតថាគតធ្លាប់អាស្រ័យអាហារបំពោះអង្ករតែ ១ គ្រាប់ប៉ុណ្ណោះ ។ ម្នាលសារីបុត្ត អ្នកប្រហែលជាមានសេចក្តីយល់ឃើញយ៉ាងនេះថា អង្ករក្នុងសម័យនោះជាអង្ករធំ ៗ ទេដឹង ។ ម្នាលសារីបុត្ត ដំណើរនុ៎ះអ្នកមិនគួរយល់ឃើញយ៉ាងនេះឡើយ ។ ព្រោះថា អង្ករក្នុងកាលឥឡូវនេះ មានទំហំប៉ុនណា ក្នុងកាលនោះក៏មានទំហំប៉ុណ្ណោះដែរ ។ ម្នាលសារីបុត្ត កាលដែលតថាគតនោះអាស្រ័យអាហារបំពោះអង្ករតែ ១ គ្រាប់ កាយក៏ដល់នូវភាពស្គាំងស្គម ហួសប្រមាណ ។ ព្រោះតែអាហារតិចនោះឯង អវយវៈតូចធំរបស់តថាគតក៏ដូចជាថ្នាំងវល្លិឈ្មោះអាសីតិកៈ ឬថ្នាំងវល្លិ៍កាឡា ។ ព្រោះតែអាហារតិចនោះឯង ត្រគាករបស់តថាគត ។ បេ ។ ដូចជាជើងសត្វឧដ្ឋ ។ ព្រោះតែអាហារតិចនោះឯង ឆ្អឹងខ្នងរបស់តថាគត ។ បេ ។ ដូចជាខ្សែដែលគេវេញ ។ ដូចជាបង្កង់នៃសាលាចាស់ ។ បេ ។ ដូចជា

តារកា គម្ភីរេ ។ បេ ។ សេយ្យថាបិ នាម តិត្ត-
កាលាពុ ។ បេ ។ សោ ខោ អហំ សារីបុត្ត ឧទរច្ឆវឹ ។ បេ ។ សោ ខោ អហំ សារីបុត្ត វច្ចំ វា ។ បេ ។ សោ ខោ អហំ សារីបុត្ត ឥមមេវ កាយំ ។ បេ ។ កាយស្មា បបតន្តិ តាយេវប្បាហារតាយ តាយបិ ខោ អហំ សារីបុត្ត ឥរិយាយ តាយ បដិបទាយ តាយ ទុក្ករការិកាយ នាជ្ឈគមំ ឧត្តរិ មនុស្សធម្មា អលមរិយញាណទស្សនវិសេសំ តំ កិស្ស ហេតុ ឥមិស្សាយេវ អរិយាយ បញ្ញាយ អនធិគមា យាយំ បញ្ញា អធិគតា អរិយា និយ្យានិកា និយ្យាតិ តក្ករស្ស សម្មា ទុក្ខក្ខយាយ ។

(១៥៧) សន្តិ បន[១] សារីបុត្ត ឯកេ សមណព្រាហ្មណា ឯវំវាទិនោ ឯវំទិដ្ឋិនោ សំសារេន សុទ្ធីតិ ។ ន ខោ បនេសោ[២] សារីបុត្ត សំសារោ សុលភរូបោ យោ មយា អសំសរិតបុព្វោ ឥមិនា ទីឃេន អទ្ធុនា

១ ឱ.ម. សន្តិ ខោ បន ។ ២ ឱ. ន ខោ បនេសោ ។



ក៏ពេញចិត្តដែលជ្រៅនូវចុះទៅ ។ បេ ។ ដូចជាផ្លែឃ្លោកល្វីង ។ បេ ។ ម្នាលសារីបុត្ត តថាគតនោះគិតថានឹងស្ទាបស្បែកពោះ ។ បេ ។ ម្នាលសារីបុត្ត តថាគតនោះគិតថានឹងបន្ទោបង់នូវវច្ចៈក្តី ។ បេ ។ ម្នាលសារីបុត្ត តថាគតនោះកាលធ្វើកាយនោះឯងឲ្យបានស្រួល ។ បេ ។ ឯរោមទាំងឡាយមានគល់ស្អុយ ក៏ជ្រុះចេញចាកកាយ ព្រោះហេតុតថាគតមានអាហារតិចនោះឯង ។ ម្នាលសារីបុត្ត តថាគតមិនបានត្រាស់ដឹងនូវគុណវិសេសគឺញាណទស្សនៈ ជាគុណធ្វើខ្លួនឲ្យជាអរិយៈ ដ៏ក្រៃលែងជាងធម៌មនុស្សធម៌ ដោយសេចក្ដីប្រតិបត្តិដ៏ប្រសើរ ជាអំពើដែលគេធ្វើតាមបានដោយកម្រនោះៗ ដំណើរនោះព្រោះហេតុអ្វី ព្រោះហេតុ (តថាគត) មិនបានត្រាស់ដឹងនូវបញ្ញាដ៏ប្រសើរនេះឯង ពោលគឺបញ្ញាណាដែលតថាគតបានត្រាស់ដឹងហើយ ពោលគឺបញ្ញានោះ ជាបញ្ញាដ៏ប្រសើរ ជាទីស្រោចស្រង់សត្វ រមែងដឹកនាំសត្វអ្នកធ្វើតាមនោះ ឲ្យអស់ទៅនៃទុក្ខ ដោយប្រពៃបាន ។

(១៥៧) ម្នាលសារីបុត្ត មានសមណព្រាហ្មណ៍ពួកមួយ តែងនិយាយយ៉ាងនេះ តែងយល់យ៉ាងនេះថា សេចក្ដីបរិសុទ្ធកើតមាន ព្រោះសង្សារ គឺការអន្ទោលទៅ (ច្រើនជាតិ) ។ ម្នាលសារីបុត្ត សង្សារណា ដែលតថាគតមិនធ្លាប់អន្ទោលទៅដោយកាលវែងនេះ វៀរលែងតែទេវលោកឈ្មោះសុទ្ធាវាសទាំងឡាយចេញ សង្សារនុ៎ះឯង បុគ្គល

អញ្ញត្រ សុទ្ធាវាសេហិ ទេវេហិ សុទ្ធាវាសេ ចាហំ សារីបុត្ត ទេវេ សំសរេយ្យំ ន យិទំ លោកំ បុន អាគច្ឆេយ្យំ ។

[១៨៨] សន្តិ ខោ បន សារីបុត្ត ឯកេ សមណព្រាហ្មណា ឯវំវាទិនោ ឯវំទិដ្ឋិនោ ឧបបត្តិយា សុទ្ធីតិ ។ ន ខោ បនេសា សារីបុត្ត ឧបបត្តិ សុលភរូបា យា មយា អនុបបន្នបុព្វា ឥមិនា ទីឃេន អទ្ធុនា អញ្ញត្រ សុទ្ធាវាសេហិ ទេវេហិ សុទ្ធាវាសេ ចាហំ សារីបុត្ត ទេវេ ឧបបជ្ជេយ្យំ ន យិទំ លោកំ បុន អាគច្ឆេយ្យំ ។

[១៨៩] សន្តិ ខោ បន សារីបុត្ត ឯកេ សមណព្រាហ្មណា ឯវំវាទិនោ ឯវំទិដ្ឋិនោ អាវាសេន សុទ្ធីតិ ។ ន ខោ បនេសោ សារីបុត្ត អាវាសោ សុលភរូបោ យោ មយា អនាវុដ្ឋបុព្វោ ឥមិនា ទីឃេន អទ្ធុនា អញ្ញត្រ សុទ្ធាវាសេហិ ទេវេហិ សុទ្ធាវាសេ ចាហំ សារីបុត្ត ទេវេ អាវសេយ្យំ[១] ន យិទំ លោកំ បុន អាគច្ឆេយ្យំ ។

១ ឱ. ម. និវសេយ្យំ ។



មិនងាយរកបានឡើយ ម្នាលសារីបុត្ត ព្រោះថា បើតថាគតអន្ទោលទៅកាន់ទេវលោកឈ្មោះសុទ្ធាវាស តថាគតមិនបានមកកាន់កាយលោកនេះទៀតទេ ។

[១៨៨] ម្នាលសារីបុត្ត មានសមណព្រាហ្មណ៍ពួកមួយ តែងនិយាយយ៉ាងនេះ តែងយល់យ៉ាងនេះថា សេចក្តីបរិសុទ្ធិកើតមានព្រោះការកើតឡើង (ច្រើនជាតិ) ។ ម្នាលសារីបុត្ត ការកើតឡើងណា ដែលតថាគត មិនធ្លាប់កើត ដោយកាលវែងនេះ វៀរលែងតែទេវលោកឈ្មោះសុទ្ធាវាសទាំងឡាយចេញ ការកើតឡើងនុ៎ះឯង បុគ្គលមិនងាយរកបានទេ ម្នាលសារីបុត្ត ព្រោះថា បើតថាគតទៅកើតក្នុងទេវលោកឈ្មោះសុទ្ធាវាស តថាគតមិនបានមកកាន់កាយលោកនេះទៀតទេ ។

[១៨៩] ម្នាលសារីបុត្ត មានសមណព្រាហ្មណ៍ពួកមួយ តែងនិយាយយ៉ាងនេះ តែងយល់យ៉ាងនេះថា សេចក្តីបរិសុទ្ធិ កើតមានព្រោះអាវាស គឺការនៅ (ច្រើនកន្លែង) ។ ម្នាលសារីបុត្ត អាវាសណា ដែលតថាគត មិនធ្លាប់នៅហើយ ដោយកាលវែងនេះ វៀរលែងតែសុទ្ធាវាសទេវលោកទាំងឡាយចេញ អាវាសនុ៎ះឯង បុគ្គលមិនងាយរកបានទេ ម្នាលសារីបុត្ត ព្រោះថា បើតថាគតនៅក្នុងសុទ្ធាវាសទេវលោក តថាគតមិនបានមកកាន់កាយលោកនេះទៀតទេ ។

(១៩០) សន្តិ ខោ បន សារីបុត្ត ឯកេ សមណព្រាហ្មណា ឯវំវាទិនោ ឯវំទិដ្ឋិនោ យញ្ញេន សុទ្ធីតិ ។ ន ខោ បនេសោ សារីបុត្ត យញ្ញោ សុលភរូបោ យោ មយា អយិដ្ឋបុព្វោ ឥមិនា ទីឃេន អទ្ធុនា អញ្ញត្រ រញ្ញា វា សតា ខត្តិយេន មុទ្ធាវសិត្តេន ព្រាហ្មណេន វា មហាសាលេន ។

(១៩១) សន្តិ ខោ បន សារីបុត្ត ឯកេ សមណព្រាហ្មណា ឯវំវាទិនោ ឯវំទិដ្ឋិនោ អគ្គិបរិចរិយាយ សុទ្ធីតិ ។ ន ខោ បនេសោ សារីបុត្ត អគ្គិ សុលភរូបោ យោ មយា អបរិចិណ្ណបុព្វោ ឥមិនា ទីឃេន អទ្ធុនា អញ្ញត្រ រញ្ញា វា សតា ខត្តិយេន មុទ្ធាវសិត្តេន ព្រាហ្មណេន វា មហាសាលេន ។

(១៩២) សន្តិ ខោ បន សារីបុត្ត ឯកេ សមណព្រាហ្មណា ឯវំវាទិនោ ឯវំទិដ្ឋិនោ យាវទេវាយំ ភវំ បុរិសោ ទហរោ ហោតិ យុវា សុសុកាឡកេសោ ភទ្រេន យោព្វនេន សមន្នាគតោ បឋមេន វយសា តាវទេវ បរមេន បញ្ញាវេយ្យត្តិយេន



(១៩០) ម្នាលសារីបុត្ត មានសមណព្រាហ្មណ៍ពួកមួយ តែងនិយាយយ៉ាងនេះ តែងយល់យ៉ាងនេះថា សេចក្តីបរិសុទ្ធិ កើតមានព្រោះការបូជាយញ្ញ (ច្រើនយ៉ាង) ។ ម្នាលសារីបុត្ត យញ្ញណាដែលតថាគតកើតជាស្តេចបានមុទ្ធាភិសេកជាក្សត្រក្តី កើតជាព្រាហ្មណ៍មហាសាលក្តី ដោយកាលដ៏វែងនេះ ហើយមិនដែលបានបូជាយញ្ញនុ៎ះឯង បុគ្គលមិនងាយរកបានទេ ។

(១៩១) ម្នាលសារីបុត្ត មានសមណព្រាហ្មណ៍ពួកមួយ តែងនិយាយយ៉ាងនេះ តែងយល់យ៉ាងនេះថា សេចក្តីបរិសុទ្ធិកើតមានព្រោះបម្រើភ្លើង ។ ម្នាលសារីបុត្ត ភ្លើងណាដែលតថាគតកើតជាស្តេចបានមុទ្ធាភិសេកជាក្សត្រក្តី កើតជាព្រាហ្មណ៍មហាសាលក្តី ដោយកាលដ៏វែងនេះ ហើយមិនដែលបានបម្រើភ្លើងនុ៎ះឯង បុគ្គលមិនងាយរកបានទេ ។

(១៩២) ម្នាលសារីបុត្ត មានសមណព្រាហ្មណ៍ពួកមួយ តែងនិយាយយ៉ាងនេះ តែងយល់យ៉ាងនេះថា បុរសដ៏ចំរើននេះ នៅក្មេងកំលោះ មានសក់ខ្មៅល្អ មានវ័យដ៏ចំរើនដោយបឋមវ័យ ដរាបណា បុរសនេះជាអ្នកប្រកបដោយបញ្ញាដ៏ឈ្លាសវៃយ៉ាងសំខាន់ ដរាបនោះ

សមន្នាគតោ ហោតិ យតោ ច ខោ អយំ ភវំ បុរិសោ ជិណ្ណោ ហោតិ វុឌ្ឍោ មហល្លកោ អទ្ធគតោ វយោ អនុប្បត្តោ អាសីតិកោ វា នាវុតិកោ វា វស្សសតិកោ វា ជាតិយា អថ តម្ហា បញ្ញាវេយ្យត្តិយា បរិហាយតីតិ ។ ន ខោ បនេតំ សារីបុត្ត ឯវំ ទដ្ឋព្វំ ។ អហំ ខោ បន សារីបុត្ត ឯតរហិ ជិណ្ណោ វុឌ្ឍោ មហល្លកោ អទ្ធគតោ វយោ អនុប្បត្តោ អាសីតិកោ មេ វយោ វត្តតិ ។ ឥធស្សុ មេ[១] សារីបុត្ត ចត្តារោ សាវកា វស្សសតាយុកា វស្សសតជីវិនោ បរមាយ សតិយា ច គតិយា ច ធិតិយា ច សមន្នាគតា បរមេន ច បញ្ញាវេយ្យត្តិយេន សេយ្យថាបិ សារីបុត្ត ទឡ្ហធម្មោ ធនុគ្គហោ សិក្ខិតោ កតហត្ថោ កតុបាសនោ[២] លហុកេន អសនេន អប្បកសិរេនេវ តិរិយំ តាលច្ឆាយំ អតិបាតេយ្យ ឯវំ អធិមត្តសតិមន្តោ ឯវំ អធិមត្តគតិមន្តោ ឯវំ អធិមត្តធិតិមន្តោ ឯវំ បរមេន បញ្ញាវេយ្យត្តិយេន សមន្នាគតា តេ មំ ចតុន្នំ សតិបដ្ឋានានំ ឧបាទាយុបាទាយ





ក៏ជាកាលណាបុរសដ៏ចំរើននេះ គ្រាំគ្រា ចំរើនវ័យ ចាស់ ដល់ហើយនូវសេចក្ដីចាស់ជរាដោយលំដាប់ មានអាយុ ៨០ ឬ ៩០ ឆ្នាំ ឬ ១០០ ឆ្នាំ រាប់តាំងពីកំណើតមក ក្នុងកាលនោះ បុរសនេះក៏សាបសូន្យចាកបញ្ញាដ៏ឈ្លាសវៃ ។ ម្នាលសារីបុត្ត សេចក្ដីនុ៎ះអ្នកមិនត្រូវយល់យ៉ាងនេះឡើយ ។ ម្នាលសារីបុត្ត ឥឡូវនេះតថាគតគ្រាំគ្រា ចំរើនវ័យ ចាស់ ដល់ហើយនូវសេចក្ដីចាស់ជរាដោយលំដាប់ មានអាយុ ៨០ ឆ្នាំហើយ វ័យរបស់តថាគត ក៏នៅតែប្រព្រឹត្តទៅបាន ។ ម្នាលសារីបុត្ត ក្នុងទីនេះ សាវ័ករបស់តថាគតទាំង ៤ រូប សុទ្ធតែមានអាយុ ១០០ ឆ្នាំ រស់នៅអស់ ១០០ ឆ្នាំ ជាអ្នកប្រកបដោយសតិនិងគតិនិងសេចក្ដីព្យាយាមដ៏ក្រៃលែងផង ដោយបញ្ញាដ៏ឈ្លាសវៃក្រៃលែងផង ម្នាលសារីបុត្ត អ្នកកាន់ធ្នូ [illegible] មានសិក្សាសិល្បៈរួចហើយ មានថ្វីដៃស្ទាត់ក្នុងការបាញ់ [illegible] ស្រាល (ចាញ់) ឲ្យហួសវែងស្រមោលដើមត្នោតទទឹងដោយមិនលំបាកឡើយ យ៉ាងណាមិញ សាវ័កទាំង ៤ មានស្មារតីដ៏ក្រៃលែង ក៏យ៉ាងនោះ មានគតិដ៏ក្រៃលែង ក៏យ៉ាងនោះ មានព្យាយាមដ៏ក្រៃលែង ក៏យ៉ាងនោះ ប្រកបដោយបញ្ញាដ៏ឈ្លាសវៃក្រៃលែង ក៏យ៉ាងនោះ ពួកសាវ័កទាំង ៤ នោះតែងសួរប្រស្នា [illegible]

បញ្ហំ បុច្ឆេយ្យុំ បុដ្ឋោ បុដ្ឋោ ចាហំ តេសំ ព្យាករេយ្យំ ព្យាកតញ្ច មេ ព្យាកតតោ ធារេយ្យុំ ន ច មំ ទុតិយកំ ឧត្តរឹ បដិបុច្ឆេយ្យុំ អញ្ញត្រ អសិតបីតខាយិតសាយិតា អញ្ញត្រ ឧច្ចារបស្សាវកម្មា អញ្ញត្រ និទ្ទាកិលមថប្បដិវិនោទនា អបរិយាទិន្នាយេវស្ស សារីបុត្ត តថាគតស្ស ធម្មទេសនា អបរិយាទិន្នំយេវស្ស តថាគតស្ស ធម្មបទព្យញ្ជនំ អបរិយាទិន្នំយេវស្ស តថាគតស្ស បញ្ហាបដិភានំ ។ អថ មេ តេ ចត្តារោ សាវកា វស្សសតាយុកា វស្សសតជីវិនោ វស្សសតស្ស អច្ចយេន កាលំ ករេយ្យុំ ។ មញ្ចកេន ចេបិ មំ សារីបុត្ត បរិហរិស្សថ នេវត្ថិ តថាគតស្ស បញ្ញាវេយ្យត្តិយស្ស អញ្ញថត្តំ ។ យំ ខោ តំ សារីបុត្ត សម្មា វទមានោ វទេយ្យ អសម្មោហធម្មោ សត្តោ លោកេ ឧប្បន្នោ ពហុជនហិតាយ ពហុជនសុខាយ លោកានុកម្បាយ អត្ថាយ ហិតាយ សុខាយ ទេវមនុស្សានន្តិ ។



នឹងតថាគត ចំណែកតថាគតដែលសាវ័កទាំងនោះសួរហើយ ៗ ក៏ដោះស្រាយនូវប្រស្នានោះ ដល់ពួកសាវ័កទាំងនោះ ឯសាវ័កទាំងនោះ ក៏ចាំទុកនូវប្រស្នា ដែលតថាគតដោះស្រាយហើយ ថាជាប្រស្នាដែលតថាគតដោះស្រាយហើយ មិនបាច់សួរតថាគតឲ្យដាក់របៀបដដែលទៀតឡើយ វៀរលែងតែការស៊ីផឹក ទំពាស៊ីនិងជញ្ជក់ជញ្ជក់ភោជនៈ វៀរលែងតែការបន្ទោបង់នូវឧច្ចារៈនិងបស្សាវៈ វៀរលែងតែការដេកលក់និងការស្រាកស្រាន្តលំបាក ម្នាលសារីបុត្ត ធម្មទេសនារបស់តថាគតមិនចេះអស់ បទនិងព្យញ្ជនៈនៃធម៌របស់តថាគតមិនចេះអស់ បញ្ញាព្យាករណ៍របស់តថាគត ក៏មិនចេះអស់ឡើយ ។ ចំណែកខាងពួកសាវ័កទាំង ៤ របស់តថាគតនោះ មានអាយុ ១០០ ឆ្នាំ រស់នៅបាន ១០០ ឆ្នាំ ហើយធ្វើមរណកាលដោយកាលកន្លងនៃឆ្នាំ ១០០ ។ ម្នាលសារីបុត្ត បើពួកអ្នកជាអ្នកទាំងឡាយនាំយកតថាគតដោយគ្រែតូច ប្រាជ្ញានិងសេចក្ដីឈ្លាសវៃរបស់តថាគត ក៏មិនក្លាយទៅជាដទៃឡើយ ។ ម្នាលសារីបុត្ត អ្នកផងកាលពោលដោយប្រពៃ តែងពោលចំពោះបុគ្គលណាថា សត្វមានធម៌មិនវង្វេងទេ កើតឡើងក្នុងលោក ដើម្បីប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្ដីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីសេចក្ដីចំរើន ដើម្បីប្រយោជន៍ ដើម្បីសេចក្ដីសុខដល់ទេវតានិងមនុស្ស ។

មមេវ តំ សម្មា វទមានោ វទេយ្យ អសម្មោហធម្មោ សត្តោ លោកេ ឧប្បន្នោ ពហុជនហិតាយ ពហុជនសុខាយ លោកានុកម្បាយ អត្ថាយ ហិតាយ សុខាយ ទេវមនុស្សានន្តិ ។

(១៩៣) តេន ខោ បន សមយេន អាយស្មា នាគសមាលោ ភគវតោ បិដ្ឋិតោ ហោតិ ភគវន្តំ វីជយមានោ ។ អថខោ អាយស្មា នាគសមាលោ ភគវន្តំ ឯតទវោច អច្ឆរិយំ ភន្តេ អព្ភុតំ ភន្តេ អបិច មេ ភន្តេ ឥមំ ធម្មបរិយាយំ សុត្វា លោមានិ ហដ្ឋានិ កោ នាមាយំ(១) ភន្តេ ធម្មបរិយាយោតិ ។ តស្មាតិហ ត្វំ នាគសមាល ឥមំ ធម្មបរិយាយំ លោមហំសនបរិយាយោត្វេវ នំ ធារេហីតិ ។ ឥទមវោច ភគវា អត្តមនោ អាយស្មា នាគសមាលោ ភគវតោ ភាសិតំ អភិនន្ទីតិ ។

មហាសីហនាទសុត្តំ ទុតិយំ និដ្ឋិតំ ។

១ ឱ.ម. កោ នាមោ អយំ ។



អ្នកផងកាលពោលដោយប្រពៃ ចំពោះបុគ្គលនោះ គួរពោលចំពោះតថាគតហ្នឹងឯងថា សត្វមានធម៌មិនវង្វេងទេ កើតឡើងក្នុងលោក ដើម្បីប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្ដីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីសេចក្ដីចំរើន ដើម្បីប្រយោជន៍ ដើម្បីសេចក្ដីសុខដល់ទេវតានិងមនុស្សទាំងឡាយ ។

(១៩៣) សម័យនោះឯង ព្រះនាគសមាលៈដ៏មានអាយុ កំពុងពត់ (បក់) ថ្វាយព្រះមានព្រះភាគ អំពីខាងក្រោយព្រះមានព្រះភាគ ។ លំដាប់នោះ ព្រះនាគសមាលៈដ៏មានអាយុ ក្រាបបង្គំទូលចំពោះព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន អស្ចារ្យពេកណាស់ បពិត្រព្រះអង្គដ៏ចំរើន ហេតុនេះ មិនដែលមានសោះ បពិត្រព្រះអង្គដ៏ចំរើន មិនតែប៉ុណ្ណោះ ខ្ញុំព្រះអង្គស្ដាប់ធម្មបរិយាយនេះហើយ ក៏ព្រឺព្រួចរោម បពិត្រព្រះអង្គដ៏ចំរើន ធម្មបរិយាយនេះឈ្មោះដូចម្ដេច ។ ព្រះអង្គត្រាស់ថា ម្នាលនាគសមាលៈ បើដូច្នោះអ្នកចូរចាំទុកនូវធម្មបរិយាយនេះចុះ ឈ្មោះថា លោមហំសនបរិយាយ ។ លុះព្រះមានព្រះភាគត្រាស់ព្រះសូត្រនេះចប់ហើយ នាគសមាលៈដ៏មានអាយុ ក៏មានចិត្តត្រេកអររីករាយ ចំពោះភាសិតរបស់ព្រះមានព្រះភាគ ។

ចប់ មហាសីហនាទសូត្រ ទី ២ ។

## តតិយំ មហាទុក្ខក្ខន្ធសុត្តំ

(១៩៦) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា
សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។
អថខោ សម្ពហុលា ភិក្ខូ បុព្វណ្ហសមយំ និវាសេត្វា
បត្តចីវរមាទាយ សាវត្ថឹ បិណ្ឌាយ បាវិសឹសុ ។ អថខោ
តេសំ ភិក្ខូនំ ឯតទហោសិ អតិប្បគោ ខោ តាវ
សាវត្ថិយំ បិណ្ឌាយ ចរិតុំ យន្នូន មយំ យេន អញ្ញ-
តិត្ថិយានំ បរិព្វាជកានំ អារាមោ តេនុបសង្កមេយ្យា-
មាតិ ។ អថខោ តេ ភិក្ខូ យេន អញ្ញតិត្ថិយានំ
បរិព្វាជកានំ អារាមោ តេនុបសង្កមឹសុ ឧបសង្កមិត្វា
តេហិ អញ្ញតិត្ថិយេហិ បរិព្វាជកេហិ សទ្ធឹ សម្មោទឹសុ
សម្មោទនីយំ កថំ សារណីយំ វីតិសារេត្វា ឯកមន្តំ
និសីទឹសុ ។ ឯកមន្តំ និសិន្នេ ខោ តេ ភិក្ខូ តេ
អញ្ញតិត្ថិយា បរិព្វាជកា ឯតទវោចុំ សមណោ អា-
វុសោ គោតមោ កាមានំ បរិញ្ញំ បញ្ញាបេតិ មយម្បិ

## មហាទុក្ខក្ខន្ធសូត្រ ទី ៣

(១៩៦) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមាន
ព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀប
ក្រុងសាវត្ថី ។ គ្រានោះឯង ភិក្ខុទាំងឡាយច្រើនរូប ស្លៀកស្បង់ប្រ-
ដាប់បាត្រនិងចីវរ ហើយចូលទៅកាន់ក្រុងសាវត្ថី ដើម្បីបិណ្ឌបាតក្នុង
ពេលព្រឹកព្រហាម ។ លំដាប់នោះ ភិក្ខុទាំងនោះបានគិតយ៉ាងនេះ
ថា ការត្រាច់ទៅបិណ្ឌបាតក្នុងក្រុងសាវត្ថី (នេះ) គឺនៅព្រឹកពេកណាស់
បើដូច្នោះ គួរតែពួកយើងឈៀងចូលទៅឯអារាមរបស់ពួកបរិព្វាជកអន្យ-
តិរ្ថិយសិន ។ គ្រានោះឯង ភិក្ខុទាំងនោះ ក៏ចូលទៅឯអារាមរបស់
បរិព្វាជកអន្យតិរ្ថិយ លុះចូលទៅដល់ហើយ ក៏ពោលពាក្យរាក់ទាក់
សំណេះសំណាលទៅនឹងពួកបរិព្វាជកអន្យតិរ្ថិយនោះ លុះបញ្ចប់ពាក្យ
ដែលគួររីករាយ និងពាក្យដែលគួររលឹកហើយ ក៏អង្គុយក្នុងទីដ៏សមគួរ
លុះភិក្ខុទាំងនោះអង្គុយក្នុងទីដ៏សមគួរហើយ ទើបពួកបរិព្វាជកអន្យតិរ្ថិយ
បានពោលពាក្យនេះថា ម្នាលអាវុសោទាំងឡាយ ព្រះសមណគោតម
បញ្ញត្តការកំណត់ដឹង នូវកាមារម្មណ៍ទាំងឡាយ ចំណែកខាងពួកយើង

កាមានំ បរិញ្ញំ បញ្ញបេម សមណោ អាវុសោ គោតមោ រូបានំ បរិញ្ញំ បញ្ញបេតិ មយម្បិ រូបានំ បរិញ្ញំ បញ្ញបេម សមណោ អាវុសោ គោតមោ វេទនានំ បរិញ្ញំ បញ្ញបេតិ មយម្បិ វេទនានំ បរិញ្ញំ បញ្ញបេម ឥធ នោ អាវុសោ កោ វិសេសោ កោ អធិប្បាយោ កឹ នានាករណំ សមណស្ស វា គោតមស្ស អម្ហាកំ វា យទិទំ ធម្មទេសនាយ វា ធម្មទេសនំ អនុសាសនិយា វា អនុសាសនិន្តិ ។ អថ ខោ តេ ភិក្ខូ តេសំ អញ្ញតិត្ថិយានំ បរិព្វាជកានំ ភាសិតំ នេវ អភិនន្ទឹសុ នប្បដិក្កោសឹសុ អនភិនន្ទិត្វា អប្បដិក្កោសិត្វា ឧដ្ឋាយាសនា បក្កមឹសុ ភគវតោ សន្តិកេ ឯតស្ស ភាសិតស្ស អត្ថំ អាជានិស្សាមាតិ ។





ក៏បញ្ញត្តការកំណត់ដឹងនូវកាមារម្មណ៍ទាំងឡាយដែរ ។ ម្នាលអាវុសោទាំងឡាយ ព្រះសមណគោតម បញ្ញត្តការកំណត់ដឹង នូវរូបារម្មណ៍ទាំងឡាយ ចំណែកខាងពួកយើង ក៏បញ្ញត្តការកំណត់ដឹងនូវរូបារម្មណ៍ទាំងឡាយដែរ ។ ម្នាលអាវុសោទាំងឡាយ ព្រះសមណគោតម តែងបញ្ញត្តការកំណត់ដឹងនូវវេទនាទាំងឡាយ ចំណែកខាងពួកយើងក៏បញ្ញត្តការកំណត់ដឹងនូវវេទនាទាំងឡាយដែរ ។ ម្នាលអាវុសោទាំងឡាយ ចុះក្នុងការបញ្ញត្តនេះ ( បើប្រៀបធៀប ) នូវធម៌ទេសនាដោយធម៌ទេសនា ឬ ( ប្រៀបធៀប ) នូវពាក្យប្រៀនប្រដៅ ដោយពាក្យប្រៀនប្រដៅ របស់ព្រះសមណគោតមក្តី របស់ពួកយើងក្តី តើណាមានសេចក្តីវិសេសដាច់ណា មានអធិប្បាយដូចម្តេច មានហេតុផ្សេងគ្នាដូចម្តេច ។ លំដាប់នោះ ភិក្ខុទាំងនោះ មិនបានត្រេកអរ មិនបានហាមឃាត់នូវភាសិតរបស់ពួកបរិព្វាជកអញ្ញតិរ្ថិយនោះឡើយ លុះមិនបានត្រេកអរ មិនបានហាមឃាត់ហើយ ក៏នាំគ្នាក្រោកចាកអាសនៈចៀសចេញទៅ ដោយគិតគ្នាថា ពួកយើងនឹងដឹងច្បាស់នូវសេចក្តីនៃភាសិតនេះ ក្នុងសំណាក់នៃព្រះមានព្រះភាគមិនខាន ។

(១៩៨) អថខោ តេ ភិក្ខូ សាវត្ថិយំ បិណ្ឌាយ ចរិត្វា បច្ឆាភត្តំ បិណ្ឌបាតប្បដិក្កន្តា យេន ភគវា តេនុបសង្កមិំសុ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិំសុ ។ ឯកមន្តំ និសិន្នា ខោ តេ ភិក្ខូ ភគវន្តំ ឯតទវោចុំ ឥធ មយំ ភន្តេ បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ សាវត្ថិំ បិណ្ឌាយ បាវិសិម្ហ តេសំ នោ ភន្តេ អម្ហាកំ ឯតទហោសិ អតិប្បគោ ខោ តាវ សាវត្ថិយំ បិណ្ឌាយ ចរិតុំ យន្នូន មយំ យេន អញ្ញតិត្ថិយានំ បរិព្វាជកានំ អារាមោ តេនុបសង្កមេយ្យាមាតិ ។ អថខោ មយំ ភន្តេ យេន អញ្ញតិត្ថិយានំ បរិព្វាជកានំ អារាមោ តេនុបសង្កមិម្ហ ឧបសង្កមិត្វា តេហិ អញ្ញតិត្ថិយេហិ បរិព្វាជកេហិ សទ្ធិំ សម្មោទិម្ហ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទិម្ហ ។ ឯកមន្តំ និសិន្នេ ខោ អម្ហេ ភន្តេ តេ អញ្ញតិត្ថិយា បរិព្វាជកា ឯតទវោចុំ(១) សមណោ អាវុសោ គោតមោ កាមានំ

១. [illegible]



(១៩៨) គ្រានោះឯង ភិក្ខុទាំងនោះ ក៏ត្រាច់ទៅដើម្បីបិណ្ឌបាត ក្នុងក្រុងសាវត្ថី លុះត្រឡប់ពីបិណ្ឌបាតមកវិញ ក្នុងវេលាក្រោយភត្ត ក៏ចូលទៅគាល់ព្រះមានព្រះភាគ ត្រង់ទីដែលព្រះអង្គគង់នៅ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះភិក្ខុទាំងនោះអង្គុយ ក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គទាំងឡាយស្លៀកស្បង់ប្រដាប់បាត្រនិងចីវរ ហើយចូលទៅកាន់ក្រុងសាវត្ថីដើម្បីបិណ្ឌបាត ក្នុងវេលាព្រឹកព្រហាមនេះ បពិត្រព្រះអង្គដ៏ចំរើន ពួកខ្ញុំព្រះអង្គបានគិតគ្នាយ៉ាងនេះថា ការត្រាច់ទៅដើម្បីបិណ្ឌបាតក្នុងក្រុងសាវត្ថី (នេះ) ក៏នៅព្រឹកពេកណាស់ បើដូច្នោះពួកយើងគួរតែចូលទៅឯអារាមរបស់ពួកបរិព្វាជកអន្យតិរ្ថិយសិនចុះ ។ បពិត្រព្រះអង្គដ៏ចំរើន គ្រានោះឯង ខ្ញុំព្រះអង្គទាំងឡាយក៏ចូលទៅឯអារាមរបស់ពួកបរិព្វាជកអន្យតិរ្ថិយ លុះចូលទៅដល់ហើយក៏ពោលពាក្យរាក់ទាក់ សំណេះសំណាលទៅនឹងបរិព្វាជកអន្យតិរ្ថិយនោះ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររលឹកហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ។ បពិត្រព្រះអង្គដ៏ចំរើន លុះពួកខ្ញុំព្រះអង្គអង្គុយក្នុងទីដ៏សមគួរហើយ ពួកបរិព្វាជកអន្យតិរ្ថិយនោះ បានពោលសេចក្តីនេះថា ម្នាលអាវុសោទាំងឡាយ ព្រះសមណគោតម

បរិញ្ញំ បញ្ញាបេតិ មយម្បិ កាមានំ បរិញ្ញំ បញ្ញាបេម សមណោ អាវុសោ គោតមោ រូបានំ បរិញ្ញំ បញ្ញាបេតិ មយម្បិ រូបានំ បរិញ្ញំ បញ្ញាបេម សមណោ អាវុសោ គោតមោ វេទនានំ បរិញ្ញំ បញ្ញាបេតិ មយម្បិ វេទនានំ បរិញ្ញំ បញ្ញាបេម ឥធ នោ អាវុសោ កោ វិសេសោ កោ អធិប្បាយោ កិំ នានាករណំ សមណស្ស វា គោតមស្ស អម្ហាកំ វា យទិទំ ធម្មទេសនាយ វា ធម្មទេសនំ អនុសាសនិយា វា អនុសាសនិន្តិ ។ អថខោ តេ ភិក្ខូ តេសំ អញ្ញតិត្ថិយានំ បរិព្វាជកានំ ភាសិតំ នេវ អភិនន្ទឹសុ នប្បដិក្កោសឹសុ អនភិនន្ទិត្វា អប្បដិក្កោសិត្វា ឧដ្ឋាយាសនា បក្កមឹសុ ភគវតោ សន្តិកេ ឯតស្ស ភាសិតស្ស អត្ថំ អាជានិស្សាមាតិ ។



បញ្ញត្តការកំណត់ដឹងនូវចំណែកកាមារម្មណ៍ទាំងឡាយ ចំណែកខាងពួកយើងក៏បញ្ញត្តការកំណត់ដឹងនូវកាមារម្មណ៍ទាំងឡាយដែរ ។ ម្នាលអាវុសោទាំងឡាយ ព្រះសមណគោតម បញ្ញត្តការកំណត់ដឹងនូវរូបារម្មណ៍ទាំងឡាយ ចំណែកខាងពួកយើង ក៏បញ្ញត្តការកំណត់ដឹងនូវរូបារម្មណ៍ទាំងឡាយដែរ ។ ម្នាលអាវុសោទាំងឡាយ ព្រះសមណគោតម បញ្ញត្តការកំណត់ដឹងនូវវេទនាទាំងឡាយ ចំណែកខាងពួកយើង ក៏បញ្ញត្តការកំណត់ដឹងនូវវេទនាទាំងឡាយដែរ ។ ម្នាលអាវុសោទាំងឡាយ ចុះការបញ្ញត្តនេះ (បើប្រៀបធៀប) ធម្មទេសនា ដោយធម្មទេសនា (ប្រៀបធៀប) ពាក្យប្រៀនប្រដៅ ដោយពាក្យប្រៀនប្រដៅ របស់ព្រះសមណគោតមក្តី របស់ពួកយើងក្តី តើណាមានសេចក្តីវិសេសជាងណា មានសេចក្តីអធិប្បាយដូចម្តេច មានហេតុផ្សេងគ្នាដូចម្តេច ។ បពិត្រព្រះអង្គដ៏ចំរើន លំដាប់នោះ ខ្ញុំព្រះអង្គទាំងឡាយមិនបានត្រេកអរ មិនបានហាមឃាត់ភាសិតរបស់ពួកបរិព្វាជកអន្យតិរ្ថិយនោះឡើយ លុះមិនបានត្រេកអរ មិនបានហាមឃាត់ហើយ ក៏នាំគ្នាក្រោកចាកអាសនៈចៀសចេញមកដោយគិតគ្នាថា ពួកយើងនឹងដឹងច្បាស់ នូវសេចក្តីនៃភាសិតនេះ ក្នុងសំណាក់នៃព្រះមានព្រះភាគមិនខាន ។

(១៩៦) ឯវំវាទិនោ ភិក្ខវេ អញ្ញតិត្ថិយា បរិព្វាជកា ឯវមស្សុ វចនីយា កោ បនាវុសោ កាមានំ អស្សាទោ កោ អាទីនវោ កឹ និស្សរណំ កោ រូបានំ អស្សាទោ កោ អាទីនវោ កឹ និស្សរណំ កោ វេទនានំ អស្សាទោ កោ អាទីនវោ កឹ និស្សរណន្តិ ។ ឯវំ បុដ្ឋា ភិក្ខវេ អញ្ញតិត្ថិយា បរិព្វាជកា ន ចេវ សម្បាយិស្សន្តិ ឧត្តរិញ្ច វិឃាតំ អាបជ្ជិស្សន្តិ តំ កិស្ស ហេតុ យថាតំ ភិក្ខវេ អវិសយស្មឹ ។ នាហន្តំ ភិក្ខវេ បស្សាមិ សទេវកេ លោកេ សមារកេ សព្រហ្មកេ សស្សមណព្រាហ្មណិយា បជាយ សទេវមនុស្សាយ យោ ឥមេសំ បញ្ហានំ វេយ្យាករណេន ចិត្តំ អារាធេយ្យ អញ្ញត្រ តថាគតេន វា តថាគតសាវកេន វា ឥតោ វា បន សុត្វា ។



(១៩៦) ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ កាលបើពួកបរិព្វាជកអន្យតិរ្ថិយសួរយ៉ាងនេះ ពួកអ្នក ត្រូវសួរយ៉ាងនេះវិញថា ម្នាលអាវុសោទាំងឡាយ ចុះអ្វីជាតំរេករបស់កាមទាំងឡាយ អ្វីជាទោសរបស់កាមទាំងឡាយ អ្វីជាគ្រឿងរលាស់ចេញនូវកាមទាំងឡាយ អ្វីជាតំរេករបស់រូបទាំងឡាយ អ្វីជាទោសរបស់រូបទាំងឡាយ អ្វីជាគ្រឿងរលាស់ចេញនូវរូបទាំងឡាយ អ្វីជាតំរេករបស់វេទនាទាំងឡាយ អ្វីជាទោសរបស់វេទនាទាំងឡាយ អ្វីជាគ្រឿងរលាស់ចេញនូវវេទនាទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ពួកបរិព្វាជកអន្យតិរ្ថិយ កាលបើពួកទាំងឡាយសួរយ៉ាងនេះហើយ មុខជាមិនអាចនឹងដោះស្រាយរួចផង នឹងដល់នូវសេចក្តីចង្អៀតចង្អល់ចិត្តជាយ៉ាងក្រៃពេកផង ។ ដំណើរនោះព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុថា (ប្រស្នានោះ) មិនមែនជាវិស័យ (របស់ខ្លួន) ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលណានឹងញុំាងចិត្តឲ្យត្រេកអរ ដោយវេយ្យាករណ៍នៃបញ្ហានេះបាន តថាគតពិចារណារកបុគ្គលនោះ ក្នុងលោកនេះព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេព នឹងមនុស្សដ៏សេស មិនឃើញមានឡើយ វៀរលែងតែតថាគត ឬសាវករបស់តថាគត ឬក៏បុគ្គលដែលបានស្តាប់អំពីសាសនានេះ ។

(១៩៧) កោ ច ភិក្ខវេ កាមានំ អស្សាទោ ។ បញ្ចិមេ ភិក្ខវេ កាមគុណា កតមេ បញ្ច ចក្ខុវិញ្ញេយ្យា រូបា ឥដ្ឋា កន្តា មនាបា បិយរូបា កាមូបសញ្ហិតា រជនីយា សោតវិញ្ញេយ្យា សទ្ទា... ឃានវិញ្ញេយ្យា គន្ធា... ជិវ្ហាវិញ្ញេយ្យា រសា... កាយវិញ្ញេយ្យា ផោដ្ឋព្វា ឥដ្ឋា កន្តា មនាបា បិយរូបា កាមូបសញ្ហិតា រជនីយា ឥមេ ខោ ភិក្ខវេ បញ្ច កាមគុណា ។ យំ ខោ ភិក្ខវេ ឥមេ បញ្ច កាមគុណេ បដិច្ច ឧប្បជ្ជតិ សុខំ សោមនស្សំ អយំ កាមានំ អស្សាទោ ។

(១៩៨) កោ ច ភិក្ខវេ កាមានំ អាទីនវោ ។ ឥធ ភិក្ខវេ កុលបុត្តោ យេន សិប្បដ្ឋានេន[១] ជីវិកំ កប្បេតិ យទិ មុទ្ទាយ យទិ គណនាយ

១ ឱ.ម. សិប្បដ្ឋានេន ។



(១៩៧) ម្នាលភិក្ខុទាំងឡាយ ចុះអ្វីជាតម្រេករបស់កាមទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ កាមគុណ (ចំណង់កាម) នេះ មាន ៥ ប្រការ កាមគុណ ៥ ប្រការតើអ្វីខ្លះ គឺរូបទាំងឡាយដែលគប្បីដឹងដោយភ្នែក ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីពេញចិត្ត ជាទីស្រឡាញ់ ត្រូវតាមចំណង់ ជាទីត្រេកត្រអាល ១ សំឡេងទាំងឡាយដែលគប្បីដឹងបានដោយត្រចៀក...១ ក្លិនទាំងឡាយដែលគប្បីដឹងបានដោយច្រមុះ...១ រសទាំងឡាយដែលគប្បីដឹងបានដោយអណ្តាត...១ ផ្សព្វទាំងឡាយដែលគប្បីដឹងបានដោយកាយ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីពេញចិត្ត ជាទីស្រឡាញ់ ត្រូវតាមចំណង់ ជាទីត្រេកត្រអាល ១ ម្នាលភិក្ខុទាំងឡាយ នេះឯងហៅថា កាមគុណ ៥ ប្រការ ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីសុខសោមនស្ស កើតឡើងព្រោះអាស្រ័យកាមគុណទាំង ៥ ប្រការនេះ នេះឯងជាតម្រេករបស់កាមទាំងឡាយ ។

(១៩៨) ម្នាលភិក្ខុទាំងឡាយ ចុះអ្វីជាទោសរបស់កាមទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ កុលបុត្តក្នុងលោកនេះ ចិញ្ចឹមជីវិតដោយសេចក្តីប្រឹងប្រែង ដោយសិល្បសាស្ត្រណាមួយ ទោះបីដោយការគប់ប្រាម

យទិ សង្ខានេន យទិ កសិយា យទិ វណិជ្ជាយ យទិ គោរក្ខេន យទិ ឥស្សត្ថេន យទិ រាជពោរិសេន យទិ សិប្បញ្ញតរេន សីតស្ស បុរក្ខតោ ឧណ្ហស្ស បុរក្ខតោ ឌំសមកសវាតាតបសរីសបសម្ផស្សេហិ រិស្សមានោ ខុប្បិបាសាយ មិយ្យមានោ អយម្បិ ភិក្ខវេ កាមានំ អាទីនវោ សន្ទិដ្ឋិកោ ទុក្ខក្ខន្ធោ កាមហេតុ កាមនិទានំ កាមាធិករណំ កាមានមេវ ហេតុ ។ តស្ស ចេ ភិក្ខវេ កុលបុត្តស្ស ឯវំ ឧដ្ឋហតោ ឃដ-តោ វាយមតោ តេ ភោគា នាភិនិប្ផជ្ជន្តិ សោ សោចតិ កិលមតិ បរិទេវតិ ឧរត្តាឡិំ កន្ទតិ សម្មោហំ អាបជ្ជតិ





ដៃទទេក្តី ដោយការរាប់លេខពួនក្តី ដោយការរាប់ប្រមូលក្តី(១) ដោយកសិកម្មក្តី ដោយវាណិជ្ជកម្មក្តី ដោយគោរក្ខកម្មក្តី ដោយការៈនៃខ្លួនជាអ្នកកាន់អាវុធក្តី ដោយការៈនៃខ្លួនជារាជបុរសក្តី ដោយសិល្បសាស្ត្រណាមួយក្តី កុលបុត្តដែលអាស្រ័យនូវការចិញ្ចឹមជីវិត ដោយការរាប់ម្រាមដៃទទេជាដើមនោះ តែងមានត្រជាក់បៀតបៀន មានក្តៅបៀតបៀន ប៉ះពាល់ដោយសម្ផស្សនៃរបោមមូសខ្យល់កំដៅថ្ងៃ និងពស់តូច ពស់ធំ ស្លាប់ខ្លួនព្រោះសេចក្តីស្រេកឃ្លាន ម្នាលភិក្ខុទាំងឡាយ នេះឯងជាទោសរបស់កាមទាំងឡាយ ដែលបុគ្គលគប្បីឃើញជាក់ស្តែង ជាគំនរនៃទុក្ខ មានកាមជាហេតុ មានកាមជាគ្រឿងប្រគល់ឲ្យនូវផល មានកាមជាគ្រឿងផ្តួចផ្តើម ជាបច្ច័យនៃកាមទាំងឡាយមែនពិត ។ ម្នាលភិក្ខុទាំងឡាយ កាលបើកុលបុត្តនោះ ប្រឹងប្រែងខ្នះខ្នែងព្យាយាមយ៉ាងនេះហើយ ភោគៈទាំងឡាយនោះ ក៏មិនបានសម្រេច កុលបុត្តនោះតែងក្រៀមក្រំចិត្ត លំបាក ខ្សឹកខ្សួល គក់ទ្រូង ព្រហាយំ ដល់នូវសេចក្តីវង្វេងជា

១ អដ្ឋកថា ពន្យល់ថា ដូចជារមិលមើលស្រែ ហើយកត់ថាក្នុងស្រែនេះប្រហែលជាបានស្រូវប៉ុណ្ណោះ ឬរមិលមើលដើមឈើ ហើយរាប់ស្មានថា ដើមឈើនេះប្រហែលជាមានផ្លែប៉ុណ្ណោះ ។

មោឃំ វត មេ ឧដ្ឋានំ អផលោ វត មេ វាយាមោតិ អយម្បិ ភិក្ខវេ កាមានំ អាទីនវោ សន្ទិដ្ឋិកោ ទុក្ខក្ខន្ធោ កាមហេតុ កាមនិទានំ កាមាធិករណំ កាមានមេវ ហេតុ ។ តស្ស ចេ ភិក្ខវេ កុលបុត្តស្ស ឯវំ ឧដ្ឋហតោ ឃដតោ វាយមតោ តេ ភោគា អភិនិប្ផជ្ជន្តិ សោ តេសំ ភោគានំ អារក្ខាធិករណំ ទុក្ខំ ទោមនស្សំ បដិសំវេទេតិ កិន្តិ តេ(១) ភោគេ នេវ រាជានោ ហរេយ្យុំ ន ចោរា ហរេយ្យុំ ន អគ្គិ ឌហេយ្យ ន ឧទកំ វហេយ្យ ន អប្បិយា ទាយាទា ហរេយ្យុន្តិ ។ តស្ស ឯវំ អារក្ខតោ គោបយតោ តេ ភោគេ រាជានោ វា ហរន្តិ ចោរា វា ហរន្តិ អគ្គិ វា ឌហតិ ឧទកំ វា វហតិ អប្បិយា ទាយាទា វា ហរន្តិ សោ សោចតិ កិលមតិ បរិទេវតិ ឧរត្តាឡឹ កន្ទតិ សម្មោហំ អាបជ្ជតិ យម្បិ មេ អហោសិ តម្បិ

១ ម.ប. មេ ។



« សេចក្តីប្រឹងប្រែងរបស់អញឥតកើតផលសោះ « សេចក្តីព្យាយាមរបស់អញឥតផលសោះ ។ ម្នាលភិក្ខុទាំងឡាយ នេះឯងជាទោសរបស់កាមទាំងឡាយ ដែលបុគ្គលគប្បីឃើញចាស់ស្តែង ជាគំនរនៃទុក្ខ មានកាមជាហេតុ មានកាមជាគ្រឿងប្រគល់ឲ្យនូវផល មានកាមជាគ្រឿងផ្តួចផ្តើម ជាបច្ច័យនៃកាមទាំងឡាយមែនពិត ។ ម្នាលភិក្ខុទាំងឡាយ កាលបើកុលបុត្តនោះ ប្រឹងប្រែងខ្នះខ្នែងព្យាយាម យ៉ាងនេះហើយ ភោគៈទាំងឡាយនោះក៏សម្រេច កុលបុត្តនោះតែងទទួល នូវសេចក្តីទុក្ខទោមនស្ស ព្រោះហេតុនៃការរក្សានូវភោគៈទាំងឡាយនោះថា ធ្វើដូចម្តេចហ្ន៎ កុំឲ្យព្រះរាជាទាំងឡាយ នាំយកភោគៈទាំងឡាយនោះទៅបាន កុំឲ្យចោរទាំងឡាយលួចយកបាន កុំឲ្យភ្លើងឆេះបាន កុំឲ្យទឹកបណ្តែតទៅបាន កុំឲ្យអ្នកទទួលមត៌កទាំងឡាយ ដែលមិនជាទីស្រឡាញ់នាំយកទៅបាន ។ កាលកុលបុត្តនោះ ចាំរក្សាគ្រប់គ្រងយ៉ាងនេះ ក៏ស្រាប់តែព្រះរាជាទាំងឡាយ រឹបយកនូវភោគៈទាំងឡាយនោះទៅក្តី ពួកចោរទាំងឡាយលួចយកទៅក្តី ភ្លើងឆេះទៅក្តី ទឹកបណ្តែតទៅក្តី អ្នកទទួលមត៌កទាំងឡាយ ដែលមិនជាទីស្រឡាញ់នាំយកទៅក្តី កុលបុត្តនោះតែងក្រៀមក្រំចិត្ត លំបាកខ្សឹកខ្សួល គក់ទ្រូង ទ្រហោយំ ដល់នូវសេចក្តីវង្វេងថា ទ្រព្យណាបានកើតមានហើយដល់គាត់អញ ឥឡូវនេះទ្រព្យនោះឯង ក្រឡប់ជា

ខោ ។ អយម្បិ ភិក្ខវេ កាមានំ អាទីនវោ សន្ទិដ្ឋិកោ ទុក្ខក្ខន្ធោ កាមហេតុ កាមនិទានំ កាមាធិករណំ កាមានមេវ ហេតុ ។ បុន ចបរំ ភិក្ខវេ កាមហេតុ កាមនិទានំ កាមាធិករណំ កាមានមេវ ហេតុ រាជានោបិ រាជូហិ វិវទន្តិ ខត្តិយាបិ ខត្តិយេហិ វិវទន្តិ ព្រាហ្មណាបិ ព្រាហ្មណេហិ វិវទន្តិ គហបតីបិ គហបតីហិ វិវទន្តិ មាតាបិ បុត្តេន វិវទតិ បុត្តោបិ មាតរា វិវទតិ បិតាបិ បុត្តេន វិវទតិ បុត្តោបិ បិតរា វិវទតិ ភាតាបិ ភាតរា វិវទតិ បុត្តោបិ បិតរា វិវទតិ ភាតាបិ ភាតរា វិវទតិ ភាតាបិ ភគិនិយា វិវទតិ ភគិនីបិ ភាតរា វិវទតិ សហាយោបិ សហាយេន វិវទតិ តេ តត្ថ កលហវិគ្គហវិវាទាបន្នា អញ្ញមញ្ញំ បាណីហិបិ ឧបក្កមន្តិ លេឌ្ឌូហិបិ ឧបក្កមន្តិ ទណ្ឌេហិបិ ឧបក្កមន្តិ សត្ថេហិបិ ឧបក្កមន្តិ តេ តត្ថ មរណម្បិ និគច្ឆន្តិ



មិនមានផលហ្ន៎ ព្យាយាមរបស់អញ ម្នាលភិក្ខុទាំងឡាយ នេះឯងជាទោសរបស់កាមទាំងឡាយ ដែលបុគ្គលគប្បីឃើញចំពោះខ្លួន ជាគំនរនៃទុក្ខ មានកាមជាហេតុ មានកាមជាគ្រឿងប្រគល់ឲ្យនូវផល មានកាមជាគ្រឿងផ្ដួចផ្ដើម ជាបច្ច័យនៃកាមទាំងឡាយមែនពិត ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ព្រោះតែមានកាមជាហេតុ មានកាមជាគ្រឿងប្រគល់ឲ្យនូវផល មានកាមជាគ្រឿងផ្ដួចផ្ដើម ជាបច្ច័យនៃកាមទាំងឡាយមែនពិត បានជាព្រះរាជាទាំងឡាយទាស់ទែងគ្នានឹងព្រះរាជាទាំងឡាយខ្លះ ក្សត្រទាំងឡាយ ទាស់ទែងគ្នានឹងក្សត្រទាំងឡាយខ្លះ ព្រាហ្មណ៍ទាំងឡាយទាស់ទែងគ្នានឹងព្រាហ្មណ៍ទាំងឡាយខ្លះ គហបតីទាំងឡាយទាស់ទែងគ្នានឹងគហបតីទាំងឡាយខ្លះ មាតាទាស់ទែងនឹងបុត្រខ្លះ បុត្រទាស់ទែងនឹងមាតាខ្លះ បិតាទាស់ទែងនឹងបុត្រខ្លះ បុត្រទាស់ទែងនឹងបិតាខ្លះ បងប្អូនប្រុសទាស់ទែងនឹងបងប្អូនប្រុសខ្លះ បងប្អូនប្រុសទាស់ទែងនឹងបងប្អូនស្រីខ្លះ បងប្អូនស្រីទាស់ទែងនឹងបងប្អូនប្រុសខ្លះ សំឡាញ់ទាស់ទែងនឹងសំឡាញ់ខ្លះ ពួកមនុស្សទាំងនោះ ក៏ដល់នូវសេចក្ដីឈ្លោះប្រកែកប្រកាន់ខុស ទាស់ទែងគ្នា ក្នុងទីនោះហើយ ប្រហារគ្នាទៅវិញទៅមកដោយដៃខ្លះ ប្រហារគ្នាដោយដុំដីខ្លះ ប្រហារគ្នាដោយដំបងខ្លះ ប្រហារគ្នាដោយគ្រឿងសស្ត្រាខ្លះ ជនទាំងនោះក៏ដល់នូវសេចក្ដីស្លាប់ក្នុងទីនោះខ្លះ

មរណមត្តម្បិ ទុក្ខំ អយម្បិ ភិក្ខវេ កាមានំ អាទីនវោ សន្ទិដ្ឋិកោ ទុក្ខក្ខន្ធោ កាមហេតុ កាមនិទានំ កាមាធិករណំ កាមានមេវ ហេតុ ។ បុន ចបរំ ភិក្ខវេ កាមហេតុ កាមនិទានំ កាមាធិករណំ កាមានមេវ ហេតុ អសិចម្មំ គហេត្វា ធនុកលាបំ សន្នយ្ហិត្វា ឧភតោ ព្យូឡ្ហំ[១] សង្គាមំ បក្ខន្ទន្តិ ឧសូសុបិ ខិប្បមានេសុ សត្តីសុបិ ខិប្បមានាសុ អសីសុបិ វិជ្ជោតលន្តេសុ តេ តត្ថ ឧសូហិបិ វិជ្ឈន្តិ សត្តិយាបិ វិជ្ឈន្តិ អសិនាបិ សីសំ ឆិន្ទន្តិ តេ តត្ថ មរណម្បិ និគច្ឆន្តិ មរណមត្តម្បិ ទុក្ខំ អយម្បិ ភិក្ខវេ កាមានំ អាទីនវោ សន្ទិដ្ឋិកោ ទុក្ខក្ខន្ធោ កាមហេតុ កាមនិទានំ កាមាធិករណំ កាមានមេវ ហេតុ ។ បុន ចបរំ ភិក្ខវេ កាមហេតុ កាមនិទានំ

១ ឱ. វិយូឡ្ហំ ។



ដល់នូវសេចក្ដីទុក្ខ ស្មើនឹងស្លាប់ខ្លះ ម្នាលភិក្ខុទាំងឡាយ នេះឯងជាទោសរបស់កាមទាំងឡាយ ដែលបុគ្គលគប្បីឃើញច្បាស់ក្នុង ជាគំនរនៃទុក្ខ មានកាមជាហេតុ មានកាមជាគ្រឿងប្រគល់ឲ្យនូវផល មានកាមជាគ្រឿងផ្ដួចផ្ដើម ជាបច្ច័យនៃកាមទាំងឡាយមែនពិត ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ព្រោះតែមានកាមជាហេតុ មានកាមជាគ្រឿងប្រគល់ឲ្យនូវផល មានកាមជាគ្រឿងផ្ដួចផ្ដើម ជាបច្ច័យនៃកាមទាំងឡាយ បានជាមនុស្សទាំងឡាយកាន់នូវដាវនិងខែល កាន់ធ្នូសៀតបំពង់ព្រួញ ចូលទៅកាន់សង្គ្រាម ដែលកើតជាក្បួនទ័ពមកទាំងសងខាង កាលដែលគេបាញ់ព្រួញមកក្ដី កាលដែលគេពួយលំពែងមកក្ដី កាលដែលគេឆាដាវម៉្យាងក្ដី មនុស្សទាំងឡាយនោះបាញ់គ្នាដោយព្រួញខ្លះ ចាក់គ្នាដោយលំពែងខ្លះ កាប់ក្បាលគ្នាដោយដាវខ្លះ ក្នុងសង្គ្រាមនោះ មនុស្សទាំងឡាយនោះក៏ដល់នូវសេចក្ដីស្លាប់ខ្លះ ដល់នូវសេចក្ដីទុក្ខស្មើនឹងស្លាប់ខ្លះ ក្នុងសង្គ្រាមនោះ ម្នាលភិក្ខុទាំងឡាយ នេះឯងជាទោសរបស់កាមទាំងឡាយ ដែលបុគ្គលគប្បីឃើញច្បាស់ក្នុង ជាគំនរនៃទុក្ខ មានកាមជាហេតុ មានកាមជាគ្រឿងប្រគល់ឲ្យនូវផល មានកាមជាគ្រឿងផ្ដួចផ្ដើម ជាបច្ច័យនៃកាមទាំងឡាយមែនពិត ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ព្រោះតែមានកាមជាហេតុ មានកាមជាគ្រឿងប្រគល់ឲ្យនូវផល

កាមាធិករណំ កាមានមេវ ហេតុ អសិចម្មំ គហេត្វា ធនុកលាបំ សន្នយ្ហិត្វា អដ្ដាវលេបនា(១) ឧបកា-រិយោ បក្ខន្ទន្តិ ឧសូសុបិ ខិប្បមានេសុ សត្តី-សុបិ ខិប្បមានាសុ អសីសុបិ វិជ្ជោតលន្តេសុ តេ តត្ថ ឧសុនាបិ វិជ្ឈន្តិ សត្តិយាបិ វិជ្ឈន្តិ ឆកណាដិយាបិ(២) ឱសិញ្ចន្តិ អភិវគ្គេនបិ ឱមទ្ទន្តិ អសិនាបិ សីសំ ឆិន្ទន្តិ តេ តត្ថ មរណម្បិ និគច្ឆន្តិ មរណមត្តម្បិ ទុក្ខំ អយម្បិ ភិក្ខវេ កាមានំ អាទីនវោ សន្ទិដ្ឋិកោ ទុក្ខក្ខន្ធោ កាមហេតុ កាមនិទានំ កាមាធិករណំ កាមានមេវ ហេតុ ។ បុន ចបរំ ភិក្ខវេ កាមហេតុ កាមនិទានំ កាមាធិករណំ កាមានមេវ ហេតុ សន្ធិម្បិ ឆិន្ទន្តិ និល្លោបម្បិ ហរន្តិ ឯកាគារិកម្បិ ករោន្តិ បរិបន្ថេបិ តិដ្ឋន្តិ បរទារម្បិ គច្ឆន្តិ តមេនំ រាជានោ គហេត្វា វិវិធា កម្មការណា(៣) ការេន្តិ(៤)

១ ឱ. អដ្ដាវលេបនា ។ ២ ឱ. បក្កដ្ឋិយា ។ ៣ ឱ. វិធា កម្មករណា ។ ៤ ឱ. ករេន្តិ ។



មានកាមជាគ្រឿងផ្តួចផ្តើម ជាបច្ច័យនៃកាមទាំងឡាយមែនពិត ពួកម-នុស្សទាំងឡាយនោះកាន់ដាវនិងខែល កាន់ធ្នូសៀតបំពង់ព្រួញចូលទៅកាន់បន្ទាយ ដែលលាបបូកដោយបាយអ កាលដែលគេបាញ់ព្រួញមកក្តី កាលដែលគេចួយលំពែងមកក្តី កាលដែលគេគ្រវីដាវក្តី មនុស្សទាំងនោះ ក៏បាញ់គ្នាដោយព្រួញខ្លះ ចាក់គ្នាដោយលំពែងខ្លះ ចាប់សាចដាក់គ្នាដោយអាចម៍គោក្តៅខ្លះ ញាំញីគ្នាដោយគោសដែកខ្លះ កាប់ក្បាលគ្នាដោយដាវខ្លះ ក្នុងបន្ទាយនោះ មនុស្សទាំងនោះដល់នូវសេចក្តីស្លាប់ខ្លះ ដល់នូវសេចក្តីទុក្ខស្ទើរតែនឹងស្លាប់ខ្លះ ក្នុងបន្ទាយនោះ ម្នាលភិក្ខុទាំងឡាយ នេះឯងជាទោស របស់កាមទាំងឡាយ ដែលបុគ្គលគប្បីឃើញច្បាស់ដោយខ្លួនឯងជាគំនរនៃទុក្ខ មានកាមជាហេតុ មានកាមជាគ្រឿងប្រគល់ឲ្យនូវផល មានកាមជាគ្រឿងផ្តួចផ្តើម ជាបច្ច័យនៃកាមទាំងឡាយមែនពិត ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ព្រោះតែមានកាមជាហេតុ មានកាមជាគ្រឿងប្រគល់ឲ្យនូវផល មានកាមជាគ្រឿងផ្តួចផ្តើម ជាបច្ច័យនៃកាមទាំងឡាយមែនពិត មនុស្សទាំងឡាយក៏កាត់ទំលុះផ្ទះខ្លះ ប្លន់ខ្លះ ក៏ហែងយកទ្រព្យក្នុងផ្ទះមួយៗខ្លះ ឈរស្កាត់ប្លន់ផ្លូវខ្លះ គប់រកភរិយារបស់អ្នកដទៃខ្លះ ។ ព្រះរាជាទាំងឡាយចាប់មនុស្សទាំងនោះបានហើយ ត្រាស់បង្គាប់ឲ្យធ្វើកម្មករណ៍ទាំងឡាយមានប្រការផ្សេងៗ គឺឲ្យគេវាយ

កសាហិបិ តាឡេន្តិ វេត្តេហិបិ តាឡេន្តិ អឌ្ឍទណ្ឌកេហិ-

បិ តាឡេន្តិ ហត្ថម្បិ ឆិន្ទន្តិ បាទម្បិ ឆិន្ទន្តិ ហត្ថបា-

ទម្បិ ឆិន្ទន្តិ កណ្ណម្បិ ឆិន្ទន្តិ នាសម្បិ ឆិន្ទន្តិ កណ្ណនា-

សម្បិ ឆិន្ទន្តិ ពិលង្គថាលិកម្បិ ករោន្តិ សង្ខមុណ្ឌិកម្បិ

ករោន្តិ រាហុមុខម្បិ ករោន្តិ ជោតិមាលិកម្បិ ករោន្តិ

ហត្ថបជ្ជោតិកម្បិ ករោន្តិ ឯរកវត្តិកម្បិ ករោន្តិ



រំពាត់ខ្លះ វាយនឹងផ្ដៅខ្លះ វាយនឹងដំបងខ្លីខ្លះ កាត់ដៃខ្លះ កាត់ជើងខ្លះ កាត់ទាំងដៃទាំងជើងខ្លះ កាត់ស្លឹកត្រចៀកខ្លះ កាត់ច្រមុះខ្លះ កាត់ទាំងស្លឹកត្រចៀកទាំងច្រមុះខ្លះ ធ្វើពិលង្គថាលិកកម្ម គឺអំពើដែលគេធ្វើឲ្យដូចជាឆ្នាំងដាក់ទឹកជ្រក់[១] ខ្លះ ធ្វើនូវសង្ខមុណ្ឌកកម្ម គឺអំពើដែលគេធ្វើក្បាលឲ្យស្រឡីងដូចជាសម្បកស័ង្ខ[២] ខ្លះ ធ្វើនូវរាហុមុខកម្ម គឺអំពើដែលគេធ្វើមាត់ឲ្យដូចជាមាត់រាហូ[៣] ខ្លះ ធ្វើនូវជោតិមាលិកកម្ម គឺអំពើដែលធ្វើខ្លួនមនុស្សឲ្យដូចជាផ្កាភ្លើង[៤] ខ្លះ ធ្វើនូវហត្ថបជ្ជោតិកកម្ម គឺអំពើដែលគេដុតដៃ[៥] ខ្លះ ធ្វើនូវឯរកវត្តិកកម្ម គឺអំពើដែលគេធ្វើ…

---

១ អដ្ឋកថា ថា បានដល់អំពើដែលគេបកស្បែកក្បាល ហើយយកដុំដែកក្តៅៗដាក់លើលលាដ៍ក្បាលនោះ ខួរក្នុងក្បាលក៏ពុះឡើង ។ ២ អំពើដែលគេរៀវស្បែកតាំងអំពីបបូរមាត់ខាងលើហូតដល់គល់ត្រចៀកទាំងពីរ រៀងមកដល់កញ្ចឹងក ហើយយកសក់រុំនឹងកំណាត់ឈើរួចទាញកន្ត្រាក់ឲ្យរបើកស្បែកក្បាលចេញ ហើយយកខ្សាច់គ្រើមៗដុសលលាដ៍ក្បាលឲ្យស្រឡីងរួចលាងទឹកឲ្យស្អាត ឲ្យសល់តែឆ្អឹងលលាដ៍ដែលសដូចជាសម្បកស័ង្ខ ។ ៣ អដ្ឋកថា ថា អំពើដែលគេយកកន្ទាវដែកស្កក់មាត់ឲ្យហា ហើយដុតប្រទីបក្នុងមាត់ ហើយយកពន្លាកដាប់មាត់ឲ្យរលាស់ដល់គល់ត្រចៀកទាំងពីរឲ្យដូចជាមាត់រាហូ ។ ៤ អំពើដែលគេយកកំណាត់សំពត់ជ្រលក់ប្រេងរុំសរីរៈទាំងអស់ ហើយឈូលភ្លើង ។ ៥ អំពើដែលគេយកកំណាត់សំពត់ជ្រលក់ប្រេងរុំដៃទាំងពីរហើយឈូលភ្លើង ។

ចីរកវាសិកម្បិ ការេន្តិ ឯណេយ្យកម្បិ ការេន្តិ

ពលិសមំសិកម្បិ ការេន្តិ កហាបណកម្បិ កា-

រេន្តិ ខារាបតច្ឆិកម្បិ ការេន្តិ បលិឃបរិ-

វត្តិកម្បិ ការេន្តិ បលាលបីឋកម្បិ ការេន្តិ



ពន្លាត់ស្បែកពាក់ខ្លះ[១] ធ្វើនូវចីរកវាសិកកម្ម គឺអំពើដែលគេធ្វើឲ្យដូចជាស្លៀកសំពត់សម្បកឈើខ្លះ[២] ធ្វើនូវឯណេយ្យកកម្ម គឺអំពើដែលគេធ្វើឲ្យដូចជាម្រឹគសត្វទ្រាយខ្លះ[៣] ធ្វើនូវពលិសមំសិកកម្ម គឺអំពើដែលគេច្លាក់សាច់ដោយកាន្ទួសន្ទូចខ្លះ[៤] ធ្វើនូវកហាបណកកម្ម គឺអំពើដែលគេធ្វើឲ្យរបួសកាយប្រមាណប៉ុនកហាបណៈមួយៗខ្លះ[៥] ធ្វើនូវខារាបតច្ឆិកកម្ម គឺអំពើដែលគេយកទឹកផ្សះស្រោចខ្លះ[៦] ធ្វើនូវបលិឃបរិវត្តិកកម្ម គឺអំពើដែលគេធ្វើដូចជាបង្វិលដើមគល់ឬសសរគោលខ្លះ[៧] ធ្វើនូវបលាល-

---

១ អដ្ឋកថា ជាអំពើដែលគេឆូតស្បែកពីត្រឹមករហូតដល់កជើង ហើយយកខ្សែចងស្បែកនោះ ទាញពន្លាត់ចេញ រួចឲ្យអ្នកទោសនោះជាន់ផ្ទាំងស្បែកឲ្យទាល់តែដួលខ្លួនចុះទៅ ។ ២ អំពើដែលគេឆូតស្បែកតាំងពីត្រឹមក ទុកត្រឹមចង្កេះ ឆូតពីចង្កេះមកទុកត្រឹមកជើង ស្បែកខាងលើមកគ្របសរីរៈខាងក្រោមដូចជាស្លៀកសំពត់សម្បកឈើ ។ ៣ អំពើដែលគេដាក់កងដែកគ្រង់ជុំដៃទាំងពីរនិងជង្គង់ទាំងពីរ ហើយលើកដាក់លើដែកអណ្តោតទាំង ៤ មានសណ្ឋានដូចជើងក្រោយ អ្នកទោសនោះក៏ឋិតនៅលើដែកទាំង ៤ ដែលគេបោះជាប់នឹងផែនដី ។ ៤ អំពើដែលគេយកកាំបោះទៅឲ្យជាប់សាច់ស្បែកនឹងសរសៃ ហើយទាញកន្ត្រាក់ឲ្យដាច់ ។ ៥ អំពើដែលគេយកចុងកាំបិតដ៏មុតទៅឆ្វៀលយកសាច់ឲ្យមានរណ្តៅប្រមាណប៉ុនកហាបណៈមួយៗ ។ ៦ អំពើដែលគេយកអាវុធទៅចាក់ប្រហារសរីរៈ ហើយយកទឹកផ្សះស្រោចឲ្យស្បែកសាច់និងសរសៃរលួយជ្រុះចេញអស់ទៅ នៅសល់តែកង្គាលឆ្អឹងទទេ ។ ៧ អំពើដែលគេផ្តេកអ្នកទោសឲ្យដេកផ្អៀង ហើយយកដែកស្រួចទៅបោះប្រហោងត្រចៀកខាងលើឲ្យធ្លុះ រហូតដល់ប្រហោងត្រចៀកខាងក្រោមជាប់នឹងផែនដី ហើយតាំងចាប់ជើងទាញបង្វិលជុំវិញ ។

តត្តេនបិ តេលេន ឱសិញ្ចន្តិ សុនខេហិបិ ខាទាបេន្តិ ជីវន្តម្បិ សូលេ ឧត្តាសេន្តិ អសិនាបិ សីសំ ឆិន្ទន្តិ តេ តត្ថ មរណម្បិ និគច្ឆន្តិ មរណមត្តម្បិ ទុក្ខំ អយម្បិ ភិក្ខវេ កាមានំ អាទីនវោ សន្ទិដ្ឋិកោ ទុក្ខក្ខន្ធោ កាមហេតុ កាមនិទានំ កាមាធិករណំ កាមានមេវ ហេតុ ។ បុន ចបរំ ភិក្ខវេ កាមហេតុ កាមនិទានំ កាមាធិករណំ កាមានមេវ ហេតុ កាយេន ទុច្ចរិតំ ចរន្តិ វាចាយ ទុច្ចរិតំ ចរន្តិ មនសា ទុច្ចរិតំ ចរន្តិ តេ កាយេន ទុច្ចរិតំ ចរិត្វា វាចាយ ទុច្ចរិតំ ចរិត្វា មនសា ទុច្ចរិតំ ចរិត្វា កាយស្ស ភេទា បរម្មរណា



បីឋកកម្ម គឺអំពើដែលគេធ្វើឲ្យដូចជាកណ្តាប់ចំបើងខ្លះ[១] ស្រោចដោយប្រេងដែលក្តៅខ្លះ ឲ្យឆ្កែខាំខ្លះ ឲ្យដេកផ្ងារលើឈើអណ្តោតទាំងរស់ខ្លះ កាត់ក្បាលដោយដាវខ្លះ មនុស្សទាំងនោះ ក៏ដល់នូវសេចក្តីស្លាប់ខ្លះ ដល់នូវសេចក្តីទុក្ខស្ទើរតែនឹងស្លាប់ខ្លះ ក្នុងទីនោះ ម្នាលភិក្ខុទាំងឡាយ នេះឯងជាទោស របស់កាមទាំងឡាយ ដែលបុគ្គលគប្បីឃើញទាន់ភ្នែក ជាគំនរនៃទុក្ខ មានកាម ជាហេតុ មានកាម ជាគ្រឿងប្រគល់ឲ្យនូវផល មានកាម ជាគ្រឿងផ្តួចផ្តើម ជាបច្ច័យនៃកាមទាំងឡាយមែនពិត ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ព្រោះតែមានកាម ជាហេតុ មានកាម ជាគ្រឿងប្រគល់ឲ្យនូវផល មានកាម ជាគ្រឿងផ្តួចផ្តើម ជាបច្ច័យនៃកាមទាំងឡាយ បានជាសត្វទាំងឡាយ ប្រព្រឹត្តទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្ត លុះសត្វទាំងឡាយនោះ ប្រព្រឹត្តទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្ត ហើយដល់បែកធ្លាយនៃកាយ បន្ទាប់អំពីមរណៈទៅ

---

១ អំពើដែលគេកាត់ស្បែក ហើយយកខ្នុំសំលៀងកាំបិតទៅដំបំបាក់ឆ្អឹងឲ្យខ្ទេចខ្ទី ហើយចាប់ផ្តួងរបក់លើកឡើងគ្រក់គ្រលែងឲ្យឆ្អឹងជ្រុះចេញ ឲ្យនៅសល់ដុំសាច់តែម្យ៉ាង ។

អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជន្តិ អយម្បិ ភិក្ខវេ កាមានំ អាទីនវោ សម្បរាយិកោ ទុក្ខក្ខន្ធោ កាមហេតុ កាមនិទានំ កាមាធិករណំ កាមានមេវ ហេតុ ។

(១៩៩) កិញ្ច ភិក្ខវេ កាមានំ និស្សរណំ ។ យោ ខោ ភិក្ខវេ កាមេសុ ឆន្ទរាគវិនយោ ឆន្ទរាគប្បហានំ ឥទំ កាមានំ និស្សរណំ ។

(២០០) យេ ហិ កេចិ ភិក្ខវេ សមណា វា ព្រាហ្មណា វា ឯវំ កាមានំ អស្សាទញ្ច អស្សាទតោ អាទីនវញ្ច អាទីនវតោ និស្សរណញ្ច និស្សរណតោ យថាភូតំ នប្បជានន្តិ តេ វត សាមំ វា កាមេ បរិជានិស្សន្តិ បរំ វា តថត្តាយ សមាទបេស្សន្តិ យថាបដិបន្នោ កាមេ បរិជានិស្សតីតិ នេតំ ឋានំ វិជ្ជតិ ។ យេ ច ខោ កេចិ ភិក្ខវេ សមណា វា



ក៏ទៅកើត ឯអបាយ ទុគ្គតិ វិនិបាត នរក ម្នាលភិក្ខុទាំងឡាយ នេះឯងជាទោស របស់កាមទាំងឡាយ ដែលប្រព្រឹត្តទៅក្នុងបរលោក ជាគំនរនៃទុក្ខ មានកាមជាហេតុ មានកាមជាគ្រឿងប្រគល់ឲ្យនូវផល មានកាមជាគ្រឿងផ្តួចផ្តើម ជាបច្ច័យនៃកាមទាំងឡាយមែនពិត ។

(១៩៩) ម្នាលភិក្ខុទាំងឡាយ ចុះអ្វីជាគ្រឿងរលាស់ចេញនូវកាមទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ឧបាយជាទីកំចាត់បង់នូវឆន្ទរាគៈ ការលះបង់នូវឆន្ទរាគ ក្នុងកាមទាំងឡាយណា នេះឯងឈ្មោះថាជាគ្រឿងរលាស់ចេញនូវកាមទាំងឡាយ ។

(២០០) ម្នាលភិក្ខុទាំងឡាយ សមណៈឬព្រាហ្មណ៍ទាំងឡាយពួកខ្លះ មិនដឹងនូវតម្រេករបស់កាមទាំងឡាយ ថាជាគ្រឿងត្រេកអរផង មិនដឹងនូវទោសរបស់កាមទាំងឡាយ ថាជាទោសផង មិនដឹងនូវគ្រឿងរលាស់ចេញនូវកាមទាំងឡាយ ថាជាគ្រឿងរលាស់ចេញផង យ៉ាងនេះដោយពិត សមណៈឬព្រាហ្មណ៍ទាំងនោះឯង នឹងកំណត់ដឹងនូវកាមទាំងឡាយដោយខ្លួនឯងឬ ឬក៏បុគ្គលប្រតិបត្តិយ៉ាងណា ទើបនឹងកំណត់ដឹងនូវកាមទាំងឡាយបាន នឹងបបួលនូវបុគ្គលដទៃ ដើម្បីសេចក្តីប្រតិបត្តិយ៉ាងនោះ នេះមិនមែនជាឋានៈទេ ។ ម្នាលភិក្ខុទាំងឡាយ សមណៈ

ព្រាហ្មណា វា យំ កាមានំ អស្សាទញ្ច អស្សាទតោ អាទីនវញ្ច អាទីនវតោ និស្សរណញ្ច និស្សរណតោ យថាភូតំ បជានន្តិ តេ វត សាមំ វា កាមេ បរិជានិស្សន្តិ បរំ វា តថត្តាយ សមាទបេស្សន្តិ យថាបដិបន្នោ កាមេ បរិជានិស្សតីតិ ឋានមេតំ វិជ្ជតិ ។

(២០១) កោ ច ភិក្ខវេ រូបានំ អស្សាទោ ។ សេយ្យថាបិ ភិក្ខវេ ខត្តិយកញ្ញា វា ព្រាហ្មណកញ្ញា វា គហបតិកញ្ញា វា បណ្ណរសវស្សុទ្ទេសិកា វា សោឡសវស្សុទ្ទេសិកា វា នាតិទីឃា នាតិរស្សា នាតិកិសា នាតិថូលា នាតិកាឡិកា នាច្ចោទាតា បរមា សា ភិក្ខវេ តស្មិំ សមយេ សុភា វណ្ណនិភាតិ ។ ឯវំ ភន្តេតិ ។ យំ ខោ ភិក្ខវេ សុភំ វណ្ណនិភំ បដិច្ច ឧប្បជ្ជតិ សុខំ សោមនស្សំ អយំ រូបានំ អស្សាទោ ។



ឬព្រាហ្មណ៍ទាំងឡាយណាមួយ ដឹងនូវតម្រេក របស់កាមទាំងឡាយ ថាជាគ្រឿងត្រេកផង ដឹងនូវទោសរបស់កាមទាំងឡាយ ថាជាទោសផង ដឹងនូវគ្រឿងរលាស់ចេញនូវកាមទាំងឡាយ ថាជាគ្រឿងរលាស់ចេញផង ដោយពិត សមណៈឬព្រាហ្មណ៍ទាំងនោះ នឹងកំណត់ដឹងនូវកាមទាំងឡាយដោយខ្លួនឯងឬ ឬក៏បុគ្គលប្រតិបត្តិយ៉ាងណា ហើយនឹងកំណត់ដឹងនូវកាមទាំងឡាយបាន ទាំងបបួលនូវបុគ្គលដទៃ ដើម្បីសេចក្តីប្រតិបត្តិយ៉ាងនោះ នេះហើយជាឋានៈ ។

(២០២) ម្នាលភិក្ខុទាំងឡាយ ចុះអ្វីជាតម្រេក របស់រូបទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ដូចយ៉ាងខត្តិយកញ្ញា ឬព្រាហ្មណកញ្ញា គហបតិកញ្ញា ដែលមានវ័យ ១៥ ឆ្នាំ ឬ ១៦ ឆ្នាំ ជាស្ត្រីមិនខ្ពស់ពេក មិនទាបពេក មិនស្គមពេក មិនធាត់ពេក មិនខ្មៅពេក មិនសពេក ម្នាលភិក្ខុទាំងឡាយ ចុះស្ត្រីនោះមានសម្បុរល្អល្អកសមមែន ក្នុងសម័យនោះឬទេ ។ ភិក្ខុទាំងឡាយក្រាបទូលថា ព្រះករុណាព្រះអង្គ ។ ព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ត្រង់សេចក្តីសុខ សោមនស្សកើតឡើង ព្រោះអាស្រ័យសម្បុរល្អល្អក នេះឯងជាតម្រេក របស់រូបទាំងឡាយ ។

(៤០២) កោ ច ភិក្ខវេ រូបានំ អាទីនវោ ។ ឥធ ភិក្ខវេ តមេវ ភគិនឹ បស្សេយ្យ អបរេន សមយេន អសីតិកំ វា នាវុតិកំ វា វស្សសតិកំ វា ជាតិយា ជិណ្ណំ គោបានសិវង្កំ ភោគ្គំ ទណ្ឌបរាយនំ បវេធមានំ គច្ឆន្តឹ អាតុរំ គតយោព្វនំ ខណ្ឌទន្តឹ បលិតកេសឹ វិលូនំ ខលិតសិរំ វលិនំ តិលកាហតគត្តំ ។ តំ កឹ មញ្ញថ ភិក្ខវេ យា បុរិមា សុភា វណ្ណនិភា សា អន្តរហិតា អាទីនវោ បាតុភូតោតិ ។ ឯវំ ភន្តេ ។ អយម្បិ ភិក្ខវេ រូបានំ អាទីនវោ ។ បុន ចបរំ ភិក្ខវេ តមេវ ភគិនឹ បស្សេយ្យ អាពាធិកំ ទុក្ខិតំ ពាឡ្ហគិលានំ សកេ មុត្តករីសេ បលិបន្នំ សេមានំ[១] អញ្ញេហិ វុដ្ឋាបិយមានំ អញ្ញេហិ សំវេសិយមានំ[២] ។ តំ កឹ មញ្ញថ ភិក្ខវេ យា បុរិមា សុភា វណ្ណនិភា

១ ម. សេយ្យមានំ ។ ២ ឱ. សំវេសិយមានន្តិ ទិស្សតិ ។ ម. បវេសិយមានន្តិ ទិស្សតិ ។



(៤០២) ម្នាលភិក្ខុទាំងឡាយ ចុះអ្វីជាទោសរបស់រូបទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ គប្បីមើលឃើញប្អូនស្រីនោះឯង ក្នុងសម័យខាងក្រោយមក ដែលមានអាយុ ៨០ ឆ្នាំ ឬមានអាយុ ៩០ ឆ្នាំ មានអាយុ ១០០ ឆ្នាំ ជាស្ត្រីចាស់ជរាហើយដោយជាតិ មានខ្នងកោងដូចបង្កង់ផ្ទះ មានកាយកោង កាន់ឈើច្រត់ កាលដើរទៅ ញ័ររន្ធត់ រសាប់រសល់ដោយជរា មានវ័យកន្លងហើយ មានធ្មេញបាក់ សក់ស្កូវ ក្បាលពោក ក្បាលទំពែក ស្បែកជ្រួញជ្រីវ ខ្លួនចុះដោយអាចម៍រុយ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ សំគាល់សេចក្ដីនោះ ជាដូចម្ដេច សម្បុរល្អសមរម្យណា ក្នុងសម័យពីមុន សម្បុរល្អនោះ ក៏អន្តរធានបាត់ទៅ ទោសក៏កើតប្រាកដឡើងមែនឬ ។ ភិក្ខុទាំងឡាយក្រាបទូលថា ព្រះករុណាព្រះអង្គ ។ ព្រះមានបុណ្យត្រាស់ថា ម្នាលភិក្ខុទាំងឡាយ នេះហើយដែលហៅថា ទោសរបស់រូបទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុគប្បីមើលឃើញប្អូនស្រីនោះឯង ដែលមានអាពាធ ដល់នូវសេចក្ដីទុក្ខ ឈឺធ្ងន់ជាទម្ងន់ ដួលដេកត្រាំក្នុងមូត្រនិងលាមករបស់ខ្លួន លុះតែមានជនឯទៀតគ្រាឡើងទើបបានក្រោករួច លុះតែមានជនឯទៀតនាំឲ្យចូលទៅ ទើបចូលទៅបាន ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ សំគាល់សេចក្ដីនោះដូចម្ដេច សម្បុរល្អសមរម្យណា ក្នុងកាលមុន

សា អន្តរហិតា អាទីនវោ បាតុភូតោតិ ។ ឯវំ ភន្តេតិ ។ អយម្បិ ភិក្ខវេ រូបានំ អាទីនវោ ។ បុន ចបរំ ភិក្ខវេ តមេវ ភគិនឹ បស្សេយ្យ សរីរំ សីវថិកាយ ឆឌ្ឌិតំ ឯកាហមតំ វា ទ្វីហមតំ វា តីហមតំ វា ឧទ្ធុមាតកំ វា(១) វិនីលកំ វា(២) វិបុព្វកជាតំ ។ តំ កឹ មញ្ញថ ភិក្ខវេ យា បុរិមា សុភា វណ្ណនិភា សា អន្តរហិតា អាទីនវោ បាតុភូតោតិ ។ ឯវំ ភន្តេ ។ អយម្បិ ភិក្ខវេ រូបានំ អាទីនវោ ។ បុន ចបរំ ភិក្ខវេ តមេវ ភគិនឹ បស្សេយ្យ សរីរំ សីវថិកាយ ឆឌ្ឌិតំ កាកេហិ វា ខជ្ជមានំ គិជ្ឈេហិ វា ខជ្ជមានំ កុលលេហិ វា ខជ្ជមានំ សុនខេហិ វា ខជ្ជមានំ សិង្គាលេហិ វា ខជ្ជមានំ វិវិធេហិ វា បាណកជាតេហិ

១–២ ឱ. ម. វា ន ទិស្សតិ ។



សម្បុរល្អនោះ ក៏អន្តរធានបាត់ទៅ ទោសក៏កើតប្រាកដឡើងមែនឬ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលថា ព្រះករុណាព្រះអង្គ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ហ្នឹងហើយដែលហៅថា ទោសរបស់រូបទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុគប្បីមើលបងប្អូនស្រីនោះឯង ដែលគេយកសរីរៈទៅចោល ក្នុងព្រៃស្មសាន ទោះស្លាប់អស់ ១ ថ្ងៃក្ដី ស្លាប់អស់ ២ ថ្ងៃក្ដី ស្លាប់អស់ ៣ ថ្ងៃក្ដី ដែលកំពុងហើមប៉ោងឡើង មានសម្បុរខៀវ មានខ្ទុះហូរចេញ (តាមតួផ្សេងៗ) ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ សំគាល់សេចក្ដីនោះ ដូចម្ដេច សម្បុរល្អស្អាតណា ក្នុងកាលពីមុន សម្បុរល្អនោះ ក៏អន្តរធានបាត់ទៅ ទោសក៏កើតប្រាកដឡើងមែនឬ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលថា ព្រះករុណាព្រះអង្គ ។ ទើបព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ហ្នឹងហើយដែលហៅថា ទោសរបស់រូបទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុគប្បីមើលបងប្អូនស្រីនោះឯង ដែលគេយកសរីរៈទៅចោលក្នុងព្រៃស្មសាន ក្អែកទាំងឡាយ កំពុងតែចឹកស៊ីក្ដី ត្មាតកំពុងចឹកស៊ីក្ដី ក្រដក់ទាំងឡាយកំពុងចឹកស៊ីក្ដី ឆ្កែទាំងឡាយកំពុងកកេរស៊ីក្ដី ចចកទាំងឡាយកំពុងកកេរស៊ីក្ដី ពួកពាណកជាតិទាំងឡាយ

ខជ្ជមានំ ។ តំ កឹ មញ្ញថ ភិក្ខវេ យា សា បុព្វេ សុភា វណ្ណនិភា សា អន្តរហិតា អាទីនវោ បាតុភូតោតិ ។ ឯវំ ភន្តេតិ ។ អយម្បិ ភិក្ខវេ រូបានំ អាទីនវោ ។ បុន ចបរំ ភិក្ខវេ តមេវ ភគិនឹ បស្សេយ្យ សរីរំ សីវថិកាយ ឆឌ្ឌិតំ អដ្ឋិកសង្ខលិកំ សមំសលោហិតំ ន្ហារុសម្ពន្ធំ ។ បេ ។ អដ្ឋិកសង្ខលិកំ និម្មំសលោហិតមក្ខិតំ ន្ហារុសម្ពន្ធំ ។ បេ ។ អដ្ឋិកសង្ខលិកំ អបគតមំសលោហិតំ ន្ហារុសម្ពន្ធំ ។ បេ ។ អដ្ឋិកានិ អបគតន្ហារុសម្ពន្ធានិ ទិសាវិទិសា វិក្ខិត្តានិ អញ្ញេន ហត្ថដ្ឋិកំ អញ្ញេន បាទដ្ឋិកំ អញ្ញេន ជង្ឃដ្ឋិកំ អញ្ញេន ឩរុដ្ឋិកំ អញ្ញេន កដិដ្ឋិកំ អញ្ញេន បិដ្ឋិកណ្ដកដ្ឋិកំ អញ្ញេន ផាសុកដ្ឋិកំ អញ្ញេន ឧរដ្ឋិកំ អញ្ញេន ពាហុដ្ឋិកំ អញ្ញេន អំសដ្ឋិកំ





ផ្សេង ៗ កំពុងកេះចឹកស៊ី ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ សំគាល់សេចក្ដីនោះ ដូចម្ដេច សម្បុរល្អសមរម្យណា ក្នុងកាលមុន សម្បុរល្អនោះ ក៏អន្តរធានបាត់ទៅ ទោសក៏កើតប្រាកដឡើងមែនឬ ។ ភិក្ខុទាំងឡាយ ក្រាបទូលថា ព្រះករុណាព្រះអង្គ ។ ព្រះមានព្រះភាគ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ នេះហើយដែលហៅថា ទោសរបស់រូបទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ មួយយ៉ាងទៀត ភិក្ខុគប្បីមើលបងប្អូនស្រីនោះឯង ដែលគេយកសរីរៈទៅចោល ក្នុងព្រៃស្មសាន សល់នៅតែគល់ឆ្អឹង ប្រកបដោយសាច់ឈាម មានសរសៃជាគ្រឿងចង ។ បេ ។ សល់នៅតែគល់ឆ្អឹង អត់មានសាច់ តែនៅប្រឡាក់ដោយឈាម មានសរសៃជាគ្រឿងចង ។ បេ ។ សល់នៅតែគល់ឆ្អឹង មិនមានសាច់និងឈាម មានសរសៃជាគ្រឿងចង ។ បេ ។ សល់នៅតែគល់ឆ្អឹងទទេ មិនមានសរសៃជាគ្រឿងចងរបើក ខ្ចាត់ខ្ចាយ រាត់រាយទៅក្នុងទិសតូចនិងទិសធំ គឺឆ្អឹងដៃទៅដោយឡែក ឆ្អឹងជើងទៅដោយឡែក ឆ្អឹងស្មងទៅដោយឡែក ឆ្អឹងភ្លៅទៅដោយឡែក ឆ្អឹងចង្កេះទៅដោយឡែក ឆ្អឹងខ្នងទៅដោយឡែក ឆ្អឹងជំនីរទៅដោយឡែក ឆ្អឹងទ្រូងទៅដោយឡែក ឆ្អឹងដើមដៃទៅដោយឡែក ឆ្អឹងស្មាទៅដោយឡែក

អញ្ញេន គីវដ្ឋិកំ អញ្ញេន ហនុកដ្ឋិកំ អញ្ញេន ទន្តដ្ឋិកំ អញ្ញេន សីសកដាហំ ។ តំ កឹ មញ្ញថ ភិក្ខវេ យា បុព្វេ សុភា វណ្ណនិភា សា អន្តរហិតា អាទីនវោ បាតុភូតោតិ ។ ឯវំ ភន្តេ ។ អយម្បិ ភិក្ខវេ រូបានំ អាទីនវោ ។ បុន ចបរំ ភិក្ខវេ តមេវ ភគិនឹ បស្សេយ្យ សរីរំ សិវថិកាយ ឆឌ្ឌិតំ អដ្ឋិកានិ សេតានិ សង្ខវណ្ណបដិភាគានិ ។ បេ ។ អដ្ឋិកានិ បុញ្ជកិតានិ តេរោវស្សិកានិ ។ បេ ។ អដ្ឋិកានិ បូតីនិ ចុណ្ណកជាតានិ ។ តំ កឹ មញ្ញថ ភិក្ខវេ យា បុព្វេ សុភា វណ្ណនិភា សា អន្តរហិតា អាទីនវោ បាតុភូតោតិ ។ ឯវំ ភន្តេ ។ អយម្បិ ភិក្ខវេ រូបានំ អាទីនវោ ។



ឆ្អឹងកទៅដោយឡែក ឆ្អឹងចង្កាទៅដោយឡែក ឆ្អឹងធ្មេញទៅដោយឡែក លលាដ៍ក្បាលទៅដោយឡែក ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ សំគាល់សេចក្តីនោះ ជាដូចម្តេច សម្បុរល្អសមរម្យណា ក្នុងកាលពីមុន សម្បុរល្អសមរម្យនោះ ក៏អន្តរធានបាត់ទៅ ទោសក៏កើតឡើងប្រាកដមែនឬ ។ ភិក្ខុទាំងឡាយ ក្រាបទូលថា ព្រះករុណាព្រះអង្គ ។ ព្រះសយម្ភូញាណ ទ្រង់មានព្រះពុទ្ធតម្រាស់ថា ម្នាលភិក្ខុទាំងឡាយ នេះហើយដែលហៅថា ទោសរបស់រូបទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ មួយយ៉ាងទៀត ភិក្ខុគប្បីមើលបងប្អូនស្រីនោះដែល ដែលគេយកសរីរៈទៅចោលក្នុងព្រៃស្មសាន សល់នៅតែឆ្អឹងទទេ មាន សម្បុរសប្រៀបដូចពណ៌នៃស័ង្ខ ។ បេ ។ សល់នៅតែឆ្អឹងទទេ គរ កយនៅជាគំនរ ៗ កន្លងទៅយូរឆ្នាំហើយ ។ បេ ។ សល់នៅតែឆ្អឹងទទេ ពុកផុយ ខ្ទេចខ្ទី ជាកំទេចតូច កំទេចធំផ្សេង ៗ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ សំគាល់សេចក្តីនោះ ជាដូចម្តេច សម្បុរល្អសមរម្យណា ក្នុងកាលពីមុន សម្បុរល្អនោះ ក៏អន្តរធានបាត់ទៅ ទោសក៏កើតប្រាកដឡើងមែនឬ ។ ភិក្ខុទាំងឡាយក្រាបទូលថា ព្រះករុណាព្រះអង្គ ។ ព្រះមានព្រះភាគ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ នេះហើយដែលហៅថា ទោសរបស់រូបទាំងឡាយ ។

(២០៣) គិញ្ច ភិក្ខវេ រូបានំ និស្សរណំ ។ យោ ភិក្ខវេ រូបេសុ ឆន្ទរាគវិនយោ ឆន្ទរាគប្បហានំ ឥទំ រូបានំ និស្សរណំ ។

(២០៤) យេ ហិ កេចិ ភិក្ខវេ សមណា វា ព្រាហ្មណា វា ឯវំ រូបានំ អស្សាទញ្ច អស្សាទតោ អាទីនវញ្ច អាទីនវតោ និស្សរណញ្ច និស្សរណតោ យថាភូតំ នប្បជានន្តិ តេ វត សាមំ វា រូបេ បរិជានិស្សន្តិ បរំ វា តថត្តាយ សមាទបេស្សន្តិ យថាបដិបន្នោ រូបេ បរិជានិស្សតីតិ នេតំ ឋានំ វិជ្ជតិ ។ យេ ច ខោ កេចិ ភិក្ខវេ សមណា វា ព្រាហ្មណា វា ឯវំ រូបានំ អស្សាទញ្ច អស្សាទតោ អាទីនវញ្ច អាទីនវតោ និស្សរណញ្ច និស្សរណតោ យថាភូតំ បជានន្តិ តេ វត សាមំ វា រូបេ បរិជានិស្សន្តិ



(២០៣) ម្នាលភិក្ខុទាំងឡាយ ចុះអ្វីជាគ្រឿងរលាស់ចេញនូវរូបទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ណាដែលជាគ្រឿងកំចាត់បង់នូវឆន្ទរាគ ការលះបង់នូវឆន្ទរាគ ក្នុងរូបទាំងឡាយណា នេះឯងជាគ្រឿងរលាស់ចេញនូវរូបទាំងឡាយ ។

(២០៤) ម្នាលភិក្ខុទាំងឡាយ សមណៈឬព្រាហ្មណ៍ទាំងឡាយឯណាមួយ មិនដឹងនូវតម្រេករបស់រូបទាំងឡាយ ថាជាគ្រឿងត្រេកផង មិនបានដឹងនូវទោសរបស់រូបទាំងឡាយ ថាជាទោសផង មិនបានដឹងនូវគ្រឿងរលាស់ចេញនូវរូបទាំងឡាយ ថាជាគ្រឿងរលាស់ចេញផង តាមពិតយ៉ាងនេះ សមណៈឬព្រាហ្មណ៍ទាំងនោះ នឹងកំណត់ដឹងនូវរូបទាំងឡាយដោយខ្លួនឯងឬ ឬក៏បុគ្គលប្រតិបត្តិយ៉ាងណា ទើបនឹងកំណត់ដឹងនូវរូបទាំងឡាយបាន នឹងបបួលបុគ្គលដទៃ ដើម្បីសេចក្ដីប្រតិបត្តិយ៉ាងនោះ ហេតុនេះ មិនដែលមានឡើយ ។ ម្នាលភិក្ខុទាំងឡាយ សមណៈឬព្រាហ្មណ៍ណាមួយ ដឹងនូវតម្រេក របស់រូបទាំងឡាយ ថាជាគ្រឿងត្រេកផង ដឹងនូវទោស របស់រូបទាំងឡាយ ថាជាទោសផង ដឹងនូវគ្រឿងរលាស់ចេញនូវរូបទាំងឡាយ ថាជាគ្រឿងរលាស់ចេញផង សមណៈឬព្រាហ្មណ៍ទាំងនោះ នឹងកំណត់ដឹង នូវរូបទាំងឡាយ ដោយខ្លួនឯងឬ

បរំ វា តថត្តាយ សមាទបេស្សន្តិ យថាបដិបន្នោ វេទនំ បរិជានិស្សតីតិ ឋានមេតំ វិជ្ជតិ ។

(២០៩) កោ ច ភិក្ខវេ វេទនានំ អស្សាទោ ។ ឥធ ភិក្ខវេ ភិក្ខុ វិវិច្ចេវ កាមេហិ វិវិច្ច អកុសលេហិ ធម្មេហិ សវិតក្កំ សវិចារំ វិវេកជំ បីតិសុខំ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ ។ យស្មឹ សមយេ ភិក្ខវេ ភិក្ខុ វិវិច្ចេវ កាមេហិ វិវិច្ច អកុសលេហិ ធម្មេហិ សវិតក្កំ សវិចារំ វិវេកជំ បីតិសុខំ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ នេវ តស្មឹ សមយេ អត្តព្យាពាធាយបិ ចេតេតិ ន បរព្យាពាធាយបិ ចេតេតិ ន ឧភយព្យាពាធាយបិ ចេតេតិ អព្យាបជ្ឈំយេវ តស្មឹ សមយេ វេទនំ វេទេតិ អព្យាបជ្ឈបរមាហំ ភិក្ខវេ



ឬក៏បុគ្គលប្រតិបត្តិយ៉ាងណា ទើបនឹងកំណត់ដឹងនូវវេទនាទាំងឡាយបាន ឬក៏បបួលនូវបុគ្គលដទៃ ដើម្បីសេចក្តីប្រតិបត្តិយ៉ាងនោះ នេះជាឋានៈ ។

(២០៩) ម្នាលភិក្ខុទាំងឡាយ ចុះអ្វីជាតម្រេក របស់វេទនាទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ស្ងប់ស្ងាត់ចាកកាមទាំងឡាយ ស្ងប់ស្ងាត់ចាកអកុសលធម៌ទាំងឡាយ ក៏ចូលកាន់បឋមជ្ឈាន ប្រកបដោយវិតក្កវិចារៈ មានបីតិនិងសុខៈ ដែលកើតអំពីសេចក្តីស្ងប់ស្ងាត់ជាអារម្មណ៍ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យណា ភិក្ខុស្ងប់ស្ងាត់ចាកកាមទាំងឡាយ ស្ងប់ស្ងាត់ចាកអកុសលធម៌ទាំងឡាយ ហើយ ក៏ចូលកាន់បឋមជ្ឈាន ប្រកបដោយវិតក្កៈ វិចារៈ មានបីតិនិងសុខ ដែលកើតអំពីសេចក្តីស្ងប់ស្ងាត់ជាអារម្មណ៍ ក្នុងសម័យនោះ(ភិក្ខុនោះឯង) មិនបានគិតដើម្បីបៀតបៀនខ្លួនឯង មិនបានគិតដើម្បីបៀតបៀនបុគ្គលដទៃ មិនបានគិតដើម្បីបៀតបៀនបុគ្គលទាំង ២ គឺខ្លួននិងបុគ្គលដទៃ ក្នុងសម័យនោះ (ភិក្ខុនោះ) ឈ្មោះថាទទួលនូវវេទនា មិនមានសេចក្តីព្យាបាទ (ឥតទុក្ខ)តែមួយយ៉ាង ម្នាលភិក្ខុទាំងឡាយ តថាគត

សីហនាទវគ្គស្ស មហាទុក្ខក្ខន្ធសុត្តំ វេទនានំ អស្សាទោ

វេទនានំ អស្សាទំ វទាមិ ។ បុន ចបរំ ភិក្ខវេ ភិក្ខុ វិតក្កវិចារានំ វូបសមា អជ្ឈត្តំ សម្បសាទនំ ចេតសោ ឯកោទិភាវំ អវិតក្កំ អវិចារំ សមាធិជំ បីតិសុខំ ទុតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ ។ យស្មឹ សមយេ ភិក្ខវេ ភិក្ខុ វិតក្កវិចារានំ វូបសមា ។ បេ ។ វិហរតិ នេវ តស្មឹ សមយេ អត្តព្យាពាធាយបិ ចេតេតិ ។ បេ ។ វេទេតិ អព្យាបជ្ឈបរមាហំ ភិក្ខវេ វេទនានំ អស្សាទំ វទាមិ ។ បុន ចបរំ ភិក្ខវេ ភិក្ខុ បីតិយា ច វិរាគា ឧបេក្ខកោ ច វិហរតិ សតោ ច សម្បជានោ សុខញ្ច កាយេន បដិសំវេទេតិ យន្តំ អរិយា អាចិក្ខន្តិ ឧបេក្ខកោ សតិមា សុខវិហារីតិ តតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ ។ យស្មឹ សមយេ ភិក្ខវេ ភិក្ខុ បីតិយា ច វិរាគា ។ បេ ។ វិហរតិ នេវ តស្មឹ សមយេ ។ បេ ។ វេទេតិ អព្យាបជ្ឈបរមាហំ ភិក្ខវេ



សីហនាទវគ្គ មហាទុក្ខក្ខន្ធសូត្រ គុណនៃវេទនាទាំងឡាយ

ពោលថាតម្រេករបស់វេទនាទាំងឡាយ បំផុតត្រឹមសេចក្តីមិនព្យាបាទ ។ ម្នាលភិក្ខុទាំងឡាយ មួយយ៉ាងទៀត ភិក្ខុចូលកាន់ទុតិយជ្ឈានជាទីផូរផង់ក្នុងសន្តានមានភាវៈនៃចិត្តដ៏ប្រសើរ មិនមានវិតក្កៈ មិនមានវិចារៈ មានតែបីតិនិងសុខ ដែលកើតអំពីសមាធិ ព្រោះរម្ងាប់នូវវិតក្កៈនិងវិចារៈ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យណាដែលភិក្ខុ ។ បេ ។ ព្រោះរម្ងាប់វិតក្កៈនិងវិចារៈក្នុងសម័យនោះ (ភិក្ខុនោះឯង) មិនបានគិតដើម្បីបៀតបៀនខ្លួនឯង ។ បេ ។ ទើបឈ្មោះថាទទួលនូវវេទនា មិនមានសេចក្តីព្យាបាទតែមួយយ៉ាង ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា សេចក្តីត្រេកអររបស់វេទនាទាំងឡាយ បំផុតត្រឹមសេចក្តីមិនព្យាបាទ ។ ម្នាលភិក្ខុទាំងឡាយ មួយយ៉ាងទៀត ភិក្ខុជាអ្នកមានចិត្តព្រងើយផង មានស្មារតីភាំងមាំផង មានប្រាជ្ញាដឹងសព្វផង ទទួលនូវសេចក្តីសុខ ដោយនាមកាយផង ព្រោះអស់ទៅនៃបីតិ ក៏បានចូលកាន់តតិយជ្ឈាន ដែលព្រះអរិយៈទាំងឡាយ តែងសំដែងថា បុគ្គលដែលបានចូលកាន់តតិយជ្ឈាន រមែងជាអ្នកមានចិត្តព្រងើយ មានស្មារតីនៅជាសុខ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យណា ភិក្ខុ ។ បេ ។ ព្រោះអស់ទៅនៃបីតិ ក្នុងសម័យនោះ ភិក្ខុនោះឯង មិនគិត ។ បេ ។ ទើបឈ្មោះថា ទទួលនូវវេទនាមិនមានសេចក្តីព្យាបាទតែមួយយ៉ាង ម្នាលភិក្ខុទាំងឡាយ តថាគត

វេទនានំ អស្សាទំ វទាមិ ។ បុន ចបរំ ភិក្ខវេ ភិក្ខុ សុខស្ស ច បហានា ទុក្ខស្ស ច បហានា បុព្វេវ សោមនស្សទោមនស្សានំ អត្ថង្គមា អទុក្ខមសុខំ ឧបេក្ខាសតិបារិសុទ្ធឹ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ ។ យស្មឹ សមយេ ភិក្ខវេ ភិក្ខុ សុខស្ស ច ។ បេ ។ វិហរតិ នេវ តស្មឹ សមយេ អត្តព្យាពាធម្បិ ចេតេតិ ន បរព្យាពាធម្បិ ចេតេតិ ន ឧភយព្យាពាធម្បិ ចេតេតិ អព្យាបជ្ជំយេវ តស្មឹ សមយេ វេទនំ វេទេតិ អព្យាបជ្ជបរមាហំ ភិក្ខវេ វេទនានំ អស្សាទំ វទាមិ ។

(២០៦) កោ ច ភិក្ខវេ វេទនានំ អាទីនវោ ។ យំ ភិក្ខវេ វេទនា អនិច្ចា ទុក្ខា វិបរិណាមធម្មា អយំ វេទនានំ អាទីនវោ ។



ពោលថា សេចក្តីត្រេកអរ របស់វេទនាទាំងឡាយ បំផុតត្រឹមសេចក្តីមិនព្យាបាទ ។ ម្នាលភិក្ខុទាំងឡាយ មួយយ៉ាងទៀត ភិក្ខុចូលកាន់ចតុត្ថជ្ឈាន ដែលឥតទុក្ខឥតសុខ មានតែសតិដ៏បរិសុទ្ធ ព្រោះឧបេក្ខា ព្រោះលះបង់នូវសុខផង លះបង់នូវទុក្ខផង ព្រោះរលត់ទៅ នៃសោមនស្ស និងទោមនស្ស ក្នុងកាលមុនផង ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យណា ភិក្ខុ ។ បេ ។ ព្រោះលះបង់នូវសុខផង ក្នុងសម័យនោះ ភិក្ខុនោះឯង មិនបានគិតដើម្បីបៀតបៀនខ្លួនផង មិនបានគិតដើម្បីបៀតបៀនបុគ្គលដទៃផង មិនបានគិតដើម្បីបៀតបៀនបុគ្គលទាំងពីរពួក គឺខ្លួននឹងបុគ្គលដទៃផង ក្នុងសម័យនោះ ភិក្ខុនោះ ឈ្មោះថាទទួលនូវវេទនា ដែលមិនមានសេចក្តីព្យាបាទ តែមួយយ៉ាង ម្នាលភិក្ខុទាំងឡាយ តថាគតតែងពោលថា សេចក្តីត្រេកអរ របស់វេទនាទាំងឡាយ បំផុតត្រឹមសេចក្តីមិនព្យាបាទ ។

(២០៦) ម្នាលភិក្ខុទាំងឡាយ ចុះអ្វីជាទោស របស់វេទនាទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ត្រង់ដែលវេទនាមិនទៀងជាទុក្ខ មានសេចក្តីប្រែប្រួលទៅជាធម្មតា នេះឯងជាទោសរបស់វេទនាទាំងឡាយ ។

(៦០៧) កតមញ្ច ភិក្ខវេ វេទនានំ និស្សរណំ ។ យោ ភិក្ខវេ វេទនាសុ ឆន្ទរាគវិនយោ ឆន្ទរាគប្បហានំ ឥទំ វេទនានំ និស្សរណំ ។

(៦០៨) យេ ហិ កេចិ ភិក្ខវេ សមណា វា ព្រាហ្មណា វា ឯវំ វេទនានំ អស្សាទញ្ច អស្សាទតោ អាទីនវញ្ច អាទីនវតោ និស្សរណញ្ច និស្សរណតោ យថាភូតំ នប្បជានន្តិ តេ វត សាមំ វា វេទនំ បរិជានិស្សន្តិ បរំ វា តថត្តាយ សមាទបេស្សន្តិ យថាបដិបន្នោ វេទនំ បរិជានិស្សតីតិ នេតំ ឋានំ វិជ្ជតិ ។ យេ ច ខោ កេចិ ភិក្ខវេ សមណា វា ព្រាហ្មណា វា ឯវំ វេទនានំ អស្សាទញ្ច អស្សាទតោ អាទីនវញ្ច អាទីនវតោ



(៦០៧) ម្នាលភិក្ខុទាំងឡាយ ចុះអ្វី ជាគ្រឿងរលាស់ចេញនូវវេទនាទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ណាជាគ្រឿងកំចាត់បង់នូវឆន្ទរាគ ការលះបង់នូវឆន្ទរាគ ក្នុងវេទនាទាំងឡាយណា នេះឯង ជាគ្រឿងរលាស់ចេញ នូវវេទនាទាំងឡាយ ។

(៦០៨) ម្នាលភិក្ខុទាំងឡាយ សមណៈឬព្រាហ្មណ៍ទាំងឡាយ ពួកខ្លះ មិនបានដឹងនូវតម្រេក របស់វេទនាទាំងឡាយ ថាជាគ្រឿងត្រេកផង មិនបានដឹងនូវទោសរបស់វេទនាទាំងឡាយ ថាជាទោសផង មិនបានដឹងនូវគ្រឿងរលាស់ចេញនូវវេទនាទាំងឡាយ ថាជាគ្រឿងរលាស់ចេញផង យ៉ាងនេះតាមពិត សមណព្រាហ្មណ៍ទាំងនោះ នឹងកំណត់ដឹងនូវវេទនាទាំងឡាយដោយខ្លួនឯងឬ ឬក៏បុគ្គលប្រតិបត្តិយ៉ាងណា ទើបនឹងកំណត់ដឹងនូវវេទនាទាំងឡាយបាន ទាំងបបួលនូវបុគ្គលដទៃដើម្បីសេចក្តីប្រតិបត្តិយ៉ាងនោះ នេះមិនមែនជាឋានៈទេ ។ ម្នាលភិក្ខុទាំងឡាយសមណៈ ឬព្រាហ្មណ៍ទាំងឡាយណាមួយ ដឹងនូវតម្រេករបស់វេទនាទាំងឡាយ ថាជាគ្រឿងត្រេកផង ដឹងនូវទោសរបស់វេទនាទាំងឡាយ ថាជាទោស

និស្សរណញ្ច និស្សរណតោ យថាភូតំ បជានន្តិ តេ វត សាមំ វា កាមេ បរិជានិស្សន្តិ បរំ វា តថត្តាយ សមាទបេស្សន្តិ យថាបដិបន្នោ កាមេ បរិជានិស្សតីតិ ឋានមេតំ វិជ្ជតីតិ ។ ឥទមវោច ភគវា អត្តមនា តេ ភិក្ខូ ភគវតោ ភាសិតំ អភិនន្ទុន្តិ ។

មហាទុក្ខក្ខន្ធសុត្តំ តតិយំ និដ្ឋិតំ ។



ផង ដឹងនូវគ្រឿងរលាស់ចេញនូវវេទនាទាំងឡាយ តាមគ្រឿងរលាស់ចេញផង យ៉ាងនេះតាមពិត ទើបសមណៈឬព្រាហ្មណ៍ទាំងនោះ នឹងកំណត់ដឹងនូវវេទនាដោយខ្លួនឯងឬ ឬក៏បុគ្គលប្រតិបត្តិយ៉ាងណា ទើបនឹងកំណត់ដឹងនូវវេទនាទាំងឡាយបាន ទាំងបបួលនូវបុគ្គលដទៃ ដើម្បីសេចក្តីប្រតិបត្តិយ៉ាងនោះ នេះទើបជាឋានៈ ។ លុះព្រះមានព្រះភាគ ទ្រង់ត្រាស់ព្រះសូត្រនេះចប់ហើយ ភិក្ខុទាំងនោះ ក៏មានចិត្តត្រេកអររីករាយចំពោះភាសិត នៃព្រះមានព្រះភាគ ។

ចប់ មហាទុក្ខក្ខន្ធសូត្រទី ៣ ។

## ចតុត្ថំ ចូឡទុក្ខក្ខន្ធសុត្តំ

(២០៩) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សក្កេសុ វិហរតិ កបិលវត្ថុស្មឹ និគ្រោធារាមេ ។ អថ ខោ មហានាមោ សក្កោ យេន ភគវា តេនុ- បសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ មហានាមោ សក្កោ ភគវន្តំ ឯតទវោច ទីឃរត្តាហំ ភន្តេ ភគវតា ឯវំ ធម្មំ ទេសិតំ អាជានាមិ លោភោ ចិត្តស្ស ឧបក្កិលេសោ ទោសោ ចិត្តស្ស ឧបក្កិលេសោ មោហោ ចិត្តស្ស ឧបក្កិលេសោ[១] អថ ច បន មេ ឯកទា លោភធម្មាបិ ចិត្តំ បរិយាទាយ តិដ្ឋន្តិ ទោសធម្មាបិ ចិត្តំ បរិយាទាយ តិដ្ឋន្តិ មោហធម្មាបិ ចិត្តំ បរិយាទាយ តិដ្ឋន្តិ តស្ស មយ្ហំ ភន្តេ ឯវំ ហោតិ កោសុ នាម មេ ធម្មោ អជ្ឈត្តំ អប្បហីនោ

១ ម. ឯកមន្តំ និសិន្នោ ។បេ។ ឧបក្កិលេសោតិ ។ ឯវំ ចាហំ ភន្តេ ភគវតោ ធម្មំ ទេសិតំ អាជានាមិ លោភោ ចិត្តស្ស ឧបក្កិលេសោ ទោសោ ចិត្តស្ស ឧបក្កិលេសោ មោហោ ចិត្តស្ស ឧបក្កិលេសោតិ ទិស្សតិ ។

## ចូឡទុក្ខក្ខន្ធសូត្រ ទី ៤

(២០៩) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងនិគ្រោធារាម ទៀបក្រុងកបិលពស្តុ ក្នុងសក្កជនបទ ។ លំដាប់នោះឯង សក្យរាជទ្រង់ព្រះនាមមហានាម ក៏ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយក៏ថ្វាយបង្គំព្រះមានព្រះភាគ ហើយគង់ក្នុងទីដ៏សមគួរ ។ លុះមហានាមសក្យរាជ គង់ក្នុងទីដ៏សមគួរហើយ ទើបក្រាបទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គបានដឹងច្បាស់នូវធម៌ដែលព្រះមានព្រះភាគទ្រង់សំដែងអស់កាលជាយូរហើយយ៉ាងនេះថា លោភៈជាគ្រឿងសៅហ្មងរបស់ចិត្ត ទោសៈជាគ្រឿងសៅហ្មងរបស់ចិត្ត មោហៈជាគ្រឿងសៅហ្មងរបស់ចិត្ត ប៉ុន្តែចួនកាលធម៌គឺលោភៈគ្របសង្កត់ចិត្តរបស់ខ្ញុំព្រះអង្គខ្លះ ចួនកាលធម៌គឺទោសៈគ្របសង្កត់ចិត្តរបស់ខ្ញុំព្រះអង្គខ្លះ ចួនកាលធម៌គឺមោហៈគ្របសង្កត់ចិត្តរបស់ខ្ញុំព្រះអង្គខ្លះ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គនោះទើបមានសេចក្តីត្រិះរិះយ៉ាងនេះថា ចុះធម៌អ្វីហ្ន៎ នៅខាងក្នុងសន្តានរបស់

យេន មេ ឯកទា លោភធម្មាបិ ចិត្តំ បរិយាទាយ តិដ្ឋន្តិ ទោសធម្មាបិ ចិត្តំ បរិយាទាយ តិដ្ឋន្តិ មោហធម្មាបិ ចិត្តំ បរិយាទាយ តិដ្ឋន្តីតិ ។

(៦១០) សោ ឯវ ខោ តេ មហានាម ធម្មោ អជ្ឈត្តំ អប្បហីនោ យេន តេ ឯកទា លោភធម្មាបិ ចិត្តំ បរិយាទាយ តិដ្ឋន្តិ ទោសធម្មាបិ ចិត្តំ បរិយាទាយ តិដ្ឋន្តិ មោហធម្មាបិ ចិត្តំ បរិយាទាយ តិដ្ឋន្តិ ។ សោ ច ហិ តេ មហានាម ធម្មោ អជ្ឈត្តំ បហីនោ អភវិស្ស ។ ន ត្វំ អគារំ អជ្ឈាវសេយ្យាសិ ន កាមេ បរិភុញ្ជេយ្យាសិ ។ យស្មា ច ខោ តេ មហានាម ឯសោ ធម្មោ អជ្ឈត្តំ អប្បហីនោ តស្មា ត្វំ អគារំ អជ្ឈាវសសិ កាមេ បរិភុញ្ជសិ ។

(៦១១) អប្បស្សាទា កាមា ពហុទុក្ខា ពហុបាយាសា អាទីនវោ ឯត្ថ ភិយ្យោតិ ឥតិ ចេបិ មហានាម អរិយសាវកស្ស យថាភូតំ សម្មប្បញ្ញាយ សុទិដ្ឋំ ហោតិ ។ សោ ច អញ្ញត្រេវ





អាត្មាអញមិនទាន់លះបង់អស់ បានជាជួនកាល ធម៌គឺលោភៈគ្របសង្កត់ចិត្តរបស់អាត្មាអញខ្លះ ជួនកាល ធម៌គឺទោសៈគ្របសង្កត់ចិត្តរបស់អាត្មាអញខ្លះ ជួនកាលធម៌គឺមោហៈគ្របសង្កត់ចិត្តរបស់អាត្មាអញខ្លះ ។

(៦១០) ព្រះមានព្រះភាគត្រាស់ថា ថ្វាយព្រះពរមហានាម ធម៌គឺលោភៈទោសៈមោហៈក្នុងសន្តាននោះឯង ដែលមហាបពិត្រមិនទាន់លះបង់អស់ បានជាជួនកាល ធម៌គឺលោភៈគ្របសង្កត់ចិត្តរបស់មហាបពិត្រខ្លះ ជួនកាលធម៌គឺទោសៈគ្របសង្កត់ចិត្តរបស់មហាបពិត្រខ្លះ ជួនកាលធម៌គឺមោហៈគ្របសង្កត់ចិត្តរបស់មហាបពិត្រខ្លះ ។ បពិត្រមហានាម បើធម៌ក្នុងសន្តាននោះ មហាបពិត្រ បានលះបង់អស់ហើយ ។ មហាបពិត្រនឹងគប្បីលែងនៅគ្រប់គ្រងផ្ទះ នឹងគប្បីលែងបរិភោគកាមទាំងឡាយ ។ បពិត្រមហានាម ធម៌នោះក្នុងសន្តាននោះឯង មហាបពិត្រមិនទាន់លះទាន់បាន ព្រោះហេតុនោះបានជាមហាបពិត្រនៅគ្រប់គ្រងផ្ទះ បរិភោគនូវកាមទាំងឡាយ ។

(៦១១) ថ្វាយព្រះពរមហានាម បើអរិយសាវក បានឃើញច្បាស់តាមសេចក្តីពិត ដោយប្រាជ្ញាដ៏ប្រពៃយ៉ាងនេះថា កាមទាំងឡាយមានសេចក្តីសុខតិច មានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ទោសក្នុងកាមទាំងឡាយនុ៎ះមានច្រើនពេក ។ អរិយសាវកនោះឯងបានបៀ

កាមេហិ អញ្ញត្រ អកុសលេហិ ធម្មេហិ បីតិសុខំ នាធិគច្ឆតិ អញ្ញំ វា តតោ សន្តតរំ អថ ខោ សោ នេវ តាវ អនាវដ្ដី កាមេសុ ហោតិ ។ យតោ ច ខោ មហានាម អរិយសាវកស្ស អប្បស្សាទា កាមា ពហុទុក្ខា ពហុបាយាសា អាទីនវោ ឯត្ថ ភិយ្យោតិ ឯវមេតំ[១] សម្មប្បញ្ញាយ សុទិដ្ឋំ ហោតិ ។ សោ ច អញ្ញត្រេវ កាមេហិ អញ្ញត្រ អកុសលេហិ ធម្មេហិ បីតិសុខំ អធិគច្ឆតិ អញ្ញំ វា[២] តតោ សន្តតរំ អថ ខោ សោ អនាវដ្ដី កាមេសុ ហោតិ ។ មយ្ហម្បិ ខោ មហានាម បុព្វេវ សម្ពោធា អនភិសម្ពុទ្ធស្ស

១ ម.ម. ឯវមេតំ យថាភូតំ ។ ២ ម. អញ្ញញ្ច ។





ចាកកាមទាំងឡាយ វៀរចាកអកុសលធម៌ទាំងឡាយប៉ុណ្ណោះ ក៏មិនបានប្រាកដនូវបីតិនិងសុខ[១] ឬគុណជាតដទៃដែលល្អិត[២] លើសជាងបីតិនិងសុខនោះទេ កាលបើដូច្នេះ អរិយសាវកនោះ ទើបឈ្មោះថា មិនវិលត្រឡប់មករកកាមទាំងឡាយវិញនោះ មិនមែនឡើយ ។ បពិត្រមហានាម កាលណាបើអរិយសាវក បានឃើញច្បាស់តាមពិត ដោយបញ្ញាដ៏ប្រពៃយ៉ាងនេះថា កាមទាំងឡាយមានសេចក្ដីសុខតិច មានទុក្ខច្រើន មានសេចក្ដីចង្អៀតចង្អល់ច្រើន ទោសក្នុងកាមទាំងឡាយនុ៎ះ មានច្រើនក្រៃពេក ។ អរិយសាវកនោះឯងបានវៀរចាកកាមទាំងឡាយ វៀរចាកអកុសលធម៌ទាំងឡាយ ហើយបាននូវបីតិនិងសុខ ឬគុណជាតដទៃដែលល្អិតលើសជាងបីតិនិងសុខនោះ កាលបើដូច្នេះ អរិយសាវកនោះទើបឈ្មោះថា មិនវិលត្រឡប់មករកកាមទាំងឡាយទៀតឡើយ ។ បពិត្រមហានាម ចំណែកតថាគត កាលនៅជាពោធិសត្វ មិនទាន់បានត្រាស់ដឹង ក្នុងកាលមុនអំពីកាលត្រាស់ដឹងនៅឡើយ បានឃើញ

១ អដ្ឋកថា ថា បាននូវឈានពីរដែលប្រកបដោយបីតិគឺបឋមជ្ឈាន និងទុតិយជ្ឈាន ។
២ បាននូវតតិយជ្ឈាន ចតុត្ថជ្ឈាន សោតាបត្តិមគ្គនិងសកទាគាមិមគ្គ ។

ពោធិសត្តស្សេវ សតោ អប្បស្សាទា កាមា ពហុទុក្ខា ពហុបាយាសា អាទីនវោ ឯត្ថ ភិយ្យោតិ យថាភូតំ[១] សម្មប្បញ្ញាយ សុទិដ្ឋំ ហោតិ[២] ។ សោ ច អញ្ញត្រេវ កាមេហិ អញ្ញត្រ អកុសលេហិ ធម្មេហិ បីតិសុខំ នាជ្ឈគមិ[៣] អញ្ញំ វា តតោ សន្តតរំ អថខ្វាហំ នេវ តាវ អនាវដ្ដី កាមេសុ បច្ចញ្ញាសឹ ។ យតោ ច ខោ មេ មហានាម អប្បស្សាទា កាមា ពហុទុក្ខា ពហុបាយាសា អាទីនវោ ឯត្ថ ភិយ្យោតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ សុទិដ្ឋំ អហោសិ ។ សោ ច អញ្ញត្រេវ កាមេហិ អញ្ញត្រ អកុសលេហិ ធម្មេហិ បីតិសុខំ អជ្ឈគមឹ អញ្ញញ្ច តតោ សន្តតរំ អថាហំ អនាវដ្ដី កាមេសុ បច្ចញ្ញាសឹ ។

១ ឱ.ម. ឯវមេតំ យថាភូតំ ។ ២ ឱ. អហោសិ ។ ៣ ឱ. នាជ្ឈគមំ ។



ច្បាស់តាមពិត ដោយបញ្ញាដ៏ប្រពៃយ៉ាងនេះថា កាមទាំងឡាយមានសុខតិច មានទុក្ខច្រើន មានសេចក្ដីចង្អៀតចង្អល់ច្រើន ទោសក្នុងកាមទាំងឡាយនុ៎ះមានច្រើនក្រៃពេក ។ តថាគតនោះវៀរចាកកាមទាំងឡាយ វៀរចាកអកុសលធម៌ទាំងឡាយហើយ តែមិនទាន់បាននូវបីតិនិងសុខ ឬគុណជាតដទៃ ដែលល្អិតលើសជាងបីតិនិងសុខនោះ កាលបើដូច្នេះ តថាគតនោះក៏ដឹងច្បាស់ថា គ្មានត្រឡប់មករកកាមទាំងឡាយវិញ ដោយពិត ។ បពិត្រមហានាម លុះកាលណាតថាគត បានឃើញច្បាស់តាមពិតដោយបញ្ញាដ៏ប្រពៃយ៉ាងនេះថា កាមទាំងឡាយមានសុខតិច មានទុក្ខច្រើន មានសេចក្ដីចង្អៀតចង្អល់ច្រើន ទោសក្នុងកាមទាំងឡាយនុ៎ះ មានច្រើនក្រៃពេក ។ តថាគតនោះឯង បានវៀរចាកកាមទាំងឡាយ វៀរចាកអកុសលធម៌ទាំងឡាយ ហើយបាននូវបីតិនិងសុខផង ឬគុណជាតដទៃ ដែលល្អិតលើសជាងបីតិនិងសុខនោះផង កាលបើដូច្នេះតថាគតដឹងច្បាស់ថា មិនវិលត្រឡប់មករកកាមទាំងឡាយវិញឡើយ ។

(២១២) កោ ច មហានាម កាមានំ អស្សាទោ ។ បញ្ចិមេ មហានាម កាមគុណា កតមេ បញ្ច ចក្ខុវិញ្ញេយ្យា រូបា ឥដ្ឋា កន្តា មនាបា បិយរូបា កាមូបសញ្ហិតា រជនីយា សោតវិញ្ញេយ្យា សទ្ទា ... ឃានវិញ្ញេយ្យា គន្ធា... ជិវ្ហាវិញ្ញេយ្យា រសា... កាយវិញ្ញេយ្យា ផោដ្ឋព្វា ឥដ្ឋា កន្តា មនាបា បិយរូបា កាមូបសញ្ហិតា រជនីយា ឥមេ ខោ មហានាម បញ្ច កាមគុណា ។ យំ ខោ មហានាម ឥមេ បញ្ច កាមគុណេ បដិច្ច ឧប្បជ្ជតិ សុខំ សោមនស្សំ អយំ កាមានំ អស្សាទោ ។

(២១៣) កោ ច មហានាម កាមានំ អាទីនវោ ។ ឥធ មហានាម កុលបុត្តោ យេន សិប្បដ្ឋានេន ជីវិកំ កប្បេតិ យទិ មុទ្ទាយ យទិ គណនាយ យទិ សង្ខានេន យទិ កសិយា យទិ វណិជ្ជាយ យទិ គោរក្ខេន



(២១២) ថ្វាយព្រះពរមហានាម ចុះអ្វីជាតម្រេករបស់កាមទាំងឡាយ ។ បពិត្រមហានាម កាមគុណទាំងនេះមាន ៥ ប្រការ ចុះកាមគុណ ៥ ប្រការតើអ្វីខ្លះ ។ គឺរូបទាំងឡាយដែលគប្បីដឹងច្បាស់បានដោយភ្នែក ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត ជាទីស្រឡាញ់ ត្រូវការចំណង់ ជាទីត្រេកត្រអាល ១ សំឡេងទាំងឡាយដែលគប្បីដឹងច្បាស់បានដោយត្រចៀក ..១ ក្លិនទាំងឡាយ ដែលគប្បីដឹងច្បាស់បានដោយច្រមុះ... ១ រសទាំងឡាយដែលគប្បីដឹងច្បាស់បានដោយអណ្តាត... ១ ផ្សព្វទាំងឡាយដែលគប្បីដឹងច្បាស់បានដោយកាយ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត ជាទីស្រឡាញ់ ត្រូវការចំណង់ ជាទីត្រេកត្រអាល ១ បពិត្រមហានាម នេះឯងឈ្មោះថា កាមគុណ ៥ ប្រការ ។ បពិត្រមហានាម ការដែលសេចក្តីសុខ សោមនស្ស កើតឡើងព្រោះអាស្រ័យកាមគុណទាំង ៥ នេះឯង ជាតម្រេករបស់កាមទាំងឡាយ ។

(២១៣) ថ្វាយព្រះពរមហានាម ចុះអ្វីជាទោសរបស់កាមទាំងឡាយ ។ បពិត្រមហានាម កុលបុត្តក្នុងលោកនេះ ចិញ្ចឹមជីវិតដោយសេចក្តីប្រឹងប្រែង ដោយសិល្បសាស្ត្រណានីមួយ ទោះបីដោយការរាប់ម្រាមដៃទេក្តី ដោយការរាប់លេខគន្តក្តី ដោយការរាប់ប្រមូលក្តី ដោយកសិកម្មក្តី ដោយពាណិជ្ជកម្មក្តី ដោយគោរក្ខកម្មក្តី

យទិ ឥស្សត្ថេន យទិ រាជបោរិសេន យទិ សិប្បញ្ញតរេន សីតស្ស បុរក្ខតោ ឧណ្ហស្ស បុរក្ខតោ ឌំសមកសវាតាតបសរីសបសម្ផស្សេហិ រិស្សមានោ ខុប្បិបាសាយ មិយ្យមានោ ។ អយម្បិ មហានាម កាមានំ អាទីនវោ សន្ទិដ្ឋិកោ ទុក្ខក្ខន្ធោ កាមហេតុ កាមនិទានំ កាមាធិករណំ កាមានមេវ ហេតុ ។ តស្ស ចេ មហានាម កុលបុត្តស្ស ឯវំ ឧដ្ឋហតោ ឃដតោ វាយមតោ តេ ភោគា នាភិនិប្ផជ្ជន្តិ សោ សោចតិ កិលមតិ បរិទេវតិ ឧរត្តាឡឹ កន្ទតិ សម្មោហំ អាបជ្ជតិ មោឃំ វត មេ ឧដ្ឋានំ អផលោ វត មេ វាយាមោតិ ។ អយម្បិ មហានាម កាមានំ អាទីនវោ សន្ទិដ្ឋិកោ ទុក្ខក្ខន្ធោ កាមហេតុ កាមនិទានំ កាមាធិករណំ កាមានមេវ ហេតុ ។ តស្ស ចេ មហានាម កុលបុត្តស្ស ឯវំ ឧដ្ឋហតោ ឃដតោ វាយមតោ តេ ភោគា



ដោយការៈនៃខ្លួនជាអ្នកកាន់ធ្នូក្តី ដោយការៈនៃខ្លួនជារាជបុរសក្តី ដោយសិល្បសាស្ត្រឯណាមួយក្តី កុលបុត្រដែលអាស្រ័យនូវការចិញ្ចឹមជីវិត ដោយការរាប់ម្រាមដៃជាដើមនោះ តែងមានត្រជាក់បៀតបៀន មានក្តៅបៀតបៀន ប៉ះពាល់ដោយសម្ផស្សនៃរបោមមូសខ្យល់កំដៅថ្ងៃ និងពស់តូចពស់ធំ ស្លាប់ខ្លួនដោយសេចក្តីស្រេកឃ្លាន បពិត្រមហានាម នេះឯងជាទោសរបស់កាមទាំងឡាយ ដែលបុគ្គលគប្បីឃើញចំពោះភ្នែក ជាគំនរនៃទុក្ខ មានកាមជាហេតុ មានកាមជាគ្រឿងប្រគល់ឲ្យនូវផល មានកាមជាគ្រឿងផ្តួចផ្តើម ជាបច្ច័យនៃកាមទាំងឡាយមែនពិត ។ បពិត្រមហានាម កាលបើកុលបុត្រនោះប្រឹងប្រែង ខ្នះខ្នែង ព្យាយាម យ៉ាងនេះហើយ ភោគៈទាំងនោះ ក៏មិនបានសម្រេច កុលបុត្តនោះតែងក្រៀមក្រំចិត្ត លំបាក ខ្សឹកខ្សួល គក់ទ្រូងទ្រហោយំ ដល់នូវសេចក្តីវង្វេងថា ៖ សេចក្តីប្រឹងប្រែងរបស់អាត្មាអញឥតសារផលការសោះ ៖ សេចក្តីព្យាយាមរបស់អាត្មាអញឥតផលប្រយោជន៍សោះ ។ បពិត្រមហានាម នេះឯងជាទោសរបស់កាមទាំងឡាយ ដែលបុគ្គលគប្បីឃើញចំពោះភ្នែក ជាគំនរនៃទុក្ខ មានកាមជាហេតុ មានកាមជាគ្រឿងប្រគល់ឲ្យនូវផល មានកាមជាគ្រឿងផ្តួចផ្តើម ជាបច្ច័យនៃកាមទាំងឡាយមែនពិត ។ បពិត្រមហានាម កាលបើកុលបុត្រនោះប្រឹងប្រែង ខ្នះខ្នែង ព្យាយាមយ៉ាងនេះហើយ ភោគៈទាំងនោះ

អភិនិប្ផជ្ជន្តិ សោ តេសំ ភោគានំ អារក្ខាធិករណំ ទុក្ខំ ទោមនស្សំ បដិសំវេទេតិ កិន្តិ មេ ភោគេ នេវ រាជានោ ហរេយ្យុំ ន ចោរា ហរេយ្យុំ ន អគ្គិ ឌហេយ្យ ន ឧទកំ វហេយ្យ ន អប្បិយា ទាយាទា ហរេយ្យុន្តិ ។ តស្ស ឯវំ អារក្ខតោ គោបយតោ តេ ភោគេ រាជានោ វា ហរន្តិ ចោរា វា ហរន្តិ អគ្គិ វា ឌហតិ ឧទកំ វា វហតិ អប្បិយា ទាយាទា វា ហរន្តិ ។ សោ សោចតិ កិលមតិ បរិទេវតិ ឧរត្តាឡឹ កន្ទតិ សម្មោហំ អាបជ្ជតិ យម្បិ មេ អហោសិ តម្បិ នោ នត្ថីតិ ។ អយម្បិ មហានាម កាមានំ អាទីនវោ សន្ទិដ្ឋិកោ ទុក្ខក្ខន្ធោ កាមហេតុ កាមនិទានំ កាមាធិករណំ កាមានមេវ ហេតុ ។



ក៏បានសម្រេច កុលបុត្រនោះតែងដល់នូវទុក្ខទោមនស្ស ព្រោះហេតុនៃការរក្សានូវភោគៈទាំងឡាយនោះថា ធ្វើម្តេចហ្ន៎ កុំឲ្យព្រះរាជាទាំងឡាយរឹបយកភោគៈទាំងឡាយរបស់អាត្មាអញទៅបាន កុំឲ្យចោរទាំងឡាយលួចយកទៅបាន កុំឲ្យភ្លើងឆេះបាន កុំឲ្យទឹកនាំយកទៅបាន កុំឲ្យអ្នកទទួលមត៌កទាំងឡាយ ដែលមិនជាទីស្រឡាញ់ នាំយកទៅបាន ។ កាលកុលបុត្រនោះ ខំរក្សាគ្រប់គ្រងយ៉ាងនេះហើយ តែគង់តែព្រះរាជាទាំងឡាយ រឹបយកនូវភោគៈទាំងនោះទៅក្តី ចោរទាំងឡាយលួចយកទៅក្តី ភ្លើងឆេះអស់ក្តី ទឹកបណ្តែតទៅក្តី អ្នកទទួលមត៌កទាំងឡាយដែលមិនជាទីស្រឡាញ់តាមយកទៅណាក៏ទៅក្តី កុលបុត្រនោះតែងសោកសៅលំបាក ខ្សឹកខ្សួល គក់ទ្រូង ស្រែកយំ ដល់នូវសេចក្តីវង្វេងថា ទ្រព្យណាបានកើតមានហើយដល់អាត្មាអញ សូម្បីទ្រព្យនោះឯង ក៏ត្រឡប់ជាមិនមានដល់អាត្មាអញវិញឡើយ ។ បពិត្រមហានាម នេះឯងជាទោសរបស់កាមទាំងឡាយ ដែលបុគ្គលគប្បីឃើញទាន់ភ្នែក ជាគំនរនៃទុក្ខ មានកាមជាហេតុ មានកាមជាគ្រឿងប្រគល់ឲ្យនូវផល មានកាមជាគ្រឿងផ្តួចផ្តើម ជាបច្ច័យនៃកាមទាំងឡាយមែនពិត ។

[២៣៤] បុន ចបរំ មហានាម កាមហេតុ កាមនិទានំ កាមាធិករណំ កាមានមេវ ហេតុ រាជានោបិ រាជូហិ វិវទន្តិ ខត្តិយាបិ ខត្តិយេហិ វិវទន្តិ ព្រាហ្មណាបិ ព្រាហ្មណេហិ វិវទន្តិ គហបតីបិ គហបតីហិ វិវទន្តិ មាតាបិ បុត្តេន វិវទតិ បុត្តោបិ មាតរា វិវទតិ បិតាបិ បុត្តេន វិវទតិ បុត្តោបិ បិតរា វិវទតិ ភាតាបិ ភាតរា វិវទតិ ភាតាបិ ភគិនិយា វិវទតិ ភគិនីបិ ភាតរា វិវទតិ សហាយោបិ សហាយេន វិវទតិ ។ តេ តត្ថ កលហវិគ្គហវិវាទាបន្នា អញ្ញមញ្ញំ បាណីហិបិ ឧបក្កមន្តិ លេឌ្ឌូហិបិ ឧបក្កមន្តិ ទណ្ឌេហិបិ ឧបក្កមន្តិ សត្ថេហិបិ ឧបក្កមន្តិ តេ តត្ថ មរណម្បិ និគច្ឆន្តិ មរណមត្តម្បិ ទុក្ខំ ។ អយម្បិ មហានាម



(២១៤) ម្នាលព្រះនាមមហានាម មួយទៀត ព្រោះតែកាមជាហេតុ មានកាមជាគ្រឿងប្រគល់ឲ្យនូវផល មានកាមជាគ្រឿងផ្តួចផ្តើម ជាបច្ច័យនៃកាមទាំងឡាយមែនពិត ម្នាលព្រះរាជាទាំងឡាយតែងទាស់ទែងគ្នានឹងព្រះរាជាទាំងឡាយខ្លះ ក្សត្រទាំងឡាយទាស់ទែងគ្នានឹងក្សត្រទាំងឡាយខ្លះ ព្រាហ្មណ៍ទាំងឡាយ ទាស់ទែងគ្នានឹងព្រាហ្មណ៍ទាំងឡាយខ្លះ គហបតីទាំងឡាយ ទាស់ទែងគ្នានឹងគហបតីទាំងឡាយខ្លះ មាតាទាស់ទែងគ្នានឹងបុត្រខ្លះ បុត្រទាស់ទែងគ្នានឹងមាតាខ្លះ បិតាទាស់ទែងគ្នានឹងបុត្រខ្លះ បុត្រទាស់ទែងគ្នានឹងបិតាខ្លះ បងប្អូនប្រុសទាស់ទែងគ្នានឹងបងប្អូនប្រុសខ្លះ បងប្អូនប្រុសទាស់ទែងគ្នានឹងបងប្អូនស្រីខ្លះ បងប្អូនស្រីទាស់ទែងគ្នានឹងបងប្អូនប្រុសខ្លះ សំឡាញ់ទាស់ទែងគ្នានឹងសំឡាញ់ខ្លះ ។ ពួកមនុស្សទាំងនោះ ក៏ដល់នូវសេចក្តីឈ្លោះប្រកែក ប្រកាន់ខុស ទាស់ទែងគ្នាក្នុងទីនោះ ហើយប្រហារគ្នានឹងគ្នាដោយដៃខ្លះ ប្រហារគ្នាដោយដុំដីខ្លះ ប្រហារគ្នាដោយដំបងខ្លះ ប្រហារគ្នាដោយគ្រឿងសស្ត្រាវុធខ្លះ ពួកមនុស្សទាំងនោះ ក៏ដល់នូវសេចក្តីស្លាប់ខ្លះ ដល់នូវសេចក្តីទុក្ខស្មើនឹងស្លាប់ខ្លះ ក្នុងទីនោះ ។ បពិត្រមហានាម នេះឯង

កាមានំ អាទីនវោ សន្ទិដ្ឋិកោ ទុក្ខក្ខន្ធោ កាមហេតុ កាមនិទានំ កាមាធិករណំ កាមានមេវ ហេតុ ។

(២១៨) បុន ចបរំ មហានាម កាមហេតុ កាមនិទានំ កាមាធិករណំ កាមានមេវ ហេតុ អសិចម្មំ គហេត្វា ធនុកលាបំ សន្នយ្ហិត្វា ឧភតោព្យូឡ្ហំ សង្គាមំ បក្ខន្ទន្តិ ឧសូសុបិ ខិប្បមានេសុ សត្តីសុបិ ខិប្បមានាសុ អសីសុបិ វិជ្ជោតលន្តេសុ តេ តត្ថ ឧសូហិបិ វិជ្ឈន្តិ សត្តិយាបិ វិជ្ឈន្តិ អសិនាបិ សីសំ ឆិន្ទន្តិ តេ តត្ថ មរណម្បិ និគច្ឆន្តិ មរណមត្តម្បិ ទុក្ខំ ។ អយម្បិ មហានាម កាមានំ អាទីនវោ សន្ទិដ្ឋិកោ ទុក្ខក្ខន្ធោ កាមហេតុ កាមនិទានំ កាមាធិករណំ កាមានមេវ ហេតុ ។



ជាទោសរបស់កាមទាំងឡាយ ដែលបុគ្គលគប្បីឃើញច្បាស់ក្នុង ជាគំនរនៃទុក្ខ មានកាមជាហេតុ មានកាមជាគ្រឿងប្រគល់ឲ្យនូវផល មានកាមជាគ្រឿងផ្តួចផ្តើម ជាបច្ច័យនៃកាមទាំងឡាយមែនពិត ។

(២១៨) បពិត្រមហានាម មួយទៀត ព្រោះតែមានកាមជាហេតុ មានកាម ជាគ្រឿងប្រគល់ឲ្យនូវផល មានកាម ជាគ្រឿងផ្តួចផ្តើម ជាបច្ច័យនៃកាមទាំងឡាយមែនពិត ពួកជាមនុស្សទាំងឡាយ កាន់យកនូវដាវនិងខែល កាន់យកនូវធ្នូ សៀតបំពង់ព្រួញ ចូលទៅកាន់សង្គ្រាម ដែលលើកជាក្បួនទ័ព មកទាំងសងខាង កាលដែលគេបាញ់ព្រួញមកក្តី កាលដែលគេពួយលំពែងមកក្តី កាលដែលគេឆាដាវឡើងក្តី ពួកមនុស្សទាំងនោះ ក៏បាញ់គ្នា ដោយព្រួញខ្លះ ចាក់គ្នាដោយលំពែងខ្លះ កាប់ក្បាលគ្នាដោយដាវខ្លះ ក្នុងសង្គ្រាមនោះ ពួកមនុស្សទាំងនោះ ដល់នូវសេចក្តីស្លាប់ខ្លះ ដល់នូវសេចក្តីទុក្ខស្ទើរតែនឹងស្លាប់ខ្លះ ក្នុងសង្គ្រាមនោះ ។ បពិត្រមហានាម នេះឯងជាទោស របស់កាមទាំងឡាយ ដែលបុគ្គលគប្បីឃើញច្បាស់ក្នុង មានកាមជាហេតុ មានកាមជាគ្រឿងប្រគល់ឲ្យនូវផល មានកាមជាគ្រឿងផ្តួចផ្តើម ជាបច្ច័យនៃកាមទាំងឡាយមែនពិត ។

(៤០៦) បុន ចបរំ មហានាម កាមហេតុ កាមនិទានំ កាមាធិករណំ កាមានមេវ ហេតុ អសិចម្មំ គហេត្វា ធនុកលាបំ សន្នយ្ហិត្វា អទ្ទាវលេបនា ឧបការិយោ បក្ខន្ទន្តិ ឧសូសុបិ ខិប្បមានេសុ សត្តីសុបិ ខិប្បមានេសុ អសីសុបិ វិជ្ជោតលន្តេសុ តេ តត្ថ ឧសូហិបិ វិជ្ឈន្តិ សត្តិយាបិ វិជ្ឈន្តិ ឆកណាដិយាបិ ឱសិញ្ចន្តិ អភិវគ្គេនបិ ឱមទ្ទន្តិ អសិនាបិ សីសំ ឆិន្ទន្តិ តេ តត្ថ មរណម្បិ និគច្ឆន្តិ មរណមត្តម្បិ ទុក្ខំ ។ អយម្បិ មហានាម កាមានំ អាទីនវោ សន្ទិដ្ឋិកោ ទុក្ខក្ខន្ធោ កាមហេតុ កាមនិទានំ កាមាធិករណំ កាមានមេវ ហេតុ ។

(៤០៧) បុន ចបរំ មហានាម កាមហេតុ កាមនិទានំ កាមាធិករណំ កាមានមេវ ហេតុ



(៤០៦) ម្នាលព្រះនាមមហានាម មួយទៀត ព្រោះតែមានកាមជាហេតុ មានកាម ជាគ្រឿងប្រគល់ឲ្យនូវផល មានកាម ជាគ្រឿងផ្តួចផ្តើម ជាបច្ច័យនៃកាមទាំងឡាយមែនពិត ពួកមនុស្សទាំងនោះ កាន់យកនូវដាវនិងខែល កាន់ធ្នូ សៀតបំពង់ព្រួញ ចូលទៅកាន់បន្ទាយ ដែលលាបបូកដោយបាយអ កាលដែលគេបាញ់ព្រួញមកក្តី កាលដែលគេពួយលំពែងមកក្តី កាលដែលគេឆាដាវឡើងក្តី ពួកមនុស្សទាំងនោះ ក៏បាញ់គ្នាដោយព្រួញខ្លះ ចាក់គ្នាដោយលំពែងខ្លះ ដួសសាចដាក់គ្នាដោយអាចម៍គោក្តៅខ្លះ ញាំញីគ្នា ដោយនាស់ផែកខ្លះ កាប់ក្បាលគ្នាដោយដាវខ្លះ ក្នុងបន្ទាយនោះ ពួកមនុស្សទាំងនោះ ដល់នូវសេចក្តីស្លាប់ខ្លះ ដល់នូវសេចក្តីទុក្ខស្មើតែនឹងស្លាប់ខ្លះ ក្នុងបន្ទាយនោះ ។ បពិត្រមហានាម នេះឯងជាទោស របស់កាមទាំងឡាយ ដែលបុគ្គលគប្បីឃើញបានភ្លាម ជាគំនរនៃទុក្ខ មានកាមជាហេតុ មានកាមជាគ្រឿងប្រគល់ឲ្យនូវផល មានកាមជាគ្រឿងផ្តួចផ្តើម ជាបច្ច័យនៃកាមទាំងឡាយមែនពិត ។

(៤០៧) ម្នាលព្រះនាមមហានាម មួយទៀត ព្រោះតែមានកាមជាហេតុ មានកាមជាគ្រឿងប្រគល់ឲ្យនូវផល មានកាម ជាគ្រឿងផ្តួចផ្តើម ជាបច្ច័យនៃកាមទាំងឡាយ មែនពិត មនុស្សទាំងឡាយ

សន្ធិម្បិ ឆិន្ទន្តិ និល្លោបម្បិ ហរន្តិ ឯកាគារិកម្បិ ករោន្តិ បរិបន្ថេបិ តិដ្ឋន្តិ បរទារម្បិ គច្ឆន្តិ តមេនំ រាជានោ គហេត្វា វិវិធា កម្មការណា ការេន្តិ កសាហិបិ តាឡេន្តិ វេត្តេហិបិ តាឡេន្តិ អឌ្ឍទណ្ឌកេហិបិ តាឡេន្តិ ។ បេ ។ ជោតិមាលិកម្បិ ករោន្តិ ហត្ថបជ្ជោតិកម្បិ ករោន្តិ ឯរកវត្តិកម្បិ ករោន្តិ ចីរកវាសិកម្បិ ករោន្តិ ឯណេយ្យកម្បិ ករោន្តិ ពលិសមំសិកម្បិ ករោន្តិ កហាបណកម្បិ ករោន្តិ ខារាបតច្ឆិកម្បិ ករោន្តិ បលិឃបរិវត្តិកម្បិ ករោន្តិ បលាលបីឋកម្បិ ករោន្តិ តត្តេនបិ តេលេន ឱសិញ្ចន្តិ សុនខេហិបិ ខាទាបេន្តិ ជីវន្តម្បិ សូលេ ឧត្តាសេន្តិ អសិនាបិ សីសំ ឆិន្ទន្តិ តេ



កាត់នូវផ្ទាំងផ្ទះខ្លះ ប្លន់ខ្លះ កំហែងយកទ្រព្យក្នុងផ្ទះមួយៗខ្លះ ឈរស្កាត់ប្លន់ផ្លូវខ្លះ គប់រកនូវភរិយារបស់អ្នកដទៃខ្លះ ព្រះរាជាទាំងឡាយចាប់មនុស្សទាំងនោះបានហើយ ត្រាស់បង្គាប់ឲ្យធ្វើកម្មករណ៍ទាំងឡាយ មានប្រការផ្សេងៗ គឺឲ្យវាយដោយរំពាត់ខ្លះ ឲ្យវាយដោយផ្តៅខ្លះ ឲ្យវាយដោយដំបងខ្លីខ្លះ ។ បេ ។ ធ្វើនូវជោតិមាលិកកម្ម(១) គឺអំពើដែលគេធ្វើខ្លួនមនុស្សឲ្យដូចជាផ្កាភ្លើងខ្លះ ធ្វើនូវហត្ថបជ្ជោតិកកម្ម(២) គឺអំពើដែលគេដុតដៃខ្លះ ធ្វើនូវឯរកវត្តិកកម្ម(៣) គឺអំពើដែលគេធ្វើឲ្យដូចជាពន្ទាត់ស្បែកពពែខ្លះ ធ្វើនូវចីរកវាសិកកម្ម(៤) គឺអំពើដែលគេធ្វើ ឲ្យដូចជាគេស្លៀកសំពត់សម្បកឈើខ្លះ ធ្វើនូវឯណេយ្យកកម្ម(៥) គឺអំពើដែលធ្វើ ឲ្យដូចជាជើងសត្វក្រាយខ្លះ ធ្វើនូវពលិសមំសិកកម្ម(៦) គឺអំពើដែលគេចាក់ទាញដោយកាំបុសសន្ទូចខ្លះ ធ្វើនូវកហាបណកកម្ម(៧) គឺអំពើដែលគេធ្វើ ឲ្យខូចសរីរៈប្រមាណប៉ុនកហាបណៈខ្លះ ធ្វើនូវខារាបតច្ឆិកកម្ម(៨) គឺអំពើដែលគេយកទឹកផ្សារស្រោចខ្លះ ធ្វើបលិឃបរិវត្តិកកម្ម(៩) គឺអំពើដែលគេធ្វើឲ្យដូចជាគេបង្វិលដើមគល់ឬសសរគោលខ្លះ ធ្វើនូវបលាលបីឋកកម្ម(១០) គឺអំពើដែលគេធ្វើឲ្យដូចជាកណ្តាប់ចំបើងខ្លះ ស្រោចដោយប្រេងដែលក្តៅខ្លះ ឲ្យឆ្កែខាំខ្លះ ឲ្យដេកផ្ងារលើឈើអណ្តោតទាំងរស់ខ្លះ កាត់ក្បាលដោយដាវខ្លះ មនុស្សទាំងនោះ

---

១–២–៣–៤–៥–៦–៧–៨–៩–១០ ចូរមើលមហាទុក្ខក្ខន្ធសូត្រខាងដើមសូត្រនេះចុះ ។

តត្ថ មរណម្បិ និគច្ឆន្តិ មរណមត្តម្បិ ទុក្ខំ ។ អយម្បិ មហានាម កាមានំ អាទីនវោ សន្ទិដ្ឋិកោ ទុក្ខក្ខន្ធោ កាមហេតុ កាមនិទានំ កាមាធិករណំ កាមានមេវ ហេតុ ។

(២១៨) បុន ចបរំ មហានាម កាមហេតុ កាមនិទានំ កាមាធិករណំ កាមានមេវ ហេតុ កាយេន ទុច្ចរិតំ ចរន្តិ វាចាយ ទុច្ចរិតំ ចរន្តិ មនសា ទុច្ចរិតំ ចរន្តិ តេ កាយេន ទុច្ចរិតំ ចរិត្វា វាចាយ ទុច្ចរិតំ ចរិត្វា មនសា ទុច្ចរិតំ ចរិត្វា កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជន្តិ ។ អយំ មហានាម កាមានំ អាទីនវោ សម្បរាយិកោ ទុក្ខក្ខន្ធោ កាមហេតុ កាមនិទានំ កាមាធិករណំ កាមានមេវ ហេតុ ។



ក៏ដល់នូវសេចក្ដីស្លាប់ខ្លះ ដល់នូវសេចក្ដីទុក្ខស្មើនឹងស្លាប់ខ្លះ ក្នុងទីនោះ ។ បពិត្រមហានាម នេះឯងជាទោស របស់កាមទាំងឡាយ ដែលបុគ្គលគប្បីឃើញចំពោះភ្នែក ជាគំនរនៃទុក្ខ មានកាមជាហេតុ មានកាមជាគ្រឿងប្រគល់ឲ្យនូវផល មានកាមជាគ្រឿងផ្តួចផ្តើម ជាបច្ច័យនៃកាមទាំងឡាយមែនពិត ។

(២១៨) បពិត្រមហានាម មួយទៀត ព្រោះតែមានកាមជាហេតុ មានកាមជាគ្រឿងប្រគល់ឲ្យនូវផល មានកាមជាគ្រឿងផ្តួចផ្តើម ជាបច្ច័យនៃកាមទាំងឡាយមែនពិត ពួកជនទាំងឡាយប្រព្រឹត្តទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្ត ជនទាំងឡាយនោះ លុះប្រព្រឹត្តទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្តហើយ លុះដល់បែកធ្លាយរាងកាយបន្ទាប់អំពីមរណៈទៅ ក៏ទៅកើតឯអបាយ ទុគ្គតិ វិនិបាត នរក ។ បពិត្រមហានាម នេះឯងជាទោស របស់កាមទាំងឡាយ ដែលប្រព្រឹត្តទៅក្នុងសម្បរាយិកភព ជាគំនរនៃទុក្ខ មានកាមជាហេតុ មានកាមជាគ្រឿងប្រគល់ឲ្យនូវផល មានកាមជាគ្រឿងផ្តួចផ្តើម ជាបច្ច័យនៃកាមទាំងឡាយមែនពិត ។

(២១៩) ឯកមិទាហំ មហានាម សមយំ រាជគហេ វិហរាមិ គិជ្ឈកូដេ បព្វតេ ។ តេន ខោ បន សមយេន សម្ពហុលា និគណ្ឋា ឥសិគិលិបស្សេ កាឡសិលាយំ ឧព្ភដ្ឋកា ហោន្តិ អាសនបដិក្ខិត្តា ឱបក្កមិកា ទុក្ខា តិប្បា[១] ខរា[២] កដុកា វេទនា វេទិយន្តិ ។ អថ ខ្វាហំ[៣] មហានាម សាយណ្ហសមយំ បដិសល្លានា វុដ្ឋិតោ យេន ឥសិគិលិបស្សំ[៤] កាឡសិលា យេន និគណ្ឋា[៥] តេនុបសង្កមឹ ឧបសង្កមិត្វា តេ និគណ្ឋេ ឯតទវោចំ កិន្នុ តុម្ហេ អាវុសោ និគណ្ឋា ឧព្ភដ្ឋកា ហោថ[៦] អាសនបដិក្ខិត្តា ឱបក្កមិកា ទុក្ខា តិប្បា ខរា កដុកា វេទនា វេទិយថាតិ ។ ឯវំ វុត្តេ មហានាម តេ និគណ្ឋា មំ ឯតទវោចុំ និគណ្ឋោ អាវុសោ នាដបុត្តោ សព្វញ្ញូ សព្វទស្សាវី អបរិសេសំ ញាណទស្សនំ បដិជានាតិ ចរតោ ច មេ តិដ្ឋតោ ច សុត្តស្ស ច ជាគរស្ស ច សតតំ សមិតំ ញាណទស្សនំ បច្ចុបដ្ឋិតន្តិ ។ សោ

១ ម. តិព្វា ។ ២ ឱ.ម. ខរាតិ នត្ថិ ។ ៣ ឱ.ម. អថខោហំ ។ ៤ ឱ. ឥសិគិលិបស្សំ ។ ៥ ឱ ម. តេ និគណ្ឋា ។ ៦ ឱ ម. ហោថាតិ នត្ថិ ។



(២១៩) បពិត្រមហានាម មានកាលសម័យមួយ តថាគតនៅក្នុងភ្នំគិជ្ឈកូដ ទៀបក្រុងរាជគ្រឹះ ។ សម័យនោះឯង ពួកនិគ្រន្ថជាច្រើន ជាអ្នកឈរតើយ លើផ្ទៃកាឡសិលា ទៀបភ្នំឥសិគិលិ ជាអ្នកឃាត់អាសនៈ តែងទទួលនូវវេទនា ជាទុក្ខដ៏ខ្លាំងក្លា ក្រហល់ក្រហាយ ដែលកើតអំពីសេចក្ដីព្យាយាម ។ បពិត្រមហានាម គ្រានោះឯង តថាគតក្រោកអំពីទីសម្ងំ ក្នុងវេលាល្ងាច ហើយចូលទៅឯកាឡសិលា ខាងភ្នំឥសិគិលិ សំដៅទៅត្រង់ទីដែលពួកនិគ្រន្ថនៅ លុះចូលទៅដល់ហើយ បានសួរពួកនិគ្រន្ថទាំងនោះ ដូច្នេះថា ម្នាលអាវុសោនិគ្រន្ថទាំងឡាយ ចុះព្រោះហេតុអ្វី បានជាអ្នកទាំងឡាយ នាំគ្នាឈរតើយ ឃាត់អាសនៈ ទទួលនូវវេទនាជាទុក្ខដ៏ខ្លាំងក្លា ក្រហល់ក្រហាយដែលកើតអំពីសេចក្ដីព្យាយាមដូច្នេះ ។ បពិត្រមហានាម កាលតថាគតសួរយ៉ាងនេះហើយ និគ្រន្ថទាំងនោះបាននិយាយតបពាក្យនេះនឹងតថាគតថា ម្នាលអាវុសោ និគ្រន្ថនាដបុត្រ (ជាគ្រូយើង) ជាអ្នកដឹងសព្វ ឃើញសព្វ ប្ដេជ្ញានូវញាណទស្សនៈ នៃការដឹងនិងការឃើញ មិនមានសេសសល់ថា កាលអញ កាលដើរក្ដី ឈរក្ដី ដេកលក់ក្ដី ភ្ញាក់ឡើងក្ដី ក៏មានញាណទស្សនៈតាំងស៊ប់ជានិច្ចមិនដែលដាច់ និគ្រន្ថនាដបុត្រនោះ

ឯវមាហ អត្ថិ ខោ វោ[១] និគណ្ឋា បុព្វេ បាបកម្មំ កតំ តំ ឥមាយ កដុកាយ[២] ទុក្ករការិកាយ និជ្ជរេថ យំ បនេត្ថ ឯតរហិ កាយេន សំវុតា វាចាយ សំវុតា មនសា សំវុតា តំ អាយតឹ បាបស្ស កម្មស្ស អករណំ ឥតិ បុរាណានំ កម្មានំ តបសា ព្យន្តីភាវា នវានំ កម្មានំ អករណា អាយតឹ អនវស្សវោ អាយតឹ អនវស្សវា កម្មក្ខយោ កម្មក្ខយា ទុក្ខក្ខយោ ទុក្ខក្ខយា វេទនាក្ខយោ វេទនាក្ខយា សព្វំ ទុក្ខំ និជ្ជិណ្ណំ ភវិស្សតីតិ តញ្ច បន អម្ហាកំ រុច្ចតិ ចេវ ខមតិ ច តេន ចម្ហា អត្តមនាតិ ។

(២២០) ឯវំ វុត្តេ អហំ មហានាម តេ និគណ្ឋេ ឯតទវោចំ កឹ បន តុម្ហេ អាវុសោ និគណ្ឋា ជានាថ អហុវម្ហេវ[៣] មយំ បុព្វេ ន នាហុវម្ហាតិ ។

១ ឱ. ភេតិ បាឋោ ទិស្សតិ ។ ២ ឱ.ម. កដុកាយ ។ ៣ ឱ.ម. អហុវម្ហេវ ។



ពោលយ៉ាងនេះថា ម្នាលនិគ្រន្ថទាំងឡាយជាចំរើន បាបកម្មដែលអ្នកទាំងឡាយបានធ្វើហើយ ក្នុងកាលមុនក៏មានដែរ អ្នកទាំងឡាយ ចូរញុំាងបាបកម្មនោះឲ្យសាបសូន្យទៅ ដោយអំពើតម្រង់ជាទុក្ខនេះ ក៏ការដែលអ្នកទាំងឡាយ សង្រួមដោយកាយ សង្រួមដោយវាចា សង្រួមដោយចិត្ត ក្នុងអំពើដ៏តម្រង់នុ៎ះ ក្នុងកាលឥឡូវនេះ នោះឈ្មោះថាមិនធ្វើនូវបាបកម្មតទៅ ព្រោះហេតុនោះ កម្មចាស់ទាំងឡាយដែលវិនាសទៅ ដោយសាសេចក្តីព្យាយាម ទាំងកម្មថ្មីទាំងឡាយដែលមិនបានធ្វើ ឈ្មោះថានឹងមិនមានការជាប់តាមតទៅ ព្រោះមិនមានការជាប់តាមតទៅ ឈ្មោះជានឹងអស់ទៅនៃកម្ម ព្រោះអស់ទៅនៃកម្ម ឈ្មោះជានឹងអស់ទៅនៃទុក្ខ ព្រោះអស់ទៅនៃទុក្ខ ឈ្មោះជានឹងអស់ទៅនៃវេទនា ព្រោះអស់ទៅនៃវេទនា ឈ្មោះថាទុក្ខទាំងពួងនឹងសាបសូន្យទៅ ក៏ពាក្យនោះឯងត្រូវគាប់ចិត្តផង គួរផង ដល់យើងទាំងឡាយ យើងទាំងឡាយ ជាអ្នកមានចិត្តត្រេកអរ ដោយពាក្យនោះ ។

(២២០) បពិត្រមហានាម កាលនិគ្រន្ថទាំងឡាយ ពោលយ៉ាងនេះហើយ តថាគតក៏បានសួរពួកនិគ្រន្ថទាំងនោះ ដូច្នេះថា ម្នាលអាវុសោនិគ្រន្ថទាំងឡាយ ចុះអ្នកទាំងឡាយ ដឹងថា យើងទាំងឡាយ ធ្លាប់កើត ក្នុងកាលមុន ឬមិនដឹងថា មិនធ្លាប់កើត ក្នុងកាលមុនទេ ។

នោ ហិទំ អាវុសោតិ[១] ។ កឹ បន តុម្ហេ អាវុសោ និគណ្ឋា ជានាថ អករម្ហា[២] មយំ បុព្វេ បាបកម្មំ ន នាករម្ហាតិ ។ នោ ហិទំ អាវុសោតិ ។ កឹ បន តុម្ហេ អាវុសោ និគណ្ឋា ជានាថ ឯវរូបំ វា ឯវរូបំ វា បាបកម្មំ អករម្ហាតិ ។ នោ ហិទំ អាវុសោតិ ។ កឹ បន តុម្ហេ អាវុសោ និគណ្ឋា ជានាថ ឯត្តកំ វា ទុក្ខំ និជ្ជិណ្ណំ ឯត្តកំ វា ទុក្ខំ និជ្ជីរេតព្វំ ឯត្តកម្ហិ វា ទុក្ខេ និជ្ជិណ្ណេ សព្វំ ទុក្ខំ និជ្ជិណ្ណំ ភវិស្សតីតិ ។ នោ ហិទំ អាវុសោតិ ។ កឹ បន តុម្ហេ អាវុសោ និគណ្ឋា ជានាថ ទិដ្ឋេវ ធម្មេ អកុសលានំ ធម្មានំ បហានំ កុសលានំ ធម្មានំ ឧបសម្បទន្តិ ។ នោ ហិទំ អាវុសោតិ ។ ឥតិ កិរ តុម្ហេ អាវុសោ និគណ្ឋា ន ជានាថ អហុវម្ហេវ មយំ បុព្វេ

១ ឱ.ម. អាវុសោ ។ ២ ឱ.ម. អាករម្ហ ។



និគ្រន្ថទាំងឡាយឆ្លើយតបថា ម្នាលអាវុសោ ដំណើរនេះយើងខ្ញុំមិនបានដឹងទេ ។ ម្នាលអាវុសោនិគ្រន្ថទាំងឡាយ ចុះអ្នកទាំងឡាយ ដឹងថា យើងទាំងឡាយ បានធ្វើនូវបាបកម្មក្នុងកាលមុន ឬមិនដឹងថា មិនបានធ្វើនូវបាបកម្មក្នុងកាលមុនទេ ។ ម្នាលអាវុសោ ដំណើរនេះយើងខ្ញុំមិនបានដឹងទេ ។ ម្នាលអាវុសោនិគ្រន្ថទាំងឡាយ ចុះអ្នកទាំងឡាយ ដឹងថា យើងទាំងឡាយ បានធ្វើនូវបាបកម្មមានសភាពយ៉ាងនេះខ្លះ យ៉ាងនោះខ្លះ ដូច្នេះដែរឬ ។ ម្នាលអាវុសោ ដំណើរនេះយើងខ្ញុំមិនបានដឹងទេ ។ ម្នាលអាវុសោនិគ្រន្ថទាំងឡាយ ចុះអ្នកទាំងឡាយ ដឹងថា ទុក្ខមានប្រមាណប៉ុណ្ណេះសាបសូន្យហើយឬ ទុក្ខមានប្រមាណប៉ុណ្ណេះគប្បីសាបសូន្យទៅឬ កាលបើទុក្ខមានប្រមាណប៉ុណ្ណេះសាបសូន្យហើយ ទុក្ខទាំងអស់នឹងសាបសូន្យទៅដូច្នេះដែរឬ ។ ម្នាលអាវុសោ ដំណើរនេះយើងខ្ញុំមិនបានដឹងទេ ។ ម្នាលអាវុសោនិគ្រន្ថទាំងឡាយ ចុះអ្នកទាំងឡាយ ដឹងថា ក្នុងសាសនារបស់ពួកអ្នកមានការលះបង់នូវធម៌ទាំងឡាយជាអកុសល ញុំាងធម៌ទាំងឡាយជាកុសលឲ្យកើតឡើងក្នុងបច្ចុប្បន្ននេះដូច្នេះដែរឬ ។ ម្នាលអាវុសោ ដំណើរនេះ យើងមិនបានដឹងទេ ។ ម្នាលអាវុសោនិគ្រន្ថទាំងឡាយ បានឮថា អ្នកទាំងឡាយមិនដឹងថា យើងទាំងឡាយបានកើតក្នុងកាលមុន

ន នាហុវម្ហាតិ ន ជានាថ អករម្ហេវ មយំ បុព្វេ បាបកម្មំ ន នាករម្ហាតិ ន ជានាថ ឯវរូបំ វា ឯវរូបំ វា បាបកម្មំ អករម្ហាតិ ន ជានាថ ឯត្តកំ វា ទុក្ខំ និជ្ជិណ្ណំ ឯត្តកំ វា ទុក្ខំ និជ្ជីរេតព្វំ ឯត្តកម្ហិ វា ទុក្ខេ និជ្ជិណ្ណេ សព្វំ ទុក្ខំ និជ្ជិណ្ណំ ភវិស្សតីតិ ន ជានាថ ទិដ្ឋេវ ធម្មេ អកុសលានំ ធម្មានំ បហានំ កុសលានំ ធម្មានំ ឧបសម្បទំ ឯវំ សន្តេ អាវុសោ និគណ្ឋា យេ លោកេ លុទ្ទា លោហិតបាណិនោ កុរូរកម្មន្តា មនុស្សេសុ បច្ចាជាតា តេ និគណ្ឋេសុ បព្វជ្ជន្តីតិ ។ ន ខោ អាវុសោ គោតម សុខេន សុខំ អធិគន្តព្វំ ទុក្ខេន ខោ សុខំ អាវុសោ គោតម អធិគន្តព្វំ សុខេន ច អាវុសោ គោតម សុខំ អធិគន្តព្វំ អភវិស្ស រាជា មាគធោ សេនិយោ ពិម្ពិសារោ សុខំ អធិគច្ឆេយ្យ រាជា មាគធោ សេនិយោ ពិម្ពិសារោ



មិនមែនថា មិនធ្លាប់កើតមកហើយ មិនដឹងថា យើងទាំងឡាយ បានធ្វើនូវបាបកម្មក្នុងកាលមុន មិនមែនថាមិនបានធ្វើមកហើយ មិនដឹងថា យើងទាំងឡាយបានធ្វើបាបកម្មមានសភាពយ៉ាងនេះខ្លះ យ៉ាងនោះខ្លះ ដូច្នេះទេ មិនបានដឹងថា ទុក្ខមានប្រមាណប៉ុណ្ណេះសាបសូន្យហើយ ឬទុក្ខមានប្រមាណប៉ុណ្ណេះគប្បីសាបសូន្យទៅ ឬក៏កាលបើទុក្ខ មានប្រមាណប៉ុណ្ណេះសាបសូន្យទៅហើយ ទុក្ខទាំងអស់ក៏នឹងសាបសូន្យទៅដូច្នេះទេ មិនបានដឹងថា ក្នុងសាសនារបស់ពួកអ្នកមានការលះបង់នូវធម៌ទាំងឡាយ ជាអកុសល ញុំាងធម៌ទាំងឡាយជាកុសលឲ្យកើតឡើងក្នុងបច្ចុប្បន្ននេះដូច្នេះទេ ម្នាលអាវុសោនិគ្រន្ថទាំងឡាយ កាលបើយ៉ាងនេះ ពួកជនទាំងឡាយណា ក្នុងលោកដែលជាអ្នកមានការបៀតបៀន [illegible] មានដៃប្រឡាក់ដោយឈាម មានការងារអាក្រក់ ជនទាំងនោះលុះស្លាប់ទៅកើតក្នុងពួកមនុស្សក្នុងកាលជាខាងក្រោយ ក៏បួសក្នុងពួកនិគ្រន្ថទៀតឬ ។ ពួកនិគ្រន្ថឆ្លើយតបថា អាវុសោគោតម បុគ្គលមិនត្រូវបាននូវសេចក្ដីសុខ ដោយសារសេចក្ដីសុខតែម្យ៉ាងក៏ទេ អាវុសោគោតម បុគ្គលមិនត្រូវបាននូវសេចក្ដីសុខ ដោយសារសេចក្ដីទុក្ខក៏មាន អាវុសោគោតម បុគ្គលមិនត្រូវបាននូវសេចក្ដីសុខ ដោយសារសេចក្ដីសុខក៏មាន ដូចព្រះបាទមាគធសេនិយពិម្ពិសាររាជ ទ្រង់សោយនូវសេចក្ដីសុខ ព្រះបាទមាគធសេនិយពិម្ពិសាររាជ

សុខវិហារតរោ អាយស្មតា គោតមេនាតិ ។ អទ្ធា-
យស្មន្តេហិ និគណ្ឋេហិ សហសា អប្បដិសង្ខា វាចា
ភាសិតា ន ខោ អាវុសោ គោតម សុខេន សុខំ អធិ-
គន្តព្វំ ទុក្ខេន ខោ សុខំ អធិគន្តព្វំ សុខេន ច អាវុ-
សោ គោតម សុខំ អធិគន្តព្វំ អភវិស្ស រាជា មាគធោ
សេនិយោ ពិម្ពិសារោ សុខំ អធិគច្ឆេយ្យ រាជា មាគធោ
សេនិយោ ពិម្ពិសារោ សុខវិហារតរោ អាយស្មតា គោត-
មេនាតិ អបិច អហមេវ តត្ថ បដិបុច្ឆិតព្វោ កោ នុ ខោ
អាយស្មន្តានំ សុខវិហារតរោ រាជា វា មាគធោ សេនិ-
យោ ពិម្ពិសារោ អាយស្មា វា គោតមោតិ ។ អទ្ធាវុសោ
គោតម អម្ហេហិ សហសា អប្បដិសង្ខា វាចា ភាសិតា
ន ខោ អាវុសោ គោតម សុខេន សុខំ អធិគន្តព្វំ
ទុក្ខេន ខោ សុខំ អធិគន្តព្វំ សុខេន ច អាវុសោ
គោតម សុខំ អធិគន្តព្វំ អភវិស្ស រាជា មាគធោ
សេនិយោ ពិម្ពិសារោ សុខំ អធិគច្ឆេយ្យ រាជា មាគធោ



ទ្រង់គង់នៅជាសុខលើសលុបជាងព្រះគោតមដ៏មានអាយុ ។ អាត្មាអញ
តបថា ពួកនិគ្រន្ថដ៏មានអាយុ មិនបានពិចារណា ហើយស្រាប់តែ
ពោលពាក្យដោយរហ័សថា អាវុសោគោតម បុគ្គលមិនត្រូវបាននូវសេច-
ក្តីសុខ ដោយសារសេចក្តីសុខតែម្យ៉ាងក៏ទេ បុគ្គលមិនត្រូវបាននូវ
សេចក្តីសុខ ដោយសារសេចក្តីទុក្ខក៏មាន អាវុសោគោតម បុគ្គលមិនត្រូវ
បាននូវសេចក្តីសុខ ដោយសារសេចក្តីសុខក៏មាន ដូចព្រះបាទមាគធ-
សេនិយពិម្ពិសារ ទ្រង់សោយនូវសេចក្តីសុខ ព្រះបាទមាគធសេនិយ-
ពិម្ពិសារ ទ្រង់គង់នៅជាសុខលើសលុបជាងព្រះគោតមដ៏មានអាយុ
ដូច្នេះ ចំណែកខាងអាត្មាអញ គង់មានគេសាកសួរក្នុងដំណើរនុ៎ះថា
បណ្តាអ្នកដ៏មានអាយុទាំងឡាយ ចុះព្រះបាទមាគធសេនិយពិម្ពិសារ
នឹងព្រះគោតមដ៏មានអាយុ អ្នកណានៅជាសុខជាង ។ ពួកនិគ្រន្ថឆ្លើយ
តបថា អាវុសោគោតម ពួកយើងខ្ញុំពិតជាមិនបានពិចារណា ហើយស្រាប់
តែពោលពាក្យដោយរហ័សថា អាវុសោគោតម បុគ្គលមិនត្រូវបាននូវ
សេចក្តីសុខ ដោយសារសេចក្តីសុខតែម្យ៉ាងក៏ទេ បុគ្គលមិនត្រូវបាននូវ
សេចក្តីសុខ ដោយសារសេចក្តីទុក្ខក៏មាន អាវុសោគោតម បុគ្គល
មិនត្រូវបាននូវសេចក្តីសុខ ដោយសារសេចក្តីសុខក៏មាន ដូចព្រះបាទ
មាគធសេនិយពិម្ពិសារ ទ្រង់សោយនូវសេចក្តីសុខ ព្រះបាទមាគធ-

សេនិយោ ពិម្ពិសារោ សុខវិហារតរោ អាយស្មតា គោតមេនាតិ អបិច តិដ្ឋតេតំ ឥទានិ មយំ អាយស្មន្តំ គោតមំ បុច្ឆាម កោ នុ ខោ អាយស្មន្តានំ សុខវិហារតរោ រាជា វា មាគធោ សេនិយោ ពិម្ពិសារោ អាយស្មា វា គោតមោតិ ។ តេនហាវុសោ និគណ្ឋា តុម្ហេ[១] តត្ថ បដិបុច្ឆិស្សាមិ យថា វោ ខមេយ្យ តថា នំ ព្យាករេយ្យាថ តំ កឹ មញ្ញថាវុសោ និគណ្ឋា បហោតិ រាជា មាគធោ សេនិយោ ពិម្ពិសារោ អនិញ្ជមានោ កាយេន អភាសមានោ វាចំ សត្ត រត្តិន្ទិវានិ ឯកន្តសុខំ បដិសំវេទី វិហរិតុន្តិ ។ នោ ហិទំ អាវុសោតិ ។ តំ កឹ មញ្ញថាវុសោ និគណ្ឋា បហោតិ រាជា មាគធោ សេនិយោ ពិម្ពិសារោ អនិញ្ជមានោ កាយេន អភាសមានោ វាចំ ឆ រត្តិន្ទិវានិ... បញ្ច រត្តិន្ទិវានិ... ចត្តារិ រត្តិន្ទិវានិ... តីណិ រត្តិន្ទិវានិ... ទ្វេ

១ ម. តុម្ហេវ ។



សេនិយពិម្ពិសាររាជ ទ្រង់គង់នៅជាសុខលើសលុប ជាងព្រះគោតមដ៏មានអាយុប្រាកដមែនហើយ តែថាដំណើរនុ៎ះគួរលើកទុកសិនចុះ ឥឡូវនេះ ពួកខ្ញុំនឹងសួរព្រះគោតមដ៏មានអាយុថា បណ្តាអ្នកដ៏មានអាយុទាំងឡាយ ចុះព្រះបាទមាគធសេនិយពិម្ពិសាររាជ នឹងព្រះគោតមដ៏មានអាយុ នរណានៅជាសុខជាង ។ តថាគតឆ្លើយថា ម្នាលអាវុសោនិគ្រន្ថទាំងឡាយ បើដូច្នោះ តថាគតនឹងត្រឡប់សួរអ្នកទាំងឡាយក្នុងរឿងនោះវិញ អ្នកទាំងឡាយ គួរពេញចិត្តយ៉ាងណា គប្បីព្យាកររឿងនោះយ៉ាងនោះចុះ ម្នាលអាវុសោនិគ្រន្ថទាំងឡាយ ចុះអ្នកទាំងឡាយសំគាល់សេចក្តីនោះថា ដូចម្តេច ព្រះបាទមាគធសេនិយពិម្ពិសាររាជ ទ្រង់អាចមិនកំរើកព្រះកាយ មិនពោលព្រះវាចា ប្រថាប់នៅ សោយសេចក្តីសុខតែម្យ៉ាង អស់ ៧ យប់ ៧ ថ្ងៃបានឬទេ ។ ពួកនិគ្រន្ថតបថា ម្នាលអាវុសោ មិនបានទេ ។ តថាគតសួរថា ម្នាលអាវុសោនិគ្រន្ថទាំងឡាយ អ្នកទាំងឡាយសំគាល់សេចក្តីនោះថាដូចម្តេច ព្រះបាទមាគធសេនិយពិម្ពិសាររាជ ទ្រង់មិនអាចកំរើកព្រះកាយ មិនពោលព្រះវាចា ប្រថាប់នៅ សោយចំពោះនូវសេចក្តីសុខតែម្យ៉ាងអស់ ៦ យប់ ៦ ថ្ងៃ... អស់ ៥ យប់ ៥ ថ្ងៃ... អស់ ៤ យប់ ៤ ថ្ងៃ... អស់ ៣ យប់ ៣ ថ្ងៃ... អស់ ២

រត្តិន្ទិវានិ... ឯកំ រត្តិន្ទិវំ ឯកន្តសុខំ បដិសំវេទី វិហរិតុន្តិ ។ ពោ ហិទំ អាវុសោភតិ ។ អហំ ខោ អាវុសោ និគណ្ឋា បហោមិ អនិញ្ជមានោ កាយេន អភាសមានោ វាចំ ឯកំ រត្តិន្ទិវំ ឯកន្តសុខំ បដិសំវេទី វិហរិតុំ ។ អហំ ខោ អាវុសោ និគណ្ឋា បហោមិ អនិញ្ជមានោ កាយេន អភាសមានោ វាចំ ទ្វេ រត្តិន្ទិវានិ... តីណិ រត្តិន្ទិវានិ... ចត្តារិ រត្តិន្ទិវានិ... បញ្ច រត្តិន្ទិវានិ... ឆ រត្តិន្ទិវានិ... សត្ត រត្តិន្ទិវានិ ឯកន្តសុខំ បដិសំវេទី វិហរិតុំ ។ តំ កិំ មញ្ញថាវុសោ និគណ្ឋា ឯវំ សន្តេ កោ សុខវិហារិតរោ រាជា វា មាគធោ សេនិយោ ពិម្ពិសារោ អហំ វាតិ ។ ឯវំ សន្តេ អាយស្មាវ[១] គោតមោ សុខវិហារិតរោ រញ្ញា មាគធេន សេនិយេន ពិម្ពិសារេនាតិ ។ ឥទមវោច ភគវា អត្តមនោ មហានាមោ សក្កោ ភគវតោ ភាសិតំ អភិនន្ទីតិ ។

ចូឡទុក្ខក្ខន្ធសុត្តំ ចតុត្ថំ និដ្ឋិតំ ។



យប់ ៦ ថ្ងៃ... អស់ ១ យប់ ១ ថ្ងៃបានឬទេ ។ ពួកនិគ្រន្ថឆ្លើយតបថា ម្នាលអាវុសោ មិនបានទេ ។ តថាគតពោលថា ម្នាលអាវុសោនិគ្រន្ថទាំងឡាយ តថាគតហ្នឹងឯង ទើបអាចមិនកំរើកកាយ មិនពោលវាចា សោយចំពោះនូវសេចក្តីសុខអស់ ១ យប់ ១ ថ្ងៃបាន ។ ម្នាលអាវុសោនិគ្រន្ថទាំងឡាយ តថាគតហ្នឹងឯង ទើបអាចមិនកំរើកកាយ មិនពោលវាចា សោយចំពោះនូវសេចក្តីសុខ អស់ ២ យប់ ២ ថ្ងៃ... អស់ ៣ យប់ ៣ ថ្ងៃ... អស់ ៤ យប់ ៤ ថ្ងៃ... អស់ ៥ យប់ ៥ ថ្ងៃ.. អស់ ៦ យប់ ៦ ថ្ងៃ... អស់ ៧ យប់ ៧ ថ្ងៃបាន ។ ម្នាលអាវុសោនិគ្រន្ថទាំងឡាយ អ្នកទាំងឡាយសំគាល់សេចក្តីនោះថាដូចម្តេច កាលបើហេតុយ៉ាងនេះមានហើយ ព្រះបាទមាគធសេនិយពិម្ពិសាររាជ ឬតថាគត អ្នកណាមានសេចក្តីសុខជាង ។ ពួកនិគ្រន្ថទាំងឡាយឆ្លើយតបថា កាលបើហេតុយ៉ាងនេះមានហើយ ព្រះគោតមដ៏មានអាយុ ព្រះអង្គតែងគង់នៅជាសុខ លើសលុបជាងព្រះបាទមាគធសេនិយពិម្ពិសាររាជ ។ លុះព្រះមានព្រះភាគទ្រង់ត្រាស់នូវព្រះសូត្រនេះចប់ហើយ មហានាមសក្យរាជ ក៏មានព្រះហឫទ័យរីករាយអំណរ ត្រេកអរចំពោះភាសិតនៃព្រះមានព្រះភាគ ។

ចប់ ចូឡទុក្ខក្ខន្ធសូត្រ ទី ៤ តែប៉ុណ្ណោះ ។

## បញ្ចមំ អនុមានសុត្តំ

(២២១) ឯវម្មេ សុតំ ។ ឯកំ សមយំ អាយស្មា មហាមោគ្គល្លានោ ភគ្គេសុ វិហរតិ សុំសុមារគិរេ ភេសកឡាវនេ មិគទាយេ ។ តត្រ ខោ អាយស្មា មហាមោគ្គល្លានោ ភិក្ខូ អាមន្តេសិ អាវុសោ ភិក្ខវេតិ ។ អាវុសោតិ ខោ តេ ភិក្ខូ អាយស្មតោ មហាមោគ្គល្លានស្ស បច្ចស្សោសុំ ។

(២២២) អាយស្មា មហាមោគ្គល្លានោ ឯតទវោច បវារេតិ ចេបិ អាវុសោ ភិក្ខុ វទន្តុ មំ អាយស្មន្តោ វចនីយោម្ហិ អាយស្មន្តេហីតិ សោ ច ហោតិ ទុព្វចោ ទោវចស្សករណេហិ ធម្មេហិ សមន្នាគតោ អក្ខមោ អប្បទក្ខិណគ្គាហី អនុសាសនី អថខោ(១) សព្រហ្មចារី ន ចេវ វត្តព្វំ មញ្ញន្តិ ន ច អនុសាសិតព្វំ មញ្ញន្តិ ន ច តស្មឹ បុគ្គលេ វិស្សាសំ អាបជ្ជិតព្វំ មញ្ញន្តិ ។ កតមេ ចាវុសោ ទោវចស្សករណា ធម្មា ។ ឥធាវុសោ

១ ឱ.ម. ខោ នំ ។

## អនុមានសូត្រ ទី ៥

(២២១) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមហាមោគ្គល្លានដ៏មានអាយុ នៅក្នុងភេសកឡាវ័ន ជាទីឲ្យនូវអភ័យដល់ពួកសត្វម្រឹគ ជិតក្រុងសុំសុមារគិរៈ ក្នុងភគ្គជនបទ ។ លំដាប់នោះឯង ព្រះមហាមោគ្គល្លានដ៏មានអាយុ ហៅភិក្ខុទាំងឡាយ ដែលនៅក្នុងទីនោះឯងថា ម្នាលភិក្ខុទាំងឡាយដ៏មានអាយុ ។ ភិក្ខុទាំងនោះបានទទួលតបពាក្យព្រះមហាមោគ្គល្លានដ៏មានអាយុថា ព្រះករុណា ។

(២២២) ព្រះមហាមោគ្គល្លានដ៏មានអាយុ បានពោលពាក្យនេះថា ម្នាលអាវុសោទាំងឡាយ បើភិក្ខុបវារណាថា សូមលោកដ៏មានអាយុទាំងឡាយប្រៀនប្រដៅខ្ញុំចុះ ខ្ញុំជាបុគ្គលដែលលោកដ៏មានអាយុទាំងឡាយគួរស្តីថាបានដូច្នេះ តែភិក្ខុនោះទៅជាអ្នកដែលគេប្រដៅបានដោយក្រ ប្រកបដោយធម៌ដែលធ្វើឲ្យជាអ្នកប្រដៅក្រ ជាអ្នកមិនចេះអត់ធន់ មិនកាន់យកនូវពាក្យប្រដៅដោយបំណែកខាងស្តាំ ការណ៍បើដូច្នេះ សព្រហ្មចារីបុគ្គលទាំងឡាយ តែងសំគាល់នូវភិក្ខុនោះថា មិនគួរស្តីផង សំគាល់ថា មិនគួរប្រៀនប្រដៅផង សំគាល់ថាមិនគួរដល់នូវសេចក្តីស្និទ្ធស្នាលក្នុងបុគ្គលនោះផង ។ ម្នាលអាវុសោទាំងឡាយ ចុះធម៌ដែលធ្វើឲ្យជាអ្នកប្រដៅក្រ តើដូចម្តេចខ្លះ ។ ម្នាលអាវុសោទាំងឡាយ

ភិក្ខុ បាបិច្ឆោ ហោតិ បាបិកានំ ឥច្ឆានំ វសង្គ-
តោ យម្បាវុសោ ភិក្ខុ បាបិច្ឆោ ហោតិ បាបិកានំ
ឥច្ឆានំ វសង្គតោ អយម្បិ ធម្មោ ទោវចស្សករណោ ។
បុន ចបរំ អាវុសោ ភិក្ខុ អត្តុក្កំសកោ ហោតិ បរវម្ភី
យម្បាវុសោ ភិក្ខុ អត្តុក្កំសកោ ហោតិ បរវម្ភី អយម្បិ
ធម្មោ ទោវចស្សករណោ ។ បុន ចបរំ អាវុសោ ភិក្ខុ
កោធនោ ហោតិ កោធាភិភូតោ យម្បាវុសោ ភិក្ខុ
កោធនោ ហោតិ កោធាភិភូតោ អយម្បិ ធម្មោ ទោ-
វចស្សករណោ ។ បុន ចបរំ អាវុសោ ភិក្ខុ កោធនោ
ហោតិ កោធហេតុ ឧបនាហី យម្បាវុសោ ភិក្ខុ កោ-
ធនោ ហោតិ កោធហេតុ ឧបនាហី អយម្បិ ធម្មោ
ទោវចស្សករណោ ។ បុន ចបរំ អាវុសោ ភិក្ខុ កោ-
ធនោ ហោតិ កោធហេតុ អភិសង្គី[1] យម្បាវុសោ ភិក្ខុ
កោធនោ ហោតិ កោធហេតុ អភិសង្គី អយម្បិ ធម្មោ

១ ឱ.ម. អភិសជ្ជី ។



(ធម៌ដែលធ្វើឲ្យជាអ្នកប្រដៅក្រនោះមាន១៦យ៉ាងគឺ) ភិក្ខុក្នុងសាសនានេះ
ជាអ្នកមានសេចក្ដីប្រាថ្នាលាមក លុះក្នុងអំណាចនៃសេចក្ដីប្រាថ្នាលាមក
ម្នាលអាវុសោទាំងឡាយ ត្រង់ដែលភិក្ខុ ជាអ្នកមានសេចក្ដីប្រាថ្នាលា-
មក លុះក្នុងអំណាចនៃសេចក្ដីប្រាថ្នាលាមក នេះឯងជាធម៌ដែលធ្វើឲ្យជា
អ្នកប្រដៅក្រ ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុជាអ្នកលើក
ខ្លួនឯងបន្តុះបង្អាប់អ្នកដទៃ ម្នាលអាវុសោទាំងឡាយ ត្រង់ដែលភិក្ខុជាអ្នក
លើកខ្លួនឯង បន្តុះបង្អាប់អ្នកដទៃ នេះឯងជាធម៌ដែលធ្វើឲ្យជាអ្នកប្រដៅ
ក្រ ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុជាអ្នកក្រោធ ជាអ្នក
មានសេចក្ដីក្រោធគ្របសង្កត់ ម្នាលអាវុសោទាំងឡាយ ត្រង់ដែលភិក្ខុជា
អ្នកក្រោធ ជាអ្នកមានសេចក្ដីក្រោធគ្របសង្កត់ នេះឯងជាធម៌ដែលធ្វើឲ្យ
ជាអ្នកប្រដៅក្រ ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុជា
អ្នកក្រោធ ជាអ្នកចងគំនុំព្រោះសេចក្ដីក្រោធជាហេតុ ម្នាលអាវុសោទាំង
ឡាយ ត្រង់ដែលភិក្ខុជាអ្នកក្រោធ ជាអ្នកចងគំនុំព្រោះសេចក្ដីក្រោធជា
ហេតុ នេះឯងជាធម៌ដែលធ្វើឲ្យជាអ្នកប្រដៅក្រ ១ ។ ម្នាលអាវុសោ
ទាំងឡាយ មួយទៀត ភិក្ខុជាអ្នកក្រោធ ជាអ្នកជេរប្រទេច ព្រោះ
សេចក្ដីក្រោធជាហេតុ ម្នាលអាវុសោទាំងឡាយ ត្រង់ដែលភិក្ខុជាអ្នក
ក្រោធ ជាអ្នកជេរប្រទេច ព្រោះសេចក្ដីក្រោធជាហេតុ នេះឯងជាធម៌

ទោវចស្សករណោ ។ បុន ចបរំ អាវុសោ ភិក្ខុ កោធនោ ហោតិ កោធសាមន្តំ វាចំ និច្ឆារេតា យម្បាវុសោ ភិក្ខុ កោធនោ ហោតិ កោធសាមន្តំ វាចំ និច្ឆារេតា អយម្បិ ធម្មោ ទោវចស្សករណោ ។ បុន ចបរំ អាវុសោ ភិក្ខុ ចោទិតោ ចោទកេន ចោទកំ បដិប្ផរតិ យម្បាវុសោ ភិក្ខុ ចោទិតោ ចោទកេន ចោទកំ បដិប្ផរតិ អយម្បិ ធម្មោ ទោវចស្សករណោ ។ បុន ចបរំ អាវុសោ ភិក្ខុ ចោទិតោ ចោទកេន ចោទកំ អបសាទេតិ យម្បាវុសោ ភិក្ខុ ចោទិតោ ចោទកេន ចោទកំ អបសាទេតិ អយម្បិ ធម្មោ ទោវចស្សករណោ ។ បុន ចបរំ អាវុសោ ភិក្ខុ ចោទិតោ ចោទកេន ចោទកស្ស បច្ចារោបេតិ យម្បាវុសោ ភិក្ខុ ចោទិតោ ចោទកេន ចោទកស្ស បច្ចារោបេតិ អយម្បិ ធម្មោ ទោវចស្សករណោ ។ បុន ចបរំ អាវុសោ ភិក្ខុ ចោទិតោ ចោទកេន ចោទកំ អញ្ញេនញ្ញំ បដិចរតិ ពហិទ្ធា កថំ អបនាមេតិ កោបញ្ច ទោសញ្ច



ដែលធ្វើឲ្យជាអ្នកប្រដៅក្រ ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុជាអ្នកក្រោធ ជាអ្នកបញ្ចេញវាចាជិតសេចក្តីក្រោធ ម្នាលអាវុសោទាំងឡាយ ព្រោះដែលភិក្ខុជាអ្នកក្រោធ ជាអ្នកបញ្ចេញវាចាជិតសេចក្តីក្រោធ នេះឯងជាធម៌ដែលធ្វើឲ្យជាអ្នកប្រដៅក្រ ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុដែលត្រូវភិក្ខុអ្នកចោទចោទហើយ ក៏ទទឹងតបនឹងភិក្ខុអ្នកចោទវិញ ម្នាលអាវុសោទាំងឡាយ ព្រោះដែលភិក្ខុដែលត្រូវភិក្ខុអ្នកចោទចោទហើយក៏ទទឹងតបនឹងភិក្ខុអ្នកចោទវិញ នេះឯងជាធម៌ដែលធ្វើឲ្យជាអ្នកប្រដៅក្រ ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុដែលត្រូវភិក្ខុអ្នកចោទ ចោទហើយក៏បណ្តេញភិក្ខុអ្នកចោទវិញ ម្នាលអាវុសោទាំងឡាយ ព្រោះដែលភិក្ខុត្រូវភិក្ខុអ្នកចោទចោទហើយ ក៏បណ្តេញភិក្ខុអ្នកចោទវិញ នេះឯងជាធម៌ធ្វើឲ្យជាអ្នកប្រដៅក្រ ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុដែលត្រូវភិក្ខុអ្នកចោទចោទហើយនិយាយគ្របសង្កត់ភិក្ខុអ្នកចោទវិញ ម្នាលអាវុសោទាំងឡាយ ព្រោះដែលភិក្ខុត្រូវភិក្ខុអ្នកចោទចោទហើយ ក៏និយាយគ្របសង្កត់ភិក្ខុអ្នកចោទវិញ នេះឯងជាធម៌ដែលធ្វើឲ្យជាអ្នកប្រដៅក្រ ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀតភិក្ខុដែលត្រូវភិក្ខុអ្នកចោទចោទហើយ ក៏និយាយបន្លំបន្លប់នឹងភិក្ខុអ្នកចោទ ដោយហេតុដទៃ ឬពាក្យផ្សេងៗ និយាយគេចកែដោយសំដីខាងក្រៅ ធ្វើសេចក្តីក្រោធ សេចក្តីប្រទូស

អប្បច្ចយញ្ច បាតុករោតិ យម្បាវុសោ ភិក្ខុ ចុទិតោ ចោទកេន ចោទកំ អញ្ញេនញ្ញំ បដិចរតិ ពហិទ្ធា កថំ អបនាមេតិ កោបញ្ច ទោសញ្ច អប្បច្ចយញ្ច បាតុករោតិ អយម្បិ ធម្មោ ទោវចស្សករណោ ។ បុន ចបរំ អាវុសោ ភិក្ខុ ចុទិតោ ចោទកេន អបទានេ ន សម្បាយតិ យម្បាវុសោ ភិក្ខុ ចុទិតោ ចោទកេន អបទានេ ន សម្បាយតិ អយម្បិ ធម្មោ ទោវចស្សករណោ ។ បុន ចបរំ អាវុសោ ភិក្ខុ មក្ខី ហោតិ បឡាសី យម្បាវុសោ ភិក្ខុ មក្ខី ហោតិ បឡាសី អយម្បិ ធម្មោ ទោវចស្សករណោ ។ បុន ចបរំ អាវុសោ ភិក្ខុ ឥស្សុកី ហោតិ មច្ឆរី យម្បាវុសោ ភិក្ខុ ឥស្សុកី ហោតិ មច្ឆរី អយម្បិ ធម្មោ ទោវចស្សករណោ ។ បុន ចបរំ អាវុសោ ភិក្ខុ សឋោ ហោតិ មាយាវី យម្បាវុសោ ភិក្ខុ សឋោ ហោតិ មាយាវី អយម្បិ ធម្មោ ទោវចស្សករណោ ។



និងសេចក្តីតក់អន់ចិត្តឲ្យប្រាកដឡើង ម្នាលអាវុសោទាំងឡាយ ត្រង់ដែលភិក្ខុត្រូវអ្នកចោទ ចោទហើយ ក៏និយាយបង្វែរបង្វាន់ភិក្ខុអ្នកចោទ ដោយហេតុដទៃឬពាក្យផ្សេងៗ និយាយគេចកែដោយសំដីខាងក្រៅ ធ្វើសេចក្តីក្រោធ សេចក្តីប្រទូស្ត និងសេចក្តីតក់អន់ចិត្តឲ្យប្រាកដឡើង នេះឯងជាធម៌ដែលធ្វើឲ្យជាអ្នកប្រដៅក្រ ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុដែលត្រូវភិក្ខុអ្នកចោទ ចោទហើយ មិនឆ្លើយតនឹងដំណើររបស់ខ្លួន ម្នាលអាវុសោទាំងឡាយ ត្រង់ដែលភិក្ខុត្រូវភិក្ខុអ្នកចោទ ចោទហើយ ក៏មិនឆ្លើយតនឹងដំណើររបស់ខ្លួន នេះឯងជាធម៌ដែលធ្វើឲ្យជាអ្នកប្រដៅក្រ ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុជាអ្នកលុបគុណគេ ជាអ្នកប្រឡូងកំសត ម្នាលអាវុសោទាំងឡាយ ត្រង់ដែលភិក្ខុជាអ្នកលុបគុណគេ ជាអ្នកប្រឡូងកំសត នេះឯងជាធម៌ដែលធ្វើឲ្យជាអ្នកប្រដៅក្រ ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុជាអ្នកប្រចណ្ឌ ជាអ្នកកំណាញ់ ម្នាលអាវុសោទាំងឡាយ ត្រង់ដែលភិក្ខុជាអ្នកប្រចណ្ឌ ជាអ្នកកំណាញ់ នេះឯងជាធម៌ដែលធ្វើឲ្យជាអ្នកប្រដៅក្រ ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុជាអ្នកអួតអាង ជាអ្នកមានពុតមាយា ម្នាលអាវុសោទាំងឡាយ ត្រង់ដែលភិក្ខុជាអ្នកអួតអាង ជាអ្នកមានពុតមាយា នេះឯងជាធម៌ដែលធ្វើឲ្យជាអ្នកប្រដៅក្រ ១ ។

បុន ចបរំ អាវុសោ ភិក្ខុ ថទ្ធោ ហោតិ អតិមានី យម្បាវុសោ ភិក្ខុ ថទ្ធោ ហោតិ អតិមានី អយម្បិ ធម្មោ ទោវចស្សករណោ ។ បុន ចបរំ អាវុសោ ភិក្ខុ សន្ទិដ្ឋិបរាមាសី ហោតិ អាធានគ្គាហី ទុប្បដិនិស្សគ្គី យម្បាវុសោ ភិក្ខុ សន្ទិដ្ឋិបរាមាសី ហោតិ អាធានគ្គាហី ទុប្បដិនិស្សគ្គី អយម្បិ ធម្មោ ទោវចស្សករណោ ។ ឥមេ វុច្ចន្តាវុសោ ទោវចស្សករណា ធម្មា ។

(៤៦៣) នោ ចេបិ អាវុសោ ភិក្ខុ បវារេតិ វទន្តុ មំ អាយស្មន្តោ វចនីយោម្ហិ អាយស្មន្តេហីតិ សោ ច ហោតិ សុវចោ សោវចស្សករណេហិ ធម្មេហិ សមន្នាគតោ ខមោ បទក្ខិណគ្គាហី អនុសាសនិំ អថខោ នំ សព្រហ្មចារី វត្តព្វញ្ចេវ មញ្ញន្តិ



ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុជាអ្នករឹងរូស ជាអ្នកមើលងាយគេ ម្នាលអាវុសោទាំងឡាយ ត្រង់ដែលភិក្ខុជាអ្នករឹងរូស ជាអ្នកមើលងាយគេ នេះឯងជាធម៌ដែលធ្វើឲ្យជាអ្នកប្រដៅក្រ ១ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុជាអ្នកប្រកាន់តាមតែសេចក្តីយល់ឃើញរបស់ខ្លួន ជាអ្នកប្រកាន់មាំ លះបង់ទិដ្ឋិបានដោយក្រ ម្នាលអាវុសោទាំងឡាយ ត្រង់ដែលភិក្ខុ ជាអ្នកប្រកាន់តាមតែសេចក្តីយល់ឃើញរបស់ខ្លួន ជាអ្នកប្រកាន់មាំ លះបង់ទិដ្ឋិបានដោយក្រ នេះឯងជាធម៌ដែលធ្វើឲ្យជាអ្នកប្រដៅក្រ ១ ។ ម្នាលអាវុសោទាំងឡាយ ធម៌ទាំង (១៦) នេះ ព្រះមានព្រះភាគត្រាស់ហៅថា ទោវចស្សករណធម៌ គឺធម៌ដែលធ្វើឲ្យជាអ្នកប្រដៅក្រ ។

(៤៦៣) ម្នាលអាវុសោទាំងឡាយ បើភិក្ខុមិនបានបវារណាថា សូមលោកដ៏មានអាយុទាំងឡាយ ប្រៀនប្រដៅខ្ញុំចុះ ខ្ញុំជាបុគ្គលគួរលោកដ៏មានអាយុទាំងឡាយស្តីថាបានដូច្នេះ។ តែភិក្ខុនោះឯងជាអ្នកប្រដៅងាយ ជាអ្នកប្រកបដោយធម៌ ដែលធ្វើឲ្យជាអ្នកប្រដៅងាយ ជាអ្នកចេះអត់ធន់ កាន់យកនូវពាក្យប្រៀនប្រដៅ ដោយចំណែកខាងស្តាំ កាលបើដូច្នេះ សព្រហ្មចារីបុគ្គលទាំងឡាយ តែងសំគាល់ភិក្ខុនោះថា ជាអ្នកគួរស្តីថាផង

អនុសាសនិយញ្ច នំ មញ្ញន្តិ តស្មិំ ច បុគ្គលេ វិស្សាសំ អាបជ្ជិតព្វំ មញ្ញន្តិ ។ កតមេ ចាវុសោ សោវចស្សករណា ធម្មា ។ ឥធាវុសោ ភិក្ខុ ន បាបិច្ឆោ ហោតិ ន បាបិកានំ ឥច្ឆានំ វសង្គតោ យម្បាវុសោ ភិក្ខុ ន បាបិច្ឆោ ហោតិ ន បាបិកានំ ឥច្ឆានំ វសង្គតោ អយម្បិ ធម្មោ សោវចស្សករណោ ។ បុន ចបរំ អាវុសោ ភិក្ខុ អនត្តុក្កំសកោ ហោតិ អបរវម្ភី យម្បាវុសោ ភិក្ខុ អនត្តុក្កំសកោ ហោតិ អបរវម្ភី អយម្បិ ធម្មោ សោវចស្សករណោ ។ បុន ចបរំ អាវុសោ ភិក្ខុ ន កោធនោ ហោតិ ន កោធាភិភូតោ យម្បាវុសោ ភិក្ខុ ន កោធនោ ហោតិ ន កោធាភិភូតោ អយម្បិ ធម្មោ សោវចស្សករណោ ។ បុន ចបរំ អាវុសោ ភិក្ខុ ន កោធនោ ហោតិ ន កោធហេតុ ឧបនាហី យម្បាវុសោ ភិក្ខុ ន កោធនោ ហោតិ



សំគាល់ថាគួរប្រៀនប្រដៅផង សំគាល់ថាគួរដល់នូវសេចក្តីស្និទ្ធស្នាលក្នុងបុគ្គលនោះផង ។ ម្នាលអាវុសោទាំងឡាយ ចុះធម៌ដែលធ្វើឲ្យជាអ្នកប្រដៅងាយតើដូចម្តេច ។ ម្នាលអាវុសោទាំងឡាយ (ធម៌ដែលធ្វើឲ្យជាអ្នកប្រដៅងាយមាន ១៦) គឺភិក្ខុក្នុងសាសនានេះ ជាអ្នកមិនមានសេចក្តីប្រាថ្នាលាមក មិនលុះក្នុងអំណាចនៃសេចក្តីប្រាថ្នាលាមក ម្នាលអាវុសោទាំងឡាយ ត្រង់ដែលភិក្ខុជាអ្នកមិនមានសេចក្តីប្រាថ្នាលាមក មិនលុះក្នុងអំណាចនៃសេចក្តីប្រាថ្នាលាមក នេះឯងជាធម៌ដែលធ្វើឲ្យជាអ្នកប្រដៅងាយ ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុជាអ្នកមិនលើកខ្លួនឯង មិនបន្តុះបង្អាប់អ្នកដទៃ ម្នាលអាវុសោទាំងឡាយ ត្រង់ដែលភិក្ខុជាអ្នកមិនលើកខ្លួនឯង មិនបន្តុះបង្អាប់អ្នកដទៃ នេះឯងជាធម៌ដែលធ្វើឲ្យជាអ្នកប្រដៅងាយ ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុជាអ្នកមិនក្រោធ មិនមានសេចក្តីក្រោធគ្របសង្កត់ ម្នាលអាវុសោទាំងឡាយ ត្រង់ដែលភិក្ខុជាអ្នកមិនក្រោធ មិនមានសេចក្តីក្រោធគ្របសង្កត់ នេះឯងជាធម៌ដែលធ្វើឲ្យជាអ្នកប្រដៅងាយ ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុជាអ្នកមិនក្រោធ មិនចងគំនុំព្រោះសេចក្តីក្រោធជាហេតុ ម្នាលអាវុសោទាំងឡាយ ត្រង់ដែលភិក្ខុជាអ្នកមិនក្រោធ

ន កោធហេតុ ឧបនាហី អយម្បិ ធម្មោ សោវចស្សការណោ ។ បុន ចបរំ អាវុសោ ភិក្ខុ ន កោធនោ ហោតិ ន កោធហេតុ អភិសង្គី យម្បាវុសោ ភិក្ខុ ន កោធនោ ហោតិ ន កោធហេតុ អភិសង្គី អយម្បិ ធម្មោ សោវចស្សការណោ ។ បុន ចបរំ អាវុសោ ភិក្ខុ ន កោធនោ ហោតិ ន កោធសាមន្តំ វាចំ និច្ឆារេតា យម្បាវុសោ ភិក្ខុ ន កោធនោ ហោតិ ន កោធសាមន្តំ វាចំ និច្ឆារេតា អយម្បិ ធម្មោ សោវចស្សការណោ ។ បុន ចបរំ អាវុសោ ភិក្ខុ ចុទិតោ ចោទកេន ចោទកំ ន បដិប្ផរតិ យម្បាវុសោ ភិក្ខុ ចុទិតោ ចោទកេន ចោទកំ ន បដិប្ផរតិ អយម្បិ ធម្មោ សោវចស្សការណោ ។ បុន ចបរំ អាវុសោ ភិក្ខុ ចុទិតោ ចោទកេន ចោទកំ ន អបសាទេតិ យម្បាវុសោ ភិក្ខុ ចុទិតោ ចោទកេន ចោទកំ ន អបសាទេតិ អយម្បិ ធម្មោ សោវចស្សការណោ ។





មិនចងគំនុំទុកព្រោះសេចក្តីក្រោធជាហេតុ នេះឯងក៏ជាធម៌ដែលធ្វើឲ្យជាអ្នកប្រដៅងាយ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុជាអ្នកមិនក្រោធ មិនដេរប្រទេចព្រោះសេចក្តីក្រោធជាហេតុ ម្នាលអាវុសោទាំងឡាយ ត្រង់ដែលភិក្ខុជាអ្នកមិនក្រោធ មិនដេរប្រទេចព្រោះសេចក្តីក្រោធជាហេតុ នេះឯងក៏ជាធម៌ដែលធ្វើឲ្យជាអ្នកប្រដៅងាយ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុជាអ្នកមិនក្រោធ មិនបញ្ចេញវាចាជិតសេចក្តីក្រោធ ម្នាលអាវុសោទាំងឡាយ ត្រង់ដែលភិក្ខុជាអ្នកមិនក្រោធ មិនបញ្ចេញវាចាជិតសេចក្តីក្រោធ នេះឯងក៏ជាធម៌ដែលធ្វើ ឲ្យជាអ្នកប្រដៅងាយ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀតភិក្ខុដែលត្រូវភិក្ខុអ្នកចោទចោទហើយ ក៏មិនខឹងតបនឹងភិក្ខុអ្នកចោទវិញ ម្នាលអាវុសោទាំងឡាយ ត្រង់ដែលភិក្ខុត្រូវភិក្ខុអ្នកចោទ ចោទហើយ តែមិនខឹងតបតនឹងអ្នកចោទវិញ នេះឯងក៏ជាធម៌ដែលធ្វើឲ្យជាអ្នកប្រដៅងាយ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀតភិក្ខុដែលត្រូវភិក្ខុអ្នកចោទចោទហើយក៏មិនបណ្តេញភិក្ខុអ្នកចោទ ម្នាលអាវុសោទាំងឡាយ ត្រង់ដែលភិក្ខុត្រូវភិក្ខុអ្នកចោទ ចោទហើយតែមិនបណ្តេញភិក្ខុអ្នកចោទ នេះឯងក៏ជាធម៌ដែលធ្វើឲ្យជាអ្នកប្រដៅងាយ ១ ។

បុន ចបរំ អាវុសោ ភិក្ខុ ចុទិតោ ចោទកេន ចោទកស្ស ន បច្ចារោបេតិ យម្បាវុសោ ភិក្ខុ ចុទិតោ ចោទកេន ចោទកស្ស ន បច្ចារោបេតិ អយម្បិ ធម្មោ សោវចស្សករណោ ។ បុន ចបរំ អាវុសោ ភិក្ខុ ចុទិតោ ចោទកេន ចោទកេន ន អញ្ញេនញ្ញំ បដិចរតិ ន ពហិទ្ធា កថំ អបនាមេតិ ន កោបញ្ច ទោសញ្ច អប្បច្ចយញ្ច បាតុករោតិ យម្បាវុសោ ភិក្ខុ ចុទិតោ ចោទកេន ន អញ្ញេនញ្ញំ បដិចរតិ ន ពហិទ្ធា កថំ អបនាមេតិ ន កោបញ្ច ទោសញ្ច អប្បច្ចយញ្ច បាតុករោតិ អយម្បិ ធម្មោ សោវចស្សករណោ ។ បុន ចបរំ អាវុសោ ភិក្ខុ ចុទិតោ ចោទកេន ចោទកស្ស ន អបទានេ ន សម្បាយតិ យម្បាវុសោ ភិក្ខុ ចុទិតោ ចោទកេន ចោទកស្ស ន អបទានេ ន សម្បាយតិ អយម្បិ ធម្មោ សោវចស្សករណោ ។ បុន ចបរំ អាវុសោ ភិក្ខុ អមក្ខី ហោតិ អបឡាសី យម្បាវុសោ



ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុដែលត្រូវភិក្ខុអ្នកចោទចោទហើយ ក៏មិននិយាយត្រឡប់សង្កត់ដល់ភិក្ខុអ្នកចោទ ម្នាលអាវុសោទាំងឡាយ ត្រង់ដែលភិក្ខុត្រូវភិក្ខុអ្នកចោទចោទហើយតែមិននិយាយត្រឡប់សង្កត់ភិក្ខុអ្នកចោទ នេះឯងជាធម៌ដែលធ្វើឲ្យជាអ្នកប្រដៅងាយ ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុដែលត្រូវភិក្ខុអ្នកចោទ ចោទហើយក៏មិននិយាយបន្លំបន្ទប់នូវភិក្ខុអ្នកចោទ ដោយហេតុដទៃឬហេតុផ្សេង ៗ មិននិយាយគេចចាកដោយសំដីទាំងក្រៅ មិនធ្វើសេចក្តីក្រោធ សេចក្តីប្រទូស្ត និងសេចក្តីតក់អន់ចិត្តឲ្យប្រាកដឡើង ម្នាលអាវុសោទាំងឡាយ ត្រង់ដែលភិក្ខុត្រូវភិក្ខុអ្នកចោទចោទហើយ តែមិននិយាយបន្លំបន្ទប់នូវភិក្ខុអ្នកចោទដោយហេតុដទៃឬពាក្យផ្សេង ៗ មិននិយាយគេចចាកដោយសំដីទាំងក្រៅ មិនធ្វើនូវសេចក្តីក្រោធ សេចក្តីប្រទូស្តនិងសេចក្តីតក់អន់ចិត្តឲ្យប្រាកដឡើង នេះឯងជាធម៌ដែលធ្វើឲ្យជាអ្នកប្រដៅងាយ ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុដែលត្រូវភិក្ខុអ្នកចោទ ចោទហើយ ក៏ឆ្លើយមិនទាល់ក្នុងដំណើររបស់ខ្លួន ម្នាលអាវុសោទាំងឡាយ ត្រង់ដែលភិក្ខុត្រូវភិក្ខុអ្នកចោទចោទហើយ ក៏ឆ្លើយមិនទាល់ក្នុងដំណើររបស់ខ្លួន នេះឯងជាធម៌ដែលធ្វើឲ្យជាអ្នកប្រដៅងាយ ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុជាអ្នកមិនលុបគុណគេ មិនប្រឡូកសង្វា ម្នាលអាវុសោទាំងឡាយ

ភិក្ខុ អមក្ខី ហោតិ អបឡាសី អយម្បិ ធម្មោ សោវចស្សករណោ ។ បុន ចបរំ អាវុសោ ភិក្ខុ អនិស្សុកី ហោតិ អមច្ឆរី យម្បាវុសោ ភិក្ខុ អនិស្សុកី ហោតិ អមច្ឆរី អយម្បិ ធម្មោ សោវចស្សករណោ ។ បុន ចបរំ អាវុសោ ភិក្ខុ អសឋោ ហោតិ អមាយាវី យម្បាវុសោ ភិក្ខុ អសឋោ ហោតិ អមាយាវី អយម្បិ ធម្មោ សោវចស្សករណោ ។ បុន ចបរំ អាវុសោ ភិក្ខុ អថទ្ធោ ហោតិ អនតិមានី យម្បាវុសោ ភិក្ខុ អថទ្ធោ ហោតិ អនតិមានី អយម្បិ ធម្មោ សោវចស្សករណោ ។ បុន ចបរំ អាវុសោ ភិក្ខុ អសន្ទិដ្ឋិបរាមាសី ហោតិ អនាធានគ្គាហី សុប្បដិនិស្សគ្គី យម្បាវុសោ ភិក្ខុ អសន្ទិដ្ឋិបរាមាសី ហោតិ អនាធានគ្គាហី សុប្បដិនិស្សគ្គី អយម្បិ ធម្មោ សោវចស្សករណោ ។ ឥមេ វុច្ចន្តាវុសោ សោវចស្សករណា ធម្មា ។



ត្រង់ដែលភិក្ខុជាអ្នកមិនលុបគុណគេ មិនប្រឡងស្មើ នេះឯងជាធម៌ដែលធ្វើឲ្យជាអ្នកប្រដៅងាយ ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុជាអ្នកមិនច្រណែន មិនកំណាញ់ ម្នាលអាវុសោទាំងឡាយ ត្រង់ដែលភិក្ខុជាអ្នកមិនច្រណែន មិនកំណាញ់ នេះឯងជាធម៌ដែលធ្វើឲ្យជាអ្នកប្រដៅងាយ ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុជាអ្នកមិនអួតអាង មិនមានពុតមាយា ម្នាលអាវុសោទាំងឡាយ ត្រង់ដែលភិក្ខុជាអ្នកមិនអួតអាង មិនមានពុតមាយា នេះឯងជាធម៌ដែលធ្វើឲ្យជាអ្នកប្រដៅងាយ ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុជាអ្នកមិនរឹងរូស មិនមើលងាយគេ ម្នាលអាវុសោទាំងឡាយ ត្រង់ដែលភិក្ខុជាអ្នកមិនរឹងរូស មិនមើលងាយគេ នេះឯងជាធម៌ដែលធ្វើឲ្យជាអ្នកប្រដៅងាយ ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុជាអ្នកមិនប្រកាន់យកតាមតែសេចក្តីយើញរបស់ខ្លួន មិនប្រកាន់មាំ លះបង់វិញបានដោយងាយ ម្នាលអាវុសោទាំងឡាយ ត្រង់ដែលភិក្ខុជាអ្នកមិនប្រកាន់យកតាមតែសេចក្តីយល់ឃើញរបស់ខ្លួន មិនប្រកាន់មាំ លះបង់វិញបានដោយងាយ នេះឯងជាធម៌ដែលធ្វើឲ្យជាអ្នកប្រដៅងាយ ១ ។ ម្នាលអាវុសោទាំងឡាយ ធម៌ទាំង (១៦) ប្រការនេះ ព្រះមានព្រះភាគត្រាស់ហៅថា សោវចស្សករណធម៌ គឺធម៌ជាទីធ្វើឲ្យជាអ្នកប្រដៅងាយ ។

(២២៤) តត្រាវុសោ ភិក្ខុនា អត្តនា វ អត្តានំ ឯវំ អនុមានិតព្វំ[១] យោ ខ្វាយំ បុគ្គលោ បាបិច្ឆោ បាបិកានំ ឥច្ឆានំ វសង្គតោ អយំ មេ បុគ្គលោ អប្បិយោ អមនាបោ អហញ្ចេវ ខោ បនស្សំ[២] បាបិច្ឆោ បាបិកានំ ឥច្ឆានំ វសង្គតោ អហំ បស្សំ[៣] បរេសំ អប្បិយោ អមនាបោតិ ។ ឯវំ ជានន្តេនាវុសោ ភិក្ខុនា ន បាបិច្ឆោ ភវិស្សាមិ ន បាបិកានំ ឥច្ឆានំ វសង្គតោតិ ចិត្តំ ឧប្បាទេតព្វំ ។ យោ ខ្វាយំ បុគ្គលោ អត្តុក្កំសកោ បរវម្ភី អយំ មេ បុគ្គលោ អប្បិយោ អមនាបោ អហញ្ចេវ ខោ បនស្សំ អត្តុក្កំសកោ បរវម្ភី អហំ បស្សំ បរេសំ អប្បិយោ អមនាបោតិ ។ ឯវំ ជានន្តេនាវុសោ ភិក្ខុនា អនត្តុក្កំសកោ ភវិស្សាមិ អបរវម្ភីតិ ចិត្តំ ឧប្បាទេតព្វំ ។

១ ឱ. អនុមិនិតព្វំ ។ ២ ម. បនាស្សំ ។ ៣ ម. បាស្សំ ។



(២២៤) ម្នាលអាវុសោទាំងឡាយ ភិក្ខុគួរពិចារណាខ្លួនដោយខ្លួនឯង ក្នុងធម៌ទាំងឡាយ ១៦ នោះយ៉ាងនេះថា បុគ្គលណាជាអ្នកមានសេចក្តីប្រាថ្នាលាមក លុះក្នុងអំណាចនៃសេចក្តីប្រាថ្នាលាមក បុគ្គលនេះមិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់អាត្មាអញទេ បើប្រសិនជាអាត្មាអញ ជាអ្នកមានសេចក្តីប្រាថ្នាលាមក លុះក្នុងអំណាចនៃសេចក្តីប្រាថ្នាលាមកវិញ អាត្មាអញហ្នឹងឯង ក៏មុខជាមិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់អ្នកដទៃដែរ ។ ម្នាលអាវុសោទាំងឡាយ កាលបើភិក្ខុដឹងយ៉ាងនេះហើយ គប្បីញុំាងចិត្តឲ្យកើតឡើងថា អាត្មាអញនឹងមិនត្រូវជាអ្នកមានសេចក្តីប្រាថ្នាលាមក មិនត្រូវលុះក្នុងអំណាចនៃសេចក្តីប្រាថ្នាលាមកឡើយ ។ បុគ្គលណា ជាអ្នកលើកខ្លួនឯង បន្តុះបង្អាប់អ្នកដទៃ បុគ្គលនេះមិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់អាត្មាអញទេ បើប្រសិនជាអាត្មាអញ ជាអ្នកលើកខ្លួនឯង បន្តុះបង្អាប់អ្នកដទៃវិញ អាត្មាអញហ្នឹងឯង ក៏មុខជាមិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់អ្នកដទៃដែរ ។ ម្នាលអាវុសោទាំងឡាយ កាលបើភិក្ខុដឹងយ៉ាងនេះហើយ គប្បីញុំាងចិត្តឲ្យកើតឡើងថា អាត្មាអញនឹងមិនត្រូវជាអ្នកលើកខ្លួនឯង មិនត្រូវបន្តុះបង្អាប់អ្នកដទៃឡើយ ។ បុគ្គល

យោ ខ្វាយំ បុគ្គលោ កោធនោ កោធាភិភូតោ អយំ មេ បុគ្គលោ អប្បិយោ អមនាបោ អហញ្ចេ ខោ បនស្សំ កោធនោ កោធាភិភូតោ អហំ បស្សំ បរេសំ អប្បិយោ អមនាបោតិ ។ ឯវំ ជានន្តេន ភិក្ខុនា ន កោធនោ ភវិស្សាមិ ន កោធាភិភូតោតិ ចិត្តំ ឧប្បាទេតព្វំ ។ យោ ខ្វាយំ បុគ្គលោ កោធនោ កោធហេតុ ឧបនាហី អយំ មេ បុគ្គលោ អប្បិយោ អមនាបោ អហញ្ចេ ខោ បនស្សំ កោធនោ កោធហេតុ ឧបនាហី អហំ បស្សំ បរេសំ អប្បិយោ អមនាបោតិ ។ ឯវំ ជានន្តេន ភិក្ខុនា ន កោធនោ ភវិស្សាមិ ន កោធហេតុ ឧបនាហីតិ ចិត្តំ ឧប្បាទេតព្វំ ។ យោ ខ្វាយំ បុគ្គលោ កោធនោ កោធហេតុ អភិសង្គី អយំ



ណា ជាអ្នកក្រោធ ជាអ្នកមានសេចក្តីក្រោធគ្របសង្កត់ បុគ្គលនេះមិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់អាត្មាអញទេ បើប្រសិនជាអាត្មាអញ ជាអ្នកក្រោធ ជាអ្នកមានសេចក្តីក្រោធគ្របសង្កត់វិញ អាត្មាអញហ្នឹងឯង ក៏មុខជាមិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់អ្នកដទៃដែរ ។ ម្នាលអាវុសោទាំងឡាយ កាលបើភិក្ខុដឹងយ៉ាងនេះហើយ គប្បីញុំាងចិត្តឲ្យកើតឡើងថា អាត្មាអញនឹងមិនត្រូវជាអ្នកក្រោធ មិនត្រូវជាអ្នកមានសេចក្តីក្រោធគ្របសង្កត់បានឡើយ ។ បុគ្គលណា ជាអ្នកក្រោធ ជាអ្នកចងគំនុំ ព្រោះសេចក្តីក្រោធជាហេតុ បុគ្គលនេះ មិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់អាត្មាអញទេ បើប្រសិនជាអាត្មាអញ ជាអ្នកក្រោធ ជាអ្នកចងគំនុំ ព្រោះសេចក្តីក្រោធជាហេតុវិញ អាត្មាអញហ្នឹងឯង ក៏មុខជាមិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់អ្នកដទៃដែរ ។ ម្នាលអាវុសោទាំងឡាយ កាលបើភិក្ខុដឹងយ៉ាងនេះហើយ គប្បីញុំាងចិត្តឲ្យកើតឡើងថា អាត្មាអញនឹងមិនត្រូវជាអ្នកក្រោធ មិនត្រូវចងគំនុំព្រោះសេចក្តីក្រោធជាហេតុឡើយ ។ បុគ្គលណាជាអ្នកក្រោធ ជាអ្នកដេរប្រទេចព្រោះសេចក្តីក្រោធជាហេតុ បុគ្គលនេះ មិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់អាត្មាអញទេ បើប្រសិនជាអាត្មាអញជាអ្នកក្រោធ ជាអ្នកដេរប្រទេចព្រោះសេចក្តីក្រោធជាហេតុវិញ អាត្មាអញ

មេ បុគ្គលោ អប្បិយោ អមនាបោ អហញ្ចេវ ខោ បនស្សំ កោធនោ កោធហេតុ អភិសង្គី អហំ បស្សំ បរេសំ អប្បិយោ អមនាបោតិ ។ ឯវំ ជានន្តេនាវុសោ ភិក្ខុនា ន កោធនោ ភវិស្សាមិ ន កោធហេតុ អភិសង្គីតិ ចិត្តំ ឧប្បាទេតព្វំ ។ យោ ខ្វាយំ បុគ្គលោ កោធនោ កោធសាមន្តំ វាចំ និច្ឆារេតា អយំ មេ បុគ្គលោ អប្បិយោ អមនាបោ អហញ្ចេវ ខោ បនស្សំ កោធនោ កោធសាមន្តំ វាចំ និច្ឆារេតា អហំ បស្សំ បរេសំ អប្បិយោ អមនា-បោតិ ។ ឯវំ ជានន្តេនាវុសោ ភិក្ខុនា ន កោធនោ ភវិស្សាមិ ន កោធសាមន្តំ វាចំ និច្ឆារេស្សាមីតិ ចិត្តំ ឧប្បាទេតព្វំ ។ យោ ខ្វាយំ បុគ្គលោ ចុទិតោ ចោទកេន ចោទកំ បដិប្ផរតិ អយំ មេ បុគ្គលោ អប្បិយោ អមនាបោ អហញ្ចេវ ខោ បនស្សំ ចុទិតោ ចោទកេន ចោទកំ បដិប្ផរេយ្យំ អហំ បស្សំ បរេសំ អប្បិយោ អមនាបោតិ ។ ឯវំ ជានន្តេនាវុសោ





ហ្នឹងឯង ក៏មុខជាមិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់អ្នកដទៃដែរ ។ ម្នាលអាវុសោទាំងឡាយ កាលបើភិក្ខុដឹងយ៉ាងនេះហើយ គប្បីញ៉ាំងចិត្តឲ្យកើតឡើងថា អាត្មាអញនឹងមិនត្រូវជាអ្នកក្រោធ មិនត្រូវជាអ្នកជេរប្រទេច ព្រោះសេចក្តីក្រោធជាហេតុឡើយ ។ បុគ្គលណា ជាអ្នកក្រោធ បញ្ចេញវាចាជិតសេចក្តីក្រោធ បុគ្គលនេះមិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់អាត្មាអញទេ បើប្រសិនជាអាត្មាអញជាអ្នកក្រោធ បញ្ចេញវាចាជិតសេចក្តីក្រោធវិញ អាត្មាអញហ្នឹងឯង ក៏មុខជាមិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់អ្នកដទៃដែរ ។ ម្នាលអាវុសោទាំងឡាយ កាលបើភិក្ខុដឹងយ៉ាងនេះហើយ គប្បីញ៉ាំងចិត្តឲ្យកើតឡើងថា អាត្មាអញនឹងមិនត្រូវជាអ្នកក្រោធ មិនត្រូវជាអ្នក បញ្ចេញវាចាជិតសេចក្តីក្រោធឡើយ ។ បុគ្គលណាដែលត្រូវអ្នកចោទ ចោទហើយ ក៏ទទឹងតបតទៅនឹងអ្នកចោទវិញ បុគ្គលនេះមិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់អាត្មាអញទេ បើប្រសិនជាអាត្មាអញត្រូវអ្នកចោទ ចោទហើយ ក៏ទទឹងតបតទៅនឹងអ្នកចោទវិញ អាត្មាអញហ្នឹងឯង ក៏មុខជាមិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់អ្នកដទៃដែរ ។ ម្នាលអាវុសោទាំងឡាយ កាល

ភិក្ខុនា ចុទិតោ ចោទកេន ចោទកំ អប្បដិប្ផរិស្សាមី-
តិ[១] ចិត្តំ ឧប្បាទេតព្វំ ។ យោ ខ្វាយំ បុគ្គលោ ចុទិតោ
ចោទកេន ចោទកំ អបសាទេតិ អយំ មេ បុគ្គ-
លោ អប្បិយោ អមនាបោ អហញ្ចេវ ខោ បនស្សំ
ចុទិតោ ចោទកេន ចោទកំ អបសាទេយ្យំ អហំ-
បស្សំ បរេសំ អប្បិយោ អមនាបោតិ ។ ឯវំ
ជានន្តេនាវុសោ ភិក្ខុនា ចុទិតោ ចោទកេន ចោ-
ទកំ ន អបសាទេស្សាមីតិ ចិត្តំ ឧប្បាទេតព្វំ ។
យោ ខ្វាយំ បុគ្គលោ ចុទិតោ ចោទកេន ចោទ-
កស្ស បច្ចារោបេតិ អយំ មេ បុគ្គលោ អប្បិយោ
អមនាបោ អហញ្ចេវ ខោ បនស្សំ ចុទិតោ ចោទកេន
ចោទកស្ស បច្ចារោបេយ្យំ អហំ បស្សំ បរេសំ
អប្បិយោ អមនាបោតិ ។ ឯវំ ជានន្តេនាវុសោ ភិក្ខុនា
ចុទិតោ ចោទកេន ចោទកស្ស ន បច្ចារោបេស្សា-
មីតិ ចិត្តំ ឧប្បាទេតព្វំ ។ យោ ខ្វាយំ បុគ្គលោ

---

១ ឱ. ម. អប្បដិប្ផរិស្សាមីតិ ។



បើភិក្ខុដឹងយ៉ាងនេះហើយ ត្រូវញ៉ាំងចិត្តឲ្យកើតឡើងថា អាត្មាអញ
បើត្រូវអ្នកដោទ ដោទហើយ នឹងមិនខឹងតបតទៅនឹងអ្នក ដោទវិញឡើយ ។
បុគ្គលណាដែលត្រូវអ្នកដោទ ដោទហើយ ក៏បណ្ដេញអ្នកដោទ បុគ្គល
នេះមិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់អាត្មាអញទេ បើប្រសិនជា
អាត្មាអញដែលត្រូវអ្នកដោទ ដោទហើយ នឹងបណ្ដេញអ្នកដោទវិញ អាត្មា
អញហ្នឹងឯង ក៏មុខជាមិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់អ្នកដទៃ
ដែរ ។ ម្នាលអាវុសោទាំងឡាយ កាលបើភិក្ខុដឹងយ៉ាងនេះហើយ ត្រូវញ៉ាំង
ចិត្តឲ្យកើតឡើងថា អាត្មាអញបើត្រូវអ្នកដោទ ដោទហើយនឹងមិនបណ្ដេញ
អ្នកដោទវិញឡើយ ។ បុគ្គលណាដែលត្រូវអ្នកដោទ ដោទហើយ
ក៏និយាយត្រឡប់សង្កត់ដល់អ្នកដោទវិញ បុគ្គលនេះ មិនជាទីស្រឡាញ់
មិនជាទីគាប់ចិត្តរបស់អាត្មាអញទេ បើប្រសិនជាអាត្មាអញ ដែលត្រូវអ្នក
ដោទ ដោទហើយ នឹងនិយាយត្រឡប់សង្កត់ដល់អ្នកដោទវិញ អាត្មា
អញហ្នឹងឯង ក៏មុខជាមិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់អ្នក
ដទៃដែរ ។ ម្នាលអាវុសោទាំងឡាយ កាលបើភិក្ខុដឹងយ៉ាងនេះហើយ
ត្រូវញ៉ាំងចិត្តឲ្យកើតឡើងថា អាត្មាអញបើត្រូវអ្នកដោទ ដោទហើយ
នឹងមិននិយាយត្រឡប់សង្កត់ ដល់អ្នកដោទវិញឡើយ ។ បុគ្គលណា

ចុទិតោ ចោទកេន ចោទកស្ស អញ្ញេនញ្ញំ បដិចរតិ ពហិទ្ធា កថំ អបនាមេតិ កោបញ្ច ទោសញ្ច អប្បច្ចយញ្ច បាតុករោតិ អយំ មេ បុគ្គលោ អប្បិយោ អមនាបោ អហញ្ចេវ ខោ បនស្សំ ចុទិតោ ចោទកេន ចោទកស្ស អញ្ញេនញ្ញំ បដិចរេយ្យំ ពហិទ្ធា កថំ អបនាមេយ្យំ កោបញ្ច ទោសញ្ច អប្បច្ចយញ្ច បាតុករេយ្យំ អហំ បស្សំ បរេសំ អប្បិយោ អមនាបោតិ ។ ឯវំ ជានន្តេនាវុសោ ភិក្ខុនា ន ចុទិតោ ចោទកេន ន អញ្ញេនញ្ញំ បដិចរិស្សាមិ ន ពហិទ្ធា កថំ អបនាមេស្សាមិ ន កោបញ្ច ទោសញ្ច អប្បច្ចយញ្ច បាតុករិស្សាមីតិ ចិត្តំ ឧប្បាទេតព្វំ ។ យោ ខ្វាយំ បុគ្គលោ ចុទិតោ ចោទកេន អបទានេ ន សម្បាយតិ អយំ មេ បុគ្គលោ អប្បិយោ អមនាបោ អហញ្ចេវ ខោ បនស្សំ ចុទិតោ ចោទកេន អបទានេ ន សម្បាយេយ្យំ អហំ បស្សំ បរេសំ





ដែលត្រូវអ្នកចោទ ៗ ហើយ ក៏និយាយបន្លប់បន្លំអ្នកចោទដោយហេតុដទៃឬពាក្យផ្សេង ៗ និយាយគេចកែដោយសំដីខាងក្រៅ ធ្វើសេចក្ដីក្រោធ សេចក្ដីប្រទូស្ដ និងសេចក្ដីតក់អន់ចិត្តឲ្យប្រាកដឡើង បុគ្គលនេះមិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់អាត្មាអញទេ បើប្រសិនជាអាត្មាអញដែលត្រូវអ្នកចោទ ៗ ហើយ នឹងនិយាយបន្លប់បន្លំអ្នកចោទ ដោយហេតុដទៃឬពាក្យផ្សេង ៗ នឹងនិយាយគេចកែដោយសំដីខាងក្រៅ នឹងធ្វើសេចក្ដីក្រោធ សេចក្ដីប្រទូស្ដ និងសេចក្ដីតក់អន់ចិត្ត ឲ្យប្រាកដឡើង អាត្មាអញហ្នឹងឯង ក៏មុខជាមិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់អ្នកដទៃដែរ ៗ ម្នាលអាវុសោទាំងឡាយ កាលបើភិក្ខុដឹងយ៉ាងនេះហើយ ត្រូវញុំាងចិត្តឲ្យកើតឡើងថា អាត្មាអញបើត្រូវអ្នកចោទ ៗ ហើយ នឹងមិននិយាយបន្លប់បន្លំអ្នកចោទ ដោយហេតុដទៃឬពាក្យផ្សេង ៗ នឹងមិននិយាយគេចកែដោយសំដីខាងក្រៅ នឹងមិនធ្វើសេចក្ដីក្រោធ សេចក្ដីប្រទូស្ដនិងសេចក្ដីតក់អន់ចិត្តឲ្យប្រាកដឡើងឡើយ ៗ បុគ្គលណាដែលត្រូវអ្នកចោទ ៗ ហើយ ក៏មិនឆ្លើយតបនឹងដំណើររបស់ខ្លួន បុគ្គលនេះមិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់អាត្មាអញទេ បើប្រសិនជាអាត្មាអញដែលត្រូវអ្នកចោទ ៗ ហើយ នឹងមិនឆ្លើយតបនឹងដំណើររបស់ខ្លួន អាត្មាអញ

អប្បិយោ អមនាបោតិ ។ ឯវំ ជានន្តេនាវុសោ ភិក្ខុនា ចោទិតោ ចោទកេន អបទានេ ន សម្បាយិស្សាមីតិ ចិត្តំ ឧប្បាទេតព្វំ ។ យោ ខ្វាយំ បុគ្គលោ មក្ខី បឡាសី អយំ មេ បុគ្គលោ អប្បិយោ អមនាបោ អហញ្ចេវ ខោ បនស្សំ មក្ខី បឡាសី អហំ បស្សំ បរេសំ អប្បិយោ អមនាបោតិ ។ ឯវំ ជានន្តេនាវុសោ ភិក្ខុនា អមក្ខី ភវិស្សាមិ អបឡាសីតិ ចិត្តំ ឧប្បាទេតព្វំ ។ យោ ខ្វាយំ បុគ្គលោ ឥស្សុកី មច្ឆរី អយំ មេ បុគ្គលោ អប្បិយោ អមនាបោ អហញ្ចេវ ខោ បនស្សំ ឥស្សុកី មច្ឆរី អហំ បស្សំ បរេសំ អប្បិយោ អមនាបោតិ ។ ឯវំ ជានន្តេនាវុសោ ភិក្ខុនា អនិស្សុកី ភវិស្សាមិ អមច្ឆរីតិ ចិត្តំ ឧប្បាទេតព្វំ ។ យោ ខ្វាយំ បុគ្គលោ សឋោ មាយាវី អយំ មេ បុគ្គលោ អប្បិយោ អមនាបោ



ហ្នឹងឯង កំពុងជាមិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់អ្នកដទៃ ។ ម្នាលអាវុសោទាំងឡាយ កាលបើភិក្ខុដឹងយ៉ាងនេះហើយ ត្រូវញុំាងចិត្តឲ្យកើតឡើងថា អាត្មាអញ បើត្រូវអ្នកចោទ ៗ ហើយ មិនត្រូវតែឆ្លើយកន្លងដំណើររបស់ខ្លួន ។ បុគ្គលណា ជាអ្នកលុបគុណគេ ជាអ្នកប្រឡូនពីសនា បុគ្គលនេះមិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់អាត្មាអញទេ បើប្រសិនជា អាត្មាអញ ជាអ្នកលុបគុណគេ ជាអ្នកប្រឡូនពីសនា អាត្មាអញហ្នឹងឯង កំពុងជាមិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់អ្នកដទៃ ។ ម្នាលអាវុសោទាំងឡាយ កាលបើភិក្ខុដឹងយ៉ាងនេះហើយ ត្រូវញុំាងចិត្តឲ្យកើតឡើងថា អាត្មាអញ នឹងមិនត្រូវជាអ្នកលុបគុណគេ មិនត្រូវជាអ្នកប្រឡូនពីសនាឡើយ ។ បុគ្គលណា ជាអ្នកប្រច័ណ្ឌ មានសេចក្តីកំណាញ់ បុគ្គលនេះមិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់អាត្មាអញទេ បើប្រសិនជាអាត្មាអញ ជាអ្នកប្រច័ណ្ឌ មានសេចក្តីកំណាញ់ អាត្មាអញហ្នឹងឯង កំពុងជាមិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់អ្នកដទៃ ។ ម្នាលអាវុសោទាំងឡាយ កាលបើភិក្ខុដឹងយ៉ាងនេះហើយត្រូវញុំាងចិត្តឲ្យកើតឡើងថា អាត្មាអញនឹងមិនត្រូវជាអ្នកប្រច័ណ្ឌ មិនត្រូវមានសេចក្តីកំណាញ់ឡើយ ។ បុគ្គលណាជាអ្នកអួតអាង ជាអ្នកមានពុតមាយា បុគ្គលនេះមិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្ត របស់អាត្មា

អហញ្ចេវ ខោ បនស្សំ សឋោ មាយាវី អហំ បស្សំ បរេសំ អប្បិយោ អមនាបោតិ ។ ឯវំ ជានន្តេនាវុសោ ភិក្ខុនា អសឋោ ភវិស្សាមិ អមាយាវីតិ ចិត្តំ ឧប្បាទេតព្វំ ។ យោ ខ្វាយំ បុគ្គលោ ថទ្ធោ អតិមានី អយំ មេ បុគ្គលោ អប្បិយោ អមនាបោ អហញ្ចេវ ខោ បនស្សំ ថទ្ធោ អតិមានី អហំ បស្សំ បរេសំ អប្បិយោ អមនាបោតិ ។ ឯវំ ជានន្តេនាវុសោ ភិក្ខុនា អថទ្ធោ ភវិស្សាមិ អនតិមានីតិ ចិត្តំ ឧប្បាទេតព្វំ ។ យោ ខ្វាយំ បុគ្គលោ សន្ទិដ្ឋិបរាមាសី អាធានគ្គាហី ទុប្បដិនិស្សគ្គី អយំ មេ បុគ្គលោ អប្បិយោ អមនាបោ អហញ្ចេវ ខោ បនស្សំ សន្ទិដ្ឋិបរាមាសី អាធានគ្គាហី ទុប្បដិនិស្សគ្គី អហំ បស្សំ បរេសំ អប្បិយោ អមនាបោតិ ។



អញទេ បើប្រសិនជាអាត្មាអញ ជាអ្នកអួតអាង ជាអ្នកមានពុតមាយា អាត្មាអញហ្នឹងឯងមុខជាមិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្ត របស់អ្នកដទៃដែរ ។ ម្នាលអាវុសោទាំងឡាយ កាលបើភិក្ខុដឹងយ៉ាងនេះហើយ ត្រូវញ៉ាំងចិត្តឲ្យកើតឡើងថា អាត្មាអញនឹងមិនត្រូវជាអ្នកអួតអាង មិនត្រូវជាអ្នកមានពុតមាយាឡើយ ។ បុគ្គលណា ជាអ្នករឹងរូស ជាអ្នកមើលងាយគេ បុគ្គលនេះមិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់អាត្មាអញទេ បើប្រសិនជា អាត្មាអញ ជាអ្នករឹងរូស ជាអ្នកមើលងាយគេ អាត្មាអញហ្នឹងឯង គង់មុខជាមិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់អ្នកដទៃដែរ ។ ម្នាលអាវុសោទាំងឡាយ កាលបើភិក្ខុ ដឹងយ៉ាងនេះហើយ ត្រូវញ៉ាំងចិត្តឲ្យកើតឡើងថា អាត្មាអញនឹងមិនត្រូវជាអ្នករឹងរូស មិនត្រូវជាអ្នកមើលងាយគេឡើយ ។ បុគ្គលណា ជាអ្នកប្រកាន់តាមតែសេចក្តីយល់ឃើញរបស់ខ្លួនឯង ជាអ្នកប្រកាន់មាំ លះបង់ទិដ្ឋិបានដោយក្រ បុគ្គលនេះមិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់អាត្មាអញទេ បើប្រសិនជាអាត្មាអញ ជាអ្នកប្រកាន់តាមតែសេចក្តីយល់ឃើញរបស់ខ្លួនឯង ជាអ្នកប្រកាន់មាំ លះបង់ទិដ្ឋិបានដោយក្រវិញ អាត្មាអញហ្នឹងឯង គង់មុខជាមិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់អ្នកដទៃដែរ ។

ឯវំ ជានន្តេនាវុសោ ភិក្ខុនា អសន្ទិដ្ឋិបរាមាសី ភវិស្សាមិ អនាធានគ្គាហី សុប្បដិនិស្សគ្គីតិ ចិត្តំ ឧប្បាទេតព្វំ ។

(៦៤៨) តត្រាវុសោ ភិក្ខុនា អត្តនាវ អត្តានំ ឯវំ បច្ចវេក្ខិតព្វំ បាបិច្ឆោ នុ ខោម្ហិ បាបិកានំ ឥច្ឆានំ វសំ គតោតិ ។ សចេ អាវុសោ ភិក្ខុ បច្ចវេក្ខមានោ ឯវំ ជានាតិ បាបិច្ឆោ ខោម្ហិ បាបិកានំ ឥច្ឆានំ វសំ គតោតិ តេនាវុសោ ភិក្ខុនា តេសំយេវ បាបកានំ អកុសលានំ ធម្មានំ បហានាយ វាយមិតព្វំ ។ សចេ បនាវុសោ ភិក្ខុ បច្ចវេក្ខមានោ ឯវំ ជានាតិ ន ខោម្ហិ បាបិច្ឆោ ន បាបិកានំ ឥច្ឆានំ វសំ គតោតិ តេនាវុសោ ភិក្ខុនា តេនេវ បីតិបាមោជ្ជេន វិហាតព្វំ អហោរត្តានុសិក្ខិនា កុសលេសុ ធម្មេសុ ។ បុន ចបរំ អាវុសោ ភិក្ខុនា អត្តនាវ អត្តានំ ឯវំ បច្ចវេក្ខិតព្វំ អត្តុក្កំសកោ នុ ខោម្ហិ បរវម្ភីតិ ។ សចេ អាវុសោ ភិក្ខុ បច្ចវេក្ខមានោ ឯវំ ជានាតិ



ម្នាលអាវុសោទាំងឡាយ កាលបើភិក្ខុ ដឹងយ៉ាងនេះហើយ ត្រូវញ៉ាំងចិត្តឲ្យកើតឡើងថា អាត្មាអញនឹងមិនត្រូវជាអ្នកប្រកាន់តាមតែសេចក្ដីយល់ឃើញរបស់ខ្លួនឯងឡើយ មិនត្រូវជាអ្នកប្រកាន់មាំ ត្រូវជាអ្នកលះបង់ទិដ្ឋិបានដោយងាយវិញ ។

(៦៤៩) ម្នាលអាវុសោទាំងឡាយ ភិក្ខុត្រូវពិចារណាខ្លួនដោយខ្លួនឯង ក្នុងធម៌ទាំង ១៦ នោះយ៉ាងនេះថា អាត្មាអញ ជាអ្នកមានសេចក្ដីប្រាថ្នាលាមក លុះក្នុងអំណាចនៃសេចក្ដីប្រាថ្នាលាមកឬទេ ។ ម្នាលអាវុសោទាំងឡាយ កាលបើភិក្ខុ ពិចារណាហើយ ដឹងយ៉ាងនេះថា អាត្មាអញជាអ្នកមានសេចក្ដីប្រាថ្នាលាមក លុះក្នុងអំណាចនៃសេចក្ដីប្រាថ្នាលាមក ម្នាលអាវុសោទាំងឡាយ ភិក្ខុនោះត្រូវព្យាយាមលះបង់នូវអកុសលធម៌ដ៏លាមកទាំងនោះចេញ ។ ម្នាលអាវុសោទាំងឡាយ តែកាលបើភិក្ខុពិចារណាហើយ ដឹងយ៉ាងនេះវិញថា អាត្មាអញមិនជាអ្នកមានសេចក្ដីប្រាថ្នាលាមក មិនលុះក្នុងអំណាចនៃសេចក្ដីប្រាថ្នាលាមកទេ ម្នាលអាវុសោទាំងឡាយ ភិក្ខុនោះត្រូវសិក្សា ក្នុងកុសលធម៌ទាំងឡាយ អស់យប់និងថ្ងៃ ហើយនៅដោយបីតិនិងបាមោជ្ជៈនោះតែមួយយ៉ាង ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុត្រូវពិចារណាខ្លួនដោយខ្លួនឯងយ៉ាងនេះថា អាត្មាអញជាអ្នកលើកខ្លួនឯង បន្ទះបន្ទាប់អ្នកដទៃឬទេ ។ ម្នាលអាវុសោទាំងឡាយ កាលបើភិក្ខុ ពិចារណាហើយដឹងយ៉ាងនេះថា

អត្តុក្កំសកោ ហោមិ បរវម្ភីតិ តេនាវុសោ ភិក្ខុនា តេសំយេវ បាបកានំ អកុសលានំ ធម្មានំ បហានាយ វាយមិតព្វំ ។ សចេ បនាវុសោ ភិក្ខុ បច្ចវេក្ខមានោ ឯវំ ជានាតិ អនត្តុក្កំសកោ ហោមិ អបរវម្ភីតិ តេនាវុសោ ភិក្ខុនា តេនេវ បីតិបាមោជ្ជេន វិហាតព្វំ អហោរត្តានុសិក្ខិនា កុសលេសុ ធម្មេសុ ។ បុន ចបរំ អាវុសោ ភិក្ខុនា អត្តនាវ អត្តានំ ឯវំ បច្ចវេក្ខិតព្វំ កិន្នុខោម្ហិ កោធនោ កោធាភិភូតោតិ ។ សចេ អាវុសោ ភិក្ខុ បច្ចវេក្ខមានោ ឯវំ ជានាតិ កោធនោ ខោម្ហិ កោធាភិភូតោតិ តេនាវុសោ ភិក្ខុនា តេសំយេវ បាបកានំ អកុសលានំ ធម្មានំ បហានាយ វាយមិតព្វំ ។ សចេ បនាវុសោ ភិក្ខុ បច្ចវេក្ខមានោ ឯវំ ជានាតិ ន ខោម្ហិ កោធនោ ន កោធាភិភូតោតិ តេនាវុសោ ភិក្ខុនា តេនេវ បីតិបាមោជ្ជេន វិហាតព្វំ អហោរត្តានុសិក្ខិនា កុសលេសុ ធម្មេសុ ។ បុន ចបរំ អាវុសោ ភិក្ខុនា អត្តនាវ អត្តានំ ឯវំ បច្ចវេក្ខិតព្វំ កិន្នុខោម្ហិ កោធនោ



កាត្មាអញជាអ្នកលើកខ្លួនឯង បន្តុះបង្អាប់អ្នកដទៃ ម្នាលអាវុសោទាំងឡាយ ភិក្ខុនោះត្រូវព្យាយាមលះបង់នូវអកុសលធម៌ ដ៏លាមកទាំងនោះចេញ ។ ម្នាលអាវុសោទាំងឡាយ តែបើភិក្ខុពិចារណាហើយដឹងយ៉ាងនេះវិញ កាត្មាអញមិនជាអ្នកលើកខ្លួនឯង មិនបន្តុះបង្អាប់អ្នកដទៃទេ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុនោះត្រូវសិក្សាក្នុងកុសលធម៌ទាំងឡាយ អស់យប់និងថ្ងៃ ហើយនៅដោយបីតិនិងបាមោជ្ជៈនោះតែមួយយ៉ាង ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុត្រូវពិចារណាខ្លួនដោយខ្លួនឯងយ៉ាងនេះថា កាត្មាអញជាអ្នកក្រោធ ជាអ្នកមានសេចក្ដីក្រោធ គ្របសង្កត់ឬទេ ។ ម្នាលអាវុសោទាំងឡាយ កាលបើភិក្ខុ ពិចារណាហើយដឹងយ៉ាងនេះថា កាត្មាអញជាអ្នកក្រោធ ជាអ្នកមានសេចក្ដីក្រោធគ្របសង្កត់ ម្នាលអាវុសោទាំងឡាយ ភិក្ខុនោះត្រូវព្យាយាម លះបង់នូវអកុសលធម៌ ដ៏លាមកទាំងនោះចេញ ។ ម្នាលអាវុសោទាំងឡាយ តែបើភិក្ខុពិចារណាហើយដឹងយ៉ាងនេះវិញថា កាត្មាអញមិនជាអ្នកក្រោធ ជាអ្នកមិនមានសេចក្ដីក្រោធគ្របសង្កត់ទេ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុនោះត្រូវសិក្សាក្នុងកុសលធម៌ទាំងឡាយ អស់យប់និងថ្ងៃ ហើយនៅដោយបីតិនិងបាមោជ្ជៈតែម្យ៉ាង ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុត្រូវពិចារណាខ្លួន ដោយខ្លួនឯងយ៉ាងនេះថា កាត្មាអញជាអ្នកក្រោធ

កោធហេតុ ឧបនាហីតិ ។ សចេ អាវុសោ ភិក្ខុ បច្ចវេក្ខមានោ ឯវំ ជានាតិ កោធនោ ខោម្ហិ កោធហេតុ ឧបនាហីតិ តេនាវុសោ ភិក្ខុនា តេសំយេវ បាបកានំ អកុសលានំ ធម្មានំ បហានាយ វាយមិតព្វំ ។ សចេ បនាវុសោ ភិក្ខុ បច្ចវេក្ខមានោ ឯវំ ជានាតិ ន ខោម្ហិ កោធនោ ន កោធហេតុ ឧបនាហីតិ តេនាវុសោ ភិក្ខុនា តេនេវ បីតិបាមោជ្ជេន វិហាតព្វំ អហោរត្តានុសិក្ខិនា កុសលេសុ ធម្មេសុ ។ បុន ចបរំ អាវុសោ ភិក្ខុនា អត្តនា វ អត្តានំ ឯវំ បច្ចវេក្ខិតព្វំ កិន្នុខោម្ហិ កោធនោ កោធហេតុ អភិសង្គីតិ ។ សចេ អាវុសោ ភិក្ខុ បច្ចវេក្ខមានោ ឯវំ ជានាតិ កោធនោ ខោម្ហិ កោធហេតុ អភិសង្គីតិ តេនាវុសោ ភិក្ខុនា តេសំយេវ បាបកានំ អកុសលានំ ធម្មានំ បហានាយ វាយមិតព្វំ ។ សចេ បនាវុសោ ភិក្ខុ បច្ចវេក្ខមានោ ជានាតិ ន ខោម្ហិ កោធនោ ន កោធហេតុ អភិសង្គីតិ តេនាវុសោ ភិក្ខុនា តេនេវ



ជាអ្នកចងគំនុំព្រោះសេចក្ដីក្រោធជាហេតុឬទេ ។ ម្នាលអាវុសោទាំងឡាយ កាលបើភិក្ខុពិចារណាហើយ ដឹងយ៉ាងនេះថា អាត្មាអញជាអ្នកក្រោធ ជាអ្នកចងគំនុំព្រោះសេចក្ដីក្រោធជាហេតុ ម្នាលអាវុសោទាំងឡាយ ភិក្ខុនោះត្រូវព្យាយាម លះបង់នូវអកុសលធម៌ដ៏លាមកទាំងនោះចេញ ។ ម្នាលអាវុសោទាំងឡាយ តែបើភិក្ខុពិចារណាហើយ ដឹងយ៉ាងនេះវិញថា អាត្មាអញជាអ្នកមិនក្រោធ ជាអ្នកមិនចងគំនុំព្រោះសេចក្ដីក្រោធជាហេតុទេ ម្នាលអាវុសោទាំងឡាយ ភិក្ខុនោះត្រូវសិក្សាក្នុងកុសលធម៌ទាំងឡាយ អស់យប់និងថ្ងៃ ហើយនៅដោយបីតិនិងបាមោជ្ជៈតែមួយយ៉ាង ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុត្រូវពិចារណាខ្លួនដោយខ្លួនឯងយ៉ាងនេះថា អាត្មាអញជាអ្នកក្រោធ ជាអ្នកដេរប្រទេចព្រោះសេចក្ដីក្រោធជាហេតុឬទេ ។ ម្នាលអាវុសោទាំងឡាយ កាលបើភិក្ខុពិចារណាហើយ ដឹងយ៉ាងនេះថា អាត្មាអញជាអ្នកក្រោធ ជាអ្នកដេរប្រទេចព្រោះសេចក្ដីក្រោធជាហេតុ ម្នាលអាវុសោទាំងឡាយ ភិក្ខុនោះត្រូវព្យាយាម លះបង់នូវអកុសលធម៌ដ៏លាមកទាំងនោះចេញ ។ ម្នាលអាវុសោទាំងឡាយ តែបើភិក្ខុពិចារណាហើយ ដឹងយ៉ាងនេះវិញថា អាត្មាអញជាអ្នកមិនក្រោធ ជាអ្នកមិនដេរប្រទេច ព្រោះសេចក្ដីក្រោធជាហេតុទេ ម្នាលអាវុសោទាំងឡាយ ភិក្ខុនោះត្រូវសិក្សាក្នុងកុសលធម៌

បីតិបាមោជ្ជេន វិហាតព្វំ អហោរត្តានុសិក្ខិនា កុស-
លេសុ ធម្មេសុ ។ បុន ចបរំ អាវុសោ ភិក្ខុនា
អត្តនា វ អត្តានំ ឯវំ បច្ចវេក្ខិតព្វំ កិន្នុខោម្ហិ កោធនោ
កោធសាមន្តំ វាចំ និច្ឆារេតាតិ ។ សចេ អាវុសោ
ភិក្ខុ បច្ចវេក្ខមានោ ឯវំ ជានាតិ កោធនោ ខោម្ហិ
កោធសាមន្តំ វាចំ និច្ឆារេតាតិ តេនាវុសោ ភិក្ខុនា
តេសំយេវ បាបកានំ អកុសលានំ ធម្មានំ បហានាយ
វាយមិតព្វំ ។ សចេ បនាវុសោ ភិក្ខុ បច្ចវេក្ខមានោ
ឯវំ ជានាតិ ន កោធនោម្ហិ ន កោធសាមន្តំ
វាចំ និច្ឆារេតាតិ តេនាវុសោ ភិក្ខុនា តេនេវ បីតិបា-
មោជ្ជេន វិហាតព្វំ អហោរត្តានុសិក្ខិនា កុសលេសុ
ធម្មេសុ ។ បុន ចបរំ អាវុសោ ភិក្ខុនា អត្តនា វ
អត្តានំ ឯវំ បច្ចវេក្ខិតព្វំ កិន្នុខោម្ហិ ចុទិតោ ចោទ-
កេន ចោទកំ បដិប្ផរាមីតិ ។ សចេ អាវុសោ
ភិក្ខុ បច្ចវេក្ខមានោ ឯវំ ជានាតិ ចុទិតោ ខោម្ហិ
ចោទកេន ចោទកំ បដិប្ផរាមីតិ តេនាវុសោ ភិក្ខុនា
តេសំយេវ បាបកានំ អកុសលានំ ធម្មានំ បហានាយ





ទាំងឡាយ អស់យប់ទាំងថ្ងៃ ហើយនៅដោយបីតិនិងបាមោជ្ជៈនោះតែ
មួយយ៉ាង ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុពិចារណា
ខ្លួនដោយខ្លួនឯង យ៉ាងនេះថា អាត្មាអញជាអ្នកក្រោធ ជាអ្នកបញ្ចេញ
វាចាជិតសេចក្ដីក្រោធឬទេ ។ ម្នាលអាវុសោទាំងឡាយ កាលបើភិក្ខុពិចា-
រណាហើយដឹងយ៉ាងនេះថា អាត្មាអញជាអ្នកក្រោធ ជាអ្នកបញ្ចេញវាចា
ជិតសេចក្ដីក្រោធ ម្នាលអាវុសោទាំងឡាយ ភិក្ខុនោះត្រូវព្យាយាមលះ
បង់នូវអកុសលធម៌ដ៏លាមកទាំងនោះចេញ ។ ម្នាលអាវុសោទាំងឡាយ
តែបើភិក្ខុពិចារណាហើយ ដឹងយ៉ាងនេះវិញថា អាត្មាអញមិនជាអ្នក
ក្រោធ ជាអ្នកមិនបញ្ចេញវាចាជិតសេចក្ដីក្រោធទេ ម្នាលអាវុសោទាំង-
ឡាយ ភិក្ខុនោះត្រូវសិក្សាក្នុងកុសលធម៌ទាំងឡាយ ហើយនៅដោយ
បីតិនិងបាមោជ្ជៈនោះតែមួយយ៉ាង ។ ម្នាលអាវុសោទាំងឡាយ មួយទៀត
ភិក្ខុត្រូវពិចារណាខ្លួនដោយខ្លួនឯង យ៉ាងនេះថា អាត្មាអញដែលត្រូវអ្នក
ចោទ គេចោទហើយ តែងទទឹងតបតនឹងអ្នកចោទវិញឬទេ ។ ម្នាលអាវុ-
សោទាំងឡាយ កាលបើភិក្ខុពិចារណាហើយ ដឹងយ៉ាងនេះថា អាត្មា
អញដែលត្រូវអ្នកចោទ គេចោទហើយ តែងទទឹងតបតនឹងអ្នកចោទវិញ
ម្នាលអាវុសោទាំងឡាយ ភិក្ខុនោះត្រូវព្យាយាម លះបង់នូវអកុសលធម៌

វាយមិតព្វំ ។ សចេ បនាវុសោ ភិក្ខុ បច្ចវេក្ខមានោ ឯវំ ជានាតិ ចុទិតោ ខោម្ហិ ចោទកេន ចោទកំ ន បដិប្ផរាមីតិ តេនាវុសោ ភិក្ខុនា តេនេវ បីតិបាមោជ្ជេន វិហាតព្វំ អហោរត្តានុសិក្ខិនា កុសលេសុ ធម្មេសុ ។ បុន ចបរំ អាវុសោ ភិក្ខុនា អត្តនាវ អត្តានំ ឯវំ បច្ចវេក្ខិតព្វំ កិន្នុខោម្ហិ ចុទិតោ ចោទកេន ចោទកំ អបសាទេមីតិ ។ សចេ អាវុសោ ភិក្ខុ បច្ចវេក្ខមានោ ឯវំ ជានាតិ ចុទិតោ ចោទកេន ចោទកំ អបសាទេមីតិ តេនាវុសោ ភិក្ខុនា តេសំយេវ បាបកានំ អកុសលានំ ធម្មានំ បហានាយ វាយមិតព្វំ ។ សចេ បនាវុសោ ភិក្ខុ បច្ចវេក្ខមានោ ឯវំ ជានាតិ ចុទិតោ ខោម្ហិ ចោទកេន ចោទកំ ន អបសាទេមីតិ តេនាវុសោ ភិក្ខុនា តេនេវ បីតិបាមោជ្ជេន វិហាតព្វំ អហោរត្តានុសិក្ខិនា កុសលេសុ ធម្មេសុ ។ បុន ចបរំ អាវុសោ ភិក្ខុនា អត្តនាវ អត្តានំ ឯវំ បច្ចវេក្ខិតព្វំ



ដ៏លាមកទាំងនោះចេញ ។ ម្នាលអាវុសោទាំងឡាយ តែកាលបើភិក្ខុពិចារណាហើយ ដឹងយ៉ាងនេះវិញថា អាត្មាអញដែលត្រូវអ្នកចោទគេចោទហើយ តែងមិនខឹងតបនឹងអ្នកចោទវិញទេ ម្នាលអាវុសោទាំងឡាយ ភិក្ខុនោះគួរសិក្សាក្នុងកុសលធម៌ទាំងឡាយ អស់យប់ទាំងថ្ងៃ ហើយនៅដោយបីតិនិងបាមោជ្ជៈនោះតែម្តងបាន ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុត្រូវពិចារណាខ្លួនដោយខ្លួនឯងយ៉ាងនេះថា អាត្មាអញដែលត្រូវអ្នកចោទគេចោទហើយ តែងបណ្ដោញអ្នកចោទវិញឬទេ ។ ម្នាលអាវុសោទាំងឡាយ កាលបើភិក្ខុពិចារណាហើយដឹងយ៉ាងនេះថា អាត្មាអញដែលត្រូវអ្នកចោទគេចោទហើយ តែងបណ្ដោញអ្នកចោទវិញ ម្នាលអាវុសោទាំងឡាយ ភិក្ខុនោះត្រូវព្យាយាមលះបង់នូវអកុសលធម៌ដ៏លាមកទាំងនោះចេញ ។ ម្នាលអាវុសោទាំងឡាយ តែកាលបើភិក្ខុពិចារណាហើយដឹងយ៉ាងនេះវិញថា អាត្មាអញដែលត្រូវអ្នកចោទ គេចោទហើយ តែងមិនបណ្ដោញអ្នកចោទវិញទេ ម្នាលអាវុសោទាំងឡាយ ភិក្ខុនោះត្រូវសិក្សាក្នុងកុសលធម៌ទាំងឡាយ អស់យប់ទាំងថ្ងៃ ហើយនៅដោយបីតិនិងបាមោជ្ជៈនោះតែម្តងបាន ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុត្រូវពិចារណាខ្លួនដោយខ្លួនឯងយ៉ាងនេះថា អាត្មាអញដែល

កិន្នុ ខោម្ហិ ចុទិតោ ចោទកេន ចោទកស្ស បច្ចារោបេមីតិ ។ សចេ អាវុសោ ភិក្ខុ បច្ចវេក្ខមានោ ឯវំ ជានាតិ ចុទិតោ ខោម្ហិ ចោទកេន ចោទកស្ស បច្ចារោបេមីតិ តេនាវុសោ ភិក្ខុនា តេសំយេវ បាបកានំ អកុសលានំ ធម្មានំ បហានាយ វាយមិតព្វំ ។ សចេ បនាវុសោ ភិក្ខុ បច្ចវេក្ខមានោ ឯវំ ជានាតិ ចុទិតោ ខោម្ហិ ចោទកេន ចោទកស្ស ន បច្ចារោបេមីតិ តេនាវុសោ ភិក្ខុនា តេនេវ បីតិបាមោជ្ជេន វិហាតព្វំ អហោរត្តានុសិក្ខិនា កុសលេសុ ធម្មេសុ ។ បុន ចបរំ អាវុសោ ភិក្ខុនា អត្តនាវ អត្តានំ ឯវំ បច្ចវេក្ខិតព្វំ កិន្នុ ខោម្ហិ ចុទិតោ ចោទកេន អញ្ញេនញ្ញំ បដិចរាមិ ពហិទ្ធា កថំ អបនាមេមិ កោបញ្ច ទោសញ្ច អប្បច្ចយញ្ច បាតុករោមីតិ ។ សចេ អាវុសោ ភិក្ខុ បច្ចវេក្ខមានោ ឯវំ ជានាតិ ចុទិតោ ខោម្ហិ ចោទកេន អញ្ញេនញ្ញំ បដិចរាមិ ពហិទ្ធា កថំ អបនាមេមិ កោបញ្ច ទោសញ្ច អប្បច្ចយញ្ច



ត្រូវអ្នកដទៃគេចោទហើយ តែងនិយាយគ្របសង្កត់អ្នកដទៃវិញឬទេ ។ ម្នាលអាវុសោទាំងឡាយ កាលបើភិក្ខុពិចារណាហើយដឹងយ៉ាងនេះថា អាត្មាអញដែលត្រូវអ្នកដទៃគេចោទហើយ តែងនិយាយគ្របសង្កត់អ្នកដទៃវិញ ម្នាលអាវុសោទាំងឡាយ ភិក្ខុនោះគប្បីព្យាយាមលះបង់នូវអកុសលធម៌ដ៏លាមកទាំងនោះចេញ ។ ម្នាលអាវុសោទាំងឡាយ តែកាលបើភិក្ខុពិចារណាហើយ ដឹងយ៉ាងនេះវិញថា អាត្មាអញដែលត្រូវអ្នកដទៃគេចោទហើយ មិននិយាយគ្របសង្កត់អ្នកដទៃវិញទេ ម្នាលអាវុសោទាំងឡាយ ភិក្ខុនោះគប្បីសិក្សាក្នុងកុសលធម៌ទាំងឡាយ អស់យប់និងថ្ងៃ ហើយនៅដោយបីតិនិងបាមោជ្ជៈនោះតែមួយយ៉ាង ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុត្រូវពិចារណាខ្លួនដោយខ្លួនឯងយ៉ាងនេះថា អាត្មាអញដែលត្រូវអ្នកដទៃ គេចោទហើយ តែងនិយាយបន្លំបន្លប់អ្នកដទៃដោយហេតុដទៃឬពាក្យផ្សេង ៗ និយាយគេចចេញដោយសំដីខាងក្រៅ ធ្វើសេចក្តីក្រោធ សេចក្តីប្រទូស្ត និងសេចក្តីអាក់អន់ចិត្តឲ្យប្រាកដឡើងដែរឬទេ ។ ម្នាលអាវុសោទាំងឡាយ កាលបើភិក្ខុពិចារណាហើយ ដឹងយ៉ាងនេះថា អាត្មាអញដែលត្រូវអ្នកដទៃ គេចោទហើយ តែងនិយាយបន្លំបន្លប់ដោយហេតុដទៃឬពាក្យផ្សេង ៗ និយាយគេចចេញដោយសំដីខាងក្រៅ ធ្វើសេចក្តីក្រោធ សេចក្តីប្រទូស្ត និងសេចក្តីអាក់អន់ចិត្តឲ្យ

បាតុករោមីតិ តេនាវុសោ ភិក្ខុនា តេសំយេវ បាបកានំ អកុសលានំ ធម្មានំ បហានាយ វាយមិតព្វំ ។ សចេ បនាវុសោ ភិក្ខុ បច្ចវេក្ខមានោ ឯវំ ជានាតិ ចោទិតោ ខោម្ហិ ចោទកេន អញ្ញេនញ្ញំ ន បដិចរាមិ ន ពហិទ្ធា កថំ អបនាមេមិ ន កោបញ្ច ទោសញ្ច អប្បច្ចយញ្ច បាតុករោមីតិ តេនាវុសោ ភិក្ខុនា តេនេវ បីតិបាមោជ្ជេន វិហាតព្វំ អហោរត្តានុសិក្ខិនា កុសលេសុ ធម្មេសុ ។ បុន ចបរំ អាវុសោ ភិក្ខុនា អត្តនាវ អត្តានំ ឯវំ បច្ចវេក្ខិតព្វំ កិន្នុខោម្ហិ ចោទិតោ ចោទកេន អបទានេ ន សម្បាយាមីតិ ។ សចេ អាវុសោ ភិក្ខុ បច្ចវេក្ខមានោ ឯវំ ជានាតិ ចោទិតោ ខោម្ហិ ចោទកេន អបទានេ ន សម្បាយាមីតិ តេនាវុសោ ភិក្ខុនា តេសំយេវ បាបកានំ អកុសលានំ ធម្មានំ បហានាយ វាយមិតព្វំ ។ សចេ បនាវុសោ ភិក្ខុ បច្ចវេក្ខមានោ ឯវំ ជានាតិ ចោទិតោ ខោម្ហិ ចោទកេន អបទានេ សម្បាយាមីតិ តេនាវុសោ



ប្រាកដឡើងដូច្នេះ ម្នាលអាវុសោទាំងឡាយ ភិក្ខុនោះគប្បីព្យាយាមលះបង់នូវអកុសលធម៌ដ៏លាមកទាំងនោះចេញ ។ ម្នាលអាវុសោទាំងឡាយ បើភិក្ខុពិចារណាហើយដឹងយ៉ាងនេះវិញថា អាត្មាអញដែលត្រូវអ្នកចោទគេចោទហើយ តែមិននិយាយបន្លំបន្លប់អ្នកចោទ ដោយហេតុដទៃឬពាក្យផ្សេងៗ មិននិយាយគេចតែដោយសំដីខាងក្រៅ មិនធ្វើសេចក្ដីក្រោធ សេចក្ដីប្រទូស្ត និងសេចក្ដីតក់អន់ចិត្តឲ្យប្រាកដឡើងទេ ម្នាលអាវុសោទាំងឡាយ ភិក្ខុនោះគប្បីសិក្សាក្នុងកុសលធម៌ទាំងឡាយ អស់យប់ទាំងថ្ងៃ ហើយនៅដោយបីតិនិងបាមោជ្ជៈនោះតែមួយយ៉ាង ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុត្រូវពិចារណាខ្លួនដោយខ្លួនឯងយ៉ាងនេះថា អាត្មាអញដែលត្រូវអ្នកចោទ ចោទហើយ តែមិនឆ្លើយក្នុងដំណើររបស់ខ្លួនឬទេ ។ ម្នាលអាវុសោទាំងឡាយ កាលបើភិក្ខុពិចារណាហើយដឹងយ៉ាងនេះថា អាត្មាអញដែលត្រូវអ្នកចោទគេចោទហើយ តែមិនឆ្លើយក្នុងដំណើររបស់ខ្លួនទេ ម្នាលអាវុសោទាំងឡាយ ភិក្ខុនោះគប្បីព្យាយាមលះបង់នូវអកុសលធម៌ដ៏លាមកទាំងនោះចេញ ។ ម្នាលអាវុសោទាំងឡាយ តែកាលបើភិក្ខុពិចារណាហើយដឹងយ៉ាងនេះវិញថា អាត្មាអញដែលត្រូវអ្នកចោទគេចោទហើយ តែនឹងតែឆ្លើយក្នុងដំណើររបស់ខ្លួន ម្នាលអាវុសោទាំង

ភិក្ខុនា តេនេវ បីតិបាមោជ្ជេន វិហាតព្វំ អហោរត្តានុសិក្ខិនា កុសលេសុ ធម្មេសុ ។ បុន ចបរំ អាវុសោ ភិក្ខុនា អត្តនា វ អត្តានំ ឯវំ បច្ចវេក្ខិតព្វំ កិន្នុខោម្ហិ មក្ខី បឡាសីតិ ។ សចេ អាវុសោ ភិក្ខុ បច្ចវេក្ខមានោ ឯវំ ជានាតិ មក្ខី ខោម្ហិ បឡាសីតិ តេនាវុសោ ភិក្ខុនា តេសំយេវ បាបកានំ អកុសលានំ ធម្មានំ បហានាយ វាយមិតព្វំ ។ សចេ បនាវុសោ ភិក្ខុ បច្ចវេក្ខមានោ ឯវំ ជានាតិ អមក្ខី ខោម្ហិ អបឡាសីតិ តេនាវុសោ ភិក្ខុនា តេនេវ បីតិបាមោជ្ជេន វិហាតព្វំ អហោរត្តានុសិក្ខិនា កុសលេសុ ធម្មេសុ ។ បុន ចបរំ អាវុសោ ភិក្ខុនា អត្តនា វ អត្តានំ ឯវំ បច្ចវេក្ខិតព្វំ កិន្នុខោម្ហិ ឥស្សុកី មច្ឆរីតិ ។ សចេ អាវុសោ ភិក្ខុ បច្ចវេក្ខមានោ ឯវំ ជានាតិ ឥស្សុកី ខោម្ហិ មច្ឆរីតិ តេនាវុសោ ភិក្ខុនា តេសំយេវ បាបកានំ អកុសលានំ ធម្មានំ បហានាយ វាយមិតព្វំ ។ សចេ បនាវុសោ ភិក្ខុ បច្ចវេក្ខមានោ ឯវំ ជានាតិ អនិស្សុកី ខោម្ហិ



ឡាយ ភិក្ខុនោះគួរសិក្សាក្នុងកុសលធម៌ទាំងឡាយ អស់យប់និងថ្ងៃហើយនៅដោយបីតិនិងបាមោជ្ជៈនោះតែមួយយ៉ាង ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុត្រូវពិចារណាខ្លួនដោយខ្លួនឯងយ៉ាងនេះថា អាត្មាអញជាអ្នកលុបគុណគេ ជាអ្នកប្រវ្សនឹងរសនាឬទេ ។ ម្នាលអាវុសោទាំងឡាយ កាលបើភិក្ខុពិចារណាហើយដឹងយ៉ាងនេះថា អាត្មាអញជាអ្នកលុបគុណគេ ជាអ្នកប្រវ្សនឹងរសនា ម្នាលអាវុសោទាំងឡាយ ភិក្ខុនោះគួរព្យាយាមលះបង់នូវអកុសលធម៌ដ៏លាមកទាំងនោះចេញ ។ ម្នាលអាវុសោទាំងឡាយ តែកាលបើភិក្ខុពិចារណាហើយដឹងយ៉ាងនេះវិញថា អាត្មាអញមិនជាអ្នកលុបគុណគេ ជាអ្នកមិនប្រវ្សនឹងរសនាទេ ម្នាលអាវុសោទាំងឡាយ ភិក្ខុនោះគួរសិក្សាក្នុងកុសលធម៌ទាំងឡាយ អស់យប់និងថ្ងៃ ហើយនៅដោយបីតិនិងបាមោជ្ជៈនោះតែមួយយ៉ាង ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុត្រូវពិចារណាខ្លួនដោយខ្លួនឯងយ៉ាងនេះថា អាត្មាអញជាអ្នកច្រណែន ជាអ្នកមានសេចក្តីកំណាញ់ឬទេ ។ ម្នាលអាវុសោទាំងឡាយ កាលបើភិក្ខុពិចារណាហើយដឹងយ៉ាងនេះថា អាត្មាអញជាអ្នកច្រណែន ជាអ្នកមានសេចក្តីកំណាញ់ ម្នាលអាវុសោទាំងឡាយ ភិក្ខុនោះគួរព្យាយាមលះបង់នូវអកុសលធម៌ដ៏លាមកទាំងនោះចេញ ។ ម្នាលអាវុសោទាំងឡាយ តែកាលបើភិក្ខុពិចារណាហើយដឹងយ៉ាងនេះវិញថា អាត្មាអញមិនជាអ្នក

អមច្ឆរីតិ តេនាវុសោ ភិក្ខុនា តេនេវ បីតិបាមោជ្ជេន វិហាតព្វំ អហោរត្តានុសិក្ខិនា កុសលេសុ ធម្មេសុ ។ បុន ចបរំ អាវុសោ ភិក្ខុនា អត្តនា វ អត្តានំ ឯវំ បច្ចវេក្ខិតព្វំ កិន្នុខោម្ហិ សឋោ មាយាវីតិ ។ សចេ អាវុសោ ភិក្ខុ បច្ចវេក្ខមានោ ឯវំ ជានាតិ សឋោ ខោម្ហិ មាយាវីតិ តេនាវុសោ ភិក្ខុនា តេសំយេវ បាបកានំ អកុសលានំ ធម្មានំ បហានាយ វាយមិតព្វំ ។ សចេ បនាវុសោ ភិក្ខុ បច្ចវេក្ខមានោ ឯវំ ជានាតិ អសឋោ ខោម្ហិ អមាយា-វីតិ តេនាវុសោ ភិក្ខុនា តេនេវ បីតិបាមោជ្ជេន វិហា-តព្វំ អហោរត្តានុសិក្ខិនា កុសលេសុ ធម្មេសុ ។ បុន ចបរំ អាវុសោ ភិក្ខុនា អត្តនា វ អត្តានំ ឯវំ បច្ចវេក្ខិ-តព្វំ កិន្នុខោម្ហិ ថទ្ធោ អតិមានីតិ ។ សចេ អាវុសោ ភិក្ខុ បច្ចវេក្ខមានោ ឯវំ ជានាតិ ថទ្ធោ ខោម្ហិ អតិមា-នីតិ តេនាវុសោ ភិក្ខុនា តេសំយេវ បាបកានំ អកុសលានំ ធម្មានំ បហានាយ វាយមិតព្វំ ។



ប្រណែន មិនជាអ្នកមានសេចក្តីកំណាញ់ទេ ម្នាលអាវុសោទាំងឡាយ ភិក្ខុនោះគួរសិក្សាក្នុងកុសលធម៌ទាំងឡាយអស់យប់និងថ្ងៃហើយនៅដោយបីតិនិងបាមោជ្ជៈនោះឯងមួយយ៉ាង ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុត្រូវពិចារណាខ្លួនដោយខ្លួនឯងយ៉ាងនេះថា អាត្មាអញជាអ្នកអួតអាង ជាអ្នកមានពុតមាយាឬទេ ។ ម្នាលអាវុសោទាំងឡាយ កាលបើភិក្ខុពិចារ-ណាហើយដឹងយ៉ាងនេះថា អាត្មាអញជាអ្នកអួតអាង ជាអ្នកមានពុតមាយា ម្នាលអាវុសោទាំងឡាយ ភិក្ខុនោះគួរព្យាយាម លះបង់នូវអកុសលធម៌លាមកទាំងនោះចេញ ។ ម្នាលអាវុសោទាំងឡាយ តែកាលបើភិក្ខុពិចារ-ណាហើយដឹងយ៉ាងនេះវិញថា អាត្មាអញមិនជាអ្នកអួតអាង មិនជាអ្នកមានពុតមាយាទេ ម្នាលអាវុសោទាំងឡាយ ភិក្ខុនោះគួរសិក្សាក្នុងកុសលធម៌ទាំងឡាយ អស់យប់និងថ្ងៃ ហើយនៅដោយបីតិនិងបាមោជ្ជៈនោះឯងមួយយ៉ាង ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុត្រូវពិចារណាខ្លួនដោយខ្លួនឯងយ៉ាងនេះថា អាត្មាអញជាអ្នករឹងរូស ជាអ្នកមើលងាយគេឬទេ ។ ម្នាលអាវុសោទាំងឡាយ កាលបើភិក្ខុពិចារណាហើយដឹងយ៉ាងនេះថា អាត្មាអញជាអ្នករឹងរូស ជាអ្នកមើលងាយគេ ម្នាលអាវុសោទាំងឡាយ ភិក្ខុនោះគួរព្យាយាមលះបង់នូវអកុសលធម៌ដ៏លាមកទាំងនោះចេញ ។

សចេ បនាវុសោ ភិក្ខុ បច្ចវេក្ខមានោ ឯវំ ជានាតិ អមក្ខី ខោម្ហិ អបឡាសីតិ តេនាវុសោ ភិក្ខុនា តេនេវ បីតិបាមោជ្ជេន វិហាតព្វំ អហោរត្តានុសិក្ខិនា កុសលេសុ ធម្មេសុ ។ បុន ចបរំ អាវុសោ ភិក្ខុនា អត្តនាវ អត្តានំ ឯវំ បច្ចវេក្ខិតព្វំ កិន្នុខោម្ហិ សន្ទិដ្ឋិបរាមាសី អាធានគ្គាហី ទុប្បដិនិស្សគ្គីតិ ។ សចេ អាវុសោ ភិក្ខុ បច្ចវេក្ខមានោ ឯវំ ជានាតិ សន្ទិដ្ឋិបរាមាសី ខោម្ហិ អាធានគ្គាហី ទុប្បដិនិស្សគ្គីតិ តេនាវុសោ ភិក្ខុនា តេសំយេវ បាបកានំ អកុសលានំ ធម្មានំ បហានាយ វាយមិតព្វំ ។ សចេ បនាវុសោ ភិក្ខុ បច្ចវេក្ខមានោ ឯវំ ជានាតិ អសន្ទិដ្ឋិបរាមាសី ខោម្ហិ អនាធានគ្គាហី សុប្បដិនិស្សគ្គីតិ តេនាវុសោ ភិក្ខុនា តេនេវ បីតិបាមោជ្ជេន វិហាតព្វំ អហោរត្តានុសិក្ខិនា កុសលេសុ ធម្មេសុ ។ សចេ អាវុសោ ភិក្ខុ បច្ចវេក្ខមានោ



ម្នាលអាវុសោទាំងឡាយ តែកាលបើភិក្ខុ ពិចារណាហើយដឹងយ៉ាងនេះវិញថា អាត្មាអញ មិនជាអ្នករើរូស មិនជាអ្នកមើលងាយគេទេ ម្នាលអាវុសោទាំងឡាយ ភិក្ខុនោះគួរសិក្សា ក្នុងកុសលធម៌ទាំងឡាយ អស់យប់និងថ្ងៃ ហើយនៅដោយបីតិនិងបាមោជ្ជៈនោះតែមួយយ៉ាង ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុត្រូវពិចារណាខ្លួនដោយខ្លួនឯងយ៉ាងនេះថា អាត្មាអញជាអ្នកប្រកាន់តាមសេចក្តីយល់ឃើញរបស់ខ្លួនឯង ជាអ្នកប្រកាន់មាំ លះបង់ទិដ្ឋិបានដោយក្រឬទេ ។ ម្នាលអាវុសោទាំងឡាយ កាលបើភិក្ខុពិចារណាហើយដឹងយ៉ាងនេះថា អាត្មាអញជាអ្នកកាន់តាមសេចក្តីយល់ឃើញរបស់ខ្លួនឯង ជាអ្នកប្រកាន់មាំ លះបង់ទិដ្ឋិបានដោយក្រ ម្នាលអាវុសោទាំងឡាយ ភិក្ខុនោះគួរព្យាយាមលះបង់នូវអកុសលធម៌ដ៏លាមកទាំងនោះចេញ ។ ម្នាលអាវុសោទាំងឡាយ តែកាលបើភិក្ខុពិចារណាហើយដឹងយ៉ាងនេះវិញថា អាត្មាអញមិនជាអ្នកប្រកាន់តាមសេចក្តីយល់ឃើញរបស់ខ្លួនឯង មិនជាអ្នកប្រកាន់មាំ ជាអ្នកលះបង់ទិដ្ឋិបានដោយងាយ ម្នាលអាវុសោទាំងឡាយ ភិក្ខុនោះគួរសិក្សាក្នុងកុសលធម៌ទាំងឡាយ អស់យប់និងថ្ងៃ ហើយនៅដោយបីតិនិងបាមោជ្ជៈនោះតែមួយយ៉ាង ។ ម្នាលអាវុសោទាំងឡាយ បើភិក្ខុពិចារណា

សព្វេមេ បាបកេ អកុសលេ ធម្មេ អប្បហីនេ អត្តនិ សមនុបស្សតិ តេនាវុសោ ភិក្ខុនា សព្វេសំយេវ ឥមេសំ បាបកានំ អកុសលានំ ធម្មានំ បហានាយ វាយមិតព្វំ ។ សចេ បនាវុសោ ភិក្ខុ បច្ចវេក្ខមានោ សព្វេមេ បាបកេ អកុសលេ ធម្មេ បហីនេ អត្តនិ សមនុបស្សតិ តេនាវុសោ ភិក្ខុនា តេនេវ បីតិបាមោជ្ជេន វិហាតព្វំ អហោរត្តានុសិក្ខិនា កុសលេសុ ធម្មេសុ ។ សេយ្យថាបិ អាវុសោ ឥត្ថី វា បុរិសោ វា ទហរោ យុវា មណ្ឌនកជាតិកោ[១] អាទាសេ វា បរិសុទ្ធេ បរិយោទាតេ អច្ឆេ វា ឧទកបត្តេ សកំ មុខនិមិត្តំ បច្ចវេក្ខមានោ សចេ តត្ថ បស្សតិ រជំ វា អង្គណំ វា តស្សេវ រជស្ស វា អង្គណស្ស វា បហានាយ វាយមតិ នោ ចេ តត្ថ បស្សតិ រជំ វា អង្គណំ វា តេនេវ អត្តមនោ ហោតិ លាភា វត មេ បរិសុទ្ធំ វត មេតិ ឯវមេវ ខោ អាវុសោ សចេ ភិក្ខុ បច្ចវេក្ខមានោ

១ ម. មណ្ឌនជាតិកោ ។



ហើយឃើញច្បាស់នូវអកុសលធម៌ ដ៏លាមកទាំងអស់នេះក្នុងខ្លួនដែលខ្លួនមិនទាន់លះបង់បាន ម្នាលអាវុសោទាំងឡាយ ភិក្ខុនោះគួរព្យាយាមលះបង់នូវអកុសលធម៌ដ៏លាមកទាំងអស់នេះចេញ ។ ម្នាលអាវុសោទាំងឡាយ បើភិក្ខុពិចារណាហើយឃើញច្បាស់នូវអកុសលធម៌ដ៏លាមកទាំងអស់នេះក្នុងខ្លួន ដែលខ្លួនលះបង់បានហើយ ម្នាលអាវុសោទាំងឡាយ ភិក្ខុនោះគួរសិក្សាក្នុងកុសលធម៌ទាំងឡាយ អស់យប់ទាំងថ្ងៃ ហើយនៅដោយបីតិនិងបាមោជ្ជៈនោះតែមួយយ៉ាង ។ ម្នាលអាវុសោទាំងឡាយ ដូចជាស្រីឬប្រុសដែលនៅក្មេងជំទង់ ប្រកបដោយជាតិជាអ្នកស្អិតស្អាង កាលឆ្លុះមើលស្រមោលមុខរបស់ខ្លួន ក្នុងកញ្ចក់ដ៏ស្អាតផូរផង់ឬក្នុងភាជនៈទឹកដ៏ថ្លា បើឃើញធូលីឬមុនត្រង់មុខនោះ តែងព្យាយាមជម្រះធូលីឬមុននោះចេញ បើមិនឃើញធូលីឬមុនត្រង់មុខនោះទេ រមែងជាអ្នកមានចិត្តត្រេកអរដោយហេតុនោះថា អើហ្ន៎ អញមានលាភហើយតើ អើហ្ន៎ អញស្អាតណាស់តើ ម្នាលអាវុសោទាំងឡាយ កាលបើភិក្ខុពិចារណា

សព្ពេបិមេ បាបកេ អកុសលេ ធម្មេ អប្បហីនេ អត្តនិ សមនុបស្សតិ តេនាវុសោ ភិក្ខុនា សព្ពេសំយេវ ឥមេសំ បាបកានំ អកុសលានំ ធម្មានំ បហានាយ វាយមិតព្វំ ។ សចេ បនាវុសោ ភិក្ខុ បច្ចវេក្ខមានោ សព្ពេបិមេ បាបកេ អកុសលេ ធម្មេ បហីនេ អត្តនិ សមនុបស្សតិ តេនាវុសោ ភិក្ខុនា តេនេវ បីតិបាមោជ្ជេន វិហាតព្វំ អហោរត្តានុសិក្ខិនា កុសលេសុ ធម្មេសូតិ ។ ឥទមវោច អាយស្មា មហាមោគ្គល្លានោ អត្តមនា តេ ភិក្ខូ អាយស្មតោ មហាមោគ្គល្លានស្ស ភាសិតំ អភិនន្ទុន្តិ ។

អនុមានសុត្តំ បញ្ចមំ និដ្ឋិតំ ។



ហើយឃើញច្បាស់នូវអកុសលធម៌ដ៏លាមកទាំងអស់នេះ ក្នុងខ្លួន ដែលខ្លួនមិនទាន់លះបង់បាន ម្នាលអាវុសោទាំងឡាយ ភិក្ខុនោះគួរព្យាយាមលះបង់នូវអកុសលធម៌ដ៏លាមកទាំងអស់នេះចេញ ។ ម្នាលអាវុសោទាំងឡាយ តែកាលបើភិក្ខុ ពិចារណាហើយឃើញច្បាស់នូវអកុសលធម៌ដ៏លាមកទាំងអស់នេះក្នុងខ្លួន ដែលខ្លួនបានលះបង់អស់ហើយ ម្នាលអាវុសោទាំងឡាយ ភិក្ខុនោះគួរសិក្សាក្នុងកុសលធម៌ទាំងឡាយ អស់យប់និងថ្ងៃ ហើយនៅដោយបីតិនិងបាមោជ្ជៈនោះ តែម្តងហោង ។ លុះព្រះមហាមោគ្គល្លាន ដ៏មានអាយុ បានសំដែងនូវព្រះសូត្រនេះចប់ហើយ ភិក្ខុទាំងឡាយនោះក៏មានសេចក្តីត្រេកអរចំពោះភាសិត នៃព្រះមហាមោគ្គល្លានដ៏មានអាយុ ។

ចប់ អនុមានសូត្រ ទី ៥ ។

## ឆដ្ឋំ ចេតោខីលសុត្តំ

(៦៦៦) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ ភិក្ខវោតិ ។ ភទន្តេតិ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។

(៦៦៧) ភគវា ឯតទវោច យស្ស កស្សចិ ភិក្ខវេ ភិក្ខុនោ បញ្ច ចេតោខីលា អប្បហីនា បញ្ច ចេតសោ វិនិពន្ធា អសមុច្ឆិន្នា សោ វតិមស្មឹ ធម្មវិនយេ វុឌ្ឍឹ វិរុឡ្ហឹ វេបុល្លំ អាបជ្ជិស្សតីតិ នេតំ ឋានំ វិជ្ជតិ ។

(៦៦៨) កតមស្ស បញ្ច ចេតោខីលា អប្បហីនា ហោន្តិ ។ ឥធ ភិក្ខវេ ភិក្ខុ សត្ថរិ កង្ខតិ វិចិកិច្ឆតិ នាធិមុច្ចតិ ន សម្បសីទតិ ។ យោ សោ ភិក្ខវេ ភិក្ខុ សត្ថរិ កង្ខតិ វិចិកិច្ឆតិ នាធិមុច្ចតិ

## ចេតោខីលសូត្រ ទី ៦

(៦៦៦) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគទ្រង់គង់ ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ ក្នុងទីនោះឯង ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះ ក៏ទទួលស្តាប់ព្រះពុទ្ធដីកានៃព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ។

(៦៦៧) ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាមួយ មិនបានលះបង់នូវបង្គោលរបស់ចិត្តទាំង ៥ ប្រការ នឹងមិនបានផ្តាច់បង់នូវចំណងរបស់ចិត្តទាំង ៥ ប្រការហើយ ភិក្ខុនោះឯងក៏ដល់នូវសេចក្តីចំរើន លូតលាស់ ធុះធាលក្នុងធម្មវិន័យនេះបានដូច្នេះ ហេតុនេះ មិនមែនជាឋានៈទេ ។

(៦៦៨) បង្គោលរបស់ចិត្តទាំង ៥ ប្រការដែលភិក្ខុនោះមិនបានលះបង់ តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ សង្ស័យ មិនដាច់ស្រេច មិនជឿស៊ប់ មិនជ្រះថ្លា ក្នុងព្រះសាស្តា ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុណា សង្ស័យ មិនដាច់ស្រេច មិនជឿស៊ប់

ន សម្បសីទតិ តស្ស ចិត្តំ ន នមតិ អាតប្បាយ អនុយោគាយ សាតច្ចាយ បធានាយ ។ យស្ស ចិត្តំ ន នមតិ អាតប្បាយ អនុយោគាយ សាតច្ចាយ បធានាយ ឯវមស្សាយំ បឋមោ ចេតោខីលោ អប្បហីនោ ហោតិ ។ បុន ចបរំ ភិក្ខវេ ភិក្ខុ ធម្មេ កង្ខតិ វិចិកិច្ឆតិ នាធិមុច្ចតិ ន សម្បសីទតិ ។បេ។ សង្ឃេ កង្ខតិ វិចិកិច្ឆតិ នាធិមុច្ចតិ ន សម្បសីទតិ ។បេ។ សិក្ខាយ កង្ខតិ វិចិកិច្ឆតិ នាធិមុច្ចតិ ន សម្បសីទតិ ។ យោ សោ ភិក្ខវេ ភិក្ខុ សិក្ខាយ កង្ខតិ វិចិកិច្ឆតិ នាធិមុច្ចតិ ន សម្បសីទតិ តស្ស ចិត្តំ ន នមតិ អាតប្បាយ អនុយោគាយ សាតច្ចាយ បធានាយ ។ យស្ស ចិត្តំ ន នមតិ អាតប្បាយ អនុយោគាយ សាតច្ចាយ បធានាយ ឯវមស្សាយំ ចតុត្ថោ ចេតោខីលោ អប្បហីនោ ហោតិ ។



មិនជ្រះថ្លា ក្នុងព្រះសាស្តាហើយ ចិត្តរបស់ភិក្ខុនោះមិនទុះទៅ ដើម្បីធ្វើព្យាយាមជាគ្រឿងផុតនូវកិលេស ដើម្បីប្រកបព្យាយាមរឿយៗ ដើម្បីប្រព្រឹត្តព្យាយាមមិនដាច់ ដើម្បីតាំងទុកនូវព្យាយាមឡើយ ។ ចិត្តរបស់ភិក្ខុណាមិនទុះទៅ ដើម្បីធ្វើព្យាយាមជាគ្រឿងផុតនូវកិលេស ដើម្បីប្រកបព្យាយាមរឿយៗ ដើម្បីប្រព្រឹត្តព្យាយាមមិនដាច់ ដើម្បីតាំងទុកនូវព្យាយាមទេ នេះឈ្មោះថាជាបង្គោលរបស់ចិត្តទី ១ ដែលភិក្ខុនោះមិនបានលះបង់ហើយយ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុសង្ស័យ មិនដាច់ស្រេច មិនជឿស៊ប់ មិនជ្រះថ្លាក្នុងធម៌ ។បេ។ សង្ស័យ មិនដាច់ស្រេច មិនជឿស៊ប់ មិនជ្រះថ្លាក្នុងសង្ឃ ។បេ។ សង្ស័យ មិនដាច់ស្រេច មិនជឿស៊ប់ មិនជ្រះថ្លាក្នុងសិក្ខា ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាសង្ស័យ មិនដាច់ស្រេច មិនជឿស៊ប់ មិនជ្រះថ្លាក្នុងសិក្ខា ចិត្តរបស់ភិក្ខុនោះមិនទុះទៅ ដើម្បីធ្វើព្យាយាម ជាគ្រឿងផុតនូវកិលេស ដើម្បីប្រកបព្យាយាមរឿយៗ ដើម្បីប្រព្រឹត្តព្យាយាមមិនដាច់ ដើម្បីតាំងទុកនូវព្យាយាមទេ ។ ចិត្តរបស់ភិក្ខុណាមិនទុះទៅ ដើម្បីធ្វើព្យាយាម ជាគ្រឿងផុតនូវកិលេស ដើម្បីប្រកបព្យាយាមរឿយៗ ដើម្បីប្រព្រឹត្តព្យាយាមមិនដាច់ ដើម្បីតាំងទុកនូវព្យាយាមទេ នេះឈ្មោះថាជាបង្គោលរបស់ចិត្តទី ៤ ដែលភិក្ខុនោះមិនបានលះបង់ហើយយ៉ាងនេះ ។

បុន ចបរំ ភិក្ខវេ ភិក្ខុ សព្រហ្មចារី កុបិតោ ហោតិ អនត្តមនោ អាហតចិត្តោ ខិលជាតោ ។ យោ សោ ភិក្ខវេ ភិក្ខុ សព្រហ្មចារីសុ កុបិតោ ហោតិ អនត្តមនោ អាហតចិត្តោ ខិលជាតោ តស្ស ចិត្តំ ន នមតិ អាតប្បាយ អនុយោគាយ សាតច្ចាយ បធានាយ ។ យស្ស ចិត្តំ ន នមតិ អាតប្បាយ អនុយោគាយ សាតច្ចាយ បធានាយ ឯវមស្សាយំ បញ្ចមោ ចេតោខិលោ អប្បហីនោ ហោតិ ។ ឥមស្ស បញ្ច ចេតោខិលា អប្បហីនា ហោន្តិ ។

(៦២៩) កតមស្ស បញ្ច ចេតសោ វិនិពន្ធា អសមុច្ឆិន្នា ហោន្តិ ។ ឥធ ភិក្ខវេ ភិក្ខុ កាមេ អវីតរាគោ ហោតិ អវិគតច្ឆន្ទោ អវិគតបេមោ អវិគតបិបាសោ អវិគតបរិឡាហោ អវិគតតណ្ហោ ។ យោ សោ ភិក្ខវេ ភិក្ខុ



ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត ភិក្ខុជាមនុស្សខឹងញ័រ មានចិត្តអាក់អន់ ។ មានចិត្តដែលគេសង្រួបសង្កត់ហើយ មានចិត្តរឹងរូសក្នុងពួកសព្រហ្មចារី ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាជាមនុស្សខឹងញ័រ មានចិត្តអាក់អន់ មានចិត្តដែលគេសង្រួបសង្កត់ហើយ មានចិត្តរឹងរូសក្នុងពួកសព្រហ្មចារីហើយ ចិត្តរបស់ភិក្ខុនោះមិនឱនទៅ ដើម្បីធ្វើព្យាយាមជាគ្រឿងដុតនូវកិលេស ដើម្បីប្រកបព្យាយាមរឿយ ៗ ដើម្បីប្រព្រឹត្តព្យាយាមមិនដាច់ ដើម្បីតាំងទុកនូវព្យាយាមទេ ។ ចិត្តរបស់ភិក្ខុណាមិនឱនទៅ ដើម្បីធ្វើព្យាយាមជាគ្រឿងដុតនូវកិលេស ដើម្បីប្រកបព្យាយាមរឿយ ៗ ដើម្បីប្រព្រឹត្តព្យាយាមមិនដាច់ ដើម្បីតាំងទុកនូវព្យាយាមទេ នេះឈ្មោះថាជាបង្គោលរបស់ចិត្តទី ៥ ដែលភិក្ខុនោះមិនលះបង់ហើយយ៉ាងនេះ ។ បង្គោលរបស់ចិត្តទាំង ៥ ប្រការនេះ ឈ្មោះថា ភិក្ខុនោះមិនបានលះបង់ហើយ ។

(៦២៩) ចំណងរបស់ចិត្តទាំង ៥ ប្រការដែលភិក្ខុនោះមិនបានផ្ដាច់បង់ហើយ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ មានភិក្ខុមិនទាន់ប្រាសចាកតម្រេក មិនទាន់ប្រាសចាកសេចក្ដីពេញចិត្ត មិនទាន់ប្រាសចាកសេចក្ដីស្រឡាញ់ មិនទាន់ប្រាសចាកសេចក្ដីស្រេកឃ្លាន មិនទាន់ប្រាសចាកសេចក្ដីក្ដៅក្រហាយ មិនទាន់ប្រាសចាកសេចក្ដីប្រាថ្នាក្នុងកាម ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាជាអ្នកមិនទាន់

កាមេ អវីតរាគោ ហោតិ អវិគតច្ឆន្ទោ អវិគតប្បេមោ អវិគតបិបាសោ អវិគតបរិឡាហោ អវិគតតណ្ហោ តស្ស ចិត្តំ ន នមតិ អាតប្បាយ អនុយោគាយ សាតច្ចាយ បធានាយ ។ យស្ស ចិត្តំ ។ បេ ។ បធានាយ ឯវមស្សាយំ បឋមោ ចេតសោ វិនិពន្ធោ អសមុច្ឆិន្នោ ហោតិ ។ បុន ចបរំ ភិក្ខវេ ភិក្ខុ កាយេ អវីតរាគោ ហោតិ ។ បេ ។ រូបេ អវីតរាគោ ហោតិ អវិគតច្ឆន្ទោ អវិគតប្បេមោ អវិគតបិបាសោ អវិគតបរិឡាហោ អវិគតតណ្ហោ ។ យោ សោ ភិក្ខវេ ភិក្ខុ រូបេ អវីតរាគោ ហោតិ ។ បេ ។ ឯវមស្សាយំ តតិយោ ចេតសោ វិនិពន្ធោ អសមុច្ឆិន្នោ ហោតិ ។ បុន ចបរំ ភិក្ខវេ ភិក្ខុ យាវទត្ថំ ឧទរាវទេហកំ ភុញ្ជិត្វា



ប្រាសចាកតម្រេក មិនទាន់ប្រាសចាកសេចក្តីពេញចិត្ត មិនទាន់ប្រាសចាកសេចក្តីស្រឡាញ់ មិនទាន់ប្រាសចាកសេចក្តីស្រេកឃ្លាន មិនទាន់ប្រាសចាកសេចក្តីក្តៅក្រហាយ មិនទាន់ប្រាសចាកសេចក្តីប្រាថ្នាក្នុងកាម ចិត្តរបស់ភិក្ខុនោះមិនទន់ទៅ ដើម្បីធ្វើព្យាយាមជាគ្រឿងដុតកិលេស ដើម្បីប្រកបព្យាយាមរឿយ ៗ ដើម្បីប្រព្រឹត្តព្យាយាមមិនដាច់ ដើម្បីតាំងទុកនូវព្យាយាមឡើយ ។ ចិត្តរបស់ភិក្ខុណា ។ បេ ។ ដើម្បីតាំងទុកនូវព្យាយាមទេ នេះឈ្មោះថាជាចំណងរបស់ចិត្តទី ១ ដែលភិក្ខុនោះមិនបានកាត់ផ្តាច់ហើយយ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត មានភិក្ខុមិនទាន់ប្រាសចាកតម្រេកក្នុងកាយ (របស់ខ្លួន) ។ បេ ។ មិនទាន់ប្រាសចាកតម្រេក មិនទាន់ប្រាសចាកសេចក្តីពេញចិត្ត មិនទាន់ប្រាសចាកសេចក្តីស្រឡាញ់ មិនទាន់ប្រាសចាកសេចក្តីស្រេកឃ្លាន មិនទាន់ប្រាសចាកសេចក្តីក្តៅក្រហាយ មិនទាន់ប្រាសចាកសេចក្តីប្រាថ្នាក្នុងរូប (ខាងក្រៅ) ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាជាអ្នកមិនទាន់ប្រាសចាកតម្រេកក្នុងរូប (ខាងក្រៅទេ) ។ បេ ។ នេះឈ្មោះថាជាចំណងរបស់ចិត្តទី ៣ ដែលភិក្ខុនោះមិនបានកាត់ផ្តាច់ហើយយ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត ភិក្ខុបរិភោគនូវភោជនដរាបដល់ឆ្អែត

សេយ្យសុខំ បស្សសុខំ មិទ្ធសុខំ អនុយុញ្ញោ(១) វិហ-
រតិ ។ យោ សោ ភិក្ខវេ ភិក្ខុ យាវទត្ថំ ឧទរា-
វទេហកំ ភុញ្ជិត្វា សេយ្យសុខំ បស្សសុខំ មិទ្ធសុខំ
អនុយុញ្ញោ(២) វិហរតិ តស្ស ចិត្តំ ន នមតិ អា-
តប្បាយ អនុយោគាយ សាតច្ចាយ បធានាយ ។
យស្ស ចិត្តំ ន នមតិ អាតប្បាយ អនុយោគាយ សា-
តច្ចាយ បធានាយ អយមស្សាយំ ចតុត្ថោ ចេតសោ
វិនិពន្ធោ អសមុច្ឆិន្នោ ហោតិ ។ បុន ចបរំ ភិក្ខវេ
ភិក្ខុ អញ្ញតរំ ទេវនិកាយំ បណិធាយ ព្រហ្មចរិយំ
ចរស្សតិ(៣) ឥមិនាហំ សីលេន វា វតេន វា តបេន
វា ព្រហ្មចរិយេន វា ទេវោ វា ភវិស្សាមិ ទេវញ្ញ-
តរោ វាតិ ។ យោ សោ ភិក្ខវេ ភិក្ខុ អញ្ញតរំ
ទេវនិកាយំ បណិធាយ ព្រហ្មចរិយំ ចរស្សតិ(៤) ឥមិ-
នាហំ សីលេន វា វតេន វា តបេន វា ព្រហ្ម-
ចរិយេន វា ទេវោ វា ភវិស្សាមិ ទេវញ្ញតរោ វាតិ
តស្ស ចិត្តំ ន នមតិ អាតប្បាយ អនុយោគាយ

---

១-២ ឱ.ម. អនុយុត្តោ ។ ៣-៤ ឱ.ម. ចរតិ ។



ពេញផ្ទៃ ហើយប្រកបរឿយ ៗ នូវការដេកស្រួល នូវការផ្អែកស្រួល នូវ
សេចក្ដីលក់ស្រួល ៗ ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាបរិភោគនូវ
ភោជនដរាបដល់ឆ្អែតពេញផ្ទៃ ហើយប្រកបរឿយ ៗ នូវការដេកស្រួល
នូវការផ្អែកស្រួល នូវសេចក្ដីលក់ស្រួល ចិត្តរបស់ភិក្ខុនោះមិនទន់ទៅ
ដើម្បីធ្វើព្យាយាមជាគ្រឿងដុតនូវកិលេស ដើម្បីប្រកបព្យាយាមរឿយ ៗ
ដើម្បីប្រព្រឹត្តព្យាយាមមិនដាច់ ដើម្បីតាំងទុកនូវព្យាយាមឡើយ ។
ចិត្តរបស់ភិក្ខុណាមិនទន់ទៅ ដើម្បីធ្វើព្យាយាមជាគ្រឿងដុតនូវកិលេស
ដើម្បីប្រកបព្យាយាមរឿយ ៗ ដើម្បីប្រព្រឹត្តព្យាយាមមិនដាច់ ដើម្បីតាំង
ទុកនូវព្យាយាមទេ នេះឈ្មោះថាជាចំណងរបស់ចិត្តទី ៤ ដែលភិក្ខុនោះមិន
ទាន់កាត់ផ្ដាច់ហើយយ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត
ភិក្ខុប្រព្រឹត្តនូវព្រហ្មចរិយធម៌ ប្រាថ្នានូវទេវនិកាយណាមួយ ដោយគិតថា
អាត្មាអញនឹងបានជាទេវតាមានសក្តិធំ ឬទេវតាមានសក្តិតូចណាមួយ
ដោយសីលឬវត្ត តបៈឬព្រហ្មចរិយៈនេះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុ
ណាប្រព្រឹត្តនូវព្រហ្មចរិយធម៌ ប្រាថ្នានូវទេវនិកាយណាមួយ ដោយ
គិតថា អាត្មាអញនឹងបានជាទេវតាមានសក្តិធំ ឬជាទេវតាមានសក្តិតូច
ណាមួយ ដោយសីលឬវត្ត តបៈឬព្រហ្មចរិយៈនេះដូច្នេះ ចិត្តរបស់ភិក្ខុ
នោះមិនទន់ទៅ ដើម្បីធ្វើព្យាយាមជាគ្រឿងដុតនូវកិលេស ដើម្បីប្រកប

សាតច្ចាយ បធានាយ ។ យស្ស ចិត្តំ ន នមតិ អាតប្បាយ អនុយោគាយ សាតច្ចាយ បធានាយ អយំ បញ្ចមោ ចេតសោ វិនិពន្ធោ អសមុច្ឆិន្នោ ហោតិ ។ ឥមស្ស បញ្ច ចេតសោ វិនិពន្ធា អសមុច្ឆិន្នា ហោន្តិ ។ យស្ស កស្សចិ ភិក្ខវេ ភិក្ខុនោ ឥមេ បញ្ច ចេតោខិលា អប្បហីនា ឥមេ បញ្ច ចេតសោ វិនិពន្ធា អសមុច្ឆិន្នា ហោន្តិ[១] សោ វតិមស្មឹ ធម្មវិនយេ វុឌ្ឍឹ វិរូឡ្ហឹ វេបុល្លំ អាបជ្ជិស្សតីតិ នេតំ ឋានំ វិជ្ជតិ ។

(៦៣០) យស្ស កស្សចិ ភិក្ខវេ ភិក្ខុនោ បញ្ច ចេតោខិលា បហីនា បញ្ច ចេតសោ វិនិពន្ធា សុសមុច្ឆិន្នា សោ វតិមស្មឹ ធម្មវិនយេ វុឌ្ឍឹ វិរូឡ្ហឹ វេបុល្លំ អាបជ្ជិស្សតីតិ ឋានមេតំ វិជ្ជតិ ។

(៦៣១) កតមស្ស បញ្ច ចេតោខិលា បហីនា ហោន្តិ ។ ឥធ ភិក្ខវេ ភិក្ខុ សត្ថរិ ន កង្ខតិ ន វិចិកិច្ឆតិ អធិមុច្ចតិ សម្បសីទតិ ។

១ ឱ. ម. ហោន្តីតិ ន ទិស្សតិ ។



ព្យាយាមរឿយ ៗ ដើម្បីប្រព្រឹត្តព្យាយាមមិនដាច់ ដើម្បីតាំងទុកនូវព្យាយាមទេ ។ ចិត្តរបស់ភិក្ខុណាមិនទុនទៅ ដើម្បីធ្វើព្យាយាមជាគ្រឿងដុតនូវកិលេស ដើម្បីប្រកបព្យាយាមរឿយ ៗ ដើម្បីប្រព្រឹត្តព្យាយាមមិនដាច់ ដើម្បីតាំងទុកនូវព្យាយាមទេ នេះឈ្មោះថាជាចំណងរបស់ចិត្តទី ៥ ដែលភិក្ខុនោះមិនបានកាត់ផ្តាច់ហើយយ៉ាងនេះ ។ ចំណងរបស់ចិត្តទាំង ៥ ប្រការនេះ ឈ្មោះថា ភិក្ខុនោះមិនបានកាត់ផ្តាច់ហើយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាមួយ មិនបានលះបង់នូវបង្គោលរបស់ចិត្តទាំង ៥ ប្រការនេះ មិនកាត់ផ្តាច់នូវចំណងរបស់ចិត្តទាំង ៥ ប្រការនេះទេ ភិក្ខុនោះឯងនឹងដល់នូវសេចក្តីចំរើន លូតលាស់ ដុះដាល ក្នុងធម្មវិន័យនេះ ដូច្នេះ នេះមិនមែនជាឋានៈទេ ។

(៦៣០) ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាមួយបានលះបង់នូវបង្គោលរបស់ចិត្តទាំង ៥ ប្រការ កាត់ផ្តាច់នូវចំណងរបស់ចិត្តទាំង ៥ ប្រការ ភិក្ខុនោះឯងនឹងដល់នូវសេចក្តីចំរើន លូតលាស់ ដុះដាល ក្នុងធម្មវិន័យនេះ ដូច្នេះ នេះរមែងជាឋានៈ ។

(៦៣១) បង្គោលរបស់ចិត្តទាំង ៥ ប្រការ ដែលភិក្ខុនោះលះបង់ហើយ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ មិនសង្ស័យ មិនស្ទាក់ស្ទើរ ជឿស៊ប់ ជ្រះថ្លា ក្នុងព្រះសាស្តា ។

យោ សោ ភិក្ខវេ ភិក្ខុ សត្ថរិ ន កង្ខតិ ន វិចិកិច្ឆតិ អធិមុច្ចតិ សម្បសីទតិ តស្ស ចិត្តំ នមតិ អាតប្បាយ អនុយោគាយ សាតច្ចាយ បធានាយ ។ យស្ស ចិត្តំ នមតិ អាតប្បាយ អនុយោគាយ សាតច្ចាយ បធានាយ អយមស្សាយំ បឋមោ ចេតោខិលោ បហីនោ ហោតិ ។ បុន ចបរំ ភិក្ខវេ ភិក្ខុ ធម្មេ ន កង្ខតិ ន វិចិកិច្ឆតិ អធិមុច្ចតិ សម្បសីទតិ ។ បេ ។ សង្ឃេ ន កង្ខតិ ន វិចិកិច្ឆតិ អធិមុច្ចតិ សម្បសីទតិ ។ បេ ។ សិក្ខាយ ន កង្ខតិ ន វិចិកិច្ឆតិ អធិមុច្ចតិ សម្បសីទតិ ។ យោ សោ ភិក្ខវេ ភិក្ខុ សិក្ខាយ ន កង្ខតិ ន វិចិកិច្ឆតិ អធិមុច្ចតិ សម្បសីទតិ តស្ស ចិត្តំ នមតិ ។ បេ ។ អយមស្សាយំ ចតុត្ថោ ចេតោខិលោ បហីនោ ហោតិ ។ បុន ចបរំ ភិក្ខវេ ភិក្ខុ សព្រហ្មចារីសុ ន កុបិតោ ហោតិ ន អនត្តមនោ ន អាហតចិត្តោ ន ខិលជាតោ ។ យោ សោ ភិក្ខវេ ភិក្ខុ សព្រហ្មចារីសុ ន កុបិតោ ហោតិ ន អនត្តមនោ



ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាមិនសង្ស័យ មិនស្នាក់ស្ទើរ ជឿស៊ប់ជ្រះថ្លាក្នុងព្រះសាស្តា ចិត្តរបស់ភិក្ខុនោះឱនទៅ ដើម្បីធ្វើព្យាយាមជាគ្រឿងដុតនូវកិលេស ដើម្បីប្រកបព្យាយាមរឿយ ៗ ដើម្បីប្រព្រឹត្តព្យាយាមមិនដាច់ ដើម្បីតាំងទុកនូវព្យាយាម ។ ចិត្តរបស់ភិក្ខុណាឱនទៅ ដើម្បីធ្វើព្យាយាមជាគ្រឿងដុតនូវកិលេស ដើម្បីប្រកបរឿយ ៗ ដើម្បីប្រព្រឹត្តព្យាយាមមិនដាច់ ដើម្បីតាំងទុកនូវព្យាយាមហើយ នេះឈ្មោះថាជាបង្គោលរបស់ចិត្តទី ១ ដែលភិក្ខុនោះលះបង់ហើយយ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុមិនសង្ស័យ មិនស្នាក់ស្ទើរ ជឿស៊ប់ ជ្រះថ្លា ក្នុងធម៌ ។ បេ ។ មិនសង្ស័យ មិនស្នាក់ស្ទើរ ជឿស៊ប់ ជ្រះថ្លា ក្នុងសង្ឃ ។ បេ ។ មិនសង្ស័យ មិនស្នាក់ស្ទើរ ជឿស៊ប់ ជ្រះថ្លា ក្នុងសិក្ខា ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាមិនសង្ស័យ មិនស្នាក់ស្ទើរ ជឿស៊ប់ ជ្រះថ្លា ក្នុងសិក្ខា ចិត្តរបស់ភិក្ខុនោះរមែងឱនទៅ ។ បេ ។ នេះឈ្មោះថាបង្គោលនៃចិត្តទី ៤ ដែលភិក្ខុនោះលះបង់ហើយយ៉ាងនេះ ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត ភិក្ខុជាមនុស្សមិនទឹងទែង មិនមានចិត្តតាក់អន់ មិនមានចិត្តដែលទោសគ្របសង្កត់ មិនមានចិត្តរឹងរូស ក្នុងពួកសព្រហ្មចារី ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាជាមនុស្សមិនទឹងទែង មិនមានចិត្តតាក់អន់

ន អាហតចិត្តោ ន ខិលជាតោ តស្ស ចិត្តំ នមតិ អាតប្បាយ អនុយោគាយ សាតច្ចាយ បធានាយ ។ យស្ស ចិត្តំ នមតិ អាតប្បាយ អនុយោគាយ សាតច្ចាយ បធានាយ អយមស្ស បញ្ចមោ ចេតោខិលោ បហីនោ ហោតិ ។ ឥមស្ស បញ្ច ចេតោខិលា បហីនា ហោន្តិ ។

(២៣៦) កតមស្ស បញ្ច ចេតសោ វិនិពន្ធា សុសមុច្ឆិន្នា ហោន្តិ ។ ឥធ ភិក្ខវេ ភិក្ខុ កាមេ វីតរាគោ ហោតិ វិគតច្ឆន្ទោ វិគតបេមោ វិគតបិបាសោ វិគតបរិឡាហោ វិគតតណ្ហោ ។ យោ សោ ភិក្ខវេ ភិក្ខុ កាមេ វីតរាគោ ហោតិ វិគតច្ឆន្ទោ វិគតបេមោ វិគតបិបាសោ វិគតបរិឡាហោ វិគតតណ្ហោ តស្ស ចិត្តំ



មិនមានចិត្តដែលពោសព្រោសផ្តុក មិនមានចិត្តរឹងរូស ក្នុងពួកសព្រហ្មចារី ចិត្តរបស់ភិក្ខុនោះរមែងទន់ទៅ ដើម្បីធ្វើព្យាយាមជាគ្រឿងដុតនូវកិលេស ដើម្បីប្រកបព្យាយាមរឿយ ៗ ដើម្បីប្រព្រឹត្តព្យាយាមមិនដាច់ ដើម្បីតាំងទុកនូវព្យាយាម ។ ចិត្តរបស់ភិក្ខុណាទន់ទៅ ដើម្បីធ្វើព្យាយាមជាគ្រឿងដុតនូវកិលេស ដើម្បីប្រកបព្យាយាមរឿយៗ ដើម្បីប្រព្រឹត្តព្យាយាមមិនដាច់ ដើម្បីតាំងទុកនូវព្យាយាមហើយ នេះឈ្មោះថាជាបង្អើលរបស់ចិត្តទី ៥ ដែលភិក្ខុនោះលះបង់ហើយយ៉ាងនេះ ។ បង្អើលរបស់ចិត្តទាំង ៥ ប្រការនេះ ឈ្មោះថា ភិក្ខុនោះលះបង់ហើយ ។

(២៣៦) ចំណងរបស់ចិត្តទាំង ៥ ប្រការ ដែលភិក្ខុនោះកាត់ផ្តាច់ហើយដោយល្អ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកប្រាសចាកតម្រេក ប្រាសចាកសេចក្តីពេញចិត្ត ប្រាសចាកសេចក្តីស្រឡាញ់ ប្រាសចាកសេចក្តីស្រេកឃ្លាន ប្រាសចាកសេចក្តីក្តៅក្រហាយ ប្រាសចាកសេចក្តីប្រាថ្នាក្នុងកាម ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាប្រាសចាកតម្រេក ប្រាសចាកសេចក្តីពេញចិត្ត ប្រាសចាកសេចក្តីស្រឡាញ់ ប្រាសចាកសេចក្តីស្រេកឃ្លាន ប្រាសចាកសេចក្តីក្តៅក្រហាយ ប្រាសចាកសេចក្តីប្រាថ្នាក្នុងកាម ចិត្តរបស់ភិក្ខុនោះ

នមតិ អាតប្បាយ អនុយោគាយ សាតច្ចាយ បធា-នាយ យស្ស ចិត្តំ នមតិ អាតប្បាយ អនុយោគាយ សាតច្ចាយ បធានាយ ឯវមស្សាយំ បឋមោ ចេត-សោ វិនិពន្ធោ សុសមុច្ឆិន្នោ ហោតិ ។ បុន ចបរំ ភិក្ខវេ ភិក្ខុ កាយេ វីតរាគោ ហោតិ ។ បេ ។ រូបេ វីតរាគោ ហោតិ ។ បេ ។ បុន ចបរំ ភិក្ខវេ ភិក្ខុ ន យាវទត្ថំ ឧទរាវទេហកំ ភុញ្ជិត្វា សេយ្យ-សុខំ បស្សសុខំ មិទ្ធសុខំ អននុយុញ្ជន្តោ វិហរតិ ។ យោ សោ ភិក្ខវេ ភិក្ខុ ន យាវទត្ថំ ឧទរា-វទេហកំ ភុញ្ជិត្វា សេយ្យសុខំ បស្សសុខំ មិទ្ធ-សុខំ អននុយុញ្ជន្តោ វិហរតិ តស្ស ចិត្តំ នមតិ អាតប្បាយ អនុយោគាយ សាតច្ចាយ បធានាយ យស្ស ចិត្តំ នមតិ អាតប្បាយ អនុយោគាយ



រមែងទំនោរទៅ ដើម្បីធ្វើព្យាយាមជាគ្រឿងដុតនូវកិលេស ដើម្បីប្រកបព្យាយាមរឿយ ៗ ដើម្បីប្រព្រឹត្តព្យាយាមមិនដាច់ ដើម្បីតាំងទុកនូវព្យា-យាម ចិត្តរបស់ភិក្ខុណាទំនោរទៅ ដើម្បីធ្វើព្យាយាមជាគ្រឿងដុតកិលេស ដើម្បីប្រកបព្យាយាមរឿយ ៗ ដើម្បីប្រព្រឹត្តព្យាយាមមិនដាច់ ដើម្បីតាំងទុកនូវព្យាយាមហើយ នេះឈ្មោះថាជាចំណងរបស់ចិត្តទី ១ ដែលភិក្ខុនោះ កាត់ផ្តាច់ហើយយ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុជាអ្នកប្រាសចាកតម្រេកក្នុងកាយ ( របស់ខ្លួន ) ។ បេ ។ ប្រាសចាកតម្រេកក្នុងរូប ( ខាងក្រៅ ) ។ បេ ។ ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត ភិក្ខុមិនបរិភោគភោជនដកបដល់ផ្ទៃពេញផ្ទៃ មិនប្រកបរឿយ ៗ នូវទីដេកស្រួល នូវទីផ្អែកស្រួល នឹងសេចក្តីលក់ស្រួល ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាមិនបរិភោគភោជនដកបដល់ផ្ទៃពេញផ្ទៃ មិនប្រកបរឿយ ៗ នូវទីដេកស្រួល នូវទីផ្អែកស្រួល នឹងសេចក្តីលក់ស្រួល ចិត្តរបស់ភិក្ខុនោះរមែងទំនោរទៅ ដើម្បីធ្វើព្យាយាមជាគ្រឿងដុតនូវកិលេស ដើម្បីប្រកបព្យាយាមរឿយ ៗ ដើម្បីប្រព្រឹត្តព្យាយាមមិនដាច់ ដើម្បីតាំងទុកនូវព្យាយាម ចិត្តរបស់ភិក្ខុណា រមែងទំនោរទៅ ដើម្បីធ្វើព្យាយាមជាគ្រឿងដុតនូវកិលេស ដើម្បីប្រកបព្យាយាមរឿយ ៗ

សាតច្ចាយ បធានាយ ឯវមស្សាយំ ចតុត្ថោ ចេត-
សោ វិនិពន្ធោ សុសមុច្ឆិន្នោ ហោតិ ។ បុន ចបរំ
ភិក្ខវេ ភិក្ខុ ន អញ្ញតរំ ទេវនិកាយំ បណិធាយ
ព្រហ្មចរិយំ ចរតិ ឥមិនាហំ សីលេន វា វតេន
វា តបេន វា ព្រហ្មចរិយេន វា ទេវោ វា ភវិស្សាមិ
ទេវញ្ញតរោ វាតិ ។ យោ សោ ភិក្ខវេ ភិក្ខុ ន
អញ្ញតរំ ទេវនិកាយំ បណិធាយ ព្រហ្មចរិយំ ចរតិ
ឥមិនាហំ សីលេន វា វតេន វា តបេន វា ព្រហ្មចរិយេន
វា ទេវោ វា ភវិស្សាមិ ទេវញ្ញតរោ វាតិ តស្ស ចិត្តំ នមតិ
អាតប្បាយ អនុយោគាយ សាតច្ចាយ បធានាយ
យស្ស ចិត្តំ នមតិ អាតប្បាយ អនុយោគាយ សា-
តច្ចាយ បធានាយ ឯវមស្សាយំ បញ្ចមោ ចេតសោ
វិនិពន្ធោ សុសមុច្ឆិន្នោ ហោតិ ។ ឥមស្ស បញ្ច
ចេតសោ វិនិពន្ធា សុសមុច្ឆិន្នា ហោន្តិ ។ យស្ស កស្សចិ
ភិក្ខវេ ភិក្ខុនោ ឥមេ បញ្ច ចេតោខិលា បហីនា



ដើម្បីប្រព្រឹត្តព្យាយាមមិនដាច់ ដើម្បីតាំងទុកនូវព្យាយាម នេះឈ្មោះថា
ជាចំណងរបស់ចិត្តទី៤ ដែលភិក្ខុនោះកាត់ផ្តាច់ហើយដោយល្អយ៉ាងនេះ ៗ
ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត ភិក្ខុប្រព្រឹត្តព្រហ្មចរិយធម៌ មិន
ប្រាថ្នានូវទេវនិកាយណាមួយ ដោយគិតថា អាត្មាអញនឹងបានជាទេវតា
មានស័ក្តិធំ ឬជាទេវតាមានស័ក្តិតូចណាមួយ ដោយសីលវត្ត តបៈ ឬព្រហ្ម-
ចរិយៈនេះៗ ៗ ម្នាលភិក្ខុទាំងឡាយ ភិក្ខុណា ប្រព្រឹត្តព្រហ្មចរិយធម៌
មិនប្រាថ្នានូវទេវនិកាយណាមួយ ដោយគិតថា អាត្មាអញនឹងបានជា
ទេវតាមានស័ក្តិធំ ឬជាទេវតាមានស័ក្តិតូចណាមួយ ដោយសីលវត្ត តបៈ
ឬព្រហ្មចរិយៈនេះទេ ចិត្តរបស់ភិក្ខុនោះរមែងឱនទៅ ដើម្បីធ្វើព្យាយាមជា
គ្រឿងដុតនូវកិលេស ដើម្បីប្រកបព្យាយាមរឿយៗ ដើម្បីប្រព្រឹត្តព្យាយាម
មិនដាច់ ដើម្បីតាំងទុកនូវព្យាយាម ចិត្តរបស់ភិក្ខុណា រមែងឱនទៅ
ដើម្បីធ្វើព្យាយាមជាគ្រឿងដុតនូវកិលេស ដើម្បីប្រកបព្យាយាមរឿយ ៗ
ដើម្បីប្រព្រឹត្តព្យាយាមមិនដាច់ ដើម្បីតាំងទុកនូវព្យាយាម នេះឈ្មោះថា
ជាចំណងរបស់ចិត្តទី៥ ដែលភិក្ខុនោះកាត់ផ្តាច់ហើយដោយល្អយ៉ាងនេះ ៗ
ចំណងរបស់ចិត្តទាំង៥ ប្រការនេះឯងឈ្មោះថាភិក្ខុនោះកាត់ផ្តាច់ហើយ ៗ
ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាមួយបានលះបង់ នូវបង្គោលរបស់ចិត្ត

ឥមេ បញ្ច ចេតសោ វិនិពន្ធា សុសមុច្ឆិន្នា ហោន្តិ ។ សោ ឥមស្មឹ ធម្មវិនយេ វុឌ្ឍឹ វិរូឡ្ហឹ វេបុល្លំ អា-បជ្ជិស្សតីតិ ឋានមេតំ វិជ្ជតិ ។

(២៣៣) សោ ឆន្ទសមាធិប្បធានសង្ខារសមន្នាគតំ ឥទ្ធិបាទំ ភាវេតិ វីរិយសមាធិ ចិត្តសមាធិ វីមំសាសមា-ធិប្បធានសង្ខារសមន្នាគតំ ឥទ្ធិបាទំ ភាវេតិ ឧស្សោឡ្ហិ-ញ្ញេវ បញ្ចមី ។ ស ខោ សោ ភិក្ខវេ ឯវំ ឧស្សោ-ឡ្ហិបណ្ណរសង្គសមន្នាគតោ ភិក្ខុ ភព្វោ អភិនិព្វិទាយ ភព្វោ សម្ពោធាយ ភព្វោ អនុត្តរស្ស យោគក្ខេមស្ស អធិគមាយ ។ សេយ្យថាបិ ភិក្ខវេ កុក្កុដិយា អណ្ឌានិ អដ្ឋ វា ទស វា ទ្វាទស វា តានស្សុ កុក្កុ-ដិយា សម្មា អធិសយិតានិ សម្មា បរិសេទិតានិ សម្មា បរិភាវិតានិ ។ កិញ្ចាបិ តស្សា កុក្កុដិយា ន ឯវំ ឥច្ឆា ឧប្បជ្ជេយ្យ អហោ វតិមេ កុក្កុដបោតកា បាទ-នខសិខាយ វា មុខតុណ្ឌកេន វា អណ្ឌកោសំ បទា-លេត្វា សោត្ថិនា អភិនិព្ភិជ្ជេយ្យុន្តិ អថខោ ភព្វា



ទាំង ៥ ប្រការនេះ បានកាត់ផ្តាច់នូវចំណងរបស់ចិត្តទាំង ៥ ប្រការនេះ ។ ភិក្ខុនោះឯងនឹងដល់នូវសេចក្តីចំរើន លូតលាស់ ផុះផុល ក្នុងសាសនានេះដូច្នេះ នេះទើបជាឋានៈ ។

(២៣៣) ភិក្ខុនោះ ចំរើននូវឥទ្ធិបាទ ដែលប្រកបដោយឆន្ទស-មាធិ និងបធានសង្ខារ ចំរើននូវឥទ្ធិបាទដែលប្រកបដោយវីរិយសមាធិ ចិត្តសមាធិ វីមំសាសមាធិ និងបធានសង្ខារ មានសេចក្តីព្យាយាមជាគំរប់ ៥ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះឯង ប្រកបដោយអង្គ ១៥[*] មួយអន្លើដោយសេចក្តីព្យាយាមខ្ជាប់ យ៉ាងនេះហើយ ភិក្ខុនោះគួរដើម្បីនឿយណាយនូវកិលេស គួរដើម្បីត្រាស់ដឹង គួរដើម្បីបាននូវគោលក្តជាអនុត្តរ-ធម៌ដ៏ក្សេមចាកយោគៈ ។ ម្នាលភិក្ខុទាំងឡាយ ដូចជាស៊ុតមាន់ទាំងឡាយ ៨ ក្តី ១០ ក្តី ១២ ក្តី ស៊ុតមាន់ទាំងនោះដែលមេមាន់ក្រាបដោយប្រពៃ ហើយធ្វើឲ្យក្តៅដោយប្រពៃហើយ ឲ្យជាប់ក្លិនជាតិមាន់ដោយប្រពៃហើយ ។ មេមាន់នោះមិនបាច់មានសេចក្តីប្រាថ្នាកើតឡើងយ៉ាងនេះថា ឱហ្ន៎ កូនមាន់ទាំងនេះ គួរទំលាយនូវសំបកស៊ុតដោយចុងក្រចក ឬដោយចុងចំពុះហើយញាស់ចេញមកដោយសួស្តីដូច្នេះ ក៏ពិតមែនហើយ ប៉ុន្តែ

* អង្គ ១៥ នោះគឺ កប់យកចេតោខិលប្បហាន ៥ វិនិពន្ធប្បហាន ៥ ឥទ្ធិបាទ ៤ ឧស្សោឡ្ហី ១ ផ្សំគ្នាត្រូវជា ១៥ ។ អដ្ឋកថា ។

តេ កុក្កុដបោតកា បាទនខសិខាយ វា មុខតុណ្ឌ-
កេន វា អណ្ឌកោសំ បទាលេត្វា សោត្ថិនា អភិនិព្ភិ-
ជ្ជិតុំ ឯវមេវ ខោ ភិក្ខវេ ឯវំ ឧស្សោឡ្ហិបណ្ណរសង្គសមន្នា-
គតោ ភិក្ខុ ភព្វោ អភិនិព្ភិទាយ ភព្វោ សម្ពោធាយ
ភព្វោ អនុត្តរស្ស យោគក្ខេមស្ស អធិគមាយាតិ ។
ឥទមវោច ភគវា អត្តមនា តេ ភិក្ខូ ភគវតោ
ភាសិតំ អភិនន្ទុន្តិ ។

ចេតោខិលសុត្តំ ឆដ្ឋំ និដ្ឋិតំ(១) ។

១ ឱ.ម. និដ្ឋិតន្តិ ន ទិស្សតិ ។ ឯវំ សព្វត្ថ ។



កូនមាន់ទាំងនោះនឹងទម្លាយសម្បកស៊ុតដោយចុងក្រចក ឬដោយចុងចំពុះ ហើយញាស់ចេញមកដោយសួស្តីបាន ដូចម្តេចមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលប្រកបដោយអង្គទាំង ១៥ មួយអន្លើដោយសេចក្តីព្យាយាមមាំយ៉ាងនេះហើយ ជាអ្នកគួរដើម្បីទម្លាយ ( នូវកិលេស ) គួរដើម្បីត្រាស់ដឹង គួរដើម្បីបាននូវអរហត្តជាអនុត្តរធម៌ដ៏ក្សេមចាកយោគៈ ក៏ដូច្នោះដែរ ។ លុះព្រះមានព្រះភាគ បានសំដែងចេតោខិលសូត្រនេះចប់ហើយ ភិក្ខុទាំងនោះក៏មានសេចក្តីពេញចិត្ត ត្រេកអរចំពោះភាសិតរបស់ព្រះមានព្រះភាគ ។

ចប់ ចេតោខិលសូត្រ ទី ៦ ។

## សត្តមំ វនបត្ថសុត្តំ

(២៣៤) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ ភិក្ខវោតិ ។ ភទន្តេតិ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច វនបត្ថបរិយាយំ វោ ភិក្ខវេ ទេសិស្សាមិ តំ សុណាថ សាធុកំ មនសិករោថ ភាសិស្សាមីតិ ។ ឯវំ ភន្តេតិ ខោ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។

(២៣៥) ភគវា ឯតទវោច ឥធ ភិក្ខវេ ភិក្ខុ អញ្ញតរំ វនបត្ថំ ឧបនិស្សាយ វិហរតិ តស្ស តំ វនបត្ថំ ឧបនិស្សាយ វិហរតោ អនុបដ្ឋិតា ចេវ សតិ ន ឧបដ្ឋាតិ អសមាហិតញ្ច ចិត្តំ ន សមាធិយតិ អបរិក្ខីណា ច អាសវា ន បរិក្ខយំ គច្ឆន្តិ អននុប្បត្តញ្ច អនុត្តរំ យោគក្ខេមំ នានុបាបុណាតិ

## វនបត្ថសូត្រ ទី ៧

(២៣៤) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគទ្រង់គង់ក្នុងវត្តជេតពនរបស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ ក្នុងទីនោះឯង ព្រះមានព្រះភាគទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះទទួលព្រះពុទ្ធដីកាព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ។ ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែងនូវហេតុនៃការនៅក្នុងព្រៃដល់អ្នកទាំងឡាយ ចូរអ្នកទាំងឡាយប្រុងស្តាប់ធ្វើទុកក្នុងចិត្តនូវហេតុនោះដោយប្រពៃចុះ តថាគតនឹងសំដែងឥឡូវនេះ ។ ភិក្ខុទាំងនោះទទួលព្រះពុទ្ធដីកាព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។

(២៣៥) ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចូលទៅអាស្រ័យនូវដងព្រៃណាមួយ កាលភិក្ខុនោះចូលទៅអាស្រ័យនូវដងព្រៃនោះ សតិដែលមិនបានតាំងមាំ ក៏នៅតែមិនបានតាំងមាំដដែល ចិត្តដែលមិនខ្ជាប់ខ្ជួន ក៏នៅតែមិនខ្ជាប់ខ្ជួនដដែល អាសវៈទាំងឡាយដែលមិនទាន់អស់ទៅ ក៏នៅតែមិនទាន់ដល់នូវកិរិយាអស់ទៅដដែល ធម៌ដ៏ក្សេមចាកយោគៈ គឺអរហត្តផល ធម៌ប្រសើរបំផុត ដែលខ្លួនមិនទាន់បានដល់ ក៏នៅតែមិនទាន់បានដល់

យេ ចិមេ បព្វជិតេន ជីវិតបរិក្ខារា សមុទានេតព្វា ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារា តេ កសិរេន សមុទាគច្ឆន្តិ ។ តេន ភិក្ខវេ ភិក្ខុនា ឥតិ បដិសញ្ចិក្ខិតព្វំ អហំ ខោ ឥមំ វនបត្ថំ ឧបនិស្សាយ វិហរាមិ តស្ស មេ ឥមំ វនបត្ថំ ឧបនិស្សាយ វិហរតោ អនុបដ្ឋិតា ចេវ សតិ ន ឧបដ្ឋាតិ អសមាហិតញ្ច ចិត្តំ ន សមាធិយតិ អបរិក្ខីណា ច អាសវា ន បរិក្ខយំ គច្ឆន្តិ អននុប្បត្តញ្ច អនុត្តរំ យោគក្ខេមំ នានុបាបុណាមិ យេ ចិមេ បព្វជិតេន ជីវិតបរិក្ខារា សមុទានេតព្វា ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារា តេ កសិរេន សមុទាគច្ឆន្តីតិ ។ តេន ភិក្ខវេ ភិក្ខុនា រត្តិភាគំ វា ទិវសភាគំ វា តម្ហា វនបត្ថា បក្កមិតព្វំ ន វត្ថព្វំ ។



ឯដែល គ្រឿងបម្រុងជីវិត គឺចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ច័យភេសជ្ជបរិក្ខារណាមួយនេះ ដែលបព្វជិតគប្បីប្រមូលមក គ្រឿងបម្រុងជីវិតទាំងនោះ ក៏កើតឡើងដោយលំបាក ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះគប្បីពិចារណាដូច្នេះថា អាត្មាអញចូលមកអាស្រ័យនូវដងព្រៃនេះ កាលអាត្មាអញចូលមកអាស្រ័យនូវដងព្រៃនេះ សតិដែលមិនបានតាំងមាំ ក៏នៅតែមិនបានតាំងមាំដដែល ចិត្តដែលមិនខ្ជាប់ខ្ជួន ក៏នៅតែមិនខ្ជាប់ខ្ជួនដដែល អាសវៈទាំងឡាយដែលមិនទាន់អស់ទៅ ក៏នៅតែមិនទាន់ដល់នូវកិរិយាអស់ទៅដដែល ធម៌ដ៏ក្សេមចាកយោគៈគឺអរហត្តផលដ៏ប្រសើរបំផុត ដែលអាត្មាអញមិនទាន់ដល់ ក៏នៅតែមិនទាន់ដល់ដដែល គ្រឿងបម្រុងជីវិតទាំងឡាយ គឺចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ច័យភេសជ្ជបរិក្ខារឯណា ដែលបព្វជិតគប្បីប្រមូលមក គ្រឿងបម្រុងជីវិតទាំងនោះ ក៏កើតឡើងដោយលំបាក ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះគប្បីចៀសចេញចាកដងព្រៃនោះ ក្នុងចំណែកនៃរាត្រី ឬក្នុងចំណែកនៃថ្ងៃ មិនត្រូវនៅក្នុងដងព្រៃនោះឡើយ ។

(២៣៦) ឥធ បន ភិក្ខវេ ភិក្ខុ អញ្ញតរំ វនបត្ថំ ឧបនិស្សាយ វិហរតិ តស្ស តំ វនបត្ថំ ឧបនិស្សាយ វិហរតោ អនុបដ្ឋិតា ចេវ សតិ ន ឧបដ្ឋាតិ អសមាហិតញ្ច ចិត្តំ ន សមាធិយតិ អបរិក្ខីណា ច អាសវា ន បរិក្ខយំ គច្ឆន្តិ អននុប្បត្តញ្ច អនុត្តរំ យោគក្ខេមំ នានុបាបុណាតិ យេ ច ខោ ឥមេ[១] បព្វជិតេន ជីវិតបរិក្ខារា សមុទានេតព្វា ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារា តេ អប្បកសិរេន សមុទាគច្ឆន្តិ ។ តេន ភិក្ខវេ ភិក្ខុនា ឥតិ បដិសញ្ចិក្ខិតព្វំ អហំ ខោ ឥមំ វនបត្ថំ ឧបនិស្សាយ វិហរាមិ តស្ស មេ ឥមំ វនបត្ថំ ឧបនិស្សាយ វិហរតោ អនុបដ្ឋិតា ចេវ សតិ ន ឧបដ្ឋាតិ អសមាហិតញ្ច ចិត្តំ ន សមាធិយតិ អបរិក្ខីណា ច អាសវា ន បរិក្ខយំ គច្ឆន្តិ អននុប្បត្តញ្ច អនុត្តរំ យោគក្ខេមំ នានុបាបុណាមិ យេ ច ខោ ឥមេ[២] បព្វជិតេន ជីវិតបរិក្ខារា សមុទានេតព្វា ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារា តេ

១-២ ម. យេ ចិមេ ។



(២៣៦) ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចូលទៅអាស្រ័យនូវដងព្រៃណាមួយ កាលភិក្ខុនោះចូលទៅអាស្រ័យនូវដងព្រៃនោះ សតិដែលមិនបានតាំងមាំ ក៏នៅតែមិនបានតាំងមាំដដែល ចិត្តដែលមិនខ្ជាប់ខ្ជួន ក៏នៅតែមិនខ្ជាប់ខ្ជួនដដែល អាសវៈទាំងឡាយដែលមិនទាន់អស់ទៅ ក៏នៅតែមិនទាន់ដល់នូវកិរិយាអស់ទៅដដែល ធម៌ដ៏ក្សេមចាកយោគៈ គឺអរហត្តជាធម៌ប្រសើរបំផុត ដែលមិនទាន់ដល់ ក៏នៅតែមិនទាន់ដល់ដដែល គ្រឿងបរិក្ខារនៃជីវិតទាំងឡាយ គឺចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ចយភេសជ្ជបរិក្ខារឯណានេះ ដែលបព្វជិតគប្បីប្រមូលមក គ្រឿងបរិក្ខារនៃជីវិតទាំងនោះ ក៏កើតឡើងដោយមិនលំបាក ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះគប្បីពិចារណាដូច្នេះថា អាត្មាអញចូលទៅអាស្រ័យនូវដងព្រៃនេះ កាលអាត្មាអញចូលទៅអាស្រ័យនូវដងព្រៃនេះ ចិត្តដែលមិនតាំងមាំ ក៏នៅតែមិនបានតាំងមាំដដែល ចិត្តដែលមិនខ្ជាប់ខ្ជួនក៏នៅតែមិនខ្ជាប់ខ្ជួនដដែល អាសវៈទាំងឡាយដែលមិនទាន់អស់ទៅ ក៏នៅតែមិនទាន់ដល់នូវកិរិយាអស់ទៅដដែល ធម៌ដ៏ក្សេមចាកយោគៈ គឺអរហត្តជាធម៌ប្រសើរបំផុត ដែលមិនទាន់ដល់ ក៏នៅតែមិនទាន់ដល់ដដែល គ្រឿងបរិក្ខារនៃជីវិតទាំងឡាយ គឺចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ចយភេសជ្ជបរិក្ខារឯណានេះ ដែលបព្វជិតគប្បីប្រមូលមក គ្រឿងបរិក្ខារនៃជីវិត

អប្បកសិរេន សមុទាគច្ឆន្តិ ន ខោ បនាហំ ចីវរហេតុ អគារស្មា អនគារិយំ បព្វជិតោ ន បិណ្ឌបាតហេតុ ន សេនាសនហេតុ ន គិលានប្បច្ចយភេសជ្ជបរិក្ខារហេតុ អគារស្មា អនគារិយំ បព្វជិតោ អថ ច បន មេ ឥមំ វនបត្ថំ ឧបនិស្សាយ វិហរតោ អនុបដ្ឋិតា ចេវ សតិ ន ឧបដ្ឋាតិ អសមាហិតញ្ច ចិត្តំ ន សមាធិយតិ អបរិក្ខីណា ច អាសវា ន បរិក្ខយំ គច្ឆន្តិ អននុប្បត្តញ្ច អនុត្តរំ យោគក្ខេមំ នានុបាបុណាមីតិ ។ តេន ភិក្ខវេ ភិក្ខុនា សង្ខាបិ តម្ហា វនបត្ថា បក្កមិតព្វំ ន វត្ថព្វំ ។

(២៣៧) ឥធ ភិក្ខវេ ភិក្ខុ អញ្ញតរំ វនបត្ថំ ឧបនិស្សាយ វិហរតិ តស្ស តំ វនបត្ថំ ឧបនិស្សាយ វិហរតោ អនុបដ្ឋិតា ចេវ សតិ ឧបដ្ឋាតិ អសមាហិតញ្ច ចិត្តំ សមាធិយតិ អបរិក្ខីណា ច អាសវា បរិក្ខយំ គច្ឆន្តិ អននុប្បត្តញ្ច អនុត្តរំ យោគក្ខេមំ អនុបាបុណាតិ



តាំងនោះ ក៏កើតឡើងដោយមិនលំបាក អាត្មាអញចេញចាកផ្ទះមកបួសនេះសោត ព្រោះហេតុតែចីវរក៏ទេ អាត្មាអញចេញចាកផ្ទះមកបួសព្រោះហេតុតែបិណ្ឌបាតក៏ទេដែរ ព្រោះហេតុតែសេនាសនៈក៏ទេដែរ ព្រោះហេតុតែគិលានប្បច្ច័យភេសជ្ជបរិក្ខារក៏ទេដែរ តាំងពីដូចអាត្មាអញចូលទៅអាស្រ័យនូវដងព្រៃនេះ សតិដែលមិនបានតាំងមាំ ក៏នៅតែមិនបានតាំងមាំដដែល ចិត្តដែលមិនខ្ជាប់ខ្ជួន ក៏នៅតែមិនខ្ជាប់ខ្ជួនដដែល អាសវៈដែលមិនទាន់អស់ទៅ ក៏នៅតែមិនទាន់ដល់នូវកិរិយាអស់ទៅដដែល ធម៌ដ៏ក្សេមចាកយោគៈ គឺអរហត្តជាធម៌ប្រសើរបំផុតដែលអាត្មាអញមិនទាន់បានដល់ ក៏នៅតែមិនទាន់បានដល់ដដែល ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះបើដឹង ( នូវកិរិយាមិនដល់នូវសមណធម៌យ៉ាងនេះហើយ ) ត្រូវចេញចាកដងព្រៃនោះ មិនត្រូវនៅ ( ក្នុងដងព្រៃនោះឡើយ ) ។

(២៣៧) ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចូលទៅអាស្រ័យនូវដងព្រៃណាមួយ កាលភិក្ខុនោះចូលទៅអាស្រ័យនូវដងព្រៃនោះ សតិដែលមិនបានតាំងមាំ ក៏បានតាំងមាំឡើងផង ចិត្តដែលមិនខ្ជាប់ខ្ជួន ក៏បានខ្ជាប់ខ្ជួនឡើងផង អាសវៈទាំងឡាយដែលមិនទាន់អស់ទៅ ក៏បានដល់នូវកិរិយាអស់ទៅផង ធម៌ដ៏ក្សេមចាកយោគៈ គឺអរហត្ត ជាធម៌ប្រសើរបំផុតដែលមិនទាន់ដល់ ក៏បានដល់តាមលំដាប់

យេ ច ខោ ឥមេ បព្វជិតេន ជីវិតបរិក្ខារា សមុទានេតព្វា ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារា តេ កសិរេន សមុទាគច្ឆន្តិ តេន ភិក្ខវេ ភិក្ខុនា ឥតិ បដិសញ្ចិក្ខិតព្វំ អហំ ខោ ឥមំ វនបត្ថំ ឧបនិស្សាយ វិហរាមិ តស្ស មេ ឥមំ វនបត្ថំ ឧបនិស្សាយ វិហរតោ អនុបដ្ឋិតា ចេវ សតិ ឧបដ្ឋាតិ អសមាហិតញ្ច ចិត្តំ សមាធិយតិ អបរិក្ខីណា ច អាសវា បរិក្ខយំ គច្ឆន្តិ អននុប្បត្តញ្ច អនុត្តរំ យោគក្ខេមំ អនុបាបុណាមិ ។ យេ ច ខោ ឥមេ បព្វជិតេន ជីវិតបរិក្ខារា សមុទានេតព្វា ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារា តេ កសិរេន សមុទាគច្ឆន្តិ ។ ន ខោ បនាហំ ចីវរហេតុ អគារស្មា អនគារិយំ បព្វជិតោ ន បិណ្ឌបាតហេតុ ន សេនាសនហេតុ ន គិលានប្បច្ចយភេសជ្ជបរិក្ខារហេតុ អគារស្មា អនគារិយំ បព្វជិតោ អថ ច បន មេ ឥមំ វនបត្ថំ ឧបនិស្សាយ វិហរតោ អនុបដ្ឋិតា ចេវ សតិ



ផង គ្រឿងបម្រុងជីវិតទាំងឡាយ គឺចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ច័យភេសជ្ជបរិក្ខារឯណានេះ ដែលបព្វជិតគប្បីប្រមូលមក គ្រឿងបម្រុងជីវិតទាំងនោះ ក៏កើតឡើងដោយលំបាក ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះគប្បីពិចារណាដូច្នេះថា អាត្មាអញចូលមកអាស្រ័យនូវដងព្រៃនេះ កាលអាត្មាអញចូលមកអាស្រ័យនូវដងព្រៃនេះ សតិដែលមិនទាន់បានតាំងមាំ ក៏បានតាំងមាំឡើងផង ចិត្តដែលមិនទាន់បានខ្ជាប់ខ្ជួន ក៏ខ្ជាប់ខ្ជួនឡើងផង អាសវៈទាំងឡាយដែលមិនទាន់អស់ទៅ ក៏ដល់នូវកិរិយាអស់ទៅផង ធម៌ដ៏ក្សេមចាកយោគៈ គឺអរហត្តជាធម៌ប្រសើរបំផុតដែលមិនទាន់ដល់ អាត្មាអញក៏បានដល់ ដោយលំដាប់ផង ។ គ្រឿងបម្រុងជីវិតទាំងឡាយ គឺចីវរ បិណ្ឌបាត សេនាសនៈនិងគិលានប្បច្ច័យភេសជ្ជបរិក្ខារឯណានេះ ដែលបព្វជិតគប្បីប្រមូលមក គ្រឿងបម្រុងជីវិតទាំងនោះ ក៏កើតឡើងដោយលំបាក ។ អាត្មាអញចេញចាកផ្ទះមកបួសនេះសោត ព្រោះហេតុតែចីវរក៏ទេ អាត្មាអញចេញចាកផ្ទះមកបួស ព្រោះហេតុតែបិណ្ឌបាតក៏ទេដែរ ព្រោះហេតុតែសេនាសនៈក៏ទេដែរ ព្រោះហេតុតែគិលានប្បច្ច័យភេសជ្ជបរិក្ខារក៏ទេដែរ តាំងពីដូចអាត្មាអញចូលមកអាស្រ័យនូវដងព្រៃនេះ សតិដែលមិនទាន់បានតាំងមាំ

ឧបដ្ឋាតិ អសមាហិតញ្ច ចិត្តំ សមាធិយតិ អបរិក្ខីណា ច អាសវា បរិក្ខយំ គច្ឆន្តិ អននុប្បត្តញ្ច អនុត្តរំ យោគក្ខេមំ អនុបាបុណាតិ ។ តេន ភិក្ខវេ ភិក្ខុនា សង្ខាបិ តស្មឹ វនបត្ថេ វត្ថព្វំ ន បក្កមិតព្វំ ។

(២៣៨) ឥធ បន ភិក្ខវេ ភិក្ខុ អញ្ញតរំ វនបត្ថំ ឧបនិស្សាយ វិហរតិ តស្ស តំ វនបត្ថំ ឧបនិស្សាយ វិហរតោ អនុបដ្ឋិតា ចេវ សតិ ឧបដ្ឋាតិ អសមាហិតញ្ច ចិត្តំ សមាធិយតិ អបរិក្ខីណា ច អាសវា បរិក្ខយំ គច្ឆន្តិ អននុប្បត្តញ្ច អនុត្តរំ យោគក្ខេមំ អនុបាបុណាតិ យេ ច ខោ ឥមេ បព្វជិតេន ជីវិតបរិក្ខារា សមុទានេតព្វា ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារា តេ អប្បកសិរេន សមុទាគច្ឆន្តិ ។ តេន ភិក្ខវេ ភិក្ខុនា ឥតិ បដិសញ្ចិក្ខិតព្វំ អហំ ខោ ឥមំ វនបត្ថំ ឧបនិស្សាយ វិហរាមិ តស្ស មេ ឥមំ វនបត្ថំ ឧបនិស្សាយ វិហរតោ អនុបដ្ឋិតា ចេវ សតិ



ក៏បានតាំងមាំឡើងផង ចិត្តដែលមិនទាន់ខ្ជាប់ខ្ជួន ក៏បានខ្ជាប់ខ្ជួនឡើងផង អាសវៈទាំងឡាយដែលមិនទាន់អស់ទៅ ក៏ដល់នូវកិរិយាអស់ទៅផង ធម៌ដ៏ក្សេមចាកយោគៈ គឺអរហត្ត ជាធម៌ប្រសើរបំផុត ដែលមិនទាន់ដល់ អាត្មាអញក៏បានដល់ដោយលំដាប់ផង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះ បើពិចារណាឃើញ (យ៉ាងនេះ) ហើយ គប្បីនៅក្នុងដងព្រៃនោះ មិនត្រូវចៀសចេញទេ ។

(២៣៨) ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចូលទៅអាស្រ័យនូវដងព្រៃណាមួយ កាលភិក្ខុនោះ ចូលទៅអាស្រ័យនូវដងព្រៃនោះ សតិដែលមិនបានតាំងមាំ ក៏បានតាំងមាំឡើងផង ចិត្តដែលមិនខ្ជាប់ខ្ជួន ក៏ខ្ជាប់ខ្ជួនឡើងផង អាសវៈទាំងឡាយដែលមិនទាន់អស់ទៅ ក៏ដល់នូវកិរិយាអស់ទៅផង ធម៌ដ៏ក្សេមចាកយោគៈគឺអរហត្តជាធម៌ប្រសើរបំផុត ដែលមិនទាន់ដល់ ក៏បានដល់តាមលំដាប់ផង គ្រឿងបម្រុងជីវិតទាំងឡាយ គឺចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ចយភេសជ្ជបរិក្ខារណានេះ ដែលបព្វជិត គប្បីប្រមូលមក គ្រឿងបម្រុងជីវិតទាំងនោះ ក៏កើតឡើងដោយមិនលំបាក ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះ គប្បីពិចារណាដូច្នេះថា អាត្មាអញចូលមកអាស្រ័យនូវដងព្រៃនេះ កាលអាត្មាអញចូលមកអាស្រ័យនូវដងព្រៃនេះ សតិដែលមិនបានតាំងមាំ

ឧបដ្ឋាតិ អសមាហិតញ្ច ចិត្តំ សមាធិយតិ អបរិក្ខីណា ច អាសវា បរិក្ខយំ គច្ឆន្តិ អននុប្បត្តញ្ច អនុត្តរំ យោគក្ខេមំ អនុបាបុណាតិ យេ ច ខោ ឥមេ បព្វជិតេន ជីវិតបរិក្ខារា សមុទានេតព្វា ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារា តេ អប្បកសិរេន សមុទាគច្ឆន្តិ ។ តេន ភិក្ខវេ ភិក្ខុនា យាវជីវម្បិ តស្មិំ វនបត្ថេ វត្ថព្វំ ន បក្កមិតព្វំ ។

(២៣៩) ឥធ ភិក្ខវេ ភិក្ខុ អញ្ញតរំ គាមំ ឧបនិស្សាយ វិហរតិ ។បេ។ អញ្ញតរំ និគមំ ឧបនិស្សាយ វិហរតិ ។បេ។ អញ្ញតរំ នគរំ ឧបនិស្សាយ វិហរតិ ។បេ។ អញ្ញតរំ ជនបទំ ឧបនិស្សាយ វិហរតិ ។បេ។ អញ្ញតរំ បុគ្គលំ ឧបនិស្សាយ វិហរតិ តស្ស តំ បុគ្គលំ ឧបនិស្សាយ វិហរតោ អនុបដ្ឋិតា ចេវ សតិ ន ឧបដ្ឋាតិ អសមាហិតញ្ច ចិត្តំ ន សមាធិយតិ អបរិក្ខីណា ច អាសវា ន បរិក្ខយំ គច្ឆន្តិ អននុប្បត្តញ្ច អនុត្តរំ យោគក្ខេមំ នានុបាបុណាតិ



ក៏បានតាំងមាំឡើងផង ចិត្តដែលមិនខ្ជាប់ខ្ជួន ក៏ខ្ជាប់ខ្ជួនឡើងផង អាសវៈទាំងឡាយ ដែលមិនទាន់អស់ទៅ ក៏ដល់នូវកិរិយាអស់ទៅផង ធម៌ជាគ្រឿងក្សេមចាកយោគៈ គឺអរហត្ត ជាធម៌ប្រសើរបំផុត ដែលមិនទាន់បានដល់ ក៏បានដល់តាមលំដាប់ផង គ្រឿងបរិក្ខារជីវិតទាំងឡាយ គឺចីវរ បិណ្ឌបាត សេនាសនៈនិងគិលានប្បច្ច័យភេសជ្ជបរិក្ខារណានេះ ដែលបព្វជិត គប្បីប្រមូលមក គ្រឿងបរិក្ខារជីវិតទាំងនោះ ក៏កើតឡើងដោយមិនលំបាក ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះគប្បីនៅក្នុងដងព្រៃនោះ ដរាបដល់អស់ជីវិត មិនត្រូវចៀសចេញទេ ។

(២៣៩) ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចូលទៅអាស្រ័យនូវស្រុកណាមួយ ។បេ។ ចូលទៅអាស្រ័យនូវនិគមណាមួយ ។បេ។ ចូលទៅអាស្រ័យនូវក្រុងណាមួយ ។បេ។ ចូលទៅអាស្រ័យនូវជនបទណាមួយ ។បេ។ ចូលទៅអាស្រ័យនូវបុគ្គលណាមួយ កាលភិក្ខុនោះ ចូលទៅអាស្រ័យនូវបុគ្គលនោះ សតិដែលមិនបានតាំងមាំ ក៏នៅតែមិនបានតាំងមាំដដែល ចិត្តដែលមិនខ្ជាប់ខ្ជួន ក៏នៅតែមិនខ្ជាប់ខ្ជួនដដែល អាសវៈទាំងឡាយដែលមិនទាន់អស់ទៅ ក៏នៅតែមិនដល់នូវកិរិយាអស់ទៅដដែល ធម៌ជាគ្រឿងក្សេមចាកយោគៈ គឺអរហត្តជាធម៌ប្រសើរបំផុត ដែលមិនទាន់ដល់ ក៏នៅតែមិនដល់ដដែល

យេ ច មេ បព្វជិតេន ជីវិតបរិក្ខារា សមុទានេតព្វា ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារា តេ កសិរេន សមុទាគច្ឆន្តិ ។ តេន ភិក្ខវេ ភិក្ខុនា ឥតិ បដិសញ្ចិក្ខិតព្វំ អហំ ខោ ឥមំ បុគ្គលំ ឧបនិស្សាយ វិហរាមិ តស្ស មេ ឥមំ បុគ្គលំ ឧបនិស្សាយ វិហរតោ អនុបដ្ឋិតា ចេវ សតិ ន ឧបដ្ឋាតិ អសមាហិតញ្ច ចិត្តំ ន សមាធិយតិ អបរិក្ខីណា ច អាសវា ន បរិក្ខយំ គច្ឆន្តិ អននុប្បត្តញ្ច អនុត្តរំ យោគក្ខេមំ នានុបាបុណាមិ យេ ច មេ បព្វជិតេន ជីវិតបរិក្ខារា សមុទានេតព្វា ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារា តេ កសិរេន សមុទាគច្ឆន្តិ ។ តេន ភិក្ខវេ ភិក្ខុនា រត្តិភាគំ វា ទិវសភាគំ វា សោ បុគ្គលោ អនាបុច្ឆា បក្កមិតព្វំ នានុពន្ធិតព្វោ ។

[២៦០] ឥធ ភិក្ខវេ ភិក្ខុ អញ្ញតរំ បុគ្គលំ ឧបនិស្សាយ វិហរតិ តស្ស តំ បុគ្គលំ ឧបនិស្សាយ វិហរតោ អនុបដ្ឋិតា ចេវ សតិ ន ឧបដ្ឋាតិ



គ្រឿងបរិក្ខារជីវិតទាំងឡាយ គឺចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ច័យភេសជ្ជបរិក្ខារណានេះ ដែលបព្វជិតគប្បីប្រមូលមក គ្រឿងបរិក្ខារជីវិតទាំងនោះ ក៏កើតឡើងដោយលំបាក ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះ គប្បីពិចារណាដូច្នេះថា អាត្មាអញចូលមកអាស្រ័យនូវបុគ្គលនេះ កាលអាត្មាអញចូលមកអាស្រ័យនូវបុគ្គលនេះ សតិដែលមិនបានតាំងមាំ ក៏នៅតែមិនបានតាំងមាំដដែល ចិត្តដែលមិនខ្ជាប់ខ្ជួន ក៏នៅតែមិនខ្ជាប់ខ្ជួនដដែល អាសវៈទាំងឡាយដែលមិនទាន់អស់ទៅ ក៏នៅតែមិនដល់នូវកិរិយាអស់ទៅដដែល ធម៌ដ៏ក្សេមចាកយោគៈ គឺអរហត្តជាធម៌ប្រសើរបំផុតដែលមិនទាន់ដល់ អាត្មាអញក៏នៅតែមិនដល់ដដែល គ្រឿងបរិក្ខារជីវិតទាំងឡាយ គឺចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ច័យភេសជ្ជបរិក្ខារណានេះ ដែលបព្វជិតគប្បីប្រមូលមក គ្រឿងបរិក្ខារជីវិតទាំងនោះ ក៏កើតឡើងដោយលំបាក ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះមិនបាច់លាបុគ្គលនោះទេ គប្បីចៀសចេញទៅក្នុងចំណែកនៃរាត្រី ឬក្នុងចំណែកនៃថ្ងៃ មិនគប្បីដើរតាម (បុគ្គលនោះ) ឡើយ ។

[២៦០] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចូលទៅអាស្រ័យនូវបុគ្គលណាមួយ កាលភិក្ខុនោះ ចូលទៅអាស្រ័យនូវបុគ្គលនោះ សតិដែលមិនបានតាំងមាំ ក៏នៅតែមិនបានតាំងមាំដដែល

អសមាហិតញ្ច ចិត្តំ ន សមាធិយតិ អបរិក្ខីណា ច អាសវា ន បរិក្ខយំ គច្ឆន្តិ អននុប្បត្តញ្ច អនុត្តរំ យោគក្ខេមំ នានុបាបុណាតិ យេ ច ខោ ឥមេ បព្វជិតេន ជីវិតបរិក្ខារា សមុទានេតព្វា ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារា តេ អប្បកសិរេន សមុទាគច្ឆន្តិ ។ តេន ភិក្ខវេ ភិក្ខុនា ឥតិ បដិសញ្ចិក្ខិតព្វំ អហំ ខោ ឥមំ បុគ្គលំ ឧបនិស្សាយ វិហរាមិ តស្ស មេ ឥមំ បុគ្គលំ ឧបនិស្សាយ វិហរតោ អនុបដ្ឋិតា ចេវ សតិ ន ឧបដ្ឋាតិ អសមាហិតញ្ច ចិត្តំ ន សមាធិយតិ អបរិក្ខីណា ច អាសវា ន បរិក្ខយំ គច្ឆន្តិ អននុប្បត្តញ្ច អនុត្តរំ យោគក្ខេមំ នានុបាបុណាមិ យេ ច ខោ ឥមេ បព្វជិតេន ជីវិតបរិក្ខារា សមុទានេតព្វា ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារា តេ អប្បកសិរេន សមុទាគច្ឆន្តិ ន ខោ បនាហំ ចីវរហេតុ អគារស្មា អនគារិយំ បព្វជិតោ



ចិត្តដែលមិនខ្ជាប់ខ្ជួន ក៏នៅតែមិនខ្ជាប់ខ្ជួនដដែល អាសវៈទាំងឡាយដែលមិនទាន់អស់ទៅ ក៏នៅតែមិនដល់នូវកិរិយាអស់ទៅដដែល ធម៌ដ៏ក្សេមចាកយោគៈ គឺអរហត្តជាធម៌ប្រសើរបំផុតដែលមិនទាន់ដល់ ក៏នៅតែមិនទាន់ដល់តាមលំដាប់ គ្រឿងបរិក្ខារជីវិតទាំងឡាយគឺចីវរបិណ្ឌបាតសេនាសនៈនិងគិលានប្បច្ចយភេសជ្ជបរិក្ខារណាខ្លះ ដែលបព្វជិត គប្បីប្រមូលមក គ្រឿងបរិក្ខារជីវិតទាំងនោះក៏កើតឡើងដោយមិនលំបាក ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះគប្បីពិចារណាដូច្នេះថា អាត្មាអញចូលមកអាស្រ័យនូវបុគ្គលនេះ កាលអាត្មាអញចូលមកអាស្រ័យបុគ្គលនេះ សតិដែលមិនបានតាំងមាំ ក៏នៅតែមិនបានតាំងមាំដដែល ចិត្តដែលមិនខ្ជាប់ខ្ជួន ក៏នៅតែមិនខ្ជាប់ខ្ជួនដដែល អាសវៈដែលមិនទាន់អស់ទៅ ក៏នៅតែមិនទាន់ដល់នូវកិរិយាអស់ទៅដដែល ធម៌ដ៏ក្សេមចាកយោគៈ គឺអរហត្ត ជាធម៌ប្រសើរបំផុតដែលមិនទាន់ដល់ អាត្មាអញក៏នៅតែមិនទាន់បានដល់តាមលំដាប់ គ្រឿងបរិក្ខារជីវិតទាំងឡាយ គឺចីវរបិណ្ឌបាតសេនាសនៈនិងគិលានប្បច្ចយភេសជ្ជបរិក្ខារណាខ្លះ ដែលបព្វជិត គប្បីប្រមូលមក គ្រឿងបរិក្ខារជីវិតទាំងនោះ ក៏កើតឡើងដោយមិនលំបាក អាត្មាអញចេញចាកផ្ទះមកបួសនេះសោត ព្រោះហេតុតែចីវរក៏ទេ អាត្មាអញចេញចាក

ន បិណ្ឌបាតហេតុ ន សេនាសនហេតុ ន គិលា-នប្បច្ចយភេសជ្ជបរិក្ខារហេតុ អគារស្មា អនគារិយំ បព្វជិតោ អថ ច បន មេ ឥមំ បុគ្គលំ ឧបនិស្សាយ វិហរតោ អនុបដ្ឋិតា ចេវ សតិ ន ឧបដ្ឋាតិ អស-មាហិតញ្ច ចិត្តំ ន សមាធិយតិ អបរិក្ខីណា ច អាសវា ន បរិក្ខយំ គច្ឆន្តិ អននុប្បត្តញ្ច អនុត្តរំ យោគក្ខេមំ នានុបាបុណាមីតិ ។ តេន ភិក្ខវេ ភិក្ខុនា សង្ខាបិ សោ បុគ្គលោ អនាបុច្ឆា បក្កមិតព្វោ នានុពន្ធិតព្វោ ។

(៦៤១) ឥធ ភិក្ខវេ ភិក្ខុ អញ្ញតរំ បុគ្គលំ ឧបនិស្សាយ វិហរតិ តស្ស តំ បុគ្គលំ ឧបនិស្សា-យ វិហរតោ អនុបដ្ឋិតា ចេវ សតិ ឧបដ្ឋាតិ អស-មាហិតញ្ច ចិត្តំ សមាធិយតិ អបរិក្ខីណា ច អាសវា បរិក្ខយំ គច្ឆន្តិ អននុប្បត្តញ្ច អនុត្តរំ យោគក្ខេមំ អនុបា-បុណាតិ យេ ច ខោ ឥមេ បព្វជិតេន ជីវិតបរិក្ខារា ស-មុទានេតព្វា ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយ-



ផ្នួសមកបួស ព្រោះហេតុតែបិណ្ឌបាតក៏ទេដែរ ព្រោះហេតុតែសេនាសនៈក៏ទេដែរ ព្រោះហេតុតែគិលានប្បច្ចយភេសជ្ជបរិក្ខារក៏ទេដែរ តាំងពីដូចអាត្មាអញ ចូលមកអាស្រ័យនូវបុគ្គលនេះ សតិដែលមិនបានតាំងមាំក៏នៅតែមិនបានតាំងមាំដដែល ចិត្តដែលមិនខ្ជាប់ខ្ជួន ក៏នៅតែមិនខ្ជាប់ខ្ជួនដដែល អាសវៈទាំងឡាយដែលមិនទាន់អស់ទៅ ក៏នៅតែមិនដល់នូវកិរិយាអស់ទៅដដែល ធម៌ដ៏ក្សេមចាកយោគៈគឺអរហត្តជាធម៌ប្រសើរបំផុតដែលមិនទាន់បានដល់ អាត្មាអញក៏នៅតែមិនទាន់បានដល់តាមលំដាប់ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះពិចារណាឃើញ (យ៉ាងនេះ) ហើយមិនបាច់លាបុគ្គលនោះទេ គប្បីចៀសចេញទៅ មិនត្រូវដើរតាមទេ ។

(៦៤១) ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចូលទៅអាស្រ័យនូវបុគ្គលណាមួយ កាលភិក្ខុនោះចូលទៅអាស្រ័យនូវបុគ្គលនោះ សតិដែលមិនបានតាំងមាំ ក៏បានតាំងមាំឡើងផង ចិត្តដែលមិនបានខ្ជាប់ខ្ជួន ក៏បានខ្ជាប់ខ្ជួនឡើងផង អាសវៈទាំងឡាយដែលមិនទាន់អស់ទៅ ក៏ដល់នូវកិរិយាអស់ទៅផង ធម៌ដ៏ក្សេមចាកយោគៈគឺអរហត្តជាធម៌ប្រសើរបំផុត ដែលមិនទាន់បានដល់ ក៏បានដល់តាមលំដាប់ផង គ្រឿងបម្រុងជីវិតទាំងឡាយ គឺចីវរ បិណ្ឌបាត សេនាសនៈនិងគិលានប្បច្ច័យ-

ភេសជ្ជបរិក្ខារា តេ កសិរេន សមុទាគច្ឆន្តិ ។ តេន ភិក្ខវេ ភិក្ខុនា ឥតិ បដិសញ្ចិក្ខិតព្វំ អហំ ខោ ឥមំ បុគ្គលំ ឧបនិស្សាយ វិហរាមិ តស្ស មេ ឥមំ បុគ្គលំ ឧបនិស្សាយ វិហរតោ អនុបដ្ឋិតា ចេវ សតិ ឧបដ្ឋាតិ អសមាហិតញ្ច ចិត្តំ សមាធិយតិ អបរិក្ខីណា ច អាសវា បរិក្ខយំ គច្ឆន្តិ អននុប្បត្តញ្ច អនុត្តរំ យោគ-ក្ខេមំ អនុបាបុណាមិ យេ ច ខោ ឥមេ បព្វជិតេន ជីវិតបរិក្ខារា សមុទានេតព្វា ចីវរបិណ្ឌបាតសេនាស-នគិលានប្បច្ចយភេសជ្ជបរិក្ខារា តេ កសិរេន សមុទា-គច្ឆន្តិ ន ខោ បនាហំ ចីវរហេតុ អគារស្មា អនគារិយំ បព្វជិតោ ន បិណ្ឌបាតហេតុ ន សេនាសនហេតុ ន គិលានប្បច្ចយភេសជ្ជបរិក្ខារហេតុ អគារស្មា អនគារិ-យំ បព្វជិតោ អថ ច បន មេ ឥមំ បុគ្គលំ ឧបនិស្សាយ វិហរតោ អនុបដ្ឋិតា ចេវ សតិ ឧបដ្ឋាតិ អសមាហិ-តញ្ច ចិត្តំ សមាធិយតិ អបរិក្ខីណា ច អាសវា



ភេសជ្ជបរិក្ខារណានេះ ដែលបព្វជិត គប្បីប្រមូលមក គ្រឿងបម្រុងជីវិតទាំងនោះក៏កើតឡើងដោយលំបាក ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះ គប្បីពិចារណាដូច្នេះថា អាត្មាអញចូលមកអាស្រ័យនូវបុគ្គលនេះ កាលអាត្មាអញចូលមកអាស្រ័យនូវបុគ្គលនេះ សតិដែលមិនបានតាំងមាំ ក៏បានតាំងមាំឡើងផង ចិត្តដែលមិនខ្ជាប់ខ្ជួន ក៏បានខ្ជាប់ខ្ជួនឡើងផង អាសវៈទាំងឡាយដែលមិនទាន់អស់ទៅ ក៏ដល់នូវកិរិយាអស់ទៅផង ធម៌ដ៏ក្សេមចាកយោគៈ គឺអរហត្ត ជាធម៌ប្រសើរបំផុត ដែលមិនទាន់បានដល់ អាត្មាអញក៏បានដល់តាមលំដាប់ផង គ្រឿងបម្រុងជីវិតទាំងឡាយ គឺចីវរ បិណ្ឌបាត សេនាសនៈនិងគិលានប្បច្ច័យភេសជ្ជបរិក្ខារណានេះ ដែលបព្វជិតគប្បីប្រមូលមក គ្រឿងបម្រុងជីវិតទាំងនោះ ក៏កើតឡើងដោយលំបាក អាត្មាអញចេញចាកផ្ទះមកបួសនេះសោត ព្រោះហេតុតែចីវរក៏ទេ អាត្មាអញចេញចាកផ្ទះមកបួស ព្រោះហេតុតែបិណ្ឌបាតក៏ទេដែរ ព្រោះហេតុតែសេនាសនៈក៏ទេដែរ ព្រោះហេតុតែគិលានប្បច្ច័យភេសជ្ជបរិក្ខារក៏ទេដែរ តាំងពីដូចអាត្មាអញ ចូលមកអាស្រ័យនូវបុគ្គលនេះ សតិដែលមិនបានតាំងមាំ ក៏បានតាំងមាំឡើងផង ចិត្តដែលមិនបានខ្ជាប់ខ្ជួន ក៏បានខ្ជាប់ខ្ជួនឡើងផង អាសវៈទាំងឡាយដែលមិនទាន់អស់ទៅ

បរិក្ខយំ គច្ឆន្តិ អននុប្បត្តញ្ច អនុត្តរំ យោគក្ខេមំ អនុបាបុណាមីតិ ។ តេន ភិក្ខវេ ភិក្ខុនា សង្ខាបិ សោ បុគ្គលោ អនុពន្ធិតព្វោ ន បច្ចក្ខាតព្វំ ។

(២៦២) ឥធ បន ភិក្ខវេ ភិក្ខុ អញ្ញតរំ បុគ្គលំ ឧបនិស្សាយ វិហរតិ តស្ស តំ បុគ្គលំ ឧបនិស្សាយ វិហរតោ អនុបដ្ឋិតា ចេវ សតិ ឧបដ្ឋាតិ អសមាហិតញ្ច ចិត្តំ សមាធិយតិ អបរិក្ខីណា ច អាសវា បរិក្ខយំ គច្ឆន្តិ អននុប្បត្តញ្ច អនុត្តរំ យោគក្ខេមំ អនុបាបុណាតិ យេ ច ខោ ឥមេ បព្វជិតេន ជីវិតបរិក្ខារា សមុទានេតព្វា ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារា តេ អប្បកសិរេន សមុទាគច្ឆន្តិ ។ តេន ភិក្ខវេ ភិក្ខុនា ឥតិ បដិសញ្ចិក្ខិតព្វំ អហំ ខោ ឥមំ បុគ្គលំ ឧបនិស្សាយ វិហរាមិ តស្ស មេ ឥមំ បុគ្គលំ ឧបនិស្សាយ វិហរតោ អនុបដ្ឋិតា ចេវ សតិ ឧបដ្ឋាតិ អសមាហិតញ្ច ចិត្តំ សមាធិយតិ អបរិក្ខីណា ច អាសវា បរិក្ខយំ គច្ឆន្តិ



ក៏ដល់នូវកិរិយាអស់ទៅផង ធម៌ដ៏ក្សេមចាកយោគៈគឺអរហត្តដ៏ប្រសើរបំផុត ដែលមិនទាន់បានដល់ អាត្មាអញក៏បានដល់តាមលំដាប់ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះបើពិចារណាឃើញ ( យ៉ាងនេះ ) ហើយ ត្រូវដើរតាមបុគ្គលនោះ មិនត្រូវចៀសចេញទេ ។

(២៦២) ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចូលទៅអាស្រ័យនូវបុគ្គលណាមួយ កាលភិក្ខុនោះចូលទៅអាស្រ័យនូវបុគ្គលនោះ សតិដែលមិនបានតាំងមាំ ក៏បានតាំងមាំឡើងផង ចិត្តដែលមិនខ្ជាប់ខ្ជួន ក៏បានខ្ជាប់ខ្ជួនឡើងផង អាសវៈទាំងឡាយដែលមិនទាន់អស់ទៅ ក៏ដល់នូវកិរិយាអស់ទៅផង ធម៌ដ៏ក្សេមចាកយោគៈគឺអរហត្តជាធម៌ប្រសើរបំផុត ដែលមិនទាន់បានដល់ ក៏បានដល់តាមលំដាប់ផង គ្រឿងបម្រុងជីវិតទាំងឡាយ គឺចីវរ បិណ្ឌបាត សេនាសនៈនិងគិលានប្បច្ចយភេសជ្ជបរិក្ខារ ណានេះ ដែលបព្វជិតគប្បីប្រមូលមក គ្រឿងបម្រុងជីវិតទាំងនោះ ក៏កើតឡើងដោយមិនលំបាក ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះគប្បីពិចារណាដូច្នេះថា អាត្មាអញចូលមកអាស្រ័យនូវបុគ្គលនេះ កាលអាត្មាអញចូលមកអាស្រ័យនូវបុគ្គលនេះ សតិដែលមិនបានតាំងមាំ ក៏បានតាំងមាំឡើងផង ចិត្តដែលមិនបានខ្ជាប់ខ្ជួន ក៏បានខ្ជាប់ខ្ជួនឡើងផង អាសវៈទាំងឡាយ ដែលមិនទាន់អស់ទៅ ក៏ដល់នូវកិរិយាអស់ទៅផង

អននុប្បត្តញ្ច អនុត្តរំ យោគក្ខេមំ អនុបាបុណាតិ យេ ច ខោ ឥមេ បព្វជិតេន ជីវិតបរិក្ខារា សមុទានេតព្វា ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារា តេ អប្បកសិរេន សមុទាគច្ឆន្តិ ។ តេន ភិក្ខវេ ភិក្ខុនា យាវជីវម្បិ សោ បុគ្គលោ អនុពន្ធិតព្វោ ន បក្កមិតព្វំ អបិ សមុជ្ជមានេនបិ[1] ។ ឥទមវោច ភគវា ។ អត្តមនា តេ ភិក្ខូ ភគវតោ ភាសិតំ អភិនន្ទុន្តិ ។

វនបត្ថសុត្តំ សត្តមំ និដ្ឋិតំ ។

---

១ ម. បនុជ្ជមានេនបីតិ ឥតិ ទិស្សតិ ។



ធម៌ដ៏ក្សេមចាកយោគៈ គឺអរហត្ត ជាធម៌ប្រសើរបំផុត ដែលមិនទាន់បានដល់តាត្មាអញក៏បានដល់តាមលំដាប់ផង គ្រឿងបរិក្ខារជីវិតទាំងឡាយ គឺចីវរ បិណ្ឌបាត សេនាសនៈនិងគិលានប្បច្ច័យភេសជ្ជបរិក្ខារណានេះ ដែលបព្វជិត គប្បីប្រមូលមក គ្រឿងបរិក្ខារជីវិតទាំងនោះ ក៏កើតឡើងដោយមិនលំបាក ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះទោះបីបុគ្គលនោះបណ្តេញចេញក៏ដោយ ត្រូវតែដើរតាម មិនត្រូវចៀសចេញចាកបុគ្គលនោះដរាបដល់អស់ជីវិត ។ លុះព្រះមានព្រះភាគបានសំដែងនូវវនបត្ថសូត្រនេះចប់ហើយ ពួកភិក្ខុទាំងនោះ ក៏មានសេចក្តីពេញចិត្ត ត្រេកអរនឹងភាសិតរបស់ព្រះមានព្រះភាគ ។

ចប់ វនបត្ថសូត្រ ទី ៧ ។

## អដ្ឋមំ មធុបិណ្ឌិកសុត្តំ

(២៤៣) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សក្កេសុ វិហរតិ កបិលវត្ថុស្មឹ និគ្រោធារាមេ ។ អថខោ ភគវា បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ កបិលវត្ថុំ បិណ្ឌាយ បាវិសិ ។ កបិលវត្ថុស្មឹ បិណ្ឌាយ ចរិត្វា បច្ឆាភត្តំ បិណ្ឌបាតប្បដិក្កន្តោ យេន មហាវនំ តេនុបសង្កមិ ទិវាវិហារាយ មហាវនំ អជ្ឈោគាហេត្វា ពេលុវលដ្ឋិកាយ មូលេ ទិវាវិហារំ និសីទិ ។ ទណ្ឌបាណិបិ ខោ សក្កោ ជង្ឃាវិហារំ អនុចង្កមមានោ អនុវិចរមានោ យេន មហាវនំ តេនុបសង្កមិ មហាវនំ អជ្ឈោគាហេត្វា យេន ពេលុវលដ្ឋិកា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវតា សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ទណ្ឌមោលុព្ភ ឯកមន្តំ អដ្ឋាសិ ។

## មធុបិណ្ឌិកសូត្រ ទី ៨

(២៤៣) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគទ្រង់គង់ក្នុងនិគ្រោធារាម ទៀបក្រុងកបិលវត្ថុ ក្នុងដែនសក្កៈ ។ គ្រានោះឯង ព្រះមានព្រះភាគ ទ្រង់ស្បង់ប្រដាប់បាត្រនិងចីវរ ក្នុងបុព្វណ្ហសម័យ ហើយចូលទៅកាន់ក្រុងកបិលវត្ថុ ដើម្បីបិណ្ឌបាត ។ កាលព្រះមានព្រះភាគ ទ្រង់ត្រាច់ដើរទៅបិណ្ឌបាត ក្នុងក្រុងកបិលវត្ថុ លុះត្រឡប់មកអំពីបិណ្ឌបាត ក្នុងវេលាក្រោយភត្ត ទ្រង់ស្តេចសំដៅទៅកាន់ព្រៃមហាវ័ន លុះដល់ហើយ ក៏ស្តេចចូលទៅកាន់ព្រៃមហាវ័ន ដើម្បីសម្រាកក្នុងវេលាថ្ងៃ ទើបគង់នៅក្នុងវេលាថ្ងៃ ទៀបគល់ស្មៅសារ ។ មានសក្យៈ ១ រូបឈ្មោះទណ្ឌបាណិ[១] ដើរទៅដើរមកឲ្យស្រួលជើង ក៏ដើរសំដៅទៅព្រៃមហាវ័ន លុះទៅដល់ហើយក៏ចូលទៅកាន់ព្រៃមហាវ័ន ហើយសំដៅទៅរកព្រះមានព្រះភាគ ដែលគង់ទៀបគល់ស្មៅសារនោះ លុះចូលទៅដល់ហើយក៏ពោលពាក្យរាក់ទាក់សំណេះសំណាលជាមួយនឹងព្រះមានព្រះភាគ លុះបញ្ចប់ពាក្យគួររីករាយ និងពាក្យគួររឭកហើយក៏ច្រត់ចុះនូវដំបងឈើ (ស្ទប់ចង្កា) នៅក្នុងទីដ៏សមគួរ ។

---

១ សក្យៈនេះ ជាមនុស្សដ៏ទន់ប៉ិតនៅក្នុងបឋមវ័យនៅឡើយ ប៉ុន្តែវែងកាន់ដំបងមាសដើរ ព្រោះហេតុដែលមានដំបងដ៏វិចិត្រដូច្នោះ បានជាហៅថា ទណ្ឌបាណិ ជាបក្ខពួកនឹងទេវទត្ត ។ អដ្ឋកថា ។

ឯកមន្តំ ឋិតោ ខោ ទណ្ឌបាណិ សក្កោ ភគវន្តំ ឯតទវោច កឹវាទី សមណោ កិមក្ខាយីតិ ។ យថាវាទី ខោ អាវុសោ សទេវកេ លោកេ សមារកេ សព្រហ្មកេ សស្សមណព្រាហ្មណិយា បជាយ សទេវមនុស្សាយ ន កេនចិ លោកេ វិគ្គយ្ហ តិដ្ឋតិ យថា ច បន កាមេហិ វិសំយុត្តំ[១] វិហរន្តំ តំ ព្រាហ្មណំ អកថំកថឹ ឆិន្នកុក្កុច្ចំ ភវាភវេ វីតតណ្ហំ សញ្ញា នានុសេន្តិ ឯវំវាទី ខោ អហំ អាវុសោ ឯវមក្ខាយីតិ ។ ឯវំ វុត្តេ ទណ្ឌបាណិ សក្កោ សីសំ ឱកម្បេត្វា ជិវ្ហំ និល្លាលេត្វា តិវិសាខំ នលាដិកំ នលាដេ វុដ្ឋាបេត្វា ទណ្ឌមោលុព្ភ បក្កាមិ ។

(២៤៤) អថខោ ភគវា សាយណ្ហសមយំ បដិសល្លានា វុដ្ឋិតោ យេន និគ្រោធារាមោ តេនុបសង្កមិ ឧបសង្កមិត្វា បញ្ញត្តេ អាសនេ និសីទិ ។

១ ម. វិសញ្ញុត្តំ ។



លុះទណ្ឌបាណិសក្យៈឈរនៅក្នុងទីសមគួរហើយ ក៏ពោលពាក្យនេះនឹងព្រះមានព្រះភាគថា សមណៈជាអ្នកប្រកាន់នូវទិដ្ឋិដូចម្តេច តែងពោលនូវទិដ្ឋិដូចម្តេច ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលអាវុសោ ក្នុងលោក (នេះ) ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វព្រមទាំងសមណព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស មានបុគ្គលអ្នកប្រកាន់ទិដ្ឋិយ៉ាងណា ដែលមិនមានជម្លោះតស៊ូនឹងជាមួយបុគ្គលណាមួយក្នុងលោក មួយទៀត កិលេសសញ្ញាទាំងឡាយ មិនបានដេកតាមនូវខីណាស្រពព្រាហ្មណ៍នោះ ដែលជាអ្នកប្រាសចាកកាមទាំងឡាយ មិនមានសេចក្តីងឿងឆ្ងល់ ផ្តាច់បង់នូវសេចក្តីស្តាយក្រោយ និងការកើតវែងវើន ប្រាសចាកសេចក្តីប្រាថ្នា ក្នុងភពតូចនិងភពធំយ៉ាងណា ម្នាលអាវុសោ តថាគតប្រកាន់ទិដ្ឋិយ៉ាងនោះ ពោលទិដ្ឋិយ៉ាងនោះដែរ ។ កាលបើព្រះមានព្រះភាគទ្រង់ត្រាស់យ៉ាងនេះហើយ ទើបទណ្ឌបាណិសក្យៈងក់ក្បាល លៀនអណ្តាត ហើយដាក់ម្រាមដៃលើថ្ងាសដែលមានផ្នត់បី ក្រោកឡើងកាន់ឈើច្រត់ចៀសចេញទៅ ។

(២៤៤) លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ចេញអំពីទីសម្ងំ ក្នុងសាយណ្ហសម័យ ទ្រង់ពុទ្ធដំណើរ ទៅកាន់និគ្រោធារាម លុះចូលទៅដល់ហើយ ទ្រង់គង់លើអាសនៈ ដែលគេក្រាលទុក ។

និសជ្ជ ខោ ភគវា ភិក្ខូ អាមន្តេសិ ឥធាហំ ភិក្ខវេ បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ កបិលវត្ថុំ បិណ្ឌាយ បាវិសឹ កបិលវត្ថុស្មឹ បិណ្ឌាយ ចរិត្វា បច្ឆាភត្តំ បិណ្ឌបាតប្បដិក្កន្តោ យេន មហាវនំ តេនុបសង្កមឹ ទិវាវិហារាយ មហាវនំ អជ្ឈោគាហេត្វា ពេលុវលដ្ឋិកាយ មូលេ ទិវាវិហារំ និសីទឹ ។ ទណ្ឌបាណិបិ ខោ ភិក្ខវេ សក្កោ ជង្ឃាវិហារំ អនុចង្កមមានោ អនុវិចរមានោ យេន មហាវនំ តេនុបសង្កមិ មហាវនំ អជ្ឈោគាហេត្វា យេន ពេលុវលដ្ឋិកា យេនាហំ តេនុបសង្កមិ ឧបសង្កមិត្វា មយ(១) សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ទណ្ឌមោលុព្ភ ឯកមន្តំ អដ្ឋាសិ ។ ឯកមន្តំ ឋិតោ ខោ ភិក្ខវេ ទណ្ឌបាណិ សក្កោ មំ ឯតទវោច កឹវាទី សមណោ កិមក្ខាយីតិ ឯវំ វុត្តេ អហំ ភិក្ខវេ ទណ្ឌបាណឹ សក្កំ ឯតទវោចំ យថាវាទី ខោ អាវុសោ សទេវកេ លោកេ សមារកេ សព្រហ្មកេ សស្សមណព្រាហ្មណិយា បជាយ

---





លុះព្រះមានព្រះភាគ ទ្រង់គង់ហើយ ក៏ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ តថាគតស្លៀកស្បង់ប្រដាប់បាត្រនិងចីវរ ក្នុងវេលាបុព្វណ្ហសម័យនេះ ចូលទៅក្រុងកបិលវត្ថុ ដើម្បីបិណ្ឌបាត លុះត្រាច់ទៅបិណ្ឌបាតក្នុងក្រុងកបិលវត្ថុហើយ ត្រឡប់មកពីបិណ្ឌបាតវិញ ក្នុងវេលាបច្ឆាភត្តក៏សំដៅទៅព្រៃមហាវ័ន ចូលទៅកាន់ព្រៃមហាវ័នដើម្បីនៅសម្រាកក្នុងវេលាថ្ងៃ ក៏អង្គុយសម្រាកក្នុងវេលាថ្ងៃទៀបគល់នៃស្មៅសាវ ។ ម្នាលភិក្ខុទាំងឡាយ ទណ្ឌបាណិសក្យៈដើរទៅដើរមកឲ្យស្រួលជើង ក៏ដើរសំដៅមកព្រៃមហាវ័ន លុះចូលមកកាន់ព្រៃមហាវ័នហើយ ក៏បានចូលមករកតថាគតដែលអង្គុយទៀបដើមស្មៅសាវ លុះចូលមកដល់ហើយ ក៏ពោលពាក្យរាក់ទាក់សំណេះសំណាលមួយអន្លើដោយតថាគត លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររលឹកហើយ ក៏ច្រត់ចុះខ្លួនដំបង ឈរ (ស្ងប់ចង្កា) នៅក្នុងទីដ៏សមគួរ ។ ម្នាលភិក្ខុទាំងឡាយ លុះទណ្ឌបាណិសក្យៈឈរក្នុងទីដ៏សមគួរហើយ បានពោលពាក្យនេះនឹងតថាគតថា សមណៈប្រកាន់វាទៈដូចម្តេច ពោលវាទៈដូចម្តេច កាលបើទណ្ឌបាណិសក្យៈសួរយ៉ាងនេះហើយ ម្នាលភិក្ខុទាំងឡាយ តថាគតក៏ពោលពាក្យនេះនឹងទណ្ឌបាណិសក្យៈថា ម្នាលអាវុសោ ក្នុងលោក (នេះ) ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វព្រមទាំងសមណ.

សទេវមនុស្សាយ ន កេនចិ លោកេ វិគ្គយ្ហ តិដ្ឋតិ យថា ច បន កាមេហិ វិសំយុត្តំ វិហរន្តំ តំ ព្រាហ្មណំ អកថំកថឹ ឆិន្នកុក្កុច្ចំ ភវាភវេ វីតតណ្ហំ សញ្ញា នានុសេន្តិ ឯវំវាទី ខោ អហំ អាវុសោ ឯវមក្ខាយីតិ ។ ឯវំ វុត្តេ ភិក្ខវេ ទណ្ឌបាណិ សក្កោ សីសំ ឱកម្បេត្វា ជិវ្ហំ និល្លាឡេត្វា តិវិសាខំ នលាដិកំ នលាដេ វុដ្ឋាបេត្វា ទណ្ឌមោលុព្ភ បក្កាមីតិ ។

(២៤៨) ឯវំ វុត្តេ អញ្ញតរោ ភិក្ខុ ភគវន្តំ ឯតទវោច កិំវាទី បន ភន្តេ ភគវា សទេវកេ លោកេ សមារកេ សព្រហ្មកេ សស្សមណព្រាហ្មណិយា បជាយ សទេវមនុស្សាយ ន កេនចិ លោកេ វិគ្គយ្ហ តិដ្ឋតិ កថំ[1] បន ភន្តេ[2]

១ ឱ.ម. កថញ្ច ។ ២ ឱ.ម. ភន្តេ ភគវន្តំ ។



ព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស មានបុគ្គលប្រកាន់យ៉ាងណា ដែលមិនមានជម្លោះ ទាស់ទែងដោយបុគ្គលណាមួយក្នុងលោក មួយទៀត កិលេសសញ្ញាទាំងឡាយ មិនបានជាប់តាមនូវខីណាស្រពព្រាហ្មណ៍នោះ ដែលប្រាសចាកកាមទាំងឡាយ មិនមានសេចក្តីងឿងឆ្ងល់ ផ្តាច់បង់នូវសេចក្តីស្តាយក្រោយ និងការកើតដ៏ទៃ ប្រាសចាកសេចក្តីប្រាថ្នាក្នុងភពតូចនិងភពធំ យ៉ាងណា ម្នាលអាវុសោ តថាគតប្រកាន់វាទៈយ៉ាងនោះ ពោលវាទៈយ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ កាលបើតថាគតពោលយ៉ាងនេះហើយ ទណ្ឌបាណិសក្យៈក៏គ្រវីក្បាល លៀនអណ្តាត ហើយដាក់ម្រាមដៃលើថ្ងាសដែលមានផ្នត់បី ហើយក្រោកឡើងកាន់ដំបងចេញទៅ ។

(២៤៨) កាលបើព្រះមានព្រះភាគទ្រង់ត្រាស់យ៉ាងនេះហើយ មានភិក្ខុ ១ រូបក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ក្នុងលោក (នេះ) ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ទាំងមនុស្ស ជាសម្មតិទេព និងមនុស្សដ៏សេស ព្រះមានព្រះភាគប្រកាន់វាទៈដូចម្តេច ដែលមិនមានជម្លោះទាស់ទែងដោយបុគ្គលណាមួយក្នុងលោក បពិត្រព្រះអង្គដ៏ចំរើន

កាមេហិ វិសំយុត្តំ វិហរន្តំ តំ ព្រាហ្មណំ អកថំកថឹ
ឆិន្នកុក្កុច្ចំ ភវាភវេ វីតតណ្ហំ សញ្ញា នានុសេន្តីតិ ។
យតោនិទានំ ភិក្ខុ បុរិសំ បបញ្ចសញ្ញាសង្ខា សមុទា-
ចរន្តិ ឯត្ថ ចេ នត្ថិ អភិនន្ទិតព្វំ អភិវទិតព្វំ អជ្ឈោសិ-
តព្វំ ឯសេវន្តោ រាគានុសយានំ ឯសេវន្តោ បដិឃា-
នុសយានំ ឯសេវន្តោ ទិដ្ឋានុសយានំ ឯសេវន្តោ
វិចិកិច្ឆានុសយានំ ឯសេវន្តោ មានានុសយានំ ឯសេ-
វន្តោ ភវរាគានុសយានំ ឯសេវន្តោ អវិជ្ជានុសយានំ
ឯសេវន្តោ ទណ្ឌាទានសត្ថាទានកលហវិគ្គហវិវាទតុ-
វំតុវំបេសុញ្ញមុសាវាទានំ ឯត្ថេតេ បាបកា អកុសលា
ធម្មា អបរិសេសា និរុជ្ឈន្តីតិ ។ ឥទមវោច ភគវា ឥទំ
វត្វាន សុគតោ ឧដ្ឋាយាសនា វិហារំ បាវិសិ ។



កិលេសសញ្ញាទាំងឡាយ [illegible] ព្រាហ្មណ៍នោះ
ដែលប្រាសចាកកាមទាំងឡាយ មិនមានសេចក្តីងឿងឆ្ងល់ ផ្តាច់បង់នូវ
សេចក្តីស្តាយក្រោយនូវការកើតដដែល ប្រាសចាកសេចក្តីប្រាថ្នាក្នុង
ភពតូចនិងភពធំយ៉ាងណា ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាល
ភិក្ខុ ចំណែកនៃបបញ្ចសញ្ញា[1] រមែងប្រព្រឹត្តទៅតាមបុរស ព្រោះមាន
សភាវៈណាជាហេតុ សេចក្តីដែលបុគ្គលគប្បីត្រេកអរ គប្បីពោល គប្បី
ប្រកាន់ ( ជាអញជាយើង ) បើមិនមានក្នុងសភាវៈនុ៎ះទេ សេចក្តីមិន
ត្រេកអរជាដើមនុ៎ះឯង ហៅថា ទីបំផុតនៃរាគានុស័យ ហៅថា ទីបំផុតនៃ
បដិឃានុស័យ ហៅថា ទីបំផុតនៃទិដ្ឋានុស័យ ហៅថា ទីបំផុតនៃវិចិកិច្ឆា-
នុស័យ ហៅថា ទីបំផុតនៃមានានុស័យ ហៅថា ទីបំផុតនៃភវរាគានុស័យ
ហៅថាទីបំផុតនៃអវិជ្ជានុស័យ ហៅថាទីបំផុតនៃការកាន់ដំបង កាន់សស្ត្រា
ជម្លោះ ប្រកែក ទាស់ទែង ពោលពាក្យស៊កសៀតថាឯងថាមិន នឹង
ពាក្យមុសាវាទ អកុសលធម៌ទាំងឡាយដ៏លាមកនេះ រមែងរលត់ទៅវិញ
ដោយមិនសេសសល់ក្នុងសភាវៈ ១៤ នុ៎ះ ។ លុះព្រះសុគតទ្រង់ត្រាស់
ដូច្នេះហើយ ក៏ក្រោកចាកអាសនៈហើយទ្រង់ស្តេចចូលទៅកាន់វិហារ ។

---

១ អដ្ឋកថា ថា សញ្ញាដែលប្រកបដោយបបញ្ចធម៌ ៣ ប្រការគឺ តណ្ហា មានៈ ទិដ្ឋិ ។

(៤៤៦) អថខោ តេសំ ភិក្ខូនំ អចិរបក្កន្តស្ស ភគវតោ ឯតទហោសិ ឥទំ ខោ នោ អាវុសោ ភគវា សង្ខិត្តេន ឧទ្ទេសំ ឧទ្ទិសិត្វា វិត្ថារេន អត្ថំ អវិភជិត្វា ឧដ្ឋាយាសនា វិហារំ បវិដ្ឋោ យតោនិទានំ ភិក្ខុ បុរិសំ បបញ្ចសញ្ញាសង្ខា សមុទាចរន្តិ ឯត្ថ ចេ នត្ថិ អភិនន្ទិតព្វំ អភិវទិតព្វំ អជ្ឈោសិតព្វំ ឯសេវន្តោ រាគានុសយានំ ឯសេវន្តោ បដិឃានុសយានំ ឯសេវន្តោ វិចិកិច្ឆានុសយានំ ឯសេវន្តោ មានានុសយានំ ឯសេវន្តោ ភវរាគានុសយានំ ឯសេវន្តោ អវិជ្ជានុសយានំ ឯសេវន្តោ ទណ្ឌាទានសត្ថាទានកលហវិគ្គហវិវាទតុវំតុវំបេសុញ្ញមុសាវាទានំ ឯត្ថេតេ បាបកា អកុសលា ធម្មា អបរិសេសា និរុជ្ឈន្តីតិ កោ នុ ខោ ឥមស្ស ភគវតា សង្ខិត្តេន ឧទ្ទេសស្ស ឧទ្ទិដ្ឋស្ស វិត្ថារេន អត្ថំ អវិភត្តស្ស វិត្ថារេន អត្ថំ វិភជេយ្យាតិ ។ អថខោ តេសំ ភិក្ខូនំ ឯតទហោសិ អយំ ខោ អាយស្មា មហាកច្ចា-



(៤៤៦) កាលដែលព្រះមានព្រះភាគស្តេចចេញទៅមិនយូរប៉ុន្មាន ភិក្ខុទាំងនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ព្រះមានព្រះភាគរបស់យើងទាំងឡាយ សំដែងឧទ្ទេសនេះ ដោយបំព្រួញ មិនបានចែកអត្ថដោយពិស្តារថា ម្នាលភិក្ខុ ចំណែកនៃបបញ្ចសញ្ញាដែលប្រព្រឹត្តទៅតាមបុរស ព្រោះមានសភាវៈណាជាហេតុ សេចក្តីដែលបុគ្គលគប្បីត្រេកអរ គប្បីពោល គប្បីប្រកាន់ (ថាអញថាយើង) បើមិនមានក្នុងសភាវៈនុ៎ះទេ សេចក្តីមិនត្រេកអរជាដើមនុ៎ះឯង ហៅថាទីបំផុតនៃរាគានុស័យ ហៅថាទីបំផុតនៃបដិឃានុស័យ ហៅថាទីបំផុតនៃវិចិកិច្ឆានុស័យ ហៅថាទីបំផុតនៃមានានុស័យ ហៅថាទីបំផុតនៃភវរាគានុស័យ ហៅថាទីបំផុតនៃអវិជ្ជានុស័យ ហៅថាទីបំផុតនៃការកាន់ដំបងកាន់សស្ត្រា ជម្លោះ ប្តឹងហេតុ ទាស់ទែង ពោលពាក្យស៊កសៀតថាឯងថាមឹង និងពាក្យមុសា អកុសលធម៌ទាំងឡាយដ៏លាមកនេះ រមែងរលត់ទៅមិនសេសសល់ក្នុងសភាវៈនុ៎ះ ដូច្នេះហើយក៏ស្រាប់តែស្តេចក្រោកអំពីអាសនៈចូលទៅកាន់វិហារទៅ ភិក្ខុណាហ្ន៎ គប្បីចែកសេចក្តីនៃឧទ្ទេសដែលព្រះមានព្រះភាគទ្រង់សំដែងដោយបំព្រួញ មិនចែកអត្ថឲ្យពិស្តារនេះ ឲ្យពិស្តារទៅបាន ។ ទើបភិក្ខុទាំងនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា មហាកច្ចាយៈ

យោ សត្ថុ ចេវ សំវណ្ណិតោ សម្ភាវិតោ ច វិញ្ញូនំ សព្រហ្មចារីនំ បហោតិ ចាយស្មា មហាកច្ចានោ ឥមស្ស ភគវតា សង្ខិត្តេន ឧទ្ទេសស្ស ឧទ្ទិដ្ឋស្ស វិត្ថារេន អត្ថំ អវិភត្តស្ស វិត្ថារេន អត្ថំ វិភជិតុំ យន្នូន មយំ យេនាយស្មា មហាកច្ចានោ តេនុបសង្កមេយ្យាម ឧបសង្កមិត្វា អាយស្មន្តំ មហាកច្ចានំ ឯតមត្ថំ បដិបុច្ឆេយ្យាមាតិ ។ អថខោ តេ ភិក្ខូ យេនាយស្មា មហាកច្ចានោ តេនុបសង្កមិំសុ ឧបសង្កមិត្វា អាយស្មតា មហាកច្ចានេន សទ្ធិំ សម្មោទិំសុ សម្មោទនីយំ កថំ សារណីយំ វីតិសារេត្វា ឯកមន្តំ និសីទិំសុ ។ ឯកមន្តំ និសិន្នា ខោ តេ ភិក្ខូ អាយស្មន្តំ មហាកច្ចានំ ឯតទវោចុំ ឥទំ ខោ នោ អាវុសោ កច្ចាន ភគវា សង្ខិត្តេន ឧទ្ទេសំ ឧទ្ទិសិត្វា វិត្ថារេន អត្ថំ អវិភជិត្វា ឧដ្ឋាយាសនា វិហារំ បវិដ្ឋោ យតោនិទានំ ភិក្ខុ បុរិសំ បបញ្ចសញ្ញាសង្ខា សមុទាចរន្តិ ឯត្ថ ចេ នត្ថិ អភិនន្ទិតព្វំ ។ បេ ។ ឯត្ថេតេ បាបកា អកុសលា ធម្មា អបរិសេសា និរុជ្ឈន្តិ



ដ៏មានអាយុនេះឯង ព្រះសាស្តាទ្រង់សរសើរ ទាំងពួកសព្រហ្មចារី ជាអ្នកប្រាជ្ញក៏សរសើរហើយ ព្រះមហាកច្ចានៈដ៏មានអាយុនេះ អាចនឹងចែកសេចក្តីនៃឧទ្ទេសដែលព្រះមានព្រះភាគ ទ្រង់សំដែងដោយបំព្រួញ មិនទាន់ចែកអត្ថឲ្យពិស្តារនេះ ឲ្យពិស្តារទៅបាន បើដូច្នោះ គួរយើងទាំងឡាយ ចូលទៅរកមហាកច្ចានៈដ៏មានអាយុនោះ លុះចូលទៅដល់ហើយ គប្បីសាកសួរខ្លឹមសេចក្តីនេះ នឹងមហាកច្ចានៈដ៏មានអាយុ ។ ទើបភិក្ខុទាំងនោះ នាំគ្នាចូលទៅរកមហាកច្ចានៈដ៏មានអាយុ លុះចូលទៅដល់ហើយ ក៏ពោលពាក្យរាក់ទាក់សំណេះសំណាល ជាមួយ នឹងមហាកច្ចានៈដ៏មានអាយុ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររលឹកហើយ ទើបអង្គុយក្នុងទីដ៏សមគួរ ។ លុះភិក្ខុទាំងនោះអង្គុយក្នុងទីសមគួរហើយ បានពោលពាក្យនេះ នឹងមហាកច្ចានៈដ៏មានអាយុថា ម្នាលអាវុសោកច្ចានៈ ព្រះមានព្រះភាគរបស់យើងទាំងឡាយ សំដែងឧទ្ទេសនេះ ដោយសេចក្តីបំព្រួញ មិនទាន់បានចែកសេចក្តីដោយពិស្តារថា ម្នាលភិក្ខុ ចំណែកនៃបបញ្ចសញ្ញា រមែងប្រព្រឹត្តទៅតាមបុរស ព្រោះមានសភាវៈណាជាហេតុ សូម្បីសេចក្តីដែលបុគ្គលគប្បីត្រេកអរ បើមិនមានក្នុងសភាវៈនុ៎ះទេ ។ បេ ។ អកុសលធម៌ទាំងឡាយដ៏លាមកនេះ តែងរលត់ទៅវិញដោយមិនសេសសល់ក្នុងសភាវៈនុ៎ះដូច្នេះ ហើយក៏ស្ដេចក្រោកអំពី

តេសំ នោ អាវុសោ កច្ចាន អម្ហាកំ អចិរបក្កន្តស្ស ភគវតោ ឯតទហោសិ ឥទំ ខោ នោ អាវុសោ ភគវា សង្ខិត្តេន ឧទ្ទេសំ ឧទ្ទិសិត្វា វិត្ថារេន អត្ថំ អវិភជិត្វា ឧដ្ឋាយាសនា វិហារំ បវិដ្ឋោ យតោនិទានំ ភិក្ខុ បុរិសំ បបញ្ចសញ្ញាសង្ខា សមុទាចរន្តិ ឯត្ថ ចេ នត្ថិ អភិនន្ទិតព្វំ ។ បេ ។ ឯត្ថេតេ បាបកា អកុសលា ធម្មា អបរិសេសា និរុជ្ឈន្តីតិ កោ នុ ខោ ឥមស្ស ភគវតា សង្ខិត្តេន ឧទ្ទេសស្ស ឧទ្ទិដ្ឋស្ស វិត្ថារេន អត្ថំ អវិភត្តស្ស វិត្ថារេន អត្ថំ វិភជេយ្យាតិ តេសំ នោ អាវុសោ កច្ចាន អម្ហាកំ ឯតទហោសិ អយំ ខោ អាវុសោ អាយស្មា មហាកច្ចានោ សត្ថុ ចេវ សំវណ្ណិតោ សម្ភាវិតោ ច វិញ្ញូនំ សព្រហ្មចារីនំ បហោតិ ចាយស្មា មហាកច្ចានោ ឥមស្ស ភគវតា សង្ខិត្តេន ឧទ្ទេសស្ស ឧទ្ទិដ្ឋស្ស វិត្ថារេន អត្ថំ អវិភត្តស្ស វិត្ថារេន អត្ថំ វិភជិតុំ យន្នូន មយំ



អាសនៈចូលទៅកាន់វិហារទៅ ម្នាលអាវុសោកច្ចានៈ កាលបើព្រះមានព្រះភាគរបស់យើងទាំងឡាយ ស្តេចចេញទៅមិនយូរប៉ុន្មាន យើងទាំងនោះក៏មានសេចក្តីត្រិះរិះដូច្នេះថា ម្នាលអាវុសោ ព្រះមានព្រះភាគរបស់យើង សំដែងឧទ្ទេសនេះដោយសេចក្តីបំប្រួញ មិនទាន់ចាប់ចែកសេចក្តីដោយពិស្តារថា ម្នាលភិក្ខុ ចំណែកនៃបបញ្ចសញ្ញា រមែងប្រព្រឹត្តទៅតាមបុរសព្រោះមានសភាវៈណាជាហេតុ សូម្បីសេចក្តីដែលបុគ្គលគប្បីត្រេកអរ បើមិនមានក្នុងសភាវៈនុ៎ះទេ ។ បេ ។ អកុសលធម៌ទាំងឡាយដ៏លាមកនេះ រមែងរលត់ទៅវិញដោយមិនសេសសល់ក្នុងសភាវៈនុ៎ះ ដូច្នេះហើយក៏ស្រាប់តែស្តេចក្រោកអំពីអាសនៈចូលទៅកាន់វិហារទៅ ភិក្ខុណាហ្ន៎គប្បីចែកសេចក្តីនៃឧទ្ទេសដែលព្រះមានព្រះភាគទ្រង់សំដែងហើយដោយបំប្រួញ មិនទាន់ចែកអត្ថឲ្យពិស្តារនេះ ឲ្យពិស្តារទៅបាន ម្នាលអាវុសោកច្ចានៈ យើងទាំងអស់គ្នានេះមានសេចក្តីត្រិះរិះដូច្នេះទៀតថា ម្នាលអាវុសោទាំងឡាយ មហាកច្ចានៈដ៏មានអាយុនេះព្រះសាស្តាទ្រង់សរសើរ ទាំងពួកសព្រហ្មចារី ជាអ្នកប្រាជ្ញក៏សរសើរដែរ មានតែមហាកច្ចានៈដ៏មានអាយុនេះ ទើបអាចនឹងចែកសេចក្តីនៃឧទ្ទេសដែលព្រះមានព្រះភាគទ្រង់សំដែងហើយដោយសេចក្តីបំប្រួញ មិនទាន់ចាប់ចែកសេចក្តីឲ្យពិស្តារនេះ ឲ្យពិស្តារទៅបាន បើដូច្នោះគួរតែយើង

យេនាយស្មា មហាកច្ចានោ តេនុបសង្កមេយ្យាម ឧបសង្កមិត្វា អាយស្មន្តំ មហាកច្ចានំ ឯតមត្ថំ បដិបុច្ឆេយ្យាមាតិ វិភជតាយស្មា មហាកច្ចានោតិ ។

(៤៨) សេយ្យថាបិ អាវុសោ បុរិសោ សារត្ថិកោ សារគវេសី សារបរិយេសនំ ចរមានោ មហតោ រុក្ខស្ស តិដ្ឋតោ សារវតោ[១] អតិក្កម្មេវ មូលំ អតិក្កម្ម ខន្ធំ សាខាបលាសេ សារំ បរិយេសិតព្វំ មញ្ញេយ្យ ឯវំ សម្បទមិទំ អាយស្មន្តានំ សត្ថរិ សម្មុខីភូតេ តំ ភគវន្តំ អតិសិត្វា អម្ហេ ឯតមត្ថំ បដិបុច្ឆិតព្វំ មញ្ញថ[២] សោ ហាវុសោ ភគវា ជានំ ជានាតិ បស្សំ បស្សតិ ចក្ខុភូតោ ញាណភូតោ ធម្មភូតោ ព្រហ្មភូតោ វត្តា បវត្តា អត្ថស្ស និន្នេតា អមតស្ស ទាតា ធម្មស្សាមី តថាគតោ សោ ចេវ បនេតស្ស កាលោ អហោសិ យំ ភគវន្តំយេវ

១ ឱ.ម. សារវតោ ។ ២ ឱ. មញ្ញេថ ។



ទាំងឡាយ ចូលទៅរកមហាកច្ចានៈដ៏មានអាយុនោះ លុះចូលទៅដល់ហើយ គប្បីសាកសួរនូវសេចក្ដីនេះ នឹងមហាកច្ចានៈដ៏មានអាយុថា សូមមហាកច្ចានៈដ៏មានអាយុចែក (សេចក្ដីនេះឲ្យបាន) ។

(៤៨) មហាកច្ចានៈដ៏មានអាយុឆ្លើយថា ម្នាលអាវុសោ ដូចបុរសជាអ្នកត្រូវការដោយខ្លឹមឈើ ស្វែងរកខ្លឹមឈើ ដើរទៅកាន់ទីស្វែងរកខ្លឹមឈើ ហើយដើរហួសខ្លឹមឈើធំ ដែលនៅក្នុងទីនោះ ដើរហួសគល់និងដើម ហើយសំគាល់ថា គួរស្វែងរកខ្លឹមត្រង់មែកនិងស្លឹកវិញ មានឧបមាយ៉ាងណា សេចក្ដីឧបមេយ្យនេះក៏យ៉ាងនោះដែរ កាលបើព្រះសាស្ដាគង់ក្នុងទីចំពោះមុខនៃលោកដ៏មានអាយុទាំងឡាយ លោកទាំងឡាយ ដើរហួសព្រះមានព្រះភាគនោះ ហើយសំគាល់ថាគប្បីសួរសេចក្ដីនេះនឹងខ្ញុំវិញ ម្នាលអាវុសោ ព្រោះថា ព្រះមានព្រះភាគនោះ កែងទ្រង់ជ្រាបនូវហេតុដែលគួរជ្រាប ទ្រង់ឃើញនូវហេតុដែលគួរឃើញ ព្រះតថាគតនោះមានចក្ខុកើតហើយ មានញាណកើតហើយ មានធម៌ [illegible] កើតហើយ ព្រះអង្គជាបុរសដ៏ប្រសើរ ព្រះអង្គជាអ្នកពោលនូវធម៌ អ្នកប្រាប់នូវធម៌ អ្នកបង្អោននូវប្រយោជន៍ អ្នកឲ្យនូវសេចក្ដីប្រតិបត្តិ ដើម្បីត្រាស់ដឹងនូវព្រះនិព្វានឈ្មោះអមតៈ ជាម្ចាស់នៃធម៌ កាលនេះជាកាលគួរដល់ព្រះតថាគតនុ៎ះហើយ លោកទាំងឡាយគប្បីសាកសួរ

ឯតមត្ថំ បដិបុច្ឆេយ្យាថ យថា វោ ភគវា ព្យាករេយ្យ តថា នំ ធារេយ្យាថាតិ ។ អទ្ធាវុសោ កច្ចាន ភគវា ជានំ ជានាតិ បស្សំ បស្សតិ ចក្ខុភូតោ ញាណភូតោ ធម្មភូតោ ព្រហ្មភូតោ វត្តា បវត្តា អត្ថស្ស និន្នេតា អមតស្ស ទាតា ធម្មស្សាមិ តថាគតោ សោ ចេវ បនេតស្ស កាលោ អហោសិ យំ ភគវន្តំយេវ ឯតមត្ថំ បដិបុច្ឆេយ្យាម យថា នោ ភគវា ព្យាករេយ្យ តថា នំ ធារេយ្យាម អបិចាយស្មា មហាកច្ចានោ សត្ថុ ចេវ សំវណ្ណិតោ សម្ភាវិតោ ច វិញ្ញូនំ សព្រហ្មចារីនំ បហោតិ ចា-យស្មា មហាកច្ចានោ ឥមស្ស ភគវតោ សង្ខិត្តេន ឧទ្ទេសស្ស ឧទ្ទិដ្ឋស្ស វិត្ថារេន អត្ថំ អវិភត្តស្ស វិត្ថារេន អត្ថំ វិភជិតុំ វិភជតាយស្មា មហាកច្ចានោ អគរុករិត្វាតិ[១] ។

១ ម. អគរុំ កត្វាតិ ។



នូវសេចក្តីនៃឧទ្ទេសនេះនឹងព្រះមានព្រះភាគចុះ (បើ) ព្រះមានព្រះភាគនៃយើងទ្រង់សំដែងយ៉ាងណា អ្នកទាំងឡាយ គប្បីចាំទុកនូវឧទ្ទេសនោះដូច្នោះ ។ ម្នាលអាវុសោកច្ចានៈ ព្រះមានព្រះភាគទ្រង់ជ្រាបនូវហេតុដែលគួរជ្រាប ទ្រង់ឃើញនូវហេតុដែលគួរឃើញដោយពិតណាស់ ព្រះតថាគតនោះមានចក្ខុកើតហើយ មានញាណកើតហើយ មានធម៌មិនវិបរិតកើតហើយ ព្រះអង្គជាបុរសដ៏ប្រសើរ ព្រះអង្គជាអ្នកពោលនូវធម៌ ជាអ្នកប្រាប់នូវធម៌ អ្នកបង្អោនមកនូវប្រយោជន៍ អ្នកឲ្យនូវសេចក្តីប្រតិបត្តិដើម្បីត្រាស់ដឹងនូវព្រះនិព្វានឈ្មោះអមតៈ ជាម្ចាស់នៃធម៌ កាលនេះជាកាលគួរដល់ព្រះតថាគតនុ៎ះហើយ យើងទាំងឡាយគប្បីសាកសួរនូវសេចក្តីនៃឧទ្ទេសនេះនឹងព្រះមានព្រះភាគចុះ (បើ) ព្រះមានព្រះភាគនៃយើងទ្រង់សំដែងយ៉ាងណា យើងទាំងឡាយ គប្បីចាំទុកនូវឧទ្ទេសនោះដូច្នោះ គឺមែនពិតហើយ ប៉ុន្តែមហាកច្ចានៈដ៏មានអាយុ ព្រះសាស្តាទ្រង់សរសើរ ទាំងពួកសព្រហ្មចារី ជាអ្នកប្រាជ្ញក៏សរសើរដែរ មហាកច្ចានៈដ៏មានអាយុនេះ អាចចែកសេចក្តីនៃឧទ្ទេសដែលព្រះមានព្រះភាគសំដែងដោយបំប្រួញ មិនទាន់ចែកអត្ថឲ្យពិស្តារនេះ ឲ្យពិស្តារបាន សូមមហាកច្ចានៈដ៏មានអាយុកុំបន្ទុំបន្ទង់ ហេតុតែ (សេចក្តីឲ្យតាម) ។

(៤៤៨) តេនហាវុសោ សុណាថ សាធុកំ មនសិ-
ករោថ ភាសិស្សាមីតិ ។ ឯវមាវុសោតិ ខោ តេ ភិក្ខូ
អាយស្មតោ មហាកច្ចានស្ស បច្ចស្សោសុំ ។ អាយ-
ស្មា មហាកច្ចានោ ឯតទវោច យំ ខោ នោ អាវុសោ
ភគវា សង្ខិត្តេន ឧទ្ទេសំ ឧទ្ទិសិត្វា វិត្ថារេន អត្ថំ
អវិភជិត្វា ឧដ្ឋាយាសនា វិហារំ បវិដ្ឋោ យតោនិទានំ
ភិក្ខុ បុរិសំ បបញ្ចសញ្ញាសង្ខា សមុទាចរន្តិ ឯត្ថ
ចេ នត្ថិ អភិនន្ទិតព្វំ ។បេ។ ឯត្ថេតេ បាបកា អ-
កុសលា ធម្មា អបរិសេសា និរុជ្ឈន្តីតិ ឥមស្ស ខោ
អហំ អាវុសោ ភគវតា សង្ខិត្តេន ឧទ្ទេសស្ស ឧទ្ទិ-
ដ្ឋស្ស វិត្ថារេន អត្ថំ អវិភត្តស្ស ឯវំ វិត្ថារេន អត្ថំ
អាជានាមិ ចក្ខុញ្ចាវុសោ បដិច្ច រូបេ ច ឧប្បជ្ជតិ
ចក្ខុវិញ្ញាណំ តិណ្ណំ សង្គតិ ផស្សោ ផស្សបច្ចយា
វេទនា យំ វេទេតិ តំ សញ្ជានាតិ យំ សញ្ជានាតិ



(៤៤៨) ព្រះមហាកច្ចានៈឆ្លើយថា ម្នាលអាវុសោ បើដូច្នោះ អ្នក
ទាំងឡាយចូរស្តាប់ ចូរធ្វើទុកក្នុងចិត្តឲ្យល្អចុះ ខ្ញុំនឹងសំដែង (សេចក្តីនេះ) ។
ភិក្ខុទាំងនោះ ក៏ឆ្លើយតបព្រះមហាកច្ចានៈដ៏មានអាយុថា ព្រះករុណា
អាវុសោ ។ ព្រះមហាកច្ចានៈដ៏មានអាយុ បានពោលពាក្យនេះថា ម្នាល
អាវុសោទាំងឡាយ ព្រះមានព្រះភាគរបស់យើង សំដែងនូវឧទ្ទេស
ណា ដោយសេចក្តីបំប្រួញ មិនចាត់ចែងនូវអត្ថ ដោយពិស្តារថា
ម្នាលភិក្ខុ ចំណែកនៃបបញ្ចសញ្ញាតែងប្រព្រឹត្តទៅកាន់បុរស ព្រោះមាន
សភាវៈណាជាហេតុ ស្រឡះសេចក្តីដែលបុគ្គលគប្បីត្រេកអរ បើមិនមាន
ក្នុងសភាវៈនុ៎ះទេ ។បេ។ អកុសលធម៌ទាំងឡាយដ៏លាមកនេះ រមែង
រលត់ទៅដោយមិនសេសសល់ ក្នុងសភាវៈនុ៎ះ ដូច្នេះហើយក៏ក្រោកចាក
អាសនៈ ចូលទៅកាន់វិហារទៅ ម្នាលអាវុសោ ខ្ញុំដឹង
ច្បាស់នូវសេចក្តីនៃឧទ្ទេស ដែលព្រះមានព្រះភាគទ្រង់សំដែង ដោយ
បំប្រួញ មិនចាត់ចែងអត្ថឲ្យពិស្តារនេះ ដោយពិស្តារយ៉ាងនេះថា ម្នាល
អាវុសោ ចក្ខុវិញ្ញាណកើតឡើង ព្រោះអាស្រ័យចក្ខុប្រសាទនឹងរូបារម្មណ៍
ការប្រជុំធម៌ ៣ យ៉ាង (ចក្ខុ ១ រូប ១ ចក្ខុវិញ្ញាណ ១) ឈ្មោះថា ផស្សៈ
វេទនាកើតឡើងព្រោះផស្សៈជាបច្ច័យ វេទនាទទួលនូវអារម្មណ៍ណា
សញ្ញាក៏ស្គាល់ច្បាស់នូវអារម្មណ៍នោះ សញ្ញាស្គាល់ច្បាស់នូវអារម្មណ៍ណា

តំ វិតក្កេតិ យំ វិតក្កេតិ តំ បបញ្ចេតិ យំ ប-
បញ្ចេតិ តតោនិទានំ បុរិសំ បបញ្ចសញ្ញាសង្ខា សមុ-
ទាចរន្តិ អតីតានាគតបច្ចុប្បន្នេសុ ចក្ខុវិញ្ញេយ្យេសុ
រូបេសុ ។ សោតញ្ចាវុសោ បដិច្ច សទ្ទេ ច ឧប្បជ្ជតិ
សោតវិញ្ញាណំ ។ បេ ។ ឃានញ្ចាវុសោ បដិច្ច គន្ធេ
ច ឧប្បជ្ជតិ ឃានវិញ្ញាណំ... ។ ជិវ្ហញ្ចាវុសោ បដិច្ច
រសេ ច ឧប្បជ្ជតិ ជិវ្ហាវិញ្ញាណំ... ។ កាយញ្ចាវុសោ
បដិច្ច ផោដ្ឋព្វេ ច ឧប្បជ្ជតិ កាយវិញ្ញាណំ... ។
មនញ្ចាវុសោ បដិច្ច ធម្មេ ច ឧប្បជ្ជតិ មនោវិញ្ញាណំ
តិណ្ណំ សង្គតិ ផស្សោ ផស្សបច្ចយា វេទនា យំ វេទេតិ
តំ សញ្ជានាតិ យំ សញ្ជានាតិ តំ វិតក្កេតិ យំ វិតក្កេតិ



វិតក្កៈក៏ត្រិះរិះនូវអារម្មណ៍នោះ វិតក្កៈត្រិះរិះនូវអារម្មណ៍ណា បបញ្ច-
ធម៌ក៏ធ្វើឲ្យយឺតយូរនូវអារម្មណ៍នោះ បបញ្ចធម៌ធ្វើឲ្យយឺតយូរនូវអារម្មណ៍
ណា ចំណែកនៃបបញ្ចសញ្ញាក៏មកគ្របសង្កត់នូវបុរស ព្រោះមានចក្ខុនិង
រូបជាដើមនោះជាហេតុ (សហជាតធម៌ទាំងឡាយ) ក្នុងរូបដែលគេគប្បីដឹង
ដោយចក្ខុជាអតីត អនាគត និងបច្ចុប្បន្ន (បណ្ឌិតគប្បីយល់តាមន័យនេះ
ចុះ) ។ ម្នាលអាវុសោ សោតវិញ្ញាណកើតឡើងព្រោះអាស្រ័យសោត-
ប្រសាទនិងសទ្ទារម្មណ៍ ។ បេ ។ ម្នាលអាវុសោ ឃានវិញ្ញាណកើត
ឡើងព្រោះអាស្រ័យឃានប្រសាទនិងគន្ធារម្មណ៍... ។ ម្នាលអាវុសោ
ជិវ្ហាវិញ្ញាណកើតឡើង ព្រោះអាស្រ័យជិវ្ហាប្រសាទនិងរសារម្មណ៍ ។
ម្នាលអាវុសោ កាយវិញ្ញាណកើតឡើង ព្រោះអាស្រ័យកាយប្រសាទនិង
ផោដ្ឋព្វារម្មណ៍... ។ ម្នាលអាវុសោ មនោវិញ្ញាណ គឺភវង្គចិត្តជាទួចិត្ត
កើតឡើងព្រោះអាស្រ័យភវង្គចិត្តនិងធម្មារម្មណ៍ ដែលប្រព្រឹត្តទៅក្នុងភូមិ
៣ ការប្រជុំនៃភវង្គចិត្ត ធម្មារម្មណ៍ និងមនោវិញ្ញាណទាំង៣(នេះ)ឈ្មោះ
ជាផស្សៈ វេទនាកើតឡើងព្រោះមានផស្សៈជាបច្ច័យ វេទនាទទួលនូវ
អារម្មណ៍ណា សញ្ញាក៏ស្គាល់ច្បាស់នូវអារម្មណ៍នោះ សញ្ញាស្គាល់ច្បាស់
នូវអារម្មណ៍ណា វិតក្កៈក៏ត្រិះរិះនូវអារម្មណ៍នោះ វិតក្កៈត្រិះរិះនូវអារម្មណ៍

តំ បបញ្ចេតិ យំ បបញ្ចេតិ តតោនិទានំ បុរិសំ បបញ្ចសញ្ញាសង្ខា សមុទាចរន្តិ អតីតានាគតបច្ចុប្បន្នេសុ មនោវិញ្ញេយ្យេសុ ធម្មេសុ ។ សោ វតាវុសោ ចក្ខុស្មឹ សតិ រូបេ សតិ ចក្ខុវិញ្ញាណេ សតិ ផស្សបញ្ញត្តឹ បញ្ញាបេស្សតីតិ ឋានមេតំ វិជ្ជតិ ផស្សបញ្ញត្តិយា សតិ វេទនាបញ្ញត្តឹ បញ្ញាបេស្សតីតិ ឋានមេតំ វិជ្ជតិ វេទនាបញ្ញត្តិយា សតិ សញ្ញាបញ្ញត្តឹ បញ្ញាបេស្សតីតិ ឋានមេតំ វិជ្ជតិ សញ្ញាបញ្ញត្តិយា សតិ វិតក្កបញ្ញត្តឹ បញ្ញាបេស្សតីតិ ឋានមេតំ វិជ្ជតិ វិតក្កបញ្ញត្តិយា សតិ បបញ្ចសញ្ញាសង្ខាសមុទាចរណបញ្ញត្តឹ បញ្ញាបេស្សតីតិ ឋានមេតំ វិជ្ជតិ ។ សោ វតាវុសោ សោតស្មឹ សតិ សទ្ទេ សតិ... ។ ឃានស្មឹ សតិ គន្ធេ សតិ... ។ ជិវ្ហាយ សតិ រសេ សតិ... ។ កាយស្មឹ សតិ ផោដ្ឋព្វេ សតិ... ។ មនស្មឹ សតិ ធម្មេ សតិ មនោវិញ្ញាណេ សតិ



ណា បបញ្ចធម៌ធ្វើឲ្យយឺតយូរនូវអារម្មណ៍នោះ បបញ្ចធម៌ធ្វើឲ្យយឺតយូរនូវអារម្មណ៍ណា ចំណែកនៃបបញ្ចសញ្ញាតែងគ្របសង្កត់នូវបុរសព្រោះមានអារម្មណ៍នោះជាហេតុ ( សហជាតធម៌ទាំងឡាយ ) ក្នុងអារម្មណ៍ដែលគេគប្បីដឹងដោយចិត្ត ជាអតីត អនាគត បច្ចុប្បន្ន បណ្ឌិតគប្បីយល់តាមន័យនេះចុះ ។ ម្នាលអាវុសោ កាលបើចក្ខុប្រសាទ រូបារម្មណ៍និងចក្ខុវិញ្ញាណមានហើយ បុរសនោះឯងនឹងធ្វើឲ្យប្រាកដនូវផស្សបញ្ញត្តិបាន ហេតុនេះមានមែន កាលបើផស្សបញ្ញត្តិមានហើយ នឹងធ្វើឲ្យប្រាកដនូវវេទនាបញ្ញត្តិបាន ហេតុនេះមានមែន កាលបើវេទនាបញ្ញត្តិមានហើយ នឹងធ្វើឲ្យប្រាកដនូវសញ្ញាបញ្ញត្តិបាន ហេតុនេះមានមែន កាលបើសញ្ញាបញ្ញត្តិមានហើយ នឹងធ្វើឲ្យប្រាកដនូវវិតក្កបញ្ញត្តិបាន ហេតុនេះមានមែន កាលបើវិតក្កបញ្ញត្តិមានហើយ នឹងធ្វើឲ្យប្រាកដនូវបបញ្ចសញ្ញាសង្ខាសមុទាចរណបញ្ញត្តិ គឺសំដែងនូវការគ្របសង្កត់នូវចំណែកនៃបបញ្ចសញ្ញាបាន ហេតុនេះមានមែន ។ ម្នាលអាវុសោ កាលបើសោតប្រសាទនិងសទ្ទារម្មណ៍មានហើយ បុរសនោះឯង... ។ កាលបើឃានប្រសាទនិងគន្ធារម្មណ៍មានហើយ... ។ បើជិវ្ហាប្រសាទនិងរសារម្មណ៍មានហើយ ។ កាលបើកាយប្រសាទនិងផោដ្ឋព្វារម្មណ៍មានហើយ... ។ កាលបើភវង្គចិត្ត ធម្មារម្មណ៍និងមនោវិញ្ញាណមានហើយ បុរសនោះឯងនឹងធ្វើ

ផស្សបញ្ញត្តឹ បញ្ញាបេស្សតីតិ ឋានមេតំ វិជ្ជតិ ផស្សបញ្ញត្តិយា សតិ វេទនាបញ្ញត្តឹ បញ្ញាបេស្សតីតិ ឋានមេតំ វិជ្ជតិ វេទនាបញ្ញត្តិយា សតិ សញ្ញាបញ្ញត្តឹ បញ្ញាបេស្សតីតិ ឋានមេតំ វិជ្ជតិ សញ្ញាបញ្ញត្តិយា សតិ វិតក្កបញ្ញត្តឹ បញ្ញាបេស្សតីតិ ឋានមេតំ វិជ្ជតិ វិតក្កបញ្ញត្តិយា សតិ បបញ្ចសញ្ញាសង្ខាសមុទាចរណបញ្ញត្តឹ បញ្ញាបេស្សតីតិ ឋានមេតំ វិជ្ជតិ ។ សោ វតាវុសោ ចក្ខុស្មឹ អសតិ រូបេ អសតិ ចក្ខុវិញ្ញាណេ អសតិ ផស្សបញ្ញត្តឹ បញ្ញាបេស្សតីតិ នេតំ ឋានំ វិជ្ជតិ ផស្សបញ្ញត្តិយា អសតិ វេទនាបញ្ញត្តឹ បញ្ញាបេស្សតីតិ នេតំ ឋានំ វិជ្ជតិ វេទនាបញ្ញត្តិយា អសតិ សញ្ញាបញ្ញត្តឹ បញ្ញាបេស្សតីតិ នេតំ ឋានំ វិជ្ជតិ សញ្ញាបញ្ញត្តិយា អសតិ វិតក្កបញ្ញត្តឹ បញ្ញាបេស្សតីតិ នេតំ ឋានំ វិជ្ជតិ វិតក្កបញ្ញត្តិយា អសតិ បបញ្ចសញ្ញាសង្ខាសមុទាចរណបញ្ញត្តឹ បញ្ញាបេស្សតីតិ នេតំ ឋានំ វិជ្ជតិ ។ សោ វតាវុសោ សោតស្មឹ អសតិ សទ្ទេ អសតិ ។ បេ ។



ឲ្យប្រាកដនូវផស្សបញ្ញត្តិបាន ហេតុនេះមានមែន កាលបើផស្សបញ្ញត្តិមានហើយ ទំនងធ្វើឲ្យប្រាកដនូវវេទនាបញ្ញត្តិបាន ហេតុនេះមានមែន កាលបើវេទនាបញ្ញត្តិមានហើយ ទំនងធ្វើឲ្យប្រាកដនូវសញ្ញាបញ្ញត្តិបាន ហេតុនេះមានមែន កាលបើសញ្ញាបញ្ញត្តិមានហើយ ទំនងធ្វើឲ្យប្រាកដនូវវិតក្កបញ្ញត្តិបាន ហេតុនេះមានមែន កាលបើវិតក្កបញ្ញត្តិមានហើយ ទំនងធ្វើឲ្យប្រាកដនូវបបញ្ចសញ្ញាសង្ខាសមុទាចរណបញ្ញត្តិបាន ហេតុនេះមានមែន ។ ម្នាលអាវុសោ កាលបើចក្ខុប្រសាទមិនមាន រូបារម្មណ៍មិនមាន ទាំងចក្ខុវិញ្ញាណមិនមានហើយ បុរសនោះឯងទំនងធ្វើឲ្យប្រាកដនូវផស្សបញ្ញត្តិបាន ហេតុនេះមិនមានឡើយ កាលបើផស្សបញ្ញត្តិមិនមានហើយ ទំនងធ្វើឲ្យប្រាកដនូវវេទនាបញ្ញត្តិបាន ហេតុនេះមិនមានឡើយ កាលបើវេទនាបញ្ញត្តិ មិនមានហើយ ទំនងធ្វើឲ្យប្រាកដនូវសញ្ញាបញ្ញត្តិបាន ហេតុនេះមិនមានឡើយ កាលបើសញ្ញាបញ្ញត្តិមិនមានហើយ ទំនងធ្វើឲ្យប្រាកដនូវវិតក្កបញ្ញត្តិបាន ហេតុនេះមិនមានឡើយ កាលបើវិតក្កបញ្ញត្តិមិនមាន ទំនងធ្វើឲ្យប្រាកដនូវបបញ្ចសញ្ញាសង្ខាសមុទាចរណបញ្ញត្តិបាន ហេតុនេះមិនមានឡើយ ។ ម្នាលអាវុសោ កាលបើសោតប្រសាទទាំងសទ្ទារម្មណ៍មិនមានហើយ បុរសនោះឯង ។ បេ ។

ឃានស្មឹ អសតិ គន្ធេ អសតិ... ។ ជិវ្ហាយ អសតិ រសេ អសតិ... ។ កាយស្មឹ អសតិ ផោដ្ឋព្វេ អសតិ... ។ មនស្មឹ អសតិ ធម្មេ អសតិ មនោវិញ្ញាណេ អសតិ ផស្សបញ្ញត្តឹ បញ្ញាបេស្សតីតិ នេតំ ឋានំ វិជ្ជតិ ផស្សបញ្ញត្តិយា អសតិ វេទនាបញ្ញត្តឹ បញ្ញាបេស្សតីតិ នេតំ ឋានំ វិជ្ជតិ វេទនាបញ្ញត្តិយា អសតិ សញ្ញាបញ្ញត្តឹ បញ្ញាបេស្សតីតិ នេតំ ឋានំ វិជ្ជតិ សញ្ញាបញ្ញត្តិយា អសតិ វិតក្កបញ្ញត្តឹ បញ្ញាបេស្សតីតិ នេតំ ឋានំ វិជ្ជតិ វិតក្កបញ្ញត្តិយា អសតិ បបញ្ចសញ្ញាសង្ខាសមុទាចរណបញ្ញត្តឹ បញ្ញាបេស្សតីតិ នេតំ ឋានំ វិជ្ជតិ ។ យំ ខោ នោ អាវុសោ ភគវា សង្ខិត្តេន ឧទ្ទេសំ ឧទ្ទិសិត្វា វិត្ថារេន អត្ថំ អវិភជិត្វា ឧដ្ឋាយាសនា វិហារំ បវិដ្ឋោ យតោនិទានំ ភិក្ខុ បុរិសំ បបញ្ចសញ្ញាសង្ខា សមុទាចរន្តិ ឯត្ថ ចេ នត្ថិ អភិនន្ទិតព្វំ ។ បេ ។ ឯត្ថេតេ បាបកា អកុសលា ធម្មា អបរិសេសា និរុជ្ឈន្តីតិ



កាលបើឃានប្រសាទមិនមានគន្ធារម្មណ៍មិនមានហើយ... ។ កាលបើជិវ្ហាប្រសាទមិនមានរសារម្មណ៍មិនមានហើយ... ។ កាលបើកាយប្រសាទមិនផោដ្ឋព្វារម្មណ៍មិនមានហើយ... ។ កាលបើវត្ថុចិត្តមិនមាន ធម្មារម្មណ៍មិនមាន នឹងមនោវិញ្ញាណមិនមានហើយ នឹងធ្វើឲ្យប្រាកដនូវផស្សបញ្ញត្តិបាន ហេតុនេះមិនមានឡើយ កាលបើផស្សបញ្ញត្តិ មិនមានហើយ នឹងធ្វើឲ្យប្រាកដនូវវេទនាបញ្ញត្តិបាន ហេតុនេះមិនមានឡើយ កាលបើវេទនាបញ្ញត្តិមិនមានហើយ នឹងធ្វើឲ្យប្រាកដនូវសញ្ញាបញ្ញត្តិបាន ហេតុនេះមិនមានឡើយ កាលបើសញ្ញាបញ្ញត្តិមិនមានហើយ នឹងធ្វើឲ្យប្រាកដនូវវិតក្កបញ្ញត្តិបាន ហេតុនេះមិនមានឡើយ កាលបើវិតក្កបញ្ញត្តិមិនមានហើយ នឹងធ្វើឲ្យប្រាកដនូវបបញ្ចសញ្ញាសង្ខាសមុទាចរណបញ្ញត្តិបាន ហេតុនេះមិនមានឡើយ ។ ម្នាលអាវុសោ ព្រះមានព្រះភាគរបស់យើងទាំងឡាយ ទ្រង់សំដែងនូវឧទ្ទេសណា ដោយសេចក្ដីបង្រួញ មិនទាន់ចែកសេចក្ដីដោយពិស្ដារថា ម្នាលភិក្ខុ ចំណែកនៃបបញ្ចសញ្ញា រមែងគ្របសង្កត់នូវបុរស ព្រោះអារម្មណ៍ណាជាហេតុ ។ សេចក្ដីដែលបុគ្គលគប្បីត្រេកអរ បើមិនមានក្នុងអារម្មណ៍នុ៎ះទេ ។ បេ ។ អកុសលធម៌ដ៏លាមកទាំងឡាយនេះ រមែងរលត់ទៅ ដោយមិនសេសសល់ ក្នុង

ធម្មស្ស សោ អហំ អាវុសោ ភគវតា សង្ខិត្តេន ឧទ្ទេសស្ស ឧទ្ទិដ្ឋស្ស វិត្ថារេន អត្ថំ អវិភត្តស្ស ឯវំ វិត្ថារេន អត្ថំ អាជានាមិ ។ អាកង្ខមានា ច បន តុម្ហេ អាយស្មន្តោ ភគវន្តំយេវ ឧបសង្កមិត្វា ឯតមត្ថំ បដិបុច្ឆេយ្យាថ យថា នោ ភគវា ព្យាករោតិ តថា នំ ធារេយ្យាថាតិ ។

(៦៤៨) អថខោ តេ ភិក្ខូ អាយស្មតោ មហា-កច្ចានស្ស ភាសិតំ អភិនន្ទិត្វា អនុមោទិត្វា ឧដ្ឋាយា-សនា យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នា ខោ តេ ភិក្ខូ ភគវន្តំ ឯតទវោចុំ យំ(១) ខោ នោ ភន្តេ ភគវា សង្ខិត្តេន ឧទ្ទេសំ ឧទ្ទិសិត្វា វិត្ថារេន អត្ថំ អវិភជិត្វា ឧដ្ឋាយាសនា វិហារំ បវិដ្ឋោ យតោ-និទានំ ភិក្ខុ បុរិសំ បបញ្ចសញ្ញាសង្ខា សមុទាចរន្តិ

១ ម. ឥទំ ។





(សភាវៈនុ៎ះ) ដូច្នេះហើយ ក៏ស្រាប់តែស្ដេចក្រោកអំពីអាសនៈចូល ទៅកាន់វិហារទៅ ម្នាលអាវុសោ ខ្ញុំដឹងច្បាស់នូវសេចក្ដីនៃឧទ្ទេសដែល ព្រះមានព្រះភាគទ្រង់សំដែង ដោយសេចក្ដីបំប្រួញ មិនទាន់ចែក សេចក្ដីឲ្យពិស្ដារនេះ ដោយពិស្ដារយ៉ាងនេះឯង ។ តែថាបើលោក ដ៏មានអាយុទាំងឡាយចង់ដឹង (សេចក្ដីនេះឲ្យច្បាស់លាស់) គប្បីនាំគ្នា ចូលទៅគាល់ព្រះមានព្រះភាគ ហើយសាកសួរសេចក្ដីនេះចុះ (បើ) ព្រះមានព្រះភាគនៃយើងទាំងឡាយ ទ្រង់ព្យាករយ៉ាងណា លោក ទាំងឡាយ គប្បីចាំសេចក្ដីនោះយ៉ាងនោះចុះ ។

(៦៤៨) ភិក្ខុទាំងនោះ ក៏ត្រេកអរអនុមោទនានូវភាសិតរបស់ព្រះ មហាកច្ចានៈដ៏មានអាយុ ហើយក្រោកអំពីអាសនៈ នាំគ្នាចូលទៅគាល់ ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបអភិវាទព្រះ មានព្រះភាគ រួចហើយអង្គុយក្នុងទីដ៏សមគួរ ។ កាលដែលភិក្ខុទាំងនោះ អង្គុយក្នុងទីដ៏សមគួរហើយ បានក្រាបបង្គំទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះមានព្រះភាគដ៏ចំរើន ព្រះអង្គទ្រង់សំដែង នូវឧទ្ទេសណា ដោយសេចក្ដីបំប្រួញ មិនទាន់ចែកសេចក្ដីដោយពិស្ដារ ដល់ពួកខ្ញុំព្រះ អង្គថា ម្នាលភិក្ខុ ចំណែកនៃបបញ្ចសញ្ញា រមែងគ្របសង្កត់នូវបុរស

ឯត្ថ ចេ នត្ថិ អភិនន្ទិតព្ពំ ។ បេ ។ ឯត្ថេតេ បាបកា អកុសលា ធម្មា អបរិសេសា និរុជ្ឈន្តីតិ តេសំ នោ ភន្តេ អម្ហាកំ អចិរបក្កន្តស្ស ភគវតោ ឯតទហោសិ ឥទំ ខោ នោ អាវុសោ ភគវា សង្ខិត្តេន ឧទ្ទេសំ ឧទ្ទិសិត្វា វិត្ថារេន អត្ថំ អវិភជិត្វា ឧដ្ឋាយាសនា វិហារំ បវិដ្ឋោ យតោនិទានំ ភិក្ខុ បុរិសំ បបញ្ចសញ្ញាសង្ខា សមុទាចរន្តិ ឯត្ថ ចេ នត្ថិ អភិនន្ទិតព្ពំ អភិវទិតព្ពំ អជ្ឈោសិតព្ពំ ឯសេវន្តោ រាគានុសយានំ ឯសេវន្តោ បដិឃានុសយានំ ឯសេវន្តោ ទិដ្ឋានុសយានំ ឯសេវន្តោ វិចិកិច្ឆានុសយានំ ឯសេវន្តោ មានានុសយានំ ឯសេវន្តោ ភវរាគានុសយានំ ឯសេវន្តោ អវិជ្ជានុសយានំ ឯសេវន្តោ ទណ្ឌាទានសត្ថាទានកលហវិគ្គហវិវាទតុវំតុវំបេសុញ្ញមុសាវាទានំ ឯត្ថេតេ បាបកា អកុសលា ធម្មា អបរិសេសា និរុជ្ឈន្តិ



ព្រោះមានសភាវៈណាជាហេតុ សេចក្តីដែលបុគ្គលគប្បីត្រេកអរ បើមិនមានក្នុងសភាវៈនុ៎ះទេ ។ បេ ។ អកុសលធម៌ដ៏លាមកទាំងឡាយនេះ រមែងរលត់ទៅ ដោយមិនសេសសល់ក្នុងសភាវៈនុ៎ះ ដូច្នេះហើយក៏ស្រាប់តែស្តេចក្រោកអំពីអាសនៈ ចូលទៅកាន់វិហារទៅ ។ បពិត្រព្រះមានព្រះភាគដ៏ចំរើន កាលព្រះមានព្រះភាគស្តេចចេញទៅមិនយូរប៉ុន្មាន ខ្ញុំព្រះអង្គទាំងនោះ ក៏មានសេចក្តីត្រិះរិះដូច្នេះថា ម្នាលអាវុសោទាំងឡាយ ព្រះមានព្រះភាគរបស់យើង ទ្រង់សំដែងនូវឧទ្ទេសនេះ ដោយសេចក្តីបំប្រួញណាស់ មិនទាន់ចែកសេចក្តីដោយពិស្តារថា ម្នាលភិក្ខុ ចំណែកនៃបបញ្ចសញ្ញា រមែងគ្របសង្កត់នូវបុរស ព្រោះមានសភាវៈណាជាហេតុ សូម្បីសេចក្តីដែលបុគ្គលគប្បីត្រេកអរ គប្បីពោល គប្បីប្រកាន់ (ថាអញ ថាយើង) បើមិនមានក្នុងសភាវៈនុ៎ះទេ សេចក្តីមិនត្រេកអរ ជាដើមនុ៎ះឯង ហៅថាទីបំផុតនៃរាគានុស័យ ហៅថាទីបំផុតនៃបដិឃានុស័យ ហៅថាទីបំផុតនៃទិដ្ឋានុស័យ ហៅថាទីបំផុតនៃវិចិកិច្ឆានុស័យ ហៅថាទីបំផុតនៃមានានុស័យ ហៅថាទីបំផុតនៃភវរាគានុស័យ ហៅថាទីបំផុតនៃអវិជ្ជានុស័យ ហៅថាទីបំផុតនៃការកាន់ដំបង កាន់សស្ត្រា បង្កហេតុជម្លោះ ទាស់ទែង ពោលពាក្យចាក់ដោតថាឯងថាអញ និងពាក្យមុសាវាទ អកុសលធម៌ដ៏លាមកទាំងឡាយនេះ រមែងរលត់ទៅ ដោយមិនសេសសល់

កោ នុ ខោ ឥមស្ស ភគវតា សង្ខិត្តេន ឧទ្ទេសស្ស ឧទ្ទិដ្ឋស្ស វិត្ថារេន អត្ថំ អវិភត្តស្ស វិត្ថារេន អត្ថំ វិភជេយ្យាតិ ។ តេសំ នោ ភន្តេ អម្ហាកំ ឯតទហោសិ អយំ ខោ អាយស្មា មហាកច្ចានោ សត្ថុ ចេវ សំវណ្ណិតោ សម្ភាវិតោ ច វិញ្ញូនំ សព្រហ្មចារីនំ បហោតិ ចាយស្មា មហាកច្ចានោ ឥមស្ស ភគវតា សង្ខិត្តេន ឧទ្ទេសស្ស ឧទ្ទិដ្ឋស្ស វិត្ថារេន អត្ថំ អវិភត្តស្ស វិត្ថារេន អត្ថំ វិភជិតុំ យន្នូន មយំ យេនាយស្មា មហាកច្ចានោ តេនុបសង្កមេយ្យាម ឧបសង្កមិត្វា អាយស្មន្តំ មហាកច្ចានំ ឯតមត្ថំ បដិបុច្ឆេយ្យាមាតិ ។ អថខោ មយំ ភន្តេ យេនាយស្មា មហាកច្ចានោ តេនុបសង្កមិម្ហ ឧបសង្កមិត្វា អាយស្មន្តំ មហាកច្ចានំ ឯតមត្ថំ បដិបុច្ឆិម្ហ ។ តេសំ នោ ភន្តេ អាយស្មតា មហាកច្ចានេន ឥមេហិ អាការេហិ ឥមេហិ បទេហិ ឥមេហិ ព្យញ្ជនេហិ អត្ថោ វិភត្តោតិ ។ បណ្ឌិតោ ភិក្ខវេ



ក្តីសង្ខេបនុ៎ះ ដូច្នេះហើយក៏ស្រាប់តែស្តេចក្រោកអំពីអាសនៈចូលទៅកាន់វិហារទៅ ភិក្ខុណាហ្ន៎ នឹងគប្បីចែកសេចក្តីនៃឧទ្ទេស ដែលព្រះមានព្រះភាគទ្រង់សំដែងដោយបំប្រួញ មិនទាន់ចែកអត្ថ ឲ្យពិស្តារនេះ ឲ្យពិស្តារទៅបាន ។ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គទាំងនោះមានសេចក្តីត្រិះរិះដូច្នេះថា មហាកច្ចានៈដ៏មានអាយុនេះឯង ព្រះសាស្តាទ្រង់សរសើរ ទាំងពួកសព្រហ្មចារីជាអ្នកប្រាជ្ញក៏សរសើរដែរ មានតែមហាកច្ចានៈដ៏មានអាយុនេះ ទើបនឹងអាចចែកសេចក្តីនៃឧទ្ទេសនេះ ដែលព្រះមានព្រះភាគទ្រង់សំដែងដោយបំប្រួញ មិនទាន់ចែកអត្ថឲ្យពិស្តារ ឲ្យពិស្តារទៅបាន បើដូច្នោះ គួរយើងទាំងឡាយចូលទៅរកមហាកច្ចានៈដ៏មានអាយុ លុះចូលទៅដល់ហើយ គប្បីសាកសួរសេចក្តីនេះ នឹងមហាកច្ចានៈដ៏មានអាយុ ។ បពិត្រព្រះអង្គដ៏ចំរើន ទើបខ្ញុំព្រះអង្គទាំងនោះ នាំគ្នាចូលទៅរកមហាកច្ចានៈដ៏មានអាយុ លុះចូលទៅដល់ហើយ បានសាកសួរសេចក្តីនេះ នឹងមហាកច្ចានៈដ៏មានអាយុ ។ បពិត្រព្រះអង្គដ៏ចំរើន មហាកច្ចានៈដ៏មានអាយុ បានចែកសេចក្តីដោយអាការទាំងនេះ ដោយបទទាំងនេះ ដោយព្យញ្ជនៈទាំងនេះ ដល់យើងទាំងឡាយនោះ ។ ព្រះមានព្រះភាគទ្រង់ត្រាស់សរសើរថា ម្នាលភិក្ខុទាំងឡាយ

មហាកច្ចានោ មហាបញ្ញោ ភិក្ខវេ មហាកច្ចានោ មញ្ចេបិ តុម្ហេ ភិក្ខវេ ឯតមត្ថំ បដិបុច្ឆេយ្យាថ អហម្បិ តំ ឯវមេវំ ព្យាករេយ្យំ យថា តំ មហាកច្ចានេន ព្យាកតំ ឯសោ ចេវ ឯតស្ស អត្ថោ ឯវញ្ច នំ ធារេថាតិ ។

(៤៨០) ឯវំ វុត្តេ អាយស្មា អានន្ទោ ភគវន្តំ ឯតទវោច សេយ្យថាបិ ភន្តេ បុរិសោ ជិឃច្ឆាទុព្វល្យបរេតោ មធុបិណ្ឌិកំ អធិគច្ឆេយ្យ សោ យតោ យតោ សាយេយ្យ លភេថេវ[១] សាទុំ រសំ[២] អសេចនកំ

១ ឱ. លភេថ ។ ២ ម. សាទុរសំ ។



មហាកច្ចានៈ (នេះ) ជាបណ្ឌិត[១] ម្នាលភិក្ខុទាំងឡាយ មហាកច្ចានៈ (នេះ) ជាអ្នកមានប្រាជ្ញាច្រើន[២] ម្នាលភិក្ខុទាំងឡាយ ទុកជាអ្នកទាំងឡាយ សាកសួរសេចក្តីនេះនឹងតថាគត តថាគតក៏គង់តែព្យាករសេចក្តីនោះយ៉ាងហ្នឹងដែរ មហាកច្ចានៈព្យាករសេចក្តី នៃឧទ្ទេសនោះយ៉ាងណា សេចក្តីនៃឧទ្ទេសនេះយ៉ាងហ្នឹងហើយ អ្នកទាំងឡាយ ចូរចាំនូវសេចក្តីនោះចុះ ។

(៤៨០) កាលបើព្រះមានព្រះភាគត្រាស់យ៉ាងនេះហើយ ព្រះអានន្ទដ៏មានអាយុ ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ដូចបុរសដែលសេចក្តីស្រេកឃ្លាន គ្របសង្កត់ឲ្យមានកំឡាំងថយ ហើយស្រាប់តែបាននំផ្អែម បុរសនោះបានទទួលសេពក្នុងកាលណា ក៏បាននូវសេចក្តីឆ្ងាញ់ដែលមិនលាយដោយទឹកដម្កា ក្នុងកាលណោះ សេចក្តីនេះ

១ បណ្ឌិតក្នុងទីនេះបានដល់បុគ្គលដែលប្រកបដោយអង្គ ៤ នេះ គឺ ធាតុកុសលោ ឈ្លាសវៃក្នុងពួកធាតុ ១ អាយតនកុសលោ ឈ្លាសវៃក្នុងពួកអាយតនៈ ១ បច្ចយាការកុសលោ ឈ្លាសវៃក្នុងបច្ចយាការនៃបដិច្ចសមុប្បាទ ១ ការណាការណកុសលោ ឈ្លាសវៃក្នុងហេតុនិងមិនមែនហេតុ ១ ។ ២ មានបញ្ញាច្រើនក្នុងទីនេះ សំដៅយកបញ្ញាដែលកំណត់ដឹងនូវអត្ថនិងផលរបស់ហេតុ ឬសេចក្តីអធិប្បាយ ១ ធម៌នឹងហេតុជាទីកើតនៃផល ឬបាលី ១ និរុត្តិ គឺពាក្យពោលនូវអត្ថនិងធម៌មិនវិបរិត ១ បដិភាណ ស្ទាត់ជំនាញក្នុងអត្ថនិងធម៌ទាំងនោះ ១ ។ អដ្ឋកថា ។

ឯវមេវ ខោ ភន្តេ ចេតសោ ភិក្ខុ ទព្វជាតិកោ យតោ យតោ ឥមស្ស ធម្មបរិយាយស្ស បញ្ញាយ អត្ថំ ឧបបរិក្ខេយ្យ លភេថេវ[១] អត្តមនតំ លភេថេវ ចេតសោ បសាទំ កោ នាមាយំ ភន្តេ ធម្មបរិយាយោតិ ។ តស្មាតិហ ត្វំ អានន្ទ ឥមំ ធម្មបរិយាយំ មធុបិណ្ឌិកបរិយាយោត្វេវ នំ ធារេហីតិ ។ ឥទមវោច ភគវា អត្តមនោ អាយស្មា អានន្ទោ ភគវតោ ភាសិតំ អភិនន្ទីតិ ។

មធុបិណ្ឌិកសុត្តំ អដ្ឋមំ និដ្ឋិតំ ។

១ ឱ. ម. លភេថេវ ។



យ៉ាងណា បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុដែលមានជាតិជាអ្នករំពឹង មានសភាពជាបណ្ឌិត គប្បីកំណត់នូវសេចក្តីនៃធម្មបរិយាយនេះ ដោយបញ្ញាក្នុងកាលណា គឺបាននូវភាវៈជាអ្នកមានចិត្តរីករាយផង បាននូវសេចក្តីជ្រះថ្លានៃចិត្តផង (ក្នុងកាលណោះ) ដូច្នោះឯង បពិត្រព្រះអង្គដ៏ចំរើន ធម្មបរិយាយនេះឈ្មោះដូចម្តេច ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលអានន្ទ បើដូច្នោះ ចូរអ្នកចាំទុកនូវសេចក្តីនោះថា ធម្មបរិយាយនេះឈ្មោះមធុបិណ្ឌិកបរិយាយដូច្នេះចុះ ។ ព្រះមានព្រះភាគបានសំដែងព្រះសូត្រនេះចប់ហើយ ព្រះអានន្ទដ៏មានអាយុក៏ពេញចិត្ត ត្រេកអរចំពោះភាសិតរបស់ព្រះមានព្រះភាគ ។

ចប់ មធុបិណ្ឌិកសូត្រ ទី ៨ ។

# ៩. ទ្វេធាវិតក្កសុត្តំ

(២៨១) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ ភិក្ខវោតិ ។ ភទន្តេតិ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។

(២៨២) ភគវា ឯតទវោច បុព្វេវ មេ ភិក្ខវេ សម្ពោធា អនភិសម្ពុទ្ធស្ស ពោធិសត្តស្សេវ សតោ ឯតទហោសិ យន្នូនាហំ ទ្វេធា(១) កត្វា ទ្វេធា កត្វា វិតក្កេ វិហរេយ្យន្តិ ។ សោ ខោ អហំ ភិក្ខវេ យោ ចាយំ កាមវិតក្កោ យោ ច ព្យាបាទវិតក្កោ យោ ច វិហឹសាវិតក្កោ ឥមំ ឯកំ ភាគមកាសឹ ។ យោ ចាយំ នេក្ខម្មវិតក្កោ យោ ច អព្យាបាទវិតក្កោ យោ ច អវិហឹសាវិតក្កោ ឥមំ ទុតិយំ ភាគមកាសឹ ។ តស្ស មយ្ហំ ភិក្ខវេ ឯវំ អប្បមត្តស្ស អាតាបិនោ បហិតត្តស្ស វិហរតោ ឧប្បជ្ជតិ កាមវិតក្កោ ។ សោ ឯវំ បជានាមិ ឧប្បន្នោ ខោ មេ អយំ កាមវិតក្កោ

១ ម. ម. ទ្វិធាតិ ទិស្សតិ ។

# ទ្វេធាវិតក្កសូត្រទី ៩

(២៨១) ខ្ញុំបានស្តាប់មកហើយយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ សម័យនោះឯង ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះ ក៏ឆ្លើយតបពុទ្ធដីកានៃព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ។

(២៨២) ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ កាលដែលតថាគតនៅជាពោធិសត្វ មិនទាន់ត្រាស់ដឹងនៅឡើយ គឺក្នុងកាលមុនអំពីការត្រាស់ដឹង មានសេចក្តីត្រិះរិះដូច្នេះថា បើដូច្នោះមានតែអាត្មាអញត្រូវធ្វើវិតក្កៈឲ្យជាចំណែកពីរ ។ ម្នាលភិក្ខុទាំងឡាយ (លុះត្រិះរិះដូច្នេះហើយ) តថាគតនោះឯង ក៏ធ្វើនូវកាមវិតក្កៈ ព្យាបាទវិតក្កៈ និងវិហឹសាវិតក្កៈនេះឲ្យជាចំណែកទី ១ ធ្វើនូវនេក្ខម្មវិតក្កៈ អព្យាបាទវិតក្កៈ និងអវិហឹសាវិតក្កៈនេះឲ្យជាចំណែកទី ២ ។ ម្នាលភិក្ខុទាំងឡាយ កាលដែលតថាគតនោះ ជាអ្នកមិនប្រមាទ មានព្យាយាមជាគ្រឿងដុតនូវកិលេស មានចិត្តបញ្ជូនទៅយ៉ាងនេះហើយ កាមវិតក្កៈនោះ កើតឡើង តថាគត ដឹងច្បាស់យ៉ាងនេះថា កាមវិតក្កៈនេះ កើតឡើងដល់តថាគតហើយ

សោ ច ខោ អត្តព្យាពាធាយបិ សំវត្តតិ បរព្យាពាធាយបិ សំវត្តតិ ឧភយព្យាពាធាយបិ សំវត្តតិ បញ្ញានិរោធិកោ វិឃាតបក្ខិកោ អនិព្វានសំវត្តនិកោ អត្តព្យាពាធាយ សំវត្តតីតិបិ មេ ភិក្ខវេ បដិសញ្ចិក្ខតោ អត្ថំ គច្ឆតិ បរព្យាពាធាយ សំវត្តតីតិបិ មេ ភិក្ខវេ បដិសញ្ចិក្ខតោ អត្ថំ គច្ឆតិ ឧភយព្យាពាធាយ សំវត្តតីតិបិ មេ ភិក្ខវេ បដិសញ្ចិក្ខតោ អត្ថំ គច្ឆតិ បញ្ញានិរោធិកោ វិឃាតបក្ខិកោ អនិព្វានសំវត្តនិកោតិបិ មេ ភិក្ខវេ បដិសញ្ចិក្ខតោ អត្ថំ គច្ឆតិ ។ សោ ខោ អហំ ភិក្ខវេ ឧប្បន្នុប្បន្នំ កាមវិតក្កំ បជហមេវ វិនោទមេវ ព្យន្តមេវ(១) នំ អកាសឹ ។ តស្ស មយ្ហំ ភិក្ខវេ ឯវំ អប្បមត្តស្ស អាតាបិនោ

១ ឱ. ព្យន្តឹ ។



កាមវិតក្កៈនោះឯង តែងប្រព្រឹត្តទៅដើម្បីបៀតបៀនខ្លួនផង ប្រព្រឹត្តទៅដើម្បីបៀតបៀនបុគ្គលដទៃផង ប្រព្រឹត្តទៅដើម្បីបៀតបៀនទាំងពីរខាងគឺខ្លួនឯងនិងបុគ្គលដទៃផង (កាមវិតក្កៈនេះ) ធ្វើបញ្ញាឲ្យរលត់ ជាចំណែកនៃសេចក្តីចង្អៀតចង្អល់ មិនប្រព្រឹត្តទៅដើម្បីព្រះនិព្វានទេ ម្នាលភិក្ខុទាំងឡាយ កាលតថាគតពិចារណាឃើញថា កាមវិតក្កៈនេះតែងប្រព្រឹត្តទៅដើម្បីបៀតបៀនខ្លួនដូច្នេះ ក៏កាមវិតក្កៈនោះដល់នូវសេចក្តីវិនាសទៅ ម្នាលភិក្ខុទាំងឡាយ កាលតថាគតទើបតែពិចារណាឃើញថា កាមវិតក្កៈនេះ តែងប្រព្រឹត្តទៅដើម្បីបៀតបៀនបុគ្គលដទៃដូច្នេះ ក៏កាមវិតក្កៈនោះដល់នូវសេចក្តីវិនាសទៅ ម្នាលភិក្ខុទាំងឡាយ កាលតថាគតទើបតែពិចារណាឃើញ កាមវិតក្កៈនេះ តែងប្រព្រឹត្តទៅដើម្បីបៀតបៀនទាំងពីរខាង គឺខ្លួនឯងនិងបុគ្គលដទៃដូច្នេះ ក៏កាមវិតក្កៈនោះដល់នូវសេចក្តីវិនាសទៅ ម្នាលភិក្ខុទាំងឡាយ តថាគតពិចារណាឃើញថា កាមវិតក្កៈនេះជាធម៌ធ្វើបញ្ញាឲ្យរលត់ ជាចំណែកនៃសេចក្តីចង្អៀតចង្អល់ មិនប្រព្រឹត្តទៅដើម្បីព្រះនិព្វានដូច្នេះ កាមវិតក្កៈនោះដល់នូវសេចក្តីវិនាសទៅ ។ ម្នាលភិក្ខុទាំងឡាយ ទើបតថាគតនោះលះបង់ដកបន្ទោបង់នូវកាមវិតក្កៈដែលកើតឡើងហើយ ៗ ធ្វើកាមវិតក្កៈនោះមិនឲ្យសេសសល់ទៅ ។ ម្នាលភិក្ខុទាំងឡាយ តថាគតនោះជាអ្នកមិនប្រមាទ មានព្យាយាមដុតកំដៅកិលេស

បហិតត្តស្ស វិហរតោ ឧប្បជ្ជតិ ព្យាបាទវិតក្កោ ។ បេ ។ ឧប្បជ្ជតិ វិហឹសាវិតក្កោ សោ ឯវំ បជានាមិ ឧប្បន្នោ ខោ មេ អយំ វិហឹសាវិតក្កោ សោ ច ខោ អត្តព្យាពាធាយបិ សំវត្តតិ បរព្យាពាធាយបិ សំវត្តតិ ឧភយព្យាពាធាយបិ សំវត្តតិ បញ្ញានិរោធិកោ វិឃាតបក្ខិកោ អនិព្វានសំវត្តនិកោ អត្តព្យាពាធាយ សំវត្តតីតិបិ មេ ភិក្ខវេ បដិសញ្ចិក្ខតោ អព្ភត្ថំ គច្ឆតិ បរព្យាពាធាយ សំវត្តតីតិបិ មេ ភិក្ខវេ បដិសញ្ចិក្ខតោ អព្ភត្ថំ គច្ឆតិ ឧភយព្យាពាធាយ សំវត្តតីតិបិ មេ ភិក្ខវេ បដិសញ្ចិក្ខតោ អព្ភត្ថំ គច្ឆតិ បញ្ញានិរោធិកោ វិឃាតបក្ខិកោ អនិព្វានសំវត្តនិកោតិបិ មេ ភិក្ខវេ បដិសញ្ចិក្ខតោ អព្ភត្ថំ គច្ឆតិ ។



មានចិត្តបញ្ជូនទៅហើយ នៅយ៉ាងនេះ ព្យាបាទវិតក្កៈ នោះក៏កើតឡើង ។ បេ ។ វិហឹសាវិតក្កៈនោះក៏កើតឡើង តថាគតដឹងច្បាស់យ៉ាងនេះថា វិហឹសាវិតក្កៈនេះ កើតឡើងដល់តថាគតហើយ គឺវិហឹសាវិតក្កៈនោះឯងតែងប្រព្រឹត្តទៅ ដើម្បីបៀតបៀនខ្លួនឯងផង ប្រព្រឹត្តទៅ ដើម្បីបៀតបៀនបុគ្គលដទៃផង ប្រព្រឹត្តទៅ ដើម្បីបៀតបៀនទាំងពីរខាង គឺខ្លួនឯងនិងបុគ្គលដទៃផង ជាធម៌ធ្វើបញ្ញាឲ្យរលត់ ជាចំណែកនៃសេចក្តីចង្អៀតចង្អល់ មិនប្រព្រឹត្តទៅ ដើម្បីព្រះនិព្វាន ម្នាលភិក្ខុទាំងឡាយ កាលតថាគត ទើបតែនឹងពិចារណាថា វិហឹសាវិតក្កៈនេះ តែងប្រព្រឹត្តទៅ ដើម្បីបៀតបៀនខ្លួនដូច្នេះ វិហឹសាវិតក្កៈនោះដល់នូវសេចក្តីវិនាសទៅ ម្នាលភិក្ខុទាំងឡាយ កាលតថាគតពិចារណាថា វិហឹសាវិតក្កៈនេះតែងប្រព្រឹត្តទៅដើម្បីបៀតបៀននូវបុគ្គលដទៃដូច្នេះ វិហឹសាវិតក្កៈនោះក៏ដល់នូវសេចក្តីវិនាសទៅ ម្នាលភិក្ខុទាំងឡាយ កាលតថាគតពិចារណាឃើញថា វិហឹសាវិតក្កៈនេះ តែងប្រព្រឹត្តទៅដើម្បីបៀតបៀនទាំងពីរខាងគឺខ្លួនឯងនិងបុគ្គលដទៃដូច្នេះ វិហឹសាវិតក្កៈនោះ ក៏ដល់នូវសេចក្តីវិនាសទៅ ម្នាលភិក្ខុទាំងឡាយ កាលតថាគតពិចារណាឃើញថា វិហឹសាវិតក្កៈនេះជាធម៌ធ្វើបញ្ញាឲ្យរលត់ ជាចំណែកនៃសេចក្តីចង្អៀតចង្អល់ មិនប្រព្រឹត្តទៅដើម្បីព្រះនិព្វានដូច្នេះ វិហឹសាវិតក្កៈនោះ ក៏ដល់នូវសេចក្តីវិនាសទៅ ។

សោ ខោ អហំ ភិក្ខវេ ឧប្បន្នុប្បន្នំ វិហឹសាវិតក្កំ បជហមេវ វិនោទមេវ ព្យន្តមេវ នំ អកាសឹ ។ យញ្ញទេវ ភិក្ខវេ ភិក្ខុ ពហុលមនុវិតក្កេតិ អនុវិចារេតិ តថា តថា នតិ ហោតិ ចេតសោ ។ កាមវិតក្កញ្ចេ ភិក្ខវេ ភិក្ខុ ពហុលមនុវិតក្កេតិ អនុវិចារេតិ បហាសិ នេក្ខម្មវិតក្កំ កាមវិតក្កំ ពហុលមកាសិ តស្ស តំ កាមវិតក្កាយ ចិត្តំ នមតិ ។ ព្យាបាទវិតក្កញ្ចេ ភិក្ខវេ ភិក្ខុ... ។ វិហឹសាវិតក្កញ្ចេ ភិក្ខវេ ភិក្ខុ ពហុលមនុវិតក្កេតិ អនុវិចារេតិ បហាសិ អវិហឹសាវិតក្កំ វិហឹសាវិតក្កំ ពហុលមកាសិ តស្ស តំ វិហឹសាវិតក្កាយ ចិត្តំ នមតិ ។ សេយ្យថាបិ ភិក្ខវេ វស្សានំ បច្ឆិមេ មាសេ សរទសមយេ កិដ្ឋសម្ពាធេ គោបាលកោ គាវោ រក្ខេយ្យ សោ តា គាវោ តតោ តតោ ទណ្ឌេន អាកោដេយ្យ បដិកោដេយ្យ សន្និរុន្ធេយ្យ សន្និវារេយ្យ ។ តំ កិស្ស ហេតុ ។ បស្សតិ ហិ សោ ភិក្ខវេ គោបាលកោ



ម្នាលភិក្ខុទាំងឡាយ តថាគតក៏លះបង់ បន្ទោបង់នូវវិហឹសាវិតក្កៈដែលកើតឡើងហើយ ៗ ធ្វើវិហឹសាវិតក្កៈនោះមិនឲ្យសេសសល់ទៅ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុត្រិះរិះរឿយ ៗ ពិចារណារឿយ ៗ នូវអារម្មណ៍ដ៏ច្រើនដោយអាការណា ៗ ចិត្តក៏បង្អោនទៅកាន់អារម្មណ៍នោះដោយអាការនោះ ៗ ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុត្រិះរិះរឿយ ៗ ពិចារណារឿយ ៗ នូវកាមវិតក្កៈឲ្យច្រើនហើយ ក៏ឈ្មោះថាលះបង់នូវនេក្ខម្មវិតក្កៈ បើធ្វើនូវកាមវិតក្កៈឲ្យច្រើនហើយ ចិត្តរបស់ភិក្ខុនោះនឹងឱនទៅ ដើម្បីកាមវិតក្កៈ ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុ (ត្រិះរិះរឿយ ៗ ពិចារណារឿយ ៗ) នូវព្យាបាទវិតក្កៈ... ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុត្រិះរិះរឿយ ៗ ពិចារណារឿយ ៗ នូវវិហឹសាវិតក្កៈឲ្យច្រើនហើយ ឈ្មោះថា លះបង់នូវអវិហឹសាវិតក្កៈ បើធ្វើនូវវិហឹសាវិតក្កៈឲ្យច្រើនហើយ ចិត្តរបស់ភិក្ខុនោះនឹងឱនទៅ ដើម្បីវិហឹសាវិតក្កៈ ។ ម្នាលភិក្ខុទាំងឡាយ ដូចជាគង្វាលគោ រក្សាគោទាំងឡាយ ក្នុងទីចង្អៀតដោយសំណាបក្នុងសរទសម័យ គឺខែជាខាងចុងនៃវស្សានរដូវ គង្វាលគោនោះវាយគោ ហៀងប្រមូលនូវគោទាំងឡាយអំពីទីចង្អៀតនោះ ៗ ដោយដំបង ។ ដំណើរនោះព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថា គង្វាលគោនោះឃើញនូវទោស គឺការ

តតោនិទានំ វធំ វា ពន្ធំ វា ជានឹ វា គរហំ វា ឯវមេវ ខោ អហំ ភិក្ខវេ អទ្ទសំ អកុសលានំ ធម្មានំ អាទីនវំ ឱការំ សង្កិលេសំ កុសលានំ ធម្មានំ នេក្ខម្មេ អានិសំសំ វោទានបក្ខំ ។ តស្ស មយ្ហំ ភិក្ខវេ ឯវំ អប្បមត្តស្ស អាតាបិនោ បហិតត្តស្ស វិហរតោ ឧប្បជ្ជតិ នេក្ខម្មវិតក្កោ ។ សោ ឯវំ បជានាមិ ឧប្បន្នោ ខោ មេ អយំ នេក្ខម្មវិតក្កោ ។ សោ ច ខោ នេវ អត្តព្យាពាធាយ សំវត្តតិ ន បរព្យាពាធាយ សំវត្តតិ ន ឧភយព្យាពាធាយ សំវត្តតិ បញ្ញាវុឌ្ឍិកោ អវិឃាតបក្ខិកោ និព្វានសំវត្តនិកោ ។ រត្តិញ្ចេបិ នំ ភិក្ខវេ អនុវិតក្កេយ្យំ អនុវិចារេយ្យំ នេវ តតោនិទានំ ភយំ សមនុបស្សាមិ ។ ទិវសញ្ចេបិ នំ ភិក្ខវេ អនុវិតក្កេយ្យំ អនុវិចារេយ្យំ នេវ តតោនិទានំ ភយំ សមនុបស្សាមិ ។ រត្តិន្ទិវញ្ចេបិ នំ ភិក្ខវេ



សម្លាប់ ការចាប់ចង សេចក្តីខាតៈ និងពាក្យតិះដៀល ព្រោះតែគោស៊ីស្រូវរបស់បុគ្គលដទៃនោះជាហេតុ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ តថាគតបានឃើញនូវទោសដ៏ថោកទាប សៅហ្មង របស់អកុសលធម៌ទាំងឡាយ និងអានិសង្សនៃសេចក្តីផូរផង់ក្នុងនេក្ខម្មៈ របស់កុសលធម៌ទាំងឡាយយ៉ាងនោះឯង ម្នាលភិក្ខុទាំងឡាយ កាលដែលតថាគតនោះជាអ្នកមិនប្រមាទ មានព្យាយាមជាគ្រឿងដុតនូវកិលេស មានចិត្តបញ្ជូនទៅយ៉ាងនេះហើយ នេក្ខម្មវិតក្កៈកើតឡើង តថាគតក៏ដឹងច្បាស់យ៉ាងនេះថា នេក្ខម្មវិតក្កៈនេះកើតឡើងដល់អាត្មាអញហើយ នេក្ខម្មវិតក្កៈនោះឯង មិនប្រព្រឹត្តទៅដើម្បីបៀតបៀនខ្លួនឯងទេ មិនប្រព្រឹត្តទៅដើម្បីបៀតបៀនបុគ្គលដទៃទេ មិនប្រព្រឹត្តទៅដើម្បីបៀតបៀនទាំងពីរខាងគឺខ្លួនឯងនិងបុគ្គលដទៃទេ ជាវិតក្កៈធ្វើប្រាជ្ញាឲ្យចំរើន ជាចំណែកនៃសេចក្តីមិនចង្អៀតចង្អល់ ប្រព្រឹត្តទៅដើម្បីព្រះនិព្វាន ម្នាលភិក្ខុទាំងឡាយ បើទុកជាតថាគតត្រិះរិះរឿយ ៗ ពិចារណារឿយ ៗ នូវនេក្ខម្មវិតក្កៈនោះអស់មួយរាត្រី តថាគតក៏មិនបានឃើញភ័យព្រោះមាននេក្ខម្មវិតក្កៈនោះជាហេតុទេ ។ ម្នាលភិក្ខុទាំងឡាយ បើទុកជាតថាគតត្រិះរិះរឿយ ៗ ពិចារណារឿយ ៗ នូវនេក្ខម្មវិតក្កៈនោះអស់មួយថ្ងៃ ក៏តថាគតមិនបានឃើញនូវភ័យព្រោះមាននេក្ខម្មវិតក្កៈនោះជាហេតុឡើយ ។ ម្នាលភិក្ខុទាំងឡាយ

អនុវិតក្កេយ្យំ អនុវិចារេយ្យំ នេវ តតោនិទានំ ភយំ សមនុបស្សាមិ ។ បេ ។ អបិច ខោ មេ អតិចិរំ អនុ-វិតក្កយតោ អនុវិចារយតោ កាយោ កិលមេយ្យ កាយេ កិលន្តេ[១] ចិត្តំ ឩហញ្ញេយ្យ[២] ឩហតេ ចិត្តេ អារា ចិត្តំ សមាធិម្ហាតិ សោ ខោ អហំ ភិក្ខវេ អជ្ឈត្តមេវ ចិត្តំ សណ្ឋាបេមិ សន្និសាទេមិ ឯកោទឹ[៣] ករោមិ សមាទហាមិ តំ កិស្ស ហេតុ មា មេ ចិត្តំ ឩហញ្ញីតិ[៤] ។ តស្ស មយ្ហំ ភិក្ខវេ ឯវំ អប្បមត្តស្ស អាតាបិនោ បហិតត្តស្ស វិហរតោ ឧប្បជ្ជតិ អព្យាបាទវិតក្កោ ។ បេ ។ ឧប្បជ្ជតិ អវិ-ហឹសាវិតក្កោ សោ ឯវំ បជានាមិ ឧប្បន្នោ ខោ មេ អយំ អវិហឹសាវិតក្កោ សោ ច ខោ នេវ អត្តព្យាពាធាយ សំវត្តតិ ន បរព្យាពាធាយ សំវត្តតិ ន ឧភយព្យាពាធាយ សំវត្តតិ បញ្ញាវុឌ្ឍិកោ អវិឃា-តបក្ខិកោ និព្វានសំវត្តនិកោ រត្តិញ្ចេបិ នំ ភិក្ខវេ

---

១ ម. កិលមថេ ។ ២ ឱ.ម. ឧហញ្ញេយ្យ ។ ៣ ឱ. ឯកោទិំ ។ ៤ ឱ. ឧហនីតិ ម. ឧហេតីតិ ។



បើទុកជាតថាគតត្រិះរិះរឿយ ៗ ពិចារណារឿយ ៗ ពេញមួយថ្ងៃក្តី ពេញមួយយប់ពេញថ្ងៃ ក៏តថាគតមិនឃើញភ័យ ព្រោះមានវិតក្កៈនោះជាហេតុឡើយ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត តថាគតនោះឯងគិតថា កាលតថាគតត្រិះរិះរឿយ ៗ ពិចារណារឿយ ៗ យូរពេកទៅ កាយក៏លំបាក កាលបើកាយលំបាកហើយ ចិត្តក៏ញាប់ កាលបើចិត្តញាប់ហើយ ចិត្តក៏ឆ្ងាយអំពីសមាធិ ដើម្បីតម្កល់ចិត្តឲ្យខ្ជាប់នៅខាងក្នុង ធ្វើចិត្តឲ្យស្ងប់ ធ្វើចិត្តឲ្យមានអារម្មណ៍តែមួយ តាំងចិត្តឲ្យមាំ ដំណើរនោះព្រោះហេតុអ្វី ព្រោះតថាគតយល់ថា ចិត្តរបស់តថាគតកុំរវើរវាយឡើយ ។ ម្នាលភិក្ខុទាំងឡាយ កាលបើតថាគតជាអ្នកមិនប្រមាទ មានព្យាយាមដុតកំដៅកិលេស មានចិត្តបញ្ជូនទៅយ៉ាងនេះហើយ អព្យាបាទវិតក្កៈក៏កើតឡើង ។ បេ ។ អវិហឹសាវិតក្កៈក៏កើតឡើង តថាគតនោះដឹងច្បាស់យ៉ាងនេះថា អវិហឹសាវិតក្កៈនេះកើតឡើងដល់អាត្មាអញហើយ ក៏ឯអវិហឹសាវិតក្កៈនោះឯង មិនបានប្រព្រឹត្តទៅដើម្បីបៀតបៀនខ្លួនឯងទេ មិនប្រព្រឹត្តទៅដើម្បីបៀតបៀនបុគ្គលដទៃទេ មិនប្រព្រឹត្តទៅដើម្បីបៀតបៀនទាំងពីរខាងគឺខ្លួនឯងនិងបុគ្គលដទៃទេ ជាវិតក្កៈធ្វើបញ្ញាឲ្យចំរើន ជាចំណែកនៃសេចក្តីមិនចង្អៀតចង្អល់ ប្រព្រឹត្តទៅដើម្បីព្រះនិព្វាន ម្នាលភិក្ខុទាំងឡាយ

អនុវិតក្កេយ្យំ អនុវិចារេយ្យំ នេវ តតោនិទានំ ភយំ សមនុបស្សាមិ ។ ទិវសញ្ចេបិ នំ ភិក្ខវេ អនុវិតក្កេយ្យំ អនុវិចារេយ្យំ នេវ តតោនិទានំ ភយំ សមនុបស្សាមិ ។ រត្តិន្ទិវញ្ចេបិ នំ ភិក្ខវេ អនុវិតក្កេយ្យំ អនុវិចារេយ្យំ នេវ តតោនិទានំ ភយំ សមនុបស្សាមិ ។ អបិច ខោ មេ អតិចិរំ អនុវិតក្កយតោ អនុវិចារយតោ កាយោ កិលមេយ្យ កាយេ កិលន្តេ ចិត្តំ ឩហញ្ញេយ្យ ឩហតេ ចិត្តេ អារា ចិត្តំ សមាធិម្ហាតិ ។ សោ ខោ អហំ ភិក្ខវេ អជ្ឈត្តមេវ ចិត្តំ សណ្ឋបេមិ សន្និសីទេមិ ឯកោទឹ ករោមិ សមាទហាមិ ។ តំ កិស្ស ហេតុ មា មេ ចិត្តំ ឩហញ្ញីតិ ។ យញ្ញទេវ ភិក្ខវេ ភិក្ខុ ពហុលមនុវិតក្កេតិ អនុវិចារេតិ តថា តថា នតិ ហោតិ ចេតសោ ។ នេក្ខម្មវិតក្កំ ចេ ភិក្ខវេ ភិក្ខុ ពហុលមនុវិតក្កេតិ អនុវិចារេតិ



បើទុកជាតថាគតត្រិះរិះរឿយ ៗ ពិចារណារឿយ ៗ នូវអវិហឹសាវិតក្កៈនោះ អស់ ១ រាត្រីហើយ ក៏តថាគតមិនបានឃើញនូវភ័យ ព្រោះមានអវិហឹសាវិតក្កៈនោះជាហេតុឡើយ ។ ម្នាលភិក្ខុទាំងឡាយ បើទុកជាតថាគតត្រិះរិះរឿយ ៗ ពិចារណារឿយ ៗ នូវអវិហឹសាវិតក្កៈនោះអស់១ថ្ងៃ ក៏តថាគតមិនបានឃើញនូវភ័យ ព្រោះមានអវិហឹសាវិតក្កៈនោះជាហេតុឡើយ ។ ម្នាលភិក្ខុទាំងឡាយ បើទុកជាតថាគតត្រិះរិះរឿយ ៗ ពិចារណារឿយ ៗ នូវអវិហឹសាវិតក្កៈនោះ អស់យប់និងថ្ងៃ ក៏តថាគតមិនបានឃើញនូវភ័យ ព្រោះមានអវិហឹសាវិតក្កៈនោះជាហេតុឡើយ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត តថាគតនោះឯងនឹកថា កាលអាត្មាអញត្រិះរិះរឿយ ៗ ពិចារណារឿយ ៗ យូរពេកនៅ កាយក៏លំបាក កាលបើកាយលំបាកហើយ ចិត្តក៏ភ្ញាក់ កាលបើចិត្តភ្ញាក់ហើយ ចិត្តក៏ឆ្ងាយអំពីសមាធិ ទើបដម្កល់ចិត្តឲ្យនឹងនៅខាងក្នុង ធ្វើចិត្តឲ្យស្ងប់ ធ្វើចិត្តឲ្យមានអារម្មណ៍តែមួយ តាំងចិត្តឲ្យមាំ ដំណើរនោះ ព្រោះហេតុអ្វី ព្រោះតថាគតយកចិត្តថា ចិត្តរបស់តថាគត កុំភ្ញាក់ឡើយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុត្រិះរិះរឿយ ៗ ពិចារណារឿយ ៗ នូវអារម្មណ៍ដ៏ច្រើនដោយអាការណា ៗ ចិត្តក៏ឱនទៅកាន់អារម្មណ៍នោះ ដោយអាការនោះ ៗ ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុត្រិះរិះរឿយ ៗ ពិចារណារឿយ ៗ នូវនេក្ខម្មវិតក្កៈដោយច្រើនហើយ

បហាសិ កាមវិតក្កំ នេក្ខម្មវិតក្កំ ពហុលមកាសិ តស្ស តំ នេក្ខម្មវិតក្កាយ ចិត្តំ នមតិ ។ អព្យាបាទវិតក្កំ ចេ ភិក្ខវេ ភិក្ខុ... ។ អវិហឹសាវិតក្កំ ចេ ភិក្ខវេ ភិក្ខុ ពហុលមនុវិតក្កេតិ អនុវិចារេតិ បហាសិ វិហឹសាវិតក្កំ អវិហឹសាវិតក្កំ ពហុលមកាសិ តស្ស តំ អវិហឹសាវិតក្កាយ ចិត្តំ នមតិ ។ សេយ្យថាបិ ភិក្ខវេ គិម្ហានំ បច្ឆិមេ មាសេ សព្វសស្សេសុ គាមន្តសម្ភតេសុ[១] គោបាលកោ គាវោ រក្ខេយ្យ តស្ស រុក្ខមូលគតស្ស វា អព្ភោកាសគតស្ស វា សតិករណីយមេវ ហោតិ ឯតា គាវោតិ ឯវមេវ ខោ ភិក្ខវេ សតិករណីយមេវ អហោសិ ឯតេ ធម្មាតិ ។

[២៨៣] អារទ្ធំ ខោ បន មេ ភិក្ខវេ វីរិយំ អហោសិ អសល្លីនំ ឧបដ្ឋិតា សតិ អប្បម្មុដ្ឋា[២] បស្សទ្ធោ កាយោ អសារទ្ធោ សមាហិតំ ចិត្តំ ឯកគ្គំ សោ ខោ អហំ ភិក្ខវេ វិវិច្ចេវ

១ ឱ.ម. សព្វសស្សេសុ គាមន្តសម្ភតេសុ ។ ២ ឱ. អសម្មុដ្ឋា ។ ម. អសម្មុដ្ឋា ។



ឈ្មោះថា លះបង់នូវកាមវិតក្កៈ ហើយធ្វើនេក្ខម្មវិតក្កៈឲ្យច្រើន ចិត្តរបស់ភិក្ខុនោះ រមែងឱនទៅដើម្បីនេក្ខម្មវិតក្កៈ ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុត្រិះរិះរឿយ ៗ នូវអព្យាបាទវិតក្កៈ... ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុត្រិះរិះរឿយ ៗ ពិចារណារឿយ ៗ នូវអវិហឹសាវិតក្កៈឲ្យច្រើនហើយ ឈ្មោះថា លះបង់នូវវិហឹសាវិតក្កៈ ធ្វើអវិហឹសាវិតក្កៈឲ្យច្រើន ចិត្តរបស់ភិក្ខុនោះ រមែងឱនទៅដើម្បីអវិហឹសាវិតក្កៈ ។ ម្នាលភិក្ខុទាំងឡាយ ដូចនាយគង្វាលគោ រក្សាគោទាំងឡាយ ក្នុងស្រូវទាំងពួងដែលមាននៅក្នុងស្រុក ក្នុងខែជាខាងចុងនៃគិម្ហរដូវ គង្វាលគោនោះ ទោះចូលទៅកាន់ទីជិតឈើឬចូលទៅនៅក្នុងទីវាល គួរធ្វើស្មារតីថា គោទាំងឡាយមានប្រមាណប៉ុណ្ណោះ សេចក្តីនោះយ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ តថាគតធ្វើស្មារតីថា ធម៌ទាំងឡាយមានប្រមាណប៉ុណ្ណោះ សេចក្តីនេះក៏យ៉ាងនោះដែរ ។

[១៨៣] ម្នាលភិក្ខុទាំងឡាយ សេចក្តីព្យាយាមដែលតថាគតបានផ្តើមហើយ មិនបន្ធូរបន្ថយឡើយ ទាំងស្មារតីក៏តថាគតប្រុងមិនឲ្យមានភ្លាត់ កាយសោតក៏ស្ងប់រម្ងាប់មិនក្រវល់ក្រវាយ ចិត្តក៏នឹងល្អ ជាចិត្តមានអារម្មណ៍តែមួយ ម្នាលភិក្ខុទាំងឡាយ លុះតថាគតឯង ស្ងាត់

កាមេហិ វិវិច្ច អកុសលេហិ ធម្មេហិ សវិតក្កំ សវិចារំ វិវេកជំ បីតិសុខំ បឋមំ ឈានំ ឧបសម្បជ្ជ វិហាសឹ ។ វិតក្កវិចារានំ វូបសមា អជ្ឈត្តំ សម្បសាទនំ ចេតសោ ឯកោទិភាវំ អវិតក្កំ អវិចារំ សមាធិជំ បីតិសុខំ ទុតិយំ ឈានំ ។ បេ ។ តតិយំ ឈានំ... ។ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហាសឹ ។ សោ ឯវំ សមាហិតេ ចិត្តេ បរិសុទ្ធេ បរិយោទាតេ អនង្គណេ វិគតូបក្កិលេសេ មុទុភូតេ កម្មនិយេ ឋិតេ អានេញ្ជប្បត្តេ បុព្វេនិវាសានុស្សតិញាណាយ ចិត្តំ អភិនិន្នាមេសឹ ។ សោ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរាមិ សេយ្យថីទំ ឯកម្បិ ជាតឹ ទ្វេបិ ជាតិយោ ។ បេ ។ ឥតិ សាការំ សឧទ្ទេសំ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរាមិ ។ អយំ ខោ មេ ភិក្ខវេ រត្តិយា បឋមេ យាមេ បឋមា វិជ្ជា អធិគតា អវិជ្ជា វិហតា វិជ្ជា ឧប្បន្នា តមោ វិហតោ អាលោកោ ឧប្បន្នោ យថាតំ អប្បមត្តស្ស អាតាបិនោ បហិតត្តស្ស វិហរតោ ។



ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយហើយ ចូលកាន់បឋមជ្ឈាន ប្រកបដោយវិតក្កៈ វិចារៈ បីតិ សុខៈ ដែលកើតអំពីសេចក្តីស្ងប់ស្ងាត់ជាអារម្មណ៍ ។ លុះតថាគតបានដល់ទុតិយជ្ឈាន ជាធម្មជាតកើតមានក្នុងសន្តាន ចិត្តប្រកបដោយសេចក្តីជ្រះថ្លា មានសភាពជាចិត្តខ្ពស់ឯក មិនមានវិតក្កៈមិនមានវិចារៈ មានតែបីតិនិងសុខៈដែលកើតអំពីសមាធិ ព្រោះរម្ងាប់បង់នូវវិតក្កៈនិងវិចារៈ ។បេ។ ចូលតតិយជ្ឈាន... ។ ចូលចតុត្ថជ្ឈាន ។ កាលដែលចិត្តខ្ជាប់ខ្ជួន បរិសុទ្ធ ផូរផង់ មិនមានទីទួលគឺកិលេស ប្រាសចាកសេចក្តីសៅហ្មង ជាចិត្តទន់ គួរដល់កម្ម ជាចិត្តនឹងធឹង មិនបានញាប់ញ័រ យ៉ាងនេះហើយ តថាគតនោះក៏បង្អោនចិត្តទៅក្នុងបុព្វេនិវាសានុស្សតិញ្ញាណ តថាគតនោះរលឹកនូវជាតិដែលអាស្រ័យនៅពីមុនមកបានច្រើនប្រការ គឺរលឹកបាន ១ ជាតិខ្លះ ២ ជាតិខ្លះ ។បេ។ រលឹកនូវជាតិដែលអាស្រ័យនៅពីមុនមកបានច្រើនប្រការ ព្រមទាំងអាការៈ ព្រមទាំងឧទ្ទេសដូច្នេះឯង ។ ម្នាលភិក្ខុទាំងឡាយ បឋមវិជ្ជានេះឯងហើយ ដែលតថាគត បានត្រាស់ដឹងក្នុងបឋមយាមនៃរាត្រី លុះដល់សេចក្តីល្ងង់ខ្លៅបាត់ទៅ សេចក្តីចេះដឹងក៏កើតប្រាកដឡើង ងងឹតខ្លាក់បាត់ទៅ ពន្លឺក៏កើតឡើងដល់តថាគតដែលកំពុងអង្គុយប្រុងស្មារតីមិនប្រហែសធ្វេស ទំប្រឹងដុតបំផ្លាញកិលេស មានចិត្តមូលស្លុង (ឥតមាននឹកនាដល់កាយនិងជីវិតឡើយ) ដូចជាបណ្ឌិតទាំងឡាយដែលបាននូវបឋមវិជ្ជានោះដូច្នោះដែរ ។

សោ ឯវំ សមាហិតេ ចិត្តេ បរិសុទ្ធេ បរិយោទាតេ អនង្គណេ វិគតូបក្កិលេសេ មុទុភូតេ កម្មនិយេ ឋិតេ អានេញ្ជប្បត្តេ សត្តានំ ចុតូបបាតញាណាយ ចិត្តំ អភិនិន្នាមេសឹ សោ ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន សត្តេ បស្សាមិ ចវមានេ ឧបបជ្ជមានេ ។បេ។ ឥមេ វត ភោន្តោ សត្តា កាយទុច្ចរិតេន សមន្នាគតា ។បេ។ ឥតិ ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន សត្តេ បស្សាមិ ចវមានេ ឧបបជ្ជមានេ ហីនេ បណីតេ សុវណ្ណេ ទុព្វណ្ណេ សុគតេ ទុគ្គតេ យថាកម្មូបគេ សត្តេ បជានាមិ ។ អយំ ខោ មេ ភិក្ខវេ រត្តិយា មជ្ឈិមេ យាមេ ទុតិយា វិជ្ជា អធិគតា អវិជ្ជា វិហតា វិជ្ជា ឧប្បន្នា តមោ វិហតោ អាលោកោ ឧប្បន្នោ យថាតំ អប្បមត្តស្ស អាតាបិនោ បហិតត្តស្ស វិហរតោ ។ សោ ឯវំ សមាហិតេ ចិត្តេ បរិសុទ្ធេ បរិយោទាតេ អនង្គណេ



កាលដែលចិត្តខ្ជាប់ខ្ជួន បរិសុទ្ធ ផូរផង់មិនមានទីទួលគឺកិលេស ប្រាសចាកសេចក្តីសៅហ្មង ជាចិត្តទន់ គួរដល់កម្ម ជាចិត្តនឹងធឹង មិនបានញាប់ញ័រយ៉ាងនេះហើយ ទើបតថាគតបង្អោនចិត្តទៅក្នុងចុតូបបាតញ្ញាណ (ប្រាជ្ញាដែលលើកឃើញនូវចុតិនិងបដិសន្ធិ) នៃសត្វទាំងឡាយ តថាគតនោះពិចារណាមើលនូវពួកសត្វ ដែលច្យុតទៅ កើតឡើង ដោយទិព្វចក្ខុដ៏បរិសុទ្ធ កន្លងនូវចក្ខុនៃមនុស្ស ។បេ។ ថា អើហ្ន៎ សត្វទាំងឡាយអម្បាលនេះ ប្រកបដោយកាយទុច្ចរិត ។បេ។ តថាគតពិចារណាមើលនូវពួកសត្វដែលច្យុតទៅ និងកើតឡើង ជាសត្វថោកទាបនិងឧត្តម មានសម្បុរល្អនិងអាក្រក់ ទៅកាន់សុគតិនិងទុគ្គតិ ដោយទិព្វចក្ខុដ៏បរិសុទ្ធកន្លងនូវចក្ខុជារបស់មនុស្ស ក៏ដឹងច្បាស់នូវពួកសត្វដែលអន្ទោលទៅតាមកម្មដោយប្រការដូច្នេះឯង ។ ម្នាលភិក្ខុទាំងឡាយ វិជ្ជាទី ២ នេះឯងហើយ ដែលតថាគតបានត្រាស់ដឹងហើយក្នុងមជ្ឈិមយាមនៃរាត្រី លុះដល់សេចក្តីល្ងង់ខ្លៅបាត់ទៅ សេចក្តីចេះដឹងក៏ប្រាកដកើតឡើង ងងឹតក៏បាត់ទៅ ពន្លឺក៏កើតឡើងដល់តថាគត ដែលកំពុងប្រុងស្មារតី មិនប្រហែសធ្វេស រំលើងដុតបំផ្លាញកិលេស មានចិត្តមុតស្លុង (ឥតមានអាល័យដល់កាយនិងជីវិតឡើយ) ដូចជាបណ្ឌិតទាំងឡាយដែលបាននូវវិជ្ជាទី ២ នោះដូច្នោះដែរ ។ កាលដែលចិត្តខ្ជាប់ខ្ជួន បរិសុទ្ធ ផូរផង់មិនមានទីទួលគឺកិលេស

វិគតូបក្កិលេសេ មុទុភូតេ កម្មនិយេ ឋិតេ អានេញ្ជប្បត្តេ អាសវានំ ខយញាណាយ ចិត្តំ អភិនិន្នាមេសឹ សោ ឥទំ ទុក្ខន្តិ យថាភូតំ អព្ភញ្ញាសឹ អយំ ទុក្ខសមុទយោតិ យថាភូតំ អព្ភញ្ញាសឹ អយំ ទុក្ខនិរោធោតិ យថាភូតំ អព្ភញ្ញាសឹ អយំ ទុក្ខនិរោធគាមិនី បដិបទាតិ យថាភូតំ អព្ភញ្ញាសឹ ឥមេ អាសវាតិ យថាភូតំ អព្ភញ្ញាសឹ អយំ អាសវសមុទយោតិ យថាភូតំ អព្ភញ្ញាសឹ អយំ អាសវនិរោធោតិ យថាភូតំ អព្ភញ្ញាសឹ អយំ អាសវនិរោធគាមិនី បដិបទាតិ យថាភូតំ អព្ភញ្ញាសឹ តស្ស មេ ឯវំ ជានតោ ឯវំ បស្សតោ កាមាសវាបិ ចិត្តំ វិមុច្ចិត្ថ ភវាសវាបិ ចិត្តំ វិមុច្ចិត្ថ អវិជ្ជាសវាបិ ចិត្តំ វិមុច្ចិត្ថ វិមុត្តស្មឹ វិមុត្តមិតិ ញាណំ អហោសិ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ





ប្រាសចាកសេចក្តីសៅហ្មង ជាចិត្តទន់ សមគួរដល់កម្ម ជាចិត្តនឹងនឹង មិនញាប់ញ័រយ៉ាងនេះហើយ តថាគតក៏បង្អោនចិត្តទៅ ដើម្បីអាសវក្ខយញ្ញាណ (ប្រាជ្ញាដែលជ្រាបច្បាស់នូវកិរិយាអស់ទៅនៃអាសវធម៌ទាំងឡាយ) តថាគតនោះដឹងប្រាកដតាមពិតថា នេះជាទុក្ខ ដឹងប្រាកដតាមពិតថា នេះជាហេតុនាំឲ្យកើតទុក្ខ ដឹងប្រាកដតាមពិតថា នេះជាសេចក្តីរលត់ទុក្ខ ដឹងប្រាកដតាមពិតថា នេះជាបដិបទាឲ្យដល់នូវសេចក្តីរលត់ទុក្ខ ដឹងប្រាកដតាមពិតថា ធម៌ប៉ុណ្ណេះជាអាសវៈ ដឹងប្រាកដតាមពិតថា ធម៌នេះជាហេតុនាំឲ្យកើតអាសវៈ ដឹងប្រាកដតាមពិតថា នេះជាសេចក្តីរលត់នៃអាសវៈ ដឹងប្រាកដតាមពិតថា នេះជាបដិបទាឲ្យបានដល់នូវសេចក្តីរលត់នៃអាសវៈ កាលដែលតថាគតដឹងយ៉ាងនេះ ឃើញយ៉ាងនេះហើយ ចិត្តតថាគតក៏ផុតស្រឡះចាកកាមាសវៈ (គ្រឿងត្រាំគឺកាម) ផង ផុតស្រឡះចាកភវាសវៈ (គ្រឿងត្រាំគឺភព) ផង ផុតស្រឡះចាកអវិជ្ជាសវៈ (គ្រឿងត្រាំគឺអវិជ្ជា) ផង កាលបើចិត្តតថាគតផុតស្រឡះ (ចាកអាសវធម៌) ហើយ ប្រាជ្ញាក៏កើតប្រាកដថា អាត្មាអញផុតស្រឡះ(ចាកអាសវធម៌)ហើយ តថាគតដឹងច្បាស់ថា កំណើត(របស់អាត្មាអញ) អស់ហើយ ព្រហ្មចរិយធម៌ អាត្មាអញបានប្រព្រឹត្តគ្រប់គ្រាន់

កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ អព្ភញ្ញាសឹ ។ អយំ ខោ មេ ភិក្ខវេ រត្តិយា បច្ឆិមេ យាមេ តតិយា វិជ្ជា អធិគតា អវិជ្ជា វិហតា វិជ្ជា ឧប្បន្នា តមោ វិហតោ អាលោកោ ឧប្បន្នោ យថាតំ អប្បមត្តស្ស អាតាបិនោ បហិតត្តស្ស វិហរតោ ។

(២៦៨) សេយ្យថាបិ ភិក្ខវេ អរញ្ញេ បវនេ មហន្តំ និន្នំ បល្លលំ តមេនំ មហា មិគសង្ឃោ ឧបនិស្សាយ វិហរេយ្យ តស្ស កោចិទេវ បុរិសោ ឧប្បជ្ជេយ្យ អនត្ថកាមោ អហិតកាមោ អយោគក្ខេមកាមោ សោ យ្វាស្ស មគ្គោ ខេមោ សោវត្ថិកោ បីតិគមនីយោ តំ មគ្គំ បិទហេយ្យ វិវរេយ្យ កុម្មគ្គំ ឱទហេយ្យ ឱកចរំ ឋបេយ្យ ឱកចារិកំ ឯវញ្ហិ សោ ភិក្ខវេ មហា មិគសង្ឃោ អបរេន សមយេន អនយព្យសនំ អាបជ្ជេយ្យ ។ តស្សេវ ខោ បន ភិក្ខវេ មហាតោ មិគសង្ឃស្ស កោចិទេវ បុរិសោ ឧប្បជ្ជេយ្យ អត្ថកាមោ ហិតកាមោ យោគក្ខេមកាមោ សោ



ហើយ សោឡសកិច្ចក៏តថាគតធ្វើស្រេចហើយ កិច្ចដទៃក្រៅពីសោឡសកិច្ចនេះទៅទៀតមិនមានឡើយ ។ ម្នាលភិក្ខុទាំងឡាយ វិជ្ជាទី៣ នេះហើយ ដែលតថាគតបានត្រាស់ដឹងក្នុងបច្ឆិមយាមនៃរាត្រី លុះដល់អវិជ្ជាខ្ចាត់បាត់ទៅ វិជ្ជាក៏កើតឡើង ងងឹតខ្ចាត់បាត់ទៅ ពន្លឺក៏កើតឡើង ដល់តថាគតដែលកំពុងប្រុងស្មារតីមិនប្រហែសធ្វេស ខំប្រឹងដុតបំផ្លាញកិលេស មានចិត្តមូលស្ងួន (ឥតមានចំណងដល់កាយនិងជីវិតឡើយ) ដូចជាបណ្ឌិតទាំងឡាយដែលបាននូវវិជ្ជា ៣ ទុំដូច្នោះដែរ ។

(២៣៦) ម្នាលភិក្ខុទាំងឡាយ ដូចជាក្រពាំងទំនាបធំ ក្នុងដងព្រៃធំ មានពួកម្រឹគច្រើន ចូលទៅអាស្រ័យនៅទីក្រពាំងនោះ បុរសណាមួយដែលប្រាថ្នានូវសេចក្តីវិនាស មិនប្រាថ្នានូវប្រយោជន៍ មិនប្រាថ្នានូវសេចក្តីក្សេមដល់ពួកម្រឹគនោះ បុរសនោះក៏បិទផ្លូវដែលក្សេម ដែលប្រកបដោយសួស្តី នាំឲ្យដល់សេចក្តីត្រេកអរ ដល់ពួកម្រឹគនោះ ហើយបើកផ្លូវខុស ស្រែះសម្រាស់ បន្ទុកនូវម្រឹគឈ្មោល ដាក់ទុកម្រឹគញី ម្នាលភិក្ខុទាំងឡាយ លុះសម័យខាងក្រោយមក ពួកម្រឹគច្រើននោះឯង ក៏ដល់នូវសេចក្តីវិនាស ស្លាប់ស្លន់ទៅដូច្នោះឯង ។ ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត បុរសណាមួយដែលប្រាថ្នានូវសេចក្តីចំរើន ប្រាថ្នានូវប្រយោជន៍ ប្រាថ្នានូវសេចក្តីក្សេមដល់ពួកម្រឹគច្រើននោះ បុរសនោះក៏

យ្វាស្ស មគ្គោ ខេមោ សោវត្ថិកោ បីតិគមនីយោ តំ មគ្គំ វិវរេយ្យ បិទហេយ្យ កុម្មគ្គំ ឩហនេយ្យ(១) ឱកចរំ នាសេយ្យ ឱកចារិកំ ឯវញ្ហិ សោ ភិក្ខវេ មហា មិគសង្ឃោ អបរេន សមយេន វុឌ្ឍឹ វិរុឡ្ហឹ វេបុល្លំ អាបជ្ជេយ្យ ។ ឧបមា ខោ មេ អយំ ភិក្ខវេ កតា អត្ថស្ស វិញ្ញាបនាយ ។ អយញ្ចេវេត្ថ អត្ថោ មហន្តំ និន្នំ បល្លលន្តិ ខោ ភិក្ខវេ កាមានមេតំ អធិវចនំ ។ មហា មិគសង្ឃោតិ ខោ ភិក្ខវេ សត្តានមេតំ អធិវចនំ ។ បុរិសោ អនត្ថកាមោ អហិតកាមោ អយោគក្ខេមកាមោតិ ខោ ភិក្ខវេ មារស្សេតំ បាបិមតោ អធិវចនំ ។ កុម្មគ្គោតិ ខោ ភិក្ខវេ អដ្ឋង្គិកស្សេតំ មិច្ឆាមគ្គស្ស អធិវចនំ សេយ្យថីទំ មិច្ឆាទិដ្ឋិយា មិច្ឆាសង្កប្បស្ស មិច្ឆាវាចាយ មិច្ឆាកម្មន្តស្ស មិច្ឆាអាជីវស្ស មិច្ឆាវាយាមស្ស មិច្ឆាសតិយា មិច្ឆាសមាធិស្ស ។ ឱកចរោតិ ខោ ភិក្ខវេ នន្ទិរាគស្សេតំ អធិវចនំ ។



បើកនូវផ្លូវដែលក្សេមក្សាន្ត ដែលប្រកបដោយសួស្តី ដ៏គួរដល់ដោយសេចក្តីត្រេកអរដល់ពួកម្រឹគនោះ ហើយបិទផ្លូវខុសនោះ បំផ្លូវ រើយកសម្រាប់ចេញ ធ្វើមម្រឹគស្ទាក់ឲ្យវិនាស ដូចម្តេចមិញ ម្នាលភិក្ខុទាំងឡាយ លុះសម័យខាងក្រោយមក ពួកម្រឹគច្រើននោះ ក៏ដល់នូវសេចក្តីចំរើន កុះករ បរិបូណ៌ឡើង ដូច្នោះឯង ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីឧបមានេះ តថាគតធ្វើដើម្បីបញ្ជាក់នូវសេចក្តីនេះប៉ុណ្ណោះ ។ សេចក្តីអធិប្បាយក្នុងពាក្យឧបមានេះ ដូចសំដែងតទៅ ម្នាលភិក្ខុទាំងឡាយ ត្រង់ពាក្យថា ត្រពាំងទំនាបធំទុះ គឺជាឈ្មោះរបស់កាមទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ត្រង់ពាក្យថា ពួកម្រឹគច្រើនទុះ ជាឈ្មោះរបស់ពួកសត្វច្រើន ។ ម្នាលភិក្ខុទាំងឡាយ ត្រង់ពាក្យថា បុរសមិនប្រាថ្នានូវសេចក្តីចំរើន មិនប្រាថ្នានូវប្រយោជន៍ មិនប្រាថ្នានូវសេចក្តីក្សេមទុះ ជាឈ្មោះនៃមារដែលមានធម៌លាមក ។ ត្រង់ពាក្យថា ផ្លូវខុសទុះ ជាឈ្មោះមិច្ឆាមគ្គ (ផ្លូវខុស) ប្រកបដោយអង្គ ៨ ប្រការ គឺ មិច្ឆាទិដ្ឋិ មិច្ឆាសង្កប្បៈ មិច្ឆាវាចា មិច្ឆាកម្មន្តៈ មិច្ឆាអាជីវៈ មិច្ឆាវាយាមៈ មិច្ឆាសតិ មិច្ឆាសមាធិ ។ ម្នាលភិក្ខុទាំងឡាយ ត្រង់ពាក្យថា សម្រាស់ទុះ ជាឈ្មោះនៃនន្ទិរាគ ។

ឱកចារិកាតិ ខោ ភិក្ខវេ អវិជ្ជាយេតំ អធិវចនំ ។ បុរិសោ អត្ថកាមោ ហិតកាមោ យោគក្ខេមកាមោតិ ខោ ភិក្ខវេ តថាគតស្សេតំ អធិវចនំ អរហតោ សម្មាសម្ពុទ្ធស្ស ។ មគ្គោ ខេមោ សោវត្ថិកោ បីតិគមនីយោតិ ខោ ភិក្ខវេ អរិយស្សេតំ អដ្ឋង្គិកស្ស មគ្គស្ស អធិវចនំ សេយ្យថីទំ សម្មាទិដ្ឋិយា សម្មាសង្កប្បស្ស សម្មាវាចាយ សម្មាកម្មន្តស្ស សម្មាអាជីវស្ស សម្មាវាយាមស្ស សម្មាសតិយា សម្មាសមាធិស្ស ។

[៦៨៨] ឥតិ ខោ ភិក្ខវេ វិវដោ មយា ខេមោ មគ្គោ សោវត្ថិកោ បីតិគមនីយោ បិហិតោ កុម្មគ្គោ ឩហតោ(១) ឱកចរោ នាសិតា ឱកចារិកា ។ យំ ភិក្ខវេ សត្ថារា ករណីយំ សាវកានំ ហិតេសិនា អនុកម្បកេន អនុកម្បំ ឧបាទាយ កតំ វោ តំ មយា ។ ឯតានិ ភិក្ខវេ

១ ម. ឧហតោ ។



ម្នាលភិក្ខុទាំងឡាយ ត្រង់ពាក្យថា មេម្រឹគញាក់នុ៎ះ ជាឈ្មោះនៃអវិជ្ជា ។ ម្នាលភិក្ខុទាំងឡាយ ត្រង់ពាក្យថា បុរសប្រាថ្នានូវសេចក្តីចំរើន ប្រាថ្នានូវប្រយោជន៍ ប្រាថ្នានូវសេចក្តីក្សេមក្សាន្តនុ៎ះ ជាឈ្មោះនៃតថាគត ជាអរហន្តសម្មាសម្ពុទ្ធ ។ ម្នាលភិក្ខុទាំងឡាយ ត្រង់ពាក្យថា ផ្លូវក្សេមក្សាន្តដែលប្រកបដោយសួស្តី គួរដល់សេចក្តីត្រេកអរនុ៎ះ ជាឈ្មោះនៃអរិយមគ្គប្រកបដោយអង្គ៨ប្រការ គឺ សម្មាទិដ្ឋិ សម្មាសង្កប្បៈ សម្មាវាចា សម្មាកម្មន្តៈ សម្មាអាជីវៈ សម្មាវាយាមៈ សម្មាសតិ សម្មាសមាធិ ។

(៦៨៨) ម្នាលភិក្ខុទាំងឡាយ ផ្លូវដែលក្សេមប្រកបដោយសួស្តី ជាផ្លូវគួរដល់សេចក្តីត្រេកអរ តថាគតបានបើកហើយ ផ្លូវខុសក៏តថាគតបិទហើយ សម្រាស់ក៏តថាគតរើចោលហើយ មេម្រឹគញាក់ក៏តថាគតធ្វើឲ្យវិនាសហើយដោយប្រការដូច្នេះឯង ។ ម្នាលភិក្ខុទាំងឡាយ កិច្ចណាដែលតថាគតជាសាស្តា ជាអ្នកស្វែងរកប្រយោជន៍ មានសេចក្តីអនុគ្រោះ ត្រូវធ្វើដល់អ្នកទាំងឡាយជាសាវ័កព្រោះអាស្រ័យសេចក្តីអនុគ្រោះ កិច្ចនោះតថាគត បានធ្វើហើយ ដល់អ្នកទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ

រុក្ខមូលានិ ឯតានិ សុញ្ញាគារានិ ឈាយថ ភិក្ខវេ មា បមាទត្ថ មា បច្ឆា វិប្បដិសារិនោ អហុវត្ថ ។ អយំ វោ អម្ហាកំ អនុសាសនីតិ ។ ឥទមវោច ភគវា អត្តមនា តេ ភិក្ខូ ភគវតោ ភាសិតំ អភិនន្ទុន្តិ ។

ទុធាភិក្ខុសុត្តំ នវមំ ។



អ្នកទាំងឡាយសម្លឹងមើលនូវគល់ឈើទាំងនុ៎ះ នូវសុញ្ញាគារទាំងនុ៎ះ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយកុំប្រមាទ កុំមានសេចក្តីក្តៅក្រហាយ ស្តាយក្រោយឡើយ ។ នេះជាពាក្យប្រៀនប្រដៅរបស់តថាគត ចំពោះអ្នកទាំងឡាយ ។ លុះព្រះមានព្រះភាគបានត្រាស់ព្រះសូត្រនេះចប់ហើយ ក៏ភិក្ខុទាំងនោះ មានសេចក្តីពេញចិត្តត្រេកអរ ចំពោះភាសិតរបស់ព្រះមានព្រះភាគជាម្ចាស់ ។

ចប់ ទុធាភិក្ខុសូត្រ ទី ៩ ។

# ទសមំ វិតក្កសណ្ឋានសុត្តំ

(៤៨៦) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ ភិក្ខវោតិ ។ ភទន្តេតិ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។

(៤៨៧) ភគវា ឯតទវោច អធិចិត្តមយុត្តេន ភិក្ខវេ ភិក្ខុនា បញ្ច និមិត្តានិ កាលេន កាលំ មនសិកាតព្វានិ ។ កតមានិ បញ្ច ។ ឥធ ភិក្ខវេ ភិក្ខុនោ យំ និមិត្តំ អាគម្ម យំ និមិត្តំ មនសិករោតោ ឧប្បជ្ជន្តិ បាបកា អកុសលា ឆន្ទូបសញ្ហិតាបិ(១) ទោសូបសញ្ហិតាបិ វិតក្កា មោហូបសញ្ហិតាបិ តេន ភិក្ខវេ ភិក្ខុនា តម្ហា និមិត្តា អញ្ញំ និមិត្តំ ។ មនសិកាតព្វំ កុសលូបសញ្ហិតំ តស្ស តម្ហា និមិត្តា អញ្ញំ និមិត្តំ មនសិករោតោ កុសលូបសញ្ហិតំ យេ បាបកា អកុសលា វិតក្កា ឆន្ទូបសញ្ហិតាបិ ទោសូបសញ្ហិតាបិ មោហូបសញ្ហិតាបិ

---

១ ម. ឆន្ទូបសំហិតាបិ ។

# វិតក្កសណ្ឋានសូត្រ ទី ១០

(៤៨៦) ខ្ញុំបានស្ដាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ សម័យនោះឯង ព្រះមានព្រះភាគទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះក្រាបបង្គំទូលព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ។

(៤៨៧) ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបរឿយៗ នូវអធិចិត្ត គឺសមាបត្តិ ៨ ហើយគប្បីធ្វើទុកក្នុងចិត្តនូវហេតុទាំង ៥ ប្រការសព្វៗកាល ។ ហេតុទាំង ៥ គឺអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ អាស្រ័យនូវហេតុណា ធ្វើទុកក្នុងចិត្តនូវហេតុណា អកុសលវិតក្កៈដ៏លាមកទាំងឡាយ ដែលប្រកបដោយឆន្ទៈគឺលោភៈខ្លះ ប្រកបដោយទោសៈខ្លះ ប្រកបដោយមោហៈខ្លះ កើតឡើងដល់ភិក្ខុនោះ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះគប្បីចេញចាកហេតុនោះ ហើយធ្វើទុកក្នុងចិត្តនូវហេតុដទៃដែលប្រកបដោយកុសលវិតក្កៈវិញ កាលបើភិក្ខុនោះចេញចាកហេតុនោះ ហើយធ្វើទុកក្នុងចិត្តនូវហេតុដទៃ ដែលប្រកបដោយកុសលវិតក្កៈ អកុសលវិតក្កៈដ៏លាមកទាំងឡាយណា ដែលប្រកបដោយឆន្ទៈខ្លះ ប្រកបដោយទោសៈខ្លះ ប្រកបដោយមោហៈខ្លះ

តេ បហីយន្តិ តេ អព្ភត្ថំ គច្ឆន្តិ តេសំ បហានា អជ្ឈត្តមេវ ចិត្តំ សន្តិដ្ឋតិ សន្និសីទតិ ឯកោទិភោតិ[១] សមាធិយតិ ។ សេយ្យថាបិ ភិក្ខវេ ទក្ខោ ផលគណ្ឌោ វា ផលគណ្ឌន្តេវាសី[២] វា សុខុមាយ អាណិយា ឱឡារិកំ អាណិំ អភិនិហនេយ្យ អភិនីហរេយ្យ អភិនិវត្តេយ្យ[៣] ឯវមេវ ខោ ភិក្ខវេ ភិក្ខុនោ យំ និមិត្តំ អាគម្ម យំ និមិត្តំ មនសិករោតោ ឧប្បជ្ជន្តិ បាបកា អកុសលា វិតក្កា ឆន្ទូបសញ្ហិតាបិ ទោសូបសញ្ហិតាបិ មោហូបសញ្ហិតាបិ តេន ភិក្ខវេ ភិក្ខុនា តម្ហា និមិត្តា អញ្ញំ និមិត្តំ មនសិកាតព្វំ កុសលូបសញ្ហិតំ តស្ស តម្ហា និមិត្តា អញ្ញំ និមិត្តំ មនសិករោតោ កុសលូបសញ្ហិតំ យេ បាបកា អកុសលា វិតក្កា ឆន្ទូបសញ្ហិតាបិ ទោសូបសញ្ហិតាបិ មោហូបសញ្ហិតាបិ តេ បហីយន្តិ តេ អព្ភត្ថំ គច្ឆន្តិ តេសំ បហានា អជ្ឈត្តមេវ ចិត្តំ សន្តិដ្ឋតិ សន្និសីទតិ ឯកោទិភោតិ សមាធិយតិ ។

---

១ ម. ឯកោទិហោតិ ។ ២ ម. បលគណ្ឌោ វា បលគណ្ឌន្តេវាសី វា ។ ៣ ម.



អកុសលវិតក្កៈទាំងនោះនឹងសាបសូន្យទៅ ក៏ដល់នូវសេចក្ដីវិនាសផុតបង់ទៅពុំខាន ព្រោះលះបង់នូវអកុសលវិតក្កៈទាំងនោះបានហើយ ទើបចិត្តខាងក្នុងក៏តាំងនៅស្ងប់ស៊ប់ស្ងួន ជាចិត្តមានអារម្មណ៍តែមួយ ជាចិត្តនឹងនៅក្នុងអារម្មណ៍ ។ ម្នាលភិក្ខុទាំងឡាយ ដូចជាជាងឈើ ឬកូនសិស្សជាងឈើដែលប្រសប់ គប្បីកយបញ្ចូន នាំចេញ ដកចេញ នូវគន្លាស់ធំ ដោយគន្លាស់តូចដូចម្ដេចមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអាស្រ័យហេតុណា ធ្វើទុកក្នុងចិត្តនូវហេតុណា អកុសលវិតក្កៈដ៏លាមកទាំងឡាយដែលប្រកបដោយឆន្ទៈខ្លះ ប្រកបដោយទោសៈខ្លះ ប្រកបដោយមោហៈខ្លះ តែងកើតឡើងដល់ភិក្ខុនោះ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះគប្បីចេញចាកហេតុនោះហើយ ធ្វើទុកក្នុងចិត្តនូវហេតុដទៃដែលប្រកបដោយកុសលវិតក្កៈវិញ កាលភិក្ខុនោះចេញចាកហេតុនោះហើយ ធ្វើទុកក្នុងចិត្តនូវហេតុដទៃដែលប្រកបដោយកុសលវិតក្កៈ អកុសលវិតក្កៈដ៏លាមកទាំងឡាយណាដែលប្រកបដោយឆន្ទៈខ្លះ ទោសៈខ្លះ មោហៈខ្លះ អកុសលវិតក្កៈទាំងនោះ នឹងសាបសូន្យទៅ នឹងដល់នូវសេចក្ដីវិនាសផុតបង់ទៅពុំខាន ព្រោះលះបង់នូវអកុសលវិតក្កៈទាំងនោះបានហើយ ទើបចិត្តខាងក្នុងក៏តាំងនៅស្ងប់ស៊ប់ស្ងួន ជាចិត្តមានអារម្មណ៍តែមួយ ជាចិត្តនឹងនៅក្នុងអារម្មណ៍ផ្ទះឯង ។

(២៩៨) តស្ស ចេ ភិក្ខវេ ភិក្ខុនោ តម្ហា និមិត្តា អញ្ញំ និមិត្តំ មនសិករោតោ កុសលូបសញ្ហិតំ ឧប្បជ្ជន្តេវ បាបកា អកុសលា វិតក្កា ឆន្ទូបសញ្ហិតាបិ ទោសូបសញ្ហិតាបិ មោហូបសញ្ហិតាបិ តេន ភិក្ខវេ ភិក្ខុនា តេសំ វិតក្កានំ អាទីនវោ ឧបបរិក្ខិតព្វោ ឥតិបិមេ វិតក្កា អកុសលា ឥតិបិមេ វិតក្កា សាវជ្ជា ឥតិបិមេ វិតក្កា ទុក្ខវិបាកាតិ ។ តស្ស តេសំ វិតក្កានំ អាទីនវំ ឧបបរិក្ខតោ យេ បាបកា អកុសលា វិតក្កា ឆន្ទូបសញ្ហិតាបិ ទោសូបសញ្ហិតាបិ មោហូបសញ្ហិតាបិ តេ បហីយន្តិ តេ អព្ភត្ថំ គច្ឆន្តិ តេសំ បហានា អជ្ឈត្តមេវ ចិត្តំ សន្តិដ្ឋតិ សន្និសីទតិ ឯកោទិ ហោតិ សមាធិយតិ ។ សេយ្យថាបិ ភិក្ខវេ ឥត្ថី វា បុរិសោ វា ទហរោ វា យុវា មណ្ឌនកជាតិកោ អហិកុណបេន វា កុក្កុរកុណបេន វា មនុស្សកុណបេន វា កណ្ឋេ អាលគ្គេន (១) អដ្ដិយេយ្យ ហរាយេយ្យ ជិគុច្ឆេយ្យ ឯវមេវ ខោ ភិក្ខវេ តស្ស ចេ ភិក្ខុនោ



(២៩៨) ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុនោះចេញចាកហេតុនោះ ហើយធ្វើទុកក្នុងចិត្តនូវហេតុដទៃដែលប្រកបដោយកុសលវិតក្កៈវិញ អកុសលវិតក្កៈដ៏លាមកទាំងឡាយដែលប្រកបដោយឆន្ទៈខ្លះ ប្រកបដោយទោសៈខ្លះ ប្រកបដោយមោហៈខ្លះ តែងកើតឡើងដល់ភិក្ខុនោះ ម្នាលភិក្ខុទាំងឡាយ លុះភិក្ខុនោះកំណត់នូវទោសនៃវិតក្កៈទាំងនោះថា វិតក្កៈទាំងនេះជាអកុសល វិតក្កៈទាំងនេះប្រកបដោយទោស វិតក្កៈទាំងនេះឲ្យផលជាទុក្ខ ។ កាលភិក្ខុនោះកំណត់នូវទោសនៃវិតក្កៈទាំងនោះហើយ អកុសលវិតក្កៈដ៏លាមកទាំងឡាយណាដែលប្រកបដោយឆន្ទៈខ្លះ ប្រកបដោយទោសៈខ្លះ ប្រកបដោយមោហៈខ្លះ អកុសលវិតក្កៈទាំងនោះ ទីនសាបសូន្យទៅ ទីនដល់នូវសេចក្តីវិនាសបាត់បង់ទៅពុំខាន ព្រោះលះបង់នូវអកុសលវិតក្កៈទាំងនោះចេញបានហើយ ទើបចិត្តខាងក្នុង ក៏តាំងនៅស្ងួតស្ងប់ស៊ប់ស្ងួន ជាចិត្តមានអារម្មណ៍តែមួយ ជាចិត្តតាំងនៅក្នុងអារម្មណ៍ ។ ម្នាលភិក្ខុទាំងឡាយ ដូចជាស្ត្រីឬបុរស កំលោះឬក្រមុំ ប្រកបដោយជាតិជាអ្នកប្រដាប់តាក់តែងកាយ គប្បីនឿយណាយធុញទ្រាន់ ខ្ពើមរអើមសាកសពពស់ សាកសពឆ្កែ សាកសពមនុស្ស ដែលជាប់នៅត្រង់ក យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុនោះ

តម្ហា និមិត្តា អញ្ញំ និមិត្តំ មនសិការោតោ កុស-លូបសំហិតំ ឧប្បជ្ជន្តេវ បាបកា អកុសលា វិតក្កា ឆន្ទូបសំហិតាបិ ទោសូបសំហិតាបិ មោហូបសំហិតាបិ តេន ភិក្ខវេ ភិក្ខុនា តេសំ វិតក្កានំ អាទីនវោ ឧប-បរិក្ខិតព្វោ ឥតិបិមេ វិតក្កា អកុសលា ឥតិបិមេ វិតក្កា សាវជ្ជា ឥតិបិមេ វិតក្កា ទុក្ខវិបាកាតិ ។ តស្ស តេសំ វិតក្កានំ អាទីនវំ ឧបបរិក្ខតោ យេ បាបកា អកុសលា វិតក្កា ឆន្ទូបសំហិតាបិ ទោសូ-បសំហិតាបិ មោហូបសំហិតាបិ តេ បហីយន្តិ តេ អព្ភត្ថំ គច្ឆន្តិ តេសំ បហានា អជ្ឈត្តមេវ ចិត្តំ សន្តិដ្ឋតិ សន្និសីទតិ ឯកោទិ ហោតិ សមាធិយតិ ។

(២៤៩) តស្ស ចេ ភិក្ខវេ ភិក្ខុនោ តេសំ[១] វិតក្កានំ អាទីនវំ ឧបបរិក្ខតោ ឧប្បជ្ជន្តេវ បាបកា អកុសលា វិតក្កា ឆន្ទូបសំហិតាបិ ទោសូបសំហិតា-បិ មោហូបសំហិតាបិ តេន ភិក្ខវេ ភិក្ខុនា តេសំ វិតក្កានំ អសតិអមនសិការោ អាបជ្ជិតព្វោ តស្ស

១ ឱ. ម. តេសម្បិ ។



ចេញចាកនិមិត្តនោះ កាលធ្វើទុកក្នុងចិត្តនូវនិមិត្តដទៃដែលប្រកបដោយកុសលវិតក្កៈវិញ អកុសលវិតក្កៈដ៏លាមកទាំងឡាយដែលប្រកបដោយឆន្ទៈខ្លះ ប្រកបដោយទោសៈខ្លះ ប្រកបដោយមោហៈខ្លះ តែងកើតឡើងដល់ភិក្ខុនោះ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះគប្បីកំណត់នូវទោសនៃវិតក្កៈទាំងនោះថា វិតក្កៈទាំងនេះជាអកុសល វិតក្កៈទាំងនេះប្រកបដោយទោស វិតក្កៈទាំងនេះឲ្យផលជាទុក្ខ ។ កាលភិក្ខុនោះកំណត់នូវទោសនៃវិតក្កៈទាំងនោះ អកុសលវិតក្កៈដ៏លាមកទាំងឡាយណា ដែលប្រកបដោយឆន្ទៈខ្លះ ប្រកបដោយទោសៈខ្លះ ប្រកបដោយមោហៈខ្លះ អកុសលវិតក្កៈទាំងនោះនឹងសាបសូន្យទៅ នឹងដល់នូវសេចក្តីវិនាសបាត់បង់ទៅពុំខាន ព្រោះលះបង់នូវអកុសលវិតក្កៈទាំងនោះចេញបាន ទើបចិត្តខាងក្នុងតាំងនៅស្ងប់ស្ងៀមស៊ប់ស្ងួន ជាចិត្តមានអារម្មណ៍តែមួយ ជាចិត្តនឹងនៅក្នុងអារម្មណ៍ ។

(២៤៩) ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុនោះកំណត់នូវទោសនៃវិតក្កៈទាំងនោះហើយ អកុសលវិតក្កៈដ៏លាមកទាំងឡាយ ដែលប្រកបដោយឆន្ទៈខ្លះ ប្រកបដោយទោសៈខ្លះ ប្រកបដោយមោហៈខ្លះ តែងកើតឡើងដល់ភិក្ខុនោះ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះមិនគប្បីរលឹក មិនគប្បីធ្វើទុកក្នុងចិត្តនូវវិតក្កៈទាំងនោះឡើយ កាលភិក្ខុនោះ

តេសំ វិតក្កានំ អសតិអមនសិការំ អាបជ្ជតោ យេ បាបកា អកុសលា វិតក្កា ឆន្ទូបសញ្ហិតាបិ ទោសូបសញ្ហិតាបិ មោហូបសញ្ហិតាបិ តេ បហីយន្តិ តេ អព្ភត្ថំ គច្ឆន្តិ តេសំ បហានា អជ្ឈត្តមេវ ចិត្តំ សន្តិដ្ឋតិ សន្និសីទតិ ឯកោទិហោតិ សមាធិយតិ ។ សេយ្យថាបិ ភិក្ខវេ ចក្ខុមា បុរិសោ អាបាថគតានំ រូបានំ អទស្សនកាមោ អស្ស សោ និមីលេយ្យ[១] វា អញ្ញេន វា អបលោកេយ្យ ឯវមេវ ខោ ភិក្ខវេ តស្ស ចេ ភិក្ខុនោ តេសំ វិតក្កានំ អាទីនវំ ឧបបរិក្ខតោ ឧប្បជ្ជន្តេវ បាបកា អកុសលា វិតក្កា ឆន្ទូបសញ្ហិតាបិ ។បេ។ ឯកោទិហោតិ សមាធិយតិ ។

(២៦០) តស្ស ចេ ភិក្ខវេ ភិក្ខុនោ តេសំ វិតក្កានំ អសតិអមនសិការំ អាបជ្ជតោ ឧប្បជ្ជន្តេវ បាបកា អកុសលា វិតក្កា ឆន្ទូបសញ្ហិតាបិ ទោសូបសញ្ហិតាបិ មោហូបសញ្ហិតាបិ

១ ម. និមីលេយ្យ វា ។



មិនរលឹកមិនធ្វើទុកក្នុងចិត្តចំពោះវិតក្កៈទាំងនោះទេ អកុសលវិតក្កៈដ៏លាមកទាំងឡាយណាដែលប្រកបដោយឆន្ទៈខ្លះ ប្រកបដោយទោសៈខ្លះ ប្រកបដោយមោហៈខ្លះ អកុសលវិតក្កៈទាំងនោះក៏សាបសូន្យទៅ ទើបដល់នូវសេចក្តីវិនាសបាត់បង់ទៅក្នុងខាង ព្រោះលះបង់នូវអកុសលវិតក្កៈទាំងនោះចេញបានហើយ ទើបចិត្តខាងក្នុងតាំងនៅស្ងប់ស្ងៀមល្អ ជាចិត្តមានអារម្មណ៍តែមួយ ជាចិត្តនឹងនៅក្នុងអារម្មណ៍ ។ ម្នាលភិក្ខុទាំងឡាយ ដូចបុរសដែលមានចក្ខុមិនចង់ឃើញរូបទាំងឡាយដែលមកប្រាកដដល់ចក្ខុ បុរសនោះគប្បីធ្មេចភ្នែកខ្លះ ឬគប្បីក្រឡេកមើលដោយហេតុដទៃ យ៉ាងណា ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុនោះកំណត់នូវទោសនៃវិតក្កៈទាំងនោះហើយ អកុសលវិតក្កៈដ៏លាមកទាំងឡាយដែលប្រកបដោយឆន្ទៈតែងកើតឡើង ។បេ។ ជាចិត្តមានអារម្មណ៍តែមួយ ជាចិត្តនឹងនៅក្នុងអារម្មណ៍ ។

(២៦០) ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុនោះមិនរលឹក មិនធ្វើទុកក្នុងចិត្តចំពោះវិតក្កៈទាំងនោះទេ អកុសលវិតក្កៈដ៏លាមកទាំងឡាយដែលប្រកបដោយឆន្ទៈខ្លះ ប្រកបដោយទោសៈខ្លះ ប្រកបដោយមោហៈខ្លះ

តេន ភិក្ខវេ ភិក្ខុនា តេសំ វិតក្កានំ វិតក្កសង្ខារសណ្ឋានំ មនសិកាតព្វំ តស្ស តេសំ វិតក្កានំ វិតក្កសង្ខារសណ្ឋានំ មនសិករោតោ យេ បាបកា អកុសលា វិតក្កា ឆន្ទូបសញ្ហិតាបិ ទោសូបសញ្ហិតាបិ មោហូបសញ្ហិតាបិ តេ បហីយន្តិ តេ អព្ភត្ថំ គច្ឆន្តិ តេសំ បហានា អជ្ឈត្តមេវ ចិត្តំ សន្តិដ្ឋតិ សន្និសីទតិ ឯកោទិហោតិ សមាធិយតិ ។ សេយ្យថាបិ ភិក្ខវេ បុរិសោ សីឃំ គច្ឆេយ្យ តស្ស ឯវមស្ស កិន្នុខោ អហំ សីឃំ គច្ឆាមិ យន្នូនាហំ សណិកំ គច្ឆេយ្យន្តិ សោ សណិកំ គច្ឆេយ្យ ។ តស្ស ឯវមស្ស កិន្នុខោ អហំ សណិកំ គច្ឆាមិ យន្នូនាហំ តិដ្ឋេយ្យន្តិ សោ តិដ្ឋេយ្យ ។ តស្ស ឯវមស្ស កិន្នុខោ អហំ ឋិតោ យន្នូនាហំ និសីទេយ្យន្តិ សោ និសីទេយ្យ ។ តស្ស ឯវមស្ស កិន្នុខោ អហំ និសិន្នោ យន្នូនាហំ និបជ្ជេយ្យន្តិ សោ និបជ្ជេយ្យ



តែងកើតឡើងដល់ភិក្ខុនោះ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះគប្បីធ្វើទុកក្នុងចិត្តនូវវិតក្កសង្ខារសណ្ឋាន គឺហេតុជាទីតាំងនៃវិតក្កៈទាំងនោះ កាលភិក្ខុនោះធ្វើទុកក្នុងចិត្តនូវវិតក្កសង្ខារសណ្ឋាននៃវិតក្កៈទាំងនោះហើយ អកុសលវិតក្កៈដ៏លាមកទាំងឡាយណា ដែលប្រកបដោយឆន្ទៈខ្លះ ប្រកបដោយទោសៈខ្លះ ប្រកបដោយមោហៈខ្លះ អកុសលវិតក្កៈទាំងនោះនឹងសាបសូន្យទៅ នឹងដល់នូវសេចក្ដីវិនាសបាត់បង់ទៅ ព្រោះលះបង់នូវអកុសលវិតក្កៈនោះចេញបានហើយ ទើបចិត្តខាងក្នុងក៏តាំងនៅស៊ប់ស្ងប់ស៊ប់ស្ងួន ជាចិត្តមានអារម្មណ៍តែមួយ ជាចិត្តនឹងនៅក្នុងអារម្មណ៍ ។ ម្នាលភិក្ខុទាំងឡាយ ដូចជាបុរសដើរលឿន បុរសនោះមានសេចក្ដីត្រិះរិះយ៉ាងនេះថា ហេតុអ្វីហ្ន៎ក៏អាត្មាអញដើរលឿនម្ល៉េះ បើដូច្នោះមានតែអាត្មាអញដើរទៅសន្សឹមៗ (លុះគិតដូច្នេះហើយ) បុរសនោះក៏ដើរទៅសន្សឹមៗ ។ បុរសនោះមានសេចក្ដីត្រិះរិះយ៉ាងនេះថា ហេតុអ្វីហ្ន៎ក៏អាត្មាអញដើរសន្សឹមៗម្ល៉េះ បើដូច្នោះមានតែអាត្មាអញឈរ ហើយបុរសនោះក៏ឈរ ។ បុរសនោះមានសេចក្ដីត្រិះរិះយ៉ាងនេះថា ហេតុអ្វីហ្ន៎ក៏អាត្មាអញឈរ បើដូច្នោះមានតែអាត្មាអញអង្គុយ ហើយបុរសនោះក៏អង្គុយ ។ បុរសនោះមានសេចក្ដីត្រិះរិះយ៉ាងនេះថា ហេតុអ្វីហ្ន៎ក៏អាត្មាអញអង្គុយ បើដូច្នោះមានតែអាត្មាអញដេក ហើយបុរសនោះក៏ដេក ។

ឯវញ្ហិ សោ ភិក្ខវេ បុរិសោ ឱឡារិកំ ឱឡារិកំ ឥរិយាបថំ អភិនិស្សជ្ជេត្វា[១] សុខុមំ សុខុមំ ឥរិយាបថំ កប្បេយ្យ ឯវមេវ ខោ ភិក្ខវេ តស្ស ចេ ភិក្ខុនោ តេសំបិ វិតក្កានំ វិតក្កសង្ខារសណ្ឋានំ មនសិការោតោ ឧប្បជ្ជន្តេវ បាបកា អកុសលា វិតក្កា ឆន្ទូបសញ្ហិតាបិ ។ បេ ។ ឯកោទិ ហោតិ សមាធិយតិ ។

(២៦១) តស្ស ចេ ភិក្ខវេ ភិក្ខុនោ តេសំបិ វិតក្កានំ វិតក្កសង្ខារសណ្ឋានំ មនសិការោតោ ឧប្បជ្ជន្តេវ បាបកា អកុសលា វិតក្កា ឆន្ទូបសញ្ហិតាបិ ទោសូបសញ្ហិតាបិ មោហូបសញ្ហិតាបិ តេន ភិក្ខវេ ភិក្ខុនា ទន្តេភិ ទន្តមាធាយ ជិវ្ហាយ តាលុំ អាហច្ច ចេតសា ចិត្តំ អភិនិគ្គណ្ហិតព្វំ អភិនិប្បីឡេតព្វំ អភិសន្តាបេតព្វំ តស្ស ទន្តេភិ ទន្តមាធាយ ជិវ្ហាយ តាលុំ អាហច្ច ចេតសា ចិត្តំ អភិនិគ្គណ្ហតោ អភិនិប្បីឡយតោ អភិសន្តាបយតោ យេ បាបកា អកុសលា វិតក្កា ឆន្ទូបសញ្ហិតាបិ ទោសូបសញ្ហិតាបិ

១ ម. អភិនិវជ្ជេត្វា ។



ម្នាលភិក្ខុទាំងឡាយ បុរសនោះលះបង់ឥរិយាបថដ៏គ្រោតគ្រាតៗ យ៉ាងនេះហើយ គប្បីសម្រេចឥរិយាបថដ៏ល្អិតសុខុមវិញ សេចក្តីនេះយ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុនោះធ្វើទុកក្នុងចិត្តនូវវិតក្កសង្ខារសណ្ឋាននៃវិតក្កៈទាំងនោះហើយ អកុសលវិតក្កៈ ដ៏លាមកទាំងឡាយ ប្រកបដោយឆន្ទៈខ្លះ តែងកើតឡើងដល់ភិក្ខុនោះ ។ បេ ។ ជាចិត្តមានអារម្មណ៍តែមួយ ជាចិត្តនឹងនៅក្នុងអារម្មណ៍ សេចក្តីនេះដូច្នោះឯង ។

(២៦១) ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុនោះធ្វើទុកក្នុងចិត្តនូវវិតក្កសង្ខារសណ្ឋាននៃវិតក្កៈទាំងនោះហើយ អកុសលវិតក្កៈដ៏លាមកទាំងឡាយ ដែលប្រកបដោយឆន្ទៈខ្លះ ប្រកបដោយទោសៈខ្លះ ប្រកបដោយមោហៈខ្លះ នៅតែកើតឡើងទៀត ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះត្រូវសង្កត់ធ្មេញខាងលើនឹងធ្មេញខាងក្រោម យកអណ្តាតទល់ពិតាន សង្កត់សង្កិន គាប កំដៅនូវអកុសលចិត្តដោយកុសលចិត្ត កាលភិក្ខុនោះកំពុងសង្កត់ធ្មេញខាងលើនឹងធ្មេញខាងក្រោម យកអណ្តាតទល់ពិតាន សង្កត់សង្កិន គាប កំដៅនូវអកុសលចិត្តដោយកុសលចិត្ត អកុសលវិតក្កៈដ៏លាមកទាំងឡាយណា ដែលប្រកបដោយឆន្ទៈខ្លះ ប្រកបដោយទោសៈខ្លះ

មោហូបសញ្ហិតាបិ តេ បហីយន្តិ តេ អព្ភត្ថំ គច្ឆន្តិ តេសំ បហានា អជ្ឈត្តមេវ ចិត្តំ សន្តិដ្ឋតិ សន្និសីទតិ ឯកោទិហោតិ សមាធិយតិ ។ សេយ្យថាបិ ភិក្ខវេ ពលវា បុរិសោ ទុព្វលតរំ បុរិសំ សីសេ វា គលេ វា ខន្ធេ វា គហេត្វា(១) អភិនិគ្គណ្ហេយ្យ អភិនិប្បីឡេយ្យ អភិសន្តាបេយ្យ ឯវមេវ ខោ ភិក្ខវេ តស្ស ចេ ភិក្ខុនោ តេសំ វិតក្កានំ វិតក្កសង្ខារសណ្ឋានំ មនសិការោតោ ឧប្បជ្ជន្តេវ បាបកា អកុសលា វិតក្កា ឆន្ទូបសញ្ហិតាបិ ទោសូបសញ្ហិតាបិ មោហូបសញ្ហិតាបិ តេន ភិក្ខវេ ភិក្ខុនា ទន្តេភិ ទន្តមាធាយ ជិវ្ហាយ តាលុំ អាហច្ច ចេតសា ចិត្តំ អភិនិគ្គណ្ហិតព្វំ អភិនិប្បីឡេតព្វំ អភិសន្តាបេតព្វំ តស្ស ទន្តេភិ ទន្តមាធាយ ជិវ្ហាយ តាលុំ អាហច្ច ចេតសា ចិត្តំ អភិនិគ្គណ្ហតោ អភិនិប្បីឡយតោ អភិសន្តាបយតោ យេ បាបកា អកុសលា វិតក្កា

---

១ ម. សីសេ វា គហេត្វា ខន្ធេ វា គហេត្វាតិ ឥមេ បាឋា បញ្ញាយន្តិ ។



ប្រកបដោយមោហៈខ្លះ អកុសលវិតក្កៈទាំងនោះក៏សាបសូន្យទៅ ដល់នូវសេចក្តីវិនាសបាត់បង់ទៅពុំខាន ព្រោះលះបង់នូវអកុសលវិតក្កៈទាំងនោះបានហើយ ទើបចិត្តខាងក្នុងក៏តាំងនៅស្ងួតស្ងប់ស៊ប់ស្ងួន មានអារម្មណ៍តែមួយ ទំនងនៅក្នុងអារម្មណ៍ ។ ម្នាលភិក្ខុទាំងឡាយ ដូចជាបុរសដែលមានកម្លាំង ចាប់បុរសដែលមានកម្លាំងថយជាង ត្រង់ក្បាលក្តី ត្រង់កក្តី ត្រង់ស្មាក្តី ហើយសង្កត់សង្កិនគាបកំដៅយ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុនោះធ្វើទុកក្នុងចិត្តនូវវិតក្កសង្ខារសណ្ឋាននៃវិតក្កៈទាំងឡាយហើយ អកុសលវិតក្កៈ ដ៏លាមកទាំងឡាយ ដែលប្រកបដោយឆន្ទៈខ្លះ ប្រកបដោយទោសៈខ្លះ ប្រកបដោយមោហៈខ្លះ នៅតែកើតឡើងទៀត ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះត្រូវសង្កត់ធ្មេញខាងលើនឹងធ្មេញខាងក្រោម យកអណ្តាតទល់ពិតានសង្កត់សង្កិន គាប កំដៅនូវអកុសលចិត្តដោយកុសលចិត្ត កាលភិក្ខុនោះកំពុងសង្កត់ធ្មេញខាងលើនឹងធ្មេញខាងក្រោម យកអណ្តាតទល់ពិតាន សង្កត់ គាបកំដៅនូវអកុសលចិត្តដោយកុសលចិត្តហើយ អកុសលវិតក្កៈដ៏លាមកទាំងឡាយណា

ឆន្ទូបសញ្ហិតាបិ ទោសូបសញ្ហិតាបិ មោហូបសញ្ហិតាបិ តេ បហីយន្តិ តេ អព្ភត្ថំ គច្ឆន្តិ តេសំ បហានា អជ្ឈត្តមេវ ចិត្តំ សន្តិដ្ឋតិ សន្និសីទតិ ឯកោទិហោតិ សមាធិយតិ ។

(២៦២) យតោ ច[១] ខោ ភិក្ខវេ ភិក្ខុនោ យំ និមិត្តំ អាគម្ម យំ និមិត្តំ មនសិការោតោ ឧប្បជ្ជន្តិ បាបកា អកុសលា វិតក្កា ឆន្ទូបសញ្ហិតាបិ ទោសូបសញ្ហិតាបិ មោហូបសញ្ហិតាបិ តស្ស តម្ហា និមិត្តា អញ្ញំ និមិត្តំ មនសិការោតោ កុសលូបសញ្ហិតំ យេ បាបកា អកុសលា វិតក្កា ឆន្ទូបសញ្ហិតាបិ ទោសូបសញ្ហិតាបិ មោហូបសញ្ហិតាបិ តេ បហីយន្តិ តេ អព្ភត្ថំ គច្ឆន្តិ តេសំ បហានា អជ្ឈត្តមេវ ចិត្តំ សន្តិដ្ឋតិ សន្និសីទតិ ឯកោទិហោតិ សមាធិយតិ ។ តេសំ វិតក្កានំ អាទីនវំ ឧបបរិក្ខតោ យេ បាបកា អកុសលា វិតក្កា ឆន្ទូបសញ្ហិតាបិ ទោសូបសញ្ហិតាបិ មោហូបសញ្ហិតាបិ តេ បហីយន្តិ



ដែលប្រកបដោយឆន្ទៈខ្លះ ប្រកបដោយទោសៈខ្លះ ប្រកបដោយមោហៈខ្លះ អកុសលវិតក្កៈទាំងនោះ ក៏សាបសូន្យទៅ ដល់នូវសេចក្ដីវិនាសផុតបង់ទៅពុំមាន ព្រោះលះបង់នូវអកុសលវិតក្កៈទាំងនោះចេញបាន ទើបចិត្តខាងក្នុងក៏តាំងនៅស្ងួតស្ងប់ស៊ប់ស្ងួន មានអារម្មណ៍តែមួយ នឹងនៅក្នុងអារម្មណ៍ ។

(២៦២) ម្នាលភិក្ខុទាំងឡាយ កាលណាបើភិក្ខុអាស្រ័យហេតុណា ធ្វើទុកក្នុងចិត្តនូវហេតុណាហើយ អកុសលវិតក្កៈដ៏លាមកទាំងឡាយដែលប្រកបដោយឆន្ទៈខ្លះ ប្រកបដោយទោសៈខ្លះ ប្រកបដោយមោហៈខ្លះ រមែងកើតឡើង ភិក្ខុនោះចេញចាកហេតុនោះហើយធ្វើទុកក្នុងចិត្តនូវហេតុដទៃ ដែលប្រកបដោយកុសលវិញ អកុសលវិតក្កៈ ដ៏លាមកទាំងឡាយណា ដែលប្រកបដោយឆន្ទៈខ្លះ ប្រកបដោយទោសៈខ្លះ ប្រកបដោយមោហៈខ្លះ អកុសលវិតក្កៈទាំងនោះក៏សាបសូន្យទៅ ដល់នូវសេចក្ដីវិនាសផុតបង់ទៅពុំមាន ព្រោះលះបង់នូវអកុសលវិតក្កៈទាំងនោះចេញបាន ទើបចិត្តខាងក្នុងក៏តាំងនៅស្ងួតស្ងប់ស៊ប់ស្ងួន មានអារម្មណ៍តែមួយ នឹងនៅក្នុងអារម្មណ៍ ។ កាលភិក្ខុកំណត់នូវទោសនៃវិតក្កៈទាំងនោះហើយ អកុសលវិតក្កៈដ៏លាមកទាំងឡាយណាដែលប្រកបដោយឆន្ទៈខ្លះ ប្រកបដោយទោសៈខ្លះ ប្រកបដោយមោហៈខ្លះ អកុសលវិតក្កៈទាំងនោះ ក៏សាបសូន្យទៅ

តេ អព្ភត្ថំ គច្ឆន្តិ តេសំ បហានា អជ្ឈត្តមេវ ចិត្តំ សន្តិដ្ឋតិ សន្និសីទតិ ឯកោទិហោតិ សមាធិយតិ ។ តេសំ វិតក្កានំ អសតិអមនសិការំ អាបជ្ជតោ យេ បាបកា អកុសលា វិតក្កា ឆន្ទូបសញ្ហិតាបិ ទោសូបសញ្ហិតាបិ មោហូបសញ្ហិតាបិ តេ បហីយន្តិ តេ អព្ភត្ថំ គច្ឆន្តិ តេសំ បហានា អជ្ឈត្តមេវ ចិត្តំ សន្តិដ្ឋតិ សន្និសីទតិ ឯកោទិហោតិ សមាធិយតិ ។ តេសំ វិតក្កានំ វិតក្កសង្ខារសណ្ឋានំ មនសិករោតោ យេ បាបកា អកុសលា វិតក្កា ឆន្ទូបសញ្ហិតាបិ ទោសូបសញ្ហិតាបិ មោហូបសញ្ហិតាបិ តេ បហីយន្តិ តេ អព្ភត្ថំ គច្ឆន្តិ តេសំ បហានា អជ្ឈត្តមេវ ចិត្តំ សន្តិដ្ឋតិ សន្និសីទតិ ឯកោទិហោតិ សមាធិយតិ ។ ទន្តេភិ ទន្តមាធាយ



ដល់នូវសេចក្តីវិនាសបាត់បង់ទៅពុំមាន ព្រោះលះបង់នូវអកុសលវិតក្កៈទាំងនោះចេញបាន ទើបចិត្តខាងក្នុងក៏តាំងនៅស្ងៀមស្ងប់ស៊ប់ស្ងួន មានអារម្មណ៍តែមួយ នឹងនៅក្នុងអារម្មណ៍ ។ កាលភិក្ខុមិនបាននឹកនា មិនបានយកចិត្តទុកដាក់ចំពោះវិតក្កៈទាំងនោះហើយ អកុសលវិតក្កៈដ៏លាមកទាំងឡាយណា ដែលប្រកបដោយឆន្ទៈខ្លះ ប្រកបដោយទោសៈខ្លះ ប្រកបដោយមោហៈខ្លះ អកុសលវិតក្កៈទាំងនោះក៏សាបសូន្យទៅ ដល់នូវសេចក្តីវិនាសបាត់បង់ទៅពុំមាន ព្រោះលះបង់អកុសលវិតក្កៈទាំងនោះចេញបានហើយ ទើបចិត្តខាងក្នុងក៏តាំងនៅស្ងៀមស្ងប់ស៊ប់ស្ងួន មានអារម្មណ៍តែមួយ នឹងនៅក្នុងអារម្មណ៍ ។ កាលភិក្ខុធ្វើទុកក្នុងចិត្តនូវវិតក្កសង្ខារសណ្ឋាននៃវិតក្កៈទាំងនោះហើយ អកុសលវិតក្កៈទាំងឡាយណា ដែលប្រកបដោយឆន្ទៈខ្លះ ប្រកបដោយទោសៈខ្លះ ប្រកបដោយមោហៈខ្លះ អកុសលវិតក្កៈទាំងនោះក៏សាបសូន្យទៅ ដល់នូវសេចក្តីវិនាសបាត់បង់ទៅពុំមាន ព្រោះលះបង់នូវអកុសលវិតក្កៈទាំងនោះចេញបានហើយ ទើបចិត្តខាងក្នុងក៏តាំងនៅស្ងៀមស្ងប់ស៊ប់ស្ងួន មានអារម្មណ៍តែមួយ នឹងនៅក្នុងអារម្មណ៍ ។ (កាលភិក្ខុនោះ) កំពុងសង្កត់ធ្មេញខាងលើនឹងធ្មេញខាង

ជិវ្ហាយ តាលុំ អាហច្ច ចេតសា ចិត្តំ អភិនិគ្គណ្ហតោ អភិនិប្បីឡយតោ អភិសន្តាបយតោ យេ បាបកា អកុសលា វិតក្កា ឆន្ទូបសញ្ហិតាបិ ទោសូបសញ្ហិតាបិ មោហូបសញ្ហិតាបិ តេ បហីយន្តិ តេ អព្ភត្ថំ គច្ឆន្តិ តេសំ បហានា អជ្ឈត្តមេវ ចិត្តំ សន្តិដ្ឋតិ សន្និសីទតិ ឯកោទិ ហោតិ សមាធិយតិ ។ អយំ វុច្ចតិ ភិក្ខវេ ភិក្ខុ វសី វិតក្កបរិយាយបថេសុ យំ វិតក្កំ អាកង្ខិស្សតិ តំ វិតក្កំ វិតក្កេស្សតិ យំ វិតក្កំ នាកង្ខិស្សតិ ន តំ វិតក្កំ វិតក្កេស្សតិ អច្ឆេច្ឆិ តណ្ហំ វិវដ្ដយិ(១) សញ្ញោជនំ សម្មា មានាភិសមយា អន្តមកាសិ ទុក្ខស្សាតិ ។ ឥទមវោច ភគវា អត្តមនា តេ ភិក្ខូ ភគវតោ ភាសិតំ អភិនន្ទុន្តិ ។

វិតក្កសណ្ឋានសុត្តំ ទសមំ និដ្ឋិតំ ។

សីហនាទវគ្គោ ទុតិយោ ។

---

១ ម. វិវត្តយិ ។



ក្រោម អណ្តាតទល់ពិតាន សង្កិន គាប កំដៅនូវអកុសលចិត្តដោយកុសលចិត្តហើយ អកុសលវិតក្កៈដ៏លាមកទាំងឡាយណា ដែលប្រកបដោយឆន្ទៈខ្លះ ប្រកបដោយទោសៈខ្លះ ប្រកបដោយមោហៈខ្លះ អកុសលវិតក្កៈទាំងនោះក៏សាបសូន្យទៅ ដល់នូវសេចក្តីវិនាសបាត់បង់ទៅពុំមាន ព្រោះលះបង់អកុសលវិតក្កៈទាំងនោះចេញបានហើយ ទើបចិត្តខាងក្នុងក៏តាំងនៅស៊ប់ស្ងប់ស្ងៀម មានអារម្មណ៍តែមួយ នឹងនៅក្នុងអារម្មណ៍ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះ តថាគតហៅថាជាអ្នកស្ទាត់ក្នុងគន្លងនៃវិតក្កៈបរិយាយទាំងឡាយ ភិក្ខុនោះ (បើ) ប្រាថ្នានូវវិតក្កៈណា នឹងត្រិះរិះនូវវិតក្កៈនោះ (បើ) មិនប្រាថ្នានូវវិតក្កៈណា នឹងមិនត្រិះរិះនូវវិតក្កៈនោះ ហើយផ្តាច់បង់នូវតណ្ហា លះបង់នូវសំយោជនធម៌ ធ្វើនូវព្រះនិព្វានជាទីបំផុតនៃទុក្ខ ព្រោះបានត្រាស់ដឹងដោយចិត្តដ៏ប្រពៃ ។ លុះព្រះមានព្រះភាគបានត្រាស់ព្រះសូត្រនេះចប់ហើយ ភិក្ខុទាំងនោះក៏មានសេចក្តីពេញចិត្ត ត្រេកអរចំពោះភាសិតរបស់ព្រះមានព្រះភាគ ។

ចប់ វិតក្កសណ្ឋានសូត្រ ទី ១០ ។

ចប់ សីហនាទវគ្គ ទី ២ ។

## តស្សុទ្ទានំ

ចូឡសីហលោមហំសវរោ មហា
ចូឡទុក្ខក្ខន្ធអនុមានិកសុត្តំ
ខីលបត្ថមធុបិណ្ឌកទ្វេធាវិតក្កំ
បញ្ចនិមិត្តកថា បុន វគ្គោ ។

---





ឧទ្ទានគឺបញ្ជីរឿងនៃសីហនាទវគ្គនោះគឺ

ចូឡសីហនាទសូត្រ ទី ១ មហាសីហនាទសូត្រ ទី ២

មហាទុក្ខក្ខន្ធសូត្រ ទី ៣ ចូឡទុក្ខក្ខន្ធសូត្រ ទី ៤

អនុមានសូត្រ ទី ៥ ចេតោខិលសូត្រ ទី ៦

វនបត្ថសូត្រ ទី ៧ មធុបិណ្ឌិកសូត្រ ទី ៨

ទ្វេធាវិតក្កសូត្រ ទី ៩ វិតក្កសណ្ឋានសូត្រ ទី ១០

ព្រមទាំងកថា ដែលនិយាយ ពីហេតុ ៥ ប្រការ

ចប់ សីហនាទវគ្គទី ២ តែប៉ុណ្ណេះ ។

---

# សុត្តន្តបិដកេ មជ្ឈិមនិកាយស្ស

## មូលបណ្ណាសកំ

## បឋមោ ភាគោ

### មូលបរិយាយវគ្គោ

### បឋមំ មូលបរិយាយសុត្តំ


| | | |
|---|---|---|
| | | អង្កោ |
| មូលបរិយាយវគ្គស្ស មូលបរិយាយសុត្តេ | បឋមនយភូមិបរិច្ឆេទោ | ៣ |
| | ទុតិយនយភូមិបរិច្ឆេទោ | ១១ |
| | តតិយនយភូមិបរិច្ឆេទោ | ១៣ |
| | បញ្ចមនយភូមិបរិច្ឆេទោ | ១៥ |
| | ឆដ្ឋនយភូមិបរិច្ឆេទោ | ១៧ |
| | អដ្ឋមនយភូមិបរិច្ឆេទោ | ១៨ |


### ទុតិយំ សព្វាសវសំវរសុត្តំ


| | | |
|---|---|---|
| មូលបរិយាយវគ្គស្ស សព្វាសវសំវរសុត្តេ | ទស្សនប្បហាតព្វាសវា | ២៣ |
| | សេវនាបហាតព្វាសវា | ៣១ |
| | អធិវាសនាបហាតព្វាសវា | ៣៣ |
| | វិនោទនាបហាតព្វាសវា | ៣៤ |
| | ទស្សនាទិបហីនាសវា | ៣៧ |


# សុត្តន្តបិដក មជ្ឈិមនិកាយ

## មូលបណ្ណាសក

## ភាគទី ១

### មូលបរិយាយវគ្គ

### មូលបរិយាយសូត្រ ទី ១


| | | |
|---|---|---|
| | | លេខទំព័រ |
| មូលបរិយាយវគ្គ មូលបរិយាយសូត្រ | នយភូមិបរិច្ឆេទទី ១ . . . . . . . . | ៣ |
| | នយភូមិបរិច្ឆេទទី ២ . . . . . . . . | ១១ |
| | នយភូមិបរិច្ឆេទទី ៣ . . . . . . . . | ១៣ |
| | នយភូមិបរិច្ឆេទទី ៥ . . . . . . . . | ១៥ |
| | នយភូមិបរិច្ឆេទទី ៦ . . . . . . . . | ១៧ |
| | នយភូមិបរិច្ឆេទទី ៨ . . . . . . . . | ១៨ |


### សព្វាសវសំវរសូត្រ ទី ២


| | | |
|---|---|---|
| មូលបរិយាយវគ្គ សព្វាសវសំវរសូត្រ | អាសវៈដែលត្រូវលះដោយការឃើញ | ២៣ |
| | អាសវៈដែលត្រូវលះដោយការសេព . | ៣១ |
| | អាសវៈដែលត្រូវលះដោយការអត់ធន់ . | ៣៣ |
| | អាសវៈដែលត្រូវលះដោយការបន្ទោបង់ | ៣៤ |
| | អាសវៈដែលបានលះហើយដោយការឃើញជាដើម | ៣៧ |

## តតិយំ ធម្មទាយាទសុត្តំ

អង្កេ


មូលបរិយាយវគ្គស្ស ធម្មទាយាទសុត្តេ តថាគតបិណ្ឌបាតកថា ៤១

ធម្មទាយាទកថា . . . ៤៣

វិវេកនានុសិក្ខកថា. . ៤៥

វិវេកានុសិក្ខកថា . . ៤៧

មជ្ឈិមា បដិបទា . . ៤៩


## ចតុត្ថំ ភយភេរវសុត្តំ


មូលបរិយាយវគ្គស្ស ភយភេរវសុត្តេ បន្តសេនាសនកថា . . ៥៣

សោឡសសេនាសន–
បរិយាយា. . . . . ៥៥

ភយភេរវកថា . . . . ៦៧

អសម្មោហធម្មា . . . ៦៩

បុព្វេនិវាសានុស្សតិញ្ញា–
ណកថា . . . . . ៧១

ចុតូបបាតញ្ញាណកថា ៧៣

អាសវក្ខយញ្ញាណកថា ៧៥

ជាណុស្សោណិទុតិយ–
កត្តុទេសនា. . . . ៧៧




## ធម្មទាយាទសូត្រ ទី ៣

លេខទំព័រ


មូលបរិយាយវគ្គ ធម្មទាយាទសូត្រ ពោលអំពីបិណ្ឌបាតរបស់ព្រះតថាគត . . ៤១

ពោលអំពីការយកធម៌ជាមត៌ក . . . . . ៤៣

ពោលអំពីការមិនហាត់ធ្វើនូវវិវេក . . . . ៤៥

ពោលអំពីការហាត់ធ្វើនូវវិវេក . . . . . ៤៧

មជ្ឈិមាបដិបទា . . . . . . . . . . ៤៩


## ភយភេរវសូត្រ ទី ៤


មូលបរិយាយវគ្គ ភយភេរវសូត្រ ពោលអំពីសេនាសនៈដ៏ស្ងាត់ . . . . . . ៥៣

សេនាសនបរិយាយ ១៦ . . . . . . . . ៥៥

ពោលអំពីភ័យនឹងសេចក្ដីស្ញប់. . . . . . ៦៧

ការនៃសត្វមានសេចក្ដីមិនវង្វេងជាធម្មតា . . ៦៩

ពោលអំពីបុព្វេនិវាសានុស្សតិញ្ញាណ . . . . ៧១

ពោលអំពីចុតូបបាតញ្ញាណ . . . . . . . ៧៣

ពោលអំពីអាសវក្ខយញ្ញាណ. . . . . . . ៧៥

ការសំដែងខ្លួនជាឧបាសកជាណុស្សោណិព្រាហ្មណ៍ ៧៧

## បឋមំ អនង្គណសុត្តំ

អង្កេ

មូលបរិយាយវគ្គស្ស អនង្គណសុត្តេ ចត្តារោ បុគ្គលា ..... ៧៩
អង្គណំ អង្គណន្តិ វេវចនំ ៨៥
ចតុត្ថង្គណំ ........ ៨៧
សត្តមអដ្ឋមង្គណំ .... ៨៩
ទសមង្គណំ ....... ៩១
ឯកាទសមង្គណំ .... ៩៣
តេរសមង្គណំ ...... ៩៥
ឥន្ទាវចកុសលតា ... ៩៧
កំសបាតូបមា ....... ៩៩
ទហរយុវូបមា ..... ១០៣

## ឆដ្ឋំ អាកង្ខេយ្យសុត្តំ

មូលបរិយាយវគ្គស្ស អាកង្ខេយ្យសុត្តេ បញ្ចមាទិកា អាកង្ខា .. ១០៧
ឯកាទសមទ្វាទសមា អា–
កង្ខា .......... ១០៩
បណ្ណរសមា អាកង្ខា... ១១១
សោឡសមា អាកង្ខា .. ១១៣



## អនង្គណសូត្រ ទី ៥

លេខទំព័រ

មូលបរិយាយវគ្គ អនង្គណសូត្រ បុគ្គល ៤ ពួក ............. ៧៩
ពាក្យដែលហៅថាអង្គណៈអង្គណៈ .... ៨៥
អង្គណៈ ទី ៤ ............. ៨៧
អង្គណៈ ទី៧–៩ ............ ៨៩
អង្គណៈ ទី ១០ ............ ៩១
អង្គណៈ ទី ១១ ............ ៩៣
អង្គណៈ ទី ១៣ ............ ៩៥
ការៈនៃអកុសលគ្របសង្កត់ចិត្តដោយអំណាចនៃ
សេចក្តីប្រាថ្នា ............. ៩៧
សេចក្តីប្រៀបធៀបដោយផានចាន .... ៩៩
សេចក្តីប្រៀបធៀបដោយមនុស្សកំឡោះឬជំទង់ ១០៣

## អាកង្ខេយ្យសូត្រ ទី ៦

មូលបរិយាយវគ្គ អាកង្ខេយ្យសូត្រ សេចក្តីប្រាថ្នាជាគំរប់ ៥ ជាដើម ..... ១០៧
សេចក្តីប្រាថ្នាជាគំរប់ ១១ និង ១២ .... ១០៩
សេចក្តីប្រាថ្នាជាគំរប់ ១៥ ........ ១១១
សេចក្តីប្រាថ្នាជាគំរប់ ១៦ ........ ១១៣

## សត្តមំ វត្ថូបមសុត្តំ

អង្កេ

មូលបរិយាយវគ្គស្ស វត្ថូបមសុត្តេ សោឡស ឧបក្កិលេសា . . ១១៧
គេនត្ថាយេ អវេច្ចប្បសាទោ . ១២១
គេនត្ថាយេ បសាទផលំ . . . ១២៣
អប្បមញ្ញាភាវនាកថា . . . . ១២៥
ភគវតា ភាសិតគាថា . . . ១២៧
សុន្ទរិកា អរហត្តប្បត្តិ . . ១២៩

## អដ្ឋមំ សល្លេខសុត្តំ

មូលបរិយាយវគ្គស្ស សល្លេខសុត្តេ ចតុត្ថំ រូបជ្ឈានំ . . . . ១៣១
ចតុត្ថំ អរូបជ្ឈានំ . . . . ១៣៣
សល្លេខបរិយាយោ . . . . ១៣៥
បរិក្កមនបរិយាយោ . . . . ១៤១
ឧបរិភាវបរិយាយោ . . . . ១៤៥
បរិនិព្វានបរិយាយោ . . . . ១៤៧
សុត្តាវសានគាថា . . . . ១៥១



## វត្ថូបមសូត្រ ទី ៧

លេខទំព័រ

មូលបរិយាយវគ្គ វត្ថូបមសូត្រ ឧបក្កិលេស ១៦ . . . . . . . . ១១៧
សេចក្តីជ្រះថ្លាមិនញាប់ញ័រក្នុងព្រះរត្នត្រ័យ . . ១២១
ផលនៃសេចក្តីជ្រះថ្លាក្នុងព្រះរត្នត្រ័យ . . . . ១២៣
ពោលអំពីអប្បមញ្ញាភាវនា . . . . . . ១២៥
គាថាដែលព្រះមានព្រះភាគទ្រង់សំដែង . . ១២៧
សុន្ទរិកភិក្ខុបានសំរេចព្រះអរហត្ត . . . . ១២៩

## សល្លេខសូត្រ ទី ៨

មូលបរិយាយវគ្គ សល្លេខសូត្រ រូបជ្ឈាន ៤ យ៉ាង . . . . . . . . ១៣១
អរូបជ្ឈាន ៤ យ៉ាង . . . . . . . . ១៣៣
ហេតុនៃសេចក្តីខ្ជូរផង់ . . . . . . . ១៣៥
ហេតុនៃការវៀសវាង . . . . . . . ១៤១
ហេតុនៃការញ៉ាំងខ្លួនឲ្យបានខ្ពស់ . . . . ១៤៥
ហេតុនៃសេចក្តីរំលត់ . . . . . . . ១៤៧
គាថាជាទីបំផុតនៃសូត្រ . . . . . . . ១៥១

## នវមំ សម្មាទិដ្ឋិសុត្តំ

អង្ក

មូលបរិយាយវគ្គស្ស សម្មាទិដ្ឋិសុត្តេ កុសលាកុសលកថា ..... ១៥៣
ភិក្ខូនំ បញ្ហាបុច្ឆា ...... ១៥៤
អាហារវារោ .......... ១៥៧
ទុក្ខវារោ ........ ១៥៩
ជរាមរណវារោ ..... ១៦១
ជាតិវារោ ........ ១៦៣
ភវវារោ ........ ១៦៥
ឧបាទានវារោ ...... ១៦៧
វេទនាវារោ ........ ១៦៩
ផស្សវារោ ........ ១៧១
សឡាយតនវារោ ..... ១៧៣
នាមរូបវារោ ....... ១៧៤
សង្ខារវារោ ....... ១៧៧
អវិជ្ជាវារោ ....... ១៧៩



## សម្មាទិដ្ឋិសូត្រ ទី ៩

លេខទំព័រ

មូលបរិយាយវគ្គ សម្មាទិដ្ឋិសូត្រ ពោលអំពីកុសលនិងអកុសល ..... ១៥៣
ការសួរប្រស្នានៃភិក្ខុទាំងឡាយ ..... ១៥៤
អាហារវារៈ ............. ១៥៧
ទុក្ខវារៈ ............. ១៥៩
ជរាមរណវារៈ ........... ១៦១
ជាតិវារៈ ............. ១៦៣
ភវវារៈ ............. ១៦៥
ឧបាទានវារៈ ........... ១៦៧
វេទនាវារៈ ............ ១៦៩
ផស្សវារៈ ............ ១៧១
សឡាយតនវារៈ .......... ១៧៣
នាមរូបវារៈ ........... ១៧៤
សង្ខារវារៈ ........... ១៧៧
អវិជ្ជាវារៈ ........... ១៧៩

អង្ក

មូលបរិយាយវគ្គស្ស សម្មាទិដ្ឋិសុត្ត អាលោកោ ....... ១៨១

និគមនំ ....... ១៨៣

ទសមំ សតិបដ្ឋានសុត្តំ

មូលបរិយាយវគ្គស្ស សតិបដ្ឋានសុត្ត នវសីវថិកាបព្វំ ..... ១៨៤

អានាបានបព្វំ ..... ១៨៧

ឥរិយាបថបព្វំ ..... ១៨៩

បដិកូលបព្វំ ...... ១៩១

ធាតុបព្វំ ....... ១៩៣

នវសីវថិកាបព្វំ ..... ១៩៨

វេទនានុបស្សនាសតិ-

បដ្ឋានំ ....... ១៩៩

ចិត្តានុបស្សនាសតិ-

បដ្ឋានំ ....... ២០១

នីវរណបព្វំ ...... ២០៣

ខន្ធបព្វំ ....... ២០៩

អាយតនបព្វំ ..... ២១៣

ពោជ្ឈង្គបព្វំ ..... ២១៨





លេខទំព័រ

មូលបរិយាយវគ្គ សម្មាទិដ្ឋិសូត្រ អាលោកៈ ............ ១៨១

ពាក្យជានិគម ............ ១៨៣

សតិបដ្ឋានសូត្រ ទី ១០

មូលបរិយាយវគ្គ សតិបដ្ឋានសូត្រ នវសីវថិកាបព្វៈ ........... ១៨៤

អានាបានបព្វៈ ........... ១៨៧

ឥរិយាបថបព្វៈ ........... ១៨៩

បដិកូលបព្វៈ ........... ១៩១

ធាតុបព្វៈ ............. ១៩៣

នវសីវថិកាបព្វៈ ........... ១៩៨

វេទនានុបស្សនាសតិប្បដ្ឋាន ....... ១៩៩

ចិត្តានុបស្សនាសតិប្បដ្ឋាន ....... ២០១

នីវរណបព្វៈ ............ ២០៣

ខន្ធបព្វៈ ............ ២០៩

អាយតនបព្វៈ ........... ២១៣

ពោជ្ឈង្គបព្វៈ ........... ២១៨

អង្គ

មូលបរិយាយវគ្គស្ស សតិបដ្ឋានសុត្តេ សង្ខេបតោ........ ៦១៨
ទុក្ខំ អរិយសច្ចំ..... ៦២១
ទុក្ខសមុទយោ អរិយសច្ចំ ៦២៨
ទុក្ខនិរោធោ អរិយសច្ចំ ៦២៩
ទុក្ខនិរោធគាមិនី បដិបទា-
អរិយសច្ចំ....... ៦៣៣
ចតុសតិបដ្ឋានភាវនានិ-
សំសោ........ ៦៣៧
និគមនំ ...... ៦៣៩

## សីហនាទវគ្គោ

### បឋមំ ចូឡសីហនាទសុត្តំ

សីហនាទវគ្គស្ស ចូឡសីហនាទសុត្តេ ចត្តារោ សមណា .. ៦៤៣
ទិដ្ឋិ........ ៦៤៨
ទ្វេ ទិដ្ឋិយោ ..... ៦៤៩
ចត្តារិ ឧបាទានានិ .. ៦៥០
តណ្ហានិទានាទិកថា ... ៦៥៤
តថាគតោ ការសិក អភិនន្ទនំ ៦៥៧



លេខទំព័រ

មូលបរិយាយវគ្គ សតិប្បដ្ឋានសូត្រ សង្ខេបៈ .............. ៦១៨
ទុក្ខអរិយសច្ច ........... ៦២១
ទុក្ខសមុទយអរិយសច្ច........ ៦២៨
ទុក្ខនិរោធអរិយសច្ច ........ ៦២៩
ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច ... ៦៣៣
អានិសង្សនៃការចំរើនសតិប្បដ្ឋានទាំង ៤ . ៦៣៧
ពាក្យជានិគម........... ៦៣៩

## សីហនាទវគ្គ

### ចូឡសីហនាទសូត្រ ទី ១

សីហនាទវគ្គ ចូឡសីហនាទសូត្រ សមណៈមាន ៤ យ៉ាង ........ ៦៤៣
ទីបំផុតនៃសេចក្ដីជ្រះថ្លា ........ ៦៤៨
ទិដ្ឋិ ២ ប្រការ ........... ៦៤៩
ឧបាទាន ៤ យ៉ាង.......... ៦៥០
ពោលអំពីឧបាទានមានតណ្ហាជាហេតុជាដើម ៦៥៤
ការត្រេកអរចំពោះកាសិតរបស់ព្រះមានព្រះ–
ភាគ .............. ៦៥៧

## សូចិយំ មហាសីហនាទសុត្តំ


អង្ក

សីហនាទវគ្គស្ស មហាសីហនាទសុត្តំ សារីបុត្តវេសាលិវាសនំ ៤៤៩

ឥទ្ធិវិធកថា ..... ៤៦១

ទស តថាគតពលានិ. . ៤៦៣

ចត្តារិ វេសារជ្ជានិ. . . ៤៧១

អដ្ឋ បរិសា ..... ៤៧៤

ចតស្សោ យោនិយោ. . ៤៧៧

បញ្ច គតិយោ .... ៤៧៩

ធសុ បឋមំ ឧបមំ . . ៤៨១

ធសុ ទុតិយំ ឧបមំ . . ៤៨៣

ធសុ ចតុត្ថំ ឧបមំ . . ៤៨៤

ធសុ បញ្ចមំ ឧបមំ . . ៤៨៧

ធសុ ឆដ្ឋំ ឧបមំ . . . ៤៨៩

ចតុរង្គិកំ ព្រហ្មចរិយំ . . ៤៩១

ទុក្ករការិយាបរកោ . . ៤៩៧

កេសញ្ចិ វាទិនំ. . . . ៤៩៩




## មហាសីហនាទសូត្រ ទី ២


លេខទំព័រ

សីហនាទវគ្គ មហាសីហនាទសូត្រ ការចូលទៅស្រុកវេសាលីនៃព្រះសារីបុត្រ . ២៤៩

ពោលអំពីឥទ្ធិវិធិ . . . . . . . ២៦១

តថាគតពលញ្ញាណ ១០ ប្រការ . . . ២៦៣

វេសារជ្ជញ្ញាណ ៤ យ៉ាង . . . ២៧១

បរិសទ្យ ៨ ពួក . . . . . . ២៧៤

កំណើត ៤ យ៉ាង . . . . . . ២៧៧

គតិ ៥ យ៉ាង . . . . . . . ២៧៩

បណ្ដាឧបមាទាំង ៦ ពោលអំពីសេចក្ដីឧបមា– ទី ១ . . . . . . . . . . ២៨១

បណ្ដាឧបមាទាំង ៦ ពោលអំពីសេចក្ដីឧបមា– ទី ២ . . . . . . . . . . ២៨៣

បណ្ដាឧបមាទាំង ៦ ពោលអំពីសេចក្ដីឧបមា– ទី ៤ . . . . . . . . . . ២៨៤

បណ្ដាឧបមាទាំង ៦ ពោលអំពីសេចក្ដីឧបមា– ទី ៥ . . . . . . . . . ២៨៧

បណ្ដាឧបមាទាំង ៦ ពោលអំពីសេចក្ដីឧបមា– ទី ៦ . . . . . . . . . ២៨៩

ព្រហ្មចរិយធម៌ប្រកបដោយអង្គ ៤ . . . ២៩១

ប្រភេទនៃទុក្ករកិរិយា . . . . . . ២៩៧

ការដឹងទិដ្ឋិរបស់សមណព្រាហ្មណ៍ពួកខ្លះ . ២៩៩

## តតិយំ មហាទុក្ខក្ខន្ធសុត្តំ

អង្កេ


សីហនាទវគ្គស្ស មហាទុក្ខក្ខន្ធសុត្តេ អញ្ញតិត្ថិយកថា .... ៣១១

កាមានំ អស្សាទោ .. ៣១៣

កាមានំ អាទីនវោ .... ៣១៥

កាមានំ និស្សរណំ .. ៣២៣

រូបានំ អាទីនវោ .... ៣២៥

រូបបរិជាននំ ...... ៣២៩

វេទនានំ អស្សាទោ ... ៣៣១

វេទនាបរិជាននំ ..... ៣៣៣


## ចតុត្ថំ ចូឡទុក្ខក្ខន្ធសុត្តំ


សីហនាទវគ្គស្ស ចូឡទុក្ខក្ខន្ធសុត្តេ វេទនាបរិជាននំ..... ៣៣៧

កាមានំ អាទីនវោ ... ៣៣៩

និគណ្ឋានំ ទុក្ខកា.... ៣៤៧

និគណ្ឋានំ បដិបុច្ឆំ ... ៣៤៩

សុខវិហារិតរកថា .... ៣៥១




## មហាទុក្ខក្ខន្ធសូត្រ ទី ៣

លេខទំព័រ


សីហនាទវគ្គ មហាទុក្ខក្ខន្ធសូត្រ កថារបស់អន្យតិរ្ថិយ . . . . . ៣១១

តម្រេករបស់កាមទាំងឡាយជាដើម . . ៣១៣

ទោសរបស់កាមទាំងឡាយ . . . . ៣១៥

ការរលាស់ចោលនូវកាមទាំងឡាយជាដើម. ៣២៣

ទោសនៃរូបទាំងឡាយ . . . . ៣២៥

ការកំណត់នឹងនូវរូប . . . . . ៣២៩

តម្រេកនៃវេទនាទាំងឡាយ. . . . ៣៣១

ការកំណត់នឹងនូវវេទនា . . . . ៣៣៣


## ចូឡទុក្ខក្ខន្ធសូត្រ ទី ៤


សីហនាទវគ្គ ចូឡទុក្ខក្ខន្ធសូត្រ ការកំណត់នឹងនូវវេទនា . . . . ៣៣៧

ទោសនៃកាមទាំងឡាយ . . . . ៣៣៩

ការឈឺរងើយនៃពួកនិគ្រន្ថ . . . . ៣៤៧

ការទ្រង់សាកសួរពួកនិគ្រន្ថ. . . . ៣៤៩

ពោលអំពីការនៅជាសុខដ៏លើសលុប. . ៣៥១

## បញ្ចមំ អនុមានសុត្តំ

អង្កេ

សីហនាទវគ្គស្ស អនុមានសុត្តេ ទោវចស្សករណធម្មា .... ៣៥៥

សោវចស្សករណធម្មា ... ៣៥៩

អត្តនា អត្តានុមានប្បភេទោ . ៣៦៣

អត្តនា អត្តប្បច្ចវេក្ខណា .. ៣៧១

មហាមោគ្គល្លានស្ស ភាសិតំ

អភិនន្ទនំ ........ ៣៨១

## ឆដ្ឋំ ចេតោខិលសុត្តំ

សីហនាទវគ្គស្ស ចេតោខិលសុត្តេ បញ្ច ចេតោខិលា ..... ៣៨៣

បញ្ច ចេតសោ វិនិពន្ធា ... ៣៨៥

បញ្ច ចេតោខិលា .... ៣៨៧

បញ្ច ចេតសោ វិនិពន្ធា .. ៣៨៩

កុក្កុដណ្ឌូបមា ...... ៣៩៣



# សេចក្ដីប្រែមាតិកា

## អនុមានសូត្រ ទី ៥

លេខទំព័រ

សីហនាទវគ្គ អនុមានសូត្រ ធម៌ដែលធ្វើឲ្យជាអ្នកប្រដៅក្រ ... ៣៥៥

ធម៌ដែលធ្វើឲ្យជាអ្នកប្រដៅងាយ ... ៣៥៩

ប្រភេទនៃការយល់ផ្ទឹមមើលខ្លួនដោយខ្លួនឯង ៣៦៣

ការពិចារណាខ្លួនដោយខ្លួនឯង .. ៣៧១

ការត្រេកអរចំពោះភាសិតរបស់ព្រះមហាមោគ្គល្លាន ៣៨១

## ចេតោខិលសូត្រ ទី ៦

សីហនាទវគ្គ ចេតោខិលសូត្រ បង្គោលរបស់ចិត្ត ៥ ប្រការ ... ៣៨៣

ចំណងរបស់ចិត្ត ៥ ប្រការ ... ៣៨៥

បង្គោលរបស់ចិត្ត ៥ ប្រការ ... ៣៨៧

ចំណងរបស់ចិត្ត ៥ ប្រការ ... ៣៨៩

សេចក្ដីប្រៀបធៀបដោយស៊ុតមាន់ .. ៣៩៣

## សត្តមំ នេបក្កសុត្តំ


អង្ក

សង្ខេបវត្ថុស្ស នេបក្កសុត្តេ នេបក្កបរិស្សយប្បភេទោ . . . ៣៩៨
បុគ្គលបរិស្សយប្បភេទោ . . . ៤០១


## អដ្ឋមំ មធុបិណ្ឌិកសុត្តំ


សង្ខេបវត្ថុស្ស មធុបិណ្ឌិកសុត្តេ ទណ្ឌបាណិបញ្ហា . . . . . . ៤០៩
សង្ខិត្តេន ឧទ្ទេសោ . . . . . ៤១១
វិត្ថារេន និទ្ទេសោ . . . . . ៤១៨
វិភជិតប្បដិបុច្ឆា . . . . . . . ៤២៣
អានន្ទត្ថេរឧបមាវចនំ . . . . ៤២៨


## នវមំ ទ្វេធាវិតក្កសុត្តំ


សង្ខេបវត្ថុស្ស ទ្វេធាវិតក្កសុត្តេ ឆព្វិធោ វិតក្កោ . . . . . . ៤២៩
តិស្សោ វិជ្ជា . . . . . . . . ៤៣៥
អដ្ឋង្គិកោ មិច្ឆាមគ្គោ . . . . . ៤៣៩
តថាគតានុសាសនី . . . . . . ៤៤១
សង្ខេបវត្ថុស្ស វិតក្កសណ្ឋានសុត្តេ បឋមំ និមិត្តំ . . . . . . ៤៤៣
តតិយំ និមិត្តំ . . . . . ៤៤៥
ចតុត្ថំ និមិត្តំ . . . . . . ៤៤៧
បញ្ចមំ និមិត្តំ . . . . . ៤៤៩
អកុសលវិតក្កប្បហានំ . . ៤៥១
ឧទានគាថា . . . . . . . ៤៥៣




## នេបក្ខសូត្រ ទី ៧


លេខទំព័រ

សង្ខេបវត្ថុ នេបក្ខសូត្រ ប្រភេទនៃការចូលទៅអាស្រ័យតាមដងព្រៃ . . ៣៩៨
ប្រភេទនៃការចូលទៅអាស្រ័យនូវបុគ្គល . . ៤០១


## មធុបិណ្ឌិកសូត្រ ទី ៨


សង្ខេបសូត្រ មធុបិណ្ឌិកសូត្រ ប្រស្នារបស់ទណ្ឌបាណិសក្យៈ . . . ៤០៩
ការទ្រង់សំដែងដោយសេចក្តីសង្ខេប . . ៤១១
អធិប្បាយដោយសេចក្តីពិស្តារ . . . ៤១៨
ការក្រាបបង្គំទូលសួរចំពោះសេចក្តីដែលចែកហើយ ៤២៣
ពាក្យឧបមារបស់ព្រះអានន្ទត្ថេរ . . . ៤២៨


## ទ្វេធាវិតក្កសូត្រ ទី ៩


សង្ខេបវត្ថុ ទ្វេធាវិតក្កសូត្រ វិតក្កមាន ៦ យ៉ាង . . . . . ៤២៩
វិជ្ជា ៣ ប្រការ . . . . . . ៤៣៥
មិច្ឆាមគ្គមានអង្គ ៨ . . . . . ៤៣៩
ព្រះបណ្តាំនៃព្រះតថាគត . . . . ៤៤១
សង្ខេបវត្ថុ វិតក្កសណ្ឋានសូត្រ ហេតុទី ១ . . . . . . . ៤៤៣
ហេតុទី ៣ . . . . . . . ៤៤៥
ហេតុទី ៤ . . . . . . . ៤៤៧
ហេតុទី ៥ . . . . . . . ៤៤៩
ការលះបង់នូវអកុសលវិតក្ក . . . . ៤៥១
ឧទានគាថា . . . . . . . ៤៥៣

## វិរុទ្ធាវិរុទ្ធបត្តំ

| វិរុទ្ធបាឋោ | អវិរុទ្ធបាឋោ | អង្កេ | បន្តិលេខាយំ |
|---|---|---|---|
| វិញ្ញាណញ្ញាយតនំ | វិញ្ញាណញ្ចាយតនំ | ៧ | ២ |
| វិញ្ញាណញ្ញាយតនតោ | វិញ្ញាណញ្ចាយតនតោ | ” | ” |
| កម្មនីយេ | កម្មនិយេ | ៧១ | ៤ |
| ពមិអត្តនោ | ពមិ អត្តនោ | ៧៥ | ៨ |
| សត្តេ | សុត្តេ | ៩១ | ១ |
| ទុក្ខសិការោ (១) | ទុក្ខសិការោ | ៩៣ | ១០ |
| ” | ” | ” | ១១ |
| សត្តន្តបិដកេ | សុត្តន្តបិដកេ | ៩៥ | ១ |
| បរិកេក្ខា | បរិកេក្ខា | ១០០ | ១៥ |
| គច្ឆតិ | គច្ឆតិ | ” | ១៧ |
| សុតេ | សុត្តេ | ១០៩ | ១ |
| អតិជ | អតិជ្ជា | ១១៧ | ៩ |
| សុត្តេនា | សុត្តេត្តា | ១៥១ | ១៤ |
| អសីតិ | អសីតិ | ១៦០ | ១៣ |
| គណ្ហាសមុទេយោ | គណ្ហាសមុទយោ | ១៦៧ | ៨ |



## វិរុទ្ធាវិរុទ្ធបត្តំ

| វិរុទ្ធបាឋោ | អវិរុទ្ធបាឋោ | អង្កេ | បន្តិលេខាយំ |
|---|---|---|---|
| គណ្ហិនេកោ | គណ្ហិនេកោ | ” | ៥ |
| ទិដ្ឋី | ទិដ្ឋិ | ១៧៤ | ១៨ |
| អតោ | តតោ | ១៧៧ | ១៦ |
| នដិឃានុសយំ | បដិឃានុសយំ | ១៨២ | ១៤ |
| ឧដ្ឋានធិ | ឧដ្ឋានទ្ធិ | ១៩៤ | ១៧ |
| សតិប្បដ្ឋានធិ | សតិប្បដ្ឋានទ្ធិ | ១៩៨ | ” |
| ឧន្ទបត្ត | ឧន្ទបត្តំ | ២១១ | ១ |
| ឯត្ថេសោ | ឯត្ថេសា | ២២៨ | ១០ |
| បណិធាយ | បណិធាយ | ២៨៧ | ១៧ |
| ភិក្ខុ | ភិក្ខុ- | ៣០៣ | ២ |
| បរិញ្ញុជក | បរិញ្ញុជក | ៣១១ | ១៨ |
| ទិល្យតិ | ទិស្យតិ | ” | ” |
| គោមយោតោ | គោបយោតោ | ៣១៥ | ១១ |
| អម្បិ | អយម្បិ | ៣១៧ | ២ |
| វិគ្គស | វិគ្គហ | ” | ១៤ |

## វិរុទ្ធាវិរុទ្ធបត្តំ

| វិរុទ្ធបាឋោ | អវិរុទ្ធបាឋោ | អង្កេ | រជ្ជុលេខាយំ |
|---|---|---|---|
| កាពេន្តិ | ការេន្តិ | ៣១៩ | ១៥ |
| សុក្ខស្ស | សុខស្ស | ៣៣២ | ៦ |
| អភិនន្ទន្តិ | អភិនន្ទុន្តិ | ៣៣៤ | " |
| សុត្តន | សុត្តន្ត | ៣៣៦ | ១ |
| ឯវរូបំ | ឯវរូបំ ក | ៣៨០ | ៣ |
| អនិដ្ឋមានោ | អនិញ្ជមានោ | ៣៨២ | ១០ |
| ចូឡទុក្ខក្ខន្ធសុត្តេ | ចូឡទុក្ខក្ខន្ធសុត្តេ | ៣៨៣ | ១ |
| សុវិហារិ | សុខវិហារិ | " | " |
| ភេន្ទុកិនិ | ភេត្តុកិនិ | " | ១០ |
| ភាបដិតុំ | អាបជ្ជិតុំ | ៣៨៩ | ៣ |
| វិហាតុំ | វិហាតុំ | ៣៧៧ | ១១ |
| ឥស្សរិ | ឥស្សរី | " | ១៥ |
| អនិស្សរិ | អនិស្សរី | " | ១៨ |
| សម្មានេព្វ | សម្មានេតព្វ | ៤០១ | ១១ |
| វុសោ | អាវុសោ | ៤១៣ | ១៣ |



## វិរុទ្ធាវិរុទ្ធបត្តំ

| វិរុទ្ធបាឋោ | អវិរុទ្ធបាឋោ | អង្កេ | រជ្ជុលេខាយំ |
|---|---|---|---|
| បនញ្ញាវុសោ | មនញ្ញាវុសោ | ៤១៨ | ១០ |
| បញ្ញាបេសតីតិ | បញ្ញាបេស្សតីតិ | ៤៤០ | ៨ |
| បក្កោតា | បក្កោកា | ៤៣៤ | ១៦ |
| ឱហញ្ញេយ្យ | ឩហញ្ញេយ្យ | " | ១៧ |
| វិមុត្តមិតិ | វិមុត្តមីតិ | ៤៣៧ | ១៤ |
| (២៤៥) | (២៥៤) | ៤៣៨ | ៧ |
| ភោបីតិ តមនីយោ | ភោ បីតិតមនីយោ | ៤៤០ | ៦ |
| បីតិតមនីយោថ ហាភោ | បីតិតមនីយោ បហាភោ | " | ១៤ |
| និមិត្ត ។ | និមិត្តំ | ៤៤២ | " |
| ភិក្ខា | ភិក្ខុនោ | ៤៤៤ | ២ |
| ទោសូបសញ្ញិតាបិ | ទោសូបសញ្ហិតាបិ | " | ៥ |
| មោហូបសញ្ហាតាបិ | មោហូបសញ្ហិតាបិ | " | " |
| អភិនិព្វិជ្ជយតា | អភិនិព្វិជ្ជយតោ | ៤៤៩ | ១៥ |

## សន្លឹកប្រាប់ពាក្យ-ខុសត្រូវ

| ពាក្យខុស | ពាក្យត្រូវ | ទំព័រ | បន្ទាត់ |
|---|---|---|---|
| ព្រហ្មពិតហើយ | ព្រហ្មជាជានៅសញ្ញានា សញ្ញាយកនព្រហ្មពិតហើយ | ៧ | ១៧ |
| សុត្តន្តបិដក | សុត្តន្តបិដក | ១៤ | ១ |
| នាឲ្យខូច | នាំឲ្យខូច | ៣៣ | ១៤ |
| មូលបរយាយ | មូលបរិយាយ | ៤៣ | ១ |
| មិនដាក់ធុរៈ | ដាក់ធុរៈ | ៤៧ | ១៣ |
| គុណមាប្រព្រឹត្ត | គុណការប្រព្រឹត្ត៌ | " | " |
| មិនដាក់ធុរៈ | ដាក់ធុរៈ | ៤៨ | ៨ |
| ការប្រព្រឹត្ត | ការប្រព្រឹត្ត៌ | " | " |
| មិនដាក់ធុរៈ | ដាក់ធុរៈ | ៤៩ | ៣ |
| ការប្រព្រឹត្ត | ការប្រព្រឹត្តិ | " | ៤ |
| រលោន | រំលោន | ៧៣ | ១០ |
| ក្រលែង | ក្រៃលែង | " | ១៣ |
| ជីវិត | ជីវិត | ៧៨ | " |
| គមនុស្ស | មនុស្ស | ៩៦ | " |



## សន្លឹកប្រាប់ពាក្យខុសត្រូវ

| ពាក្យខុស | ពាក្យត្រូវ | ទំព័រ | បន្ទាត់ |
|---|---|---|---|
| នោះនោះ | នោះ | ១១៦ | ២ |
| កក្រប | ប្រកប | ១២១ | ៨ |
| តែមើល | តែងមើល | ១២៨ | ១៦ |
| ទាំងឡ | ទាំងឡាយ | " | " |
| យ៉ានេះ | យ៉ាងនេះ | ១៣៩ | ៤ |
| សីលព្វតុបាទាន | សីលព្វតុបាទាន | ១៦៧ | ៤ |
| ស្រូវឡាច | ស្រូវឡាយ | ១៩២ | ៣ |
| ២៤២៨ | ២៤-២៨ | ១៩៨ | ២០ |
| មានឋនគី | មានឋគី | ២១០ | ១៩ |
| ជាដនកើត | ជាដែនកើត | ២១១ | ២ |
| ឥន្ទ្រីយ | ឥន្ទ្រីយ | ២២០ | ១៨ |
| ជីវិតន្ទ្រីយ | ជីវិតិន្ទ្រីយ | ២២១ | ៧ |
| វិសា | វិនាស | ២២២ | ១៤ |
| សុត្តន្តបដក | សុត្តន្តបិដក | ២៦០ | ១ |
| សំដែងហើ | សំដែងហើយ | " | ៦ |

## សន្លឹកប្រាប់ពាក្យខុស-ត្រូវ

| ពាក្យខុស | ពាក្យត្រូវ | ទំព័រ | បន្ទាត់ |
| --- | --- | --- | --- |
| អន៏នោះ | អន្លើនោះ | " | ១៨ |
| មាគនុភាព | មានអានុភាព | ២៦១ | ១៤ |
| ត្រកូលគម្ព | ត្រកូលគម្ភ ១ | ២៦៣ | " |
| នៃកុសល | នៃកុសល | ២៦៤ | ១៣ |
| តាំងពាយ | តាំងឲ្យាយ | ៣១២ | " |
| បំណោះ | ប៉ុណ្ណោះ | ៣១៥ | ១៦ |
| កបស្មាន | កប់ស្មាន | " | " |
| មានយម | មានកាម | ៣១៨ | ៧ |
| មច័យ | បច្ច័យ | ៣១៩ | ២ |
| ផ្កា | ផ្កាំ | ៣២០ | " |
| ចំញ្ចាំ | ចិញ្ចាំ | ៣២១ | ១៧ |
| កិត្ត | កិត្តុ | ៣២៩ | ៣ |
| វិត្តក | វិតក្កៈ | ៣៣០ | ៧ |
| ដាយពិត | ដោយពិត | ៣៣៨ | ៨ |
| ទុក្ខក្ខនក | ទុក្ខក្ខន | ៣៣៩ | ១ |



## សន្លឹកប្រាប់ពាក្យខុស-ត្រូវ

| ពាក្យខុស | ពាក្យត្រូវ | ទំព័រ | បន្ទាត់ |
| --- | --- | --- | --- |
| ពោសនៃ | កម្រុកនៃ | ៣៣៩ | ១ |
| ជីវិត | ជីវិត | " | ១៨ |
| នពន្ធ | និពន្ធ | " | ១៧ |
| ដាយ | ដោយ | " | ១៨ |
| និកាយស្ស | និកាយ | ៣៤៤ | ១ |
| មនុស | មនុស្ស | " | ៧ |
| ខ្ទវផល | ខ្ទូវផល | " | ១៤ |
| ស្បូក | ស្បែក | ៣៤៥ | ៨ |
| ខមាពុក | មានពុក | ៣៥៧ | ១៨ |
| ជវេដែរ | ជាវដែរ | ៣៦៥ | ២ |
| អ្នកទាច | អ្នកទោច | ៣៦៦ | ៣ |
| នៅតមិន | នៅតែមិន | ៤០២ | ២ |
| តមិន | តែមិន | " | ១០ |
| វេលាថ្ង | វេលាថ្ងៃ | ៤០៩ | ៧ |
| សេចក្ដី | សេចក្ដី | ៤១៣ | " |

# សន្លឹកប្រាប់ពាក្យខុស-ត្រូវ

| ពាក្យខុស | ពាក្យត្រូវ | ទំព័រ | បន្ទាត់ |
|---|---|---|---|
| ប៉ុន្មា | ប៉ុន្មាន | ៤១៤ | ៣ |
| ករន្តចិត្តខឹន | ករន្តចិក្តខឹង | ៤១៨ | ១៣ |
| យឺតយូវ | យឺតយូរ | ៤១៩ | ៤ |
| ពិសារ | ពិស្តារ | ៤២១ | ១ |
| បពិត | បពិត្រ | ៤២២ | ១៥ |
| បគ្គល | បុគ្គល | ៤២៥ | ១៤ |
| ទីនែះ | ទីនេះ | " | ១៥ |
| និរត្តិ | និរុត្តិ | " | ១៦ |
| បដិភាណ | បដិភាណ | " | ១៧ |
| លបង់ | លះបង់ | ៤៣៤ | ៦ |
| (១៥៣) | (២៥៣) | " | ១៣ |
| បំផ្លូវ | បំផ្លូវខុស | ៤៣៩ | ៣ |
| សម្រេប | សម្រេច | ៤៤៨ | " |
| វតក្ក | វិតក្ក | ៤៥១ | ១ |
| ការះឃើញ | ការឃើញ | ៤៥៤ | ១៧ |